# បច្ចេកពុទ្ធសំយុត្តកថា

## ភាគ ១

ផ្សព្វផ្សាយដោយសមាគមធម្មទាន
អរិយវង្សយង់ សុផាត

ព.ស.២៥៦៧

# បច្ចេកពុទ្ធសំយុត្តកថា

## ភាគ ១

ផ្សព្វផ្សាយដោយសមាគមធម្មទាន

អរិយវង្សយង់ សុផាត

រៀបរៀងដោយ ឧបាសក ឡាន សុខុម

ព.ស.២៥៦៧

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ២២៥ សជណ

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ពិតថេរដីកា**
**ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត**

**កម្មវត្ថុ** : អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ ។

**យោង** : លិខិតលេខ***០១/១០ស.ធ.អ.យ.ផ*** ចុះថ្ងៃទី***២៣*** ខែ***តុលា*** ឆ្នាំ***២០០៩*** ស្តីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅភូមិ***រំចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន ។
សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

**ស ខេង**

***ចម្លងជូន:***
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលាខេត្តបាត់ដំបង
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

# ពាក្យប្រារព្ធ

*សៀវភៅ “* **បច្ចេកពុទ្ធសំយុត្តកថា** *” នេះ ខ្ញុំគិតថា នឹងចងក្រងរៀបរៀងជាយូរមកហើយ ដោយយល់ឃើញថា ពុទ្ធប្បវត្តិក្តី ប្រវត្តិព្រះអសីតិមហាសាវ័កក្តី លោកអ្នកសប្បុរសទាំងឡាយ បានរៀបរៀងចងក្រងច្រើនមកហើយ តែរឿងរ៉ាវដែលទាក់ទងនឹងព្រះបច្ចេកពុទ្ធ ហាក់ដូចជាបាំងបាត់ស្ងាត់កំបាំងនៅឡើយ តែការគិត ក៏បានត្រឹមតែគិត ព្រោះមិនមានអ្នកជួយជ្រោមជ្រែងក្នុងការងារនេះ ។ លុះក្រោយមក មានលោកអ្នកសប្បុរស ដែលជាអ្នកមានសទ្ធាជ្រះថ្លាក្នុងធម៌ព្រះមានព្រះភាគ បានសូមឲ្យខ្ញុំរៀបសៀវភៅនេះឡើង ដោយជានាជួយធ្វើកិច្ចការនេះ មានបច្ចេកទេសវាយអក្សរពុម្ពជាដើម ទើបសៀវភៅនេះ សម្រេចឡើងបាន ។*

*សៀវភៅនេះ ជាសៀវភៅដកស្រង់ រៀបរៀង មិនមែនជាការប្រែទាំងស្រុងទេ គឺមានកាត់សេចក្តីចេញខ្លះ បន្ថែមសេចក្តីពីអដ្ឋកថាក្នុងព្រះសូត្រដទៃចូលខ្លះ តែមិនឲ្យបាត់បង់អត្ថក្នុងផ្ទៃរឿង បើលោកអ្នកត្រូវការសេចក្តីពិស្តារ សូមស្វែងរកមើលក្នុងទីមកនៃព្រះសូត្រនោះ ៗ ដែលមានក្នុងនយលក្ខណៈ ( លេខយោង ) ឯណោះចុះ ។*

រឿងរ៉ាវទាំងឡាយណា ដែលទាក់ទងនឹងព្រះបច្ចេកពុទ្ធ ដែលមានក្នុងអដ្ឋកថាក្តី ក្នុងព្រះត្រៃបិដកក្តី ខ្ញុំបាទបានលើកយកមកដាក់ក្នុងទីនេះ ដើម្បីទុកជាធម្មបទីប សម្រាប់អ្នកមានឧបនិស្ស័យក្នុងការសិក្សាគ្រប់ជំនាន់តទៅ ។

ការងារធម្មទាននេះ ជាភារៈធ្ងន់ ព្រោះហេតុនោះ យើងខ្ញុំសូមទទួលយកនូវការកែលម្អ ត្រង់ចំណុចដែលខុសឆ្គង អំពីលោកអ្នកសប្បុរសទាំងឡាយ ដើម្បីនឹងកែតម្រូវ ។

កុសលឯណា ដែលសម្រេចដោយការរៀបរៀងសៀវភៅនេះ សូមកុសលនោះ ប្រតិស្ឋានក្នុងហទយៈ គឺចិត្តរបស់លោកអ្នក ដោយអនុមោទនាថា សាធុ សាធុ សាធុ ទៅហោង ។

សូមសត្វលោកសម្លឹងគ្នា ដោយភ្នែកប្រកបដោយមេត្តា !

សូមពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ជ្រួតជ្រាបក្នុងចិត្តរបស់សត្វលោក !

វត្តព្រះគន្ធកុដិ ខេត្តបាត់ដំបង

ថ្ងៃ ១៥ កើត ខែកទ្រ្ទបទ ព.ស.២៥៦៧

ឧបាសក ឡាន សុខុម

# សន្លឹកប្រាប់មាតិកា

**មាតិកា** **លេខទំព័រ**

## បច្ចេកពុទ្ធសំយុត្តកថា


លំនាំដើម ..................................... ១


### វគ្គទី ១


| | | |
|---|---|---|
| បឋមគាថា | ទី ១ | ១១ |
| សំសគ្គគាថា | ទី ២ | ៥២ |
| មិត្តសុហជ្ជគាថា | ទី ៣ | ៧៥ |
| វំសក្កឡីរគាថា | ទី ៤ | ៨០ |
| មិគោអរញ្ញគាថា | ទី ៥ | ៨៤ |
| អាមន្តនាគាថា | ទី ៦ | ៩៨ |
| ខិឌ្ឌារតិគាថា | ទី ៧ | ១០១ |
| ចាតុទ្ទិសគាថា | ទី ៨ | ១០៤ |
| ទុស្សង្គហគាថា | ទី ៩ | ១១០ |
| កោវិឡារគាថា | ទី ១០ | ១១៤ |


វគ្គទី ១ ចប់

**មាតិកា** **លេខទំព័រ**

## វគ្គទី ២


| | | | |
|---|---|---|---|
| *សហាយគាថា* | ទី ១-២ | ................................... | ១១៨ |
| *អទ្ធាបសំសាគាថា* | ទី ៣ | ................................... | ១២៤ |
| *សុវណ្ណាវលយគាថា* | ទី ៤ | ................................... | ១២៨ |
| *អាយតិកយគាថា* | ទី ៥ | ................................... | ១៣២ |
| *កាមគាថា* | ទី ៦ | ................................... | ១៣៨ |
| *ឦតិគាថា* | ទី ៧ | ................................... | ១៤២ |
| *សីតាលុកគាថា* | ទី ៨ | ................................... | ១៤៥ |
| *នាគគាថា* | ទី ៩ | ................................... | ១៤៧ |
| *អដ្ឋានគាថា* | ទី ១០ | ................................... | ១៥២ |


វគ្គទី ២ ចប់

## មាតិកា លេខទំព័រ

## វគ្គទី ៣


*ទិដ្ឋីវិសូកគាថា* ទី ១ ................................... ១៥៨

*និល្លោលុបគាថា* ទី ២ ................................... ១៦១

*បាបសហាយគាថា* ទី ៣ ................................... ១៦៦

*ពហុស្សុតគាថា* ទី ៤ ................................... ១៦៩

*វិភូសនដ្ឋានគាថា* ទី ៥ ................................... ១៧៥

*បុត្តទារគាថា* ទី ៦ ................................... ១៧៨

*សង្គគាថា* ទី ៧ ................................... ១៨០

*សន្ទាលគាថា* ទី ៨ ................................... ១៩១

*ឱក្ខិត្តចក្ខុគាថា* ទី ៩ ................................... ១៩៤

*បារិច្ឆត្តកគាថា* ទី ១០ ................................... ១៩៧


វគ្គទី ៣ ចប់

**មាតិកា** **លេខទំព័រ**

## វគ្គទី ៤


| | | | |
|---|---|---|---|
| *រសគេធគាថា* | ទី ១ | .................................. | ២០០ |
| *អាវរណគាថា* | ទី ២ | .................................. | ២០៣ |
| *វិបិដ្ឋិគាថា* | ទី ៣ | .................................. | ២០៥ |
| *អារទ្ធវីរិយគាថា* | ទី ៤ | .................................. | ២០៨ |
| *បដិសល្លានគាថា* | ទី ៥ | .................................. | ២១៥ |
| *តណ្ហក្ខយគាថា* | ទី ៦ | .................................. | ២១៨ |
| *សីហាទិគាថា* | ទី ៧ | .................................. | ២២១ |
| *ទាឋពលីគាថា* | ទី ៨ | .................................. | ២២៦ |
| *អប្បមញ្ញាគាថា* | ទី ៩ | .................................. | ២៣៤ |
| *ជីវិតសង្ខយគាថា* | ទី ១០ | .................................. | ២៣៧ |
| *ការណត្ថគាថា* | ទី ១១ | .................................. | ២៣៩ |


**វគ្គទី ៤ ចប់**

# មាតិកា លេខទំព័រ


អភិសម្ពុទ្ធគាថា .................................... ២៤៤

បកិណ្ណកកថា .................................... ២៤៩

ព្រះអនុរុទ្ធត្ថេរ .............................................. ២៥១

ព្រះឧបាលិត្ថេរ .............................................. ៣០១

ខទិរង្គារជាតក .............................................. ៣៨៤

មហាជនកជាតក .............................................. ៤០២

មេណ្ឌកសេដ្ឋី .............................................. ៥០០

ទរីមុខជាតក .............................................. ៥១៦

វិជ្ជាធរជាតក .............................................. ៥២៩

កុម្ភការជាតក .............................................. ៥៣៨

កុម្មាសបិណ្ឌិជាតក .............................................. ៥៥៣

គង្គមាលជាតក .............................................. ៥៧២

ភិក្ខាបរម្បរជាតក .............................................. ៥៩២

សង្ខជាតក .............................................. ៦០១

បានីយជាតក .............................................. ៦១៣

**មាតិកា** **លេខទំព័រ**

តេលបត្តជាតក ............................................ ៦២៥

មហាមោរជាតក ............................................ ៦៣៦

សោណកជាតក ............................................ ៦៥៨

បញ្ចុបោសថជាតក ....................................... ៦៩៥

នាងបញ្ចបាបី ......................................... ៧១០

កុសជាតក ....................................... ៧២១

ព្រះនាងឧប្បលវណ្ណាថេរី ....................................... ៨០៦

មុនាឡិពោធិសត្វ ទី ១ ....................................... ៨៧៥

មុនាឡិពោធិសត្វ ទី ២ ....................................... ៩២៧

អញ្ញតរទេហរពោធិសត្វ ....................................... ៩៣១

ហត្ថាចារ្យពោធិសត្វ ....................................... ៩៣៣

ឃោសកសេដ្ឋី ....................................... ៩៣៦

សុត្តប្រេត ....................................... ១០៣២

# បច្ចេកពុទ្ធសំយុត្តកថា

## ភាគទី ១

**ព្រះបច្ចេកពុទ្ធ** *គឺជាអ្នកសន្សំបារមីគ្រប់យ៉ាង មានទានបារមីជាដើម ហើយត្រាស់ដឹងឯង ដោយពុំចាំបាច់ស្តាប់អំពីអ្នកដទៃឡើយ ។ បណ្តាសត្វដែលស្វែងរកគុណធំទាំងឡាយ មានអគ្គសាវ័កជាដើម បើមិនបានស្តាប់ធម៌របស់ព្រះសម្មាសម្ពុទ្ធទេ មិនអាចត្រាស់ដឹងឯងបានឡើយ ។ ពួកសត្វទាំងនោះ អាស្រ័យព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ ទើបត្រាស់ដឹងបាន បើកប្បទទេចាកព្រះសម្មាសម្ពុទ្ធទាំងឡាយ មួយអសង្ខេយ្យកប្បក្តី ពីរអសង្ខេយ្យកប្បក្តី បីអសង្ខេយ្យកប្បក្តី សត្វទាំងនោះ ក៏អន្ទោលវិលវល់ស្លាប់កើត រង់ចាំការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ ទើបឆ្លងវដ្តសង្សារបាន ។ ព្រះបច្ចេកពុទ្ធ ថ្វីដ្បិតតែលោកមានសេចក្តីខ្វល់ខ្វាយតិចក្នុងការសម្តែងធម៌ ឬធម៌ដែលលោកសម្តែងហើយ មិនអាចឲ្យសត្វដែលស្តាប់ ត្រាស់ដឹងបានក៏ដោយ តែគង់បានជាឧបនិស្ស័យនៃការត្រាស់ដឹងក្នុងអនាគត ឬបើសត្វណា មានឧបនិស្ស័យសមគួរត្រាស់ដឹងជាព្រះបច្ចេកពុទ្ធ លោកក៏ទូន្មានប្រៀនប្រដៅ ឲ្យនូវនិមិត្តផ្សេង ៗ ដឹកនាំ*

សត្វនោះ ឲ្យចេញចាកផ្ទះ បួសហើយត្រាស់ដឹងជាព្រះបច្ចេកពុទ្ធតែម្តង ។ បើសត្វណាមិនអាចត្រាស់ដឹងជាព្រះបច្ចេកពុទ្ធដូចលោកបាន លោកតែងអប់រំសត្វទាំងនោះថា អ្នកទាំងឡាយ ចូរធ្វើទានយ៉ាងនេះ ចូររក្សាសីលយ៉ាងនេះ ចូរគោរពមាតាបិតា ត្រកូលរៀមច្បង សមណព្រាហ្មណ៍យ៉ាងនេះ ឲ្យអប់រំបន្ទុំនិស្ស័យក្នុងកុសលធម៌តទៅ បើសត្វណាមានឧបនិស្ស័យសមគួរបាននូវលោកិយសម្បត្តិ លោកតែងនិមន្តទៅបិណ្ឌបាតដើម្បីឲ្យសត្វនោះ បានដាក់បាត្រ ហើយសម្រេចបុណ្យធំក្នុងបច្ចុប្បន្ន ជាស្តេច ជាសេដ្ឋី ក្នុងបច្ចុប្បន្នទាន់ភ្នែក មិនយឺតយូរឡើយ ។

ទ្វីបលោកយើងនេះ សម័យណា យុគណា មិនមានព្រះសម្មាសម្ពុទ្ធត្រាស់ដឹងឡើងក្នុងលោក ពួកឥសីដែលជាកម្មវាទីទាំងឡាយ ជាអ្នកទូន្មានប្រៀនប្រដៅសត្វលោក បើមានព្រះពោធិសត្វ ( សត្វដែលប្រាថ្នាត្រាស់ដឹងជាព្រះពុទ្ធ ) ព្រះពោធិសត្វនោះ ក៏ជាអ្នកទូន្មានប្រៀនប្រដៅដឹកនាំឲ្យប្រព្រឹត្តនូវសីលាចារវត្ត ឲ្យស្គាល់បុណ្យ ស្គាល់បាបផ្សេងៗ បើមានស្តេចចក្កពត្តិ ក៏ជាតួនាទីរបស់ស្តេចចក្កពត្តិ ដែលដឹកនាំសត្វឲ្យតាំងនៅក្នុងសីល ៥ ជាដើម បើមានព្រះបច្ចេកពុទ្ធ ក៏ជាតួនាទីរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ។ បើពោលដោយការធ្វើទាន ក្នុងទក្ខិណាវិភង្គសូត្រ ព្រះមានព្រះភាគបានត្រាស់ទុកថា

ម្នាលអានន្ទ បណ្តាបុគ្គលអ្នកទទួលទានទាំងនោះ ទក្ខិណាមាន

គុណមួយរយ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះសត្វតិរច្ឆាន ។ ទក្ខិណាមានគុណមួយពាន់ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះបុថុជ្ជនទ្រុស្តសីល ។ ទក្ខិណាមានគុណមួយសែន ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះបុថុជ្ជនមានសីល ។ ទក្ខិណាមានគុណមួយសែនកោដិ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះអ្នកបួសខាងក្រៅ ដែលប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ។ ទក្ខិណាមានគុណរាប់មិនបានប្រមាណមិនកើត ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ នឹងបាច់និយាយទៅថ្វី ( ដល់ទក្ខិណាដែលបុគ្គលឲ្យ ) ចំពោះសោតាបន្នបុគ្គល នឹងនិយាយទៅថ្វី ចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិ-ផល នឹងនិយាយទៅថ្វី ចំពោះសកទាគាមិបុគ្គល នឹងនិយាយទៅថ្វី ចំពោះបុគ្គល ដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល នឹងនិយាយទៅថ្វី ចំពោះអនាគាមិបុគ្គល នឹងនិយាយទៅថ្វី ចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល នឹងនិយាយទៅថ្វី ចំពោះព្រះអរហន្តជាសាវ័ករបស់តថាគត នឹងនិយាយទៅថ្វី ចំពោះព្រះបច្ចេកសម្ពុទ្ធ នឹងនិយាយទៅថ្វី ចំពោះព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ [១] ដូច្នេះ ។

---

១-បិដកខ្មែរលេខ ២៨ ទំព័រលេខ ២២៣-២២៤ ឃ្នាបលេខ ១៨៦ ។

ក្នុងលោកនេះ វៀរព្រះបច្ចេកពុទ្ធផងគ្នា និងព្រះសម្មាសម្ពុទ្ធចេញហើយ ពុំមានបុគ្គលណាអាចប្រៀបនូវគុណ ឬពណ៌នានូវគុណរបស់ព្រះបច្ចេកពុទ្ធឲ្យអស់ទៅបានឡើយ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា

**សព្វម្ហិ លោកម្ហិ មមំ ឋបេត្វា**
**បច្ចេកពុទ្ធាន សមោវ ឆត្ថិ**

ក្នុងលោកទាំងមូល វៀរលែងតែតថាគតចេញ មិន
មានបុគ្គលណា ស្មើនឹងព្រះបច្ចេកពុទ្ធឡើយ[១] ។

ព្រះបច្ចេកពុទ្ធទាំងឡាយ លោកបំពេញបារមី ១០ អស់ ២ អសង្ខេយ្យ និង ១ សែនកប្ប ទើបត្រាស់ដឹងបាន បើមិនប្រព្រឹត្តទៅអស់កាលប៉ុណ្ណោះ សូម្បីធ្វើទានជាដើម ឲ្យហូរដូចស្ទឹងរាល់ៗថ្ងៃ ដូចគ្នានឹងទានរបស់ព្រះបាទវេស្សន្តរ ឬវេលាមព្រាហ្មណ៍ជាដើម ក៏មិនអាចត្រាស់ដឹងបានក្នុងចន្លោះមុននេះឡើយ ។ បុគ្គល កាលប្រាថ្នាភាពជាព្រះបច្ចេកពុទ្ធ ត្រូវប្រកបដោយសមោធានធម៌ ៥ គឺ

**មនុស្សត្តំ** មានអត្តភាពជាមនុស្ស ១

**លិង្គសម្បត្តិ** មានភេទជាបុរស ១

**វិគតាសវទស្សនំ** បានចួបបុគ្គលអស់អាសវៈ ១

---

១-បិ.៧២ ទំ.១៧ ឃ.២ ។

**អធិការោ** បានធ្វើកុសល គឺហ៊ានលះបង់ជីវិត ១

**ឆន្ទតា** មានសេចក្តីពេញចិត្តក្នុងបច្ចេកពោធិញ្ញាណ ១ ។

ពិតហើយ បច្ចេកពោធិញ្ញាណនោះ លុះត្រាតែប្រាថ្នាក្នុងកំណើតជាមនុស្សប៉ុណ្ណោះ ទើបសម្រេចបាន បើតាំងនៅក្នុងកំណើតដទៃ មានកំណើតសត្វតិរច្ឆាន ឬទេវតាជាដើម សូម្បីប្រាថ្នា ក៏មិនសម្រេចឡើយ មិនតែប៉ុណ្ណោះ សូម្បីបានអត្តភាពជាមនុស្ស មិនមែនជាបុរស គឺជាខ្ទើយក្តី ជាឧភតោព្យញ្ជនកៈក្តី ជាស្រីក្តី សេចក្តីប្រាថ្នាក៏មិនសម្រេចដែរ មិនតែប៉ុណ្ណោះ សូម្បីជាបុរសហើយ តែមិនបានធ្វើកុសល ហើយប្រាថ្នាក្នុងទីចំពោះមុខបុគ្គលដែលអស់កិលេស មានព្រះអរហន្តជាដើម សេចក្តីប្រាថ្នានោះ ក៏មិនបានសម្រេច មិនតែប៉ុណ្ណោះ ការបំពេញកុសលចំពោះមុខបុគ្គលដែលអស់អាសវៈនោះ ត្រូវតែជាកុសលឧក្រិដ្ឋ សូម្បីជីវិត ក៏ហ៊ានលះបង់ ទើបសេចក្តីប្រាថ្នានោះ សម្រេចបាន ។ មិនតែប៉ុណ្ណោះ ព្រះបច្ចេកពោធិសត្វនោះ ត្រូវមានឆន្ទៈខ្លាំងក្លាបំផុត ទើបការប្រាថ្នាសម្រេចបាន ។ ក្នុងរឿងឆន្ទៈនោះ មានឧបមា ៤ យ៉ាងដូច្នេះថា បើមានបុរសណាម្នាក់ស្រែកប្រកាសថា អ្នកណាដើរឆ្លងចក្កវាឡនេះ ដែលពេញដោយរងើកភ្លើងបាន ឬថា បើបុគ្គលណាអាចដើរកាត់ចក្កវាឡដែលពេញដោយលំពែង ឬចម្រូង ឬថា បុគ្គលណាហែលឆ្លងផ្ទៃចក្កវាឡដែលពេញដោយទឹកបាន ឬថា បើបុគ្គលណាដើរឆ្លងផ្ទៃចក្កវាឡដែលពេញ

ដោយគុម្ពឫស្សីបាន បុគ្គលនោះ នឹងបានជាព្រះបច្ចេកពុទ្ធ បុគ្គលណា ឆ្លើយដោយរហ័សថា ខ្ញុំ ខ្ញុំ ដូច្នេះ បុគ្គលនោះ ឈ្មោះថា មានឆន្ទៈ បរិបូណ៌ ។ ធម៌ ៥ នេះ មកប្រជុំគ្នាព្រមក្នុងកាលណា ការប្រាថ្នារបស់សត្វនោះ នឹងសម្រេចបាន ។

ព្រះបច្ចេកពោធិសត្វទាំងឡាយ កាលដល់ព្រមដោយសមោធានធម៌ ៥ ប្រការនេះហើយ លោកតែងប្រកបដោយអជ្ឈាស្រ័យ ៦ ប្រការ គឺ

**នេក្ខម្មជ្ឈាសយោ** អជ្ឈាស្រ័យក្នុងការចេញបួស ១

**បវិវេកជ្ឈាសយោ** អជ្ឈាស្រ័យក្នុងទីស្ងាត់ ១

**អលោភជ្ឈាសយោ** អជ្ឈាស្រ័យក្នុងការមិនចង់បាន ១

**អទោសជ្ឈាសយោ** អជ្ឈាស្រ័យក្នុងការមិនខឹងក្រោធ ១

**អមោហជ្ឈាសយោ** អជ្ឈាស្រ័យក្នុងការមិនវង្វេង ១

**និស្សរណជ្ឈាសយោ** អជ្ឈាស្រ័យក្នុងការរលាស់ខ្លួនចេញចាកវដ្តៈ ១ ។

អជ្ឈាស្រ័យ ៦ ប្រការនេះឯង ជាគ្រឿងបន្ទុំបញ្ញារបស់ព្រះបច្ចេកពោធិសត្វទាំងឡាយ ឲ្យដល់ត្រើយនៃសង្សារទុក្ខ ក្នុងរយៈពេលមិនក្រោម ២ អសង្ខេយ្យ និង ១ សែនកប្បឡើយ ។ ព្រះបច្ចេកពោធិសត្វកាលត្រាស់ដឹង តែងត្រាស់ដឹងក្នុងត្រកូល ៣ គឺត្រកូលក្សត្រ ត្រកូលព្រាហ្មណ៌ ត្រកូលគហបតី ត្រកូលណាមួយ ។

តទៅនេះ សូមស្តាប់គុណកថារបស់ព្រះបច្ចេកពោធិសត្វទាំងឡាយ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយនឹងព្រះនតង្គវេទេហមុនី គឺព្រះអានន្ទដូចតទៅនេះថា

តថាគតំ ជេតវនេ វសន្តំ
អបុច្ឆិ វេទេហមុនី នតង្គោ
បច្ចេកពុទ្ធា កិរ នាម ហោន្តិ
ភវន្តិ តេ ហេតុហិ កេហិ ធីរ ។

នតង្គៈជាអ្នកប្រាជ្ញ ជាបុត្តនៃនាងទេវី ក្នុងដែនវេទេហៈ បានសួរព្រះតថាគត កាលគង់នៅក្នុងវត្តជេតពនថា ឮថា ព្រះបច្ចេកពុទ្ធទាំងឡាយ រមែងមាន តើព្រះបច្ចេកពុទ្ធជាអ្នកប្រាជ្ញទាំងនោះ រមែងកើតឡើងដោយហេតុដូចម្តេចខ្លះ ។

តទាហ សព្វញ្ញុវរោ មហេសី
អានន្ទភទ្ទំ មធុរស្សរេន
យេ សព្វពុទ្ធេសុ កតាធិការា
អលទ្ធមោក្ខា ជិនសាសនេសុ ។

គ្រានោះ ព្រះសព្វញ្ញុពុទ្ធដ៏ប្រសើរ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ទ្រង់បែរទៅត្រាស់នឹងព្រះអានន្ទដ៏ចម្រើន ដោយ

ព្រះសូរសៀងដ៏ពីរោះថា ពួកជនណា មានការកសាង បានធ្វើទុកហើយ ក្នុងសម្នាក់នៃព្រះពុទ្ធទាំងពួង តែមិនទាន់បានមោក្ខធម៌ ក្នុងសាសនានៃព្រះជិនស្រីទេ ។

តេនេវ សំវេគមុខេន ធីរា
វិនាបិ ពុទ្ធេហិ សុតិក្ខបញ្ញា
អារម្មណេនាបិ បរិត្តកេន
បច្ចេកពោធឹ អនុបាបុណន្តិ ។

ជនទាំងនោះ ជាអ្នកប្រាជ្ញ ជាអ្នកមានប្រាជ្ញាមុតថ្វា វៀរលែងតែព្រះពុទ្ធទាំងឡាយ រមែងបាននូវបច្ចេកពោធិញ្ញាណ ដោយប្រធាននៃសង្វេគនោះផង ដោយអារម្មណ៍ដ៏ស្តួចស្តើងនោះផង ។

សព្វម្ហិ លោកម្ហិ មមំ ឋបេត្វា
បច្ចេកពុទ្ធាន សមោវ នត្ថិ
តេសំ ឥមំ វណ្ណបទេសមត្តំ
វក្ខាមហំ សាធុ មហាមុនីនំ ។

ក្នុងលោកទាំងមូល វៀរលែងតែតថាគតចេញ មិនមានបុគ្គលណាស្មើនឹងព្រះបច្ចេកពុទ្ធឡើយ តថាគតនឹងសម្តែងនូវគុណ ត្រឹមតែសង្ខេបនេះ របស់ព្រះបច្ចេកពុទ្ធ

*ទាំងឡាយនោះ ( អ្នកទាំងឡាយចូរស្តាប់នូវគុណ ) របស់ពួកព្រះបច្ចេកពុទ្ធ ជាមហាមុនី ដោយប្រពៃចុះ ។*

សយមេវ ពុទ្ធាន មហាឥសីនំ
សាធូនិ វាក្យានិ មធូវ ខុទ្ទំ
អនុត្តរំ ភេសជ្ជំ បត្ថយន្តា
សុណាថ សព្វេ សុបសន្នចិត្តា ។

*អ្នកទាំងឡាយ កាលប្រាថ្នានូវភេសជ្ជៈដ៏ប្រសើរផុត គឺព្រះនិព្វាន ចូរមានចិត្តជ្រះថ្លាទាំងអស់គ្នា ស្តាប់នូវពាក្យដ៏ពីរោះ ដូចជាទឹកឃ្មុំផ្អិត របស់ព្រះមហាឥសីដែលត្រាស់ដឹងឯង ។*

បច្ចេកពុទ្ធាន សមាគតានំ
បរម្បរំ ព្យាករណានិ យានិ
អាទីនវោ យញ្ច វិរាគវត្ថុំ
យថា ច ពោធឹ អនុចាបុណឹសុ ។

*ព្រះបច្ចេកពុទ្ធទាំងឡាយ ដែលមកប្រជុំគ្នា មានព្យាករណ៍មានទោស មានវត្ថុនៃសេចក្តីរសាយចិត្ត ទាំងមានហេតុដែលបានសម្រេចនូវ ( បច្ចេក ) ពោធិញ្ញាណ ផ្សេងៗ គ្នា ។*

សរាគវត្ថូសុ វិរាគសញ្ញី

រត្តម្ហិ លោកម្ហិ វិរត្តចិត្តា
ហិត្វា បបញ្ចំ ជិតជន្តិតានិ
តត្ថេវ ពោធឹ អធុចាបុណឹសុ ។

*( ព្រះបច្ចេកពុទ្ធទាំងនោះ ) មានសេចក្តីសម្គាល់ ក្នុងការរសាយចិត្ត ក្នុងវត្ថុដែលប្រកបដោយរាគៈ មានចិត្តរសាយក្នុងលោក ដែលគេត្រេកត្រអាល លះបង់នូវបបញ្ចធម៌និងកិលេសជាត ដែលញុំាងសត្វឲ្យអន្ទះសា ហើយបានសម្រេចនូវពោធិញ្ញាណ ក្នុងទីនោះឯង* [១] ។

---

*១-បិ.៧២ ទំ.១៦-១៨ ឃ.២ ។*

# វគ្គទី ១

## បឋមគាថា

*បានឮថា* **ព្រះបច្ចេកពុទ្ធ** *អង្គនេះ ឈមចុះកាន់ភូមិបច្ចេក-ពោធិសត្វ បំពេញបារមីអស់ ២ អសង្ខេយ្យ និង ១ សែនកប្ប បួសក្នុងសាសនានៃព្រះមានព្រះភាគកស្សបៈ ជាអ្នកសមាទានការនៅព្រៃជាវត្ត បំពេញគតបច្ចាគតវត្តឲ្យបរិបូណ៌ បានធ្វើសមណធម៌ហើយ ។*

*បានឮថា បុគ្គលមិនបំពេញវត្តដូចពោលមកនេះ ឲ្យបរិបូណ៌ នឹងសម្រេចបច្ចេកពោធិញ្ញាណមិនបាន ។*

*សួរថា វត្ត ឈ្មោះគតបច្ចាគតវត្ត គឺអ្វី ។*

*ឆ្លើយថា ការនាំទៅនិងនាំត្រឡប់មក ។*

*ខ្ញុំនឹងពោលរឿងជាការអធិប្បាយវត្តនោះ ឲ្យជាក់ច្បាស់ដូច្នេះថា*

*ភិក្ខុរូបខ្លះ ក្នុងសាសនានេះ នាំទៅ តែមិននាំត្រឡប់មក ។ រូបខ្លះនាំត្រឡប់មក តែមិននាំទៅ ។ រូបខ្លះមិននាំទៅ មិននាំត្រឡប់មក ។ រូបខ្លះនាំទៅផង នាំត្រឡប់មកផង ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុណាក្រោកឡើងអំពីព្រឹក ធ្វើវត្តត្រង់លានព្រះចេតិយ និងលានពោធិព្រឹក្សស្រោចទឹកត្រង់ដើមពោធិ យកក្អមដងទឹក នាំមកតម្កល់ទុកត្រង់រោងទឹកផឹក ធ្វើអាចរិយវត្តនិងឧបជ្ឈាយវត្ត សមាទានខន្ធកវត្ត ៨២ និងមហាវត្ត*

១៤ ។ ភិក្ខុនោះ ជម្រះកាយហើយចូលកាន់សេនាសនៈ សម្ងំក្នុងទីអង្គុយដ៏ស្ងាត់ រហូតដល់ពេលត្រាច់បិណ្ឌបាត ដឹងថា បានពេលហើយ ស្លៀកស្បង់ ចងវត្តពន្ធ ដណ្ដប់ចីវរធៀងស្មាម្ខាង យកសង្ឃាដីដាក់លើស្មា ស្ពាយបាត្រត្រង់ចង្កេះស្មា ដាក់ចិត្តដល់កម្មដ្ឋាន ដើរទៅកាន់លានព្រះចេតិយ ថ្វាយបង្គំព្រះចេតិយ និងពោធិព្រឹក្ស ហើយឃ្លុំចីវរក្នុងទីជិតស្រុក កាន់បាត្រចូលក្នុងស្រុកដើម្បីបិណ្ឌបាត ។ ភិក្ខុដែលចូលទៅហើយយ៉ាងនេះ ជាអ្នកមានលាភ មានបុណ្យ ដែលពួកឧបាសកឧបាសិកាធ្វើសក្ការគោរព ត្រឡប់មកត្រង់ត្រកូលរបស់ឧបដ្ឋាកឬរោងសម្នាក់ ត្រូវពួកឧបាសកនិងឧបាសិកាសួរបញ្ហានោះ ៗ រមែងលះមនសិការនោះ ចេញអំពីស្រុកទៅ ព្រោះឆ្លើយបញ្ហារបស់ឧបាសកឧបាសិកាទាំងនោះ និងព្រោះការរាយមាយដែលកើតអំពីការសម្ដែងធម៌ មកកាន់វិហារ ត្រូវពួកភិក្ខុសួរបញ្ហា ក៏ត្រូវឆ្លើយបញ្ហាខ្លះ ពោលនូវធម៌ខ្លះ ដល់នូវការខ្វល់ខ្វាយក្នុងរឿងដទៃខ្លះ ខាតពេលជាមួយពួកភិក្ខុទាំងនោះ ដោយប្រការយ៉ាងនេះ អស់កាលក្រោយភត្ត ទាំងបឋមយាម និងមជ្ឈិមយាម ត្រូវភាពគ្រោតគ្រាតផ្លូវកាយគ្របសង្កត់ ក្នុងបច្ឆិមយាមក៏ដេក មិនដាក់ចិត្តដល់កម្មដ្ឋាន ។ ភិក្ខុនេះ ហៅថា នាំទៅ តែមិននាំត្រឡប់មក ។

ឯភិក្ខុណា ជាអ្នកមានជំងឺច្រើន ឆាន់ភត្តហើយ ក្នុងពេលទៀបភ្លឺអាហារមិនរលួយល្អ ក្នុងពេលព្រឹក មិនអាចក្រោកឡើងធ្វើវត្តតាមដែល

ពោលបាន ឬមិនអាចមនសិការកម្មដ្ឋានបាន តែត្រូវការបបរ របស់ទំពា ភេសជ្ជៈឬភត្ត គ្រាន់តែបានពេលប៉ុណ្ណោះ ក៏កាន់បាត្រនិងចីវរចូលក្នុងស្រុក បាននូវបបរ របស់ទំពា ភេសជ្ជៈ និងភត្តក្នុងស្រុកនោះហើយ នាំបាត្រចេញមក ធ្វើភត្តកិច្ចស្រេចហើយ អង្គុយលើអាសនៈដែលគេក្រាលទុក ធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាន សម្រេចគុណវិសេសក្ដី មិនបានសម្រេចក្ដី ត្រឡប់មកកាន់វិហារ នៅតែមនសិការនោះឯង ។ ភិក្ខុនេះ ហៅថា នាំត្រឡប់មក តែមិននាំទៅ ។ ពិតហើយ ភិក្ខុបែបនេះ ឆាន់បបរហើយ ចម្រើនវិបស្សនា សម្រេចអរហត្តក្នុងព្រះពុទ្ធសាសនា មានរាប់មិនអស់ ។ ក្នុងកោះសីហឡៈ អាសនៈតាមរោងឆាន់ក្នុងស្រុកនោះ ៗ ដែលភិក្ខុទាំងឡាយអង្គុយឆាន់បបរហើយ មិនសម្រេចអរហត្ត មិនមានឡើយ ។

ឯភិក្ខុណា ជាអ្នកច្រើនដោយសេចក្ដីប្រមាទ ដាក់នូវធុរៈ ទម្លាយវត្តទាំងពួង មានចិត្តចងដោយចំណង គឺចេតោខីលៈ ៥ យ៉ាង មិនធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាន ចូលទៅបិណ្ឌបាតក្នុងស្រុក ក៏យឺតយូរដោយការជជែកជាមួយនឹងពួកគ្រហស្ថ ជាមនុស្សទទេចាកចេញ ភិក្ខុនេះ ហៅថា មិននាំទៅ ទាំងមិននាំត្រឡប់មក ។

ឯភិក្ខុណាក្រោកឡើងអំពីព្រលឹម ធ្វើវត្តគ្រប់យ៉ាងឲ្យបរិបូណ៌ដោយន័យដែលពោលក្នុងកាលមុននោះឯង ពត់ភ្នែន មនសិការកម្មដ្ឋានរហូតដល់វេលាភិក្ខាចារ ។ ធម្មតាកម្មដ្ឋានមាន ២ យ៉ាង គឺសព្វត្ថកម្មដ្ឋាន

កម្មដ្ឋានដែលគប្បីចម្រើនគ្រប់ស្ថានទី ១ បារិហារិយកម្មដ្ឋាន គឺកម្មដ្ឋានដែលត្រូវនាំទៅ ( រក្សា ) ជានិច្ច ១ ។ ក្នុងកម្មដ្ឋាន ២ យ៉ាងនោះ មេត្តានិងមរណានុស្សតិ ឈ្មោះថា សព្វត្ថកម្មដ្ឋាន ព្រោះកម្មដ្ឋានដូចពោលនោះ ចាំបាច់ក្នុងទីគ្រប់កន្លែង ព្រោះហេតុនោះ ទើបហៅថា សព្វត្ថកម្មដ្ឋាន ។ ធម្មតាមេត្តាចាំបាច់ក្នុងទីទាំងពួង មានក្នុងអាវាសជាដើម ។ ពិតហើយ ភិក្ខុដែលមានប្រក្រតីនៅដោយមេត្តាក្នុងអាវាសទាំងឡាយ រមែងជាទីស្រឡាញ់ជាទីពេញចិត្តរបស់សព្រហ្មចារីទាំងឡាយដោយមេត្តានោះ ធ្វើឲ្យនៅជាសុខ មិនខ្ចាំងខ្ចប់គ្នា ។ ភិក្ខុមានប្រក្រតីនៅដោយមេត្តាក្នុងទេវតាទាំងឡាយ នឹងជាបុគ្គលដែលពួកទេវតាគ្រប់គ្រងរក្សានៅជាសុខ ។ ភិក្ខុមានប្រក្រតីនៅដោយមេត្តាក្នុងព្រះរាជា និងមហាមាត្យរបស់ព្រះរាជាជាដើម ជាបុគ្គលដែលព្រះរាជា និងមហាមាត្យទាំងនោះ ស្រឡាញ់រាប់អាន នៅជាសុខ ។ ភិក្ខុអ្នកមានប្រក្រតីនៅដោយមេត្តាចំពោះអ្នកស្រុក និងអ្នកនិគមជាដើម ជាបុគ្គលដែលមនុស្សទាំងឡាយក្នុងទីគ្រប់កន្លែង មានទីត្រាច់ភិក្ខាជាដើម ធ្វើសក្ការគោរពរមែងនៅជាសុខ ។ ឯការចម្រើនមរណានុស្សតិ ភិក្ខុរមែងលះនូវការជាប់ចំពាក់ក្នុងជីវិត ជាអ្នកនៅដោយសេចក្តីមិនប្រមាទ ។

ចំណែកកម្មដ្ឋានដែលត្រូវនាំទៅជានិច្ច ជាកម្មដ្ឋានដែលរៀនយកតាមសមគួរដល់ចរិត ។ កម្មដ្ឋានណាមួយ បណ្តាអសុភ ១០ កសិណ

១០ និងអនុស្សតិ ១០ ចតុធាតុវវដ្ឋាន ហៅថា បារិហារិយកម្មដ្ឋាន ព្រោះចាំបាច់ត្រូវនាំទៅ ចាំបាច់ត្រូវរក្សា និងចាំបាច់ត្រូវចម្រើនសព្វកាលជានិច្ច ។ បារិហារិយកម្មដ្ឋាននេះឯង ហៅថា មូលកម្មដ្ឋានក៏បាន ។

កុលបុត្តណា ប្រាថ្នាប្រយោជន៍ បួសក្នុងសាសនានេះ នៅរួមគ្នា ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ ៤០ ឆ្នាំខ្លះ ៥០ ឆ្នាំខ្លះ ១០០ ឆ្នាំខ្លះ ធ្វើកតិកាវត្តថា នែអាវុសោទាំងឡាយ លោកទាំងឡាយមិនមែនបួសព្រោះជាកូនបំណុល មិនមែនបួសព្រោះមានភ័យ មិនមែនបួសដើម្បីចិញ្ចឹមជីវិត តែបំណងនឹងរួចផុតចាកទុក្ខ ទើបបានបួសក្នុងសាសនានេះ ព្រោះហេតុនោះ កិលេសកើតក្នុងពេលដើរ លោកទាំងឡាយ ចូរសង្កត់សង្កិនក្នុងពេលដើរនោះឯង កិលេសដែលកើតក្នុងពេលឈរ ចូរសង្កត់សង្កិនក្នុងពេលឈរនោះឯង កិលេសដែលកើតក្នុងពេលអង្គុយ ចូរសង្កត់សង្កិនក្នុងពេលអង្គុយនោះឯង កិលេសដែលកើតក្នុងពេលដេក ចូរសង្កត់សង្កិនក្នុងពេលដេកនោះឯង ។

កុលបុត្តទាំងនោះ កាលធ្វើកតិកាវត្តយ៉ាងនេះហើយ ខណៈដើរទៅបិណ្ឌបាតក្នុងរវាងកន្ទះឧសភៈ មួយឧសភៈ កន្ទះគាវុតនិងមួយគាវុត មានថ្មទំនេរ ក៏យកដុំថ្មនោះជាទីចំណាំ ធ្វើទុកក្នុងចិត្តដល់កម្មដ្ឋាន ដើរទៅ ។ បើក្នុងពេលដើរទៅ កិលេសកើតឡើងដល់បុគ្គលណា បុគ្គលនោះ រមែងសង្កត់កិលេសនោះ ក្នុងពេលដើរនោះឯង បើធ្វើយ៉ាងនោះ

មិនបាន ក៏ឈប់ហើយឈរ កាលភិក្ខុដើរមកតាមក្រោយក៏ឈប់ដូចគ្នា ។ បុគ្គលនោះ នឹងចោទខ្លួនឯងឡើងថា ភិក្ខុនេះ ដឹងនូវការត្រិះរិះដែលកើតឡើងហើយដល់អ្នក សេចក្តីនេះ មិនសមគួរដល់អ្នក ដូច្នេះហើយ ចម្រើនវិបស្សនា រមែងឈានចុះកាន់អរិយភូមិក្នុងគ្រាឈរនោះឯង កាលមិនអាចធ្វើយ៉ាងនោះ ទើបអង្គុយ កាលភិក្ខុដើរមកតាមក្រោយទាន់គ្នា ក៏អង្គុយដែរ បែបនេះរឿយ ៗ ទៅ ។ កាលមិនអាចឈានចុះកាន់អរិយភូមិ ក៏សង្កត់កិលេសនោះ ហើយដាក់ចិត្តដល់កម្មដ្ឋានប៉ុណ្ណោះ ដើរទៅ បើមានចិត្តឃ្លាតចាកកម្មដ្ឋាន មិនលើកជើង បើលើកជើង ត្រូវត្រឡប់មកឈរក្នុងទីដើមសិន ដូចព្រះមហាផុស្សទេវត្ថេរនៅក្នុងអាលិន្ទកវិហារដូច្នោះ ។

បានឮថា ព្រះថេរៈនោះ បំពេញគតបច្ចាគតវត្តយ៉ាងមាំទាំអស់ ១៩ ឆ្នាំ ឯមនុស្សទាំងឡាយ ភ្ជួរស្រែ ព្រោះស្រូវ ដកសំណាប ធ្វើការងារក្នុងរវាងផ្លូវ ឃើញព្រះថេរៈដើរទៅយ៉ាងនោះ និយាយគ្នាថា ព្រះថេរៈដើរត្រឡប់ទៅត្រឡប់មក គង់វង្វេងផ្លូវ ឬភ្លេចអ្វីហ្ន៎ ។ ព្រះថេរៈមិនដាក់ចិត្តក្នុងវាចានោះ មានចិត្តប្រកបដោយកម្មដ្ឋានតែម្យ៉ាង ធ្វើនូវសមណធម៌ក្នុងឆ្នាំទី ២០ ក៏បានសម្រេចអរហត្ត ។ ក្នុងថ្ងៃដែលព្រះថេរៈសម្រេចអរហត្តនោះឯង ទេវតាដែលអាស្រ័យនៅត្រង់ចុងទីចង្ក្រម បានឈរយកម្រាមដៃទាំងឡាយ ធ្វើពន្លឺឲ្យភ្លឺឡើង មហារាជទាំងបួន សក្កទេវរាជនិង

សហម្បតីព្រហ្ម ក៏នាំគ្នាមកកាន់ទីបម្រើ ។ ព្រះមហាតិស្សត្ថេរដែលនៅក្នុងព្រៃបានឃើញពន្លឺនោះ ក្នុងថ្ងៃទី ២ ក៏សួរថា ក្នុងពេលយប់ មានពន្លឺក្នុងសម្នាក់របស់អាវុសោ តើពន្លឺនោះ ជាពន្លឺអ្វី ។ ព្រះថេរៈនោះ កាលធ្វើនូវការបន្ទប់ ទើបពោលពាក្យយ៉ាងនេះថា ធម្មតាពន្លឺ ជាពន្លឺរបស់ប្រទីបក៏មាន ជាពន្លឺរបស់កែវមណីក៏មាន ។ លុះព្រះមហាតិស្សត្ថេរចាប់ចំណុចបាន សួរថា លោកម្ចាស់បិទបាំងឬ ទើបទទួលថា ករុណា ហើយប្រាប់ ។

ដូចព្រះមហានាគត្ថេរអ្នកនៅក្នុងកាឡវល្លិមណ្ឌប បានឮថា ព្រះថេរៈនោះ កាលបំពេញគតបច្ចាគតវត្ត បានគិតថា ខាងដើម អញនឹងបូជាមហាបធាន ( សេចក្តីព្យាយាមធំ ) របស់ព្រះមានព្រះភាគ ហើយអធិដ្ឋានការឈរ និងការចង្ក្រមប៉ុណ្ណោះ អស់ ៧ ឆ្នាំ បានបំពេញគតបច្ចាគតវត្តអស់ ១៦ ឆ្នាំ ទើបសម្រេចអរហត្ត ។ ព្រះថេរៈមានចិត្តមាំទាំក្នុងកម្មដ្ឋានយ៉ាងនេះឯង ទើបលើកជើង កាលលើកជើងឡើង បើចិត្តប្រាសចាកកម្មដ្ឋាន ក៏បែរត្រឡប់មក លោកទៅរហូតជិតស្រុកហើយឈរក្នុងទីដែលអ្នកស្រែគួរសង្ស័យថា ជាគោ ឬជាបព្វជិតហ្ន៎ ទើបដណ្តប់សង្ឃាដី កាន់បាត្រចូលទៅដល់ទ្វារស្រុក យកទឹកអំពីកុណ្ឌីដែលត្បៀតត្រង់ចន្លោះក្លៀកមកបៀមហើយ ទើបចូលស្រុកដោយគិតថា អាត្មាអញកុំបីលះបង់កម្មដ្ឋាន ដោយហេតុត្រឹមតែពោលនឹងពួកមនុស្សដែលចូល

មករកដើម្បីប្រគេនភិក្ខា ឬដើម្បីថ្វាយបង្គំថា ចូរមានអាយុវែងចុះ ។ បើពួកគេសួរដល់ថ្ងៃថា បពិត្រលោកម្ចាស់ ថ្ងៃនេះជាថ្ងៃ ៧ ឬថ្ងៃ ៨ លោកខ្វាក់ទឹកហើយ ទើបប្រាប់ បើមិនមានបុគ្គលសួរដល់ថ្ងៃ ក្នុងពេលចេញទៅ លោកខ្វាក់ទឹកត្រង់ទ្វារស្រុក ហើយដើរទៅ ។

និងដូចភិក្ខុ ៥០ រូប ចាំវស្សាក្នុងកលម្ពតិត្ថវិហារ ក្នុងកោះសីហឡៈ ។ បានឮថា ក្នុងថ្ងៃវស្សូបនាយិកឧបោសថ ភិក្ខុទាំងនោះ បានធ្វើកតិកាគ្នាថា យើងទាំងឡាយ បើមិនសម្រេចអរហត្ត នឹងមិននិយាយគ្នា ។ កាលចូលស្រុកដើម្បីបិណ្ឌបាត ក៏បៀមទឹកត្រង់ទ្វារស្រុកហើយ ទើបចូលទៅ ។ កាលគេសួរដល់ថ្ងៃ ក៏ខ្វាក់ទឹកហើយ ទើបប្រាប់ កាលមិនមានអ្នកសួរ ក៏ខ្ពុរចោលត្រង់ទ្វារស្រុក ហើយត្រឡប់មកកាន់វិហារ ។ មនុស្សទាំងឡាយក្នុងទីនោះ ឃើញស្នាមទឹកដែលខ្ពុរ ក៏ដឹងបានថា ថ្ងៃនេះ មកមួយរូប ថ្ងៃនេះ មក ២ រូប នាំគ្នាគិតយ៉ាងនេះថា ភិក្ខុទាំងនេះ មិននិយាយជាមួយនឹងពួកយើង ឬមិននិយាយគ្នានឹងគ្នាដែរ បើមិននិយាយរកគ្នា គង់កើតជម្លោះពិត ណ្ហើយចុះ ពួកយើងនឹងឲ្យភិក្ខុទាំងនោះខមាទោសដល់គ្នានឹងគ្នា មនុស្សទាំងឡាយក៏នាំគ្នាទៅកាន់វិហារ កាលភិក្ខុ ៥០ រូបនៅក្នុងវិហារនោះ ចូលវស្សា មិនឃើញភិក្ខុ ២ រូប ក្នុងទីតែមួយ ។ លំដាប់នោះ បណ្ដាមនុស្សទាំងនោះ បុរសមានភ្នែកល្អម្នាក់ពោលយ៉ាងនេះថា អ្នកដ៏ចម្រើនទាំងឡាយ ឱកាសនៃអ្នកទាស់ទែងគ្នា

រមែងមិនដូច្នេះ លានព្រះចេតិយ លានពោធិព្រឹក្សស្អាតបាត អំបោសក៏រក្សាទុករៀបរយ ទឹកផឹក ទឹកប្រើប្រាស់ ក៏តម្កល់ទុកល្អ បន្ទាប់អំពីនោះមនុស្សទាំងនោះ ក៏នាំគ្នាត្រឡប់ ។ ខាងក្នុងវស្សានោះឯង ភិក្ខុទាំងនោះចម្រើនវិបស្សនាបានសម្រេចអរហត្ត ក្នុងថ្ងៃមហាបវារណា ទើបបវារណាជាវិសុទ្ធិបវារណា ។

ភិក្ខុដូចគ្នានឹងព្រះមហានាគត្ថេរដែលនៅក្នុងកាឡវល្លិមណ្ឌប និងដូចភិក្ខុដែលនៅចាំវស្សាក្នុងកលម្ពតិត្ថវិហារយ៉ាងនេះហើយ ភិក្ខុមានចិត្តប្រកបដោយកម្មដ្ឋានតែម្យ៉ាង ឈានដើរទៅ កាលចូលទៅក្បែរស្រុកទើបបៀមទឹក កំណត់ផ្លូវដែលមិនមានបុគ្គលនាំឲ្យអន្តរាយ មានអ្នកលេងសុរា ដំរីកាច សេះកាចជាដើម ហើយដើរទៅតាមផ្លូវនោះ ។ កាលត្រាច់បិណ្ឌបាតក្នុងផ្លូវនោះ មិនប្រញាប់ប្រញាល់ទៅ ឈ្មោះថា ធុតង្គរបស់ភិក្ខុដែលត្រាច់បិណ្ឌបាតដើរដោយរហ័ស មិនមាន នឹងដើរត្រង់ ៗ ដូចរទេះផ្ទុកទឹកពេញ ធ្វងទីមិនរាបស្មើ ។ កាលដល់លំដាប់ផ្ទះហើយរង់ចាំកាលដែលសមគួរជាមុន ដើម្បីមើលថា មានមនុស្សពេញចិត្តប្រគេន ឬមិនមាន ទទួលភិក្ខាមកហើយ អង្គុយក្នុងទីដែលសមគួរ កាលដាក់ចិត្តក្នុងកម្មដ្ឋាន ឲ្យអាហារេបដិកូលសញ្ញា (សេចក្តីសម្គាល់ថា គួរខ្ពើមក្នុងអាហារ) ប្រាកដឡើង ពិចារណាប្រៀបធៀបដោយប្រេងបន្តក់ភ្លៅរទេះ ថ្នាំលាបដំបៅ និងសាច់កូនឯងថា

បានឮថា ស្វាមីភរិយាពកូនតូចធ្វើដំណើរឆ្លងកន្តារ គឺផ្លូវដាច់ស្រយាលមិនមានបាយនិងទឹក ដែលមានចម្ងាយ ១០០ យោជន៍ ដោយស្បៀងបន្តិចបន្តួច ។ លុះធ្វើដំណើរបានចម្ងាយ ៥០ យោជន៍ ស្បៀងក៏អស់ទៅ ។ ជនទាំងពីរស្រេកឃ្លានជាខ្លាំង កម្លាំងក៏ថមថយ មិនអាចបន្តដំណើរទៅមុខទៀតបាន ក៏សម្រាកក្រោមដើមឈើមួយដើមដែលមានម្លប់ត្រសុំត្រសាយ ។ ស្វាមីក៏និយាយទៅកាន់ភរិយាថា នែនាងដ៏ចម្រើនពីនេះទៅមុខ ៥០ យោជន៍ដោយជុំវិញ មិនមានស្រុក ឬនិគមឡើយឥឡូវនេះ កិច្ចដែលមនុស្សប្រុសគប្បីធ្វើ មានកសិកម្ម គោរក្ខកម្មជាដើមសូម្បីច្រើន ក៏ខ្ញុំមិនអាចដើម្បីធ្វើការងារទាំងនោះ ( មកចិញ្ចឹមគ្រួសារ ) បានឡើយ សូមនាងសម្លាប់ខ្ញុំ យកសាច់ពាក់កណ្តាលបរិភោគ ហើយវេចខ្ចប់ពាក់កណ្តាលធ្វើជាស្បៀង នាំកូនធ្វើដំណើរទៅចុះ ។

ភរិយាពោលថា អ្នកជាម្ចាស់ កិច្ចដែលមនុស្សស្រីគប្បីធ្វើការងារមានត្បាញរវៃអំបោះជាដើម សូម្បីច្រើន ក៏ខ្ញុំមិនអាចដើម្បីធ្វើការងារទាំងនោះ ( មកចិញ្ចឹមគ្រួសារ ) បានឡើយ សូមអ្នកសម្លាប់ខ្ញុំ យកសាច់ពាក់កណ្តាលបរិភោគ ហើយវេចខ្ចប់ពាក់កណ្តាល ធ្វើជាស្បៀងនាំកូនធ្វើដំណើរទៅចុះ ។ ចំណែកស្វាមីក៏ពោលទៀតថា នាងដ៏ចម្រើន សេចក្តីស្លាប់រមែងប្រាកដដល់មនុស្សពីរនាក់ ព្រោះការស្លាប់របស់ម្តាយ ព្រោះថា កូនតូច បើអត់អំពីម្តាយហើយ ក៏មិនអាចរស់នៅបាន តែបើយើង

ទាំងពីរនៅមានជីវិត នឹងបានកូនទៀត ណ្ហើយចុះ ពួកយើងនឹងសម្លាប់កូនប្រុសតូចឥឡូវនេះ កាន់យកសាច់បរិភោគ ហើយធ្វើដំណើរឆ្លងផ្លូវដាច់ស្រយាលនេះ ។ លំដាប់នោះ មាតាក៏ពោលនឹងបុត្តថា នែបា ចូរកូនទៅរកឪពុកកូនចុះ ។ កូនតូចនោះ ក៏ដើរទៅរកបិតា ។ លំដាប់នោះ ឪពុកក្មេងតូចនោះពោលថា អញបានទទួលនូវសេចក្តីទុក្ខមិនមែនតិច ព្រោះកសិកម្មនិងគោរក្ខកម្មជាដើម ដើម្បីរកទ្រព្យចិញ្ចឹមកូន អញមិនអាចសម្លាប់កូនបាន នាងនុ៎ះឯង ចូរសម្លាប់កូនរបស់នាង ហើយប្រាប់កូនថា នែបា ចូរកូនទៅរកម្តាយរបស់កូនចុះ ។ កូនតូចនោះ ក៏ដើរទៅរកមាតា ។ លំដាប់នោះ ភរិយាពោលថា ខ្ញុំទទួលសេចក្តីទុក្ខមិនមែនតិច ដោយការប្រព្រឹត្តគោវត្ត កុក្កុរវត្ត ព្រោះបន់ស្រន់សូមឲ្យបានបុត្ត និយាយទៅថ្វី ដល់ការរក្សាគភ៌ ខ្ញុំមិនអាចសម្លាប់កូនបានទេ ហើយពោលនឹងកូនតូចថា នែបា ចូរកូនទៅរកឪពុករបស់កូនចុះ ។ ទារកដើរទៅដើរមកក្នុងរវាងឪពុកម្តាយនោះឯង ក៏ដាច់ខ្យល់ស្លាប់ទៅដោយប្រការដូច្នេះ ។ ស្វាមីភរិយាឃើញដូច្នោះ ក៏ទ្រហោយំ កាន់យកសាច់កូនទំពាស៊ី ចៀសចេញទៅ ដោយន័យដែលពោលហើយ ។

អាហារ គឺសាច់កូនរបស់ជនទាំងពីរ គឺស្វាមីនិងភរិយានោះ មិនមែនបរិភោគដើម្បីលេង មិនមែនបរិភោគដើម្បីឲ្យស្រវឹង គឺឡើងកម្លាំង មិនមែនបរិភោគដើម្បីប្រដាប់តាក់តែង ព្រោះសាច់កូននោះ ជាសាច់

*បដិកូល ( គួរខ្ពើម ) ដោយហេតុ ៩ ប្រការ ជាអាហារដើម្បីឆ្លងកន្តារតែម្យ៉ាងប៉ុណ្ណោះ ។*

*សួរថា បដិកូលដោយហេតុ ៩ ប្រការ គឺអ្វីខ្លះ ។*

*ឆ្លើយថា*

| | |
|---|---|
| ១-សជាតិមំសតាយ | *ជាសាច់មនុស្សមានជាតិដូចគ្នា* |
| ២-ញាតិមំសតាយ | *ជាសាច់របស់ញាតិ* |
| ៣-បុត្តមំសតាយ | *ជាសាច់របស់កូន* |
| ៤-បិយបុត្តមំសតាយ | *ជាសាច់របស់កូនដ៏ជាទីស្រឡាញ់* |
| ៥-តរុណមំសតាយ | *ជាសាច់ក្មេងតូច* |
| ៦-អាមកមំសតាយ | *ជាសាច់ឆៅ* |
| ៧-អភោគមំសតាយ | *ជាសាច់មិនគួរបរិភោគ* |
| ៨-អលោណតាយ | *ជាសាច់សាប* |
| ៩-អធូបិតតាយ | *ជាសាច់ដែលមិនបានចម្អិន ។* |

*ពិតណាស់ ស្វាមីភរិយានោះ បរិភោគសាច់កូនដែលបដិកូលដោយហេតុ ៩ ប្រការនោះ ដោយប្រការដូច្នេះ ទើបមិនបានបរិភោគដោយត្រេកអរ តែបរិភោគដោយចិត្តជាកណ្តាល ៗ នោះឯង គឺបរិភោគដោយមិនមានសេចក្តីពេញចិត្តនិងត្រេកអរឡើយ កាលទំពាស៊ី មិនបានរើសយកសាច់ដែលជាប់ឆ្អឹង សរសៃ និងស្បែកចេញ ហើយទំពាស៊ីតែសាច់*

ដែលល្អ ៗ ឡើយ ទំពាស៊ីតែសាច់ដែលនៅចំពោះមុខប៉ុណ្ណោះ មិនបានទំពាស៊ីតាមដែលត្រូវការរហូតពេញមាត់ តែទំពាស៊ីម្ដងបន្តិច ៗ ល្មមញុំាងជីវិតឲ្យប្រព្រឹត្តទៅមួយថ្ងៃ ៗ ប៉ុណ្ណោះ មិនបានដណ្ដើមគ្នានឹងគ្នាទំពាស៊ីដោយចិត្តបរិសុទ្ធពិត ៗ ប្រាសចាកមន្ទិលគឺសេចក្ដីកំណាញ់ មិនបានទំពាស៊ីដោយវង្វេងថា ពួកយើងទំពាស៊ីសាច់ម្រឹគ ឬជាសាច់ក្ងោកជាដើម សាច់សត្វឯណានីមួយ តែទំពាស៊ីដោយដឹងថា នេះជាសាច់កូនជាទីស្រឡាញ់ មិនបានទំពាស៊ីដោយចំណង់ថា ធ្វើដូចម្ដេចហ្ន៎ អញនឹងបានសាច់កូនបែបនេះស៊ីទៀត មិនបានសន្សំទុកថា កាលឆ្លងផុតផ្លូវកន្តារហើយ អញនឹងយកសាច់ដែលសល់នេះ ផ្សំជាមួយរសប្រៃរសជូរជាដើមហើយបរិភោគ តែកាលឆ្លងផ្លូវកន្តារហើយ គិតថា មហាជនក្នុងក្រុង នឹងឃើញ ទើបកប់ក្នុងដី ឬយកភ្លើងដុត មិនបានប្រកាន់ខ្លួន និងអួតអាងថាអ្នកដទៃមិនបានស៊ីសាច់កូនបែបនេះ ដូចអញ តែទំពាស៊ីដោយកម្ចាត់នូវសេចក្ដីប្រកាន់ និងការអួតអាង មិនបានទំពាស៊ីដោយមើលងាយថាប្រយោជន៍អ្វី ដោយសាច់បែបនេះ មិនប្រៃ មិនជូរ មិនបានចម្អិន មានក្លិនស្អុយ តែទំពាស៊ីដោយប្រាសចាកការមើលងាយ មិនមើលងាយគ្នានឹងគ្នាថា នេះចំណែកនាង នេះចំណែកខ្ញុំ កូនរបស់នាង កូនរបស់ខ្ញុំមានការព្រមព្រៀងគ្នា ទំពាស៊ីនុ៎ះឯង [១] យ៉ាងណា បណ្ឌិតគប្បីទុក

---

១-ស្រង់ចាកអដ្ឋកថា បុត្តមំសូបមសូត្រ បិ.៣១ ទំ.២១៥ ឃ.២៤១ ។

អាហារដែលខ្លួនបរិភោគហាក់ដូចជាសាច់កូន ក៏យ៉ាងនោះ ។

ភិក្ខុអ្នកប្រព្រឹត្តគតបច្ចាគតវត្តនោះ បរិភោគអាហារដែលប្រកបដោយអង្គ ៨ គឺមិនមែនដើម្បីលេង ១ មិនមែនដើម្បីស្រវឹង ១ មិនមែនដើម្បីប្រដាប់តាក់តែង ១ មិនមែនដើម្បីឲ្យផូរផង់សម្បុរ ១ ដើម្បីឲ្យកាយតាំងនៅ ១ ដើម្បីញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ១ ដើម្បីបំបាត់នូវសេចក្តីលំបាក ១ ដើម្បីអនុគ្រោះព្រហ្មចរិយធម៌ ១ បរិភោគហើយធ្វើកិច្ចដោយទឹក បន្ទោបង់នូវសេចក្តីលំបាកព្រោះភត្តមួយស្របក់ ហើយធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាន អស់កាលខាងក្រោយភត្ត អស់បឋមយាម និងបច្ឆិមយាមដូចកាលមុនភត្ត ។ ភិក្ខុនេះ ហៅថា នាំទៅផង នាំត្រឡប់មកផង ។ ការនាំទៅនិងនាំត្រឡប់មកនេះ ហៅថា គតបច្ចាគតវត្ត ។

ភិក្ខុបំពេញវត្តនេះ បើជាអ្នកដល់ព្រមដោយឧបនិស្ស័យ រមែងសម្រេចអរហត្តក្នុងបឋមវ័យនោះឯង បើមិនសម្រេចក្នុងបឋមវ័យ ក៏នឹងសម្រេចក្នុងមជ្ឈិមវ័យ បើមិនសម្រេចក្នុងមជ្ឈិមវ័យ ក៏សម្រេចក្នុងពេលជិតស្លាប់ បើមិនសម្រេចក្នុងពេលជិតស្លាប់ បានជាទេវបុត្តហើយនឹងសម្រេច បើជាទេវបុត្តមិនសម្រេច ក៏នឹងបានជាព្រះបច្ចេកសម្ពុទ្ធហើយបរិនិព្វាន ។ បើមិនបានជាព្រះបច្ចេកសម្ពុទ្ធបរិនិព្វាន ក៏នឹងបានជាខិប្បាភិញ្ញាបុគ្គល ក្នុងកាលបានចួបព្រះពុទ្ធទាំងឡាយ ដូចព្រះពាហិយត្ថេរ ឬនឹងជាអ្នកមានបញ្ញាច្រើន ដូចព្រះសារីបុត្តត្ថេរ ។

ព្រះបច្ចេកពោធិសត្វអង្គនេះ បួសក្នុងសាសនារបស់ព្រះមានព្រះ-ភាគកស្សបៈ ជាអ្នកសមាទានការនៅព្រៃជាវត្ត បំពេញគតបច្ចាគតវត្តនេះ អស់ ២ ម៉ឺនឆ្នាំ ធ្វើកាលកិរិយាហើយ កើតក្នុងកាមាវចរទេវលោក ចុតិអំពីនោះហើយ បដិសន្ធិក្នុងផ្ទៃនៃអគ្គមហេសីរបស់ព្រះបាទពារាណសី ។ ស្ត្រីទាំងឡាយដែលជាអ្នកឈ្លាស រមែងដឹងនូវការតាំងគភ៌ក្នុងថ្ងៃនោះឯង អគ្គមហេសីអង្គនោះ ក៏ជាស្ត្រីមួយរូបក្នុងចំណោមស្ត្រីទាំងនោះ ព្រោះហេតុនោះ ព្រះនាងក៏ក្រាបទូលនូវការតាំងគភ៌នោះ ដល់ព្រះរាជា ។ កាលសត្វអ្នកមានបុណ្យកើតឡើងក្នុងឧទរ ស្ត្រីរមែងបាននូវការរក្សាគភ៌នោះ សេចក្តីនេះ ជាធម្មតា ព្រោះហេតុនោះ ព្រះរាជាបានប្រទាននូវការរក្សាគភ៌ដល់អគ្គមហេសីអង្គនោះ ។ ចាប់តាំងអំពីនោះមក ព្រះនាងមិនបានបរិភោគរបស់ដែលក្តៅខ្លាំង ត្រជាក់ខ្លាំង ជូរខ្លាំង ប្រៃខ្លាំង ហឹរខ្លាំង និងល្វីងខ្លាំង ។ ព្រោះកាលមាតាបរិភោគរបស់ក្តៅខ្លាំង សត្វដែលកើតក្នុងផ្ទៃ រមែងដូចនៅក្នុងលោហកុម្ភីនរក កាលបរិភោគរបស់ត្រជាក់ពេក រមែងដូចនៅក្នុងលោកន្តរនរក កាលបរិភោគរបស់ជូរពេក ប្រៃពេក ហឹរពេក ល្វីងពេក អវយវៈរបស់ទារកដល់នូវវេទនាដ៏ខ្លាំងក្លា ដូចត្រូវកាត់ដោយកាំបិត ស្រោចដោយទឹកក្បុងជាដើម ទើបអ្នកថែរក្សាគភ៌ទាំងឡាយ ហាមព្រះនាងដោយការដើរច្រើន ឈរច្រើន អង្គុយច្រើន ដេកច្រើន ដោយបំណងថា ទារកក្នុងផ្ទៃ កុំមានសេចក្តីលំបាកព្រោះការ

កម្រើកឡើយ ។ ព្រះនាងបានទទួលការអនុញ្ញាតឲ្យដើរទៅដើរមកជាដើម យ៉ាងគ្រប់គ្រាន់ លើទីដែលក្រាលដោយកម្រាលដ៏ទន់ បានសោយបាយ និងទឹកដែលសមគួរ ឆ្ងាញ់ ដល់ព្រមដោយពណ៌និងក្លិនជាដើម អ្នកថែរក្សាចាំផ្គង (គ្រាហ៍) ឲ្យព្រះនាងយាង គង់ និងក្រោកឡើង ។

ព្រះនាងដែលគេរក្សាយ៉ាងនេះ ក្នុងពេលព្រះគភ៌ចាស់ យាងចូលផ្ទះប្រសូតិ ក្នុងពេលទៀបភ្លឺ ប្រសូតព្រះរាជឱរសដូចគ្នានឹងដុំមនោសិលាដែលលាបដោយប្រេងដែលចម្រាញ់ហើយ ប្រកបដោយធញ្ញលក្ខណៈ និងបុញ្ញលក្ខណៈ ។ ក្នុងថ្ងៃទី ៥ បន្ទាប់អំពីថ្ងៃនោះ ព្រះញាតិទាំង-ឡាយ ក៏នាំព្រះរាជឱរសដែលប្រដាប់តាក់តែងហើយ ទៅថ្វាយព្រះរាជាទត ។ ព្រះរាជាទ្រង់សប្បាយព្រះរាជហឫទ័យ ឲ្យទំនុកបម្រុងដោយមេដោះ ៦៦ នាក់ ព្រះរាជឱរសនោះ ចម្រើនដោយសម្បត្តិទាំងពួង មិនយូរប៉ុន្មាន ទ្រង់ក៏ដល់នូវភាពជាអ្នកដឹងក្តី ។ ព្រះរាជាទ្រង់អភិសេកព្រះរាជឱរសនោះ ដែលមានព្រះជន្ម ១៦ វស្សា ដោយរាជសម្បត្តិ និងឲ្យបម្រើដោយអ្នករបាំផ្សេង ៗ ព្រះរាជឱរសអភិសេកហើយ មានព្រះនាមថា ព្រហ្មទត្ត គ្រងរាជសម្បត្តិ មាននគរ ២ ម៉ឺន ក្នុងសកលជម្ពូទ្វីប ។

បានឮថា ក្នុងកាលមុន ជម្ពូទ្វីបនេះ មាននគរ ៨ ម៉ឺន ៤ ពាន់ នគរទាំងនោះ វិនាសនៅសល់ ៦ ម៉ឺននគរ បន្ទាប់អំពីនោះ វិនាសនៅសល់ត្រឹម ៤ ម៉ឺននគរ ក្នុងពេលចុងក្រោយ នៅសល់ត្រឹមតែ ២ ម៉ឺននគរ ។

ព្រះបាទព្រហ្មទត្តនេះ កើតឡើងក្នុងពេលនគរវិនាសអស់ ព្រោះហេតុនោះ ទើបទ្រង់មាននគរ ២ ម៉ឺន មានប្រាសាទ ២ ម៉ឺន មានពលដំរី ២ ម៉ឺន មានពលសេះ ២ ម៉ឺន មានពលរថ ២ ម៉ឺន មានពលថ្មើរជើង ២ ម៉ឺន មានស្រ្តី ២ ម៉ឺន គឺស្រីស្នំនិងស្រីរបាំ និងមានអាមាត្យ ២ ម៉ឺននាក់ ។

ព្រះបាទព្រហ្មទត្តអង្គនោះ កំពុងគ្រងមហារាជសម្បត្តិនោះឯង ទ្រង់ធ្វើនូវកសិណបរិកម្ម (ទ្រង់ញ៉ាំង) អភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតឡើងបាន ។ ធម្មតាព្រះរាជាដែលអភិសេកហើយ ត្រូវគង់ក្នុងសាលាវិនិច្ឆ័យជាប្រចាំ ព្រោះហេតុនោះ ព្រឹកថ្ងៃមួយ ទ្រង់សោយក្រយាស្ងោយព្រឹកហើយ គង់ក្នុងទីវិនិច្ឆ័យ ។ ក្នុងទីនោះ ពួកមនុស្សបានធ្វើសំឡេងអឺងកង ទ្រង់ព្រះតម្រិះថា សំឡេងនេះ ជាឧបក្កិលេសនៃសមាបត្តិ ទើបឡើងកាន់ប្រាសាទគង់ប្រថាប់ បំណងនឹងចូលសមាបត្តិ ក៏មិនអាចចូលបាន ព្រោះក្រវល់ក្រវាយនឹងការគ្រប់គ្រងរាជ្យ ទើបសមាបត្តិវិនាស ។ លំដាប់នោះ ទ្រង់ព្រះតម្រិះទៀតថា រាជសម្បត្តិប្រសើរ ឬសមណធម៌ប្រសើរ បន្ទាប់អំពីនោះ ទ្រង់ជ្រាបថា សេចក្តីសុខក្នុងរាជសម្បត្តិបន្តិចបន្តួច មានទោសច្រើន តែសេចក្តីសុខក្នុងសមណធម៌ទូលំទូលាយ មានអានិសង្សមិនមែនតិច បុរសដ៏ឧត្តមសេពហើយ ទើបទ្រង់បញ្ជាអាមាត្យម្នាក់ថា ចូរអ្នកគ្រប់គ្រងរាជសម្បត្តិនេះ ដោយធម៌ស្មើ កុំគ្រប់គ្រងដោយអធម៌ ដូច្នេះហើយ ប្រគល់រាជសម្បត្តិទាំងពួងឲ្យដល់អាមាត្យនោះ ហើយ

ទ្រង់ឡើងកាន់ប្រាសាទ ទ្រង់ឲ្យពេលវេលាកន្លងទៅដោយសេចក្តីសុខក្នុងសមាបត្តិ បុគ្គលណាមួយចូលទៅគាល់មិនបាន វៀរលែងតែអ្នកថ្វាយទឹកលុបព្រះភក្ត្រនិងឈើស្ទន់ និងអ្នកនាំព្រះក្រយាស្ងោយទៅថ្វាយប៉ុណ្ណោះ ។

តមក ក្នុងកាលកន្លងទៅកន្លះខែ អគ្គមហេសីសួរថា មិនឃើញព្រះរាជាក្នុងទីណាមួយ ក្នុងការយាងទៅប្រពាតឧទ្យាន ការត្រួតពលនិងការមើលស្រីរបាំជាដើម ព្រះរាជាទ្រង់យាងទៅណា ។ អាមាត្យទាំងឡាយក៏ក្រាបទូលសេចក្តីនោះ ដល់អគ្គមហេសី ។ ព្រះនាងបញ្ជូនដំណឹងទៅប្រាប់អាមាត្យនោះថា កាលអ្នកទទួលរាជសម្បត្តិ សូម្បីខ្ញុំ ក៏ឈ្មោះថា អ្នកទទួលដែរ អ្នកចូរមក ចូរសម្រេចការនៅរួមជាមួយខ្ញុំ ។ អាមាត្យនោះ បិទត្រចៀកទាំងពីរបដិសេធថា ព្រះនាងកុំមានព្រះសវនីយ៍យ៉ាងនេះ ។

ព្រះនាងក៏បញ្ជូនដំណឹងទៅទៀត អស់វារៈ ២ ដង ៣ ដង ហើយគំរាមអាមាត្យនោះ ដែលមិនប្រាថ្នាថា បើអ្នកមិនធ្វើ យើងនឹងដកតំណែងនឹងឲ្យផ្តាច់ជីវិតអ្នក ។ អាមាត្យនោះខ្លាច គិតថា ធម្មតាមាតុគ្រាម ជាអ្នកចិត្តដាច់ ជួនកាលអាចធ្វើដូចពាក្យសម្តីនោះ ថ្ងៃមួយ ទៅកាន់ទីស្ងាត់សម្រេចការនៅរួមជាមួយព្រះនាងលើសិរីសយនា ។ ព្រះនាងជាស្រីមានបុណ្យ មានសម្ផស្សទន់ អាមាត្យនោះត្រេកអរហើយ ដោយតម្រេកក្នុងសម្ផស្សរបស់ព្រះនាង ទាំងដែលមានការភ័យខ្លាច ចូលទៅក្នុងទីនោះ

ឯងរឿយ ៗ ក្រោយមក អស់សេចក្តីភ័យខ្លាច ចេញចូលដូចខ្លួនជាម្ចាស់ផ្ទះ ។

លំដាប់នោះ ពួកមនុស្សរបស់ព្រះរាជា បានក្រាបទូលរឿងនោះដល់ព្រះរាជា ។ ព្រះរាជាទ្រង់មិនជឿ ទើបនាំគ្នាក្រាបទូលអស់វារៈ ២ ដង អស់វារៈ ៣ ដង ។ គ្រានោះ ព្រះរាជាទ្រង់លបសង្កេត បានឃើញដោយព្រះអង្គឯង ទើបត្រាស់ឲ្យប្រជុំអាមាត្យទាំងអស់ ហើយប្រាប់ឲ្យដឹង ។ អាមាត្យទាំងនោះ ក្រាបទូលថា អាមាត្យនេះ ធ្វើខុសចំពោះព្រះរាជា គួរកាត់ដៃ គួរកាត់ជើង ។

ព្រះរាជាត្រាស់ថា ការសម្លាប់ ការចង និងការវាយបុរសនេះ វិហឹសាគឺការបៀតបៀន គប្បីកើតឡើងដល់យើង ក្នុងការផ្តាច់ជីវិត បាណាតិបាតក៏គប្បីកើតមាន បើរឹបអូសយកទ្រព្យ អទិន្នាទានក៏គប្បីកើតមាន មិនគួរធ្វើកម្មបែបនេះ ពួកអ្នកចូរបណ្តេញអាមាត្យនេះ ចេញអំពីអាណាចក្ររបស់យើង ។ អាមាត្យទាំងឡាយបានធ្វើអាមាត្យនោះឲ្យជាមនុស្សមិនមានទីពឹង ។ បុរសនោះ ក៏បាននាំបុត្ត ភរិយានិងទ្រព្យរបស់ខ្លួន ដែលល្មមនាំយកទៅបាន ( ធ្វើដំណើរ ) ទៅកាន់ដែននៃព្រះរាជាដទៃ ។ ព្រះរាជាក្នុងដែននោះ ទ្រង់ជ្រាប ទើបត្រាស់សួរថា **កឹ អាគតោសិ** អ្នកមកដើម្បីអ្វី ។

បុរសនោះ ក្រាបទូលថា **ទេវ ឥច្ឆាមិ តំ ឧបដ្ឋាតុំ** បពិត្រព្រះ

សម្មតិទេព ទូលព្រះបង្គំប្រាថ្នានឹងបម្រើព្រះអង្គ ។ ព្រះរាជាអង្គនោះ ក៏ទទួល ។ លុះកន្លងទៅពីរបីថ្ងៃ អាមាត្យនោះ បានស្និទ្ធស្នាលហើយ ក្រាបទូលពាក្យនេះ នឹងព្រះរាជានោះថា បពិត្រមហារាជ ទូលព្រះបង្គំឃើញឃ្មុំមិនមានមេ អ្នកបរិភោគទឹកឃ្មុំនោះ ក៏មិនមាន ។ ព្រះរាជាទ្រង់ព្រះតម្រិះថា បុរសនេះ និយាយបែបនេះ គង់និយាយលេង ទើបទ្រង់មិនស្តាប់ ។ អាមាត្យនោះ បានឱកាស ក៏ពណ៌នាក្រាបទូលឲ្យល្អក្រៃលែងឡើងទៀត ។ ព្រះរាជាត្រាស់សួរថា ទឹកឃ្មុំនោះ គឺអ្វី ។

អាមាត្យនោះក្រាបទូលថា បពិត្រព្រះទេវៈ រាជសម្បត្តិក្នុងនគរពារាណសី ។ ព្រះរាជាត្រាស់ថា លោកបំណងនាំយើងឲ្យទៅស្លាប់ឬ ។

អាមាត្យនោះក្រាបទូលថា បពិត្រព្រះទេវៈ ទ្រង់កុំត្រាស់យ៉ាងនោះ បើទ្រង់មិនជឿ សូមទ្រង់បញ្ជូនមនុស្សទៅស៊ើបមើល ។ ព្រះរាជាទ្រង់ក៏បញ្ជូនមនុស្សទាំងឡាយទៅ ។ មនុស្សទាំងនោះទៅដល់ហើយ ក៏ជីករូងដីក្បែរខ្លោងទ្វារ ហើយផុសឡើងក្នុងដំណាក់ ត្រង់ក្រឡាបន្ទំរបស់ព្រះរាជា ។ ព្រះរាជាទ្រង់ឃើញហើយ ត្រាស់សួរថា ពួកអ្នកមកធ្វើអ្វី ។

មនុស្សទាំងនោះក្រាបទូលថា បពិត្រមហារាជ ទូលព្រះបង្គំទាំង-ឡាយ ជាចោរ ។ ព្រះរាជាបានឲ្យទ្រព្យដល់មនុស្សទាំងនោះ ហើយទូន្មានថា ពួកអ្នកកុំធ្វើយ៉ាងនេះទៀត ហើយដោះលែងទៅ ។

មនុស្សទាំងនោះ ក៏មកក្រាបទូលដំណើរនោះ ឲ្យព្រះរាជារបស់ខ្លួន

ជ្រាប ។ ព្រះរាជានោះ ទ្រង់ពិសោធយ៉ាងនោះឯង ពីរបីដងទៀត កាល ទ្រង់ជ្រាបថា ព្រះបាទព្រហ្មទត្ត ទ្រង់មានសីល ទើបលើកកងទ័ពដែល មានអង្គ ៤ ចូលទៅជិតនគរមួយត្រង់ចន្លោះព្រំដែន ហើយបញ្ជូនដំណឹង ដល់អាមាត្យក្នុងនគរនោះថា ឲ្យនគរដល់យើង ឬក៏ច្បាំង ។

អាមាត្យទាំងនោះ ឲ្យមនុស្សក្រាបទូលរឿងនោះ ដល់ព្រះបាទ ព្រហ្មទត្តថា បពិត្រព្រះទេវៈ សូមទ្រង់បញ្ជាមកថា ច្បាំង ឬលើកនគរឲ្យ ស្តេចនោះ ។ ព្រះរាជាទ្រង់បញ្ជូនដំណឹងទៅថា មិនចាំបាច់ច្បាំងទេ ចូរ ឲ្យនគរ ហើយមកក្នុងទីនេះ ។ អាមាត្យទាំងឡាយបានធ្វើតាមព្រះរាជ បញ្ជាយ៉ាងនោះ ឯព្រះរាជាដែលជាសត្រូវ ដណ្តើមយកនគរនោះបាន ហើយ ទ្រង់បញ្ជូនទូតទៅកាន់នគរដ៏សេសយ៉ាងនោះឯង ។ អាមាត្យ ទាំងនោះ ក៏ក្រាបទូលដល់ព្រះបាទព្រហ្មទត្តយ៉ាងនោះដូចគ្នា ។ កាល ព្រះបាទព្រហ្មទត្តត្រាស់ថា មិនចាំបាច់ច្បាំង គប្បីមកក្នុងទីនេះ ទើបនាំ គ្នាទៅកាន់នគរពារាណសី ។

លំដាប់នោះ អាមាត្យទាំងឡាយ ក្រាបទូលដល់ព្រះបាទព្រហ្មទត្ត ថា បពិត្រមហារាជ ពួកទូលព្រះបង្គំនឹងច្បាំងជាមួយព្រះរាជាអង្គនោះ ។ ព្រះរាជាទ្រង់ឃាត់ថា បាណាតិបាតនឹងមានដល់យើង ។

អាមាត្យទាំងឡាយក្រាបទូលថា បពិត្រមហារាជ ពួកទូលព្រះបង្គំ នឹងចាប់ព្រះរាជាអង្គនោះ ទាំងនៅមានព្រះជន្ម ហើយនាំមកក្នុងទីនេះ

ឲ្យបាន ប្រើឧបាយផ្សេង ៗ ឲ្យព្រះរាជាទ្រង់អនុញ្ញាត ហើយក្រាបទូលថា បពិត្រមហារាជ សូមស្ដេចយាង ដូច្នេះហើយ ផ្ដើមនឹងទៅ ។

ព្រះរាជាត្រាស់ថា បើអ្នកទាំងឡាយមិនធ្វើការសម្លាប់សត្វ មិនវាយ មិនប្ញន់ យើងក៏នឹងទៅ ។ ពួកអាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ពួកទូលព្រះបង្គំនឹងមិនធ្វើ ពួកទូលព្រះបង្គំនឹងធ្វើឲ្យភ័យខ្លាច ហើយឲ្យគេចទៅ ដូច្នេះហើយ ទើបប្រមូលចតុរង្គិនីសេនា ដាក់ប្រទីបក្នុងឆ្នាំង ដើរទៅទាំងកណ្ដាលរាត្រី ។

ថ្ងៃនោះ ព្រះរាជាជាសត្រូវដណ្ដើមនគរក្នុងទីជិតនគរពារាណសីបានហើយ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ គង់មិនមានអ្វីក្នុងពេលរាត្រីទើបឲ្យដោះគ្រោះ ជាអ្នកប្រមាទ ឈានចុះកាន់និទ្រា មួយអន្លើដោយពួកពល ។ លំដាប់នោះ អាមាត្យទាំងឡាយ បាននាំព្រះបាទព្រហ្មទត្តទៅដល់បន្ទាយរបស់ព្រះរាជាដែលជាសត្រូវ ហើយឲ្យនាំប្រទីបចេញអំពីឆ្នាំងទាំងអស់ ធ្វើឲ្យភ្លឺទូទៅ ហើយធ្វើនូវការស្រែកហ៊ោ ។ អាមាត្យរបស់ព្រះរាជាជាសត្រូវ ឃើញពួកពលដ៏ច្រើន ភ័យខ្លាច ក៏ចូលទៅគាល់ព្រះរាជារបស់ខ្លួន បានធ្វើនូវសំឡេងខ្លាំងថា សូមទ្រង់តើនឡើងសោយទឹកឃ្មុំដែលមិនមានមេ ។ អាមាត្យទី ២ ក្ដី អាមាត្យទី ៣ ក្ដី ក៏បានធ្វើយ៉ាងនោះដូចគ្នា ។ ព្រះរាជាដែលជាបដិបក្ខ ទ្រង់តើនឡើងដោយសំឡេងនោះ ទ្រង់ដល់នូវការភ័យខ្លាច ព្រោះសំឡេងកងរំពងរាប់

រយកំពុងប្រព្រឹត្តទៅ ទ្រង់ព្រះតម្រិះថា អញជឿពាក្យរបស់អ្នកដទៃ ទើបធ្លាក់នៅក្នុងកណ្តាប់ដៃរបស់សត្រូវ ទ្រង់ត្រាស់ពាក្យនោះ ៗ អស់មួយរាត្រី ក្នុងថ្ងៃទី ២ ទ្រង់គិតថា ព្រះបាទព្រហ្មទត្តនោះ ជាព្រះរាជាទ្រទ្រង់នូវធម៌ មិនគប្បីដាក់ទោស អញនឹងទៅសូមខមាទោសព្រះអង្គដូច្នេះហើយ ទើបយាងទៅគាល់ព្រះរាជា ទ្រង់លុតព្រះជានុទាំងពីរហើយពោលថា បពិត្រមហារាជ សូមទ្រង់អភ័យទោសចំពោះកំហុសរបស់ទូលព្រះបង្គំចុះ ។

ព្រះរាជាទ្រង់ទូន្មានព្រះរាជាដែលជាសត្រូវនោះហើយ ត្រាស់ថាសូមទ្រង់ក្រោកឡើង យើងអត់ទោសឲ្យដល់ទ្រង់ ។ ព្រះរាជាដែលជាសត្រូវនោះ លុះព្រះបាទពារាណសីត្រាស់ត្រឹមតែប៉ុណ្ណោះ ទ្រង់ដល់នូវការធូរស្បើយក្នុងព្រះហឫទ័យក្រៃលែង ទ្រង់បានរាជសម្បត្តិក្នុងជនបទជិតព្រំដែនរបស់ព្រះបាទពារាណសី ព្រះរាជាទាំងពីរអង្គនោះ បានជាសម្លាញ់នឹងគ្នា ។

លំដាប់នោះ ព្រះបាទព្រហ្មទត្តទ្រង់ទតសេនាទាំងពីរចំណែកដែលត្រេកអររាក់ទាក់រកគ្នា ទ្រង់ព្រះតម្រិះថា ព្រោះអាត្មាអញតែម្នាក់តាមរក្សាចិត្ត ទើបមិនមានតំណក់ឈាម សូម្បីត្រឹមតែមួយចម្អែតរុយកើតឡើងក្នុងពួកមហាជនទាំងនេះ ឱល្អពិតហ្ន៎ ! ឱប្រសើរពិតហ្ន៎ ! សត្វទាំងឡាយទាំងពួង ចូរមានសេចក្តីសុខ កុំបីមានពៀរ កុំបៀតបៀនគ្នា

ទ្រង់ធ្វើមេត្តាឈានឲ្យកើតឡើង ទ្រង់ធ្វើមេត្តាឈាននោះឯង ឲ្យជាបាទ ពិចារណាសង្ខារទាំងឡាយ ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ សម្រេចភាពជាព្រះសយម្ភូហើយ ។

អាមាត្យទាំងឡាយថ្វាយបង្គំហើយ ក្រាបទូលព្រះបាទព្រហ្មទត្ត ដែលជាអ្នកមានសេចក្ដីសុខដោយសុខក្នុងមគ្គ និងផល ដែលប្រថាប់គង់លើកដំរីថា បពិត្រមហារាជ ដល់កាល ( ដែលត្រូវយាងត្រឡប់ហើយ ) ទ្រង់គប្បីធ្វើសក្ការៈដល់ពួកពលដែលឈ្នះ គប្បីឲ្យស្បៀងគឺកត្ត ដល់ពួកពលដែលចាញ់ ។

ព្រះបច្ចេកពុទ្ធពោលថា នែអ្នកទាំងឡាយ យើងមិនមែនជាព្រះរាជា យើងឈ្មោះថា **ព្រះបច្ចេកពុទ្ធ** ។ អាមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់ត្រាស់អ្វី ព្រះបច្ចេកពុទ្ធទាំងឡាយ មិនមែនមានសភាពយ៉ាងនេះឡើយ ។

ព្រះបច្ចេកពុទ្ធសួរថា នែអ្នកទាំងឡាយ ព្រះបច្ចេកពុទ្ធទាំងឡាយ តើដូចម្ដេច ។ អាមាត្យទាំងនោះទូលថា ធម្មតាព្រះបច្ចេកពុទ្ធទាំងឡាយ ជាអ្នកមានសក់ និងពុកមាត់ ២ ធ្នាប់ មួយអន្ទើដោយបរិក្ខារ ៨ ។ ព្រះបច្ចេកពុទ្ធយកព្រះហស្តស្ទាបព្រះសិរសា រំពេចនោះឯង យាវាស-ភេទក៏អន្តរធានទៅ បព្វជិតភេទក៏ប្រាកដឡើង លោកមានព្រះកេសា និងព្រះមស្សុប្រមាណពីរធ្នាប់ មានបរិក្ខារ ៨ ( ស្បង់ ចីពរ សង្ឃាដី

វត្ថពន្ធបង្កើះ បាត្រ ធម្មក្រក កាំបិតកោរ ម្ជុល ) ដូចគ្នានឹងព្រះថេរៈមានវស្សា ១០០ ។ ព្រះបច្ចេកពុទ្ធចូលចតុត្ថជ្ឈាន ហោះអំពីកដំរីទៅកាន់អាកាស គង់លើផ្កាឈូក ។ ពួកអាមាត្យថ្វាយបង្គំហើយទូលសួរថា បពិត្រលោកម្ចាស់ អ្វីជាកម្មដ្ឋាន លោកសម្រេចបានដូចម្ដេច ។ ព្រោះលោកមានកម្មដ្ឋាន គឺមេត្តាជាអារម្មណ៍ លោកឃើញច្បាស់នូវមេត្តានោះ ទើបបានសម្រេច ហេតុនោះ កាលលោកសម្ដែងសេចក្ដីនោះ ទើបពោលគាថានេះ ដែលជាគាថាឧទាន ជាគាថាព្យាករណ៍ថា

**សព្វេសុ ភូតេសុ និធាយ ទណ្ឌំ**
**អវិហេឋយំ អញ្ញតរម្បិ តេសំ**
**មេត្តេន ចិត្តេន ហិតានុកម្បី**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលទម្លាក់ចោលនូវអាជ្ញា ចំពោះសត្វទាំងពួង មិនបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយទេ ទាំងជាអ្នកអនុគ្រោះចំពោះប្រយោជន៍ ដោយមេត្តាចិត្ត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

បណ្ដាបទទាំងនោះ បទថា **សព្វេសុ ភូតេសុ និធាយ ទណ្ឌំ** សេចក្ដីថា ដាក់ គឺវៀរចាកការសម្ពុតគំរាម ការទម្ងាយ ការសម្លាប់ និងការចង មិនបៀតបៀនសត្វណាមួយ គឺសត្វណាសូម្បីតែមួយ ក្នុងរវាង

សត្វទាំងពួងនោះ គឺមិនធ្វើឲ្យលំបាក មានចិត្តប្រកបដោយមេត្តា គឺមានចិត្តសហគតៈដោយមេត្តាថា សត្វទាំងឡាយទាំងពួង ចូរមានសេចក្ដីសុខទាំងជាអ្នកអនុគ្រោះដោយប្រយោជន៍ ដោយចិត្ត គឺអនុគ្រោះដោយប្រយោជន៍ដែលជាសភាវៈ ។ មួយវិញទៀត ពាក្យថា **សព្វេសុ** ក្នុងបទថា **សព្វេសុ ភូតេសុ និធាយ ទណ្ឌំ** នេះ ជាបទចង្អុលបង្ហាញ គឺការរួមយកទាំងអស់មិនសេសសល់ ។ ក្នុងបទថា **ភូតេសុ** គប្បីជ្រាបដូច្នេះថា សត្វដែលតក់ស្លុតនិងសត្វដែលមិនតក់ស្លុត ហៅថា **ភូត** ។ សត្វទាំងឡាយណា លះនូវតណ្ហាដែលធ្វើឲ្យតក់ស្លុត មិនបាន ទាំងលះនូវភ័យនិងការខ្លាច មិនបាន សត្វទាំងនោះ ឈ្មោះថា តក់ស្លុត ។

សួរថា ព្រោះហេតុអ្វី ទើបហៅថា តក់ស្លុត ។

ឆ្លើយថា សត្វពួកណា រមែងតក់ស្លុត គឺតក់ស្លុតឡើង តក់ស្លុតជុំវិញ រមែងខ្លាច រមែងដល់នូវការតក់ស្លុតព្រម ព្រោះហេតុនោះ ទើបសត្វទាំងនោះ លោកហៅថា ជាអ្នកតក់ស្លុត ។ សត្វពួកណា លះនូវតណ្ហាដែលធ្វើឲ្យតក់ស្លុតបាន ទាំងលះនូវភ័យនិងការខ្លាចបាន សត្វទាំងនោះ ឈ្មោះថា ជាអ្នកមិនតក់ស្លុត ។

សួរថា ព្រោះហេតុអ្វី ទើបហៅថា ជាអ្នកមិនតក់ស្លុត ។

ឆ្លើយថា សត្វពួកណា រមែងមាំទាំ គឺមិនតក់ស្លុត មិនតក់ស្លុតឡើង មិនតក់ស្លុតដោយជុំវិញ មិនខ្លាច មិនដល់នូវការតក់ស្លុតព្រម

ព្រោះហេតុនោះ ទើបសត្វទាំងនោះ លោកហៅថា ជាអ្នកមិនតក់ស្លុត ។

អាជ្ញាមាន ៣ យ៉ាង គឺកាយអាជ្ញា វចីអាជ្ញា និងមនោអាជ្ញា ។ កាយទុច្ចរិត ៣ ឈ្មោះថា កាយអាជ្ញា វចីទុច្ចរិត ៤ ឈ្មោះថា វចីអាជ្ញា មនោទុច្ចរិត ៣ ឈ្មោះថា មនោអាជ្ញា ។ ដាក់ គឺទម្លាក់ចុះ លើកចុះ លើកចុះព្រម ដាក់ទុក គឺវម្ងាប់អាជ្ញា ៣ យ៉ាងនោះ ក្នុងភូត គឺសត្វទាំងពួង គឺទាំងអស់ បានដល់ មិនកាន់យកអាជ្ញាដើម្បីបៀតបៀន ព្រោះហេតុនោះ ទើបឈ្មោះថា ដាក់ចុះនូវអាជ្ញាក្នុងសត្វទាំងពួង ។

បទថា **អវិហេឋយំ អញ្ញតរម្បិ តេសំ** សេចក្ដីថា មិនបៀតបៀនសូម្បីសត្វមួយដោយបាតដៃ ឬដុំដី ដំបង សស្ត្រា ខ្នោះ ខ្សែ មិនបៀតបៀនសត្វគ្រប់ប្រភេទដោយបាតដៃ ឬដុំដី ដំបង សស្ត្រា ខ្នោះ ខ្សែ មិនបៀតបៀនសត្វទាំងនោះ សូម្បីសត្វមួយ ។

បទថា **ឯកោ** សេចក្ដីថា ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជា ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា មិនមានបុគ្គលជាគម្រប់ពីរ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា លះបង់តណ្ហា ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកទោសៈដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកមោហៈដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុមិនមានកិលេសដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុទៅ

កាន់ផ្លូវជាទីទៅតែម្នាក់ឯង ជាបុគ្គលម្នាក់ឯង ព្រោះហេតុត្រាស់ដឹងនូវបច្ចេកសម្ពោធិដ៏ប្រសើរតែម្នាក់ឯង ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជា តើដូចម្តេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ ទ្រង់កាត់បលិពោធក្នុងឃរាវាស កាត់បលិពោធក្នុងបុត្តនិងភរិយា កាត់បលិពោធក្នុងញាតិ កាត់បលិពោធក្នុងមិត្តនិងអាមាត្យ កាត់បលិពោធក្នុងការសន្សំ កោរសក់ពុកមាត់ និងពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ដល់នូវភាពមិនមានកង្វល់ ជាបុគ្គលម្នាក់ឯង ចរទៅ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជា យ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថាមិនមានបុគ្គលជាគម្រប់ពីរ តើដូចម្តេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ កាលបួសហើយយ៉ាងនេះ ជាបុគ្គលម្នាក់ឯង គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃរបោះនិងព្រៃញៀតស្ងាត ជាទីមិនមានសំឡេង មិនមានសំឡេងគឹកកងប្រាសចាកខ្យល់ដែលកើតអំពីសរីរៈមនុស្ស ជាទីស្ងាត់កំបាំងរបស់មនុស្សសមគួរដល់ទីពួនសម្ងំ លោកដើរទៅម្នាក់ឯង ឈរនៅម្នាក់ឯង អង្គុយម្នាក់ឯង សិងម្នាក់ឯង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង អង្គុយក្នុងទីស្ងាត់ម្នាក់ឯង អធិដ្ឋានចង្ក្រមម្នាក់ឯង

ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅម្នាក់ឯង ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា មិនមានបុគ្គលជាគម្រប់ពីរ យ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា លះបង់តណ្ហា តើដូចម្តេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ឥតមានបុគ្គលជាគម្រប់ពីរយ៉ាងនេះហើយ ជាអ្នកមិនប្រហែស មានព្យាយាមដុតកម្តៅកិលេស មានចិត្តស្ទុង (ទៅកាន់ព្រះនិព្វាន) ផ្គង់ព្យាយាមធំ កម្ចាត់បង់មារ ព្រមទាំងសេនានៃមារដែលមិនដោះលែង [១] ជាផៅពង្សនៃបុគ្គលប្រហែស គឺថា លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ញុំាង តណ្ហាដូចជាបណ្តាញដែលហូរទៅ ផ្សាយទៅ ឲ្យដល់នូវការមិនកើតមាន ។

តណ្ហាទុតិយោ បុរិសោ ទីឃមទ្ធាន សំសរំ
ឥត្ថភាវញ្ញថាភាវំ សំសារំ នាតិវត្តតិ
ឯវមាទីនវំ ញត្វា តណ្ហំ ទុក្ខស្ស សម្ភវំ
វីតតណ្ហោ អនាទានោ សតោ ភិក្ខុ បរិព្វជេ ។

បុរសមានតណ្ហាជាគម្រប់ពីរ កាលអន្ទោលទៅអស់កាល

---

១-មារមានឈ្មោះថា នមុចិ ព្រោះមិនប្រាថ្នាឲ្យសត្វទាំងឡាយរួចផុត ទើបមានពាក្យថា មិនដោះលែងនេះ ។

ដ៏វែង រមែងមិនកន្លងផុតសង្សារ មានភាពបែបនេះ និង
ភាពដទៃ ភិក្ខុអ្នកមានសតិ ប្រាសចាកតណ្ហា មិនមាន
សេចក្ដីប្រកាន់ លុះឃើញទោសយ៉ាងនេះហើយ គួរវៀរ
នូវតណ្ហា ជាដែនកើតទុក្ខចេញ[១] ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា លះបង់នូវតណ្ហា យ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះប្រាសចាករាគៈដោយដាច់ខាត តើដូចម្ដេច ។ ជាបុគ្គលម្នាក់ឯង ព្រោះប្រាសចាករាគៈដោយដាច់ខាត ព្រោះលោកលះរាគៈហើយ ។ ជាបុគ្គលម្នាក់ឯង ព្រោះប្រាសចាកទោសៈដោយដាច់ខាត ព្រោះលោកលះទោសៈហើយ ។ ជាបុគ្គលម្នាក់ឯង ព្រោះប្រាសចាកមោហៈដោយដាច់ខាត ព្រោះលោកលះមោហៈហើយ ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុមិនមានកិលេសដោយដាច់ខាត ព្រោះលោកលះកិលេសទាំង-ឡាយហើយ ។ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះប្រាសចាករាគៈដោយដាច់ខាត យ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុទៅកាន់ផ្លូវជាទីទៅម្នាក់ឯង តើដូចម្ដេច ។ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ

---

១-បិ.៦៨ ទំ.១៩៦ ឃ.២៣៥ ។

៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ អរិយមគ្គប្រកបដោយអង្គ ៨ លោកហៅថា ផ្លូវជាទីទៅម្នាក់ឯង ។

ឯកាយនំ ជាតិខយន្តទស្សី
មគ្គំ បជានាតិ ហិតានុកម្បី
ឯតេន មគ្គេន តរីសុ បុព្វេ
តរិស្សន្តិ ចេវ តរន្តិ ឱឃំ ។

បុគ្គលអ្នកឃើញទីបំផុតនៃកិរិយាអស់ជាតិ ជាអ្នកអនុគ្រោះនូវប្រយោជន៍ រមែងដឹងច្បាស់នូវផ្លូវជាទីទៅម្នាក់ឯង ពួកអរិយបុគ្គលបានឆ្លងហើយក្នុងអតីតកាលក្តី នឹងឆ្លងក្នុងអនាគតក្តី កំពុងឆ្លងក្នុងបច្ចុប្បន្ននេះក្តី នូវឱឃៈ តាមផ្លូវនេះឯង[១] ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុទៅកាន់ផ្លូវជាទីទៅម្នាក់ឯង យ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុត្រាស់ដឹងនូវបច្ចេកសម្ពោធិដ៏ប្រសើរតែម្នាក់ឯង តើដូចម្តេច ។ ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ ធម្មវិចយសម្ពោជ្ឈង្គៈ វីមំសា វិបស្សនា សម្មាទិដ្ឋិ ក្នុងមគ្គទាំង ៤ លោកហៅថា ពោធិ ។ ព្រះបច្ចេកសម្ពុទ្ធនោះ ត្រាស់ដឹង

---

១-បិ.៦៨ ទំ.១៩៧ ឃ.២៣៥ ។

ហើយនូវសច្ចៈទាំងឡាយដោយបច្ចេកពុទ្ធញ្ញាណនោះ ត្រាស់ដឹងហើយថា សង្ខារទាំងពួង មិនទៀង ត្រាស់ដឹងហើយថា សង្ខារទាំងពួង ជាទុក្ខ ត្រាស់ដឹងហើយថា ធម៌ទាំងពួង ជាអនត្តា ។ ត្រាស់ដឹងហើយថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ ត្រាស់ដឹងហើយថា វិញ្ញាណ ( កើតមាន ) ព្រោះសង្ខារជាបច្ច័យ ត្រាស់ដឹងហើយថា នាមនិងរូប ( កើតមាន ) ព្រោះវិញ្ញាណជាបច្ច័យ ត្រាស់ដឹងហើយថា អាយតនៈ ៦ ( កើតមាន ) ព្រោះនាមរូបជាបច្ច័យ ត្រាស់ដឹងហើយថា ផស្សៈ ( កើតមាន ) ព្រោះអាយតនៈ ៦ ជាបច្ច័យ ត្រាស់ដឹងហើយថា វេទនា ( កើតមាន ) ព្រោះផស្សៈជាបច្ច័យ ត្រាស់ដឹងហើយថា តណ្ហា ( កើតមាន ) ព្រោះវេទនាជាបច្ច័យ ត្រាស់ដឹងហើយថា ឧបាទាន ( កើតមាន ) ព្រោះតណ្ហាជាបច្ច័យ ត្រាស់ដឹងហើយថា ភព ( កើតមាន ) ព្រោះឧបាទានជាបច្ច័យ ត្រាស់ដឹងហើយថា ជាតិ ( កើតមាន ) ព្រោះភពជាបច្ច័យ ត្រាស់ដឹងហើយថា ជរានិងមរណៈ ( កើតមាន ) ព្រោះជាតិជាបច្ច័យ ។ ត្រាស់ដឹងហើយថា ការរលត់សង្ខារ ព្រោះការរលត់ទៅនៃអវិជ្ជា ត្រាស់ដឹងហើយថា ការរលត់វិញ្ញាណ ព្រោះការរលត់សង្ខារ ត្រាស់ដឹងហើយថា ការរលត់នាមរូប ព្រោះការរលត់វិញ្ញាណ ត្រាស់ដឹងហើយថា ការរលត់អាយតនៈ ៦ ព្រោះការរលត់នាមនិងរូប ត្រាស់ដឹងហើយថា ការរលត់ផស្សៈ ព្រោះការរលត់អាយតនៈ ៦ ត្រាស់

ដឹងហើយថា ការរលត់វេទនា ព្រោះការរលត់ផស្សៈ ត្រាស់ដឹងហើយថា ការរលត់តណ្ហា ព្រោះការរលត់វេទនា ត្រាស់ដឹងហើយថា ការរលត់ឧបាទាន ព្រោះការរលត់តណ្ហា ត្រាស់ដឹងហើយថា ការរលត់ភព ព្រោះការរលត់ឧបាទាន ត្រាស់ដឹងហើយថា ការរលត់ជាតិ ព្រោះការរលត់ភព ត្រាស់ដឹងហើយថា ការរលត់ជរាមរណៈ ព្រោះការរលត់ជាតិ ។ ត្រាស់ដឹងហើយថា នេះទុក្ខ ត្រាស់ដឹងហើយថា នេះការកើតទុក្ខ ត្រាស់ដឹងហើយថា នេះការរលត់ទុក្ខ ត្រាស់ដឹងហើយថា នេះបដិបទាជាដំណើរទៅកាន់ការរលត់ទុក្ខ ។ ត្រាស់ដឹងហើយថា ទាំងនេះអាសវៈ ត្រាស់ដឹងហើយថា នេះការកើតអាសវៈ ត្រាស់ដឹងហើយថា នេះការរលត់អាសវៈ ត្រាស់ដឹងហើយថា នេះបដិបទាជាដំណើរទៅកាន់ការរលត់អាសវៈ ។ ត្រាស់ដឹងហើយថា នេះពួកធម៌គួរត្រាស់ដឹង ត្រាស់ដឹងហើយថា នេះពួកធម៌គួរលះបង់ ត្រាស់ដឹងហើយថា នេះពួកធម៌គួរធ្វើឲ្យជាក់ច្បាស់ ត្រាស់ដឹងហើយថា នេះពួកធម៌គួរចម្រើន ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ គឺហេតុឲ្យកើតផង ឲ្យរលត់ផង សេចក្តីរីករាយផង ទោសផង រលាស់ចេញផង នៃផស្សាយតនៈ ៦ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ គឺហេតុឲ្យកើតផង ឲ្យរលត់ផង សេចក្តីរីករាយផង ទោសផង រលាស់ចេញផង នៃឧបាទានក្ខន្ធ ៥ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ គឺហេតុឲ្យកើតផង ឲ្យរលត់ផង សេចក្តីរីករាយ

ផង ទោសផង រលាស់ចេញផង នៃមហាភូតរូប ៤ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅជាធម្មតា ។

គឺថា ត្រាស់ដឹង ត្រាស់ដឹងតាម ត្រាស់ដឹងឯង ប៉ះពាល់ ធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលត្រូវត្រាស់ដឹង ដែលត្រូវត្រាស់ដឹងតាម ដែលត្រូវត្រាស់ដឹងឯង ដែលត្រូវប៉ះពាល់ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ទាំងអស់ ដោយបច្ចេកពោធិញ្ញាណនោះ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុត្រាស់ដឹងនូវបច្ចេកសម្ពោធិដ៏ប្រសើរម្នាក់ឯង យ៉ាងនេះ ។

បទថា **ចរេ** បានដល់ ចរិយា ៨ គឺឥរិយាបថចរិយា ១ អាយតនចរិយា ១ សតិចរិយា ១ សមាធិចរិយា ១ ញាណចរិយា ១ មគ្គចរិយា ១ បត្តិចរិយា ១ លោកត្ថចរិយា ១ ។

ចរិយាក្នុងឥរិយាបថទាំង ៤ ឈ្មោះថា ឥរិយាបថចរិយា ។ ចរិយាក្នុងអាយតនៈខាងក្នុង ៦ និងអាយតនៈខាងក្រៅ ៦ ឈ្មោះថា អាយតនចរិយា ។ ចរិយាក្នុងសតិប្បដ្ឋាន ៤ ឈ្មោះថា សតិចរិយា ។ ចរិយាក្នុងឈាន ៤ ឈ្មោះថា សមាធិចរិយា ។ ចរិយាក្នុងអរិយសច្ច ៤ ឈ្មោះថា ញាណចរិយា ។ ចរិយាក្នុងអរិយមគ្គ ៤ ឈ្មោះថា មគ្គចរិយា ។ ចរិយាក្នុងសាមញ្ញផល ៤ ឈ្មោះថា បត្តិចរិយា ។ ការ

ប្រព្រឹត្តប្រយោជន៍ដើម្បីសត្វលោកទាំងអស់ របស់ព្រះតថាគតអរហន្ត សម្មាសម្ពុទ្ធ របស់ព្រះបច្ចេកសម្ពុទ្ធដោយចំណែកខ្លះ របស់សាវ័កទាំងឡាយដោយចំណែកខ្លះ ឈ្មោះថា លោកត្ថចរិយា ។

ម្យ៉ាងទៀត ចរិយារបស់បុគ្គលដែលដល់ព្រមដោយការតម្កល់ខ្លួនទុកប្រពៃ ឈ្មោះថា ឥរិយាបថចរិយា ។ ចរិយារបស់បុគ្គលដែលគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ឈ្មោះថា អាយតនចរិយា ។ ចរិយារបស់បុគ្គលដែលមានប្រក្រតីនៅដោយការមិនប្រមាទ ឈ្មោះថា សតិចរិយា ។ ចរិយារបស់បុគ្គលដែលប្រកបរឿយ ៗ ក្នុងអធិចិត្ត ឈ្មោះថា សមាធិចរិយា ។ ចរិយារបស់បុគ្គលដែលសម្បូរដោយបញ្ញាជាគ្រឿងត្រាស់ដឹង ឈ្មោះថា ញាណចរិយា ។ ចរិយារបស់បុគ្គលដែលបដិបត្តិដោយប្រពៃ ឈ្មោះថា មគ្គចរិយា ។ ចរិយារបស់បុគ្គលដែលសម្រេចផលហើយ ឈ្មោះថា បត្តិចរិយា និងចរិយារបស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ របស់ព្រះបច្ចេកសម្ពុទ្ធចំណែកខ្លះ របស់សាវ័កទាំងឡាយចំណែកខ្លះ ឈ្មោះថា លោកត្ថចរិយា នេះជាចរិយា ៨ ប្រការ ។

ចរិយា ៨ ដទៃទៀត គឺបុគ្គលកាលបង្អោនចិត្តជឿ រមែងប្រព្រឹត្តដោយសទ្ធា ១ កាលផ្គង រមែងប្រព្រឹត្តដោយព្យាយាម ១ កាលចូលទៅតាំងមាំ រមែងប្រព្រឹត្តដោយសតិ ១ កាលធ្វើនូវការមិនរាយមាយរមែងប្រព្រឹត្តដោយសមាធិ ១ កាលឃើញច្បាស់ រមែងប្រព្រឹត្តដោយ

បញ្ញា ១ កាលដឹងច្បាស់ រមែងប្រព្រឹត្តដោយវិញ្ញាណចរិយា ១ កាលមនសិការថា កុសលធម៌ទាំងឡាយ រមែងប្រព្រឹត្តទូទៅដល់អ្នកបដិបត្តិយ៉ាងនេះ រមែងប្រព្រឹត្តដោយអាយតនចរិយា ១ កាលមនសិការថា អ្នកបដិបត្តិយ៉ាងនេះ រមែងសម្រេចគុណវិសេស រមែងប្រព្រឹត្តដោយវិសេសចរិយា ១ នេះជាចរិយា ៨ ប្រការ ។

ចរិយា ៨ ដទៃទៀត គឺចរិយាក្នុងសម្មាទិដ្ឋិ ឈ្មោះថា ទស្សនចរិយា គឺចរិយាក្នុងការឃើញ ១ ចរិយាក្នុងសម្មាសង្កប្បៈ ឈ្មោះថា អភិនិរោបនចរិយា គឺចរិយាក្នុងការលើកចិត្ត ១ ចរិយាក្នុងសម្មាវាចា ឈ្មោះថា បរិគ្គហចរិយា គឺចរិយាក្នុងការកំណត់ ១ ចរិយាក្នុងសម្មាកម្មន្តៈ ឈ្មោះថា សមុដ្ឋានចរិយា គឺចរិយាក្នុងការប្រឹងប្រែង ១ ចរិយាក្នុងសម្មាអាជីវៈ ឈ្មោះថា វោទានចរិយា គឺចរិយាក្នុងសេចក្ដីផូរផង់ ១ ចរិយាក្នុងសម្មាវាយាមៈ ឈ្មោះថា បគ្គហចរិយា គឺចរិយាក្នុងការផ្គង ១ ចរិយាក្នុងសម្មាសតិ ឈ្មោះថា ឧបដ្ឋានចរិយា គឺចរិយាក្នុងការប្រាកដ ១ ចរិយាក្នុងសម្មាសមាធិ ឈ្មោះថា អវិក្ខេបចរិយា គឺចរិយាក្នុងការមិនរាយមាយ ១ នេះជាចរិយា ៨ ប្រការ ។

បទថា **ខគ្គវិសាណកប្បោ** សេចក្ដីថា ធម្មតារមាសមានកុយតែមួយប៉ុណ្ណោះ មិនមានកុយជាគម្រប់ ២ យ៉ាងណា ព្រះបច្ចេកសម្ពុទ្ធនោះ ក៏យ៉ាងនោះ ដូចគ្នា ដូចកុយរមាសនោះ មានចំណែកប្រៀបដោយ

កុយរមាសនោះ ។ វត្ថុមានរសប្រៃក្រៃលែង អ្នកផងតែងនិយាយថា ដូចអំបិល វត្ថុមានរសល្វីងក្រៃលែង អ្នកផងតែងនិយាយថា ដូចម្រះ វត្ថុមានរសផ្អែមក្រៃលែង អ្នកផងតែងនិយាយថា ដូចទឹកឃ្មុំ កម្តៅដ៏ក្រៃលែង អ្នកផងតែងនិយាយថា ដូចភ្លើង វត្ថុត្រជាក់ក្រៃលែង អ្នកផងតែងនិយាយថា ដូចព្រឹល (ឬទឹកកក) ធារនៃទឹកច្រើន អ្នកផងតែងនិយាយថា ដូចសមុទ្ទ សាវ័កដែលដល់នូវកម្លាំងអភិញ្ញាដ៏ច្រើន អ្នកផងតែងនិយាយថា ដូចព្រះសាស្តា យ៉ាងណាមិញ ព្រះបច្ចេកសម្ពុទ្ធនោះ ក៏ដូចកុយរមាសប្រាកដស្មើដោយកុយរមាស មានការប្រៀបដោយកុយរមាស ជាបុគ្គលឯក មិនមានបុគ្គលជាគម្រប់ពីរ របូតចាកចំណងហើយ តែងចរ ត្រាច់ទៅប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅក្នុងលោកដោយប្រពៃ ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ ទើបឈ្មោះថា គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

កាលព្រះបច្ចេកពុទ្ធត្រាស់យ៉ាងនេះហើយ អាមាត្យទាំងឡាយសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន ឥឡូវនេះ លោកម្ចាស់និមន្តទៅណា ។

លំដាប់នោះ ព្រះបច្ចេកពុទ្ធពិចារណាថា ព្រះបច្ចេកពុទ្ធទាំងឡាយក្នុងកាលមុន នៅក្នុងទីណាហ្ន៎ កាលជ្រាបហើយ ទើបពោលថា អាត្មានឹងទៅកាន់ភ្នំគន្ធមាទន៍ ។ អាមាត្យទាំងឡាយក្រាបទូលទៀតថា បពិត្រលោកម្ចាស់ដ៏ចម្រើន ឥឡូវនេះ លោកលះបង់ពួកខ្ញុំទៅ មិនប្រាថ្នាពួកខ្ញុំ

ហើយឬ ។ លំដាប់នោះ ព្រះបច្ចេកសម្ពុទ្ធពោលពាក្យទាំងពួងថា

**សព្វេសុ ភូតេសុ និធាយ ទណ្ឌំ**
**អវិហេឋយំ អញ្ញតរម្បិ តេសំ**
**ន បុត្តមិច្ឆេយ្យ កុតោ សហាយំ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលទម្លាក់ចោលនូវអាជ្ញា ចំពោះពួកសត្វទាំងពួង មិនបៀតបៀនចំពោះសត្វទាំងនោះ សូម្បីសត្វណាមួយទេ មិនបានប្រាថ្នានូវបុត្ត ( ទៅហើយ ) តើនឹងប្រាថ្នានូវសម្លាញ់អំពីណា គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

សព្ទថា ន ក្នុងពាក្យថា **ន បុត្តមិច្ឆេយ្យ កុតោ សហាយំ** ជាពាក្យបដិសេធ ។ បទថា **បុត្តំ** បានដល់កូន ៤ ប្រភេទ គឺ **អត្រជោ** កូនកើតអំពីខ្លួន ១ **ខេត្តជោ** កូនកើតក្នុងខេត្ត មានកើតលើគ្រែ លើបល្ល័ង្ក លើភ្លៅជាដើម ១ **ទិន្នកោ** កូនដែលគេឲ្យ ១ **អន្តេវាសិកោ** កូនសិស្ស ១ ព្រះបច្ចេកពុទ្ធមិនប្រាថ្នាបុត្តទាំងឡាយនេះ តើការប្រាថ្នាសម្លាញ់ មានមកអំពីណា ។

ក្នុងបទថា **សហាយំ** គប្បីជ្រាបថា ការមក ការទៅ ការឈរ ការអង្គុយ ការហៅរក ការចរចា ការសន្ទនា ជាមួយបុគ្គលណា យ៉ាង

*សប្បាយ បុគ្គលនោះ លោកហៅថា សម្លាញ់ ។ បទថា* **ន បុត្ត-មិច្ឆេយ្យ កុតោ សហាយំ** *សេចក្តីថា សូម្បីបុត្ត ក៏មិនចង់បាន មិនត្រេកអរ មិនប្រាថ្នា មិនត្រូវការ មិនចង់មាន ធ្វើម្តេចចង់បាន ត្រេកអរ ប្រាថ្នា ត្រូវការ ចង់មានបុគ្គលដែលស្និទ្ធស្នាល បុគ្គលដែលទើបតែស្និទ្ធស្នាល ឬសម្លាញ់នោះ ព្រោះហេតុនោះ ឈ្មោះថា មិនប្រាថ្នាសូម្បីតែបុត្ត តើនឹងត្រូវការសម្លាញ់មកអំពីណា ។*

*ក្នុងពាក្យនោះ មានអធិប្បាយថា ឥឡូវនេះ អាត្មាមិនប្រាថ្នាសូម្បីតែបុត្តប្រភេទណានីមួយ មានបុត្តកើតអំពីខ្លួនជាដើម នឹងប្រាថ្នាសម្លាញ់អម្បាលពួកអ្នកដូចម្តេចកើត ព្រោះហេតុនោះ បណ្តាពួកអ្នក អ្នកណាចង់ទៅជាមួយអាត្មា ឬចង់ដូចអាត្មា អ្នកនោះ គប្បីជាបុគ្គលម្នាក់ឯងត្រាច់ទៅដូចកុយរមាសដូច្នោះ ។ម្យ៉ាងទៀត កាលអាមាត្យទាំងនោះក្រាបទូលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ឥឡូវនេះ លោកលះបង់ពួកខ្ញុំ មិនត្រូវការពួកខ្ញុំទេឬ ។*

*ព្រះបច្ចេកពុទ្ធពោលថា បុគ្គលមិនប្រាថ្នាកូន នឹងប្រាថ្នាសម្លាញ់អំពីណាកើត បានឃើញគុណនៃការត្រាច់ទៅម្នាក់ឯង ដោយអត្ថតាមដែលពោលហើយ ទើបត្រេកអរ កើតនូវបីតិសោមនស្ស បន្លឺឧទាននេះថា គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។ លុះពោលដូច្នេះហើយ កាលមហាជនកំពុងឃើញនោះឯង ក៏ហោះទៅកាន់ភ្នំគន្ធមាទន៍*

តាមផ្លូវអាកាស ។

ឈ្មោះថា ភ្នំគន្ធមាទន៍នេះ នៅត្រង់ហិមវន្តប្បទេស រំលងភ្នំ ៧ ទៅ គឺចូឡកាឡបព៌ត ១ មហាកាឡបព៌ត ១ នាគបលិវេឋនបព៌ត ១ ចន្ទគព្ភបព៌ត ១ សុរិយគព្ភបព៌ត ១ សុវណ្ណបស្សបព៌ត ១ ហិមវន្តបព៌ត ១ ។ ត្រង់ភ្នំគន្ធមាទន៍នោះ មានញកឈ្មោះនន្ទមូលកៈ ជាលំនៅរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ មានគុហា ៣ គឺសុវណ្ណគុហា ១ មណិគុហា ១ រជតគុហា ១ ។ បណ្ដាគុហាទាំង ៣ នោះ ត្រង់ទ្វារមណិគុហា មានដើមឈើ ឈ្មោះថា មញ្ជូសកៈ ( ដើមឪឡោក ) កម្ពស់ ១ យោជន៍ ទំហំ ១ យោជន៍ ។ ផ្កាទាំងឡាយ ( ដែលមាននៅ ) ក្នុងទឹក ឬលើគោក មានប្រមាណត្រឹមណា ដើមមញ្ជូសកៈនោះ ក៏បញ្ចេញផ្កាទាំងឡាយទាំងពួងនោះ មានប្រមាណត្រឹមនោះ ដោយវិសេស ក្នុងថ្ងៃដែលព្រះបច្ចេកពុទ្ធនិមន្តមកដល់ ។ បន្ទាប់អំពីដើមឈើនោះទៅ មានផ្ទះរតនៈគ្រប់ប្រភេទ ក្នុងផ្ទះរតនៈនោះ ខ្យល់ដែលធ្វើការបោស ក៏បោសសំរាមយកទៅចោល ខ្យល់ដែលធ្វើផ្ទៃដីឲ្យរាប ក៏កៀរខ្សាច់ដែលសម្រេចហើយដោយរតនៈឲ្យរាបស្មើ ខ្យល់ដែលស្រោចទឹក ក៏នាំទឹកមកអំពីអនោតត្តស្រះមកស្រោច ខ្យល់ដែលធ្វើក្លិនក្រអូប ក៏នាំក្លិនក្រអូបមកអំពីព្រៃហិមពាន្ត ខ្យល់ដែលរោយ ក៏រោយផ្កាទាំងឡាយឲ្យធ្លាក់ចុះមក ខ្យល់ដែលក្រាល ក៏ក្រាលកម្រាលក្នុងទីទាំងពួង ក្នុងរោងនោះ ក្រាលអាសនៈ

រៀបរយទុកជាប្រចាំ សម្រាប់ជាទីដែលព្រះបច្ចេកពុទ្ធទាំងពួងអង្គុយប្រជុំ ក្នុងថ្ងៃដែលព្រះបច្ចេកពុទ្ធកើតឡើង និងក្នុងថ្ងៃឧបោសថ នេះជាប្រក្រតី ក្នុងទីនោះ ។ ព្រះបច្ចេកពុទ្ធអង្គនេះ ទៅក្នុងទីនោះហើយ អង្គុយលើ អាសនៈដែលក្រាលទុក ។ លំដាប់នោះ បើក្នុងពេលនោះ មានព្រះ បច្ចេកពុទ្ធអង្គដទៃ ៗ ព្រះបច្ចេកពុទ្ធទាំងអស់នោះ ក៏មកប្រជុំគ្នា អង្គុយ លើអាសនៈដែលក្រាលទុកមួយរំពេច កាលអង្គុយហើយ នាំគ្នាចូល សមាបត្តិខ្លះ ហើយចេញអំពីសមាបត្តិ បន្ទាប់អំពីនោះ ដើម្បីឲ្យព្រះ បច្ចេកពុទ្ធទាំងពួង អនុមោទនា ព្រះសង្ឃត្ថេរក៏សួរកម្មដ្ឋាននឹងព្រះ បច្ចេកពុទ្ធដែលទើបមកថ្មីយ៉ាងនេះថា លោកម្ចាស់សម្រេចដូចម្ដេច ។ ក្នុងកាលនោះ ព្រះបច្ចេកពុទ្ធដែលទើបមកថ្មី ក៏ពោលឧទានគាថា និង ព្យាករណ៍គាថារបស់ខ្លួននោះឯង ។ ព្រះមានព្រះភាគត្រូវព្រះអានន្ទសួរ ក៏ត្រាស់គាថានោះដដែលទៀត ព្រះអានន្ទក៏ពោលគាថានោះ ក្នុងកាល សង្គាយនា រួមសេចក្ដីមក គាថានីមួយ ៗ មានការពោល ៤ ដង គឺ ក្នុងទីត្រាស់ដឹងបច្ចេកសម្ពោធិញ្ញាណ ១ ក្នុងរោងក្បែរដើមមញ្ជូសកៈ ១ ក្នុងពេលដែលព្រះអានន្ទក្រាបបង្គំទូលសួរ ១ ក្នុងពេលសង្គាយនា ១ ដោយប្រការដូច្នេះ ។

## បឋមគាថា ចប់

# សំសគ្គគាថា

*គាថាថា* **សំសគ្គជាតស្ស** *ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។*

*ព្រះបច្ចេកពោធិសត្វអង្គនេះ ក៏បានធ្វើសមណធម៌ក្នុងសាសនានៃព្រះមានព្រះភាគកស្សបៈអស់ ២ ម៉ឺនឆ្នាំ ដោយន័យក្នុងរឿងមុននោះឯង ធ្វើកសិណបរិកម្ម ញុំាងបឋមជ្ឈានឲ្យកើតហើយ កំណត់នាមនិងរូប ពិចារណាត្រៃលក្ខណ៍ តែមិនទាន់សម្រេចអរិយមគ្គ ក៏ទៅកើតក្នុងព្រហ្មលោក ។ ព្រះបច្ចេកពោធិសត្វនោះ ចុតិអំពីព្រហ្មលោកនោះហើយ កើតក្នុងផ្ទៃរបស់អគ្គមហេសីនៃព្រះបាទពារាណសី ចម្រើនវ័យឡើងដោយន័យមុននោះឯង ។ ចាប់តាំងអំពីការដឹងផ្សេងគ្នាថា នេះជាស្រី នេះជាប្រុសហើយ មិនគាប់ចិត្តនៅក្នុងដៃរបស់ពួកស្ត្រី មិនត្រេកអរសូម្បីត្រឹមតែការអប់ ការងូតនិងការប្រដាប់ជាដើម បុរសប៉ុណ្ណោះ ចិញ្ចឹមព្រះបច្ចេកពោធិសត្វនោះ ក្នុងកាលឲ្យបៅដោះ ស្រីស្នំទាំងឡាយ ក្លែងភេទជាបុរស បំបៅព្រះបច្ចេកពោធិសត្វនោះ ។ ព្រះបច្ចេកពោធិសត្វនោះ បានធុំក្លិន ឬបានឮសំឡេងរបស់មនុស្សស្រី ក៏យំ ទោះបីដឹងក្តីហើយ ក៏មិនប្រាថ្នានឹងឃើញស្រី ព្រោះហេតុនោះ ទើបមនុស្សទាំងឡាយថ្វាយព្រះនាមព្រះបច្ចេកពោធិសត្វនោះថា អនិត្ថិគន្ធៈ ( អ្នកមិនប្រាថ្នាក្លិនស្រី ) ។*

*កាលអនិត្ថិគន្ធកុមារនោះ មានព្រះជន្ម ១៦ វស្សា ព្រះរាជាទ្រង់ព្រះតម្រិះថា យើងនឹងឲ្យតាំងវង្សត្រកូល ទើបទ្រង់បញ្ជាអាមាត្យម្នាក់ ឲ្យនាំស្រីក្រមុំទាំងឡាយដែលសមគួរដល់ព្រះរាជកុមារនោះ មកអំពីត្រកូលផ្សេងៗ ហើយត្រាស់ថា* **កុមារំ រមាបេហិ** *ចូរធ្វើឲ្យព្រះរាជកុមារត្រេកអរ ។ អាមាត្យនោះ មានបំណងឲ្យព្រះរាជកុមារនោះ ត្រេកអរដោយឧបាយ ទើបឲ្យបាំងរាំងននទុក ក្នុងទីមិនឆ្ងាយអំពីព្រះរាជកុមារនោះ ហើយឲ្យពួកស្រីរបាំ ច្រៀង រាំក្នុងរាំងនន ។ ព្រះរាជកុមារនោះ បានស្តាប់ឮសំឡេងច្រៀង និងសំឡេងប្រគំតូរ្យតន្ត្រីហើយ ត្រាស់សួរថា នេះសំឡេងរបស់អ្នកណា ។*

*អាមាត្យក្រាបទូលថា បពិត្រព្រះទេវៈ នេះជាសំឡេងពួកស្រីរបាំរបស់ព្រះអង្គ អ្នកមានបុណ្យទាំងឡាយ ទើបមានស្រីរបាំបែបនេះ បពិត្រព្រះទេវៈ ទ្រង់មានបុណ្យច្រើន សូមទ្រង់ត្រេកអរក្រៃលែងចុះ ។*

*ព្រះរាជកុមារបានឲ្យវាយអាមាត្យនោះ ដោយដំបង ហើយឲ្យអូសចេញទៅ ។ អាមាត្យនោះ ក៏ក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាយាងទៅមួយអន្លើដោយព្រះជននីរបស់ព្រះរាជកុមារ ឲ្យព្រះរាជកុមារសូមខមាទោសហើយ ត្រាស់បង្គាប់អាមាត្យនោះ ឲ្យញុំាងព្រះរាជកុមារឲ្យត្រេកអរទៀត ។ ព្រះរាជកុមារត្រូវព្រះបិតាជាដើមនោះ រំអុកពេក ទើបឲ្យមាសដែលមានសាច់ល្អ ហើយត្រាស់នឹងពួកជាងមាសថា* **សុវណ្ណរំ**

**ឥត្ថិរូបំ ការេថ** ពួកអ្នក ចូរធ្វើរូបស្រីឲ្យស្អាត ។ ជាងមាសទាំងនោះ ធ្វើរូបស្រីប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង ដូចវិស្សុកម្មទេវបុត្តនិម្មិត ហើយឲ្យព្រះរាជកុមារទត ។ ព្រះរាជកុមារទ្រង់ឃើញហើយ ទ្រង់ងក់សីសៈ ដោយការចម្លែកព្រះហឫទ័យ ទ្រង់បញ្ជូនមនុស្សឲ្យទៅក្រាបទូលព្រះជនកនិងព្រះជននីថា បើបានស្រីបែបនេះ ខ្ញុំនឹងទទួល ។

ព្រះជនកនិងព្រះជននីត្រាស់ថា បុត្តរបស់យើងមានបុណ្យច្រើន គង់នឹងរកបានទារិកាណានីមួយ ដែលបានធ្វើបុណ្យរួមជាមួយបុត្តរបស់យើងនោះ ដែលមកកើតក្នុងលោកនេះ ( យ៉ាងពិតប្រាកដ ) ទើបឲ្យលើករូបមាសនោះ ដាក់លើរថ ប្រាប់ដល់អាមាត្យថា **គច្ឆថ ឦទិសឹ ទារិកំ គវេសថ** អ្នកទាំងឡាយចូរទៅ ចូរស្វែងរកទារិកាដែលមានរូបដូចរូបមាសនេះ ។ អាមាត្យទាំងនោះ នាំរូបមាសនោះ ត្រាច់ទៅក្នុងជនបទធំទាំង ១៦ ទៅដល់ស្រុកនោះ ៗ ឃើញពួកជនក្នុងទីណាមួយមានកំពង់ទឹកជាដើម ក៏យករូបមាសដែលមានសភាពដូចទេពធីតា តម្កល់ទុកក្នុងទីនោះ ៗ ធ្វើនូវការបូជាដោយផ្កា សំពត់ គ្រឿងអលង្ការផ្សេង ៗ ចងពិតាន ហើយឈរក្នុងចំណែកម្ខាង ដោយទន្ទឹងថា បុគ្គលណាមួយធ្លាប់ឃើញទារិកាមានរូបបែបនេះ បុគ្គលនោះ នឹងពោលឡើង ។ អាមាត្យទាំងឡាយត្រាច់ទៅហើយ គ្រប់ជនបទដោយឧបាយនោះ វៀរលែងតែមទ្ទរដ្ឋ មើលងាយដែនមទ្ទរដ្ឋនោះថា ជាដែនតូច ទើបមិនទៅ

ក្នុងដែននោះ នាំគ្នាត្រឡប់ ។

លំដាប់នោះ អាមាត្យទាំងនោះ ក៏បានគិតដូច្នេះថា ពួកយើងនឹងទៅកាន់ដែនមទ្ទរដ្ឋសិន កាលពួកយើងទៅដល់នគរពារាណសីហើយ ព្រះរាជាកុំបញ្ជូនពួកយើងទៅទៀត គិតដូច្នេះហើយ អាមាត្យទាំងនោះ ក៏សម្រេចចិត្តនាំគ្នាទៅកាន់សាគលនគរ ក្នុងដែនមទ្ទរដ្ឋ ។ ក្នុងសាគលនគរនោះ មានព្រះរាជាព្រះនាមថា មទ្ទៈ ធីតារបស់ព្រះអង្គ មានព្រះជន្មាយុ ១៦ វស្សា មានព្រះរូបឆោមល្អ ។ ពួកវណ្ណទាសីរបស់ព្រះរាជធីតានោះ នាំគ្នាទៅកាន់កំពង់ទឹកដើម្បីដងទឹក ឃើញរូបមាសដែលពួកអាមាត្យតម្កល់ទុកត្រង់កំពង់ទឹកនោះ អំពីចម្ងាយ នាំគ្នាពោលថា ព្រះរាជបុត្រីបញ្ជូនពួកយើងមកដងទឹក ហេតុអ្វីក៏យាងមកឯង ទើបទៅជិតហើយពោលថា នេះមិនមែនជាព្រះនាង ព្រះនាងរបស់ពួកយើងមានរូបស្អាតជាងនេះ ។ អាមាត្យទាំងឡាយបានស្ដាប់ដូច្នោះ ទើបចូលទៅគាល់ព្រះរាជា ហើយទូលសូមទារិកាដោយន័យដែលសមគួរ ។ ព្រះរាជាក៏ទ្រង់ព្រះរាជទាន ។ អាមាត្យទាំងនោះ ក៏បញ្ជូនដំណឹងទៅក្រាបទូលព្រះបាទពារាណសីថា បពិត្រព្រះទេវៈ ទូលព្រះបង្គំទាំងឡាយ បាននាងកុមារិកាហើយ ទ្រង់យាងមកឯង ឬឲ្យទូលព្រះបង្គំទាំងឡាយនាំទៅ ។

ព្រះរាជាទ្រង់បញ្ជូនរាជសាសន៍ទៅថា កាលយើងទៅ នឹងមានការបៀតបៀននូវជនបទ ពួកលោកនោះឯង ចូរនាំមក ។

អាមាត្យទាំងឡាយនាំទារិកានោះ ចេញអំពីនគរ ហើយបញ្ជូនដំណឹងថ្វាយព្រះរាជកុមារថា បានកុមារិកាដូចរូបមាសហើយ ។ ព្រះរាជកុមារគ្រាន់តែបានស្តាប់ឮប៉ុណ្ណោះ ត្រូវរាគៈគ្របសង្កត់ សាបសូន្យចាកបឋមជ្ឈាន ។ ព្រះរាជកុមារនោះ ក៏បញ្ជូនដំណឹងទៅរឿយៗ ថា ពួកអ្នកចូរប្រញាប់នាំមក ពួកអ្នកចូរប្រញាប់នាំមក ។ អាមាត្យទាំងនោះក៏មកដល់ក្រុងពារាណសី ដោយសម្រាកក្នុងទីគ្រប់កន្លែង ត្រឹមមួយយប់ ហើយបញ្ឈប់រថខាងក្រៅនគរ បញ្ជូនដំណឹងទៅថ្វាយព្រះរាជាថា តើពួកទូលព្រះបង្គំគួរចូលទៅក្នុងថ្ងៃនេះឬ ។

ព្រះរាជាត្រាស់ថា កុមារិកានាំមកអំពីត្រកូលដ៏ប្រសើរ ពួកយើងធ្វើមង្គលកិរិយាហើយ នាំចូលទៅដោយសក្ការៈធំ អ្នកទាំងឡាយចូរនាំនាងទៅកាន់ព្រះរាជឧទ្យានសិន ។ អាមាត្យទាំងនោះ បានធ្វើតាមព្រះរាជបញ្ជា ។ កុមារិកានោះ ជាស្រីសុខុមាលជាតិ អស់កម្លាំងព្រោះយានរលាក់ កើតរោគខ្យល់ ព្រោះលំបាកក្នុងផ្លូវឆ្ងាយ ដូចផ្កាស្រពោន ទើបស្លាប់ក្នុងកណ្តាលរាត្រី ។ អាមាត្យទាំងឡាយបរិទេវនាការថា ពួកយើងជាអ្នកវិនាសចាកសក្ការៈហើយ ។ ព្រះរាជានិងអ្នកនគរកន្ទក់កន្ទេញថា វង្សត្រកូលវិនាសហើយ ។ ព្រះនគរទាំងមូល ក៏កើតកោលាហល ។ សេចក្តីសោកដ៏ខ្លាំងក្លា បានកើតឡើងហើយដល់ព្រះរាជកុមារ ព្រោះបានស្តាប់ដំណឹងនេះប៉ុណ្ណោះ ។

លំដាប់នោះ ព្រះរាជកុមារផ្ដើមដឹកឫសគល់របស់សេចក្ដីសោក ទ្រង់ព្រះតម្រិះថា ឈ្មោះថា សេចក្ដីសោកនេះ រមែងមិនមានដល់អ្នកមិនកើត តែសម្រាប់បុគ្គលដែលកើតមកហើយ រមែងមាន ព្រោះហេតុនោះ សេចក្ដីសោកមាន ព្រោះអាស្រ័យជាតិ ។ ជាតិមាន ព្រោះអាស្រ័យអ្វី ។ ទ្រង់ជ្រាបថា ជាតិមាន ព្រោះអាស្រ័យភព ។ កាលទ្រង់មនសិការដោយឧបាយ ដោយអានុភាពនៃការអប់រំការនាក្នុងកាលមុន ទើបទ្រង់បានឃើញបដិច្ចសមុប្បាទទាំងអនុលោមនិងបដិលោម ។ កាលត្រឡប់ពិចារណាសង្ខារទាំងឡាយដោយអនុលោមទៀត គង់ប្រថាប់ក្នុងទីនោះឯង បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកសម្ពោធិញ្ញាណហើយ ។

អាមាត្យទាំងឡាយឃើញព្រះរាជកុមារមានសេចក្ដីសុខ ដោយសុខក្នុងមគ្គនិងផល មានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ប្រថាប់គង់ ទើបថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់កុំសោយសោកឡើយ ជម្ពូទ្វីបធំ ទូលព្រះបង្គំទាំងឡាយ នឹងនាំកញ្ញាដទៃដែលស្អាតជាងនេះមកថ្វាយ ។

ព្រះបច្ចេកពុទ្ធត្រាស់ថា អាត្មាមិនសោក អាត្មាអស់សេចក្ដីសោកហើយ អាត្មាជា **ព្រះបច្ចេកពុទ្ធ** ។ អាមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់ត្រាស់អ្វី ព្រះបច្ចេកពុទ្ធទាំងឡាយ មិនមែនមានសភាពបែបនេះឡើយ ។

ព្រះបច្ចេកពុទ្ធត្រាស់សួរថា នៃអ្នកទាំងឡាយ តើព្រះបច្ចេកពុទ្ធទាំងឡាយ មានសភាពដូចម្ដេច ។ អាមាត្យទាំងនោះ ក្រាបទូលថា ឈ្មោះថា ព្រះបច្ចេកពុទ្ធទាំងឡាយ លោកមានសក់ និងពុកមាត់ពុកចង្កា ត្រឹមតែ ២ ធ្នាប់ មួយអន្ទើដោយបរិក្ខារ ៨ ប៉ុណ្ណោះ ។ ព្រះបច្ចេកពុទ្ធក៏យកព្រះហស្តស្ទាបសិរសា រំពេចនោះឯង យាវាសភេទ ក៏អន្តរធានទៅ បព្វជិតភេទ ក៏ប្រាកដឡើង ព្រះអង្គមានព្រះកេសានិងព្រះមស្សុប្រមាណពីរធ្នាប់ប៉ុណ្ណោះ ប្រកបដោយបរិក្ខារ ៨ ដូចគ្នានឹងព្រះថេរៈ មានវស្សា ១០០ ។ ព្រះបច្ចេកពុទ្ធចូលចតុត្ថជ្ឈាន ហោះឡើងទៅកាន់អាកាស ហើយគង់លើផ្កាឈូក ។

អាមាត្យទាំងឡាយថ្វាយបង្គំហើយទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាកម្មដ្ឋាន ទ្រង់សម្រេចបានដូចម្ដេច ។ ព្រះបច្ចេកពុទ្ធព្រោះមានកម្មដ្ឋានដែលមានការជាប់ចំពាក់ជាអារម្មណ៍ ទ្រង់ឃើញច្បាស់ក្នុងវិបស្សនា ទើបត្រាស់ដឹង ព្រោះហេតុនោះ កាលសម្ដែងសេចក្ដីនោះ ទើបត្រាស់គាថាដូច្នេះថា

សំសគ្គជាតស្ស ភវន្តិ ស្នេហា
ស្នេហន្វយំ ទុក្ខមិទំ បហោតិ
អាទីនវំ ស្នេហជំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

សេចក្ដីស្រឡាញ់របស់សត្វ ដែលនៅប្រឡូកប្រឡំគ្នា រមែងមាន ឯសេចក្ដីទុក្ខនេះ មានឡើង ព្រោះអាស្រ័យសេចក្ដីស្រឡាញ់ បុគ្គលកាលឃើញទោសដែលកើតអំពីសេចក្ដីស្រឡាញ់ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

ឯការពណ៌នាគាថា គប្បីជ្រាបដូច្នេះថា បទថា **សំសគ្គជាតស្ស** ប្រែថា កើតការជាប់ចំពាក់ ។

ក្នុងបទថា **សំសគ្គជាតស្ស** នោះ **សំសគ្គ** ( ការប្រឡូកប្រឡំ ) មាន ៥ យ៉ាង គឺ **ទស្សនសំសគ្គ** ប្រឡូកប្រឡំដោយការឃើញ ១ **សវនសំសគ្គ** ប្រឡូកប្រឡំដោយការស្ដាប់ ១ **កាយសំសគ្គ** ប្រឡូក-ប្រឡំដោយកាយ ១ **សមុល្លបនសំសគ្គ** ប្រឡូកប្រឡំដោយការចរចា ១ **សម្ភោគសំសគ្គ** ប្រឡូកប្រឡំដោយការបរិភោគរួម ១ ។

ក្នុងការប្រឡូកប្រឡំ ៥ យ៉ាងនោះ រាគៈកើតក្នុងចក្ខុវិញ្ញាណវិថី ព្រោះឃើញគ្នានឹងគ្នា ឈ្មោះថា **ទស្សនសំសគ្គ** ( ប្រឡូកប្រឡំដោយការឃើញ ) ។ បណ្ដាសំសគ្គៈទាំងនោះ មានរឿងខាងក្រោមនេះជាឧទាហរណ៍ថា

បានឮថា ភិក្ខុកំលោះ ១ រូប ទៅកាន់កាលទីឃវាបិទ្វារវិហារ ដើម្បីរៀនឧទ្ទេស ។ អាចារ្យឃើញអន្តរាយរបស់លោក ក៏មិនឲ្យឱកាស

ភិក្ខុកំលោះនោះ ក៏ព្យាយាមដាប់តាមអាចារ្យទៅ ។ អាចារ្យពោលថា បើលោកមិនចូលទៅក្នុងស្រុក ខ្ញុំនឹងបង្រៀនឧទ្ទេសដល់លោក ។ លោកទទួលពាក្យហើយរៀនឧទ្ទេសចប់ ក៏ថ្វាយបង្គំលាអាចារ្យទៅ ដោយគិតថា អាចារ្យរបស់អញ មិនឲ្យអញចូលទៅក្នុងស្រុកនោះ តើមានរឿងអ្វី ហ្ន៎ ឃ្លុំចីវរហើយ ក៏ចូលទៅកាន់ស្រុក ។ សម័យនោះ កុលធីតាម្នាក់ស្លៀកសំពត់ពណ៌លឿងឈរត្រង់ផ្ទះ ឃើញភិក្ខុកំលោះ រាគៈក៏កើតឡើង យកវែកដួសបបរដាក់ក្នុងបាត្រហើយ ត្រឡប់ទៅដេកលើគ្រែ ។ លំដាប់នោះ មាតាបិតាសួរថា តើកូនមានរឿងអ្វី ។ កុលធីតានោះឆ្លើយថា បើបានភិក្ខុកំលោះដែលឈរត្រង់ទ្វារអម្បាញ់មិញនេះ ខ្ញុំនឹងមានជីវិត បើមិនបាន ខ្ញុំនឹងស្លាប់ ។

មាតាបិតាក៏រលះរលាំងទៅចួបភិក្ខុនោះ ត្រង់ទ្វារស្រុក ថ្វាយបង្គំហើយពោលថា សូមលោកម្ចាស់ត្រឡប់មកចុះ ខ្ញុំនឹងប្រគេនភិក្ខា ។ ភិក្ខុកំលោះពោលថា អាត្មាគ្រប់គ្រាន់ហើយ ។

មាតាបិតាទារិកានោះអង្វរថា រឿងនេះ មានដូច្នេះ ក្នុងផ្ទះរបស់ខ្ញុំមានទ្រព្យប្រមាណប៉ុណ្ណេះ ខ្ញុំមានកូនស្រីតែមួយប៉ុណ្ណោះ សូមលោកម្ចាស់មកជាកូនប្រសារបស់ខ្ញុំចុះ លោកម្ចាស់នឹងរស់នៅយ៉ាងសប្បាយ ។

ភិក្ខុកំលោះនោះពោលថា អាត្មាមិនត្រូវការដោយកង្វល់ទាំងនេះហើយធ្វើដំណើរទៅ ។

មាតាបិតាចូលទៅប្រាប់កូនស្រីថា នែកូន ពួកយើងមិនអាចធ្វើឲ្យភិក្ខុនោះ ត្រឡប់បានឡើយ ចូរកូនជ្រើសរើសបុរសដទៃ ហើយក្រោកឡើងបរិភោគបាយទឹកចុះ ។ កុលធីតានោះ មិនប្រាថ្នាបុរសដទៃ សូម្បីអាហារក៏មិនត្រូវការ នាងអត់អាហារអស់ ៧ ថ្ងៃ ក៏ស្លាប់ទៅ ។ មាតាបិតាធ្វើឈាបនកិច្ចស្រេចបាច់ហើយ ក៏យកសំពត់ពណ៌លឿងនោះ ទៅប្រគេនភិក្ខុដែលនៅក្នុងវិហារ ។ ភិក្ខុទាំងឡាយក៏ហែកសំពត់នោះ ជាចម្រៀកតូចធំចែកគ្នា ។ ភិក្ខុចាស់ ១ រូបទទួលចំណែករបស់ខ្លួនហើយ ត្រឡប់មកកាន់កល្យាណវិហារ ។ ភិក្ខុកំលោះនោះគិតថា ទៅថ្វាយបង្គំព្រះចេតិយ ក៏ធ្វើដំណើរទៅកាន់វិហារនោះ អង្គុយសម្រាកពេលថ្ងៃ ។ ភិក្ខុចាស់ចាប់យកសំពត់ពណ៌លឿងនោះ ប្រាប់ភិក្ខុកំលោះថា សូមលោកម្ចាស់ប្រើប្រាស់សំពត់នេះ ជាតម្រងទឹកចុះ ។ ភិក្ខុកំលោះសួរថា លោកម្ចាស់បានសំពត់នេះ មកអំពីណា ។ ភិក្ខុចាស់ក៏តំណាលរឿងទាំងអស់ប្រាប់ភិក្ខុកំលោះនោះ ។ ភិក្ខុកំលោះស្តាប់រឿងនោះហើយ គិតថា អញមិនបាននៅរួមជាមួយស្រីនោះហ្ន៎ ត្រូវភ្លើងរាគៈដុតរោល ក៏សុគតក្នុងទីនោះឯង[១] ។ នេះឈ្មោះថា ច្រឡូកច្រឡំដោយការឃើញ ។

រាគៈកើតតាមសោតវិញ្ញាណវិថី ព្រោះបានស្តាប់អំពីរូបសម្បត្តិជាដើម ដែលអ្នកដទៃពោល ឬបានស្តាប់សំឡេងសើច សំឡេងចរចា

---

១-ស្រង់ចាកអដ្ឋកថា រថវិនីតសូត្រ បិ.២១ ទំ.៨០ យ.៣០ ។

និងសំឡេងច្រៀងដោយខ្លួនឯង ឈ្មោះថា **សវនសំសគ្គ** គឺប្រឡូកប្រឡំដោយការស្តាប់ ។ ក្នុងរឿងប្រឡូកប្រឡំដោយការស្តាប់ មានរឿងជាបុគ្គលាធិដ្ឋានថា

បានឮថា ព្រះថេរៈជាព្រះខីណាស្រពមួយអង្គ គិតថា អញនឹងថ្វាយបង្គំព្រះមហាចេតិយ និងព្រះមហាពោធិព្រឹក្ស ទើបមកអំពីជនបទមកកាន់មហាវិហារជាមួយសាមណេរដែលកាន់កណ្ឌៈ សាមណេរនោះជាអ្នកបាននូវសមាបត្តិ ហើយចូលទៅកាន់បរិវេណវិហារ ។ កាលភិក្ខុសង្ឃជាច្រើនថ្វាយបង្គំព្រះចេតិយក្នុងពេលល្ងាច ព្រះថេរៈក៏មិនទាន់ចេញទៅដើម្បីថ្វាយបង្គំនូវព្រះចេតិយឡើយ ។

សួរថា ព្រោះហេតុអ្វី ។

ឆ្លើយថា ព្រោះព្រះខីណាស្រព មានសេចក្តីគោរពច្រើនក្នុងព្រះរតនត្រៃ ព្រោះហេតុនោះ កាលភិក្ខុសង្ឃថ្វាយបង្គំត្រឡប់ទៅហើយ ក្នុងវេលាដែលពួកមនុស្សបរិភោគអាហារល្ងាច ព្រះថេរៈមិនឲ្យសាមណេរដឹង គិតថា នឹងថ្វាយបង្គំព្រះចេតិយ ទើបចេញទៅតែមួយអង្គឯងប៉ុណ្ណោះ ។ សាមណេរគិតថា ព្រះថេរៈនិមន្តទៅតែមួយអង្គឯង ក្នុងវេលាដែលមិនមែនជាកាល អញនឹងដឹង ទើបធ្វើដំណើរតាមស្នាមជើងរបស់ព្រះឧបជ្ឈាយ៍ទៅ ព្រះថេរៈមិនដឹងថា សាមណេរមកតាមក្រោយឡើយ ព្រោះមិនបានគិតដល់ ទើបឡើងកាន់លានព្រះចេតិយតាមទ្វារទិសខាង

ត្បូង សាមណេរក៏ឡើងតាមស្នាមជើងទៅ ព្រះមហាថេរសម្លឹងមើលមហាចេតិយ មានបីតិក្នុងព្រះពុទ្ធជាអារម្មណ៍ សង្រួមចិត្តទាំងអស់ថ្វាយបង្គំព្រះចេតិយ សាមណេរឃើញអាការថ្វាយបង្គំរបស់ព្រះថេរៈ គិតថា ឧបជ្ឈាយ៍របស់អញមានចិត្តជ្រះថ្លាក្រៃលែង ថ្វាយបង្គំព្រះចេតិយ បើបានផ្កាឈើហើយ តើលោកបូជាដែរឬហ្ន៎ ។ កាលព្រះថេរៈក្រោកឡើងផ្គងអញ្ជលីលើសិរសា សម្លឹងមើលមហាចេតិយនោះឯង សាមណេរ ក៏គ្រហែមឲ្យព្រះថេរៈដឹងថា ខ្លួនមក ។ ព្រះថេរៈសម្លឹងមើល ហើយសួរថា នែសាមណេរ អ្នកមកអំពីថ្មើរណា ។

សាមណេរពោលថា បពិត្រលោកម្ចាស់ ក្នុងវេលាដែលលោកម្ចាស់ថ្វាយបង្គំព្រះចេតិយ លោកម្ចាស់ជ្រះថ្លាពន់ពេក ក្នុងការថ្វាយបង្គំព្រះចេតិយនេះ បើលោកម្ចាស់បានផ្កាហើយ គប្បីបូជាដែរឬទេ ។

ព្រះថេរៈពោលថា អើសាមណេរ ឈ្មោះថា ការបញ្ចុះព្រះធាតុមានប្រមាណប៉ុណ្ណេះ ក្រៅអំពីក្នុងព្រះចេតិយនេះហើយ រមែងមិនមានទេ បើបានផ្កាហើយ អ្នកណាមិនបូជាមហាសថូប ដែលមិនមានទីដទៃដូចយ៉ាងនេះ ។

សាមណេរពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់បង្អង់សិន ខ្ញុំនឹងនាំផ្កាមកប្រគេន ។ រំពេចនោះឯង សាមណេរក៏ចូលឈាន ហោះទៅកាន់ព្រៃហិមពាន្តដោយឫទ្ធិ បេះផ្កាដែលសម្បូរ

ដោយពណ៌និងក្លិន ដាក់ក្នុងធម្មក្រក ( តម្រងទឹក ) រហូតពេញ កាលព្រះមហាថេរចេញពីច្រកទ្វារខាងត្បូង មិនទាន់ដល់មុខខាងលិច ( នៃព្រះចេតិយ ) សាមណេរក៏មកដល់វិញ ដាក់ធម្មក្រកទុកក្នុងដៃរបស់ព្រះថេរៈ ហើយពោលថា សូមលោកម្ចាស់បូជាចុះ ។ ព្រះថេរៈពោលថា សាមណេរ ផ្ការបស់អ្នកតិចពេកណាស់ ។

សាមណេរពោលថា សូមលោកម្ចាស់និមន្តទៅ ហើយរឭកដល់គុណព្រះមានព្រះភាគបូជាចុះ ។ ព្រះថេរៈឡើងដណ្តើរតាមច្រកទ្វារខាងលិច ផ្តើមធ្វើការបូជាដោយផ្កាក្នុងទីសម្រាប់បូជា យកផ្កាបាចបូជាវេទិកា ( រានផ្កា ) ក៏ពេញទាំងអស់ ផ្កាធ្លាក់ទៅពេញក្នុងជាន់ទីពីរដោយប្រមាណត្រឹមក្បាលជង្គង់ ព្រះថេរៈចុះអំពីជាន់ទីពីរ ក៏ញុំាងជាន់ខាងក្រោមឲ្យពេញ កាលជាន់ខាងក្រោមពេញហើយ ទើបពោលថា នៃសាមណេរ ផ្ការបស់អ្នកមិនទាន់អស់ឡើយ ។

សាមណេរពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ផ្កាប់ធម្មក្រកចុះ ។ ព្រះថេរៈផ្កាប់ធម្មក្រកហើយក៏រលាស់ ក្នុងកាលនោះ ផ្កាក៏អស់ទៅ ព្រះថេរៈឲ្យធម្មក្រកដល់សាមណេរ ហើយធ្វើប្រទក្សិណព្រះចេតិយដែលមានកំពែងកម្ពស់ ៦០ ហត្ថ ៣ ជុំ ថ្វាយបង្គំក្នុងទិសទាំងបួន ហើយត្រឡប់ទៅកាន់បរិវេណ គិតថា សាមណេរនេះ មានឫទ្ធិច្រើនហ្ន៎ តើសាមណេរអាចរក្សាឥទ្ធានុភាពនេះ ទុកបានឬទេ ។ បន្ទាប់

អំពីនោះ ព្រះថេរៈឃើញថា មិនអាចរក្សាបាន ទើបពោលនឹងសាមណេរថា នៃសាមណេរ ឥឡូវនេះ អ្នកមានឫទ្ធិច្រើន ក្នុងកាលជាខាងក្រោយកាលឫទ្ធិវិនាស អ្នកនឹងផឹកទឹកបាយដែលស្រីជាងតម្បាញខ្វាក់ភ្នែកម្ខាងច្របាច់ដោយដៃ ។ នេះឈ្មោះថា ទោសរបស់យុវវ័យ ។ សាមណេរនោះ ដែលឧបជ្ឈាយ៍ឲ្យតក់ស្លុតហើយ ដោយពាក្យនោះ ក៏មិនសូមថាបពិត្រលោកម្ចាស់ សូមលោកម្ចាស់ប្រាប់កម្មដ្ឋានដល់ខ្ញុំចុះ សាមណេរគិតថា ព្រះឧបជ្ឈាយ៍របស់អញពោលអ្វី ធ្វើហាក់ដូចជាមិនបានឮពាក្យនោះ ហើយក៏ទៅ ។

ព្រះថេរៈ កាលថ្វាយបង្គំមហាចេតិយ និងមហាពោធិព្រឹក្សហើយទើបឲ្យសាមណេរទទួលបាត្រនិងចីវរ ហើយទៅកាន់កុដេឡិតិស្សមហាវិហារតាមលំដាប់ ។ សាមណេរដើរជាប់តាមឧបជ្ឈាយ៍ទៅ តែមិនដើរទៅបិណ្ឌបាតជាមួយ សួរឧបជ្ឈាយ៍ថា បពិត្រលោកម្ចាស់ លោកម្ចាស់ចូលទៅកាន់ស្រុកមួយណា ។ កាលដឹងថា ឥឡូវនេះ ព្រះឧបជ្ឈាយ៍របស់អញជិតដល់ទ្វារស្រុកហើយ ទើបកាន់បាត្រនិងចីវររបស់ព្រះឧបជ្ឈាយ៍ ហោះទៅ ប្រគេនបាត្រនិងចីវរដល់ព្រះថេរៈហើយ ទើបចូលទៅបិណ្ឌបាត ។

ព្រះថេរៈទូន្មានជានិច្ចថា នៃសាមណេរ អ្នកកុំធ្វើយ៉ាងនេះ ឈ្មោះថា ឫទ្ធិរបស់បុថុជ្ជន ជាធម្មជាតិកម្រើកញាប់ញ័រ មិនមាំមួនទេ កាល

បានអារម្មណ៍ មានរូបជាដើម ដែលមិនជាទីសប្បាយ សូម្បីបន្តិចបន្តួច ប៉ុណ្ណោះ ក៏បែកធ្លាយបាន ។ សាមណេរមិនប្រាថ្នាស្តាប់ ដោយគិតថា ព្រះឧបជ្ឈាយ៍របស់អញពោលអ្វី ក៏នៅតែធ្វើដូចមុនដដែល ។ ព្រះថេរៈ ថ្វាយបង្គំព្រះចេតិយទៅដោយលំដាប់ គឺនិមន្តទៅកាន់កម្មពិន្ទុវិហារ កាលព្រះថេរៈនៅក្នុងវិហារនោះ សាមណេរក៏នៅតែធ្វើយ៉ាងនោះឯង ។

សម័យថ្ងៃមួយ ធីតារបស់ជាងតម្បាញម្នាក់ ជាស្ត្រីមានរូបស្អាត នៅក្នុងបឋមវ័យ ចេញអំពីកម្មពិន្ទុគ្រាម ចុះទៅក្នុងស្រះឈូក ស្រែក ច្រៀងបណ្តើរ បេះផ្កាឈូកបណ្តើរ ។ សម័យនោះ សាមណេរក៏ហោះ ទៅខាងលើស្រះឈូក កាលហោះទៅ ជាប់ចិត្តនឹងសំឡេងច្រៀងរបស់ ស្ត្រីនោះ ដូចរុយខ្វាក់ភ្នែកជាប់ចំពាក់ក្នុងទឹករម្អិលដូច្នោះ[១] រំពេចនោះ ឯង ឫទ្ធិរបស់សាមណេរនោះ ក៏វិនាសទៅ ហាក់ដូចជាក្អែកបាក់ស្លាប ដូច្នោះ តែដោយផលរបស់សមាបត្តិនៅមាន សាមណេរមិនធ្លាក់ទៅលើ ទឹកដូចដុំដីធ្លាក់នោះឡើយ គឺធ្លាក់ចុះទៅថ្នម ៗ ដោយលំដាប់ ដូចសំឡី ដូច្នោះ ហើយឈរក្បែរមាត់ស្រះឈូកនោះ សាមណេរនោះ ប្រញាប់ទៅ ប្រគេនបាត្រនិងចីវរដល់ព្រះឧបជ្ឈាយ៍ ហើយត្រឡប់ ។ ព្រះមហាថេរ គិតថា អាត្មាអញឃើញហេតុនោះ ក្នុងកាលមុនហើយ ទោះបីហាម ក៏ សាមណេរមិនត្រឡប់ ទើបមិនពោលពាក្យណាមួយឡើយ ហើយនិមន្ត

១-ក្នុងទីខ្លះថា ដូចមេត្រីខ្វាក់ភ្នែកជាប់ជំពាក់ក្នុងទឹករម្អិលដូច្នោះ ។

ទៅបិណ្ឌបាត ។

សាមណេរទៅដល់មាត់ស្រះ រង់ចាំស្រីនោះ ឡើងមក សូម្បីស្រីនោះ ក៏ឃើញសាមណេរទាំងក្នុងខណៈដែលមកតាមអាកាស និងក្នុងខណៈដែលមកឈរ ក៏ដឹងថា សាមណេរនេះ អផ្សុកព្រោះអាស្រ័យអាត្មាអញដោយពិត ទើបពោលថា សាមណេរ សូមចៀសចេញទៅ ។ សាមណេរនោះ ក៏ចៀសចេញទៅ ។ ស្រីនោះឡើងមក ផ្លាស់សំពត់ហើយចូលទៅរកសាមណេរ សួរថា លោកម្ចាស់ត្រូវការអ្វីឬ ។ សាមណេរក៏ប្រាប់សេចក្តីនោះ នាងសម្តែងទោសក្នុងការគ្រប់គ្រងផ្ទះ ដោយហេតុច្រើនយ៉ាង និងអានិសង្សនៃការនៅក្នុងព្រហ្មចរិយៈ សូម្បីទូន្មាន ( យ៉ាងនេះហើយ ) ក៏មិនអាចបន្ទោបង់សេចក្តីអផ្សុក ( ការចង់សឹក ) របស់សាមណេរនោះបាន ទើបគិតថា សាមណេរនេះ វិនាសចាកឫទ្ធិមានសភាពបែបនេះ ព្រោះតែអាត្មាអញ ឥឡូវនេះ អញមិនគួរនឹងបោះបង់លោកឡើយ ទើបពោលថា សូមលោកម្ចាស់ចាំនៅទីនេះចុះ ហើយទៅកាន់ផ្ទះរបស់ខ្លួន ប្រាប់រឿងនោះដល់មាតាបិតា ។ ឯមាតាបិតាក៏មកហើយទូន្មានច្រើនយ៉ាង បានពោលនឹងសាមណេរដែលមិនស្តាប់នោះថា សូមលោកកុំយល់ថា ពួកខ្ញុំមានត្រកូលខ្ពង់ខ្ពស់ ពួកខ្ញុំត្រឹមតែជាត្រកូលជាងតម្បាញ លោកនឹងធ្វើត្រឹមតែការងារត្បាញប៉ុណ្ណោះ ។

សាមណេរពោលថា ឧបាសក ធម្មតាបុគ្គលដែលជាគ្រហស្ថ គួរ

ធ្វើការងារត្បាញ ឬគួរធ្វើការងារត្បាញផែងក៏បាន លោកកំណាញ់អ្វី ត្រឹមតែសំពត់សាដកនេះ ។ ជាងតម្បាញឲ្យសំពត់សាដកដែលចង់ត្រង់ ពោះ ហើយនាំទៅកាន់ផ្ទះ លើកកូនស្រីឲ្យ ។

បុរសនោះ សឹកអំពីសាមណេរហើយ រៀនធ្វើការងាររបស់ជាង តម្បាញ ធ្វើការងារក្នុងរោងតម្បាញ ជាមួយពួកជាងដទៃនោះឯង ។ បណ្តាភរិយារបស់ជាងតម្បាញដទៃ បានត្រៀមអាហារនាំមកអំពីព្រឹក ភរិយារបស់បុរសនោះ ក៏មិនទាន់មកនៅឡើយ ។ បុរសនោះ កាលអ្នក ដទៃបរិភោគអាហារ ក៏អង្គុយរង់ចាំដោយត្បាញបណ្តើរ ៗ នោះឯង ។ ភរិយាក៏មកឯក្រោយ ។ លំដាប់នោះ បុរសនោះ ក៏គំហកដាក់ភរិយាថា ហេតុអ្វី ក៏មកយឺតម្ល៉េះ ។

ធម្មតាមាតុគ្រាមដឹងថា សូម្បីស្តេចចក្កពត្តិដែលមានចិត្តជាប់ ចំពាក់ក្នុងខ្លួន ក៏គង់សម្គាល់ថា ដូចជាទាសៈ ព្រោះហេតុនោះ ទើបនាង ពោលថា ក្នុងផ្ទះរបស់អ្នកដទៃ គេមានឧស បន្លែ និងអំបិលស្រាប់ សូម្បី អ្នកបម្រើរបស់គេក៏មាន តែខ្ញុំជាស្រីម្នាក់ឯងប៉ុណ្ណោះ អ្នកមិនដឹងថា ក្នុង ផ្ទះរបស់យើង វត្ថុនេះ មាន វត្ថុនេះ មិនមាន បើអ្នកត្រូវការ ក៏ចូរ បរិភោគចុះ បើមិនត្រូវការ កុំបរិភោគឡើយ ។

បុរសនោះគំហកថា នាងមិនត្រឹមតែនាំអាហារមកយឺតប៉ុណ្ណោះ ទេ ថែមទាំងនៅនិយាយបញ្ឆោះទៀត គាត់មានចិត្តខឹងក្រោធ កាលមិន

ឃើញវត្ថុសម្រាប់ប្រហារ (បៀតបៀន) ដទៃ ទើបដោះត្រល់ ហើយពួយទៅ ត្រល់នោះក៏ហើរទៅតម្រង់មុខរបស់ភរិយា ។ ស្ត្រីនោះ ឃើញត្រល់ហើយ គេចបន្តិច ចុងត្រល់ក៏មុតត្រង់កន្ទុយភ្នែក ស្រីនោះយកដៃទាំងពីរក្តោបភ្នែក ឈាមហូរចេញក្នុងទីដែលមុត ។ បុរសនោះ រឭកដល់ពាក្យរបស់ឧបជ្ឈាយ៍បាន ក្នុងពេលនោះថា ឧបជ្ឈាយ៍គង់សំដៅដល់ហេតុនេះ ទើបពោលថា ក្នុងអនាគត អ្នកនឹងផឹកទឹកបាយ ដែលស្រីជាងតម្បាញខ្វាក់ភ្នែក ច្របាច់ដោយដៃ ដូច្នេះ ព្រះថេរៈគង់ឃើញហេតុនេះ ដោយពិត ទើបទ្រហោយំ ពោលថា ឱ! លោកម្ចាស់ឃើញកាលវែង ។

ពួកជាងតម្បាញដទៃ ៗ បានពោលនឹងបុរសនោះថា ណ្ហើយចុះអ្នក អ្នកកុំយំឡើយ ធម្មតាភ្នែកដែលបែកហើយ មិនអាចធ្វើឲ្យដូចដើមវិញបានទេ តើអ្នកយំធ្វើអ្វី ។

បុរសនោះពោលថា ខ្ញុំមិនបានយំដល់រឿងនោះទេ ខ្ញុំយំសំដៅដល់ហេតុឈ្មោះនេះ ហើយប្រាប់រឿងទាំងអស់តាមលំដាប់ ដោយប្រការដូច្នេះ ។ សមថវិបស្សនាទាំងឡាយដែលកើតឡើងហើយ កាលរលត់ទៅវិញ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍យ៉ាងនេះ[១] ។

---

១-ស្រង់ចាកអដ្ឋកថា មហាសកុលុទាយិសូត្រ បិ.២៤ ទំ.១៣២ ឃ.៧៩ និងអដ្ឋកថា អភិធម្ម សម្មប្បធានវិភង្គ បិ.៨១ ទំ.១៦៧ ឃ.២១១ ។

រាគៈកើតឡើង ព្រោះការស្ទាបអង្អែលអវយវៈនៃគ្នានឹងគ្នា ឈ្មោះថា កាយសំសគ្គៈ គឺការជាប់ចំពាក់ដោយកាយ ។ ក្នុងរឿងកាយសំសគ្គៈនេះ មានភិក្ខុកំលោះអ្នកពោលធម៌ និងព្រះរាជធីតាជាតំរូ ។ បានឮថា មានភិក្ខុកំលោះមួយរូបនៅក្នុងមហាវិហារ ជាអ្នកសម្ដែងធម៌ ។ មហាជនទាំងឡាយនាំគ្នាមកក្នុងវិហារនោះ សូម្បីព្រះរាជានិងព្រះអគ្គមហេសីមួយអន្ទើដោយព្រះរាជធីតា ក៏បានយាងមកដែរ ។ ខណៈនោះ ព្រោះអាស្រ័យរូបនិងសំឡេងរបស់ភិក្ខុនោះ រាគៈដ៏មានកម្លាំង ក៏កើតឡើងដល់ព្រះរាជធីតាផង កើតឡើងដល់ភិក្ខុកំលោះផង ។ ព្រះរាជាទតឃើញដូច្នោះ ទ្រង់ក៏ឲ្យមហាជនយករាំងននមកបាំង ។ ជនទាំងពីរក៏ពាល់ត្រូវកាយ ឱបក្រសោបគ្នានឹងគ្នា ។ កាលមហាជនបើករាំងននចេញហើយ ក៏បានឃើញជនទាំងពីរស្លាប់ក្នុងទីនោះឯង[១] ។

មានរឿងមួយទៀតថា

បានឮថា ត្រង់មហាចេតិយង្គណៈ ពួកភិក្ខុកំលោះធ្វើការស្វាធ្យាយ ពួកភិក្ខុនីអង្គុយស្ដាប់ធម៌អំពីខាងក្រោយ ពួកភិក្ខុកំលោះទាំងនោះ ។ បណ្ដាភិក្ខុកំលោះទាំងនោះ មានភិក្ខុកំលោះមួយរូប លាដៃចេញទៅ ក៏ពាល់ត្រូវកាយភិក្ខុនីក្រមុំមួយរូប ។ ភិក្ខុនីក្រមុំនោះ ក៏ចាប់ដៃភិក្ខុកំលោះនោះ មកផ្ទឹបត្រង់ដើមទ្រូងរបស់ខ្លួន ។ ដោយកាយសំសគ្គៈនោះ ជន

---

១-ស្រង់ចាកអដ្ឋកថា បច្ចេកពុទ្ធាបទាន បិ.៧២ ទំ.១៦ ឃ.២ ។

ទាំងពីរមិនអាចនៅក្នុងព្រហ្មចរិយធម៌បាន ក៏សឹកមកជាគ្រហស្ថ[១] ។

មានរឿងមួយទៀតថា

រាគៈកើតឡើង ព្រោះការហៅរកនិងការចរចាគ្នា ឈ្មោះថា **សមុល្លបនសំសគ្គ** ជាប់ចំពាក់ដោយការចរចា ។ រាគៈដែលកើតឡើង ព្រោះភិក្ខុធ្វើការបរិភោគរួមគ្នាជាមួយភិក្ខុនីទាំងឡាយ ឈ្មោះថា **សម្ភោគសំសគ្គ** ជាប់ចំពាក់ដោយការបរិភោគរួមគ្នា ។

ក្នុង **សំសគ្គ** ទាំង ២ នេះ មានភិក្ខុភិក្ខុនីដែលត្រូវអាបត្តិបារាជិកជាគំរូ ។ បានឮថា ក្នុងកាលធ្វើងមរិចវដ្តិមហាវិហារ ព្រះបាទទុដ្ឋគាមណិ-អភ័យបានធ្វើមហាទានចំពោះឧភតោសង្ឃ មានភិក្ខុ ១ សែនរូប ភិក្ខុនី ៩ ម៉ឺនរូប ។ សាមណេរមួយរូបទទួលយាគូក្តៅ ក៏ដាក់លើជាយចីវរម្តង ដាក់លើផែនដីម្តង សាមណេរីមួយរូបឃើញដូច្នោះ ក៏ប្រគេនរង្វេលបាត្រដែលធ្វើអំពីភ្នុក ហើយពោលថា សូមលោកម្ចាស់ដាក់បាត្រលើរង្វេលនេះហើយសឹមទៅ ។ ក្នុងកាលក្រោយមកទៀត កាលភ័យកើតឡើង ទាំងពីររូបនោះ ក៏ទៅកាន់បរសមុទ្ទវិហារ ។ បណ្តាជនទាំងពីរនោះ ភិក្ខុនីទៅមុន ។ ភិក្ខុនីនោះបានឮថា ភិក្ខុអ្នកសីហឡៈមួយរូបនិមន្តមក ក៏ទៅកាន់សម្នាក់ព្រះថេរៈ ធ្វើបដិសណ្ឋារៈ អង្គុយហើយសួរថា បពិត្រលោកម្ចាស់ ក្នុងកាលធ្វើងមរិចវដ្តិវិហារ លោកម្ចាស់មានព្រះជន្មប៉ុន្មាន ។

---

១-ស្រង់ចាកអដ្ឋកថា រថវិនីតសូត្រ បិ.២១ ទំ.៨០ ឃ.៣០ ។

លោកឆ្លើយថា ក្នុងកាលនោះ ខ្ញុំជាសាមណេរអាយុ ៧ ឆ្នាំ ចុះនាងមានអាយុប៉ុន្មាន ។

ភិក្ខុនីនោះពោលថា ក្នុងកាលនោះ ខ្ញុំជាសាមណេរីមានអាយុ ៧ ឆ្នាំ ខ្ញុំបានប្រគេនវង្វេលបាត្រដល់សាមណេរមួយរូប ដែលទទួលបបរមានសភាពក្តៅ ។ ព្រះថេរៈនោះពោលថា សាមណេរក្នុងកាលនោះ គឺខ្ញុំនេះឯង ហើយក៏យកវង្វេលបាត្របង្ហាញ ។ ដោយ **សម្ភោគសំសគ្គ** នោះឯង ជនទាំងពីរមិនអាចបន្តព្រហ្មចរិយធម៌បាន ក៏សឹកក្នុងទីនោះ ។ ភិក្ខុនិងភិក្ខុនីនោះ មិនអាចទ្រទ្រង់នូវព្រហ្មចរិយៈ ព្រោះសំសគ្គៈនោះមានប្រមាណប៉ុណ្ណោះ ជនទាំងពីររូប ( ត្រូវអាបត្តិបារាជិក ) ហើយទើបសឹក ក្នុងកាលនៃខ្លួនមានអាយុ ៦០ ឆ្នាំ [១] ។

សេចក្តីស្នេហា រមែងមានដល់បុគ្គលដែលធ្វើនូវការច្រឡូកច្រឡំដោយការច្រឡូកច្រឡំណាមួយ បណ្តាសំសគ្គៈ ៥ យ៉ាង ដោយប្រការដូច្នេះ ។ បន្ទាប់អំពីរាគៈដ៏ខ្លាំងក្លានោះ សេចក្តីទុក្ខនេះ កាលទៅតាមសេចក្តីស្រឡាញ់ រមែងកើត គឺថា សេចក្តីទុក្ខនេះ មានប្រការផ្សេង ៗ មានសេចក្តីសោក សេចក្តីខ្សឹកខ្សួលជាដើម ដែលគប្បីឃើញក្នុងបច្ចុប្បន្ននិងលោកខាងមុខ ការជាប់តាមនូវសេចក្តីស្រឡាញ់នោះឯង រមែងកើត

---

១-ស្រង់ចាកអដ្ឋកថា រថវិនីតសូត្រ បិ.២១ ទំ.៨០ ឃ.៣០ និងអដ្ឋកថាបច្ចេកពុទ្ធាបទាន បិ.៧២ ទំ.១៦ ឃ.២ ។

មាន ហូរចេញមក មានប្រាកដ ។

អាចារ្យពួកដទៃពោលថា ការបណ្តោយចិត្តទៅក្នុងអារម្មណ៍ឈ្មោះថា សំសគ្គៈ សេចក្តីស្រឡាញ់បន្ទាប់អំពីសំសគ្គៈនោះ ចាត់ជាទុក្ខដែលកើតព្រោះសេចក្តីស្រឡាញ់នេះ ដូច្នេះ ។ ព្រះបច្ចេកពុទ្ធនោះពោលកន្លះគាថានេះ ដែលមានអត្ថយ៉ាងនេះហើយ ទើបពោលថា សេចក្តីទុក្ខ មានសោកជាដើម ជាប់តាមសេចក្តីស្រឡាញ់ឯណា អាត្មាជីកនូវឫសគល់នៃសេចក្តីស្រឡាញ់នោះ បានសម្រេចបច្ចេកពោធិញ្ញាណហើយ ។

កាលព្រះបច្ចេកពុទ្ធពោលយ៉ាងនេះហើយ អាមាត្យទាំងឡាយនោះ ក្រាបទូលសួរថា បពិត្រលោកម្ចាស់ ឥឡូវនេះ យើងខ្ញុំទាំងឡាយគួរធ្វើដូចម្តេច ។

លំដាប់នោះ កាលព្រះបច្ចេកពុទ្ធពោលថា អ្នកទាំងឡាយ ឬអ្នកឯណានីមួយ ដែលប្រាថ្នាដើម្បីនឹងផុតចាកសេចក្តីទុក្ខនេះ អ្នកទាំងអស់នោះ គប្បីឃើញទោសដែលកើតព្រោះសេចក្តីស្រឡាញ់ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាសដូច្នោះ ។ ក្នុងទីនេះ គប្បីជ្រាបថា លោកសំដៅយកពាក្យដែលពោលថា សេចក្តីទុក្ខនេះ ជាប់តាមនូវសេចក្តីស្រឡាញ់ រមែងកើតឡើង ទើបពោលថា បុគ្គលកាលឃើញទោសដែលកើតព្រោះសេចក្តីស្រឡាញ់ ដូច្នេះ ។

*ម្យ៉ាងទៀត ភ្ជាប់សេចក្ដីយ៉ាងនេះថា សេចក្ដីស្រឡាញ់ រមែងមានដល់បុគ្គលដែលប្រឡូកប្រឡំដោយសំសគ្គៈ តាមដែលពោលហើយ សេចក្ដីទុក្ខប្រព្រឹត្តទៅតាមសេចក្ដីស្រឡាញ់នេះ ( មានច្រើន ) អាត្មាឃើញទោស ដែលកើតព្រោះសេចក្ដីស្រឡាញ់តាមសេចក្ដីពិតយ៉ាងនេះ ទើបសម្រេចហើយ ។ គប្បីជ្រាបថា ព្រះបច្ចេកពុទ្ធពោលបាទទី ៤ ដោយអំណាចសេចក្ដីស្រឡាញ់ ដោយន័យដូចពោលហើយខាងដើម ។ ខាងមុខអំពីនេះទៅ បទទាំងពួងដូចគ្នាតាមដែលពោលហើយ ក្នុងគាថាទី ១ នោះឯង ។*

សំសគ្គគាថាទី ២ ចប់

# មិត្តសុហជ្ជគាថា

*គាថាថា* **មិត្តេ សុហជ្ជេ** *ដូច្នេះជាដើម តើមានហេតុកើតដូចម្តេច ។*

*ព្រះបច្ចេកពោធិសត្វអង្គនេះ កើតឡើងហើយដោយន័យដូចពោលក្នុងគាថាទី ១ នោះឯង សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ធ្វើបឋមជ្ឈានឲ្យកើតហើយ ចង់ពិសោធថា សមណធម៌ប្រសើរ ឬរាជសម្បត្តិប្រសើរ ទើបប្រគល់រាជសម្បត្តិឲ្យដល់អាមាត្យទាំងឡាយ ហើយបានធ្វើសមណធម៌ ។ អាមាត្យទាំងនោះ សូម្បីព្រះបច្ចេកពោធិសត្វត្រាស់ថា ពួកអ្នកចូរកាត់ក្តីដោយធម៌ (កុំស៊ីសំណូកឡើយ) ហើយក៏ដោយ ក៏នៅតែកាត់ក្តីដោយអធម៌ ។ អាមាត្យទាំងនោះ ទទួលសំណូកហើយធ្វើម្ចាស់ទ្រព្យឲ្យចាញ់ ។ គ្រាមួយ ធ្វើរាជវល្លភៈ (អ្នកស្និទ្ធស្នាលជាមួយព្រះរាជា) ម្នាក់ ឲ្យចាញ់ ។ រាជវល្លភៈនោះ ចូលទៅគាល់ព្រះរាជាមួយអន្លើដោយពួកអ្នកចម្អិនក្រយាស្ងោយរបស់ព្រះរាជា ហើយក្រាបទូលរឿងទាំងពួងឲ្យទ្រង់ជ្រាប ។ ក្នុងថ្ងៃទី ២ ព្រះរាជាយាងទៅកាន់ទីវិនិច្ឆ័យដោយព្រះអង្គឯង ។ លំដាប់នោះ ពួកមហាជនក៏បន្លឺសំឡេងអឺងកងថា បពិត្រព្រះសម្មតិទេព ពួកអាមាត្យកាត់ក្តី ធ្វើម្ចាស់ទ្រព្យមិនឲ្យជាម្ចាស់ទ្រព្យ ហើយបានធ្វើអាកប្បកិរិយាដូចមហាចម្បាំង ។ លំដាប់នោះ ព្រះរាជាក្រោកឡើងចាកទីវិនិច្ឆ័យ ហើយយាងឡើងកាន់ប្រាសាទ ប្រថាប់*

គង់ចូលសមាបត្តិ ទ្រង់មានចិត្តរាយមាយព្រោះសំឡេងនោះ មិនអាចចូលសមាបត្តិបាន ។ ទ្រង់ព្រះតម្រិះថា ប្រយោជន៍អ្វីដោយរាជសម្បត្តិសម្រាប់អញ សមណធម៌ប្រសើរជាង ទើបលះសុខក្នុងរាជសម្បត្តិ ធ្វើសមាបត្តិឲ្យកើតឡើងទៀត ហើយចម្រើនវិបស្សនាដោយន័យដូចពោលក្នុងកាលមុននោះឯង ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកសម្ពោធិញ្ញាណ ត្រូវព្រះសង្ឃត្ថេរសួរកម្មដ្ឋាន ទើបពោលគាថានេះថា

**មិត្តេ សុហជ្ជេ អនុកម្បមានោ**
**ហាបេតិ អត្ថំ បដិពទ្ធចិត្តោ**
**ឯតំ ភយំ សន្ថវេ បេក្ខមានោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

*បុគ្គលមានចិត្តជាប់ចំពាក់ កាលអនុគ្រោះចំពោះពួក*
*មិត្ត និងសម្លាញ់ រមែងញុំាងប្រយោជន៍ឲ្យវិនាស*
*បុគ្គល កាលឃើញនូវភ័យ ក្នុងសេចក្តីស្និទ្ធស្នាលនុ៎ះ*
*គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។*

បណ្តាមិត្ត និងសម្លាញ់នោះ ឈ្មោះថា មិត្ត ព្រោះនាំមកនូវមេត្រីចិត្ត ឈ្មោះថា សម្លាញ់ ព្រោះជាអ្នកមានចិត្តល្អ ។ បុគ្គលពួកខ្លះត្រឹមតែជាមិត្ត ព្រោះជាអ្នកប្រាថ្នាប្រយោជន៍តែម្យ៉ាង ពួកខ្លះ ត្រឹមតែជាសម្លាញ់ ដោយធ្វើសេចក្តីសុខឲ្យកើត ក្នុងការទៅ ការមក ការឈរ

ការអង្គុយ និងការប្រាស្រ័យ តែមិនបានជាមិត្ត ។ ពួកខ្លះជាសម្លាញ់ផង ជាមិត្តផង ព្រោះប្រព្រឹត្តទៅបានទាំង ២ យ៉ាងនោះ ។

មិត្តនោះ មាន ២ ពួក គឺអគារិយមិត្ត និងអនាគារិយមិត្ត ។ បណ្ដាមិត្ត ២ ពួកនោះ អគារិយមិត្តមាន ៣ គឺមិត្តមានឧបការៈ ១ មិត្តរួមសុខរួមទុក្ខ ១ មិត្តមានសេចក្ដីឈឺឆ្អាល ១ ។ អនាគារិយមិត្ត ជាអ្នកប្រាប់ប្រយោជន៍ដោយពិសេសនោះឯង ។ មិត្តទាំងនោះ ជាអ្នកប្រកបដោយអង្គ ៤ ។ សមដូចព្រះតម្រាស់ថា

ម្នាលគហបតិបុត្ត មិត្តមានឧបការៈ ជាមិត្តមានសន្ដានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺរក្សាមិត្តដែលធ្វេសប្រហែស ១ រក្សាសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស ១ ជាទីពឹងពំនាក់នៃមិត្តដែលមានសេចក្ដីភិតភ័យ ១ កាលបើកិច្ចដែលត្រូវធ្វើកើតឡើងហើយ តែងជួយផ្ដល់ភោគៈជាទ្វិគុណជាងទ្រព្យដែលមិត្តត្រូវការនោះ ១ ។

ម្នាលគហបតិបុត្ត មិត្តរួមសុខទុក្ខ ជាមិត្តមានសន្ដានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺប្រាប់នូវអាថ៌កំបាំងរបស់ខ្លួនដល់មិត្ត ១ ជួយបិទបាំងនូវអាថ៌កំបាំងរបស់មិត្ត ១ មិនបោះបង់គ្នាក្នុងគ្រាមានវិបត្តិ ១ សូម្បីជីវិតក៏ហ៊ានលះបង់ ដើម្បីប្រយោជន៍ដល់មិត្ត ( ស៊ូប្ដូរជីវិត ) ១ ។

ម្នាលគហបតិបុត្ត មិត្តមានសេចក្ដីឈឺឆ្អាល ជាមិត្តមានសន្ដានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺជួយព្រួយចិត្តពីព្រោះមិត្តបានសេចក្ដីវិនាស

១ ជួយត្រេកអរព្រោះមិត្តបានសេចក្ដីចម្រើន ១ ទទឹងទាស់នឹងមនុស្ស ដែលពោលទោសមិត្ត ១ សរសើរតែមនុស្សដែលពណ៌នាគុណមិត្ត ១ ។

ម្នាលគហបតិបុត្ត មិត្តប្រាប់ប្រយោជន៍ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺហាមមិត្តឲ្យឃ្លាតចាកអំពើអាក្រក់ ១ ដឹកនាំឲ្យមិត្តតម្កល់នៅតែក្នុងអំពើល្អ ១ ឲ្យបានឮពាក្យដែលមិនធ្លាប់បានឮ ១ ប្រាប់ផ្លូវឋានសួគ៌ ១ [(១)] ។

បណ្ដាមិត្ត ២ ពួកនោះ ក្នុងទីនេះ បំណងយកអគារិយមិត្ត តែដោយសេចក្ដី រមែងរួមយកមិត្តទាំងអស់ ។ បទថា **មិត្តេ សុហជ្ជេ អត្ថកាមានុសា** បានដល់ កាលអាណិតអាសូរមិត្តសម្លាញ់ទាំងនោះ ( គឺ ) ប្រាថ្នានាំសេចក្ដីសុខចូលទៅឲ្យមិត្តទាំងនោះ និងប្រាថ្នាកម្ចាត់សេចក្ដីទុក្ខចោល ។

បទថា **ហាបេតិ អត្ថំ** សេចក្ដីថា រមែងធ្វើប្រយោជន៍ ៣ គឺទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ ឲ្យវិនាស ។ម្យ៉ាងទៀត រមែងធ្វើប្រយោជន៍ ៣ គឺប្រយោជន៍ខ្លួន ប្រយោជន៍អ្នកដទៃ និងប្រយោជន៍របស់ខ្លួនផង អ្នកដទៃផង ឲ្យវិនាស គឺឲ្យវិនាសទៅដោយចំណែកទាំង ២ គឺធ្វើវត្ថុដែលបានហើយ ឲ្យវិនាសទៅ ១ ធ្វើវត្ថុដែលមិនទាន់កើត មិនឲ្យកើតឡើង ១ ។ បុគ្គលមានចិត្តជាប់

---

១-បិ.១៩ ទំ.៨១-៨២ ឃ.៦៤-៦៧ ។

ចំពាក់ គឺដាក់ខ្លួនទុកក្នុងឋានៈដែលទាបយ៉ាងនេះថា វៀរបុគ្គលនេះ បេញ អាត្មាអញរស់នៅមិនបាន បុគ្គលនេះជាគតិ ជាអ្នកនាំមុខរបស់អញ ដូច្នេះក្តី ឈ្មោះថា បុគ្គលមានចិត្តជាប់ចំពាក់ ។ ឬតម្កល់ខ្លួនក្នុងឋានៈដែលខ្ពស់យ៉ាងនេះថា មនុស្សទាំងនេះ ប្រាសចាកអញហើយ ជាអ្នករស់នៅមិនបាន អញជាគតិរបស់មនុស្សទាំងនោះ អញជាអ្នកនាំមុខរបស់មនុស្សទាំងនោះ ដូច្នេះក្តី ឈ្មោះថា បុគ្គលមានចិត្តជាប់ចំពាក់ ។ ក្នុងទីនេះ លោកបំណងយកបុគ្គលមានចិត្តជាប់ចំពាក់យ៉ាងនេះ ។ បទថា **ឯតំ ភយំ** បានដល់ ភ័យនោះ គឺការធ្វើប្រយោជន៍ឲ្យវិនាស ។ ពាក្យនេះ ព្រះរាជាត្រាស់សំដៅដល់ការសាបសូន្យចាកសមាបត្តិរបស់ព្រះអង្គ ។

បទថា **សន្ថវេ** សេចក្តីថា សន្ថវៈ មាន ៣ យ៉ាង គឺតណ្ហាសន្ថវៈ ១ ទិដ្ឋិសន្ថវៈ ១ មិត្តសន្ថវៈ ១ ។ ក្នុងសន្ថវៈ ៣ យ៉ាងនោះ តណ្ហាទាំង ១០៨ ឈ្មោះថា តណ្ហាសន្ថវៈ ទិដ្ឋិ ៦២ ឈ្មោះថា ទិដ្ឋិសន្ថវៈ ការអនុគ្រោះមិត្ត ដោយភាពជាអ្នកមានចិត្តជាប់ចំពាក់ ឈ្មោះថា មិត្តសន្ថវៈ ។ បណ្តាសន្ថវៈ ៣ នោះ ក្នុងទីនេះ បំណងយកមិត្តសន្ថវៈនោះ ។ ពិតហើយ សមាបត្តិរបស់ព្រះរាជានោះ វិនាសព្រោះមិត្តសន្ថវៈនោះ ព្រោះហេតុនោះ ទើប **ព្រះបច្ចេកពុទ្ធ** ត្រាស់ថា អាត្មា កាលឃើញនូវភ័យក្នុងការស្និទ្ធស្នាលនុ៎ះ ទើបត្រាស់ដឹង ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

មិត្តសុហជ្ជគាថា ទី ៣ ចប់

# ចំសក្កទ្បីរគាថា

*បទថា **វំសោ វិសាលោ** ដូច្នេះ តើមានហេតុកើតដូចម្តេច ។*

*បានឮថា ក្នុងកាលមុន ព្រះបច្ចេកពោធិសត្វ ៣ អង្គ បួសក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមកស្សបៈ បំពេញគតបច្ចាគតវត្តអស់ ២ ម៉ឺនឆ្នាំ កើតឡើងក្នុងទេវលោក ចុតិចាកទេវលោកនោះហើយ ទេវបុត្តដែលជាប្រធានកើតក្នុងរាជត្រកូលក្នុងនគរពារាណសី ពីរអង្គទៀតកើតក្នុងបច្ចន្តរាជត្រកូល ព្រះរាជាទាំងពីរអង្គនោះ រៀនកម្មដ្ឋាន លះរាជសម្បត្តិ បួស បានជា **ព្រះបច្ចេកពុទ្ធ** តាមលំដាប់ អាស្រ័យនៅត្រង់ញកភ្នំនន្ទមូលកៈ ។ ក្នុងថ្ងៃមួយ ចេញអំពីសមាបត្តិរឭកថា ពួកយើងធ្វើកម្មអ្វីទើបសម្រេចលោកុត្តរសុខនេះ ពិចារណាបានឃើញចរិយារបស់ខ្លួនក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ លំដាប់នោះ រឭកទៀតថា ជនទី ៣ នៅឯណា ឃើញជនទី ៣ សោយរាជសម្បត្តិក្នុងនគរពារាណសី រឭកដល់គុណរបស់ជនជាប្រធាននោះហើយ គិតថា ដោយប្រក្រតី ព្រះរាជាអង្គនោះ ទ្រង់ដល់ព្រមដោយគុណ មានភាពជាអ្នកប្រាថ្នាតិចជាដើម ជាអ្នកឲ្យឱវាទទូន្មានពួកយើង ទ្រង់ប្រព្រឹត្តអត់ធន់ចំពោះពាក្យពោល ទ្រង់តិះដៀលនូវបាប ណ្ហើយចុះ ពួកយើងនឹងសម្តែងអារម្មណ៍ ដើម្បីដោះព្រះអង្គ ដូច្នេះហើយ ស្វែងរកឱកាស ។ ក្នុងថ្ងៃមួយ ឃើញព្រះ*

រាជាអង្គនោះ ទ្រង់ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង កំពុងយាងទៅកាន់ព្រះរាជឧទ្យាន ទើបហោះទៅតាមអាកាស ឈរត្រង់គុម្ពឫស្សី ក្បែរទ្វារព្រះរាជឧទ្យាន ។ មហាជន រមែងមិនឆ្អែតក្នុងការមើលព្រះរាជាសម្លឹងមើលតែព្រះរាជារបស់ខ្លួន ។ លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា មានអ្នកណាហ្ន៎ ខ្វល់ខ្វាយក្នុងការមើលអាត្មាអញ ទ្រង់សម្លឹងមើល បានឃើញព្រះបច្ចេកពុទ្ធទាំងឡាយ ។ ដំណាលគ្នានឹងការឃើញនោះឯង សេចក្តីស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធទាំងនោះ ក៏កើតឡើង ។ ព្រះរាជាទ្រង់ចុះអំពីកដំរីចូលទៅរកព្រះបច្ចេកពុទ្ធទាំងឡាយនោះ ដោយអាកប្បកិរិយាដ៏សុប់រម្ងាប់ ហើយត្រាស់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន តើលោកម្ចាស់ទាំងឡាយ ឈ្មោះអ្វី ។ ព្រះបច្ចេកពុទ្ធទាំងនោះ តបថា មហាបពិត្រ ពួកអាត្មាឈ្មោះថា អសជ្ជមានៈ ។

ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ឈ្មោះថា អសជ្ជមានៈ មានន័យដូចម្តេច ។ ព្រះបច្ចេកពុទ្ធពោលថា បពិត្រមហារាជ មានន័យថា ការមិនជាប់ចំពាក់ ។ បន្ទាប់អំពីនោះ កាលនឹងសម្តែងគុម្ពឫស្សីនោះ ទើបពោលថា មហាបពិត្រ ប្រៀបដូចបុរសមានដាវក្នុងដៃកាត់គុម្ពឫស្សីនោះ ដែលមានឫស ដើម និងមែក ចាក់ស្រែះគ្នាដោយប្រការទាំងពួង ទាញមក មិនអាចលើកឡើង យ៉ាងណា ទ្រង់ត្រូវតណ្ហារឹតរុំនៅខាងក្នុង និងខាងក្រៅ ជាអ្នកចាក់ស្រែះជាប់ក្នុងតណ្ហានោះ ក៏យ៉ាងនោះដែរ ទំពាំង

ឫស្សីនេះ សូម្បីនៅត្រង់កណ្ដាលគុម្ពឫស្សីនោះ តែព្រោះមែកមិនកើត ទើបមិនជាប់នឹងអ្វីមួយឡើយ បុគ្គលណាមួយ ក៏អាចកាត់ចុង ឬគល់ លើកឡើងបាន យ៉ាងណា ពួកអាត្មាមិនជាប់ចំពាក់ក្នុងទីទាំងពួង ត្រាច់ទៅសព្វទិស ក៏យ៉ាងនោះដែរ ហើយចូលចតុត្ថជ្ឈានក្នុងមួយរំពេចនោះឯង កាលព្រះរាជាទ្រង់កំពុងទត ក៏ហោះទៅកាន់ញកភ្នំនន្ទមូលកៈ ។

បន្ទាប់អំពីនោះ ព្រះរាជាទ្រង់ព្រះតម្រិះថា ក្នុងកាលណាហ្ន៎ សូម្បីអាត្មាអញ ក៏គប្បីជាអ្នកមិនជាប់ចំពាក់យ៉ាងនេះ ប្រថាប់គង់ក្នុងទីនោះឯង ទ្រង់ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ កាលត្រូវសួរដល់កម្មដ្ឋានដោយន័យមុន ទើបត្រាស់គាថានេះថា

**វំសោ វិសាលោវ យថា វិសត្តោ**
**បុត្តេសុ ទារេសុ ច យា អបេក្ខា**
**វំសក្កឡីរោវ អសជ្ជមានោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

សេចក្ដីស្រឡាញ់ ក្នុងបុត្តនិងភរិយា ដូចជាឫស្សីមាន
មែកចាក់កណ្ដាញ់ បុគ្គល កាលមិនជាប់ចំពាក់ ដូចជា
ទំពាំងឫស្សី គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

ឫស្សី ឈ្មោះថា **វំស** ក្នុងគាថានេះ ។ បទថា **វិសាលោ** បានដល់ ផ្សាយចេញទៅ ។ វ អក្ខរៈ មានអត្ថថា ឃាត់នូវអត្ថដទៃ ។

ម្យ៉ាងទៀត រ អក្ខរៈនេះ គឺ ឃរ អក្ខរៈ ។ ក្នុងទីនេះ ឃ អក្ខរៈ បាត់ទៅដោយអំណាចសន្ធិ ឃ អក្ខរៈនោះ ភ្ជាប់ជាមួយបទខាងក្រោយ ។ ខ្ញុំនឹងអធិប្បាយសេចក្ដីនោះ ខាងក្រោយ ។ បទថា **យថា** ប្រើក្នុងការប្រៀបធៀប ។ បទថា **វិសត្តោ** បានដល់ ជាប់ចាក់ស្រែះគ្នា ។ បទថា **បុត្តេសុ ទារេសុ ច** បានដល់ ក្នុងកូនប្រុស កូនស្រី និងភរិយា ។ បទថា **យា អបេក្ខា** បានដល់ ចំណង់ណា គឺសេចក្ដីស្រឡាញ់ឯណា ។ បទថា **វំសក្កឡីរោវ អសជ្ជមានោ** សេចក្ដីថា មិនជាប់ដូចទំពាំងឫស្សី ។ លោកអធិប្បាយដូចម្ដេច ។ លោកអធិប្បាយថា ឫស្សីផ្សាយទៅ រមែងជារបស់ចាក់ស្រែះគ្នាទាំងអស់ យ៉ាងណា ការជាប់ចំពាក់ក្នុងបុត្តធីតានិងភរិយានោះ ក៏យ៉ាងនោះ ឈ្មោះថាជាប់ចំពាក់ ព្រោះចាក់ស្រែះដោយវត្ថុទាំងពួងនោះ ។ អាត្មានោះ មានការជាប់ចំពាក់ ដោយការជាប់ចំពាក់នោះ ដូចឫស្សីដែលផ្សាយទៅដូច្នោះ ព្រោះហេតុនោះ អាត្មាឃើញទោសក្នុងការជាប់ចំពាក់យ៉ាងនេះ ទើបកាត់នូវការជាប់ចំពាក់នោះ ដោយមគ្គញ្ញាណ មិនជាប់ចំពាក់ដោយតណ្ហា មានះ ទិដ្ឋិ ក្នុងអារម្មណ៍ មានរូបជាដើម ក្នុងវត្ថុដែលគួរប្រាថ្នា មានលាភជាដើម ឬក្នុងភព មានកាមភពជាដើម ដូចទំពាំងនេះ ទើបសម្រេចបច្ចេកពោធិញ្ញាណ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យមុននោះឯង ។

វិសក្កឡីរគាថាទី ៤ ចប់

# មិគោអរញ្ញគាថា

បទថា **មិគោ អរញ្ញម្ហិ** ដូច្នេះ តើមានហេតុកើតដូចម្ដេច ។

បានឮថា ភិក្ខុមួយរូប ជាព្រះយោគាវចរក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថា កស្សបៈ ធ្វើកាលកិរិយាហើយ ទៅកើតក្នុងត្រកូលសេដ្ឋីដែលស្ដុកស្ដម្ភ មានទ្រព្យច្រើន មានភោគៈច្រើន ក្នុងនគរពារាណសី ។ សេដ្ឋីបុត្តនោះ ជាបុគ្គលមានរាគៈច្រើន ព្រោះហេតុនោះទើបប្រព្រឹត្តខុសក្នុងភរិយាអ្នកដទៃ ធ្វើកាលកិរិយាក្នុងជាតិនោះហើយកើតក្នុងនរក ឆេះក្នុងនរកនោះហើយ បដិសន្ធិជាស្រីក្នុងផ្ទៃរបស់ភរិយាសេដ្ឋីដោយសេសសល់ផលកម្ម ។ រាងកាយរបស់សត្វទាំងឡាយដែលមកអំពីនរក រមែងជារបស់ក្ដៅ ព្រោះហេតុនោះ ភរិយាសេដ្ឋីទ្រទ្រង់នូវគភ៌នោះ ដោយផ្ទៃដែលក្ដៅដ៏លំបាកក្រៃលែង បានប្រសូតទារិកាតាមកាល ។

ចាប់តាំងអំពីថ្ងៃកើតហើយ នាងជាទីស្អប់ខ្ពើមរបស់មាតាបិតា និងពួកបរិជនដ៏សេស ។ លុះចម្រើនវ័យហើយ មាតាបិតាឲ្យទៅក្នុងត្រកូលណា ក៏ជាទីស្អប់ខ្ពើមរបស់ស្វាមី ឪពុកក្មេកម្ដាយក្មេកក្នុងត្រកូលនោះ ។ លំដាប់នោះ ពួកជនប្រកាសនក្ខត្តឫក្ស សេដ្ឋីបុត្ត កាលមិនប្រាថ្នាដើម្បីនឹងលេងជាមួយសេដ្ឋីធីតា ទើបនាំស្រីពេស្យាមកដើម្បីលេង ។ នាង

បានស្តាប់អំពីសម្នាក់របស់ទាសីទាំងឡាយ ទើបចូលទៅរកសេដ្ឋីបុត្ត ពោលរៀបរាប់ដោយប្រការផ្សេង ៗ ថា បពិត្រអយ្យបុត្ត ធម្មតាស្ត្រី ទោះបីជាប្អូនស្រីរបស់ព្រះរាជា ១០ អង្គក្តី ជាធីតារបស់ស្តេចចក្កពត្តិក្តី សូម្បីដូច្នោះ ក៏ជាអ្នកធ្វើការបម្រើស្វាមី ។ កាលស្វាមីមិនចរចាជាមួយ ក៏សោយទុក្ខដូចត្រូវលើកឡើងកាន់លំពែង ។ បើខ្ញុំគួរដល់ការអនុគ្រោះ គប្បីអនុគ្រោះផងចុះ បើមិនគួរដល់ការអនុគ្រោះទេ ក៏គប្បីបោះបង់ ខ្ញុំនឹងទៅកាន់ត្រកូលញាតិរបស់ខ្លួនវិញ ។

សេដ្ឋីបុត្តពោលថា ណ្ហើយចុះ នាងដំចម្រើន នាងកុំសុបសៅឡើយ ចូរត្រៀមការលេង ពួកយើងនឹងលេងនក្ខត្តឫក្ស ។ សេដ្ឋីធីតាកើតឧស្សាហៈ ដោយហេតុត្រឹមតែការប្រាស្រ័យមានប្រមាណប៉ុណ្ណោះ គិតថា ស្អែកនេះ អញនឹងលេងនក្ខត្តឫក្ស ទើបរៀបចំរបស់ទំពានិងរបស់បរិភោគជាច្រើន ។ ក្នុងថ្ងៃទី ២ សេដ្ឋីបុត្តមិនប្រាប់ ហើយទៅក្នុងទីដែលមានការលេង ។ នាងគិតថា ស្វាមីនឹងនាំអញទៅក្នុងកាលឥឡូវនេះ ស្វាមីនឹងនាំអញទៅក្នុងកាលឥឡូវនេះ ។ នាងទន្ទឹងមើលផ្លូវ ឃើញថ្ងៃខ្ពស់ហើយ ទើបបញ្ជូនមនុស្សទាំងឡាយឲ្យទៅតាម មនុស្សទាំងនោះ មកប្រាប់ថា សេដ្ឋីបុត្តទៅហើយ ទើបនាងកាន់យករបស់ទំពានិងរបស់បរិភោគដែលត្រៀមទាំងអស់នោះ ឡើងកាន់យាន ប្រារព្ធដើម្បីទៅកាន់ឧទ្យាន ។

លំដាប់នោះ **ព្រះបច្ចេកសម្ពុទ្ធ** អាស្រ័យនៅត្រង់ញកភ្នំនន្ទមូលកៈ ចេញអំពីនិរោធក្នុងថ្ងៃទី ៧ លុបមុខត្រង់អនោតត្តស្រះ ទំពាឈើស្ទន់ឈ្មោះនាគលតា ពិចារណាថា ថ្ងៃនេះ អញនឹងត្រាច់ទៅបិណ្ឌបាតក្នុងទីណាហ្ន៎ ឃើញសេដ្ឋីធីតានោះ ក៏ដឹងថា សេដ្ឋីធីតានឹងធ្វើសក្ការៈដល់អាត្មាអញ កម្មនោះ នឹងដល់នូវការអស់ទៅ ឈរលើផ្ទាំងមនោសិលាទំហំ ៦០ យោជន៍ ក្បែរញកភ្នំនោះ ស្លៀកដណ្តប់ហើយកាន់បាត្រនិងចីវរ ចូលឈានដែលមានអភិញ្ញាជាបាទ ហោះចុះមក បែរមុខប្រាសផ្លូវជាមួយសេដ្ឋីធីតានោះ ទៅកាន់នគរពារាណសី ។ ទាសីទាំងឡាយឃើញព្រះបច្ចេកពុទ្ធនោះហើយ ប្រាប់ដល់សេដ្ឋីធីតា ។ នាងឃើញព្រះបច្ចេកសម្ពុទ្ធនោះហើយ ក៏ចុះអំពីយាន ថ្វាយបង្គំដោយគោរពទទួលបាត្រមក ដាក់ឲ្យពេញដោយខាទនីយភោជនីយាហារដែលដល់ព្រមដោយរសទាំងពួង បិទដោយផ្កាឈូក ធ្វើផ្កាឈូកទុកខាងក្រោមបាត្រ កាន់បាច់ផ្កាឈូកចូលទៅរកព្រះបច្ចេកពុទ្ធ ប្រគេនបាត្រត្រង់ដៃរបស់លោក ថ្វាយបង្គំហើយ កាន់យកផ្កាឈូក តាំងសេចក្តីប្រាថ្នាថា

បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំកើតក្នុងទីណា ៗ សូមឲ្យជាទីស្រឡាញ់ជាទីពេញចិត្តរបស់មហាជនក្នុងទីនោះៗ ដូចផ្កាឈូកនេះចុះ ។

កាលតាំងសេចក្តីប្រាថ្នាដូច្នេះហើយ ទើបតាំងសេចក្តីប្រាថ្នាទី ២ ថា

បពិត្រលោកម្ចាស់ដ៏ចម្រើន ការនៅក្នុងគភ៌ជាទុក្ខ សូមបដិសន្ធិ

គប្បីមានក្នុងផ្កាឈូកប៉ុណ្ណោះ មិនគប្បីអាស្រ័យគភ៌ឡើយ ។

ហើយតាំងសេចក្តីប្រាថ្នាទី ៣ ថា

បពិត្រលោកម្ចាស់ដ៏ចម្រើន មាតុគ្រាម មហាជនគប្បីរង្កៀស សូម្បីធីតារបស់ស្តេចចក្កពត្តិ ក៏នៅក្នុងអំណាចបុរស ព្រោះហេតុនោះ ខ្ញុំសូមកុំជាស្ត្រី គប្បីបានជាបុរសចុះ ។

តាំងសេចក្តីប្រាថ្នាទី ៤ ថា

បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំគប្បីឈានកន្លងនូវសង្សារទុក្ខនេះ សូមសម្រេចនូវព្រះនិព្វានដែលប្រាសចាកការស្លាប់ ដែលលោកម្ចាស់បានសម្រេចហើយក្នុងទីបំផុតចុះ ។

កាលធ្វើសេចក្តីប្រាថ្នា ៤ យ៉ាងនេះហើយ កាន់យកបាច់ផ្កាឈូកនោះ បូជាព្រះបច្ចេកពុទ្ធ បានថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ( គឺការតាំងទុកអវយវៈ ៥ គឺក្បាល ១ កែងដៃ ២ ជង្គង់ ២ ) ហើយធ្វើសេចក្តីប្រាថ្នាទី ៥ ថា

សូមឲ្យខ្ញុំមានក្លិននិងពណ៌សម្បុរ ដូចគ្នានឹងផ្កាឈូកនេះចុះ ។

លំដាប់នោះ ព្រះបច្ចេកពុទ្ធទទួលបាត្រនិងផ្កាហើយ ឈរក្នុងអាកាស ធ្វើអនុមោទនាដល់សេដ្ឋីធីតាដោយគាថានេះថា

**ឥច្ឆិតំ បត្ថិតំ តុយ្ហំ ខិប្បមេវ សមិជ្ឈតុ**

**សព្វេ បូរេន្តុ សង្កប្បា ចន្ទោ បន្នរសោ យថា ។**

*សូមវត្ថុដែលត្រូវការ វត្ថុដែលប្រាថ្នា ចូរសម្រេចដល់អ្នក ដោយឆាប់រួសរាន់ចុះ សូមការត្រិះរិះទាំងពួង ចូរពេញ ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត ។*

ហើយអធិដ្ឋានថា សូមសេដ្ឋីធីតាឃើញអាត្មាអញដែលកំពុងទៅចុះ ហើយទៅកាន់ញកភ្នំនន្ទមូលកៈ ។ បីតិយ៉ាងខ្លាំង កើតហើយដល់សេដ្ឋីធីតា ព្រោះឃើញព្រះបច្ចេកពុទ្ធអង្គនោះ ។ អកុសលកម្មដែលធ្វើទុកក្នុងចន្លោះនៃភព ក៏អស់ទៅ ព្រោះមិនមានឱកាស នាងជាអ្នកបរិសុទ្ធ ដូចភាជនៈមាសដែលខាត់ដោយម្សៅអម្ពិលដូច្នោះ ។ មួយរំពេចនោះឯង ជនទាំងអស់ក្នុងត្រកូលស្វាមី និងត្រកូលញាតិទាំងពួង ក៏ត្រេកអរចំពោះនាង នាំគ្នាគិតថា ពួកយើងនឹងធ្វើអ្វី ហើយបញ្ជូនពាក្យដែលជាទីស្រឡាញ់ និងគ្រឿងបណ្ណាការមកឲ្យ ។ សេដ្ឋីបុត្តក៏បញ្ជូនមនុស្សទាំងឡាយទៅថា ពួកអ្នក ចូរនាំសេដ្ឋីធីតាមកកាន់ឧទ្យានឲ្យឆាប់ យើងនឹករឭក ។ ចាប់តាំងអំពីនោះ ក៏ស្រឡាញ់ថ្និតថ្នមនាងដូចលម្អិតខ្លឹមចន្ទន៍ ដែលលាបត្រង់ទ្រូង ដូចមុក្តាហារដែលសំយុងទុក និងដូចកម្រងផ្កា ។ នាងសោយឥស្សរិយសុខនិងភោគសុខដរាបដល់អស់អាយុ ស្លាប់ទៅកើតក្នុងផ្កាឈូកនាទេវលោក ដោយភាពជាបុរស ។ ទេវបុត្តនោះ កាលនឹងទៅ ក៏ទៅលើត្របកផ្កាឈូកប៉ុណ្ណោះ កាលនឹងឈរក្តី អង្គុយក្តី ដេកក្តី ក៏ឈរ អង្គុយ ដេកលើត្របកផ្កាឈូកប៉ុណ្ណោះ ទើបទេវតាទាំងឡាយដាក់ឈ្មោះ

ទេវបុត្តនោះថា មហាបទុមទេវបុត្ត ។ ទេវបុត្តនោះ អន្ទោលទៅមកក្នុងទេវលោក ៦ ជាន់ប៉ុណ្ណោះ ដោយអានុភាពនោះ ដោយប្រការដូច្នេះ ។

សម័យនោះ ព្រះបាទពារាណសីទ្រង់មានស្រ្តី ២០ ពាន់នាក់ ព្រះរាជាទ្រង់មិនបានព្រះរាជឱរសក្នុងផ្ទៃនៃស្រ្តី សូម្បីតែម្នាក់ ។ អាមាត្យទាំងឡាយក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាបថា បពិត្រព្រះសម្មតិទេព សូមទ្រង់ប្រាថ្នាព្រះរាជឱរសដែលគប្បីបន្តរាជវង្ស កាលមិនមានព្រះរាជឱរសដែលកើតអំពីព្រះអង្គ សូម្បីព្រះរាជឱរសដែលកើតក្នុងខេត្ត ក៏អាចបន្តរាជវង្សបាន ។ ព្រះរាជាទ្រង់ឲ្យស្រីស្នំទាំងឡាយ ប្រព្រឹត្តជាមួយបុរសដទៃ បានតាមគាប់ចិត្តថា វៀរអគ្គមហេសី ពួកនាងដ៏សេស ចូរធ្វើជាស្រ្តីរបាំដោយធម៌អស់ ៧ ថ្ងៃ ។ សូម្បីយ៉ាងនោះ ក៏មិនបានព្រះរាជបុត្ត អាមាត្យទាំងឡាយក្រាបទូលទៀតថា បពិត្រមហារាជ ធម្មតាព្រះមហេសីមានបុណ្យ និងមានបញ្ញាប្រសើរជាងស្រ្តីទាំងពួង បើដូច្នោះ ទ្រង់គប្បីបានព្រះរាជឱរសក្នុងគភ៌របស់ព្រះមហេសីនោះ ។ ព្រះរាជាត្រាស់ប្រាប់សេចក្តីនោះ ដល់មហេសី ។ ព្រះនាងក្រាបទូលថា ពិតហើយ មហារាជ ស្រ្តីណា មានប្រក្រតីពោលពាក្យពិត រក្សាសីល ស្រ្តីនោះ គប្បីបានបុត្ត ស្រ្តីដែលវៀរចាកហិរិនិងឱត្តប្បៈហើយ បុត្តនឹងមានអំពីណា ។ ព្រះនាងឡើងកាន់ប្រាសាទ សមាទានសីល ៥ ជម្រះសីលឲ្យបរិសុទ្ធរឿយៗ ។ កាលព្រះរាជធីតាអ្នកមានសីល ជម្រះសីល ៥ ឲ្យបរិសុទ្ធហើយ គ្រាន់តែ

មានព្រះហឫទ័យប្រាថ្នាឲ្យព្រះរាជឱរសកើតឡើង អាសនៈរបស់សក្កទេវរាជ ក៏កម្រើកញាប់ញ័រ ។

លំដាប់នោះ សក្កទេវរាជទ្រង់ពិចារណា ជ្រាបសេចក្ដីនោះ ទ្រង់ព្រះតម្រិះថា អញនឹងឲ្យពរគឺបុត្ត ដល់ព្រះរាជធីតាអ្នកមានសីល ដូច្នេះហើយ មកតាមអាកាស ប្រថាប់ឈរត្រង់ព្រះកក្រ្តរបស់ព្រះទេវី ហើយត្រាស់ថា នែព្រះទេវី ព្រះនាងប្រាថ្នាអ្វី ។

ព្រះទេវីក្រាបទូលថា បពិត្រមហារាជ ខ្ញុំម្ចាស់ប្រាថ្នាបុត្ត ។

សក្កទេវរាជត្រាស់ថា ព្រះទេវី យើងនឹងឲ្យបុត្តដល់ព្រះនាង សូមព្រះនាងកុំគិតឡើយ ហើយយាងទៅកាន់ទេវលោកវិញ ពិចារណាថា ក្នុងទេវលោក ទេវបុត្តដែលអស់អាយុមានឬហ្ន៎ ទ្រង់ជ្រាបថា មហាបទុមទេវបុត្តនេះ ចុតិចាកទេវលោកនេះ ដើម្បីកើតក្នុងទេវលោកជាន់លើ ទ្រង់យាងទៅកាន់វិមានរបស់មហាបទុមទេវបុត្តនោះ ត្រាស់សូមថា នែបា មហាបទុម ចូរបាទៅកាន់មនុស្សលោក ។

ទេវបុត្តនោះក្រាបទូលថា បពិត្រមហារាជ ទ្រង់កុំត្រាស់យ៉ាងនេះឡើយ មនុស្សលោកគួរឲ្យខ្ពើម ។ សក្កទេវរាជត្រាស់ថា នែបា អ្នកធ្វើបុណ្យទុកក្នុងមនុស្សលោកហើយ ទើបកើតក្នុងទេវលោកនេះ អ្នកនៅក្នុងមនុស្សលោកប៉ុណ្ណោះ ទើបបំពេញបារមីទាំងឡាយឲ្យពេញបរិបូណ៌បាន នែបា ចូរទៅចុះ ។

មហាបទុមទេវបុត្តពោលថា បពិត្រមហារាជ ការនៅក្នុងគភ៌ជាទុក្ខ ទូលព្រះបង្គំមិនអាចនៅក្នុងគភ៌នោះ ។

សក្កទេវរាជត្រាស់ថា ម្នាលអ្នកដ៏ចម្រើន ការនៅក្នុងផ្ទៃនៃមាតារបស់អ្នក មិនមានទេ ដ្បិតថា អ្នកបានធ្វើកម្មដោយប្រការដែលខ្លួននឹងកើតក្នុងគភ៌ ( ត្របក ) ផ្កាឈូកប៉ុណ្ណោះ ទៅចុះបា ។ ទេវបុត្តនោះកាលត្រូវសក្កទេវរាជត្រាស់រឿយ ៗ ក៏ព្រមទទួលពាក្យអារាធនា ។

លំដាប់នោះ មហាបទុមទេវបុត្តឃ្លាតចាកទេវលោក កើតក្នុងផ្កាឈូក ក្នុងស្រះបោក្ខរណី ដែលដេរដាសដោយផ្ទាំងសិលា ក្នុងព្រះរាជឧទ្យានរបស់ព្រះបាទពារាណសី ។ ក្នុងរាត្រីនោះ ព្រះមហេសីព្រះនាងព្រះសុបិនក្នុងសម័យទៀបភ្លឺថា ហាក់បីដូចមានស្ត្រី ២ ម៉ឺននាក់ ចោមរោមព្រះនាង យាងទៅកាន់ព្រះរាជឧទ្យាន ហើយបានព្រះឱរសក្នុងផ្កាឈូកនាស្រះបោក្ខរណីដែលដេរដាសដោយផ្ទាំងសិលា ។ ព្រះនាងទ្រង់រក្សាសីលក្នុងរាត្រី វេលាទៀបភ្លឺ យាងទៅកាន់ព្រះរាជឧទ្យាននោះ ឃើញផ្កាឈូកមួយ ផ្កាឈូកនោះ នៅមិនឆ្ងាយអំពីច្រាំង ក្នុងទឹកមិនជ្រៅដំណាលគ្នានឹងការឃើញនោះឯង សេចក្តីស្រឡាញ់ដូចបុត្ត ក៏កើតឡើងក្នុងផ្កាឈូកនោះ ។ ព្រះនាងយាងចូលទៅតាមទំនើងព្រះអង្គឯង ចាប់ផ្កាឈូកនោះ គ្រាន់តែព្រះនាងពាល់ត្រូវប៉ុណ្ណោះ ត្របកផ្កាឈូកទាំងឡាយក៏រីក ។ ព្រះនាងទតឃើញទារកដូចបដិមាមាស នៅក្នុងផ្កាឈូកនោះ

កាលព្រះនាងទតឃើញហើយ ក៏បន្ទឺព្រះសូរសៀងថា យើងបានបុត្ត ហើយ ។ មហាជនក៏បន្ទឺសាធុការរាប់ពាន់ ។ ព្រះនាងក៏បញ្ជូនដំណឹង ទៅថ្វាយព្រះរាជា ។ ព្រះរាជាទ្រង់ស្តាប់ហើយត្រាស់សួរថា បានបុត្តក្នុង ទីណា ។ កាលទ្រង់បានស្តាប់រឿងដែលបានបុត្តហើយ ទើបត្រាស់ថា ក្នុងឧទ្យាន និងក្នុងផ្កាឈូក នាស្រះបោក្ខរណី ដែលជាខេត្តរបស់យើង ព្រោះហេតុនោះ បុត្តនេះ ឈ្មោះថា បុត្តកើតក្នុងខេត្ត ព្រោះកើតក្នុងខេត្ត របស់យើង ។ ទ្រង់ត្រាស់ឲ្យយាងចូលកាន់ព្រះនគរ ឲ្យស្ត្រី ២ ម៉ឺននាក់ ធ្វើនាទីជាមេដោះ ។ ស្ត្រីណាមួយដឹងថា ព្រះរាជកុមារគាប់ចិត្តវត្ថុណា ឲ្យព្រះរាជកុមារសោយរបស់ទំពាដែលទ្រង់ចង់សោយ ស្ត្រីនោះ នឹងបាន ទ្រព្យ ១ ពាន់ ។ អ្នកក្រុងពារាណសីទាំងមូល រំជើបរំជួល ជនទាំងពួង បញ្ជូនបណ្ណាការរាប់ពាន់ទៅថ្វាយព្រះរាជកុមារ ។ ព្រះរាជកុមារដែល មហាជននាំវត្ថុនោះ ៗ មកទូលថា សូមទ្រង់ទំពារបស់នេះ សូមទ្រង់ សោយរបស់នេះ ក៏ធុញទ្រាន់ក្នុងភោជន យាងទៅកាន់ខ្លោងទ្វារ លេង ដុំល័ក្ត ។

ក្នុងកាលនោះ ព្រះបច្ចេកពុទ្ធមួយអង្គ អាស្រ័យនគរពារាណសី នៅត្រង់ព្រៃឥសិបតនៈ ក្រោកឡើងតាមកាល ធ្វើកិច្ចទាំងពួង មាន សេនាសនវត្ត បរិកម្មរាងកាយនិងមនសិការជាដើម ចេញអំពីទីពួនសម្ងំ គិតថា ថ្ងៃនេះ នឹងទទួលភិក្ខាក្នុងទីណា ឃើញសម្បត្តិរបស់ព្រះរាជកុមារ

នោះហើយ ពិចារណាថា ក្នុងកាលមុន ព្រះរាជកុមារនេះ ទ្រង់ធ្វើកម្ម អ្វី ដឹងថា ព្រះរាជកុមារនេះ បានប្រគេនបិណ្ឌបាតដល់ព្រះបច្ចេកពុទ្ធ ដូចអាត្មាអញ ហើយតាំងសេចក្តីប្រាថ្នា ៤ ប្រការ ក្នុងសេចក្តីប្រាថ្នា ៤ ប្រការនោះ ៣ ប្រការសម្រេចហើយ មួយប្រការនៅមិនទាន់សម្រេច អាត្មាអញនឹងឲ្យអារម្មណ៍ដោយឧបាយដល់កុមារនោះ ដូច្នេះហើយ ទៅកាន់សម្នាក់របស់ព្រះរាជកុមារដោយភិក្ខាចារ ។ ព្រះរាជកុមារឃើញព្រះបច្ចេកពុទ្ធនោះហើយ ត្រាស់ថា បពិត្រសមណៈ លោកម្ចាស់កុំនិមន្តមកក្នុងទីនេះ ពិតមែន មនុស្សទាំងនោះ គប្បីពោលនឹងលោកម្ចាស់ថា ចូរទំពារបស់នេះ ចូរឆាន់របស់នេះ ។ ព្រះបច្ចេកពុទ្ធនោះ ក៏ត្រឡប់អំពីទីនោះ ដោយពាក្យត្រឹមតែមួយម៉ាត់ប៉ុណ្ណោះ ហើយចូលទៅកាន់សេនាសនៈរបស់ខ្លួន ។ ឯព្រះរាជកុមារត្រាស់នឹងបរិជនថា សមណៈនេះ គ្រាន់តែយើងហាមាត់ពោល ក៏ត្រឡប់ទៅវិញ លោកក្រោធនឹងយើងឬ ។

ពួកបរិជនទាំងនោះ ក្រាបទូលថា បពិត្រព្រះសម្មតិទេព ធម្មតាបព្វជិតទាំងឡាយ មិនមែនជាអ្នកនាំមុខដោយសេចក្តីក្រោធ រមែងជាអ្នកនៅដោយបច្ច័យដែលអ្នកដទៃឲ្យដោយចិត្តជ្រះថ្លា ។ ព្រះរាជកុមារទ្រង់ព្រះតម្រិះថា សមណៈនេះ គង់ជាអ្នកខឹងនឹងអញហើយ អញនឹងសូមឲ្យលោកអត់ទោស ទើបក្រាបទូលសេចក្តីនោះ ដល់ព្រះមាតា និង

ព្រះបិតា ហើយឡើងដំរី យាងទៅកាន់ព្រៃឥសិបតនៈ ដោយអានុភាព របស់ព្រះរាជាដ៏ធំ កាលទតឃើញហ្វូងម្រឹគ ទើបត្រាស់សួរថា សត្វនេះ ឈ្មោះអ្វី ។ បរិជនក្រាបទូលថា បពិត្រព្រះអង្គ នុ៎ះឈ្មោះថា ម្រឹគ ។

ព្រះរាជកុមារត្រាស់សួរថា ម្រឹគទាំងនោះ មានគេបដិបត្តិដោយ ពោលថា ចូរទំពារបស់នេះ ចូរស៊ីរបស់នេះ ចូរលិឍភក្សរបស់នេះ ( ដែរ ឬទេ ) ។ បរិជនក្រាបទូលថា មិនមានទេ ព្រះអង្គ ទីណាមានស្មៅនិង ទឹករកបានងាយ ម្រឹគទាំងឡាយក៏នៅក្នុងទីនោះ ។

ព្រះរាជកុមារទ្រង់ព្រះតម្រិះថា ម្រឹគទាំងនេះ កាលមិនមានអ្នក រក្សា បើប្រាថ្នាក្នុងទីណា រមែងនៅក្នុងទីនោះ ក្នុងកាលណាហ្ន៎ អាត្មាអញ គប្បីរស់នៅយ៉ាងនោះ ហើយទ្រង់កាន់យកម្រឹគនោះ ជាអារម្មណ៍ ។ ចំណែកព្រះបច្ចេកពុទ្ធ ជ្រាបការយាងមករបស់ព្រះរាជកុមារនោះហើយ បោសផ្លូវសម្រាប់ដើរទៅកាន់សេនាសនៈនិងទីចង្ក្រម ធ្វើឲ្យរលីង ហើយ ដើរចង្ក្រមមួយ ពីរ បី ជំហាន រួចបង្ហាញស្នាមជើង បោសឱកាស ( កន្លែង ) ដែលជាលំនៅក្នុងពេលថ្ងៃនិងបណ្ណសាលា ធ្វើឲ្យរលីង បង្ហាញស្នាមជើង ចូលទៅ តែមិនបង្ហាញស្នាមជើងចេញមក ហើយទៅក្នុងទីដទៃ ។ ព្រះរាជកុមារយាងទៅក្នុងទីនោះ ទ្រង់ឃើញប្រទេសនោះ ដែលបោស ស្អាតហើយ ទ្រង់ស្តាប់ពាក្យដែលបរិជន ក្រាបទូលហើយថា ប្រហែល ព្រះបច្ចេកពុទ្ធនោះនៅក្នុងទីនេះ ទើបត្រាស់ថា សមណៈនោះ ក្រោធ

អំពីព្រឹក ឥឡូវនេះ បើឃើញដំរីនិងសេះជាដើម ជាន់ក្នុងឱកាសរបស់ខ្លួន ដែលបោសហើយ ក៏គប្បីក្រោធក្រៃលែង ពួកអ្នក ចូរឈរក្នុងទីនេះប៉ុណ្ណោះ ដូច្នេះហើយ ចុះអំពីកដំរីមួយអង្គឯងប៉ុណ្ណោះ យាងទៅកាន់សេនាសនៈ ទតឃើញស្នាមដើងក្នុងឱកាស ដែលបោសល្អហើយតាមវត្ត (កិច្ចវត្ត) ជាធំ មានព្រះហឫទ័យជ្រះថ្លាថា សមណៈនេះ ចង្ក្រមនៅក្នុងទីនេះ គង់មិនគិតដល់ការជួញដូរជាដើម ប្រហែលជាគិតដល់ប្រយោជន៍របស់ខ្លួនប៉ុណ្ណោះ ដោយពិត ទើបទ្រង់ឡើងកាន់ទីចង្ក្រម កម្ចាត់វិតក្កៈដ៏គ្រោតគ្រាតឲ្យឃ្លាតឆ្ងាយ យាងទៅប្រថាប់គង់លើផ្ទាំងថ្ម មានអារម្មណ៍តែមួយ ហើយចូលកាន់បណ្ណសាលា ទ្រង់ចម្រើនវិបស្សនា សម្រេចបច្ចេកពោធិញ្ញាណ កាលបុរោហិតទូលសួរដល់កម្មដ្ឋានដោយន័យមុននោះឯង ប្រថាប់គង់ក្នុងអាកាស ត្រាស់ព្រះគាថានេះថា

**មិគោ អរញ្ញម្ហិ យថា អពទ្ធោ[១]**
**យេនិច្ឆកំ គច្ឆតិ គោចរាយ[២]**
**វិញ្ញូ នរោ សេរិតំ បេក្ខមានោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

ម្រឹគក្នុងព្រៃ (ជាសត្វ) មិនជាប់ចំណង ដើរទៅរក

១-អដ្ឋកថា ច្បាប់ឆដ្ឋសង្គាយនា ជា អពទ្ធោ ។ ២-អដ្ឋកថា ច្បាប់ឆដ្ឋសង្គាយនា ជា យេនិច្ឆកំ គច្ឆតិ គោចរាយ ។

*ចំណីតាមចំណង់ចិត្តបាន យ៉ាងណា វិញ្ញូជន កាលបើប្រាថ្នាសេរីភាព ( យ៉ាងនោះ ) គប្បីប្រព្រឹត្ត តែម្នាក់ឯង ដូចកុយរមាស ។*

*បណ្ដាបទទាំងនោះ បទថា* **មិគោ** *បានដល់ ម្រឹគ ២ ប្រភេទ គឺ* **ឯណីមិគោ** *ម្រឹគទ្រាយ ១* **បសទមិគោ** *ម្រឹគមានរោមដ៏វិចិត្រ ឬ ម្រឹគដ៏វិចិត្រ ( សត្វក្ដាន់ ) ១ ។ម្យ៉ាងទៀត ពាក្យថា* **មិគោ** *នេះ ជាឈ្មោះរបស់សត្វចតុប្បាទដែលនៅក្នុងព្រៃគ្រប់ប្រភេទ ។ តែក្នុងទីនេះ អាចារ្យពួកមួយ បំណងយកក្ដាន់ ។ បទថា* **អរញ្ញម្ហិ** *សេចក្ដីថា វៀរស្រុក និងឧបចារៈរបស់ស្រុក ក្រៅអំពីនោះ ចាត់ជាព្រៃ តែក្នុងទីនេះ បំណងយកឧទ្យាន ព្រោះហេតុនោះ ទើបមានន័យថា ក្នុងឧទ្យាន ។ សព្ទថា* **យថា** *ប្រើក្នុងអត្ថប្រៀបធៀប ។ បទថា* **អពទ្ធោ** *ប្រែថា មិនត្រូវចងដោយចំណង គឺខ្សែជាដើម ។ ដោយពាក្យនេះ លោកសម្ដែងនូវការត្រាច់ទៅដែលត្រូវជឿទុកចិត្ត គឺការត្រាច់ទៅដោយឥតមានភ័យ ។ បទថា* **យេនិច្ឆកំ គច្ឆតិ គោចរាយ** *សេចក្ដីថា ទៅរកចំណីដោយចំណែកនៃទិសដែលខ្លួនប្រាថ្នាចង់ទៅ ។*

*សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា*

*ម្នាលភិក្ខុទាំងឡាយ ម្រឹគព្រៃ កាលត្រាច់ទៅក្នុងព្រៃរបោះព្រៃស្បាត រមែងដើរទៅឥតរង្កៀស ឈប់ឥតរង្កៀស អង្គុយ*

ឥតរង្វើស សម្រេចការដេកឥតរង្វើស ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ម្រឹគនោះ នៅក្នុងទីមិនមែនជាគន្លងរបស់ព្រាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកធម៌ទាំងឡាយ ជាអកុសលហើយ ចូលបឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខដែលកើតអំពីវិវេក ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតពោលថា បានធ្វើមារឲ្យងងឹត សម្លាប់មារមិនឲ្យមានដានជើង ដល់នូវការមិនចួបប្រទះដោយភ្នែកមារ របស់មារលាមក[១] ។

បទថា **សេរិតំ** បានដល់ ការប្រព្រឹត្ត ការពេញចិត្ត ឬមិនទាក់ទងដោយអ្នកដទៃ លោកអធិប្បាយថា ម្រឹគមិនត្រូវចងទុកក្នុងព្រៃរមែងទៅរកចំណីតាមប្រាថ្នា យ៉ាងណា កាលណាហ្ន៎ អាត្មាអញគប្បីកាត់បំណង គឺតណ្ហា ត្រាច់ទៅ យ៉ាងនោះ ហេតុនោះ វិញ្ញូជន គឺបុគ្គលដែលជាបណ្ឌិត ប្រាថ្នាសេរីភាព គប្បីត្រាច់ទៅតែម្នាក់ឯង ដូច្នោះ ។

## មិគោអរញ្ញគាថាទី ៥ ចប់

---

១-បិ.៦៨ ទំ.២២៦ ឃ.២៤៨ ។

# អាមន្តនាគាថា

គាថាថា **អាមន្តនា ហោតិ** ដូច្នេះជាដើម មានហេតុកើតដូចម្តេច ។

បានឮថា អាមាត្យទាំងឡាយចូលទៅគាល់ក្នុងសម័យបម្រើធំរបស់ព្រះបាទពារាណសី ។ បណ្តាអាមាត្យទាំងនោះ អាមាត្យម្នាក់ក្រាបទូលថា បពិត្រព្រះទេវៈ មានវត្ថុដែលគួរស្តាប់ ហើយទូលឲ្យទ្រង់យាងទៅក្នុងចំណែកម្ខាង ព្រះរាជាទ្រង់ក្រោកចាកអាសនៈ ហើយយាងទៅ ។ អាមាត្យម្នាក់ទៀត ក្រាបទូលសូមឲ្យព្រះរាជាគង់ក្នុងទីបម្រើធំទៀត ។ អាមាត្យម្នាក់ទៀត ទូលសូមឲ្យគង់លើកដំរី អាមាត្យម្នាក់ទៀត ក្រាបទូលសូមឲ្យគង់លើខ្នងសេះ អាមាត្យម្នាក់ទៀត ក្រាបទូលសូមឲ្យគង់ក្នុងរថមាស អាមាត្យម្នាក់ទៀត ក្រាបទូលសូមឲ្យគង់ក្នុងវ យាងទៅកាន់ព្រះរាជឧទ្យាន ។ ព្រះរាជាចុះអំពីវនោះ យាងទៅ ។ អាមាត្យម្នាក់ទៀត ក្រាបទូលសូមឲ្យទ្រង់យាងទៅប្រពាសជនបទ ។ ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់អាមាត្យនោះ ទើបចុះអំពីកដំរី ហើយយាងទៅក្នុងទីមួយកន្លែង ។ កាលបើដូច្នោះ ទ្រង់នឿយណាយក្នុងពួកអាមាត្យទាំងនោះ ទើបទ្រង់បួស ។ អាមាត្យទាំងឡាយចង់បានភាពជាធំក្រៃលែង ។ បណ្តាអាមាត្យទាំងនោះ អាមាត្យម្នាក់ទៅក្រាបទូលព្រះរាជាថា បពិត្រ

មហារាជ សូមទ្រង់ប្រទានជនបទឈ្មោះនោះ ដល់ទូលព្រះបង្គំ ។

ព្រះរាជាទ្រង់ត្រាស់ថា បុគ្គលឈ្មោះនោះ បរិភោគ (គ្រប់គ្រង) ។

អាមាត្យនោះ មិនអើពើនឹងព្រះតម្រាស់របស់ព្រះរាជា ក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំនឹងទៅកាន់យកជនបទនោះគ្រប់គ្រង ហើយទៅកាន់ជនបទនោះ បង្កនូវជម្លោះ ។ ជនទាំង ២ នាំគ្នាមកកាន់សម្នាក់របស់ព្រះរាជាទៀត ហើយក្រាបទូលទោសនៃគ្នានឹងគ្នា ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អញមិនអាចឲ្យពួកអាមាត្យទាំងនេះត្រេកអរបាន ទ្រង់ឃើញទោសក្នុងសេចក្ដីលោភរបស់អាមាត្យទាំងនោះ ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ បានពោលឧទាននេះថា

អាមន្តនា ហោតិ សហាយមជ្ឈេ
វាសេ ឋានេ គមនេ ចារិកាយ
អនភិជ្ឈិតំ សេវិតំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ការហៅរក រមែងមាន ក្នុងកណ្ដាលនៃសម្លាញ់ គឺ
ក្នុងលំនៅ ក្នុងទីបម្រើ ក្នុងការដើរ ក្នុងការត្រាច់ចារិក
បុគ្គលកាលប្រាថ្នានូវសេរីភាព ដែលពួកជនពាលមិន
ប្រាថ្នា គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

សេចក្តីនៃគាថានេះថា ការប្រឹក្សាដោយប្រការនោះ ៗ ដោយន័យថា អ្នកចូរស្តាប់ពាក្យនេះរបស់ខ្ញុំ អ្នកចូរឲ្យវត្ថុនេះ ដល់ខ្ញុំជាដើម ក្នុងលំនៅ គឺទីសម្រាកពេលថ្ងៃ ក្នុងទីឈរ គឺការបម្រើធំ ក្នុងទីទៅ ទីទៅគឺឧទ្យាន ក្នុងទីត្រាច់ចារិក គឺទីត្រាច់ចារិកទៅក្នុងជនបទ រមែងមានដល់បុគ្គលដែលនៅក្នុងកណ្តាលនៃសម្លាញ់ ព្រោះហេតុនោះ អាត្មាភាពនឿយណាយក្នុងការប្រឹក្សា ក្នុងកណ្តាលនៃសម្លាញ់ទាំងនោះ កាលសម្លឹងឃើញបព្វជ្ជាដែលមានអានិសង្សច្រើន មានសេចក្តីសុខដោយចំណែកមួយ ដែលអរិយបុគ្គលសេពហើយ កាលបើដូច្នោះ ក៏ជាបព្វជ្ជាដែលពួកមនុស្សអាក្រក់ទាំងពួង ត្រូវសេចក្តីលោភគ្របសង្កត់ហើយ មិនត្រូវការ មិនប្រាថ្នា និងសម្លឹងការប្រព្រឹត្តតាមការពេញចិត្ត ដោយការមិនធ្លាក់ទៅក្នុងអំណាចរបស់បុគ្គលដទៃ និងដោយអំណាចនៃបុគ្គលដែលរស់នៅដោយធម៌ ដែលមនុស្សអាក្រក់មិនប្រាថ្នាហើយ ប្រារព្ធវិបស្សនា បានសម្រេចបច្ចេកសម្ពោធិញ្ញាណដោយលំដាប់ ។ ពាក្យដ៏សេស មានន័យដូចដែលពោលហើយនោះឯង ។

## អាមន្តនាគាថាទី ៦ ចប់

# **ចិញ្ចារតិគាថា**

*គាថាថា* **ចិញ្ចា រតី** *ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។*

*បានឮថា ក្នុងនគរពារាណសី មានព្រះរាជាព្រះនាមថា ឯកបុត្តក-ព្រហ្មទត្ត ។ ព្រះរាជាអង្គនោះ មានព្រះរាជឱរសតូចមួយអង្គ ជាទីស្រឡាញ់ពេញព្រះហឫទ័យស្មើដោយជីវិត ។ ព្រះរាជាទ្រង់នាំយកព្រះរាជឱរសតូចយាងទៅគ្រប់ឥរិយាបថ ។*

*ថ្ងៃមួយ ព្រះរាជាយាងទៅកាន់ព្រះរាជឧទ្យាន ទ្រង់យាងទៅដោយមិននាំព្រះរាជឱរសទៅផង ។ ឯព្រះរាជកុមារនោះ ក៏អស់ព្រះជន្មព្រោះព្យាធិដែលកើតឡើងក្នុងថ្ងៃនោះឯង អាមាត្យទាំងឡាយប្រឹក្សាគ្នាថា ហទយៈរបស់ព្រះរាជានឹងបែកសញ្ចែក ព្រោះសេចក្ដីស្រឡាញ់ក្នុងព្រះរាជឱរស ទើបមិនក្រាបទូលឲ្យទ្រង់ជ្រាប នាំគ្នាថ្វាយព្រះភ្លើងព្រះរាជកុមារនោះ ។ ព្រះរាជាទ្រង់ស្រវឹងទឹកច័ណ្ឌក្នុងព្រះរាជឧទ្យាន មិនបាននឹកដល់ព្រះរាជឱរស ក្នុងថ្ងៃទី ២ ក៏ដូចគ្នា ក្នុងពេលស្រង់និងក្នុងពេលសោយ ក៏មិនបានរឭកដល់ ។ លំដាប់នោះ ព្រះរាជាទ្រង់សោយហើយប្រថាប់គង់ ទ្រង់រឭកបាន ទើបត្រាស់ថា* **បុត្តំ មេ អានេថ** *ចូរនាំកូនរបស់យើងមក អាមាត្យទាំងឡាយក៏ក្រាបទូលរឿងនោះ ដល់ព្រះរាជាដោយពិធីដ៏សមគួរ ។ លំដាប់នោះ ព្រះរាជាត្រូវសេចក្ដីសោកគ្រប*

សង្កត់ ប្រថាប់គង់ប៉ុណ្ណោះ ទ្រង់ធ្វើព្រះហឫទ័យដោយឧបាយថា កាលវត្ថុនេះ មាន វត្ថុនេះ ក៏មាន ព្រោះវត្ថុនេះ កើត វត្ថុនេះ ក៏កើត ទ្រង់ពិចារណាបដិច្ចសមុប្បាទ ទាំងអនុលោម និងបដិលោម ដោយលំដាប់យ៉ាងនេះ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកសម្ពោធិញ្ញាណ ហើយត្រាស់គាថានេះថា

**ខិឌ្ឌា រតី ហោតិ សហាយមជ្ឈេ**
**បុត្តេសុ បេមំ វិបុលញ្ច ហោតិ**
**បិយវិប្បយោគំ វិជិគុច្ឆមានោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

ល្បែងនិងតម្រេក រមែងមានក្នុងកណ្តាលនៃសម្លាញ់
ទាំងសេចក្តីស្រឡាញ់ដ៏ធំទូលាយ រមែងមានក្នុងបុត្ត
ទាំងឡាយ បុគ្គលកាលខ្ពើមរអើម ចំពោះការព្រាត់
ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ គប្បីប្រព្រឹត្ត
តែម្នាក់ឯង ដូចកុយរមាស ។

ពាក្យដ៏សេស ដូចគ្នាតាមន័យដែលបានពោលហើយ ក្នុងសំសគ្គគាថានោះឯង វៀរតែការពណ៌នាគាថា ។

ឯការពណ៌នាគាថា មានសេចក្តីដូច្នេះថា ការលេង ឈ្មោះថា **ខិឌ្ឌា** ។ ការលេងនោះ មាន ២ យ៉ាង គឺលេងផ្លូវកាយ ១ លេងផ្លូវ

វាចា ១ ។ បណ្ដាការលេង ២ យ៉ាងនោះ ការលេងយ៉ាងនេះ គឺ លេងដំរីខ្លះ លេងសេះខ្លះ លេងរថខ្លះ លេងធ្នូខ្លះ លេងដាវខ្លះជាដើម ឈ្មោះថា លេងផ្លូវកាយ ។ ការលេងយ៉ាងនេះ គឺការច្រៀង ការ ពោលកំណាព្យ ឬពាក្យស្លោក ការលេងស្គរមាត់ជាដើម ឈ្មោះថា ការ លេងផ្លូវវាចា ។ ការត្រេកអរក្នុងកាមគុណ ៥ ឈ្មោះថា **រតិ** ។

បទថា **វិបុលំ** បានដល់ ត្រេកអរពេញអត្តភាព រហូតដល់ខួរក្នុង ឆ្អឹង ។ ពាក្យដ៏សេសប្រាកដច្បាស់ហើយ ។ សូម្បីវាចាប្រកបសេចក្ដីក្នុង គាថានេះ ក៏គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងសំសគ្គគាថា នោះឯង ។ រឿងទាំងអស់បន្ទាប់អំពីនេះទៅ ក៏ន័យនេះ ដូចគ្នា ។

**ខិឌ្ឌារតិគាថាទី ៧ ចប់**

# ចាតុទ្ទិសគាថា

*គាថាថា* **ចាតុទ្ទិសោ** *ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។*

*បានឮថា ក្នុងកាលមុនព្រះបច្ចេកពោធិសត្វ ៩ អង្គ បួសក្នុងសាសនារបស់ព្រះមានព្រះភាគកស្សបៈ បំពេញគតបច្ចាគតវត្តអស់ ២ ម៉ឺនឆ្នាំហើយ កើតក្នុងទេវលោក ចុតិចាកទេវលោកនោះហើយ បណ្ដាព្រះបច្ចេកពោធិសត្វទាំងនោះ ព្រះបច្ចេកពោធិសត្វអង្គធំបានជាព្រះបាទពារាណសី ព្រះបច្ចេកពោធិសត្វដ៏សេសបានជាបទេសរាជា ។ ព្រះរាជា ៨ អង្គនោះ រៀនកម្មដ្ឋានហើយ ទ្រង់លះរាជសម្បត្តិចេញបួស បានជា* **ព្រះបច្ចេកពុទ្ធ** *ដោយលំដាប់ ហើយនៅត្រង់ញកភ្នំនន្ទមូលកៈ ។ សម័យថ្ងៃមួយ ចេញចាកសមាបត្តិហើយ ពិចារណាដល់កម្ម និងសម្ពាញ់របស់ខ្លួន ដោយន័យដូចពោលហើយក្នុងវិសក្កទ្បីរគាថា ។ កាលដឹងហើយទើបរកឱកាសដើម្បីសម្ដែងអារម្មណ៍ ដល់ព្រះបាទពារាណសីដោយឧបាយ ។ ព្រះរាជានោះ ស្ដុតព្រះហឫទ័យក្នុងពេលយប់ អស់វារៈ ៣ ដង ទ្រង់ខ្លាច ទើបទ្រង់ស្រែកដោយសំឡេងខ្លាំង ទ្រង់ស្ទុះទៅកាន់ល្វែងធំ កាលត្រូវបុរោហិតដែលក្រោកឡើងអំពីព្រលឹម ក្រាបទូលសួរដល់ការផ្ទំជាសុខ ទើបត្រាស់ថា លោកអាចារ្យ យើងមានសេចក្ដីសុខអំពីណា ហើយទ្រង់ប្រាប់រឿងទាំងអស់នោះ ។ បុរោហិតគិតថា រោគនេះ បុគ្គលណាមួយ មិនអាចព្យាបាលដោយភេសជ្ជៈណាមួយ មានការដាក់ថ្នាំធ្វើ*

ឲ្យក្អួតជាដើម តែឧបាយសម្រាប់បរិភោគកើតឡើងដល់អញហើយ ទើបក្រាបទូលថា បពិត្រមហារាជ នេះជាបុព្វនិមិត្តនៃការវិនាសរាជសម្បត្តិ និងអន្តរាយនៃព្រះជន្ម ធ្វើឲ្យព្រះរាជាតក់ស្លុតខ្លាំងឡើង ហើយក្រាបទូលថា ដើម្បីឲ្យបុព្វនិមិត្តនេះ ស្ងប់ ទ្រង់គប្បីប្រទានដំរី សេះ និងរថជាដើម មានប្រមាណប៉ុណ្ណេះ ៗ មួយអន្លើដោយប្រាក់និងមាស ឲ្យជាទក្ខិណា បូជាយញ្ញ ដូច្នេះហើយ ចាត់ចែងការបូជាយញ្ញ ។

លំដាប់នោះ ព្រះបច្ចេកពុទ្ធទាំងឡាយ ឃើញសត្វមានជីវិតច្រើនពាន់ ដែលគេប្រមូលមកដើម្បីជាប្រយោជន៍ដល់យញ្ញ ទើបគិតថា កាលព្រះរាជាធ្វើកម្មនេះ ទ្រង់នឹងជាបុគ្គលដែលបុគ្គលណាមួយឲ្យត្រាស់ដឹងបានលំបាក ណ្ហើយចុះ យើងទាំងឡាយប្រញាប់ទៅគាល់ព្រះរាជានោះ ទើបនិមន្តមក ត្រាច់បិណ្ឌបាត បានទៅកាន់លានព្រះរាជវាំងតាមលំដាប់ ដោយន័យដូចពោលហើយក្នុងវិសក្កឡីរគាថា ។ ព្រះរាជាប្រថាប់ឈរត្រង់សីហបញ្ជរ ទតលានព្រះរាជវាំង បានឃើញព្រះបច្ចេកសម្ពុទ្ធទាំងនោះ ដំណាលគ្នានឹងការឃើញនោះឯង សេចក្តីស្រឡាញ់បានកើតឡើងដល់ព្រះអង្គ ។ លំដាប់នោះ ទើបត្រាស់ឲ្យនិមន្តព្រះបច្ចេកសម្ពុទ្ធទាំងនោះមក និមន្តឲ្យគង់លើអាសនៈដែលក្រាលទុកត្រង់រានហាល និមន្តឲ្យឆាន់ដោយគោរព ត្រាស់សួរព្រះបច្ចេកពុទ្ធដែលធ្វើភត្តកិច្ចស្រេចហើយថា លោកម្ចាស់ទាំងឡាយឈ្មោះអ្វី ។ ព្រះបច្ចេកពុទ្ធទាំងនោះ ឆ្លើយថា

បពិត្រមហារាជ ពួកអាត្មាឈ្មោះចាតុទ្ទិសៈ ។

ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ពាក្យថា ចាតុទ្ទិសៈនេះ មានន័យដូចម្ដេច ។ ព្រះបច្ចេកពុទ្ធតបថា បពិត្រមហារាជ ពួកអាត្មាមិនមានការខ្លាច ឬការតក់ស្លុតចិត្តក្នុងទីណា អំពីទីណាមួយក្នុងទិសទាំង ៤ ។

ព្រះរាជាសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះហេតុអ្វី ទើបការខ្លាច មិនមានដល់លោកម្ចាស់ទាំងឡាយ ។ ព្រះបច្ចេកសម្ពុទ្ធតបថា បពិត្រមហារាជ អាត្មាទាំងឡាយចម្រើនមេត្តា ចម្រើនករុណា ចម្រើនមុទិតា ចម្រើនឧបេក្ខា ដោយហេតុនោះ ទើបការខ្លាចនោះ មិនមានដល់អាត្មា ដូច្នេះហើយ ក្រោកចាកអាសនៈទៅកាន់លំនៅរបស់ខ្លួន ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា សមណៈទាំងនេះ ពោលថា មិនមានការខ្លាច ព្រោះចម្រើនមេត្តាជាដើម តែពួកព្រាហ្មណ៍សរសើរការសម្លាប់សត្វច្រើនពាន់ ពាក្យរបស់អ្នកណាហ្ន៎ ជាពាក្យពិត ទ្រង់ព្រះតម្រិះបន្តទៀតថា សមណៈទាំងឡាយលាងរបស់មិនស្អាត ដោយរបស់ស្អាត តែព្រាហ្មណ៍លាងរបស់មិនស្អាត ដោយរបស់មិនស្អាត បុគ្គលណាមួយមិនអាចលាងរបស់មិនស្អាត ដោយរបស់មិនស្អាតបានទេ ពាក្យរបស់បព្វជិតនោះឯង ជាពាក្យពិត ដូច្នេះហើយ ទ្រង់ចម្រើនព្រហ្មវិហារទាំង ៤ មានមេត្តាជាដើម ដោយន័យជាដើមថា **សព្វេ សត្តា សុខិតា ហោន្តុ** សូមសត្វទាំងឡាយទាំងពួងបាននូវសេចក្តីសុខចុះ ទ្រង់មានព្រះហឫទ័យ

ផ្សាយប្រយោជន៍ ទ្រង់ត្រាស់បង្គាប់អាមាត្យទាំងឡាយថា ពួកអ្នក ចូរលែងសត្វទាំងអស់ សត្វទាំងអស់ ចូរផឹកទឹកត្រជាក់ ចូរស៊ីស្មៅពណ៌ខៀវខ្យល់ត្រជាក់ ចូរបក់សត្វទាំងនោះ អាមាត្យទាំងនោះ បានធ្វើតាមព្រះរាជបញ្ជាសព្វប្រការ ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា អញផុតចាកបាបកម្មព្រោះពាក្យរបស់កល្យាណមិត្ត ប្រថាប់គង់ក្នុងទីនោះឯង ចម្រើនវិបស្សនាបានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ។ លុះដល់វេលាសោយព្រះក្រយាស្ងោយ ពួកអាមាត្យក្រាបទូលថា **កុញ្ច មហារាជ កាលោ** បពិត្រមហារាជ ដល់កាលហើយ សូមទ្រង់សោយ ។ ព្រះបច្ចេកពុទ្ធត្រាស់ពាក្យទាំងពួង ដោយន័យមុននោះឯងថា **ណាហំ រាជ** អាត្មាមិនមែនព្រះរាជាដូច្នេះជាដើម ហើយបានត្រាស់ឧទានគាថា និងព្យាករណ៍គាថានេះថា

**ចាតុទ្ទិសោ អប្បដិឃោ ច ហោតិ**
**សន្តុស្សមានោ ឥតរីតរេន**
**បរិស្សយានំ សហិតា អឆម្ភី**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

*បុគ្គលជាអ្នកនៅជាសុខ ក្នុងទិសទាំង ៤ មិនមានថ្នាំងថ្នាក់ចិត្ត ត្រេកអរក្នុងវត្ថុតាមមានតាមបាន ជាអ្នកអត់ធន់ចំពោះអន្តរាយ ជាអ្នកមិនតក់ស្លុត គប្បី*

*ប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។*

*បណ្ដាបទទាំងនោះ បទថា* **ចាតុទ្ទិសោ** *សេចក្ដីថា មានប្រក្រតីនៅជាសុខក្នុងទិសទាំង ៤ ។ម្យ៉ាងទៀត ឈ្មោះថា* **ចាតុទ្ទិសោ** *ព្រោះមានទិសទាំង ៤ ផ្សាយទៅដោយព្រហ្មវិហារភាវនា ដោយន័យជាដើមថា* **ឯកំ ទិសំ ផរិត្វា វិហរតិ** *ផ្សាយទៅកាន់ទិស ១ ។ ឈ្មោះថា* **អប្បដិឃោ** *ព្រោះមិនបៀតបៀនសត្វឬសង្ខារក្នុងទីណាមួយក្នុងទិសទាំង ៤ នោះ ព្រោះការខ្លាច ។ បទថា* **សន្តុស្សមានោ** *បានដល់ ជាអ្នកសន្តោសដោយអំណាចសន្តោស ១២ យ៉ាង ។ បទថា* **ឥតរីតរេន** *បានដល់ ដោយបច្ច័យល្អនិងមិនល្អ ។ ក្នុងបទថា* **បរិស្សយានំ សហិតា អឆម្ភី** *នេះ មានវិនិច្ឆ័យដូច្នេះថា ឈ្មោះថា* **បរិស្សយ** *ព្រោះបៀតបៀនកាយនិងចិត្ត ឬញុំាំងសម្បត្តិនៃកាយនិងចិត្តឲ្យវិនាសទៅជុំវិញ ឬអាស្រ័យកាយនិងចិត្តនោះ ដេកនៅ ។*

*ពាក្យថា* **បរិស្សយ** *នេះ ជាឈ្មោះនៃឧបទ្រវន្តរាយផ្លូវកាយនិងចិត្ត ដែលជាខាងក្រៅ មានសីហៈនិងខ្លាធំជាដើម ដែលជាខាងក្នុង មានកាមច្ឆន្ទៈជាដើម ។ ឈ្មោះថា* **សហិតា** *ព្រោះអត់សង្កត់អន្តរាយទាំងនោះ ដោយអធិវាសនខន្តី និងដោយធម៌ទាំងឡាយ មានវីរិយៈជាដើម ។ ឈ្មោះថា* **អឆម្ភី** *ព្រោះមិនមានការខ្លាច ដែលធ្វើឲ្យខ្លួនរឹង ។*

*សួរថា តើលោកអធិប្បាយដូចម្ដេច ។*

ឆ្លើយថា លោកអធិប្បាយទុកថា សន្តោសដោយបច្ច័យតាមមានតាមបាន ដូចសមណៈ ៤ អង្គនោះ តាំងនៅក្នុងសន្តោសដែលជាបទដ្ឋាននៃការបដិបត្តិនេះ ឈ្មោះថា **ចាតុទ្ទិស** ព្រោះចម្រើនមេត្តាជាដើម ក្នុងទិសទាំង ៤ និងឈ្មោះថា **អប្បដិឃ** ព្រោះមិនមានការភ័យខ្លាច ព្រោះការបៀតបៀនក្នុងសត្វនិងសង្ខារទាំងឡាយ ។ បុគ្គលនោះ ឈ្មោះថា **បរិស្សយានំ សហិតា** ព្រោះជាអ្នកនៅតាមសប្បាយក្នុងទិសទាំង ៤ និងឈ្មោះថា **អឆម្ភី** ព្រោះភាពជាអ្នកមិនមានការអាក់អន់ ខ្ញុំឃើញគុណនៃការបដិបត្តិយ៉ាងនេះ ដោយប្រការដូច្នេះ ទើបបដិបត្តិដោយឧបាយ បានសម្រេចបច្ចេកពោធិញ្ញាណហើយ ។

ម្យ៉ាងទៀត លោកអធិប្បាយថា ខ្ញុំដឹងថា បុគ្គលដែលសន្តោសដោយបច្ច័យតាមមានតាមបាន ជាអ្នកនៅតាមសប្បាយក្នុងទិសទាំង ៤ ដោយន័យដូចពោលហើយ ដូចសមណៈទាំងនោះ ទើបប្រាថ្នាជាអ្នកនៅតាមសប្បាយក្នុងទិសទាំង ៤ យ៉ាងនោះ បដិបត្តិដោយឧបាយ ទើបបានសម្រេច ព្រោះហេតុនោះ បុគ្គលដទៃ ប្រាថ្នាឋានៈដូច្នេះ គប្បីជាអ្នកគ្របសង្កត់អន្តរាយ ដោយភាពជាអ្នកផ្សាយមេត្តាទៅក្នុងទិសទាំង ៤ និងជាអ្នកមិនតក់ស្លុត ដោយភាពជាអ្នកមិនអាក់អន់ ត្រាច់ទៅម្នាក់ឯងដូចកុយរមាស ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

ចាតុទ្ទិសគាថាទី ៨ ចប់

# ឧស្សង្គហគាថា

គាថាថា **ឧស្សង្គហា** ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។

បានឮថា ព្រះអគ្គមហេសីរបស់ព្រះបាទពារាណសីសោយព្រះវិលាល័យហើយ ។ បន្ទាប់អំពីនោះ កាលថ្ងៃសោយសោកកន្លងទៅថ្ងៃមួយ អាមាត្យទាំងឡាយក្រាបទូលអង្វរព្រះរាជាថា ធម្មតាព្រះរាជាទាំងឡាយ ចាំបាច់ប្រាថ្នាអគ្គមហេសីក្នុងរាជកិច្ចផ្សេង ៗ ដោយខានមិនបាន ទូលព្រះបង្គំទាំងឡាយសូមឱកាស សូមព្រះសម្មតិទេព ទ្រង់នាំព្រះទេវីអង្គដទៃមក ។

ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរអ្នកទាំងឡាយដឹងចុះ ។

កាលអាមាត្យទាំងនោះ កំពុងស្វែងរក ព្រះរាជាក្នុងរាជអាណាចក្រជិតខាងមួយអង្គ សោយទិវង្គត ព្រះទេវីរបស់ព្រះរាជាអង្គនោះ គ្រប់គ្រងរាជសម្បត្តិ ព្រះនាងមានព្រះគភ៌ អាមាត្យទាំងឡាយដឹងថា ព្រះទេវីនោះ សមគួរដល់ព្រះរាជា ទើបអង្វរព្រះនាង ។

ព្រះនាងមានព្រះសវនីយ៍ថា ធម្មតាស្ត្រីមានគភ៌ រមែងមិនជាទីគាប់ចិត្តរបស់មនុស្សទាំងឡាយ បើអ្នកបង្អង់ ទម្រាំយើងប្រសូត ជាការប្រពៃ បើរង់ចាំមិនបាន ពួកអ្នក ចូររកស្រីដទៃចុះ ។

អាមាត្យទាំងឡាយក៏ក្រាបទូលសេចក្ដីនោះ ដល់ព្រះរាជា ។ ព្រះ

រាជាត្រាស់ថា ទោះបីព្រះនាងមានគភ៌ ក៏ចូរនាំមកចុះ ។

អាមាត្យទាំងនោះ ក៏នាំមក ។ ព្រះរាជាទ្រង់អភិសេកព្រះទេវីនោះហើយ បានប្រទានគ្រឿងប្រើប្រាស់សម្រាប់ព្រះមហេសីសព្វយ៉ាង ទ្រង់សង្គ្រោះព្រះនាងនិងបរិវារជន ដោយគ្រឿងបណ្ណាការច្រើនយ៉ាង ។ ព្រះមហេសីនោះ ប្រសូតព្រះរាជបុត្តតាមកាល ព្រះរាជាទ្រង់បី ព ព្រះរាជបុត្តរបស់ព្រះនាង ទុកលើភ្លៅនិងដើមទ្រូង ក្នុងឥរិយាបថទាំងពួង ដូចបុត្តរបស់ព្រះអង្គ ។ កាលនោះ បរិវារជនរបស់ព្រះទេវីនោះ នាំគ្នាគិតថា ព្រះរាជាទ្រង់សង្គ្រោះយ៉ាងក្រៃលែង ទ្រង់ធ្វើការស្និទ្ធស្នាលបំផុតក្នុងព្រះរាជកុមារ ណ្ហើយចុះ ពួកយើងនឹងញុះញង់ព្រះរាជកុមារនោះ ឲ្យបែកអំពីព្រះរាជា ។

បន្ទាប់អំពីនោះ ក៏នាំគ្នាទូលព្រះរាជកុមារថា បពិត្រអយ្យបុត្ត ទ្រង់ជាឱរសនៃព្រះរាជារបស់ទូលព្រះបង្គំទាំងឡាយ មិនមែនជាព្រះរាជឱរសរបស់ព្រះរាជាអង្គនេះទេ ទ្រង់កុំទុកព្រះហឫទ័យក្នុងព្រះរាជាអង្គនេះ ។ លំដាប់នោះ ព្រះរាជកុមារ កាលព្រះរាជាត្រាស់ថា មកបុត្ត ដូច្នេះក្តី យកព្រះហស្តទាញមកក្តី ក៏មិនឱបព្រះរាជាដូចកាលមុន ។ ព្រះរាជាទ្រង់ពិចារណាថា តើមានរឿងអ្វីហ្ន៎ កាលទ្រង់ជ្រាបហេតុនោះហើយ ទ្រង់ព្រះតម្រិះថា ឱហ្ន៎! ជនទាំងនេះ សូម្បីអាត្មាអញសង្គ្រោះហើយយ៉ាងនេះ នៅតែប្រព្រឹត្តអំពើគួរស្អប់ខ្ពើមទៀត ដូច្នេះហើយ ទ្រង់នឿយណាយ

ទើបលះរាជសម្បត្តិ ចេញបួស ។

ចំណែកបរិជនជាច្រើនដឹងថា ព្រះរាជាទ្រង់បួសហើយ ក៏ចេញបួសតាម ។ មនុស្សទាំងឡាយដឹងថា ព្រះរាជាមួយអន្លើដោយបរិជនបួសហើយ ក៏នាំបច្ច័យដ៏ប្រណីតមកប្រគេន ព្រះរាជាឲ្យប្រគេនបច្ច័យដែលប្រណីតតាមលំដាប់ដល់ព្រះថេរៈ បព្វជិតទាំងនោះ បព្វជិតណាបានបច្ច័យល្អ បព្វជិតនោះ ក៏ត្រេកអរ បព្វជិតក្រៅអំពីនោះ ក៏ពោលទោសថា ពួកយើងធ្វើកិច្ចទាំងពួង មានការបោសបរិវេណជាដើម តែបានកត្តអាក្រក់ បានសំពត់ចាស់ ។ ព្រះរាជាទ្រង់ជ្រាបរឿងនោះហើយទ្រង់ព្រះតម្រិះថា ឱហ្ន៎ ! កាលឲ្យបច្ច័យតាមលំដាប់ដល់បុគ្គលចាស់បព្វជិតទាំងឡាយ ក៏សម្ទឹងទោស ឱ ! បរិស័ទនេះ សង្គ្រោះបានដោយក្រ ដូច្នេះហើយ ទ្រង់កាន់បាត្រនិងចីវរតែមួយព្រះអង្គឯង យាងចូលព្រៃ ប្រារព្ធវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ ។ ជនទាំងឡាយដែលមកក្នុងទីនោះ ទូលសួរកម្មដ្ឋាន បានត្រាស់គាថានេះថា

ទុស្សង្គហា បព្វជិតាបិ ឯកេ
អថោ គហដ្ឋា ឃរមាវសន្តា
អប្បោស្សុក្កោ បរបុត្តេសុ ហុត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

*បព្វជិតពួកខ្លះ ឬពួកគ្រហស្ថ ដែលនៅគ្រប់គ្រងផ្ទះ*
*ខ្លះ គេសង្គ្រោះបានដោយកម្រ បុគ្គលអ្នកមិនមាន*
*សេចក្តីខ្វល់ខ្វាយ ចំពោះពួកកូននៃបុគ្គលដទៃ គប្បី*
*ប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។*

*គាថានោះ ដោយអត្ថប្រាកដច្បាស់ហើយ តែមានពាក្យអធិប្បាយប្រកបសេចក្តីដូច្នេះថា សូម្បីបព្វជិតពួកខ្លះ ដែលត្រូវអសន្តោសៈគ្របសង្កត់ ក៏សង្គ្រោះបានដោយក្រ ម្យ៉ាងទៀត គ្រហស្ថអ្នកគ្រប់គ្រងផ្ទះ ក៏យ៉ាងនោះដូចគ្នា ខ្ញុំស្អប់ខ្ពើមភាពជាអ្នកសង្គ្រោះលំបាកនេះ ទើបផ្តើមចម្រើនវិបស្សនា បានសម្រេចហើយ ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យមុននោះឯង ។*

## ទុស្សង្គហគាថាទី ៩ ចប់

# ភោជិឡារគាថា

គាថាថា **ឱរោបយិត្វា** ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។

បានឮថា ព្រះរាជានគរពារាណសី ព្រះនាមចាតុមាសិកព្រហ្មទត្ត ទ្រង់យាងទៅកាន់ព្រះរាជឧទ្យានក្នុងខែដំបូងនៃគិម្ហរដូវ ទ្រង់ឃើញដើមរលួសផ្អុងពេញទៅដោយស្លឹកពណ៌ខៀវនិងក្រាស់ ក្នុងភូមិភាគដែលគួរជាទីត្រេកអរក្នុងព្រះរាជឧទ្យាននោះ ទើបត្រាស់ថា ចូរក្រាលទីបន្ទំឲ្យយើងត្រង់គល់រលួសផ្អុង ហើយទ្រង់ក្រសាលក្នុងព្រះរាជឧទ្យាន ពេលល្ងាច ទ្រង់សម្រេចការផ្ទំទៀបគល់រលួសផ្អុងនោះ ។ ក្នុងខែកណ្ដាលនៃគិម្ហរដូវ បានយាងទៅកាន់ព្រះរាជឧទ្យាននោះទៀត ក្នុងកាលនោះ ដើមរលួសផ្អុងកំពុងចេញផ្កា ទ្រង់ធ្វើយ៉ាងនោះដូចគ្នា ។ ក្នុងខែខាងចុងនៃគិម្ហរដូវ បានយាងទៅម្ដងទៀត ក្នុងកាលនោះ ដើមរលួសផ្អុងជ្រុះស្លឹក ដូចជាដើមឈើងាប់ ។ ក្នុងកាលនោះ ព្រះរាជាទ្រង់មិនបានទតមើលដើមឈើនោះ ដ្បិតធ្លាប់ស្និទ្ធស្នាលក្នុងកាលមុន ទើបត្រាស់ឲ្យក្រាលកម្រាលដើម្បីផ្ទំត្រង់គល់រលួសផ្អុងនោះ ។ អាមាត្យទាំងឡាយ ទោះបីដឹង ក៏ក្រាលទីបន្ទំត្រង់គល់រលួសផ្អុងនោះ តាមពាក្យរបស់ទ្រង់ ។

ព្រះរាជា ទ្រង់ក្រសាលក្នុងព្រះរាជឧទ្យាន លុះពេលល្ងាច កាលផ្ទំក្នុងទីនោះ ទ្រង់ទតឃើញដើមឈើនោះ ទើបព្រះតម្រិះថា អាក្រក់ពិត

ហ្ន៎ ដើមឈើនេះ កាលមុនពេញដោយស្លឹក ជាដើមឈើស្អាតគួរមើល ដូចសម្រេចដោយកែវមណី បន្ទាប់អំពីនោះ ក៏មានសម្រស់គួរមើលដោយផ្កាទាំងឡាយ ដូចគ្នានឹងពន្លកកែវប្រពាល ដែលដាក់ក្នុងវាំងមែក មានពណ៌ដូចកែវមណី ឯភូមិភាគខាងក្រោមដើមឈើនេះ ក៏ក្រាលដោយដីខ្សាច់ ដូចគ្នានឹងបណ្ដាញកែវមុក្ដា ដេរដាសដោយផ្កាដែលជ្រុះចាកទង ដូចក្រាលដោយសំពត់កម្ពលក្រហម ។ ថ្ងៃនេះ ដើមឈើនេះ ដូចដើមឈើងាប់ សល់ត្រឹមតែមែកហើយនិងដើម ឱ ! ដើមរលួសផ្លុង ក៏ត្រូវជរាបៀតបៀន ទ្រង់បានចំពោះនូវអនិច្ចសញ្ញាថា វត្ថុដែលមិនមានវិញ្ញាណ ក៏គង់ជរានោះ បៀតបៀន នឹងពោលថ្វីដល់វត្ថុដែលមានវិញ្ញាណ ទ្រង់ឃើញច្បាស់នូវសង្ខារទាំងពួង ដោយភាពជាទុក្ខ និងដោយភាពជាអនត្តា ដោយទំនងដូចគ្នា ទ្រង់ប្រាថ្នាថា ឱហ្ន៎ ! អាត្មាអញគប្បីប្រាសចាកភេទគ្រហស្ថ ដូចដើមរលួសផ្លុងជម្រុះនូវស្លឹកដូច្នោះ ។ ព្រះរាជាទ្រង់ផ្ទំដោយបង្អៀងខាងស្ដាំ ត្រង់ទីបន្ទំនោះ ដោយលំដាប់ ទ្រង់ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ ។ ក្នុងពេលយាងចេញអំពីទីនោះ កាលពួកអាមាត្យក្រាបទូលថា **កាលោ ទេវ គន្តុំ** បពិត្រព្រះទេវៈ ដល់កាលយាងត្រឡប់ហើយ ទើបត្រាស់ពាក្យជាដើមថា **នាហំ**

**រាជា** *យើងមិនមែនព្រះរាជា ហើយត្រាស់គាថានេះ ដោយន័យមុននោះឯងថា*

**ឱរោបយិត្វា គិហិព្យញ្ជនានិ**
**សញ្ឆិន្នបត្តោ យថា កោវិឡារោ**
**ឆេត្វាន វីរោ គិហិពន្ធនានិ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

*វីរបុគ្គលលះបង់នូវវត្ថុទាំងឡាយ ជាគ្រឿងប្រាកដរបស់គ្រហស្ថ កាត់បង់នូវចំណងរបស់គ្រហស្ថទាំងឡាយ ដូចដើមរលួសផ្អុងជម្រុះស្លឹក គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។*

*បណ្តាបទទាំងនោះ បទថា* **ឱរោបយិត្វា** *បានដល់ នាំចេញទៅ ។ បទថា* **គិហិព្យញ្ជនានិ** *បានដល់ សក់ ពុកមាត់ សំពត់សគ្រឿងប្រដាប់ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប បុត្ត ភរិយា ទាសី និងទាសៈជាដើម វត្ថុទាំងនេះ ធ្វើឲ្យភាពជាគ្រហស្ថប្រាកដ ព្រោះហេតុនោះ ទើបហៅថា ជាគ្រឿងប្រាកដរបស់គ្រហស្ថ ។*

*បទថា* **សញ្ឆិន្នបត្តោ** *ប្រែថា មានស្លឹកជ្រុះទៅហើយ ។ បទថា* **ឆេត្វាន** *បានដល់ កាត់ដោយមគ្គញ្ញាណ ។ បទថា* **វីរោ**

*បានដល់ ប្រកបដោយសេចក្ដីព្យាយាមក្នុងមគ្គ ។ បទថា* **គិហិព្យញ្ជនានិ** *បានដល់ គ្រឿងចង គឺកាម ។ ពិតហើយ កាមទាំងឡាយជាគ្រឿងចងរបស់គ្រហស្ថ អត្ថនៃបទមានត្រឹមប៉ុណ្ណេះ ។ ចំណែកពាក្យអធិប្បាយមានដូច្នេះថា ព្រះរាជាទ្រង់ព្រះតម្រិះយ៉ាងនេះថា ឱហ្ន៎ ! សូមឱ្យអញ ក៏គប្បីដាក់ចុះនូវគ្រឿងសម្គាល់របស់គ្រហស្ថ គប្បីដូចដើមរលួសផ្អុង ដែលជ្រុះស្លឹកដូច្នោះ ទ្រង់ចម្រើនវិបស្សនា បានសម្រេចហើយ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដែលពោលមុននោះឯង ។*

កោវិឡារគាថាទី ១០ ចប់

**វគ្គទី ១ ចប់**

# វគ្គទី ២

# សហាយគាថា

គាថាថា **សចេ លភេថ** ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។

បានឮថា ក្នុងអតីតកាល ព្រះបច្ចេកពោធិសត្វ ២ អង្គ បួសក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមកស្សបៈ បំពេញគតបច្ចាគតវត្ត អស់ ២ ម៉ឺនឆ្នាំហើយ កើតក្នុងទេវលោក ចុតិចាកទេវលោកនោះហើយ បុគ្គលដែលជាច្បង បានជាព្រះរាជឱរសរបស់ព្រះបាទពារាណសី បុគ្គលដែលជាប្អូនបានជាបុត្តរបស់បុរោហិត ជនទាំងពីរនោះ បដិសន្ធិក្នុងថ្ងៃតែមួយ ប្រសូតចេញចាកគភ៌មាតាក្នុងថ្ងៃតែមួយ ជាសម្លាញ់លេងដីជាមួយគ្នា ។ បុត្តបុរោហិតជាអ្នកមានបញ្ញា បានទូលព្រះរាជបុត្តថា បពិត្រសម្លាញ់ ទ្រង់នឹងបានរាជសម្បត្តិដោយអំណឹះតតអំពីព្រះរាជបិតា ឯខ្ញុំនឹងបានតំណែងជាបុរោហិត បើទ្រង់បានទទួលការសិក្សាល្អហើយ គួរដើម្បីគ្រប់គ្រងរាជសម្បត្តិឲ្យជាសុខ មកពួកយើងនឹងរៀនសិប្បៈជាមួយគ្នា ។ បន្ទាប់អំពីនោះ ជនទាំងពីរជាអ្នកមានកម្មបានសន្សំហើយអំពីជាតិមុន កាលត្រាច់រកភិក្ខាក្នុងគាមនិងនិគមជាដើម បានទៅដល់ស្រុកក្នុងជនបទជាយដែន ។ **ព្រះបច្ចេកពុទ្ធ** ៥ អង្គ ចូលទៅកាន់ស្រុកនោះ ក្នុងវេលាភិក្ខាចារ ។ លំដាប់នោះ មនុស្សទាំងឡាយឃើញព្រះ

បច្ចេកពុទ្ធហើយ កើតនូវឧស្សាហៈ ក្រាលអាសនៈ បង្អោនខាទនីយៈ និងភោជនីយៈដ៏ប្រណីតបូជាហើយ ។ សម្លាញ់ទាំងពីរនោះ មានការគិតយ៉ាងនេះថា មនុស្សមានត្រកូលខ្ពស់ដូចជាពួកយើង មិនមាន អើ មនុស្សទាំងនេះ បើប្រាថ្នា ក៏ឲ្យភិក្ខាដល់ពួកយើង បើមិនប្រាថ្នា ក៏មិនឲ្យ តែរមែងធ្វើសក្ការៈមានសភាពបែបនោះ ដល់បព្វជិតទាំងនេះ លោកទាំងនេះ គង់ចេះនូវសិប្បៈឯណានីមួយពិតប្រាកដ ណ្ហើយចុះ ពួកយើងនឹងរៀននូវសិប្បៈក្នុងសម្នាក់របស់បព្វជិតទាំងនោះ ។ សម្លាញ់ទាំងពីរនោះ កាលមនុស្សទាំងឡាយត្រឡប់ហើយ បានឱកាស ទើបអង្វរថា បពិត្រលោកម្ចាស់ដ៏ចម្រើនទាំងឡាយ លោកម្ចាស់ទាំងឡាយ ចេះនូវសិប្បៈណា សូមឲ្យពួកខ្ញុំសិក្សានូវសិប្បៈនោះផងចុះ ។

ព្រះបច្ចេកពុទ្ធទាំងឡាយពោលថា បុគ្គលដែលមិនបានបួស មិនអាចសិក្សាបាន ។ សម្លាញ់ទាំងពីរនោះ ក៏សូមបព្វជ្ជា ហើយបួស ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធទាំងឡាយ បានប្រាប់អភិសមាចារិកវត្តដល់បព្វជិតទាំងពីរនោះ ដោយន័យជាដើមថា អ្នកគប្បីស្លៀកយ៉ាងនេះ គប្បីដណ្តប់យ៉ាងនេះ ហើយប្រគល់បណ្ណសាលាឲ្យមួយអង្គមួយខ្នង ដោយពោលថា ការត្រេកអរក្រៃលែងក្នុងភាពជាបុគ្គលម្នាក់ឯង ជាការសម្រេចនៃសិប្បៈនេះ ព្រោះហេតុនោះ គប្បីអង្គុយម្នាក់ឯងប៉ុណ្ណោះ គប្បីចង្ក្រមគប្បីឈរ គប្បីដេកម្នាក់ឯង ។ បន្ទាប់អំពីនោះ បព្វជិតទាំងពីរនោះ ចូល

កាន់បណ្ណសាលារៀង ៗ ខ្លួន ហើយអង្គុយ ។ បុត្តបុរោហិតបាននូវការតាំងមាំនៃចិត្តចាប់តាំងអំពីកាលដែលអង្គុយ ហើយបានឈាន ។ ចំណែកព្រះរាជបុត្តអផ្សុកដោយវេលាមួយស្របក់ប៉ុណ្ណោះ មកកាន់សម្នាក់របស់បុត្តបុរោហិតនោះ ។ បុត្តបុរោហិតឃើញព្រះរាជបុត្តនោះ ទើបសួរថា មានរឿងអ្វីសម្លាញ់ ។ ព្រះរាជបុត្តពោលថា ខ្ញុំអផ្សុក ។

បុត្តបុរោហិតពោលថា បើដូច្នោះ ចូរអង្គុយចុះក្នុងទីនេះ ។

ព្រះរាជបុត្តនោះ អង្គុយក្នុងទីនោះ មួយស្របក់ ពោលថា សម្លាញ់ បានឮថា ការត្រេកអរក្រៃលែងក្នុងភាពជាបុគ្គលម្នាក់ឯង ជាការសម្រេចនៃសិប្បៈនេះ ។

បុត្តបុរោហិតពោលថា យ៉ាងនោះឯងសម្លាញ់ បើដូច្នោះ លោកចូរទៅកាន់ឱកាសដែលខ្លួនអង្គុយនោះឯង ខ្ញុំនឹងរៀនយកនូវការសម្រេចផលនៃសិប្បៈនេះ ។ ព្រះរាជបុត្តទៅហើយមួយស្របក់ប៉ុណ្ណោះ ក៏អផ្សុកទៀត ទើបត្រឡប់មកអស់វារៈ ៣ ដង ដោយន័យមុននោះឯង ។

បន្ទាប់អំពីនោះ បុត្តបុរោហិតក៏បញ្ជូនព្រះរាជបុត្តទៅយ៉ាងនោះ កាលព្រះរាជបុត្តទៅហើយ គិតថា ព្រះរាជបុត្តនេះ កាលមកក្នុងទីនេះរឿយ ៗ នឹងធ្វើកម្មរបស់ខ្លួនផង កម្មរបស់អាត្មាអញផង ឲ្យវិនាស ។ បុត្តបុរោហិតនោះ ក៏ចេញអំពីបណ្ណសាលាចូលកាន់ព្រៃ ។ ចំណែកព្រះរាជបុត្តអង្គុយក្នុងបណ្ណសាលារបស់ខ្លួន ជាអ្នកអផ្សុកទៀត ដោយ

មួយស្របក់ប៉ុណ្ណោះ ទើបមកកាន់បណ្ណសាលារបស់បុត្តបុរោហិតនោះ សម្លឹងរកមើលក្នុងទីផ្សេង ៗ ក៏មិនឃើញបុត្តបុរោហិតនោះ ទើបគិតថា បុគ្គលណា ក្នុងកាលនៅជាគ្រហស្ថ នាំបណ្ណាការមក ក៏មិនបានឃើញអញ ឈ្មោះថា បុគ្គលនោះ កាលអញមកហើយ ក៏មិនប្រាថ្នាដើម្បីនឹងឲ្យចួបអាត្មាអញ បានចៀសចេញទៅហើយ ឱហ្ន៎! ចិត្ត ឯងមិនខ្មាស ឯងនាំអញមកក្នុងទីនេះ អស់វារៈ ៤ ដង ឥឡូវនេះ អញនឹងមិនប្រព្រឹត្តទៅក្នុងអំណាចរបស់ឯង តែនឹងឲ្យឯងប៉ុណ្ណោះ ប្រព្រឹត្តទៅក្នុងអំណាចរបស់អញដោយពិត ដូច្នេះហើយ ចូលកាន់សេនាសនៈរបស់ខ្លួន ប្រារព្ធវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ហើយហោះទៅកាន់ញកភ្នំនន្ទមូលកៈ ។ ចំណែកបុត្តរបស់បុរោហិតចូលកាន់ព្រៃ ប្រារព្ធវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ បានទៅដូចគ្នាយ៉ាងនោះឯង ព្រះបច្ចេកពុទ្ធទាំងពីរអង្គនោះ គង់លើផ្ទាំងមនោសិលាហើយ បានពោលឧទានគាថាទាំងនេះ មួយអង្គមួយគាថាដូច្នេះថា

សចេ លភេថ និបកំ សហាយំ
សទ្ធិញ្ចរំ សាធុវិហារិ ធីរំ [១]
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតីមា ។

---

១- សាធុវិហារិ ធីរំ កាត់បទជា សាធុវិហារី ធីរំ ។

បើបុគ្គលបានសម្លាញ់ជាអ្នកប្រាជ្ញ មានបញ្ញាខ្ជាប់ខ្ជួន ជាអ្នកប្រព្រឹត្តត្រូវគ្នា មានធម៌ជាគ្រឿងនៅដ៏ល្អ គប្បីជាអ្នកមានស្មារតីគ្របសង្កត់នូវអន្តរាយទាំងពួង ហើយមានចិត្តរីករាយ ប្រព្រឹត្តជាមួយសម្លាញ់នោះចុះ ។

**នោ ចេ លភេថ និបកំ សហាយំ**
**សទ្ធិញ្ចរំ សាធុវិហារិ ធីរំ**
**រាជាវ រដ្ឋំ វិជិតំ បហាយ**
**ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។**

បើបុគ្គលមិនបានសម្លាញ់ ជាអ្នកប្រាជ្ញ មានបញ្ញាខ្ជាប់ខ្ជួន ជាអ្នកប្រព្រឹត្តត្រូវគ្នា មានធម៌ជាគ្រឿងនៅដ៏ល្អទេ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចព្រះរាជាទ្រង់លះបង់នូវដែនដែលទ្រង់ឈ្នះហើយ ឬដូចដំរីឈ្មោះមាតង្គៈ ( លះបង់នូវហ្វូង កាលត្រាច់ទៅ ) ក្នុងព្រៃ ។

បណ្តាបទទាំងនោះ បទថា **និបកំ** បានដល់ ជាអ្នកមានបញ្ញារក្សាខ្លួនតាមប្រក្រតី គឺជាបណ្ឌិត បានដល់ ជាអ្នកឈ្លាសក្នុងការបរិកម្មកសិណជាដើម ។ បទថា **សាធុវិហារី** បានដល់ ប្រកបដោយវិហារធម៌ដ៏នឹងធឹង ឬដោយវិហារធម៌យ៉ាងស៊ប់សួន ។ បទថា **ធីរំ** គឺជាអ្នកបរិបូណ៌ដោយបញ្ញាជាគ្រឿងទ្រទ្រង់ចាំ ។ ក្នុងសេចក្តីនោះ លោក

ពោលសំដៅដល់ធិតិសម្បទា គឺការដល់ព្រមដោយបញ្ញាជាគ្រឿងទ្រទ្រង់ចាំ ដោយភាពជាអ្នកមានបញ្ញារក្សាខ្លួន ។ តែក្នុងទីនេះ បានដល់ ជាអ្នកបរិបូណ៌ដោយធិតិប៉ុណ្ណោះ ។ ការព្យាយាមមិនធូរថយ ឈ្មោះថា **ធិតិ** ។ ពាក្យនេះ ជាឈ្មោះនៃសេចក្ដីព្យាយាមដែលប្រព្រឹត្តទៅយ៉ាងនេះថា **កាមំ តចោ ច ឆហារុ ច** ... សូមឲ្យស្បែក សរសៃ ( និងឆ្អឹង ) សល់នៅចុះ ...[១] ។ ម្យ៉ាងទៀត ឈ្មោះថា ធីរៈ ព្រោះខ្ពើមរអើមនូវបាប ដូច្នេះ ក៏មាន ។ បទថា **រាជាវ រដ្ឋំ វិជិតំ បហាយ** សេចក្ដីថា គប្បីលះនូវសម្លាញ់ដែលជាបុគ្គលពាល ត្រាច់ទៅម្នាក់ឯងដូចព្រះរាជា តាមប្រក្រតី ទ្រង់ដឹងថា ដែនដែលអញឈ្នះហើយ នាំសេចក្ដីវិនាសមកឲ្យ ទើបលះរាជសម្បត្តិ ត្រាច់ទៅមួយអង្គឯងដូច្នោះ ។ ម្យ៉ាងទៀត បទថា **រាជាវ រដ្ឋំ** នោះ មានសេចក្ដីដូចតទៅនេះថា ជាបុគ្គលម្នាក់ឯង ត្រាច់ទៅ ដូចព្រះបាទសុតសោម ទ្រង់លះនូវដែនដែលទ្រង់ឈ្នះហើយ ត្រាច់ទៅមួយអង្គឯង និងដូចព្រះមហាជនកដូច្នោះ ។ ពាក្យដ៏សេស អាចដឹងតាមគន្លងដែលពោលហើយ ព្រោះហេតុនោះ ទើបមិនចាំបាច់ពោលឲ្យពិស្ដារនោះឯង ។

## សហាយគាថាទី ១-២ ចប់

---

១-បិ.២៣ ទំ.៤០៥ ឃ.២៣៩ ។

# អឌ្ឍាបសំសាគាថា

គាថាថា **អឌ្ឍា បសំសាម** ដូច្នេះជាដើម មានហេតុកើតដូចគ្នានឹងហេតុកើតរបស់ **ចាតុទ្ទិសគាថា** ទៅទល់គ្នានឹងព្រះបច្ចេកពុទ្ធទាំងឡាយ អង្គុយលើអាសនៈដែលក្រាលទុកត្រង់យ៉មុខ ។ ឯសេចក្តីប្លែកគ្នា មានដូចតទៅនេះថា

ព្រះរាជាអង្គនេះ មិនតក់ស្លុតដូចព្រះរាជាអង្គនោះ ដែលតក់ស្លុតក្នុងវេលាយប់ អស់វារៈ ៣ ដង ។ ព្រះរាជាអង្គនេះ ទ្រង់មិនបានត្រៀមការបូជាយញ្ញ ទ្រង់និមន្តព្រះបច្ចេកពុទ្ធទាំងឡាយ ឲ្យគង់លើអាសនៈដែលគេក្រាលទុកត្រង់យ៉មុខ ហើយត្រាស់សួរថា **កេ តុម្ហេ** លោកម្ចាស់ទាំងឡាយ ឈ្មោះអ្វី ។

ព្រះបច្ចេកពុទ្ធឆ្លើយតបថា **មយំ មហារាជ អនវជ្ជភោជិនោ នាម** បពិត្រមហារាជ ពួកអាត្មាឈ្មោះអនវជ្ជភោជី ។

ព្រះរាជាត្រាស់សួរថា លោកដ៏ចម្រើន ពាក្យថា អនវជ្ជភោជី នេះ មានសេចក្តីដូចម្តេច ។

ព្រះបច្ចេកពុទ្ធទាំងឡាយឆ្លើយថា បពិត្រមហារាជ ពួកអាត្មាបានរបស់ល្អក្តី មិនល្អក្តី ក៏ឆាន់បាន ដោយមិនសម្តែងអាការខុសប្រក្រតី ។ ព្រះរាជាបានស្តាប់ដូច្នោះ ទើបទ្រង់ព្រះតម្រិះដូច្នេះថា បើដូច្នោះ អញគួរ

ពិសោធមើល លោកម្ចាស់ទាំងនេះ ជាបុគ្គលដូច្នេះ ឬមិនមែន ។ ថ្ងៃនោះ ទ្រង់ក៏អង្គាសដោយបាយចុងអង្ករ មានទឹកជ្រក់ជាគម្រប់ ២ ព្រះបច្ចេកពុទ្ធទាំងឡាយមិនមានអាការខុសប្លែក ឆាន់បាយចុងអង្ករនោះ ដូចឆាន់អមតភោជន ។ ព្រះរាជាទ្រង់ព្រះតម្រិះថា លោកម្ចាស់ទាំងនេះជាអ្នកមិនមានអាការខុសប្រក្រតីក្នុងមួយថ្ងៃ ព្រោះប្តេជ្ញាទុកហើយ ស្អែកនេះ អញនឹងដឹង ទើបនិមន្តដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ក្នុងថ្ងៃទី ២ ក៏ទ្រង់ធ្វើយ៉ាងនោះ ។ ព្រះបច្ចេកពុទ្ធទាំងនោះ ក៏ឆាន់យ៉ាងនោះ ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា អញនឹងថ្វាយរបស់ល្អសាកមើល ទើបនិមន្តទៀត ទ្រង់ធ្វើមហាសក្ការៈអស់ ២ ថ្ងៃ ទ្រង់អង្គាសដោយរបស់ទំពាររបស់ឆាន់ដ៏ប្រណីតក្រៃលែង ។ ព្រះបច្ចេកពុទ្ធទាំងនោះ ក៏មិនសម្តែងអាការខុសប្រក្រតី ឆាន់យ៉ាងនោះឯង ពោលមង្គលដល់ព្រះរាជាហើយ ក៏ចៀសចេញទៅ ។ កាលព្រះបច្ចេកពុទ្ធទាំងនោះចៀសចេញទៅមិនយូរប៉ុន្មាន ព្រះរាជាទ្រង់ព្រះតម្រិះថា លោកទាំងនេះជាអនវជ្ជភោជី ឱហ្ន៎ ! សូម្បីអាត្មាអញ ក៏គួរជាអនវជ្ជភោជីដែរ ទើបលះរាជសម្បត្តិធំ កាន់យកភេទជាអ្នកបួស ចម្រើនវិបស្សនាហើយ បានជា **ព្រះបច្ចេកពុទ្ធ** កាលចង្អុលបង្ហាញអារម្មណ៍របស់ខ្លួន ក្នុងកណ្តាលព្រះបច្ចេកពុទ្ធទាំងឡាយ ត្រង់គល់មញ្ជូសកៈ បានពោលគាថានេះថា

**អទ្ធា បសំសាម សហាយសម្បទំ**

**សេដ្ឋា សមា សេវិតព្វា សហាយា**
**ឯតេ អលទ្ធា អនវជ្ជភោជី**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

តាមពិត យើងសរសើរនូវការបរិបូណ៌ដោយសម្លាញ់ហើយ តែបុគ្គលគួរគប់រកសម្លាញ់ ដែលមានគុណប្រសើរជាងខ្លួន ឬសម្លាញ់មានគុណស្មើនឹងខ្លួន បើរកមិនបានពួកសម្លាញ់ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគនូវចតុប្បច្ច័យដែលមិនជាទោស ហើយប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

គាថានោះ ដោយអត្ថជាក់ច្បាស់ហើយ តែក្នុងបទថា **សហាយសម្បទំ** នេះ សម្លាញ់ដែលដល់ព្រមដោយសីលក្ខន្ធជាដើម ដែលជាអសេក្ខៈប៉ុណ្ណោះ ទើបចាត់ជាសហាយសម្បទា ។

ឯពាក្យប្រកបសេចក្តីក្នុងបទថា **សហាយសម្បទំ** នេះ មានដូចតទៅនេះថា ខ្ញុំសរសើរសហាយសម្បទាដែលពោលហើយនោះ ដោយពិត អធិប្បាយថា ខ្ញុំសរសើរដោយចំណែកមួយ ។

សួរថា សរសើរដូចម្តេច ។

ឆ្លើយថា សរសើរថា គួរគប់រកសម្លាញ់ដែលមានគុណប្រសើរជាងខ្លួន ឬសម្លាញ់ដែលមានគុណស្មើនឹងខ្លួន ។

សួរថា ព្រោះហេតុអ្វី ។

ឆ្លើយថា ព្រោះកាលបុគ្គលគប់រកបុគ្គលដែលប្រសើរជាងដោយគុណ មានសីលជាដើមរបស់ខ្លួន ធម៌ទាំងឡាយ មានសីលជាដើម ដែលមិនទាន់កើត រមែងកើតឡើង និងដែលកើតហើយ រមែងដល់នូវសេចក្ដីចម្រើន ដុះដាលបរិបូណ៌ ។ កាលគប់រកបុគ្គលដែលស្មើ ធម៌ដែលបានហើយ ក៏មិនវិនាស ព្រោះស្មើគ្នានឹងគ្នា ទាំងព្រោះបន្ទោបង់នូវការក្ដៅក្រហាយចិត្តបាន កុលបុត្តដែលប្រាថ្នាប្រយោជន៍ បើមិនបាននូវសម្លាញ់ដែលប្រសើរជាង និងស្មើគ្នាទាំងនោះ គប្បីលះមិច្ឆាជីវៈ មានការបោកបញ្ឆោតជាដើម បរិភោគភោជនដែលកើតឡើងដោយធម៌ ដោយកាយសុចរិតជាដើមដ៏ស្មើ នឹងមិនធ្វើសេចក្ដីត្រេកអរ និងមិនត្រេកអរឲ្យកើតឡើងក្នុងភោជននោះ ជាអ្នកមានប្រក្រតីបរិភោគដោយមិនមានទោសត្រាច់ទៅម្នាក់ឯង ដូចកុយរមាសដូច្នោះ ខ្ញុំប្រព្រឹត្តយ៉ាងនេះ ទើបបានសម្រេចសម្បត្តិនេះ ។

អទ្ធាបសំសាគាថាទី ៣ ចប់

# សុវណ្ណវលយគាថា

គាថាថា **ឩិស្វា សុវណ្ណស្ស** ដូច្នេះជាដើម មានហេតុកើតដូចម្តេច ។

បានឮថា ព្រះរាជាក្នុងនគរពារាណសីមួយអង្គ បានយាងចូលក្រឡាបន្ទំពេលថ្ងៃក្នុងរដូវក្តៅ ។ នាងវណ្ណទាសីនៅក្នុងសម្នាក់របស់ព្រះរាជានោះ កំពុងបុកខ្លឹមចន្ទន៍ក្រហមស្រាប់ដូចទឹក ។ ត្រង់ដៃម្ខាងរបស់នាងវណ្ណទាសីនោះ មានកងមាស ១ ត្រង់ដៃម្ខាងទៀត មាន ២ ។ កងដៃមាស ២ នោះ ទង្គិចគ្នា កងដៃមាស ១ ក្រៅអំពីនោះ មិនប៉ះជាមួយអ្វីឡើយ ។ ព្រះរាជាទ្រង់ឃើញដូច្នោះ ទ្រង់ព្រះតម្រិះថា ព្រោះការនៅជាគណៈយ៉ាងនេះឯង ទើបមានការប៉ះទង្គិចគ្នា ឯការនៅម្នាក់ឯង ទើបមិនមានការប៉ះទង្គិចគ្នា ហើយទ្រង់ទតមើលទាសីនោះរឿយ ៗ ។ សម័យនោះ ព្រះទេវីប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង ឈរបក់ផ្លិតព្រះទេវីនោះ មានព្រះតម្រិះថា ព្រះរាជាប្រហែលជាមានព្រះហឫទ័យប្រតិព័ទ្ធក្នុងនាងវណ្ណទាសី ទើបឲ្យនាងវណ្ណទាសីក្រោកឡើង ហើយបុកខ្លឹមចន្ទន៍ដោយខ្លួនឯង កាលនោះ ត្រង់កដៃទាំង ២ របស់ព្រះនាង មានកងដៃមាសជាច្រើន កងទាំងនោះ ក៏ប៉ះទង្គិចគ្នា ធ្វើឲ្យកើតសំឡេងខ្លាំង ។ ព្រះរាជា កាលទ្រង់នឿយណាយខ្លាំងឡើង ទើបទ្រង់ផ្ទំដោយ

ព្រះបង្អៀងស្មាំនោះឯង ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេក-ពោធិញ្ញាណហើយ ។ ព្រះទេវីកាន់ខ្ទឹមចន្ទន៍ចូលទៅរកព្រះបច្ចេកពុទ្ធ ដែលផ្ទំដោយសេចក្តីសុខដ៏ក្រៃលែង ទូលថា បពិត្រមហារាជ សូមទ្រង់លាប ។ ព្រះបច្ចេកពុទ្ធត្រាស់ថា ចៀសចេញទៅ កុំលាបឡើយ ។

ព្រះទេវីក្រាបទូលសួរថា បពិត្រមហារាជ តើមានហេតុអ្វី ។ ព្រះបច្ចេកពុទ្ធត្រាស់ថា យើងមិនមែនជាព្រះរាជាទេ ។ អាមាត្យទាំងឡាយបានស្តាប់ពាក្យប្រាស្រ័យរបស់ព្រះរាជា និងព្រះទេវីយ៉ាងនោះ ទើបនាំគ្នាចូលគាល់ ។ ព្រះបច្ចេកពុទ្ធ សូម្បីអាមាត្យទាំងនោះ ក្រាបទូលដោយវាទៈថា បពិត្រមហារាជ ក៏ត្រាស់ថា នៃសម្លាញ់ យើងមិនមែនជាព្រះរាជារបស់អ្នកទាំងឡាយទេ យើងជា **ព្រះបច្ចេកពុទ្ធ** ។

អាមាត្យទាំងនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់ត្រាស់អ្វី ព្រះបច្ចេកពុទ្ធទាំងឡាយ មិនមែនមានសភាពយ៉ាងនេះឡើយ ។ ព្រះបច្ចេកពុទ្ធត្រាស់សួរថា នៃអ្នកទាំងឡាយ តើព្រះបច្ចេកពុទ្ធទាំងឡាយមានសភាពដូចម្តេច ។

អាមាត្យទាំងឡាយក្រាបទូលថា ព្រះបច្ចេកពុទ្ធទាំងឡាយ មានសក់ និងពុកមាត់ ពុកចង្កា ត្រឹមតែពីរធ្នាប់ មួយអន្ទើដោយបរិក្ខារ ៨ ប៉ុណ្ណោះ ។ ព្រះបច្ចេកពុទ្ធក៏យកព្រះហស្តស្ទាបព្រះសិរសា រំពេចនោះឯង យរាវាសភេទក៏អន្តរធានទៅ បព្វជិតភេទក៏ប្រាកដឡើង លោកមាន

ព្រះកេសានិងព្រះមស្សុ ប្រមាណពីរធ្នាប់ប៉ុណ្ណោះ ប្រកបដោយបរិក្ខារ ៨ គឺស្បង់ ចីពរ សង្ឃាដី វត្តពន្ធចង្កេះ បាត្រ ធម្មក្រក កាំបិតកោរមុល ដូចគ្នានឹងព្រះថេរៈមានវស្សា ១០០ ។

អាមាត្យទាំងនោះថ្វាយបង្គំ ហើយទូលសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន អ្វីជាកម្មដ្ឋាន លោកម្ចាស់សម្រេចបានដូចម្តេច ។

ព្រះបច្ចេកពុទ្ធ កាលសម្តែងសេចក្តីនោះ ទើបពោលព្រះគាថានេះថា

**ទិស្វា សុវណ្ណស្ស បភស្សរានិ**
**កម្មារបុត្តេន សុនិដ្ឋិតានិ**
**សង្ឃដ្តមានានិ ទុវេ ភុជស្មឹ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលឃើញនូវកងមាសទាំងពីរ ដែលកូនជាង
មាសធ្វើសម្រេចល្អហើយ រណ្តំគ្នាត្រង់កដៃ គប្បី
ប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

គាថានោះ មានការពណ៌នាដូចតទៅនេះថា

បណ្តាបទទាំងនោះ បទថា **ទិស្វា** បានដល់ ទ្រង់មើលហើយ ។ បទថា **សុវណ្ណស្ស** បានដល់ មាស ។ លោកឲ្យបន្ថែមពាក្យដែលមិនមាន គឺពាក្យថា **វលយានិ** ( កងដៃ ) ចូលមក ព្រោះសេចក្តីត្រូវមាន

ពាក្យបន្ថែមចូលមក ។

បទថា **បភស្សរានិ** បានដល់ មានពន្លឺចាំងចែងជាប្រក្រតី អធិប្បាយថា រុងរឿង ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។ ចំណែកវាចាប្រកបសេចក្តីមានដូចតទៅនេះថា ខ្ញុំឃើញកងមាសត្រង់ដៃ ទើបគិតយ៉ាងនេះថា កាលមានការនៅជាគណៈ ការប៉ះទង្គិចគ្នារមែងមាន កាលនៅម្នាក់ឯង ក៏មិនមានការប៉ះខ្ទប់គ្នា ទើបផ្តើមចម្រើនវិបស្សនា បានសម្រេចហើយ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយនុ៎ះឯង ។

សុវណ្ណវលយគាថាទី ៤ ចប់

# អាយតិកយគាថា

*គាថាថា* **ឯវំ ឧតិយេឆ** *ដូច្នេះជាដើម មានហេតុកើតដូចម្តេច ។*

*បានឮថា ព្រះរាជាពារាណសីមួយអង្គនៅក្មេង មានបំណងចង់បួស ទើបត្រាស់នឹងអាមាត្យទាំងឡាយថា អ្នកទាំងឡាយ ចូរកាន់យក (ទទួល) ព្រះទេវី ហើយរក្សានូវរាជ្យចុះ យើងនឹងបួស ។*

*អាមាត្យទាំងនោះក្រាបទូលថា បពិត្រមហារាជ ទូលព្រះបង្គំទាំងឡាយ មិនអាចរក្សារាជសម្បត្តិដែលមិនមានព្រះរាជា ព្រះរាជាក្បែរខាងទាំងឡាយមកហើយ នឹងប្លន់យក សូមទ្រង់បង្អង់ទម្រាំព្រះរាជឱរសមួយអង្គកើតឡើង ។ ព្រះរាជាទ្រង់មានព្រះហឫទ័យទន់ ទើបទទួលពាក្យ ។ លំដាប់នោះ ព្រះទេវីទ្រង់តាំងគភ៌ ព្រះរាជាទ្រង់ត្រាស់នឹងអាមាត្យទាំងនោះទៀតថា ព្រះទេវីមានព្រះគភ៌ហើយ អ្នកទាំងឡាយចូរអភិសេកព្រះរាជឱរសដែលប្រសូតហើយក្នុងរាជសម្បត្តិ ហើយរក្សារាជសម្បត្តិ យើងនឹងបួស ។*

*អាមាត្យទាំងឡាយក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាបទៀតថា បពិត្រមហារាជ កាលដែលព្រះទេវីប្រសូតព្រះរាជឱរស ឬព្រះរាជធីតានោះដឹងបានលំបាក ព្រោះហេតុនោះ សូមទ្រង់រង់ចាំកាលប្រសូតសិន ។ លំដាប់នោះ ព្រះទេវីប្រសូតបានព្រះរាជបុត្ត ។ ព្រះរាជាក៏ទ្រង់ត្រាស់*

នឹងអាមាត្យទាំងឡាយយ៉ាងនោះទៀត អាមាត្យទាំងឡាយនោះ នាំគ្នាក្រាបទូលព្រះរាជាឲ្យទ្រង់យល់ព្រម ដោយហេតុផលជាច្រើនទៀតថា បពិត្រមហារាជ សូមទ្រង់បង្អង់សិន ទម្រាំព្រះរាជឱរសមានសមត្ថភាព ។

លំដាប់នោះ កាលព្រះរាជកុមារជាអ្នកមានសមត្ថភាពហើយ ព្រះរាជា ឲ្យអាមាត្យទាំងឡាយប្រជុំគ្នា ហើយត្រាស់ថា ឥឡូវនេះ ព្រះរាជកុមារ ជាអ្នកមានសមត្ថភាពហើយ អ្នកទាំងឡាយ ចូរអភិសេកព្រះរាជកុមារនោះ ក្នុងរាជសម្បត្តិ ហើយប្រណិប័តន៍ចុះ ។ កាលត្រាស់ហើយ មិនឲ្យឱកាសដល់ពួកអាមាត្យ ឲ្យនាំបរិក្ខារទាំងពួង មានសំពត់កាសាវៈជាដើម មកអំពីរានផ្សារ ទ្រង់បួសខាងក្នុងបុរីនោះឯង ហើយយាងចេញទៅដូចព្រះមហាជនក ។ បរិវារជនទាំងពួង នាំគ្នាកន្ទក់កន្ទេញ មានប្រការផ្សេង ៗ ជាប់តាមព្រះរាជាទៅ ។ ព្រះរាជាយាងទៅអស់រដ្ឋសីមារបស់ព្រះអង្គហើយ យកឈើច្រត់គូស ត្រាស់ថា **អយំ លេខា ជាតិក្កមិតព្វា** កុំឈានកន្ទង់ស្នាមគំនូសនេះ ។ មហាជនក្រាបចុះលើផែនដី ធ្វើក្បាលទុកត្រង់ស្នាមគំនូស កន្ទក់កន្ទេញថា **តុយ្ហំ ជានិ តាត រញ្ញោ អាណា កឹ ករិស្សតិ** បពិត្រព្រះរាជកុមារ ឥឡូវនេះ អាជ្ញារបស់ព្រះរាជាធ្វើអ្វីដល់ព្រះអង្គបាន ហើយឲ្យព្រះរាជកុមារឈានកន្ទង់គំនូសទៅ ។

ព្រះរាជកុមារទូលថា ព្រះបិតា ព្រះបិតា ហើយរត់ទៅទាន់ព្រះ

រាជា ។ ព្រះរាជាទ្រង់ទតឃើញព្រះរាជកុមារហើយ ទ្រង់ព្រះតម្រិះថា អញ ( អាច ) គ្រប់គ្រងរាជសម្បត្តិ គ្រប់គ្រងមហាជននេះ បាន ឥឡូវនេះ គ្រប់គ្រងទារកម្នាក់មិនបានឬ ទើបនាំព្រះរាជកុមារនោះ ទៅព្រៃ ទ្រង់ឃើញបណ្ណសាលាដែលព្រះបច្ចេកពុទ្ធទាំងឡាយមុន ៗ ធ្លាប់នៅហើយក្នុងព្រៃនោះ ទើបអាស្រ័យនៅជាមួយព្រះរាជឱរស ។

ក្នុងកាលនោះ ព្រះរាជកុមារដែលធ្លាប់ស្និទ្ធស្នាលក្នុងក្រឡាព្រះបន្ទំដ៏ប្រសើរ តែកាលផ្ទំក្នុងទីដែលក្រាលដោយស្មៅ ឬលើគ្រែដែលត្បាញដោយវល្លិ ត្រូវរងានិងខ្យល់បៀតបៀន ក៏ព្រះកន្សែងទូលថា បពិត្រព្រះបិតា ត្រជាក់ណាស់ បពិត្រព្រះបិតា ក្តៅណាស់ បពិត្រព្រះបិតា មូសនិងរបោមច្រើនណាស់ បពិត្រព្រះបិតា ខ្ញុំឃ្លានណាស់ ខ្ញុំស្រេកណាស់ ។ ព្រះរាជាលួងលោមព្រះរាជកុមារនោះ ញុំាងរាត្រីឲ្យកន្លងទៅ ។ ក្នុងពេលថ្ងៃ ក៏ត្រាច់បិណ្ឌបាត នាំភត្តមកឲ្យព្រះរាជកុមារនោះ ភត្តនោះ ជាភត្តដែលលាយគ្នាដោយស្ពៅ ស្ពួយ និងសម្ទសណ្ដែកបាយជាដើម ព្រះរាជកុមារទ្រង់ស្រេកឃ្លាន ក៏សោយភត្តនោះ ដោយអំណាចសេចក្តីស្រេកឃ្លាន លុះកាលមិនយូរប៉ុន្មាន ក៏ទ្រង់ស្គាំងស្គមដូចផ្កាឈូកដែលដាក់ក្នុងទីដែលមានកម្តៅថ្ងៃដូច្នោះ ។ ចំណែកព្រះបច្ចេកពោធិសត្វទ្រង់មិនសម្ដែងអាការខុសប្លែកឡើយ ទ្រង់សោយដោយកម្លាំងនៃការពិចារណា ។ បន្ទាប់អំពីនោះ ព្រះបច្ចេកពោធិសត្វទ្រង់ក៏ឲ្យព្រះរាជ

កុមារយល់ព្រមថា នែបា អាហារដែលប្រណីត រមែងបានក្នុងនគរ ពួកយើងនឹងទៅក្នុងនគរនោះ ។

ព្រះរាជកុមារទូលថា ករុណាថ្លៃវិសេស ព្រះបិតា ។ បន្ទាប់អំពីនោះ ទ្រង់នាំព្រះរាជកុមារនោះ យាងត្រឡប់តាមផ្លូវដែលយាងមកនោះឯង ។ ចំណែកព្រះទេវីព្រះមាតារបស់ព្រះរាជកុមារ ព្រះនាងព្រះតម្រិះថា ឥឡូវនេះ ព្រះរាជាទ្រង់នាំព្រះរាជកុមារទៅប្រថាប់គង់ក្នុងព្រៃ មិនយូរប៉ុន្មាន គង់នឹងយាងត្រឡប់ដោយកាលពីរបីថ្ងៃប៉ុណ្ណោះ ទើបព្រះនាងឲ្យព័ទ្ធរបងក្នុងទីដែលគួសដោយឈើច្រត់ ហើយគង់នៅ ។ លំដាប់នោះ ព្រះរាជាប្រថាប់ឈរក្នុងទីមិនឆ្ងាយអំពីរបងនោះ ទ្រង់បញ្ជូនព្រះរាជកុមារទៅថា នែបុត្ត មាតារបស់បុត្តអង្គុយក្នុងទីនោះ ចូរបុត្តទៅចុះហើយប្រថាប់ឈរមើលរហូតដល់ព្រះរាជកុមារយាងដល់ទីនោះ ដោយព្រះតម្រិះថា បុគ្គលណាមួយ កុំបីបៀតបៀនកុមារនោះ ។ ព្រះរាជកុមារនោះ យាងទៅកាន់សម្នាក់របស់ព្រះមាតា ។

បុរសដែលជាអ្នករក្សាទាំងឡាយ ឃើញព្រះរាជកុមារនោះហើយទូលដល់ព្រះទេវី ។ ព្រះទេវីមានស្ត្រីរបាំ ២ ម៉ឺននាក់ ចោមរោមហើយយាងទៅទទួល និងត្រាស់សួរអំពីព្រះរាជា កាលព្រះនាងបានស្តាប់ថាព្រះរាជានឹងយាងមកខាងក្រោយ ទើបបញ្ជូនមនុស្សទាំងឡាយទៅ ឯព្រះរាជា ក៏យាងទៅកាន់លំនៅរបស់ព្រះអង្គមួយរំពេចនោះឯង ។

មនុស្សទាំងឡាយមិនឃើញព្រះរាជា ក៏ត្រឡប់មកវិញ បន្ទាប់អំពីនោះ ព្រះទេវីព្រះនាងប្រាសចាកសេចក្ដីសង្ស័យ ក៏នាំព្រះរាជឱរសចូលកាន់ព្រះនគរ អភិសេកព្រះរាជកុមារនោះ ទុកក្នុងរាជសម្បត្តិ ។ ចំណែកព្រះរាជាយាងដល់លំនៅរបស់ព្រះអង្គហើយ ប្រថាប់គង់ក្នុងទីនោះ ចម្រើនវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ត្រាស់ឧទានគាថានេះ ក្នុងកណ្ដាលនៃ **ព្រះបច្ចេកពុទ្ធ** ទាំងឡាយ ត្រង់គល់មញ្ជូសកព្រឹក្សថា

ឯវំ ទុតិយេន សហា មមស្ស
វាចាភិលាបោ អភិសជ្ជនា វា
ឯតំ ភយំ អាយតិ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ឯការធ្វើយធ្ងន់ដោយវាចាក្ដី ការជាប់ចំពាក់ក្ដី ជាមួយនឹងបុគ្គលគម្រប់ពីររបស់អញ ដូចកងមាសមួយគូ មានយ៉ាងនុ៎ះ បុគ្គលកាលរំពឹងឃើញនូវភ័យនុ៎ះ ក្នុងកាលខាងមុខ គប្បីប្រព្រឹត្តតែម្នាក់ឯងដូចកុយរមាស ។

ឧទានគាថានោះ ដោយអត្ថងាយយល់ហើយ ។

ក្នុងឧទានគាថានេះ មានអធិប្បាយដូចតទៅនេះថា ការបន្ទីវាចា

សន្ទនា ឬវាចាជាគ្រឿងជាប់ចំពាក់ ដោយអំណាចសេចក្ដីស្រឡាញ់ក្នុងកុមារនោះ កើតហើយដល់ខ្ញុំ មានកុមារម្នាក់ជាសម្លាញ់ ដែលរង់ចាំរំអុករឿងរ៉ាវ រឿងក្ដៅជាដើម បើខ្ញុំមិនលះបង់កុមារនោះសោត បន្ទាប់អំពីនោះ ការបន្ទីវាចាសន្ទនា ឬវាចាដោយពាក្យស្និទ្ធស្នាល ជាមួយបុគ្គលដែលនៅជាមួយ ក៏នឹងមានយ៉ាងនោះ រហូតដល់ឥឡូវនេះ ។ ខ្ញុំសម្លឹងឃើញភ័យនេះ តទៅខាងមុខថា ការបន្ទីវាចាសន្ទនា និងវាចាជាគ្រឿងជាប់ចំពាក់ទាំង ២ នេះ នឹងធ្វើអន្តរាយដល់ការសម្រេចគុណវិសេស ទើបលះបង់កុមារនោះ ហើយបដិបត្តិដោយឧបាយ សម្រេចបច្ចេក-ពោធិញ្ញាណហើយ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

## អាយតិភយគាថាទី ៥ ចប់

# កាមគាថា

*គាថាថា* **កាមា ហិ ចិត្រា** *ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។*

*បានឮថា សេដ្ឋីបុត្តក្នុងនគរពារាណសី បានតំណែងសេដ្ឋីតាំងអំពីនៅក្មេងនោះឯង ។ សេដ្ឋីបុត្តនោះ មានប្រាសាទ ៣ សម្រាប់ ៣ រដូវ បានទទួលការបម្រើដោយសម្បត្តិទាំងពួង ដូចទេវកុមារ ។ លំដាប់នោះ សេដ្ឋីបុត្តនោះ ទាំងនៅក្មេងនុ៎ះឯង គិតថា នឹងបួស ទើបលាមាតាបិតា ឯមាតាបិតា ក៏ហាមឃាត់ ។ កុលបុត្តនោះ ក៏រំអុករឿយ ៗ ។ មាតាបិតាក៏ហាមឃាត់ទៀត ដោយប្រការផ្សេង ៗ ថា នែបា បាជាមនុស្សសុខុមាលជាតិ បព្វជ្ជាធ្វើបានដោយក្រ ដូចការដើរទៅមកលើមុខកាំបិតកោរ ។ សេដ្ឋីបុត្តនោះ ក៏នៅតែរំអុកយ៉ាងនោះឯង ទើបមាតាបិតាគិតថា បើកូននេះបួស ពួកយើងក៏មានទោមនស្ស បើរារាំងកូន កូនក៏កើតទោមនស្ស សូមឲ្យទោមនស្សកើតដល់ពួកយើងចុះ កុំបីមានដល់កូនយើងឡើយ ទើបអនុញ្ញាតឲ្យបួស ។ បន្ទាប់អំពីនោះ សេដ្ឋីបុត្តនោះ មិនដាក់ចិត្តដល់បរិវារជនដែលកំពុងបរិទេវនាការ ទៅកាន់ព្រៃឥសិបតនៈ បួសក្នុងសម្នាក់* **ព្រះបច្ចេកពុទ្ធ**

ទាំងឡាយ ។ សេនាសនៈដ៏ប្រសើរ មិនដល់លំដាប់កុលបុត្តនោះ ទើបកុលបុត្តនោះ ក្រាលកន្ទេលផែងលើគ្រែតូច ហើយសិង ។ កុលបុត្តនោះ ធ្លាប់ស្និទ្ធស្នាលក្នុងដំណេកល្អមកអំពីមុន ទើបមានសេចក្ដីលំបាកក្រៃលែង អស់មួយយប់ទល់ភ្លឺ កាលរាត្រីអស់ហើយ កុលបុត្តនោះ ធ្វើបរិកម្មសរីរៈ ហើយកាន់បាត្រនិងចីវរ ចូលទៅបិណ្ឌបាត មួយអន្លើដោយព្រះបច្ចេកពុទ្ធទាំងឡាយ ។ បណ្ដាព្រះបច្ចេកពុទ្ធទាំងនោះ ព្រះបច្ចេកពុទ្ធដែលចាស់ជាង បាននូវសេនាសនៈប្រសើរនិងភោជនប្រសើរ ព្រះបច្ចេកពុទ្ធដែលជានវកៈ បាននូវសេនាសនៈនិងភោជនដ៏សៅហ្មងតាមមានតាមបាន ។ កុលបុត្តនោះ បានទទួលសេចក្ដីទុក្ខយ៉ាងក្រៃលែង ព្រោះភោជនសៅហ្មងនោះ ។ លុះកន្លងទៅ ពីរបីថ្ងៃប៉ុណ្ណោះ ក៏ស្គាំងស្គម មានពណ៌សម្បុរសៅហ្មង ហើយក៏នឿយណាយ ព្រោះសមណធម៌មិនទាន់ដល់នូវការចាស់ក្លា ។ បន្ទាប់អំពីនោះ ក៏បញ្ជូនទូតឲ្យជម្រាបដល់មាតាបិតា ហើយសឹក ។ លុះកន្លងទៅពីរបីថ្ងៃ កុលបុត្តនោះ មានកម្លាំងហើយ បំណងនឹងបួសទៀត ។ បន្ទាប់អំពីនោះ ទើបបួសជាលើកទី ២ ហើយសឹកទៀត ។ ក្នុងលើកទី ៣ កុលបុត្តនោះ ក៏បួសទៀត ហើយបដិបត្តិដោយប្រពៃ ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់ហើយ

នូវបច្ចេកពោធិញ្ញាណ បានពោលឧទានគាថានេះ ហើយពោលព្យាករណ៍គាថានេះឯងដដែលទៀត ក្នុងកណ្ដាលព្រះបច្ចេកពុទ្ធទាំងឡាយថា

**កាមា ហិ ចិត្រា មធុរា មនោរមា**
**វិរូបរូបេន មថេន្តិ ចិត្តំ**
**អាទីនវំ កាមគុណេសុ ទិស្វា**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

ពិតណាស់ កាមទាំងឡាយដ៏វិចិត្រ មានរសផ្អែម ជាទីរីករាយនៃចិត្ត រមែងញាំញីនូវចិត្ត ដោយសភាពដ៏ប្លែក ៗ បុគ្គលឃើញទោសក្នុងកាមគុណទាំងឡាយហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

បណ្ដាបទទាំងនោះ បទថា **កាមា** បានដល់ កាម ២ យ៉ាង គឺវត្ថុកាម ១ កិលេសកាម ១ ។ ក្នុងកាម ២ យ៉ាងនោះ ធម៌គឺអារម្មណ៍ ដូចជាបិយរូប (រូបជាទីស្រឡាញ់) ជាដើម ឈ្មោះថា វត្ថុកាម រាគៈគ្រប់ប្រភេទ ឈ្មោះថា កិលេសកាម ។ តែក្នុងទីនេះ លោកបំណងយកវត្ថុកាម ។ កាមទាំងឡាយជារបស់វិចិត្រ

ព្រោះមានច្រើនយ៉ាង មានរូបជាដើម ។ ឈ្មោះថា មានរសផ្អែម ព្រោះជាទីពេញចិត្តរបស់សត្វលោក ។ ឈ្មោះថា ជាទីរីករាយនៃចិត្ត ព្រោះធ្វើឲ្យចិត្តរបស់ពាលបុថុជ្ជនត្រេកអរ ។ ឈ្មោះថា មានសភាពដ៏ប្លែក ៗ បានដល់ ដោយសភាពផ្សេង ៗ លោកអធិប្បាយថា ដោយសភាវៈផ្សេង ៗ ។ ពិតហើយ កាមទាំងនោះ វិចិត្រល្អដោយអំណាចរូបជាដើម មានរូបផ្សេង ៗ ច្រើនប្រភេទ ដោយអំណាចពណ៌ខៀវជាដើម ក្នុងរូបជាដើម ។ អធិប្បាយថា កាមទាំងឡាយ សម្តែងនូវការពេញចិត្ត ដោយប្រការនោះ ៗ ដោយរូបផ្សេង ៗ នោះ ៗ យ៉ាងនេះ រមែងញាំញីនូវចិត្ត គឺមិនឲ្យត្រេកអរក្នុងការបួស ។ ពាក្យដ៏សេសក្នុងគាថានេះ ប្រាកដច្បាស់ហើយ សូម្បីបទសរុប ក៏គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងគាថាទី ១ នោះឯង ដោយរួម ២ បទ ឬ ៣ បទ ប្រកបគ្នា ។

កាមគាថាទី ៦ ចប់

# ឡូតិគាថា

គាថាថា **ឡូតី ច** ដូច្នេះជាដើម មានហេតុកើតដូចម្តេច ។

បានឮថា ក្នុងនគរពារាណសី បូសកើតឡើងដល់ព្រះរាជា ។ វេទនាដ៏ខ្លាំងក្លាបានចម្រើនឡើង គ្រូពេទ្យទាំងឡាយក្រាបទូលថា **សត្ថកម្មេន វិនា ផាសុ ន ហោតិ** វៀរសត្ថកម្ម គឺការវះកាត់ នឹងមិនមានផាសុក ។ ព្រះរាជាទ្រង់ឲ្យអភ័យដល់ពេទ្យទាំងនោះ ហើយឲ្យធ្វើការវះកាត់ ។ ពេទ្យទាំងនោះ វះបូសនោះហើយ នាំខ្ទុះនិងឈាមចេញ ធ្វើឲ្យអស់នូវការឈឺចាប់ហើយ យកសំពត់រុំ និងថ្វាយដំបូន្មានព្រះរាជា ឲ្យសោយក្រយាស្ងោយដែលផ្សំដោយសាច់ដែលសៅហ្មង ។ ព្រះរាជាទ្រង់មានព្រះសរីរៈស្គាំងស្គមព្រោះភោជនសៅហ្មង បូសរបស់ព្រះរាជានោះក៏ក្រៀមទៅ ។ ព្រះរាជាទ្រង់សម្គាល់ថា ទ្រង់មានផាសុកហើយ ទើបសោយក្រយាស្ងោយមានរសដ៏ប្រសើរ ព្រោះហេតុនោះ ទើបទ្រង់មានកម្លាំង ។ បូសរបស់ព្រះរាជានោះ ត្រឡប់កើតដូចមុនទៀត ។ កាលបើដូច្នោះ ទើបទ្រង់ឲ្យធ្វើការវះកាត់អស់វារៈ ៣ ដង ត្រូវពេទ្យទាំងឡាយវៀរហើយចាកការរក្សា ទើបទ្រង់នឿយណាយ លះមហារាជសម្បត្តិចេញបួស ចូលព្រៃ ប្រារព្ធវិបស្សនាអស់ ៧ ឆ្នាំ ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ បានពោលឧទានគាថានេះថា

**ឞ្លីតី ច គណ្ឌោ ច ឧបទ្ទវោ ច**
**រោគោ ច សល្លញ្ច ភយញ្ច មេតំ**
**ឯតំ ភយំ កាមគុណេសុ ទិស្វា**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

*បុគ្គលឃើញនូវភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយ*
*ថា នេះជាចង្រៃ ជាបូស ជាឧបទ្រព ជារោគ*
*ជាសរ ទាំងជាភ័យរបស់អញហើយ គប្បីប្រព្រឹត្ត*
*តែម្នាក់ឯង ដូចកុយរមាស ។*

*លុះពោលគាថានេះហើយ បានទៅកាន់ញកភ្នំនន្ទមូលកៈ ។*

*បណ្ដាបទទាំងនោះ បទថា* **ឞ្លីតី** *បានដល់ ចង្រៃ ។ ពាក្យថា ចង្រៃនេះ ជាឈ្មោះនៃហេតុរបស់សេចក្ដីវិនាស ដែលជាចំណែកនៃអកុសលដែលចូលមក ។ ព្រោះហេតុនោះ កាមគុណទាំងនោះ ក៏ឈ្មោះថា ចង្រៃ ព្រោះអត្ថថា ជាហេតុនាំមកនូវសេចក្ដីវិនាសច្រើនយ៉ាង និងព្រោះជាទីប្រជុំចុះនៃសេចក្ដីវិនាស ។ បូស រមែងហូរចេញនូវរបស់មិនស្អាត គឺហើមឡើងនិងទុំ ហើយក៏បែកធ្លាយទៅ ព្រោះហេតុនោះ កាមគុណទាំងនោះ ឈ្មោះថា បូស ព្រោះជាទីហូរចេញនូវរបស់មិនស្អាត គឺកិលេស និងព្រោះភាពជារបស់បែកចេញ និងព្រោះជារបស់ហើមឡើង ទុំដោយការកើត ការចាស់ និងការបែកធ្លាយ ។ ឈ្មោះថា*

ឧបទ្រព ព្រោះអត្ថថា ចង្រៃ អធិប្បាយថា ញុំាងការវិនាសឲ្យកើតរមែងញាំញី គឺគ្របសង្កត់ ។

បទថា **ឧបទ្ទវ** នោះ ជាឈ្មោះនៃទោសទាំងឡាយ មានរាគៈដែលដូចជាបូសជាដើម ។ ព្រោះហេតុនោះ កាមគុណទាំងឡាយឈ្មោះថា ឧបទ្រព ព្រោះជាហេតុមិនឲ្យឈានចុះកាន់ព្រះនិព្វានដែលខ្លួនមិនទាន់ដឹង និងព្រោះជាទីតាំងនៃឧបទ្រពទាំងពួង ព្រោះកាមគុណទាំងនោះ ញុំាងនូវការក្តៅក្រហាយ គឺកិលេសឲ្យកើតឡើង ញុំាងនូវការមិនមានរោគ ពោលគឺសីល ឲ្យដល់នូវការបែកធ្លាយ រមែងប្លន់នូវការមិនមានរោគតាមប្រក្រតីនោះឯង ព្រោះហេតុនោះ ទើបឈ្មោះថា រោគ ព្រោះអត្ថថា ប្លន់នូវការមិនមានរោគនោះឯង ។ ឈ្មោះថា **សល្លំ** ព្រោះអត្ថថា តាមចូលទៅខាងក្នុង ព្រោះអត្ថថា ធ្វើនូវការក្តៅក្រហាយខាងក្នុង និងព្រោះអត្ថថា ជារបស់នាំចេញបានដោយក្រ ។ ឈ្មោះថា **ភយំ** ព្រោះនាំមកនូវភ័យក្នុងភពបច្ចុប្បន្ន និងក្នុងសម្បរាយិកភព ( គឺភពខាងមុខ ) ។ បទថា **មេតំ** មកពី **មេ** និង **ឯតំ** ។ បទដ៏សេសក្នុងគាថានេះ ប្រាកដច្បាស់ហើយ ។ សូម្បីពាក្យនិគម ក៏គប្បីជ្រាបដោយន័យដូចដែលបានពោលហើយនោះឯង ។

## ឰត្តិគាថាទី ៧ ចប់

# សីតាលុកគាថា

គាថាថា **សីតញ្ច** ដូច្នេះជាដើម មានហេតុកើតដូចម្តេច ។

បានឮថា ក្នុងនគរពារាណសី មានព្រះរាជាព្រះនាមថា សីតាលុកព្រហ្មទត្ត ទ្រង់បួសហើយ គង់នៅក្នុងកុដិស្មៅក្នុងព្រៃ ប្រទេសនោះ កាលរងា ក៏មានតែភាពរងា កាលក្តៅ ក៏មានតែភាពក្តៅប៉ុណ្ណោះ ព្រោះជាប្រទេសតាំងនៅក្នុងទីវាល ភិក្ខាហារក្នុងគោចរគ្រាម ក៏មិនបានតាមសេចក្តីត្រូវការ ទឹកផឹកសម្រាប់អ្នកផឹក ក៏រកបានដោយក្រ ខ្យល់ កម្តៅថ្ងៃ របោម សត្វលូនវារ ក៏បៀតបៀន ។ ព្រះរាជានោះ ទ្រង់ព្រះតម្រិះដូច្នេះថា ក្នុងទីប្រមាណកន្លះយោជន៍អំពីនេះ មានប្រទេសដែលសម្បូរ អន្តរាយទាំងនោះ រមែងមិនមានក្នុងប្រទេសនោះ ណ្ហើយចុះ អាត្មាអញគប្បីទៅក្នុងប្រទេសនោះ កាលនៅជាសុខ ក៏អាចសម្រេចលោកុត្តរធម៌បានងាយ ហើយទ្រង់ព្រះតម្រិះទៀតថា ធម្មតាបព្វជិតទាំងឡាយ មិនគួរធ្លាក់ទៅក្នុងអំណាចនៃបច្ច័យ និងរមែងញុំាំងចិត្តបែបនោះ ឲ្យប្រព្រឹត្តទៅក្នុងអំណាច រមែងមិនប្រព្រឹត្តទៅក្នុងអំណាចរបស់ចិត្ត អាត្មាអញនឹងមិនទៅទីនោះឡើយ ។ កាលទ្រង់ពិចារណាហើយ ទ្រង់មិនយាងទៅ ទ្រង់ពិចារណាចិត្តដែលកើតឡើងហើយយ៉ាងនេះ អស់វារៈ ៣ ដង ហើយយាងត្រឡប់ ។ តាំងអំពីនោះមក គង់នៅក្នុង

ព្រៃនោះឯង អស់ ៧ ឆ្នាំ ទ្រង់បដិបត្តិដោយប្រពៃ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកសម្ពោធិញ្ញាណហើយ ត្រាស់ឧទានគាថានេះថា

**សីតញ្ច ឧណ្ហញ្ច ខុទំ បិបាសំ**

**វាតាតបេ ឌំសសិរីសបេ ច**

**សព្វានិបេតានិ អភិភវិត្វា**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

*បុគ្គលគ្របសង្កត់ នូវសត្រូវទាំងអស់នុ៎ះ គឺត្រជាក់*

*ក្តៅ គម្លាន សម្រេក ខ្យល់និងកម្តៅថ្ងៃ របោមនិងសត្វ*

*លូនហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។*

*លុះពោលគាថានេះហើយ ទើបនិមន្តទៅកាន់ញកភ្នំនន្ទមូលកៈ ។*

*បណ្តាបទទាំងនោះ បទថា* **សីតញ្ច** *សេចក្តីថា រងាមាន ២ យ៉ាង គឺរងាមានធាតុខាងក្នុងកម្រើកជាបច្ច័យ ១ រងាមានធាតុខាងក្រៅកម្រើកជាបច្ច័យ ១ ។ កម្តៅក៏មាន ២ យ៉ាងដូចគ្នា ។ រុយពណ៌លឿងឈ្មោះថា* **ឌំស** *( របោម ) ។ បទថា* **សរីសបា** *បានដល់ទីឃជាតិប្រភេទណាមួយ ដែលលូនវារទៅ ។ ពាក្យដ៏សេស ប្រាកដច្បាស់ហើយ ។ សូម្បីបទសរុប គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។*

សីតាលុកគាថាទី ៨ ចប់

# នាគគាថា

គាថាថា **ជាតោរ** ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។

បានឮថា ក្នុងនគរពារាណសី ព្រះរាជាមួយអង្គសោយរាជសម្បត្តិអស់វេលា ២០ ឆ្នាំ សោយទិវង្គតហើយឆេះក្នុងនរកអស់ ២០ ឆ្នាំដូចគ្នា ( បន្ទាប់មក ) កើតក្នុងកំណើតដំរី ក្នុងហិមវន្តប្បទេស មានខន្ធកើតល្អហើយ មានរាងកាយទាំងមូលមានពណ៌ដូចផ្កាឈូក ជាដំរីមេហ្វូង ជាដំរីធំ ។ កូនដំរីទាំងឡាយ រមែងទំពាស៊ីមែកឈើដែលស្ដេចដំរីនោះកាច់ក្នុងវេលាចុះកាន់ទឹក ដំរីញីទាំងឡាយក៏បៀតបៀនស្ដេចដំរីនោះ ដោយភក់ ។ រឿងទាំងអស់ដូចរឿងស្ដេចដំរីបាលិលេយ្យកៈ ។ ស្ដេចដំរីនោះនឿយណាយ ក៏ចៀសចេញអំពីហ្វូង បន្ទាប់អំពីនោះ ដំរីទាំងនោះ ក៏ជាប់តាមស្ដេចដំរីនោះទៀត ដោយដើរតាមស្នាមជើង ។ ស្ដេចដំរីចៀសចេញទៅអស់វារៈ ៣ ដង ក៏ត្រូវហ្វូងដំរីដើរតាមទៀត ទើបគិតតទៅថា ឥឡូវនេះ ចៅរបស់អញសោយរាជសម្បត្តិក្នុងក្រុងពារាណសី ណ្ហើយចុះ អញគប្បីទៅកាន់ព្រះរាជឧទ្យាន ក្នុងជាតិមុនរបស់អញ ចៅរបស់អញនឹងរក្សាអញក្នុងឧទ្យាននោះ ។ កាលហ្វូងដំរីដេកលក់ក្នុងកណ្ដាលយប់ ទើបលះបង់ហ្វូងចូលទៅកាន់ព្រះរាជឧទ្យាននោះឯង ។

អ្នករក្សាព្រះរាជឧទ្យានបានឃើញហើយ ក៏ទូលសេចក្ដីនោះដល់

ព្រះរាជា ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អញនឹងចាប់ដំរី ដូច្នេះហើយ ទ្រង់ចោមរោមដោយសេនាយាងទៅ ដំរីក៏ដើរបែរមុខឆ្ពោះមករកព្រះរាជា នោះឯង ព្រះរាជាទ្រង់ព្រះតម្រិះថា ដំរីនេះ ដើរមករកអញ ទើបផ្ទាប់ធ្នូ ឡើង ប្រថាប់ឈរ ។ បន្ទាប់អំពីនោះ ដំរីនោះគិតថា ព្រះរាជានេះ គប្បី បាញ់អញពិត ទើបនិយាយដោយវាចាមនុស្សថា បពិត្រព្រហ្មទត្ត សូម ទ្រង់កុំបាញ់ខ្ញុំឡើយ ខ្ញុំធ្លាប់ជាជីតារបស់ទ្រង់ ។

ព្រះរាជាត្រាស់សួរថា អ្នកនិយាយអ្វី ហើយត្រាស់សួររឿងទាំង អស់ ស្តេចដំរីក៏ប្រាប់រឿងទាំងអស់ដែលទាក់ទងដោយរាជសម្បត្តិ ការ ប្រព្រឹត្តទៅក្នុងកំណើតនរក និងកំណើតដំរី ។ ព្រះរាជាទ្រង់លួងលោម ថា កុំខ្លាច កុំធ្វើឲ្យអ្នកណាមួយខ្លាចឡើយ ហើយទ្រង់ឲ្យគេទំនុកបម្រុង អាហារ កម្រាល និងគ្រឿងដំរីដល់ស្តេចដំរីនោះ ។

សម័យថ្ងៃមួយ ព្រះរាជាប្រថាប់គង់លើកដំរីដ៏ប្រសើរ ទ្រង់ព្រះ តម្រិះថា ដំរីនេះ ធ្លាប់សោយរាជសម្បត្តិអស់កាល ២០ ឆ្នាំ ធ្លាក់នរក ហើយកើតក្នុងកំណើតតិរច្ឆាន ដោយវិបាកដែលនៅសេសសល់នោះឯង កាលមិនអាចអត់ធន់នូវការច្របូកច្របល់ ព្រោះនៅរួមគ្នាជាពួកក្នុងព្រៃ នោះ ទើបមកក្នុងទីនេះ ឱហ្ន៎ ! ការនៅក្នុងពួកគណៈជាទុក្ខ ឯការនៅ ម្នាក់ឯងប៉ុណ្ណោះ ជាសុខ ទ្រង់ប្រារព្ធវិបស្សនាក្នុងទីនោះឯង ទ្រង់ធ្វើឲ្យ ជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ ។

អាមាត្យទាំងឡាយចូលទៅគាល់ **ព្រះបច្ចេកពុទ្ធ** នោះ ដែលនៅជាសុខដោយលោកុត្តរសុខ ផ្គងអញ្ជលី ក្រាបទូលថា ដល់កាលចេញដំណើរហើយ មហារាជ ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធត្រាស់ថា យើងមិនមែនជាព្រះរាជា ហើយត្រាស់គាថានេះ ដោយន័យមុននោះឯងថា

ឆាគោវ យូថានិ វិវជ្ជយិត្វា
សញ្ជាតខន្ធោ បទុមី ឧឡារោ
យថាភិរន្តំ វិហរំ អរញ្ញេ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ដំរីមានខ្លួនសមរម្យ មាំមួន មានសម្បុរដូច
ផ្កាឈូក[១] កាលលះបង់ហ្វូងហើយ នៅក្នុងព្រៃ
គួរដល់អធ្យាស្រ័យយ៉ាងណា បុគ្គលគប្បីប្រព្រឹត្ត
តែម្នាក់ឯង ដូចកុយរមាស យ៉ាងនោះឯង ។

គាថានោះ មានអត្ថនៃបទប្រាកដច្បាស់ហើយ ។ តែក្នុងទីនេះមានពាក្យអធិប្បាយប្រកបសេចក្ដីដូចតទៅនេះថា គាថានោះ លោកពោលរឿងពិត មិនមែនពោលតាមដែលបានស្ដាប់មក ។ ដំរីនេះ ឈ្មោះថា នាគ ព្រោះមិនមកកាន់ភូមិដែលខ្លួនមិនបានទូន្មាន ព្រោះទូន្មានខ្លួនហើយ ក្នុងសីលដែលជាទីស្រឡាញ់របស់ព្រះអរិយៈក៏បាន ព្រោះជាអ្នក

---

១-ច្បាប់និស្សយៈភូមា ប្រែថា ជាដំរីដ៏ប្រសើរ មានរាងកាយដូចផ្កាឈូក ។

មានរាងកាយធំ ក៏បានយ៉ាងណា ក្នុងកាលណាហ្ន៎ អាត្មាអញគប្បីជានាគ ព្រោះមិនបានត្រឡប់មកកាន់ភូមិដែលមិនបានទូន្មាន ព្រោះភាពដែលខ្លួនទូន្មានល្អហើយ ក្នុងសីលទាំងឡាយដែលព្រះអរិយៈពេញចិត្ត ព្រោះមិនធ្វើបាប និងព្រោះមិនត្រឡប់មកកាន់ភាពយ៉ាងនេះទៀត ឬព្រោះភាពដែលខ្លួនមានសរីរៈធំ គឺគុណ មានសភាពយ៉ាងនោះដែរ ។

ម្យ៉ាងទៀត ដំរីនោះលះបង់នូវហ្វូង ហើយនៅក្នុងព្រៃតាមគាប់ចិត្ត ដោយសេចក្ដីសុខ គឺការត្រាច់ទៅតែម្នាក់ឯងដូចកុយរមាស យ៉ាងណា ក្នុងកាលណាហ្ន៎ អាត្មាអញនឹងបាននៅក្នុងព្រៃតាមគាប់ចិត្ត ដោយវិហារសុខ ដោយចំណែកមួយ បានដល់ ដោយសេចក្ដីសុខដែលកើតអំពីឈាន គឺនៅក្នុងព្រៃដោយប្រការដែលខ្លួនមានសេចក្ដីសុខ ឬតាមសេចក្ដីប្រាថ្នា ត្រាច់ទៅតែម្នាក់ឯង គឺគប្បីប្រព្រឹត្តដូចកុយរមាស មានសភាពយ៉ាងនោះដែរ ។

ម្យ៉ាងទៀត ដំរីនោះឈ្មោះថា សញ្ជាតក្ខន្ធ ព្រោះមានរាងកាយរៀបរយល្អហើយ យ៉ាងណា ក្នុងកាលណាហ្ន៎ អាត្មាអញគប្បីឈ្មោះថាមានខន្ធកើតល្អហើយ ព្រោះភាពជាធំដោយសីលក្ខន្ធ ដែលជាអសេក្ខៈ មានសភាពយ៉ាងនោះដែរ ។

ម្យ៉ាងទៀត ដំរីនោះដូចផ្កាឈូក ព្រោះមានរាងដូចគ្នានឹងផ្កាឈូក ឬព្រោះកើតហើយក្នុងត្រកូលដំរីបទុម យ៉ាងណា ក្នុងកាលណាហ្ន៎

*អាត្មាអញគប្បីឈ្មោះថា ដូចជាផ្កាឈូក ព្រោះភាពជាអ្នកមានកាយត្រង់ដូចផ្កាឈូក ឬព្រោះកើតហើយក្នុងផ្កាឈូក គឺអរិយជាតិ មានសភាពយ៉ាងនោះដែរ ។*

*ម្យ៉ាងទៀត ដំរីនោះ ឧត្តមដោយកម្លាំងនិងសន្ទុះជាដើម យ៉ាងណា ក្នុងកាលណាហ្ន៎ អាត្មាអញគប្បីឧត្តមដោយគុណធម៌ មានការប្រព្រឹត្តផ្លូវកាយបរិសុទ្ធិជាដើម ឬដោយសីល សមាធិ និងបញ្ញា ជាគ្រឿងចាក់ធ្លុះជាដើម មានសភាពយ៉ាងនោះដែរ ។ យើងកាលគិតយ៉ាងនេះ ទើបប្រារព្ធវិបស្សនា បានត្រាស់ដឹងនូវបច្ចេកពោធិញ្ញាណហើយ ។*

**នាគគាថាទី ៩ ចប់**

# អដ្ឋានគាថា

គាថាថា **អដ្ឋាន តំ** ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។

បានឮថា ឱរសរបស់ព្រះបាទពារាណសី ទ្រង់នៅក្មេងនោះឯង មានបំណងនឹងបួស ទើបទូលអង្វរព្រះមាតាបិតា ។ ព្រះមាតាបិតាទ្រង់ឃាត់ព្រះរាជឱរសនោះ ។ ព្រះរាជឱរសនោះ សូម្បីត្រូវឃាត់ ក៏នៅតែរំអុកដូចមុនថា នឹងបួស ។ ព្រះមាតាបិតាក៏ទ្រង់អនុញ្ញាតដូចសេដ្ឋីបុត្តដែលពោលខាងដើម ហើយឲ្យព្រះរាជឱរសប្ដេជ្ញាថា បួសហើយត្រូវនៅក្នុងឧទ្យានប៉ុណ្ណោះ ។ ព្រះរាជឱរសនោះបានធ្វើតាមនោះ ។ ព្រះមាតារបស់ព្រះអង្គ ចោមរោមដោយស្រីរបាំ ២ ម៉ឺន យាងទៅកាន់ឧទ្យានអំពីព្រឹក ឲ្យព្រះរាជឱរសឆាន់បបរ ក្នុងរវាងកត្ត ព្រះនាងឲ្យទំពារបស់ដែលគួរទំពាជាដើម ព្រះនាងសន្ទនាជាមួយព្រះរាជឱរសនោះ រហូតដល់ថ្ងៃត្រង់ ទើបយាងចូលនគរ ។ ចំណែកព្រះបិតាក៏យាងមកក្នុងពេលថ្ងៃត្រង់ ព្រះរាជឱរសនោះសោយ ទ្រង់ក៏សោយដែរ ទ្រង់សន្ទនាជាមួយព្រះរាជឱរសនោះ អស់ពេលថ្ងៃ ក្នុងពេលល្ងាច ទ្រង់ដាក់អ្នកប្រណិប័តន៍ទុក ហើយយាងចូលព្រះនគរ ។ ព្រះរាជឱរសនោះ មិនស្ងាត់អស់កាលទាំងថ្ងៃទាំងយប់ ដោយប្រការដូច្នេះ ។

សម័យនោះឯង **ព្រះបច្ចេកពុទ្ធ** ព្រះនាមថា អាទិច្ចពន្ធុ នៅត្រង់

ញកភ្ជំនទ្ធមូលកៈ កាលពិចារណាមើល ក៏បានឃើញព្រះរាជបុត្តនោះថា ព្រះរាជកុមារទ្រង់អាចបួស តែមិនអាចកាត់ការប្រឡូកប្រឡំបាន ។ បន្ទាប់អំពីនោះ ក៏ពិចារណាថា ព្រះរាជកុមារនេះ នឹងនឿយណាយដោយធម្មតារបស់ខ្លួន ឬថា នឹងមិននឿយណាយទេហ្ន៎ ។ លំដាប់នោះ ក៏ដឹងថា កាលទ្រង់នឿយណាយដោយធម្មតា នឹងយឺតយូរក្រៃលែង ទើបគិតថា អញនឹងសម្ដែងអារម្មណ៍ដល់ព្រះរាជកុមារនោះ ទើបមកអំពីផ្ទាំងមនោសិលា ដោយន័យដែលពោលហើយក្នុងកាលមុននោះឯង ចុះត្រង់ព្រះរាជឧទ្យាន ។ រាជបុរសឃើញហើយ ក្រាបទូលព្រះរាជាថា បពិត្រមហារាជ ព្រះបច្ចេកពុទ្ធនិមន្តមក ។

ព្រះរាជាទ្រង់មានព្រះហឫទ័យត្រេកអរថា ឥឡូវនេះ កូនរបស់អញនឹងមិនអផ្សុក នឹងនៅជាមួយព្រះបច្ចេកពុទ្ធ ទ្រង់ទំនុកបម្រុងព្រះបច្ចេកពុទ្ធដោយគោរព ទ្រង់សូមឲ្យព្រះបច្ចេកពុទ្ធនៅក្នុងព្រះរាជឧទ្យាននោះឯង ទ្រង់ឲ្យធ្វើវត្ថុទាំងពួង មានបណ្ណសាលា ទីសម្រាកពេលថ្ងៃ និងទីចង្ក្រមជាដើម ទ្រង់និមន្តឲ្យគង់នៅ ។

ព្រះបច្ចេកពុទ្ធគង់នៅក្នុងឧទ្យាននោះ ថ្ងៃមួយ បានឱកាស ទើបសួរព្រះរាជកុមារថា ព្រះអង្គជាអ្វី ។

ព្រះរាជកុមារត្រាស់តបថា ខ្ញុំករុណាជាបព្វជិត ។

ព្រះបច្ចេកពុទ្ធពោលថា បព្វជិតទាំងឡាយ មិនមានសភាពដូច្នេះ

ឡើយ ។ កាលព្រះរាជកុមារសួរថា បពិត្រលោកម្ចាស់ កាលបើដូច្នោះ បព្វជិតទាំងឡាយមានសភាពដូចម្ដេច អ្វីមិនសមគួរដល់ខ្ញុំ ។

ព្រះបច្ចេកពុទ្ធពោលថា ទ្រង់មិនសម្លឹងមើលវត្ថុដែលមិនសមគួរដល់ទ្រង់ ព្រះមាតារបស់ទ្រង់ យាងមកក្នុងវេលាព្រឹកជាមួយស្រីស្នំ ២ ម៉ឺននាក់ ធ្វើឲ្យព្រះរាជឧទ្យានមិនស្ងាត់ មិនមែនឬ ឯព្រះបិតាយាងមកក្នុងពេលល្ងាច មួយអន្លើដោយរេហ៍ពលជាច្រើន បុរសដែលបដិបត្តិទាំងឡាយមកអស់រាត្រី ធម្មតាបព្វជិតទាំងឡាយមិនមានសភាពដូចទ្រង់ទេ តែ ( ទ្រង់ ) ត្រឡប់បានជាដូច្នេះវិញ ហើយសម្ដែងវិហារមួយកន្លែង ក្នុងហិមវន្តប្បទេសដោយឫទ្ធិ ដល់ព្រះរាជកុមារដែលប្រថាប់ឈរក្នុងទីនោះឯង ។

ព្រះរាជកុមារឃើញព្រះបច្ចេកពុទ្ធទាំងឡាយក្នុងវិហារនោះ កំពុងឈរសំយុងព្រះហស្តផង កំពុងដើរចង្ក្រមផង កំពុងធ្វើការជ្រលក់និងដេរចីវរជាដើមផង ទើបត្រាស់ថា លោកម្ចាស់ទាំងឡាយ មិនមកក្នុងទីនេះទេ ឯបព្វជ្ជាវិញ គឺលោកម្ចាស់ទាំងឡាយបានអនុញ្ញាត ( បានទទួល ) ហើយឬ ។

ព្រះអាទិច្ចពន្ធុបច្ចេកពុទ្ធតបថា ត្រូវហើយ បព្វជ្ជា ( បានទទួល ) អនុញ្ញាតហើយ ឈ្មោះថា សមណៈទាំងឡាយ ចាប់តាំងពីកាលដែលខ្លួនបួសហើយ រមែងបានធ្វើនូវការរលាស់ចេញចាកទុក្ខដើម្បីខ្លួន និង

ដើម្បីទៅកាន់ប្រទេសដទៃដែលខ្លួនត្រូវការនិងប្រាថ្នា ហេតុមានប្រមាណប៉ុណ្ណោះសមគួរ ដូច្នេះហើយ ឈរក្នុងអាកាស ពោលកន្ទុះគាថានេះថា

**អដ្ឋាន តំ សង្គណិការតស្ស**

**យំ ផុស្សយេ[១] សាមយិកំ វិមុត្តឹ**

បុគ្គលបានទូវសាមយិកវិមុត្តិ ដោយហេតុ

ណា ហេតុនោះ មិនមែនជាទីតាំងនៃបុគ្គល

អ្នកត្រេកអរក្នុងពួកទេ ។

ព្រះបច្ចេកពុទ្ធ កាលមនុស្សកំពុងឃើញនោះឯង បានទៅកាន់ញកភ្នំនន្ទមូលកៈតាមអាកាស ។ កាលព្រះបច្ចេកពុទ្ធនិមន្តទៅយ៉ាងនោះហើយ ព្រះរាជកុមារនោះចូលទៅកាន់បណ្ណសាលារបស់ខ្លួន ហើយក៏សិង ។ ឯបុរសអ្នករក្សា ប្រហែសធ្វេសថា ព្រះរាជកុមារផ្ទំហើយ នឹងទៅណាបាន ទើបចុះកាន់និទ្រា ។ ព្រះរាជកុមារដឹងថា បុរសនោះប្រមាទហើយ ទើបកាន់យកបាត្រនិងចីវរចូលទៅក្នុងព្រៃ ។ ព្រះរាជកុមារនៅក្នុងទីនោះ ផ្តើមចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ហើយទៅកាន់លំនៅរបស់ព្រះបច្ចេកពុទ្ធ ។ ក្នុងទីនោះ ត្រូវសួរថា សម្រេចបានដូចម្តេច ទើបពោលកន្ទុះគាថាដែលព្រះអាទិច្ចពន្ធុបច្ចេកពុទ្ធពោលទុក ឲ្យគ្រប់បរិបូណ៌ ( ១ គាថា ) ថា

---

១-អដ្ឋកថា ច្បាប់ឆដ្ឋសង្គាយនា ជា ផស្សយេ ។

**អដ្ឋាន តំ សង្គណិការតស្ស**
**យំ ផុស្សយេ សាមយិកំ វិមុត្តឹ**
**អាទិច្ចពន្ធុស្ស វចោ និសម្ម**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

*បុគ្គលបាននូវសាមយិកវិមុត្តិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំងនៃបុគ្គលអ្នកត្រេកអរក្នុងពួកទេ បុគ្គលពិចារណានូវពាក្យនៃព្រះពុទ្ធ ជាអាទិច្ចពន្ធុហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។*

*សេចក្ដីនៃគាថានោះថា បទថា* **អដ្ឋាន តំ** *កាត់បទជា* **អដ្ឋានំ តំ** *មានសេចក្ដីស្មើគ្នានឹង* **អការណំ តំ** *ប្រែថា សេចក្ដីនោះ មិនមែនហេតុ ។ លោកលុបនិគ្គហិតចេញ ដូចក្នុងពាក្យថា* **អរិយសច្ចានទស្សនំ** *ការឃើញនូវអរិយសច្ចៈទាំងឡាយ*[១] *ដូច្នេះជាដើម ។*

*បទថា* **សង្គណិការតស្ស** *ប្រែថា ជាអ្នកត្រេកអរក្នុងពួកគណៈ ។*

*បទថា* **យំ** *នោះ ជាតតិយាវិភត្តិ ដូចក្នុងប្រយោគថា* **យំ ហិរិយតិ ហិរិយិតព្វេន** *ត្រង់ដែលបុគ្គលខ្មាស ដោយវត្ថុដែលគួរខ្មាស*[២] *ដូច្នេះជាដើម ។*

---

*១-បិ.៥២ ទំ.៥ ឃ.៦, បិ.៥៤ ទំ.៨៧ ឃ.២៥ ។ ២-បិ.៧៨ ទំ.២៨ ឃ. ៤៥ ។*

*បទថា* **ជស្សយេ** *បានដល់ គប្បីបានសម្រេច ។*

*បទថា* **សាមយិកំ វិមុត្តឹ** *បានដល់ លោកិយសមាបត្តិ ។ មែនពិត លោកិយសមាបត្តិនោះ ហៅថា* **សាមយិកា វិមុត្តិ** *ព្រោះផុតចាកនីវរណធម៌ទាំងឡាយ ដែលជាសត្រូវរាល់ៗ ពេលដែលចូលសមាធិ មិនទាន់ចុះស៊ប់ និងចុះស៊ប់នោះឯង ។*

*ព្រះបច្ចេកពុទ្ធពោលថា ខ្ញុំពិចារណាពាក្យរបស់ព្រះបច្ចេកសម្ពុទ្ធព្រះនាមអាទិច្ចពន្ធុយ៉ាងនេះថា ការដែលបុគ្គលត្រេកអរហើយដោយការប្រឡូកប្រឡំដោយគណៈ គប្បីសម្រេចវិមុត្តិដែលមាននៅក្នុងសម័យនោះ មិនមែនជាឋានៈ គឺនោះមិនជាហេតុ ដូច្នេះហើយ លះសេចក្ដីត្រេកអរដោយការប្រឡូកប្រឡំដោយគណៈ បដិបត្តិដោយឧបាយ ទើបសម្រេច ។ បទដ៏សេស មានន័យដូចពោលមកហើយនោះឯង ។*

**អដ្ឋានគាថាទី ១០ ចប់**

**វគ្គទី ២ ចប់**

# វគ្គទី ៣

# ទិដ្ឋីវិសូកគាថា

*គាថាថា* **ទិដ្ឋីវិសូកានិ** *ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។*

*បានឮថា ព្រះបាទពារាណសីមួយអង្គ ទៅក្នុងទីស្ងាត់ ទ្រង់ព្រះតម្រិះថា ការក្ដៅជាដើម ដែលកម្ចាត់ត្រជាក់ជាដើម មានយ៉ាងណា វិវដ្ដៈដែលកម្ចាត់វដ្ដៈ នឹងមានយ៉ាងនោះឬហ្ន៎ ទើបទ្រង់ត្រាស់សួរអាមាត្យទាំងឡាយថា* **វិវដ្ដំ ជានាថ** *ពួកអ្នកស្គាល់វិវដ្ដៈដែរឬទេ ។ អាមាត្យទាំងនោះ ក្រាបទូលថា* **ជានាម មហារាជ** *បពិត្រមហារាជ ស្គាល់ ។*

*ព្រះរាជាត្រាស់សួរថា* **កឹ តំ** *វិវដ្ដៈនោះ គឺអ្វី ។ បន្ទាប់អំពីនោះ អាមាត្យទាំងឡាយក៏ពោលដល់ការទៀង និងការដាច់សូន្យដោយន័យជាដើមថា* **អន្តវា លោកោ** *លោកមានទីបំផុតជាដើម ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អាមាត្យទាំងនេះ មិនដឹង អាមាត្យទាំងនេះ ជាមិច្ឆាទិដ្ឋិ ទ្រង់ឃើញភាពដែលទ្រង់ជំទាស់ (មានទិដ្ឋិផ្ទុយ) និងចូលគ្នាមិនបានជាមួយអាមាត្យទាំងនោះ ទ្រង់ព្រះតម្រិះថា វិវដ្ដៈដែលកម្ចាត់វដ្ដៈមានពិត គួរស្វែងរកវិវដ្ដៈនោះ ទើបទ្រង់លះរាជសម្បត្តិ ចេញបួសចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ បានត្រាស់ឧទានគាថានេះ និងព្យាករណ៍គាថាក្នុងកណ្ដាល* **ព្រះបច្ចេកពុទ្ធ**

ទាំងឡាយថា

**ទិដ្ឋីវិសូកានិ ឧបាតិវត្តោ**

**បត្តោ និយាមំ បដិលទ្ធមគ្គោ**

**ឧប្បន្នញាណោម្ហិ អនញ្ញនេយ្យោ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលកន្លងចម្រូង គឺទិដ្ឋិ ដល់នូវធម៌ទៀង គឺមគ្គទី ១ មានមគ្គ ( ដ៏សេស ) បានហើយ មិនមានអ្នកដទៃ ដឹកនាំ ព្រោះដឹងថា អាត្មាអញមានញាណកើតឡើង ហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

សេចក្ដីនៃគាថានោះថា បទថា **ទិដ្ឋីវិសូកានិ** បានដល់ ទិដ្ឋិ ៦២ ។ ពិតហើយ ទិដ្ឋិទាំងនោះ ឈ្មោះថា ចម្រូង ព្រោះអត្ថថា ជាសត្រូវ ព្រោះអត្ថថា ជាគ្រឿងចាក់ដោត និងព្រោះអត្ថថា ជាបដិបក្ខចំពោះមគ្គសម្មាទិដ្ឋិ កាលបើដូច្នោះ សត្រូវរបស់ទិដ្ឋិ ឬទិដ្ឋិនោះឯងជាសត្រូវ ឈ្មោះថា ចម្រូងគឺទិដ្ឋិ ។ បទថា **ឧបាតិវត្តោ** ប្រែថា ឈានកន្លងហើយដោយមគ្គ គឺទស្សនៈ ។ បទថា **បត្តោ និយាមំ** សេចក្ដីថា សម្រេចដល់និយតភាវៈ ដោយភាពជាបុគ្គលមិនធ្លាក់ទៅជាធម្មតា និងដោយភាពជាបុគ្គលមានសម្ពោធិញ្ញាណជាទីទៅខាងមុខ ឬបានសម្រេចបឋមមគ្គ ដែលហៅថា សម្មត្តនិយាម ។ លោកពោលការសម្រេចកិច្ច

ក្នុងបឋមមគ្គ និងការបានចំពោះនូវបឋមមគ្គនោះ ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណេះ ។ ឥឡូវនេះ លោកសម្តែងការបានចំពោះនូវមគ្គដ៏សេស ដោយពាក្យថា **បដិលទ្ធមគ្គោ** ដូច្នេះ ។

បទថា **ឧប្បន្នញាណោម្ហិ** បានដល់ ជាអ្នកមានបច្ចេកពោធិញ្ញាណ កើតឡើងហើយ ។ ព្រះបច្ចេកពុទ្ធសម្តែងផលដោយពាក្យនេះ ។ បទថា **អនញ្ញនេយ្យោ** បានដល់ ដែលបុគ្គលពួកដទៃមិនគប្បីដឹកនាំថា **ឥទំ សច្ចំ** វត្ថុនេះ ពិត ។ ព្រះបច្ចេកពុទ្ធសម្តែងភាពជាអ្នកត្រាស់ដឹងឯង ដោយពាក្យនេះ ។ ម្យ៉ាងទៀត សម្តែងដល់ភាពជាអ្នកជំនាញឯង ព្រោះភាពជាបុគ្គលមិនមានអ្នកដទៃគប្បីដឹកនាំក្នុងបច្ចេកពោធិញ្ញាណដែលបានសម្រេចហើយ ឬកន្លងផុតសត្រូវ គឺទិដ្ឋិបានហើយ ដោយសមថៈនិងវិបស្សនាដោយខ្លួនឯង ដល់នូវភាពជាអ្នកទៀងដោយមគ្គខាងដើម មានមគ្គដែលបានចំពោះហើយ ដោយមគ្គដ៏សេសទាំងឡាយ ឬមានញាណកើតហើយ ដោយផលញ្ញាណ បានហើយនូវញាណទាំងពួងដោយខ្លួនឯង ព្រោះហេតុនោះ បុគ្គលនោះឈ្មោះថា **អនញ្ញនេយ្យោ** ។ បទដ៏សេស គប្បីជ្រាបដោយន័យដែលបានពោលហើយនោះឯង ។

**ទិដ្ឋីវិសូកគាថាទី ១ ចប់**

# និល្លោលុបគាថា

គាថាថា និល្លោលុចោ ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។

បានឮថា អ្នកពិសេសរបស់ព្រះបាទពារាណសី ចម្អិនក្រយា-ស្ងោយក្នុងចន្ទោះភត្ត ឃើញគួរជាទីពេញចិត្ត មានរសឆ្ងាញ់ ទើបបង្អោនចូលទៅថ្វាយព្រះរាជា ដោយបំណងថា ធ្វើដូចម្ដេចហ្ន៎ ព្រះរាជាគប្បីប្រទានទ្រព្យដល់អញ ។ ក្រយាស្ងោយនោះ គ្រាន់តែក្លិនប៉ុណ្ណោះ ក៏ធ្វើឲ្យព្រះរាជាចង់សោយ ធ្វើឲ្យព្រះខេឡៈ ( ទឹកមាត់ ) កើតក្នុងព្រះឱស្ឋ លុះដាក់ពំនូតបាយ ១ ម៉ាត់ដំបូងចូលក្នុងព្រះឱស្ឋ សរសៃទាំង ៧ ពាន់ បីដូចទឹកអម្រឹតពាល់ត្រូវហើយ ។ អ្នកពិសេសគិតថា ទ្រង់នឹងប្រទានទ្រព្យដល់អញ ក្នុងកាលឥឡូវនេះ ទ្រង់នឹងប្រទានទ្រព្យដល់អញ ក្នុងកាលឥឡូវនេះ ។

ឯព្រះរាជាទ្រង់ព្រះតម្រិះថា អ្នកពិសេសសមគួរដល់សក្ការៈ ទ្រង់ព្រះតម្រិះទៀតថា បើអញភ្លក្សរសហើយធ្វើសក្ការៈ កិត្តិសព្ទមិនល្អ ក៏នឹងផ្សាយទៅថា ព្រះរាជាអង្គនេះ ជាមនុស្សល្មោភ ជាប់ក្នុងរស ដូច្នេះ ទើបមិនត្រាស់ពាក្យណាមួយ ។ តែទោះជាដូច្នោះ បុរសអ្នកពិសេសនោះ ក៏នៅតែគិតថា ទ្រង់នឹងប្រទានឥឡូវនេះ ទ្រង់នឹងប្រទានឥឡូវនេះ រហូតដល់សោយស្រេច ។

*សូម្បីព្រះរាជាក៏មិនបានត្រាស់ពាក្យណាមួយ ព្រោះខ្លាចចំពោះការតិះដៀល ។ លំដាប់នោះ អ្នកពិសេសគិតថា ជិវ្ហាវិញ្ញាណរបស់ព្រះរាជានេះ ប្រហែលជាមិនមាន ។ ក្នុងថ្ងៃទី ២ ក៏បង្អោនក្រយាស្ងោយដែលមានរសមិនឆ្ងាញ់ចូលទៅថ្វាយ ។ ព្រះរាជា លុះទ្រង់បានសោយទ្រង់ក៏ដឹងថា ថ្ងៃនេះ អ្នកពិសេសគួរដល់ការគំរាមកំហែង គួរដល់ការសង្កត់សង្កិន តែទ្រង់ពិចារណាដូចក្នុងកាលមុន ទើបមិនបានត្រាស់ពាក្យណាមួយ ព្រោះខ្លាចការតិះដៀល ។ លំដាប់នោះ អ្នកពិសេសគិតថា ព្រះរាជា ល្អក៏មិនដឹង មិនល្អក៏មិនដឹង ទើបកាន់យកគ្រឿងចម្អិនទាំងអស់ដោយខ្លួនឯង ប្រើគ្រឿងចម្អិនធម្មតាថ្វាយព្រះរាជា ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ឱ! លោកៈ អាក្រក់ណាស់ហ្ន៎! ឈ្មោះថា អាត្មាអញបរិភោគ គឺគ្រប់គ្រងនគរដល់ទៅ ២ ម៉ឺន ក៏មិនបានត្រឹមតែកត្តដែលល្អព្រោះសេចក្តីលោភរបស់អ្នកដាំស្ងនេះ ដូច្នេះហើយ ទ្រង់ក៏នឿយណាយទើបលះរាជសម្បត្តិ ចេញបួស ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកសម្ពោធិញ្ញាណ ហើយបានពោលគាថានេះថា*

**និល្លោលុបោ និក្កុហោ និប្បិបាសោ**
**និម្មក្ខោ និទ្ធន្តកសាវមោហោ**
**និរាសយោ សព្វលោកេ ភវិត្វា**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

*បុគ្គលមិនជាប់ចិត្ត ( ក្នុងអាហារ ) មិនកុហក មិនស្រេកឃ្លាន មិនលុបគុណគេ កម្ចាត់បង់មោហៈដូចជាទឹកចត់ មិនមានទីអាស្រ័យនៅ គឺតណ្ហាក្នុងលោកទាំងពួងហើយ គប្បីប្រព្រឹត្តតែម្នាក់ឯងដូចកុយរមាស ។*

*បណ្ដាបទទាំងនោះ បទថា* **និល្លោលុបោ** *ប្រែថា មិនមានសេចក្ដីលោភ ។ ពិតហើយ បុគ្គលណា ត្រូវចំណង់ក្នុងរសគ្របសង្កត់ បុគ្គលនោះ រមែងលោភខ្លាំង លោភហើយលោភទៀត ព្រោះហេតុនោះ ទើបលោកពោលថា លោលុបៈ គឺបុគ្គលលោភ ។ ព្រោះហេតុនោះ* **ព្រះបច្ចេកពុទ្ធ** *អង្គនេះ កាលបដិសេធថា ព្រះអង្គមិនជាបុគ្គលលោភ ទើបពោលថា និល្លោលុបៈ គឺបុគ្គលមិនមានសេចក្ដីលោភ ។ ក្នុងបទថា* **និក្កុហោ** *នេះ មានអធិប្បាយដូចតទៅនេះថា វត្ថុគែបន្ទំ ៣ យ៉ាង មិនមានដល់បុគ្គលណា បុគ្គលនោះ លោកហៅថា ជាបុគ្គលមិនកុហក ពិតហើយ ទោះជាយ៉ាងនោះ ក្នុងគាថានេះ ឈ្មោះថា មិនកុហក ព្រោះមិនមានការត្រេកអរ ក្នុងភោជនដែលជាទីពេញចិត្តជាដើម ។*

*ក្នុងបទថា* **និប្បិបាសោ** *នេះ ការចង់ផឹក ឈ្មោះថា ការស្រេក ឈ្មោះថា ជាអ្នកមិនស្រេក ព្រោះមិនមានការចង់ផឹកនោះ អធិប្បាយថា វៀរហើយចាកភាពជាអ្នកប្រាថ្នានឹងបរិភោគ ព្រោះជាប់ចំពាក់ក្នុងរស*

ធ្ងាញ់ ។ ក្នុងបទថា **និម្មក្ខោ** នេះ ឈ្មោះថា ជាអ្នកមិនលុបគុណគេ ព្រោះមិនមានមក្ខៈ គឺការលុបគុណ ដែលមានការទម្លាយគុណរបស់អ្នកដទៃ ជាលក្ខណៈ ។ ព្រះបច្ចេកពុទ្ធពោលសំដៅយកការមិនមានការលុបគុណអ្នកពិសេស ក្នុងកាលលោកនៅជាគ្រហស្ថ ។

ក្នុងបទថា **និទ្ធន្តកសាវមោហោ** នេះ ធម៌ ៦ យ៉ាង គឺ ៣ យ៉ាង មានរាគៈជាដើម និង ៣ យ៉ាងទៀត មានកាយទុច្ចរិតជាដើម គប្បីជ្រាបថាជា កសាវៈ ( ទឹកចត់ ) ដោយអត្ថថា មិនជ្រះថ្លាតាមសេចក្តីពិត និងដោយអត្ថថា ឲ្យលះភាវៈរបស់ខ្លួន ឲ្យកាន់យកភាវៈដទៃ ដូចព្រះតម្រាស់ថា

បណ្តាធម៌ទាំងនោះ ទឹកចត់ ៣ តើដូចម្តេច ។ ទឹកចត់គឺរាគៈ ១ ទឹកចត់គឺទោសៈ ១ ទឹកចត់គឺមោហៈ ១ នេះទឹកចត់ ៣ [១] ។

បណ្តាធម៌ទាំងនោះ ទឹកចត់ ៣ ដទៃទៀត តើដូចម្តេច ។ ទឹកចត់គឺកាយ ១ ទឹកចត់គឺវាចា ១ ទឹកចត់គឺចិត្ត ១ នេះទឹកចត់ ៣ [២] ។

ឈ្មោះថា មានបាបធម៌ដូចទឹកចត់ និងមោហៈ ដែលកម្ចាត់ហើយ ព្រោះកម្ចាត់កសាវៈ ៥ យ៉ាង ក្នុងកសាវៈ ៦ យ៉ាងនោះ វៀរមោហៈ និងកម្ចាត់មោហៈដែលជាឫសគល់នៃកសាវៈ ៥ យ៉ាងទាំងអស់នោះ ចេញហើយ ។ ម្យ៉ាងទៀត ឈ្មោះថា មានបាបធម៌ដូចទឹកចត់និងមោហៈ

---

១-បិ.៨២ ទំ.២០១ ឃ.១៨១ ។ ២-បិ.៨២ ទំ.២០១ ឃ.១៨២ ។

ដែលកម្ចាត់ហើយ ព្រោះកម្ចាត់កាយកសាវៈ វចីកសាវៈ និងមនោកសាវៈ ទាំង ៣ យ៉ាងនោះ និងមោហៈចេញហើយ ។ ក្នុងកសាវៈក្រៅអំពីនេះ ព្រោះមិនមានសេចក្តីលោភជាដើម រាគកសាវៈ ឈ្មោះថា កម្ចាត់ស្រេច ហើយ ព្រោះមិនមានការលុបគុណ ទោសកសាវៈ ក៏ឈ្មោះថា កម្ចាត់ ហើយដូចគ្នា ។

បទថា **និរាសយោ** បានដល់ មិនមានតណ្ហា ។ បទថា **សព្វលោកេ ភវិត្វា** បានដល់ លោកទាំងមូល អធិប្បាយថា ជាអ្នក វៀរចាកភវតណ្ហានិងវិភវតណ្ហាក្នុងភពទាំង ៣ ឬក្នុងអាយតនៈ ១២ ។ បទដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។ម្យ៉ាង ទៀត អ្នកសិក្សា កាលពោលបាទទាំង ៣ ហើយ គប្បីធ្វើនូវការភ្ជាប់ ក្នុងបាទនេះ យ៉ាងនេះថា គប្បីត្រាច់ទៅម្នាក់ឯង ឬយ៉ាងនេះថា គប្បី អាចត្រាច់ទៅម្នាក់ឯង ដូច្នេះ ។

### និល្លោលុបគាថាទី ២ ចប់

# ចាបសហាយគាថា

គាថាថា **ចាបំ សហាយំ** ដូច្នេះជាដើម មានហេតុកើតដូចម្តេច ។

បានឮថា ព្រះរាជាមួយអង្គក្នុងនគរពារាណសី ទ្រង់ធ្វើប្រទក្សិណព្រះនគរដោយរាជានុភាពធំ ទ្រង់ឃើញមនុស្សទាំងឡាយនាំយកស្រូវចាស់ជាដើម ចេញអំពីជង្រុកទៅខាងក្រៅ ទើបត្រាស់សួរអាមាត្យថា **កឹ ករណោ ឥជំ** នៃអ្នក ( មនុស្សទាំងនេះ ) កំពុងធ្វើអ្វី ។

ពួកអាមាត្យក្រាបទូលថា បពិត្រមហារាជ ឥឡូវនេះ ស្រូវថ្មីជាដើមកើតឡើង ទើបមនុស្សទាំងនេះ យកស្រូវចាស់ជាដើមចេញ ដើម្បីនឹងមានទីទំនេរសម្រាប់ស្រូវថ្មីជាដើមនេះ ។

ព្រះរាជាត្រាស់សួរថា នៃបា ស្បៀងរបស់ពួកស្រីស្នំនិងពួកពលជាដើម ពេញបរិបូណ៌ឬ ។ ពួកអាមាត្យក្រាបទូលថា បពិត្រមហារាជ នៅពេញបរិបូណ៌ ព្រះអង្គ ។

ព្រះរាជាត្រាស់ថា បើដូច្នោះ អ្នកទាំងឡាយ ចូរសាងរោងទាន យើងនឹងឲ្យទាន ស្រូវទាំងនេះ កុំបីវិនាសទទេ ដោយឥតប្រយោជន៍ឡើយ ។ លំដាប់នោះ អាមាត្យដែលមានមិច្ឆាទិដ្ឋិម្នាក់ ក្រាបទូលថា បពិត្រមហារាជ ទានដែលឲ្យហើយមិនមានផលទេ ហើយក្រាបទូលព្រះរាជាទៀតថា បុគ្គលទាំងឡាយនោះ ទោះបីជាពាលក្តី បណ្ឌិតក្តី

ស្ទុះទៅ អន្ទោលទៅ នឹងធ្វើទីបំផុតនៃទុក្ខបានឯង ហើយទូលហាម ។ ព្រះរាជាទ្រង់ឃើញជម្រុកត្រូវជញ្ជូនស្រូវចេញ លើកទី ២ លើកទី ៣ ក៏ត្រាស់ដូចមុន ។ ទោះបីក្នុងលើកទី ៣ អាមាត្យដែលមានគតិក្នុងការឃើញខុសនោះ ក៏នៅតែពោលពាក្យជាដើមថា បពិត្រមហារាជ ទាននេះ បុគ្គលល្ងង់ជាអ្នកបញ្ញត្ត ហើយទូលហាមព្រះរាជានោះ ។

ព្រះរាជាទ្រង់នឿយណាយថា អើហ្ន៎ អញមិនបានឲ្យ សូម្បីទ្រព្យរបស់ខ្លួន អញមានប្រយោជន៍អ្វីដោយបាបមិត្តទាំងនេះ ដូច្នេះហើយទើបលះរាជសម្បត្តិ ចេញបួស ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ ។ **ព្រះបច្ចេកពុទ្ធ** កាលទ្រង់តិះដៀលបាបមិត្តនោះ ទើបត្រាស់ឧទានគាថានេះថា

**បាបំ សហាយំ បរិវជ្ជយេថ**
**អនត្ថទស្សឹ វិសមេ និវិដ្ឋំ**
**សយំ ន សេវេ បសុតំ បមត្តំ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលគប្បីវៀរស្រឡះនូវសម្លាញ់អាក្រក់ អ្នកមិនឃើញនូវសេចក្តីវិនាស អ្នកអាស្រ័យនៅក្នុងកម្មមិនស្មើ មិនគប្បីគប់រកនូវសម្លាញ់ ដែលជាប់ចំពាក់ដែលស្រវឹង ( ក្នុងកាមគុណ ) ដោយខ្លួនឯង គប្បី

*ប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។*

*គាថានោះ មានសេចក្ដីសង្ខេបដូច្នេះថា សម្លាញ់នេះ ឈ្មោះថា អាក្រក់ ព្រោះជាអ្នកប្រកបដោយមិច្ឆាទិដ្ឋិ ១០ យ៉ាង ។ ឈ្មោះថា ដែលបង្ហាញនូវអំពើមិនជាប្រយោជន៍ ព្រោះអត្ថថា ចង្អុលប្រាប់នូវសេចក្ដីវិនាសដល់អ្នកដទៃ និងតាំងក្នុងកម្មដែលមិនស្មើ មានកាយទុច្ចរិតជាដើម ។ កុលបុត្តអ្នកប្រាថ្នាប្រយោជន៍ គប្បីវៀរសម្លាញ់ដែលអាក្រក់នោះ ដែលបង្ហាញនូវអំពើមិនជាប្រយោជន៍ ដែលតាំងនៅក្នុងកម្មមិនស្មើ ។*

*បទថា* **សយំ ន សេវេ** *បានដល់ មិនគប្បីសេពដោយអំណាចនៃខ្លួនឯង អធិប្បាយថា បើធ្លាក់នៅក្នុងអំណាចរបស់អ្នកដទៃសោត ខ្លួនឯងនឹងអាចធ្វើអ្វីបាន ។ បទថា* **បសុតំ** *បានដល់ លែងទៅ ( តាមអារម្មណ៍នោះ ៗ ) បង្កើតឡើង ( ទៅតាមអារម្មណ៍នោះ ៗ ) អធិប្បាយថា ជាប់នៅក្នុងអារម្មណ៍នោះ ៗ ដោយអំណាចទិដ្ឋិ ។*

*បទថា* **បមត្តំ** *បានដល់ ជាអ្នកបណ្ដោយចិត្តទៅក្នុងកាមគុណ ៥ យ៉ាងទៀត បានដល់ ជាអ្នកវៀរចាកកុសលភាវនា ។ មិនគប្បីសេព មិនគប្បីគប់រក មិនគប្បីចូលទៅអង្គុយជិតសម្លាញ់នោះ គឺបុគ្គលបែបនោះ គប្បីជាបុគ្គលម្នាក់ឯង ត្រាច់ទៅដូចកុយរមាសដូច្នោះ ។*

បាបសហាយគាថាទី ៣ ចប់

# ពហុស្សុតគាថា

គាថាថា **ពហុស្សុតំ** ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។

បានឮថា ក្នុងកាលមុន ព្រះបច្ចេកពោធិសត្វ ៨ អង្គ បួសក្នុងសាសនារបស់ព្រះមានព្រះភាគកស្សបៈ បំពេញគតបច្ចាគតវត្តអស់ ២ ម៉ឺនឆ្នាំ ហើយកើតក្នុងទេវលោក ចុតិចាកទេវលោកនោះហើយ ។ បណ្ដាព្រះបច្ចេកពោធិសត្វទាំងនោះ ព្រះបច្ចេកពោធិសត្វអង្គធំ បានជាព្រះបាទពារាណសី ព្រះបច្ចេកពោធិសត្វដ៏សេសបានជាបទេសរាជា ។ ឯព្រះរាជា ៧ អង្គនោះ រៀនកម្មដ្ឋានហើយ ទ្រង់លះរាជសម្បត្តិ ចេញបួស បានជា **ព្រះបច្ចេកពុទ្ធ** ដោយលំដាប់ អាស្រ័យនៅត្រង់ញកភ្នំនន្ទមូលកៈ ។ សម័យថ្ងៃមួយ ចេញអំពីសមាបត្តិហើយរឭកថា យើងទាំងឡាយធ្វើកម្មអ្វី ទើបសម្រេចលោកុត្តរសុខនេះដោយលំដាប់ ពិចារណាក៏បានឃើញចរិយារៀង ៗ ខ្លួន ក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ ។ បន្ទាប់អំពីនោះ ទើបអាវជ្ជនៈ ( ពិចារណា ) ថា អង្គទី ៨ នៅឯណា ក៏បានដឹងថា នៅក្នុងនគរពារាណសី រឭកដល់គុណទាំងឡាយរបស់ព្រះបច្ចេកពោធិសត្វអង្គនោះថា ព្រះរាជាអង្គនោះ តាមប្រក្រតីជាអ្នកប្រកបដោយគុណ មានការប្រាថ្នាតិចជាដើម ជាអ្នកឲ្យឱវាទ ប្រៀនប្រដៅចំពោះពួកយើង ទ្រង់អត់ធន់ចំពោះពាក្យសម្ដី មានប្រក្រតីតិះដៀលបាប

ណ្ហើយចុះ យើងនឹងសម្តែងអារម្មណ៍នោះ ដើម្បីដោះព្រះអង្គ ទើបនិមន្ត ទៅ ត្រាច់បិណ្ឌបាត បានទៅកាន់ទីលានព្រះរាជវាំងតាមលំដាប់ ។ ព្រះរាជាទ្រង់ប្រថាប់ឈរត្រង់សីហបញ្ជរ ទតលានព្រះរាជវាំង បានឃើញព្រះបច្ចេកពុទ្ធទាំងនោះ ដំណាលគ្នានឹងការឃើញនោះឯង សេចក្តីស្រឡាញ់បានកើតឡើងដល់ព្រះអង្គ ។ លំដាប់នោះ ទើបត្រាស់ឲ្យនិមន្តព្រះបច្ចេកសម្ពុទ្ធទាំងនោះមក ឲ្យគង់លើអាសនៈដែលក្រាលទុកត្រង់រានហាល និមន្តឲ្យឆាន់ដោយគោរព ហើយត្រាស់សួរព្រះបច្ចេកពុទ្ធដែលធ្វើកត្តកិច្ចស្រេចហើយថា លោកម្ចាស់ទាំងឡាយ ឈ្មោះអ្វី ។

ព្រះបច្ចេកសម្ពុទ្ធទាំងនោះឆ្លើយថា មហាបពិត្រ ពួកអាត្មាឈ្មោះថា ពហុស្សុតៈ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អញឈ្មោះសុតព្រហ្មទត្ត មិនឆ្អែតក្នុងការស្តាប់ ណ្ហើយចុះ អញនឹងស្តាប់ធម្មទេសនាដែលមានន័យដ៏វិចិត្រក្នុងសម្នាក់របស់លោកម្ចាស់ទាំងនេះ ដូច្នេះហើយ ទ្រង់ពេញព្រះហឫទ័យ ថ្វាយទឹកទក្ខិណោទក ហើយទ្រង់អង្គាស ក្នុងកាលស្រេចកត្តកិច្ច បានប្រថាប់គង់ក្នុងទីជិតព្រះសង្ឃត្ថេរ ហើយត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ពោលធម្មកថាចុះ ។

ព្រះបច្ចេកពុទ្ធពោលថា **សុខិតោ ហោតុ មហារាជ រាគក្ខយោ ហោតុ** មហាបពិត្រ សូមទ្រង់បានដល់នូវសេចក្តីសុខ ចូរជាអ្នកអស់ទៅនៃរាគៈចុះ ហើយក្រោកទៅ ។

*ព្រះរាជាទ្រង់ព្រះតម្រិះថា លោកម្ចាស់អង្គនេះ មិនមែនជាពហុស្សូត អង្គទី ២ ពិតជាពហុស្សូត អញនឹងស្តាប់ធម្មកថាដ៏វិចិត្រក្នុងថ្ងៃស្អែក នេះ ដូច្នេះហើយ ទើបទ្រង់និមន្តឲ្យឆាន់ក្នុងថ្ងៃស្អែក ។ ព្រះរាជាទ្រង់និមន្តព្រះបច្ចេកពុទ្ធទាំងអស់ រហូតលំដាប់អង្គចុងក្រោយ ដោយប្រការដូច្នេះ ។ ព្រះបច្ចេកពុទ្ធទាំង ៧ អង្គនោះ សម្តែងបទមួយឲ្យប្លែកគ្នា ហើយពោលបទដ៏សេសដូចបទដើមថា*

**សុខិតោ ហោតុ មហារាជ ទោសក្ខយោ ហោតុ** *មហាបពិត្រ សូមទ្រង់បានដល់នូវសេចក្តីសុខ ចូរជាអ្នកអស់ទៅនៃទោសៈចុះ ។*

**សុខិតោ ហោតុ មហារាជ មោហក្ខយោ ហោតុ** *មហាបពិត្រ សូមទ្រង់បានដល់នូវសេចក្តីសុខ ចូរជាអ្នកអស់ទៅនៃមោហៈចុះ ។*

**សុខិតោ ហោតុ មហារាជ គតិក្ខយោ ហោតុ** *មហាបពិត្រ សូមទ្រង់បានដល់នូវសេចក្តីសុខ ចូរជាអ្នកអស់ទៅនៃគតិចុះ ។*

**សុខិតោ ហោតុ មហារាជ វដ្តក្ខយោ ហោតុ** *មហាបពិត្រ សូមទ្រង់បានដល់នូវសេចក្តីសុខ ចូរជាអ្នកអស់ទៅនៃវដ្តៈចុះ ។*

**សុខិតោ ហោតុ មហារាជ ឧបធិក្ខយោ ហោតុ** *មហាបពិត្រ សូមទ្រង់បានដល់នូវសេចក្តីសុខ ចូរជាអ្នកអស់ទៅនៃឧបធិចុះ ។*

**សុខិតោ ហោតុ មហារាជ តណ្ហាក្ខយោ ហោតុ** *មហាបពិត្រ សូមទ្រង់បានដល់នូវសេចក្តីសុខ ចូរជាអ្នកអស់ទៅនៃតណ្ហាចុះ ដូច្នេះ*

ហើយ ក្រោកទៅ ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា សមណៈទាំងឡាយនេះពោលថា ពួកអាត្មាភាពជាពហុស្សូត តែសមណៈទាំងនេះ មិនមានកថាដ៏វិចិត្រឡើយ ពាក្យដែលសមណៈទាំងនេះពោល នឹងមានប្រយោជន៍អ្វីហ្ន៎ ។ ទ្រង់ប្រារព្ធដើម្បីពិចារណាអត្ថនៃពាក្យរបស់ព្រះបច្ចេកពុទ្ធទាំងនោះ ទ្រង់ពិចារណាមើលថា **រាគក្ខយោ ហោតុ** ក៏ទ្រង់ជ្រាបថា កាលរាគៈអស់ហើយ ទោសៈក្តី មោហៈក្តី កិលេសទាំងឡាយដទៃ ៗ ក្តី រមែងឈ្មោះថា អស់ហើយផងដែរ ទើបទ្រង់សព្វព្រះរាជហឫទ័យថា សមណៈទាំងនេះ ជាពហុស្សូតដោយត្រង់ ប្រៀបដូចបុរសចង្អុលផែនដីធំក្តី អាកាសក្តី ដោយម្រាមដៃ តែមិនមែនសំដៅដល់ទីប្រមាណប៉ុនម្រាមដៃដែលចង្អុលបង្ហាញនោះឡើយ សេចក្តីពិត ជាការចង្អុលបង្ហាញផែនដីនិងអាកាសទាំងមូលនោះឯង យ៉ាងណា សមណៈទាំងនេះ កាលចង្អុលបង្ហាញអត្ថនីមួយ ៗ ក៏ឈ្មោះថា ចង្អុលបង្ហាញអត្ថដែលមិនមានប្រមាណ យ៉ាងនោះ ។ បន្ទាប់អំពីនោះ ទ្រង់ប្រាថ្នានូវភាពជាពហុស្សូតដែលមានសភាពបែបនោះថា ក្នុងកាលណាហ្ន៎ អាត្មាអញគប្បីជាពហុស្សូត យ៉ាងនេះ ទ្រង់លះរាជសម្បត្តិ បួសហើយ ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ហើយត្រាស់ឧទានគាថានេះថា

**ពហុស្សុតំ ធម្មធរំ ភជេថ**

**មិត្តំ ឧឡារំ បដិភាណវន្តំ**
**អញ្ញាយ អត្ថានិ វិនេយ្យ កង្ខំ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

*បុគ្គលគប្បីគប់រកនូវបុគ្គលជាពហុស្សូត អ្នកទ្រទ្រង់ធម៌ អ្នកប្រកបដោយគុណដ៏ក្រៃលែង មានប្រាជ្ញាវាងវៃ បុគ្គលដឹងច្បាស់នូវប្រយោជន៍ទាំងឡាយ គួរបន្ទោបង់សេចក្ដីសង្ស័យ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។*

*សេចក្ដីសង្ខេបក្នុងឧទានគាថានេះ មានដូចតទៅនេះថា*

*បទថា* **ពហុស្សុតំ** *សេចក្ដីថា ពហុស្សូតមាន ២ យ៉ាង គឺបរិយត្តិ-ពហុស្សុតៈ អ្នកជំនាញក្នុងព្រះត្រៃបិដក ១ បដិវេធពហុស្សុតៈ អ្នកចាក់ធ្លុះមគ្គ ផល វិជ្ជា និងអភិញ្ញា ១ ។ បុគ្គលមានអាគម (អ្នកទ្រទ្រង់បរិយត្តិ) ដែលមកហើយ ឈ្មោះថា* **ធម្មធរោ** *។ម្យ៉ាងទៀត បុគ្គលប្រកបដោយកាយកម្ម វចីកម្ម និងមនោកម្មដ៏ក្រៃលែង ឈ្មោះថា* **ឧឡារោ** *។ បុគ្គលមានយុត្តប្បដិភាណ ( ឈ្លាសក្នុងការសួរ ) មានមុត្តប្បដិភាណ ( ឈ្លាសក្នុងការឆ្លើយ ) និងមានយុត្តមុត្តប្បដិភាណ ( ឈ្លាសក្នុងការសួរផង ឈ្លាសក្នុងការឆ្លើយផង ) ឈ្មោះថា* **បដិភាណវា** *។ ម្យ៉ាងទៀត គប្បីជ្រាបបុគ្គលអ្នកមានបដិភាណ ៣ យ៉ាង គឺបរិយត្តិ បរិបុច្ឆា និងអធិគម ។ ពិតហើយ បរិយត្តិរមែងជាក់ច្បាស់ដល់បុគ្គលណា*

បុគ្គលនោះ ជាអ្នកមានបរិយត្តិបដិភាណ គឺឈ្លាសក្នុងបរិយត្តិ ។ ការសាកសួរទាក់ទងនឹងអត្ថ ញាណ លក្ខណៈ ឋានៈ និងអឋានៈជាក់ច្បាស់ដល់បុគ្គលណា បុគ្គលនោះ ជាអ្នកមានបរិបុច្ឆាបដិភាណ គឺឈ្លាសក្នុងការសួរ ។ មគ្គជាដើម ដែលបុគ្គលណាចាក់ធ្លុះហើយ បុគ្គលនោះ ជាអ្នកមានអធិគមប្បដិភាណ គឺឈ្លាសក្នុងការសម្រេច ។ បុគ្គលគប្បីសេពគប់មិត្តនោះ គឺបែបនោះ ដែលជាពហុស្សូតទ្រទ្រង់នូវធម៌ ប្រកបដោយគុណដ៏ក្រៃលែង និងមានបដិភាណ ។ បន្ទាប់អំពីនោះ គប្បីស្គាល់ប្រយោជន៍ច្រើនយ៉ាង គឺប្រយោជន៍របស់ខ្លួន ប្រយោជន៍អ្នកដទៃ និងទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ បរមត្ថប្រយោជន៍ ដោយអានុភាពរបស់មិត្តនោះ បន្ទាប់អំពីនោះ បន្ទោបង់នូវសេចក្តីសង្ស័យ គឺបន្ទោបង់ បានដល់ កម្ចាត់ចោលនូវសេចក្តីសន្ទិះសង្ស័យក្នុងឋានៈដែលជាទីតាំងនៃសេចក្តីសង្ស័យ មានសង្ស័យថា **អហោសឹ នុ ខោ អហំ អតីតមទ្ធានំ** អំពីអតីតកាល អាត្មាអញបានកើតដែរឬ[១] ដូច្នេះជាដើម ។ ជាអ្នកធ្វើកិច្ចទាំងពួងស្រេចហើយ យ៉ាងនេះ គប្បីជាអ្នកត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាសដូច្នោះ ។

## ពហុស្សុតគាថាទី ៤ ចប់

---

១-បិ.២០ ទំ.២៥ ឃ.១២ ។

# ចិត្តសនដ្ឋានគាថា

*គាថាថា **ចិត្តំ រតី** ដូច្នេះជាដើម មានហេតុកើតដូចម្តេច ។*

*បានឮថា ព្រះរាជាព្រះនាមថា វិក្ខសកព្រហ្មទត្ត ក្នុងនគរពារាណសី កាលសោយយាគូ ឬក្រយាស្ងោយអំពីព្រលឹមហើយ ឲ្យជនទាំងឡាយប្រដាប់ព្រះកាយដោយគ្រឿងអលង្ការច្រើនប្រភេទ ហើយទ្រង់ទតព្រះសរីរៈទាំងមូលក្នុងកញ្ចក់ធំ មិនពេញចិត្តវត្ថុណា ក៏យកវត្ថុនោះចេញហើយឲ្យប្រដាប់ដោយគ្រឿងអលង្ការដទៃ ។ ថ្ងៃមួយ កាលទ្រង់ធ្វើតាមទម្លាប់ ក៏ដល់ពេលសោយព្រះក្រយាហារថ្ងៃត្រង់ល្មម ។ ទ្រង់ផ្អាកការតាក់តែង យកសំពត់ព័ទ្ធព័ន្ធព្រះសីសៈ សោយហើយ ទ្រង់ចូលផ្ទំពេលថ្ងៃ ។ កាលទ្រង់ក្រោកឡើង ទ្រង់ធ្វើយ៉ាងនោះដដែលទៀត ព្រះអាទិត្យក៏លិច ។ ក្នុងថ្ងៃទី ២ ក្នុងថ្ងៃទី ៣ ក៏យ៉ាងនោះ ។ កាលទ្រង់ខ្វល់ខ្វាយតែក្នុងការប្រដាប់តាក់តែងយ៉ាងនោះ រោគត្រង់ព្រះបិដ្ឋិគឺខ្នង ក៏កើតឡើង ទ្រង់ព្រះតម្រិះថា ឱ! អាត្មាអញឆ្ងាក់នៅក្នុងការតាក់តែងដោយកម្លាំងទាំងអស់ ក៏មិនល្មមក្នុងគ្រឿងប្រដាប់ដែលសមគួរនេះ ញុំាងសេចក្តីលោភឲ្យកើតឡើង ឈ្មោះថា សេចក្តីលោភនេះ ធ្វើឲ្យបុគ្គលចូលដល់អបាយ ណ្ហើយចុះ អញនឹងគ្របសង្កត់សេចក្តីលោភនេះ ដូច្នេះហើយ ទ្រង់លះរាជសម្បត្តិ ចេញបួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវ*

បច្ចេកពោធិញ្ញាណ ហើយត្រាស់ឧទានគាថានេះថា

**ខិឌ្ឌំ រតឹ កាមសុខញ្ច លោកេ**

**អនលង្ករិត្វា អនបេក្ខមានោ**

**វិភូសនដ្ឋានា វិរតោ សច្ចវាទី**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលមិនអើពើ មិនអាឡោះអាល័យ នូវល្បែង

ផង តម្រេកផង កាមសុខក្នុងលោកផង ជាអ្នកវៀរ

ស្រឡះចាកគ្រឿងស្អិតស្អាង អ្នកពោលនូវពាក្យ

សច្ចៈ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

ការលេងនិងការត្រេកអរក្នុងគាថានេះ បានពោលហើយក្នុងកាលមុននោះឯង ។ បទថា **កាមសុខំ** បានដល់ សេចក្ដីសុខក្នុងវត្ថុកាម ។ ពិតហើយ វត្ថុកាមទាំងឡាយហៅថា សុខ ព្រោះជាអារម្មណ៍របស់សេចក្ដីសុខជាដើម ដូចព្រះមានព្រះភាគត្រាស់ថា

ម្នាលមហលិ តែរូបនេះជាសុខ មានសុខជាប់តាម[១] ។

បុគ្គលមិនពេញចិត្ត គឺមិនធ្វើនូវភាពសមគួរ នូវការលេង នូវការត្រេកអរនិងនូវកាមសុខនោះ ក្នុងឱកាសលោកនេះ យ៉ាងនេះហើយ មិនកាន់យកវត្ថុនោះថា ជាការរុងរឿង ឬមិនកាន់យកវត្ថុនោះថា ជាសារៈ ។

---

១-បិ.៣៣ ទំ.១៦២ ឃ.១៣១ ។

បទថា **អនបេក្ខមានោ** បានដល់ មានប្រក្រតីមិនសម្លឹង គឺមិនមានការចង់បាន មិនមានសេចក្ដីល្មោភ ដោយការធ្វើនូវការពេញចិត្តនោះ ។ ក្នុងបទថា **វិភូសនដ្ឋានា វិរតោ សច្ចវាទី** នេះ គប្បីឃើញអត្ថយ៉ាងនេះថា គ្រឿងប្រដាប់មាន ២ យ៉ាង គឺគ្រឿងប្រដាប់សម្រាប់ឃរាវាស ១ គ្រឿងប្រដាប់សម្រាប់បព្វជិត ១ ។ គ្រឿងប្រដាប់សម្រាប់ឃរាវាស មានសំពត់សាដក សំពត់ជួតក្បាល ផ្កា និងគ្រឿងក្រអូបជាដើម ចំណែកគ្រឿងប្រដាប់សម្រាប់បព្វជិត មានគ្រឿងតាក់តែង គឺបាត្រជាដើម ។ គ្រឿងប្រដាប់នោះឯង ឈ្មោះថា វិភូសនដ្ឋាន ។ វៀរចាកឋានៈនៃការប្រដាប់នោះ ដោយវិរតិ ៣ យ៉ាង ។ ឈ្មោះថា សច្ចវាទី ព្រោះពោលមិនខុសចាកការពិត ដូច្នេះ ។

វិភូសនដ្ឋានគាថាទី ៥ ចប់

# **បុត្តទារគាថា**

*គាថាថា* **បុត្តញ្ច ទារំ** *ដូច្នេះជាដើម មានហេតុកើតដូចម្តេច ។*

*បានឮថា ឱរសរបស់ព្រះបាទពារាណសីបានទទួលអភិសេក គ្រងរាជសម្បត្តិក្នុងកាលនៅក្មេងនោះឯង ទ្រង់សោយសិរីរាជសម្បត្តិដូចព្រះបច្ចេកពោធិសត្វដែលពោលហើយក្នុងគាថាទី ១ ។ ថ្ងៃមួយ ទ្រង់ព្រះតម្រិះថា អញគ្រងរាជសម្បត្តិ រមែងធ្វើទុក្ខដល់ជនជាច្រើន ប្រយោជន៍អ្វីរបស់អាត្មាអញដោយបាបនេះ ដើម្បីប្រយោជន៍ដល់បាយតែម្យ៉ាងនោះណ្ហើយចុះ អញនឹងធ្វើសេចក្តីសុខឲ្យកើតឡើង ទើបទ្រង់លះរាជសម្បត្តិចេញបួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយបានត្រាស់ឧទានគាថានេះថា*

**បុត្តញ្ច ទារំ បិតរញ្ច មាតរំ**
**ធនានិ ធញ្ញានិ ច ពន្ធវានិ**
**ហិត្វាន កាមានិ យថោធិកានិ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

*បុគ្គលលះបង់នូវកាមទាំងឡាយ តាមចំណែក គឺ*
*បុត្ត ភរិយា បិតា មាតា ទ្រព្យសម្បត្តិ ស្រូវ អង្ករ*
*និងផៅពង្សហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូច*

កុយរមាស ។

បណ្ដាបទទាំងនោះ បទថា **ធនានិ** បានដល់ រតនៈទាំងឡាយ មានកែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាល ប្រាក់ និង មាសជាដើម ។ បទថា **ធញ្ញានិ** បានដល់ បុព្វន្នជាតិ ៧ ប្រភេទ មានស្រូវសាលី ស្រូវខ្សាយ ស្រូវដំណើប ស្រងែ ស្ពៅ ស្គួយ និងស្មៅ គែលលកជាដើម និងអបរណ្ណជាតិ មានសណ្ដែក ល្ងជាដើម ។ បទថា **ពន្ធវានិ** បានដល់ ផៅពង្ស ៤ យ៉ាងគឺ ផៅពង្សគឺញាតិ ១ ផៅពង្សគឺ គោត្ត ១ ផៅពង្សគឺមិត្ត ១ និងផៅពង្សគឺអ្នករួមសិប្បៈ ១ ។

បទថា **យថោធិកានិ** បានដល់ ដែលតាំងនៅតាមចំណែក រៀងៗ ខ្លួន ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

**បុត្តទារគាថាទី ៦ ចប់**

# សត្តគាថា

គាថាថា **សត្តោ ឯសោ** ដូច្នេះជាដើម មានហេតុកើតដូចម្តេច ។

បានឮថា ក្នុងនគរពារាណសី មានព្រះរាជាមួយអង្គ ព្រះនាមថា បាទលោលព្រហ្មទត្ត ។ ព្រះរាជាអង្គនោះ ទ្រង់សោយយាគូ ឬក្រយា-ស្ងោយអំពីព្រលឹមហើយ ទ្រង់ទតអ្នករបាំ ៣ ប្រភេទ ក្នុងប្រាសាទទាំង ៣ ។ ពាក្យថា អ្នករបាំ ៣ ប្រភេទ បានដល់ អ្នករបាំដែលមកអំពីព្រះរាជាក្នុងអតីត ១ អ្នករបាំដែលមកអំពីព្រះរាជាបន្ទាប់ ១ អ្នករបាំដែលកើតឡើងក្នុងរជ្ជកាលរបស់ព្រះអង្គ ១ ។

ថ្ងៃមួយ ទ្រង់យាងទៅកាន់ប្រាសាទអ្នករបាំវ័យក្មេងអំពីព្រលឹម ស្ត្រីអ្នករបាំទាំងឡាយគិតថា ពួកយើងនឹងឲ្យព្រះរាជាត្រេកអរ ទើបប្រកបការរាំច្រៀង និងការប្រគំដែលគួរចាប់ចិត្តក្រៃលែង ដូចពួកស្រីទេពអប្សររបស់សក្កទេវរាជស្តេចទេវតាដូច្នោះ ។ ព្រះរាជាមិនពេញព្រះហឫទ័យថា ការរាំរបស់អ្នករបាំវ័យក្មេងទាំងឡាយនោះ មិនអស្ចារ្យសោះ ទើបយាងទៅកាន់ប្រាសាទរបស់អ្នករបាំវ័យកណ្តាល ស្ត្រីអ្នករបាំទាំងនោះ ក៏បានធ្វើយ៉ាងនោះដូចគ្នា ទ្រង់មិនពេញព្រះហឫទ័យក្នុងស្ត្រីរបាំវ័យកណ្តាលនោះដូចគ្នា ទើបយាងទៅកាន់ប្រាសាទរបស់ស្រីរបាំវ័យចាស់ ស្ត្រីអ្នករបាំទាំងនោះ ក៏ធ្វើយ៉ាងនោះដូចគ្នា ។ ព្រះរាជាទ្រង់ឃើញការ

រាំដូចគ្នានឹងការលេងនៃគ្រោងឆ្អឹង ព្រោះស្ត្រីអ្នករបាំទាំងនោះ ជាមនុស្សចាស់ជរា កន្លងពីរបីរជ្ជកាលមកហើយ ទ្រង់ស្តាប់សំឡេងច្រៀងក៏មិនពីរោះ ទើបយាងទៅកាន់ប្រាសាទរបស់អ្នករបាំវ័យក្មេង ប្រាសាទរបស់អ្នករបាំវ័យកណ្តាល ទៅមក ៗ យ៉ាងនេះ ក៏ទ្រង់មិនពេញព្រះហឫទ័យក្នុងទីណាមួយឡើយ ទ្រង់ព្រះតម្រិះថា ស្ត្រីអ្នករបាំទាំងនេះ បំណងនឹងឲ្យអាត្មាអញត្រេកអរ ដូចស្រីទេពអប្សររបស់សក្កទេវរាជជាស្តេចទេវតាដូច្នោះ ទើបប្រកបការរាំ ការច្រៀង និងការប្រគំ ពេញសមត្ថភាពគ្រប់យ៉ាង អាត្មាអញនោះ មិនពេញចិត្តក្នុងទីណាសោះ ធ្វើឲ្យលោភៈចម្រើនឡើងប៉ុណ្ណោះ ឈ្មោះថា លោភៈនោះ ជាធម៌គប្បីនាំទៅកាន់អបាយណ្ហើយចុះ អាត្មាអញនឹងគ្របសង្កត់លោភៈនោះ ដូច្នេះហើយ ទ្រង់លះរាជសម្បត្តិ ហើយបួស ចម្រើនវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ ទើបត្រាស់ឧទានគាថានេះថា

**សង្គោ ឯសោ បរិត្តមេត្ថ សោខ្យំ**
**អប្បស្សាទោ ទុក្ខមេវេត្ថ ភិយ្យោ**
**គណ្ឌោ ឯសោ ឥតិ ញត្វា មតិមា**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

កាមគុណនេះ ជាគ្រឿងជាប់ចំពាក់ ឯសេចក្តីសុខក្នុង
កាមគុណនុ៎ះ មានប្រមាណតិច កាមគុណនុ៎ះ មាន

សេចក្តីត្រេកអរតិច បុគ្គលអ្នកមានគំនិតប្រាជ្ញា លុះ
ដឹងច្បាស់ថា កាមគុណទាំ់ះ ដូចជាដំបៅពក ដូច្នេះ
ហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

អត្ថនៃឧទានគាថានោះ មានដូច្នេះថា ព្រះរាជាទ្រង់ចង្អុលបង្ហាញនូវគ្រឿងប្រើប្រាស់របស់ព្រះអង្គ ដោយបទថា **សង្គោ ឯសោ** ដូច្នេះជាដើម ។ គ្រឿងប្រើប្រាស់នោះ ឈ្មោះថា សង្គៈ ព្រោះជាទីជាប់ចំពាក់របស់សត្វទាំងឡាយ ដូចដំរីជាប់ក្នុងភក់ដូច្នោះ ។ បទថា **បរិត្តមេត្ថ សោខ្យំ** បានដល់ ក្នុងកាលបរិភោគបញ្ចកាមគុណនេះ ឈ្មោះថា មានសុខតិច ព្រោះអត្ថថា លាមក ដោយឲ្យកើតនូវការសម្គាល់ខុស ឬដោយរាប់បញ្ចូលដោយកាមាវចរធម៌ មានអធិប្បាយថា មានបន្តិចបន្តួច គឺមានមួយជួរខណៈ ដូចក្នុងការមើលអ្នករបាំដែលរាំក្នុងទីដែលមានផ្ទេកបន្ទោរដូច្នោះ ។ ទោសរបស់កាមទាំងឡាយ គប្បីជ្រាបថា **អប្បស្សាទោ ទុក្ខមេវេត្ថ ភិយ្យោ** មានសេចក្តីត្រេកអរតិច ដូចជាដំណក់ទឹកបន្តិចបន្តួច កាលប្រៀបធៀបជាមួយទុក្ខដែលព្រះមានព្រះភាគត្រាស់ទុកដោយន័យយ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាតម្រេករបស់កាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កាមគុណ ( ចំណង់ កាម ) នេះ មាន ៥ ប្រការ កាមគុណ ៥ ប្រការ តើអ្វីខ្លះ គឺរូបទាំងឡាយដែលគប្បីដឹងដោយភ្នែក

ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ត្រូវតាមចំណង់ ជាទីត្រេកត្រអាល ១ សំឡេងទាំងឡាយដែលគប្បីដឹងបានដោយត្រចៀក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ត្រូវតាមចំណង់ ជាទីត្រេកត្រអាល ១ ក្លិនទាំងឡាយដែលគប្បីដឹងបានដោយច្រមុះ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ត្រូវតាមចំណង់ ជាទីត្រេកត្រអាល ១ រសទាំងឡាយដែលគប្បីដឹងបានដោយអណ្តាត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ត្រូវតាមចំណង់ ជាទីត្រេកត្រអាល ១ ផ្សព្វទាំងឡាយដែលគប្បីដឹងបានដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ត្រូវតាមចំណង់ ជាទីត្រេកត្រអាល ១ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា កាមគុណ ៥ ប្រការ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខសោមនស្ស កើតឡើងព្រោះអាស្រ័យកាមគុណទាំង ៥ ប្រការនេះ នេះឯងជាតម្រេករបស់កាមគុណទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាទោសរបស់កាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងលោកនេះ ចិញ្ចឹមជីវិតដោយសេចក្តីប្រឹងប្រែងដោយសិល្បសាស្ត្រណាមួយ ទោះបីដោយការរាប់ម្រាមដៃទទេក្តី ដោយការរាប់លេខនព្វន្តក្តី ដោយការរាប់ប្រមូលក្តី ដោយកសិកម្មក្តី ដោយពាណិជ្ជកម្មក្តី ដោយគោរក្ខកម្មក្តី ដោយភាវៈនៃខ្លួនជាអ្នកកាន់អាវុធក្តី

ដោយការៈនៃខ្លួនជារាជបុរសក្តី ដោយសិល្បសាស្ត្រណាមួយក្តី កុលបុត្ត ដែលអាស្រ័យនូវការចិញ្ចឹមជីវិត ដោយការរាប់ម្រាមដៃទទេជាដើមនោះ តែងមានត្រជាក់បៀតបៀន មានក្តៅបៀតបៀន ប៉ះពាល់ដោយសម្ផស្ស នៃរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំ ស្លាប់ខ្លួនព្រោះ សេចក្តីស្រេកឃ្លាន ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាម ទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជា ហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយ មែនពិត ។ ម្នាលភិក្ខុទាំងឡាយ កាលបើ កុលបុត្តនោះ ប្រឹងប្រែងខ្នះខ្នែងព្យាយាមយ៉ាងនេះហើយ ភោគៈទាំង-ឡាយនោះ ក៏មិនបានសម្រេច កុលបុត្តនោះ តែងក្រៀមក្រំចិត្ត លំបាក ខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំ ដល់នូវសេចក្តីវង្វេងថា ឱសេចក្តីប្រឹងប្រែង របស់អញ ឥតអំពើសោះ ឱសេចក្តីព្យាយាមរបស់អញ ឥតផលសោះ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គល គប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿង ប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយ មែនពិត ។ ម្នាលភិក្ខុទាំងឡាយ កាលបើកុលបុត្តនោះ ប្រឹងប្រែងខ្នះខ្នែង ព្យាយាមយ៉ាងនេះហើយ ភោគៈទាំងឡាយនោះក៏សម្រេច កុលបុត្តនោះ តែងទទួលនូវសេចក្តីទុក្ខទោមនស្ស ព្រោះហេតុនៃការរក្សានូវភោគៈ

ទាំងឡាយនោះថា ធ្វើដូចម្ដេចហ្ន៎ កុំឲ្យព្រះរាជាទាំងឡាយនាំយកភោគៈ ទាំងឡាយនោះទៅបាន កុំឲ្យចោរទាំងឡាយលួចយកបាន កុំឲ្យភ្លើងឆេះបាន កុំឲ្យទឹកបន្សាត់ទៅបាន កុំឲ្យអ្នកទទួលមត៌កទាំងឡាយ ដែលមិនជាទីស្រឡាញ់នាំយកទៅបាន ។ កាលកុលបុត្តនោះ ខំរក្សាគ្រប់គ្រងយ៉ាងនេះ ក៏ស្រាប់តែព្រះរាជាទាំងឡាយ រឹបយកនូវភោគៈទាំងឡាយនោះទៅក្ដី ចោរទាំងឡាយលួចយកទៅក្ដី ភ្លើងឆេះទៅក្ដី ទឹកបន្សាត់ទៅក្ដី អ្នកទទួលមត៌កទាំងឡាយ ដែលមិនជាទីស្រឡាញ់នាំយកទៅក្ដី កុលបុត្តនោះ តែងក្រៀមក្រំចិត្ត លំបាក ខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំ ដល់នូវសេចក្ដីវង្វេងថា ទ្រព្យណា បានកើតមានដល់អាត្មាអញហើយ ឥឡូវនេះ ទ្រព្យនោះឯង ត្រឡប់ជាមិនមានដល់អាត្មាអញវិញឡើយ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្ដួចផ្ដើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្ដួចផ្ដើម ជាបច្ច័យនៃកាមទាំងឡាយ មែនពិត បានជាព្រះរាជាទាំងឡាយទាស់ទែងគ្នានឹងព្រះរាជាទាំងឡាយខ្លះ ក្សត្រទាំងឡាយទាស់ទែងគ្នានឹងក្សត្រទាំងឡាយខ្លះ

ព្រាហ្មណ៍ទាំងឡាយទាស់ទែងគ្នានឹងព្រាហ្មណ៍ទាំងឡាយខ្លះ គហបតីទាំងឡាយទាស់ទែងគ្នានឹងគហបតីទាំងឡាយខ្លះ មាតាទាស់ទែងនឹងបុត្តខ្លះ បុត្តទាស់ទែងនឹងមាតាខ្លះ បិតាទាស់ទែងនឹងបុត្តខ្លះ បុត្តទាស់ទែងនឹងបិតាខ្លះ បងប្អូនប្រុសទាស់ទែងនឹងបងប្អូនប្រុសខ្លះ បងប្អូនប្រុសទាស់ទែងនឹងបងប្អូនស្រីខ្លះ បងប្អូនស្រីទាស់ទែងនឹងបងប្អូនប្រុសខ្លះ សម្លាញ់ទាស់ទែងនឹងសម្លាញ់ខ្លះ ពួកមនុស្សទាំងនោះ ក៏ដល់នូវសេចក្តីឈ្លោះប្រកែក ប្រកាន់ខុស ទាស់ទែងគ្នាក្នុងទីនោះហើយ ប្រហារគ្នាទៅវិញទៅមក ដោយដៃខ្លះ ប្រហារគ្នាដោយដុំដីខ្លះ ប្រហារគ្នាដោយដំបងខ្លះ ប្រហារគ្នាដោយគ្រឿងសស្ត្រាខ្លះ ជនទាំងនោះ ក៏ដល់នូវសេចក្តីស្លាប់ក្នុងទីនោះខ្លះ ដល់នូវសេចក្តីទុក្ខស្មើរនឹងស្លាប់ខ្លះ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយ មែនពិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយ បានជាមនុស្សទាំងឡាយ កាន់នូវដាវនិងខែល កាន់ធ្នូសៀតបំពង់ព្រួញចូលទៅកាន់សង្គ្រាម ដែលកើតជាក្បួនទ័ពមកទាំងសងខាង កាលដែលគេបាញ់ព្រួញមកក្តី កាលដែលគេពួយលំពែងមកក្តី កាលដែលគេផ្គា

ដាវឡើងក្ដី មនុស្សទាំងឡាយនោះ បាញ់គ្នាដោយព្រួញខ្លះ ចាក់គ្នាដោយលំពែងខ្លះ កាប់ក្បាលគ្នាដោយដាវខ្លះ ក្នុងសង្គ្រាមនោះ មនុស្សទាំងឡាយនោះ ក៏ដល់នូវសេចក្ដីស្លាប់ខ្លះ ដល់នូវសេចក្ដីទុក្ខស្មើរនឹងស្លាប់ខ្លះ ក្នុងសង្គ្រាមនោះ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្ដួចផ្ដើមជាបច្ច័យនៃកាមទាំងឡាយ មែនពិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀតព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្ដួចផ្ដើម ជាបច្ច័យនៃកាមទាំងឡាយ មែនពិត បានជាមនុស្សទាំងឡាយនោះ កាន់ដាវនិងខែល កាន់ធ្នូសៀតបំពង់ព្រួញ ចូលទៅកាន់បន្ទាយ ដែលលាបបូកដោយបាយអ កាលដែលគេបាញ់ព្រួញមកក្ដី កាលដែលគេពួយលំពែងមកក្ដី កាលដែលគេងាដាវឡើងក្ដី មនុស្សទាំងនោះ ក៏បាញ់គ្នាដោយព្រួញខ្លះ ចាក់គ្នាដោយលំពែងខ្លះ បាចសាចដាក់គ្នាដោយអាចម៍គោជ្រាយខ្លះ ញាំញីគ្នាដោយរនាស់ដែកខ្លះ កាប់ក្បាលគ្នាដោយដាវខ្លះ ក្នុងបន្ទាយនោះ មនុស្សទាំងនោះ ដល់នូវសេចក្ដីស្លាប់ខ្លះ ដល់នូវសេចក្ដីទុក្ខស្មើរនឹងស្លាប់ខ្លះ ក្នុងបន្ទាយនោះ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញចំពោះខ្លួនឯង ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់

ឲ្យនូវផល មានកាមជាគ្រឿងផ្គួបផ្ដើម ជាបច្ច័យនៃកាមទាំងឡាយ មែនពិត ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្គួបផ្ដើម ជាបច្ច័យនៃកាមទាំងឡាយ មែនពិត មនុស្សទាំងឡាយក៏កាត់នូវជញ្ជាំងផ្ទះខ្លះ ប្លន់ខ្លះ កំហែងយកទ្រព្យក្នុងផ្ទះមួយ ។ ខ្លះ ឈរស្ទាក់ប្រកផ្លូវខ្លះ គប់រកភរិយារបស់អ្នកដទៃខ្លះ ។ ព្រះរាជាទាំងឡាយចាប់មនុស្សទាំងនោះបានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ទាំងឡាយ មានប្រការផ្សេង ។ គឺវាយដោយរំពាត់ខ្លះ វាយដោយផ្ដៅខ្លះ វាយដោយដំបងខ្លីខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ទាំងដៃទាំងជើងខ្លះ កាត់ស្លឹកត្រចៀកខ្លះ កាត់ច្រមុះខ្លះ កាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ ធ្វើពិលង្គថាលិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់ខ្លះ ធ្វើនូវសង្ខមុណ្ឌកកម្ម គឺអំពើដែលគេធ្វើក្បាលឲ្យរលីងដូចជាសម្បកស័ង្ខខ្លះ ធ្វើនូវរាហុមុខកម្ម គឺអំពើដែលគេធ្វើមាត់ឲ្យដូចជាមាត់រាហូខ្លះ ធ្វើនូវជោតិមាលិកកម្ម គឺអំពើដែលធ្វើខ្លួនមនុស្សឲ្យដូចជាផ្កាភ្លើងខ្លះ ធ្វើនូវហត្ថប្បជ្ជោតិកកម្ម គឺអំពើដែលគេដុតដៃខ្លះ ធ្វើនូវឯរកវត្តិកកម្ម គឺអំពើដែលធ្វើដូចជាពន្ទាត់ស្បែកពពែខ្លះ ធ្វើនូវចីរកវាសិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាស្លៀកសំពត់សម្បកឈើខ្លះ ធ្វើនូវឯណេយ្យកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាជើងសត្វទ្រាយខ្លះ ធ្វើនូវពលិសមំសិកកម្ម គឺអំពើដែលគេចក់មាត់ដោយកាង ឬ

សន្ទូចខ្លះ ធ្វើនូវកហាបណកកម្ម គឺអំពើដែលគេធ្វើឲ្យខ្ទូចសរីរៈប្រមាណប៉ុនកហាបណៈមួយ ៗ ខ្លះ ធ្វើនូវខារាបដិច្ឆកកម្ម គឺអំពើដែលគេយកទឹកផ្សាស្រោចខ្លះ ធ្វើនូវបលិឃបរិវត្តិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាបង្វិលដើមគុល ឬសសរគោលខ្លះ ធ្វើនូវបលាលបីឋកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាកណ្តាប់ចំបើងខ្លះ ស្រោចដោយប្រេងដែលក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ មនុស្សទាំងនោះ ក៏ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ខ្លះក្នុងទីនោះ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលឃើញទាន់ភ្នែក ជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយ មែនពិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយ បានជាជនទាំងឡាយប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះជនទាំងឡាយនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ ដល់បែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ ក៏ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសរបស់កាមទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបរលោក ជាគំនរ

នៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយ មែនពិត ដូច្នេះ [១] ។

ប្រៀបធៀបហើយ វត្ថុណាគួរពេញចិត្ត វត្ថុនោះ មានតិចប្រមាណប៉ុនតំណក់ទឹក ដោយពិត ទុក្ខនោះឯង មានច្រើនក្រៃលែងជាងដូចទឹកក្នុងមហាសមុទ្ទទាំង ៤ ដោយហេតុនោះ ទើបលោកពោលថា **អប្បស្សាទោ ទុក្ខមេវេត្ថ ភិយ្យោ** ដូច្នេះ ។ បទថា **គណ្ឌោ**[២] **ឯសោ** សេចក្តីថា គ្រឿងឧបភោគបរិភោគជាវត្ថុជាប់ចំពាក់ គឺកាមគុណ ៥ នេះ ប្រៀបដូចសន្ទូចដែលបិទនុយ ព្រោះបង្ហាញនូវអារម្មណ៍ជាទីត្រេកអរ ហើយអូសទាញមក ។

បទថា **ឥតិ ញត្វា មតិមា** សេចក្តីថា បុរសដែលមានការដឹង គឺបណ្ឌិតដឹងយ៉ាងនេះហើយ គប្បីលះការជាប់ចំពាក់ទាំងអស់នោះ ហើយត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាសដូច្នោះ ។

## សង្គគាថាទី ៧ ចប់

---

១-បិ.២០ ទំ.៣១៤-៣២៣ ឃ.១៩៧-១៩៨ ។ ក្នុងអដ្ឋកថា ព្រះសូត្រនេះ លោកលើកមកដោយសង្ខេប តែដោយព្រះពុទ្ធដីកាមានសេចក្តីពីរោះ ទើបយើងលើកយកមកដោយពិស្តារទុកក្នុងទីនេះ ។ ២-បិដកខ្មែរជា គណ្ឌោ ។

# សន្ទាលគាថា

*គាថាថា* **សន្ទាលយិត្វាន** *ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។*

*បានឮថា ក្នុងនគរពារាណសី មានព្រះរាជាព្រះនាមថា អនិវត្ត-ព្រហ្មទត្ត ព្រះរាជានោះ កាលចូលកាន់សង្គ្រាមហើយ បើទ្រង់ធ្វើការច្បាំង ហើយមិនឈ្នះ ឬបើទ្រង់ធ្វើកិច្ចការដទៃ ហើយមិនសម្រេច ទ្រង់មិនត្រឡប់មក ព្រោះហេតុនោះ ទើបជនទាំងឡាយស្គាល់ទ្រង់យ៉ាងនោះ ។*

*ថ្ងៃមួយ ទ្រង់យាងទៅកាន់ព្រះរាជឧទ្យាន ។ សម័យនោះ ភ្លើងព្រៃកើតឡើង ភ្លើងនោះ ឆេះឈើស្ងួតនិងស្មៅស្រស់ជាដើម រាលទៅមិនត្រឡប់ឡើយ ។ ព្រះរាជាទ្រង់ឃើញភ្លើងនោះហើយ ទ្រង់ញុំាងនិមិត្តដែលប្រៀបដោយភ្លើងនោះ ឲ្យកើតឡើងថា ភ្លើងនេះ យ៉ាងណា ភ្លើង ១១ កង[១] ក៏យ៉ាងនោះ ដូចគ្នា ឆេះសត្វទាំងពួង រាលទៅមិនត្រឡប់បង្កនូវសេចក្ដីទុក្ខដ៏ធំ បើដូច្នោះ ដើម្បីឲ្យទុក្ខនេះ អស់ទៅ អញគួរដុតកិលេសទាំងឡាយមិនឲ្យត្រឡប់មក ដោយភ្លើងគឺអរិយមគ្គញ្ញាណ ដូចភ្លើងនេះ ឲ្យបាន ។*

---

*១-ភ្លើង ១១ កងគឺ ភ្លើងគឺរាគៈ ភ្លើងគឺទោសៈ ភ្លើងគឺមោហៈ ភ្លើងគឺជាតិ ភ្លើងគឺជរា ភ្លើងគឺមរណៈ ភ្លើងគឺសោកៈ ភ្លើងគឺបរិទេវៈ ភ្លើងគឺទុក្ខ ភ្លើងគឺទោមនស្ស ភ្លើងគឺឧបាយាសៈ ។*

បន្ទាប់អំពីនោះ ទ្រង់យាងទៅបន្តិចទៀត ឃើញពួកអ្នកប្រមង់ទាំងឡាយកំពុងចាប់ត្រីក្នុងស្ទឹង ត្រីធំមួយជាប់សំណាញ់របស់អ្នកប្រមង់នោះ បានទម្លាយសំណាញ់គេចទៅ អ្នកប្រមង់ទាំងនោះស្រែកថា ត្រីទម្លាយសំណាញ់គេចទៅហើយ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះ ទើបទ្រង់កាន់យកនិមិត្តប្រៀបធៀបដោយត្រីនោះ ឲ្យកើតឡើងថា កាលណាហ្ន៎ អាត្មាអញគប្បីទម្លាយសំណាញ់ គឺតណ្ហានិងទិដ្ឋិ ដោយអរិយមគ្គញ្ញាណ មិនជាប់ចំពាក់ហើយទៅ ដូច្នេះ ។ ព្រះរាជានោះ ទ្រង់លះរាជសម្បត្តិ ហើយបួសទ្រង់ប្រារព្ធវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ត្រាស់ឧទានគាថានេះថា

**សន្ទាលយិត្វាន សំយោជនានិ**

**ជាលំវ ភិត្វា សលិលម្ពុចារី**

**អគ្គីវ ទឌ្ឍំ អនិវត្តមានោ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលទម្លាយនូវសំយោជនៈ ដូចត្រីក្នុងទឹក ទម្លាយនូវសំណាញ់ មិនត្រឡប់មករកសំយោជនៈវិញ ដូចភ្លើងឆេះ ( មិនត្រឡប់វិញ ) គប្បីប្រព្រឹត្តតែម្នាក់ឯងដូចកុយរមាស ។

*ក្នុងបទទី ២ របស់គាថានោះ វត្ថុដែលធ្វើដោយអំបោះ ហៅថា* **ជាល** *( សំណាញ់ ) ។ ទឹកហៅថា* **អម្ពុ** *ឈ្មោះថា* **អម្ពុចារី** *ព្រោះត្រាច់ទៅក្នុងទឹកនោះ ។ ពាក្យថា* **អម្ពុចារី** *នោះ ជាឈ្មោះនៃត្រី ។ ត្រីក្នុងទឹក ឈ្មោះថា* **សលិលម្ពុចារី** *អធិប្បាយថា ដូចត្រីទម្លាយសំណាញ់គេចទៅក្នុងទឹកដូច្នោះ ។*

*ក្នុងបាទទី ៣ ទីដែលត្រូវភ្លើងឆេះ ហៅថា* **ទឌ្ឍំ** *អធិប្បាយថា ភ្លើងរមែងមិនវិលត្រឡប់មកកាន់ទីដែលឆេះហើយ គឺមកកើតត្រង់នោះទៀត មិនបានយ៉ាងណា អញក៏មិនវិលត្រឡប់មកកាន់ស្ថានទី គឺកាមគុណ ដែលត្រូវដុតដោយភ្លើងគឺមគ្គញ្ញាណ គឺមិនមករកកាមគុណនោះទៀត ក៏យ៉ាងនោះដែរ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនុ៎ះឯង ។*

សន្ទាលគាថាទី ៨ ចប់

# ឱក្ខិត្តចក្ខុគាថា

គាថាថា **ឱក្ខិត្តចក្ខូ** ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។

បានឮថា ក្នុងនគរពារាណសី ព្រះរាជាព្រះនាមថា ចក្ខុលោលព្រហ្មទត្ត ជាអ្នកខ្វល់ខ្វាយក្នុងការមើលរបាំ ដូចព្រះរាជាព្រះនាមថា បាទលោលព្រហ្មទត្តដែរ ។ ឯសេចក្ដីប្លែកគ្នាមានដូចតទៅនេះថា

ព្រះបាទបាទលោលព្រហ្មទត្តនោះ ជាអ្នកមិនពេញព្រះហឫទ័យ យាងទៅតាមប្រាសាទផ្សេង ៗ ឯព្រះបាទចក្ខុលោលព្រហ្មទត្តអង្គនេះ ទតរបាំនោះ ៗ ទ្រង់ត្រេកអរក្រៃលែង ទ្រង់បន្ថែមនូវចំណង់ដោយផ្លាស់ប្ដូរការទត ការសម្ដែងរបាំនោះ ។ បានឮថា ទ្រង់ឃើញកិរិយារបស់កុដុម្ពិកៈម្នាក់ដែលមកមើលការសម្ដែង បានញុំាងតម្រេកឲ្យកើតឡើង ។ បន្ទាប់អំពីនោះ ទ្រង់ដល់នូវសេចក្ដីសង្វេគ ទើបព្រះតម្រិះថា ឱ! អញកាលញុំាងតណ្ហានេះ ឲ្យចម្រើនឡើង នឹងជាអ្នកពេញក្នុងអបាយ ណ្ហើយចុះ អញនឹងគ្របសង្កត់តណ្ហានេះ ដូច្នេះហើយ ទើបចេញបួស ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ ។ កាលទ្រង់តិះដៀលការបដិបត្តិដំបូងរបស់ព្រះអង្គ ទើបទ្រង់ត្រាស់ឧទានគាថានេះ ដែលសម្ដែងគុណដែលជាបដិបក្ខចំពោះការបដិបត្តិនោះថា

**ឱក្ខិត្តចក្ខូ ន ច បាទលោលោ**

**គុត្តិន្ទ្រិយោ រក្ខិតមានសានោ**
**អនវស្សុតោ អបរិឌយ្ហមានោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

*បុគ្គលមានចក្ខុដាក់ចុះ មានជើងមិនរពឹស ជាអ្នក*
*គ្រប់គ្រងឥន្ទ្រិយ រក្សាចិត្តទុក ( ដោយល្អ ) មិន*
*ដោកជាំ មិនរោលរាល ( ដោយកិលេស ) គប្បី*
*ប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។*

*បណ្ដាបទទាំងនោះ បទថា* **ឱក្ខិត្តចក្ខុ** *បានដល់ ជាអ្នកមានចក្ខុដាក់ចុះទៅក្រោម លោកអធិប្បាយទុកថា ដាក់ចុះនូវឆ្អឹងក ៧ កំណាត់ដោយលំដាប់ សម្លឹងមើលមួយជួរនឹម ដើម្បីនឹងមើលវត្ថុដែលគួរវៀរ និងវត្ថុដែលគួរកាន់យក តែមិនមែនយកឆ្អឹងចង្កាមកទល់នឹងឆ្អឹងដើមទ្រូង ព្រោះកាលបើយ៉ាងនោះ ក៏មិនជាសមណសារុប្ប: ( ភាពសមរម្យរបស់សមណ: ) ។*

*បទថា* **ន ច បាទលោលោ** *សេចក្ដីថា មិនដូចបុគ្គលមានជើងរមាស់ ព្រោះចង់ដើរចូលទៅរកពួកជនដោយអាការយ៉ាងនេះ គឺមានបុគ្គល ១ ទៅឲ្យបានគម្រប់ ២ មានបុគ្គល ២ ទៅឲ្យបានគម្រប់ ៣ គឺវៀរចាកការត្រាច់ចារិកទៅយូរ និងត្រាច់ចារិកទៅមិនត្រឡប់ ។*

*បទថា* **គុត្តិន្ទ្រិយោ** *សេចក្ដីថា ជាអ្នកមានឥន្ទ្រិយគ្រប់គ្រងដោយ*

អំណាចការគ្រប់គ្រងឥន្ទ្រិយដ៏សេសអំពីដែលពោលហើយ ព្រោះបណ្ដាឥន្ទ្រិយទាំង ៦ ក្នុងទីនេះ លោកចែកមនិន្ទ្រិយទុកដោយឡែក ។ បទថា **រក្ខិតមានសានោ** សេចក្ដីថា **មានសានំ** គឺ **មានសំ** នោះឯង ។ ឈ្មោះថា **រក្ខិត** ព្រោះរក្សាចិត្តនោះបាន ។ លោកអធិប្បាយថា ជាអ្នករក្សាចិត្តបាន ដោយប្រការដែលមិនត្រូវកិលេសប្ងន់ ។

បទថា **អនវស្សុតោ** សេចក្ដីថា ជាអ្នកវៀរចាកការត្រូវកិលេសលិចស្រោចក្នុងអារម្មណ៍នោះ ៗ ដោយការបដិបត្តិនេះ ។

បទថា **អបរិឌយ្ហមានោ** បានដល់ មិនត្រូវភ្លើងកិលេសដុត ។ម្យ៉ាងទៀត បានដល់ មិនត្រូវកិលេសលិចស្រោចខាងក្រៅ មិនត្រូវភ្លើងកិលេសដុតខាងក្នុង ។ ពាក្យដ៏សេស មានន័យដូចពោលហើយនុ៎ះឯង ។

ឱក្ខិត្តចក្ខុគាថាទី ៩ ចប់

# ចារិច្ឆត្តកគាថា

គាថាថា **ឱហារយិត្វា** ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។

បានឮថា ក្នុងនគរពារាណសី មានព្រះរាជាមួយអង្គ ព្រះនាមថា ចាតុមាសិកព្រហ្មទត្ត ទ្រង់យាងទៅប្រពាសឧទ្យានរៀងរាល់ ៤ ខែម្ដង ។ ថ្ងៃមួយ ទ្រង់យាងចូលទៅកាន់ឧទ្យានក្នុងខែកណ្ដាលនៃគិម្ហរដូវ ទ្រង់ឃើញដើមរលួសផ្អុងដេរដាសដោយស្លឹក មានមែកនិងប្រគាបប្រដាប់ដោយផ្កាត្រង់ទ្វារឧទ្យាន ទ្រង់កាន់យកផ្កាមួយ ហើយយាងចូលទៅកាន់ឧទ្យាន ។

លំដាប់នោះ អាមាត្យម្នាក់នៅលើកដំរី គិតថា ព្រះរាជាទ្រង់កាន់យកផ្កាដ៏ប្រសើរទៅហើយ ទើបកាន់យកផ្កាមួយដូចគ្នា ។ ពួកពលទាំងអស់បានកាន់យកដោយឧបាយនេះ ដូចគ្នា ពួកអ្នកដែលមិនចូលចិត្តផ្កាក៏បេះស្លឹកកាន់យកទៅ ។ ដើមឈើនោះ អស់ស្លឹកនិងផ្កា មានត្រឹមតែដើមប៉ុណ្ណោះ ។

ក្នុងវេលាល្ងាច ព្រះរាជាយាងចេញអំពីឧទ្យាន ទ្រង់ឃើញដូច្នោះ ទ្រង់ព្រះតម្រិះថា ដើមឈើនេះ អ្នកណាធ្វើឬ ក្នុងវេលាដែលអាត្មាអញមក ដើមឈើនេះ នៅល្អដោយផ្កាដូចគ្នានឹងកែវប្រពាល ក្នុងរវាងមែកដែលមានពណ៌ដូចកែវមណី ឥឡូវនេះ ក្លាយជាដើមឈើប្រាសចាកស្លឹក

និងផ្កា ។ កាលព្រះរាជាកំពុងត្រិះរិះ ក៏បានទតឃើញដើមឈើមិនមានផ្កា មានស្លឹកត្រសាយត្រសុំ ក្នុងទីមិនឆ្ងាយអំពីដើមរលួសផ្អុងនោះ កាលទ្រង់បានឃើញហើយ ទ្រង់មានព្រះតម្រិះដូច្នេះថា ដើមឈើនេះ ព្រោះមែកមានផ្កា ទើបធ្វើឲ្យមនុស្សជាច្រើនចង់បាន ព្រោះហេតុនោះ ទើបដល់នូវសេចក្ដីវិនាស ត្រឹមមួយរំពេចប៉ុណ្ណោះ ។ ចំណែកដើមឈើមួយទៀត តាំងនៅដដែល ព្រោះមនុស្សមិនចង់បាន ។ ឯរាជសម្បត្តិនេះសោត ក៏មានមនុស្សចង់បានដូចដើមឈើមានផ្កាដូច្នោះ ចំណែកភិក្ខុភាវៈ មិនមានមនុស្សចង់បាន ដូចដើមឈើដែលមិនមានផ្កា ព្រោះហេតុនោះ ដរាបណាដែលរាជសម្បត្តិនេះ មិនទាន់ត្រូវដណ្ដើមដូចដើមឈើនេះ ដរាបនោះ អញនឹងស្លៀកដណ្ដប់សំពត់កាសាវៈ ហើយបួសដូចដើមរលួសផ្អុងដទៃ ដែលមានស្លឹកត្រសុំត្រសាយដូច្នោះ ។ ព្រះរាជានោះ ទ្រង់លះរាជសម្បត្តិ បួស ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ហើយបានត្រាស់ឧទានគាថានេះថា

ឱហារយិត្វា គិហិព្យញ្ជនានិ
សញ្ឆិន្នបត្តោ យថា ចារិឆត្តោ
កាសាយវត្ថោ អភិនិក្ខមិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

បុគ្គលលះបង់នូវភេទគ្រហស្ថ ដូចដើមបារិច្ឆត្តព្រឹក្ស

*ដែលមានស្នឹកដាច់ហើយ មានសំពត់កាសាយៈ*
*ចេញបួសហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយ*
*រមាស ។*

*បណ្ដាបទទាំងនោះ បាទគាថាថា* **កាសាយវត្ថោ អភិនិក្ខមិត្វា** *នេះ គប្បីជ្រាបអត្ថយ៉ាងនេះថា ទ្រង់ចេញចាកដំណាក់ ជាអ្នកស្លៀកដណ្ដប់សំពត់កាសាវៈ ។ ពាក្យដ៏សេស អាចដឹងច្បាស់បានដោយន័យដូចពោលហើយនុ៎ះឯង ព្រោះហេតុនោះ ទើបមិនចាំបាច់ពោលឲ្យពិស្ដារ ។*

បារិច្ឆត្តកគាថាទី ១០ ចប់

## វគ្គទី ៣ ចប់

# វគ្គទី ៤

# រសគេធគាថា

គាថាថា **រសេសុ** ដូច្នេះជាដើម មានហេតុកើតដូចម្តេច ។

បានឮថា ព្រះបាទពារាណសីមួយអង្គ មានបុត្តរបស់អាមាត្យទាំងឡាយចោមរោមក្នុងឧទ្យាន ទ្រង់ក្រសាលក្នុងស្រះបោក្ខរណីដែលដេរដាសដោយផ្ទាំងថ្ម ។ អ្នកពិសេសរបស់ព្រះអង្គយករសសាច់គ្រប់ប្រភេទ មកចម្អិនក្នុងអន្តរភត្ត ដែលផ្សំល្អក្រៃលែងដូចអមតរស ហើយបង្អោនចូលទៅថ្វាយ ។ ព្រះរាជាទ្រង់ជាប់ក្នុងរសនោះ មិនប្រទានដល់បុគ្គលណា សោយតែមួយអង្គឯងប៉ុណ្ណោះ ។ ទ្រង់យាងចេញអំពីទីលេងទឹក ក្នុងវេលាថ្ងៃជ្រេពេក ក៏សោយប្រញាប់ៗ ។ ក្នុងកាលមុនទ្រង់សោយជាមួយនឹងពួកបរិជនណា ទ្រង់មិនរឭកនូវបរិជនទាំងនោះណាម្នាក់ឡើយ ។ ក្រោយមក ទ្រង់ធ្វើការពិចារណា ទ្រង់សង្វេគថា ឱហ្ន៎ ! អញត្រូវចំណង់ក្នុងរសគ្របសង្កត់ ភ្លេចជនទាំងពួង បរិភោគម្នាក់ឯងប៉ុណ្ណោះ បានធ្វើកម្មដ៏អាក្រក់ហើយ ណ្ហើយចុះ អញនឹងគ្របសង្កត់ចំណង់ក្នុងរសនោះ ដូច្នេះហើយ ទ្រង់លះរាជសម្បត្តិ ចេញបួសចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ កាលទ្រង់

តិះដៀលការបដិបត្តិដែលមានក្នុងកាលមុនរបស់ព្រះអង្គ ទើបពោលឧទានគាថានេះ សម្តែងគុណផ្ទុយនឹងការបដិបត្តិនោះថា

**រសេសុ គេធំ អករំ អលោលោ**
**អនញ្ញបោសី សបទានចារី**
**កុលេ កុលេ អប្បដិពទ្ធចិត្តោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គល មិនធ្វើនូវសេចក្តីប្រាថ្នាក្នុងរសទាំងឡាយ
ជាអ្នកមិនល្មោភ មិនចិញ្ចឹមនូវបុគ្គលដទៃ ជាអ្នក
ត្រាច់ទៅសព្វច្រក មិនជាប់ចិត្តក្នុងត្រកូលមួយ ៗ
គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

បណ្តាបទទាំងនោះ បទថា **រសេសុ** បានដល់ ក្នុងរបស់គួរលិទ្ធភ្លក្ស មានរសជូរ រសផ្អែម រសល្វីង រសហឹរ រសប្រៃ រសខារ រសចត់ជាដើម ។ បទថា **គេធំ អករំ** ប្រែថា មិនធ្វើនូវការចង់បាន អធិប្បាយថា មិនញុំាំងនូវតណ្ហាឲ្យកើតឡើង ។ បទថា **អលោលោ** បានដល់ មិនវង្វេងក្នុងការឆ្ងាញ់នៃរសទាំងឡាយយ៉ាងនេះថា អញនឹងលិទ្ធភ្លក្សវត្ថុនេះ អញនឹងលិទ្ធភ្លក្សវត្ថុនេះ ។

បទថា **អនញ្ញបោសី** បានដល់ វៀរចាកបុគ្គល មានសទ្ធិវិហារិកដែលខ្លួនគប្បីចិញ្ចឹមជាដើម មានអធិប្បាយថា ត្រេកអរហើយ ដោយ

ហេតុត្រឹមតែការសង្រួមផ្លូវកាយ ។ម្យ៉ាងទៀត អធិប្បាយថា ឈ្មោះថា **អជ្ឈោសី** ព្រោះមិនដូចកាលមុន គឺក្នុងឧទ្យានដែលខ្ញុំមានប្រក្រតីធ្វើនូវចំណង់ក្នុងរសទាំងឡាយ ឲ្យអ្នកដទៃចិញ្ចឹម (ខ្ញុំ) លះតណ្ហាដែលជាហេតុឲ្យកើតលោភៈ ដែលធ្វើចំណង់ក្នុងរសទាំងឡាយ មិនឲ្យអ្នកដទៃចិញ្ចឹម ដោយមិនធ្វើឲ្យកើតអត្តភាព (ក្នុងភព) ដទៃ ដែលមានតណ្ហាជាឫសគល់ ។ ម្យ៉ាងទៀត ក្នុងបទនេះ មានអត្ថដូចតទៅនេះថា កិលេសទាំងឡាយហៅថា **អញ្ញ** ព្រោះអត្ថថា បំផ្លាញប្រយោជន៍ ឈ្មោះថា **អជ្ញោសី** ព្រោះមិនចិញ្ចឹមកិលេសទាំងនោះ ។

បទថា **សបទានចារី** បានដល់ មានប្រក្រតីត្រាច់ទៅ មិនគេចចេញក្រៅផ្លូវ គឺមានប្រក្រតីត្រាច់ទៅតាមលំដាប់ អធិប្បាយថា មិនលះនូវលំដាប់ផ្ទះ ចូលទៅបិណ្ឌបាតជាប់តគ្នាទៅ ទាំងត្រកូលស្តុកស្តម្ភ និងត្រកូលក្រីក្រ ។

បទថា **កុលេ កុលេ អប្បដិពទ្ធចិត្តោ** បានដល់ មានចិត្តមិនជាប់ចំពាក់ក្នុងត្រកូលណាមួយ មានត្រកូលក្សត្រជាដើម ដោយអំណាចកិលេស អធិប្បាយថា ជាអ្នកថ្មីជានិច្ច ឧបមាដូចព្រះចន្ទ ។ ពាក្យដ៏សេស មានន័យដូចបានពោលហើយនុ៎ះឯង ។

**រសគេធគាថាទី ១ ចប់**

# អាវរណគាថា

*គាថាថា* **បហាយ បញ្ចាវរណានិ** *ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។*

*បានឮថា ព្រះរាជាមួយអង្គក្នុងនគរពារាណសី ជាអ្នកបានបឋមជ្ឈាន កាលទ្រង់រក្សាឈាននោះ ទើបលះរាជសម្បត្តិ ចេញបួស ចម្រើនវិបស្សនា ហើយសម្រេចបច្ចេកពោធិញ្ញាណ កាលសម្ដែងបដិបទាក្នុងការបដិបត្តិរបស់ព្រះអង្គ ទើបត្រាស់ឧទានគាថានេះថា*

**បហាយ បញ្ចាវរណានិ ចេតសោ**
**ឧបក្កិលេសេ ព្យបនុជ្ជ សព្វេ**
**អនិស្សិតោ ឆេជ្ជ សិនេហទោសំ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

*បុគ្គលលះបង់នូវហេតុ ជាគ្រឿងរារាំង ៥ យ៉ាង*
*របស់ចិត្ត បន្ទោបង់នូវឧបក្កិលេសទាំងពួង ទាំងមិន*
*អាស្រ័យ ( ដោយតណ្ហានិងទិដ្ឋិ ) កាត់បង់នូវទោស*
*នៃសេចក្ដីស្រឡាញ់ហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង*
*ដូចកុយរមាស ។*

*បណ្ដាបទទាំងនោះ បទថា* **បញ្ចាវរណានិ** *បានដល់ នីវរណៈ*

៥ នុ៎ះឯង ។ នីវរណៈ ៥ នោះ ដោយអត្ថបានពោលហើយក្នុងឧរគសូត្រ ( ក្នុងខុទ្ទកនិកាយ សុត្តនិបាត ) ព្រោះនីវរណៈទាំងនោះ រារាំងចិត្តដូចពពកជាដើម បិទបាំងព្រះចន្ទនិងព្រះអាទិត្យដូច្នោះ ទើបហៅថា ជាគ្រឿងរារាំងចិត្ត អធិប្បាយថា គប្បីលះ គឺលះផ្តាច់នូវនីវរណៈទាំងនោះ ដោយឧបចារសមាធិឬអប្បនាសមាធិ ។ បទថា **ឧបក្កិលេសេ** បានដល់ អកុសលធម៌ដែលចូលទៅបៀតបៀនចិត្ត ។ ម្យ៉ាងទៀត បានដល់ អភិជ្ឈាជាដើម ដែលពោលក្នុងវត្ថោបមសូត្រ ( វត្ថូបមសូត្រ ) ជាដើម ។

បទថា **ព្យបនុជ្ជ** ប្រែថា បន្ទោបង់ អធិប្បាយថា លះដោយវិបស្សនានិងមគ្គ ។ បទថា **សព្វេ** បានដល់ មិនមានសេសសល់ ។ បុគ្គលដល់ព្រមដោយសមថ និងវិបស្សនាយ៉ាងនេះ ឈ្មោះថា ដែលតណ្ហានិងទិដ្ឋិមិនអាស្រ័យ ព្រោះលះទិដ្ឋិនិស្ស័យបានហើយ ដោយបឋមមគ្គ ។ កាត់នូវទោស គឺសេចក្តីស្រឡាញ់ អធិប្បាយថា លះតណ្ហានិងរាគៈដែលប្រព្រឹត្តទៅក្នុងធាតុទាំង ៣ ដោយមគ្គដ៏សេស ។ ពិតហើយ សេចក្តីស្រឡាញ់នុ៎ះឯង លោកហៅថា សិនេហទោស ព្រោះជាបដិបក្ខចំពោះគុណ ។ ពាក្យដ៏សេស មានន័យដូចបានពោលហើយនោះឯង ។

**អាវរណគាថាទី ២ ចប់**

# វិបិដ្ឋិគាថា

*គាថាថា* **វិបិដ្ឋិកត្វាន** *ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។*

*បានឮថា ព្រះរាជាមួយអង្គក្នុងនគរពារាណសី ជាអ្នកបាន ចតុត្ថជ្ឈាន ព្រះរាជានោះ ដើម្បីរក្សាឈាន ក៏ទ្រង់លះរាជសម្បត្តិ ចេញបួស ចម្រើនវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ កាលសម្ដែងបដិបទា ក្នុងការបដិបត្តិរបស់ព្រះអង្គ ទើបពោលឧទានគាថានេះថា*

**វិបិដ្ឋិកត្វាន សុខញ្ច ទុក្ខំ**

**បុព្វេវ សោមនស្សំ ទោមនស្សំ**[១]

**លទ្ធានុបេក្ខំ សមថំ វិសុទ្ធំ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

*បុគ្គលធ្វើនូវសុខ ទុក្ខ សោមនស្ស និងទោមនស្ស ក្នុងកាលមុន ឲ្យនៅពីក្រោយខ្នង បាននូវឧបេក្ខា ជាសមថៈដ៏ស្អាត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។*

*បណ្ដាបទទាំងនោះ បទថា* **វិបិដ្ឋិកត្វាន** *ប្រែថា ធ្វើទុកខាងក្រោយ អធិប្បាយថា បោលគឺលះ ។ បទថា* **សុខញ្ច ទុក្ខំ** *បានដល់*

---

*១-អដ្ឋកថា អបទាន ច្បាប់ឆដ្ឋសង្គាយនា ជា សោមនស្សទោមនស្សំ ។*

ដោយសុខនិងទុក្ខផ្លូវកាយ ។ បទថា **សោមនស្សទោមនស្សានំ** បានដល់ សេចក្តីសុខនិងសេចក្តីទុក្ខផ្លូវចិត្ត ។ បទថា **ឧបេក្ខំ** បានដល់ ឧបេក្ខា ក្នុងចតុត្ថជ្ឈាន ។ បទថា **សមចំ** បានដល់ សមាធិក្នុងចតុត្ថជ្ឈាននោះ ឯង ។ បទថា **វិសុទ្ធំ** សេចក្តីថា ឈ្មោះថា បរិសុទ្ធិក្រៃលែង ព្រោះ ផុតចាកធម៌ដែលជាសត្រូវ ៩ ប្រការ គឺនីវរណៈ ៥ វិតក្កៈ ១ វិចារៈ ១ បីតិ ១ សុខៈ ១ អធិប្បាយថា ប្រាសចាកឧបក្កិលេស ដូចមាស ដែលខាត់ហើយ ។

ចំណែកពាក្យអធិប្បាយប្រកបសេចក្តី មានដូចតទៅនេះថា លះ សុខនិងទុក្ខក្នុងកាលមុននុ៎ះឯង អធិប្បាយថា ទុក្ខក្នុងឧបចារភូមិនៃ បឋមជ្ឈាន សុខក្នុងឧបចារភូមិនៃតតិយជ្ឈាន ។ អធិការដែលនាំ ច អក្ខរៈ ដែលបានពោលខាងដើមមកទុកខាងក្រោយវិញ សម្រេចរូបជា **សោមនស្សានំ ទោមនស្សញ្ច វិប្បដិកត្វាន បុព្វេវ** ( ធ្វើនូវសោមនស្ស និងទោមនស្សទុកក្នុងខាងដើមនុ៎ះឯង ) ព្រោះហេតុនោះ ទើបលោក សម្តែងថា សោមនស្សក្នុងឧបចារៈនៃចតុត្ថជ្ឈាន និងទោមនស្សក្នុងឧបចារៈ នៃទុតិយជ្ឈាននុ៎ះឯង ។ ពិតហើយ ឈានទាំងនោះ ជាគ្រឿងទ្រសម្រាប់ លះសោមនស្ស និងទោមនស្សដោយអម តែបើពោលដោយត្រង់ បឋមជ្ឈានជាបាទសម្រាប់លះនូវទុក្ខ ទុតិយជ្ឈានជាបាទសម្រាប់លះនូវ ទោមនស្ស តតិយជ្ឈានជាបាទសម្រាប់លះនូវសុខ ចតុត្ថជ្ឈានជាបាទ

*សម្រាប់លះនូវសោមនស្ស ។*

*សមដូចព្រះមានព្រះភាគត្រាស់ថា*

**បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឯត្ថ ចុប្បន្នំ ទុក្ខិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ ។** *រមែងចូលកាន់បឋមជ្ឈាន ( ដែលប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីវិវេក ) ។ ទុក្ខិន្ទ្រិយកើតឡើងក្នុងបឋមជ្ឈាននេះ តែងរលត់ទៅឥតមានសេសសល់* [១] *ដូច្នេះជាដើម ។*

*សេចក្ដីទាំងអស់នោះ ខ្ញុំពោលទុកហើយក្នុងអដ្ឋកថា ធម្មសង្គហៈឈ្មោះអដ្ឋសាលិនី ។*

*លះបង់ទុក្ខ ទុកអំពីខាងក្រោយក្នុងបឋមជ្ឈាន លះបង់នូវទោមនស្សក្នុងទុតិយជ្ឈាន និងលះបង់នូវសុខក្នុងតតិយជ្ឈាន ដែលហៅថា ក្នុងកាលមុន យ៉ាងណា ក្នុងទីនេះ ក៏យ៉ាងនោះ លះបង់នូវសោមនស្សទុកអំពីខាងក្រោយ ក្នុងចតុត្ថជ្ឈាន បាននូវឧបេក្ខានិងសមថៈដែលបរិសុទ្ធ ដោយបដិបទានេះហើយ គប្បីត្រាច់ទៅតែម្នាក់ឯងនុ៎ះឯង ។ ពាក្យដ៏សេស មានន័យដូចពោលហើយនុ៎ះឯង ។*

## វិបិដ្ឋិគាថាទី ៣ ចប់

---

*១-បិ.៣៨ ទំ.១៨១ ឃ.២៨០ ។*

# អារទ្ធវីរិយគាថា

គាថាថា **អារទ្ធវីរិយោ** ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។

បានឮថា ព្រះរាជាបច្ចន្តប្បទេសមួយអង្គ មានទាហានជាពលនិកាយ ១ ពាន់នាក់ ជាអ្នកមានរាជសម្បត្តិតិចតួច តែជាអ្នកមានបញ្ញាច្រើន ។ ថ្ងៃមួយ ទ្រង់ព្រះតម្រិះថា អាត្មាអញជាស្ដេចក្រីក្រ ក៏ពិតមែន តែអាត្មាអញមានបញ្ញា អាចដណ្ដើមយកជម្ពូទ្វីបទាំងមូលបាន ដូច្នេះហើយ ទ្រង់ក៏បញ្ជូនទូតទៅព្រះបាទសាមន្តរាជថា ក្នុងខាងក្នុង ៧ ថ្ងៃ ចូរឲ្យរាជសម្បត្តិដល់យើង ឬក៏ច្បាំង ។ បន្ទាប់អំពីនោះ ទ្រង់ប្រជុំពួកអាមាត្យរបស់ព្រះអង្គ ហើយត្រាស់ថា យើងមិនបានប្រឹក្សាជាមួយពួកអ្នក បានធ្វើការដោយឆាប់រួសរាន់ បានបញ្ជូនទូតយ៉ាងនេះ ដល់ព្រះរាជាឈ្មោះនោះ នឹងគប្បីធ្វើដូចម្ដេច ។

អាមាត្យទាំងនោះ ក្រាបទូលថា បពិត្រមហារាជ ទ្រង់អាចហៅទូតនោះឲ្យត្រឡប់បានឬ ។ ព្រះរាជាត្រាស់ថា មិនអាចទេ ទូតនោះបានទៅហើយ ។

អាមាត្យទាំងឡាយពោលថា បើយ៉ាងនោះ ពួកទូលបង្គំត្រូវព្រះអង្គធ្វើឲ្យវិនាសហើយ បើដូច្នោះ ការស្លាប់ដោយដៃរបស់អ្នកដទៃ ជាទុក្ខ ពួកទូលព្រះបង្គំនឹងសម្លាប់គ្នានឹងគ្នាឲ្យស្លាប់ នឹងសម្លាប់ខ្លួនឲ្យស្លាប់ ឬ

ចងកឲ្យស្លាប់ បរិភោគថ្នាំពិសឲ្យស្លាប់ ។ បណ្ដាអាមាត្យទាំងនោះ អាមាត្យនីមួយ ៗ បានពណ៌នាដល់សេចក្ដីស្លាប់យ៉ាងនេះប៉ុណ្ណោះ ។

បន្ទាប់អំពីនោះ ព្រះរាជាត្រាស់ថា ប្រយោជន៍អ្វីដោយអាមាត្យទាំងនេះ យើងមានទាហាន ដូច្នេះ ។ លំដាប់នោះ ទាហានទាំងមួយពាន់នាក់នោះ ក្រោកឡើង ក្រាបទូលថា បពិត្រមហារាជ ទូលព្រះបង្គំជាទាហាន បពិត្រមហារាជ ទូលព្រះបង្គំជាទាហាន ។

ព្រះរាជាទ្រង់ព្រះតម្រិះថា អញនឹងសាកល្បងទាហានទាំងនេះដូច្នេះហើយ ទ្រង់ឲ្យត្រៀមជើងថ្ករជំទុក ត្រាស់ថា នៃអ្នកទាំងឡាយ យើងបានធ្វើការរួសរាន់ឈ្មោះនេះ ពួកអាមាត្យជំទាស់ការធ្វើរបស់យើង យើងនឹងលោតចូលជើងថ្ករ អ្នកណាស្ម័គ្រចិត្តលោតទៅជាមួយយើង អ្នកណាព្រមលះបង់ជីវិតដើម្បីយើង ។ កាលព្រះរាជាត្រាស់យ៉ាងនេះហើយ ទាហាន ៥០០ នាក់ នាំគ្នាក្រោកឡើងពោលថា បពិត្រមហារាជ ទូលព្រះបង្គំទាំងឡាយ នឹងលោតចូលទៅ ។

លំដាប់នោះ ព្រះរាជាត្រាស់នឹងទាហាន ៥០០ នាក់ទៀតថា នៃបាទាំងឡាយ ឥឡូវនេះ ពួកអ្នកនឹងធ្វើដូចម្ដេច ។

ទាហាន ៥០០ នោះ ក្រាបទូលថា បពិត្រមហារាជ នេះមិនមែនជាការធ្វើរបស់កូនប្រុសទេ នេះជាការប្រព្រឹត្តរបស់មនុស្សស្រី សេចក្ដីពិត មហារាជទ្រង់បញ្ជូនទូតដល់អរិរាជ ( ស្ដេចជាសត្រូវ ) ហើយ ពួក

ទូលព្រះបង្គំនឹងច្បាំងជាមួយព្រះរាជានោះ ដរាបដល់ជីវិតចុងក្រោយ ។

បន្ទាប់អំពីនោះ ព្រះរាជាត្រាស់ថា ពួកអ្នករមែងលះបង់ជីវិតដើម្បីយើង ដូច្នេះហើយ ទ្រង់ត្រៀមចតុរង្គសេនា ចោមរោមដោយទាហាន ១ ពាន់ យាងទៅប្រថាប់គង់ត្រង់ជាយដែនរដ្ឋសីមា ។ ឯព្រះបាទបដិរាជនោះ ទ្រង់ស្តាប់ព្រឹត្តិការណ៍នោះហើយ ទ្រង់ព្រះតម្រិះថា អើហ្ន៎ ស្តេចខុទ្ទករាជនេះ មិនល្មមធ្វើជាទាសៈរបស់អញ ដូច្នេះហើយ ទ្រង់លើកកងទ័ពទាំងអស់ចេញច្បាំង ។

ព្រះបាទខុទ្ទករាជទ្រង់ឃើញព្រះបាទបដិរាជនោះ លើកកងទ័ពមកប្រឈមមុខ ទើបត្រាស់នឹងពលនិកាយថា នែប្រស្តែងទាំងឡាយ ពួកអ្នកមានគ្នាមិនច្រើនទេ អ្នកទាំងអស់ចូលរួមគ្នា កាន់ដាវនិងខែលរត់តម្រង់ទៅខាងមុខព្រះរាជានោះ ដោយរហ័ស ។ ទាហានទាំងនោះបានធ្វើតាមព្រះរាជតម្រាស់ ។ លំដាប់នោះ កងទ័ពរបស់ព្រះរាជានោះបានបែកចេញជាពីរចំណែក បើកឱកាសដល់ពួកទាហានទាំងនោះ ចាប់ព្រះរាជានោះបានទាំងរស់ ពួកទាហានដទៃ ក៏បាក់បែកខ្ចាត់ខ្ចាយទៅ ។ ព្រះបាទខុទ្ទករាជទ្រង់ស្ទុះទៅខាងមុខ ដោយព្រះតម្រិះថា នឹងសម្លាប់ព្រះរាជានោះ ព្រះបាទបដិរាជទ្រង់ទូលសូមអភ័យអំពីព្រះបាទខុទ្ទករាជនោះ ។ បន្ទាប់អំពីនោះ ព្រះបាទខុទ្ទករាជទ្រង់ប្រទានអភ័យដល់ព្រះបាទបដិរាជនោះ ទ្រង់ឲ្យព្រះបាទបដិរាជនោះ ធ្វើនូវការស្បថ ធ្វើឲ្យជា

គ្នារបស់ព្រះអង្គ ហើយទ្រង់ផ្តើមចាប់ព្រះរាជាអង្គដទៃទាំងរស់ទៀត ។ ព្រះបាទខុទ្ទករាជ ទ្រង់យាងទៅមួយអន្លើដោយព្រះបាទបដិរាជនោះ ប្រថាប់ឈរត្រង់ជាយដែនរដ្ឋសីមារបស់ព្រះបាទបដិរាជនោះ បញ្ជូនដំណឹងទៅថា ចូរឲ្យរាជសម្បត្តិដល់យើង ឬក៏ច្បាំង ព្រះរាជានោះទ្រង់ព្រះតម្រិះថា យើងមិនហ៊ានច្បាំង ទើបប្រគល់រាជសម្បត្តិ ។ ដោយឧបាយនោះឯង ព្រះរាជាទាំងឡាយនោះ ក៏ទ្រង់ចាញ់ ព្រះរាជាទាំងឡាយនោះ ទ្រង់មិនច្បាំង ប្រគល់រាជសម្បត្តិថ្វាយព្រះបាទខុទ្ទករាជក្នុងទីបំផុត ព្រះបាទខុទ្ទករាជនោះ ទ្រង់នាំព្រះរាជាទាំងអស់ទៅចាប់ព្រះបាទពារាណសី ។

ព្រះបាទខុទ្ទករាជនោះ ទ្រង់មានព្រះរាជា ១០១ ចោមរោម ទ្រង់គ្រប់គ្រងរាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ។ ក្នុងកាលតមក ទ្រង់ព្រះតម្រិះថា ក្នុងកាលមុន អញជាអ្នកក្រីក្រ បានជាធំក្នុងជម្ពូទ្វីបទាំងមូលដោយញាណសម្បត្តិរបស់ខ្លួន ។ ញាណសម្បត្តិរបស់អញប្រកបដោយលោកិយវីរិយៈ ញាណនេះ រមែងមិនប្រព្រឹត្តទៅដើម្បីនិព្វិទា រមែងមិនប្រព្រឹត្តទៅដើម្បីប្រាសចាករាគៈឡើយ បើដូច្នោះ អាត្មាអញគប្បីស្វែងរកលោកុត្តរធម៌ដោយញាណនេះ ។ បន្ទាប់អំពីនោះ ទើបទ្រង់ព្រះរាជទានរាជសម្បត្តិដល់ព្រះបាទពារាណសី ទ្រង់បញ្ជូនព្រះរាជបុត្តនិងព្រះមហេសីឲ្យត្រឡប់ទៅកាន់ជនបទរបស់ខ្លួនរៀបរយហើយ ទ្រង់លះបង់

ទាំងអស់ ហើយចេញបួស ប្រារព្ធវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេក-ពោធិញ្ញាណ កាលទ្រង់សម្តែងវីរិយសម្បត្តិរបស់ព្រះអង្គ ទើបត្រាស់ឧទានគាថានេះថា

**អារទ្ធវីរិយោ បរមត្ថបត្តិយា**
**អលីនចិត្តោ អកុសីតវុត្តិ**
**ទឡ្ហនិក្កមោ ថាមពលូបបន្នោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលប្រារព្ធព្យាយាមដើម្បីដល់នូវព្រះនិព្វាន មាន
ចិត្តមិនរួញរា មានការប្រព្រឹត្តមិនខ្ជិលច្រអូស មាន
សេចក្តីប្រឹងប្រែងដ៏មាំមួន ប្រកបដោយកម្លាំងកាយ
និងកម្លាំងបញ្ញាហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូច
កុយរមាស ។

ក្នុងឧទានគាថានោះ គប្បីជ្រាបពាក្យអធិប្បាយដូចតទៅនេះថា ឈ្មោះថា ជាអ្នកប្រារព្ធសេចក្តីព្យាយាម ព្រោះមានសេចក្តីព្យាយាមប្រារព្ធហើយ ។ ដោយបទនេះ លោកសម្តែងថា លោកជាបុគ្គលមានសេចក្តីព្យាយាមធំក្រៃលែង ។ ព្រះនិព្វានលោកហៅថា **បរមត្ថ** ការសម្រេចនិព្វាននោះ ឈ្មោះថា **បរមត្ថបត្តិ** ។ ដើម្បីសម្រេចនិព្វានដែលឈ្មោះថា **បរមត្ថ** នោះ ។ ដោយបទនេះ លោកសម្តែងដល់

ផលដែលគប្បីសម្រេច ដោយការប្រារព្ធសេចក្តីព្យាយាមនោះ ។

បទថា **អលីនចិត្តោ** នេះ លោកសម្តែងនូវការមិនរួញរារបស់ចិត្តនិងចេតសិក ដែលមានសេចក្តីព្យាយាមជាគ្រឿងឧបត្ថម្ភ ។

ដោយបទថា **អកុសីតវុត្តិ** នេះ លោកសម្តែងដល់ការមិនលិចចុះនៃកាយក្នុងការឈរនិងការចង្រ្កមជាដើម ។ សម្តែងសេចក្តីព្យាយាមដែលតាំងមាំប្រព្រឹត្តទៅហើយយ៉ាងនេះថា សូមឲ្យស្បែក សរសៃ និងឆ្អឹងសល់នៅចុះ[១] ដោយពាក្យថា **ទឡ្ហនិក្កមោ** នេះ ។

បុគ្គលដែលផ្តើមតាំងទុកក្នុងអនុបុព្វសិក្ខាជាដើម លោកហៅថា **កាយេន ចេវ បរមត្ថសច្ចំ សច្ឆិករោតិ** ធ្វើឲ្យជាក់ច្បាស់នូវបរមត្ថសច្ចៈដោយកាយ ។

ម្យ៉ាងទៀត ដោយបទថា **ទឡ្ហនិក្កមោ** នេះ លោកសម្តែងដល់សេចក្តីព្យាយាម ដែលសម្បយុត្តដោយមគ្គ ។ សេចក្តីព្យាយាមនោះឈ្មោះថា **ទឡ្ហ** ព្រោះដល់នូវភាពបរិបូណ៌នៃភាវនា ឈ្មោះថា **និក្កម** ព្រោះចេញចាកសត្រូវដោយប្រការទាំងពួង ព្រោះហេតុនោះ បុគ្គលដែលដល់ព្រមដោយសេចក្តីព្យាយាមនោះ លោកហៅថា **ទឡ្ហនិក្កមោ** ព្រោះមានសេចក្តីព្យាយាមជាគ្រឿងឈមចុះដ៏មាំ ។

---

១-បិ.២៣ ទំ.៤០៥ ឃ.២៣៩; បិ.៤០ ទំ.១១០ ឃ.២៥១; បិ.៦៤ ទំ.១២៣ ឃ.៨១ ។

*បទថា* **ថាមពលូបបន្នោ** *បានដល់ បុគ្គលដែលប្រកបដោយកម្លាំងកាយ និងកម្លាំងញាណ ក្នុងមគ្គខណៈ ។ ម្យ៉ាងទៀត បានដល់បុគ្គលប្រកបដោយពលៈដែលជាកម្លាំង អធិប្បាយថា ជាអ្នកប្រកបដោយកម្លាំងញាណដ៏មាំទាំ ។ ដោយបទថា* **ថាមពលូបបន្នោ** *នេះ លោកសម្តែងដល់ការប្រកបព្រមដោយវិបស្សនាញាណ នៃសេចក្តីព្យាយាមនោះ ទើបធ្វើបជាន គឺសេចក្តីព្យាយាមជាគ្រឿងប្រកប ឲ្យសម្រេច ។ ម្យ៉ាងទៀត គប្បីប្រកបបាទទាំង ៣ ដោយអំណាចសេចក្តីព្យាយាមដែលជាខាងដើម កណ្តាល និងឧក្រិដ្ឋ ។ ពាក្យដ៏សេស មានន័យដូចបានពោលហើយនុ៎ះឯង ។*

**អារទ្ធវីរិយគាថាទី ៤ ចប់**

# បដិសល្លានគាថា

គាថាថា **បដិសល្លានំ** ដូច្នេះជាដើម មានហេតុកើតដូចម្តេច ។ បានឮថា ព្រះរាជាមួយអង្គក្នុងនគរពារាណសី ជាអ្នកបាន បឋមជ្ឈាន កាលទ្រង់រក្សាឈាននោះ ទើបលះរាជសម្បត្តិ ចេញបួស ទ្រង់ចម្រើនវិបស្សនា សម្រេចបច្ចេកពោធិញ្ញាណហើយ កាលទ្រង់ សម្តែងបដិបទាក្នុងការបដិបត្តិ ទើបត្រាស់ឧទានគាថានេះថា

**បដិសល្លានំ ឈានមរិញ្ចមានោ**
**ធម្មេសុ និច្ចំ អនុធម្មចារី**
**អាទីនវំ សម្មសិតា ភវេសុ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គល កាលមិនលះបង់នូវឈានដ៏ស្ងប់ស្ងាត់ ( ចាក សត្វនិងសង្ខារ ) ជាអ្នកប្រព្រឹត្តនូវធម៌ ដ៏សមគួរក្នុង ធម៌ទាំងឡាយ អស់កាលជានិច្ច ពិចារណានូវទោស ក្នុងភពទាំងឡាយហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូច កុយរមាស ។

ការពណ៌នាអត្ថនៃគាថានេះ មានដូចតទៅនេះថា ការគេចចេញ ចាកសត្វនិងសង្ខារនោះៗ ហើយពួនសម្ងំ អធិប្បាយថា ការសេពនូវការ

មានខ្លួនតែមួយ ភាពជាបុគ្គលតែឯងដោយកាយវិវេក ។ ចិត្តវិវេក លោកហៅថា ឈាន ព្រោះដុតកិលេសដូចសត្រូវ និងព្រោះចូលទៅសម្ងឹងដោយអារម្មណូបនិជ្ឈាននិងលក្ខណូបនិជ្ឈាន ។

ក្នុងពាក្យថា **ឈាន** នោះ សមាបត្តិ ៨ ហៅថា **ឈាន** ព្រោះដុតកិលេសដូចសត្រូវ មាននីវរណៈជាដើម និងព្រោះចូលទៅសម្ងឹងអារម្មណ៍មានកសិណជាដើម ។ វិបស្សនា មគ្គ ផល ក៏ហៅថា ឈាន ព្រោះដុតកិលេសដូចជាសត្រូវ មានសត្តសញ្ញា ការសម្គាល់ថា សត្វជាដើម និងព្រោះចូលទៅសម្ងឹងលក្ខណៈ ។ តែក្នុងទីនេះ លោកបំណងយកអារម្មណូបនិជ្ឈានប៉ុណ្ណោះ ។ មិនលះ គឺមិនបោះបង់ បានដល់ មិនលះបង់ការពួនសម្ងំនិងឈាននោះ ដោយប្រការយ៉ាងនោះ ។ បទថា **ធម្មេសុ** បានដល់ ក្នុងធម៌ គឺបញ្ចក្ខន្ធជាដើម ដែលឲ្យចូលដល់វិបស្សនា ។ បទថា **និច្ចំ** បានដល់ ជាប់ត គឺទៅរឿយ ៗ បានដល់ប្រឡូកប្រឡំ ។

បទថា **អនុធម្មចារី** បានដល់ ប្រព្រឹត្តវិបស្សនាធម៌ដែលទៅហើយរឿយ ៗ ដោយប្រារព្ធធម៌នោះ ៗ ប្រព្រឹត្តទៅ ។ម្យ៉ាងទៀត ក្នុងបទថា **ធម្មេសុ** នេះ លោកុត្តរធម៌ ៩ ឈ្មោះថា ធម៌ ។ ឈ្មោះថា អនុធម៌ ព្រោះជាធម៌ដែលអនុលោមដល់ធម៌ទាំងនោះ ។ ពាក្យថា អនុធម្មចារីនេះ ជាឈ្មោះរបស់វិបស្សនា ។ ក្នុងគាថានោះ កាលគួរ

*នឹងពោលថា* **ធម្មានំ និច្ចំ អនុធម្មចារី** *តែបែរជាពោលថា* **ធម្មេសុ** ( **និច្ចំ អនុធម្មចារី** ) *ដើម្បីងាយស្រួលក្នុងការចងគាថា ព្រោះលោកជាអ្នកឈ្លាសក្នុងវិភត្តិ ។*

*ក្នុងបទថា* **អាទីនវំ សម្មសិតា ភវេសុ** *នេះ គប្បីជ្រាបវាចាប្រកបសេចក្តីដូច្នេះថា ពិចារណាឃើញទោស មានការមិនទៀងជាដើមក្នុងភពទាំង ៣ ដោយវិបស្សនា ពោលគឺភាពជាអ្នកមានប្រក្រតីប្រព្រឹត្តនូវធម៌ដ៏សមគួរដល់ធម៌នោះ គប្បីពោលថា ជាអ្នកសម្រេចដោយបដិបទាគឺវិបស្សនាដែលដល់កំពូលនៃកាយវិវេក និងចិត្តវិវេកនេះ ដោយអាការយ៉ាងនេះ គប្បីជាបុគ្គលម្នាក់ឯង ត្រាច់ទៅ ។*

បដិសល្លានគាថាទី ៥ ចប់

# តណ្ហាក្ខយគាថា

គាថាថា **តណ្ហក្ខយំ** ដូច្នេះជាដើម មានហេតុកើតដូចម្តេច ។

បានឮថា ព្រះបាទពារាណសីមួយអង្គ ទ្រង់ធ្វើប្រទក្សិណព្រះនគរ ដោយរាជានុភាពដ៏ធំ សត្វទាំងឡាយមានហទយៈវិលទៅហើយ ព្រោះលម្អនៃព្រះកាយរបស់ព្រះរាជា សូម្បីកាលទៅខាងមុខក្តី ទៅខាងក្រោយក្តី ដោយខាងទាំងពីរក្តី ក៏ត្រឡប់មកសម្លឹងមើលព្រះរាជាអង្គនោះឯង ។ មែនពិត តាមប្រក្រតី សត្វលោកមិនឆ្អែតក្នុងការមើលព្រះពុទ្ធ ក្នុងការមើលព្រះចន្ទពេញបូណ៌មី សមុទ្ទ និងព្រះរាជា ។ ក្នុងខណៈនោះ ភរិយារបស់កុដុម្ពិកៈម្នាក់ ឡើងប្រាសាទជាន់លើ បើកបង្អួចឈរសម្លឹងមើល ។ ព្រះរាជាទ្រង់ឃើញស្រីនោះ ក៏មានចិត្តប្រតិព័ទ្ធ ទើបត្រាស់បញ្ជាអាមាត្យថា នែប្រស្តែង អ្នកចូរដឹងថា ស្ត្រីនេះមានស្វាមីហើយ ឬមិនទាន់មាន ។ អាមាត្យនោះទៅហើយ ត្រឡប់មកក្រាបទូលថា មានស្វាមីហើយ ។ លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា ស្រីស្នំ ២ ម៉ឺននាក់នេះ ដូចទេពអប្សរ អភិរម្យអាត្មាអញតែម្នាក់ ឥឡូវនេះ អញមិនត្រេកអរដោយស្រីទាំងនោះ កើតតណ្ហាក្នុងស្ត្រីរបស់បុរសដទៃ តណ្ហានោះ កើតឡើង នឹងប្រានអញទៅកាន់អបាយប៉ុណ្ណោះ ដូច្នេះហើយ ទ្រង់ឃើញទោសក្នុងតណ្ហា ទ្រង់ព្រះតម្រិះថា ណ្ហើយចុះ អញនឹងសង្កត់សង្កិន

តណ្ហានោះ ទ្រង់លះរាជសម្បត្តិ ចេញបួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ ទើបត្រាស់ឧទានគាថានេះថា

**តណ្ហក្ខយំ បត្ថយមប្បមត្តោ**
**អនេឡមូគោ សុតវា សតីមា**
**សង្ខាតធម្មោ និយតោ បធានវា**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលកាលប្រាថ្នា នូវការអស់តណ្ហា ជាអ្នកមិនប្រហែស មិនល្ងង់ មានការចេះដឹង មានស្មារតី មានធម៌ពិចារណាហើយ ជាបុគ្គលទៀង មានសេចក្ដីខ្មីឃ្មាត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

បណ្ដាបទទាំងនោះ បទថា **តណ្ហក្ខយំ** បានដល់ ព្រះនិព្វាន ។ ម្យ៉ាងទៀត បានដល់ ព្រះនិព្វានជាទីមិនប្រព្រឹត្តទៅនៃតណ្ហា ដែលមានទោស ដែលគេឃើញ (ប្រាកដ) យ៉ាងនេះ ។ បទថា **អប្បមត្តោ** បានដល់ មានប្រក្រតីធ្វើ (កុសល) ជាប់តរហូត គឺមានប្រក្រតីធ្វើដោយគោរព ។ បទថា **អនេឡមូគោ** បានដល់ ជាអ្នកមិនមានទឹកមាត់ហូរចេញអំពីមាត់ (មិនឆ្កួតជ្រូក) ។ ម្យ៉ាងទៀត បានដល់ មិនជាមនុស្សឆ្កួតនិងមនុស្សគ អធិប្បាយថា ជាបណ្ឌិត ជាអ្នកឈ្លាសវៃ ។ ឈ្មោះថា **សុតវា** ព្រោះមានសុតៈដែលញុំាងហិតសុខ គឺប្រយោជន៍

និងសេចក្តីសុខឲ្យដល់ព្រម អធិប្បាយថា ជាអ្នកសម្បូរដោយបរិយត្តិ ។ បទថា **សតីមា** បានដល់ ជាអ្នករឮកបាននូវវត្ថុដែលខ្លួនធ្វើទុកយូរជាដើមបាន ។ បទថា **សង្ខាតធម្មោ** បានដល់ ជាអ្នកមានធម៌កំណត់ដឹងដោយការចូលទៅពិចារណាធម៌ ។ បទថា **និយតោ** បានដល់ ជាអ្នកដល់នូវភាពជាអ្នកទៀងដោយអរិយមគ្គ ។ បទថា **បធានវា** បានដល់ ជាអ្នកដល់ព្រមដោយការព្យាយាម ជាគ្រឿងតាំងទុកដោយប្រពៃ ។ បុគ្គលប្រកបដោយធម៌ មានការមិនប្រមាទជាដើមនោះ ដោយប្រការយ៉ាងនេះ ជាអ្នកមានសេចក្តីខ្មីឃ្មាត ដោយសេចក្តីព្យាយាមដែលឲ្យដល់នូវភាពទៀង ជាបុគ្គលទៀង ដោយការទៀង ដែលដល់ព្រមដោយសេចក្តីព្យាយាមនោះ បន្ទាប់អំពីនោះ ឈ្មោះថា ជាអ្នកមានធម៌ពិចារណាហើយ ព្រោះបានសម្រេចអរហត្ត ។ ពិតហើយ ព្រះអរហន្តទាំងឡាយ លោកហៅថា ជាអ្នកមានធម៌ដែលពិចារណាស្រេចហើយ ព្រោះមិនមានធម៌ដែលត្រូវពិចារណាទៀត ។ ដូចលោកពោលទុកថា **យេ ច សង្ខាតធម្មាសេ យេ ច សេក្ខា បុថូ ឥធ** ពួកអសេក្ខបុគ្គលអ្នកមានធម៌ពិចារណាហើយ និងពួកសេក្ខបុគ្គលជាច្រើនណា ក្នុងសាសនានេះ[១] ដូច្នេះ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនុ៎ះឯង ។

## តណ្ហក្ខយគាថាទី ៦ ចប់

---

១-បិ.៥៤ ទំ.៣៣៦ ឃ.១១២ ; បិ.៦៧ ទំ.៣៥ ឃ.៨៦ ។

# សីហាទិគាថា

*គាថាថា* **សីហោរ** *ដូច្នេះជាដើម មានហេតុកើតដូចម្តេច ។*

*បានឮថា ព្រះបាទពារាណសីមួយអង្គ មានឧទ្យាននៅក្នុងទីឆ្ងាយ ទ្រង់តើនឡើងអំពីព្រលឹម យាងទៅកាន់ឧទ្យាន ក្នុងរវាងផ្លូវ ទ្រង់ចុះអំពីយានចូលទៅកាន់ទីដែលមានទឹក ដោយបំណងថា នឹងលុបព្រះភក្ត្រ ។ ក្នុងទីនោះ មានសីហៈញីកើតកូន ហើយចេញទៅរកចំណី ។ រាជបុរសឃើញកូនសីហៈនោះហើយ ទើបក្រាបទូលថា* **សីហាចោតកោ ទេវ** *បពិត្រព្រះសម្មតិទេព ( នេះ ) កូនសីហៈ ។*

*ព្រះរាជាទ្រង់ព្រះតម្រិះថា បានឮថា សីហៈមិនខ្លាចនរណា ។ ដើម្បីសាកល្បងកូនសីហៈនោះ ទើបឲ្យវាយស្គរជាដើម កូនសីហៈនោះសូម្បីបានឮសំឡេងនោះ ក៏នៅតែដេកបែបនោះ កាលបើដូច្នោះ ទើបព្រះរាជាទ្រង់ឲ្យវាយស្គរជាលើកទី ២ និងលើកទី ៣ ។ ក្នុងលើកទី ៣ កូនសីហៈនោះ អើតក្បាលឡើងមើលបរិស័ទទាំងអស់ ហើយក៏ដេកយ៉ាងនោះឯង ។*

*លំដាប់នោះ ព្រះរាជាត្រាស់ថា ពួកយើងចូរគេចទៅមុន ទាន់មេរបស់វាមិនទាន់មក ។ ខណៈយាងទៅ ទ្រង់ព្រះតម្រិះថា កូនសីហៈសូម្បីកើតក្នុងថ្ងៃនោះ ក៏មិនតក់ស្លុត មិនខ្លាច កាលណាហ្ន៎ អាត្មាអញ*

គប្បីលះបង់នូវការញាប់ញ័រដោយតណ្ហានិងទិដ្ឋិ ហើយមិនតក់ស្លុត មិនខ្លាច ។ ព្រះរាជាកាន់យករឿងនោះ ឲ្យជាអារម្មណ៍ យាងទៅ ទ្រង់ឃើញអ្នកប្រមង់ចាប់ត្រី ហើយហាលសំណាញ់ត្រង់មែកឈើ ខ្យល់បក់មក មិនជាប់ត្រង់សំណាញ់ដែលសន្ទឹងទុក ទ្រង់បានកាន់យកនិមិត្តក្នុងរឿងនោះទៀតថា កាលណាហ្ន៎ អាត្មាអញគប្បីទម្លាយសំណាញ់ គឺតណ្ហា ទិដ្ឋិ និងមោហៈ មិនជាប់ចំពាក់យ៉ាងនោះ ហើយទៅ ។

លំដាប់នោះ ព្រះរាជាទ្រង់យាងទៅកាន់ឧទ្យាន គង់ប្រថាប់ត្រង់ប្រាំងស្រះបោក្ខរណីដែលដេរដាសដោយផ្កាំងថ្ម ទ្រង់ទតឃើញផ្កាឈូកដែលត្រូវខ្យល់បក់ប៉ះពាល់ខ្លាំង ក៏ឱនទៅក្នុងទឹក ហើយផុសមកវិញ ក្នុងកាលដែលប្រាសចាកខ្យល់ មិនសើមដោយទឹក ទ្រង់បានកាន់យកនិមិត្តក្នុងសេចក្តីនោះថា កាលណាហ្ន៎ អាត្មាអញកើតមកហើយក្នុងលោកមិនប្រឡាក់ដោយលោក គប្បីឋិតនៅដូចផ្កាឈូកទាំងនេះ កើតក្នុងទឹកតែតាំងនៅដោយទឹកប្រឡាក់មិនបាន ។ ទ្រង់ព្រះតម្រិះរឿយ ៗ ថាអាត្មាអញគប្បីជាអ្នកមិនតក់ស្លុត មិនជាប់មិនចំពាក់ មិនប្រឡាក់ ដូចសីហៈ ខ្យល់ និងផ្កាឈូក ទើបទ្រង់លះរាជសម្បត្តិ ចេញបួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ បានពោលឧទានគាថានេះថា

សីហោវ សទ្ទេសុ អសន្តសន្តោ

សីហោវ សទ្ទេសុ អសន្តសន្តោ
វាតោវ ជាលម្ហិ អសជ្ជមានោ
បទុមំវ តោយេន អលិម្បមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

*បុគ្គល កាលមិនតក់ស្លុតក្នុងលក្ខណៈ មានមិនទៀង ជាដើម ដូចសីហៈ មិនតក់ស្លុតក្នុងសំឡេងទាំងឡាយ មិនជាប់ចំពាក់ក្នុងធម៌ទាំងឡាយ មានខន្ធជាដើម ដូចខ្យល់មិនជាប់នឹងសំណាញ់ មិនប្រឡាក់ដោយលោកៈ ជាដើម ដូចស្លឹកឈូកមិនប្រឡាក់ដោយទឹក គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។*

*ពាក្យថា សីហៈ ក្នុងគាថានោះ សីហៈមាន ៤ ពួក គឺតិណសីហៈ ១ បណ្ឌុសីហៈ ១ កាឡសីហៈ ១ និងកេសរសីហៈ ១ ។ បណ្ដាសីហៈទាំងនោះ កេសរសីហៈ លោកពោលថា ប្រសើរ ។ កេសរសីហៈនោះ លោកបំណងយកក្នុងទីនេះ ។ ខ្យល់មានច្រើនយ៉ាង មានខ្យល់ទិសខាងកើតជាដើម ។ ផ្កាឈូកមានច្រើនយ៉ាង មានផ្កាឈូកពណ៌ក្រហម និងផ្កាឈូកពណ៌សជាដើម ។ បណ្ដាខ្យល់និងផ្កាឈូកទាំងនោះ ខ្យល់ប្រភេទណាមួយ និងផ្កាឈូកប្រភេទណាមួយ ក៏គួរ មែនពិត ។ បណ្ដាការតក់ស្លុតជាដើមនោះ ឈ្មោះថា ការតក់ស្លុត មាន ព្រោះការស្រឡាញ់ខ្លួន ក៏ការស្រឡាញ់ខ្លួននោះ ឈ្មោះថា ការប្រឡាក់ដោយតណ្ហា ការ*

ប្រឡាក់ដោយតណ្ហានោះ មាន ព្រោះសេចក្ដីលោភដែលប្រកបដោយទិដ្ឋិខ្វះ ប្រាសចាកទិដ្ឋិខ្វះ ការស្រឡាញ់ខ្លួននោះ គឺតណ្ហាហ្នឹងឯង ។

ម្យ៉ាងទៀត ក្នុងគាថានេះ ការជាប់ចំពាក់ រមែងមានដល់បុគ្គលដែលខ្វះការពិចារណាជាដើម ក្នុងអារម្មណ៍នោះ ព្រោះមោហៈ មោហៈគឺអវិជ្ជា ។ ក្នុងតណ្ហានិងអវិជ្ជានោះ លះតណ្ហាដោយសមថៈ លះអវិជ្ជាដោយវិបស្សនា ។ ព្រោះហេតុនោះ គប្បីលះសេចក្ដីស្រឡាញ់ខ្លួនដោយសមថៈ ហើយមិនតក់ស្លុតក្នុងលក្ខណៈទាំងឡាយ មានអនិច្ចលក្ខណៈទុក្ខលក្ខណៈជាដើម ដូចសីហៈមិនតក់ស្លុតក្នុងសំឡេងទាំងឡាយ លះមោហៈដោយវិបស្សនា មិនជាប់ចំពាក់ក្នុងខន្ធនិងអាយតនៈជាដើម ដូចខ្យល់មិនជាប់នឹងសំណាញ់ លះលោភៈនិងទិដ្ឋិប្រកបដោយលោភៈដោយសមថៈដូចគ្នា មិនប្រឡាក់ដោយលោភៈក្នុងភព និងភោគៈទាំងពួងដូចផ្កាឈូកមិនប្រឡាក់ដោយទឹកដូច្នោះ ។

បណ្ដាធម៌ទាំងនោះ សីលជាបទដ្ឋាននៃសមថៈ សមថៈ ឈ្មោះថា សមាធិ ។ កាលបើធម៌ ២ ប្រការនោះ គឺវិបស្សនានិងសមាធិសម្រេចហើយ ខន្ធគឺគុណទាំង ៣ ក៏ឈ្មោះថា សម្រេចដែរ ។ បណ្ដាខន្ធគឺគុណទាំងនោះ បុគ្គលរមែងជាអ្នកក្សៀវក្លាដោយសីលក្ខន្ធ ។ បុគ្គលនោះ រមែងមិនតក់ស្លុត ដូចសីហៈមិនតក់ស្លុតក្នុងសំឡេងទាំងឡាយ ព្រោះសីហៈនោះ ចូលចិត្តក្រោធក្នុងសំឡេងដែលជាអាឃាតវត្ថុ ។ បុគ្គលមាន

*សភាវៈចាក់ធ្លុះហើយដោយបញ្ញាខន្ធ រមែងមិនជាប់ចំពាក់ក្នុងប្រភេទនៃធម៌ មានខន្ធជាដើម ដូចខ្យល់មិនជាប់ក្នុងសំណាញ់ ។ ជាបុគ្គលមានរាគៈទៅប្រាសហើយដោយសមាធិក្ខន្ធ រមែងមិនប្រឡាក់ដោយរាគៈ ដូចស្លឹកឈូកមិនប្រឡាក់ដោយទឹកដូច្នោះ ។*

*កាលបើដូច្នោះ បណ្ឌិតគប្បីជ្រាបបុគ្គលដែលមិនតក់ស្លុត មិនជាប់ និងមិនប្រឡាក់ ដោយអំណាចការលះតណ្ហា អវិជ្ជា និងអកុសលមូល ៣ ដែលកើតមានតាមសមគួរ ដោយសមថៈនិងវិបស្សនាផង ដោយសីលក្ខន្ធ សមាធិក្ខន្ធ និងបញ្ញាខន្ធផង ។ ពាក្យដ៏សេស មានន័យដូចពោលហើយនុ៎ះឯង ។*

## សីហាទិគាថាទី ៧ ចប់

# ទារុពលិគាថា

គាថាថា **សីហោ យថា** ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។

បានឮថា ព្រះបាទពារាណសីមួយអង្គ ដើម្បីញុំាងជនបទជាយដែនដែលបះបោរឲ្យស្ងប់ ទើបទ្រង់វៀរចាកការធ្វើដំណើរតាមលំដាប់នៃស្រុក យាងតាមផ្លូវកាត់ក្នុងព្រៃដែលជាផ្លូវត្រង់ យាងទៅដោយកងទ័ពធំ ។ ក្នុងសម័យនោះ ត្រង់ជើងភ្នំមួយកន្លែង មានរាជសីហ៍ដេកយកកម្ដៅព្រះអាទិត្យដែលស្រទន់ ។ រាជបុរសទាំងឡាយឃើញរាជសីហ៍នោះ ក៏ក្រាបទូលព្រះរាជា ។ ព្រះរាជាទ្រង់ព្រះតម្រិះថា បានឮថារាជសីហ៍មិនតក់ស្លុត ទើបឲ្យធ្វើសំឡេង មានសំឡេងស្គរធំ និងស្គរតូចជាដើម ។ ឯរាជសីហ៍ក៏នៅតែដេកដដែល ទ្រង់ឲ្យធ្វើសំឡេងជាលើកទី ២ រាជសីហ៍ក៏នៅតែដេកដដែល ទ្រង់ឲ្យធ្វើសំឡេងជាលើកទី ៣ ។ កាលនោះ រាជសីហ៍គិតថា បុគ្គលជាសត្រូវរបស់អញ គង់មាន ទើបឈរយ៉ាងមាំដោយជើងទាំង ៤ ហើយបន្លឺសីហនាទ ។ ហ្មដំរីជាដើម បានស្ដាប់សំឡេងសីហនាទនោះ ក៏ចុះអំពីកដំរីជាដើម គេចចូលទៅពួនត្រង់គុម្ពស្មៅ ពួកសេះនិងពួកដំរី រត់ខ្ចាត់ខ្ចាយទៅក្នុងទិសផ្សេង ៗ ដំរីរបស់ព្រះរាជាក៏នាំព្រះរាជារែកព្រៃស្បាតរត់ទៅ ។ ព្រះរាជាមិនអាចគង់លើដំរីបាន ទ្រង់តោងមែកឈើ ហើយទម្លាក់ខ្លួនមកលើផែនដី យាងទៅតាម

ផ្លូវដែលដើរបានតែម្នាក់ ដល់លំនៅរបស់ **ព្រះបច្ចេកពុទ្ធ** ទាំងឡាយ ទ្រង់ត្រាស់សួរព្រះបច្ចេកពុទ្ធទាំងឡាយក្នុងទីនោះថា បពិត្រលោកម្ចាស់ដ៏ចម្រើនទាំងឡាយ លោកម្ចាស់ទាំងឡាយ បានឮសំឡេងខ្លះដែរឬ ។ ព្រះបច្ចេកពុទ្ធទាំងនោះតបថា ថ្វាយព្រះពរមហារាជ បានឮ ។

ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ តើសំឡេងអ្វី ។ ព្រះបច្ចេកពុទ្ធតបថា ដំបូងជាសំឡេងស្គរ សំឡេងស័ង្ខជាដើម ក្រោយមកជាសំឡេងរាជសីហ៍ ។

ព្រះរាជាត្រាស់សួរថា លោកម្ចាស់ទាំងឡាយ មិនខ្លាចទេឬ ។ ព្រះបច្ចេកពុទ្ធទាំងឡាយពោលថា មហាបពិត្រ អាត្មាទាំងឡាយមិនខ្លាចចំពោះសំឡេងណាមួយឡើយ ។

ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់អាចធ្វើខ្ញុំឲ្យជាបុគ្គលបែបនោះ បានដែរឬទេ ។ ព្រះបច្ចេកពុទ្ធទាំងឡាយពោលថា អាច មហារាជ បើទ្រង់បួស ។

ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំនឹងបួស ។ លំដាប់នោះព្រះបច្ចេកពុទ្ធទាំងឡាយឲ្យព្រះរាជាបួស ហើយឲ្យសិក្សាអភិសមាចារិក-វត្ត ដោយន័យដូចពោលហើយខាងដើមនុ៎ះឯង ។ ព្រះរាជាទ្រង់ចម្រើនវិបស្សនា ដោយន័យដូចពោលហើយក្នុងកាលមុននុ៎ះឯង ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ បានត្រាស់ឧទានគាថានេះថា

សីហោ យថា ឱាឋពលី បសយ្ហ
រាជា មិគានំ អភិភុយ្យចារី
សេវេថ បន្តានិ សេនាសនានិ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

*សីហៈជាស្តេចសត្វ មានចង្កូមជាកម្លាំង ប្រព្រឹត្តគ្រប សង្កត់ កំហែងនូវពួកម្រឹគ យ៉ាងណា បុគ្គលគប់រកនូវ សេនាសនៈដ៏ស្ងាត់ (មានព្រៃជាគ្រឿងអាង) ក៏យ៉ាង នោះដែរ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។*

*ក្នុងគាថានោះ ឈ្មោះថា សីហៈ ព្រោះអត់ធន់ ព្រោះសម្លាប់ និង ព្រោះស្ទុះទៅដោយរហ័ស ។ ក្នុងអដ្ឋកថា សីហសូត្រ[១] លោកពោល ទុកថា សីហៈមាន ៤ ប្រភេទ គឺតិណសីហៈ ១ កាឡសីហៈ ១ បណ្ឌុ-សីហៈ ១ កេសរសីហៈ ១ ។ ក្នុងសីហៈទាំងនោះ តិណសីហៈស៊ីស្មៅ ដូចមេគោដែលមានពណ៌ដូចសត្វព្រាប ។ កាឡសីហៈក៏ស៊ីស្មៅដូចមេ គោសម្បុរខ្មៅ ។ បណ្ឌុសីហៈស៊ីសាច់ មានសម្បុរដូចមេគោមានសម្បុរ ដូចស្លឹកឈើទុំ ។ កេសរសីហៈប្រកបដោយមុខ ចុងកន្ទុយ និងចុងជើង ទាំង ៤ ដូចគេយកទឹកល័ក្តមកតាក់តែង តាំងអំពីក្បាលរបស់កេសរសីហៈ នោះចុះទៅ មានស្នាម ៣ ឆ្នូត ដូចគេគូរទុកដោយល័ក្ត ឬជាតិហិង្គុ*

---

*១-ស្រង់ចាកអដ្ឋកថា សីហសូត្រ បិ.៣៣ ទំ.១៩៧ ឃ.១៥៥ ។*

រហូតដល់ខាងក្នុងភ្លៅ ជាវង្វង់ទក្ខិណាវដ្ដ ។ ចំណែកត្រង់ដងករបស់សីហៈនោះ មានរោមជាកម្រង គឺកេសរជាវង្វង់ ដូចគេចងទុកដោយសំពត់កម្ពលក្រហមមានតម្លៃរាប់សែន ។ ឯអវយវៈដ៏សេសក្នុងរាងកាយមានពណ៌សសុទ្ធ ដូចដុំម្សៅស្រូវសាលីសុទ្ធ ឬដូចដុំលម្អិតនៃស័ង្ខ ។ បានឮថា កេសរសីហៈអាស្រ័យនៅក្នុងគុហាមាស គុហាប្រាក់ គុហាកែវមណី គុហាកែវផលិកនិងគុហាមនោសិលា ( គុហាណាមួយ ) ។ កេសរសីហៈនេះ កាលនឹងចេញអំពីគុហា រមែងចេញដោយហេតុ ៤ យ៉ាង គឺត្រូវងងឹតបៀតបៀន ចេញទៅដើម្បីត្រូវការពន្លឺ ១ ឈឺបន្ទោបង់ឧច្ចារបស្សាវៈ ចេញទៅដើម្បីបន្ទោបង់ឧច្ចារបស្សាវៈ ១ ត្រូវសេចក្ដីឃ្លានបៀតបៀន ចេញទៅដើម្បីចាប់ចំណី ១ ត្រូវការបន្តពូជបៀតបៀនចេញទៅដើម្បីមេថុន ១ ។

កេសរសីហៈ កាលបន្លឺសីហនាទ លាតជើងក្រោយទាំង ២ ឲ្យស្មើគ្នាលើផ្ទៃគុហាមាស ឬលើផ្ទៃគុហាប្រាក់ គុហាកែវមណី គុហាកែវផលិកឬគុហាមនោសិលា គុហាណាមួយ សណ្ដូកជើងមុខត្រង់ទៅមុខ បន្ទាបដងខ្លួនចំណែកខាងក្រោយ អើតចំណែកខាងមុខ ចំកោងខ្នង អើតកឡើងរលាស់នូវធូលីដែលជាប់ត្រង់ខ្លួន សំឡេងរលាស់ហាក់បីដូចសំឡេងរន្ទះ ។ កេសរសីហៈនោះ រត់ត្រឡប់ទៅត្រឡប់មកលើទីមិតពត់នោះឯង ដូចកូនគោជំទង់ដូច្នោះ កាលកំពុងរត់ទៅរត់មក រាងកាយប្រាកដ ក្នុងទីងងឹត ដូច

អង្កត់ភ្លើងដែលគេគ្រវែងឲ្យវិល ដូច្នោះ ។ មុនបន្ទឺសីហនាទ កេសរសីហៈរមែងសម្លឹងមើលឆ្វេងស្តាំ ។

សួរថា ព្រោះហេតុអ្វី ទើបកេសរសីហៈសម្លឹងមើល ។

ឆ្លើយថា ព្រោះអាណិតសត្វដទៃ ។ បានឮថា កាលកេសរសីហៈបញ្ចេញសំឡេង សត្វទាំងឡាយ មានដំរី ខ្ទីង ក្របីជាដើម ដើររកស៊ីក្បែរជ្រោះ ឬអណ្តូង ក៏នឹងផ្អើលធ្លាក់ទៅក្នុងជ្រោះខ្លះ ក្នុងអណ្តូងខ្លះ ទើបក្រឡេកមើលឆ្វេងស្តាំ ព្រោះការអាណិតអាសូរសត្វទាំងនោះ ។

សួរថា កេសរសីហៈជាសត្វធ្វើកិច្ចដូចព្រានព្រៃ ស៊ីសាច់របស់សត្វដទៃជានិច្ច នៅមានការអាណិតអាសូរដែរឬ ។

ឆ្លើយថា មាន ពិតហើយ កេសរសីហៈមិនចាប់សត្វតូច ៗ ដើម្បីជាអាហាររបស់ខ្លួន ដោយគិតថា ប្រយោជន៍អ្វីរបស់អញដោយសត្វជាច្រើនដែលត្រូវសម្លាប់ដូច្នេះ ។ កេសរសីហៈធ្វើការអាណិតអាសូរដោយអាការយ៉ាងនេះ ។ សេចក្តីនោះ សមដូចព្រះមានព្រះភាគត្រាស់ទុកថា

អាត្មាអញកុំធ្វើពួកសត្វតូច ៗ ដែលដើរទៅរកស៊ីក្នុងទីក្រហេង-ក្រហូងឲ្យស្លាប់[១] ។

ដំបូងកេសរសីហៈបន្ទឺសំឡេងរបស់អ្នកអង់អាច (សីហនាទ) មិនភ័យខ្លាច ៣ ដង ។ ក៏កាលកេសរសីហៈឈរលើទីសម្រាប់មិតពត់ បន្ទឺ

---

១-បិ.៥០ ទំ.៧៣ ឃ.២១ ។

សំឡេងកងរំពងជាសំឡេងតែមួយ ជុំទិស អស់ទីប្រមាណ ៣ យោជន៍ ពួកសត្វជើង ២ និងជើង ៤ ដែលនៅខាងក្នុងទី ៣ យោជន៍ បានឮសំឡេងកងរំពងរបស់កេសរសីហៈហើយ ក៏មិនអាចឈរក្នុងទីដើមបាន ។ កេសរសីហៈ កាលទៅចាប់ចំណី រមែងឈរលើទីសម្រាប់មិតពត់ កាលលោតទៅខាងស្តាំ ខាងឆ្វេង ខាងក្រោយ ក៏លោតទៅបានក្នុងទីប្រមាណ ១ ឧសភៈ កាលនឹងលោតទៅលើ ក៏លោតបាន ៤ ឧសភៈខ្លះ ៨ ឧសភៈខ្លះ កាលលោតត្រង់ទៅមុខក្នុងទីរាបស្មើ ក៏លោតទៅបានរហូតចម្ងាយប្រមាណ ១៦ ឧសភៈខ្លះ ប្រមាណ ២០ ឧសភៈខ្លះ កាលលោតអំពីច្រាំងស្ទឹង ឬលោតអំពីភ្នំ ក៏លោតបានទីប្រមាណ ៦០ ឧសភៈខ្លះ ៨០ ឧសភៈខ្លះ ឃើញដើមឈើ ឬភ្នំក្នុងចន្លោះផ្លូវ កាលគេចដើមឈើ ឬភ្នំនោះ ក៏គេចទៅខាងឆ្វេង ខាងស្តាំ ឬខាងលើ បានប្រមាណ ១ ឧសភៈ[១] ។ តែលុះបន្លឺសំឡេងលើកទី ៣ ក៏ប្រាកដខ្លួនក្នុងទី ៣ យោជន៍ ជាមួយនឹងសំឡេងនោះឯង ។ កាលទៅបាន ៣ យោជន៍ហើយ ក៏ត្រឡប់មកឈរស្តាប់សំឡេងរំពងដែលខ្លួនបន្លឺនោះឯង ។ កេសរសីហៈ រមែងស្ទុះទៅដោយកម្លាំងជើងដ៏រហ័សយ៉ាងនេះ ។ ពិតហើយ សត្វនិងមនុស្សចំនួនច្រើន បានឮសំឡេងរបស់កេសរសីហៈនោះហើយ រមែងភ័យខ្លាច សត្វ

១-មួយឧសភៈ ស្មើនឹង ១៤០ ហត្ថ ( វចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ) ។

ដែលមិនភ័យខ្លាច មានចំនួនតិច ។

សួរថា សត្វមានចំនួនតិចនោះ តើសត្វពួកណា ។

ឆ្លើយថា សត្វទាំងនោះ គឺពួករាជសីហ៍ដែលមានជាតិស្មើគ្នា ១ ដំរីអាជានេយ្យ ១ សេះអាជានេយ្យ ១ គោឧសភអាជានេយ្យ ១ បុរសអាជានេយ្យ ១ ព្រះខីណាស្រព ១ ។

សួរថា ព្រោះហេតុអ្វី ទើបសត្វនិងមនុស្សទាំងនោះ មិនខ្លាច ។

ឆ្លើយថា សីហៈដែលមានជាតិស្មើគ្នា រមែងមិនខ្លាច ព្រោះគិតថា អញស្មើគ្នាដោយជាតិ គោត្ត ត្រកូល និងសេចក្ដីអង់អាច ។ ដំរីអាជានេយ្យជាដើម មិនខ្លាច ព្រោះថា ខ្លួនមានសក្កាយទិដ្ឋិខ្លាំងក្លា ព្រះខីណាស្រពមិនខ្លាច ព្រោះលះសក្កាយទិដ្ឋិបានហើយ ។

សត្វដែលដេកនៅក្នុងរន្ធ ក្នុងរូង មានពស់ ស្កា និងទន្សោងជាដើម សត្វក្នុងទឹក មានត្រី និងអណ្ដើកជាដើម សត្វក្នុងព្រៃ មានដំរី សេះ ខ្ទីង ម្រឹគជាដើម ។ សត្វទាំងឡាយនោះ សម្លឹងមើលផ្លូវដោយគិតថា ឥឡូវនេះ អ្នកណានឹងមកចាប់អញ ទើបចូលទៅ (ក្នុងរន្ធ ក្នុងទឹក ក្នុងព្រៃ) ។ កេសរសីហៈមានឫទ្ធិច្រើន ព្រោះអាចឈរក្នុងទីសម្រាប់មិតពត់ លោតទៅខាងស្ដាំជាដើម បានប្រមាណ ១ ឧសភៈ លោតត្រង់ទៅមុខ បានប្រមាណ ២០ ឧសភៈជាដើម ។ គប្បីជ្រាបភាពដែលកេសរសីហៈមានសក្តិធំ ព្រោះជាម្ចាស់ ជាធំជាងម្រឹគដ៏សេស ។ គប្បីជ្រាបភាពដែល

កេសរសីហៈមានអានុភាពច្រើន ដោយអំណាចនៃសត្វទាំងឡាយបាន
ឮសំឡេងក្នុងទី ៣ យោជន៍ដោយជុំវិញហើយ នាំគ្នាគេចទៅដូច្នេះ ។

ក្នុងទីនេះ បំណងយកកេសរសីហៈនោះឯង ។ ឈ្មោះថា ទាឋពលី ព្រោះសីហៈនោះ មានចង្កូមជាកម្លាំង ។ បទ ២ គឺ **បសយ្ហ អភិភុយ្យ** គប្បីប្រកបជាមួយសព្ទថា **ចារី** ជា **បសយ្ហចារី អភិភុយ្យចារី** ។ ក្នុង ២ បទនោះ ឈ្មោះថា **បសយ្ហចារី** ព្រោះប្រព្រឹត្តសង្កត់សង្កិន គឺញាំញី ។ ឈ្មោះថា **អភិភុយ្យចារី** ព្រោះប្រព្រឹត្តគ្របសង្កត់ គឺធ្វើឲ្យតក់ស្លុត បានដល់ ធ្វើឲ្យនៅក្នុងអំណាច ។ រាជសីហ៍នោះ មានប្រក្រតីប្រព្រឹត្តសង្កត់សង្កិនដោយកម្លាំងកាយ និងមានប្រក្រតីប្រព្រឹត្តគ្របសង្កត់ដោយតេជះ ។ ក្នុងសេចក្ដីនោះ បើបុគ្គលណាមួយសួរថា រាជសីហ៍មានប្រក្រតីប្រព្រឹត្តសង្កត់សង្កិនគ្របសង្កត់អ្វី ។ ព្រោះហេតុនោះ ឆដ្ឋីវិភត្តិដែលថា **មិគានំ** ទើបគួរប្រើក្នុងទុតិយាវិភត្តិ ហើយឆ្លើយថា មានប្រក្រតីប្រព្រឹត្តសង្កត់សង្កិន គ្របសង្កត់នូវម្រឹគទាំងឡាយ ។ បទថា **បន្តានិ** បានដល់ នៅឆ្ងាយ ។ បទថា **សេនាសនានិ** បានដល់ ទីជាលំនៅ ។ ពាក្យដ៏សេស អាចដឹងបានដោយន័យដូចពោលហើយនោះឯង ព្រោះហេតុនោះ ទើបមិនចាំបាច់ឲ្យពិស្ដារ ។

ទាឋពលីគាថាទី ៨ ចប់

# អប្បមញ្ញាគាថា

*គាថាថា* **មេត្តំ ឧបេក្ខំ** *ដូច្នេះជាដើម មានហេតុកើតដូចម្តេច ។*

*បានឮថា ព្រះរាជាមួយអង្គទ្រង់បានមេត្តាឈានជាដើម ទ្រង់ព្រះតម្រិះថា រាជសម្បត្តិជាអន្តរាយចំពោះសុខក្នុងឈាន ។ ដើម្បីរក្សាឈានទើបទ្រង់លះរាជសម្បត្តិ ចេញបួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ហើយបានពោលឧទានគាថានេះថា*

**មេត្តំ ឧបេក្ខំ ករុណំ វិមុត្តឹ**
**អាសេវមានោ មុទិតញ្ច កាលេ**
**សព្វេន លោកេន អវិរុជ្ឈមានោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

*បុគ្គលកាលចម្រើននូវមេត្តា ឧបេក្ខា ករុណា និង*
*មុទិតា ជាហេតុរួចចាកកិលេសក្នុងកាលដ៏គួរ មិន*
*ខឹងសម្បានឹងលោកទាំងពួង គប្បីប្រព្រឹត្តតែម្នាក់*
*ឯង ដូចកុយរមាស ។*

*ក្នុងគាថានោះ ភាពជាអ្នកប្រាថ្នាដើម្បីនាំចូលមកនូវហិតសុខដោយន័យថា* **សព្វេ សត្តា សុខិតា ហោន្តុ** *សូមសត្វទាំងឡាយមានសេចក្តីសុខចុះ ដូច្នេះជាដើម ឈ្មោះថា មេត្តា ។ ភាពជាអ្នកប្រាថ្នា*

ដើម្បីនាំចេញទៅនូវអហិតទុក្ខ ដោយន័យថា **អហោ វត ឥមម្ហា ទុក្ខា មុច្ចេយ្យុំ** ឱហ្ន៎ ! សូមសត្វទាំងឡាយ គប្បីផុតចាកទុក្ខនេះ ដូច្នេះជាដើម ឈ្មោះថា ករុណា ។ ភាពជាអ្នកប្រាថ្នាដើម្បីមិនឲ្យសត្វទាំងឡាយព្រាត់ប្រាសចាកហិតសុខ ដោយន័យថា **មោទន្តិ វត ភោន្តោ សត្តា មោទន្តិ សាធុ សុដ្ឋុ** សត្វទាំងឡាយត្រេកអរពិតហ្ន៎ រីករាយពិតហ្ន៎ ល្អប្រពៃហ្ន៎ ដូច្នេះជាដើម ឈ្មោះថា មុទិតា ។ ភាពជាអ្នកព្រងើយក្នុងសុខ និងទុក្ខទាំងឡាយថា **បញ្ញាយិស្សន្តិ សកេន កម្មេន** សត្វទាំងឡាយនឹងប្រាកដដោយកម្មរបស់ខ្លួនដូច្នេះ ឈ្មោះថា ឧបេក្ខា ។ តែលោកពោលមេត្តាហើយពោលឧបេក្ខា ហើយពោលមុទិតាក្នុងកាលជាខាងក្រោយ ដោយប្តូរលំដាប់ទាំងនេះ ដើម្បីងាយស្រួលក្នុងការចងគាថា ។

បទថា **វិមុត្តឹ** បានដល់ ធម៌ ៤ នេះ ឈ្មោះថា វិមុត្តិ ព្រោះជាធម៌ផុតហើយចាកធម៌ដែលជាសត្រូវទាំងឡាយរបស់ខ្លួន ។ ព្រោះហេតុនោះ ទើប **ព្រះបច្ចេកពុទ្ធ** ពោលថា

**មេត្តំ ឧបេក្ខំ ករុណំ វិមុត្តឹ**

**អាសេវមានោ មុទិតញ្ច កាលេ**

បុគ្គលកាលចម្រើននូវមេត្តា ឧបេក្ខា ករុណា និង

មុទិតា ជាហេតុរួចចាកកិលេស ក្នុងកាលដ៏គួរ ។

ក្នុងគាថានោះ បទថា **អាសេវមានោ** បានដល់ អប់រំនូវធម៌ទាំងឡាយ ៣ ដោយអំណាចនៃឈានពួក ៣ និងឈានពួក ៤ អប់រំនូវឧបេក្ខាដោយអំណាចនៃចតុត្ថជ្ឈាន ។ បទថា **កាលេ** បានដល់ បុគ្គលចម្រើនមេត្តាហើយ ចេញចាកមេត្តានោះ ហើយសេពករុណា ចេញចាកករុណានោះ ហើយសេពមុទិតា ចេញចាកមុទិតានោះ ឬចាកឈាននោះ ដែលមិនមានបីតិក្រៅអំពីនេះ ហើយសេពឧបេក្ខា ហៅថា **កាលេ អាសេវមានោ** សេពក្នុងកាលសមគួរ ឬហៅថា សេពក្នុងកាលដែលជាផាសុកដើម្បីនឹងសេព ។ បទថា **សព្វេន លោកេន អវិរុជ្ឈមានោ** បានដល់ មិនប្រទូស្តនឹងសត្វលោកទាំងពួងក្នុងទិសទាំង ១០ ។ ពិតហើយ ព្រោះភាពដែលធម៌ទាំងឡាយ មានមេត្តាជាដើម ដែលខ្លួនចម្រើនហើយ សត្វទាំងឡាយក៏ជាអ្នកមិនគួរស្អប់ខ្ពើម ឯបដិឃៈ ដែលនាំឲ្យក្រោធក្នុងសត្វទាំងឡាយ រមែងស្ងប់រម្ងាប់ ។ ព្រោះហេតុនោះ ទើបព្រះបច្ចេកពុទ្ធពោលថា **សព្វេន លោកេន អវិរុជ្ឈមានោ** ។ សេចក្តីសង្ខេបក្នុងគាថានេះ មានប្រមាណប៉ុណ្ណេះ ចំណែកមេត្តាទិកថា ខ្ញុំបានពោលទុកហើយក្នុងអដ្ឋកថា ធម្មសង្គហៈ ឈ្មោះអដ្ឋសាលិនី ។ បទដ៏សេសដូចគ្នានឹងន័យមុននោះឯង ។

## អប្បមញ្ញាគាថាទី ៩ ចប់

# ជីវិតសង្ខយគាថា

គាថាថា ភគ្គា ភោសគ្គា ដូច្នេះជាដើម មានហេតុកើតដូចម្តេច ។

បានឮថា **ព្រះបច្ចេកពុទ្ធ** ព្រះនាមមាតង្គៈ អាស្រ័យនគររាជគ្រឹះ ជាព្រះបច្ចេកពុទ្ធអង្គចុងក្រោយ ក្នុងចំនួនព្រះបច្ចេកពុទ្ធទាំងឡាយ ។ គ្រានោះ ព្រះពោធិសត្វនៃយើងទាំងឡាយកើតឡើងហើយ ទេវតាទាំងឡាយមកដើម្បីបូជាព្រះពោធិសត្វ ឃើញព្រះមាតង្គបច្ចេកពុទ្ធ ក៏ពោលថា **មារិសា មារិសា ពុទ្ធោ លោកេ ឧប្បន្នោ** លោកនិរទុក្ខ លោកនិរទុក្ខ ព្រះពុទ្ធកើតឡើងហើយក្នុងលោក ។ ព្រះមាតង្គបច្ចេកពុទ្ធនោះ ទើបតែចេញអំពីនិរោធ បានឮពាក្យនោះផង ដឹងថា ខ្លួនអស់ជីវិតផង ក៏ហោះទៅកាន់ភ្នំឈ្មោះមហាបបាតៈ ក្នុងហិមវន្តប្បទេស ដែលជាទីបរិនិព្វានរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ បោះធាតុរបស់ព្រះបច្ចេកពុទ្ធដែលបរិនិព្វានហើយចូលទៅក្នុងជ្រោះ លោកខ្លួនឯង ក៏អង្គុយលើផ្ទាំងសិលា បានពោលឧទានគាថានេះថា

**ភគ្គា ភោសគ្គា បហាយ មោហំ**
**សន្ទាលយិត្វាន សំយោជនានិ**
**អសន្តសំ ជីវិតសង្ខយម្ហិ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

*បុគ្គលលះបង់នូវរាគៈផង ទោសៈផង មោហៈផង ហើយទម្លាយចេញនូវសំយោជនៈ មិនតក់ស្លុតក្នុងការអស់ទៅនៃជីវិតហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។*

*រាគៈទោសៈមោហៈ ក្នុងគាថានេះ បានពោលហើយក្នុងឧរគសូត្រ ( ក្នុងខុទ្ទកនិកាយ សុត្តនិបាត ) ។ បទថា* **សំយោជនានិ** *បានដល់សំយោជនៈ ១០ ។ ទម្លាយសំយោជនៈទាំង ១០ នោះ ដោយមគ្គនោះៗ ។ បទថា* **អសន្តសំ ជីវិតសង្ខយម្ហិ** *សេចក្ដីថា ការបែកធ្លាយជុំវិញនៃចុតិចិត្ត ហៅថា ការអស់ទៅនៃជីវិត ។ ឈ្មោះថា ជាអ្នកមិនតក់ស្លុតក្នុងការអស់ជីវិតនោះ ព្រោះលះសេចក្ដីស្រឡាញ់ក្នុងជីវិតបានហើយ ។ ព្រះបច្ចេកពុទ្ធសម្ដែងឧបាទិសេសនិព្វានរបស់លោកដោយពាក្យមានប្រមាណប៉ុណ្ណោះឯង ក្នុងវេលាចប់គាថា បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។*

**ជីវិតសង្ខយគាថាទី ១០ ចប់**

# ការណត្ថគាថា

គាថាថា **កជង្គិ** ដូច្នេះជាដើម មានហេតុកើតដូចម្ដេច ។

បានឮថា ព្រះរាជាមួយអង្គក្នុងនគរពារាណសី គ្រប់គ្រងរាជអាណាចក្កដ៏ធំទូលាយ មានប្រការដូចពោលហើយខាងដើមនុ៎ះឯងអាពាធជាទម្ងន់កើតឡើងដល់ទ្រង់ ទុក្ខវេទនាទាំងឡាយកំពុងប្រព្រឹត្តទៅ ។ ស្ត្រី ២ ម៉ឺននាក់ចោមរោមព្រះអង្គ ធ្វើនូវការច្របាច់ព្រះហស្តនិងព្រះបាទជាដើម ។

ពួកអាមាត្យគិតគ្នាថា ព្រះរាជានឹងសោយទិវង្គតក្នុងកាលឥឡូវនេះ ណ្ហើយចុះ ពួកយើងនឹងស្វែងរកទីពឹងឲ្យខ្លួនឯង ទើបគេចទៅកាន់សម្នាក់របស់ព្រះរាជាមួយអង្គ ទូលសូមបម្រើ ។ អាមាត្យទាំងនោះទទួលបម្រើក្នុងទីនោះ មិនបានរបស់ណាមួយឡើយ ។ ព្រះរាជាទ្រង់ជាអំពីប្រឈួនហើយ ត្រាស់សួរថា **ឥត្ថន្នាមោ ច ឥត្ថន្នាមោ ច កុហឹ** អាមាត្យឈ្មោះនេះៗ ទៅណា បន្ទាប់អំពីនោះ ទ្រង់បានស្ដាប់រឿងនោះ ទ្រង់គ្រវីព្រះសីសៈ ហើយនៅស្ងៀម ។

ចំណែកអាមាត្យទាំងនោះ បានស្ដាប់ដំណឹងថា ព្រះរាជាទ្រង់ជាអំពីប្រឈួនហើយ មិនបានអ្វីក្នុងទីនោះ ត្រូវសេចក្ដីវិនាសធំបៀតបៀនទើបត្រឡប់មកវិញ ថ្វាយបង្គំព្រះរាជាហើយ ឈរក្នុងទីបំផុតនាចំណែក

ម្ចាស់ ត្រូវព្រះរាជាត្រាស់សួរថា នែបាទាំងឡាយ ពួកអ្នកទៅណា ទើបនាំគ្នាក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំទាំងឡាយឃើញទ្រង់ទុព្វល ទើបនាំគ្នាទៅកាន់ជនបទឈ្មោះនោះ ព្រោះភ័យដែលកើតអំពីការចិញ្ចឹមជីវិត ។

ព្រះរាជាទ្រង់គ្រវីសីសៈ ហើយទ្រង់ព្រះតម្រិះថា បើដូច្នោះ អញនឹងសម្តែងអាការអាពាធនោះទៀត ពួកអាមាត្យនឹងធ្វើយ៉ាងនោះទៀត ឬមិនធ្វើហ្ន៎ ។ ព្រះរាជា កាលទ្រង់ធ្វើពុតជាឈឺ ទើបទ្រង់សម្តែងវេទនាដ៏ខ្លាំងក្លា ដូចរោគពាល់ត្រូវហើយក្នុងកាលមុនដូច្នោះ ។ ពួកស្រ្តីនាំគ្នាចោមរោម បានធ្វើកិច្ចដូចកាលមុននុ៎ះឯង ។

ឯពួកអាមាត្យក៏នាំមនុស្សច្រើនជាងមុន ចៀសចេញទៅយ៉ាងនោះឯងទៀត ព្រះរាជាទ្រង់ធ្វើកម្មគ្រប់យ៉ាង ដូចកាលមុន រហូតដល់លើកទី ៣ ដោយអាការយ៉ាងនេះ ឯអាមាត្យទាំងនោះ ក៏នាំគ្នាចៀសចេញទៅយ៉ាងនោះឯង ។ បន្ទាប់អំពីនោះ ព្រះរាជាទ្រង់ឃើញអាមាត្យទាំងនោះត្រឡប់មកក្នុងវារៈទី ៤ ទ្រង់ព្រះតម្រិះថា ឱហ្ន៎ ! ពួកអាមាត្យលះបង់អញដែលជាអ្នកមានជំងឺ មិនអាឡោះអាល័យ ចៀសចេញទៅ ជនទាំងនេះ ធ្វើកម្មដែលធ្វើបានដោយក្រ ទើបទ្រង់នឿយណាយ លះរាជសម្បត្តិចេញបួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយត្រាស់ឧទានគាថានេះថា

**ភជន្តិ សេវន្តិ ការណត្ថា**

**និក្ការណា ទុល្លភា អជ្ជ មិត្តា**

**អត្តត្ថបញ្ញា[១] អសុចី មនុស្សា**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

*ពួកជនមានប្រយោជន៍ជាហេតុ ទើបគប់រកផង បម្រើផង ឯពួកមិត្តដែលឥតហេតុ គេរកបានដោយក្រ ក្នុងថ្ងៃនេះ ឯពួកមនុស្សអ្នកមានបញ្ញា ប្រាថ្នាប្រយោជន៍ផ្ទាល់ខ្លួន ឈ្មោះថា ជាមនុស្សមិនស្អាត បុគ្គលគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។*

ក្នុងគាថានោះ បទថា **ភជន្តិ** បានដល់ លួចចូលទៅអង្គុយជិតដោយរាងកាយ ។ បទថា **សេវន្តិ** បានដល់ រមែងបម្រើដោយអញ្ជលិកម្មជាដើម និងដោយភាពជាអ្នកទទួលបម្រើ ។ ហេតុ ជាប្រយោជន៍របស់មនុស្សទាំងនោះ ព្រោះហេតុនោះ ទើបមនុស្សទាំងនោះ ឈ្មោះថាមានប្រយោជន៍ជាហេតុ អធិប្បាយថា ហេតុដទៃក្នុងការគប់រក និងការសេព មិនមាន ។ ហេតុរបស់មនុស្សទាំងនោះយ៉ាងនេះ មានអធិប្បាយថា រមែងសេពព្រោះហេតុនៃខ្លួន ។

---

១-អដ្ឋកថា ច្បាប់ឆដ្ឋសង្គាយនា ជា អត្តដ្ឋបញ្ញា ។ ក្នុងទីនេះ ថ ក្តី ឋ ក្តី ប្រែថា តាំងនៅ មិនមែនអត្ថទេ ។

*បទថា* **និក្ការណា ទុល្លភា អជ្ជ មិត្តា** *បានដល់ មិនមានហេតុ ដោយហេតុនៃការបាននូវអត្តភាពយ៉ាងនេះថា ពួកយើងនឹងបាននូវអ្វីអំពីលោកនេះ ។ មិត្តដែលប្រកបដោយភាពជាមិត្តដ៏ប្រសើរ ដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ទុក ( ក្នុងសិង្គាលកសូត្រ ) យ៉ាងនេះថា*

**ឧបការោ ច យោ មិត្តោ សុខទុក្ខោ ច យោ សខា**
**អត្ថក្ខាយី ច យោ មិត្តោ យោ ច មិត្តានុកម្បកោ ។**

*មិត្តដែលមានឧបការៈ សម្លាញ់ដែលរួមសុខទុក្ខ មិត្តដែលប្រាប់ប្រយោជន៍ និងមិត្តដែលមានសេចក្ដីឈឺឆ្អាល[១] ។*

*គឺជាមិត្តដែលគេរកបានដោយក្រ ក្នុងថ្ងៃនេះ ។*

*បទថា* **អត្តដ្ឋបញ្ញា** *សេចក្ដីថា ជនទាំងនេះ មានបញ្ញាស្ថិតនៅក្នុងខ្លួន អធិប្បាយថា ឃើញតែខ្លួនឯង មិនឃើញនូវអ្នកដទៃ ។ ព្រះបាលីថា* **អត្តត្ថបញ្ញា** *ដូច្នេះក៏មាន បាលីនោះ មានសេចក្ដីថា ឃើញតែប្រយោជន៍របស់ខ្លួនប៉ុណ្ណោះ មិនឃើញប្រយោជន៍របស់អ្នកដទៃ ។ បានឮថា បាឋៈថា* **ទិដ្ឋត្ថបញ្ញា** *នេះ ជាបាឋៈមានមកក្នុងកាលមុន មានសេចក្ដីអធិប្បាយថា ជនទាំងនោះ មានបញ្ញាក្នុងប្រយោជន៍ដែលខ្លួនគប្បីឃើញក្នុងបច្ចុប្បន្នប៉ុណ្ណោះ មិនមានបញ្ញាសម្លឹងឃើញក្នុងកាលជាអនាគតទេ ។*

---

*១-បិ.១៩ ទំ.៨៣ ឃ.៦៨ ។*

*បទថា* **អសុចី** *បានដល់ ដែលប្រកបដោយកាយកម្ម វចីកម្ម និងមនោកម្មដែលមិនស្អាត គឺមិនប្រសើរ ។*

*បទថា* **ខគ្គវិសាណកប្បោ** *សេចក្ដីថា ឈ្មោះថា ខគ្គវិសាណៈ ព្រោះរមាសយកកុយរបស់ខ្លួន ត្រាច់ធ្វើក្នុំជាដើម ឲ្យជាលម្អិតតូចធំ ដូចបុគ្គលយកដាវកាត់ដើមឈើដូច្នោះ ។ ឈ្មោះថា* **វិសាណ** *ព្រោះមានអំណាចដូចគ្នានឹងថ្នាំពិស ។ ឈ្មោះថា* **ខគ្គ** *ព្រោះដូចដាវ ។ ម្រឹគណា មានស្នែងដូចដាវ ម្រឹគនោះ ឈ្មោះថា* **ខគ្គវិសាណ** *។ កុយរបស់ម្រឹគដែលមានស្នែងដូចដាវនោះ ឈ្មោះថា* **ខគ្គវិសាណកប្ប** *អធិប្បាយថា* **ព្រះបច្ចេកពុទ្ធ** *ប្រៀបដូចកុយរមាស ជាបុគ្គលម្នាក់ឯង មិនមានមិត្ត មិនមានសម្លាញ់ ត្រាច់ទៅ គឺនៅ ប្រព្រឹត្តទៅ ដើរទៅ ឲ្យដើរទៅ ។*

## ការណត្ថគាថាទី ១១ ចប់

## វគ្គទី ៤ ចប់ [១]

---

*១-គាថាទាំង ៤២ នេះ ស្រង់ចាកបិដកខ្មែរលេខ ៧២ ទំព័រលេខ ១៨-៣០ ឃ្នាបលេខ ២ មួយអន្ទើដោយអដ្ឋកថា ។*

# អភិសម្ពុទ្ធគាថា

**វិសុទ្ធសីលា សុវិសុទ្ធបញ្ញា**

**សមាហិតា ជាគរិយានុយុត្តា**

**វិបស្សកា ធម្មវិសេសទស្សី**

**មគ្គង្គពោជ្ឈង្គគតេ វិជញ្ញា ។**

*ពួកព្រះបច្ចេកពុទ្ធ មានសីលបរិសុទ្ធ មានប្រាជ្ញាបរិសុទ្ធល្អ មានចិត្តតម្កល់មាំ ប្រកបរឿយ ៗ នូវព្យាយាមជាគ្រឿងភ្ញាក់រឭក អ្នកពិចារណានូវសង្ខារ ឃើញនូវធម៌ដ៏វិសេស ដឹងច្បាស់នូវធម៌ដែលជាអង្គនៃមគ្គនិងពោជ្ឈង្គៈ ។*

**សុញ្ញប្បណិធិញ្ច តថានិមិត្តំ**

**អាសេវយិត្វា ជិនសាសនម្ហិ**

**យេ សាវកត្តំ ន វជន្តិ ធីរា**

**ភវន្តិ បច្ចេកជិនា សយម្ភូ ។**

*ពួកជនជាអ្នកប្រាជ្ញណា ចម្រើននូវសុញ្ញតវិមោក្ខ អប្បណិហិតវិមោក្ខ និងអនិមិត្តវិមោក្ខ ក្នុងសាសនានៃព្រះជិនស្រីហើយ តែមិនសម្រេចនូវភាពជាសាវ័កទេ*

ពួកជនជាអ្នកប្រាជ្ញនោះ គង់បានជាព្រះបច្ចេកពុទ្ធ ត្រាស់ដឹងឯង ។

មហន្តធម្មា ពហុធម្មកាយា
ចិត្តិស្សរា សព្វទុក្ខោឃតិណ្ណា
ឧទគ្គចិត្តា បរមត្ថទស្សី
សីហោបមា ខគ្គវិសាណកប្បា ។

ពួកជននោះ ជាអ្នកមានធម៌ដ៏ច្រើន មានធម្មកាយដ៏សម្បូណ៌ មានចិត្តជាធំ ឆ្លងនូវទុក្ខនិងឱឃៈទាំងពួង មានចិត្តខ្ពង់ខ្ពស់ផុត ជាអ្នកឃើញនូវប្រយោជន៍ដ៏ក្រៃលែង គឺព្រះនិព្វាន មានឧបមាដូចសីហៈ ( តែង ប្រព្រឹត្តតែម្នាក់ឯង ) ដូចកុយរមាស ។

សន្តិន្ទ្រិយា សន្តមនា សមាធី
បច្ចន្តសត្តេសុ បតិប្បចារា
ទីបា បរត្ថ ឥធ វិជ្ជលន្តា
បច្ចេកពុទ្ធា សតតហិតាមេ ។

ព្រះបច្ចេកពុទ្ធទាំងឡាយ ជាបុគ្គលមានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ស្ងាត់ មានចិត្តជាសមាធិ ប្រព្រឹត្តដោយប្រាជ្ញាចំពោះសត្វ ក្នុងទីបំផុតដែន ដូចប្រទីបឆ្នុះបំភ្លឺ

ក្នុងលោកខាងមុខ និងលោកនេះ ជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ដល់ពួកសត្វ ។

បហីនសព្វាវរណា ជនិន្ទា
លោកប្បទីបា ឃនកញ្ចនាភា
និស្សំសយំ លោកសុទក្ខិណេយ្យា
បច្ចេកពុទ្ធា សតតប្បិតាមេ ។

ព្រះបច្ចេកពុទ្ធទាំងឡាយ ជាធំជាងជន លះកិលេសជាគ្រឿងរាំងទាំងពួងហើយ ជាប្រទីបនៃលោក មានរស្មីដូចមាសដុំ ជាទក្ខិណេយ្យបុគ្គលដ៏ល្អ របស់សត្វលោក ដោយឥតសង្ស័យ ជាបុគ្គលសម្រេចដោយនិរោធសមាបត្តិជារឿយៗ ។

បច្ចេកពុទ្ធាន សុភាសិតានិ
ចរន្តិ លោកម្ហិ សទេវកម្ហិ
សុត្វា តថា យេ ន ករោន្តិ ពាលា
វជ្ជន្តិ ទុក្ខេសុ បុនប្បុនន្តេ ។

សុភាសិតរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ រមែងប្រព្រឹត្តទៅក្នុងមនុស្សលោក ព្រមទាំងទេវលោក ពួកជនពាលណា ស្តាប់ហើយ តែមិនបានធ្វើតាមសុភាសិត មាន

*សភាពដូច្នោះទេ ពួកជនពាលនោះឯង រមែងធ្លាក់ទៅរងទុក្ខទាំងឡាយរឿយៗ ។*

បច្ចេកពុទ្ធាន សុភាសិតានិ
មធុំ យថា ខុទ្ទមិវស្សវន្តំ
សុត្វា តថា យេ បដិបត្តិយុត្តា
ភវន្តិ សច្ចទសា សបញ្ញា ។

*សុភាសិតរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ផ្អែមល្ហែមដូចទឹកឃ្មុំផ្អិត ដែលហូរចុះ ពួកជនណា បានស្តាប់ហើយ ប្រកបនូវសេចក្តីប្រតិបត្តិតាមយ៉ាងនោះ ពួកជននោះប្រកបដោយប្រាជ្ញា រមែងឃើញនូវសច្ចធម៌ ។*

បច្ចេកពុទ្ធេហិ ជិនេហិ ភាសិតា
គាថា ឧឡារា អភិនិក្ខមិត្វា
តា សក្យសីហេន នរុត្តមេន
បកាសិតា ធម្មវិជាននត្ថំ ។

*គាថាដ៏ខ្ពង់ខ្ពស់ណា ដែលព្រះបច្ចេកពុទ្ធទាំងឡាយជាអ្នកឈ្នះកិលេស សម្តែងហើយនោះ ព្រះសម្ពុទ្ធជាសីហៈក្នុងសក្យវង្ស ទ្រង់ខ្ពង់ខ្ពស់ជាងជន ទ្រង់ចេញបព្វជ្ជាហើយ បានប្រកាសទុក ដើម្បីការដឹងច្បាស់នូវ*

*ធម៌ ។*

លោកានុកម្បាយ ឥមានិ តេសំ
បច្ចេកពុទ្ធាន វិកុព្វិតានិ
សំវេគសង្គមតិវឌ្ឍនត្ថំ
សយម្ភុសីហេន បកាសិតានិ ។

*សុភាសិតទាំងនេះ ដែលព្រះបច្ចេកពុទ្ធទាំងនោះ សម្តែងផ្សេង ៗ គ្នា ដើម្បីអនុគ្រោះដល់សត្វលោក ព្រះសយម្ភូដូចជាសីហៈ ទ្រង់ប្រកាសទុកហើយ ដើម្បីញុំាងសំវេគធម៌ សង្គហធម៌ និងឧបាយប្រាជ្ញា ឲ្យចម្រើនឡើង ។*

អភិសម្ពុទ្ធគាថា ចប់ [១]

---

*១-អភិសម្ពុទ្ធគាថាទាំងនេះ ស្រង់ចាកអបទាន បិ.៧២ ទំ.៣១-៣៣ ឃ.២ ។*

# បកិណ្ណកកថា

**ព្រះបច្ចេកពុទ្ធ** ទាំងឡាយ ជាធំ ជាប្រធាន ជាម្ចាស់ទ្រព្យ ព្រោះលោកទទួលវត្ថុតិចតួចនៃពួកទាយក ធ្វើឲ្យជាវត្ថុមានផលច្រើន ហើយធ្វើឲ្យចូលទៅកាន់ស្ថានសួគ៌ និងនិព្វានបាន ។

ពិតហើយ **ព្រះបច្ចេកពុទ្ធ** ជាធំ ជាប្រធាន ដោយធ្វើឲ្យកើតទ្រព្យរាប់កោដិ ដល់អ្នករែកស្មៅ ឈ្មោះអន្នភារៈ ដោយទទួលកត្តដែលជាចំណែករបស់អន្នភារៈ កាលអន្នភារៈកំពុងសម្លឹងមើលនោះឯង ឆាន់ឲ្យឃើញ ញុំាំងពួកទេវតាឲ្យបន្លឺសាធុការ ហើយនាំឲ្យអន្នភារៈដែលជាជនទុរគត បានទទួលតំណែងសេដ្ឋីក្នុងថ្ងៃនុ៎ះឯង ។

**ព្រះបច្ចេកពុទ្ធ** ជាធំ ជាប្រធាន ដោយការធ្វើឲ្យកើតសោមនស្សក្នុងខទិរង្គារជាតក ព្រោះលោកទទួលបិណ្ឌបាតដែលព្រះពោធិសត្វប្រគេន ដោយជាន់ផ្កាឈូក ដែលផុសឡើងអំពីរណ្តៅរងើកភ្លើងគគីរ ដែលមារនិម្មិតឡើង កាលព្រះពោធិសត្វកំពុងឃើញនុ៎ះឯង ហោះទៅក្នុងអាកាស ។

**ព្រះបច្ចេកពុទ្ធ** ជាធំ ជាប្រធាន ដោយការធ្វើឲ្យកើតសោមនស្សដល់ព្រះមហាជនកពោធិសត្វនិងព្រះទេវី ដោយការដែល ( ព្រះបច្ចេក-ពុទ្ធ ) ជាឱរសរបស់អគ្គមហេសីបទុមវតី ហោះមកអំពីភ្នំគន្ធមាទន៍ហើយ

*ទទួលនូវទាន ដោយការអារាធនារបស់ព្រះទេវីនៃព្រះមហាជនក ។*

**ព្រះបច្ចេកពុទ្ធ** *ជាធំ ជាប្រធាន ដោយការធ្វើឲ្យកើតបាយ ដូចរឿងក្នុងអតីតរបស់មេណ្ឌកសេដ្ឋី ។*

*ព្រះពុទ្ធមហេសី គឺ* **ព្រះបច្ចេកពុទ្ធ** *អ្នកស្វែងរកគុណធំ ជាម្ចាស់ក្នុងការធ្វើឲ្យពួកសត្វជាច្រើន ដូចពោលមកនេះជាដើម ឲ្យឈានចុះកាន់សេចក្តីសុខ ជួយបរិបាល និងការឲ្យដល់ស្ថានសួគ៌និងព្រះនិព្វាន ព្រោះហេតុនោះ ទើបឈ្មោះថា* **បច្ចេកសម្ពុទ្ធ** *។*

បកិណ្ណកកថា ចប់

# ព្រះអនុរុទ្ធត្ថេរ

បានឮថា កុលបុត្តនេះ ជាអ្នកមានបុញ្ញាធិការ បានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុន ៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះ ៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតជាកុដុម្ពិកៈ ជាអ្នកសម្បូរដោយទ្រព្យសម្បត្តិ ។ ថ្ងៃមួយចូលទៅកាន់វិហារស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា បានឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គបុគ្គល នៃភិក្ខុដែលមានទិព្វចក្ខុ ខ្លួនឯងក៏ប្រាថ្នាឋានន្តរនោះ ញុំាងមហាទានឲ្យប្រព្រឹត្តទៅអស់ ៧ ថ្ងៃ ចំពោះព្រះមានព្រះភាគ ដែលមានភិក្ខុសង្ឃ ១ សែន ជាបរិវារ ក្នុងថ្ងៃទី ៧ បានថ្វាយសំពត់ដ៏ប្រសើរ ចំពោះព្រះមានព្រះភាគនិងភិក្ខុសង្ឃ ហើយធ្វើបណិធាន គឺសេចក្តីប្រាថ្នា ឯព្រះសាស្តាទ្រង់ជ្រាបថា សេចក្តីប្រាថ្នារបស់កុលបុត្តនេះ សម្រេចដោយមិនមានអន្តរាយ ទើបទ្រង់ព្យាករថា **អនាគតេ គោតមស្ស នាម សម្មាសម្ពុទ្ធស្ស សាសនេ ទិព្វចក្ខុកានំ អគ្គោ ភវិស្សតិ** ក្នុងអនាគតកាល ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធព្រះនាមគោតម បុរសនេះ នឹងបានជាបុគ្គលដ៏ប្រសើរជាងភិក្ខុ ដែលមានចក្ខុទិព្វ ។

កុលបុត្តនោះ ក៏បំពេញបុណ្យជាច្រើន ក្នុងព្រះសាស្តានោះ កាល

ព្រះសាស្តាបរិនិព្វានហើយ កាលព្រះចេតិយមាស កម្ពស់ ៧ យោជន៍ សម្រេចហើយ ធ្វើការបូជាប្រទីបដ៏ឧឡារ ( មួយអន្លើដោយ ) ប្រទីបមានដង៍ច្រើនពាន់ ដោយអធិដ្ឋានថា **ទិព្វចក្ខុញាណស្ស ឧបនិស្សយបច្ចយោ ហោតុ** សូមជាឧបនិស្ស័យដល់ទិព្វចក្ខុចុះ ។

កុលបុត្តនោះ ធ្វើបុណ្យជាច្រើន ដរាបដល់អស់ជីវិត ដោយប្រការដូច្នេះហើយ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងសាសនានៃព្រះមានព្រះភាគកស្សបៈ កើតឡើងក្នុងផ្ទះកុដុម្ពិកៈ ក្នុងនគរពារាណសី ដល់នូវភាពជាអ្នកដឹងក្តីហើយ កាលព្រះសាស្តាបរិនិព្វាន កាលជនទាំងឡាយសាងព្រះចេតិយមាស កម្ពស់ ១ យោជន៍ សម្រេចហើយ ឲ្យធ្វើថាសសំរឹទ្ធជាច្រើន ដាក់ពេញដោយសប្បិ ដាក់ស្កអំពៅមួយដុំត្រង់កណ្តាលនៃថាសនីមួយ ៗ ដាក់ថាសជុំវិញព្រះចេតិយ ឲ្យមាត់ថាសនិង មាត់ថាសទល់គ្នា ហើយធ្វើថាសសំរឹទ្ធធំមួយ ដាក់ពេញដោយសប្បិ ដុតប្រទេះ ១ ពាន់ ទូលលើក្បាល ដើរប្រទក្សិណជុំវិញព្រះចេតិយ អស់មួយយប់ទល់ភ្លឺ ។

ក្នុងអត្តភាពនោះ កុលបុត្តនោះ ធ្វើកុសលដរាបដល់អស់ជីវិត ដោយប្រការដូច្នេះ ចុតិចាកអត្តភាពនោះ ទៅកើតក្នុងទេវលោក តាំងនៅក្នុងទេវលោកនោះ ដរាបដល់អស់អាយុ ចុតិអំពីទេវលោកនោះ កាលព្រះពុទ្ធមិនទាន់កើតឡើង បានកើតក្នុងត្រកូលក្រីក្រ ក្នុងនគរពារាណសី

មានឈ្មោះថា អន្នភារៈ ។ អន្នភារៈនោះ អាស្រ័យផ្ទះសុមនសេដ្ឋីធ្វើការចិញ្ចឹមជីវិត ។

ថ្ងៃមួយ **ព្រះបច្ចេកពុទ្ធ** ព្រះនាមថា ឧបរិដ្ឋៈ ចេញអំពីនិរោធសមាបត្តិត្រង់ភ្នំគន្ធមាទន៍ហើយ គិតថា ថ្ងៃនេះ អាត្មាអញនឹងធ្វើសេចក្តីអនុគ្រោះដល់អ្នកណាហ្ន៎ ជ្រាបថា ថ្ងៃនេះ ការដែលអាត្មាអញធ្វើសេចក្តីអនុគ្រោះដល់បុរសឈ្មោះអន្នភារៈ គួរ ឥឡូវនេះ បុរសនោះ រែកស្មៅចេញអំពីព្រៃហើយ នឹងមកផ្ទះ ដូច្នេះហើយ ទើបកាន់បាត្រនិងចីវរទៅដោយឫទ្ធិ ប្រាកដចំពោះមុខអន្នភារៈនោះ ។ អន្នភារៈបានឃើញព្រះបច្ចេកពុទ្ធមានបាត្រទទេក្នុងដៃហើយ សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់បានភិក្ខាខ្លះដែរឬទេ ។

កាលព្រះបច្ចេកពុទ្ធតបថា អ្នកមានបុណ្យច្រើន អាត្មានឹងបាន ។ ទើបពិតថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់មេត្តារង់ចាំបន្តិច ហើយក៏ទុកអម្រែកស្មៅ រត់ទៅកាន់ផ្ទះដោយរហ័ស សួរភរិយាថា នែនាងដ៏ចម្រើន ភត្តចំណែកដែលនាងទុកដើម្បីខ្ញុំ មាន ឬមិនមាន ។

កាលភរិយាឆ្លើយថា បពិត្រអ្នកជាម្ចាស់ មាន ទើបត្រឡប់មកដោយរហ័ស ទទួលបាត្ររបស់ព្រះបច្ចេកពុទ្ធ ទៅកាន់ផ្ទះដោយគិតថា កាលអញប្រាថ្នាដើម្បីឲ្យ ទេយ្យធម៌មិនមាន កាលទេយ្យធម៌មាន អញមិនបានបដិគ្គាហកៈ ។ តែថ្ងៃនេះ បដិគ្គាហកៈក៏អញចួបហើយ ទាំង

ទេយ្យធម៌របស់អញក៏មាន ជាលាភរបស់អញហ្ន៎ ឲ្យចាក់កត្ត ( ទាំងអស់ ) ក្នុងបាត្រ ហើយនាំត្រឡប់មក ដាក់ក្នុងដៃរបស់ព្រះបច្ចេកពុទ្ធ តាំងសេចក្តីប្រាថ្នាថា

**ឥមិនា បន ទានេន មា មេ ទាលិទ្ទិយំ អហុ**
**នត្ថីតិ វចនំ នាម មា អហោសិ ភវាភវេ ។**

ដោយទាននេះ ភាពជាអ្នកខ្វះខាត កុំបីមានដល់ខ្ញុំឡើយ
ពាក្យថា មិនមាន កុំប្រាកដ ក្នុងភពតូចភពធំ[១] ។

បពិត្រលោកម្ចាស់ដ៏ចម្រើន សូមឲ្យខ្ញុំផុតចាកជីវិតក្រីក្របែបនេះ ហើយមិនគប្បីបានឮពាក្យថា មិនមានឡើយ ។

ព្រះបច្ចេកសម្ពុទ្ធធ្វើអនុមោទនាថា **ឯវំ ហោតុ មហាបុញ្ញ** សេចក្តីប្រាថ្នារបស់អ្នក ចូរសម្រេចយ៉ាងនោះចុះ អ្នកមានបុណ្យច្រើន ដូច្នេះហើយ ក៏ចៀសចេញទៅ ។ ទេវតាដែលអាស្រ័យត្រង់ឆត្ររបស់សុមនសេដ្ឋី ពោលថា គួរត្រេកអរពិតហ្ន៎ ទាននេះ ជាទានដ៏កំពូល ដែលតម្កល់ទុកល្អហើយក្នុងព្រះឧបរិដ្ឋបច្ចេកពុទ្ធ ហើយបានឲ្យសាធុការ ៣ ដង ។ គ្រានោះ សេដ្ឋីពោលនឹងទេវតានោះថា អ្នកមិនដែលឃើញយើងឲ្យទានជានិច្ច អស់កាលមានប្រមាណប៉ុណ្ណេះទេឬ ។

ទេវតាពោលថា ខ្ញុំមិនបានឲ្យសាធុការប្រារព្ធទានរបស់លោក តែ

---

១-ស្រង់ចាកអដ្ឋកថា ធម្មបទ សុមនសាមណេរវត្ថុ ។

សាធុការនេះ ខ្ញុំឲ្យប្រព្រឹត្តទៅហើយ ព្រោះសេចក្តីជ្រះថ្លាក្នុងបិណ្ឌបាត ដែលអន្នភារៈប្រគេនហើយដល់ព្រះឧបរិដ្ឋបច្ចេកពុទ្ធ ។ សុមនសេដ្ឋីគិតថា គួរអស្ចារ្យហ្ន៎ អញឲ្យទានអស់កាលមានប្រមាណប៉ុណ្ណោះ ក៏មិនអាចឲ្យទេវតាធ្វើនូវសាធុការបាន អន្នភារៈអាស្រ័យអញរស់នៅសោះ គង់ឲ្យទេវតាធ្វើសាធុការដោយបិណ្ឌបាតម្តងប៉ុណ្ណោះ អញនឹងធ្វើវត្ថុដែលសមគួរក្នុងទានរបស់អន្នភារៈ ហើយធ្វើបិណ្ឌបាតនោះ ឲ្យជារបស់អញដូច្នេះហើយ ទើបឲ្យហៅអន្នភារៈមកសួរថា **អជ្ជ តយា កស្សចិ កិញ្ចិ ទិន្នំ** ថ្ងៃនេះ ឯងបានឲ្យអ្វីដល់អ្នកណាដែរឬទេ ។

អន្នភារៈឆ្លើយថា បពិត្រលោកម្ចាស់ ថ្ងៃនេះ ខ្ញុំបានប្រគេនចំណែកភត្តាហាររបស់ខ្ញុំ ចំពោះព្រះឧបរិដ្ឋបច្ចេកពុទ្ធ ។ សេដ្ឋីពោលថា ណ្ហើយចុះ បា ចូរឯងយកកហាបណៈ ហើយឲ្យបិណ្ឌបាតនោះ ដល់ខ្ញុំចុះ ។ អន្នភារៈពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនឲ្យទេ ។

សេដ្ឋីនោះ ឡើងតម្លៃឲ្យដល់មួយពាន់ ចំណែកអន្នភារៈ ក៏មិនបានឲ្យ សូម្បីទ្រព្យមួយពាន់ ។ លំដាប់នោះ សេដ្ឋីពោលថា អ្នកដ៏ចម្រើនសេចក្តីនោះ ស្ទេះទុកចុះ បើឯងមិនឲ្យបិណ្ឌបាត ចូរកាន់យកទ្រព្យមួយពាន់ ហើយឲ្យចំណែកបុណ្យដល់ខ្ញុំចុះ ។

អន្នភារៈពោលថា បពិត្រលោកម្ចាស់ ខ្ញុំសួរព្រះបច្ចេកពុទ្ធហើយនឹងប្រាប់ឲ្យដឹង ប្រញាប់រត់ទៅ ទាន់ព្រះបច្ចេកពុទ្ធហើយសួរថា បពិត្រ

លោកម្ចាស់ សុមនសេដ្ឋីឲ្យទ្រព្យមួយពាន់ ហើយសូមចំណែកបុណ្យក្នុងបិណ្ឌបាតដែលប្រគេនដល់លោកម្ចាស់ តើខ្ញុំត្រូវធ្វើដូចម្ដេច ។

លំដាប់នោះ ព្រះបច្ចេកពុទ្ធនាំឧបមាមកប្រៀបធៀបដល់បុរសនោះថា នែបណ្ឌិត គេអុជប្រទីបឲ្យឆេះឡើងក្នុងផ្ទះមួយខ្នង ក្នុងស្រុកដែលមានត្រកូលមួយរយ ពួកជនដ៏សេស យកប្រឆេះរបស់ខ្លួនជ្រលក់ប្រេងហើយទៅអុជបន្ត ហើយកាន់យក ពន្លឺប្រទីបដើម បុគ្គលគប្បីពោលថា មានឬមិនមាន ។ អន្នភារៈពោលថា ពន្លឺរឹងរឹតតែមានច្រើនឡើង ។

ព្រះបច្ចេកពុទ្ធពោលថា យ៉ាងនោះឯងបណ្ឌិត ទោះជាបបរមួយបោយក្ដី ឬភិក្ខាមួយវែកក្ដី កាលបុគ្គលឲ្យចំណែកបុណ្យក្នុងបិណ្ឌបាតរបស់ខ្លួនដល់អ្នកដទៃ ឲ្យប៉ុនណា បុណ្យក៏ចម្រើនឡើងប៉ុណ្ណោះ អ្នកបានឲ្យបិណ្ឌបាតមួយចំណែកប៉ុណ្ណោះ តែកាលអ្នកឲ្យចំណែកបុណ្យដល់សេដ្ឋី បិណ្ឌបាតឈ្មោះថា ពីរចំណែក ចំណែកមួយជារបស់អ្នកចំណែកមួយជារបស់សេដ្ឋី ។ អន្នភារៈទទួលថា ប្រពៃហើយលោកម្ចាស់ថ្វាយបង្គំព្រះបច្ចេកពុទ្ធទៅកាន់សម្នាក់សេដ្ឋី ពោលថា សូមលោកម្ចាស់ទទួលយកចំណែកបុណ្យចុះ ។

សេដ្ឋីពោលថា បើដូច្នោះ ចូរអ្នកទទួលយកកហាបណៈទាំងនេះ ។ អន្នភារៈពោលថា ខ្ញុំមិនបានលក់បិណ្ឌបាត ខ្ញុំឲ្យចំណែកបុណ្យដល់លោកម្ចាស់ដោយសទ្ធា ។

សេដ្ឋីពោលថា អ្នកឲ្យដោយសទ្ធា ខ្ញុំក៏បូជាគុណរបស់អ្នក ( ដោយសទ្ធា ) ណ្ហើយចុះបា ចាប់តាំងអំពីពេលនេះទៅ អ្នកកុំធ្វើការដោយដៃរបស់ខ្លួន ចូរសង់ផ្ទះក្បែរដងវិថី ហើយចូរកាន់យកវត្ថុគ្រប់យ៉ាងដែលអ្នកត្រូវការ អំពីសម្នាក់របស់ខ្ញុំចុះ ។

ធម្មតាបិណ្ឌបាតដែលប្រគេនដល់ព្រះបច្ចេកពុទ្ធ ដែលចេញអំពីនិរោធសមាបត្តិ រមែងឲ្យផលក្នុងថ្ងៃនោះឯង ។ ព្រោះហេតុនោះ ក្នុងថ្ងៃនោះ សុមនសេដ្ឋី កាលចូលទៅគាល់ព្រះរាជា បាននាំនាយអន្នភារៈនោះទៅផង ព្រះរាជាក៏ទ្រង់ទតដោយអើពើ ។ សុមនសេដ្ឋីក្រាបទូលថា បពិត្រមហារាជ បុរសនេះ សមគួរទទួលការប្រោសប្រណី ដោយពិត ហើយក្រាបទូលដល់បុណ្យដែលគេធ្វើក្នុងកាលនោះ ទាំងភាពដែលខ្លួនបានឲ្យទ្រព្យ ១ ពាន់ដល់អន្នភារៈនោះ ឲ្យព្រះរាជាទ្រង់ជ្រាប ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ ក៏ទ្រង់ត្រេកអរ ប្រោសប្រទានទ្រព្យ ១ ពាន់ ហើយត្រាស់ប្រាប់កន្លែងធ្វើផ្ទះដល់អន្នភារៈថា អ្នកចូរធ្វើផ្ទះក្នុងទីឈ្មោះនោះ ហើយរស់នៅចុះ ។ កាលអន្នភារៈ កំពុងជម្រះទីនោះ ថ្នាំងទ្រព្យធំ ៗ ក៏ផុសឡើង គាត់ក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាប ។ ព្រះរាជាទ្រង់ឲ្យជញ្ជូនទ្រព្យទាំងឡាយមកគរទុក ហើយត្រាស់សួរថា ក្នុងនគរនេះ ក្នុងផ្ទះរបស់អ្នកណា មានទ្រព្យប្រមាណប៉ុណ្ណោះខ្លះ ។

អាមាត្យរាជបរិវារនាំគ្នាក្រាបទូលថា បពិត្រព្រះសម្មតិទេព មិន

មានអ្នកណាមានទេ ។ ព្រះរាជាត្រាស់ថា បើដូច្នោះ អន្ទកការៈនេះ ចូរមានឈ្មោះថា មហាធនសេដ្ឋីចុះ ដូច្នេះ ។ ព្រះរាជាទ្រង់ប្រទានឆត្រសេដ្ឋីដល់អន្នភារៈ ក្នុងថ្ងៃនោះឯង ។

តាំងអំពីនោះមក កុលបុត្តនោះ ធ្វើកុសលកម្មដរាបដល់អស់ជីវិត ចុតិអំពីអត្តភាពនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ បដិសន្ធិក្នុងព្រះរាជវាំងរបស់ព្រះបាទអមិតោទនសក្កៈ[១] ក្នុងនគរកបិលពស្តុ មានឈ្មោះថា អនុរុទ្ធ ។ អនុរុទ្ធសក្កៈនោះ ជាព្រះកនិដ្ឋភាតារបស់ព្រះបាទមហានាមសក្កៈ ជាឱរសរបស់ព្រះបិតុលានៃព្រះសាស្តា ជាស្តេចសុខុមាលជាតិក្រៃលែង មានបុណ្យច្រើន មានស្រីរបាំដែលប្រដាប់តាក់តែងដ៏ស្រស់ត្រកាល ចោមរោមក្នុងប្រាសាទទាំង ៣ ដ៏សមគួរដល់រដូវទាំង ៣ សោយសម្បត្តិដូចទេវតា ។

បានឮថា ថ្ងៃមួយ កាលក្សត្រ ៦ អង្គ លេងអង្គញ់ យកនំភ្នាល់គ្នា អនុរុទ្ធកុមារចាញ់ ទើបបញ្ជូនដំណឹងទៅកាន់សម្នាក់របស់ព្រះមាតា ដើម្បីត្រូវការនំ ព្រះមាតាយកភាជនៈមាសធំ ដាក់នំពេញ ហើយបញ្ជូនទៅឲ្យ ។ ព្រះអនុរុទ្ធសោយនំហើយ ទ្រង់លេងចាញ់ទៀត ក៏បញ្ជូន

---

១- អដ្ឋកថា ថេរគាថា បិ.៥៧ ទំ.៧៥ ឃ.២៥៧ និងអដ្ឋកថា អបទាន បិ. ៧២ ទំ.៨០ ឃ.៦ ជាព្រះបាទសុក្កោទនសក្កៈ តែក្នុងអដ្ឋកថា ធម្មបទ សុមនសាមណេរវត្ថុ ជាអមិតោទនសក្កៈ ។

ដំណឹងទៅយ៉ាងនោះឯង ។

កាលមនុស្សនាំនំមកយ៉ាងនេះ អស់វារៈ ៣ ដង លើកទី ៤ ព្រះមាតាបញ្ជូនដំណឹងទៅថា ឥឡូវនេះ នំមិនមាន ។ ព្រោះពាក្យថា មិនមាន ជាពាក្យដែលខ្លួនមិនធ្លាប់ឮអំពីមុនមក ទើបព្រះអនុរុទ្ធស្តាប់ពាក្យរបស់ព្រះមាតានោះហើយ ធ្វើសេចក្តីសម្គាល់ថា ឥឡូវនេះ នឹងមាននំ ឈ្មោះមិនមាន ទើបបញ្ជូនមនុស្សទៅដោយព្រះតម្រាស់ថា ចូរទៅយកនំមិនមានមក ។

ក្នុងកាលនោះ ព្រះមាតារបស់ព្រះរាជកុមារ កាលអ្នកបម្រើទូលថា បពិត្រព្រះនាង បានឮថា ព្រះនាងនឹងឲ្យនំមិនមាន ទើបព្រះនាងត្រិះរិះថា ពាក្យថា មិនមាន កូនរបស់អញមិនធ្លាប់ឮមកអំពីមុន អញគប្បីឲ្យកូនរបស់អញដឹងភាពដែលមិនមាននោះ មានសភាពដូចម្តេច ទើបព្រះនាងលាងថាសមាស គ្របដោយថាសមាសដទៃ បញ្ជូនទៅថា ទៅចុះបា ចូរបាឲ្យថាសមាសនេះ ដល់កូនរបស់យើង ។

ខណៈនោះ ទេវតាទាំងឡាយដែលជាអ្នករក្សានគរ គិតថា អនុរុទ្ធជាម្ចាស់របស់ពួកយើង ប្រគេនភត្តជាចំណែកខ្លួន ដល់ព្រះបច្ចេកពុទ្ធព្រះនាមឧបរិដ្ឋៈ ហើយតាំងសេចក្តីប្រាថ្នាថា ខ្ញុំមិនគប្បីបានឮពាក្យថា មិនមាន កាលនៅជាអ្នករែកស្មៅឈ្មោះអន្នភារៈ បើយើងដឹងសេចក្តីនោះហើយ ព្រងើយកន្តើយ ក្បាលរបស់ពួកយើងនឹងបែកជា ៧ ភាគ ទើបធ្វើ

ថាសឲ្យពេញដោយនំទិព្វទាំងឡាយហើយ ។ បុរសនោះ នាំថាសមក ទុកក្នុងសម្នាក់របស់ស្តេចសក្យៈទាំងនោះ ហើយបើកថាស ក្លិនរបស់នំទិព្វទាំងនោះ ក៏ផ្សាយទៅពេញនគរ នំនោះ គ្រាន់តែស្តេចសក្យៈទាំងនោះ ដាក់ក្នុងព្រះឱស្ឋ រសនៃនំនោះ បានផ្សាយទៅកាន់សរសៃសម្រាប់ទទួលរសទាំង ៧ ពាន់ តាំងនៅហើយ ។ ព្រះអនុរុទ្ធកុមារទ្រង់ព្រះតម្រិះថា ក្នុងកាលមុន ព្រះមាតាប្រហែលជាមិនស្រឡាញ់អញ ព្រោះក្នុងកាលដទៃ ទ្រង់មិនធ្លាប់ធ្វើនំមិនមានឲ្យដល់អញ ។ កុមារនោះទៅហើយ ទូលព្រះមាតាយ៉ាងនេះថា បពិត្រព្រះមាតា ខ្ញុំមិនជាទីស្រឡាញ់របស់ទ្រង់ឬ ។ ព្រះមាតាពោលថា នែបា កូននិយាយអ្វី បាជាទីស្រឡាញ់ក្រៃលែងជាងកែវភ្នែកទាំងគូផង ក្រៃលែងជាងសាច់បេះដូងរបស់មាតាផង ។

ព្រះអនុរុទ្ធទូលសួរថា បពិត្រព្រះមាតា បើខ្ញុំជាទីស្រឡាញ់របស់ព្រះមាតាសោត ព្រោះហេតុអ្វី ក្នុងកាលមុន ទើបព្រះមាតាមិនប្រទាននំមិនមានបែបនេះ ដល់ខ្ញុំ ។ ព្រះនាងសួរបុរសនោះថា នែបា តើមានអ្វីកើតក្នុងថាសនោះឬ ។

បុរសនោះពោលថា បពិត្រព្រះនាង មាន ថាសនោះ ពេញដោយនំទាំងឡាយ នំបែបនោះ ទូលព្រះបង្គំមិនធ្លាប់ឃើញអំពីមុនឡើយ ។ ព្រះនាងព្រះតម្រិះថា កូនរបស់អញបានធ្វើបុណ្យទុកហើយ ទេវតា

ទាំងឡាយបញ្ជូននំទិព្វទៅឲ្យ ។

ព្រះអនុរុទ្ធក្រាបទូលព្រះមាតាថា បពិត្រព្រះមាតា នំបែបនេះ ខ្ញុំមិនធ្លាប់សោយឡើយ តាំងអំពីថ្ងៃនេះទៅ សូមព្រះមាតាធ្វើនំមិនមាននេះប៉ុណ្ណោះ ដល់ខ្ញុំ ។

តាំងពីកាលនោះមក ក្នុងពេលដែលព្រះអនុរុទ្ធពោលថា ខ្ញុំត្រូវការសោយនំ ។ ព្រះនាងលាងថាសមាសហើយគ្របដោយថាសដទៃ បញ្ជូនទៅ ទេវតាទាំងឡាយរមែងញ៉ាំងថាសឲ្យពេញ ( ដោយនំទិព្វ ) ។ ព្រះរាជកុមារនោះ កាលនៅក្នុងព្រះរាជវាំងមិនបានយល់ពាក្យថា មិនមាន ដោយប្រការយ៉ាងនេះ ទ្រង់សោយតែនំទិព្វប៉ុណ្ណោះ ។

កាលឱរសរបស់ស្តេចសក្យៈបួសតាមលំដាប់ត្រកូល ដើម្បីជាបរិវាររបស់ព្រះសាស្តា កាលព្រះបាទមហានាមសក្យៈត្រាស់ថា នែបា ក្នុងត្រកូលរបស់ពួកយើង បុគ្គលណាមួយដែលបួសហើយ មិនមាន ឯងគួរបួស ឬក៏អញបួស ។ ព្រះអនុរុទ្ធពោលថា ខ្ញុំជាមនុស្សសុខមាលជាតិក្រៃលែង មិនអាចបួសបានទេ ។

ព្រះមហានាមពោលថា បើដូច្នោះ ចូរប្អូនរៀនធ្វើការងារចុះ អញនឹងបួស ។ ព្រះអនុរុទ្ធពោលថា ការងារនោះ ដូចម្តេច ។ មែនពិត ព្រះអនុរុទ្ធរមែងមិនដឹងទីកើតឡើងនៃភត្ត នឹងដឹងការងារបានដូចម្តេច ព្រោះហេតុនោះ ទើបត្រាស់យ៉ាងនេះ ។

បានឮថា ថ្ងៃមួយ សក្យៈ ៣ អង្គ គឺ អនុរុទ្ធ ភទ្ទិយៈ កិមិលៈ ប្រឹក្សាគ្នាថា ឈ្មោះថា ភត្ត កើតឡើងក្នុងទីណា ។ បណ្តាសក្យៈទាំង ៣ អង្គនោះ កិមិលៈពោលថា ភត្តកើតឡើងក្នុងជង្រុក ។ បានឮថា ថ្ងៃមួយ កិមិលៈនោះ បានឃើញស្រូវគេជញ្ជូនដាក់ជង្រុក ព្រោះហេតុនោះ ទើបពោលយ៉ាងនោះ ដោយសម្គាល់ថា ភត្តរមែងកើតក្នុងជង្រុក ។ កាលនោះ ភទ្ទិយៈពោលនឹងកិមិលៈថា ឯងមិនដឹង ដូច្នេះហើយ ទើបពោលថា ធម្មតាភត្ត តែងតែកើតឡើងក្នុងឆ្នាំងបាយ ។ បានឮថា ថ្ងៃមួយ ភទ្ទិយៈនោះ ឃើញជនទាំងឡាយដួសភត្តចេញអំពីឆ្នាំងបាយ ទើបធ្វើសេចក្តីសម្គាល់ថា ភត្តនោះ កើតក្នុងឆ្នាំងបាយនោះឯង ព្រោះហេតុនោះ ទើបពោលយ៉ាងនោះ ។ អនុរុទ្ធពោលនឹងស្តេចទាំងពីរអង្គថា អ្នកទាំងពីរមិនដឹង ហើយពោលថា ភត្តកើតឡើងក្នុងថាសមាសធំ កម្ពស់មួយហត្ថ ។ បានឮថា ព្រះអនុរុទ្ធមិនធ្លាប់ឃើញគេបុកស្រូវ មិនធ្លាប់ឃើញគេដាំបាយ ឃើញតែភត្តដែលគេដួសទុកក្នុងថាស ហើយតម្កល់ទុកចំពោះមុខប៉ុណ្ណោះ ព្រោះហេតុនោះ ទើបធ្វើសេចក្តីសម្គាល់ថា ភត្តនោះ រមែងកើតឡើងក្នុងថាសប៉ុណ្ណោះ ព្រោះហេតុនោះ ទើបពោលយ៉ាងនោះ ។ កុលបុត្តមានបុណ្យច្រើន មិនដឹងទីកើតនៃភត្តយ៉ាងនោះ តើនឹងដឹងការងារទាំងឡាយបានដូចម្តេច ។

ក្នុងរឿងចេញបួសនេះ ក្នុងវិនយបិដក សង្ឃភេទក្ខន្ធកៈ បាន

ពោលទុកថា

សម័យនោះ ព្រះពុទ្ធមានព្រះភាគគង់នៅក្នុងនិគម ឈ្មោះអនុបិយា ជានិគមរបស់មល្លក្សត្រ ទៀបព្រៃអនុបិយា ។ ក៏សម័យនោះឯង ពួកសក្យកុមារសុទ្ធតែជាអ្នកមាននាមល្បីល្បាញ ចេញបួសតាមព្រះមានព្រះភាគដែលទ្រង់ព្រះផ្នួសហើយ ។

សម័យនោះ មានសក្យៈជាបងប្អូន ២ អង្គ ឈ្មោះមហានាមសក្កៈ ១ ឈ្មោះអនុរុទ្ធសក្កៈ ១ ។ ឯអនុរុទ្ធសក្កៈជាស្តេចសុខុមាលជាតិ ។ អនុរុទ្ធសក្កៈនោះ មានប្រាសាទ ៣ ខ្នង ប្រាសាទមួយសម្រាប់រដូវរងា ប្រាសាទមួយសម្រាប់រដូវក្តៅ ប្រាសាទមួយសម្រាប់រដូវភ្លៀង ។ អនុរុទ្ធសក្កៈនោះ (គង់នៅ) លើប្រាសាទសម្រាប់រដូវភ្លៀងអស់បួនខែ មានតន្ត្រីនៅចាំគាល់បម្រើ មិនមានមនុស្សប្រុស (នៅលាយ) មិនដែលចុះអំពីប្រាសាទមកខាងក្រោមឡើយ ។ គ្រានោះឯង មហានាមសក្កៈមានសេចក្តីត្រិះរិះដូច្នេះថា ឥឡូវនេះ ពួកសក្យកុមារសុទ្ធតែជាអ្នកមាននាមល្បីល្បាញ បានចេញបួសតាមព្រះមានព្រះភាគ ដែលទ្រង់ព្រះផ្នួសហើយ ចំណែកខាងត្រកូលរបស់យើង គ្មាននរណាមួយចេញចាកផ្ទះទៅបួសក្នុងសាសនាសោះ បើដូច្នោះ គួរតែអាត្មាអញ ឬអនុរុទ្ធ បួសកុំខានចុះ ។ ទើបមហានាមសក្កៈចូលទៅរកអនុរុទ្ធសក្កៈ លុះចូលទៅដល់ហើយ បាននិយាយរឿងនុ៎ះចំពោះអនុរុទ្ធសក្កៈថា ម្នាលអនុរុទ្ធជា

អនុជ ឥឡូវនេះ ពួកសក្យកុមារសុទ្ធតែជាអ្នកមាននាមល្បីល្បាញ បាន
ចេញបួសតាមព្រះមានព្រះភាគ ដែលទ្រង់ព្រះផ្នួសហើយ ចំណែកខាង
ត្រកូលរបស់យើង គ្មាននរណាមួយចេញចាកផ្ទះទៅបួសក្នុងសាសនា
សោះ បើដូច្នោះ ចូរឯងបួស ឬអញនឹងបួសក៏បាន ។ អនុរុទ្ធឆ្លើយថា ខ្ញុំ
ជាមនុស្សសុខុមាលជាតិ ខ្ញុំមិនអាចនឹងចេញចាកផ្ទះទៅបួសក្នុងសាសនា
បានទេ សូមទ្រង់ស្តេចបួសចុះ ។ មហានាមសក្កៈនិយាយថា ម្នាល
អនុរុទ្ធជាអនុជ ចូរប្អូនមកអាយ បងនឹងពន្យល់ប្រយោជន៍របស់ឃរាវាស
ដល់ប្អូនថា ការធ្វើស្រែនោះ មុនដំបូងត្រូវភ្ជួរ ភ្ជួររួចហើយត្រូវព្រោះ ព្រោះ
រួចហើយ ត្រូវបញ្ចូលទឹក បញ្ចូលទឹករួចហើយ ត្រូវបញ្ចេញទឹក បញ្ចេញ
ទឹករួចហើយ ត្រូវជម្រះស្មៅ ជម្រះស្មៅរួចហើយ ត្រូវច្រូតស្រូវ ច្រូតស្រូវ
ហើយ ត្រូវចងកណ្តាប់ ចងជាកណ្តាប់ហើយ ត្រូវធ្វើឲ្យជាគំនរ ធ្វើឲ្យជា
គំនរហើយ ត្រូវបោកឬបញ្ជាន់ បញ្ជាន់ហើយ ត្រូវជជុះយកចំបើង ជជុះ
យកចំបើងហើយ ត្រូវជជុះយកកម្ទេចចេញ ជជុះយកកម្ទេចចេញ
ហើយ ត្រូវរោយ រោយហើយ ត្រូវជញ្ជូនយកមកទុក ជញ្ជូនយកមកទុក
ហើយ ត្រូវចាប់ធ្វើតែយ៉ាងនេះតទៅទៀតរាល់ៗ ឆ្នាំ ត្រូវចាប់ធ្វើ (សា
ពីដើម) តាមទំនងនេះទៀត តែរាល់ ៗ ឆ្នាំ ។ អនុរុទ្ធសក្កៈនិយាយ
ថា ការងារមិនចេះអស់ទេ ទីបំផុតនៃការងារមិនប្រាកដទេ កាលណា
នឹងអស់ការងារ កាលណានឹងប្រាកដថា ផុតការងារបាន កាលណា

យើងនឹងថយខ្វល់ខ្វាយឆ្អែតឆ្អន់ និងស្កប់ស្កល់បម្រើដោយកាមគុណ ៥ ។ ម្នាលអនុរុទ្ធជាអនុជ ការងារមិនចេះអស់ទេ ទីបំផុតការងារ ក៏មិនប្រាកដ មាតាបិតាក្តី ជីតាក្តី ធ្វើមរណកាល ( ទៅអស់ ) ឯការងារមិនចេះអស់ទេ ។ បើដូច្នោះ អនុជឯង ចូរជ្រាបអំពីប្រយោជន៍របស់ឃរាវាសចុះ បងមុខជានឹងចេញចាកផ្ទះទៅបួសក្នុងសាសនា ( មិនខាន ) ។

ក្នុងគ្រានោះ អនុរុទ្ធសក្កៈចូលទៅរកព្រះមាតា លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះមាតាយ៉ាងនេះថា បពិត្រព្រះមាតា ខ្ញុំចង់ចេញចាកផ្ទះទៅបួសក្នុងសាសនា បពិត្រព្រះមាតា សូមព្រះមាតាអនុញ្ញាតឲ្យខ្ញុំចេញចាកផ្ទះទៅបួសក្នុងសាសនា ។ កាលបើអនុរុទ្ធសក្កៈនិយាយយ៉ាងនេះហើយ ព្រះមាតានៃអនុរុទ្ធសក្កៈ និយាយយ៉ាងនេះថា ម្នាលអនុរុទ្ធកូន អ្នកជាបុត្តប្រុសទាំងពីររបស់យើង រមែងជាទីស្រឡាញ់ពេញចិត្ត ឥតមានស្អប់ខ្ពើមទេ សូម្បីដល់មរណកាល យើងក៏ពុំចង់ព្រាត់ប្រាសនិរាសចាកអ្នកឡើយ កាលបើអ្នករស់នៅ ៗ ឡើយ យើងធ្វើម្តេចនឹងយល់ព្រមឲ្យអ្នកចេញចាកផ្ទះទៅបួសក្នុងសាសនាបាន ។ អនុរុទ្ធសក្កៈនិយាយនឹងព្រះមាតាយ៉ាងនេះ អស់វារៈពីរដងផង ។ បេ ។ អស់វារៈបីដងផងថា បពិត្រព្រះមាតា ខ្ញុំចង់ចេញចាកផ្ទះទៅបួសក្នុងសាសនា បពិត្រព្រះមាតា សូមព្រះមាតាអនុញ្ញាតឲ្យខ្ញុំចេញចាកផ្ទះទៅបួសក្នុងសាសនា ។

សម័យនោះឯង ភទ្ទិយសក្យរាជសោយរាជ្យជាស្តេចរបស់សក្យៈទាំងឡាយ ។ ឯភទ្ទិយសក្យរាជនោះ ត្រូវជាសម្លាញ់នឹងអនុរុទ្ធសក្កៈ ។ គ្រានោះឯង ព្រះមាតារបស់អនុរុទ្ធសក្កៈទ្រង់ព្រះចិន្តាថា ព្រះភទ្ទិយ-សក្យរាជនេះ ទ្រង់សោយរាជ្យជាស្តេចរបស់ពួកសក្យៈ ស្តេចនោះ ជាសម្លាញ់នឹងអនុរុទ្ធសក្កៈ គង់មិនអាចចេញចាកអគារដ្ឋានទៅបួសក្នុងសាសនាទេ (លុះទ្រង់ព្រះចិន្តាដូច្នេះហើយ) ទើបមានព្រះសវនីយ៍ទៅនឹងអនុរុទ្ធសក្កៈទៀតថា ម្នាលអនុរុទ្ធកូន ប្រសិនបើភទ្ទិយសក្យរាជចេញចាកផ្ទះទៅបួសក្នុងសាសនា កាលបើដូច្នេះ សឹមកូនឯងទៅបួសចុះ ។ លំដាប់នោះ អនុរុទ្ធសក្កៈចូលទៅរកព្រះភទ្ទិយសក្យរាជ លុះចូលទៅដល់ហើយ ទើបថ្លែងសេចក្តីនុ៎ះទៅនឹងភទ្ទិយសក្យរាជថា ម្នាលសម្លាញ់ ការបួសរបស់ខ្ញុំជាប់ទាក់ទងគ្នានឹងអ្នក ។ ភទ្ទិយសក្យរាជក៏ឆ្លើយតបថា ម្នាលសម្លាញ់ បើបព្វជ្ជារបស់អ្នកជាប់ទាក់ទងគ្នានឹងខ្ញុំក្តី មិនជាប់ក្តី បព្វជ្ជានោះ ចូរលើកទុកចុះ យើងគង់តែនឹងបួសជាមួយអ្នកតាមសប្បាយដែរ ។ អនុរុទ្ធសក្កៈបបួលទៀតថា ម្នាលសម្លាញ់ អ្នកចូរមក យើងទាំងពីរនាក់នឹងចេញចាកផ្ទះទៅបួសក្នុងសាសនា ។ ព្រះភទ្ទិយសក្យរាជតបថា ម្នាលសម្លាញ់ ខ្ញុំមិនអាចចេញចាកផ្ទះទៅបួសក្នុងសាសនាបានទេ កិច្ចឯទៀតដែលខ្ញុំល្មមធ្វើជំនួសអ្នកបាន ខ្ញុំនឹងធ្វើជំនួសអ្នក អ្នកចូរបួសចុះ ។ អនុរុទ្ធសក្កៈនិយាយថា ម្នាលសម្លាញ់ ព្រះមាតានិយាយ

នឹងខ្ញុំយ៉ាងនេះថា ម្នាលអនុរុទ្ធ បើភទ្ទិយសក្យរាជចេញចាកផ្ទះទៅបួស ក្នុងសាសនា កាលបើដូច្នោះ អ្នកឯង ចូរបួសចុះ ។ ភទ្ទិយសក្យរាជ ឆ្លើយថា ម្នាលសម្លាញ់ ខ្ញុំបាននិយាយវាចាទុំះចំពោះអ្នកមែនថា ម្នាល សម្លាញ់ បើបព្វជ្ជារបស់អ្នកជាប់ទាក់ទងនឹងខ្ញុំក្តី មិនជាប់ក្តី បព្វជ្ជានោះ លើកទុកទៅចុះ ខ្ញុំគង់តែនឹងបួសជាមួយនឹងអ្នកតាមសប្បាយដែរ ។ អនុរុទ្ធបបួលថា ម្នាលសម្លាញ់ អ្នកចូរមក យើងទាំងពីរនាក់នឹងចេញ ចាកផ្ទះទៅបួសក្នុងសាសនា ។ ក្នុងសម័យនោះ ពួកមនុស្សច្រើននិយាយ ពាក្យសច្ចៈ ប្តេជ្ញាគ្នាដោយពាក្យសច្ចៈ ។ លំដាប់នោះ ព្រះភទ្ទិយសក្យ-រាជតបនឹងអនុរុទ្ធសក្កៈយ៉ាងនេះថា ម្នាលសម្លាញ់ អ្នកចូរបង្អង់ ៧ ឆ្នាំ សិន លុះអំណើះ ៧ ឆ្នាំទៅ យើងទាំងពីរនាក់នឹងចេញចាកផ្ទះទៅបួស ក្នុងសាសនា ។ អនុរុទ្ធសក្កៈឆ្លើយតបថា ម្នាលសម្លាញ់ ៧ ឆ្នាំនោះ យូរណាស់ ខ្ញុំមិនអាចនឹងបង្អង់ចាំដល់ ៧ ឆ្នាំទេ ។ ព្រះភទ្ទិយសក្យ-រាជឆ្លើយថា ម្នាលសម្លាញ់ អ្នកចូររង់ចាំ ៦ ឆ្នាំចុះ ។ បេ ។ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំចុះ លុះអំណើះ ១ ឆ្នាំទៅ យើងទាំងពីរនាក់ នឹងចេញចាកផ្ទះទៅបួសក្នុងសាសនា ។ អនុរុទ្ធសក្កៈបបួលទៀតថា ម្នាលសម្លាញ់ ១ ឆ្នាំនោះ យូរពេកណាស់ ខ្ញុំមិនអាចនឹងរង់ចាំទៅដល់ ១ ឆ្នាំបានទេ ។ ព្រះភទ្ទិយសក្យរាជអង្វរទៀតថា ម្នាលសម្លាញ់ អ្នក ចូរបង្អង់ ៧ ខែចុះ លុះអំណើះ ៧ ខែទៅ យើងទាំងពីរនាក់នឹងចេញ

ចាកផ្ទះទៅបួសក្នុងសាសនា ។ អនុរុទ្ធសក្កៈតបថា ម្នាលសម្លាញ់ ៧ ខែនោះ យូរណាស់ ខ្ញុំមិនអាចនឹងរង់ចាំដល់ទៅ ៧ ខែបានទេ ។ ព្រះភទ្ទិយសក្យរាជអង្វរថា ម្នាលសម្លាញ់ អ្នកចូរបង្អង់ដល់ ៦ ខែ ។ បេ ។ ៥ ខែ ៤ ខែ ៣ ខែ ២ ខែ ១ ខែ កន្លះខែចុះ លុះអំណឹះកន្លះខែទៅ សឹមយើងទាំងពីរនាក់ចេញចាកផ្ទះទៅបួសក្នុងសាសនា ។ អនុរុទ្ធសក្កៈតបទៀតថា ម្នាលសម្លាញ់ កន្លះខែយូរពេកណាស់ ខ្ញុំមិនអាចនឹងរង់ចាំដល់កន្លះខែបានទេ ។ ព្រះភទ្ទិយសក្យរាជអង្វរចុះមកទៀតថា ម្នាលសម្លាញ់ អ្នកចូរបង្អង់ ៧ ថ្ងៃសិន ទម្រាំតែខ្ញុំនឹងប្រគល់រាជសម្បត្តិឲ្យកូន ឬបងប្អូន ។ អនុរុទ្ធសក្កៈទទួលព្រមថា ម្នាលសម្លាញ់ ៧ ថ្ងៃនោះ មិនជាយូរប៉ុន្មានទេ ខ្ញុំនឹងរង់ចាំបាន ។

គ្រានោះឯង ( ពួកសក្យៈទាំង ៦ អង្គ ) គឺភទ្ទិយសក្យរាជ ១ អនុរុទ្ធ ១ អានន្ទ ១ ភគ្គុ ១ កិមិលៈ ១ ទេវទត្ត ១ ជាគំរប់ ៧ នាក់ នឹងខ្មាន់ព្រះកេស ឈ្មោះឧបាលិ ចេញទៅកាន់ឧទ្យានមួយអន្លើដោយសេនាមានអង្គ ៤ ក្នុងកាលពីដើម យ៉ាងណា សក្យរាជទាំងនោះ យាងចេញទៅ ( ដើម្បីបព្វជ្ជា មួយអន្លើ ) ដោយសេនាមានអង្គ ៤ ក៏យ៉ាងនោះដែរ ។ សក្យៈទាំងនោះ លុះយាងទៅដល់ទីឆ្ងាយ ទើបឲ្យសេនាវិលមកវិញ លុះចូលទៅដល់ដែនដទៃហើយ ទើបដោះគ្រឿងប្រដាប់វេចជាបង្វេចដោយព្រះពស្ត្រសម្រាប់ពានា រួចហើយទើបមានព្រះបន្ទូល

ទៅនឹងខ្នាន់ព្រះកេស ឈ្មោះឧបាលិថា នៃនាយឧបាលិ ណ្ហើយនាយឧបាលិ ចូរអ្នកឯងវិលទៅវិញចុះ ទ្រព្យប៉ុណ្ណោះ ក៏ល្មមនឹងចិញ្ចឹមជីវិតរបស់អ្នកបានហើយ ។

គ្រានោះឯង កាលឧបាលិកប្បកៈកំពុងតែដើរវិលមកវិញ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកសក្យៈសុទ្ធតែជាអ្នកកាច ៗ នឹងសម្លាប់អញក៏បាន ព្រោះគិតថា ឧបាលិកប្បកៈនេះហើយ សម្លាប់ព្រះរាជកុមារអម្បាលសក្យកុមារទាំងឡាយ ម្តេចគង់ចេញចាកអគារដ្ឋានទៅបួសក្នុងសាសនាបាន ចំណាំងបើអញនឹងបាច់និយាយទៅថ្វី ។ ឧបាលិកប្បកៈនោះ ក៏ស្រាយបង្វេចចេញ ហើយព្យួររបស់នោះ លើដើមឈើ ទើបនិយាយថា បើអ្នកណាឃើញ ចូររើសយករបស់ដែលអញឲ្យហើយចុះ ហើយដើរចូលទៅរកពួកសក្យកុមារវិញ ។ ពួកសក្យកុមារទាំងនោះបានឃើញឧបាលិកប្បកៈកំពុងដើរមកអំពីចម្ងាយហើយ ទើបនិយាយទៅនឹងឧបាលិកប្បកៈយ៉ាងនេះថា នៃនាយឧបាលិ ហេតុដូចម្តេចបានជាអ្នកវិលមកវិញ ។ ឧបាលិកប្បកៈក៏ក្រាបទូលថា បពិត្រព្រះអយ្យបុត្តកាលដែលខ្ញុំព្រះអង្គវិលអំពីទីនេះទៅ ក៏ភ្នកមានសេចក្តីត្រិះរិះដូច្នេះថា ពួកសក្យរាជសុទ្ធតែកាច ៗ នឹងសម្លាប់ខ្ញុំព្រះអង្គចោលក៏បាន ព្រោះគិតថា ខ្ញុំព្រះអង្គនេះហើយ ដែលសម្លាប់ព្រះរាជកុមារ អម្បាលពួកសក្យកុមារនេះ (ម្តេចក៏) ចេញចាកអគារដ្ឋានទៅបួសក្នុងសាសនា

ចុះនឹងចាំស្តីទៅថ្វីដល់ខ្លួនខ្ញុំព្រះអង្គ បពិត្រព្រះអយ្យបុត្ត ខ្ញុំព្រះអង្គស្រាយបង្វេចចេញ ហើយព្យួររបស់នោះលើដើមឈើ ហើយនិយាយថា បើអ្នកណាឃើញ ចូររើសយករបស់ដែលអញឲ្យហើយចុះ ខ្ញុំព្រះអង្គក៏វិលអំពីទីនោះមកវិញ ។ ពួកសក្យកុមារនិយាយថា នែនាយឧបាលិ ដែលអ្នកត្រឡប់មកវិញនោះ ឈ្មោះថា បានធ្វើប្រពៃហើយ ដ្បិតពួកសក្យៈកាច ៗ ណាស់ នឹងសម្លាប់អ្នកចោល ក៏បាន ព្រោះគិតថា អ្នកនេះហើយ ជាអ្នកសម្លាប់ព្រះរាជកុមារទាំងឡាយ ។

គ្រានោះ ពួកសក្យកុមារទាំងនោះ នាំឧបាលិកប្បកៈចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំចំពោះព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ ពួកសក្យកុមារទាំងនោះលុះអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលសេចក្តីនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំជាសក្យរាជ តែងមានមានះ បពិត្រព្រះអង្គដ៏ចម្រើន ឧបាលិកប្បកៈនេះ ជាអ្នកធ្លាប់បម្រើយើងខ្ញុំអស់កាលជាអង្វែងមកហើយ សូមព្រះមានព្រះភាគបំបួសឧបាលិ-កប្បកៈនេះមុន យើងខ្ញុំនឹងធ្វើនូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម និងសាមីចិកម្ម ចំពោះឧបាលិកប្បកៈនេះ កាលបើយើងខ្ញុំបានធ្វើយ៉ាងនេះហើយ សេចក្តីប្រកាន់ថា ខ្លួនយើងខ្ញុំជាសក្យៈនោះ នឹងថយចុះទៅ ។ លំដាប់នោះឯង ព្រះមានព្រះភាគបានបំបួសឧបាលិកប្បកៈមុន ហើយ

*ទើបបំបួសពួកសក្យកុមារទាំងនោះក្រោយ ។*

*គ្រានោះ ព្រះភទ្ទិយៈដ៏មានអាយុ បានសម្រេចនូវវិជ្ជាបីយ៉ាងខាង ក្នុងនៃវស្សានោះឯង ។ ព្រះអនុរុទ្ធដ៏មានអាយុបានសម្រេចទិព្វចក្ខុ ។ ព្រះអានន្ទដ៏មានអាយុបានសម្រេចសោតាបត្តិផល ។ ឯទេវទត្តបាន សម្រេចឫទ្ធិជារបស់បុថុជ្ជន[១] ។*

*សមដូចគាថាដែលលោកពោលទុកក្នុងអបទានថា*

សុមេធំ ភគវន្តាហំ លោកជេដ្ឋំ នរាសភំ
វូបកដ្ឋំ វិហរន្តំ អទ្ទសំ លោកនាយកំ ។

*ខ្ញុំបានឃើញព្រះមានព្រះភាគ ទ្រង់ព្រះនាមសុមេធៈ ជា ច្បងក្នុងលោក ជានរាសភៈ ជាលោកនាយក ទ្រង់ចេញ ចាកគណៈ ហើយគង់នៅតែមួយអង្គឯង ។*

ឧបគន្ត្វាន សម្ពុទ្ធំ សុមេធំ លោកនាយកំ
អញ្ជលឹ បគ្គហេត្វាន ពុទ្ធសេដ្ឋំ អយាចហំ ។

*ទើបខ្ញុំចូលទៅជិតព្រះសុមេធសម្ពុទ្ធ ជាលោកនាយក ហើយផ្គងអញ្ជលីអារាធនាព្រះសម្ពុទ្ធដ៏ប្រសើរថា*

អនុកម្ប មហាវីរ លោកជេដ្ឋ នរាសភ
បទីបន្តេ បទស្សាមិ រុក្ខមូលម្ហិ ឈាយតោ ។

---

*១-បិ.១១ ទំ.១-១០ យ.១-៨ ។*

*បពិត្រព្រះអង្គ ទ្រង់មានព្យាយាមធំ ជាច្បងក្នុងលោក ជានរាសភៈ សូមព្រះអង្គអនុគ្រោះ ខ្ញុំព្រះអង្គសូមថ្វាយប្រទីបដល់ព្រះអង្គ ដែលទ្រង់ចម្រើនឈាន ក្បែរគល់ឈើ ។*

**អធិភាសេសិ សោ ធីរោ សយម្ភូ វទតំ វរោ**
**ទុមេសុ វិធិវិជ្ឈិត្វា យន្តំ យោជេត្វហន្តជា ។**

*ព្រះសយម្ភូជាអ្នកប្រាជ្ញ ប្រសើរជាងពួកអ្នកប្រាជ្ញនោះ ទ្រង់បានទទួលហើយ ក្នុងវេលានោះ ខ្ញុំបានទម្លុះឈើទាំងឡាយ ដើម្បីប្រកបនូវប្រទីប ។*

**សហស្សវដ្ដិចាជាសិ ពុទ្ធស្ស លោកពន្ធុនោ**
**សត្តាហំ បជ្ជលិត្វាន បឌីបា វូបសម្មិសុំ ។**

*មិនតែប៉ុណ្ណោះ ខ្ញុំបានថ្វាយប្រឆេះចង្កៀងមួយពាន់ ដល់ព្រះសម្ពុទ្ធជាលោកពន្ធុ ឯប្រទីបទាំងឡាយ ក៏ឆេះរុងរឿងឡើងអស់ ៧ ថ្ងៃហើយ ទើបរលត់ទៅវិញ ។*

**តេន ចិត្តប្បសាទេន ចេតនាបណិធីហិ ច**
**ជហិត្វា មានុសំ ទេហំ វិមានំ ឧបបជ្ជហំ ។**

*លុះខ្ញុំលះរាងកាយ ជារបស់មនុស្សហើយ ទៅកើតក្នុងវិមាន ( ឋានសួគ៌ ) ដោយចិត្តជ្រះថ្លានោះផង ដោយការតាំងចេតនានោះផង ។*

**ឧបបន្នស្ស ទេវត្តំ ព្យម្ហា អាសិ សុនិម្មិតោ**
**សមន្តតោ បជ្ជលតិ ទីបទានស្សិទំ ផលំ ។**

*កាលដែលខ្ញុំទៅកើតជាទេវតាហើយ មានប្រាសាទដែលបុញ្ញកម្មតាក់តែងដោយល្អ ភ្លឺរុងរឿងដោយជុំវិញ នេះជាផលនៃការថ្វាយនូវប្រទីប ។*

**អដ្ឋវីសតិក្ខត្តុញ្ច ចក្កវត្តិ អហោសហំ**
**ទិវារត្តិញ្ច បស្សាមិ សមន្តា យោជនន្តទា ។**

*ខ្ញុំកើតជាស្តេចចក្កពត្តិអស់ ២៨ ដង បានឃើញរូប ចម្ងាយ ១ យោជន៍ជុំវិញ ទាំងថ្ងៃទាំងយប់ក្នុងកាលនោះ ។*

**សមន្តា យោជនំ សព្វំ វិរោចេមិ អហំ តទា**
**សព្វេ ទេវេ អភិភោមិ ទីបទានស្សិទំ ផលំ ។**

*ខ្ញុំតែងធ្វើនូវទិសទាំងពួង ចម្ងាយ ១ យោជន៍ ដោយជុំវិញឲ្យភ្លឺរុងរឿង ក្នុងកាលនោះ ខ្ញុំគ្របសង្កត់ទេវតាទាំងអស់ នេះជាផលនៃការថ្វាយប្រទីប ។*

**តឹសកប្បានិ ទេវិន្ទោ ទេវេ រជ្ជមការយឹ**
**ន មំ កេចាតិមញ្ញន្តិ ទីបទានស្សិទំ ផលំ ។**

*ខ្ញុំជាធំជាងទេវតា បានសោយរាជ្យក្នុងពួកទេវតា អស់ ៣០ កប្ប ឥតមានពួកទេវតាណា មើលងាយខ្ញុំបានឡើយ*

*នេះជាផលនៃការថ្វាយនូវប្រទីប ។*

**សហស្សលោកំ ញាណេន បស្សាមិ សត្ថុសាសនេ**
**ទិព្វចក្ខុំ អនុប្បត្តោ ទីបទានស្សិទំ ផលំ ។**

*ខ្ញុំបានសម្រេចទិព្វចក្ខុ ក្នុងសាសនានៃព្រះសាស្តា តែងឃើញលោកធាតុមួយពាន់ដោយញាណ នេះជាផលនៃការថ្វាយនូវប្រទីប ។*

**សុមេធោ នាម សម្ពុទ្ធោ តឹសកប្បសហស្សិតោ**
**តស្ស ទីបោ មយា ទិន្នោ វិប្បសន្នេន ចេតសា ។**

*ព្រោះតែខ្ញុំបានថ្វាយប្រទីប ដោយចិត្តជ្រះថ្លា ដល់ព្រះសម្ពុទ្ធព្រះនាមសុមេធៈ ទ្រង់កើតក្នុងកាល ៣០ ពាន់កប្បនោះ ។*

**បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ**
**ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។**

*បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ [១] ។*

*ក្នុងកាលតមក ព្រះសាស្តាគង់ក្នុងកណ្តាលពួកព្រះអរិយៈ ក្នុងវត្ត*

---

*១-បិ.៧២ ទំ.៨០-៨២ ឃ.៦ ។*

ជេតពនមហាវិហារ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈ នៃភិក្ខុទាំងឡាយ ខាងមានចក្ខុទិព្វថា

**ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ទិព្វចក្ខុកានំ យទិទំ អនុរុទ្ធោ** ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកមានទិព្វចក្ខុ ដែលជាសាវ័ករបស់តថាគត ស្រេចនឹងអនុរុទ្ធ ប្រសើរជាងគេ[១] ។

ព្រះថេរៈសោយវិមុត្តិសុខ ថ្ងៃមួយ ពិចារណាដល់បដិបទារបស់ខ្លួនហើយ កើតបីតិសោមនស្ស បានពោលគាថាដោយអំណាចឧទាន ជាដើមថា **បហាយ មាតាបិតរោ** (ខ្ញុំ) លះបង់នូវមាតាបិតា ដូច្នេះ ។ ឯអាចារ្យពួកខ្លះពោលថា ព្រះសង្គីតិកាចារ្យទាំងឡាយ កាលប្រកាសបព្វជ្ជានិងការសម្រេចអរហត្តរបស់ព្រះថេរៈ បានពោល ៤ គាថាខាងដើម គាថាបន្ទាប់អំពីនោះ ព្រះមានព្រះភាគទ្រង់មានព្រះហឫទ័យសរសើរអរិយវង្សប្បដិបត្តិរបស់ព្រះថេរៈ ទើបត្រាស់ ។ ឯគាថាក្រៅអំពីនេះ ព្រះថេរៈពោលតាមហេតុការណ៍នោះៗ ។ ដូច្នោះគាថាទាំងនេះ ព្រះថេរៈពោលផង ព្រះមានព្រះភាគត្រាស់ដោយចំពោះដល់ព្រះថេរៈផង ។ គប្បីជ្រាបថា ជាគាថារបស់ព្រះថេរៈដោយប្រការទាំងពួង គឺលោកពោលគាថាទាំងនេះថា

**បហាយ មាតាបិតរោ ភគិនី ញាតិភាតរោ**

---

១-បិ.៤០ ទំ.៥៣ ឃ.១៤៦ ។

បញ្ច កាមគុណេ ហិត្វា     អនុរុទ្ធោ ឈាយតិ ។

*អនុរុទ្ធ បានលះបង់នូវមាតា បិតា បងប្អូនស្រី ញាតិ និង បងប្អូនប្រុសទាំងឡាយ លះបង់នូវកាមគុណ ៥ ហើយ ចម្រើននូវឈាន ។*

សមេតោ នច្ចគីតេហិ     សម្មតាឡប្បពោធនោ
ន តេន សុទ្ធិមជ្ឈគមា     មារស្ស វិសយេ រតោ ។

*( ក្នុងកាលមុន ) អនុរុទ្ធ ជាអ្នកបរិបូណ៌ដោយរបាំ និង ចម្រៀង ភ្ញាក់រឭកដោយគ្រឿងប្រគំ ជាអ្នកត្រេកអរតែក្នុង វិស័យរបស់មារ ក៏មិនបានដល់នូវសេចក្តីបរិសុទ្ធ ដោយ ហេតុនោះ ។*

ឯតញ្ច សមតិក្កម្ម     រតោ ពុទ្ធស្ស សាសនេ
សព្វោឃំ សមតិក្កម្ម     អនុរុទ្ធោ ឈាយតិ ។

*( ឥឡូវនេះ ) អនុរុទ្ធ បានកន្លងនូវវិស័យរបស់មារនុ៎ះ ហើយត្រេកអរក្នុងសាសនារបស់ព្រះពុទ្ធ បានឆ្លងផុតនូវ ឱឃៈទាំងពួង ចម្រើនឈាន ។*

រូបា សទ្ទា រសា គន្ធា     ផោដ្ឋព្វា ច មនោរមា
ឯតេ ច សមតិក្កម្ម     អនុរុទ្ធោ ឈាយតិ ។

*អនុរុទ្ធបានកន្លងនូវរូប សំឡេង ក្លិន រស ផ្សព្វ ជាទីគាប់*

*ចិត្តទាំងនុ៎ះ ចម្រើនឈាន ។*

**បិណ្ឌបាតបតិក្កន្តោ ឯកោ អទុតិយោ មុនិ**
**ឯសតិ បំសុកូលានិ អនុរុទ្ធោ អនាសវោ ។**

*អនុរុទ្ធ ជាបុគ្គលម្នាក់ឯង មិនមានតណ្ហាជាគម្រប់ពីរ ជាអ្នកប្រាជ្ញ មិនមានអាសវៈ ត្រឡប់អំពីបិណ្ឌបាត ស្វែងរកនូវចីវរបង្សុកូលទាំងឡាយ ។*

**វិចិនិ អគ្គហី ធោវិ រជយី ធារយី មុនិ**
**បំសុកូលានិ មតិមា អនុរុទ្ធោ អនាសវោ ។**

*អនុរុទ្ធ ជាអ្នកប្រាជ្ញ មានយោបល់ មិនមានអាសវៈ រើសកាន់យក គក់លាង ជ្រលក់ ប្រើប្រាស់នូវចីវរបង្សុកូលទាំងឡាយ ។*

**មហិច្ឆោ ច អសន្តុដ្ឋោ សំសដ្ឋោ យោ ច ឧទ្ធតោ**
**តស្ស ធម្មា ឥមេ ហោន្តិ បាបកា សង្កិលេសិកា ។**

*បុគ្គលណា មានសេចក្តីប្រាថ្នាច្រើន មិនមានសន្តោស ជាអ្នកច្រឡំដោយពួក មានចិត្តរាយមាយ ធម៌ដ៏លាមក ជាគ្រឿងសៅហ្មងទាំងនេះ តែងកើតមានដល់បុគ្គលនោះ ។*

**សតោ ច ហោតិ អប្បិច្ឆោ សន្តុដ្ឋោ អវិឃាតវា**
**បវិវេករតោ វិត្តោ និច្ចមារទ្ធវីរិយោ ។**

*បុគ្គលណា ជាអ្នកមានស្មារតី មានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស មិនមានចិត្តបង្វៀតបង្វល់ ត្រេកអរក្នុងទីស្ងាត់ ជាអ្នកស្ងាត់ មានការព្យាយាមតឹងតែងជានិច្ច ។*

**តស្ស ធម្មា ឥមេ ហោន្តិ កុសលា ពោធិបក្ខិកា**
**អនាសវោ ច សោ ហោតិ ឥតិ វុត្តំ មហេសិនា ។**

*ធម៌ជាកុសល ជាចំណែកនៃការត្រាស់ដឹងទាំងនេះ តែងកើតមានដល់បុគ្គលនោះ ព្រះពុទ្ធជាមហេសី ទ្រង់ត្រាស់ថា បុគ្គលនោះ ជាអ្នកមិនមានអាសវៈ ។*

**មម សង្កប្បមញ្ញាយ សត្ថា លោកេ អនុត្តរោ**
**មនោមយេន កាយេន ឥទ្ធិយា ឧបសង្កមិ ។**

*ព្រះសាស្តា ជាបុគ្គលប្រសើរក្នុងលោក ទ្រង់ជ្រាបនូវសេចក្តីត្រិះរិះរបស់ខ្ញុំ ក៏យាងមកដោយឫទ្ធិ ដោយព្រះកាយដែលសម្រេចអំពីចិត្ត ។*

**យទា មេ អហុ សង្កប្បោ តតោ ឧត្តរឹ ទេសយិ**
**និប្បបញ្ចរតោ ពុទ្ធោ និប្បបញ្ចមទេសយិ ។**

*ខ្ញុំមានសេចក្តីត្រិះរិះក្នុងកាលណា ព្រះសាស្តាទ្រង់បានសម្តែងនូវធម៌ ( មហាបុរិសវិតក្កៈ ) ដ៏លើសលុប ក្នុងកាលនោះ ព្រះពុទ្ធទ្រង់ត្រេកអរក្នុងធម៌ ដែលមិនមានដំណើរ*

*យឺតយូរ សម្ដែងនូវធម៌ដែលមិនមានដំណើរយឺតយូរ ។*

តស្សាហំ ធម្មមញ្ញាយ វិហាសឹ សាសនេ រតោ
តិស្សោ វិជ្ជា អនុប្បត្តា កាតំ ពុទ្ធស្ស សាសនំ ។

*ខ្ញុំដឹងនូវធម្មទេសនារបស់ព្រះសាស្ដានោះហើយ ត្រេកអរក្នុងសាសនា វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ពុទ្ធសាសនាខ្ញុំបានធ្វើហើយ ។*

បញ្ចបញ្ញាស វស្សានិ យតោ នេសជ្ជិកោ អហំ
បញ្ចវីសតិ វស្សានិ យតោ មិទ្ធំ សមូហតំ ។

*ខ្ញុំបានសមាទាននេសជ្ជិកង្គធុតង្គ អស់ ៥៥ ឆ្នាំ ខ្ញុំបានដកវំលើង នូវកិរិយាងោកងុយអស់ ២៥ ឆ្នាំហើយ ។*

( *ព្រះអនុរុទ្ធប្រកាស ក្នុងវេលាដែលព្រះមានព្រះភាគបរិនិព្វានដោយគាថានេះថា* )

នាហុ អស្សាសបស្សាសា ឋិតចិត្តស្ស តាទិនោ
អនេជោ សន្តិមារព្ភ ចក្ខុមា បរិនិព្វុតោ ។

*ព្រះពុទ្ធព្រះអង្គជាបុគ្គលនឹងធឹង មានព្រះទ័យខ្ជាប់ខ្ជួនមិនមានខ្យល់អស្សាសបស្សាសៈហើយ ព្រះពុទ្ធមានចក្ខុមិនមានកិលេសជាគ្រឿងញាប់ញ័រ ទ្រង់ប្រារព្ធនូវសេចក្ដីស្ងប់ បរិនិព្វានហើយ ។*

**អសល្លីនេន ចិត្តេន វេទនំ អជ្ឈវាសយិ**
**បជ្ជោតស្សេវ និព្វានំ វិមោក្ខោ ចេតសោ អហុ ។**

*ព្រះពុទ្ធទ្រង់អត់សង្កត់នូវវេទនា ដោយព្រះទ័យមិនរួញរា ការផុតស្រឡះនៃចិត្ត (របស់ព្រះអង្គ) ដូចជាកិរិយារលត់នៃប្រទីប ។*

**ឯតេ បច្ឆិមកា ទានិ មុនិនោ ផស្សបញ្ចមា**
**នាញ្ញេ ធម្មា ភវិស្សន្តិ សម្ពុទ្ធេ បរិនិព្វុតេ ។**

*សភាវៈមានផស្សៈជាគម្រប់ ៥ របស់ព្រះពុទ្ធ ជាអ្នកប្រាជ្ញ នុ៎ះ មានក្នុងទីបំផុត ក្នុងកាលឥឡូវនេះហើយ នាកាលព្រះសម្ពុទ្ធទ្រង់បរិនិព្វានហើយ ធម៌ដទៃ គឺចិត្តនិងចេតសិកមិនមានទៀតទេ ។*

*(ព្រះអនុរុទ្ធពោលតបនឹងទេវតាដែលមករកថា)*

**នត្ថិ ទានិ បុនាវាសោ ទេវកាយស្មិ ជាលិនិ**
**វិក្ខីណោ ជាតិសំសារោ នត្ថិ ទានិ បុនព្ភវោ ។**

*ម្នាលទេវតា ឈ្មោះជាលិនី ឥឡូវនេះ (អាត្មា) មិនមានការអាស្រ័យនៅក្នុងពួកទេវតាទៀតឡើយ ជាតិសង្សាររបស់អាត្មាក៏អស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទេ ។*

*(ព្រះអនុរុទ្ធពោលនឹងសព្រហ្មចារីថា)*

យស្ស មុហុត្តេន សហស្សធា លោកោ
សំវិទិតោ សព្រហ្មកប្បោ
វសី ឥទ្ធិគុណេ ចុតូបបាតេ
កាលេ បស្សតិ ទេវតា ស ភិក្ខុ ។

*ភិក្ខុណា អាចដឹងច្បាស់នូវលោក មានចំណែកមួយពាន់ ព្រមទាំងព្រហ្មលោក ក្នុងមួយរំពេចបាន ភិក្ខុនោះ ជាអ្នកស្ទាត់ក្នុងឥទ្ធិគុណ ក្នុងចុតូបបាតញ្ញាណ រមែងឃើញពួកទេវតា ក្នុងកាលគួរ ។*

អន្នភារោ បុរេ អាសឹ ទលិទ្ទោ ឃាសហារកោ
សមណំ បដិបាទេសឹ ឧបរិដ្ឋំ យសស្សិនំ ។

*ក្នុងកាលមុន ខ្ញុំបានកើតជាបុរសកម្សត់ ឈ្មោះអន្នភារៈ ជាអ្នកធ្វើការឈ្នួល ដើម្បីអាហារ បានផ្គត់ផ្គង់សមណៈ (ព្រះបច្ចេកពុទ្ធ) ឈ្មោះឧបរិដ្ឋៈ ជាអ្នកមានយស ។*

សោម្ហិ សក្យកុលេ ជាតោ អនុរុទ្ធោតិ មំ វិទូ
ឧបេតោ នច្ចគីតេហិ សម្មតាឡប្បពោធនោ ។

*ពួកជនអ្នកចេះដឹង តែងស្គាល់ខ្ញុំថា ខ្ញុំនោះឈ្មោះអនុរុទ្ធ កើតក្នុងសក្យត្រកូល ជាអ្នកបរិបូណ៌ដោយរបាំ និងចម្រៀង ភ្ញាក់រឭកដោយគ្រឿងប្រគំ ។*

អជ្ឈសាសឹ សម្ពុទ្ធំ សត្ថារំ អកុតោភយំ
តស្មឹ ចិត្តំ បសាទេត្វា បព្វជឹ អនគារិយំ ។

*ខ្ញុំបានឃើញព្រះសម្ពុទ្ធ ជាសាស្ដា មិនមានភ័យអំពីទីណា ក៏ញុំាងចិត្តឲ្យជ្រះថ្លា ក្នុងព្រះសម្ពុទ្ធនោះ ហើយចូលទៅកាន់ផ្នួស ។*

បុព្វេនិវាសំ ជានាមិ យត្ថ មេ វុសិតំ បុរេ
តាវត្តឹសេសុ ទេវេសុ អដ្ឋាសឹ សក្កជាតិយា ។

*ខ្ញុំដឹងនូវបុព្វេនិវាស ដែលជាលំនៅរបស់អាត្មា ធ្លាប់នៅក្នុងកាលមុន ក្នុងទេវលោកឈ្មោះតាវត្តិង្ស បានឋិតនៅក្នុងជាតិជាសក្កៈ ( ព្រះឥន្ទ ) ។*

សត្តក្ខត្តុំ មនុស្សិន្ទោ អហំ រជ្ជមការយឹ
ចាតុរន្តោ វិជិតាវី ជម្ពុសណ្ឌស្ស ឥស្សរោ
អទណ្ឌេន អសត្ថេន ធម្មេន អនុសាសយឹ ។

*អាត្មាបានជាធំក្នុងមនុស្ស សោយរាជ្យអស់ ៧ ជាតិ ជាធំលើផែនដី មានសមុទ្ទទាំងបួនជាទីបំផុត មានជ័យជម្នះជាឥស្សរៈក្នុងជម្ពូទ្វីប ប្រៀនប្រដៅ ( ប្រជាជន ) ដោយធម៌ មិនប្រើដំបងនិងគ្រឿងសស្ត្រា ។*

ឥតោ សត្ត ឥតោ សត្ត សំសារានិ ចតុទ្ទស

**និវាសមភិជានិស្សំ ទេវលោកេ ឋិតោ តទា ។**

*កាលនោះ ខ្ញុំបានឋិតនៅក្នុងទេវលោក ដឹងច្បាស់នូវខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន អស់ ១៤ សង្សារវដ្ត (១៤ ជាតិ) គឺខាងទេវលោកនេះ ៧ ជាតិ ខាងមនុស្សលោកនេះ ៧ ជាតិ ។*

**បញ្ចង្គិកេ សមាធិម្ហិ សន្តេ ឯកោទិភាវិតេ**
**បដិប្បស្សទ្ធិលទ្ធម្ហិ ទិព្វចក្ខុំ វិសុជ្ឈិ មេ ។**

*កាលសមាធិប្រកបដោយអង្គ ៥ ខ្ញុំបានចម្រើនឲ្យមានអារម្មណ៍មូលតែមួយហើយ ខ្ញុំក៏បានសេចក្តីស្ងប់រម្ងាប់ ទិព្វចក្ខុរបស់ខ្ញុំក៏បរិសុទ្ធិ ។*

**ចុតូបបាតំ ជានាមិ សត្តានំ អាគតឹ គតឹ**
**ឥត្ថភាវញ្ញថាភាវំ ឈានេ បញ្ចង្គិកេ ឋិតោ ។**

*ខ្ញុំលុះបានឋិតនៅក្នុងឈានប្រកបដោយអង្គ ៥ ហើយ ក៏ដឹងនូវការច្យុតនិងការកើត គឺដំណើរមក និងដំណើរទៅ (ព្រមទាំង) ការកើតឡើងយ៉ាងនេះ និងការប្រែប្រួលទៅជាយ៉ាងដទៃ របស់សត្វទាំងឡាយ ។*

**បរិចិណ្ណោ មយា សត្ថា កតំ ពុទ្ធស្ស សាសនំ**
**ឱហិតោ គរុកោ ភារោ ភវនេត្តិ សមូហតា ។**

*ព្រះសាស្តា ខ្ញុំបានបម្រើហើយ ព្រះពុទ្ធសាសនា ខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់គឺខន្ធ ខ្ញុំបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំបានដកចោលហើយ ។*

**វជ្ជីនំ វេឡុវគាមេ អហំ ជីវិតសង្ខយា**
**ហេដ្ឋតោ វេឡុគុម្ពស្មឹ និព្វាយិស្សំ អនាសវោ ។**

*ខ្ញុំជាបុគ្គលមិនមានអាសវៈ លុះអស់ជីវិត ខ្ញុំនឹងនិព្វានក្រោមគុម្ពឫស្សី ក្នុងវេឡុវគ្រាម របស់ពួកជនអ្នកនៅក្នុងដែនវជ្ជី [១] ។*

*៣ គាថា មានពាក្យថា ព្រះពុទ្ធព្រះអង្គជាបុគ្គលនឹងធឹង មានព្រះទ័យខ្ជាប់ខ្ជួន មិនមានខ្យល់អស្សាសបស្សាសៈហើយនេះជាដើម ព្រះថេរៈត្រូវភិក្ខុទាំងឡាយសួរ ក្នុងកាលដែលព្រះសាស្តាទ្រង់បរិនិព្វានថា ព្រះមានព្រះភាគបរិនិព្វានហើយឬ កាលនឹងប្រកាសភាវៈនៃកិរិយាបរិនិព្វាន ទើបពោលគាថានេះ ។*

*បានឮថា ទេវតានោះ ជាភរិយា ( បាទបរិចារិកា ) របស់ព្រះថេរៈក្នុងជាតិមុន ព្រោះហេតុនោះ ទេវតានោះ ឃើញព្រះថេរៈចាស់ជរាហើយ ដោយសេចក្តីស្រឡាញ់ដែលមានក្នុងកាលមុន ទើបមកអង្វរសូមឲ្យកើតក្នុងទេវតាថា សូមលោកម្ចាស់តាំងចិត្តក្នុងទេវនិកាយ ដែលលោកម្ចាស់*

---

*១-បិ.៥៧ ទំ.៧៥-៧៨ ឃ.២៥៧ ។*

ធ្លាប់នៅក្នុងកាលមុន ។ លំដាប់នោះ ព្រះថេរៈបានឲ្យចម្លើយដល់ទេវតានោះ ដោយពាក្យជាដើមថា ម្នាលទេវតា ឈ្មោះជាលិនី ឥឡូវនេះ ( អាត្មា ) មិនមានការអាស្រ័យនៅក្នុងពួកទេវតាទៀតឡើយ ។ ទេវតាបានស្តាប់ដូច្នោះ ក៏អស់សង្ឃឹម អន្តរធានទៅក្នុងទីនោះឯង ។

លំដាប់នោះ ព្រះថេរៈហោះទៅកាន់អាកាស កាលនឹងប្រកាសនូវអានុភាពរបស់ខ្លួនដល់សព្រហ្មចារីទាំងឡាយ ទើបពោលគាថាថា ភិក្ខុណា អាចដឹងច្បាស់នូវលោក មានចំណែកមួយពាន់ដូច្នេះជាដើម ។ អត្ថនៃពាក្យដែលជាគាថានោះ មានដូច្នេះថា ភិក្ខុជាព្រះខីណាស្រពដឹងច្បាស់ ដឹងបានដោយប្រពៃ បានដល់ ធ្វើឲ្យប្រចក្សនូវលោក ព្រមទាំងព្រហ្មលោក មានប្រការនៃសហស្សៈ ( មួយពាន់ចក្កវាឡ ) ផ្សេងដោយតិសហស្សី មហាសហស្សី ( សែនកោដិចក្កវាឡ ) ដោយកាលត្រឹមមួយរំពេចប៉ុណ្ណោះ ភិក្ខុនោះ ជាអ្នកដល់នូវភាពជំនាញក្នុងឥទ្ធិគុណ គឺការដល់ព្រមដោយឥទ្ធិ និងក្នុងចុតិបដិសន្ធិដោយប្រការដូច្នេះ រមែងឃើញទេវតា ក្នុងពេលមករក គឺមិនភ្ញាំងភ្ញាត់ក្នុងការឃើញទេវតាទាំងឡាយ ។

ឥឡូវនេះ ព្រះថេរៈកាលសម្តែងអាការដែលខ្លួនបានទិព្វចក្ខុញ្ញាណនិងចុតូបបាតញ្ញាណ ទើបពោល ២ គាថា ដោយន័យថា សមាធិប្រកបដោយអង្គ ៥ ជាដើម ។

ព្រះថេរៈ កាលសម្តែងវិជ្ជា ៣ យ៉ាងនេះហើយ កាលនឹងសម្តែង

វិជ្ជាទី ៣ ដែលលោកបានសម្តែងទុកក្នុងកាលមុនហើយ ដោយមានការទាក់ទងនឹងវិជ្ជា ៣ នោះ ព្រមទាំងការសម្រេចនៃកិច្ច ទើបពោល ២ គាថាដោយន័យថា ព្រះសាស្តា ខ្ញុំបានបម្រើហើយជាដើម ។

ថ្ងៃមួយ ព្រះថេរៈពិចារណាថា អញធ្វើកម្មអ្វីហ្ន៎ ទើបបានសម្បត្តិនេះ ក៏បានដឹងថា បានតាំងសេចក្តីប្រាថ្នាទុកទៀបបាទមូលរបស់ព្រះសម្មាសម្ពុទ្ធព្រះនាមបទុមុត្តរៈ ហើយដឹងបន្តទៀតថា អាត្មាអញអន្ទោលទៅក្នុងសង្សារអស់កាលឈ្មោះនោះ អាស្រ័យសុមនសេដ្ឋីក្នុងក្រុងពារាណសី ចិញ្ចឹមជីវិត ឈ្មោះអន្នភារៈ ក្នុងកាលឈ្មោះនោះ ដូច្នេះហើយ ទើបពោលគាថានេះថា

**អន្នភារោ បុរេ អាសឹ ទលិទ្ទោ ឃាសហារកោ**
**សមណំ បដិបាទេសឹ ឧបរិដ្ឋំ យសស្សិនំ ។**

ក្នុងកាលមុន ខ្ញុំបានកើតជាបុរសកម្សត់ ឈ្មោះអន្នភារៈ
ជាអ្នកធ្វើការឈ្នួល ដើម្បីអាហារ បានផ្គត់ផ្គង់សមណៈ
( ព្រះបច្ចេកពុទ្ធ ) ឈ្មោះឧបរិដ្ឋៈ ជាអ្នកមានយស ។

ក្នុងកាលនោះ ព្រះថេរៈមានបរិវិតក្កៈថា សុមនសេដ្ឋីសម្លាញ់របស់អញ បានឲ្យកហាបណៈ ហើយទទួលយកចំណែកបុណ្យអំពីបិណ្ឌបាត ដែលអញប្រគេនដល់ព្រះឧបរិដ្ឋបច្ចេកពុទ្ធ ក្នុងកាលនោះឥឡូវនេះ កើតក្នុងទីណាហ្ន៎ ។ លំដាប់នោះ ក៏បានឃើញថា កើតក្នុង

ស្រុកឈ្មោះមុណ្ឌនិគម ត្រង់ដើមភ្នំ ក្បែរព្រៃក្បើងចេះ ឧបាសកឈ្មោះ មហាមុណ្ឌៈ នៅក្នុងមុណ្ឌនិគមនោះ មានកូនប្រុសពីរនាក់ គឺមហាសុមនៈ ១ ចូឡសុមនៈ ១ បណ្តាកូនទាំងពីរនោះ សុមនសេដ្ឋីនោះ កើតជាចូឡសុមនៈ ។ កាលឃើញហើយគិតថា បើអាត្មាអញទៅក្នុងទីនោះ ប្រយោជន៍នឹងមានឬហ្ន៎ ។ លោកពិចារណាបានឃើញហេតុនេះថា កាលអាត្មាអញទៅក្នុងទីនោះ ចូឡសុមនៈនោះ មានអាយុ ៧ ឆ្នាំប៉ុណ្ណោះ នឹងចេញបួស ហើយសម្រេចអរហត្តក្នុងពេលកោរសក់ស្រេចនោះឯង ។ កាលឃើញហេតុនេះហើយ រដូវវស្សាជិតចូលមកដល់ ទើបទៅតាមអាកាស ចុះត្រង់ទ្វារស្រុក ។ ចំណែកមហាមុណ្ឌឧបាសកជាអ្នកស្និទ្ធស្នាលរបស់ព្រះថេរៈក្នុងកាលមុននុ៎ះឯង ឃើញព្រះថេរៈឃ្លុំចីវរក្នុងពេលបិណ្ឌបាត ទើបពោលនឹងមហាសុមនៈជាកូនថា នែបាព្រះអនុរុទ្ធត្ថេររបស់យើងនិមន្តមកហើយ ចូរបាទៅទទួលបាត្រ ឲ្យទាន់ពេលដែលអ្នកដទៃមិនទាន់ទទួលបាត្រលោក ឪពុកនឹងឲ្យគេក្រាលអាសនៈទុក ។ មហាសុមនៈបានធ្វើយ៉ាងនោះហើយ ឧបាសកអង្គាសព្រះថេរៈខាងក្នុងផ្ទះដោយគោរពហើយ សូមឲ្យលោកទទួលបេ្តជ្ញាដើម្បីនៅចាំវស្សាអស់ត្រៃមាស ព្រះថេរៈទទួលនិមន្តន៍ហើយ ។

គ្រានោះ ឧបាសកបដិបត្តិព្រះថេរៈអស់ត្រៃមាស ដូចបដិបត្តិមួយថ្ងៃនោះឯង ក្នុងថ្ងៃមហាបវារណា ទើបនាំត្រៃចីវរ និងស្ករអំពៅ ប្រេង

អង្កុរជាដើមមកហើយ ទុកទៀបជើងរបស់ព្រះថេរៈ ពោលថា **គណ្ហថ ភន្តេ** សូមលោកម្ចាស់ទទួលចុះ ។

ព្រះថេរៈពោលថា **អលំ ឧបាសក ន មេ ឥមិនា អត្ថោ** កុំឡើយឧបាសក សេចក្ដីត្រូវការដោយវត្ថុនេះ របស់អាត្មា មិនមាន ។

មហាមុណ្ឌឧបាសកពោលថា បពិត្រលោកម្ចាស់ នេះជាលាភដែលកើតដល់លោកអ្នកចាំវស្សា សូមលោកម្ចាស់ទទួលវត្ថុនេះចុះ ។

ព្រះថេរៈពោលថា កុំឡើយឧបាសក ។ ឧបាសកសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន ហេតុអ្វីទើបលោកម្ចាស់មិនទទួល ។

ព្រះថេរៈពោលថា សាមណេរដែលជាកប្បិយការកៈក្នុងសម្នាក់របស់អាត្មា មិនមាន ។ ឧបាសកពោលថា បើដូច្នោះ មហាសុមនៈជាកូនរបស់ខ្ញុំព្រះករុណា នឹងជាសាមណេរ ។

ព្រះថេរៈពោលថា ឧបាសក សេចក្ដីត្រូវការដោយមហាសុមនៈរបស់អាត្មា មិនមាន ។ ឧបាសកពោលថា បពិត្រលោកម្ចាស់ បើដូច្នោះសូមលោកម្ចាស់ឲ្យចូឡសុមនៈបួសចុះ ។

ព្រះថេរៈទទួលថា សាធុ ហើយឲ្យចូឡសុមនៈបួស ។ ចូឡសុមនៈសម្រេចអរហត្តក្នុងពេលកោរសក់ស្រេចប៉ុណ្ណោះ ។ ព្រះថេរៈនៅក្នុងទីនោះ ជាមួយចូឡសុមនសាមណេរនោះ ប្រមាណកន្លះខែហើយ លាពួកញាតិរបស់សាមណេរថា អាត្មានឹងទៅគាល់ព្រះសាស្ដា ដូច្នេះហើយ

បានទៅតាមអាកាស ចុះត្រង់កុដិដែលតាំងនៅក្នុងហិមវន្តប្បទេស ។

ក៏ព្រះថេរៈ តាមប្រក្រតីជាអ្នកប្រារព្ធសេចក្ដីព្យាយាម កាលលោកកំពុងចង្ក្រមក្នុងទីនោះ ពេលព្រលប់និងពេលជិតភ្លឺ ខ្យល់ក្នុងផ្ទៃតាំងឡើងហើយ ។ ក្នុងកាលនោះ សាមណេរឃើញព្រះថេរៈលំបាក ទើបសួរថា **ភន្តេ កឹ ពាធតិ** បពិត្រលោកម្ចាស់ រោគអ្វីចាក់ដោតលោកម្ចាស់ ។

ព្រះថេរៈពោលថា **ឧទរវាតោ មេ សមុដ្ឋិតោ** ខ្យល់សៀតផ្ទៃកើតឡើងដល់ខ្ញុំហើយ ។ សាមណេរសួរថា ក្នុងកាលដទៃ ខ្យល់សៀតផ្ទៃធ្លាប់កើតឡើងឬទេ លោកម្ចាស់ ។

ព្រះថេរៈពោលថា អើ អាវុសោ ។ សាមណេរពោលថា លោកម្ចាស់ដ៏ចម្រើន សេចក្ដីសប្បាយ រមែងមានដោយអ្វី ។

ព្រះថេរៈពោលថា អាវុសោ កាលខ្ញុំបានទឹកអំពីអនោតត្តស្រះផឹកផាសុកនឹងមាន ។ សាមណេរពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ ខ្ញុំព្រះករុណានឹងទៅយកមក ។

ព្រះថេរៈសួរថា អ្នកអាចឬ សាមណេរ ។ សាមណេរឆ្លើយថា អាច លោកម្ចាស់ ។

ព្រះថេរៈពោលថា នាគរាជឈ្មោះបន្នគៈ ដែលនៅក្នុងអនោតត្តស្រះ ស្គាល់ខ្ញុំ បើដូច្នោះ ចូរលោកប្រាប់ដល់នាគរាជនោះ ហើយនាំទឹកមួយក្អមមក ដើម្បីប្រយោជន៍ដល់ការប្រកបថ្នាំចុះ ។

សាមណេរទទួលថា សាធុ ហើយថ្វាយបង្គំឧបជ្ឈាយ៍ ហោះទៅកាន់អាកាសដែលមានចម្ងាយផ្លូវ ៥០០ យោជន៍ ។

ថ្ងៃនោះ នាគរាជមានអ្នករបាំចោមរោមហើយ ប្រាថ្នានឹងលេងទឹក នាគរាជនោះ លុះបានឃើញសាមណេរកំពុងមកនោះឯង ក៏ក្រោធហើយគិតថា សមណៈត្រងោលនេះ រោយធូលីដែលជាប់នឹងជើងលើអំបែងក្បាលរបស់អញ លោកមកដើម្បីត្រូវការទឹកក្នុងអនោតត្តស្រះឥឡូវនេះ អញនឹងមិនឲ្យទឹកដល់លោក ដូច្នេះហើយ ដេកបិទអនោតត្តស្រះដែលមានទំហំ ៥០ យោជន៍ ដោយពពារ ដូចបិទថ្នាំងបាយដោយថាសធំដូច្នោះ ។ សាមណេរសម្លឹងមើលអាការរបស់នាគរាជហើយ ដឹងថា នាគនេះក្រោធហើយ ទើបពោលគាថាដូច្នេះថា

**សុណោហិ មេ នាគរាជ ឧគ្គតេជ មហព្វល**
**ទេហិ មេ បានីយឃដំ ភេសជ្ជត្ថម្ហិ អាគតោ ។**

នៃនាគរាជ អ្នកជាបុគ្គលមានតេជះខ្លាំងក្លា មានកម្លាំងច្រើន ចូរអ្នកស្តាប់ពាក្យអាត្មា សូមឲ្យទឹកផឹកដល់អាត្មាមួយក្អម អាត្មាមកហើយដើម្បីប្រយោជន៍ដល់ទឹកសម្រាប់ធ្វើថ្នាំ ។

នាគរាជស្តាប់ពាក្យនោះ ទើបពោលគាថានេះថា

**បុរត្ថិមស្មឹ ទិសាភាគេ គង្គា នាម មហានទី**

មហាសមុទ្ទមប្បេតិ តតោ ត្វំ ចានីយំ ហរ ។

*ស្ទឹងធំឈ្មោះគង្គា ត្រង់ទិសបូព៌ រមែងហូរទៅកាន់មហាសមុទ្ទ សូមលោកនាំទឹកអំពីស្ទឹងគង្គានោះទៅចុះ ។*

*សាមណេរស្តាប់ពាក្យនោះហើយ គិតថា ស្តេចនាគនេះ មិនឲ្យតាមសេចក្តីប្រាថ្នារបស់អញ អញនឹងប្រើកម្លាំងឲ្យនាគនេះ ដឹងអានុភាពអញនឹងសង្កត់ស្តេចនាគនេះ ហើយយកទឹកទៅ ដូច្នេះហើយ ពោលថាមហារាជ ព្រះឧបជ្ឈាយ៍ឲ្យអាត្មានាំទឹកផឹកអំពីអនោតត្តស្រះនេះប៉ុណ្ណោះ ព្រោះហេតុនោះ ទើបអាត្មានាំទឹកផឹកនេះតែម្យ៉ាងទៅ សូមលោកចៀសចេញ កុំឃាត់អាត្មាឡើយ ដូច្នេះហើយ ពោលគាថានេះថា*

ឥតោវ ចានីយំ ហាស្សំ ឥមិនាវម្ហិ អត្ថិកោ
យទិ តេ ថាមពលំ អត្ថិ នាគរាជ និវារយ ។

*អាត្មាយកទឹកអំពីអនោតត្តស្រះនេះប៉ុណ្ណោះ អាត្មាត្រូវការទឹកអំពីអនោតត្តស្រះ នៃស្តេចនាគ បើកម្លាំងលោកមាន ចូររាំងចុះ ។*

*លំដាប់នោះ ស្តេចនាគពោលថា*

សាមណេរ សចេ អត្ថិ តវ វិក្កម ចោរិសំ
អភិនន្ទាមិ តេ វាចំ ហរស្សុ ចានីយំ មម ។

*នៃសាមណេរ បើលោកក្លាហាន ជាកូនប្រុសសោត ខ្ញុំ*

*ពេញចិត្តនឹងពាក្យរបស់លោក សូមអញ្ជើញលោកនាំ ទឹករបស់ខ្ញុំទៅចុះ ។*

*លំដាប់នោះ សាមណេរពោលថា* **ឯវំ មហារាជ ហរាមិ** *មហារាជ ខ្ញុំនឹងនាំទៅយ៉ាងនេះ ។ ស្តេចនាគពោលថា* **យទិ សក្កោន្តោ ហរាហិ** *បើលោកអាច ក៏ចូរនាំទៅចុះ ។*

*សាមណេរឲ្យស្តេចនាគទទួលប្តេជ្ញាអស់វារៈ ៣ ដងថា* **តេន ហិ សុដ្ឋុ ជានស្សុ** *បើដូច្នោះ ចូរលោកដឹងដោយល្អចុះ ហើយគិតថា ការដែលអញសម្តែងអានុភាពរបស់ព្រះពុទ្ធសាសនា ហើយយកទឹកទៅ រមែងគួរ ដូច្នេះហើយ ដំបូងបានទៅកាន់សម្នាក់របស់ពួកអាកាសដ្ឋទេវតា ទេវតាទាំងនោះ មកថ្វាយបង្គំ ពោលថា មានរឿងអ្វីលោកម្ចាស់ ហើយនាំគ្នាឈរ ។*

*សាមណេរពោលថា សង្គ្រាមរបស់អាត្មាជាមួយនឹងបន្នគនាគរាជនឹងមានត្រង់ផ្ទៃអនោតត្តស្រះនេះ សូមពួកអ្នកទៅកាន់ទីនោះ ហើយមើលនូវការឈ្នះនិងការចាញ់ ។ សាមណេរទៅកាន់សម្នាក់ស្តេចចតុលោកបាល សក្កទេវរាជ សុយាមទេវរាជ សន្តុសិតទេវរាជ សុនិម្មិតនិងវសវត្តីទេវរាជ ហើយប្រាប់សេចក្តីនោះ ដោយទំនង់នុ៎ះឯង ។ បន្ទាប់អំពីនោះ សាមណេរទៅដោយលំដាប់ រហូតដល់ព្រហ្មលោក កាលព្រហ្មទាំងឡាយក្នុងទីនោះៗ មកថ្វាយបង្គំ ហើយឈរ សួរថា មានរឿងអ្វី*

លោកម្ចាស់ ទើបប្រាប់សេចក្ដីនោះ ។ សាមណេរប្រាប់ក្នុងទីគ្រប់កន្លែង មួយរំពេច វៀរអសញ្ញីសត្វ និងអរូបព្រហ្មដោយអាការយ៉ាងនេះ សូម្បីទេវតាគ្រប់ពួក ស្ដាប់ពាក្យលោកហើយ ប្រជុំគ្នាពេញអាកាស មិនមានចន្លោះ ត្រង់អនោតត្តស្រះ ដូចលម្អិតនៃនំដែលដាក់ក្នុងនាឡិដូច្នោះ ។ កាលពួកទេវតាប្រជុំគ្នាហើយ សាមណេរឈរក្នុងអាកាស ពោលនឹងស្ដេចនាគថា

**សុណោហិ មេ នាគរាជ ឧគ្គតេជ មហាពល**
**ទេហិ មេ បានីយឃដំ ភេសជ្ជត្ថម្ហិ អាគតោ ។**

នៃនាគរាជ អ្នកជាបុគ្គលមានតេជៈខ្លាំងក្លា មានកម្លាំងច្រើន ចូរស្ដាប់ពាក្យអាត្មា សូមឲ្យទឹកផឹកដល់អាត្មាមួយក្អម អាត្មាមកហើយប្រយោជន៍ដល់ទឹកសម្រាប់ធ្វើថ្នាំ ។

លំដាប់នោះ នាគរាជពោលថា

**សាមណេរ សចេ អត្ថិ តវ វិក្កម ចោរិសំ**
**អភិនន្ទាមិ តេ វាចំ ហរស្សុ បានីយំ មម ។**

នៃសាមណេរ បើលោកក្លាហាន ជាកូនប្រុសសោត ខ្ញុំពេញចិត្តនឹងពាក្យរបស់លោក សូមអញ្ជើញលោកនាំទឹករបស់ខ្ញុំទៅចុះ ។

សាមណេរនោះ ទទួលពាក្យប្ដេជ្ញារបស់នាគរាជ ៣ ដង ហើយ

ឈរក្នុងអាកាសនោះឯង និម្មិតអត្តភាពជាព្រហ្ម ( កម្ពស់ ) ប្រមាណ ១២ យោជន៍ ទម្លាក់ខ្លួនអំពីអាកាស ជាន់ត្រង់ពពាររបស់ស្តេចនាគ សង្កត់ឲ្យផ្កាប់មុខចុះហើយ រំពេចនុ៎ះឯង កាលសាមណេរជាន់ពពាររបស់ស្តេចនាគប៉ុណ្ណោះ ពពារស្តេចនាគបានរួញនៅសល់ប្រមាណប៉ុនវែក ដូចស្បែកស្រស់ដែលបុរសមានកម្លាំងជាន់ហើយដូច្នោះ ។ ក្នុងទីដែលផុតចាកពពាររបស់ស្តេចនាគមក ខ្សែទឹកប្រមាណប៉ុនដើមត្នោត ក៏បាញ់ឡើងលើ សាមណេរញ៉ាំងក្អមទឹកឲ្យពេញក្នុងអាកាសនុ៎ះឯង ។ ពួកទេវតាបានឲ្យសាធុការហើយ ។ លំដាប់នោះ នាគរាជខ្មាស ហើយក្រោធនឹងសាមណេរ ភ្នែកទាំងពីររបស់នាគរាជនោះ មានពណ៌ដូចផ្កាឲ្យ ។ ស្តេចនាគគិតថា សមណៈត្រងោលនេះ ឲ្យពួកទេវតាប្រជុំគ្នាហើយ កាន់យកទឹកផឹក ធ្វើអញឲ្យខ្មាសហើយ អញនឹងចាប់លោកលូកដៃចូលក្នុងមាត់ ច្របាច់បេះដូងរបស់លោក ឬចាប់ជើងរបស់លោកហើយគ្រវែងទៅត្រើយម្ខាង ដូច្នេះហើយ ដេញតាមសាមណេរដោយសន្ទុះដ៏រហ័ស តែមិនអាចទាន់លោកឡើយ ។ សាមណេរមកហើយដាក់ទឹកផឹកក្នុងដៃព្រះឧបជ្ឈាយ៍ ពិតថា **បិវថ ភន្តេ** សូមលោកម្ចាស់ឆាន់ចុះ ។

ស្តេចនាគមកតាមក្រោយ ទូលព្រះអនុរុទ្ធថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន សាមណេរកាន់យកទឹកដែលខ្ញុំមិនបានឲ្យមក សូមលោកម្ចាស់

កុំផាន់ ។ ព្រះថេរៈសួរថា នែសាមណេរ បានឮថា សេចក្ដីនេះ យ៉ាង នោះឬ ។

សាមណេរពោលថា សូមលោកម្ចាស់ផាន់ចុះ ទឹកនេះ ស្ដេចនាគឲ្យហើយ ទើបខ្ញុំនាំមក ។ ព្រះថេរៈដឹងថា ឈ្មោះថា ការពោលពាក្យកុហករបស់សាមណេរដែលជាព្រះខីណាស្រព រមែងមិនមាន ទើបផាន់ទឹក អាពាធក៏ស្ងប់ក្នុងខណៈនុ៎ះឯង ។

នាគរាជទូលព្រះថេរៈទៀតថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំជាបុគ្គលដែលសាមណេរឲ្យពួកទេវតាទាំងអស់ប្រជុំគ្នា ធ្វើឲ្យខ្មាសហើយ ខ្ញុំនឹងហែកបេះដូងរបស់លោក ឬនឹងចាប់លោកត្រង់ជើង គ្រវែងទៅកាន់ត្រើយនាយ ។

ព្រះថេរៈពោលថា មហារាជ សាមណេរមានអានុភាពច្រើន អ្នកមិនអាចប្រយុទ្ធជាមួយសាមណេរបានឡើយ ចូរអ្នកឲ្យសាមណេរអត់ទោស ហើយទៅវិញចុះ ។ ស្ដេចនាគដឹងអានុភាពរបស់សាមណេរដោយខ្លួនឯងនោះឯង តែដេញមកព្រោះការខ្មាស ។ លំដាប់នោះ ស្ដេចនាគឲ្យសាមណេរនោះអត់ទោស តាមពាក្យរបស់ព្រះថេរៈ ធ្វើនូវការពេញចិត្តជាមិត្តភាព ហើយពោលថា តាំងអំពីកាលនេះទៅ បើសេចក្ដីត្រូវការដោយទឹកក្នុងអនោតត្តស្រះ មាន កិច្ចដោយការមកនៃលោកម្ចាស់ រមែងមិនមាន សូមលោកម្ចាស់បញ្ជូនដំណឹងដល់ខ្ញុំ ខ្ញុំនឹងនាំទឹកមកប្រគេនឯង

ដូច្នេះហើយ ចៀសចេញទៅ ។

សូម្បីព្រះថេរៈ ក៏នាំសាមណេរទៅហើយ ។ ព្រះសាស្តាទ្រង់ជ្រាប ការមករបស់ព្រះថេរៈហើយ ប្រថាប់គង់ទតការមករបស់ព្រះថេរៈ លើប្រាសាទរបស់មិគារមាតា ។ សូម្បីពួកភិក្ខុឃើញព្រះថេរៈកំពុងមក ក៏ក្រោកឡើងទទួលបាត្រនិងចីវរ ។ គ្រានោះ ភិក្ខុពួកខ្លះ ស្ទាបសាមណេរត្រង់ក្បាលខ្លះ ចាប់ត្រចៀកទាំងពីរខ្លះ ដើមដៃខ្លះ អង្រួនខ្លះ ពោលថា នែសាមណេរតូច លោកប្អូនមិនអផ្សុកទេឬ ។

ព្រះសាស្តាទតឃើញកិរិយារបស់ភិក្ខុទាំងនោះហើយ ទ្រង់ព្រះតម្រិះថា កម្មរបស់ភិក្ខុទាំងនោះ គ្រោតគ្រាតពិត ភិក្ខុទាំងនោះ ចាប់សាមណេរ ដូចចាប់អាសិរពិសត្រង់ក ពួកភិក្ខុទាំងនោះ មិនដឹងអានុភាពរបស់សាមណេរឡើយ ថ្ងៃនេះ តថាគតគួរធ្វើគុណរបស់សុមនសាមណេរឲ្យប្រាកដ ។ ព្រះថេរៈមកថ្វាយបង្គំព្រះសាស្តាហើយ ។ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈហើយ ហៅព្រះអានន្ទមក ត្រាស់ថា ម្នាលអានន្ទ តថាគតមានបំណងនឹងលាងជើងទាំងពីរដោយទឹកក្នុងអនោតត្តស្រះ ចូរអ្នកឲ្យក្អមដល់សាមណេរ ឲ្យនាំទឹកមកចុះ ។ ព្រះថេរៈឲ្យសាមណេរប្រមាណ ៥០០ រូប ក្នុងវិហារប្រជុំគ្នាហើយ ។ បណ្តាសាមណេរទាំងនោះ សុមនសាមណេរបួសថ្មីជាងសាមណេរទាំងពួង ។ ព្រះអានន្ទត្ថេរពោលនឹងសាមណេរដែលមានវស្សាច្រើនជាងគេបង្អស់ថា នែសាមណេរ

ព្រះសាស្តាមានបំណងលាងព្រះបាទទាំងគូ ដោយទឹកក្នុងអនោតត្តស្រះ ចូរលោកកាន់យកក្អមទឹក ទៅនាំទឹកមក ។

សាមណេរនោះ មិនប្រាថ្នា ដោយពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំមិនអាច ។ ព្រះថេរៈសួរសាមណេរទាំងឡាយដ៏សេសដោយលំដាប់ សាមណេរទាំងនោះ ក៏ពោលដោះខ្លួនយ៉ាងនោះឯង ។ មានពាក្យសួរថា បណ្តាសាមណេរទាំងនោះ សាមណេរដែលជាព្រះខីណាស្រព មិនមានឬ ។

ឆ្លើយថា មាន តែសាមណេរទាំងនោះមិនប្រាថ្នា ដោយគិតឃើញថា កម្រងផ្កានេះ ព្រះសាស្តាទ្រង់មិនចងទុកដើម្បីពួកយើង ទ្រង់ចងទុកដើម្បីសុមនសាមណេរមួយអង្គប៉ុណ្ណោះ ។ តែពួកសាមណេរដែលជាបុថុជ្ជន មិនប្រាថ្នាទៅ ក៏ព្រោះភាពដែលខ្លួនមិនអាចនោះឯង ក្នុងទីបំផុត កាលវារៈដល់សុមនសាមណេរ ព្រះថេរៈពោលថា នែសាមណេរ ព្រះសាស្តាមានបំណងលាងព្រះបាទទាំងគូ ដោយទឹកក្នុងអនោតត្តស្រះ ចូរលោក ( កាន់យកក្អមទឹក ) ទៅដងទឹកមក ។

សុមនសាមណេរពោលថា កាលព្រះសាស្តា ទ្រង់ឲ្យនាំមក ខ្ញុំនឹងទៅ ទើបថ្វាយបង្គំព្រះសាស្តាក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ទ្រង់ឲ្យខ្ញុំព្រះអង្គនាំទឹកមកអំពីអនោតត្តស្រះឬ ។

ព្រះសាស្តាត្រាស់ថា ម្នាលសុមនៈ យ៉ាងនោះឯង ។

សុមនសាមណេរនោះ យកដៃចាប់ក្អមធំមួយដែលដាក់ទឹកបាន ៦០ ក្អម បណ្ដាក្អមសម្រាប់សេនាសនៈដែលធ្វើអំពីមាស ដែលនាង វិសាខាសាងទុក គិតថា សេចក្ដីត្រូវការរបស់អញ ដោយក្អមដែលលើក ឡើងដាក់លើស្មា មិនមាន ហើយហោះឡើងទៅកាន់អាកាស បែរមុខ ទៅកាន់ហិមវន្តប្បទេស ។

នាគរាជឃើញសាមណេរកំពុងមកអំពីចម្ងាយ ទើបទទួលលីក្អម ដោយចង្កួយស្មា ពោលថា បពិត្រលោកម្ចាស់ បើទាសៈដូចខ្ញុំ មាន ព្រោះហេតុអ្វី ទើបលោកម្ចាស់មកឯង បើសេចក្ដីត្រូវការដោយទឹក មាន ហេតុអ្វីលោកម្ចាស់មិនបញ្ជូនដំណឹងមក ដូច្នេះហើយ យកក្អមដងទឹក លីដោយស្មា ពោលថា សូមលោកម្ចាស់និមន្តទៅមុនចុះ ខ្ញុំឯងនឹងនាំ ទៅ ។ សាមណេរពោលថា មហារាជ ចូរលោកឈប់ចុះ ខ្ញុំឯងដែល ព្រះសម្មាសម្ពុទ្ធប្រើមក ឲ្យស្ដេចនាគត្រឡប់ហើយ យកដៃចាប់ត្រង់ កណ្ដាប់មាត់ក្អម ហោះមកតាមអាកាស ។

លំដាប់នោះ ព្រះសាស្ដាទ្រង់សម្លឹងមើលសាមណេរដែលកំពុង ត្រឡប់មក (អំពីចម្ងាយ) ហៅពួកភិក្ខុមក ហើយត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ ពួកអ្នកចូរមើលលីលារបស់សាមណេរ ដែលល្អរុងរឿង ដូច ស្ដេចហង្សរុងរឿងក្នុងអាកាសដូច្នោះ ។

សាមណេរដាក់ក្អមចុះហើយ ថ្វាយបង្គំព្រះសាស្ដា ឈរក្នុង

ចំណែកម្ខាង ។ លំដាប់នោះ ព្រះសាស្ដាត្រាស់សួរថា ម្នាលសុមនៈ អ្នកមានអាយុប៉ុន្មាន ។ សាមណេរក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានអាយុ ៧ ឆ្នាំ ។

ព្រះសាស្ដាត្រាស់ថា ម្នាលសុមនៈ បើដូច្នោះ តាំងអំពីនេះទៅ អ្នកចូរជាភិក្ខុចុះ ដូច្នេះហើយ បានប្រទានទាយជ្ជឧបសម្បទា ។ បានឮថា សាមណេរអាយុ ៧ ឆ្នាំ ពីររូបប៉ុណ្ណោះ ដែលបានឧបសម្បទា គឺ សុមនសាមណេរនេះមួយរូប និងសោបាកសាមណេរមួយរូប ។

កាលសុមនសាមណេរឧបសម្បទាហើយយ៉ាងនោះ ពួកភិក្ខុ សន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ គួរអស្ចារ្យហ្ន៎ ឈ្មោះថា សាមណេរតូច មានអានុភាពបែបនេះ អានុភាពបែបនេះ ពួកយើងមិន ធ្លាប់ឃើញឡើយ ក្នុងកាលមុនអំពីនេះ ។ ព្រះសាស្ដាយាងមកហើយ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយ សន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះ អង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ។

ព្រះសាស្ដាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនារបស់ តថាគត បុគ្គលទោះបីជានៅក្មេង បើបដិបត្តិប្រពៃហើយ រមែងបាន សម្បត្តិបែបនេះដូចគ្នា ។ កាលទ្រង់សម្ដែងធម៌ ទើបត្រាស់ព្រះគាថា នេះថា

យោ ហវេ ទហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

*ភិក្ខុណានៅកំលោះ ប្រឹងប្រែងក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែងញុំាងលោកនេះ ឲ្យភ្លឺស្វាងបាន ដូចព្រះចន្ទដែលរះផុតអំពីពពក[១] ដូច្នេះ ។*

*ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ។*

*បានឮថា ព្រះអនុរុទ្ធប្រព្រឹត្តជុសខាត់កិលេស ជានេសជ្ជិកៈ ( អ្នកមានការមិនសិងជាវត្ត ) នោះ អស់ ៥៥ ឆ្នាំ ។ អាចារ្យពួកខ្លះពោលថា ព្រះថេរៈសមាទាននេសជ្ជិកវត្ត អស់ ៥៥ ឆ្នាំ ២៥ ឆ្នាំដំបូង មិនបានសិងឡើយ បន្ទាប់អំពីនោះ ទើបសិងក្នុងបច្ឆិមយាម ព្រោះរាងកាយទន់ខ្សោយ ។*

ព្រះអនុរុទ្ធត្ថេរ ចប់[២]

---

*១-បិ.៥២ ទំ.១០១ ឃ.៣៥ ។ ២-ស្រង់ចាកវិនយបិដក ចុល្លវគ្គ ថេរគាថា ធម្មបទ និងអបទាន មួយអន្លើដោយអដ្ឋកថា ។*

# ព្រះឧបាលិត្ថេរ

បានឮថា កុលបុត្តនេះ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរហង្សវតី ។ ថ្ងៃមួយ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា បានឃើញព្រះសាស្តាទ្រង់តែងតាំងភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈ គឺជាកំពូលលើសភិក្ខុទាំងឡាយខាងទ្រទ្រង់នូវព្រះវិន័យ ធ្វើកម្មគឺបុញ្ញាធិការ ហើយបានប្រាថ្នាតំណែងនោះ ។ កុលបុត្តនោះ បំពេញកុសលជរាបដល់អស់ជីវិត អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ លុះដល់ពុទ្ធុប្បាទនេះ បដិសន្ធិក្នុងផ្ទះជាងកោរកាត់ មាតាបិតាបានដាក់ឈ្មោះកុលបុត្តនោះថា ឧបាលិ ។ កុលបុត្តនោះ ចម្រើនវ័យហើយ ជាទីប្រោសប្រាណរបស់ស្តេច ៦ អង្គ មានអនុរុទ្ធរាជកុមារជាដើម ។ កាលព្រះតថាគតគង់ត្រង់អនុបិយម្ពវ័ន បានចេញបួសជាមួយក្សត្រ ៦ អង្គ ដែលចេញទៅបព្វជ្ជា ។ ការចេញបួសរបស់កុលបុត្តនោះ មានហើយក្នុងរឿងព្រះអនុរុទ្ធត្ថេរខាងដើម ។

ព្រះថេរៈ កាលបព្វជ្ជាឧបសម្បទាហើយ បានទទួលយកកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តា ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គនៅព្រៃចុះ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ បើអ្នកនៅព្រៃ ធុរៈមួយប៉ុណ្ណោះ

*នឹងចម្រើន តែបើបដិបត្តិក្នុងសម្នាក់របស់តថាគត គន្ថធុរៈផង វិបស្សនាធុរៈផង នឹងបរិបូណ៌ ។ ព្រះថេរៈទទួលព្រះពុទ្ធតម្រាស់ហើយ បំពេញវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តផល ។ សមដូចគាថាដែលលោកពោលទុកក្នុងអបទានថា*

នគរេ ហំសវតិយា សុជាតោ នាម ព្រាហ្មណោ
អសីតិកោដិសន្និចយោ បហូតធនធញ្ញវា ។

*ខ្ញុំកើតជាព្រាហ្មណ៍ ឈ្មោះសុជាត ក្នុងក្រុងហង្សវតី ជាអ្នកសន្សំនូវទ្រព្យសម្បត្តិ ចំនួន ៨០ កោដិ មានទ្រព្យនិងស្រូវជាច្រើន ។*

អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទាន បារគូ
លក្ខណេ ឥតិហាសេ ច សធម្មេ បារមឹ គតោ ។

*ខ្ញុំជាអ្នកបង្រៀនមន្ត ចេះចាំមន្ត សម្រេចត្រៃវេទ ដល់នូវត្រើយក្នុងធម៌របស់ខ្លួន គឺក្បួនទាយលក្ខណៈ និងក្បួនឈ្មោះឥតិហាសៈ ។*

បរិព្វជា ឯកសិខា គោតមា ពុទ្ធសាវកា
ចរកា តាបសា ចេវ ចរន្តិ មហិយា តទា ។

*ក្នុងគ្រានោះ ពួកបរិព្វាជក អ្នកមានផ្នួងសក់មួយ ពួកពុទ្ធសាវ័ករបស់ព្រះគោតម និងពួកតាបសអ្នកប្រព្រឹត្តតបៈ តែង*

*នាំគ្នាគ្រាប់ទៅលើផែនដី ។*

តេបិ មំ បរិភាវេន្តិ ព្រាហ្មណោ វិស្សុតោ ឥតិ
ពហូ ជនា មំ បូជេន្តិ នាហំ បូជេមិ កិញ្ចិនំ ។

*ពួកទាំងនោះ តែងចោមរោមខ្ញុំ ពួកជនជាច្រើនតែងបូជាខ្ញុំ ដោយសម្គាល់ថា ជាព្រាហ្មណ៍មានកិត្តិសព្ទល្បីល្បាញ ខ្ញុំមិនបូជាជនណាមួយ ។*

បូជារហំ ន បស្សាមិ មានថទ្ធោ អហំ តទា
ពុទ្ធោតិ វចនំ នត្ថិ តាវ នុប្បជ្ជតេ ជិនោ ។

*វេលានោះ ខ្ញុំជាមនុស្សរឹងត្អឹង ដោយមានះ មិនឃើញបុគ្គលគួរបូជា ទាំងពាក្យថា ព្រះពុទ្ធ ក៏មិនដែលមាន ព្រោះព្រះជិនស្រី ទ្រង់មិនទាន់កើតឡើងនៅឡើយ ។*

អច្ចយេន អហោរត្តំ បទុមុត្តរនាមកោ
សព្វំ តមំ វិនោទេត្វា លោកេ ឧប្បជ្ជិ ចក្ខុមា ។

*លុះកន្លងថ្ងៃនិងយប់ទៅ ព្រះពុទ្ធទ្រង់ព្រះនាមបទុមុត្តរៈ ទ្រង់មានបញ្ញាចក្ខុ កម្ចាត់បង់នូវងងឹតទាំងពួង ទ្រង់កើតឡើងក្នុងលោក ។*

វិត្ថារិកេ ពហុ ជញ្ញេ បុថុភូតេ ច សាសនេ
ឧបាគមិ តទា ពុទ្ធោ នគរំ ហំសសវ្ហយំ ។

*កាលបើពួកជន ជាអ្នកប្រាជ្ញ មានចំនួនច្រើនផ្សាយទៅផង សាសនារីកក្រាស់ក្រៃលផង គ្រានោះ ព្រះសម្ពុទ្ធស្តេចចូលទៅកាន់ក្រុងហង្សវតី ។*

**បិតុ អត្ថាយ សោ ពុទ្ធោ ធម្មំ ទេសេសិ ចក្ខុមា**
**តេន កាលេន បរិសា សមន្តា យោជនំ តទា ។**

*ព្រះពុទ្ធមានបញ្ញាចក្ខុនោះ ទ្រង់សម្តែងធម៌ដើម្បីប្រយោជន៍ដល់ព្រះបិតាក្នុងវេលានោះ ពួកបរិស័ទប្រមាណមួយយោជន៍ដោយជុំវិញ ( មកគាល់ព្រះអង្គ ) តាមកាលដ៏គួរនោះ ។*

**សម្មតោ មនុជានំ យោ សុនន្ទោ នាម តាបសោ**
**យាវតា ពុទ្ធបរិសា បុប្ផេហិច្ឆាទយិ តទា ។**

*គ្រានោះ តាបសឈ្មោះសុនន្ទៈ ដែលពួកមនុស្សរាប់អានបានបិទបាំងពុទ្ធបរិស័ទទាំងអស់ ដោយផ្កាទាំងឡាយ ។*

**ចតុសច្ចំ បកាសេន្តោ សេដ្ឋេ ច បុប្ផមណ្ឌបេ**
**កោដិសតសហស្សានំ ធម្មាភិសមយោ អហុ ។**

*កាលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសសច្ចៈទាំង ៤ ក្នុងមណ្ឌបដ៏ហើយដោយផ្កាដ៏ប្រសើរ ពួកបរិស័ទមួយសែនកោដិ ក៏បានសម្រេចធម្មាភិសម័យ ។*

សត្តរត្តិន្ទិវំ ពុទ្ធោ វសិត្វា ជម្មរុជ្ជិយោ
អដ្ឋមេ ទិវសេ បត្តេ សុនន្ទំ កិត្តយី ជិនោ ។

*ព្រះសម្ពុទ្ធទ្រង់បង្ហូរភ្លៀង គឺព្រះធម៌ អស់ ៧ យប់ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៨ ព្រះជិនស្រី ក៏ទ្រង់បានទំនាយនូវតាបស ឈ្មោះសុនន្ទៈថា ។*

ទេវលោកេ មនុស្សេ វា សំសរន្តោ អយំ ភវេ
សព្វេសំ បវរោ ហុត្វា ភវេសុ សំសរិស្សតិ ។

*សុនន្ទតាបសនេះ កាលអន្ទោលទៅក្នុងភព គឺទេវលោក ឬ មនុស្សលោក នឹងបានជាអ្នកប្រសើរជាងទេវតា ទាំងជាង មនុស្សទាំងអស់ នឹងអន្ទោលទៅក្នុងភពទាំងឡាយ ។*

កប្បសតសហស្សម្ហិ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។

*លុះដល់រវាងមួយសែនកប្ប នឹងមានព្រះសម្ពុទ្ធ ព្រះនាម គោតម កើតឡើងក្នុងត្រកូលឱក្កាកៈ នឹងបានជាសាស្តាក្នុង លោក ។*

តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
មន្តានីបុត្តោ បុណ្ណោតិ ហេស្សតិ សត្ថុ សាវកោ ។

*សុនន្ទតាបសនេះ នឹងបានជាទាយាទក្នុងធម៌ ជាឱរស ជា*

*ធម្មនិម្មិត ជាសាវកឈ្មោះបុណ្ណៈ ជាបុត្តនៃនាងមន្តានី របស់ព្រះសាស្តានោះ ។*

**ឯវំ កិត្តយិ សម្ពុទ្ធោ សុនន្ទំ តាបសំ តទា**
**ហាសយន្តោ ជនំ សព្វំ ទស្សយន្តោ សកំ ពលំ ។**

*លុះព្រះសម្ពុទ្ធ បានព្យាករសុនន្ទតាបសយ៉ាងនេះហើយ បានញ៉ាំងជនទាំងពួងឲ្យរីករាយ ទ្រង់សម្តែងតាមកម្លាំងរបស់ព្រះអង្គ ។*

**កតញ្ជលី នមស្សន្តិ សុនន្ទំ តាបសំ តទា**
**ពុទ្ធេ ការំ ករិត្វាន សោធេសិ គតិមត្តនោ ។**

*វេលានោះ ពួកបរិស័ទបានប្រណម្យអញ្ជលី នមស្ការចំពោះសុនន្ទតាបស សុនន្ទតាបស ក៏ធ្វើសក្ការបូជាចំពោះព្រះសម្ពុទ្ធរួចហើយ ទើបធ្វើគតិរបស់ខ្លួនឲ្យស្អាត ។*

**តត្ថ មេ អហុ សង្កប្បោ សុត្វាន មុនិនោ វចំ**
**អហំ ការំ ករិស្សាមិ យថា បស្សាមិ គោតមំ ។**

*ខ្ញុំបានស្តាប់ព្រះពុទ្ធដីការបស់ព្រះមុនី ( ព្រះនាមបទុមុត្តរៈ ) ក៏មានបំណងក្នុងវេលានោះថា អាត្មាអញនឹងបានឃើញព្រះគោតមយ៉ាងណា នឹងធ្វើសក្ការបូជាយ៉ាងនោះ ។*

**ឯវាហំ ចិន្តយិត្វាន កិរិយំ ចិន្តយឹ មមំ**

ក្យាហំ កម្មំ អាចរាមិ បុញ្ញក្ខេត្តេ អនុត្តរេ ។

*លុះខ្ញុំគិតយ៉ាងនេះរួចហើយ ទើបគិតរកបុញ្ញកិរិយាវត្ថុដែលខ្ញុំគួរធ្វើថា អាត្មាអញនឹងប្រព្រឹត្តអំពើអ្វីហ្ន៎ ក្នុងបុញ្ញក្ខេត្តដ៏ប្រសើរ ។*

អយញ្ច ចាបិកោ ភិក្ខុ សព្វចាបីន សាសនេ
វិនយេ អគ្គនិក្ខិត្តោ តំ ឋានំ បត្ថយេ អហំ ។

*ឯភិក្ខុជាអ្នកសូត្រអង្គនេះ ព្រះមានព្រះភាគបានតាំងថា ជាអ្នកប្រសើរខាងព្រះវិន័យ ជាងភិក្ខុអ្នកសូត្រទាំងពួង ក្នុងសាសនា ដូច្នេះ អាត្មាអញនឹងប្រាថ្នាយកតំណែងនោះ ។*

ឥទំ មេ អមិតំ ភោគំ អក្ខោភំ សាគរូបមំ
តេន ភោគេន ពុទ្ធស្ស អារាមំ មាបយេ អហំ ។

*ទ្រព្យរបស់អាត្មាអញនេះ ច្រើនណាស់ រាប់មិនអស់ ឧបមាដូចសាគរ បុគ្គលមិនអាចនឹងឲ្យញាប់ញ័របានឡើយ ហេតុនេះ អាត្មាអញគួរសាងអារាមថ្វាយព្រះសម្ពុទ្ធ ដោយទ្រព្យនោះ ។*

សោភនំ នាម អារាមំ នគរស្ស បុរត្ថតោ
កត្វា សតសហស្សេន សង្ឃារាមំ អមាបយឹ ។

*ខ្ញុំបានសាងអារាមមួយ ឈ្មោះសោភនៈ នៅខាងមុខទីក្រុង*

*ឲ្យជាអារាមសម្រាប់សង្ឃ អស់ចំនួនមួយសែនកហាបណៈ ។*

កុដាគារេ ច បាសាទេ មណ្ឌបេ ហម្មិយេ គុហា
ចង្កមេ សុកតេ កត្វា សង្ឃារាមេ អមាបយឹ ។

*ខ្ញុំបានសាងផ្ទះមានកំពូលផង ប្រាសាទវែងផង មណ្ឌបផង ប្រាសាទមានដំបូលរលីងផង គុហាផង ទីចង្ក្រមដ៏ល្អផង ក្នុងអារាមរបស់សង្ឃ ។*

ជន្តាឃរំ អគ្គិសាលំ អថោ ឧទកមាឡកំ
ន្ហានឃរំ មាបយិត្វា ភិក្ខុសង្ឃស្សទាសហំ ។

*មួយទៀត ខ្ញុំបានសាងរោងកម្តៅកាយ រោងភ្លើង រោងទឹក បន្ទប់សម្រាប់ស្រង់ទឹក ថ្វាយចំពោះព្រះភិក្ខុសង្ឃ ។*

អាសន្ទិយោ ច បីឋកេ បរិភោគេ ច ភាជនេ
អារាមិកញ្ច ភេសជ្ជំ សព្វមេតំ អទាសហំ ។

*ខ្ញុំបានថ្វាយជើងម៉ា តាំង គ្រឿងប្រើប្រាស់ ភាជន៍ ភេសជ្ជៈ ទាំងអស់នុ៎ះ សម្រាប់អារាម ។*

អារក្ខំ បដ្ឋបេត្វាន បាការំ ការយឹ ទឡ្ហំ
មា នំ កោចិ វិហេឋេសិ សន្តចិត្តាន តាទិនំ ។

*ខ្ញុំបានតម្កល់ទុក បុគ្គលអ្នករក្សា ឲ្យគេធ្វើកំពែងយ៉ាងមាំ (ការពារ) កុំឲ្យមានសត្រូវណាមួយ មកបៀតបៀនព្រះ*

*អង្គ ទ្រង់ជាតាទិបុគ្គល មានព្រះហឫទ័យស្ងប់រម្ងាប់ ។*

**អាវាសេ សតសហស្សេ សង្ឃារាមេ អមាបយឹ**
**វេបុល្លំ មាបយិត្វា សម្ពុទ្ធំ ឧបនាមយឹ ។**

*ខ្ញុំបានឲ្យគេសាងអាវាស ជាអារាមសម្រាប់សង្ឃ អស់ចំនួនទ្រព្យមួយសែន លុះសាងអារាមមានសភាពស្តុកស្តម្ភរួចហើយ ក៏បានបង្អោនថ្វាយដល់ព្រះសម្មាសម្ពុទ្ធថា ។*

**និដ្ឋាបិតោ មយារាមោ សម្បដិច្ឆ តុវំ មុនិ**
**និយ្យាទេស្សាមិ តំ ធីរ អធិវាសេហិ ចក្ខុម ។**

*បពិត្រព្រះមុនី អារាម ខ្ញុំបានឲ្យគេសាងស្រេចហើយ សូមព្រះអង្គទទួលយក បពិត្រព្រះធីរៈ ខ្ញុំព្រះអង្គនឹងថ្វាយទានចំពោះព្រះអង្គ បពិត្រព្រះអង្គមានចក្ខុ សូមព្រះអង្គទ្រង់ទទួលនិមន្តន៍ ។*

**បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ**
**មម សង្កប្បមញ្ញាយ អធិវាសេសិ នាយកោ ។**

*ព្រះលោកនាយក ព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវសត្វលោក ទ្រង់គួរទទួលយកនូវគ្រឿងបូជា ទ្រង់ទទួលនិមន្តន៍ហើយ ព្រោះទ្រង់ជ្រាបនូវបំណងរបស់ខ្ញុំ ។*

**អធិវាសនមញ្ញាយ សព្វញ្ញុស្ស មហេសិនោ**

**ភោជនំ បដិយាទេត្វា កាលមារោចយឹ អហំ ។**

*លុះខ្ញុំបានដឹងថា ព្រះអង្គទ្រង់ទទួលនិមន្តន៍ហើយ ទើបចាត់ចែងនូវភោជនាហារបម្រុងថ្វាយដល់ព្រះសព្វញ្ញូ ទ្រង់ស្វែងរកគុណដ៏ធំ រួចហើយ ទើបក្រាបទូលភត្តកាល ។*

**អារោចិតម្ហិ កាលម្ហិ បទុមុត្តរនាយកោ**

**ខីណាសវសហស្សេហិ អាគមំ មេ ឧបាគមិ ។**

*លុះខ្ញុំក្រាបទូលនូវភត្តកាលរួចហើយ ទើបព្រះលោកនាយកព្រះនាមបទុមុត្តរៈ ស្តេចមកកាន់អារាមរបស់ខ្ញុំ ( មួយអន្លើ ) ដោយព្រះខីណាស្រព ប្រមាណមួយពាន់អង្គ ។*

**និសិន្នកាលមញ្ញាយ អន្នបានេន តប្បយឹ**

**ភុត្តាវីកាលមញ្ញាយ ឥទំ វចនមព្រវី ។**

*ខ្ញុំដឹងនូវវេលាដែលព្រះអង្គទ្រង់គង់ស៊ប់ហើយ ក៏បានញុំាងព្រះអង្គ ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនឹងទឹក លុះខ្ញុំដឹងនូវវេលាដែលព្រះអង្គសោយស្រេចហើយ ទើបក្រាបបង្គំទូលនូវពាក្យនេះថា ។*

**កីតោ សតសហស្សេន តត្តកេនេវ ការិតោ**

**សោភនោ នាម អារាមោ សម្បដិច្ឆ តុវំ មុនិ ។**

*បពិត្រព្រះមហាមុនី ខ្ញុំព្រះអង្គបានជាវទីដី អស់តម្លៃមួយ*

*សេនកហាបណៈ បានឲ្យគេសាងអារាម ឈ្មោះសោភនៈ ដោយតម្លៃកហាបណៈប៉ុណ្ណោះដែរ សូមព្រះអង្គទ្រង់ទទួល។*

**ឥមិនា ភូមិទានេន ចេតនាបណិធីហិ ច**
**ភវេ និព្វត្តមានោហំ លភាមិ មម បត្ថិតំ ។**

*ដោយការថ្វាយភូមិនេះផង ដោយការតម្កល់ចេតនាទាំងនេះផង ខ្ញុំព្រះអង្គ កាលទៅកើតក្នុងភព ( ណា ៗ ) សូមឲ្យបានសម្រេច តាមដែលខ្ញុំព្រះអង្គប្រាថ្នា ។*

**បដិគ្គហេត្វា សម្ពុទ្ធោ សង្ឃារាមំ សុមាបិតំ**
**ភិក្ខុសង្ឃេ និសីទិត្វា ឥទំ វចនមព្រវិ ។**

*ព្រះសម្ពុទ្ធទ្រង់បានទទួលសង្ឃារាម ដែលខ្ញុំបានសាងល្អហើយ ព្រះអង្គគង់កណ្តាលនៃជំនុំភិក្ខុសង្ឃ ហើយទ្រង់ត្រាស់នូវព្រះពុទ្ធដីកានេះថា ។*

**យោ សោ ពុទ្ធស្ស ទាទាសិ សង្ឃារាមំ សុមាបិតំ**
**តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ។**

*បុគ្គលណា បានថ្វាយសង្ឃារាម ដែលខ្លួនបានសាងល្អហើយ ដល់ព្រះពុទ្ធ តថាគតនឹងព្យាករបុគ្គលនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។*

**ហត្ថី អស្សា រថា បត្តី សេនា ច ចតុរង្គិនី**

**បរិវារេស្សន្តិមំ និច្ចំ          សង្គាមស្សិទំ ផលំ ។**

*សេនាមានអង្គ ៤ គឺដំរី សេះ រថ ពលថ្មើរជើង រមែងចោម បុគ្គលនេះជានិច្ច នេះជាផលនៃសង្គ្រាម ។*

**សដ្ឋី តុរិយសហស្សានិ     ភេរិយោ សមលង្កតា**
**បរិវារេស្សន្តិមំ និច្ចំ          សង្គាមស្សិទំ ផលំ ។**

*តូរ្យតន្ត្រី ៦០ ពាន់ និងស្គរប្រដាប់ល្អហើយ រមែងចោមរោម បុគ្គលនេះជានិច្ច នេះជាផលនៃសង្គ្រាម ។*

**ឆឡាសីតិសហស្សានិ     នារិយោ សមលង្កតា**
**វិចិត្តវត្ថាភរណា          អាមុត្តមណិកុណ្ឌលា ។**

*ពួកនារីចំនួន ៨៦ ពាន់ ស្អិតស្អាងល្អហើយ សឹងស្លៀក សំពត់និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់កុណ្ឌលជាវិការៈ នៃកែវមណី ។*

**អាឡារមុខា ហសុលា     សុសញ្ញា តនុមជ្ឈិមា**
**បរិវារេស្សន្តិមំ និច្ចំ          សង្គាមស្សិទំ ផលំ ។**

*( នារីទាំងនោះ ) មានមុខស្រស់រីករាយ មានសរីរៈល្អ មាន ចង្កេះរៀវ រមែងចោមរោមបុគ្គលនេះជានិច្ច នេះជាផល នៃសង្គ្រាម ។*

**តឹសកប្បសហស្សានិ          ទេវលោកេ រមិស្សតិ**

សហស្សក្ខត្តុំ ទេវិន្ទោ ទេវរជ្ជំ ការិស្សតិ ។

*បុគ្គលនេះ នឹងត្រេកអរក្នុងទេវលោក អស់ ៣០ ពាន់កប្ប បានជាធំជាងទេវតា សោយទេវរាជ្យ អស់ចំនួនមួយពាន់ដង ។*

ទេវរាជេន បត្តព្វំ សព្វំ បដិលភិស្សតិ

អនូនភោគោ ហុត្វាន ទេវរជ្ជំ ការិស្សតិ ។

*នឹងបានសម្បត្តិទាំងពួង ដែលទេវរាជគប្បីបាន ជាអ្នកមានភោគៈមិនខ្វះខាត ហើយសោយរាជ្យក្នុងឋានទេវលោក ។*

សហស្សក្ខត្តុំ ចក្កវត្តិ រាជា រដ្ឋេ ភវិស្សតិ

បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។

*នឹងបានជាស្តេចចក្រពត្តិក្នុងដែន អស់មួយពាន់ដង នឹងបានជាស្តេចផែនដីដ៏ស្តុកស្តម្ភ គណនារាប់មិនបាន ។*

កប្បសតសហស្សម្ហិ ឱក្កាកកុលសម្ភវោ

គោតមោ នាម គោត្តេន សត្ថា លោកេ ភវិស្សតិ ។

*លុះដល់មួយសែនកប្បទៀត ព្រះគោតមបរមគ្រូ កើតក្នុងត្រកូលឱក្កាកៈ នឹងបានជាសាស្តាក្នុងលោក ។*

តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ

ឧបាលិ នាម នាមេន ហេស្សតិ សត្ថុ សាវកោ ។

*បុគ្គលនេះ នឹងបានជាឱរស ជាទាយាទក្នុងធម៌ ជាធម្មនិម្មិត មាននាមថា ឧបាលិ នឹងបានជាសាវ័កនៃព្រះសាស្តាអង្គនោះ ។*

វិនយេ បារមឹ បត្វា ឋានាឋានេ ច កោវិទោ
ជិនសាសនំ ធារយន្តោ វិហរិស្សតិនាសវោ ។

*នឹងដល់នូវត្រើយក្នុងព្រះវិន័យផង ឈ្លាសវៃក្នុងហេតុ និងមិនមែនហេតុផង ទ្រទ្រង់នូវសាសនារបស់ព្រះជិនស្រី ទាំងជាបុគ្គលមិនមានអាសវៈ ។*

សព្វមេតំ អភិញ្ញាយ គោតមោ សក្យបុង្គវោ
ភិក្ខុសង្ឃេ និសីទិត្វា ឯតទគ្គេ ឋបេស្សតិ ។

*ព្រះគោតមជាបុគ្គលប្រសើរ ក្នុងសក្យត្រកូល ទ្រង់ជ្រាបដំណើរនុ៎ះ សព្វគ្រប់ហើយ ទ្រង់គង់ក្នុងកណ្តាលនៃភិក្ខុសង្ឃ ហើយនឹងតាំងឧបាលិនុ៎ះ ក្នុងឋានៈជាឯតទគ្គៈ ។*

អបរិមេយ្យំ ឧបាទាយ បត្ថេមិ តវ សាសនំ
សោ មេ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោ ។

*ខ្ញុំប្រាថ្នានូវសាសនា គឺពាក្យប្រៀនប្រដៅរបស់ព្រះអង្គ អាស្រ័យនូវកប្បរាប់មិនបាន ប្រយោជន៍ គឺការអស់ទៅនៃសញ្ញោជនៈទាំងពួងនោះ ខ្ញុំក៏បានសម្រេចហើយ ។*

យថា សូលាវុតោ ចោរោ ឃាតនេន តជ្ជិតោ
សូលេ សាតំ អវិន្ទន្តោ បរិមុត្តឹវ ឥច្ឆតិ ។

*បុរសជាប់ក្នុងដែកអណ្ដោត ត្រូវរាជទណ្ឌគំរាមហើយ មិនបានស្រួលក្នុងដែកអណ្ដោត ប្រាថ្នាចង់ឲ្យរួចវិញ ដូចម្ដេចមិញ ។*

តថេវាហំ មហាវីរ ភវឃាតេន តជ្ជិតោ
កម្មសូលាវុតោ សន្តោ បិបាសាវេទនាដ្ឋិតោ ។

*បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គត្រូវអាជ្ញា គឺភព គំរាមហើយ ជាប់នៅហើយក្នុងដែកអណ្ដោត គឺកម្ម បិតនៅហើយដោយកម្លាំងវេទនា គឺសេចក្ដីស្រេកឃ្លាន ។*

ភវេ សាតំ ន វិន្ទាមិ ឌយ្ហន្តោ តីហិ អគ្គិហិ
បរិមុត្តឹ គវេសាមិ យថា ច រាជទណ្ឌិតោ ។

*មិនបានស្រួលក្នុងភព ក្ដៅក្រហាយដោយភ្លើងទាំង ៣ ស្វែងរកឧបាយ ដើម្បីនឹងរួចស្រឡះ ដូចបុរសដែលប្រាថ្នាដើម្បីរួចចាករាជទណ្ឌយ៉ាងនោះ ។*

យថា វិសាទោ បុរិសោ វិសេន បរិបីឡិតោ
អគទំ សោ គវេសេយ្យ វិសឃាតាយុបាលនំ ។

*មួយទៀត បុរសអ្នកក្លៀវក្លា ត្រូវពិសបៀតបៀនហើយ គេ*

*ក៏គប្បីស្វែងរកនូវឱសថ ជាឧបាយដើម្បីបន្សាបនូវពិស ។*

**គវេសមានោ បស្សេយ្យ　　　អគទំ វិសឃាតកំ**

**តំ បិវិត្វា សុខី អស្ស　　　វិសម្ហា បរិមុត្តិយា ។**

*កាលស្វែងរក ក៏បានឃើញនូវឱសថដែលជាគ្រឿងបន្សាបនូវពិស ក៏ផឹកនូវឱសថនោះ ហើយក៏បានសេចក្ដីសុខ ព្រោះរួចផុតអំពីពិស យ៉ាងណាមិញ ។*

**តថេវាហំ មហាវីរ　　　យថា វិសគតោ នរោ**

**សម្បីឡិតោ អវិជ្ជាយ　　　សទ្ធម្មាគទមេសហំ ។**

*បពិត្រព្រះអង្គមានព្យាយាមដ៏ធំ ខ្ញុំព្រះអង្គក៏ដូចជាជនអ្នកលង់នៅក្នុងពិស ត្រូវអវិជ្ជាបៀតបៀនហើយ បានស្វែងរកឱសថគឺព្រះសទ្ធម្ម ។*

**ធម្មាគទំ គវេសន្តោ　　　អទ្ទក្ខឹ សក្យសាសនំ**

**អគ្គសព្វោសថានន្តំ　　　សព្វសល្លវិនោទនំ ។**

*កាលស្វែងរកឱសថគឺធម៌ ក៏ប្រទះនូវសាសនារបស់ព្រះសក្យមុនីសម្ពុទ្ធ ជាឱសថគឺសច្ចៈដ៏ប្រសើរបំផុត ជាថ្នាំសម្រាប់បន្ទោបង់នូវសរទាំងពួង ។*

**ធម្មោសថំ បិវិត្វាន　　　វិសំ សព្វំ សមូហនឹ**

**អជរាមរំ សីតិភាវំ　　　និព្វានំ បស្សយឹ អហំ ។**

*ខ្ញុំព្រះអង្គបានផឹកឱសថគឺធម៌ ហើយដកនូវពិសទាំងពួង ចោលចេញ ក៏បានឃើញព្រះនិព្វាន ជាគុណ ឥតមាន ចាស់ស្លាប់ មានសភាពត្រជាក់ ក៏យ៉ាងនោះដែរ ។*

**យថា ភូតដ្ដិតោ ចោសោ ភូតគ្គាហេន បីឡិតោ**
**ភូតវេជ្ជំ គវេសេយ្យ ភូតស្មា បរិមុត្តិយា ។**

*បុរសត្រូវខ្មោចគំរាមហើយ ត្រូវគ្រោះថ្នាក់ គឺខ្មោចបៀតបៀន ហើយ គប្បីស្វែងរកពេទ្យសម្រាប់ចាប់ខ្មោច ដើម្បីឲ្យរួចផុត អំពីខ្មោច ។*

**គវេសមានោ បស្សេយ្យ ភូតវិជ្ជាសុ កោវិទំ**
**តស្ស សោ វិហញ្ញេ ភូតំ សមូលញ្ច វិនាសយេ ។**

*បុរសនោះ កំពុងតែស្វែងរក ក៏បានឃើញបុគ្គលអ្នក ឈ្លាសវៃ ក្នុងវិជ្ជាចាប់ខ្មោច បុគ្គលនោះ ក៏បានបំបរបង់ ខ្មោច ព្រមទាំងធ្វើឫសគល់ឲ្យវិនាស អំពីបុរសនោះចេញ យ៉ាងណាមិញ ។*

**តថេវាហំ មហាវីរ តមគ្គាហេន បីឡិតោ**
**ញាណាលោកំ គវេសាមិ តមតោ បរិមុត្តិយា ។**

*បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គត្រូវគ្រោះថ្នាក់ គឺ ងងឹតបៀតបៀនហើយ ក៏ខំស្វែងរកពន្លឺគឺញាណ ដើម្បីឲ្យ*

*ផុតអំពីផងឹត ។*

**អថទ្ទសំ សក្យមុនឹ ក្កិលេសតមសោជនំ**

**សោ មេ តមំ វិនោទេសិ ភូតវេជ្ជោវ ភូតិកំ ។**

*ក៏បានប្រទះឃើញព្រះសក្យមុនី ទ្រង់ជម្រះផងឹត គឺកិលេសរួចហើយ ព្រះអង្គទ្រង់កម្ចាត់ផងឹតរបស់ខ្ញុំព្រះអង្គ ដូចជាពេទ្យចាប់ខ្មោច បានបណ្ដេញបង់នូវខ្មោចចេញ ។*

**សំសារសោតំ សញ្ឆិន្ទឹ តណ្ហាសោតំ និវារយឹ**

**ភវំ ឧគ្ឃាតយឹ សព្វំ ភូតវេជ្ជោវ មូលតោ ។**

*ខ្ញុំព្រះអង្គបានផ្ដាច់បង់ នូវខ្សែគឺសង្សារ ហាមឃាត់នូវខ្សែ គឺតណ្ហា ដកចោលនូវភពទាំងអស់ ប្រៀបដូចពេទ្យចាប់ខ្មោច ( បៀតបៀនខ្មោច ) ឲ្យអស់ឫសគល់ ក៏យ៉ាងនោះដែរ ។*

**គរុឡោ យថា ឱបតតិ បន្នគំ ភក្ខមត្តនោ**

**សមន្តា យោជនសតំ វិក្ខោភតិ មហាសរំ ។**

*សត្វគ្រុឌ ឆាបយកពួកនាគ ជាចំណីរបស់ខ្លួន ធ្វើមហាស្រះទំហំ ១០០ យោជន៍ដោយជុំវិញ ឲ្យរំភើបញាប់ញ័រ ។*

**បន្នគំ សោ គហេត្វាន អធោសីសំ វិហេឋយំ**

**អាទាយ សោ បក្កមតិ យេន កាមំ វិហង្គមោ ។**

*លុះគ្រុឌនោះ ឆាបយកនាគ ធ្វើឲ្យមានក្បាលចុះក្រោម ឲ្យ*

*បានសេចក្តីលំបាក ហើយនាំយកទៅកាន់ទីតាមសេចក្តីប្រាថ្នារបស់ខ្លួន យ៉ាងណាមិញ ។*

តថេវាហំ មហាវីរ យថាបិ តរុណ្ឌោ ពលី
អសង្ខតំ គវេសន្តោ នោសេ វិក្ខាលយឹ អហំ ។

*បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គមានកម្លាំងខ្លាំងដូចគ្រុឌ ខ្ញុំព្រះអង្គកំពុងស្វែងរកអសង្ខតធម៌ គឺព្រះនិព្វានហើយបានខ្ជាក់ទោសចោលចេញ អស់ហើយ ។*

ទិដ្ឋោ អហំ ធម្មវរំ សន្តិបទំ អនុត្តរំ
អាទាយ វិហារាមេតំ តរុណ្ឌោ បន្នគំ យថា ។

*ខ្ញុំព្រះអង្គបានឃើញព្រះធម៌ដ៏ប្រសើរ ជាចំណែកនៃសេចក្តីស្ងប់រម្ងាប់ មិនមានគុណជាតដទៃប្រសើរលើស ហើយកាន់យកនូវធម៌នោះ ដូចគ្រុឌចាបយកនាគ ក៏យ៉ាងនោះដែរ ។*

អាសាវតី នាម លតា ជាតា ចិត្តលតាវនេ
តស្សា វស្សសហស្សេន ឯកំ និព្វត្តតេ ផលំ ។

*វល្លិឈ្មោះអាសាវតី កើតក្នុងចិត្តលតាវ័ន កន្លងទៅមួយពាន់ឆ្នាំ វល្លិនោះ ក៏កើតផ្លែមួយឡើង ។*

តំ ទេវា បយិរុបាសន្តិ តាវ ទូរផលំ សតឹ
ទេវានំ សា បិយា ឯវំ អាសាវតី ផលុត្តមា ។

ពួកទេវតា ( ក្នុងឋានតាវត្តិង្ស ) តែងនាំគ្នាចូលទៅអង្គុយជិតវល្លិនោះ ដែលមានផ្លែយូរ ៗ ម្តង តាមពិត វល្លិឈ្មោះអាសាវតីនោះ មានផ្លែដ៏ឧត្តម ជាទីពេញចិត្តរបស់ពួកទេវតាយ៉ាងនេះ ។

**សតសហស្សំ ឧចាជាយ តាហំ បរិចរេ មុនឹ**
**សាយំ ចាតំ នមស្សាមិ ទេវា អាសាវតឹ យថា ។**

ចំណែកខាងខ្ញុំព្រះអង្គ ខំបម្រើព្រះមុនីអង្គនោះ រាប់សែនកប្ប ( ប៉ុណ្ណោះ ) តែងនមស្ការរាល់ព្រឹកល្ងាច ដូចជាពួកទេវតា តែងចូលទៅអង្គុយជិតវល្លិអាសាវតី ។

**អវញ្ឈា ចារិចរិយា អមោឃា ច នមស្សនា**
**ទូរាគតំបិ មំ សន្តំ ខណោ មំ ន វិរាធយិ ។**

ការបម្រើ ( របស់ខ្ញុំព្រះអង្គ ) មិនឥតអំពើ ទាំងការនមស្ការក៏មិនជាមោឃៈ ពុទ្ធុប្បាទក្ខណៈ ក៏មិនបានប្រព្រឹត្តកន្លងនូវខ្ញុំព្រះអង្គ អស់កាលជាយូរអង្វែង ។

**បដិសន្ធឹ ន បស្សាមិ វិចិនន្តោ ភវេ អហំ**
**និរូបធិ វិប្បមុត្តោ ឧបសន្តោ ចរាមហំ ។**

ឥឡូវនេះ ខ្ញុំព្រះអង្គត្រិះរិះទៅ មិនឃើញបដិសន្ធិក្នុងភពថ្មីទៀតទេ ខ្ញុំព្រះអង្គមិនមានឧបធិក្កិលេស រួចស្រឡះចាក

*សង្ខារ មានចិត្តស្ងប់រម្ងាប់ ។*

**យថាបិ បទុមំ ជាម  សុរិយរំសេន បុប្ផតិ**
**តថេវាហំ មហាវីរ  ពុទ្ធរំសេន បុប្ផិតោ ។**

*ធម្មតាផ្កាឈូក តែងរីកដោយសាររស្មីនៃព្រះអាទិត្យ យ៉ាងណាមិញ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គ បានរីកដោយសាររស្មីព្រះពុទ្ធ ក៏យ៉ាងនោះដែរ ។*

**យថា ពលាកយោនិម្ហិ  ន វិជ្ជតិ បុមា សទា**
**មេឃេសុ គជ្ជមានេសុ  គព្ភំ គណ្ហន្តិ តា សទា ។**

*កំណើតកុកស មិនមានឈ្មោល សព្វៗ កាលទេ កាលបើមេឃគំរាម ( ផ្គរលាន់ ) កុកទាំងនោះ ក៏កាន់យកនូវគភ៌សព្វ ៗ កាល ។*

**ចិរំបិ គព្ភំ ធារេន្តិ  យាវ មេឃោ ន គជ្ជតិ**
**ភារតោ បរិមុច្ចន្តិ  យទា មេឃោ បវស្សតិ ។**

*កុកទាំងនោះ ទ្រទ្រង់គភ៌អស់កាលដ៏យូរ ដរាបទាល់តែមេឃលែងគំរាម ទាល់តែមេឃបង្អុរភ្លៀង ទើបកុកទាំងនោះ រួចផុតចាកភារៈ យ៉ាងណាមិញ ។*

**បទុមុត្តរពុទ្ធស្ស  ធម្មមេឃេន គជ្ជតោ**
**សទ្ទេន ធម្មមេឃស្ស  ធម្មគព្ភំ អគណ្ហាហំ ។**

*កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់គំរាមដោយមេឃ គឺធម៌ ខ្ញុំព្រះអង្គបានកាន់យកនូវគភ៌ គឺធម៌ ដោយសំឡេងនៃមេឃ គឺធម៌ ។*

**សតសហស្សំ ឧចាជាយ  បុញ្ញកព្ភំ ជរេមហំ**
**ជប្បមុញ្ចាមិ ភារតោ  ជម្មមេឃោ ជ កជ្ជតិ ។**

*ខ្ញុំព្រះអង្គទ្រទ្រង់នូវគភ៌ គឺបុណ្យ រាប់សែនកប្ប មេឃគឺធម៌មិនគំរាម ( ដរាបណា ) ខ្ញុំក៏មិនបានរួចចាកភារៈធ្ងន់ ( ដរាបនោះ ) ។*

**យជា តុវំ សក្យមុជិ  រម្មេ កាបិលវត្ថវេ**
**កជ្ជសិ ជម្មមេឃេជ  ភារតោ បរិមុច្ចហំ ។**

*បពិត្រព្រះសក្យមុនី ពេលណាព្រះអង្គទ្រង់គំរាមដោយមេឃគឺធម៌ ក្នុងក្រុងកបិលព័ស្តុដែលជាទីត្រេកអរ ខ្ញុំព្រះអង្គក៏បានរួចចាកភារៈដ៏ធ្ងន់ យ៉ាងនោះដែរ ។*

**សុញ្ញតំ អជិមិត្តញ្ច  អចាបណិហិតំបិ ច**
**ចតុរោ ច ផលេ សព្វេ  ជម្មំ វិជជិ តំបិហំ ។**

*ខ្ញុំព្រះអង្គ ( បានទាំងធ្វើឲ្យជាក់ច្បាស់ ) នូវសុញ្ញតវិមោក្ខផង អនិមិត្តវិមោក្ខផង អប្បណិហិតវិមោក្ខផង ត្រាស់ដឹងនូវធម៌ទាំងពួង គឺផលទាំង ៤ ផង ទម្លាយនូវធម៌ គឺ*

បណ្ដាញនោះផង ។

**អបរិមេយ្យំ ឧបាទាយ បត្ថេមិ តវ សាសនំ**

**សោ មេ អត្ថោ អនុប្បត្តោ សន្តិបទំ អនុត្តរំ ។**

*ខ្ញុំព្រះអង្គប្រាថ្នានូវសាសនារបស់ព្រះអង្គ រាប់កប្បប្រមាណមិនបាន ប្រយោជន៍ គឺចំណែកនៃសេចក្ដីស្ងប់ ដ៏ប្រសើរបំផុត ខ្ញុំព្រះអង្គបានសម្រេចហើយ ។*

**វិនយេ បារមី ភតោ យថាបិ បាឋិកោ ឥសី**

**ន មេ សមសមោ អត្ថិ ធារេមិ សាសនំ អហំ ។**

*ខ្ញុំព្រះអង្គដល់នូវត្រើយក្នុងព្រះវិន័យ ដូចភិក្ខុអ្នកស្វែងរកនូវគុណ អ្នកសូត្រ (ក្នុងជំនាន់សាសនាព្រះពុទ្ធ ព្រះនាមបទុមុត្តរៈនោះដែរ) ភិក្ខុជាអ្នកមានគុណស្មើនឹងខ្ញុំព្រះអង្គមិនមានឡើយ ខ្ញុំព្រះអង្គទ្រទ្រង់សាសនា ។*

**វិនយេ ខន្ធកេ ចាបិ តិកច្ឆេទេ ច បញ្ចកេ**

**ឯត្ថ មេ វិមតិ នត្ថិ អក្ខរេ ព្យញ្ជនេបិ វា ។**

*សេចក្ដីសង្ស័យរបស់ខ្ញុំព្រះអង្គ ក្នុងវិន័យនុ៎ះផង ក្នុងខន្ធកវិន័យផង ក្នុងតិកច្ឆេទៈផង ក្នុងបញ្ចកៈផង សូម្បីតែអក្ខរៈមួយ ឬក៏ព្យញ្ជនៈមួយ មិនមានឡើយ ។*

**និគ្គហេ បដិកម្មេ ច ឋានាឋានេ ច កោវិទោ**

**ឱសារណេ វុដ្ឋាបនេ សព្វត្ថ ចារមឹ គតោ ។**

*ខ្ញុំព្រះអង្គដល់នូវត្រើយក្នុងព្រះវិន័យទាំងពួង រាប់វៃក្នុងការសង្កត់សង្កិនភិក្ខុបាបផង ក្នុងបដិកម្ម គឺការសម្ដែងអាបត្តិផង ក្នុងហេតុដ៏គួរនិងមិនគួរផង ក្នុងឱសារណកម្ម គឺហៅភិក្ខុចូលកាន់ទីប្រជុំសង្ឃ ក្នុងកាលញុាំងភិក្ខុឲ្យចេញចាកអាបត្តិផង ។*

**វិនយេ ខន្ធកេ ចាបិ និក្ខិបិត្វា បទំ អហំ**

**ឧភតោ វិភង្គេ ចេវ រសតោ ឱសរេយ្យហំ ។**

*ខ្ញុំព្រះអង្គបានរៀបទុកដាក់នូវចំណែក ក្នុងវិន័យផង ក្នុងខន្ធកៈផង ក្នុងឧភតោវិភង្គផង ហើយគប្បីឲ្យប្រជុំចុះដោយកិច្ចបាន ។*

**និរុត្តិយា ច កុសលោ អត្ថានត្ថេ ច កោវិទោ**

**អនញ្ញាតំ មយា នត្ថិ ឯកគ្គោ សត្ថុ សាសនេ ។**

*ខ្ញុំព្រះអង្គជាអ្នកឈ្លាសវៃ ក្នុងវោហារផង រាប់វៃក្នុងហេតុចម្រើន និងហេតុមិនចម្រើនផង សភាពដែលខ្ញុំព្រះអង្គមិនចេះដឹង (នោះ) មិនមានឡើយ ខ្ញុំព្រះអង្គជាភិក្ខុខ្ពស់ឯក ក្នុងសាសនារបស់ព្រះសាស្ដា ។*

**រូបនក្ខេ អហំ អជ្ជ សក្យបុត្តស្ស សាសនេ**

**កាជ្ជំ សត្ថុ វិនោទេមិ  ឆិន្ទាមិ សព្វសំសយំ ។**

*ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គជាបុគ្គលយល់រូប ក្នុងសាសនានៃព្រះពុទ្ធ ជាសក្យបុត្ត ហើយបន្ទោបង់នូវកង្ខាទាំងពួង កាត់បង់នូវសង្ស័យទាំងអស់បាន ។*

**បទំ អនុបទញ្ចាបិ  អក្ខរញ្ចាបិ ព្យញ្ជនំ**
**និទានេ បរិយោសានេ  សព្វត្ថ កោវិទោ អហំ ។**

*ខ្ញុំព្រះអង្គ (ដឹងច្បាស់) នូវបទផង អនុបទផង អក្ខរៈផង ព្យញ្ជនៈផង ឈ្លាសវៃក្នុងហេតុសព្វអន្លើ គឺហេតុជាទីតាំង (ខាងដើម) និងហេតុជាទីតាំងខាងចុង (នៃសិក្ខាបទ) ។*

**យថាបិ រាជា ពលវា  និគ្គហេត្វា បរន្តបេ**
**វិជិនិត្វាន សង្គាមំ  នគរំ តត្ថ មាបយេ ។**

*ព្រះរាជាមានកម្លាំងទ្រង់សង្កត់សង្កិន នូវពួកស្ដេចជាសត្រូវ លុះទ្រង់ឈ្នះសង្គ្រាមហើយ ទើបសាងទីក្រុងក្នុងដែនដែលទ្រង់ឈ្នះហើយនោះ ។*

**បាការំ បរិក្ខញ្ចាបិ  ឯសិកំ ទ្វារកោដ្ឋកំ**
**អដ្ដាលកេ ច វិវិធេ  ការយេ នគរេ ពហូ ។**

*ទ្រង់ឲ្យជាងធ្វើកំពែង ស្នាមភ្លោះ សសរខឿន ខ្លោងទ្វារ និងប៉មទាំងឡាយផ្សេងៗ ជាច្រើន ក្នុងនគរ ។*

សិង្ឃាដកំ បចុរញ្ច សុវិភត្តន្តរាបណំ
ការាបេយ្យ សកំ តត្ថ អត្ថានត្ថវិនិច្ឆយំ ។

*ទ្រង់ឲ្យជាងធ្វើនូវផ្លូវត្រឡែងកែង ផ្លូវថ្នល់ រានផ្សារ ជាចន្លោះ ដែលតាក់តែងល្អ ព្រមទាំងសភាសម្រាប់វិនិច្ឆ័យនូវសេចក្តីចម្រើននិងសេចក្តីមិនចម្រើន ក្នុងនគរនោះ ។*

និគ្ឃាដត្តំ អមិត្តានំ និទ្ធានិទ្ធញ្ច ជានិតុំ
ពល កាយស្ស រក្ខាយ សេនាបច្ចំ បបេតិ សោ ។

*ព្រះរាជាអង្គនោះ ទ្រង់តាំងសេនាមាត្យដើម្បីឲ្យសង្កត់សង្កិននូវពួកសត្រូវ ឲ្យស្គាល់ទោសនិងមិនមែនទោស ដើម្បីរក្សានូវពួកពល ។*

អារក្ខត្ថាយ ភណ្ឌស្ស និធានកុសលំ នរំ
មា មេ ភណ្ឌំ វិនស្សីតិ ភណ្ឌារក្ខំ បបេតិ សោ ។

*ព្រះរាជាអង្គនោះ ទ្រង់តាំងបុរសអ្នករក្សានូវភណ្ឌៈ ជាអ្នកឈ្លាសវៃក្នុងការទុកដាក់ ដើម្បីប្រយោជន៍រក្សានូវភណ្ឌៈដោយព្រះរាជបំណាងថា កុំឲ្យភណ្ឌៈរបស់អាត្មាអញវិនាសទៅបានឡើយ ។*

សមគ្គោ ហោតិ យោ រញ្ញោ វុឌ្ឍី យស្ស ច ឥច្ឆតិ
តស្សាធិករណំ ទេតិ មិត្តស្ស បដិបជ្ជិតុំ ។

*បុរសនោះ ជាអ្នកមានចិត្តស្វាមីភក្តិចំពោះព្រះរាជា ព្រោះព្រះរាជាប្រាថ្នាការចម្រើនដល់បុរសណា ទ្រង់ក៏ព្រះរាជទាននូវឥស្សរៈ ក្នុងការវិនិច្ឆ័យអធិករណ៍ដល់បុរសនោះ ដើម្បីប្រតិបត្តិកុំឲ្យបែកមិត្ត ។*

**ឧប្បាទេសុ និមិត្តេសុ លក្ខណេសុ ច កោវិទំ**
**អជ្ឈាយកំ មន្តធរំ ចោរោហិច្ចេ ឋបេតិ សោ ។**

*ព្រះរាជានោះ ទ្រង់តាំងបុរសអ្នកវាងវៃ ក្នុងឧប្បាទហេតុទាំងឡាយផង ក្នុងនិមិត្តទាំងឡាយផង ក្នុងលក្ខណៈទាំងឡាយផង ជាអ្នកបង្រៀនមន្ត ចេះចាំមន្ត ក្នុងឋានៈជាបុរោហិត ។*

**ឯតេហង្គេហិ សម្បន្នោ ខត្តិយោតិ បវុច្ចតិ**
**សទា រក្ខន្តិ រាជានំ ចក្កវាកោវ ទុក្ខិតំ ។**

*ព្រះរាជាបរិបូណ៌ដោយអង្គទាំងឡាយនុ៎ះហើយ ទើបហៅថា ក្សត្រិយ៍ បុរសទាំងនោះ តែងរក្សាព្រះរាជានោះ សព្វ ៗ កាល ដូចសត្វចាក្រពាក រក្សាក្រុមញាតិដែលដល់សេចក្តីទុក្ខ ។*

**តថេវ ត្វំ មហាវីរ ហតាមិត្តោវ ខត្តិយោ**
**សទេវកស្ស លោកស្ស ធម្មរាជាតិ វុច្ចតិ ។**

*បពិត្រព្រះអង្គ មានព្យាយាមធំ អ្នកផងតែងហៅព្រះអង្គ ថា ធម្មរាជរបស់សត្វលោក ព្រមទាំងទេវលោក ដូចក្សត្រិយ៍ដែលកម្ចាត់សត្រូវហើយ ដូច្នោះដែរ ។*

**តិត្ថិយេ ជីហរិត្វាន មារញ្ចាបិ សសេនកំ**
**តមន្ធការំ វិធំសេត្វា ធម្មនគរំ អមាបយិ ។**

*ព្រះធម្មរាជនោះ ទ្រង់ញាំញីនូវពួកតិរ្ថិយទាំងឡាយផង នូវមារព្រមទាំងសេនាផង ទ្រង់ទម្លាយមោហន្ធការដ៏ងងឹត រួចហើយកសាងធម្មនគរ ។*

**សីលំ ចាការិកំ តត្ថ ញាណន្តេ ទ្វារកោដ្ឋកំ**
**សទ្ធា តេ ឯសិកា ធីរ ទ្វារបាលោ ច សំវរោ ។**

*បពិត្រព្រះអង្គមានបញ្ញាជាគ្រឿងទ្រទ្រង់ ឯក្នុងធម្មនគរនោះ មានសីលជាកំពែង មានញាណរបស់ព្រះអង្គ ជាខ្លោងទ្វារ មានសទ្ធារបស់ព្រះអង្គ ជាសសរខឿន មានការសង្រួម ជានាយឆ្មាំទ្វារ ។*

**សតិប្បដ្ឋានមដ្ដាលំ បញ្ញា តេ ចច្ចរំ មុនេ**
**ឥទ្ធិបាទញ្ច សីឃាដំ ធម្មវីថិ សុមាបិតំ ។**

*បពិត្រព្រះមុនី សតិប្បដ្ឋានជាប៉ម បញ្ញារបស់ព្រះអង្គជាផ្លូវថ្នល់ ឥទ្ធិបាទជាផ្លូវត្រឡែងកែង ថ្នល់គឺពោធិបក្ខិយធម៌*

*ទាំង ៣៧ ព្រះអង្គទ្រង់និម្មិតទុកល្អហើយ ។*

សុត្តន្តំ អភិធម្មញ្ច វិនយំ ចាបិ កេវលំ
នវង្គំ ពុទ្ធវចនំ ឯសា ធម្មសភា តវ ។

*ព្រះសូត្រ ព្រះអភិធម្ម និងព្រះវិន័យ ពុទ្ធវចនៈមានអង្គ ៩ ទាំងអស់នុ៎ះ ជាធម្មសភារបស់ព្រះអង្គ ។*

សុញ្ញតំ អនិមិត្តញ្ច វិហារញ្ចាប្បណីហិតំ
អនេជោ ច និរោធោ ច ឯសា ធម្មកុដី តវ ។

*សុញ្ញតវិហារ អនិមិត្តវិហារ អប្បណិហិតវិហារ ការមិនមានតណ្ហាជាគ្រឿងញាប់ញ័រ និងការរំលត់ទុក្ខ នេះជាធម្មកុដិរបស់ព្រះអង្គ ។*

បញ្ញាយ អគ្គោ និក្ខិត្តោ បដិភាណោ ច កោវិទោ
សារីបុត្តោតិ នាមេន ធម្មសេនាបតី តវ ។

*ព្រះថេរៈជាបុគ្គលប្រសើរខាងប្រាជ្ញា ដែលព្រះអង្គតាំងទុកហើយ ជាអ្នកវាងវៃក្នុងប្រាជ្ញា មានឈ្មោះថា សារីបុត្ត ជាធម្មសេនាបតីរបស់ព្រះអង្គ ។*

ចុតូបបាតកុសលោ ឥទ្ធិយា បារមឹ គតោ
កោលិតោ នាម នាមេន បោរោហិច្ចោ តវំ មុនេ ។

*បពិត្រព្រះមុនី ព្រះថេរៈដែលឈ្លាសវៃក្នុងចុតូបបាតញ្ញាណ*

*គឺប្រាជ្ញាដែលដឹងនូវចុតិនិងបដិសន្ធិរបស់សត្វ ដល់នូវត្រើយនៃឫទ្ធិ មានឈ្មោះថា កោលិត ជាបុរោហិតរបស់ព្រះអង្គ ។*

**ធោរាណាកវំសធរោ ឧគ្គតេជោ ទុរាសទោ**
**ធុតវាទិគុណេ អគ្គោ អគ្ឃធស្សោ តវំ មុនេ ។**

*បពិត្រព្រះមុនី ព្រះថេរៈឈ្មោះកស្សប អ្នកទ្រទ្រង់វង្សបុរាណ មានតេជៈដ៏ខ្ពង់ខ្ពស់ ដែលគេគ្របសង្កត់បានដោយក្រ ប្រសើរក្នុងគុណ មានការកម្ចាត់បង់នូវទោសជាដើម គឺទ្រទ្រង់ធុតង្គទាំង ១៣ ជាអ្នកសម្រាប់ពិភាក្សារបស់ព្រះអង្គ ។*

**ពហុស្សុតោ ធម្មធរោ សព្វបាឋី ច សាសនេ**
**អានន្ទោ នាម នាមេន ធម្មរក្ខោ តវំ មុនេ ។**

*បពិត្រព្រះមុនី ព្រះថេរៈជាពហុស្សុត អ្នកទ្រទ្រង់ធម៌ ចេះចាំពុទ្ធវចនៈទាំងអស់ក្នុងសាសនា មាននាមថា អានន្ទ ជាអ្នករក្សាធម៌របស់ព្រះអង្គ ។*

**ឯតេ សព្វេ អតិក្កម្ម មហេសី ភគវា មម**
**វិនិច្ឆយំ មេ បាទាសិ វិនយេ វិញ្ញុទេសិតំ ។**

*ព្រះមានព្រះភាគរបស់ខ្ញុំ ជាអ្នកស្វែងរកគុណដ៏ធំ ទ្រង់ប្រទានការវិនិច្ឆ័យក្នុងវិន័យ ដែលវិញ្ញូភិក្ខុទាំងឡាយសម្តែង*

*ហើយ ដល់ខ្ញុំព្រះអង្គ រំលងព្រះថេរៈទាំងអស់នុ៎ះ ។*

**យោ កោចិ វិនយេ បញ្ហំ  បុច្ឆតិ ពុទ្ធសាវកោ**
**តត្ថ មេ ចិន្តនា នត្ថិ  តញ្ញេវត្ថំ កថេមហំ ។**

*ពុទ្ធសាវកណាមួយ សួរបញ្ហាក្នុងវិន័យ ( នឹងខ្ញុំព្រះអង្គ ) ខ្ញុំព្រះអង្គមិនបាច់គិត ក្នុងបញ្ហានោះទេ ខ្ញុំព្រះអង្គប្រាប់សេចក្តីនោះតែម្តង ។*

**យាវតា ពុទ្ធខេត្តម្ហិ  ឋបេត្វា ច មហាមុនឹ**
**វិនយេ មាទិសោ នត្ថិ  កុតោ ភិយ្យោ ភវិស្សតិ ។**

*ពុទ្ធក្ខេត្តកំណត់ត្រឹមណា វៀរលែងតែព្រះមហាមុនីចេញ មិនមានភិក្ខុណា នឹងស្មើដោយខ្ញុំព្រះអង្គក្នុងវិន័យ តើនឹងមានភិក្ខុប្រសើរលើសខ្ញុំព្រះអង្គ ពីណា ។*

**ភិក្ខុសង្ឃេ និសីទិត្វា  ឯវំ គជ្ជតិ គោតមោ**
**ឧបាលិស្ស សមោ នត្ថិ  វិនយេ ខន្ធកេសុ ច ។**

*ព្រះគោតមទ្រង់គង់ក្នុងកណ្តាលជំនុំភិក្ខុសង្ឃ ហើយទ្រង់ប្រកាសយ៉ាងនេះថា ភិក្ខុណាមួយជាអ្នកស្មើដោយឧបាលិក្នុងវិន័យនិងខន្ធកៈ មិនមានឡើយ ។*

**យាវតា ពុទ្ធភណិតំ  នវង្គំ សត្ថុសាសនំ**
**វិនយេ កថិតំ សព្វំ  វិនយមូលបស្សិនោ ។**

*សត្ថុសាសនា មានអង្គ ៩ ដែលព្រះពុទ្ធសម្តែងហើយ ទាំងអម្បាលម៉ាន ខ្ញុំព្រះអង្គជាអ្នកឃើញឫសគល់របស់វិន័យ ( កាត់បង់ ) នូវសេចក្តីជាប់ចំពាក់ទាំងពួង ដែលព្រះអង្គសម្តែងហើយក្នុងវិន័យ ។*

**មម កម្មំ សរិត្វាន គោតមោ សក្យបុង្គវោ**
**ភិក្ខុសង្ឃេ និសីទិត្វា ឯតទគ្គេ ឋបេសិ មំ ។**

*ព្រះគោតមជាបុគ្គលប្រសើរ ក្នុងសក្យត្រកូល ទ្រង់រឭកឃើញនូវអំពើរបស់ខ្ញុំ ហើយគង់ក្នុងភិក្ខុសង្ឃ ទ្រង់តម្កល់ខ្ញុំក្នុងទីជាឯតទគ្គៈ ។*

**សតសហស្សំ ឧបាទាយ ឥមំ ឋានំ អបត្ថយឹ**
**សោ មេ អត្ថោ អនុប្បត្តោ វិនយេ បារមឹ គតោ ។**

*ខ្ញុំបានប្រាថ្នាយកនូវតំណែងនេះ រាប់សែនកប្បមកហើយ ឥឡូវនេះ ប្រយោជន៍នោះ ខ្ញុំបានសម្រេចហើយ ខ្ញុំបានដល់នូវត្រើយក្នុងព្រះវិន័យហើយ ។*

**សក្យានំ នន្ទិជននោ កប្បកោ អាសិហំ បុរេ**
**វិជហិត្វាន តំ ជាតឹ បុត្តោ ជាតោ មហេសិនោ ។**

*កាលពីដើម ខ្ញុំជានាយខ្មាន់ព្រះកេស ជាអ្នកបណ្តុះសេចក្តីត្រេកអរដល់ពួកសក្យៈ លះបង់កំណើតនោះ ចោលចេញ*

*បានមកជាបុត្ត របស់ព្រះមហេសីសម្មុទ្ទវិញ ។*

**ឥតោ ទុតិយកេ កប្បេ អញ្ញសោ នាម ខត្តិយោ**
**អនន្តតេជោ អមិតយសោ ភូមិបាលោ មហទ្ធនោ ។**

*ក្នុងកប្បទី ២ រាប់អំពីភទ្ទកប្បនេះទៅ មានក្សត្រិយ៍ឈ្មោះ អញ្ញសៈ មានតេជះរកទីបំផុតគ្មាន មានយសរាប់មិនបាន ជាម្ចាស់ផែនដី មានទ្រព្យច្រើន ។*

**តស្ស រញ្ញោ អហំ បុត្តោ ចន្ទនោ នាម ខត្តិយោ**
**ជាតិមទេន បត្ថទ្ធោ យសភោគមទេន ច ។**

*ខ្ញុំជាព្រះរាជបុត្តរបស់ព្រះរាជានោះ ជាក្សត្រិយ៍ ឈ្មោះ ចន្ទនៈ ជាអ្នករឹងត្អឹង ដោយស្រវឹងព្រោះជាតិផង ដោយ ស្រវឹងព្រោះយសស័ក្តិ និងភោគៈផង ។*

**នាគសតសហស្សានិ សព្វាលង្ការភូសិតា**
**តិធា បភិន្នា មាតង្គា បរិវារេន្តិ មំ សទា ។**

*មានពួកដំរីមាតង្គៈចំនួន ១ សែន សុទ្ធតែចុះប្រេង ដោយ ហេតុ ៣ ប្រការ*[១] *ដ៏ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ចោមរោមខ្ញុំ សព្វៗ កាល ។*

---

*១-ដំរីចុះប្រេងបែកអាការចេញប្រេង ៣ កន្លែង គឺបែកក្បែរភ្នែក ១ បែក ក្បែរត្រចៀក ១ បែកត្រង់សាច់គល់ភ្លុក ១ (អដ្ឋកថា) ។*

សពលេហិ បរេតោហំ ឧយ្យានំ គន្តុកាមកោ
អារុយ្ហ សិរិកំ ជាតំ ឯកកា និក្ខមឹ តទា ។

*វេលានោះ ខ្ញុំមានពួកពលរបស់ខ្លួនចោមរោមហើយ ប្រាថ្នាទៅកាន់ឧទ្យាន ឡើងជិះដំរីឈ្មោះសិរិកៈ ចេញអំពីនគរទៅ ។*

ចរណេន ច សម្បន្នោ គុត្តទ្វារោ សុសំវុតោ
រេវតោ នាម សម្ពុទ្ធោ អាគច្ឆិ បុរតោ មមំ ។

*ស្រាប់តែមានព្រះបច្ចេកសម្ពុទ្ធ ព្រះនាមរេវតៈ ទ្រង់បរិបូណ៌ដោយចរណៈ មានទ្វារគ្រប់គ្រង សង្រួមល្អ បាននិមន្តមកចំពោះមុខខ្ញុំ ។*

បេសេត្វា សិរិកំ ជាតំ ពុទ្ធំ អាសាទយឹ តទា
តតោ សញ្ជាតកោបោវ នាគោ នុទ្ធរតេ បទំ ។

*វេលានោះ ខ្ញុំបានបរដំរីឈ្មោះសិរិកៈ ទៅឲ្យបៀតបៀនព្រះសម្ពុទ្ធ លំដាប់នោះ ដំរីក៏ក្រោធខឹង មិនលើកជើង ។*

នាគំ រុណ្ណមនំ ទិស្វា ពុទ្ធេ កោបំ អកាសហំ
វិហេឋយិត្វា សម្ពុទ្ធំ ឧយ្យានំ អគមាសហំ ។

*លុះខ្ញុំឃើញដំរីមានចិត្តខឹង ក៏ក្រេវក្រោធនឹងព្រះពុទ្ធជាម្ចាស់ បៀតបៀនព្រះសម្ពុទ្ធហើយ ក៏ទៅក្នុងឧទ្យាន ។*

សាតំ តត្ថ ន វិន្ទាមិ សិរោ បជ្ជលិតោ យថា
បរិឡាហេន ឌយ្ហាមិ មច្ឆោវ ពលិសាទកោ ។

*ខ្ញុំមិនបាននូវសេចក្ដីសុខស្រួល ក្នុងឧទ្យាននោះ ក្បាល (របស់ខ្ញុំ) ហាក់ដូចជាភ្លើងឆេះ ខ្ញុំក្ដៅអន្ទះអន្ទែងដោយសេចក្ដីក្រហល់ក្រហាយ ដូចត្រីជាប់សន្ទូច ។*

សសាគរន្តា បឋវី អាទិត្តា វិយ ហោតិ មេ
បិតុ សន្តិកុបាគម្ម ឥទំ វចនមព្រវឹ ។

*ផែនដីដែលមានសាគរជាទីបំផុត ហាក់ដូចជាដុតកម្ដៅខ្ញុំ ទើបខ្ញុំចូលទៅកាន់សម្នាក់នៃព្រះបិតា ហើយក្រាបបង្គំទូលថា*

អាសិវិសំវ កុបិតំ អគ្គិក្ខន្ធំវ អាគតំ
មត្តំវ កុញ្ជរំ ទន្តឹ យំ សយម្ភុំ អាសាទយឹ ។

*យើងខ្ញុំបៀតបៀនព្រះពុទ្ធសយម្ភូណា ដូចបុគ្គលបៀតបៀនអាសិរពិស ដែលកំពុងក្រោធ ឬដូចបុគ្គលបៀតបៀនគំនរភ្លើងដែលឆេះរាលមក ឬក៏ដូចបុគ្គលបៀតបៀនដំរីមានភ្លុកដែលចុះប្រេង ។*

អាសាទិតោ មយា ពុទ្ធោ ឃោរោ ឧគ្គតបោ ជិនោ
បុរា សព្វេ វិនស្សាម ខមាបេស្សាម តំ មុនឹ ។

*ព្រះពុទ្ធជាម្ចាស់អង្គនោះ មានតបៈដ៏ខ្ពង់ខ្ពស់ក្រៀវក្លា ជា*

*ព្រះជិនស្រី យើងខ្ញុំបៀតបៀនហើយ យើងខ្ញុំទាំងអស់គ្នានឹងវិនាស យើងខ្ញុំនឹងញ៉ាំងព្រះសយម្ភូ ជាមុនីអង្គនោះ ឲ្យអត់ទោស ។*

**នោ ចេ តំ និជ្ឈាបេស្សាម  អត្តទន្តំ សមាហិតំ**
**ឱរេន សត្តមេ ទិវសេ  រដ្ឋម្មេ វិជមិស្សតិ ។**

*ប្រសិនបើយើងខ្ញុំ នឹងមិនបានញ៉ាំងព្រះពុទ្ធ ដែលមានខ្លួនទូន្មានហើយ មានព្រះហឫទ័យខ្ជាប់ខ្ជួននោះ ឲ្យអត់ទោសទេ ដែនរបស់យើងខ្ញុំមុខជាវិនាស ថយពីថ្ងៃទី ៧ ទៅ មិនខាន ។*

**សុមេខលោ កោសិយោ ច  សិគ្គវោ ចាបិ សត្តកោ**
**អាសាទយិត្វា ឥសយោ  ទុគ្គតា តេ សសេនកា ។**

*ក្សត្រិយ៍ ៤ ព្រះអង្គ ព្រះនាមសុមេខលៈ ១ កោសិយៈ ១ សិគ្គវៈ ១ សត្តកៈ ១ ជាមួយនឹងពួកសេនានោះ បានបៀតបៀនឥសីទាំងឡាយ ហើយដល់នូវសេចក្តីវិនាស ។*

**យទា កុប្បន្តិ ឥសយោ  សញ្ញតា ព្រហ្មចារិនោ**
**សទេវកំ វិនាសេន្តិ  សសាគរំ សបព្វតំ ។**

*ពួកឥសីអ្នកសង្រួម ប្រព្រឹត្តព្រហ្មចរិយធម៌ ក្រោធខឹងក្នុងកាលណា រមែងធ្វើសត្វលោក ព្រមទាំងទេវលោក ទាំង*

*សមុទ្ទនិងភ្នំ ឲ្យវិនាសទៅបាន ។*

**តិយោជនសហស្សម្ហិ បុរិសេ សន្និបាតយឹ**
**អច្ចយំ ទេសនត្ថាយ សយម្ភុំ ឧបសង្កមឹ ។**

*ខ្ញុំបានប្រជុំពួកបុរស ក្នុងទី ៣ ពាន់យោជន៍ បានចូលទៅគាល់ព្រះសយម្ភូ ដើម្បីនឹងសម្តែងទោស ។*

**អល្លវត្ថា អល្លសិរា សព្វេ បញ្ជលីកតា**
**ពុទ្ធស្ស ចរណេ និបតិត្វា ឥទំ វចនមព្រវុំ ។**

*ពួកបុរសទាំងពួង ស្លៀកសំពត់ទទឹក មានក្បាលទទឹក ធ្វើក្រពុំម្រាមដៃ ក្រាបទៀប ( ព្រះបាទារបស់ ) ព្រះពុទ្ធ ហើយទូលថា ។*

**ខមស្សុ ត្វំ មហាវីរ អភិយាចតិ តំ ជនោ**
**បរិឡាហំ វិនោទេហិ មា ច រដ្ឋំ វិនាសយ ។**

*បពិត្រព្រះអង្គមានព្យាយាមធំ សូមព្រះអង្គអត់ទោស ( ព្រោះ ) ជនសូមទោសនឹងព្រះអង្គ សូមព្រះអង្គរម្ងាប់ក្រវល់ក្រវាយ សូមព្រះអង្គកុំធ្វើដែន ( របស់យើងខ្ញុំ ) ឲ្យវិនាសឡើយ ។*

**សទេវមានុសា សព្វេ សទានវា សរក្ខសា**
**អយោមយេន កូដេន សិរំ ភិន្ទេយ្យុ មេ សទា ។**

*( ប្រសិនបើព្រះអង្គមិនអនុគ្រោះទេ ) ពួកបុរសទាំងអស់ព្រមទាំងទេវតានិងមនុស្ស ទាំងអ្នកធ្វើទាន ទាំងអ្នកថែរក្សា គេនឹងយកញញួរដែក មកទម្វាយអម្បែងក្បាលយើងខ្ញុំសព្វៗ កាល ។*

**ឧទកោ អគ្គិ ន សណ្ឋាតិ ពីជំ សេលេ ន រូហតិ**
**អគទេ ភិមិ ន សណ្ឋាតិ កោធោ ពុទ្ធេ ន ជាយតិ ។**

*( ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ) ភ្លើងមិនឋិតនៅក្នុងទឹក ពូជមិនដុះលើថ្មភ្នំ ដង្កូវមិនឋិតនៅក្នុងឱសថ សេចក្តីក្រោធមិនកើតក្នុងព្រះពុទ្ធ ។*

**យថា ច ភូមិ អចលា អប្បមេយ្យោ ច សាគរោ**
**អនន្តកោ ច អាកាសោ ឯវំ ពុទ្ធា អខោភិយា ។**

*ផែនដីមិនកម្រើក សមុទ្ទសាគរប្រមាណមិនបាន អាកាសរកទីបំផុតគ្មាន យ៉ាងណាមិញ ព្រះពុទ្ធទាំងឡាយ មានព្រះហឫទ័យមិនរំជួយញាប់ញ័រ ក៏យ៉ាងនោះដែរ ។*

**អត្តទន្តា មហាវីរា ខមិតា ច តបស្សិនោ**
**ខន្តានំ ខមិតានំ ច គមនំ ភោ ន វិជ្ជតិ ។**

*ព្រះពុទ្ធទាំងឡាយមានព្យាយាមធំ មានខ្លួនទូន្មាន ទ្រង់អត់ធន់ មានតបៈ ពួកបុគ្គលអ្នកអំណត់អត់ធន់ មិនមាន*

*ការលុះក្នុងអគតិ ។*

**ឥជំ វត្វាន សម្ពុទ្ធោ បរិឡាហំ វិនោទយិ**
**មហាជនស្ស បុរតោ នភំ អព្ភុគ្គមី តទា ។**

*ព្រះបច្ចេកសម្ពុទ្ធទ្រង់ពោលដូច្នេះហើយ ទើបរម្ងាប់ក្រវល់-ក្រវាយរបស់ខ្ញុំ ហើយហោះទៅតាមអាកាស ក្នុងទីចំពោះមុខមហាជន ក្នុងកាលនោះ ។*

**តេន កម្មេនហំ វីរ ហីនត្តំ អជ្ឈុបាគតោ**
**សមតិក្កម្ម តំ ជាតឹ បាវិសឹ អភយំ បុរំ ។**

*បពិត្រព្រះអង្គមានព្យាយាម ព្រោះអំពើនោះហើយ បានជាខ្ញុំព្រះអង្គចូលទៅកាន់ភាពជាអ្នកថោកទាប លុះកន្លងជាតិនោះមកហើយ ក៏បានចូលទៅកាន់អភយបុរី គឺព្រះនិព្វាន ។*

**តទាបិ មំ មហាវីរ ឌយ្ហមានំ សុសណ្ឋិតំ**
**បរិឡាហំ វិនោទេសិ សយម្ភុំ ច ខមាបយឹ ។**

*បពិត្រព្រះអង្គមានព្យាយាមធំ វេលានោះ ព្រះពុទ្ធបានញុំាងខ្ញុំព្រះអង្គ ដែលកំពុងក្តៅក្រហាយ នៅមិនទាន់រលត់ឲ្យបន្ទោបង់ក្រវល់ក្រវាយចេញ ខ្ញុំព្រះអង្គបានញុំាងព្រះសយម្ភូឲ្យអត់ទោស ។*

អជ្ជាបិ មំ មហាវីរ ឌយ្ហមានំ តិហគ្គិហិ
និព្វាបេសិ តយោ អគ្គី សីតិភាវញ្ច ចាបយឹ ។

*បពិត្រព្រះអង្គមានព្យាយាមធំ ក៏ក្នុងថ្ងៃនេះ ព្រះអង្គបាន ញុំាងខ្ញុំព្រះអង្គ ដែលកំពុងក្តៅក្រហាយដោយភ្លើងទាំង ៣ ឲ្យរលត់ផង ញុំាងភ្លើងទាំង ៣ ឲ្យរលត់ផង ឥឡូវនេះ ខ្ញុំព្រះអង្គបានដល់នូវភាពត្រជាក់ហើយ ។*

យេសំ សោតាវធានត្ថិ សុណាថ មម ភាសតោ
អត្ថំ តុយ្ហំ បវក្ខាមិ យថា ទិដ្ឋំ បទំ មមំ ។

*លោកទាំងឡាយណា មានការតម្កល់នូវសោតប្រសាទ លោកទាំងនោះ ចូរស្តាប់ខ្ញុំចុះ ខ្ញុំនឹងប្រាប់ប្រយោជន៍ដល់ អ្នក ដូចជាចំណែកដែលខ្ញុំបានឃើញ ។*

សយម្ភុំ តំ វិមានេត្វា សន្តចិត្តំ សមាហិតំ
តេន កម្មេនហំ អជ្ជ ជាតោម្ហិ នីចយោនិយំ ។

*ខ្ញុំបានមើលងាយព្រះសយម្ភូនោះ ដែលមានព្រះហឫទ័យ ស្ងប់រម្ងាប់ មានព្រះហឫទ័យខ្ជាប់ខ្ជួន ដោយកម្មនោះហើយ បានជាក្នុងថ្ងៃនេះ ខ្ញុំមកកើតក្នុងកំណើតថោកទាប ។*

មា វោ ខណំ វិរាធេថ ខណាតីតា ហិ សោចរេ
សទត្ថេ វាយមេយ្យាថ ខណោ វោ បដិបាទិតោ ។

អ្នកទាំងឡាយ កុំឲ្យខណៈឃ្លាតទៅទេ ព្រោះបុគ្គលដែលខណៈកន្លងហើយ រមែងសោកសៅ អ្នកទាំងឡាយគប្បីព្យាយាមក្នុងប្រយោជន៍របស់ខ្លួន ( ព្រោះ ) ខណៈប្រាកដដល់អ្នកទាំងឡាយហើយ ។

ឯកច្ចានញ្ច វមនំ ឯកច្ចានំ វិរេចនំ
វិសំ ហលាហលំ ឯកេ ឯកច្ចានញ្ច ឱសថំ ។

ជនពួកខ្លះបានថ្នាំក្អួត ជនពួកខ្លះបានថ្នាំបញ្ចុះ ជនពួកខ្លះបានថ្នាំពិសដែលខ្លាំង ជនពួកខ្លះបានឱសថ ។

វមនំ បដិបន្នានំ ផលដ្ឋានំ វិរេចនំ
ឱសថំ ផលលាភីនំ បុញ្ញក្ខេត្តំ គវេសិនំ ។

ថ្នាំក្អួតសម្រាប់ពួកបុគ្គលអ្នកប្រតិបត្តិ ( នូវមគ្គ ) ថ្នាំបញ្ចុះសម្រាប់ពួកបុគ្គលអ្នកឋិតនៅក្នុងផល ឱសថសម្រាប់ពួកបុគ្គលអ្នកបាននូវផល ជាអ្នកស្វែងរកបុញ្ញក្ខេត្ត ។

សាសនេន វិរុទ្ធានំ វិសំ ហលាហលំ យថា
អាសិវិសោ ទុដ្ឋវិសោ ឯវំ ឈាបេតិ តំ នរំ ។

ពិសដែលខ្លាំង សម្រាប់បុគ្គលអ្នកប្រតិបត្តិខុសចាកសាសនា អាសិរពិស ដែលមានពិសកាច តែងដុតនរៈនោះ តែមួយដង ។

**សតំ បីតំ ហលាហលំ ឧបរុន្ធេតិ ជីវិតំ**

**សាសនេន វិរុជ្ឈិត្វា កប្បកោដិម្ហិ ឌយ្ហតិ ។**

*ពិសដ៏ខ្លាំងដែលបុគ្គលផឹកហើយ បៀតបៀនជីវិតបានតែមួយដង ឯបុគ្គលអ្នកប្រតិបត្តិខុសចាកសាសនា រមែងក្តៅក្រហាយអស់កោដិនៃកប្ប ។*

**ខន្តិយា អវិហឹសាយ មេត្តចិត្តវតាយ ច**

**សទេវកំ សោ តរតិ តស្មា តេ អវិរោធិយា ។**

*គេតែងឆ្លងចាកលោក ព្រមទាំងទេវលោក ដោយការអត់ធន់ ១ ដោយការមិនបៀតបៀន ១ ដោយមានចិត្តមេត្តា ១ ហេតុនោះ បុគ្គល មិនគប្បីឲ្យផ្តាំផ្គងនឹងព្រះពុទ្ធទាំងនោះ ។*

**លាភាលាភេ ន សជ្ជន្តិ សម្មានេ វិមានេ**

**បឋវីសទិសា ពុទ្ធា តស្មា តេ ន វិរោធិយា ។**

*ព្រះពុទ្ធទាំងឡាយ មានព្រះហឫទ័យស្មើដោយផែនដី មិនជាប់ចំពាក់ក្នុងលាភនិងអលាភ ក្នុងការរាប់អាន ក្នុងការមើលងាយ ហេតុនោះ បុគ្គល មិនគប្បីឲ្យផ្តាំផ្គងនឹងព្រះពុទ្ធទាំងនោះ ។*

**ទេវទត្តេ ច វធកេ ចោរេ អង្គុលិមាលកេ**

**រាហុលេ ធនបាលេ ច សព្វេសំ សមកោ មុនិ ។**

*ព្រះមុនីមានហឫទ័យស្មើចំពោះសត្វទាំងពួង គឺទេវទត្ត ខ្មាន់ធ្នូ ចោរអង្គុលិមាល រាហុល និងដំរីធនបាល ។*

**ឯតេសំ បដិឃំ នត្ថិ រាគោមេសំ ន វិជ្ជតិ**
**សព្វេសំ សមកោ ពុទ្ធោ វធកស្សោរសស្ស ច ។**

*ព្រះពុទ្ធមិនមានសេចក្តីស្អប់ជនទាំងនុ៎ះ មិនមានសេចក្តីស្រឡាញ់ជនទាំងនុ៎ះទេ មានព្រះហឫទ័យស្មើ ចំពោះជនទាំងអស់ គឺចំពោះខ្មាន់ធ្នូ និងចំពោះឱរស ។*

**បន្ថេ ទិស្វាន កាសាវំ ឆឌ្ឌិតំ មិឡ្ហមក្ខិតំ**
**សិរសា អញ្ជលឹ កត្វា វន្ទិតព្វំ ឥសិទ្ធជំ ។**

*បុគ្គលបើឃើញសំពត់កាសាវៈ ជាទង់ជ័យរបស់ព្រះពុទ្ធ ដែលប្រឡាក់ដោយលាមក ដែលគេចោលហើយក្នុងផ្លូវ គប្បីធ្វើអញ្ជលីថ្វាយបង្គំដោយត្បូង ។*

**អព្ភតីតា ច យេ ពុទ្ធា វត្តមានា អនាគតា**
**ធជេនានេន សុជ្ឈន្តិ តស្មា ឯតេ នមស្សិយា ។**

*ព្រះសម្ពុទ្ធទាំងឡាយ ដែលកន្លងទៅហើយក្តី ក្នុងបច្ចុប្បន្ននេះក្តី ក្នុងអនាគតក្តី តែងបរិសុទ្ធ ដោយទង់ជ័យនេះ ព្រោះហេតុនោះ ព្រះសម្ពុទ្ធទាំងនុ៎ះ បុគ្គលគប្បីនមស្ការ ។*

**សត្ថុកប្បំ សុវិនយំ ធារេមិ ហទយេនហំ**

ធម្មស្សមានោ វិនយំ វិហរិស្សាមិ សព្វទា ។

*ខ្ញុំចាំវិន័យដោយប្រពៃ គួរតាមអធ្យាស្រ័យរបស់ព្រះសាស្តា ដោយហឫទ័យ ខ្ញុំតែងនមស្ការវិន័យនោះ សព្វ ៗ កាល ។*

វិនយោ អាសយោ មយ្ហំ វិនយោ ឋានចង្កមំ
កប្បេមិ វិនយេ វាសំ វិនយោ មយ្ហ គោចរោ ។

*វិន័យជាទីអាស្រ័យ វិន័យជាទីឈរ ទាំងជាទីចង្ក្រមរបស់ខ្ញុំ ខ្ញុំតែងដេកនៅក្នុងវិន័យ វិន័យជាទីគោចររបស់ខ្ញុំ ។*

វិនយេ បារមិប្បត្តោ សមថេ ចាបិ កោវិទោ
ឧបាលិ តំ មហាវីរ បាទេ វន្ទតិ សត្ថុនោ ។

*បពិត្រព្រះអង្គមានព្យាយាមធំ ឧបាលិដល់នូវត្រើយក្នុងវិន័យផង ឈ្លាសវៃក្នុងសមថៈផង តែងថ្វាយបង្គំនូវព្រះបាទារបស់ព្រះសាស្តា ។*

សោ អហំ វិចរិស្សាមិ គាមាគាមំ បុរាបុរំ
នមស្សមានោ សម្ពុទ្ធំ ធម្មស្ស ច សុធម្មតំ ។

*ខ្ញុំព្រះអង្គនោះ នឹងត្រាច់ទៅអំពីស្រុកមួយ ទៅកាន់ស្រុកមួយ អំពីបុរីមួយ ទៅកាន់បុរីមួយ ហើយនមស្ការនូវព្រះសម្ពុទ្ធផង នូវភាពនៃធម៌ជាធម៌ដ៏ល្អផង ។*

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

**សព្វាសវា បរិក្ខីណា នត្ថិទានិ បុនព្ភវោ ។**

*ខ្ញុំព្រះអង្គដុតកិលេសទាំងឡាយហើយ ដកចោលនូវភព ទាំងអស់ហើយ អាសវៈទាំងពួងអស់រលីងហើយ ឥឡូវ នេះ ភពថ្មីមិនមានទេ ។*

**ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ**
**តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។**

*ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់របស់ព្រះពុទ្ធដ៏ប្រសើរ ( នេះ ) ជាដំណើរមកដោយល្អ វិជ្ជាទាំង ៣ ខ្ញុំព្រះអង្គ បានសម្រេចហើយ សាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំព្រះអង្គក៏ បានប្រតិបត្តិហើយ ។*

**បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ**
**ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។**

*បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើ ឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំក៏ បានប្រតិបត្តិហើយ [១] ។*

*ក្នុងទីនោះ ព្រះសាស្តាឲ្យព្រះថេរៈរៀនព្រះវិន័យទាំងអស់ ដោយ ព្រះអង្គឯង ។ ថ្ងៃមួយ លោកបានវិនិច្ឆ័យរឿង ៣ គឺរឿងភារុកច្ឆៈ*

---

*១-បិ.៧២ ទំ.៨៤-១១០ ឃ.៨ ។*

១ រឿងអដ្ឋកត្ថេរ ១ រឿង ( មាតា ) ព្រះកុមារកស្សបៈ ១ កាលវិនិច្ឆ័យស្រេចហើយ ព្រះសាស្តាទ្រង់ប្រទានសាធុការ ទ្រង់អាស្រ័យការវិនិច្ឆ័យរឿងទាំង ៣ ឲ្យជាហេតុកើតឡើង ទើបទ្រង់តែងតាំងព្រះថេរៈក្នុងតំណែងជាឯតទគ្គៈលើសភិក្ខុទាំងឡាយ ខាងទ្រទ្រង់ព្រះវិន័យថា

**ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ វិនយធរានំ យទិទំ ឧបាលិ ។** ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុ អ្នកទ្រទ្រង់វិន័យដែលជាសាវករបស់តថាគត ស្រេចនឹងឧបាលិ ប្រសើរជាងគេ[១] ។

រឿងទាំង ៣ នោះ មានដូចតទៅនេះថា

សម័យនោះ មានភិក្ខុ ១ រូប ជាកូនអ្នកស្រុកភារុកច្ឆកៈ យល់សប្តិឃើញថា សេពមេថុនធម្មនឹងនាងបុរាណទុតិយិកា ហើយគិតថា ខ្លួនអញមិនមែនជាសមណៈទេ អញនឹងសឹកទៅវិញ ដូច្នេះហើយ ដើរទៅកាន់ជនបទឈ្មោះភារុកច្ឆៈ ក៏បានឃើញព្រះឧបាលិដ៏មានអាយុ ក្នុងទីពាក់កណ្តាលផ្លូវ ហើយនិយាយប្រាប់រឿងនុ៎ះ ។ ព្រះឧបាលិត្ថេរដ៏មានអាយុបានប្រាប់យ៉ាងនេះថា ម្នាលអាវុសោ ឥតមានអាបត្តិអ្វីដោយចំណែកនៃយល់សប្តិនោះទេ[២] ។ នេះជារឿងទី ១ ។

សម័យនោះឯង ក្មេងពីរនាក់ គឺកូនប្រុស ១ ក្មួយប្រុស ១ របស់គហបតីជាឧបដ្ឋាករបស់ព្រះអដ្ឋកត្ថេរដ៏មានអាយុ ក្នុងក្រុងវេសាលី ។

១-បិ.៤០ ទំ.៥៥ ឃ.១៤៩ ។ ២-បិ.១ ទំ.១២៨ ឃ.៧១ ។

គ្រានោះ គហបតីនោះ បាននិយាយពាក្យនេះ នឹងព្រះអជ្ជុកត្ថេរដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន ជំនុំក្មេងទាំងពីរនាក់នេះ ក្មេងណាមានសទ្ធាជ្រះថ្លា ព្រះករុណាគប្បីប្រាប់ឱកាសនេះ ដល់ក្មេងនោះ ។ គហបតីនោះ ធ្វើកាលកិរិយាទៅ ។ សម័យនោះឯង ក្មួយរបស់គហបតីនោះ មានសទ្ធាជ្រះថ្លា ។ លំដាប់នោះ ព្រះអជ្ជុកត្ថេរដ៏មានអាយុ បានប្រាប់ឱកាសនោះ ដល់ទារកដែលជាក្មួយនោះ ។ ទារកដែលជាក្មួយនោះ ក៏បានបីបាច់រក្សានូវទ្រព្យ និងចាត់ចែងនូវទាន ដោយសម្បត្តិនោះ ។ លំដាប់នោះ កូនរបស់គហបតីនោះ បាននិយាយពាក្យនេះ នឹងព្រះអានន្ទដ៏មានអាយុថា បពិត្រព្រះអានន្ទដ៏ចម្រើន អ្នកណាជាអ្នកទទួលមរតករបស់បិតា កូនឬក្មួយ ។ ព្រះអានន្ទនិយាយតបថា ម្នាលអ្នកដ៏មានអាយុ កូនទើបត្រូវទទួលទ្រព្យមរតករបស់បិតាបាន ។ កូនរបស់គហបតីនោះ បាននិយាយតទៅទៀតថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់អជ្ជុកត្ថេរនេះ ប្រាប់សម្បត្តិរបស់ខ្ញុំ ដល់បងប្អូនជីដូនមួយរបស់ខ្ញុំហើយ ។ ព្រះអានន្ទពោលថា ម្នាលអ្នកដ៏មានអាយុ អជ្ជុកត្ថេរដ៏មានអាយុនេះ មិនមែនជាសមណៈទេ ។ គ្រានោះ ព្រះអជ្ជុកត្ថេរដ៏មានអាយុ បាននិយាយពាក្យនេះ នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអាវុសោអានន្ទ លោកចូរឲ្យសេចក្តីវិនិច្ឆ័យដល់ខ្ញុំចុះ ។ សម័យនោះឯង ព្រះឧបាលិដ៏មានអាយុ ជាបក្ខពួករបស់ព្រះអជ្ជុកត្ថេរដ៏មានអាយុ ។ លំដាប់

នោះ ព្រះឧបាលិដ៏មានអាយុ បាននិយាយពាក្យនេះ នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអាវុសោអានន្ទ ភិក្ខុណាដែលម្ចាស់ទ្រព្យផ្តាំទុកថា លោកចូរប្រាប់ឱកាសនេះ ដល់អ្នកនេះ ហើយភិក្ខុនោះ ទៅប្រាប់ដល់អ្នកនោះ ភិក្ខុនោះ ត្រូវអាបត្តិអ្វី ។ ព្រះអានន្ទឆ្លើយតបទៅវិញថា បពិត្រលោកដ៏ចម្រើន ភិក្ខុនោះ មិនត្រូវអាបត្តិអ្វីបន្តិចទេ ដោយហោចទៅ តែអាបត្តិទុក្កដ ក៏មិនត្រូវដែរ ។ ព្រះឧបាលិឆ្លើយថា ម្នាលអាវុសោ ព្រះអដ្ឋកត្ថេរដ៏មានអាយុនេះ ម្ចាស់ទ្រព្យបានផ្តាំទុកថា លោកចូរប្រាប់ឱកាសនេះ ដល់ជនឈ្មោះនេះ ក៏បានប្រាប់ដល់អ្នកនោះមែន ម្នាលអាវុសោ អដ្ឋកត្ថេរដ៏មានអាយុ មិនត្រូវអាបត្តិទេ [១] ។ នេះជារឿងទី ២ ។

បានឮថា មានភិក្ខុនីមួយរូប ជាធីតារបស់សេដ្ឋីមានទ្រព្យច្រើនក្នុងនគររាជគ្រឹះ មានកុសលមូលក្រាស់ មានសង្ខារញ៉ាំញីហើយ ជាបច្ឆិមកវិកសត្វ ឧបនិស្ស័យនៃអរហត្ត ភ្លឺរុងរឿងក្នុងហទយៈរបស់នាង ដូចប្រទីបឆេះនៅក្នុងផ្ទាំងដូច្នោះ ។ តាំងអំពីកាលដែលដឹងក្តីហើយ ធីតារបស់សេដ្ឋីនោះ មិនត្រេកអរក្នុងផ្ទះ មានបំណងនឹងបួស ទើបពោលនឹងមាតាបិតាថា បពិត្រលោកឪពុកអ្នកម្តាយ ចិត្តរបស់ខ្ញុំមិនត្រេកអរក្នុងឃរាវាស ខ្ញុំមានបំណងនឹងបួសក្នុងព្រះពុទ្ធសាសនា ដែលជាគ្រឿងនាំ (សត្វ) ចេញចាកទុក្ខ សូមលោកទាំងឡាយ ឲ្យខ្ញុំបួសចុះ ។

---

១-បិ.១ ទំ.២១៧ ឃ.១៧២ ។

មាតាបិតាពោលថា នែកូន នាងនិយាយអ្វី ត្រកូលយើងមានទ្រព្យច្រើន នាងក៏ជាកូនស្រីតែមួយរបស់យើងទាំងឡាយ នាងមិនគួរបួសទេ ។ សូម្បីធីតានោះ អង្វររឿយ ៗ ក៏មិនបានចេញបួសអំពីសម្នាក់មាតាបិតា ទើបគិតថា ណ្ហើយចុះ អញទៅកាន់ត្រកូលស្វាមី ញ៉ាំងស្វាមីឲ្យត្រេកអរហើយ នឹងសូមបួស ។ នាងចម្រើនវ័យហើយ បានទៅកាន់ត្រកូលស្វាមី ជាស្រីមានសីល មានកល្យាណធម៌ គ្រប់គ្រងផ្ទះ ។

លំដាប់នោះ ព្រោះអាស្រ័យការនៅរួម នាងក៏មានគភ៌ ។ នាងមិនដឹងថា ខ្លួនមានគភ៌ ។ សម័យនោះ ជនទាំងឡាយឃោសនាបុណ្យនក្ខត្តឫក្សក្នុងនគរ អ្នកនគរទាំងមូលនាំគ្នាលេងនក្ខត្តឫក្ស ។ ព្រះនគរមានការប្រដាប់តាក់តែងដូចទេវនគរ គ្រាលេងនក្ខត្តឫក្ស សូម្បីគគ្រឹកគគ្រេងប្រព្រឹត្តទៅដល់ម្ល៉ោះ នាងក៏មិនលាបស្រឡាបរាងកាយរបស់ខ្លួនមិនពាក់គ្រឿងអលង្ការ ត្រាច់ទៅដោយភេទធម្មតានោះឯង ។ លំដាប់នោះ ស្វាមីពោលថា នែនាងដ៏ចម្រើន នគរទាំងមូលអាស្រ័យនក្ខត្តឫក្សតែនាងមិនប្រដាប់តាក់តែងរាងកាយ ព្រោះហេតុអ្វី ។

នាងពោលថា បពិត្រអយ្យបុត្ត រាងកាយពេញដោយរបស់មិនស្អាត ៣២ ប្រការ ប្រយោជន៍អ្វីដោយរាងកាយនេះ ដែលប្រដាប់ហើយព្រោះកាយនេះ ទេវតា ព្រហ្ម មិនបានជប់មក មិនមែនកើតអំពីមាសកែវមណី ខ្លឹមចន្ទន៍ក្រហម មិនមែនកើតអំពីផ្កាបុណ្ឌរិក ផ្កាកុមុទ និង

ផ្កាឧប្បលខៀវ តែពេញទៅដោយលាមក មិនស្អាត មិនមែនពេញដោយអមតឱសថ ដោយពិត កើតក្នុងរបស់មិនស្អាត មានឪពុកម្តាយជាដែនកើត មានការផុសលាស់ និងគក់ច្របាច់ជានិច្ច មានការបែកធ្លាយ និងការខ្ចាត់ខ្ចាយទៅជាធម្មតា ជាព្រៃស្មសាន ដែលតណ្ហាប្រកាន់មាំ ជាហេតុនៃសោក ជាទីតាំងនៃសេចក្តីខ្សឹកខ្សួល ជាលំនៅនៃរោគទាំងឡាយ ជាទីទទួលគ្រឿងកម្មករណៈ ជារបស់ស្អុយក្នុង ហូរចេញជានិច្ច ជាលំនៅរបស់ជង្គួរច្រើនត្រកូល នឹងទៅកាន់ឈាបនដ្ឋាន មានការស្លាប់ជាទីបំផុត នឹងប្រែប្រួលទៅក្នុង (គន្ធង) ចក្ខុនៃសត្វលោកទាំងពួង ។

អដ្ឋិន្ហារុហិ សំយុត្តោ តចមំសាវលេបនោ
ឆវិយា កាយោ បដិច្ឆន្នោ យថាភូតំ ន ទិស្សតិ ។

កាយប្រកបដោយឆ្អឹង និងសរសៃទាំងឡាយ គ្របដណ្តប់ដោយស្បែក និងសាច់ បិទបាំងដោយសម្បុរថ្ងៃ មិនប្រាកដតាមពិត ។

អន្តបូរោ ឧទរបូរោ យកាបេឡស្ស វត្ថិនោ
ហទយស្ស បប្ផាសស្ស វក្កស្ស បិហកស្ស ច
សិង្ឃាណិកាយ ខេលស្ស សេទស្ស ច មេទស្ស ច
លោហិតស្ស លសិកាយ បិត្តស្ស ច វសាយ ច ។

កាយពេញដោយពោះវៀនផង ពេញដោយអាហារថ្មីផង

ដោយដុំថ្មើមផង ដោយក្រពះនោមផង ដោយបេះដូងផង ដោយសួតផង ដោយទាចផង ដោយក្រពះបាយផង ដោយទឹកសំបោរផង ដោយទឹកមាត់ផង ដោយញើសផង ដោយខ្លាញ់ខាប់ផង ដោយឈាមផង ដោយទឹករំអិលផង ដោយទឹកប្រមាត់ផង ដោយខ្លាញ់រាវផង ។

អថស្ស នវហិ សោតេហិ អសុចី សវតិ សព្វទា
អក្ខិម្ហា អក្ខិគូថកោ កណ្ណម្ហា កណ្ណគូថកោ
សិង្ឃាណិកា ច នាសតោ មុខេន វមតេកទា
បិត្តំ សេម្ហំ ច វមតិ កាយម្ហា សេទជល្លិកា ។

មួយទៀត វត្ថុមិនស្អាត រមែងហូរចេញតាមរន្ធទាំង ៩ របស់កាយនោះ សព្វកាល គឺព្រៀកភ្នែក ហូរចេញអំពីភ្នែក មូលត្រចៀក ហូរចេញអំពីត្រចៀក ទឹកសំបោរ ហូរចេញអំពីច្រមុះ ជួនណាចេញតាមមាត់ ប្រមាត់និងស្លេស្ម ក៏ខ្ចុរចេញតាមមាត់ដែរ ញើសនិងក្អែល ហូរចេញអំពីកាយ ។

អថស្ស សុសិរំ សីសំ មត្ថលុង្គស្ស បូរិតំ
សុភតោ នំ មញ្ញតិ ពាលោ អវិជ្ជាយ បុរក្ខតោ ។

មួយទៀត កាយនោះ មានក្បាលប្រហោង ពេញដោយខួរក្នុងក្បាល ជនពាលត្រូវអវិជ្ជារួបរឹតហើយ រមែងសម្គាល់កាយ

*នោះថាល្អ[១] ដូច្នេះ ។*

អជញ្ញាជីនវោ កាយោ វិសរុក្ខសមូបមោ
អាវាសោ សព្ពរោគានំ បុញ្ជោ ទុក្ខស្ស កេវលោ ។

*រាងកាយជារបស់មានទោស រកទីបំផុតគ្មាន មានឧបមាដូចដើមឈើមានពិស ជាលំនៅនៃរោគទាំងពួង ជាគំនរនៃកងទុក្ខទាំងអស់[២] ។*

សចេ ឥមស្ស កាយស្ស អន្តោ ពាហិរកោ សិយា
ទណ្ឌំ នូន គហេត្វាន កាកេ សោណេ ច វារយេ ។

*បើត្រឡប់ផ្នែកខាងក្នុងរបស់រាងកាយនេះ ឲ្យមកខាងក្រៅ នឹងត្រូវកាន់ដំបងចាំដេញក្អែកនិងឆ្កែ ដោយពិត ។*

ទុគ្គន្ធោ អសុចិ កាយោ កុណបោ ឧក្ករូបមោ
និន្ទិតោ ចក្ខុភូតេហិ កាយោ ពាលាភិនន្ទិតោ ។

*កាយមិនស្អាត មានក្លិនស្អុយ ពេញដោយសាកសព ប្រៀបដូចបង្គន់ បុគ្គលមានចក្ខុ តិះដៀល តែបុគ្គលល្ងង់ខ្លៅនាំគ្នាត្រេកអរហើយ ។*

អល្លចម្មបដិច្ឆន្នោ នវទ្វារោ មហាវណោ
សមន្តតោ បគ្ឃរតិ អសុចី បូតិគន្ធិយោ ។

---

១-បិ.៥៤ ទំ.៦៥ ឃ.១៩ ។ ២-បិ.៧៥ ទំ.២៩៦ ឃ.១២២ ។

កាយនេះ ត្រូវស្បែកស្រស់បិទបាំងទុក មានទ្វារ ៩ ប្រៀប ដូចជាមុខដំបៅ ជារបស់មិនស្អាត មានក្លិនស្អុយហូរចេញ សព្វទិស[១] ។

**យទា ច សោ មតោ សេតិ ឧទ្ធុមាតោ វិនីលកោ**
**អបវិទ្ធោ សុសានស្មឹ អនបេក្ខា ហោន្តិ ញាតយោ ។**
**ខាទន្តិ នំ សុវាណា ច សិង្គាលា ច វកា កិមី**
**កាកា គិជ្ឈា ច ខាទន្តិ យេ ចញ្ញេ សន្តិ បាណិនោ ។**

កាលណា កាយនោះ ស្លាប់ទៅ ដេកនៅហើមប៉ោង មានពណ៌ខៀវ ត្រូវគេបោះចោលទៅក្នុងព្រៃស្មសានហើយ កាលណោះ ជនទាំងឡាយជាញាតិ ក៏លែងរមិល ស្វាន ចចក ក្អែ ដង្កូវ ជញ្ជ្រែងស៊ីកាយស្លាប់នោះ ចំណែកពួកសត្វដទៃ មានក្អែក ត្មាតជាដើម ក៏ចឹកស៊ីនូវកាយស្លាប់នោះដែរ ។

**សុត្វាន ពុទ្ធវចនំ ភិក្ខុ បញ្ញាណវា ឥធ**
**សោ ខោ នំ បរិជានាតិ យថាភូតញ្ហិ បស្សតិ ។**

ភិក្ខុណា ក្នុងសាសនានេះ ជាអ្នកមានបញ្ញា បានស្តាប់នូវពុទ្ធវចនៈហើយ ភិក្ខុនោះ រមែងកំណត់ដឹងនូវកាយនោះ ព្រោះឃើញច្បាស់តាមពិត ។

---

១-វិសុទ្ធិមគ្គ អសុភកម្មដ្ឋាននិទ្ទេស ។

**យថា ឥទំ តថា ឯតំ យថា ឯតំ តថា ឥទំ**
**អជ្ឈត្តញ្ច ពហិទ្ធា ច កាយេ ឆន្ទំ វិរាជយេ ។**

*សរីរៈរស់នេះយ៉ាងណា សរីរៈស្លាប់នុ៎ះក៏យ៉ាងនោះ សរីរៈស្លាប់នុ៎ះយ៉ាងណា សរីរៈរស់នេះក៏យ៉ាងនោះ ភិក្ខុគប្បីរសាយនូវសេចក្តីប្រាថ្នាក្នុងកាយ ទាំងខាងក្នុង ទាំងខាងក្រៅ ។*

**ឆន្ទរាគវិរត្តោ សោ ភិក្ខុ បញ្ញាណវា ឥធ**
**អជ្ឈគា អមតំ សន្តឹ និព្វានបទមច្ចុតំ ។**

*ក្នុងសាសនានេះ ភិក្ខុនោះ មានបញ្ញាប្រាសចាកឆន្ទរាគៈ ដល់នូវបទគឺព្រះនិព្វាន ជាធម្មជាតមិនស្លាប់ ចេញចាកវានៈគឺតណ្ហា ជាធម្មជាតស្ងប់ មិនច្យុត[១] ។*

*បពិត្រអយ្យបុត្ត ខ្ញុំនឹងប្រដាប់រាងកាយនេះ ធ្វើអ្វី ការប្រដាប់កាយនេះ រមែងដូចគ្នានឹងការធ្វើចិត្រកម្មខាងក្រៅធ្លាំង ដែលពេញដោយលាមក ។ សេដ្ឋីបុត្តបានស្តាប់ពាក្យរបស់នាងដូច្នោះហើយ ទើបពោលថា នែនាងដ៏ចម្រើន បើនាងឃើញទោសទាំងឡាយក្នុងកាយយ៉ាងនេះ ហេតុអ្វី ក៏នាងមិនបួស ។*

*នាងពោលថា បពិត្រអយ្យបុត្ត បើខ្ញុំអាចបួសបាន នឹងបួសក្នុងថ្ងៃនេះឯង ។ សេដ្ឋីបុត្តពោលថា សាធុ ខ្ញុំនឹងឲ្យនាងបួស ញុំាំងមហាទាន*

---

*១-បិ.៥៤ ទំ.៦៦ ឃ.១៩ ។*

ឲ្យប្រព្រឹត្តទៅ ធ្វើមហាសក្ការៈ នាំទៅកាន់សម្នាក់ភិក្ខុនីដោយបរិវារធំ ។ កាលឲ្យនាងបួស បានឲ្យបួសក្នុងសម្នាក់ភិក្ខុនីដែលជាបក្សពួករបស់ភិក្ខុទេវទត្ត នាងបានទទួលបព្វជ្ជាហើយ តម្រិះពេញបរិបូណ៌ ត្រេកអរហើយ ។

គ្រានោះ កាលគភ៌របស់នាងចាស់ហើយ ភិក្ខុនីទាំងឡាយឃើញភាពដែលឥន្ទ្រិយទាំងឡាយប្រែប្រួលទៅជាដទៃ ខ្នងដៃខ្នងជើងហើម និងឃើញពោះធំ ទើបសួរថា អ្នកនាងម្ចាស់ នាងប្រាកដដូចជាមានគភ៌ តើរឿងនេះ ដូចម្តេច ។

ភិក្ខុនីនោះពោលថា អ្នកនាងម្ចាស់ទាំងឡាយ ខ្ញុំមិនដឹងថា ហេតុឈ្មោះនេះ ( មាន ) តែសីលរបស់ខ្ញុំនៅបរិបូណ៌ ។ លំដាប់នោះ ទើបភិក្ខុនីទាំងនោះ នាំភិក្ខុនីនោះទៅកាន់សម្នាក់របស់ភិក្ខុទេវទត្ត ហើយសួរភិក្ខុទេវទត្តថា បពិត្រលោកម្ចាស់ កុលធីតានេះ ញ៉ាំងស្វាមីឲ្យប្រោស-ប្រាណបានដោយលំបាក ទើបបានបួស ឥឡូវនេះ គភ៌របស់នាងប្រាកដ យើងខ្ញុំមិនដឹងថា កុលធីតានេះ តាំងគភ៌ក្នុងកាលជាគ្រហស្ថ ឬក្នុងកាលបួសហើយ ឥឡូវនេះ យើងទាំងឡាយនឹងធ្វើដូចម្តេច ។ ព្រោះភាពដែលខ្លួនមិនដឹង និងព្រោះខន្តី មេត្តា និងករុណាមិនមាន ទើបទេវទត្តគិតយ៉ាងនេះថា ការនិន្ទានឹងកើតឡើងដល់អញថា ភិក្ខុនីនៅក្នុងចំណែករបស់ទេវទត្ត មានគភ៌ តែទេវទត្តបែរជាព្រងើយកន្តើយ អញនឹងឲ្យភិក្ខុនីនេះសឹក ទើបគួរ ។ ទេវទត្តនោះ មិនទាន់ពិចារណា ក៏ស្ទុះទៅដូចដុំថ្ម

វមៀល ពោលថា ពួកនាង ចូរឲ្យភិក្ខុនីនេះសឹក ។ ភិក្ខុនីទាំងនោះ ស្ដាប់ពាក្យរបស់ទេវទត្តហើយ ថ្វាយបង្គំ ក្រោកឡើងត្រឡប់ទៅកាន់លំនៅ ។

លំដាប់នោះ ភិក្ខុនីនោះ ពោលនឹងភិក្ខុនីទាំងនោះថា អ្នកនាងម្ចាស់ទាំងឡាយ ព្រះថេរៈទេវទត្តមិនមែនជាព្រះពុទ្ធ ការបួសរបស់ខ្ញុំក្នុងសម្នាក់របស់លោកម្ចាស់ទេវទត្តនោះ ក៏មិនមែន បព្វជ្ជារបស់ខ្ញុំក្នុងសម្នាក់របស់ព្រះសម្មាសម្ពុទ្ធ ដែលជាអគ្គបុគ្គលក្នុងលោក ម្យ៉ាងទៀត បព្វជ្ជានេះ ខ្ញុំបានដោយលំបាក អ្នកនាងម្ចាស់ទាំងឡាយ កុំធ្វើផ្ដួស ( របស់ខ្ញុំ ) នោះ ឲ្យអន្តរធានទៅឡើយ មកអ្នកនាងម្ចាស់ទាំងឡាយ ចូរនាំខ្ញុំទៅកាន់វត្តជេតពន ដើម្បីគាល់ព្រះសាស្ដា ។ ភិក្ខុនីទាំងឡាយនោះ ក៏នាំភិក្ខុនីនោះ ចេញអំពីនគររាជគ្រឹះ អស់ចម្ងាយផ្លូវ ៤៥ យោជន៍ ដល់វត្តជេតពនដោយលំដាប់ ថ្វាយបង្គំព្រះសាស្ដាហើយ ក្រាបបង្គំទូលរឿងនោះ ឲ្យទ្រង់ជ្រាប ។ ព្រះសាស្ដាទ្រង់ព្រះតម្រិះថា ភិក្ខុនីនេះ មានគភ៌ក្នុងកាលនៅជាគ្រហស្ថដោយពិត ទោះបីជាដូច្នោះ ក៏ពួកតិរ្ថិយនឹងបានឱកាសថា ព្រះសមណគោតមទទួលយកភិក្ខុនី ដែលទេវទត្តបោះបង់ចោលហើយ ព្រោះហេតុនោះ ដើម្បីកាត់នូវពាក្យនេះ គួរវិនិច្ឆ័យអធិករណ៍នេះ ក្នុងកណ្ដាលបរិស័ទដែលមានព្រះរាជា ។ ស្អែកឡើងទើបឲ្យយាងព្រះបាទកោសល អញ្ជើញអនាថបិណ្ឌិកសេដ្ឋី ចូឡអនាថ-បិណ្ឌិកសេដ្ឋី នាងវិសាខាមហាឧបាសិកា និងត្រកូលធំ ៗ ដទៃ ៗ ដែល

មានគេភ្ញីឈ្មោះ ។ ក្នុងវេលាល្ងាច កាលបរិស័ទ ៤ ប្រជុំគ្នាហើយ ទើបត្រាស់ហៅព្រះឧបាលិត្ថេរមកថា អ្នកចូរជម្រះកម្មរបស់ភិក្ខុនីនេះ ក្នុងកណ្ដាលបរិស័ទ ៤ ។ ព្រះថេរៈទទួលព្រះតម្រាស់ថា សាធុព្រះអង្គ ហើយ ទៅកណ្ដាលបរិស័ទ អង្គុយលើអាសនៈដែលគេរៀបចំដើម្បីខ្លួន ឲ្យហៅនាងវិសាខាមហាឧបាសិកាមក ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះរាជា ឲ្យទទួលអធិករណ៍នេះថា នែនាងវិសាខា ចូរនាងទៅ ចូរដឹងថាភិក្ខុនីនេះ បួសក្នុងខែនោះ ថ្ងៃនោះ ហើយចូរដឹងថា នាងមានគភ៌មុនឬក៏ក្រោយបួស ។

មហាឧបាសិកាទទួលពាក្យថា សាធុហើយ ឲ្យបាំងរាំងនន ពិនិត្យមើលត្រង់ទីបំផុតដៃ ជើង ផ្ចិត និងពោះរបស់ភិក្ខុនីនោះ ខាងក្នុងរាំងននរាប់ខែ និងថ្ងៃ ដឹងថា នាងបានតាំងគភ៌ក្នុងកាលជាគ្រហស្ថ ដោយពិតទើបទៅកាន់សម្នាក់របស់ព្រះថេរៈ ហើយប្រាប់សេចក្ដីនោះ ។ ព្រះថេរៈបានធ្វើភិក្ខុនីនោះ ឲ្យជាអ្នកបរិសុទ្ធក្នុងកណ្ដាលបរិស័ទ ៤ ភិក្ខុនីនោះ ជាអ្នកបរិសុទ្ធហើយ ថ្វាយបង្គំព្រះសាស្ដា និងភិក្ខុសង្ឃ ហើយទៅកាន់លំនៅនោះឯង មួយអន្លើដោយភិក្ខុនីទាំងឡាយ ។ ភិក្ខុនីនោះ កាលគភ៌ចាស់ហើយ ក៏ប្រសូតបុត្តមានអានុភាពច្រើន ដែលតាំងសេចក្ដីប្រាថ្នាទុក ទៀបបាទមូលរបស់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ។

ថ្ងៃមួយ ព្រះរាជាយាងទៅក្បែរ ៗ សម្នាក់របស់ភិក្ខុនី បានឮ

សំឡេងទារក ទើបត្រាស់សួរអាមាត្យទាំងឡាយ ។ អាមាត្យទាំងឡាយដឹងហេតុនោះ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ភិក្ខុនីនោះប្រសូតបុត្តហើយ នុ៎ះជាសំឡេងកូនរបស់ភិក្ខុនីនោះឯង ។

ព្រះរាជាត្រាស់ថា ឈ្មោះថា ការមើលថែទារក ជាកង្វល់របស់ភិក្ខុនីទាំងឡាយ ពួកយើងនឹងចិញ្ចឹមទារកនោះ ។ ព្រះរាជាទ្រង់ប្រគល់ទារកនោះ ដល់ស្រីរបាំទាំងឡាយ ឲ្យធំធាត់ដោយការរក្សាដូចរាជកុមារ ។ ក្នុងថ្ងៃដាក់ឈ្មោះកុមារនោះ ក៏បានដាក់ឈ្មោះថា កស្សបៈ ។ គ្រានោះមនុស្សទាំងឡាយស្គាល់ថា កុមារកស្សបៈ ព្រោះចម្រើនដោយការថែរក្សាដូចព្រះរាជកុមារ ។ ក្នុងកាលមានអាយុ ៧ ឆ្នាំ កុមារកស្សបៈនោះបួសក្នុងសម្នាក់របស់ព្រះសាស្តា ។ ( កាលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរហៅកស្សបៈមក ភិក្ខុទាំងឡាយក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន តើកស្សបៈមួយណា ព្រះមានព្រះភាគត្រាស់ថា កុមារកស្សបៈ អាស្រ័យព្រះបន្ទូលនេះ សូម្បីព្រះថេរៈចាស់ជរាហើយ ក៏គេនៅតែហៅថា កុមារកស្សបៈ ៗ នោះឯង ) ។ លុះមានអាយុគ្រប់ ២០ ឆ្នាំ ក៏បានឧបសម្បទា ញុំាងកាលវេលាឲ្យកន្លងទៅ ជាអ្នកពោលធម៌ដ៏វិចិត្រ ក្នុងធម្មកថិកទាំងឡាយ ។ លំដាប់នោះ ព្រះសាស្តាទ្រង់តាំងព្រះកុមារកស្សបៈនោះ ក្នុងតំណែងឯតទគ្គៈដោយព្រះតម្រាស់ថា

**ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ចិត្តកថិកានំ យទិទំ កុមារកស្សបោ ។** ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកចេះសម្តែងវិចិត្រ ដែលជាសាវ័ករបស់តថាគត ស្រេចនឹងកុមារកស្សបៈប្រសើរជាងគេ [១] ។

ក្រោយមក ព្រះកុមារកស្សបៈនោះ សម្រេចអរហត្ត ដោយបានស្តាប់វម្មិកសូត្រ ។ សូម្បីភិក្ខុនីដែលជាមាតារបស់ព្រះកុមារកស្សបៈនោះ ចម្រើនវិបស្សនា ហើយសម្រេចអរហត្ត ។ កុមារកស្សបត្ថេរនោះ ប្រាកដក្នុងព្រះពុទ្ធសាសនា ដូចព្រះចន្ទពេញវង់អណ្តែតកណ្តាលអាកាសដូច្នោះ [២] ។ នេះជារឿងទី ៣ ។

កាលព្រះមានព្រះភាគដែលជាទីពឹងនៃសត្វលោក ទ្រង់ធ្វើពុទ្ធកិច្ចទាំងឡាយ តាំងពីទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅជាដើម ដរាបដល់ទ្រង់ប្រោសសុភទ្ទបរិព្វាជក ហើយទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងពេលទៀបភ្លឺ ក្នុងថ្ងៃវិសាខបុណ្ណមី ត្រង់ចន្លោះដើមសាលព្រឹក្សទាំងគូ ក្នុងសាលវ័ន ដែលជាទីប្រពាតរបស់ស្តេចមល្លៈទាំងឡាយ ជិតក្រុងកុសិនារា ព្រះមហាកស្សបមានអាយុ ដែលជាសង្ឃត្ថេរនៃភិក្ខុប្រមាណ ៧ សែនអង្គ ដែលប្រជុំគ្នាត្រង់ទីបរិនិព្វាននៃព្រះមានព្រះភាគ

---

១-បិ.៤០ ទំ.៥៤ ឃ.១៤៨ ។ ២-អដ្ឋកថា ជាតក ឯកនិបាត និគ្រោធមិគជាតក បិ.៥៨ ទំ.៦ ឃ.១២ ។

រឭកដល់ពាក្យដែលសុភទ្ទភិក្ខុបួសឯចាស់ពោល កាលព្រះមានព្រះភាគទ្រង់បរិនិព្វានហើយ បាន ៧ ថ្ងៃ ថា ម្នាលអាវុសោទាំងឡាយ ណ្ហើយអ្នកទាំងឡាយ កុំសោកសៅ កុំខ្សឹកខ្សួលឡើយ ពួកយើងនឹងបានរួចស្រឡះហើយ ព្រោះថា ពួកយើង មហាសមណៈនោះ តែងបៀតបៀនថា អំពើនេះគួរដល់អ្នក អំពើនេះមិនគួរដល់អ្នក ក៏ឥឡូវនេះ ពួកយើងនឹងប្រាថ្នាធ្វើនូវអំពើណា នឹងធ្វើអំពើនោះបាន មិនប្រាថ្នាធ្វើនូវអំពើណានឹងមិនធ្វើអំពើនោះបាន ដូច្នេះ លោកពិចារណាឃើញថា ការប្រជុំសង្ឃមានចំនួនច្រើនដូច្នេះ អំណឹះតទៅ នឹងរកបានដោយក្រ ទើបត្រិះរិះថាការដែលពួកភិក្ខុបាប នឹងគប្បីជាអ្នកសម្គាល់ថា បាវចនៈ មានព្រះសាស្តាកន្លងទៅហើយដូច្នេះ បានបក្ខពួកហើយ គប្បីញ៉ាំងព្រះសទ្ធម្មឲ្យអន្តរធានបាន មិនយូរឡើយ ក៏ដំណើរនេះ ជាឋានៈ ( ហេតុ ) ដែលនឹងមានជាប្រាកដ ។ សេចក្តីពិត ព្រះវិន័យតាំងនៅដរាបណា បាវចនៈនៅមានព្រះសាស្តាមិនកន្លងទៅដរាបនោះ ។ សេចក្តីនេះ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា

ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសម្តែងហើយបញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះអំណឹះឥតអំពីតថាគតទៅ ធម៌និងវិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ[១] ដូច្នេះ ។ បើដូច្នោះ យើង

---

១-បិ.១៦ ទំ.៣២១ យ.១៤១ ។

គប្បីសង្គាយនាព្រះធម៌និងព្រះវិន័យ ដែលជាហេតុឲ្យព្រះសាសនានេះ គប្បីតាំងនៅមាំអស់កាលយូរ ។ ម្យ៉ាងទៀត ដោយហេតុដែលយើងជាអ្នកដែលព្រះមានព្រះភាគត្រាស់ថា កស្សប អ្នកនឹងទ្រទ្រង់សំពត់បង្សុកូលដែលធ្វើដោយធ្មៃរបស់តថាគត ដែលតថាគតប្រើប្រាស់ស្លៀកដណ្ដប់ហើយឬ ដូច្នេះ ហើយទ្រង់អនុគ្រោះដោយសាធារណបរិភោគក្នុងចីវរ និងដោយការទ្រង់លើកតម្កើងទុក ប្រៀបធៀបព្រះអង្គក្នុងឧត្តរិមនុស្សធម្ម មានអនុបុព្វវិហារ ៩ និងអភិញ្ញា ៦ ដោយន័យយ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាដរាបណា ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្ដីស្ងាត់នោះ ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកកស្សបប្រាថ្នាដរាបណា ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្ដីស្ងាត់នោះ ដរាបនោះដែរ [១] ដូច្នេះជាដើម ភាពជាអ្នកមិនមានបំណុលដទៃណាមួយ នឹងមានដល់អាត្មាអញនោះបាន ព្រះមានព្រះភាគទ្រង់ជ្រាបអាត្មាអញថា កស្សបនេះ នឹងជាអ្នកបន្តវង្សព្រះសទ្ធម្មរបស់តថាគត ដូច្នេះហើយ ទើបទ្រង់អនុគ្រោះដោយ

១-បិ.៣២ ទំ.១៨៩ ឃ.១៦៥ ។

អសាធារណានុគ្រោះនេះ ដូចព្រះរាជាទ្រង់ជ្រាបព្រះរាជឱរស ដែលនឹងបន្តវង្សត្រកូលរបស់ព្រះអង្គ ហើយទ្រង់អនុគ្រោះដោយប្រគល់គ្រឿងគ្រោះនិងឥស្សរិយយសរបស់ព្រះអង្គដូច្នោះ មិនមែនឬ ដូច្នេះហើយ ទើបញុំាងឧស្សាហៈឲ្យកើតដល់ភិក្ខុទាំងឡាយ ដើម្បីប្រារព្ធសង្គាយនាព្រះធម៌ព្រះវិន័យ ដូចដែលព្រះធម្មសង្គាហកាចារ្យពោលទុកថា

លំដាប់នោះ ព្រះមហាកស្សបមានអាយុហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ សម័យមួយ ខ្ញុំគិតថា នឹងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងបាវានេះ រួចហើយនឹងទៅកាន់ក្រុងកុសិនារា ហើយក៏ដើរទៅតាមផ្លូវឆ្ងាយជាមួយនឹងភិក្ខុសង្ឃជាច្រើន ចំនួន ៥០០ រូប[១] ដូច្នេះជាដើម ។

ខាងមុខអំពីនេះ ព្រះមហាកស្សបមានអាយុបានពោលថា

ម្នាលអាវុសោទាំងឡាយ ណ្ហើយចុះ យើងរាល់គ្នាសង្គាយនានូវធម៌និងវិន័យ តំណទៅមុខ អកុសលធម៌មុខជានឹងរុងរឿងឡើង កុសល-ធម៌មុខជានឹងសាបសូន្យទៅ សភាវៈមិនមែនជាវិន័យ មុខជានឹងរុងរឿងឡើង វិន័យមុខជានឹងសាបសូន្យទៅ តំណទៅមុខ ពួកបុគ្គលជាអធម្មវាទីនឹងមានកម្លាំងឡើង ពួកបុគ្គលជាធម្មវាទីនឹងថយកម្លាំងចុះ ពួកបុគ្គលជាអវិនយវាទី នឹងមានកម្លាំងឡើង ពួកបុគ្គលជាវិនយវាទី នឹងថយកម្លាំងចុះ[២] ដូច្នេះ ។

---

១-បិ.១១ ទំ.៣៥៦ ឃ.២៧៨ ។ ២-បិ.១១ ទំ.៣៥៨ ឃ.២៧៨ ។

ភិក្ខុទាំងឡាយពោលថា បពិត្រព្រះថេរៈដ៏ចម្រើន បើដូច្នោះ សូមព្រះថេរៈជ្រើសរើសនូវភិក្ខុទាំងឡាយចុះ[១] ។

ព្រះថេរៈវៀរភិក្ខុដែលជាបុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះខីណាស្រពសុក្ខវិបស្សកៈ ដែលទ្រទ្រង់ព្រះបរិយត្តិ គឺនវង្គសត្ថុសាសនៈទាំងអស់ចេញ ច្រើនរយ និងច្រើនពាន់ ជ្រើសរើសយកតែភិក្ខុជាព្រះខីណាស្រពចំនួន ៤៩៩ អង្គ ដែលទ្រទ្រង់ទុកនូវប្រភេទសព្វបរិយត្តិគឺព្រះត្រៃបិដក បានសម្រេចបដិសម្ភិទា មានអានុភាពច្រើន បែកធ្លាយក្នុងវិជ្ជា ៣ ជាដើម ដែលព្រះមានព្រះភាគទ្រង់លើកឡើងកាន់ឯតទគ្គៈដោយច្រើនប៉ុណ្ណោះ ដែលព្រះធម្មសង្គាហកាចារ្យជ្រើសយក ទើបពោលពាក្យនេះថា ព្រះមហាកស្សបមានអាយុ ជ្រើស-រើសនូវព្រះអរហន្តទាំងឡាយ បានចំនួន ៤៩៩ អង្គ[២] ដូច្នេះជាដើម ។

សួរថា ព្រះកស្សបត្ថេរធ្វើឲ្យខ្វះមួយអង្គ ដើម្បីបុគ្គលណា ។

ឆ្លើយថា ដើម្បីឲ្យឱកាសដល់ព្រះអានន្ទត្ថេរ ។ ពិតហើយ ការធ្វើសង្គាយនាព្រះធម៌ មិនអាចធ្វើ ទាំងរួម ទាំងបែក ចាកព្រះអានន្ទបាននោះទេ ព្រោះព្រះអានន្ទនោះ នៅជាព្រះសេក្ខៈ មានកិច្ចចាំបាច់ត្រូវធ្វើនៅឡើយ ដូច្នោះហើយ ទើបមិនអាចធ្វើរួមនឹងលោក តែព្រោះនវង្គ-សត្ថុសាសនៈ មានសុត្តៈ គេយ្យៈជាដើម ដែលព្រះទសពលសម្តែងហើយ

---

១-២ បិ.១១ ទំ.៣៥៩ យ.២៧៩ ។

ឈ្មោះថា លោកមិនបានទទួលចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគនោះ មិនមាន ព្រោះហេតុនោះ ទើបមិនអាចរៀរលោកបាន ។

សួរថា កាលបើមិនអាចធ្វើយ៉ាងនោះបាន សូម្បីព្រះអានន្ទត្ថេរនៅជាព្រះសេក្ខៈនៅឡើយ ព្រះថេរៈក៏គួរជ្រើសរើស ព្រោះជាអ្នកមានឧបការៈច្រើន ដល់ការធ្វើសង្គាយនាព្រះធម៌ កាលមានសេចក្តីចាំបាច់ត្រូវជ្រើសរើសយ៉ាងនោះ ហេតុអ្វី ទើបព្រះថេរៈមិនជ្រើសរើសលោក ។

ឆ្លើយថា ព្រោះចៀសវាងពាក្យតិះដៀលរបស់អ្នកដទៃ ។ សេចក្តីពិត ព្រះថេរៈជាអ្នកស្និទ្ធស្នាលក្នុងព្រះអានន្ទមានអាយុយ៉ាងក្រៃលែង ។ ពិតហើយ សូម្បីសក់ស្កូវហើយ ព្រះមហាកស្សបត្ថេរក៏នៅតែហៅព្រះអានន្ទមានអាយុនោះ ដោយប្រើកុមារវាទថា ព្រះអានន្ទនេះ នៅក្មេង មិនដឹងប្រមាណឡើយ(១) ដូច្នេះ ។

ម្យ៉ាងទៀត ព្រះអានន្ទនេះ ប្រសូតក្នុងសក្យត្រកូល ជាព្រះភាតារបស់ព្រះតថាគត ជាឱរសរបស់ព្រះបិតុលា ពិតមែន ភិក្ខុទាំងឡាយនឹងសម្គាល់ក្នុងព្រះមហាកស្សបត្ថេរនោះថា ដូចជាដល់នូវឆន្ទាគតិ នឹងគប្បីពោលតិះដៀលថា ព្រះថេរៈរៀរភិក្ខុទាំងឡាយ ដែលបានសម្រេចបដិសម្ភិទា ជាអសេក្ខៈចេញជាច្រើន បែរជាជ្រើសរើសយកព្រះអានន្ទដែលសម្រេចបដិសម្ភិទាជាសេក្ខៈទៅវិញ ។ ព្រះថេរៈ កាលនឹងរៀរ

---

១-បិ.៣២ ទំ.១៦៦ ឃ.១៨៩ ។

ពាក្យតិះដៀលរបស់អ្នកដទៃនោះចេញ ទើបគិតថា ការធ្វើសង្គាយនា មិនអាចធ្វើបានឡើយ បើវៀរអានន្ទចេញ អញនឹងទទួលយកអានន្ទចូលផង តាមអនុម័តិរបស់ភិក្ខុទាំងឡាយប៉ុណ្ណោះ ទើបមិនបានជ្រើសរើសព្រះអានន្ទនោះឲ្យចូលរួម ។

គ្រានោះ ទើបភិក្ខុទាំងឡាយនាំគ្នាអង្វរព្រះថេរៈដើម្បីឲ្យជ្រើសរើសព្រះអានន្ទដោយខ្លួនឯងនោះឯង សមដូចបុរាណាចារ្យពោលទុកថា

ភិក្ខុទាំងឡាយបាននិយាយពាក្យនេះ នឹងព្រះមហាកស្សបមានអាយុថា បពិត្រព្រះករុណាដ៏ចម្រើន ព្រះអានន្ទមានអាយុនេះ នៅជាសេក្ខបុគ្គលពិតមែន តែលោកមិនអាចនឹងលុះដោយឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិទេ ធម៌ក្តី វិន័យក្តី ព្រះអានន្ទនេះ បានសិក្សារៀនសូត្រក្នុងសម្នាក់ព្រះមានព្រះភាគជាច្រើន បពិត្រព្រះករុណាដ៏ចម្រើន បើដូច្នោះ សូមព្រះថេរៈជ្រើសរើសយកព្រះអានន្ទដ៏មានអាយុផង ។ ទើបព្រះមហាកស្សបមានអាយុ ជ្រើសរើសយកព្រះអានន្ទមានអាយុបញ្ចូលផង[១] ។ រួមជាមួយភិក្ខុទាំងឡាយនោះ ដែលព្រះមហាកស្សបជ្រើសរើស តាមអនុម័តិរបស់ភិក្ខុទាំងឡាយ ទើបជាព្រះថេរៈ ៥០០ អង្គដោយប្រការដូច្នេះ ។

លំដាប់នោះ ភិក្ខុទាំងឡាយដែលជាថេរៈ មានសេចក្តីរិះគិតដូច្នេះ

---

១-បិ.១១ ទំ.៣៥៩ យ.២៧៩ ។

ថា យើងទាំងឡាយ គប្បីសង្គាយនាធម៌និងវិន័យក្នុងទីណាហ្ន៎ ។ គ្រានោះឯង ភិក្ខុទាំងឡាយដែលជាថេរៈ មានសេចក្ដីរិះគិតឃើញដូច្នេះថា នគររាជគ្រឹះ ជាស្រុកមានទីគោចរក៏ច្រើន មានសេនាសនៈក៏ច្រើន បើដូច្នោះ គួរតែយើងរាល់គ្នាទៅនៅចាំវស្សាក្នុងនគររាជគ្រឹះ ទើបអាចនឹងសង្គាយនានូវធម៌និងវិន័យបាន ចំណែកភិក្ខុទាំងឡាយឯទៀត កុំគប្បីចូលទៅនៅចាំវស្សាក្នុងនគររាជគ្រឹះឡើយ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈទាំងនោះ ប្រឹក្សាព្រមព្រៀងគ្នាដូច្នោះ ។

ឆ្លើយថា ព្រោះនឹងមានវិសភាគ បុគ្គលខ្លះចូលទៅកាន់កណ្ដាលជំនុំសង្ឃហើយ គប្បីជំទាស់ថាវរកម្មរបស់លោកបាន ។ គ្រានោះ ទើបព្រះមហាកស្សបមានអាយុសូត្យប្រកាសដោយញត្តិទុតិយកម្មវាចា ។ ញត្តិទុតិយកម្មនោះ អ្នកសិក្សាគប្បីជ្រាបតាមន័យដែលលោកពោលទុកក្នុងសង្គីតិក្ខន្ធកៈនោះឯង ។

គ្រានោះ ព្រះមហាកស្សបត្ថេរជ្រាបថា ចាប់តាំងពីថ្ងៃដែលព្រះតថាគតបរិនិព្វានមក កាលថ្ងៃសាធុកីឡា និងថ្ងៃបូជាព្រះធាតុកន្លងទៅបាន ៧ ថ្ងៃម្ដង ៗ ជាការកន្លងទៅហើយ កន្លះខែ ឥឡូវនេះ គិម្ហរដូវនៅសល់កន្លះខែ ជាតិបីដែលនឹងចូលវស្សា ក៏ជិតចូលមកហើយ ទើបពោលថា អ្នកមានអាយុទាំងឡាយ ពួកយើងទៅកាន់នគររាជគ្រឹះចុះ ហើយ

បាននាំយកភិក្ខុសង្ឃពាក់កណ្តាលដើរទៅផ្លូវមួយ ។ ព្រះអនុរុទ្ធត្ថេរក៏នាំយកភិក្ខុសង្ឃពាក់កណ្តាល ដើរទៅផ្លូវមួយទៀត ។ ព្រះអានន្ទត្ថេរកាន់យកបាត្រនិងចីវររបស់ព្រះមានព្រះភាគដែលមានភិក្ខុសង្ឃហែហម មានបំណងនឹងធ្វើដំណើរឆ្លងកាត់នគរសាវត្ថីទៅកាន់នគររាជគ្រឹះ ក៏ចារិកទៅតាមផ្លូវក្នុងនគរសាវត្ថី ។

ក្នុងទីដែលព្រះអានន្ទទៅហើយ ៗ មានការស្រែកយំរៀបរាប់យ៉ាងច្រើនថា បពិត្រព្រះអានន្ទដ៏ចម្រើន លោកម្ចាស់ឃាត់ព្រះសាស្តាទុកនៅឯណា ទើបមក ។ កាលព្រះថេរៈទៅដល់ក្រុងសាវត្ថីដោយលំដាប់ មានការស្រែកទ្រហោយំរៀបរាប់យ៉ាងច្រើន ដូចក្នុងថ្ងៃដែលព្រះមានព្រះភាគស្តេចបរិនិព្វាននោះឯង ។

បានឮថា ក្នុងក្រុងសាវត្ថីនោះ ព្រះអានន្ទត្ថេរបានលួងលោមពន្យល់មហាជននោះ ឲ្យធូរស្រាលចិត្ត ដោយធម្មីកថា ដែលបដិសំយុត្តដោយត្រៃលក្ខណ៍ មានការមិនទៀងជាដើម ហើយចូលទៅកាន់វត្តជេតពន បើកទ្វារព្រះគន្ធកុដិដែលព្រះទសពលធ្លាប់គង់នៅ យកគ្រែនិងតាំងចេញមក គោះ វាយ បោសសម្អាតព្រះគន្ធកុដិ ប្រមូលសំរាមផ្កាឈើដែលស្ងួត ៗ យកទៅចោល ហើយនាំយកគ្រែ និងតាំងត្រឡប់ចូលទៅរៀបចំទុកក្នុងទីដើមវិញ បានធ្វើវត្តគ្រប់យ៉ាង ដែលគួរធ្វើ ដូចក្នុងកាលដែលព្រះមានព្រះភាគគង់ព្រះជន្មដូច្នោះ ។

ក្នុងកាលនោះ ព្រះថេរៈព្រោះជាអ្នកច្រើនទៅដោយការឈរ និងការអង្គុយ តាំងអំពីកាលព្រះមានព្រះភាគបរិនិព្វានមក ដើម្បីជម្រះកាយដែលមានធាតុក្រាស់ឲ្យសប្បាយ ក្នុងថ្ងៃទី ២ ទើបអង្គុយឆាន់ថ្នាំបញ្ចុះដែលលាយដោយទឹកដោះនៅក្នុងវិហារនោះឯង ទើបមានពាក្យដែលព្រះថេរៈពោលចំពោះមាណព ដែលសុភមាណពបញ្ជូនទៅថា ម្នាលមាណព កាលនេះ មិនគួរ (នឹងទៅទេ) ដ្បិតថ្ងៃនេះ យើងបានឆាន់ថ្នាំខ្លះទៅហើយ បើដូច្នោះ ចាំយើងពិចារណា នូវកាលនិងសម័យសិន ហើយសឹមទៅក្នុងថ្ងៃស្អែក [១] ដូច្នេះ ។

ក្នុងថ្ងៃស្អែកឡើង ព្រះថេរៈមានព្រះចេតកត្ថេរជាបច្ឆាសមណៈបានទៅ (កាន់លំនៅរបស់សុភមាណព) ត្រូវសុភមាណពសួរ ទើបសម្ដែងព្រះសូត្រទី ១០ ឈ្មោះសុភសូត្រ ក្នុងទីឃនិកាយ ។

ក្នុងកាលនោះ ព្រះថេរៈបង្គាប់ឲ្យជាងធ្វើការជួសជុលទីកន្លែងដែលទ្រុឌទ្រោមក្នុងវត្តជេតពនហើយ កាលថ្ងៃវស្សូបនាយិកាជិតចូលមកដល់ បានទៅកាន់ក្រុងរាជគ្រឹះ ។ សូម្បីព្រះមហាកស្សបត្ថេរនិងព្រះអនុរុទ្ធត្ថេរ ក៏បាននាំភិក្ខុសង្ឃទាំងអស់ទៅកាន់នគររាជគ្រឹះដូចគ្នា ។

សម័យនោះឯង ក្នុងនគររាជគ្រឹះ មានមហាវិហារ ១៨ វិហារធំ ៗ ទាំងអស់នោះ ក៏ស្រកេកស្រកាកទៅដោយរបស់ដែលត្រូវបោល

---

១-បិ.១៥ ទំ.១៦១ ឃ.១១៨ ។

ពាសពេញ ( ដោយសំរាម ) ពិតហើយ ពួកភិក្ខុទាំងអស់បាននាំគ្នាកាន់យកបាត្រនិងចីវររៀង ៗ ខ្លួន លះបង់ចោលវិហារនិងបរិវេណ ទៅក្នុងទីដែលព្រះមានព្រះភាគបរិនិព្វាន ។ ព្រះថេរៈទាំងឡាយនៅក្នុងវិហារទាំងនោះ ដើម្បីនឹងបូជាព្រះតម្រាស់របស់ព្រះមានព្រះភាគ និងដើម្បីដោះវាទៈរបស់ពួកតិរ្ថិយ ទើបគិតគ្នាថា មួយខែដំបូងនេះ ពួកយើងនឹងធ្វើការជួសជុលវិហារដែលបាក់បែក ។ ឯពួកតិរ្ថិយទាំងឡាយ គប្បីពោលថា ពួកសាវ័ករបស់ព្រះសមណគោតម កាលព្រះសាស្តាទ្រង់នៅមានព្រះជន្មប៉ុណ្ណោះ ទើបថែទាំវិហារ កាលព្រះសាស្តាបរិនិព្វានហើយក៏នាំគ្នាលះបង់ចោលអស់ ។ លោកពោលអធិប្បាយទុកថា ដើម្បីនឹងដោះនូវវាទរបស់ពួកតិរ្ថិយទាំងនោះ ទើបព្រះថេរៈទាំងឡាយ បានគិតគ្នាយ៉ាងនោះ ។ សេចក្តីនេះ សមដូចព្រះធម្មសង្គាហកាចារ្យពោលទុកថា ទើបភិក្ខុទាំងឡាយជាថេរៈ មានសេចក្តីរិះគិតដូច្នេះថា ម្នាលអាវុសោ បដិសង្ខរណកម្ម គឺការជួសជុលសេនាសនៈ ដែលដាច់ដាចធ្លុះធ្លាយ ព្រះមានព្រះភាគទ្រង់សរសើរហើយ ម្នាលអាវុសោ បើដូច្នោះ គួរតែយើងរាល់គ្នាជួសជុលសេនាសនៈ ដែលដាច់ដាចធ្លុះធ្លាយ អស់ខែមួយជាដំបូងសិន ដល់មកខែកណ្តាល យើងនឹងប្រជុំគ្នាសង្គាយនានូវធម៌និងវិន័យ [១] ដូច្នេះ ។

---

១-បិ.១១ ទំ.៣៦១ ឃ.២៨០ ។

ក្នុងថ្ងៃទី ២ ព្រះថេរៈទាំងនោះ បានទៅឈរត្រង់ទ្វារព្រះរាជវាំង ។ ព្រះបាទអជាតសត្តុ ស្តេចយាងមកថ្វាយបង្គំ ហើយត្រាស់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទាំងឡាយនាំគ្នាមកដោយហេតុដូចម្តេច ហើយត្រាស់សួរដល់កិច្ចដែលទ្រង់គួរធ្វើ ។ ព្រះថេរៈទាំងឡាយ បានប្រាប់ហត្ថកម្ម ដើម្បីប្រយោជន៍ដល់ការជួសជុលមហាវិហារទាំង ១៨ កន្លែង ។ ព្រះរាជាទ្រង់ទទួលថា សាធុលោកម្ចាស់ ហើយបានប្រគេនពួកមនុស្សអ្នកធ្វើហត្ថកម្ម ។ ព្រះថេរៈទាំងឡាយប្រាប់ឲ្យជួសជុលវិហារទាំងអស់ សម្រេចក្នុងមួយខែដំបូងប៉ុណ្ណោះ ហើយប្រាប់ឲ្យព្រះរាជាទ្រង់ជ្រាបថា សូមថ្វាយព្រះពរមហាបពិត្រ ការជួសជុលវិហារសម្រេចអស់ហើយ ឥឡូវនេះ អាត្មាភាពទាំងឡាយ នឹងធ្វើសង្គាយនាព្រះធម៌និងព្រះវិន័យ ។

ព្រះរាជាត្រាស់ថា សាធុ លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយ កុំសន្ទិះសង្ស័យ ធ្វើចុះ អាណាចក្ក សូមទុកជាភារៈរបស់ខ្ញុំ ធម្មចក្ក សូមជាភារៈរបស់លោកម្ចាស់ទាំងឡាយ សូមលោកម្ចាស់ប្រើខ្ញុំចុះ លោកម្ចាស់នឹងឲ្យខ្ញុំធ្វើអ្វី ។ ព្រះថេរៈពោលថា សូមថ្វាយព្រះពរមហាបពិត្រ សូមព្រះអង្គឲ្យធ្វើទីកន្លែងអង្គុយប្រជុំ សម្រាប់ភិក្ខុទាំងឡាយដែលធ្វើសង្គាយនា ។

ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ តើឲ្យខ្ញុំធ្វើក្នុងទីណា ។

ព្រះថេរៈពោលថា សូមថ្វាយព្រះពរមហាបពិត្រ គួរធ្វើត្រង់ទ្វារល្អាងសត្តបណ្ណគុហា នាភ្នំវេភារៈ ។

ព្រះបាទអជាតសត្តុត្រាស់ថា សាធុលោកម្ចាស់ ហើយត្រាស់ឲ្យសាងមណ្ឌប មានគ្រឿងប្រដាប់ដែលជាសារៈ ដែលគួរទស្សនា ដូចទីកន្ទេងដែលវិស្សុកម្មទេវបុត្តនិម្មិតទុក មានជញ្ជាំង សសរ និងជណ្តើរដែលជាងរៀបចំទុកដោយល្អ វិចិត្រដោយមាលាកម្ម និងលតាកម្ម មានប្រភេទផ្សេង ៗ ហាក់ដូចជាគ្របសង្កត់នូវសម្បត្តិនៃរាជមណ្ឌបរបស់ព្រះមហាក្សត្របាត់អស់ គួរនាដូចសិរីទេវវិមាន ដូចជាស្ថានជាទីអាស្រ័យនៅនៃសិរី ដូចកំពង់ជាទីប្រជុំដ៏កំពូលរបស់ពួកវិហង្គៈ គឺភ្នែកនៃទេវតានិងមនុស្ស និងដូចរមណីយដ្ឋានក្នុងលោក ដែលគេចាត់ចែងសព្វគ្រប់ ការរចនាមណ្ឌបនោះ ដូចជាវិមានព្រហ្ម មានពិដានស្រស់ស្អាត រុងរឿងដូចកម្រងផ្កាកុសុមៈ ដែលរេរាំសំយុងចុះ មានប្រភេទផ្សេង ៗ វិចិត្រដោយផ្កាឈើ និងគ្រឿងបូជាផ្សេង ៗ មានការងារដែលគួរធ្វើ ត្រង់ផ្ទៃដីខាងក្រោម សម្រេចរៀបរយល្អហើយ ដូចជាមានផ្ទៃដីក្រាលពេញដោយកែវមណី ដ៏វិចិត្រដោយរតនៈដូច្នោះ ខាងក្នុងមហាមណ្ឌបនោះ ទ្រង់ត្រាស់ឲ្យក្រាលកម្រាលដែលជាកប្បិយៈ ៥០០ ដែលគណនាតម្លៃមិនបាន សម្រាប់ភិក្ខុ ៥០០ អង្គ ហើយឲ្យក្រាលថេរាសនៈដែលមានបង្អែកនាទិសទក្សិណ បែរមុខទៅទិសឧត្តរ ត្រង់កណ្តាលមណ្ឌប ឲ្យតាំង

ធម្មាសនៈដែលគួរជាទីគង់ប្រថាប់របស់ព្រះមានព្រះភាគ បែរមុខទៅទិសបូព៌ និងទ្រង់ឲ្យតម្កល់ផ្ទិតវាលវីជនីដ៏វិចិត្រដោយភ្លុក ទុកលើធម្មាសនៈនោះ ហើយប្រាប់ឲ្យប្រកាសដល់ភិក្ខុសង្ឃថា បពិត្រលោកម្ចាស់ដ៏ចម្រើន កិច្ចរបស់ខ្ញុំសម្រេចហើយ ដូច្នេះ ។

ពួកភិក្ខុបានពោលនឹងព្រះអានន្ទថា អាវុសោ ការប្រជុំនឹងមានក្នុងថ្ងៃស្អែក តែលោកនៅជាសេក្ខបុគ្គលនៅឡើយ ព្រោះហេតុនោះ លោកមិនគួរទៅកាន់ទីប្រជុំ លោកចូរជាអ្នកមិនប្រមាទចុះ ដូច្នេះ ។

គ្រានោះឯង ព្រះអានន្ទត្រិះរិះថា ការប្រជុំនឹងមានក្នុងថ្ងៃស្អែក ឯការដែលអញនៅជាសេក្ខៈនេះ គប្បីទៅកាន់ទីប្រជុំនោះ មិនសមគួរដល់អញឡើយ ហើយបានសម្រាកនៅដោយកាយគតាសតិ រហូតដល់យប់ជ្រៅនោះឯង ក្នុងពេលជិតភ្លឺ ក៏ចុះអំពីទីចង្ក្រម ហើយចូលទៅកាន់វិហារ ( កុដិ ) គិតថា នឹងសឹង ក៏បានទម្រេតកាយចុះ ។ ជើងទាំងពីរផុតអំពីផែនដី តែសីសៈមិនទាន់ដល់ខ្នើយ ក្នុងចន្លោះឥរិយាបថនោះ ចិត្តក៏ផុតអំពីអាសវៈទាំងឡាយ មិនប្រកាន់មាំដោយឧបាទាន ។ ពិតហើយ ព្រះអានន្ទនេះ សម្រាកនៅហើយខាងក្រៅដោយការចង្ក្រម កាលមិនអាចនឹងញ៉ាំងគុណវិសេសឲ្យកើតឡើងបាន ទើបគិតថា ព្រះមានព្រះភាគបានត្រាស់ពាក្យនេះដល់អញ មិនមែនឬ ថា ម្នាលអានន្ទ ខ្លួនអ្នកជាបុគ្គលបានធ្វើបុណ្យទុកហើយ ចូរប្រកបព្យាយាមរឿយ ៗ ចុះ នឹងបាន

ជាបុគ្គលមិនមានអាសវៈដោយឆាប់[១] ដូច្នេះ ជាធម្មតា ទោសនៃព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយ មិនមាន អាត្មាអញប្រារព្ធសេចក្តីព្យាយាមច្រើនពេកណាស់ ព្រោះហេតុនោះ ទើបចិត្តរបស់អាត្មាអញប្រព្រឹត្តទៅដើម្បីសេចក្តីរាយមាយ ណ្ហើយចុះ អញនឹងប្រកបសេចក្តីព្យាយាមឲ្យស្មើ ដូច្នេះ ទើបចុះពីទីចង្ក្រម ឈរលាងជើងក្នុងទីសម្រាប់លាងជើង ហើយចូលទៅកាន់វិហារ គង់លើគ្រែ ត្រិះរិះថា នឹងសម្រាកមួយក្ញេត ក៏បានទម្រេតកាយទៅលើគ្រែ ។ ជើងទាំងពីរផុតអំពីផែនដី ក្បាលមិនទាន់ដល់ខ្នើយ ក្នុងចន្លោះឥរិយាបថនេះ ចិត្តក៏ផុតអំពីអាសវៈទាំងឡាយ មិនប្រកាន់មាំដោយឧបាទាន ។ ភាពជាព្រះអរហន្តរបស់ព្រះថេរៈ វៀរចាកឥរិយាបថ ៤ ។ ព្រោះហេតុនោះ បើមានអ្នកណាសួរថា ក្នុងសាសនានេះ ភិក្ខុអង្គណា មិនដេក មិនអង្គុយ មិនឈរ មិនចង្ក្រម បានសម្រេចអរហត្ត គប្បីឆ្លើយថា ព្រះអានន្ទត្ថេរ ក៏គួរ ។

គ្រានោះ ក្នុងថ្ងៃទី ២ ភិក្ខុជាថេរៈទាំងឡាយ ធ្វើភត្តកិច្ចស្រេច ទុកដាក់បាត្រនិងចីវរហើយ ទៅប្រជុំគ្នាក្នុងធម្មសភា ។ ឯព្រះអានន្ទត្ថេរមានបំណងនឹងឲ្យអ្នកដទៃដឹង អំពីការសម្រេចភាពជាព្រះអរហន្តរបស់ខ្លួន ទើបមិនបានទៅព្រមនឹងភិក្ខុទាំងឡាយឡើយ ភិក្ខុទាំងឡាយ កាលអង្គុយលើអាសនៈរបស់ខ្លួនតាមលំដាប់វស្សា បានអង្គុយវៀរអាសនៈទុក

---

១-បិ.១៦ ទំ.៣០២ ឃ.១៣៥ ។

សម្រាប់ព្រះអានន្ទត្ថេរ ។ កាលភិក្ខុពួកខ្លះក្នុងធម្មសភានោះសួរថា ទុំះអាសនៈរបស់ភិក្ខុណា ភិក្ខុទាំងឡាយឆ្លើយថា របស់ព្រះអានន្ទ ភិក្ខុទាំងឡាយសួរថា ចុះព្រះអានន្ទទៅណាហ្ន៎ ក្នុងសម័យនោះ ព្រះថេរៈគិតថា ឥឡូវនេះ ជាកាលដែលអញគួរទៅ ។ ក្នុងលំដាប់នោះ កាលនឹងសម្តែងអានុភាពរបស់ខ្លួន ទើបមុជចុះក្នុងផែនដី ហើយបង្ហាញខ្លួនលើអាសនៈរបស់ខ្លួននោះឯង ។ អាចារ្យពួកខ្លះពោលថា មកតាមអាកាស ហើយអង្គុយ ក៏មាន ។

កាលព្រះអានន្ទមានអាយុនោះ អង្គុយហើយយ៉ាងនេះ ទើបព្រះមហាកស្សបត្ថេរប្រឹក្សាជាមួយភិក្ខុទាំងឡាយថា អ្នកមានអាយុទាំងឡាយពួកយើងនឹងសង្គាយនាអ្វីមុន ព្រះធម៌ឬព្រះវិន័យ ។

ភិក្ខុទាំងឡាយឆ្លើយថា បពិត្រលោកម្ចាស់មហាកស្សប ធម្មតាព្រះវិន័យជាអាយុរបស់ព្រះពុទ្ធសាសនា កាលព្រះវិន័យតាំងនៅ ព្រះពុទ្ធសាសនារាប់ថា តាំងនៅ ព្រោះហេតុនោះ ពួកយើងនឹងសង្គាយនាព្រះវិន័យមុន ។

ព្រះមហាកស្សបសួរថា នឹងឲ្យធុរៈទៅអ្នកណា ។

ភិក្ខុទាំងឡាយពោលថា ឲ្យឧបាលិមានអាយុ ។

សួរថា ព្រះអានន្ទមិនអាចឬ ។

ឆ្លើយថា មិនមែនមិនអាចទេ ។ ម្យ៉ាងទៀត កាលព្រះសម្មាសម្ពុទ្ធ

គង់ព្រះជន្មនៅនោះឯង ទ្រង់អាស្រ័យវិនយបរិយត្តិ ទើបតាំងព្រះឧបាលិទុកក្នុងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកទ្រទ្រង់វិន័យដែលជាសាវ័ករបស់តថាគត ស្រេចនឹងឧបាលិ ប្រសើរជាងគេ(១) ដូច្នេះ ព្រោះហេតុនោះ ទើបភិក្ខុទាំងឡាយប្រឹក្សាគ្នាថា ពួកយើងនឹងសួរព្រះឧបាលិត្ថេរ សង្គាយនាព្រះវិន័យ ដូច្នេះ ។

លំដាប់នោះ ព្រះថេរៈក៏បានសន្មតខ្លួនឯង ដើម្បីសួរនូវព្រះវិន័យ ។ ឯព្រះឧបាលិត្ថេរក៏បានសន្មតខ្លួន ដើម្បីប្រយោជន៍ដល់ការវិសជ្ជនា ។

ក្នុងការសន្មតនោះ មានក្នុងព្រះបាលីដូចតទៅនេះថា

គ្រានោះឯង ព្រះមហាកស្សបមានអាយុ បានប្រកាសសង្ឃឲ្យដឹងថា ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ បើសង្ឃតិកម្មនេះ មានកាលគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរវិន័យនឹងព្រះឧបាលិ ។ ព្រះឧបាលិមានអាយុបានប្រកាសសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃតិកម្មនេះ មានកាលគួរដល់សង្ឃហើយ ព្រះមហាកស្សបមានអាយុត្រូវសួរព្រះវិន័យចំពោះខ្ញុំ ខ្ញុំក៏ត្រូវដោះស្រាយ ( ក្នុងកាលឥឡូវនេះ )(២) ដូច្នេះ ។

ព្រះឧបាលិ កាលសន្មតខ្លួនហើយ ក៏ក្រោកឡើងអំពីអាសនៈដណ្តប់ចីវរឆៀងស្មាម្ខាង ថ្វាយបង្គំព្រះថេរៈទាំងឡាយហើយ គង់លើ

---

១-បិ.៤០ ទំ.៥៥ ឃ.១៤៩ ។ ២-បិ.១១ ទំ.៣៦២ ឃ.២៨២ ។

ធម្មាសនៈ ចាប់ផ្ចិតវាលវិជនីដ៏វិចិត្រដោយភ្លុក ។ គ្រានោះ ព្រះមហាកស្សបគង់លើថេរាសនៈហើយ សួរព្រះវិន័យនឹងព្រះឧបាលិមានអាយុ ( ដែលមានក្នុងព្រះបាលី ) ថា

ម្នាលឧបាលិមានអាយុ បឋមបារាជិកសិក្ខាបទ ព្រះមានព្រះភាគទ្រង់បញ្ញត្តក្នុងទីណា ។ ព្រះឧបាលិឆ្លើយថា ក្នុងនគរវេសាលី លោកម្ចាស់ ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងសុទិន្នភិក្ខុ ជាកូននៃកលន្ទសេដ្ឋី ។ ព្រោះវត្ថុអ្វី ។ ព្រោះសេពមេថុនធម្ម ។ លំដាប់នោះឯង ព្រះមហាកស្សបមានអាយុ សួរវត្ថុផង សួរនិទានផង សួរបុគ្គលផង សួរបញ្ញត្តិផង សួរអនុប្បញ្ញត្តិផង សួរអាបត្តិផង សួរអនាបត្តិផង នៃបឋមបារាជិកសិក្ខាបទ ចំពោះព្រះឧបាលិមានអាយុ[១] ។ ព្រះមហាកស្សបមានអាយុ សួរវត្ថុផង ។ បេ ។ សួរអនាបត្តិផង នៃបឋមបារាជិកសិក្ខាបទយ៉ាងណា ក៏សួរវត្ថុផង ។ បេ ។ សួរអនាបត្តិផង នៃទុតិយបារាជិក ក៏យ៉ាងនោះ សួរវត្ថុផង ។ បេ ។ សួរអនាបត្តិផង នៃតតិយបារាជិកសិក្ខាបទ ក៏យ៉ាងនោះ សួរវត្ថុផង ។ បេ ។ សួរអនាបត្តិផង នៃចតុត្ថបារាជិកសិក្ខាបទ ក៏យ៉ាងនោះដែរ ។ ព្រះឧបាលិមានអាយុ កាលបើព្រះមហាកស្សបត្ថេរសួរ ( ព្រះវិន័យបិដក ) សព្វគ្រប់ហើយ ក៏បានដោះស្រាយសព្វគ្រប់ ។

---

១-បិ.១១ ទំ.៣៦២ ឃ.២៨២ ។

លំដាប់នោះ ព្រះថេរៈទាំងឡាយបានលើកបារាជិក ៤ ឡើងកាន់សង្គហៈថា នេះឈ្មោះបារាជិកកណ្ឌ ហើយបានរៀបចំសង្ឃាទិសេស ១៣ ទុកថា តេរសកណ្ឌ រៀបចំសិក្ខាបទ ២ ទុកថា អនិយតៈ រៀបចំសិក្ខាបទ ៣០ ទុកថា និស្សគ្គិយបាចិត្តិយៈ រៀបចំសិក្ខាបទ ៩២ ទុកថា បាចិត្តិយៈ រៀបចំសិក្ខាបទ ៤ ទុកថា បាដិទេសនីយៈ រៀបចំសិក្ខាបទ ៧៥ ទុកថា សេក្ខិយៈ រៀបចំធម៌ ៧ ប្រការទុកថា អធិករណសមថៈ ដូច្នេះ ។

លុះព្រះថេរៈទាំងឡាយ លើកមហាវិភង្គឡើងកាន់សង្គហៈយ៉ាងនេះហើយ ទើបរៀបចំសិក្ខាបទ ៨ ក្នុងភិក្ខុនីវិភង្គទុកថា នេះឈ្មោះបារាជិកកណ្ឌ រៀបចំសិក្ខាបទ ១៧ ទុកថា សត្តរសកណ្ឌ រៀបចំសិក្ខាបទ ៣០ ទុកថា និស្សគ្គិយបាចិត្តិយៈ រៀបចំសិក្ខាបទ ១៦៦ ទុកថា បាចិត្តិយៈ រៀបចំសិក្ខាបទ ៨ ទុកថា បាដិទេសនីយៈ រៀបចំសិក្ខាបទ ៧៥ ទុកថា សេក្ខិយៈ រៀបចំធម៌ ៧ ប្រការទុកថា អធិករណសមថៈ ដូច្នេះ ។

ព្រះថេរៈទាំងឡាយ កាលលើកភិក្ខុនីវិភង្គឡើងកាន់សង្គហៈយ៉ាងនេះហើយ ទើបលើកនូវខន្ធកៈ និងបរិវារៈ ( ឡើងកាន់សង្គាយនា ) ដោយឧបាយនោះឯង ។ ព្រះវិន័យបិដក ព្រមទាំងឧភតោវិភង្គក្ខន្ធកៈ និងបរិវារៈនេះ ព្រះថេរៈទាំងឡាយ លើកឡើងកាន់សង្គហៈហើយ ដោយ

ប្រការដូច្នេះ ។

ព្រះមហាកស្សបត្ថេរបានសួរវិនយបិដកទាំងអស់ ព្រះឧបាលិត្ថេរក៏បានវិសជ្ជនាហើយ ។ ក្នុងទីបំផុតនៃការបុច្ឆានិងវិសជ្ជនា ព្រះអរហន្តចំនួន ៥០០ អង្គ បានធ្វើការស្វាធ្យាយជាគណៈ ដោយន័យដែលលើកឡើងកាន់សង្គហៈនោះឯង ។ ក្នុងអវសាននៃការធ្វើសង្គាយនាព្រះវិន័យ ព្រះឧបាលិត្ថេរដាក់ផ្ចិតវាលវីជនីដែលវិចិត្រដោយភ្លុកហើយ ចុះពីធម្មាសនៈថ្វាយបង្គំព្រះថេរៈទាំងឡាយ ហើយគង់លើអាសនៈរបស់ខ្លួន ។

ព្រះមហាកស្សប កាលសង្គាយនាព្រះវិន័យហើយ មានបំណងនឹងសង្គាយនាព្រះធម៌ ទើបសួរភិក្ខុទាំងឡាយថា កាលពួកយើងសង្គាយនាព្រះធម៌ គួរធ្វើឲ្យជាធុរៈរបស់ភិក្ខុអង្គណា ។

ភិក្ខុទាំងឡាយឆ្លើយថា បពិត្រលោកម្ចាស់ ឲ្យព្រះអានន្ទត្ថេរ ។

ឰដ៏កាលនោះ ព្រះមហាកស្សបមានអាយុ បានប្រកាសសង្ឃឲ្យដឹងថា ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ បើសង្ឃតិកម្មមានកាលគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរនូវធម៌ចំពោះព្រះអានន្ទ ។ ព្រះអានន្ទមានអាយុបានប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃតិកម្មមានកាលគួរដល់សង្ឃហើយ ព្រះមហាកស្សបមានអាយុនឹងសួរធម៌ចំពោះខ្ញុំ ខ្ញុំគប្បីដោះស្រាយក្នុងកាលឥឡូវនេះ [១] ដូច្នេះ ។

---

១-បិ.១១ ទំ.៣៦៤ ឃ.២៨៣ ។

គ្រានោះ ព្រះមហាកស្សបមានអាយុ សួរនិទានផង សួរបុគ្គលផង នៃព្រហ្មជាលសូត្រ ចំពោះព្រះអានន្ទដ៏មានអាយុ(១) ។ ហើយសួរនូវនិកាយ(២) ទាំង ៥ ដោយឧបាយនេះឯង(៣) ។

ធម៌និងវិន័យដែលប្រាកដនៅក្នុងព្រះត្រៃបិដក បានចងក្រង ៧ ខែទើបចប់ ដោយប្រការដូច្នេះ ។

ក្នុងវេលាចប់ការចងក្រងពុទ្ធវចនៈនោះ មហាប្រឹថពីនេះ ហាក់ដូចជាកើតសេចក្តីត្រេកអរ ឲ្យសាធុការថា ព្រះមហាកស្សបត្ថេរធ្វើសាសនារបស់ព្រះទសពលនេះ ឲ្យអាចប្រព្រឹត្តទៅបានអស់កាលប្រមាណ ៥០០០ ព្រះវស្សា ដូច្នេះ ក៏ញាប់ញ័រ រញ្ជួយខ្ទរខ្ទារជាអនេកប្បការ រហូតដល់ទឹកទ្រផែនដីជាទីបំផុត ភាពអស្ចារ្យទាំងឡាយជាច្រើន បានប្រាកដមានហើយ ដោយប្រការដូច្នេះ ។

សង្គីតិណាក្នុងលោក លោកហៅថា បញ្ចសតាសង្គីតិ ព្រោះព្រះធម្មសង្គាហកត្ថេរ ៥០០ អង្គធ្វើ និងហៅថា ថេរិកាសង្គីតិ ព្រោះព្រះថេរៈទាំងឡាយនោះ ធ្វើ

---

១-បិ.១១ ទំ.៣៦៤ ឃ.២៨៣ ។ ២-ពាក្យថា និកាយទាំង ៥ គឺទីឃនិកាយ ១ មជ្ឈិមនិកាយ ១ សំយុត្តនិកាយ ១ អង្គុត្តរនិកាយ ១ ខុទ្ទកនិកាយ ១ បណ្តានិកាយទាំងនោះ ព្រះវិន័យនិងព្រះអភិធម្ម លោកសង្គ្រោះចូលក្នុងខុទ្ទកនិកាយ ដូច្នេះ ។ ៣-បិ.១១ ទំ.៣៦៥ ឃ.២៨៣ ។

ហើយ សង្គីតិនេះ ឈ្មោះថា បឋមមហាសង្គីតិ ដោយ
ប្រការដូច្នេះ ។

ព្រះវិនយបិដកនេះ ព្រះឧបាលិត្ថេរទ្រទ្រង់ទុកចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគជាខាងដើម មុនគេ ។ កាលព្រះតថាគតមិនទាន់បរិនិព្វាននោះឯង ភិក្ខុច្រើនពាន់អង្គ ដែលបានអភិញ្ញា ៦ ទ្រទ្រង់ចាំទុកតអំពីព្រះឧបាលិត្ថេរនោះ កាលព្រះតថាគតបរិនិព្វានហើយ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ មានព្រះមហាកស្សបជាប្រធាន ក៏ទ្រទ្រង់ចាំទុកតមក ។

ក្នុងជម្ពូទ្វីប ព្រះវិន័យនេះ នាំបន្តមកដោយលំដាប់នៃអាចារ្យ ចាប់ផ្ដើមអំពីព្រះឧបាលិត្ថេរ រហូតដល់សង្គាយនាលើកទី ៣ ។ ក្នុងជម្ពូទ្វីបនោះ មានលំដាប់អាចារ្យដូចតទៅនេះ

ព្រះថេរៈ ៥ អង្គ គឺព្រះឧបាលិ ១ ព្រះទាសកៈ ១ ព្រះ
សោណកៈ ១ ព្រះសិគ្គវៈ ១ ព្រះមោគ្គលីបុត្តតិស្សត្ថេរ ១
ជាអ្នកមានជ័យជម្នះដ៏វិសេស ។ បាននាំព្រះវិន័យមក
ដោយលំដាប់ មិនឲ្យដាច់ខ្សែក្នុងសិរីជម្ពូទ្វីប រហូតដល់
សង្គាយនាលើកទី ៣ ។

សេចក្ដីពិស្ដារថា ព្រះឧបាលិត្ថេររៀនយកវង្សបែបផែនបវេណីព្រះវិន័យចំពោះព្រះភក្ត្រព្រះមានព្រះភាគ ហើយឲ្យតាំងនៅក្នុងហទយៈ

របស់ភិក្ខុដ៏ច្រើន ។ ពិតហើយ បណ្ដាបុគ្គលអ្នករៀនយកវិនយវង្សក្នុងសម្នាក់របស់លោកនោះហើយ ដល់នូវភាពជាបុគ្គលឈ្លាសអង់អាចក្នុងព្រះវិន័យ បុគ្គលដែលជាបុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី រាប់មិនអស់ ដែលជាព្រះខីណាស្រពមានចំនួន ១ ពាន់អង្គ ។

ចំណែកព្រះទាសកត្ថេរ ជាសទ្ធិវិហារិករបស់ព្រះឧបាលិត្ថេរនោះឯង លោកបានរៀនយក ( ព្រះវិន័យ ) តអំពីព្រះឧបាលិត្ថេរ ហើយក៏បង្រៀនព្រះវិន័យ ( ដល់ភិក្ខុជាច្រើន ) យ៉ាងនេះ ។ បុថុជ្ជនជាដើមរៀនយកព្រះវិន័យ ក្នុងសម្នាក់របស់ព្រះថេរៈនោះ ហើយដល់នូវភាពជាបុគ្គលឈ្លាសអង់អាចក្នុងព្រះវិន័យ រាប់មិនអស់ ដែលជាព្រះខីណាស្រពមានចំនួនដល់ទៅ ១ ពាន់អង្គ ។

ចំណែកព្រះសោណកត្ថេរ ជាសទ្ធិវិហារិករបស់ព្រះទាសកត្ថេរ លោកក៏រៀនយក ( ព្រះវិន័យ ) បន្តអំពីព្រះទាសកត្ថេរដែលជាឧបជ្ឈាយ៍របស់ខ្លួន ហើយក៏បង្រៀនព្រះវិន័យ ( ដល់ភិក្ខុដ៏ច្រើន ) យ៉ាងនោះ ។ បុថុជ្ជនជាដើម ដែលរៀនយក ( ព្រះវិន័យ ) ក្នុងសម្នាក់របស់ព្រះថេរៈនោះ ហើយដល់នូវភាពជាអ្នកឈ្លាសក្នុងព្រះវិន័យ រាប់មិនអស់ ដែលជាព្រះខីណាស្រព មានចំនួនដល់ទៅ ១ ពាន់អង្គដូចគ្នា ។

ចំណែកព្រះសិគ្គវត្ថេរជាសទ្ធិវិហារិករបស់ព្រះសោណកត្ថេរ រៀន

*យកព្រះវិន័យក្នុងសម្នាក់របស់ព្រះថេរៈ ហើយបានជាអ្នកទទួលធុរៈរបស់ព្រះអរហន្ត ១ ពាន់អង្គ ។ម្យ៉ាងទៀត បុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមីនិងព្រះអនាគាមីក្តី ព្រះខីណាស្រពក្តី ដែលរៀនយក (ព្រះវិន័យ) ក្នុងសម្នាក់ព្រះថេរៈអង្គនោះ ហើយដល់នូវភាពជាបុគ្គលឈ្លាសអង់អាចក្នុងព្រះវិន័យ ក៏កំណត់មិនបានថា ប៉ុណ្ណោះរយ ឬប៉ុណ្ណោះពាន់ឡើយ ។ បានឮថា វេលានោះ ក្នុងជម្ពូទ្វីបមានការប្រជុំភិក្ខុយ៉ាងច្រើន ។ អានុភាពរបស់ព្រះមោគ្គលីបុត្តតិស្សត្ថេរនោះ នឹងមានប្រាកដច្បាស់ក្នុងតតិយសង្គាយនា ។ ព្រះវិនយបិដកនេះ គប្បីជ្រាបថា ក្នុងជម្ពូទ្វីបនាំបន្តគ្នាមកដោយលំដាប់នៃអាចារ្យនេះ ដរាបដល់សង្គាយនាលើកទី ៣ ដោយប្រការដូច្នេះ ។*

*ថ្ងៃមួយ ក្នុងថ្ងៃឧបោសថ ពេលសម្តែងបាតិមោក្ខ ព្រះឧបាលិត្ថេរកាលឲ្យឱវាទដល់ភិក្ខុទាំងឡាយ ទើបពោលគាថា ៣ ថា*

**សទ្ធាយ អភិនិក្ខម្ម នវបព្វជិតោ នវោ**
**មិត្តេ ភជេយ្យ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ ។**

*កុលបុត្តចេញ (ចាកឃរាវាស) ដោយសទ្ធាហើយ បួសថ្មី ជានវភិក្ខុ គប្បីគប់រកកល្យាណមិត្តទាំងឡាយ ដែលជាអ្នកមានការចិញ្ចឹមជីវិតដោយបរិសុទ្ធ អ្នកមិនខ្ជិលច្រអូស ។*

**សទ្ធាយ អភិនិក្ខម្ម នវបព្វជិតោ នវោ**
**សព្ពស្មឹ វិហរំ ភិក្ខុ សិក្ខេថ វិនយំ ពុធោ ។**

*កុលបុត្តចេញ ( ចាកឃរាវាស ) ដោយសទ្ធា បួសថ្មី ជានវភិក្ខុ អ្នកមានប្រាជ្ញា កាលនៅក្នុងពួក គប្បីសិក្សានូវវិន័យ ។*

**សទ្ធាយ អភិនិក្ខម្ម នវបព្វជិតោ នវោ**
**កប្បាកប្បេសុ កុសលោ ចរេយ្យ អបុរក្ខតោ ។**

*កុលបុត្តចេញ ( ចាកឃរាវាស ) ដោយសទ្ធា បួសថ្មី ជានវភិក្ខុ ជាអ្នកឈ្លាសក្នុងហេតុ ដែលគួរនិងមិនគួរទាំងឡាយ គប្បីប្រព្រឹត្តកុំឲ្យ ( ពួកកិលេស មានតណ្ហាជាដើម ) ប្រព្រឹត្តទៅក្នុងខាងមុខបាន[១] ដូច្នេះ ។*

**ព្រះឧបាលិត្ថេរ ចប់[២]**

---

*១-បិ.៥៦ ទំ.២០១ ឃ.១៨១ ។ ២-ស្រង់ចាកវិនយបិដក ថេរគាថា និងអបទាន មួយអន្ទើដោយអដ្ឋកថា ។*

# ខទិរង្គារជាតក

ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធទានរបស់អនាថបិណ្ឌិកសេដ្ឋី ទើបត្រាស់ព្រះធម្មទេសនានេះថា

សេចក្តីពិស្តារថា អនាថបិណ្ឌិកសេដ្ឋីប្រារព្ធចំពោះវិហារប៉ុណ្ណោះ ចំណាយទ្រព្យ ៥៤ កោដិ ក្នុងព្រះពុទ្ធសាសនា មិនបានធ្វើសេចក្តីសម្គាល់ក្នុងវត្ថុដទៃ ថាជារតនៈ ក្រៅអំពីរតនៈទាំង ៣ ឲ្យកើតឡើយ ។ កាលព្រះសាស្តាគង់នៅក្នុងវត្តជេតពន រមែងទៅកាន់ទីបម្រើធំ ៣ ដង រាល់ថ្ងៃ គឺពេលព្រឹកទៅម្តង ទទួលទានអាហារព្រឹកហើយទៅម្តង ពេលល្ងាចទៅម្តង ។ ការបម្រើក្នុងចន្លោះ ៗ (វេលា) ដទៃ ក៏មានដូចគ្នា ។ កាលនឹងទៅ ក៏មិនធ្លាប់មានដៃទទេទៅ ដោយគិតថា សាមណេរឬភិក្ខុកំលោះទាំងឡាយ គប្បីសម្លឹងមើលដៃរបស់អាត្មាអញ ដោយគិតថា លោកសេដ្ឋីកាន់អ្វីមកហ្ន៎ ។ កាលទៅពេលព្រឹក បានឲ្យមនុស្សកាន់យាគូទៅ ទទួលទានអាហារព្រឹកហើយ កាលនឹងទៅ ឲ្យមនុស្សកាន់សប្បិ នវនីត ទឹកឃ្មុំ និងស្ករអំពៅជាដើម ទៅ កាលទៅក្នុងពេលល្ងាច កាន់យកគ្រឿងក្រអូប ផ្កាកម្រង និងសំពត់ទៅ កាលលោកសេដ្ឋីនោះបរិច្ចាគយ៉ាងនេះ រាល់ ៗ ថ្ងៃ ប្រមាណក្នុងការបរិច្ចាគ រមែងមិនមាន ។

ឯអ្នកអាស្រ័យការលក់ដូរចិញ្ចឹមជីវិតជាច្រើន ធ្វើបញ្ជីទុកក្នុងដៃ

របស់លោកសេដ្ឋី ខ្ចីទ្រព្យទៅប្រមាណ ១៨ កោដិ លោកសេដ្ឋីក៏មិនបានទារយកទ្រព្យអំពីបុគ្គលទាំងនោះមក ។ម្យ៉ាងទៀត ទ្រព្យ ១៨ កោដិដទៃទៀត ជាទ្រព្យប្រចាំត្រកូលរបស់សេដ្ឋីនោះ កប់ទុកត្រង់ច្រាំងស្ទឹង កាលច្រាំងត្រូវទឹកស្ទឹងអចិរវតីច្រោះទម្លាយ ទឹកក៏ហូរនាំទៅកាន់មហាសមុទ្ទ ។ ក្អមលោហៈដែលបិទនិងប្រថាប់ត្រានោះ ក៏រមៀលទៅក្នុងមហាសមុទ្ទ ។ ក្នុងផ្ទះរបស់សេដ្ឋីនោះ មាននិច្ចភត្តជាប្រចាំសម្រាប់ភិក្ខុ ៥០០ រូប ពិតហើយ ផ្ទះរបស់សេដ្ឋីដូចគ្នានឹងស្រះបោក្ខរណីដែលជីកក្នុងផ្លូវធំ មានមុម ៤ សម្រាប់ភិក្ខុសង្ឃ តាំងនៅក្នុងឋានៈជាមាតាបិតានៃភិក្ខុទាំងពួង ព្រោះហេតុនោះ ព្រះសម្មាសម្ពុទ្ធ ក៏ទ្រង់យាងទៅកាន់ផ្ទះរបស់សេដ្ឋីនោះ ចំណែកព្រះមហាថេរ ៨០ អង្គ ក៏និមន្តទៅដូចគ្នា ។ ឯភិក្ខុទាំងឡាយដ៏សេស ទៅមក ៗ ប្រមាណមិនបាន ។

ផ្ទះនោះមាន ៧ ជាន់ ប្រដាប់ដោយខ្លោងទ្វារ ៧ មានទេវតាជាមិច្ឆាទិដ្ឋិមួយអង្គ អាស្រ័យត្រង់ខ្លោងទ្វារទី ៤ នៃផ្ទះនោះ ទេវតានោះកាលព្រះសម្មាសម្ពុទ្ធទ្រង់ចូលកាន់ផ្ទះ និងយាងចេញ មិនអាចនៅក្នុងវិមានរបស់ខ្លួនបាន ពទារកចុះមកឈរលើផែនដី កាលព្រះមហាថេរ ៨០ អង្គចូលទៅនិងចេញមក ក៏ធ្វើយ៉ាងនោះដូចគ្នា ។ ទេវតានោះគិតថា កាលព្រះសមណគោតម និងពួកសាវ័ករបស់ព្រះសមណគោតមនោះនៅចេញចូលផ្ទះនេះ ឈ្មោះថា សេចក្តីសុខរបស់អញ មិនមាន អញ

មិនអាចចុះមកឈរលើផែនដីអស់កាលជានិច្ចបាន អញនឹងធ្វើឲ្យសមណៈទាំងនេះ ចូលមកក្នុងផ្ទះនេះ មិនបាន ទើបគួរ ។

ថ្ងៃមួយ ទេវតានោះ ក៏ទៅកាន់សម្នាក់របស់បុគ្គលដែលជាមហាកម្មន្តិកៈ ( អ្នកជំនួយការ ) ដែលកំពុងដេក ហើយបានឈរផ្សាយឱភាស ។ កាលមហាកម្មន្តិកៈសួរថា អ្នកណានេះ ទើបឆ្លើយថា ខ្ញុំជាទេវតាដែលកើតត្រង់ខ្លោងទ្វារទី ៤ ។

មហាកម្មន្តិកៈសួរថា នាងមកព្រោះហេតុអ្វី ។ ទេវតាពោលថា លោកមិនឃើញការធ្វើរបស់លោកសេដ្ឋីទេឬ លោកសេដ្ឋីមិនសម្លឹងមើលកាលខាងក្រោយរបស់ខ្លួន នាំទ្រព្យចេញ បំពេញចំពោះព្រះសមណគោតមប៉ុណ្ណោះ ឲ្យពេញបរិបូណ៌ មិនប្រកបការជួញដូរ មិនផ្តើមធ្វើការងារ ចូរអ្នកឲ្យឱវាទដល់លោកសេដ្ឋី ចូរអ្នកធ្វើដោយប្រការដែលលោកសេដ្ឋីធ្វើការងាររបស់ខ្លួន និងកុំឲ្យព្រះសមណគោតមព្រមទាំងសាវ័ក ចូលមកកាន់ផ្ទះនេះ ។

លំដាប់នោះ មហាកម្មន្តិកៈបានពោលនឹងទេវតានោះថា នែទេវតាពាល លោកសេដ្ឋី កាលលះទ្រព្យ ក៏លះក្នុងព្រះពុទ្ធសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខ លោកសេដ្ឋីនោះ បើនឹងចាប់ខ្ញុំត្រង់ផ្នួងសក់យកទៅលក់ ក៏ខ្ញុំមិនពោលពាក្យណាឡើយ ចូរនាងទៅចុះ ។

ថ្ងៃមួយ ទេវតានោះ ចូលទៅរកបុត្តច្បងរបស់លោកសេដ្ឋី ហើយ

ពោលប្រៀនប្រដៅយ៉ាងនោះ ឯបុត្តសេដ្ឋីក៏គំរាមទេវតានោះ ដោយន័យមុននោះឯង ។ តែទេវតានោះ មិនអាចពោលនឹងលោកសេដ្ឋីបានឡើយ។

ចំណែកលោកសេដ្ឋីបានឲ្យទានមិនដាច់ មិនធ្វើជំនួញ កាលទ្រព្យសម្បត្តិមានតិច ទ្រព្យក៏ដល់នូវការអស់ទៅ ។ កាលសេដ្ឋីនោះ ធ្លាក់ខ្លួនក្រដោយលំដាប់ សំពត់សាដក ទីដេក និងភោជន ដែលជាគ្រឿងបរិភោគប្រើប្រាស់ មិនដូចអំពីមុន ។ តែទោះជាយ៉ាងនេះ លោកសេដ្ឋីក៏នៅតែឲ្យទានដល់ភិក្ខុសង្ឃ តែមិនអាចធ្វើឲ្យប្រណីតហើយឲ្យ ។ ថ្ងៃមួយ ព្រះសាស្ដាត្រាស់សួរសេដ្ឋីនោះ ដែលថ្វាយបង្គំហើយអង្គុយថា នែគហបតី ទានក្នុងត្រកូល អ្នកនៅតែឲ្យឬ ។

សេដ្ឋីនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន នៅតែឲ្យ តែទាននោះ សៅហ្មង ជាបាយចុងអង្ករ មានទឹកជ្រក់ជាគម្រប់ ២ ។

លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងសេដ្ឋីនោះថា ម្នាលគហបតី អ្នកកុំធ្វើចិត្តឲ្យលំបាកថា អញឲ្យទានសៅហ្មងឡើយ ព្រោះថា កាលចិត្តប្រណីត ទានដែលថ្វាយដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវ័កទាំងឡាយរមែងមិនឈ្មោះថា សៅហ្មងឡើយ ។

សួរថា ព្រោះហេតុអ្វី ។

ឆ្លើយថា ព្រោះទាននោះ មានផលច្រើន ។ ក្នុងសេចក្ដីនេះ គួរជ្រាបយ៉ាងនេះ កាលអាចធ្វើចិត្តឲ្យប្រណីត ទានឈ្មោះថា សៅហ្មងមិន

*មានឡើយ ។ សមដូចព្រះតម្រាស់ដែលត្រាស់ទុកថា*

**នត្ថិ ចិត្តេ បសន្នម្ហិ អប្បកា នាម ទក្ខិណា**
**តថាគតេ វា សម្ពុទ្ធេ អថ វា តស្ស សាវកេ ។**

*កាលបើចិត្តជ្រះថ្លា ចំពោះព្រះតថាគតជាសម្ពុទ្ធ ឬសាវ័ករបស់ព្រះតថាគតហើយ ទក្ខិណាទាន ឈ្មោះថា មានផលតិច មិនមែនឡើយ[១] ។*

*និងដូចព្រះតម្រាស់មួយកន្លែងទៀតថា*

**ន ហិរត្ថិ អនោមទស្សីសុ**
**ចារិចរិយា ពុទ្ធេសុ អប្បកា**
**សុក្ខាយ អលោណិកាយ ច**
**បស្ស ផលំ កុម្មាសបិណ្ឌិយា ។**

*បានព្ញថា ការបម្រើព្រះបច្ចេកពុទ្ធទាំងឡាយ ដែលលោកមានពោធិញ្ញាណ មិនថោកថយ មិនមែនមានផលានិសង្សតិចតួចឡើយ អ្នកចូរមើលផលនៃដុំនំកុម្មាសៈដែលសោះកក្រោះ ឥតរសប្រៃ[២] ដូច្នេះ ។*

*ម្យ៉ាងទៀត ព្រះសាស្តាត្រាស់ថា ម្នាលគហបតី អ្នកកាលឲ្យទានសៅហ្មង គង់ឲ្យដល់ព្រះអរិយបុគ្គល ៨ ពួក តថាគតកាលនៅជា*

---

*១-បិ.៥៥ ទំ.១០០ ឃ.៤៧ ។ ២-បិ.៥៩ ទំ.១០៧ ឃ.៤០៥ ។*

វេលាមព្រាហ្មណ៍ ឲ្យរតនៈទាំង ៧ ប្រការ ធ្វើជម្ពូទ្វីបទាំងមូល ឲ្យមាននង្គ័លលើកឡើងហើយ ញ៉ាំងមហាទានឲ្យប្រព្រឹត្តទៅដូចស្ទឹងធំ ៥ ខ្សែ ធ្វើអន្ទង់តែមួយឲ្យពេញ មិនបានបុគ្គលណាម្នាក់ ដែលដល់សរណៈ ៣ ឬរក្សាសីល ៥ បុគ្គលដែលគួរដល់ទក្ខិណា រកបានដោយក្រយ៉ាងនេះ ព្រោះហេតុនោះ អ្នកកុំធ្វើចិត្តឲ្យលំបាកថា ទានរបស់អញសៅហ្មង ។ ព្រះមានព្រះភាគ កាលត្រាស់យ៉ាងនេះហើយ ទើបត្រាស់វេលាមសូត្រ ។

កាលមុនទេវតានោះ មិនអាចពោលជាមួយលោកសេដ្ឋី ក្នុងកាលដែលលោកសេដ្ឋីនៅមានភាពជាធំ សម្គាល់ថា ឥឡូវនេះ សេដ្ឋីនោះ នឹងជឿពាក្យរបស់អញ ព្រោះជាបុគ្គលធ្លាក់ខ្លួនក្រ ។ ក្នុងពេលកណ្ដាលអធ្រាត្រ ទើបចូលទៅកាន់បន្ទប់ដ៏មានសិរី បានផ្សាយពន្លឺ ឈរនៅក្នុងអាកាស សេដ្ឋីឃើញដូច្នោះ ទើបសួរថា នុ៎ះជានរណា ។

ទេវតាឆ្លើយថា លោកសេដ្ឋី ខ្ញុំជាទេវតាស្ថិតនៅត្រង់ខ្លោងទ្វារទី ៤ ។ សេដ្ឋីសួរថា អ្នកមកដើម្បីអ្វី ។

ទេវតាឆ្លើយថា ខ្ញុំបំណងទូន្មានលោក ទើបមក ។ សេដ្ឋីពោលថា បើដូច្នោះ ចូរពោលមកចុះ ។

ទេវតាពោលថា មហាសេដ្ឋី លោកមិនគិតនូវកាលក្រោយ មិនមើលនូវបុត្តធីតា បាចទ្រព្យជាច្រើនក្នុងសាសនារបស់ព្រះសមណគោតម លោកក្លាយជាជនក្រីក្រព្រោះអាស្រ័យព្រះសមណគោតម ដោយលះបង់

ទ្រព្យហួសព្រំដែនផង ដោយការមិនធ្វើការងារ មានជួញដូរជាដើមផង ទោះបីលោកក្លាយជាជនក្រីក្រយ៉ាងនេះ ក៏មិនលះបង់ព្រះសមណ-គោតម សូម្បីរាល់ថ្ងៃនេះ សមណៈទាំងនោះ ក៏នៅតែចូលមកកាន់ផ្ទះដដែល ទ្រព្យដែលពួកសមណៈទាំងនោះនាំចេញទៅហើយ បុគ្គលណាម្នាក់ មិនអាចនាំត្រឡប់មកបានដោយការកាន់យកឡើយ ។ តាំងអំពីនេះទៅ ខ្លួនលោកកុំទៅកាន់សម្នាក់របស់ព្រះសមណគោតម កុំឲ្យសាវ័កទាំងឡាយរបស់ព្រះគោតមនោះ ចូលមកកាន់ផ្ទះនេះ ។ លោក កាលឲ្យព្រះសមណគោតមត្រឡប់ទៅហើយ កុំក្រឡេកមើល ចូរធ្វើនូវការទារបំណុលនិងការជួញដូររបស់ខ្លួន ហើយប្រមូលនូវទ្រព្យសម្បត្តិចុះ ។

លំដាប់នោះ សេដ្ឋីពោលនឹងទេវតានោះ យ៉ាងនេះថា នេះឬជាឱវាទដែលនាងឲ្យខ្ញុំ ។ ទេវតានោះពោលថា ចាស លោកម្ចាស់ ។

លោកសេដ្ឋីពោលថា ខ្ញុំដែលព្រះទសពលធ្វើឲ្យជាបុគ្គលដែលពួកទេវតាដូចអ្នក រាប់រយ រាប់ពាន់ រាប់សែន ធ្វើឲ្យញាប់ញ័រមិនបានសទ្ធារបស់ខ្ញុំមិនញាប់ញ័រ តាំងមាំល្អហើយ ដូចស្តេចភ្នំសិនេរុ ខ្ញុំលះបង់ទ្រព្យក្នុងរតនសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខ នាងពោលពាក្យមិនគួរ នាងមិនមានអាចារៈ ជាបុគ្គលទ្រុស្តសីល ជាកាឡកណ្ណីបែបនេះឲ្យនូវការប្រហារព្រះពុទ្ធសាសនា ខ្ញុំមិនមានកិច្ច គឺការនៅរួមក្នុងផ្ទះជាមួយគ្នានឹងនាងទេ ចូរប្រញាប់ចេញអំពីផ្ទះរបស់ខ្ញុំ ទៅកាន់ទីដទៃចុះ ។

*ទេវតានោះ បានស្តាប់ពាក្យរបស់ព្រះអរិយសាវ័ក ដែលជាព្រះសោតាបន្នបុគ្គល មិនអាចតាំងនៅបាន ទើបទៅកាន់លំនៅរបស់ខ្លួន ហើយយកដៃចាប់ទារកចេញទៅ ។ កាលចេញទៅហើយ មិនបានលំនៅក្នុងទីដទៃ គិតថា នឹងឲ្យសេដ្ឋីអត់ទោស ហើយនៅត្រង់ខ្លោងទ្វារនោះដដែល ទើបទៅកាន់សម្នាក់របស់ទេវបុត្តដែលរក្សានគរ ថ្វាយបង្គំទេវបុត្តនោះ ហើយឈរ ។ កាលទេវបុត្តរក្សានគរសួរថា នាងមកមានការអ្វី ទើបឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំល្ងង់ខ្លៅ មិនបានពិចារណានិយាយនឹងលោកអនាថបិណ្ឌិកសេដ្ឋី សេដ្ឋីនោះក្រោធនឹងខ្ញុំ បណ្តេញខ្ញុំចេញអំពីលំនៅ សូមលោកនាំខ្ញុំទៅកាន់សម្នាក់របស់លោកសេដ្ឋី ឲ្យលោកសេដ្ឋីអត់ទោស ហើយឲ្យលំនៅដល់ខ្ញុំ ។*

*ទេវបុត្តនោះសួរថា នាងនិយាយជាមួយលោកសេដ្ឋីដូចម្តេច ។ ទេវតានោះប្រាប់ថា ខ្ញុំពោលនឹងលោកសេដ្ឋីយ៉ាងនេះថា លោកសេដ្ឋីតាំងអំពីនេះទៅ លោកកុំឧបដ្ឋាកព្រះពុទ្ធនិងព្រះសង្ឃ លោកកុំឲ្យព្រះសមណគោតមចូលក្នុងផ្ទះ ។*

*ទេវបុត្តរក្សានគរពោលថា អើ នាងពោលពាក្យដែលមិនសមគួរ នាងឲ្យនូវការប្រហារក្នុងព្រះសាសនា ខ្ញុំមិនអាចនាំនាងទៅកាន់សម្នាក់របស់លោកសេដ្ឋីបានឡើយ ។ ទេវតានោះ មិនបាននូវការជួយសង្គ្រោះអំពីសម្នាក់របស់ទេវបុត្តនោះ ទើបទៅកាន់សម្នាក់របស់មហារាជទាំងបួន ។*

សូម្បីមហារាជទាំងបួន ក៏បដិសេធយ៉ាងនោះ ទើបចូលទៅគាល់សក្កទេវរាជក្រាបទូលរឿងនោះ ហើយអង្វរថា បពិត្រទេវរាជ ខ្ញុំមិនមានលំនៅ ដឹកដៃទារក ជាបុគ្គលអនាថា ត្រាច់ទៅ សូមទ្រង់ធ្វើឲ្យសេដ្ឋីផ្តល់លំនៅដល់ខ្ញុំ ដោយសិរីរបស់ទ្រង់ ។

សក្កទេវរាជត្រាស់ថា នាងធ្វើកម្មមិនសមគួរ នាងឲ្យនូវការប្រហារក្នុងសាសនារបស់ព្រះជិនស្រី យើងក៏មិនអាចពោលនឹងលោកសេដ្ឋីព្រោះអាស្រ័យនាង តែយើងប្រាប់ឧបាយមួយ ឲ្យសេដ្ឋីនោះ អត់ទោសដល់នាង ។ ទេវតានោះពោលថា សាធុ សូមព្រះអង្គប្រាប់ឧបាយមកចុះ ។

សក្កទេវរាជត្រាស់ថា មនុស្សទាំងឡាយធ្វើបញ្ជីទុកក្នុងដៃរបស់មហាសេដ្ឋី កាន់យកទ្រព្យ ១៨ កោដិ នាងចូរកាឡាខ្លួនជាមនុស្សអ្នកកាន់បញ្ជីរបស់លោកសេដ្ឋីនោះ កុំឲ្យបុគ្គលណាម្នាក់ស្គាល់ កាន់យកបញ្ជីទាំងនោះ មានពួកយក្ខកំលោះៗ ពីរបីរូប ចោមរោម ដៃមួយកាន់បញ្ជី ដៃមួយកាន់ដែកចារ ទៅកាន់ផ្ទះរបស់មនុស្សទាំងនោះ ឈរកណ្តាលផ្ទះ ធ្វើឲ្យមនុស្សទាំងនោះ ខ្លាច ដោយអានុភាពនៃយក្ខរបស់ខ្លួន ហើយពោលថា ពួកអ្នក ចូរមើលបញ្ជីទ្រព្យដែលខ្ចីសេដ្ឋីរបស់ពួកយើង លោកសេដ្ឋីមិនពោលពាក្យណាមួយនឹងពួកអ្នក ក្នុងកាលដែលខ្លួនជាធំ ឥឡូវនេះ សេដ្ឋីធ្លាក់ខ្លួនក្រ ពួកអ្នក ចូរឲ្យកហាបណៈដែលពួកអ្នកចំពាក់ រួចសម្តែងអានុភាពនៃយក្ខរបស់ខ្លួន ហើយទារប្រាក់ ១៨ កោដិ ធ្វើឃ្លាំង

ទទេរបស់មហាសេដ្ឋីឲ្យពេញ ទ្រព្យដែលកប់ត្រង់ច្រាំងស្ទឹងអចិរវតី កាលច្រាំងបាក់ ទឹកក៏នាំទៅកាន់សមុទ្ទ ចូរនាំទ្រព្យនោះមក ដោយអានុភាពរបស់ខ្លួន ហើយធ្វើឃ្លាំងទទេឲ្យពេញ ទ្រព្យមួយកន្លែងទៀត ១៨ កោដិ មិនមានម្ចាស់ ក្នុងទីឈ្មោះនោះ ចូរនាំទ្រព្យនោះមក ធ្វើឃ្លាំងទទេឲ្យពេញ ចូរនាងធ្វើឃ្លាំងទទេ ឲ្យពេញដោយទ្រព្យ ៥៤ កោដិនេះ ឲ្យជាទណ្ឌកម្ម ហើយឲ្យមហាសេដ្ឋីអត់ទោស ។

ទេវតានោះ ទទួលពាក្យរបស់សក្កទេវរាជថា សាធុ ព្រះអង្គ ហើយនាំទ្រព្យមកទាំងអស់ ដោយន័យដូចពោលហើយនុ៎ះឯង ។ ក្នុងវេលាកណ្ដាលយប់ ទើបចូលទៅកាន់បន្ទប់ដ៏មានសិរីរបស់សេដ្ឋី បញ្ចេញពន្លឺឈរក្នុងអាកាស លុះសេដ្ឋីសួរថា នុ៎ះជានរណា ទើបពោលថា មហាសេដ្ឋី ខ្ញុំជាទេវតាអាស្រ័យនៅត្រង់ខ្លោងទ្វារទី ៤ របស់លោក ខ្ញុំជាអ្នកវង្វេង ព្រោះមោហៈធំ មិនស្គាល់គុណព្រះពុទ្ធទាំងឡាយ បានពោលពាក្យណាមួយជាមួយនឹងលោកក្នុងកាលមុន សូមលោកអត់ទោសនោះដល់ខ្ញុំ ។ ខ្ញុំនាំទ្រព្យ ៥៤ កោដិ តាមព្រះតម្រាស់របស់សក្កទេវរាជ គឺទ្រព្យ ១៨ កោដិដោយការទារបំណុល ទ្រព្យ ១៨ កោដិដែលហូរទៅកាន់សមុទ្ទ និងទ្រព្យ ១៨ កោដិដែលមិនមានម្ចាស់ក្នុងទីនោះៗ ធ្វើទណ្ឌកម្ម ដោយធ្វើឃ្លាំងទទេឲ្យពេញ ទ្រព្យដែលដល់នូវការអស់ទៅព្រោះប្រារព្ធការសាងព្រះវិហារ ខ្ញុំបានប្រមូលមកទាំងអស់ ខ្ញុំ កាលមិន

បានលំនៅ រមែងលំបាក បពិត្រលោកសេដ្ឋី លោកកុំដាក់ចិត្តនឹងពាក្យដែលខ្ញុំពោលព្រោះការមិនដឹង សូមអត់ទោស ( ដល់ខ្ញុំ ) ចុះ ។

អនាថបិណ្ឌិកសេដ្ឋីបានស្តាប់ពាក្យរបស់ទេវតានោះហើយ គិតថាទេវតានេះ បានពោលថា ខ្ញុំបានធ្វើទណ្ឌកម្មហើយ និងប្តេជ្ញាព្រមទទួលទោសរបស់ខ្លួន ព្រះសាស្តាទ្រង់នឹងទូន្មានទេវតានេះ ឲ្យស្គាល់គុណរបស់ទ្រង់ អញនឹងបង្ហាញទេវតានេះ ដល់ព្រះសម្មាសម្ពុទ្ធ ។ លំដាប់នោះទើបមហាសេដ្ឋីពោលនឹងទេវតានោះថា នៃទេវតា បើនាងឲ្យខ្ញុំអត់ទោស ចូរឲ្យអត់ទោសក្នុងសម្នាក់ព្រះសាស្តា ។

ទេវតានោះពោលថា សាធុ ខ្ញុំនឹងធ្វើយ៉ាងនោះ ចូរលោកនាំខ្ញុំទៅកាន់សម្នាក់របស់ព្រះសាស្តាចុះ ។

មហាសេដ្ឋីពោលថា សាធុ ។ លុះរាត្រីអស់ហើយ ទើបនាំទេវតានោះ ទៅកាន់សម្នាក់របស់ព្រះសាស្តាអំពីព្រលឹម ហើយក្រាបបង្គំទូលកម្មដែលទេវតានោះធ្វើទាំងអស់ ចំពោះព្រះតថាគត ។ ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់មហាសេដ្ឋីនោះហើយ ទើបត្រាស់ថា ម្នាលគហបតីបុគ្គលបាបក្នុងលោក រមែងឃើញបាបថា ល្អ ដរាបណាដែលបាបមិនទាន់ឲ្យផល កាលណាបាបឲ្យផល កាលនោះ បុគ្គលបាបនោះ រមែងឃើញបាបថា អាក្រក់មែន ឯបុគ្គលល្អ រមែងឃើញកម្មល្អទាំងឡាយថា អាក្រក់ ដរាបណាកម្មល្អមិនទាន់ឲ្យផល ក្នុងកាលណា កម្មល្អឲ្យផល

ក្នុងកាលនោះ បុគ្គលល្អនោះ រមែងឃើញកម្មល្អ ថាល្អពិតមែន ហើយបានត្រាស់ ២ គាថា ក្នុងធម្មបទដូច្នេះថា

**ចាចោបិ បស្សតី ភទ្រំ យាវ ចាបំ ន បច្ចតិ**
**យទា ច បច្ចតី ចាបំ អថ (ចាចោ) ចាចានិ បស្សតិ ។**

*បាបមិនទាន់ឲ្យផលត្រឹមណា មនុស្សបាប ក៏នៅឃើញតែសេចក្ដីចម្រើនត្រឹមណោះ លុះកាលណា បាបឲ្យផល មនុស្សបាប ទើបឃើញបាប ក្នុងកាលនោះ ។*

**ភទ្រោបិ បស្សតី ចាបំ យាវ ភទ្រំ ន បច្ចតិ**
**យទា ច បច្ចតី ភទ្រំ អថ ( ភទ្រោ ) ភទ្រានិ បស្សតិ ។**

*អំពើល្អ មិនទាន់ឲ្យផលត្រឹមណា មនុស្សល្អ នៅឃើញតែបាបត្រឹមណោះ លុះកាលណា អំពើល្អឲ្យផល មនុស្សល្អ ទើបឃើញល្អក្នុងកាលនោះ[១] ។*

*ក្នុងកាលចប់គាថាទាំងនេះ ទេវតានោះ តាំងនៅហើយក្នុងសោតាបត្តិផល ទេវតានោះ ក្រាបចុះត្រង់ព្រះបាទទាំងគូរបស់ព្រះសាស្ដាដែលរំលេចដោយចក្ក ឲ្យព្រះសាស្ដាអត់ទោសថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់ដែលរាគៈជ្រលក់ហើយ ដែលទោសៈប្រទូស្តហើយ វង្វេងហើយដោយមោហៈ ងងឹតព្រោះអវិជ្ជា មិនដឹងគុណទាំងឡាយរបស់ព្រះអង្គ*

---

*១-បិ.៥២ ទំ.៤៧ ឃ.១៩ ។*

បានពោលពាក្យដ៏លាមក សូមទ្រង់អត់នូវទោសក្នុងពាក្យដែលជាទោស នោះ ដល់ខ្ញុំម្ចាស់ ហើយញ៉ាំងមហាសេដ្ឋីឲ្យអត់ទោស ។

សម័យនោះ អនាថបិណ្ឌិកសេដ្ឋីពោលគុណរបស់ខ្លួនក្នុងទីចំពោះព្រះភក្ត្រព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន សូម្បីទេវតានេះ ឃាត់ថា ចូរកុំធ្វើការឧបដ្ឋាកព្រះពុទ្ធជាដើម ក៏មិនអាចហាមខ្ញុំព្រះអង្គបាន ខ្ញុំព្រះអង្គត្រូវទេវតានេះ ហាមថា មិនគួរឲ្យទាន ក៏នៅតែឲ្យ បពិត្រព្រះអង្គដ៏ចម្រើន នេះជាគុណរបស់ខ្ញុំព្រះអង្គ មិនមែនឬ ។

ព្រះសាស្តាត្រាស់ថា ម្នាលគហបតី អ្នកជាអរិយសាវ័ក ជាសោតាបន្នបុគ្គល មានសទ្ធាមិនញាប់ញ័រ មានទស្សនៈបរិសុទ្ធ ការដែលអ្នកត្រូវទេវតាដែលមានសក្តិតូចនេះ ហាមឃាត់ ក៏ឃាត់មិនបាន មិនជាអស្ចារ្យទេ បណ្ឌិតទាំងឡាយក្នុងកាលមុន កាលព្រះពុទ្ធមិនទាន់កើតឡើង តាំងនៅក្នុងញាណដែលមិនទាន់ចាស់ក្លា ត្រូវមារដែលជាធំក្នុងកាមាវចរភពឈរនៅក្នុងអាកាស សម្តែងរណ្តៅរងើកភ្លើងជម្រៅ ៨០ ហត្ថ ដោយពោលថា បើអ្នកនៅតែឲ្យទានសោត អ្នកនឹងឆេះក្នុងរណ្តៅនេះ ហើយឃាត់ថា អ្នកកុំឲ្យទាន ក៏បានឈរកណ្តាលផ្កាឈូកឲ្យទាន នេះទើបអស្ចារ្យ កាលអនាថបិណ្ឌិកសេដ្ឋីក្រាបបង្គំទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរ

ពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសេដ្ឋីក្នុងនគរពារាណសី ដែលញាតិទាំងឡាយឲ្យបម្រើនព្រមដោយគ្រឿងឧបករណ៍ទាំងពួង មានប្រការផ្សេង ៗ ដូចទេវកុមារ ដល់នូវភាពដឹងក្តីដោយលំដាប់ ក្នុងកាលមានអាយុ ១៦ ឆ្នាំប៉ុណ្ណោះ ក៏ដល់នូវការសម្រេចក្នុងសិប្បៈទាំងពួង ។ អំណឹះឥតពីបិតាហើយ ព្រះពោធិសត្វតាំងនៅក្នុងតំណែងសេដ្ឋី បានឲ្យសាងរោងទាន ៦ កន្លែង គឺត្រង់ទ្វារនគរ ៤ កណ្តាលនគរ ១ ត្រង់ទ្វារនិវេសន៍របស់ខ្លួន ១ ហើយឲ្យមហាទាន រក្សាសីល ធ្វើឧបោសថកម្ម ។

សម័យថ្ងៃមួយ ក្នុងវេលាអាហារព្រឹក កាលអ្នកបម្រើនាំយកភោជនដែលជាទីគាប់ចិត្ត មានរសដ៏ប្រសើរផ្សេង ៗ ចូលទៅឲ្យព្រះពោធិសត្វ **ព្រះបច្ចេកពុទ្ធ** មួយអង្គ កាលកន្លងទៅ ៧ ថ្ងៃ បានចេញអំពីនិរោធសមាបត្តិ កំណត់ពេលភិក្ខាចារហើយ គិតថា ថ្ងៃនេះ អាត្មាអញគួរទៅកាន់ទ្វារផ្ទះរបស់សេដ្ឋីពារាណសី ដូច្នេះហើយ ទំពាឈើស្ទន់ឈ្មោះនាគលតា លុបមុខត្រង់អនោតត្តស្រះ ឈរលើផ្ទាំងមនោសិលា ស្លៀកស្បង់ ចងវត្តពន្ធចង្កេះ ឃ្លុំចីវរ កាន់បាត្រដីដែលសម្រេចដោយឫទ្ធិ មកតាមអាកាស ។ លុះអ្នកបម្រើនាំភត្តចូលទៅឲ្យព្រះពោធិសត្វ ក៏បានឈរត្រង់ទ្វារផ្ទះ ព្រះពោធិសត្វឃើញដូច្នោះ ក៏ក្រោកចាកអាសនៈ សម្តែងអាការឱនលំទោន ហើយសម្លឹងមើលបុរសដែលធ្វើការងារ កាលបុរសធ្វើការងារសួរថា **កឹ ករោមិ សាមិ** ខ្ញុំនឹងធ្វើអ្វី លោកម្ចាស់ ទើប

ពោលថា **អយ្យស្ស បត្តំ អាហរថ** ចូរនាំបាត្រលោកម្ចាស់មក ។

រំពេចនោះ មារមានចិត្តបាប ញាប់ញ័រ ក្រោកឡើងហើយ គិតថា ព្រះបច្ចេកពុទ្ធនេះ មិនបានអាហារមក ៧ ថ្ងៃហើយ រាប់អំពីថ្ងៃនេះ ក្នុងថ្ងៃនេះ បើមិនបាន (អាហារ) នឹងវិនាស អញនឹងធ្វើព្រះបច្ចេកពុទ្ធនេះ ឲ្យវិនាស ហើយនឹងធ្វើអន្តរាយដល់ទានរបស់សេដ្ឋី ដូច្នេះហើយ ក៏មកក្នុងខណៈនោះឯង និម្មិតរណ្តៅរងើកភ្លើងជម្រៅ ៨០ ហត្ថ ត្រង់ចន្លោះ ។ រណ្តៅរងើកភ្លើងនោះ ពេញដោយរងើកភ្លើងដើមគគីរ ភ្លើងឆេះ មានពន្លឺប្រាលឆ្អៅ ប្រាកដដូចអវិចីមហានរក ។ មារនោះ កាលនិម្មិតរណ្តៅរងើកភ្លើងនោះហើយ ក៏ឈរក្នុងអាកាស ។ បុរសដែលមកដើម្បីទទួលបាត្រឃើញដូច្នោះ ដល់នូវការខ្លាចក្រៃលែង ទើបត្រឡប់ទៅ ។ ព្រះពោធិសត្វសួរថា នែបា អ្នកនាំបាត្រត្រឡប់មកហើយឬ ។ បុរសនោះឆ្លើយថា បពិត្រលោកម្ចាស់ រណ្តៅរងើកភ្លើងធំនេះ មានពន្លឺប្រាលឆ្អៅ នៅត្រង់ចន្លោះ កាលបើដូច្នោះ មនុស្សដទៃ ៗ ទៅក្តី មកក្តី ដល់នូវការខ្លាច ប្រញាប់គេចទៅដោយរហ័ស ។

ព្រះពោធិសត្វគិតថា ថ្ងៃនេះ វសវត្តីមារ ជាអ្នកខ្វល់ខ្វាយ ប៉ងនឹងធ្វើអន្តរាយដល់ទានរបស់អញ តែវសវត្តីមារនោះ មិនដឹងថា អញដែលបុគ្គលដូចមារ ១ រយក្តី ១ ពាន់ក្តី ១ សែនក្តី ធ្វើឲ្យញាប់ញ័រមិនបាន ថ្ងៃនេះ អញនឹងដឹងថា អញនិងមារ មួយណាមានកម្លាំងជាង

មានអានុភាពជាង ។ លុះគិតដូច្នេះហើយ ទើបកាន់យកថាសកត្ត ដែលគេត្រៀមទុកដើម្បីខ្លួន ចេញអំពីផ្ទះ ទៅឈរត្រង់មាត់រណ្ដៅរងើក ភ្លើង សម្លឹងមើលអាកាស ឃើញមារ ទើបសួរថា អ្នកជានរណា ។ មារ ពោលថា យើងជាមារ ។

ព្រះពោធិសត្វសួរថា រណ្ដៅរងើកភ្លើងនេះ អ្នកនិម្មិតឬ ។ មារ ពោលថា អើ យើងនិម្មិត ។

ព្រះពោធិសត្វសួរថា និម្មិតដើម្បីអ្វី ។ មារពោលថា ដើម្បីធ្វើ អន្តរាយដល់ទានរបស់អ្នក និងដើម្បីឲ្យជីវិតរបស់ព្រះបច្ចេកពុទ្ធវិនាស ។

ព្រះពោធិសត្វពោលថា ខ្ញុំមិនឲ្យអ្នកធ្វើអន្តរាយដល់ទានរបស់ខ្ញុំ និងមិនឲ្យធ្វើអន្តរាយដល់ជីវិតរបស់ព្រះបច្ចេកពុទ្ធ ថ្ងៃនេះ នឹងដឹងថា ខ្ញុំ ឬអ្នក ( បុគ្គលណា ) មានកម្លាំងជាង មានអានុភាពជាង ទើបឈរត្រង់ មាត់រណ្ដៅ ពោលថា បពិត្រព្រះបច្ចេកពុទ្ធដ៏ចម្រើន ទោះបីខ្ញុំមានក្បាល ចុះក្រោម ធ្លាក់ក្នុងរណ្ដៅរងើកភ្លើងនេះ ក៏មិនត្រឡប់ក្រោយ សូមលោក ម្ចាស់ទទួលភោជនដែលខ្ញុំប្រគេនតែម្យ៉ាង ហើយពោលគាថានេះថា

**កាមំ បតាមិ និរយំ ឧទ្ធំបាទោ អវំសិរោ**
**នានរិយំ ករិស្សាមិ ហន្ទ បិណ្ឌំ បដិគ្គហ ។**

តាមពិត ខ្ញុំព្រះអង្គ ស៊ូមានជើងឡើងលើ មានក្បាលចុះ ក្រោម ហើយធ្លាក់ទៅកាន់នរក ខ្ញុំនឹងពុំធ្វើអំពើមិនប្រសើរ

ទេ បើដូច្នោះ សូមព្រះអង្គទទួលនូវចង្ហាន់បិណ្ឌបាតចុះ ។

ក្នុងគាថានោះ មានសេចក្តីដូចតទៅនេះថា បពិត្រព្រះបច្ចេកពុទ្ធដ៏ប្រសើរ បើខ្ញុំប្រគេនបិណ្ឌបាតដល់លោកម្ចាស់ហើយ ទោះបីជាមានក្បាលចុះក្រោម មានជើងឡើងលើ ធ្លាក់ចុះទៅក្នុងរណ្តៅក៏ដោយ បើទុកជាដូច្នេះ ការមិនឲ្យទាន និងការមិនរក្សាសីលឯណា ដែលបណ្ឌិតហៅថា អនរិយៈ ព្រោះអំពើនោះ ដែលពួកជនប្រសើរមិនធ្វើផង ពួកជនមិនប្រសើរធ្វើផង ខ្ញុំនឹងមិនធ្វើនូវការមិនឲ្យទាន និងការមិនរក្សាសីល ដែលហៅថា អនរិយៈនោះឡើយ បើដូច្នោះ សូមនិមន្តលោកម្ចាស់ទទួលដុំបាយដែលខ្ញុំប្រគេននេះចុះ ។

ព្រះពោធិសត្វ លុះពោលយ៉ាងនេះហើយ មានការសមាទានយ៉ាងមាំទាំ កាន់ថាសកត្តដើរលើរណ្តៅរងើកភ្លើង រំពេចនោះឯង ផ្កាឈូកធំមួយ រីកស្គុសស្គាយ ផុសឡើងជាជាន់ ៗ ចេញអំពីរណ្តៅរងើកភ្លើងជម្រៅ ៨០ ហត្ថ ទទួលជើងទាំងពីររបស់ព្រះពោធិសត្វ បន្ទាប់អំពីនោះកេសរមួយនាឡិផ្សាយឡើង តាំងនៅលើសីសៈរបស់ព្រះមហាសត្វ ហើយជ្រុះចុះមក ធ្វើសរីរៈទាំងមូលដូចរោយដោយលម្អងមាស ព្រះពោធិសត្វឈរលើផ្កាឈូក ញ៉ាំងភោជនមានរសប្រសើរផ្សេង ៗ ឲ្យប្រតិស្ឋានក្នុងបាត្ររបស់ព្រះបច្ចេកពុទ្ធ ។ ព្រះបច្ចេកពុទ្ធទទួលភោជននោះហើយ ធ្វើអនុមោទនា បោះបាត្រទៅក្នុងអាកាស ។ កាលមហាជនកំពុងឃើញ

នុ៎ះឯង ក៏ហោះឡើងកាន់អាកាស ដូចជាន់ពពក មានប្រការផ្សេង ៗ ទៅកាន់ព្រៃហិមពាន្តនុ៎ះឯង ។ ចំណែកមារចាញ់ហើយ ក៏ដល់នូវទោមនស្ស ទៅកាន់លំនៅរបស់ខ្លួននុ៎ះឯង ។ ព្រះពោធិសត្វឈរលើផ្កាឈូក សម្តែងធម៌ដល់មហាជន ដោយពណ៌នាដល់ទាននិងសីល ដែលមហាជនចោមរោម ចូលទៅកាន់និវេសន៍របស់ខ្លួន ធ្វើបុណ្យទាំងឡាយមានទានជាដើម ដរាបដល់អស់ជីវិត ហើយទៅតាមយថាកម្ម ។

ព្រះសាស្តាត្រាស់ថា ម្នាលគហបតី ការដែលអ្នកសម្បូរដោយទស្សនៈយ៉ាងនេះ ដែលទេវតាឲ្យញាប់ញ័រមិនបាន ក្នុងកាលឥឡូវនេះ មិនជាអស្ចារ្យទេ វត្ថុដែលបណ្ឌិតទាំងឡាយបានធ្វើក្នុងកាលមុនប៉ុណ្ណោះ ទើបអស្ចារ្យ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទើបទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា ព្រះបច្ចេកពុទ្ធក្នុងកាលនោះ បរិនិព្វានហើយក្នុងទីនោះឯង ចំណែកពារាណសីសេដ្ឋីធ្វើមារឲ្យចាញ់ ឈរលើផ្កាឈូក ហើយថ្វាយបិណ្ឌបាតដល់ព្រះបច្ចេកពុទ្ធ ក្នុងកាលនោះ គឺតថាគតនេះឯង ។

## ខទិរង្គារជាតក ចប់ [១]

១-ស្រង់ចាកអដ្ឋកថា ជាតក ឯកនិបាត បិ.៥៨ ទំ.១៨ ឃ.៤០ ។

# មហាជនកជាតក

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមហាភិនេក្ខម្ម-បារមី ទើបត្រាស់ព្រះធម្មទេសនានេះថា

សេចក្ដីពិស្ដារថា ថ្ងៃមួយ ភិក្ខុទាំងឡាយអង្គុយពណ៌នាមហាភិ-នេក្ខម្មបារមីរបស់ព្រះតថាគតក្នុងធម្មសភា ។ ព្រះសាស្ដាស្ដេចយាង មក ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នក ទាំងឡាយអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ។ កាលភិក្ខុទាំងនោះ ក្រាប បង្គំទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះ ប៉ុណ្ណោះទេ ដែលតថាគតចេញស្វែងរកគុណធំ សូម្បីក្នុងកាលមុន កាល ជាពោធិសត្វ តថាគតក៏ចេញស្វែងរកគុណធំដូចគ្នា ដូច្នេះហើយ ទ្រង់ ព្រះតុណ្ហីភាព កាលភិក្ខុទាំងនោះ ក្រាបបង្គំទូលអារាធនាឲ្យទ្រង់សម្ដែង ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះរាជាព្រះនាមមហាជនក គ្រង់រាជសម្បត្តិក្នុង នគរមិថិលា ដែនវិទេហៈ ។ ព្រះបាទមហាជនកនោះ មានព្រះរាជឱរស ពីរព្រះអង្គ គឺអរិដ្ឋជនកមួយអង្គ បោលជនកមួយអង្គ បណ្ដាក្សត្រទាំង ពីរអង្គនោះ ព្រះរាជាព្រះរាជទានតំណែងឧបរាជដល់ព្រះរាជឱរសច្បង

ព្រះរាជទានតំណែងសេនាបតីដល់ព្រះរាជឱរសប្អូន ។ ក្នុងកាលតមក ព្រះបាទមហាជនកទ្រង់សោយទិវង្គត ។ កាលថ្វាយព្រះភ្លើងព្រះបរមសពស្រេចហើយ ព្រះអរិដ្ឋជនកក៏បានគ្រងរាជសម្បត្តិ ទ្រង់តាំងព្រះបោលជនកដែលជាព្រះកនិដ្ឋភាតាជាឧបរាជ ។ អាមាត្យម្នាក់ដែលជាអ្នកជិតស្និទ្ធនឹងព្រះរាជា ចូលគាល់ព្រះរាជាក្រាបទូលថា **ទេវ ឧបរាជា តុម្ហេ ឃាតេតុកាមោ** បពិត្រព្រះសម្មតិទេព ព្រះឧបរាជប្រាថ្នានឹងផ្តាច់ព្រះជន្មព្រះអង្គ ។ ព្រះបាទអរិដ្ឋជនកទ្រង់ស្តាប់ពាក្យនោះរឿយ ៗ ក៏ទម្លាយសេចក្តីស្នេហាក្នុងព្រះអនុជ ធ្វើព្រះបោលជនកមហាឧបរាជដោយចំណង ឃុំទុកក្នុងទីមួយកន្លែង ក្នុងព្រះរាជដំណាក់មួយខ្នងក្បែរព្រះរាជនិវេសន៍ មានអ្នកយាមរក្សា ។

បោលជនកកុមារតាំងសច្ចាធិដ្ឋានថា **សចាហំ ភាតុ វេរី្ហិ** បើខ្ញុំបង្កពៀរចំពោះព្រះជេដ្ឋា **សង្ខលិកាបិ មេ ហត្ថបាទា មា មុច្ចន្តុ** ចំណងកុំបីរបូតអំពីដៃនិងជើងរបស់ខ្ញុំឡើយ **ទ្វារម្បិ មា វិវរីយតុ** សូម្បីទ្វារក៏កុំបីរបើក **សចេ នោ វេរី្ហិ** បើខ្ញុំមិនបានបង្កនូវពៀរវេរា (ចំពោះព្រះជេដ្ឋាទេ) **សង្ខលិកាបិ មេ ហត្ថបាទា មុច្ចន្តុ** ចំណង ចូររបូតអំពីដៃនិងជើងរបស់ខ្ញុំ **ទ្វារម្បិ វិវរីយតុ** សូម្បីទ្វារក៏ចូររបើក ។ គ្រឿងចង ក៏បាក់ជាកំណាត់ៗ ទ្វារក៏របើក ព្រះបោលជនកក៏យាងចេញទៅកាន់បច្ចន្តគ្រាមមួយកន្លែង ប្រថាប់នៅត្រង់បច្ចន្តគ្រាមនោះ ។

អ្នកបច្ចន្តគ្រាមចំណាំទ្រង់បាន ក៏ទំនុកបម្រុង ។ ក្នុងកាលនោះ ព្រះបាទអរិដ្ឋជនកមិនអាចចាប់ព្រះបោលជនកបាន ។ ព្រះបោលជនកនោះ បានធ្វើអ្នកបច្ចន្តជនបទឲ្យនៅក្នុងអំណាចដោយលំដាប់ ជាអ្នកមានបរិវារច្រើន ទ្រង់គិតថា កាលមុន យើងមិនបានបង្កនូវពៀរវេរាចំពោះព្រះជេដ្ឋារបស់យើង តែឥឡូវនេះ យើងនឹងបង្កពៀរ ចោមរោមដោយមហាជន ចេញអំពីបច្ចន្តគ្រាមដល់ក្រុងមិថិលាដោយលំដាប់ ឲ្យបោះជំរំទ័ពខាងក្រៅព្រះនគរ ។ កាលនោះ ពួកទាហានអ្នកនគរមិថិលា ដឹងថា ព្រះរាជកុមារបោលជនកយាងមក ដោយច្រើន ក៏ជញ្ជូនពាហនៈ មានសេះ ដំរី ជាដើម មកកាន់សម្នាក់របស់ព្រះបោលជនកនោះ ។ សូម្បីអ្នកនគរដទៃ ៗ ក៏មកផងដែរ ។

ព្រះបោលជនកបញ្ជូនសាសន៍ទៅថ្វាយព្រះរាជជេដ្ឋាថា ក្នុងកាលមុន ខ្ញុំមិនបានបង្កពៀរជាមួយទ្រង់ តែឥឡូវនេះ ខ្ញុំនឹងបង្កពៀរ ទ្រង់ប្រគល់ស្វេតច្ឆត្រ ( រាជ្យ ) ដល់ខ្ញុំ ឬក៏ច្បាំងគ្នា ។

ព្រះបាទអរិដ្ឋជនករាជទ្រង់បានស្តាប់ដូច្នោះ ប្រាថ្នានឹងច្បាំង ទើបត្រាស់ហៅអគ្គមហេសីមក ប្រាប់ថា នៃនាងដ៏ចម្រើន ជម្នះការច្បាំងឈ្នះឬចាញ់ មិនអាចដឹងបានទេ បើយើងមានអន្តរាយ នាងគប្បីរក្សាគភ៌ឲ្យល្អ ដូច្នេះហើយ ទ្រង់ចោមរោមដោយសេនាជាច្រើន ចេញអំពីនគរ ។

លំដាប់នោះ ទាហានរបស់ព្រះបោលជនក ញុំាងព្រះបាទអរិដ្ឋ-

ជនកឲ្យសោយទិវង្គតក្នុងទីលានចម្បាំង ។ អ្នកនគរដឹងថា ព្រះរាជាសោយទិវង្គតហើយ ក៏កើតកោលាហលទូទៅ ។ ឯព្រះទេវីដឹងថា ព្រះរាជស្វាមីសោយទិវង្គតហើយ ក៏ប្រញាប់ដាក់របស់ដែលមានតម្លៃ មានមាសជាដើម ក្នុងល្អី យកសំពត់ចាស់ៗ បិទបាំង ហើយដាក់អង្ករខាងលើ ដណ្ដប់សំពត់ចាស់សៅហ្មង គៀសខ្លួនចេញទៅ ដាក់ល្អីលើក្បាលចេញអំពីនគរក្នុងថ្ងៃនុ៎ះឯង មិនមានអ្នកណាស្គាល់ព្រះនាងឡើយ ។ ព្រះនាងចេញតាមទ្វារទិសខាងជើង មិនស្គាល់ផ្លូវ ព្រោះមិនធ្លាប់ទៅកាន់ទីណាមួយ មិនអាចកំណត់ទិស ទើបប្រថាប់គង់ត្រង់សាលាមួយកន្លែង រង់ចាំសួរថា មានអ្នកណាទៅកាន់នគរកាលចម្បាដែរឬទេ ព្រោះព្រះនាងធ្លាប់ឮថា មានអ្នកធ្វើដំណើរទៅកាន់នគរឈ្មោះកាលចម្បា ។ ចំណែកសត្វដែលបដិសន្ធិក្នុងព្រះឧទររបស់ព្រះទេវីនោះ មិនមែនជាសត្វសាមញ្ញ គឺជាព្រះមហាសត្វដែលមានបារមីបានបំពេញហើយ មកកើត ។

ដោយតេជះនៃព្រះមហាសត្វនោះ បណ្ដាលឲ្យសក្កពិភពកម្រើកញាប់ញ័រ ។ សក្កទេវរាជទ្រង់ពិចារណា ក៏ជ្រាបហេតុនោះ ទើបព្រះតម្រិះថា សត្វដែលកើតក្នុងព្រះឧទររបស់ព្រះទេវីនេះ មានបុណ្យច្រើន អញគួរទៅក្នុងទីនោះ ទើបនិម្មិតរថមានគ្រឿងបិទបាំង រៀបចំគ្រែក្នុងរថនោះ កាឡាខ្លួនជាមនុស្សចាស់ បររថទៅឈប់ត្រង់ទ្វារសាលាដែលព្រះទេវីប្រថាប់គង់ ហើយសួរថា មានអ្នកណាចង់ទៅនគរកាលចម្បាដែរឬ

ទេ ។ ព្រះទេវីបានស្តាប់ដូច្នោះ ទើបត្រាស់ថា លោកឪពុក ខ្ញុំនឹងទៅ ។

សក្កទេវរាជត្រាស់ថា ម្នាលកូនស្រី បើដូច្នោះ ចូរនាងឡើងអង្គុយលើរទេះ ។ ព្រះទេវីត្រាស់ថា បពិត្រលោកឪពុក ខ្ញុំមានគភ៌ចាស់ខែ មិនអាចឡើងរទេះបានទេ ខ្ញុំសូមដើរតាមក្រោយ ៗ លោកឪពុកទៅប៉ុណ្ណោះ តែសូមលោកឪពុកជួយទទួលល្អីរបស់ខ្ញុំនេះ ដាក់លើរទេះផង ។

សក្កទេវរាជត្រាស់ថា នែកូនស្រី នាងនិយាយអ្វី បុគ្គលដែលមានសមត្ថភាពបេះបររទេះដូចខ្ញុំ មិនមានទេ នាងកុំខ្លាចឡើយ ចូរឡើងអង្គុយលើរទេះចុះ ។ ព្រះនាងពោលថា សាធុ លោកឪពុក ដោយអានុភាពនៃព្រះឱរសរបស់ព្រះនាង កាលដែលព្រះទេវីឡើងរទេះ ផែនដីក៏ទុលឡើង ដូចពេញដោយខ្យល់ ទល់គ្នានឹងទូករទេះ ព្រះទេវីឡើងផ្ទំលើសិរីសេយ្យាសនៈ ព្រះនាងជ្រាបបានថា នេះជាទេវតា ។ គ្រាន់តែគិតប៉ុណ្ណោះ ព្រះនាងក៏លង់លក់ ព្រោះបានទីបន្ទំដែលជាទិព្វ ។

ក្នុងកាលនោះ សក្កទេវរាជទ្រង់បររថដល់ស្ទឹងមួយកន្លែង ដែលមានចម្ងាយ ៣០ យោជន៍ ទើបដាស់ព្រះទេវី ហើយត្រាស់ថា នែកូនស្រី ចូរនាងចុះអំពីរទេះ ផ្ងូតទឹកក្នុងស្ទឹង ចូរស្មៀកដណ្តប់សំពត់មួយគូដែលនៅលើក្បាលដំណេកនោះ នៅក្នុងរទេះមានកញ្ចប់កត្ត ចូរនាងបរិភោគចុះ ។ ព្រះទេវីធ្វើតាមយ៉ាងនោះ ហើយក៏ផ្ទំបន្តទៀត លុះដល់នគរ

កាលចម្បា ជួនជាពេលល្ងាច ព្រះនាងទតឃើញទ្វារត្រង់សំយាបកំពែងនគរ ទើបសួរសក្កទេវរាជថា បពិត្រលោកឪពុក នគរនេះ ឈ្មោះអ្វី ។ សក្កទេវរាជឆ្លើយថា នគរនេះ ឈ្មោះកាលចម្បា កូនស្រី ។

ព្រះទេវីពោលថា លោកឪពុកនិយាយអ្វី នគរកាលចម្បានៅឆ្ងាយអំពីនគររបស់ពួកយើងដល់ទៅ ៦០ យោជន៍ មិនមែនឬ ។ សក្កទេវរាជត្រាស់ថា យ៉ាងនោះហើយនាង តែខ្ញុំស្គាល់ផ្លូវត្រង់ ។ លំដាប់នោះ សក្កទេវរាជឲ្យព្រះទេវីចុះអំពីរទេះ ក្នុងទីក្បែរទ្វារទិសទក្សិណ ហើយប្រាប់ថា នែនាង ផ្ទះរបស់យើងនៅស្រុកខាងមុខ ចូរនាងចូលទៅកាន់នគរនេះ ដូច្នេះហើយ យាងទៅ ដូចទៅខាងមុខ ហើយក៏អន្តរធាន ទៅកាន់ទីប្រថាប់របស់ព្រះអង្គ ។

ចំណែកព្រះទេវីព្រះនាងប្រថាប់គង់ត្រង់សាលាមួយកន្លែង ។ ក្នុងខណៈនោះ មានព្រាហ្មណ៍អ្នករាយមន្តម្នាក់ ជាអ្នកស្រុកកាលចម្បា ជាអាចារ្យទិសាបាមោក្ខ មានមាណព ៥០០ ចោមរោម ដើរទៅដើម្បីងូតទឹក សម្លឹងមើលអំពីចម្ងាយ ឃើញព្រះទេវីមានព្រះរូបល្អក្រៃលែង សម្បូរដោយលម្អដ៏លើស ប្រថាប់គង់ក្នុងសាលានោះ ដោយអានុភាពនៃព្រះមហាសត្វដែលកើតក្នុងព្រះឧទររបស់ព្រះទេវី គ្រាន់តែឃើញប៉ុណ្ណោះ ក៏កើតនូវសេចក្ដីស្រឡាញ់ដូចជាប្អូនស្រីរបស់ខ្លួន ទើបឲ្យពួកមាណពឈរចាំខាងក្រៅ ចូលទៅក្នុងសាលាតែម្នាក់ឯង សួរថា នែប្អូនស្រី នាង

ជាអ្នកស្រុកណា ។

ព្រះទេវីឆ្លើយថា បពិត្របងប្រុស ខ្ញុំជាអគ្គមហេសីរបស់ព្រះបាទអរិដ្ឋជនក នគរមិថិលា ។ ព្រាហ្មណ៍សួរថា ម្នាលប្អូនស្រី ព្រោះហេតុអ្វី ទើបនាងមកទីនេះ ។

ព្រះទេវីឆ្លើយថា បពិត្របងប្រុស ព្រះបាទអរិដ្ឋជនកត្រូវព្រះបោលជនកផ្ដាច់ព្រះជន្ម កាលបើយ៉ាងនេះ ខ្ញុំខ្លាច ទើបគេចមក ដោយគិតថា នឹងរក្សាគភ៌ ។ ព្រាហ្មណ៍សួរថា ម្នាលប្អូនស្រី ក្នុងនគរនេះ មានអ្នកណាជាញាតិផៅរបស់នាងដែរឬទេ ។

ព្រះទេវីឆ្លើយថា មិនមានទេ បងប្រុស ។ ព្រាហ្មណ៍ពោលថា បើដូច្នោះ នាងកុំគិតថ្វីឡើយ ខ្ញុំជាឧទិច្ចព្រាហ្មណមហាសាល ជាអាចារ្យទិសាបាមោក្ខ ខ្ញុំនឹងតាំងនាងទុកជាប្អូនស្រី បដិបត្តិមើលថែនាង ចូរនាងហៅខ្ញុំថា បងប្រុស ហើយចាប់ត្រង់ជើងទាំងពីររបស់ខ្ញុំ យំចុះ ។

ព្រះទេវីចាប់ត្រង់ជើងទាំងពីររបស់ព្រាហ្មណ៍នោះ ហើយស្រែកយំដោយសំឡេងខ្លាំង ជនទាំងពីរយំខ្សឹកខ្សួលដល់គ្នានឹងគ្នា ។ ក្នុងកាលនោះ ពួកអន្តេវាសិកបានឮសំឡេងរបស់ព្រាហ្មណ៍ ទើបនាំគ្នាស្ទុះចូលទៅកាន់សាលា សួរថា បពិត្រលោកអាចារ្យ តើមានរឿងអ្វី ។

ព្រាហ្មណ៍ពោលថា នាងជាប្អូនស្រីរបស់ខ្ញុំ ព្រាត់អំពីខ្ញុំយូរហើយ ។ លំដាប់នោះ ពួកអន្តេវាសិកពោលថា បពិត្រលោកអាចារ្យ ចាប់តាំងអំពី

កាលដែលលោកទាំងពីរបានចួបគ្នាហើយ កុំវិតក្កៈឡើយ ។

ព្រាហ្មណ៍ឲ្យនាំយានដែលបិទបាំងមក ឲ្យព្រះទេវីប្រថាប់គង់ក្នុងយាននោះ ពោលនឹងពួកមាណពថា នែបាទាំងឡាយ ចូរប្រាប់ព្រាហ្មណីថា នាងជាប្អូនស្រីរបស់ខ្ញុំ ហើយចូរប្រាប់ព្រាហ្មណីឲ្យធ្វើកិច្ចទាំងពួងដល់នាង ហើយក៏បញ្ជូនព្រះទេវីទៅកាន់ផ្ទះ ។ លំដាប់នោះ ព្រាហ្មណីឲ្យព្រះនាងស្រង់ទឹកក្តៅ ហើយរៀបចំទីបន្ទំឲ្យផ្ទំ ព្រាហ្មណ៍ងូតទឹកហើយក៏ត្រឡប់មកកាន់ផ្ទះ ឲ្យអញ្ជើញព្រះនាងមកក្នុងវេលាបរិភោគអាហារដោយពាក្យថា ចូរអញ្ជើញប្អូនស្រីរបស់យើងមក ហើយបរិភោគរួមគ្នាជាមួយព្រះនាង បានថែទាំព្រះនាងក្នុងនិវេសន៍របស់ខ្លួននោះឯង ។

មិនយូរប៉ុន្មាន ព្រះនាងក៏ប្រសូតព្រះឱរសមានពណ៌ដូចមាស ព្រះទេវីក៏ថ្វាយព្រះនាមព្រះរាជបុត្ត ដូចព្រះនាមព្រះអយ្យកោថា មហាជនកកុមារ ។ ព្រះរាជកុមារនោះ ទ្រង់ចម្រើនវ័យ ក៏លេងជាមួយពួកក្មេង ៗ ពួកក្មេងណាធាធៅឲ្យព្រះរាជកុមារក្រោធ ព្រះរាជកុមារក៏ចាប់ក្មេងទាំងនោះយ៉ាងមាំហើយវាយ ព្រោះទ្រង់មានកម្លាំងច្រើនផង មានសេចក្តីរឹងត្អឹងព្រោះមានះផង ព្រោះទ្រង់កើតក្នុងត្រកូលក្សត្រដែលមិនលាយឡំដោយពូជពង្សដទៃ ពួកក្មេងទាំងនោះ ក៏ស្រែកយំដោយសំឡេងខ្លាំង កាលត្រូវសួរថា អ្នកណាវាយពួកឯង ក៏ប្រាប់ថា កូនស្រីមេម៉ាយ វាយពួកខ្ញុំ ។

ព្រះរាជកុមារទ្រង់ព្រះតម្រិះថា ពួកក្មេងទាំងនេះ ពោលថាអញ

ជាកូនស្រីមេម៉ាយរឿយ ៗ ណ្ហើយចុះ អញនឹងសួរមាតារបស់អញ ។ ថ្ងៃមួយ ព្រះរាជកុមារទូលសួរព្រះរាជមាតាថា បពិត្រអ្នកម៉ែ អ្នកណាជាឪពុករបស់ខ្ញុំ ។ លំដាប់នោះ ព្រះទេវីលួងលោមព្រះរាជកុមារថា ម្នាលបា ព្រាហ្មណ៍ជាឪពុករបស់កូន ។

ស្អែកឡើង ព្រះរាជកុមារក៏វាយក្មេងទាំងឡាយទៀត ពួកក្មេងទាំងនោះ ក៏ពោលថា កូនស្រីមេម៉ាយ ។ ព្រះរាជកុមារត្រាស់ថា ព្រាហ្មណ៍ជាឪពុករបស់យើង មិនមែនឬ ។

កាលពួកក្មេងសួរថា ព្រាហ្មណ៍ជាអ្វីនឹងឯង ទើបទ្រង់ព្រះតម្រិះថា ក្មេងទាំងនេះពោលថា ព្រាហ្មណ៍ជាអ្វីនឹងឯង រឿយ ៗ មាតារបស់អញមិនប្រាប់ហេតុការណ៍នេះ តាមសេចក្ដីពិត មាតាមិនប្រាប់ដល់អញតាមចិត្តរបស់ខ្លួន លើកទុកចុះ អញនឹងឲ្យមាតាប្រាប់ឲ្យខាងតែបាន ។

កាលព្រះរាជកុមារបៅដោះរបស់ព្រះមាតា ទើបខាំដោះរបស់មាតាហើយពោលថា បពិត្រអ្នកម៉ែ សូមម៉ែប្រាប់លោកឪពុកដល់ខ្ញុំ បើម៉ែមិនប្រាប់ ខ្ញុំនឹងខាំដោះម៉ែឲ្យដាច់ ។

ព្រះនាងមិនអាចបញ្ឆោតព្រះឱរសបាន ទើបប្រាប់ថា នែបា បាជាបុត្តរបស់ព្រះបាទអរិដ្ឋជនក ក្នុងនគរមិថិលា បិតារបស់បាត្រូវព្រះបាទបោលជនកផ្ដាច់ព្រះជន្ម មាតាតាំងចិត្តរក្សាបុត្ត ទើបមកកាន់នគរនេះ ព្រាហ្មណ៍នេះ ទុកម៉ែជាប្អូនស្រី ហើយចិញ្ចឹមថែទាំ ។ តាំងពីនោះមក

សូម្បីអ្នកណាពោលថា ជាកូនស្រីមេម៉ាយ ក៏ព្រះរាជកុមារមិនខឹង ។

ព្រះរាជកុមាររៀនចប់ត្រៃវេទ និងសិប្បៈទាំងពួង ក្នុងរវាងព្រះជន្ម ១៦ ឆ្នាំ ។ កាលព្រះជន្មបាន ១៦ ឆ្នាំ ជាអ្នកទ្រទ្រង់នូវព្រះរូបឆោមលោមពណ៌ដ៏ឧត្តម ទ្រង់គិតថា អញនឹងយករាជសម្បត្តិដែលជារបស់បិតា ទើបទូលសួរព្រះមាតាថា បពិត្រអ្នកម៉ែ អ្នកម៉ែមានទ្រព្យខ្លះដែរឬទេ ខ្ញុំនឹងធ្វើការជួញដូរ ឲ្យទ្រព្យកើតឡើងហើយ នឹងយករាជសម្បត្តិដែលជារបស់ព្រះបិតា ។

ព្រះនាងត្រាស់តបថា នែកូន ម៉ែមិនបានមកដៃទទេ វត្ថុដែលជាសារៈរបស់យើង មាន ៣ យ៉ាង គឺកែវមុក្តា កែវមណី និងកែវវជីរ បណ្តាវត្ថុ ៣ យ៉ាងនោះ វត្ថុនីមួយ ៗ ល្មមចំណាយដើម្បីយករាជសម្បត្តិបាន ចូរបា ទទួលកែវទាំង ៣ យ៉ាងនោះ ហើយរកឧបាយយករាជសម្បត្តិចុះ កុំធ្វើការជួញដូរឡើយ ។

ព្រះរាជកុមារក្រាបទូលថា បពិត្រអ្នកម៉ែ សូមអ្នកម៉ែប្រទានទ្រព្យនោះ ពាក់កណ្តាលដល់ខ្ញុំ ខ្ញុំនឹងយកទៅកាន់សុវណ្ណភូមិ នាំទ្រព្យជាច្រើនមក ហើយយករាជសម្បត្តិដែលជារបស់បិតា ដូច្នេះហើយ ឲ្យព្រះមាតាប្រទានទ្រព្យពាក់កណ្តាល ចំណាយជាមុខទំនិញ ដើម្បីឡើងសំពៅមួយអន្ទើដោយពួកពាណិជ ធ្វើដំណើរទៅកាន់សុវណ្ណភូមិ ហើយត្រឡប់ទៅថ្វាយបង្គំលាព្រះមាតាថា បពិត្រអ្នកម៉ែ ខ្ញុំនឹងទៅកាន់សុវណ្ណភូមិ ។

លំដាប់នោះ ព្រះនាងត្រាស់ឃាត់ថា នែបា ឈ្មោះថា សមុទ្ទ សម្រេចប្រយោជន៍តិចតួច មានអន្តរាយច្រើន កូនកុំទៅឡើយ ទ្រព្យរបស់កូនមានច្រើន ល្មមសម្រេចប្រយោជន៍យករាជសម្បត្តិហើយ ។ ព្រះរាជកុមារក្រាបទូលថា បពិត្រអ្នកម៉ែ ខ្ញុំនឹងទៅ ថ្វាយបង្គំព្រះមាតាចេញពីផ្ទះហើយ ឡើងសំពៅទៅ ។

ក្នុងថ្ងៃនោះ រោគកើតឡើងក្នុងព្រះសរីរៈរបស់ព្រះបាទបោលជនកផ្ទំហើយ ទ្រង់ក្រោកមិនរួច ។ ក្នុងកាលនោះ ពួកពាណិជប្រមាណ ៧០០ ឡើងកាន់សំពៅ ។ សំពៅស្ទុះទៅបាន ៧០០ យោជន៍ ក្នុងវេលា ៧ ថ្ងៃ ។ សំពៅស្ទុះទៅ ដោយកម្លាំងរលកដ៏ខ្លាំងក្លា មិនអាចទ្រទ្រង់ខ្លួនបាន បន្ទះក្ដារក៏បែកដោយកម្លាំងរលក ទឹកចូលមកអំពីទីនោះ ៗ សំពៅក៏លិចក្នុងកណ្ដាលសមុទ្ទ មហាជនស្រែកទ្រហោយំ ថ្វាយបង្គំទេវតាទាំងឡាយ ។ តែព្រះមហាសត្វទ្រង់មិនសោយសោកឡើយ ទ្រង់មិនកន្ទក់កន្ទេញ មិនថ្វាយបង្គំទេវតាទាំងឡាយ ទ្រង់ជ្រាបថា សំពៅនឹងលិច ទើបបរិភោគស្ករនិងសប្បិ រហូតពេញពោះ ហើយជ្រលក់សំពត់សាច់រលីងស្អាតពីរផ្ទាំង ដោយប្រេងឲ្យសើម ទ្រង់ស្លៀកសំពត់យ៉ាងខ្ជាប់ខ្ជួន ឈរត្រង់សសរក្ដោង ក្នុងវេលាដែលសំពៅលិច ទ្រង់ឡើងលើចុងសសរក្ដោង ។ មហាជនបានជាចំណីរបស់ត្រីនិងអណ្ដើក ។ ទឹកកន្ទុះឧសភៈដោយជុំវិញ មានពណ៌ដូចឈាម ព្រះមហាសត្វឈរត្រង់

ចុងសសរក្តោង ទ្រង់កំណត់ទិសថា នគរមិថិលានៅក្នុងទិសនេះ ក៏លោត អំពីចុងសសរក្តោង រំលងផុតហ្វូងត្រីនិងអណ្តើក ទៅធ្លាក់ក្នុងទីបំផុត ១ ឧសភៈ ព្រោះទ្រង់មានកម្លាំងច្រើន ។ ឯព្រះបាទបោលជនកក៏សោយ ទិវង្គតក្នុងថ្ងៃនោះ ដូចគ្នា ។ ចាប់តាំងអំពីនោះ ព្រះមហាសត្វអណ្តែត ទៅនៅក្នុងរលកដែលមានពណ៌ដូចកែវមណី ដូចកំណាត់ដើមចេកមាស ហែលឆ្លងសមុទ្ទ ( ដោយកម្លាំងដើមដៃ ) ។ ព្រះមហាសត្វទ្រង់ហែល ឆ្លងសមុទ្ទអស់ ៧ ថ្ងៃ ដូចហែលឆ្លងមួយថ្ងៃ ។ ព្រះមហាសត្វសង្កេត ពេលវេលាថា ថ្ងៃនេះ ជាថ្ងៃ ១៥ កើត ទើបខ្ពុរព្រះឱស្ឋដោយទឹកប្រៃ ទ្រង់សមាទានឧបោសថសីល ។

ក្នុងកាលនោះ ស្តេចចតុលោកបាល ប្រគល់ឲ្យទេពធីតាឈ្មោះ មណិមេខលាជាអ្នកថែរក្សាសមុទ្ទថា ចូរនាងស្រង់សត្វទាំងឡាយ ដែល ប្រកបដោយគុណ មានបម្រើមាតាជាដើម ជាអ្នកមិនសមគួរនឹងស្លាប់ ក្នុងសមុទ្ទ ។ នាងមណិមេខលាមិនបានពិនិត្យមើលសមុទ្ទអស់កាល ៧ ថ្ងៃ ។ បានឮថា នាងសោយទិព្វសម្បត្តិភ្លេចស្មារតី មិនបានពិនិត្យមើល អាចារ្យពួកខ្លះពោលថា ទេពធីតាទៅកាន់ទេវសមាគម ។ លំដាប់នោះ នាងរឭកបានថា ថ្ងៃនេះ ជាថ្ងៃទី ៧ ដែលអញមិនបានពិនិត្យមើលសមុទ្ទ តើមានហេតុអ្វីខ្លះឬហ្ន៎ កាលនាងពិនិត្យមើល ឃើញព្រះមហាសត្វ គិត ថា បើមហាជនកកុមារស្លាប់ក្នុងសមុទ្ទ អញនឹងមិនបានចូលទេវសមាគម

*គិតដូច្នេះហើយ តាក់តែងសរីរៈ ឋិតនៅក្នុងអាកាស មិនឆ្ងាយអំពីព្រះមហាសត្វ កាលពិសោធព្រះមហាសត្វ ទើបពោលបឋមគាថានេះថា*

**កោយំ មជ្ឈេ សមុទ្ទស្មឹ អបស្សន្តីរមាយុហេ**
**កំ ត្វំ អត្ថវសំ ញត្វា ឯវំ វាយាមសេ ភុសំ ។**

*បុគ្គលណានេះ កាលមិនឃើញត្រើយ ក៏ព្យាយាម ( ហែល ) ក្នុងកណ្តាលសមុទ្ទ អ្នកដឹងនូវអំណាចនៃប្រយោជន៍ដូចម្តេច ក៏ព្យាយាមក្រៃពេកម៉្លេះ ។*

*លំដាប់នោះ ព្រះមហាសត្វទ្រង់ព្រះតម្រិះថា អញហែលឆ្លងសមុទ្ទបាន ៧ ថ្ងៃ និងថ្ងៃនេះ អញមិនធ្លាប់ឃើញសម្មាញ់ជាគម្រប់ពីររបស់អញឡើយ បុគ្គលណាហ្ន៎ មកពោលជាមួយអញ កាលសម្លឹងទៅក្នុងអាកាស ឃើញនាងមណិមេខលាហើយ ទើបពោលគាថាទី ២ ថា*

**និសម្ម វត្តំ លោកស្ស វាយាមស្ស ច ទេវតេ**
**តស្មា មជ្ឈេ សមុទ្ទស្មឹ អបស្សន្តីរមាយុហេ ។**

*ម្នាលទេវតា ខ្ញុំពិចារណានូវវត្តនៃសត្វលោក និងអានិសង្ស នៃសេចក្តីព្យាយាម ព្រោះហេតុដូច្នោះ ខ្ញុំសូម្បីមិនឃើញត្រើយ ក៏នៅតែព្យាយាមក្នុងកណ្តាលសមុទ្ទ ។*

*នាងមណិមេខលា ប្រាថ្នានឹងស្តាប់ធម្មកថារបស់ព្រះមហាសត្វ ទើបពោលគាថាបន្តថា*

កម្ពីរេ អប្បមេយ្យស្មឹ តីរំ យស្ស ន ទិស្សតិ
មោឃោ តេ បុរិសវាយាមោ អប្បត្វាវ មរិស្សសិ ។

*អ្នកមិនឃើញត្រើយនៃសមុទ្រដ៏ជ្រៅ ប្រមាណមិនបាន ការព្យាយាមតាមកម្លាំងបុរសរបស់អ្នក ជាព្យាយាមសោះសូន្យទទេ អ្នកមិនដល់នូវត្រើយទេ មុខជានឹងស្លាប់ ។*

*លំដាប់នោះ ព្រះមហាសត្វត្រាស់ថា ម្នាលទេពធីតា នាងពោលអ្វីយ៉ាងនេះ ខ្ញុំធ្វើសេចក្តីព្យាយាម សូម្បីស្លាប់ក៏ផុតចាកពាក្យនិន្ទា ដូច្នេះហើយ ទើបត្រាស់គាថាដូច្នេះថា*

អននោ ញាតិនំ ហោតិ ទេវានំ បិតុនញ្ច សោ
ករំ បុរិសកិច្ចានិ ន ច បច្ឆានុតប្បតិ ។

*បុគ្គលធ្វើនូវកិច្ចរបស់បុរស ទើបជាអ្នកមិនមានបំណុល ( ក្នុងរវាង ) ពួកញាតិ ពួកទេវតា និងពួកបិតា ( ព្រហ្ម ) ទាំងមិនក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ ។*

*លំដាប់នោះ ទេពធីតាពោលគាថាថា*

អបារណេយ្យំ យំ កម្មំ អផលំ កិលមថុទ្ទយំ
តត្ថ កោ វាយមេនត្ថោ មច្ចុ យស្សាភិនិប្បតំ ។

*ការងារណា មិនគប្បីសម្រេច ( ដោយសេចក្តីព្យាយាមទេ ) ការងារនោះ ជារបស់ឥតផល មានសេចក្តីលំបាកជាកម្រៃ*

*សេចក្តីស្លាប់ រមែងសម្រេចដល់បុគ្គលណា បុគ្គលនោះមានប្រយោជន៍ដូចម្តេច ដោយសេចក្តីព្យាយាមក្នុងការងារនោះ ។*

*កាលទេពធីតាពោលយ៉ាងនេះហើយ ព្រះមហាសត្វ កាលនឹងធ្វើឲ្យទេពធីតានោះ អស់បដិភាណ ទើបត្រាស់គាថាតទៅថា*

អចារណេយ្យមច្ចន្តំ យោ វិជិត្វាន ទេវតេ
ន រក្ខេ អត្តនោ បាណំ ជញ្ញា សោ យទិ ហាបយេ ។

*ម្នាលទេវតា បុគ្គលណាដឹងច្បាស់ថា ការងារមិនគប្បីសម្រេចដោយពិត ហើយមិនរក្សាជីវិតរបស់ខ្លួន បុគ្គលនោះ បើបន្ថយសេចក្តីព្យាយាម គង់ដឹង ( នូវផលនៃសេចក្តីខ្ជិលនោះមិនខាន ) ។*

អធិប្បាយផលំ ឯកេ អស្មឹ លោកស្មិ ទេវតេ
បយោជយន្តិ កម្មានិ តានិ ឥជ្ឈន្តិ វា ន វា ។

*ម្នាលទេវតា បុគ្គលពួកខ្លះ ក្នុងលោកនេះ (កាលឃើញ) នូវផលនៃសេចក្តីប្រាថ្នាហើយ រមែងប្រកបនូវការងារទាំងឡាយ ការងារទាំងនោះ សម្រេចខ្លះ មិនសម្រេចខ្លះ ។*

សន្ទិដ្ឋិកំ កម្មផលំ ននុ បស្សសិ ទេវតេ
សន្នា អញ្ញេ តរាមហំ តញ្ច បស្សាមិ សន្តិកេ ។

ម្នាលទេវតា ត្រេ្រង៍អ្នកបានឃើញផលនៃកម្មដ៏ជាក់ច្បាស់ដោយខ្លួនឯងដែរឬ ជនទាំងឡាយដទៃលិចលង់ហើយ ខ្ញុំនៅធ្លង ទាំងបានឃើញនាងដែលឋិតនៅក្នុងទីជិតនៃខ្ញុំ ។

សោ អហំ វាយមិស្សាមិ យថាសត្តិ យថាពលំ
គច្ឆំ ចារំ សមុទ្ទស្ស កាស្សំ បុរិសការិយំ ។

ខ្ញុំនោះ នឹងព្យាយាមតាមសមគួរដល់សេចក្តីអង់អាច និងសមគួរដល់កម្លាំង ខ្ញុំកាលទៅដល់ត្រើយនៃសមុទ្ទ នឹងធ្វើនូវសេចក្តីព្យាយាមដែលបុរសគប្បីធ្វើ ។

ទេពធីតានោះ បានស្តាប់វាចាដ៏មាំទាំរបស់ព្រះមហាសត្វហើយ កាលនឹងសរសើរព្រះមហាសត្វ ទើបពោលគាថាថា

យោ ត្វំ ឯវំ គតេ ឱឃេ អប្បមេយ្យេ មហណ្ណវេ
ធម្មវាយាមសម្បន្នោ កម្មុនា នាវសីទតិ
សោ ត្វំ តត្ថេវ គច្ឆាហិ យត្ថ តេ និរតោ មនោ ។

កាលមហាសមុទ្ទ មានអន្លង់ទឹកដ៏ជ្រៅ ប្រមាណមិនបានប្រព្រឹត្តទៅយ៉ាងនេះ អ្នកណាប្រកបដោយសេចក្តីព្យាយាមដោយធម៌ រមែងមិនលិចចុះដោយកម្ម គឺសេចក្តីព្យាយាម ចិត្តរបស់អ្នកត្រេកអរក្នុងទីណា អ្នកនោះ ចូរទៅក្នុងទីនោះចុះ ។

កាលពោលដូច្នេះហើយ ទេពធីតានោះ សួរព្រះមហាសត្វថា នែ

បណ្ឌិត អ្នកមានព្យាយាមធំ ខ្ញុំនឹងនាំអ្នកទៅក្នុងទីណា ។ ព្រះមហាសត្វត្រាស់ថា មិថិលានគរ ។ ទេពធីតានោះ ត្រកងព្រះមហាសត្វ ដូចលើកនូវបាច់ផ្កា យកដើមដៃទាំងពីរផ្គងឲ្យដេកត្រង់ទ្រូង នាំហោះទៅក្នុងអាកាស ដូចម្ដាយបីកូនជាទីស្រឡាញ់ដូច្នោះ ។ ព្រះមហាសត្វមានព្រះសរីរៈសៅហ្មងដោយទឹកប្រៃអស់ ៧ ថ្ងៃ បាននូវសម្ផស្សទិព្វ ក៏ផ្ទំលក់ ។ លំដាប់នោះ នាងមណិមេខលានាំព្រះមហាសត្វដល់នគរមិថិលា ឲ្យផ្ទំផ្អៀងខាងស្ដាំ លើផ្ទាំងថ្មដែលជាមង្គល ក្នុងអម្ពវ័នឧទ្យាន ប្រគល់ឲ្យពួកទេវតាដែលនៅក្នុងឧទ្យានថែរក្សាព្រះមហាសត្វ ហើយទៅកាន់លំនៅរបស់ខ្លួន ។

ក្នុងកាលនោះ ព្រះបាទបោលជនករាជ ទ្រង់មិនមានព្រះរាជឱរស មានតែព្រះរាជធីតាមួយអង្គ ព្រះនាមសីវលីទេវី ជាស្រីមានប្រាជ្ញា ។ អាមាត្យទាំងឡាយ ក្រាបទូលសួរព្រះបាទបោលជនក កាលទ្រង់ផ្ទំលើគ្រែសម្រាប់សោយទិវង្គតថា បពិត្រមហារាជ កាលទ្រង់សោយទិវង្គតហើយ ពួកទូលព្រះបង្គំនឹងថ្វាយរាជសម្បត្តិដល់បុគ្គលណា ។

លំដាប់នោះ ព្រះបាទបោលជនករាជត្រាស់ថា អ្នកទាំងឡាយចូរប្រគល់រាជសម្បត្តិដល់បុរសណា ដែលអាចញ៉ាំងព្រះនាងសីវលីទេវីធីតារបស់យើងឲ្យត្រេកអរ ឬបុរសណាដែលដឹងក្បាលដំណេកនៃបល្ល័ង្ក ៤ ជ្រុង ឬបុរសណាអាចលើកឡើងនូវធ្នូសហស្សថាមបាន ឬបុរសណា

អាចនាំមហាកំណប់ទ្រព្យទាំង ១៦ កន្លែងមកបាន អ្នកទាំងឡាយ ចូរប្រគល់រាជសម្បត្តិឲ្យដល់បុរសនោះចុះ ។

ពួកអាមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះទេវៈ សូមព្រះអង្គត្រាស់ឧទានបញ្ហានៃកំណប់ទ្រព្យទាំងនោះ ដល់ពួកទូលព្រះបង្គំចុះ ។

លំដាប់នោះ ព្រះរាជាត្រាស់ឧទានបញ្ហារបស់វត្ថុដទៃ ៗ មួយអន្លើដោយមហាកំណប់ទ្រព្យទាំងឡាយថា

សុរិយុគ្គមនេ និធិ　　អថោ ឱគ្គមនេ និធិ
អន្តោ និធិ ពហិ និធិ　　ន អន្តោ ន ពហិ និធិ
អារោហនេ មហានិធិ　　អថោ ឱរោហនេ និធិ
ចតូសុ មហាសាលេសុ　　សមន្តា យោជនេ និធិ
ទន្តគ្គេសុ មហានិធិ　　វាលគ្គេសុ ច កេបុកេ
រុក្ខគ្គេសុ មហានិធិ　　សោឡសេតេ មហានិធី
សហស្សថាមោ បល្លង្កោ　　សីវលោរាជនេន ច ។

កំណប់ធំ ១៦ នេះគឺ កំណប់ត្រង់ទីព្រះអាទិត្យរះ កំណប់ត្រង់ទីព្រះអាទិត្យលិច កំណប់ខាងក្នុង កំណប់ខាងក្រៅ កំណប់មិនមែនខាងក្នុងមិនមែនខាងក្រៅ កំណប់ធំត្រង់ទីសម្រាប់ឡើង កំណប់ត្រង់ទីសម្រាប់ចុះ កំណប់ត្រង់សាលព្រឹក្សធំទាំងបួន កំណប់ត្រង់ទីមួយយោជន៍ជុំវិញ

កំណាប់ធំ ត្រង់ចុងភ្នកដំរីទាំងពីរ កំណាប់ត្រង់ចុងកន្ទុយ កំណាប់ក្នុងទឹក កំណាប់ធំត្រង់ចុងឈើ សហស្សថាមធ្ន បល្ល័ង្ក ៤ ជ្រុង និងញ៉ាំងនាងសីវលីរាជទេវីឲ្យត្រេកអរ ។ ព្រះរាជាត្រាស់ឧទានបញ្ហាទាំងនេះហើយ ក៏សោយទិវង្គត ។

កាលព្រះបាទបោលជនកសោយទិវង្គត ថ្វាយព្រះភ្លើងព្រះបរមសពស្រេចហើយ អាមាត្យទាំងឡាយបានប្រជុំប្រឹក្សាគ្នាក្នុងថ្ងៃទី ៧ ថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ព្រះរាជាត្រាស់ថា ឲ្យប្រគល់រាជសម្បត្តិដល់អ្នកដែលអាចឲ្យព្រះរាជធីតាត្រេកអរ អ្នកណាហ្ន៎ អាចឲ្យព្រះរាជធីតាត្រេកអរ ។ អាមាត្យទាំងនោះ ក៏ពោលថា សេនាបតីជាអ្នកដែលជិតស្និទ្ធនឹងព្រះរាជា ទើបបញ្ជូនដំណឹងដល់សេនាបតីនោះ ។ សេនាបតីបានស្តាប់ដំណឹង ទទួលថា សាធុ ហើយទៅកាន់ព្រះរាជវាំងដើម្បីរាជសម្បត្តិ ឲ្យក្រាបទូលនូវភាពដែលខ្លួនមក ដល់ព្រះរាជធីតា ។ ព្រះរាជធីតាដឹងថា សេនាបតីមក ព្រះនាងបំណងសាកល្បងសេនាបតីនោះថា តើជាអ្នកមានបញ្ញា ទ្រទ្រង់នូវសិរីស្វេតច្ឆត្របានដែរឬទេ ទើបពោលថា ចូរមកដោយរហ័ស ។ សេនាបតីបានស្តាប់ដំណឹងនោះហើយ បំណងឲ្យព្រះរាជធីតាប្រោសប្រាណ ទើបមកដោយរហ័សតាំងអំពីជើងជណ្តើរទៅឈរត្រង់ទីជិតព្រះរាជធីតា ។ លំដាប់នោះ ព្រះរាជធីតា កាលពិសោធសេនាបតីនោះ ទើបត្រាស់ថា ចូររត់ទៅក្នុងព្រះរាជដំណាក់ឲ្យ

រហ័ស ។ សេនាបតីនោះ គិតថា អញនឹងញ៉ាំងឲ្យព្រះរាជធីតាត្រេកអរ ទើបរត់ទៅដោយរហ័ស ។ ព្រះរាជធីតាថា ចូររត់មកវិញឲ្យរហ័ស ។ សេនាបតីក៏រត់មកវិញដោយរហ័ស ។ ព្រះរាជធីតាដឹងថា សេនាបតីនោះ មិនមានបញ្ញា ទើបត្រាស់ថា ចូរមកច្របាច់ជើងឲ្យយើង ។ សេនាបតីក៏អង្គុយចុះ ច្របាច់ព្រះបាទរបស់ព្រះរាជធីតា ដើម្បីឲ្យព្រះនាងសព្វព្រះរាជហឫទ័យ ។ លំដាប់នោះ ព្រះរាជធីតាយកជើងធាក់សេនាបតីនោះត្រង់ទ្រូង ឲ្យដួលផ្ងារ ហើយប្រទានសញ្ញាដល់ទាសីទាំងឡាយ ដោយព្រះតម្រាស់ថា ចូរវាយបុរសអាប់ឥតប្រាជ្ញា អន្ធពាលនេះ ហើយអូសកចេញទៅ ។ ទាសីទាំងឡាយ ក៏ធ្វើតាមបញ្ជា ។ សេនាបតីនោះ កាលត្រូវគេសួរថា បពិត្រលោកសេនាបតី តើដូចម្ដេចហើយ ក៏ឆ្លើយថា ពួកអ្នកកុំសួរឡើយ ព្រះរាជធីតានេះ មិនមែនជាស្រីមនុស្សទេ ជាយក្ខិនី ។ បន្ទាប់អំពីនោះ អ្នករក្សាឃ្លាំង ទៅដើម្បីឲ្យព្រះរាជធីតាត្រេកអរ ។ ព្រះនាងក៏ធ្វើឲ្យបានទទួលនូវការខ្មាសដូចគ្នានឹងសេនាបតីទៀត ។ លើសពីនោះ បានញ៉ាំងជនទាំងពួង គឺសេដ្ឋី ឆត្តគ្គាហៈ ( អ្នកបាំងឆត្រ ) អសិគ្គាហៈ ( អ្នកកាន់ដាវ ) ឲ្យទទួលនូវការខ្មាសដូចគ្នា ។

គ្រានោះ ពួកអាមាត្យប្រជុំគ្នា ពោលថា មិនមានអ្នកណាអាចឲ្យព្រះរាជធីតាត្រេកអរ អ្នកទាំងឡាយ ចូរប្រគល់រាជសម្បត្តិដល់អ្នកអាចលើកធ្នូដែលមានកម្លាំងបុរស ១ ពាន់ បុគ្គលណាម្នាក់ ក៏មិនអាចលើកធ្នូ

នោះឡើងបាន ។ បន្ទាប់អំពីនោះ ពួកអាមាត្យពោលថា អ្នកទាំងឡាយ ចូរប្រគល់រាជសម្បត្តិ ដល់អ្នកស្គាល់ក្បាលដំណោកនៃបល្ល័ង្កបួនជ្រុង ក៏មិនមានអ្នកណាមួយស្គាល់ ។ បន្ទាប់អំពីនោះ ពួកអាមាត្យពោលថា អ្នកទាំងឡាយ ចូរប្រគល់រាជសម្បត្តិដល់អ្នកអាចនាំយកមហាកំណប់ទ្រព្យ ១៦ កន្លែងមកបាន ក៏មិនមានអ្នកណាអាចទៀត ។ បន្ទាប់អំពីនោះ ពួកអាមាត្យទាំងឡាយប្រឹក្សាគ្នាថា យើងទាំងឡាយមិនអាចរក្សាដែនដែលគ្មានព្រះរាជាបានទេ គប្បីធ្វើដូចម្ដេចហ្ន៎ ។ លំដាប់នោះ បុរោហិតពោលថា ពួកអ្នកកុំព្រួយឡើយ យើងគួរផ្សងបុស្សរថទៅ ព្រោះព្រះរាជាដែលរកបានដោយបុស្សរថ ជាអ្នកអាចគ្រប់គ្រងរាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ។ ពួកអាមាត្យក៏ទទួលថា សាធុ ហើយឲ្យប្រដាប់តាក់តែងព្រះនគរ ឲ្យទឹមសេះបួនដែលមានពណ៌ដូចផ្កាកុមុទ ដោយរាជរថដែលជាមង្គល ក្រាលនូវកម្រាលដ៏វិចិត្រខាងលើ ឲ្យតម្កល់បញ្ច-រាជកកុធភណ្ឌ ចោមរោមដោយចតុរង្គសេនា ។ បុរោហិតពោលថា តាមធម្មតា ជនទាំងឡាយតែងប្រគំតន្ត្រីខាងមុខរាជរថ ដែលមានព្រះរាជាជាម្ចាស់ តែងប្រគំតន្ត្រីខាងក្រោយរាជរថ ដែលមិនមានព្រះរាជាជាម្ចាស់ ហេតុនោះ ចូរអ្នកទាំងឡាយប្រគំតន្ត្រីខាងក្រោយរាជរថ ដូច្នេះហើយ ឲ្យយកកុណ្ឌីមាសមកប្រោះព្រំត្រង់ចុងទូករទេះ ( ក្បាលក្រពើ ) និងជន្ទួញ ហើយប្រាប់រាជរថថា បុគ្គលណា មានបុណ្យដែលត្រូវបាន

រាជសម្បត្តិ អ្នកចូរទៅកាន់សម្នាក់របស់បុគ្គលនោះ ហើយលែងរាជរថនោះទៅ ។ លំដាប់នោះ រាជរថក៏ធ្វើប្រទក្សិណព្រះរាជនិវេសន៍ ហើយឡើងកាន់មហាវិថី ស្ទុះទៅដោយរហ័ស ។

ជនទាំងឡាយ មានសេនាបតីជាដើម នឹកគិតថា សូមបុស្សរថមកកាន់សម្នាក់អញ បុស្សរថនោះ ក៏ស្ទុះទៅហួសគេហដ្ឋានរបស់ជនទាំងពួង ធ្វើប្រទក្សិណព្រះនគរ ហើយចេញទៅតាមទ្វារទិសខាងកើត បែរមុខទៅកាន់ព្រះរាជឧទ្យាន ។ ក្នុងកាលនោះ ជនទាំងឡាយឃើញរាជរថស្ទុះទៅដោយរហ័ស ទើបពោលថា អ្នកទាំងឡាយ ចូរញុំាងរាជរថនោះ ឲ្យត្រឡប់ ។

បុរោហិតឃាត់ថា កុំឲ្យត្រឡប់ឡើយ ទោះបីស្ទុះទៅអស់ ១០០ យោជន៍ ក៏កុំឲ្យត្រឡប់ ។ រាជរថចូលទៅកាន់ព្រះរាជឧទ្យាន ធ្វើប្រទក្សិណផ្ទាំងសិលាមង្គល ហើយឈប់ ត្រៀមទទួលការយាងឡើង ។ បុរោហិតឃើញព្រះមហាសត្វផ្ទំ ទើបហៅពួកអាមាត្យមក ពោលថា នែអ្នកដ៏ចម្រើន បុរសម្នាក់ដេកលើសិលាមង្គលប្រាកដ ( ដល់ពួកយើង ) តែពួកយើងមិនដឹងថា បុរសនោះ មានបញ្ញាសមគួរដល់ស្វេតច្ឆត្រ ឬមិនមាន បើគេមានបុណ្យ នឹងមិនសម្លឹងមើលពួកយើង បើជាបុគ្គលកាឡកណ្ណី ក៏នឹងភ័យតក់ស្លុត ក្រោកឡើងញាប់ញ័រ សម្លឹងមើល ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរប្រគំតន្ត្រីដោយរហ័ស ។ ជនទាំងពួងក៏

ប្រគំតន្ត្រីក្នុងខណៈនោះ ។ សំឡេងតន្ត្រីក្នុងកាលនោះ ហាក់ដូចជាកង រំពងពេញផ្ទៃសមុទ្ទ ។

ព្រះមហាសត្វភ្ញាក់ដោយសំឡេងនោះ បើកព្រះសិរសា ទតឃើញ មហាជនហើយ ទ្រង់ព្រះតម្រិះថា ស្វេតច្ឆត្រនឹងធ្លាក់មកដល់អញ ដូច្នេះ ហើយ ទទូរក្បាលដេកទៀត ដោយប្រែព្រះកាយផ្ទំទៅខាងឆ្វេង ។ បុរោហិតបើកព្រះបាទរបស់ព្រះមហាសត្វ ពិនិត្យមើលព្រះលក្ខណៈ ហើយ ពោលថា ទ្វីប ១ ចូរស្ទេះទុកចុះ បុរសនេះ អាចគ្រប់គ្រងរាជ សម្បត្តិក្នុងមហាទ្វីបទាំង ៤ បាន ពោលដូច្នេះហើយ ឲ្យប្រគំតន្ត្រី ទៀត ។ លំដាប់នោះ ព្រះមហាសត្វទ្រង់បើកព្រះភក្ត្រម្តងទៀត ប្រែ ព្រះកាយផ្ទំទៅខាងស្តាំ ទតមើលមហាជន ។ បុរោហិតឲ្យបរិស័ទថយ ចេញ ហើយផ្គងអញ្ជលីក្រាបចុះ ទូលថា បពិត្រព្រះសម្មតិទេព សូម ទ្រង់ក្រោកឡើង រាជសម្បត្តិមកដល់ព្រះអង្គហើយ ។

លំដាប់នោះ ព្រះមហាសត្វត្រាស់សួរបុរោហិតថា ព្រះរាជារបស់ ពួកអ្នក យាងទៅណា ។ កាលបុរោហិតក្រាបទូលថា ទ្រង់សោយទិវង្គត ហើយ ព្រះអង្គ ទើបត្រាស់សួរថា ព្រះរាជឱរស ឬព្រះរាជភាតារបស់ ព្រះរាជានោះ មិនមានទេឬ ។

បុរោហិតក្រាបទូលថា មិនមានទេ ព្រះសម្មតិទេព ។ លំដាប់ នោះ ព្រះមហាសត្វទ្រង់ស្តាប់ពាក្យរបស់បុរោហិតនោះហើយ ត្រាស់ថា

បើដូច្នោះ ល្អហើយ យើងនឹងគ្រប់គ្រងរាជសម្បត្តិ ហើយទ្រង់ក្រោកឡើង ប្រថាប់គង់ពត់ភ្នែនលើផ្ទាំងមង្គលសិលា ។ លំដាប់នោះ ជនទាំងឡាយ មានអាមាត្យនិងបុរោហិតជាដើម ក៏ថ្វាយអភិសេកព្រះមហាសត្វក្នុង ទីនោះឯង ។ ព្រះមហាសត្វនោះ ទ្រង់បានព្រះនាមថា មហាជនករាជ ទ្រង់យាងឡើងកាន់រាជរថដ៏ប្រសើរ ចូលព្រះនគរដោយសិរីរាជសម្បត្តិ ដ៏ធំ ចូលកាន់ព្រះរាជនិវេសន៍ ទ្រង់ពិចារណាថា តំណែងនោះ ៗ ចូរ មានដល់ជននោះ ៗ មានសេនាបតីជាដើម ហើយទ្រង់យាងឡើងកាន់ មហាប្រាសាទ ។

ឯព្រះរាជធីតាត្រាស់នឹងបុរសម្នាក់ ដើម្បីសាកល្បងព្រះមហាសត្វ ដោយសញ្ញាដែលមានអំពីមុនថា នែបា ចូរអ្នកទៅគាល់ព្រះរាជា ក្រាប ទូលថា ព្រះនាងសីវលីត្រាស់ឲ្យយាងទៅ សូមទ្រង់ប្រញាប់យាងទៅ ។ អាមាត្យនោះ ក៏ទៅក្រាបទូលព្រះរាជាយ៉ាងនោះ ព្រះរាជាទ្រង់មិនស្តាប់ ពាក្យនោះ ទ្រង់ធ្វើដូចជាមិនបានឮ ត្រាស់សរសើរប្រាសាទជាដើមថា ប្រាសាទនេះល្អ ដូច្នេះ ព្រោះភាពដែលទ្រង់ជាបណ្ឌិត ។ រាជបុរស នោះ មិនអាចឲ្យព្រះរាជាទ្រង់ស្តាប់ពាក្យនោះ ទើបត្រឡប់មកក្រាបទូល ព្រះរាជធីតាថា បពិត្រព្រះនាង ព្រះរាជាមិនស្តាប់ពាក្យរបស់ព្រះនាងទេ រវល់តែទតប្រាសាទ មិនដាក់ចិត្តក្នុងវាចារបស់ព្រះនាងឡើយ ដូចបុគ្គល មិនដាក់ចិត្តក្នុងស្មៅដូច្នោះ ។ ព្រះរាជធីតាព្រះតម្រិះថា បុរសនេះ មាន

អធ្យាស្រ័យធំ បញ្ជូនរាជបុរសឲ្យទៅយាងទ្រង់មកទៀត អស់វារៈ ២ ដង ៣ ដង សូម្បីព្រះរាជាក៏យាងទៅដោយប្រក្រតី តាមការពេញចិត្តរបស់ព្រះអង្គ ឡើងកាន់ប្រាសាទដូចរាជសីហ៍ចេញអំពីគុហាដូច្នោះ ។ កាលព្រះរាជាយាងចូលមកជិត ព្រះរាជធីតាមិនអាចតម្កល់ព្រះកាយបានដោយអានុភាពនៃព្រះមហាសត្វ ទើបយាងមកហុចព្រះហស្តឲ្យតោង ។

ព្រះរាជាក៏ទ្រង់ចាប់ព្រះហស្តព្រះរាជធីតា ឡើងកាន់មហាប្រាសាទ ហើយគង់លើរាជបល្ល័ង្ក ខាងក្រោមមហាស្វេតច្ឆត្រ ត្រាស់ហៅអាមាត្យទាំងឡាយមក សួរថា នែអ្នកដ៏ចម្រើនទាំងឡាយ កាលព្រះរាជារបស់ពួកអ្នក ទ្រង់សោយទិវង្គត បានត្រាស់អ្វីខ្លះ ។ អាមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេព បានត្រាស់ដែរ ។

ព្រះមហាសត្វត្រាស់ថា បើដូច្នោះ ពួកអ្នកចូរពោលមកចុះ ។ អាមាត្យទាំងឡាយក្រាបទូលថា ព្រះរាជារបស់ទូលព្រះបង្គំទាំងឡាយបានត្រាស់ដូច្នេះថា ឲ្យប្រគល់រាជសម្បត្តិដល់អ្នកដែលធ្វើឲ្យព្រះរាជធីតាព្រះនាមសីវលីទេវី ត្រេកអរ ។

ព្រះមហាសត្វត្រាស់ថា ព្រះនាងសីវលីទេវីរាជធីតាយាងមកឲ្យយើងតោងព្រះហស្តរបស់ព្រះនាងហើយ សេចក្តីនេះ ឈ្មោះថា យើងបានធ្វើឲ្យព្រះរាជធីតាត្រេកអរហើយ ចូរអ្នកទាំងឡាយពោលសេចក្តីដទៃចុះ ។ អាមាត្យទាំងឡាយក្រាបទូលថា ឲ្យប្រគល់រាជសម្បត្តិដល់

អ្នកដែលអាចដឹងក្បាលដំណោកនៃបល្ល័ង្ក ៤ ជ្រុង ថានៅខាងណា ។

ព្រះមហាសត្វទ្រង់ត្រិះរិះថា សេចក្ដីនេះ ដឹងបានលំបាក តែអាចដឹងបានដោយឧបាយ ទើបទ្រង់ដោះស្នៀតសក់អំពីព្រះសិរសា ដាក់ក្នុងដៃព្រះនាងសីវលី ដោយព្រះតម្រាស់ថា ចូរទុកស្នៀតសក់នេះ ។ ព្រះនាងសីវលីទេវីទទួលស្នៀតសក់ ហើយទុកខាងក្បាលដំណោកនៃបល្ល័ង្កនោះ ។ អាចារ្យពួកខ្លះពោលថា ព្រះមហាសត្វទ្រង់ប្រទានព្រះខ័នដល់ព្រះរាជធីតា ។ ព្រះមហាសត្វទ្រង់ជ្រាបថា ខាងនេះ ជាក្បាលដំណោកដោយសញ្ញានោះ ទ្រង់ធ្វើជាមិនបានឮពាក្យនោះ ត្រាស់សួរថា លោកពោលអ្វី ។ កាលពួកអាមាត្យក្រាបទូលដដែលឲ្យទ្រង់ជ្រាបហើយ ទើបត្រាស់ថា ការដឹងក្បាលដំណោករបស់បល្ល័ង្ក ៤ ជ្រុង មិនជាអស្ចារ្យឡើយ ខាងនេះជាក្បាលដំណោក អ្នកទាំងឡាយ ចូរពោលសេចក្ដីដទៃទៀតចុះ ។

អាមាត្យទាំងឡាយទូលថា ឲ្យប្រគល់រាជសម្បត្តិដល់អ្នកដែលលើកធ្នូសហស្សថាមឡើងបាន ។ ព្រះមហាសត្វត្រាស់ថា បើដូច្នោះ ចូរនាំធ្នូសហស្សថាមនោះ មក ហើយទ្រង់ប្រថាប់គង់លើរាជបល្ល័ង្កនោះឯងលើកសហស្សថាមធ្នូឡើង ដូចលើកដងថ្លេចកប្បាសរបស់ស្រីទាំងឡាយដូច្នោះ ហើយត្រាស់ថា ចូរពោលសេចក្ដីដទៃទៀតចុះ ។

អាមាត្យទាំងឡាយក្រាបទូលថា ឲ្យប្រគល់រាជសម្បត្តិដល់អ្នក

ដែលអាចនាំយកកំណប់ទ្រព្យ ១៦ កន្លែងមកបាន ។ ព្រះមហាសត្វត្រាស់សួរថា បញ្ហាណាមួយ ទាក់ទងនឹងកំណប់ទ្រព្យនោះ មានដែរឬ ។

ពួកអាមាត្យក្រាបទូលថា មាន ព្រះសម្មតិទេព ។ ព្រះមហាសត្វត្រាស់ថា បើដូច្នោះ ចូរពោលមកចុះ ។

ពួកអាមាត្យក្រាបទូលបញ្ហាដែលទាក់ទងនឹងកំណប់ទ្រព្យថា មានកំណប់ទ្រព្យត្រង់ទីព្រះអាទិត្យរះជាដើម ។ ព្រះមហាសត្វទ្រង់ស្តាប់បញ្ហានោះហើយ ឯសេចក្តីប្រាកដដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត កំពុងអណ្តែតក្នុងផ្ទៃអាកាសដូច្នោះ ។

លំដាប់នោះ ព្រះមហាសត្វត្រាស់ថា ថ្ងៃនេះ អស់ពេលហើយ ស្អែកសឹមយើងជីកកំណប់ទ្រព្យក្នុងទីទាំងឡាយនោះ ៗ ។ ស្អែកឡើង ព្រះមហាសត្វឲ្យប្រជុំពួកអាមាត្យ ហើយត្រាស់សួរថា ព្រះរាជារបស់ពួកអ្នក និមន្ត **ព្រះបច្ចេកពុទ្ធ** មកឆាន់ដែរឬទេ ។ អាមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេព ធ្លាប់និមន្តមកឆាន់ដែរ ។

ព្រះមហាសត្វទ្រង់ព្រះតម្រិះថា ព្រះអាទិត្យ មិនមែនព្រះអាទិត្យដែលមើលឃើញនេះឡើយ ព្រះអាទិត្យសំដៅយកព្រះបច្ចេកពុទ្ធ ព្រោះព្រះបច្ចេកពុទ្ធទាំងឡាយនោះ ប្រាកដដូចព្រះអាទិត្យ កំណប់ទ្រព្យ គង់មានក្នុងទីទទួលព្រះបច្ចេកពុទ្ធទាំងនោះ ។ ព្រះមហាសត្វក៏ត្រាស់សួរថា កាលព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តមក ព្រះរាជាទ្រង់យាងទៅទទួល

ត្រង់ណា ។

កាលពួកអាមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះទេវៈ ក្នុងទីឈ្មោះនោះ ទើបត្រាស់ថា ចូរជីកកំណាប់ទ្រព្យក្នុងទីនោះ ហើយនាំចេញមក ហើយត្រាស់សួរបន្តថា កាលព្រះរាជាជូនដំណើរព្រះបច្ចេកពុទ្ធក្នុងកាលលោកត្រឡប់ ទ្រង់ប្រថាប់ឈរត្រង់ណា ។

កាលពួកអាមាត្យទូលថា ក្នុងទីឈ្មោះនោះ ទើបត្រាស់ឲ្យនាំមកដោយពាក្យថា ចូរនាំកំណាប់ទ្រព្យអំពីទីនោះមក ។ មហាជនក៏ស្រែកហ៊ោកញ្ជ្រៀវថ្វាយសាធុការរាប់ពាន់ដង សរសើរដោយបីតិសោមនស្សថា ជនទាំងឡាយត្រាច់ជីកក្នុងទីដែលព្រះអាទិត្យរះ ព្រោះបញ្ហាពោលថា កំណាប់ទ្រព្យនៅត្រង់ទីព្រះអាទិត្យរះ ។ មួយទៀត ជីកក្នុងទីដែលព្រះអាទិត្យលិច ព្រោះបញ្ហាពោលថា កំណាប់ទ្រព្យនៅត្រង់ទីព្រះអាទិត្យលិច តែកំណាប់ទ្រព្យមាននៅក្នុងទីនេះសោះ ឱ! គួរអស្ចារ្យណាស់ហ្ន៎ ។

ព្រះមហាសត្វឲ្យជីកនាំកំណាប់ទ្រព្យ មកអំពីខាងក្នុងធរណីទ្វារ នៃទ្វារធំ ក្នុងព្រះរាជវាំងហើយ ព្រោះបញ្ហាថា កំណាប់ទ្រព្យខាងក្នុង ។ ឲ្យជីកនាំកំណាប់ទ្រព្យមកអំពីខាងក្រៅធរណីទ្វារ នៃទ្វារធំ ក្នុងព្រះរាជវាំងហើយ ព្រោះបញ្ហាថា កំណាប់ទ្រព្យនៅខាងក្រៅ ។ ឲ្យជីកនាំកំណាប់ទ្រព្យមកអំពីខាងក្រោមធរណីទ្វារ នៃទ្វារធំក្នុងព្រះរាជវាំងហើយ ព្រោះបញ្ហាថា កំណាប់ទ្រព្យមិនមែនខាងក្នុងមិនមែនខាងក្រៅ ។ ឲ្យជីកនាំ

កំណាប់ទ្រព្យមកអំពីទីត្រង់ពោះដំរី ក្នុងពេលព្រះរាជាឡើងមង្គលហត្ថី ព្រោះបញ្ហាថា កំណាប់ទ្រព្យក្នុងទីឡើង ។ ឲ្យជីកនាំកំណាប់ទ្រព្យមកអំពីទីដែលទ្រង់ចុះអំពីកដំរី ព្រោះបញ្ហាថា កំណាប់ទ្រព្យក្នុងទីចុះ ។ ឲ្យជីកនាំកំណាប់ទ្រព្យទាំង ៤ ផ្ទាំង មកអំពីក្រោមជើងព្រះទែនបន្ទំដ៏មានសិរីទាំង ៤ ដែលធ្វើអំពីដើមរាំង អំពីផែនដី ព្រោះបញ្ហាថា កំណាប់ទ្រព្យត្រង់ដើមរាំងទាំង ៤ ។ ឲ្យជីកនាំកំណាប់ទ្រព្យ មកអំពីទីប្រមាណមួយជួរនឹម ដោយជុំវិញព្រះសិរីសយនា ដោយការរាប់មួយជួរនឹមរថ ឈ្មោះថា ប្រមាណមួយយោជន៍ ព្រោះបញ្ហាថា កំណាប់ទ្រព្យក្នុងទីមួយយោជន៍ដោយជុំវិញ ។ ឲ្យជីកនាំកំណាប់ទ្រព្យ ក្នុងទីដែលមង្គលហត្ថីឈរ គឺត្រង់ចុងភ្លុកទាំងពីររបស់ដំរីនោះ មកបាន ព្រោះបញ្ហាថា កំណាប់ទ្រព្យធំត្រង់ចុងភ្លុកដំរីទាំងពីរ ។ ឲ្យជីកនាំកំណាប់ទ្រព្យក្នុងទីមង្គលហត្ថីឈរត្រង់ចុងកន្ទុយរបស់ដំរីនោះ មកបាន ព្រោះបញ្ហាថា កំណាប់ទ្រព្យត្រង់ចុងកន្ទុយ ។ ឲ្យបាចទឹកក្នុងស្រះមង្គលបោក្ខរណី នាំកំណាប់ទ្រព្យមកបាន ព្រោះបញ្ហាថា កំណាប់ទ្រព្យក្នុងទឹក ។ ឲ្យជីកនាំកំណាប់ទ្រព្យខាងក្នុងស្រមោលម្ចប់រាំង ដែលមានបរិមណ្ឌលក្នុងពេលថ្ងៃត្រង់ ត្រង់គល់រាំងធំ ក្នុងព្រះរាជឧទ្យានមកបាន ព្រោះបញ្ហាថា កំណាប់ទ្រព្យធំត្រង់ចុងឈើ ។ ព្រះរាជាឲ្យនាំមហាកំណាប់ទាំង ១៦ មកបានហើយ ត្រាស់សួរថា **អញ្ញំ កិញ្ចិ អត្ថិ** បញ្ហាដទៃ នៅមានទៀតដែរឬទេ ។

អាមាត្យទាំងឡាយក្រាបទូលថា **នត្ថិ ទេវ** បពិត្រព្រះសម្មតិទេព មិនមានឡើយ ។ មហាជននាំគ្នាត្រេកអររីករាយហើយ ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា អញនឹងបរិច្ចាគទ្រព្យទាំងនេះ ក្នុងទានមុខ ទើបឲ្យសាងរោងទាន ៥ កន្លែង គឺត្រង់កណ្ដាលនគរ ១ ត្រង់ទ្វារនគរទាំង ៤ ហើយផ្ដើមឲ្យទាន ទ្រង់ឲ្យយាងព្រះមាតានិងព្រាហ្មណ៍មកអំពីកាលចម្បានគរ ទ្រង់ធ្វើសក្ការៈធំ ។ ព្រះមហាសត្វទ្រង់តាំងនៅក្នុងរាជសម្បត្តិ ក្នុងកាលទ្រង់ជាតរុណរាជកុមារ អ្នកវិទេហរដ្ឋទាំងមូលក៏ត្រេកអរ កាលបានឃើញព្រះអង្គ ដោយគិតថា បានឮថា ព្រះរាជឱរសរបស់ព្រះបាទអរិដ្ឋជនករាជ ព្រះនាមមហាជនករាជ សោយនូវរាជសម្បត្តិ បានឮថា ទ្រង់ជាបណ្ឌិត ជាអ្នកឈ្លាសក្នុងឧបាយ យើងទាំងឡាយនឹងបានឃើញព្រះអង្គ ។ បន្ទាប់អំពីនោះមក មហាជននាំគ្រឿងបណ្ណាការមកថ្វាយ អ្នកនគរទាំងឡាយ ក៏ចាត់ចែងមហោស្រពធំក្រាលនូវកម្រាលជាដើម ក្នុងព្រះរាជនិវេសន៍ ដាក់គ្រឿងក្រអូបនិងកម្រងផ្កាជាដើម ឲ្យសំយុងចុះ រោយនូវលាជ ធ្វើគ្រឿងឧបករណ៍ផ្កា គ្រឿងអប់និងផ្សែងក្រអូប តម្កល់ទឹកនិងភោជនាហារ មានប្រការផ្សេងៗ ។ ជនទាំងនោះ កាន់យកនូវខាទនីយៈ ភោជនីយៈ ទឹកឃ្មុំ ទឹកអំពៅ និងផ្លែឈើជាដើម ដោយភាជន៍ប្រាក់ និងភាជន៍មាសជាដើម ដើម្បីជាគ្រឿងបណ្ណាការថ្វាយព្រះមហាសត្វ ឈរចោមរោមក្នុងទីនោះ ៗ ។ ពួក

អាមាត្យអង្គុយម្ខាង ពួកព្រាហ្មណ៍អង្គុយម្ខាង ពួកសេដ្ឋីជាដើម អង្គុយម្ខាង ពួកស្រីរបាំដែលទ្រទ្រង់នូវរូបដ៏ឧត្តម អង្គុយម្ខាង ពួកព្រាហ្មណ៍ទាំងឡាយ ពោលជ័យមង្គលដោយមាត់ ដោយការធ្វើឲ្យមានសួស្តី ពួកជនអ្នកជំនាញ ក្នុងការរាំនិងច្រៀងជាដើម ក៏ធ្វើការរាំនិងច្រៀងឲ្យប្រព្រឹត្តទៅ ពួកជន អ្នកប្រគំតន្ត្រី ក៏ប្រគំនូវតន្ត្រីច្រើនរយ ។ ក្នុងគ្រានោះ ព្រះរាជនិវេសន៍ ក៏បន្ទឺជាសំឡេងតែមួយ ដូចផ្ទៃសាគរដែលត្រូវខ្យល់បក់មកអំពីក្នុំយុគន្ធរ ដូច្នោះ ទីដែលព្រះមហាសត្វទតហើយៗ ក៏កម្រើកញាប់ញ័រ ។

ក្នុងកាលនោះ ព្រះមហាសត្វប្រថាប់គង់លើរាជាសនៈ ខាងក្រោម មហាស្វេតច្ឆត្រ ទតសិរីវិលាសដ៏ធំ ដូចសិរីរបស់សក្កទេវរាជ ទ្រង់រឭក ដល់សេចក្តីព្យាយាមដែលទ្រង់ធ្វើក្នុងមហាសមុទ្ទ ។ កាលទ្រង់រឭកដល់ សេចក្តីព្យាយាមនោះ ទើបទ្រង់គិតថា ឈ្មោះថា សេចក្តីព្យាយាម គួរតែ ធ្វើពិត បើអញមិនបានធ្វើសេចក្តីព្យាយាមក្នុងមហាសមុទ្ទ អញក៏មិន បានសម្បត្តិនេះឡើយ ។ កាលទ្រង់រឭកដល់សេចក្តីព្យាយាមនោះ ក៏ កើតបីតិសោមនស្ស ទ្រង់បន្ទឺព្រះឧទានទាំងនេះ ដោយកម្លាំងបីតិថា

**អាសីសេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ**
**បស្សាមិ វោហំ អត្តានំ យថា ឥច្ឆឹ តថា អហុ ។**

បុរសជាបណ្ឌិត ត្រូវតែប្រាថ្នា មិនត្រូវនឿយណាយទេ
យើងឃើញច្បាស់ចំពោះខ្លួនឯង យើងប្រាថ្នាយ៉ាងណា

*ក៏បានយ៉ាងនោះ ។*

**អាសីសេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ**

**បស្សាមិ វោហំ អត្តានំ ឧទកា ថលមុព្ភតំ ។**

*បុរសជាបណ្ឌិត ត្រូវតែប្រាថ្នា មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន ( ដែលទេវតា ) ស្រង់អំពីទឹក មកដាក់លើគោក ។*

**វាយមេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ**

**បស្សាមិ វោហំ អត្តានំ យថា ឥច្ឆឹ តថា អហុ ។**

*បុរសជាបណ្ឌិត ត្រូវតែព្យាយាម មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន យើងប្រាថ្នាយ៉ាងណា ក៏បានយ៉ាងនោះ ។*

**វាយមេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ**

**បស្សាមិ វោហំ អត្តានំ ឧទកា ថលមុព្ភតំ ។**

*បុរសជាបណ្ឌិតត្រូវតែព្យាយាម មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន ( ដែលទេវតា ) ស្រង់អំពីទឹកមកដាក់លើគោក ។*

**ទុក្ខូបនីតោបិ នរោ សបញ្ញោ**

**អាសំ ន ឆិន្ទេយ្យ សុខាគមាយ**

**ពហូ ហិ ផស្សា អហិតា ហិតា ច**

**អវិតក្កិតាពោ មច្ចុមុបព្វជន្តិ ។**

*នរជនមានប្រាជ្ញា សូម្បីសេចក្ដីទុក្ខប៉ះពាល់ហើយ មិនគប្បីកាត់សេចក្ដីប្រាថ្នា ដើម្បីដល់នូវសេចក្ដីសុខទេ ព្រោះថា ការប៉ះពាល់ដ៏ច្រើន ឥតប្រយោជន៍ ក៏មាន មានប្រយោជន៍ ក៏មាន ពួកជនអ្នកមិនត្រិះរិះរមែងដល់នូវសេចក្ដីស្លាប់ ។*

**អចិន្តិតម្បិ ភវតិ ចិន្តិតម្បិ វិនស្សតិ**

**ន ហិ ចិន្តាមយា ភោគា ឥត្ថិយា បុរិសស្ស វា ។**

*ហេតុដែលបុគ្គលមិនបានគិត សម្រេចក៏មាន ហេតុដែលបុគ្គលគិតហើយ វិនាសទៅក៏មាន ព្រោះភោគៈទាំងឡាយរបស់ស្ត្រី ឬបុរស មិនមែនសម្រេចដោយការគិតទេ ។*

*តាំងអំពីនោះមក ព្រះមហាសត្វទ្រង់ញុំាំងទសពិធរាជធម៌មិនឲ្យកម្រើក គ្រងរាជសម្បត្តិដោយធម៌ ទ្រង់បម្រើព្រះបច្ចេកពុទ្ធទាំងឡាយ ។ ក្នុងកាលតមក ព្រះនាងសីវលីទេវីប្រសូតព្រះរាជបុត្តដែលសម្បូរដោយលក្ខណៈស្អុកស្អម្ភ និងភាពជាអ្នកមានបុណ្យ ព្រះមាតាបិតាទ្រង់ថ្វាយព្រះនាមថា ទីឃាវុកុមារ ។ កាលទីឃាវុរាជកុមារទ្រង់ចម្រើនវ័យ ព្រះរាជាទ្រង់ប្រទានតំណែងជាឧបរាជ ព្រះរាជាទ្រង់គ្រងរាជសម្បត្តិអស់ ៧*

ពាន់ឆ្នាំ ។

ថ្ងៃមួយ កាលនាយឧទ្យានបាលនាំផ្លៃឈើតូចធំ និងផ្កាផ្សេង ៗ មកថ្វាយ ព្រះរាជាទ្រង់ទតឃើញរបស់ទាំងនោះ ទ្រង់ត្រេកអរ ទ្រង់ធ្វើការរាប់អានឧទ្យានបាលនោះ ហើយត្រាស់ថា នែសម្លាញ់ឧទ្យានបាល យើងប្រាថ្នានឹងឃើញឧទ្យាន ចូរអ្នកតាក់តែងឧទ្យាននោះ ។ នាយឧទ្យានបាលទទួលព្រះរាជតម្រាស់ថា សាធុ ព្រះសម្មតិទេព ធ្វើតាមព្រះរាជបញ្ជា ហើយក្រាបទូលឲ្យទ្រង់ជ្រាប ។ ព្រះមហាសត្វប្រថាប់គង់លើកដំរី ចេញអំពីព្រះនគរដោយបរិវារច្រើន ដល់ទ្វារព្រះរាជឧទ្យាន ។ ក្នុងទីជិតទ្វារព្រះរាជឧទ្យាននោះ មានដើមស្វាយពីរដើម មានស្លឹកខៀវស្រងាត់ ។ មួយដើមមិនមានផ្លៃ ឯមួយដើមមានផ្លៃ ផ្លៃនោះ មានរសផ្អែមពន់ពេក បុគ្គលណាមួយមិនអាចបេះផ្លៃអំពីដើមនោះ ព្រោះផ្លៃមានរសជាតដ៏ប្រសើរ ដែលព្រះរាជាមិនទាន់បានសោយ ។ ព្រះមហាសត្វទ្រង់គង់លើកដំរីដែលកំពុងទៅនុ៎ះឯង បេះយកផ្លៃស្វាយមួយសោយ ផ្លៃស្វាយនោះ គ្រាន់តែប៉ះចុងព្រះជិវ្ហារបស់ព្រះរាជា ប្រាកដដូចទិព្វឱជា ។ ព្រះមហាសត្វទ្រង់ព្រះតម្រិះថា អញនឹងបរិភោគឲ្យច្រើនក្នុងពេលត្រឡប់ហើយយាងចូលកាន់ព្រះរាជឧទ្យាន ជនដទៃ ៗ មានឧបរាជជាដើម រហូតដល់អ្នកឃ្វាលដំរី ឃ្វាលសេះ ដឹងថា ព្រះរាជាសោយផ្លៃស្វាយមានរសដ៏ប្រសើរហើយ ក៏បេះយកផ្លៃស្វាយនោះ មកបរិភោគដូចគ្នា ចំណែក

អ្នកដែលមិនបានផ្លែនោះ ក៏ទម្លាយមែកស្វាយដោយដំបង ធ្វើឲ្យជាឈើមិនមានស្លឹក សល់តែដើមនិងមែក ស្វាយមួយដើមទៀត តាំងនៅយ៉ាងល្អដូចភ្នំកែវមណី ។

ព្រះរាជាយាងចេញអំពីព្រះរាជឧទ្យាន ទតឃើញដូច្នោះ ទើបត្រាស់សួរពួកអាមាត្យថា តើមានរឿងអ្វី ។ ពួកអាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព មហាជនដឹងថា ទ្រង់សោយផ្លែស្វាយដែលមានរសដ៏ប្រសើរហើយ ក៏ដណ្តើមគ្នាបរិភោគនូវផ្លែស្វាយនេះ ។

ព្រះរាជាត្រាស់សួរថា ស្លឹកនិងពណ៌របស់ដើមស្វាយនេះ អស់ហើយ ស្លឹកនិងពណ៌របស់ដើមស្វាយដទៃ ក៏មិនអស់ ព្រោះហេតុអ្វី ។

អាមាត្យទាំងឡាយក្រាបទូលថា ស្លឹកនិងពណ៌របស់ដើមស្វាយមួយទៀត មិនអស់ ព្រោះមិនមានផ្លែ ។ ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ទ្រង់ដល់នូវសេចក្តីសង្វេគ ទ្រង់ព្រះតម្រិះថា ដើមស្វាយនេះ មានពណ៌ខៀវ តាំងនៅហើយ ព្រោះមិនមានផ្លែ តែដើមស្វាយនេះ ត្រូវបាក់ខ្ទេចខ្ទី ព្រោះមានផ្លែ សូម្បីរាជសម្បត្តិ ក៏ដូចគ្នានឹងឈើដែលមានផ្លែ បព្វជ្ជាដូចគ្នានឹងឈើមិនមានផ្លែ ភ័យរមែងមានដល់បុគ្គលមានកង្វល់ ភ័យរមែងមិនមានដល់បុគ្គលមិនមានកង្វល់ ឯយើងនឹងមិនដូចជាដើមឈើមានផ្លែ នឹងដូចដើមឈើដែលឥតផ្លែ អញនឹងលះរាជសម្បត្តិ ចេញបួស ទ្រង់សមាទាន និងអធិដ្ឋានព្រះហឫទ័យឲ្យមាំទាំហើយ ទើបយាងចូល

កាន់នគរ ឡើងកាន់ប្រាសាទ ប្រថាប់ត្រង់ទ្វារប្រាសាទ ឲ្យហៅសេនាបតី មកត្រាស់ថា មហាសេនាបតី ចាប់តាំងអំពីថ្ងៃនេះទៅ ពួកជនក្រៅអំពីអ្នកបដិបត្តិយើងម្នាក់ ដែលជាអ្នកនាំក្រយាស្ងោយមក និងជាអ្នកថ្វាយទឹកខ្ពុរមាត់និងឈើស្ទន់ អ្នកដទៃកុំមករកយើងឡើយ អ្នកទាំងឡាយ ចូរកាន់យកតាមពួកអាមាត្យ ដែលជាអ្នកវិនិច្ឆ័យអំពីបុរាណ ពោលរាជកិច្ចតាំងអំពីថ្ងៃនេះទៅ យើងនឹងចម្រើនសមណធម៌ក្នុងព្រះរាជដំណាក់ខាងលើ ដូច្នេះហើយ ទ្រង់ឡើងកាន់ប្រាសាទ ចម្រើនសមណធម៌មួយអង្គឯងប៉ុណ្ណោះ ។ កាលពេលវេលាកន្លងទៅយ៉ាងនេះ មហាជនប្រជុំគ្នាត្រង់លានព្រះរាជវាំង មិនឃើញព្រះមហាសត្វ ក៏ពោលថា ព្រះរាជារបស់ពួកយើងមិនដូចមុន ហើយពោល ២ គាថាថា

អចោរាណំ វត ភោ រាជា សព្វភុម្មោ ទិសំបតិ
នាជ្ជ នច្ចេ និសាមេតិ ន គីតេ កុរុតេ មនោ ។
ន មិគេ នបិ ឧយ្យានេ នបិ ហំសេ ឧទិក្ខតិ
មូគោវ តុណ្ហីមាសីនោ ន អត្ថមនុសាសតិ ។

ម្នាលគ្នាយើងដ៏ចម្រើន ព្រះរាជាត្រួតនូវផែនដីទាំងមូល ជាម្ចាស់ក្នុងទិស មិនដូចអំពីដើមសោះ ថ្ងៃនេះ មិនទ្រង់ក្រសាលរបាំ មិនទ្រង់ធ្វើទុកក្នុងព្រះហឫទ័យចំពោះចម្រៀង មិនទតម្រឹគ មិនទតឧទ្យាន មិនទតហង្ស ទ្រង់គង់នៅស្ងៀម ហាក់

ដូចជាមនុស្សគ មិនទ្រង់កាត់សេចក្តី ។

ព្រះរាជា ទ្រង់មានព្រះហឫទ័យមិនជាប់ចំពាក់ក្នុងកាមទាំងឡាយ បង្អោនព្រះហឫទ័យទៅកាន់វិវេក ទ្រង់រឭកដល់ព្រះបច្ចេកពុទ្ធទាំងឡាយ ដែលធ្លាប់ស្និទ្ធស្នាលក្នុងរាជត្រកូល ទ្រង់ព្រះតម្រិះថា អ្នកណាហ្ន៎ នឹងប្រាប់លំនៅរបស់ព្រះបច្ចេកពុទ្ធដែលប្រកបដោយគុណ មានសីលជាដើម ជាអ្នកមិនមានកង្វល់ទាំងនោះ ដល់យើង ហើយទ្រង់បន្លឺឧទាន ៣ គាថា ថា

សុខកាមា រហោសីលា វត្តពន្ធា អចារុតា
កស្ស នុ អជ្ជ អារាមេ ទហរា វុឌ្ឍា ច អច្ឆរេ ។

ព្រះបច្ចេកពុទ្ធទាំងឡាយ ទាំងក្មេងទាំងចាស់ អ្នកប្រាថ្នាសេចក្តីសុខ មានសេចក្តីស្ងប់ស្ងាត់ជាប្រក្រតី ប្រាសចាកចំណង គឺកិលេស គង់នៅក្នុងអារាមនៃបុគ្គលណាហ្ន៎ ក្នុងថ្ងៃនេះ ។

អតិក្កន្តវនថា ធីរា នមោ តេសំ មហេសិនំ
យេ ឧស្សុក្កម្ហិ លោកម្ហិ វិហរន្តិ អនុស្សុកា ។

អ្នកប្រាជ្ញទាំងឡាយណា បានកន្លងនូវតណ្ហា ជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ នៅក្នុងលោក ដែលកំពុងខ្វល់ខ្វាយ ខ្ញុំសូមថ្វាយបង្គំអ្នកប្រាជ្ញទាំងនោះ ជាអ្នកស្វែងរកនូវ

*គុណដ៏ធំ ។*

**តេ ឆេត្វា មច្ចុនោ ជាលំ តតំ មាយាវិនោ ទឡ្ហំ**

**សទ្ធាលយន្តា គច្ឆន្តិ កោ តេសំ គតិ ធាបយេ ។**

*អ្នកប្រាជ្ញទាំងឡាយនោះ កាត់ទម្លាយនូវតម្បាញ ជាបណ្ដាញដ៏មាំរបស់មច្ចុ ដែលមានមាយាចេញទៅរួច បុគ្គលណា គប្បីញ៉ាំងយើងឲ្យដល់នូវគតិ ( លំអាន ) នៃអ្នកប្រាជ្ញទាំងនោះ បាន ។*

*កាលព្រះរាជាទ្រង់ចម្រើនសមណធម៌លើប្រាសាទនោះ ពេលវេលា ក៏កន្លងទៅ ៤ ខែ ។ គ្រានោះ ព្រះរាជហឫទ័យរបស់ព្រះអង្គបានបង្អោនទៅក្នុងបព្វជ្ជាយ៉ាងក្រៃលែង ព្រះរាជនិវេសន៍ប្រាកដដូចលោកន្តរនរក ភពទាំង ៣ ប្រាកដដល់ព្រះអង្គ ដូចរណ្ដៅលាមកដែលត្រូវភ្លើងឆេះ ព្រះមហាសត្វមានព្រះហឫទ័យប្រាថ្នាចំពោះបព្វជ្ជា ទ្រង់មានព្រះចិន្តនាការថា កាលណាហ្ន៎ ការលះក្រុងមិថិលា ដែលប្រដាប់តាក់តែងដូចភពរបស់សក្កទេវរាជនេះ ហើយទៅកាន់ហិមវន្តប្បទេស ទ្រទ្រង់នូវភេទបព្វជិត នឹងមានដល់យើង កាលទ្រង់ព្រះតម្រិះដូច្នេះហើយ ទើបទ្រង់ពណ៌នាក្រុងមិថិលាថា*

**កទាហំ មិថិលំ ផីតំ វិភត្តំ ភាគសោ មិតំ**

**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះនគរមិថិលា ជាក្រុងសម្បូណ៌ ដែលដាច់ចែកហើយ ( ដោយឋាន មានរាជនិវេសន៍ជាដើម ) រាស់ហើយដោយចំណែក ( នៃទ្វារនិងថ្នល់ ) ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ មិថិលំ ផីតំ វិភត្តំ ភាគសោ មិតំ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ ទូលាយ មានពន្លឺដោយជុំវិញ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ មិថិលំ ផីតំ ពហុបាការតោរណំ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានកំពែងនិងខ្លោងទ្វារដ៏ច្រើន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ មិថិលំ ផីតំ ទឡ្ហមដ្ដាលកោដ្ឋកំ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានប៉មនិងស៊ុមទ្វារដ៏មាំមួន ហើយបួស ការលះបង់នោះ*

*នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ មិថិលំ ផីតំ សុវិភត្តំ មហាបថំ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ ដែលគេចែកល្អ មានផ្លូវធំ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ មិថិលំ ផីតំ សុវិភត្តន្តរាបណំ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរានផ្សារ ដែលគេចែកដោយល្អ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ មិថិលំ ផីតំ គវស្សរថបីឡិតំ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ ដ៏កុះករដោយគោ សេះ និងរថ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ មិថិលំ ផីតំ អារាមវនមាលិនឹ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃព្រៃសួន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ មិថិលំ ផីតំ ឧយ្យានវនមាលិនឹ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃព្រៃឧទ្យាន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ មិថិលំ ផីតំ បាសាទវរមាលិនឹ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃប្រាសាទដ៏ប្រសើរ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ មិថិលំ ផីតំ តិបុរំ រាជពន្ធុនឹ**
**មាបិតំ សោមនស្សេន វេទេហេន យសស្សិនា**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានកំពែង ៣ ជាន់ ពេញដោយរាជវង្សានុវង្ស ដែល*

*ព្រះបាទវិទេហៈ ព្រះនាមសោមនស្ស មានយស ទ្រង់សាងទុក ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ វិទេហេ ផីតេ និច្ចិតេ ធម្មរក្ខិតេ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់ដែនវិទេហៈ ជាដែនសម្បូណ៌បរិបូណ៌ដោយការសន្សំ ( នូវធញ្ញាហារជាដើម ) ដែលរក្សាតាមធម៌ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ វិទេហេ ផីតេ អជេយ្យេ ធម្មរក្ខិតេ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវដែនវិទេហៈ ជាដែនសម្បូណ៌ ដែលបច្ចាមិត្តផ្ចាញ់មិនបាន ជាដែនរក្សាតាមធម៌ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ អន្តេបុរំ រម្មំ វិភត្តំ ភាគសោ មិតំ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវខាងក្នុងបុរី ដែលជាទីរីករាយ ដែលជាងចែកវាស់ដោយចំណែក ហើយបួស*

*ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ អគ្គេបុរំ រម្មំ សុធាមត្តិកលេបនំ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវខាងក្នុងបុរីជាទីរីករាយ ដែលបូកដោយកំបោរនិងដី ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ អគ្គេបុរំ រម្មំ សុចិតគ្គំ មនោរមំ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវខាងក្នុងបុរីជាទីរីករាយ មានក្លិនក្រអូប ជាទីរីករាយនៃចិត្ត ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ កូដាគារេ ច វិភត្តេ ភាគសោ មិតេ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលជាងចែកហើយ វាស់ហើយដោយចំណែក ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ កូដាគារេ ច សុធាមត្តិកលេបនេ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

កាលណា អញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលបូកដោយកំបោរនិងដី ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

**កទាហំ ក្វដាគារេ ច សុចិតេ្ត មនោរមេ**

**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

កាលណា អញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលមានក្លិនក្រអូប ជាទីរីករាយនៃចិត្ត ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

**កទាហំ ក្វដាគារេ ច លិត្តេ ចន្ទនផោសិតេ**

**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

កាលណា អញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលលាបល្អហើយ ប្រោះព្រំដោយខ្លឹមចន្ទន៍ក្រហម ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

**កទាហំ សុវណ្ណបល្លង្កេ គោណកេ ចិត្តសន្ថតេ**

**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

កាលណា អញនឹងលះបង់នូវគ្រែមាសទាំងឡាយ មានព្រំជាកម្រាលដ៏វិចិត្រ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

**កទាហំ មណិបល្លង្កំ  គោណកេ ចិត្តសន្ថតេ**
**បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវបល្ល័ង្កកែវមណី មានព្រំជាកម្រាលដ៏វិចិត្រ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ កប្បាសកោសេយ្យំ  ខោមកោទុម្ពរានិ ច**
**បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវសំពត់អំបោះ និងសំពត់សូត្រ សំពត់ទាំងឡាយដែលកើតអំពីដែនខោមៈ និងកើតអំពីដែនកោទុម្ពរ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ បោក្ខរណី រម្មា  ចក្កវាកបកូជិតា**
**មណ្ឌាលកេហិ សញ្ឆន្នា  បទុមុប្បលកេហិ ច**
**បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវស្រះបោក្ខរណីទាំងឡាយជាទីរីករាយ មានសត្វចាក្រពាកយំទ្រហឹង ដេរដាសដោយចង្កុលណីទាំងឡាយផង ដោយឈូកនិងព្រលឹតទាំងឡាយផង ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាល*

*ណាហ្ន៎ ។*

**កទាហំ ហត្ថិកុម្ពេ ច សព្វាលង្ការភូសិតេ**
**សុវណ្ណកច្ឆេ មាតង្គេ ហេមកប្បនិវាសសេ**
**អារុឡ្ហេ គាមណីយេហិ តោមរង្កុសបាណិភិ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវហ្វូងដំរីមាតង្គៈ ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់មុខ មានខ្សែជង្គន់មាស មានគ្រឿងស្អាងដោយបណ្ដាញមាស ដែលហ្មដំរីមានលំពែងស្នែងក្របីនិងកង្វេរក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ អស្សកុម្ពេ ច សព្វាលង្ការភូសិតេ**
**អាជានីយេវ ជាតិយា សិន្ធវេ សីឃវាហនេ**
**អារុឡ្ហេ គាមណីយេហិ ឥល្លិយាចាបធារិភិ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវហ្វូងសេះអាជានេយ្យអំពីជាតិ ជាសេះសិន្ធព ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់មុខ ជាវាហនៈលឿន ដែលអ្នកបង្ហាត់សេះកាន់សែនិងធ្នូ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹង*

*សម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ រថសេនិយោ សន្នទ្ធេ ឧស្សិតទ្ធជេ**
**ទីបេ អថោបិ វេយ្យគ្ឃេ សព្វាលង្ការភូសិតេ**
**អារុឡ្ហេ គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវពួករថប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ សោវណ្ណរថេ សន្នទ្ធេ ឧស្សិតទ្ធជេ**
**ទីបេ អថោបិ វេយ្យគ្ឃេ សព្វាលង្ការភូសិតេ**
**អារុឡ្ហេ គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវពួករថមាស ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ ហើយ*

*បួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កទាហំ សជ្ឈុរថេ ច　　សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ　　សព្វាលង្ការភូសិតេ
អារុឡ្ហេ គាមណីយេភិ　　ចាបហត្ថេហិ ចម្មិភិ
បហាយ បព្វជិស្សាមិ　　តំ កទា សុ ភវិស្សតិ ។

*កាលណា អញនឹងលះបង់នូវរថប្រាក់ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កទាហំ អស្សរថេ ច　　សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ　　សព្វាលង្ការភូសិតេ
អារុឡ្ហេ គាមណីយេភិ　　ចាបហត្ថេហិ ចម្មិភិ
បហាយ បព្វជិស្សាមិ　　តំ កទា សុ ភវិស្សតិ ។

*កាលណា អញនឹងលះបង់នូវរថទឹមសេះ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស*

*ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ ឱដ្ឋរថេ ច សន្នទ្ធេ ឧស្សិតទ្ធជេ**
**ជីវេ អជោបិ វេយ្យគ្ឃេ សព្វាលង្ការភូសិតេ**
**អារុឡ្ហេ គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវរថទឹមអូដ្ឋ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ គោណរថេ ច សន្នទ្ធេ ឧស្សិតទ្ធជេ**
**ជីវេ អជោបិ វេយ្យគ្ឃេ សព្វាលង្ការភូសិតេ**
**អារុឡ្ហេ គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវរថទឹមគោ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការ*

លះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទាហំ អជរថេ ច សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ សព្វាលង្ការភូសិតេ
អារុឡ្ហេ គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។

កាលណា អញនឹងលះបង់នូវរថទឹមកែះ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថី មានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ ហើយបួសការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទាហំ មេណ្ឌរថេ ច សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ សព្វាលង្ការភូសិតេ
អារុឡ្ហេ គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។

កាលណា អញនឹងលះបង់នូវរថទឹមពពែ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ ហើយ

*បួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ មិគរថេ ច សន្នទ្ធេ ឧស្សិតទ្ធជេ**
**ទីបេ អថោបិ វេយ្យគ្ឃេ សព្វាលង្ការភូសិតេ**
**អារុឡ្ហេ គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវរថទឹមម្រឹគ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និង ខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ ហត្ថារោហេ ច សព្វាលង្ការភូសិតេ**
**នីលវម្មធរេ សូរេ តោមរង្កុសធារិនោ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវពួកអ្នកជិះដំរី ដែលស្អិតស្អាង ដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានលំពែងស្នែងក្របីនិងកង្វេរក្នុងដៃ ហើយ បួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ អស្សារោហេ ច សព្វាលង្ការភូសិតេ**

នីលចម្មធរេ សូរេ ឥន្ទិយាចាបធារិនោ
បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។

*កាលណា អញនឹងលះបង់នូវពួកអ្នកជិះសេះ ដែលស្អិត-ស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវស៊ៃនិងធ្នូ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កទាហំ រថារោហេ ច សព្វាលង្ការភូសិតេ
នីលចម្មធរេ សូរេ ចាបហត្ថេ កលាបិនោ
បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។

*កាលណា អញនឹងលះបង់នូវពួកអ្នកជិះរថ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូនិងបំពង់ព្រួញក្នុងដៃ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កទាហំ ធនុគ្គហេ ច សព្វាលង្ការភូសិតេ
នីលចម្មធរេ សូរេ ចាបហត្ថេ កលាបិនោ
បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។

*កាលណា អញនឹងលះបង់នូវពួកខ្មាន់ធ្នូ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ*

*ជាអ្នកក្មៀវក្លា មានធ្នូនិងបំពង់ព្រួញក្នុងដៃ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ រាជបុត្តេ ច សញ្ញាលង្ការភូសិតេ**
**ចិត្រចម្មធរេ សូរេ កញ្ចនាវេឡុធារិនោ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវពួកព្រះរាជបុត្ត ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលដ៏វិចិត្រ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវមាសនិងកែវពិទូរ្យ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ អរិយគណេ វត្ថវន្តេ អលង្កតេ**
**ហរិចន្ទនលិត្តង្គេ កាសិកុត្តមធារិនោ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវពួកអរិយជន គឺព្រាហ្មណ៍ ដែលមានសំពត់ មានគ្រឿងប្រដាប់ហើយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ក្រហម ស្លៀកដណ្តប់ដោយសំពត់ ដែលបានមកអំពីដែនកាសីដ៏ឧត្តម ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ អមច្ចគណេ សញ្ញាលង្ការភូសិតេ**

**បីតចម្មធរេ សូរេ បុរតោ គច្ឆមាលិនោ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវពួកអាមាត្យ ដែលស្អិតស្អាង ដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌លឿង ជាអ្នកក្លៀវក្លា មានរបៀបដើរខាងមុខ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ សត្តសតា ភរិយា សព្វាលង្ការភូសិតា**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវពួកស្រីស្នំ ៧០០ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ សត្តសតា ភរិយា សុសញ្ញា តនុមជ្ឈិមា**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវពួកស្រីស្នំ ៧០០ ជាអ្នកសង្រួមល្អ មានចង្កេះរៀវ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ សត្តសតា ភរិយា អស្សវា បិយភាណិនី**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវស្រីស្នំ ៧០០ ជាស្រ្តីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ សតបល្វកំសំ សោវណ្ណំ សតរាជិកំ**
**បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អញនឹងលះបង់នូវភាជន៍មាស មានទម្ងន់ ១០០ បល្វៈ ប្រកបដោយស្នាមចម្លាក់ ១០០ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទា សុ មំ ហត្ថិគុម្ពា សព្វាលង្ការភូសិតា**
**សុវណ្ណកច្ឆា មាតង្គា ហេមកប្បនិវាសសា ។**
**អារុឡ្ហា គាមណីយេភិ តោមរង្កុសបាណិភិ**
**យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។**

*កាលណា ហ្វូងដំរីមាតង្គៈរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង មានខ្សែរដង្គន់មាស មានគ្រឿងស្អាងដោយបណ្តាញមាស ដែលហ្មដំរីមានលំពែងស្នែងក្របិនិងកង្វេរក្នុងដៃ ឡើងជិះហើយ នឹងមិនដើរតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទា សុ មំ អស្សគុម្ពា សព្វាលង្ការភូសិតា**

អាជានីយាវ ជាតិយា សិន្ធវា សីឃវាហនា
អារុឡ្ហា គាមណីយេភិ ឥន្ទិយា ចាបធារិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។

*កាលណា ហ្វូងសេះរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ជាសេះអាជានេយ្យដោយជាតិ ជាសេះសិន្ធព ជាវាហនៈដ៏លឿន ដែលពួកអ្នករក្សាសេះកាន់សៃនិងធ្នូ ឡើងជិះហើយ នឹងមិនដើរតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កទា សុ មំ រថសេនិយោ សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។

*កាលណា ពួករថរបស់អញប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង់និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនដើរតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កទា សុ មំ សុវណ្ណរថា សន្នទ្ធា ឧស្សិតទ្ធជា

ជីតា អជោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
យន្តុំ មំ ជានុយិស្សន្តិ តំ កដា សុ ភវិស្សតិ ។

*កាលណា ពួករថមាសរបស់អញប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កដា សុ មំ សជ្ឈុរថា សន្នទ្ធា ឧស្សិតទ្ធជា
ជីតា អជោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
យន្តុំ មំ ជានុយិស្សន្តិ តំ កដា សុ ភវិស្សតិ ។

*កាលណា ពួករថប្រាក់របស់អញ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កទា សុ មំ អស្សរថា សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។

*កាលណា រថទឹមដោយសេះរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កទា សុ មំ ឱដ្ឋរថា សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។

*កាលណា រថទឹមដោយអូដ្ឋរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ នឹងមិន*

*ទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កទា សុ មំ គោណរថា សន្នទ្ធា ឧស្សិតទ្ធជា
ឌីថា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។

*កាលណា រថទឹមគោរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កទា សុ មំ អជរថា សន្នទ្ធា ឧស្សិតទ្ធជា
ឌីថា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។

*កាលណា រថទឹមកែះរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ*

ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទា សុ មំ មេណ្ឌរថា សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។

កាលណា រថទឹមពពែរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទា សុ មំ មិគរថា សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។

កាលណា រថទឹមម្រឹគរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទា សុ មំ ហត្ថារោហា សព្វាលង្ការភូសិតា
នីលចម្មធរា សូរា តោមរង្កុសបាណិនោ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។

កាលណា ពួកអ្នកជិះដំរីរបស់អញ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លាមានលំពែងស្នែងក្របីនិងកង្វេរក្នុងដៃ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទា សុ មំ អស្សារោហា សព្វាលង្ការភូសិតា
នីលចម្មធរា សូរា ឥល្លិយាចាបធារិនោ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។

កាលណា ពួកអ្នកជិះសេះរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នក

*ក្បៀវក្វា ទ្រទ្រង់នូវស្បែនិងធ្នូ នឹងមិនទៅតាមអញ កាលទៅដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កទា សុ មំ រថារោហា សញ្ញលង្ការភូសិតា
នីលចម្មធរា សូរា ចាបហត្ថា កលាបិនោ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។

*កាលណា ពួកអ្នកជិះរថរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្បៀវក្វា មានធ្នូនិងបំពង់ព្រួញក្នុងដៃ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កទា សុ មំ ធនុគ្គហា សញ្ញលង្ការភូសិតា
នីលចម្មធរា សូរា ចាបហត្ថា កលាបិនោ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។

*កាលណា ពួកខ្មាន់ធ្នូរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្បៀវក្វា មានធ្នូនិងបំពង់ព្រួញក្នុងដៃ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កទា សុ មំ រាជបុត្តា សញ្ញលង្ការភូសិតា
ចិត្រចម្មធរា សូរា កញ្ចនាវេឡធារិនោ

យន្តំ មំ ជានុយិស្សន្តិ តំ កាជា សុ ភវិស្សតិ ។

*កាលណា ពួករាជបុត្ររបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលដ៏វិចិត្រ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវមាសនិងកែវពិទូរ្យ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កាជា សុ មំ អរិយគណា វត្ថវន្តា អលង្កតា

ហរិចន្ទនលិត្តង្គា កាសិកុត្តមធារិនោ

យន្តំ មំ ជានុយិស្សន្តិ តំ កាជា សុ ភវិស្សតិ ។

*កាលណា ពួកអរិយជន គឺព្រាហ្មណ៍ អ្នកមានសំពត់ មានគ្រឿងប្រដាប់ហើយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ក្រហម ទ្រទ្រង់នូវសំពត់ដ៏ឧត្តម ដែលបានមកអំពីដែនកាសី នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

កាជា សុ មំ អមច្ចគណា សញ្ញលង្ការភូសិតា

បីតចម្មធរា សូរា បុរតោ គច្ឆមាលិនី

យន្តំ មំ ជានុយិស្សន្តិ តំ កាជា សុ ភវិស្សតិ ។

*កាលណា ពួកអាមាត្យរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌លឿង ជាអ្នក*

*គៀវក្លា មានរបៀបដើរខាងមុខ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទា សុ មំ សត្តសតា ភរិយា សព្វាលង្ការភូសិតា**
**យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។**

*កាលណា ពួកស្រីស្នំ ៧០០ របស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទា សុ មំ សត្តសតា ភរិយា សុសញ្ញា តនុមជ្ឈិមា**
**យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។**

*កាលណា ពួកស្រីស្នំ ៧០០ របស់អញ ជាស្ត្រីសង្រួមល្អមានចង្កេះរៀវ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទា សុ មំ សត្តសតា ភរិយា អស្សវា បិយភាណិនី**
**យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។**

*កាលណា ពួកស្រីស្នំ ៧០០ របស់អញ ជាស្ត្រីស្តាប់បង្គាប់ពោលពាក្យជាទីស្រឡាញ់ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ បត្តំ គហេត្វាន មុណ្ឌោ សង្ឃាដិបារុតោ**

**បិណ្ឌិកាយ ចរិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អាត្មាអញនឹងបានទៅជាអ្នកកោរក្បាល ឃុំសង្ឃាដិ កាន់បាត្រ ត្រាច់ចរទៅបិណ្ឌបាត ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ បំសុកូលានំ ឧជ្ឈិតានំ មហាបថេ**
**សង្ឃាដឹ ធារយិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អាត្មាអញនឹងទ្រទ្រង់នូវសង្ឃាដិ នៃសំពត់បង្សុកូលទាំងឡាយ ដែលគេចោលក្នុងផ្លូវធំ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ សត្តាហំ មេឃេ ឱវុដ្ឋេ អល្លចីវរោ**
**បិណ្ឌិកាយ ចរិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អាត្មាអញ កាលដែលមេឃបង្អុរភ្លៀងចុះអស់ ៧ ថ្ងៃហើយ នឹងត្រាច់ទៅបិណ្ឌបាតទាំងចីវរទទឹក ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។*

**កទាហំ សព្វណ្ហំ គន្ត្វា រុក្ខា រុក្ខំ វនា វនំ**
**អនបេក្ខោ ចរិស្សាមិ តំ កទា សុ ភវិស្សតិ ។**

*កាលណា អាត្មាអញនឹងចេញទៅអំពីដើមឈើមួយ ទៅកាន់ដើមឈើមួយ អំពីព្រៃមួយទៅកាន់ព្រៃមួយ រហូតថ្ងៃ*

និងយប់ទាំងអស់ ត្រាច់ទៅឥតអាឡោះអាល័យ ដំណើរ
នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទាហំ គិរិទុគ្គេសុ បហីនភយភេរវោ
អទុតិយោ គមិស្សាមិ តំ កទា សុ ភវិស្សតិ ។

កាលណា អាត្មាអញនឹងលះបង់នូវភ័យគួរខ្លាច ហើយ
មិនមានគ្នាជាគម្រប់ពីរនាក់ ដើរទៅលើជ្រោះភ្នំទាំងឡាយ
ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទាហំ វីណារុជ្ជកោវ សត្តតន្តី មនោរមំ
ចិត្តំ ឧជុំ ករិស្សាមិ តំ កទា សុ ភវិស្សតិ ។

កាលណា អាត្មាអញធ្វើចិត្តឲ្យត្រង់ ដូចជាបុគ្គលដេញ
ពិណ អាចដេញខ្សែទាំង ៧ ឲ្យជាទីរីករាយចិត្តបាន
ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទាហំ រថការោវ បរិកន្តំ ឧបាហនំ
កាមសំយោជនេ ឆេច្ឆំ យេ ទិព្វេ យេ ច មានុសេ ។

កាលណា អាត្មាអញនឹងកាត់នូវកាមសំយោជន៍ជាទិព្វ
ទាំងជារបស់មនុស្សបាន ដូចជាជាងរថ ( ជាងស្បែក )
កាលកាត់នូវស្បែកជើងដូច្នោះ ។

បានឮថា ព្រះមហាសត្វកើតក្នុងកាលដែលមនុស្សមានអាយុ ១

ម៉ឺនឆ្នាំ សោយរាជសម្បត្តិបាន ៧០០០ ឆ្នាំ ទ្រង់បួសក្នុងកាលព្រះជន្មនៅសល់ប្រមាណ ៣០០០ ឆ្នាំ កាលទ្រង់បួស ទ្រង់បាននៅក្នុងយរាវាសវិស័យអស់ ៤ ខែ ចាប់តាំងពីកាលដែលបានទតឃើញដើមស្វាយ ត្រង់ទ្វារព្រះរាជឧទ្យាន ទ្រង់ព្រះតម្រិះថា ភេទបព្វជិត ប្រសើរជាងភេទព្រះរាជានេះ អញនឹងបួស ទើបត្រាស់បញ្ជាបុរសអ្នកបម្រើដោយសម្ងាត់ថា នែបា ចូរអ្នកនាំសំពត់ដែលជ្រលក់ទឹកម្ចត់និងបាត្រដី មកអំពីរានផ្សារ កុំឲ្យនរណាដឹង ។ រាជបុរសនោះ បានធ្វើតាមព្រះរាជតម្រាស់ ព្រះរាជាឲ្យហៅខ្មាន់ព្រះកេសមក ហើយដាក់ព្រះកេសានិងព្រះមស្សុ ព្រះរាជទានស្រុកសួយដល់ខ្មាន់ព្រះកេសហើយ ឲ្យត្រឡប់ទៅ ទ្រង់ស្លៀកសំពត់កាសាវៈមួយផ្ទាំង ទ្រង់ដណ្តប់មួយផ្ទាំង មួយផ្ទាំងទៀតពាក់ត្រង់ស្មា ដាក់បាត្រដីក្នុងស្បោកបាត្រ ហើយពាក់ត្រង់ចង្កួយស្មា ។ កាលនោះ ទ្រង់កាន់ឈើច្រត់ ចង្ក្រមទៅមកក្នុងប្រាសាទ ដោយបច្ចេកពុទ្ធលីលាអស់ថ្ងៃបន្តិចបន្តួច ។ ព្រះមហាសត្វទ្រង់ប្រថាប់ក្នុងប្រាសាទនោះឯងអស់ថ្ងៃនោះ លុះស្អែកឡើង ទ្រង់យាងចុះអំពីប្រាសាទក្នុងពេលព្រះអាទិត្យរះ ។

ក្នុងកាលនោះ ព្រះនាងសីវលីទេវី ត្រាស់ហៅស្ត្រីអ្នកស្និទ្ធស្នាល ៧០០ នាក់នោះមកថា ពួកយើងមិនបានឃើញព្រះរាជារបស់យើង ៤ ខែហើយថ្ងៃនេះ យើងទាំងឡាយនឹងនាំគ្នាទៅគាល់ទ្រង់ នាងទាំងឡាយ

គប្បីតាក់តែងគ្រឿងអលង្ការទាំងពួង សម្ដែងអាកប្បកិរិយារបស់ស្ត្រីដែលនាំឲ្យត្រេកអរ តាមកម្លាំង ព្យាយាមចងព្រះរាជាដោយចំណង គឺកិលេស ។ សូម្បីព្រះទេវី ក៏ព្រះនាងប្រដាប់តាក់តែងព្រះកាយ ហើយឡើងកាន់ប្រាសាទជាមួយស្ត្រីទាំងនោះ ដោយត្រិះរិះថា នឹងគាល់ព្រះរាជា សូម្បីទតឃើញព្រះរាជាកំពុងចុះ ក៏ព្រះនាងមិនស្គាល់ ថ្វាយបង្គំព្រះរាជា ហើយប្រថាប់ឈរក្នុងចំណែកម្ខាង ព្រោះព្រះនាងសម្គាល់ថាបព្វជិតនេះ ជាព្រះបច្ចេកពុទ្ធមកថ្វាយឱវាទដល់ព្រះរាជា ។ ចំណែកព្រះមហាសត្វ ក៏ចុះអំពីប្រាសាទ ។ ឯព្រះទេវី កាលព្រះនាងឡើងទៅកាន់ប្រាសាទ ទតឃើញព្រះកេសារបស់ព្រះរាជាមានពណ៌ដូចស្វាបកំភេមលើព្រះសិរីសយនា និងកញ្ចប់គ្រឿងអាភរណៈ ទើបមានព្រះសវនីយ៍ថា បព្វជិតនោះ មិនមែនព្រះបច្ចេកពុទ្ធ គឺជាព្រះរាជស្វាមីជាទីស្រឡាញ់របស់ពួកយើង មកនាងទាំងឡាយ យើងទាំងឡាយនឹងក្រាបទូលអង្វរឲ្យទ្រង់ត្រឡប់ ដូច្នេះហើយ ទើបយាងចុះអំពីប្រាសាទ ទាន់ព្រះរាជាត្រង់លានព្រះរាជវាំង ក៏រំសាយកេសាលើខ្នង មួយអន្លើដោយស្រីទាំងអស់ គក់ទ្រូងដោយដៃទាំងពីរ ក្រាបទូលថា បពិត្រមហារាជព្រោះហេតុអ្វី ទើបទ្រង់ធ្វើយ៉ាងនេះ ព្រះនាងខ្សឹកខ្សួល យាងតាមព្រះរាជាគួរអាណិតក្រៃលែង ។ កាលនោះ ព្រះនគរទាំងមូលក៏រំជើបរំជួលចំណែកអ្នកនគរទាំងនោះ ពោលថា បានឮថា ព្រះរាជារបស់ពួកយើង

ទ្រង់បួសហើយ ពួកយើងនឹងបានព្រះរាជាដែលតាំងនៅក្នុងធម៌បែបនេះ អំពីណា ហើយទ្រហោយំ ដើរតាមព្រះរាជាទៅ ។

ព្រះសាស្តា កាលទ្រង់ធ្វើឲ្យជាក់ច្បាស់នូវសំឡេងខ្សឹកខ្សួលរបស់ស្ត្រីទាំងនោះ និងភាពដែលព្រះរាជាទ្រង់លះបង់ស្ត្រីទាំងនោះ ដែលកំពុងយំ យាងទៅ ទើបត្រាស់ថា

តា ច សត្តសតា ភរិយា សព្វាលង្ការភូសិតា
ពាហា បគ្គយ្ហ បក្កន្ទុំ កស្មា នោ វិជហិស្សសិ ។

ពួកស្រីស្នំ ទាំង ៧០០ នាក់នោះ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ផ្គងដើមដៃទួញយំថា ព្រះអង្គនឹងលះចោលពួកខ្ញុំម្ចាស់ ព្រោះហេតុអ្វី ។

តា ច សត្តសតា ភរិយា សុសញ្ញា តនុមជ្ឈិមា
ពាហា បគ្គយ្ហ បក្កន្ទុំ កស្មា នោ វិជហិស្សសិ ។

ពួកស្រីស្នំ ៧០០ នាក់នោះ ជាស្ត្រីសង្រួមល្អ មានចង្កេះរៀវ ផ្គងដើមដៃទួញយំថា ព្រះអង្គនឹងលះចោលពួកខ្ញុំម្ចាស់ ព្រោះហេតុអ្វី ។

តា ច សត្តសតា ភរិយា អស្សវា បិយភាណិនី
ពាហា បគ្គយ្ហ បក្កន្ទុំ កស្មា នោ វិជហិស្សសិ ។

ពួកស្រីស្នំទាំង ៧០០ នាក់នោះ ជាស្ត្រីស្តាប់បង្គាប់ ពោល

*ពាក្យជាទីស្រឡាញ់ ផ្គងដើមដៃទួញយំថា ព្រះអង្គនឹងលះបោលពួកខ្ញុំម្ចាស់ ព្រោះហេតុអ្វី ។*

តា ច សត្តសតា ភរិយា សព្វាលង្ការភូសិតា

ហិត្វា សម្បទវី រាជា បព្វជ្ជាយ បុរក្ខិតោ ។

*ព្រះរាជាទ្រង់លះនូវសម្ប័ទ បានលះបង់ពួកស្រីស្នំទាំង ៧០០ នាក់នោះ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ព្រះអង្គត្រូវបព្វជ្ជាបញ្ជូនទៅខាងមុខហើយ ។*

តា ច សត្តសតា ភរិយា សុសញ្ញា តនុមជ្ឈិមា

ហិត្វា សម្បទវី រាជា បព្វជ្ជាយ បុរក្ខិតោ ។

*ព្រះរាជាទ្រង់លះបង់នូវសម្ប័ទ បានលះបង់ពួកស្រីស្នំ ៧០០ នាក់នោះ ជាស្រ្តីសង្រួមល្អ មានចង្កេះរៀវ ត្រូវបព្វជ្ជាបញ្ជូនទៅខាងមុខហើយ ។*

តា ច សត្តសតា ភរិយា អស្សវា បិយភាណិនី

ហិត្វា សម្បទវី រាជា បព្វជ្ជាយ បុរក្ខិតោ ។

*ព្រះរាជាទ្រង់លះបង់នូវសម្ប័ទ បានលះនូវពួកស្រ្តីស្នំ ៧០០ នាក់នោះ ជាស្រ្តីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ត្រូវបព្វជ្ជាបញ្ជូនទៅខាងមុខហើយ ។*

ហិត្វា សតបលុកំសំ សោវណ្ណំ សតរាជិកំ

អគ្គហិ មត្តិកាបត្តំ តំ ទុតិយាភិសេចនំ ។

*ព្រះរាជាទ្រង់លះបង់នូវភាជន៍មាស មានទម្ងន់មួយរយបល្ល: ប្រកបដោយស្នាមចម្លាក់មួយរយ បានកាន់យកនូវបាត្រដី ការកាន់នូវបាត្រដីនោះ ទុកជាអភិសេកទី ២ ។*

*សូម្បីព្រះនាងសីវលីទេវីទ្រង់ព្រះកន្សែង ក៏មិនអាចញ៉ាំងព្រះរាជាឲ្យយាងត្រឡប់បាន ព្រះនាងគិតថា មានឧបាយមួយ ទើបឲ្យហៅមហាសេនាគុត្តមកគាល់ ហើយត្រាស់ថា ចូរអ្នកទៅដុតភ្លើង គឺដុតផ្ទះចាស់ ៗ សាលាចាស់ ៗ ក្នុងចំណែកទិសខាងមុខដែលព្រះរាជាយាងទៅ ចូរប្រមូលស្មៅនិងស្លឹកឈើ នាំមកបំពក់ឲ្យមានផ្សែងក្នុងទីនោះ ៗ ។ មហាសេនាគុត្តបានធ្វើយ៉ាងនោះ ។ ព្រះនាងសីវលីទេវីយាងទៅកាន់សម្នាក់របស់ព្រះរាជា ក្រាបទៀបព្រះយុគលបាទ ហើយក្រាបទូលភាពដែលភ្លើងឆេះនគរមិថិលា ២ គាថាថា*

ភេស្មា អគ្គិសមាជាលា កោសា ឌយ្ហន្តិ ភាគសោ
រជតំ ជាតរូបញ្ច មុត្តា វេឡុរិយា ពហូ
មណយោ សង្ខមុត្តា ច វត្ថកំ ហរិចន្ទនំ
អជិនំ ឧន្តភណ្ឌញ្ច លោហំ កាឡាយសំ ពហុំ
ឯហិ រាជ និវត្តស្សុ មា តេ តំ វិនស្សា ធនំ ។

*ឃ្លាំងទាំងឡាយ គឺឃ្លាំងប្រាក់ ឃ្លាំងមាស ឃ្លាំងកែវមុក្តា ឃ្លាំង*

*កែវពិទូរ្យ ឃ្លាំងកែវមណី ឃ្លាំងស័ង្ខ ឃ្លាំងកែវមុក្តាដ៏ច្រើន ឃ្លាំងសំពត់ ឃ្លាំងខ្លឹមចន្ទន៍ក្រហម ឃ្លាំងស្បែកខ្លាឃ្មុំ ឃ្លាំងរបស់ធ្វើពីភ្លុក ឃ្លាំងទង់ដែង និងឃ្លាំងដែកខ្មៅដ៏ច្រើន ជាឃ្លាំងដែលរាជបុរសរៀបចំដោយចំណែក ត្រូវភ្លើងឆេះ មានអណ្តាតភ្លើងស្មើគ្នា គួរខ្លាច បពិត្រព្រះរាជា សូមព្រះអង្គស្តេចមក សូមស្តេចត្រឡប់វិលវិញ កុំឲ្យទ្រព្យរបស់ព្រះអង្គនោះ វិនាស ។*

*លំដាប់នោះ ព្រះមហាសត្វត្រាស់តបថា ម្នាលទេវី នាងនិយាយអ្វី កង្វល់របស់ពួកជនណា មាន កង្វល់នោះ រមែងត្រូវភ្លើងឆេះ តែយើងមិនមានកង្វល់ឡើយ កាលទ្រង់សម្តែងសេចក្តីនោះ ទើបត្រាស់ព្រះគាថាដូច្នេះថា*

**សុសុខំ វត ជីវាម យេសន្នោ នត្ថិ កិញ្ចនំ**
**មិថិលាយ ឌយ្ហមានាយ ន មេ កិញ្ចិ អឌយ្ហថ ។**

*កង្វល់មិនមានដល់យើងណា យើងនោះ ឈ្មោះថា រស់នៅជាសុខ កាលបើក្រុងមិថិលាត្រូវភ្លើងឆេះ ភ្លើងមិនមែនឆេះនូវទ្រព្យបន្តិចបន្តួចរបស់ខ្ញុំទេ ។*

*កាលត្រាស់យ៉ាងនេះហើយ ព្រះមហាសត្វបានយាងចេញតាមទ្វារទិសឧត្តរ ។ ភរិយាទាំង ៧០០ នោះ ក៏ចេញតាមព្រះរាជាទៅ ព្រះនាងសីវលីទេវី ក៏គិតរកឧបាយណាមួយទៀត ទើបត្រាស់បញ្ជាអាមាត្យ*

ទាំងឡាយថា ពួកលោក ចូរសម្ដែងហេតុការណ៍ ឲ្យដូចជាចោរសម្លាប់អ្នកស្រុក និងប្លន់ដែន ។ ខណៈនោះ មនុស្សទាំងឡាយ ក៏បង្ហាញពួកបុរសដែលកាន់អាវុធរត់មកអំពីទីនោះ ៗ ហាក់បីដូចជាត្រូវប្លន់ ស្រោចនូវទឹកល័ក្ខលើសរីរៈ ហាក់បីដូចត្រូវប្រហារ ឲ្យដេកលើបន្ទះក្ដារត្រូវទឹកបន្សាត់ទៅ ហាក់បីដូចជាស្លាប់ចំពោះព្រះភក្ត្រព្រះរាជា ។ មហាជនក្រាបទូលព្រះរាជាថា បពិត្រមហារាជ ពួកចោរប្លន់ដែន សម្លាប់ប្រជានុរាស្ត្ររបស់ព្រះអង្គ ទាំងដែលទ្រង់គង់ព្រះជន្មនៅ ។ លំដាប់នោះ ព្រះទេវីក៏ថ្វាយបង្គំព្រះរាជា ត្រាស់ព្រះគាថាដើម្បីឲ្យទ្រង់យាងត្រឡប់ថា

អដវិយោ សមុប្បន្នា    រដ្ឋំ វិទ្ធំសយន្តិ តេ

ឯហិ រាជ និវត្តស្សុ    មា រដ្ឋំ វិនស្សា ឥទំ ។

ចោរក្នុងដងព្រៃកើតឡើងហើយ បំផ្លាញដែនរបស់ព្រះអង្គ

បពិត្រព្រះរាជា សូមព្រះអង្គស្ដេចមក សូមស្ដេចត្រឡប់

វិលវិញ កុំឲ្យដែននេះ វិនាស ។

ព្រះរាជាស្ដាប់ដូច្នោះហើយ ទ្រង់ព្រះតម្រិះថា កាលយើងនៅមានជីវិត នឹងមិនកើតចោរប្លន់ទម្លាយនូវដែនឡើយ នេះជាការធ្វើរបស់ព្រះនាងសីវលី កាលទ្រង់ធ្វើឲ្យព្រះនាងទាល់ប្រាជ្ញា ទើបត្រាស់ថា

សុសុខំ វត ជីវាម    យេសន្នោ នត្ថិ កិញ្ចនំ

រដ្ឋេ វិលុម្បមានម្ហិ    ន មេ កិញ្ចិ អហារថ ។

កង្វល់មិនមានដល់យើងណា យើងនោះ ឈ្មោះថា រស់នៅជាសុខ កាលបើដែនត្រូវពួកចោរប្លន់ ចោរមិនបានយកទ្រព្យបន្តិចបន្តួចរបស់ខ្ញុំទេ ។

**សុសុខំ វត ជីវាម យេសន្នោ នត្ថិ កិញ្ចនំ**
**បីតិភក្ខា ភវិស្សាម ទេវា អាភស្សរា យថា ។**

កង្វល់មិនមានដល់យើងណា យើងនោះឈ្មោះថា រស់នៅជាសុខ យើងជាអ្នកមានបីតិជាអាហារ ដូចពួកអាភស្សរទេវតា ។

កាលព្រះរាជាត្រាស់យ៉ាងនេះហើយ មហាជនក៏នៅតែទៅតាមព្រះអង្គដដែល ។ ព្រះមហាសត្វទ្រង់ព្រះតម្រិះថា មហាជនទាំងនេះមិនប្រាថ្នាត្រឡប់ អញនឹងឲ្យមហាជននោះ ត្រឡប់ ។ កាលទ្រង់ធ្វើដំណើរទៅបានកន្លះគាវុត ទ្រង់ក៏ឈប់សម្រាក ប្រថាប់ឈរក្នុងផ្លូវធំត្រាស់សួរអាមាត្យទាំងឡាយថា រាជសម្បត្តិនេះ ជារបស់អ្នកណា ។

អាមាត្យទាំងឡាយក្រាបទូលថា ជារបស់ព្រះអង្គ ។

ព្រះរាជាត្រាស់ថា បើដូច្នោះ អ្នកទាំងឡាយ ចូរដាក់រាជទណ្ឌដល់បុគ្គលណាដែលធ្វើស្នាមគំនូសនេះ ឲ្យរលុប ដូច្នេះហើយ ទ្រង់យកឈើច្រត់គូស ធ្វើឲ្យមានស្នាមទទឹងផ្លូវ ។ បុគ្គលណាម្នាក់ ក៏មិនហ៊ានធ្វើស្នាមគំនូសដែលព្រះរាជាអ្នកមានតេជះ ទ្រង់បានគូស ឲ្យរលុបឡើយ ។

មហាជនធ្វើស្នាមគំនូសជិតក្បាល ទ្រហោយំ ។ ព្រះនាងសីវលីក៏មិនអាចធ្វើស្នាមគំនូសឲ្យរលុបបាន ទតឃើញព្រះរាជាបែរខ្នងយាងទៅ មិនអាចអត់ធន់នូវសេចក្ដីសោកបាន គក់ទ្រូង ផ្ដួលខ្លួនបម្រះនទៀលទៅវិញទៅមកលើផ្លូវធំ ហើយយាងទៅ ។ មហាជនពោលថា ម្ចាស់របស់ស្នាមគំនូសបានទម្លាយនូវស្នាមគំនូសហើយ ទើបនាំគ្នាតាមព្រះរាជាទៅតាមមាគ៌ាដែលព្រះទេវីយាងទៅនោះឯង ។ ព្រះមហាសត្វបែរព្រះភក្ត្រទៅកាន់ហិមវន្តប្បទេសនាទិសឧត្តរ ចំណែកព្រះនាងសីវលីក៏នាំពលសេនាពាហនៈទាំងពួងតាមព្រះរាជាទៅដែរ ។ ព្រះរាជាទ្រង់មិនអាចឲ្យមហាជនត្រឡប់បាន ទ្រង់យាងទៅអស់ផ្លូវប្រមាណ ៦០ យោជន៍ ។

ក្នុងកាលនោះ មានតាបសមួយរូបឈ្មោះនារទៈ នៅត្រង់សុវណ្ណ-គុហា ក្នុងហិមវន្តប្បទេស ឲ្យពេលវេលាកន្លងទៅដោយសេចក្ដីសុខដែលកើតអំពីឈាន ដែលសម្បយុត្តដោយអភិញ្ញា ៥ កន្លងទៅ ៧ ថ្ងៃ ក៏ចេញអំពីឈានសុខ បន្លឺឧទានថា ឱសុខហ្ន៎ ! ឱសុខហ្ន៎ ! ហើយរំពឹងមើលសត្វលោកដោយទិព្វចក្ខុថា មានបុគ្គលណា ក្នុងជម្ពូទ្វីប ស្វែងរកសេចក្ដីសុខនេះដែរឬទេ ឃើញព្រះមហាជនកដែលជាពុទ្ធង្កុរ ទើបគិតថា ព្រះមហាជនកនេះ ជាព្រះរាជាចេញមហាភិនេស្ក្រមណ៍ មិនអាចញ៉ាំងមហាជននិងពួករាជបរិវារ មានព្រះនាងសីវលីជាប្រធាន ឲ្យត្រឡប់ទៅនគរបាន រាជបរិវារនោះ គប្បីធ្វើអន្តរាយដល់ព្រះអង្គ អញនឹងថ្វាយ

ឱវាទដល់ព្រះអង្គ ដើម្បីឲ្យទ្រង់សមាទានឲ្យមាំមួនក្រៃលែង ទើបទៅដោយកម្លាំងឫទ្ធិ ស្ថិតនៅក្នុងអាកាសចំពោះព្រះភក្ត្រព្រះរាជា ពោលគាថាឲ្យទ្រង់កើតនូវឧស្សាហៈថា

**កិម្ហេសោ មហតោ ឃោសោ កា នុ គាមេវ កីឡិយា**
**សមណា តេវ បុច្ឆាមិ កត្ថេសោ អភិសដោ ជនោ ។**

សំឡេងគឹកកងនៃជនច្រើននេះ តើព្រោះហេតុអ្វី ស្រ្តីនោះជាអ្វី លេងជាមួយក្នុងព្រៃ ដូចក្នុងស្រុក បពិត្រសមណៈ ខ្ញុំសួរលោកថា មហាជនទ្រុំះ ប្រជុំគ្នាដើម្បីអ្វី ។

ព្រះរាជាទ្រង់បានស្តាប់ពាក្យរបស់តាបសនោះហើយ ត្រាស់ថា

**មមំ ឱហាយ គច្ឆន្តំ ឯត្ថេសោ អភិសដោ ជនោ**
**សីមាតិក្កមនំ យន្តំ មុនិមោនស្ស បត្តិយា**
**មិស្សំ នន្ទីហិ គច្ឆន្តំ កឹ ជានមនុបុច្ឆសិ ។**

ខ្ញុំកាលលះបង់នូវមហាជន ហើយចេញទៅ បានជាមហាជនប្រជុំគ្នាក្នុងទីនេះ ខ្ញុំកន្លងនូវដែនគឺកិលេស ហើយទៅបួសដើម្បីបាននូវមោនធម៌ ( ពោលគឺញាណរបស់អនាគារិយៈ ) មុនី ខ្ញុំកាលទៅកាន់ទីច្រឡូកច្រឡំ ដោយសេចក្តីរីករាយទាំងឡាយ អ្នកដឹងទើបសួរឬ ( ឬមិនដឹង ) ។

លំដាប់នោះ នារទតាបសបានពោលគាថាទៀត ដើម្បីឲ្យព្រះ

មហាសត្វសមាទានឲ្យមាំមួនថា

មាស្សុ តិណ្ណោ អមញ្ញិត្ថោ សរីរំ ធារយំ ឥមំ
អតីរណេយ្យមិទំ កម្មំ ពហូ ហិ បរិបន្ថយោ ។

ព្រះអង្គ កាលទ្រទ្រង់នូវសរីរៈនេះ កុំសម្គាល់ថា អញឆ្លង កិលេសហើយដូច្នេះ កម្ម ( គឺកិលេស ) នេះ បុគ្គលមិនគប្បី ឆ្លងបានទេ ព្រោះថា សេចក្តីអន្តរាយមានច្រើន ។

បន្ទាប់អំពីនោះ ព្រះមហាសត្វបានស្តាប់ពាក្យនោះហើយ កាលនឹងត្រាស់សួរអំពីសេចក្តីអន្តរាយ ទើបពោលគាថាថា

កោ នុ មេ បរិបន្ថស្ស មម ឯវំ វិហារិនោ
យោ នេវ ទិដ្ឋេ នាទិដ្ឋេ កាមានមភិបត្ថយេ ។

ខ្ញុំណា មិនប្រាថ្នានូវកាមទាំងឡាយក្នុងមនុស្សលោក ដែលបុគ្គលឃើញហើយ មិនប្រាថ្នានូវកាមទាំងឡាយក្នុងទេវលោក ដែលបុគ្គលមិនឃើញហើយ សេចក្តីអន្តរាយដូចម្តេចហ្ន៎ នឹងមានដល់ខ្ញុំនោះ មានកិរិយានៅយ៉ាងនេះ ។

លំដាប់នោះ នារទតាបស កាលសម្តែងអន្តរាយទាំងឡាយដល់ព្រះមហាសត្វ ទើបពោលគាថាដូច្នេះថា

និទ្ទា តន្ទិ វិជម្ភិតា អរតិ ភត្តសម្មទោ
អាវសន្តិ សរីរដ្ឋា ពហូ ហិ បរិបន្ថយោ ។

ដ្បិតថា សេចក្តីអន្តរាយតាំងឡើងច្រើន គឺការដេកលក់ សេចក្តីខ្ជិល ការមិតពត់ សេចក្តីអផ្សុក ការពុលបាយ តាំងនៅក្នុងសរីរៈ រមែងកើត ( ក្នុងសរីរៈវិញ ) ។

លំដាប់នោះ ព្រះមហាសត្វ កាលទ្រង់សរសើរនារទតាបសនោះ ទើបត្រាស់គាថាដូច្នេះថា

**កល្យាណំ វត មំ ភវំ ព្រាហ្មណ អនុសាសសិ**
**ព្រាហ្មណ ត្វេវ បុច្ឆាមិ កោ នុ ត្វមសិ មារិស ។**

បពិត្រព្រាហ្មណ៍ លោកដ៏ចម្រើនប្រៀនប្រដៅខ្ញុំល្អណាស់ បពិត្រព្រាហ្មណ៍ ខ្ញុំសួរលោក បពិត្រលោកនិរទុក្ខ លោកជាអ្វី ។

លំដាប់នោះ នារទតាបសពោលថា

**នារទោ ឥតិ នាមេន កស្សបោ ឥតិ មំ វិទូ**
**ភោតោ សកាសេ អាគច្ឆឹ សាធុ សព្ភិ សមាគមោ ។**

ជនទាំងឡាយស្គាល់អាត្មាភាពដោយនាមថា នារទៈ ដោយគោត្តថា កស្សបៈ ដូច្នេះ អាត្មាភាពមកក្នុងសម្នាក់ព្រះអង្គដ៏ចម្រើន ដោយដឹងច្បាស់ថា សមាគមដោយសប្បុរសទាំងឡាយ ជាកិច្ចញុំាងប្រយោជន៍ឲ្យសម្រេច ។

**តស្ស តេ សព្វោ អានន្ទោ វិហារោ ឧបវត្តតុ**

**យច្ឆន្ទំ តំ បរិបូរេហិ ខន្តិយា ឧបសមេន ច ។**

*សេចក្តីត្រេកអរ ( ក្នុងបព្វជ្ជា ) ទាំងអស់ និងព្រហ្មវិហារ ចូរកើតដល់ព្រះអង្គនោះចុះ បរិកម្មនិងឈានណា ការខ្វះខាត ( ដោយសីលនិងឈាន ) ណា ព្រះអង្គចូរបំពេញនូវការខ្វះខាតនោះចុះ ព្រះអង្គ ( ចូរប្រកប ) ដោយអធិវាសនក្ខន្តី និងឧបសមៈ ។*

**បសារយ សន្នតញ្ច ឧន្នតញ្ច បហារយ**
**កម្មំ វិជ្ជញ្ច ធម្មញ្ច សក្កត្វាន បរិព្វជ ។**

*ព្រះអង្គ ចូររំសាយចោលនូវសេចក្តីមើលងាយ និងសេចក្តីក្រអឺតក្រឱង ចូរធ្វើគោរពនូវកុសលកម្ម នូវវិជ្ជា និងធម៌ ។*

*នារទតាបសថ្វាយឱវាទដល់ព្រះមហាសត្វយ៉ាងនេះហើយ ត្រឡប់ទៅកាន់លំនៅរបស់ខ្លួនតាមអាកាស ។ កាលនារទតាបសទៅហើយ មានតាបសមួយរូបទៀត ឈ្មោះមិគាជិនៈ ចេញអំពីសមាបត្តិ ត្រួតមើលលោកសន្និវាស ឃើញព្រះមហាសត្វ ទើបមកហើយដូចគ្នា ដោយគិតថា អញនឹងថ្វាយឱវាទ ដើម្បីប្រយោជន៍ឲ្យមហាជនត្រឡប់ទៅនគរ ទើបស្ថិតនៅក្នុងអាកាស បង្ហាញខ្លួនឲ្យប្រាកដ ហើយពោលថា*

**ពហូ ហត្ថី ច អស្សេ ច នគរេ ជនបទានិ ច**
**ហិត្វា ជនក បព្វជិតោ កបាលេ រតិមជ្ឈគា**

កច្ចិ នុ តេ ជានបទា មិត្តាមច្ចា ច ញាតកា
ទុភី អកំសុ ជនក កស្មា តេ តំ អរុច្ចថ ។

បពិត្រព្រះជនក ព្រះអង្គលះបង់ដំរី សេះ ពួកអ្នកនគរ និងជនបទជាច្រើន ហើយទ្រង់ព្រះផ្នួស ដល់នូវសេចក្ដីត្រេកអរនឹងអំបែង បពិត្រព្រះជនក ពួកអ្នកជនបទ មិត្តអាមាត្យ និងព្រះញាតិ បានធ្វើនូវការទ្រុស្តចំពោះព្រះអង្គខ្លះដែរឬ ព្រោះហេតុអ្វី ក៏ព្រះអង្គពេញព្រះហឫទ័យ នឹងអំបែងរបស់ព្រះអង្គនោះ ។

បន្ទាប់អំពីនោះ ព្រះមហាសត្វត្រាស់ថា

ន មិគាជិន ជាតុច្ចេ អហំ កញ្ចិ កុទាចនំ
អធម្មេន ជិនេ ញាតឹ ន ចាបិ ញាតយោ មមំ ។

បពិត្រមិគាជិនៈ ក្នុងកាលណាមក ខ្ញុំមិនដែលផ្ចាញ់នូវញាតិណាមួយ ដោយអធម៌ជាដាច់ខាត ទាំងពួកញាតិ ក៏មិនដែលផ្ចាញ់ខ្ញុំដោយអធម៌ដែរ ។

ព្រះមហាសត្វទ្រង់ឃាត់នូវបញ្ហានៃមិគាជិនតាបសនោះ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងហេតុនៃការបួស ទើបត្រាស់ថា

ទិស្វាន លោកវត្តន្តំ ខជ្ជន្តំ កទ្ទមីកតំ
ហញ្ញរេ វជ្ឈរេ ចេត្ថ យត្ថ សន្នោ បុថុជ្ជនោ

**ឯតាហំ ឧបមំ កត្វា ភិក្ខុកោស្មិ មិគាជិន ។**

*បពិត្រមិគាជិនៈ ខ្ញុំបានឃើញនូវប្រវេណីនៃសត្វលោក ដែលកិលេសកំពុងទំពាស៊ី ធ្វើឲ្យដូចជាភក់ បុថុជ្ជនលិចចុះហើយក្នុងកិលេសវត្ថុណា សត្វទាំងឡាយតែងបៀតបៀនគ្នាផង តែងជាប់ក្នុងកិលេសវត្ថុនោះផង ហើយក៏ធ្វើនូវពួកបុថុជ្ជនទាំងនេះ ឲ្យជាគ្រឿងប្រៀបធៀប ទើបបួសជាភិក្ខុ ។*

*តាបសនោះ ប្រាថ្នានឹងស្តាប់ហេតុការណ៍នោះ ដោយពិស្តារ ទើបពោលគាថាដូច្នេះថា*

**កោ នុ តេ ភគវា សត្ថា កស្សេតំ វចនំ សុចឹ**

**ន ហិ កប្បំ វា វិជ្ជំ វា បច្ចក្ខាយ រថេសភ**

**សមណាមាហុ វត្តន្តំ យថា ទុក្ខស្សតិក្កមោ ។**

*បពិត្រព្រះអង្គប្រសើរក្នុងរថ បុគ្គលមានជោគណា ជាសាស្តារបស់ព្រះអង្គ ពាក្យដ៏ពីរោះនេះ ជាពាក្យរបស់បុគ្គលណា ព្រោះថា អ្នកប្រាជ្ញទាំងឡាយមិនរៀរនូវតាបស អ្នកសម្រេចអភិញ្ញា ឬនូវព្រះបច្ចេកពុទ្ធដែលប្រកបដោយវិជ្ជា ហើយពោលនូវសមណៈថា អ្នកមានវត្តជាគ្រឿងកន្លងនូវទុក្ខទេ ។*

*លំដាប់នោះ ព្រះមហាសត្វពោលថា*

**ន មិគាជិន ជាតុច្ឆេ អហំ កញ្ចិ កុទាចនំ**

សមណំ ព្រាហ្មណំ វាបិ សក្កត្វា អនុចារិសំ ។

*បពិត្រមិគាជិនៈ ខ្ញុំមិនដែលចូលទៅគោរពសមណៈ និងព្រាហ្មណ៍ណាមួយ ដោយដាច់ខាត ក្នុងកាលណាម្តងឡើយ (១) ។*

*ព្រះមហាសត្វ កាលត្រាស់យ៉ាងនេះហើយ ទើបពោលគាថាដើម្បីទ្រង់សម្តែងហេតុដែលទ្រង់បួស តាំងអំពីដើមថា*

មហតា ចានុភាវេន គច្ឆន្តោ សិរិយា ជលំ
គីយមានេសុ គីតេសុ វជ្ជមានេសុ វគ្គុសុ
តូរិយតាឡសង្ឃុដ្ឋេ សម្មតាលសមាហិតេ
សមិគាជិនមទ្ទក្ខឹ ផលឹ អម្ពំ តិរោច្ឆទំ
តុជមានំ មនុស្សេហិ ផលកាមេហិ ជន្តុភិ
សោ ខោ ហន្តំ សិរឹ ហិត្វា ឱរោហិត្វា មិគាជិន
មូលំ អម្ពស្សុបាគញ្ឆឹ ផលិនោ និប្ផលស្ស ច
ផលឹ អម្ពំ ហតំ ទិស្វា វិទ្ធត្ថំ វិនលីកតំ
អថេតំ ឥតរំ អម្ពំ នីលោភាសំ មនោរមំ

---

*១-ព្រះមហាសត្វ សូម្បីស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះបច្ចេកពុទ្ធទាំងឡាយ ក៏មិនសួរគុណនៃបព្វជ្ជាដោយចំពោះ ក្នុងកាលណាឡើយ ព្រោះហេតុនោះទើបត្រាស់យ៉ាងនេះ ។*

ឯវមេវ ឆ្ងួនម្ហូបិ ឥស្សរេ ពហុកណ្ដកោ
អមិត្តា នោ វធិស្សន្តិ យថា អម្ពោ ផលី ហតោ
អជិនម្ហិ ហញ្ញតេ ទីបិ នាគោ ទន្តេហិ ហញ្ញតិ
ធនម្ហិ ធនិនោ ហន្តិ អនិកេតមសន្ថវំ
ផលី អម្ពោ អផលោ ច តេ សត្ថារោ ឧភោ មម ។

*បពិត្រមិគាជិនៈ ខ្ញុំកាលទៅ ដោយអានុភាពដ៏ធំ រុងរឿងដោយសិរី កាលចម្រៀងដែលបុគ្គលកំពុងច្រៀង កាលតន្ត្រីមានសំឡេងដ៏ពីរោះ ដែលបុគ្គលកំពុងប្រគំ បានឃើញស្វាយមានផ្លែខាងក្រៅកំពែង ដែលពួកមនុស្សអ្នកត្រូវការផ្លែ បេះផិតឧទ្យាន ដែលគឹកកងដោយការប្រគំតន្ត្រី ជាឧទ្យានប្រកបដោយសូរប្រគំដ៏ពីរោះ បពិត្រមិគាជិនៈ ខ្ញុំនោះបានលះបង់សិរីនោះ ហើយចុះ ( អំពីដំរី ) ចូលទៅកាន់គល់ស្វាយដែលមានផ្លែ និងមិនមានផ្លែ បានឃើញស្វាយមានផ្លែ ដែលបុគ្គលបៀតបៀនហើយ កម្ទាត់ហើយ ធ្វើមិនឲ្យមានស្លឹក និងស្វាយ ១ ដើមក្រៅនេះ មានពន្លឺខៀវ ជាទីរីករាយនៃចិត្ត សត្រូវទាំងឡាយ អាចសម្លាប់យើងដែលជាឥស្សរៈ មានបន្លាច្រើន ដោយពិត ដូចដើមស្វាយដែលមានផ្លែ ដែលបុគ្គលសម្លាប់ហើយ ខ្លាដំបងត្រូវគេសម្លាប់ព្រោះស្បែក ដំរីត្រូវគេ*

សម្លាប់ព្រោះភ្នក បុគ្គលអ្នកមានទ្រព្យ ត្រូវគេសម្លាប់ព្រោះទ្រព្យ តើនរណានឹងសម្លាប់បុគ្គលអ្នកមិនមានផ្ទះ មិនមានសន្ធវៈ ដើមស្វាយមានផ្លែ និងមិនមានផ្លែទាំងពីរនោះ ជាសាស្ដារបស់ខ្ញុំ ។

មិគាជិនតាបសបានស្ដាប់ដូច្នោះហើយ ទើបថ្វាយឱវាទដល់ព្រះរាជាថា សូមទ្រង់ជាអ្នកមិនប្រមាទចុះ ហើយត្រឡប់ទៅកាន់លំនៅរបស់ខ្លួននោះឯង ។ កាលមិគាជិនតាបសទៅហើយ ព្រះនាងសីវលីទេវីក្រាបចុះទៀបព្រះយុគលបាទរបស់ព្រះរាជា ក្រាបទូលថា

សញ្ញោ ជនោ សព្យាជិតោ រាជា បព្វជិតោ ឥតិ
ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
អស្សាសយិត្វា ជនតំ បបយិត្វា បដិច្ឆជំ
បុត្តំ រជ្ជេ បបេត្វាន អថ បច្ឆា បព្វជិស្សសិ ។

ជនទាំងពួង គឺសេនាដំរី ពលសេះ ពលរថ ពលថ្មើរជើងបានព្ទថា ព្រះរាជាទ្រង់ផ្នួសហើយ ក៏តក់ស្លុត សូមព្រះអង្គលួងលោមនូវប្រជុំជន ហើយតាំងទុកនូវការរក្សា រួចតាំងព្រះរាជឱរសក្នុងរាជសម្បត្តិ ហើយសឹមទ្រង់ព្រះផ្នួសក្នុងកាលជាខាងក្រោយចុះ ។

លំដាប់នោះ ព្រះពោធិសត្វត្រាស់ថា

ចត្តា មយា ជានបទា មិត្តាមច្ចា ច ញាតកា
សន្តិ បុត្តា វិទេហានំ ទីឃាវុ រដ្ឋវឌ្ឍនោ
តេ រជ្ជំ ការយិស្សន្តិ មិថិលាយំ បជាបតិ ។

*ពួកអ្នកជនបទ មិត្តអាមាត្យនិងញាតិទាំងឡាយ ដែលយើងលះបង់ហើយ កូនរបស់អ្នកដែនវិទេហៈ ឈ្មោះទីឃាវុកុមារ អ្នកញុំាងដែនឲ្យចម្រើន ម្នាលបជាបតិ កូននោះនឹងសោយរាជ្យ ក្នុងក្រុងមិថិលាចុះ ។*

*លំដាប់នោះ ព្រះនាងសីវលីទេវីក្រាបទូលព្រះមហាសត្វថា* ទេវ តុម្ហេសុ តាវ បព្វជិតេសុ អហំ កឹ ករោមិ *បពិត្រព្រះសម្មតិទេព បើទ្រង់បួសហើយ ខ្ញុំម្ចាស់នឹងធ្វើអ្វី ។*

*លំដាប់នោះ ព្រះមហាសត្វត្រាស់ថា* ភទ្ទេ អហំ តំ អនុសិក្ខាមិ វចនំ មេ ករោហិ *ម្នាលនាងដ៏ចម្រើន អាត្មាឲ្យនាងសិក្សាតាម ចូរនាងធ្វើតាមពាក្យរបស់អាត្មា ហើយត្រាស់ថា*

ឯហិ តំ អនុសិក្ខាមិ យំ វាក្យំ មម រុច្ចតិ
រជ្ជំ តុវំ ការយន្តី បាបំ ទុច្ចរិតំ ពហុំ
កាយេន វាចា មនសា យេន គច្ឆសិ ទុគ្គតឹ
បរទិន្នកេន បរនិដ្ឋិតេន បិណ្ឌេន យាបេមិ ស ធីរធម្មោ ។

*នាងចូរមកនេះ ពាក្យណាដែលអាត្មាពេញចិត្ត អាត្មានឹងប្រាប់*

នូវពាក្យនោះ នាងនឹងទៅកាន់ទុគ្គតិ ដោយកាយ វាចា ចិត្ត ណា នាងឯងកាលសោយរាជ្យ (ឈ្មោះថាធ្វើ) នូវបាបទុច្ចរិត ដ៏ច្រើន ដោយកាយ វាចា ចិត្តនោះ អាត្មានឹងញ៉ាំងអត្តភាពឲ្យ ប្រព្រឹត្តទៅដោយដុំបាយ ដែលបុគ្គលដទៃឲ្យហើយ ដែលបុគ្គល ដទៃសម្រេចហើយ (នេះ) ជាបវេណីរបស់អ្នកប្រាជ្ញ ។

ព្រះមហាសត្វបានប្រទានឱវាទដល់ព្រះនាង ដោយប្រការដូច្នេះ ។ កាលក្សត្រទាំងពីរត្រាស់ឆ្លើយឆ្លងគ្នាយាងទៅ ព្រះអាទិត្យក៏អស្តង្គត ។ ព្រះទេវីត្រាស់ឲ្យបោះនូវជំរំក្នុងទីដែលសមគួរ ។ ព្រះមហាសត្វទ្រង់ សម្រាកត្រង់គល់ឈើមួយកន្លែង ប្រថាប់ក្នុងទីនោះអស់រាត្រី ស្អែកឡើង ទ្រង់ធ្វើសរីរកិច្ចហើយ យាងទៅតាមមាគ៌ា ។ ចំណែកព្រះទេវីត្រាស់ថា នៃអ្នកទាំងឡាយ ចូរទៅតាមអំពីក្រោយ (ព្រះរាជា) ហើយទៅអំពី ខាងក្រោយព្រះមហាសត្វ ក្សត្រទាំងពីរទៅដល់នគរមួយឈ្មោះថូណៈ ក្នុងពេលភិក្ខាចារ ។ ខណៈនោះ មានបុរសម្នាក់នៅខាងក្នុងនគរ ទិញ សាច់មួយដុំធំអំពីទីដែលសម្លាប់ ហើយយកឈើស្រួចដោតអាំងលើរងើក ភ្លើងឲ្យឆ្អិន ដាក់លើក្តារដើម្បីឲ្យត្រជាក់ ហើយឈរ ។ កាលបុរសនោះ បញ្ជូនចិត្តទៅកាន់ទីដទៃ ឆ្កែមួយពាំដុំសាច់នោះ រត់ទៅ បុរសនោះ ដឹង ហើយដេញតាមឆ្កែនោះ ទៅដល់ខាងក្រៅទ្វារនគរទិសទក្សិណ អស់ អាល័យ ក៏ត្រឡប់ចូលស្រុក ។ ព្រះរាជានិងព្រះទេវីយាងមកអំពីខាង

មុខសុនខ ដល់ផ្លូវបែកជាពីរ សុនខនោះ ក៏ទម្លាក់ដុំសាច់ រត់គេចទៅដោយសេចក្ដីភ័យខ្លាច ។

ព្រះមហាសត្វទតឃើញដុំសាច់នោះ ទ្រង់ព្រះតម្រិះថា ឆ្កែនេះចោលដុំសាច់នេះ មិនសម្លឹងមើល រត់ទៅ សូម្បីអ្នកដទៃជាម្ចាស់ ក៏មិនប្រាកដ អាហារបែបនេះ មិនមានទោស ឈ្មោះថា បំសុកូលបិណ្ឌបាត អញនឹងបរិភោគដុំសាច់នោះ ទើបទ្រង់នាំបាត្រដីចេញមក កាន់យកដុំសាច់នោះ បោសនូវធូលីដែលប្រឡាក់ហើយដាក់ក្នុងបាត្រ យាងទៅកាន់ទីដែលមានទឹកបរិបូណ៌ ទ្រង់ពិចារណាហើយ ផ្ដើមសោយនូវដុំសាច់នោះ ។ លំដាប់នោះ ព្រះទេវីទ្រង់ព្រះចិន្ដាថា បើព្រះរាជានេះទ្រង់នៅមានបំណងក្នុងរាជសម្បត្តិ មិនគប្បីសោយដុំសាច់ដែលគួរខ្ពើមបែបនេះទេ តែទ្រង់សោយដុំសាច់ដែលគួរខ្ពើម ប្រឡាក់ធូលីបែបនេះជារបស់សល់អំពីសុនខ ។ ឥឡូវនេះ ទ្រង់មិនមែនព្រះរាជស្វាមីរបស់អញឡើយ ព្រះនាងព្រះតម្រិះដូច្នេះហើយ ទើបក្រាបទូលថា បពិត្រមហារាជ កោតតែព្រះអង្គសោយសាច់ដែលគួរខ្ពើមបែបនេះ បាន ។

ព្រះមហាសត្វត្រាស់ថា ម្នាលទេវី នាងមិនស្គាល់ភាពវិសេសរបស់បិណ្ឌបាតនេះ ព្រោះល្ងង់ខ្លៅ ត្រាស់ដូច្នេះហើយ ទ្រង់ពិចារណាទីដែលដុំសាច់នោះធ្លាក់ចុះ សោយដុំសាច់នោះ ដូចសោយអមតរស ខ្ពុរព្រះឱស្ឋ លាងព្រះហស្ដនិងព្រះបាទហើយ ។ ក្នុងខណៈនោះ ព្រះ

*ទេវី កាលតិះដៀលព្រះរាជា ទើបត្រាស់ថា*

យោបិ ចតុត្ថេ ភត្តកាលេ ន កុញ្ជេ
អជ្ឈុជ្ជមារីវ ឩធាយ មិយ្យេ
ន ត្វេវ បិណ្ឌំ លុលិតំ អនរិយំ
កុលបុត្តរូបោ សប្បុរិសោ ន សេវេ
តយិទំ ន សាធុ តយិទំ ន សុដ្ឋុ
សុនខុច្ឆិដ្ឋកំ ជនក ភុញ្ជសេ តុវំ ។

*បុគ្គលណា មិនបរិភោគអាហារក្នុងកាលនៃភត្ត ជាគម្រប់ ៤ បុគ្គលនោះ គប្បីស្លាប់ដោយសេចក្ដីស្រេកឃ្លាន ដូចបុគ្គលដល់នូវសេចក្ដីស្លាប់ដ៏ពិត មានសភាពជាកុលបុត្ត មិនគប្បីបរិភោគដុំបាយ ដែលប្រឡាក់ដោយធូលីមិនស្អាតទេ ឬការបរិភោគនោះ មិនល្អទេ មិនប្រសើរទេ បពិត្រមហាជនក ព្រះអង្គសោយនូវដុំបាយដែលសល់អំពីឆ្កែ ។*

*ព្រះមហាសត្វត្រាស់តបថា*

ន ចាបិ មេ សីវលី សោ អភក្ខោ
យំ ហោតិ ចត្តំ គិហិនោ សុនខស្ស វា
យេ កេចិ ភោគា ឥធ ធម្មលទ្ធា
សព្វោ សោ ភក្ខោ អនវយោតិ វុត្តោ ។

*ម្នាលសីវលី វត្ថុណាដែលគ្រហស្ថ ឬសុនខលះបង់ហើយ វត្ថុនោះ មិនមែនជាអាត្មាមិនគួរឆាន់ទេ ភោគៈទាំងឡាយណាទីមួយ ក្នុងលោកនេះ ដែលបានដោយធម៌ ភោគៈទាំងអស់នោះ លោកពោលថា ជាអាហារមិនមានទោស ។*

*កាលក្សត្រទាំងពីរអង្គសន្ទនាគ្នាយ៉ាងនេះ ទ្រង់ក៏យាងដល់ទ្វារថូណនគរ កាលទារកទាំងឡាយកំពុងលេងក្នុងនគរនោះ មានទារិកាម្នាក់យកចង្អេរតូចអុំខ្សាច់លេង ។ កងដៃមួយពាក់ត្រង់កដៃម្ខាងរបស់នាង កងដៃពីរពាក់ត្រង់កដៃម្ខាងទៀត ។ កងដៃពីរនោះ ទង្គិចគ្នាមានសំឡេង កងដៃមួយទៀត មិនមានសំឡេង ។ ព្រះរាជាទ្រង់ជ្រាបហេតុនោះ ទើបព្រះតម្រិះថា ឥឡូវនេះ នាងសីវលីមកតាមក្រោយអញ ឈ្មោះថា ស្ត្រី រមែងជាមន្ទិលរបស់បព្វជិត ជនទាំងឡាយឃើញនាងមកតាមអញ នឹងតិះដៀលថា បព្វជិតនេះ សូម្បីបួសហើយ ក៏មិនអាចលះភរិយាបាន បើកុមារីនេះ ឈ្លាសវៃ នឹងពោលដល់ហេតុឲ្យនាងសីវលីត្រឡប់ អញនឹងស្តាប់ពាក្យរបស់កុមារីនេះ ហើយបញ្ជូននាងសីវលីត្រឡប់ ទ្រង់ព្រះតម្រិះដូច្នេះហើយ យាងទៅក្បែរកុមារីនោះ កាលនឹងសួរ ទើបត្រាស់គាថានេះថា*

**កុមារិកេ ឧបសេនិយេ និច្ចំ និគ្គលមណ្ឌិតេ**

**កស្មា តេ ឯកោ ភុជោ ជនតិ ឯកោ តេន ជនតី ភុជោ ។**

ម្នាលនាងកុមារិកា ជាក្មេងដេកជិតមាតានៅឡើយ មានគ្រឿងប្រដាប់មិនឃ្លាតអំពីខ្លួនជានិច្ច ដៃម្ខាងរបស់នាងលាន់ឮសំឡេង ដៃម្ខាងមិនលាន់ឮសំឡេង តើព្រោះហេតុអ្វី ។

នាងកុមារិកាពោលថា

ឥមស្មិំ មេ សមណ ហត្ថេ   បដិមុក្កា ទុនីវរា
សង្ឃដ្ដា ជាយតេ សទ្ទោ   ទុតិយស្សេវ សា គតិ
ឥមស្មិំ មេ សមណ ហត្ថេ   បដិមុក្កោ ឯកនីវរោ
សោ អទុតិយោ ន ជនតិ   មុនិភូតោវ តិដ្ឋតិ
វិវាទប្បត្តោ ទុតិយោ   កេនេកោ វិវទិស្សតិ
តស្ស តេ សគ្គកាមស្ស   ឯកត្តមុបរោចតំ ។

បពិត្រសមណៈ កងពីរដែលពាក់នឹងដៃរបស់ខ្ញុំនេះ ខ្ទប់គ្នាហើយ សំឡេងក៏កើតឡើង នោះជាគតិនៃកងទាំងពីរ បពិត្រសមណៈ កង ១ ដែលពាក់នឹងដៃរបស់ខ្ញុំនេះ កងនោះ មិនមានកងឯទៀត ជាគម្រប់ពីរ ទើបមិនលាន់ឮសំឡេង ដូចអរិយបុគ្គលជាអ្នកស្ងប់ស្ងៀម ឯបុគ្គលមានគ្នាជាគម្រប់ពីរនាក់ រមែងដល់នូវការជជែកគ្នា បុគ្គល ១ នាក់នឹងជជែកជាមួយនឹងបុគ្គលណាកើត ព្រះអង្គនោះ ជាអ្នកប្រាថ្នានូវឋានសួគ៌ សូមទ្រង់ពេញចិត្តនឹងភាពនៃបុគ្គល

ម្នាក់ឯងចុះ ។

ព្រះមហាសត្វបានស្តាប់ពាក្យរបស់កុមារិកានោះហើយ ទ្រង់បានហេតុឧបការៈ កាលត្រាស់ជាមួយព្រះទេវី ទើបត្រាស់ថា

សុណាសិ សីវលី គាថា   កុមារិយា បវេទិតា
បេសិយា មំ គរហិត្ថោ   ឧតិយស្សេវ សា គតិ
អយំ ទ្វេធា បថោ ភទ្ទេ   អនុចិណ្ណោ បថាវិហិ
តេសំ ត្វំ ឯកំ គណ្ហាហិ   អហមេកំ បុនាបរំ
មា ច មំ ត្វំ បតិ មេតិ   នាហំ ភរិយាតិ តំ បុន ។

ម្នាលនាងសីវលី នាងឮគាថាដែលនាងកុមារិកាពោលហើយឬទេ នាងកុមារិកាតិះដៀលនូវអាត្មាដូចជាអ្នកបម្រើនោះឯងជាគតិនៃបុគ្គលពីរនាក់ ម្នាលនាងដ៏ចម្រើន ផ្លូវបែកជាពីរនេះ ដែលអ្នកដើរផ្លូវតែងដើរទៅ បណ្តាផ្លូវទាំងពីរនោះ នាងចូរកាន់ផ្លូវ ១ អាត្មានឹងកាន់ផ្លូវ ១ ដទៃទៀត នាងកុំហៅអាត្មាថាជាស្វាមីរបស់អញ អាត្មាក៏មិនហៅនាងថាជាប្រពន្ធទៀតដែរ ។

ព្រះនាងសីវលីទេវី បានស្តាប់ព្រះតម្រាស់របស់ព្រះមហាសត្វហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់ជាក្សត្រដ៏ឧត្តម សូមទ្រង់កាន់យកផ្លូវខាងស្តាំ ចំណែកខ្ញុំម្ចាស់នឹងកាន់យកផ្លូវខាងឆ្វេង ក្រាបទូល

ដូច្នេះហើយ យាងទៅបានបន្តិច មិនអាចអត់សង្កត់សេចក្ដីសោកបាន ក៏យាងទៅតាមព្រះរាជា ចូលកាន់ថូណនគរជាមួយគ្នា ។

វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថៃង ច្បាស់ លុះព្រះបានត្រាស់ហើយ ទ្រង់ត្រាស់កន្ទះគាថាដូច្នេះថា

**ឥមមេវ កាថយន្តា ថូណំ ឧគរមុចាគមុំ ។**

ព្រះរាជានិងនាងសីវលី កាលពោលនូវពាក្យនេះហើយ

ក៏ចូលទៅកាន់ថូណនគរ ។

កាលយាងចូលទៅហើយ ព្រះមហាសត្វត្រាច់បិណ្ឌបាត ដល់ទ្វារ ផ្ទះរបស់ជាងពត់ព្រួញ សូម្បីព្រះនាងសីវលីទេវី ក៏យាងទៅតាមអំពីខាង ក្រោយ ប្រថាប់ឈរក្នុងទីសមគួរនាចំណែកម្ខាង ។ សម័យនោះ ជាង ព្រួញ កំពុងពោលព្រួញលើអំបែងរងើកភ្លើង នាំយកបាយម៉ានលាបនូវ ព្រួញ បិទភ្នែកម្ខាង សម្ញឹងមើលដោយភ្នែកម្ខាង ពត់ព្រួញឲ្យត្រង់ ព្រះ មហាសត្វ កាលទតឃើញដូច្នោះ ទ្រង់ព្រះតម្រិះថា បើជាងព្រួញនេះ ជាមនុស្សឈ្លាសវៃ នឹងពោលហេតុណាមួយដល់អញ អញនឹងសាកសួរ ជាងព្រួញនេះ ទើបចូលទៅរកជាងព្រួញ ហើយត្រាស់សួរ ។

វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថៃង ច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវបាទព្រះ គាថាដូច្នេះថា

កោដ្ឋកេ ឧសុការស្ស　　ភត្តកាលេ ឧបដ្ឋិតេ
តត្រ ច សោ ឧសុការោ　　ឯកំ ទណ្ឌំ ឧជុំ កតំ
ឯកញ្ច ចក្ខុំ និគ្គយ្ហ　　ជិម្ហមេកេន បេក្ខតិ ។

*កាលជិតវេលាភត្ត ព្រះរាជា ( ក៏ឈរ ) ជិតទ្វារនៃជាងព្រួញ ជាងព្រួញនោះ ធ្មេចភ្នែកម្ខាង សម្លឹងមើលដងព្រួញវៀចមួយ ដែលធ្វើឲ្យត្រង់ដោយភ្នែកម្ខាង ជិតខ្លោងទ្វារនោះ ។*

*លំដាប់នោះ ព្រះមហាសត្វបានត្រាស់នឹងជាងព្រួញនោះថា*

ឯវន្នោ សាធុ បស្សសិ　　ឧសុការ សុណោហិ មេ
យទេកំ ចក្ខុំ និគ្គយ្ហ　　ជិម្ហមេកេន បេក្ខសិ ។

*ម្នាលជាងព្រួញ អ្នកចូរស្ដាប់ពាក្យអាត្មា អ្នកធ្មេចភ្នែកម្ខាង សម្លឹងមើលដងព្រួញវៀច អ្នកមើលយ៉ាងនេះ ស្រួលឬ ។*

*ពាក្យដែលជាគាថានោះ មានអត្ថថា នៃជាងព្រួញសម្លាញ់ អ្នកបិទភ្នែកម្ខាង សម្លឹងមើលព្រួញដែលវៀចដោយភ្នែកម្ខាង ដោយប្រការណា អ្នកឃើញការសម្រេចប្រយោជន៍ ដោយប្រការនោះឬ ។*

*លំដាប់នោះ ជាងព្រួញ កាលក្រាបទូលព្រះមហាសត្វ ទើបពោលថា*

ទ្វីហិ សមណ ចក្ខូហិ　　វិសាលំ វិយ ខាយតិ
អប្បត្វា បរមំ លិង្គំ　　នុជុភាវាយ កប្បតិ ។

*បពិត្រសមណៈ ទីប្រាកដដូចជាទូលាយដោយភ្នែកពីរ កិច្ចដោយភាវៈនៃព្រួញត្រង់ រមែងមិនសម្រេច ព្រោះមិនឃើញនូវទីវៀចខាងមុខ ។*

ឯកញ្ច ចក្ខុំ និគ្គយ្ហ ជិម្ហមេកេន បេក្ខតោ
សម្បត្វា បរមំ លិង្គំ ឧជុភាវាយ កប្បតិ ។

*កាលបុគ្គលធ្មេចភ្នែកម្ខាង សម្ងឹងមើលទីវៀច ដោយភ្នែកម្ខាង កិច្ចដោយភាពនៃព្រួញត្រង់ រមែងសម្រេច ព្រោះឃើញទីវៀចខាងមុខ ។*

វិវាទប្បត្តោ ទុតិយោ កេនេកោ វិវទិស្សតិ
តស្ស តេ សគ្គកាមស្ស ឯកត្តមុបរោចតំ ។

*បុគ្គលជាគម្រប់ពីរ រមែងដល់នូវការជជែកគ្នា បុគ្គលម្នាក់ឯង នឹងជជែកគ្នាជាមួយនឹងអ្នកណាកើត កាលព្រះអង្គនោះ ប្រាថ្នានូវឋានសួគ៌ សូមពេញព្រះទ័យនឹងភាពនៃបុគ្គលម្នាក់ឯងចុះ ។*

*ដាងព្រួញនោះ បានថ្វាយឱវាទចំពោះព្រះរាជាយ៉ាងនោះហើយក៏នៅស្ងៀម ។ ព្រះមហាសត្វត្រាច់បិណ្ឌបាត បានភត្តាហារដែលលាយគ្នាហើយ យាងចេញអំពីនគរ ប្រថាប់គង់សោយក្នុងទីដែលមានទឹកបរិបូណ៌ ទ្រង់សោយព្រះក្រយាស្ងោយស្រេចហើយ ខ្ពុរព្រះឱស្ឋ លាង*

បាត្រដាក់ចូលស្មោកហើយ ហៅព្រះនាងសីវលីមកត្រាស់ថា

សុណាសិ សីវលី គាថា ឧសុការេន ភាសិតា
បេសិយា មំ ករហិត្ថោ ឧតិយស្សេវ សា កតិ
អយំ ទ្វេធា បថោ ភទ្ទេ អនុចិណ្ណោ បថាវិហិ
តេសំ ត្វំ ឯកំ គណ្ហាហិ អហមេកំ បុនាបរំ
នេវ មំ ត្វំ បតិ មេតិ ជាហំ ភរិយាតិ តំ បុន ។

នៃនាងសីវលី នាងឮគាថាដែលជាងព្រួញពោលហើយឬ ទេ ជាងព្រួញតិះដៀលអាត្មា ដូចជាអ្នកបម្រើ នោះជាគតិ នៃបុគ្គលពីរនាក់ ម្នាលនាងដ៏ចម្រើន ផ្លូវបែកជាពីរនេះ ដែលអ្នកដើរផ្លូវ តែងដើរទៅ បណ្តាផ្លូវទាំងពីរនោះ នាង ចូរកាន់យកផ្លូវ ១ អាត្មានឹងកាន់យកផ្លូវ ១ ដទៃទៀត នាង កុំហៅអាត្មាថា ជាស្វាមីរបស់អញ អាត្មាក៏មិនហៅនាងថា ជាភរិយារបស់អាត្មាដែរ ។

បានឮថា ព្រះនាងសីវលីនោះ សូម្បីព្រះមហាសត្វត្រាស់ថា នាង កុំហៅអាត្មាថា ជាស្វាមីរបស់នាង ដូច្នេះ ក៏នៅតែទៅតាមព្រះមហាសត្វ នោះឯង ព្រះរាជាក៏មិនអាចឲ្យព្រះនាងសីវលីនោះ យាងត្រឡប់បាន ។ សូម្បីមហាជនក៏ដើរតាមទ្រង់ទៅ ។ លុះដល់ព្រៃមួយកន្លែង ដែលនៅ មិនឆ្ងាយអំពីទីនោះ លំដាប់នោះ ព្រះមហាសត្វទតឃើញដង់ព្រៃខៀវ

ស្រង៉ាត់ មានព្រះរាជបំណងឲ្យព្រះនាងត្រឡប់ កាលយាងទៅ បាន ទតឃើញស្មៅយាប្លងក្នុងទីក្បែរផ្លូវ ទ្រង់ដកស្មៅយាប្លងនោះ ត្រាស់ហៅព្រះទេវីមកថា ម្នាលនាងសីវលី ចូរនាងមើលស្មៅយាប្លងនេះ ស្មៅយាប្លងនេះ មិនអាចជាប់គ្នាទៀតបាន យ៉ាងណា ការនៅរួមជាមួយនាងរបស់អាត្មា ក៏មិនអាចជាប់តគ្នាបាន យ៉ាងនោះដែរ ហើយត្រាស់កន្លះគាថាដូច្នេះថា

**មុញ្ជា ឞ៏សិកា បព្វូឡ្ហា ឯកា វិហរ សីវលី ។**

ម្នាលនាងសីវលី នាងចូរនៅម្នាក់ឯងចុះ ដូចស្មៅយាប្លង ដែលអាត្មាដកហើយ ។

ព្រះនាងបានស្តាប់ព្រះតម្រាស់របស់ព្រះមហាសត្វហើយ ត្រាស់ថា ចាប់អំពីនេះទៅ ខ្ញុំមិនបាននៅរួមជាមួយព្រះមហាជនកនរិន្ទ្ររាជទៀតទេ ព្រះនាងមិនអាចអត់សង្កត់សេចក្តីសោក ផ្គងដើមដៃទាំងពីរ បរិទេវនាការដោយអនេកបរិយាយ ដល់នូវវិសញ្ញីភាព ដួលចុះត្រង់ផ្លូវថ្នល់ ។ ព្រះមហាសត្វទ្រង់ជ្រាបថា ព្រះនាងសន្លប់ ក៏ឈានព្រះបាទយាងចូលកាន់ព្រៃ ។ ខណៈនោះ ពួកអាមាត្យយកទឹកមកស្រោចសរីរៈព្រះនាងសីវលីទេវីនោះ នាំគ្នាច្របាច់ត្រង់ព្រះហស្តនិងព្រះបាទ ព្រះនាងមានស្មារតីក្រោកឡើង ត្រាស់សួរថា នៃបាទាំងឡាយ ព្រះរាជាយាងទៅខាងណា ។

ពួកអាមាត្យក្រាបទូលសួរថា ព្រះនាងមិនជ្រាបទេឬ ។ ព្រះនាងមានព្រះសវនីយ៍ថា បាទាំងឡាយ ចូរដើររក ។ ជនទាំងនោះ នាំគ្នារត់ទៅខាងនោះ ខាងនេះ ក៏មិនបានចួបព្រះរាជា ។ ព្រះនាងបរិទេវនាការជាអនេក ហើយឲ្យសាងចេតិយត្រង់ទីដែលព្រះរាជាប្រថាប់ឈរ បូជាដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម ហើយយាងត្រឡប់ទៅកាន់នគរមិថិលា ។ ឯព្រះមហាសត្វយាងចូលព្រៃហិមពាន្ត ធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតខាងក្នុង ៧ ថ្ងៃ មិនបានមកកាន់ដែនដីមនុស្សទៀតឡើយ ។ ចំណែកព្រះនាងសីវលីទេវីបានយាងត្រឡប់ហើយ ឲ្យសាងចេតិយជាច្រើនកន្លែង ក្នុងទីដែលព្រះមហាសត្វត្រាស់ជាមួយជាងព្រួញ ត្រាស់ជាមួយកុមារិកា ទីសោយសាច់ដែលសុនខទម្ងាក់ចោល ទីត្រាស់ជាមួយមិគាជិនតាបស និងជាមួយនារទតាបស គ្រប់កន្លែងហើយបូជាដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម ព្រះនាងចោមរោមដោយសេនា យាងដល់មិថិលានគរហើយ អភិសេកព្រះរាជឱរសក្នុងឧទ្យានអម្ពវ័ន ព្រះនាងបញ្ជូនព្រះរាជឱរសដែលមានពួកសេនាចោមរោមហើយចូលកាន់ព្រះនគរ ព្រះនាងទ្រង់បួសជាតបស្សិនីដោយខ្លួនឯង នៅក្នុងព្រះរាជឧទ្យាននោះ ព្រះនាងធ្វើកសិណបរិកម្ម បានសម្រេចឈាន មានឈានមិនសាបសូន្យ មានព្រហ្មលោកជាទីទៅខាងមុខ ក្នុងទីបំផុតនៃព្រះជន្មាយុ ។ ចំណែកព្រះមហាសត្វ មានឈានមិនសាបសូន្យ ក៏ចូល

ដល់ព្រហ្មលោកដូចគ្នា ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតចេញសាងមហាភិនេស្រ្កមណ៍ សូម្បីក្នុងកាលមុន ក៏តថាគតចេញសាងមហាភិនេស្រ្កមណ៍ដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ទេពធីតារក្សាសមុទ្ទក្នុងកាលនោះ បានមកជាឧប្បលវណ្ណាភិក្ខុនី នារទតាបស បានមកជាសារីបុត្ត មិគាជិនតាបស បានមកជាមោគ្គល្លាន កុមារិកា បានមកជាខេមាភិក្ខុនី ជាងព្រួញ បានមកជាអានន្ទ សីវលីទេវី បានមកជារាហុលមាតា ទីឃាវុកុមារ បានមកជារាហុល ព្រះជនកព្រះជននី បានមកជាត្រកូលមហារាជ ចំណែកមហាជនកនរិន្ទ្ររាជ គឺតថាគតអរហន្តសម្មាសម្ពុទ្ធ នេះឯង ។

**មហាជនកជាតក ចប់** (១)

---

១-ស្រង់ចាកអដ្ឋកថា ជាតក មហានិបាត បិ.៦២ ទំ.២១ ឃ.៤៩ ។

# មេណ្ឌកសេដ្ឋី

បានឮថា ព្រះសាស្តា កាលចារិកទៅក្នុងអង្គុត្តរាបថជនបទ ទ្រង់ឃើញឧបនិស្ស័យសោតាបត្តិផលរបស់មនុស្សទាំងនោះ គឺមេណ្ឌកសេដ្ឋី ១ ភរិយារបស់សេដ្ឋីនោះ ឈ្មោះនាងចន្ទបទុមា ១ កូនប្រុសឈ្មោះធនញ្ជ័យសេដ្ឋី ១ កូនប្រសាស្រី ឈ្មោះនាងសុមនទេវី ១ ចៅស្រីឈ្មោះនាងវិសាខា ១ ទាសៈ ឈ្មោះបុណ្ណៈ ១ ទើបទ្រង់យាងទៅកាន់ភទ្ទិយនគរ គង់នៅក្នុងជាតិយាវ័ន ។ មេណ្ឌកសេដ្ឋីបានស្តាប់ការយាងមករបស់ព្រះសាស្តាហើយ ។

សួរថា ព្រោះហេតុអ្វី ទើបសេដ្ឋីឈ្មោះថា មេណ្ឌកៈ ។

ឆ្លើយថា បានឮថា ពពែមាសទាំងឡាយ ប្រមាណប៉ុនដំរី សេះនិងគោឧសភៈ ជ្រែកផែនដី មានខ្នងទល់គ្នា ផុសឡើងក្នុងទីប្រមាណ ៨ ករីសៈ ត្រង់ក្រោយផ្ទះរបស់សេដ្ឋីនោះ ពពែទាំងនោះ មានដុំអំបោះ ៥ ពណ៌ ចុកក្នុងមាត់ ។ កាលមានសេចក្តីត្រូវការដោយភេសជ្ជៈ មានសប្បិ ប្រេង ទឹកឃ្មុំ និងស្ករអំពៅជាដើម ឬដោយវត្ថុជាគ្រឿងបិទបាំងគឺសំពត់ (ឬមានសេចក្តីត្រូវការដោយ) ប្រាក់និងមាសជាដើម ជនទាំងឡាយ រមែងនាំដុំអំបោះចេញអំពីមាត់របស់ពពែទាំងនោះ សប្បិ ប្រេង ទឹកឃ្មុំ ស្ករអំពៅ សំពត់ស្លៀកដណ្តប់ ប្រាក់មាស រមែងហូរ

ចេញអំពីមាត់ពពែនីមួយ ៗ គ្រប់គ្រាន់ដល់មនុស្សក្នុងជម្ពូទ្វីប ។ ចាប់តាំងអំពីនោះមក ទើបសេដ្ឋីនោះ ប្រាកដឈ្មោះថា មេណ្ឌកសេដ្ឋី ។

សួរថា បុព្វកម្មរបស់សេដ្ឋីនោះ ដូចម្តេច ។

ឆ្លើយថា បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមថា វិបស្សី សេដ្ឋីនោះ ជាក្មួយរបស់កុដុម្ពិកៈឈ្មោះអវរោជៈ ឈ្មោះថា អវរោជៈ គឺមានឈ្មោះដូចអ៊ំ ។ គ្រានោះ អ៊ំរបស់គាត់ប្រារព្ធសាងព្រះគន្ធកុដិដើម្បីព្រះសាស្តា គាត់ចូលទៅកាន់សម្នាក់របស់អ៊ំហើយពោលថា បពិត្រលោកអ៊ំ យើងទាំងពីរនឹងសាងរួមគ្នា ។

ក្នុងពេលដែលអ៊ំនោះឃាត់ថា អញតែម្នាក់ប៉ុណ្ណោះ នឹងសាងមិនសាធារណៈដល់ជនដទៃឡើយ ទើបគិតថា កាលអ៊ំសាងព្រះគន្ធកុដិក្នុងទីនេះហើយ អញគួរបានសាលាឈ្មោះកុញ្ជរក្នុងទីនេះ ទើបឲ្យមនុស្សនាំឈើមកអំពីព្រៃ ឲ្យធ្វើសសរយ៉ាងនេះ គឺសសរមួយដើមរំលេចដោយមាស សសរមួយដើមរំលេចដោយប្រាក់ សសរមួយដើមរំលេចដោយកែវមណី សសរមួយដើមរំលេចដោយរតនៈ ៧ ប្រការ ឲ្យធ្វើធ្នឹម សន្ទះទ្វារ សន្ទះបង្អួច បង្កង់ គ្រឿងប្រក់ និងឥដ្ឋទាំងអស់ រំលេចដោយវត្ថុ មានមាសជាដើម ឲ្យធ្វើសាលាឈ្មោះកុញ្ជរ សម្រេចដោយរតនៈ ៧ ប្រការ ថ្វាយព្រះតថាគតត្រង់ទីខាងមុខព្រះគន្ធកុដិ ។ នៅខាងលើដំបូលសាលានោះ មានកំពូលបី ដែលសម្រេចហើយដោយដុំមាស មាន

ពណ៌ក្រហមឆ្អិន សម្រេចហើយដោយកែវផលិក និងសម្រេចហើយដោយកែវប្រពាល ឲ្យសាងមណ្ឌបប្រដាប់ដោយរតនវត្ថុត្រង់កណ្ដាលនៃសាលាឈ្មោះកុញ្ជរនោះ តម្កល់ធម្មាសនៈទុក ។ ជើងធម្មាសនៈនោះសម្រេចដោយមាស មេគ្រែទាំង ៤ ក៏ដូចគ្នា ហើយឲ្យធ្វើពពែមាស ៤ តម្កល់ទុកខាងក្រោមនៃជើងទាំង ៤ របស់អាសនៈ ឲ្យធ្វើពពែមាស ២ ទុកខាងក្រោមតាំងសម្រាប់រងជើង ឲ្យធ្វើពពែមាស ៦ ដាក់ជុំវិញមណ្ឌប ។ ឲ្យត្បាញធម្មាសនៈដោយខ្សែសរសៃល្អិត សម្រេចដោយអំបោះ ត្រង់ខាងក្រោមហើយ ទើបឲ្យត្បាញដោយខ្សែដែលសម្រេចដោយមាស ទុកត្រង់កណ្ដាល ហើយឲ្យត្បាញដោយខ្សែសម្រេចដោយកែវមុក្តាទុកខាងលើ ។ បង្អែកនៃធម្មាសនៈនោះ សម្រេចដោយដើមចន្ទន៍ ។ កាលឲ្យសាលាឈ្មោះកុញ្ជរសម្រេចយ៉ាងនេះហើយ កាលនឹងធ្វើការឆ្លង ទើបនិមន្តព្រះសាស្ដា មួយអន្លើដោយភិក្ខុ ៦ លាន ៨ សែនរូប បានថ្វាយទានអស់កាល ៤ ខែ ក្នុងថ្ងៃចុងក្រោយ បានថ្វាយត្រៃចីវរ ។ ក្នុងទានទាំងនោះ ចីវរមានតម្លៃ ១ សែនកហាបណៈ ធ្លាក់ចុះដល់ភិក្ខុដែលបួសថ្មីក្នុងសង្ឃហើយ ។

បុរសនោះ ធ្វើបុញ្ញកម្មក្នុងកាលព្រះពុទ្ធវិបស្សីយ៉ាងនេះហើយ ឃ្លាតចាកអត្តភាពនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយច្រើនជាតិ ក្នុងភទ្ទកប្បនេះ កើតក្នុងត្រកូលសេដ្ឋីមានភោគៈច្រើន ក្នុងក្រុង

ពារាណសី មានឈ្មោះថា ពារាណសីសេដ្ឋី ។ ថ្ងៃមួយ សេដ្ឋីនោះទៅកាន់ទីបម្រើព្រះរាជា ចួបបុរោហិត ទើបសួរថា លោកអាចារ្យ លោកបានពិនិត្យមើលឫក្សនិងយាមខ្វះដែរឬទេ ។ បុរោហិតពោលថា លោកសេដ្ឋី ខ្ញុំបានពិនិត្យមើលហើយ ការងាររដទៃរបស់ពួកយើង មានឬ ។

សេដ្ឋីសួរថា បើដូច្នោះ ការប្រព្រឹត្តទៅក្នុងជនបទដូចម្តេច ។ បុរោហិតពោលថា មានភ័យមួយនឹងកើតឡើង ។

សេដ្ឋីសួរថា ភ័យនោះជាអ្វី ។ បុរោហិតពោលថា លោកសេដ្ឋី គឺឆាតកភ័យ (ភ័យកើតអំពីការខ្វះអាហារ) ។

សេដ្ឋីសួរថា នឹងមានក្នុងកាលណា ។ បុរោហិតពោលថា នឹងមានក្នុងកាលកន្លងទៅ ៣ ឆ្នាំ រាប់អំពីឆ្នាំនេះ ។ សេដ្ឋីស្តាប់ពាក្យនោះហើយ ឲ្យមនុស្សធ្វើកសិកម្មជាច្រើន ទិញចំពោះតែស្រូវដោយប្រាក់ដែលមានក្នុងផ្ទះទាំងអស់ ឲ្យធ្វើជង្រុក ១២៥០ ដាក់ជង្រុកទាំងអស់ឲ្យពេញដោយស្រូវ កាលជង្រុកមិនគ្រប់គ្រាន់ ក៏ដាក់ក្នុងភាជនៈ មានពាងជាដើមឲ្យពេញ ហើយជីករណ្តៅកប់ស្រូវដែលសល់ក្នុងផែនដី ច្របាច់ស្រូវដែលសល់អំពីកប់ ជាមួយដីស្អិតបូកជញ្ជាំងទាំងឡាយ ។

សម័យតមក កាលភ័យ គឺការអត់ឃ្លានចូលមកដល់ហើយ សេដ្ឋីក៏បរិភោគស្រូវតាមដែលរក្សាទុក កាលស្រូវដែលដាក់ក្នុងជង្រុក និងភាជនៈ មានពាងជាដើមអស់ហើយ ទើបហៅបរិវារជនមក ហើយពោល

ថា នែបាទាំងឡាយ អ្នកទាំងឡាយ ចូរទៅកាន់ភ្នំ ហើយរស់នៅ បើបំណាំងមកកាន់សម្នាក់យើង ចូរមកក្នុងកាលដែលមានភិក្ខារកបានងាយ បើមិនចង់មកទេ ក៏ចូររស់នៅទីនោះចុះ ។ ជនទាំងនោះ ទ្រហោយំ មានមុខជោកដោយទឹកភ្នែក ថ្វាយបង្គំសេដ្ឋី សូមខមាទោស អង្គុយនៅអស់មួយសប្តាហ៍ ហើយបានធ្វើយ៉ាងនោះ ។ ចំណែកអ្នកបម្រើម្នាក់ឈ្មោះបុណ្ណៈ នៅសល់ក្នុងសម្នាក់របស់សេដ្ឋីនោះ រួមជា ៥ នាក់ គឺសេដ្ឋី ១ ភរិយារបស់សេដ្ឋី ១ បុត្តរបស់សេដ្ឋី ១ កូនប្រសារបស់សេដ្ឋី ១ ទាសៈឈ្មោះបុណ្ណៈនោះ ១ ។ ជនទាំងនោះ កាលស្រូវដែលកប់ទុកក្នុងផែនដីអស់ហើយ ដំបំបែកដីដែលបូកត្រង់ជញ្ជាំង ត្រាំទឹក ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយស្រូវដែលបានហើយអំពីជញ្ជាំងនោះ ។

គ្រានោះ ភរិយាសេដ្ឋី កាលដីជញ្ជាំងអស់ទៅ ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ ដំដីដែលសល់ក្នុងចំណែកនៃជញ្ជាំងទាំងឡាយហើយត្រាំទឹក បានស្រូវប្រមាណកន្ទះអាឡ្ហកៈគឺ ២ នាឡិ បុកហើយកាន់យកអង្ករប្រមាណ ១ នាឡិ ដាក់ក្នុងឆ្នាំងមួយ ព្រោះខ្លាចអំពីចោរ ដោយគិតថា ក្នុងកាលកើតឆាតកភ័យ ចោរមានច្រើន បិទហើយកប់ទុកក្នុងផែនដី ។ លំដាប់នោះ សេដ្ឋីមកអំពីទីបម្រើព្រះរាជាហើយ ពោលនឹងភរិយាថា នែនាង ខ្ញុំឃ្លាន វត្ថុណាមួយមានដែរឬទេ ។

ភរិយាមិនបានពោលដល់វត្ថុដែលមាន ថាមិនមាន តែពោលថា

មានអង្ករ ១ នាឡិ ។ សេដ្ឋីសួរថា អង្ករ ១ នាឡិនោះ នៅឯណា ។

ភរិយាឆ្លើយថា ខ្ញុំកប់ទុក ព្រោះខ្លាចចោរ ។ សេដ្ឋីពោលថា បើដូច្នោះ ចូរនាងគាស់ឡើងមក ហើយចម្អិនចុះ ។

ភរិយាពោលថា បពិត្រអ្នកជាម្ចាស់ បើដាំបបរអាចគ្រប់គ្រាន់ ២ ពេល បើដាំបាយបានត្រឹមមួយពេលប៉ុណ្ណោះ ខ្ញុំនឹងចម្អិនដូចម្ដេច ។

សេដ្ឋីនោះពោលថា បច្ច័យដទៃរបស់ពួកយើងមិនមាន ពួកយើងបរិភោគបាយហើយស្លាប់ ក៏ព្រម ចូរនាងដាំបាយចុះ ។ ភរិយាសេដ្ឋីនោះ ចម្អិនបាយហើយចែកជា ៥ ចំណែក ដួសបាយមួយចំណែកទុកខាងមុខលោកសេដ្ឋី ។

ក្នុងខណៈនោះ **ព្រះបច្ចេកពុទ្ធ** មួយអង្គ នៅត្រង់ភ្នំគន្ធមាទន៍ចេញអំពីសមាបត្តិ ។ បានឮថា ខាងក្នុងសមាបត្តិ ការស្រេកឃ្លានរមែងមិនបៀតបៀន ព្រោះផលនៃសមាបត្តិ តែកាលចេញអំពីសមាបត្តិហើយការស្រេកឃ្លានដ៏មានកម្លាំង រមែងកើតឡើង ហាក់បីដូចដុតនូវផ្ទៃពោះដូច្នោះ ព្រោះហេតុនោះ ទើបព្រះបច្ចេកពុទ្ធអង្គនោះ ពិចារណាមើលឋាន ( ទី ) ដែលអាចបានអាហារ ហើយទើបទៅ ។ ក្នុងថ្ងៃនោះជនទាំងឡាយណា បានថ្វាយទានដល់ព្រះបច្ចេកពុទ្ធហើយ រមែងបាននូវសម្បត្តិ មានតំណែងជាសេនាបតីជាដើមណាមួយ ព្រោះហេតុនោះព្រះបច្ចេកពុទ្ធនោះ ពិចារណាមើលដោយទិព្វចក្ខុ ត្រិះរិះថា ឆាតកភ័យ

កើតឡើងហើយក្នុងជម្ពូទ្វីបទាំងមូល ក្នុងផ្ទះសេដ្ឋី គេចម្អិនបាយដែលសម្រេចដោយអង្ករមួយនាឡិ ដើម្បីមនុស្ស ៥ នាក់ អ្នកទាំងនោះ នឹងមានសទ្ធាដើម្បីសង្គ្រោះដល់អាត្មាអញដែរឬហ្ន៎ ឃើញភាពដែលជនទាំងនោះ ជាអ្នកមានសទ្ធាផង អាចធ្វើការសង្គ្រោះបានផង ទើបកាន់យកបាត្រនិងចីវរទៅបង្ហាញខ្លួនត្រង់ទ្វារផ្ទះ អំពីមុខលោកសេដ្ឋី ។ សេដ្ឋីនោះ គ្រាន់តែឃើញក៏មានចិត្តជ្រះថ្លា គិតថា អញចួបនូវធាតកភ័យបែបនេះ ព្រោះអញមិនបានធ្វើទានក្នុងកាលមុន ភត្តនេះ គប្បីរក្សាអញទុកត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ចំណែកភត្តដែលអញប្រគេនហើយដល់លោកម្ចាស់ នឹងនាំមកនូវប្រយោជន៍ដល់អញ ជាច្រើនកោដិកប្ប ដូច្នេះហើយយកថាសភត្តនោះចេញ ចូលទៅរកព្រះបច្ចេកពុទ្ធ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន និមន្តឲ្យចូលទៅកាន់ផ្ទះ កាលលោកគង់លើអាសនៈហើយ ទើបលាងជើងរបស់លោក ដាក់ថាសភត្តលើតាំងមាស ហើយយកភត្តនោះ ដាក់ក្នុងបាត្រព្រះបច្ចេកពុទ្ធ កាលភត្តសល់ពាក់កណ្ដាលព្រះបច្ចេកពុទ្ធយកដៃបិទបាត្រ ។

លំដាប់នោះ លោកសេដ្ឋីពោលថា បពិត្រលោកម្ចាស់ នេះជាចំណែកមួយនៃបាយដែលគេចម្អិនដើម្បីមនុស្ស ៥ នាក់ ដោយអង្ករមួយនាឡិ ខ្ញុំមិនអាចចែកភត្តនេះ ឲ្យជាពីរចំណែកបានទេ សូមលោកម្ចាស់កុំធ្វើការសង្គ្រោះដល់ខ្ញុំតែក្នុងលោកនេះ ខ្ញុំប្រាថ្នាប្រគេនមិនឲ្យសេសសល់

ឡើយ ហើយបានប្រគេនភត្តទាំងអស់ ។ កាលប្រគេនហើយបានតាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ ខ្ញុំកុំបីចួបផាតកភ័យបែបនេះ ក្នុងទីដែលខ្ញុំកើតឡើយ តាំងអំពីឥឡូវនេះទៅ ខ្ញុំគប្បីឲ្យនូវស្រូវពូជនិងភត្តដល់មនុស្សក្នុងជម្ពូទ្វីបទាំងមូល មិនចាំបាច់ ( ឲ្យមនុស្សទាំងនោះ ) ធ្វើការងារចិញ្ចឹមជីវិតដោយដៃរបស់ខ្លួនឯង កាលខ្ញុំប្រើឲ្យមនុស្សសម្អាតជង្រុក ១២៥០ ហើយកក់សក់ អង្គុយត្រង់ទ្វារនៃជង្រុកទាំងនោះ ហើយសម្ទឹងមើលខាងលើប៉ុណ្ណោះ ផ្ការនៃស្រូវសាលីក្រហម គប្បីធ្លាក់ចុះមកពេញជង្រុកទាំងអស់ ។ បុគ្គលនេះឯង សូមជាភរិយា បុគ្គលនេះឯងសូមជាបុត្ត បុគ្គលនេះឯង សូមជាកូនប្រសាស្រី បុគ្គលនេះឯង សូមជាទាសៈរបស់ខ្ញុំ ក្នុងទីដែលខ្ញុំកើតហើយ ។

ចំណែកភរិយារបស់សេដ្ឋីនោះ គិតថា បើប្តីរបស់អញត្រូវសេចក្តីស្រេកឃ្លានបៀតបៀន អញក៏មិនអាចលេបរួច ទើបប្រគេនចំណែករបស់ខ្លួនដល់ព្រះបច្ចេកពុទ្ធ ហើយតាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់តាំងអំពីនេះទៅ ខ្ញុំកុំបីចួបនូវឆាតកភ័យបែបនេះ ក្នុងទីដែលខ្ញុំកើតហើយម្យ៉ាងទៀត កាលខ្ញុំដាក់ថាសភត្តខាងមុខ ឲ្យនូវភត្តដល់មនុស្សក្នុងជម្ពូទ្វីបទាំងមូល បើខ្ញុំមិនក្រោកដរាបណា ទីនៃភត្តដែលខ្ញុំដួសហើយ សូមពេញបរិបូណ៌ដូចដើមនោះឯង បុរសនេះ សូមជាស្វាមី បុរសនេះ សូមជាបុត្តស្ត្រីនេះ សូមជាកូនប្រសា បុរសនេះ សូមជាទាសៈរបស់ខ្ញុំ ។

សូម្បីកូនប្រុសរបស់សេដ្ឋីនោះ ក៏ប្រគេនចំណែករបស់ខ្លួនដល់ព្រះបច្ចេកពុទ្ធហើយតាំងសេចក្ដីប្រាថ្នាថា តាំងអំពីនេះទៅ ឆាតកភ័យបែបនេះ កុំបីមានដល់ខ្ញុំឡើយ ម្យ៉ាងទៀត បើខ្ញុំកាន់ថង់ប្រាក់ដាក់កហាបណៈ ១ ពាន់ សូម្បីឲ្យកហាបណៈដល់មនុស្សក្នុងជម្ពូទ្វីបទាំងមូល ថង់នោះ ចូរពេញដូចដើម លោកទាំងពីរនោះ សូមជាមាតាបិតា ស្រីនេះ សូមជាភរិយា បុរសនេះ សូមជាទាសៈរបស់ខ្ញុំ ។

ចំណែកកូនប្រសាស្រីរបស់សេដ្ឋីនោះ ក៏ប្រគេនចំណែករបស់ខ្លួនដល់ព្រះបច្ចេកពុទ្ធ ហើយបានតាំងសេចក្ដីប្រាថ្នាថា តាំងអំពីនេះទៅ ឆាតកភ័យបែបនេះ ខ្ញុំកុំបីចួបឡើយ ម្យ៉ាងទៀត កាលខ្ញុំកាន់ល្អីស្រូវទុកខាងមុខ ឲ្យនូវភត្តដែលជាពូជដល់មនុស្សក្នុងជម្ពូទ្វីបទាំងមូល ការអស់ទៅកុំបីប្រាកដ លោកទាំងពីរនេះ សូមជាមាតាបិតាក្មេក បុរសនេះ សូមជាប្ដី បុរសនេះ សូមជាទាសៈរបស់ខ្ញុំ ។

សូម្បីទាសៈរបស់សេដ្ឋីនោះ ក៏ប្រគេនចំណែករបស់ខ្លួនដល់ព្រះបច្ចេកពុទ្ធ ហើយតាំងសេចក្ដីប្រាថ្នាថា តាំងអំពីនេះទៅ ខ្ញុំមិនគប្បីចួបនូវឆាតកភ័យបែបនេះឡើយ ជនទាំងអស់សូមជាចៅហ្វាយ កាលខ្ញុំភ្ជួរស្រែ គន្លង ៧ ប៉ុនទូកកំពោល គឺខាងឆ្វេង ៣ ខាងស្ដាំ ៣ ត្រង់កណ្ដាល ១ ចូរប្រព្រឹត្តទៅ ។ នាយបុណ្ណៈនោះ ទោះបីប្រាថ្នាតំណែងសេនាបតី ក៏អាចបានក្នុងថ្ងៃនោះឯង តែដោយអំណាចសេចក្ដីស្រឡាញ់ក្នុងម្ចាស់

ទាំងឡាយ ទើបតាំងសេចក្ដីប្រាថ្នាថា ជនទាំងនោះឯង សូមជាចៅហ្វាយរបស់ខ្ញុំ ។

ក្នុងទីបំផុតនៃវាចារបស់ជនទាំងអស់ ព្រះបច្ចេកពុទ្ធពោលថា **ឯវំ ហោតុ** ចូរសម្រេចយ៉ាងនោះចុះ ហើយធ្វើអនុមោទនាដោយគាថារបស់ព្រះបច្ចេកពុទ្ធថា

**ឥច្ឆិតំ បត្ថិតំ តុយ្ហំ ខិប្បមេវ សមិជ្ឈតុ**
**សព្វេ បូរេន្តុ សង្កប្បា ចន្ទោ បន្នរសោ យថា ។**

សូមឥដ្ឋផល គឺផលជាទីគាប់ចិត្ត ដែលអ្នកប្រាថ្នាហើយ តាំងចិត្តហើយ ចូរសម្រេចដល់អ្នក ឲ្យបានឆាប់រួសរាន់ទាន់ចិត្ត សូមតម្រិះត្រូវទាំងពួងចូរពេញដល់អ្នក ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត ។

**ឥច្ឆិតំ បត្ថិតំ តុយ្ហំ ខិប្បមេវ សមិជ្ឈតុ**
**សព្វេ បូរេន្តុ សង្កប្បា មណិ ជោតិរសោ យថា ។**

សូមឥដ្ឋផល គឺផលជាទីគាប់ចិត្ត ដែលអ្នកប្រាថ្នាហើយ តាំងចិត្តហើយ ចូរសម្រេចដល់អ្នក ឲ្យបានឆាប់រួសរាន់ទាន់ចិត្ត សូមតម្រិះត្រូវទាំងពួង ចូរពេញដល់អ្នក ដូចកែវមណី មានរស្មីដ៏រុងរឿង ជាកែវវិសេស អាចញ៉ាំងសេចក្ដីប្រាថ្នាទាំងពួង ឲ្យសម្រេចបាន ។

ហើយគិតថា បើអញញ៉ាំងចិត្តរបស់ជនទាំងឡាយនេះ ឲ្យជ្រះថ្លារមែងគួរ ទើបអធិដ្ឋានថា ជនទាំងនេះ ចូរឃើញអាត្មាអញរហូតដល់ភ្នំគន្ធមាទន៍ ហើយក៏ទៅតាមអាកាស សូម្បីជនទាំងនោះ ក៏បានឈរមើលនុ៎ះឯង ។ ព្រះបច្ចេកពុទ្ធនោះ និមន្តទៅហើយ ចែកភត្តនោះ ដល់ព្រះបច្ចេកពុទ្ធ ៥០០ អង្គ ដោយអានុភាពនៃព្រះបច្ចេកពុទ្ធទាំងនោះ ភត្តនោះ គ្រប់គ្រាន់ហើយដល់ព្រះបច្ចេកពុទ្ធទាំងអស់ ។ ជនទាំងនោះបានឈរមើលនុ៎ះឯង ។

ពេលថ្ងៃត្រង់កន្លងទៅហើយ ភរិយាសេដ្ឋីលាងឆ្នាំងបាយ ហើយបិទគម្របទុក ចំណែកសេដ្ឋីត្រូវសេចក្តីឃ្លានគ្របសង្កត់ ដេកលក់ទៅលុះភ្ញាក់ឡើងក្នុងពេលល្ងាច ពោលនឹងភរិយារបស់ខ្លួនថា នៃនាង ខ្ញុំឃ្លានណាស់ បាយក្តាំងបាតឆ្នាំង មានខ្លះឬហ្ន៎ ។

ភរិយានោះ សូម្បីដឹងថា ខ្លួនលាងឆ្នាំងទុកហើយ ក៏មិនពោលថាមិនមាន គិតថា អញបើកឆ្នាំងបាយហើយ សឹមប្រាប់ ដូច្នេះហើយ ទើបក្រោកឡើងទៅក្បែរឆ្នាំងបាយហើយបើកគម្របឡើង ។ ខណៈនោះឯងឆ្នាំងបាយពេញដោយភត្ត មានពណ៌ដូចផ្កាម្ទិះក្រពុំ បានទុលគម្របតាំងនៅហើយ ។ ភរិយានោះឃើញភត្តហើយ ជាអ្នកមានសរីរៈពេញដោយបីតិ ពោលនឹងសេដ្ឋីថា បពិត្រអ្នកជាម្ចាស់ សូមក្រោកឡើង ខ្ញុំលាងឆ្នាំងបាយបិទទុក តែឆ្នាំងនោះ ពេញដោយភត្ត មានពណ៌ដូចផ្កាម្ទិះក្រពុំ

ឈ្មោះថា បុណ្យទាំងឡាយគួរធ្វើ ឈ្មោះថា ទានគួរឲ្យ សូមអ្នកក្រោកឡើងបរិភោគចុះ ។ ភរិយានោះ បានឲ្យភត្តដល់ជនទាំងពីរនាក់ គឺស្វាមីនិងបុត្ត កាលឪពុកនិងកូននោះ បរិភោគស្រេចហើយ ទើបនាងអង្គុយបរិភោគជាមួយកូនប្រសា ហើយឲ្យភត្តដល់នាយបុណ្ណៈ ។ ទីនៃភត្តដែលជនទាំងនោះ ដួសហើយ រមែងមិនអស់ទៅ ប្រាកដចំពោះត្រង់ទីដែលដួសមួយវែកដំបូងប៉ុណ្ណោះ ។ ក្នុងថ្ងៃនោះឯង ជង្រុកជាដើម ក៏ពេញហើយដោយទំនងដែលពេញពីមុននោះឯង ។ នាងឲ្យធ្វើការប្រកាសក្នុងនគរថា ភត្តកើតឡើងហើយក្នុងផ្ទះរបស់លោកសេដ្ឋី បុគ្គលណា មានសេចក្តីត្រូវការដោយស្រូវពូជនិងភត្ត ចូរមកទទួលយកចុះ ។ មនុស្សទាំងឡាយកាន់យកភត្តនិងពូជ អំពីផ្ទះរបស់សេដ្ឋីនោះហើយ មនុស្សក្នុងជម្ពូទ្វីបទាំងមូល អាស្រ័យសេដ្ឋីនោះ ទើបបាននូវជីវិតនុ៎ះឯង ។

សេដ្ឋីនោះ ឃ្លាតចាកអត្តភាពនោះហើយ កើតក្នុងទេវលោក អន្ទោលទៅក្នុងទេវលោកនិងមនុស្សលោក ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលសេដ្ឋីក្នុងភទ្ទិយនគរ សូម្បីភរិយារបស់គាត់ ក៏កើតក្នុងត្រកូលមានភោគៈច្រើន ចម្រើនវ័យហើយ បានទៅកាន់ផ្ទះរបស់លោកសេដ្ឋី ។ ពពែទាំងឡាយ មានប្រការដូចពោលហើយ អាស្រ័យកម្មក្នុងកាលមុនរបស់សេដ្ឋី ក៏ផុសឡើងខាងក្រោយផ្ទះ សូម្បីកូនប្រុស ក៏បានជាកូនប្រុសរបស់គាត់ដដែល កូនប្រសាស្រីបានជាកូនប្រសាស្រីរបស់គាត់ដដែល

ទាសៈក៏បានជាទាសៈរបស់សេដ្ឋីនិងភរិយាដដែល ។ ថ្ងៃមួយ សេដ្ឋីបំណងដើម្បីល្បងបុណ្យរបស់ខ្លួន ទើបឲ្យមនុស្សសម្អាតជង្រុក ១២៥០ កក់សក់ហើយអង្គុយត្រង់ទ្វារ សម្លឹងមើលខាងលើ ជង្រុកទាំងអស់ពេញហើយដោយស្រូវសាលីក្រហម មានប្រការដូចពោលហើយ ។ សេដ្ឋីនោះ ប្រាថ្នានឹងសាកល្បងបុណ្យរបស់ជនដ៏សេស ទើបពោលនឹងភរិយានិងកូនប្រុសជាដើមថា អ្នកទាំងឡាយ ចូរពិសោធបុណ្យរបស់ពួកអ្នកចុះ ។

លំដាប់នោះ ភរិយារបស់សេដ្ឋីនោះ ប្រដាប់ហើយដោយគ្រឿងអលង្ការទាំងពួង កាលមហាជនកំពុងមើលនុ៎ះឯង ប្រើឲ្យមនុស្សវាល់អង្ករ ឲ្យចម្អិនបាយដោយអង្ករទាំងនោះ អង្គុយលើអាសនៈដែលគេក្រាលទុកហើយត្រង់ខ្លោងទ្វារ កាន់វែកមាស ប្រកាសថា បុគ្គលណាត្រូវការដោយភត្ត ចូរមក ហើយបានឲ្យភត្តពេញភាជនៈ ដល់ជនដែលមកហើយ ៗ ។ កាលគាត់ឲ្យពេញមួយថ្ងៃ ប្រាកដខូងចំពោះត្រង់ទីដែលដួសដោយវែកដំបូងប៉ុណ្ណោះ ។ បាតដៃខាងឆ្វេងរបស់គាត់ មានក្រឡាចេញជារូបផ្កាឈូក បាតដៃខាងស្តាំ មានក្រឡាចេញជារូបព្រះចន្ទ ព្រោះគាត់ចាប់ឆ្នាំងបាយដោយដៃឆ្វេង ចាប់វែកដោយដៃស្តាំ ហើយដួសភត្តដាក់រហូតពេញបាត្រ ប្រគេនដល់ភិក្ខុសង្ឃរបស់ព្រះពុទ្ធទាំងឡាយក្នុងកាលមុន ដោយប្រការដូច្នេះឯង ។ បាតជើងខាងស្តាំរបស់គាត់ មាន

ក្រឡាចេញជារូបព្រះចន្ទ បាតជើងខាងឆ្វេង មានក្រឡាចេញជារូបផ្កាឈូក ព្រោះហេតុដែលគាត់កាន់យកជម្ពក្រែក ដោយដៃឆ្វេង ត្រងទឹកប្រគេនដល់ភិក្ខុសង្ឃ ដើរទៅមក ។ ព្រោះហេតុនេះ ទើបពួកញាតិដាក់ឈ្មោះគាត់ថា ចន្ទបទុមា ។

សូម្បីកូនប្រុសរបស់លោកសេដ្ឋីនោះ កក់សក់ហើយ កាន់យកថង់កហាបណៈ ១ ពាន់ ពោលថា អ្នកណាត្រូវការកហាបណៈ ចូរមកបានឲ្យកហាបណៈពេញភាជន៍ ដល់ពួកជនដែលមកហើយ ៗ ។ កហាបណៈ ១ ពាន់ ក៏មាននៅក្នុងថង់ដដែល ។ ចំណែកកូនប្រសាស្រីរបស់សេដ្ឋីនោះ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង កាន់យកល្អីដាក់ស្រូវ ហើយអង្គុយត្រង់ទីវាល ពោលថា អ្នកត្រូវការស្រូវពូជ ចូរមកចុះ ហើយបានឲ្យស្រូវពូជពេញភាជន៍ ដល់ជនដែលមកហើយ ៗ ។ ល្អីស្រូវក៏នៅពេញដូចដើមដដែល ។ ឯទាសៈរបស់សេដ្ឋីនោះ ប្រដាប់ហើយដោយគ្រឿងអលង្ការទាំងពួង ទឹមគោក្នុងនឹមដែលធ្វើអំពីមាសដោយខ្សែមាស កាន់យកជន្ទួញមាស យកម្រាមដៃទាំង ៥ ជ្រលក់គ្រឿងក្រអូប ហើយប្រោះព្រំដល់គោទាំងឡាយ ដែលពាក់ចង្កឹមាសត្រង់ស្នែងទាំងឡាយ ចុះកាន់ស្រែហើយភ្ជួរ ។ គន្ទង ៧ គឺខាងឆ្វេង ៣ ខាងស្តាំ ៣ កណ្តាល ១ បានបែកទៅហើយ ។ អ្នកជម្ពូទ្វីបកាន់យកទ្រព្យ មានពូជ ភត្ត ប្រាក់ មាសជាដើម អំពីផ្ទះសេដ្ឋីប៉ុណ្ណោះ តាម

ដែលខ្លួនគាប់ចិត្ត ។

សេដ្ឋីមានអានុភាពច្រើនយ៉ាងនោះ បានឮថា ព្រះសាស្តាយាង មកហើយ គិតថា អញនឹងធ្វើការទទួលដំណើរព្រះសាស្តា ខណៈធ្វើដំណើរទៅ ក៏បានចួបពួកតិរ្ថិយក្នុងរវាងផ្លូវ សូម្បីត្រូវពួកតិរ្ថិយទាំងនោះឃាត់ថា គហបតី លោកជាកិរិយវាទ ទៅកាន់សម្នាក់របស់ព្រះគោតម ដែលជាអកិរិយវាទដើម្បីអ្វី ។ លោកសេដ្ឋីក៏មិនបានដាក់ចិត្តក្នុងពាក្យរបស់ពួកតិរ្ថិយទាំងនោះ ត្រាច់ទៅហើយ ថ្វាយបង្គំព្រះសាស្តា អង្គុយក្នុងចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់អនុបុព្វីកថាដល់សេដ្ឋីនោះ ក្នុងកាលចប់ទេសនា សេដ្ឋីសម្រេចសោតាបត្តិផល ហើយក្រាបទូលភាពដែលខ្លួនត្រូវពួកតិរ្ថិយពោលទោស ហើយឃាត់ទុក ចំពោះព្រះសាស្តា ។ លំដាប់នោះ ព្រះសាស្តាត្រាស់ថា ម្នាលគហបតី ឈ្មោះថា សត្វទាំងនេះរមែងមិនឃើញទោសរបស់ខ្លួន សូម្បីច្រើន រមែងឃើញទោសរបស់ជនដទៃ សូម្បីមិនមាន ធ្វើឲ្យមាន ដូចបុគ្គលបាចអង្កាមទៅក្នុងទីនោះ ៗ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

សុទស្សំ វជ្ជមញ្ញេសំ　　អត្តនោ បន ទុទ្ទសំ
បរេសំ ហិ សោ វជ្ជានិ　　ឱបុនាតិ យថាភុសំ
អត្តនោ បន ឆាទេតិ　　កលឹវ កិតវា សឋោ ។

ទោសរបស់ពួកជនដទៃ ឃើញបានដោយងាយ ចំណែកទោសរបស់ខ្លួន ឃើញបានដោយលំបាក ព្រោះថា បុគ្គលនោះ រោយទោសទាំងឡាយ ចំពោះពួកជនដទៃ ដូចបុគ្គលរោយអង្កាមដូច្នោះ តែថា រមែងបិទបាំងទោសរបស់ខ្លួនទុក ដូចព្រានបក្សីបិទបាំងអត្តភាពដោយវត្ថុសម្រាប់បិទបាំង ( មានមែកឈើជាដើម ) ដូច្នោះ ។

ក្នុងកាលចប់ព្រះធម្មទេសនា មហាជនទាំងឡាយ បានសម្រេចអរិយផល មានសោតាបត្តិផលជាដើម ច្រើនសន្ធឹកសន្ធាប់ដោយប្រការដូច្នេះ ។

## មេណ្ឌកសេដ្ឋី ចប់ [១]

---

១-ស្រង់ចាកអដ្ឋកថា ធម្មបទ បិ.៥២ ទំ.៧៤ ឃ.២៨ ។

# ទរីមុខជាតក

ព្រះសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធមហាភិនេស្រ្កមណ៍ ទើបត្រាស់រឿងនេះថា

ក្នុងអតីតកាល ព្រះរាជាព្រះនាមថា មគធរាជ សោយរាជសម្បត្តិនៅក្នុងនគររាជគ្រឹះ ។ ក្នុងកាលនោះ ព្រះពោធិសត្វកាន់យកកំណើតក្នុងព្រះឧទរនៃអគ្គមហេសីរបស់ព្រះអង្គ ។ ព្រះញាតិទាំងឡាយបានថ្វាយព្រះនាមព្រះពោធិសត្វថា ព្រហ្មទត្តកុមារ ។ ក្នុងថ្ងៃដែលព្រះរាជកុមារប្រសូតនុ៎ះឯង បុត្តរបស់បុរោហិតក៏កើត ។ ទឹកមុខរបស់កុមារនោះល្អពន់ពេក ព្រោះហេតុនោះ ទើបញាតិរបស់កុមារឲ្យឈ្មោះថា ទរីមុខៈ ។

កុមារទាំងពីរនោះ ចម្រើនហើយក្នុងរាជត្រកូលប៉ុណ្ណោះ កុមារទាំងនោះ ជាសម្លាញ់នឹងគ្នា លុះមានអាយុ ១៦ វស្សា បានទៅកាន់នគរតក្កសិលារៀនសិល្បសាស្រ្តគ្រប់យ៉ាង ហើយនាំគ្នាត្រាច់ទៅក្នុងគាមនិគមជាដើម ដោយតាំងចិត្តថា នឹងនាំគ្នាសិក្សាគ្រប់លទ្ធិ និងស្គាល់ទំនៀមទម្លាប់តាមតំបន់ ដល់នគរពារាណសី ស្នាក់នៅត្រង់ទេវស្ថាន ( កន្លែងបូជាទេវតា ) ។ ស្អែកឡើង នាំគ្នាចូលទៅកាន់នគរពារាណសីដើម្បីភិក្ខា ។ មនុស្សក្នុងត្រកូលនីមួយ ៗ ក្នុងនគរពារាណសីនោះ តាំងចិត្តថា ពួកយើងនឹងអង្គាសព្រាហ្មណ៍ ហើយថ្វាយគ្រឿងបូជា ទើបចម្អិនបាយាស ហើយក្រាលអាសនៈទុក ។ មនុស្សទាំងឡាយឃើញជនទាំង

ពីរនោះកំពុងត្រាច់ភិក្ខា យល់ថា ព្រាហ្មណ៍មកហើយ ទើបអញ្ជើញឲ្យចូលទៅក្នុងផ្ទះ ក្រាលសំពត់សទុកសម្រាប់ព្រះមហាសត្វ ក្រាលសំពត់ក្រហមទុកសម្រាប់ទរីមុខកុមារ ។ ទរីមុខកុមារឃើញនិមិត្តនោះហើយដឹងច្បាស់ថា ថ្ងៃនេះ សម្លាញ់របស់អញនឹងបានជាព្រះបាទពារាណសី ឯអញនឹងបានជាសេនាបតី ។ ជនទាំងពីរបរិភោគក្នុងទីនោះ ហើយទទួលយកគ្រឿងបូជា ពោលមង្គលហើយចេញទៅ បានទៅដល់ព្រះរាជឧទ្យាន ។ បណ្ដាជនទាំងពីរនោះ ព្រះមហាសត្វផ្ទំលើផ្ទាំងសិលាមង្គល ឯទរីមុខកុមារអង្គុយច្របាច់ព្រះបាទរបស់ព្រះមហាសត្វនោះ ។

ថ្ងៃនោះ ជាថ្ងៃទី ៧ នៃការសោយទិវង្គតរបស់ព្រះបាទពារាណសី បុរោហិតថ្វាយព្រះភ្លើងព្រះសពហើយ បានផ្សងបុស្សរថ ក្នុងថ្ងៃទី ៧ ព្រោះរាជសម្បត្តិមិនមានរជ្ជទាយាទ ។ កិច្ចដែលទាក់ទងដោយការផ្សងបុស្សរថ មានជាក់ច្បាស់ហើយ ក្នុងមហាជនកជាតក ។ បុស្សរថនោះចេញអំពីនគរទៅ មានចតុរង្គសេនាចោមរោម មួយអន្ទើដោយតូរ្យតន្ត្រីច្រើនរយ ប្រគំ ដល់ទ្វារព្រះរាជឧទ្យាន ។ គ្រានោះ ទរីមុខកុមារបានឮសំឡេងតូរ្យតន្ត្រីហើយ គិតថា បុស្សរថមកហើយ ដើម្បីសម្លាញ់របស់អញ ថ្ងៃនេះ សម្លាញ់របស់អញនឹងបានជាព្រះរាជា ហើយនឹងប្រទានតំណែងសេនាបតីដល់អញ ប្រយោជន៍អ្វីរបស់អញដោយការគ្រប់គ្រងផ្ទះ អញនឹងចេញបួស ដូច្នេះហើយ ទើបមិនលាព្រះពោធិសត្វ ទៅ

កាន់ទីសមគួរនោចំណែកម្ខាង ហើយបានឈរក្នុងទីកំបាំង ។ បុរោហិតបញ្ឈប់រថត្រង់ទ្វារព្រះរាជឧទ្យានហើយ ចូលទៅកាន់ព្រះរាជឧទ្យាន ឃើញព្រះពោធិសត្វផ្ទំលើមង្គលសិលា ពិនិត្យមើលលក្ខណៈត្រង់ផ្ទៃព្រះបាទហើយ ដឹងថា សត្វនេះ ជាអ្នកមានបុណ្យ អាចគ្រងរាជសម្បត្តិក្នុងមហាទ្វីបទាំង ៤ មានទ្វីបតូច ២ ពាន់ ជាបរិវារបាន តែបញ្ញារបស់បុគ្គលនេះ ដូចម្ដេចហ្ន៎ ទើបឲ្យប្រគំតូរ្យតន្ត្រីទាំងអស់ ។ ព្រះពោធិសត្វភ្ញាក់អំពីផ្ទំហើយ ទ្រង់យកសំពត់សាដកចេញអំពីព្រះភក្ត្រ ទតឃើញមហាជនហើយ ទ្រង់យកសំពត់សាដកបិទព្រះភក្ត្រវិញ ផ្ទំបន្តិចទៀតរម្ងាប់សេចក្ដីក្រវល់ក្រវាយហើយ ក្រោកឡើងប្រថាប់គង់ពត់ភ្នែនលើផ្ទាំងសិលា ។ បុរោហិតលុតជង្គង់ក្រាបទូលថា បពិត្រព្រះសម្មតិទេពរាជសម្បត្តិមកដល់ព្រះអង្គហើយ ។

ព្រះពោធិសត្វសួរថា រាជសម្បត្តិមិនមានរជ្ជទាយាទទេឬ ។ បុរោហិតក្រាបទូលថា មិនមានទេ ព្រះអង្គ ។

ព្រះពោធិសត្វពោលថា បើដូច្នោះ ប្រពៃហើយ ។ ជនទាំងនោះបាននាំគ្នាធ្វើការអភិសេកព្រះពោធិសត្វ ត្រង់ព្រះរាជឧទ្យាននោះឯងទ្រង់មិនបានរឭកដល់ទរីមុខកុមារ ព្រោះភាពនៃខ្លួនមានយសច្រើន ទ្រង់ឡើងរាជរថ មានមហាជនចោមរោម ចូលកាន់នគរ ទ្រង់ធ្វើប្រទក្សិណហើយប្រថាប់ឈរត្រង់ទ្វារព្រះរាជនិវេសន៍នុ៎ះឯង ទ្រង់ពិចារណាដល់

ឋានន្តរៈរបស់អាមាត្យទាំងឡាយ ហើយឡើងកាន់ប្រាសាទ ។

ខណៈនោះ ទរីមុខកុមារគិតថា ឥឡូវនេះ ឧទ្យានទំនេរហើយ ទើបមកអង្គុយត្រង់មង្គលសិលា ។ លំដាប់នោះ ស្លឹកឈើទុំបានជ្រុះមកខាងមុខទរីមុខកុមារ ។ ទរីមុខកុមារផ្តើមនូវការអស់ទៅសូន្យទៅក្នុងស្លឹកឈើទុំប៉ុណ្ណោះ ពិចារណាត្រៃលក្ខណ៍ ញុំាងផែនដីឲ្យលាន់ឮឡើង ញុំាងបច្ចេកពោធិញ្ញាណឲ្យកើតឡើងហើយ ក្នុងខណៈនោះឯង យភាវសភេទក៏អន្តរធានទៅ បាត្រនិងចីវរដែលសម្រេចដោយឫទ្ធិ ក៏ធ្លាក់ចុះមកអំពីអាកាស ស្រោបសរីរៈរបស់លោក ។ រំពេចនោះឯង លោកក៏ជាបុគ្គលទ្រទ្រង់នូវបរិក្ខារ ៨ សម្បូរដោយឥរិយាបថ ដូចព្រះថេរៈមានវស្សា ៦០ ហោះទៅក្នុងអាកាសដោយឫទ្ធិ បានទៅកាន់ញកភ្នំនន្ទមូលកៈ ក្នុងហិមវន្តប្បទេស ។ ឯព្រះពោធិសត្វក៏សោយរាជសម្បត្តិដោយធម៌ តែព្រោះភាពជាអ្នកមានយសច្រើន ទើបទ្រង់ស្រវឹងដោយយស មិននឹកនាដល់ទរីមុខសម្លាញ់ អស់កាល ៤០ ឆ្នាំ ។ លុះកន្លងទៅ ៤០ ឆ្នាំ ទ្រង់រឭកបានហើយ ទើបត្រាស់ថា ខ្ញុំមានសម្លាញ់ម្នាក់ ឈ្មោះទរីមុខៈ គេនៅឯណាហ្ន៎ ដូច្នេះហើយ មានព្រះរាជបំណងនឹងចួបសម្លាញ់នោះ ។ ចាប់តាំងអំពីនោះមក ទ្រង់ក៏ត្រាស់សួររកខាងក្នុងនគរខ្លះ កណ្តាលបរិស័ទខ្លះថា ទរីមុខៈ សម្លាញ់របស់ខ្ញុំនៅឯណា បុគ្គលណាប្រាប់លំនៅរបស់សម្លាញ់នោះដល់ខ្ញុំ ខ្ញុំនឹងឲ្យយសធំដល់បុគ្គលនោះ ។ កាលទ្រង់

ឡេកឡើយ ៗ យ៉ាងនេះ ឆ្នាំដទៃកន្លងទៅទៀត អស់ ១០ ឆ្នាំ ។

ក្នុងកាលកន្លងទៅ ៤០ ឆ្នាំ **ព្រះទរីមុខបច្ចេកពុទ្ធ** ឡេកដល់ ក៏ជ្រាបថា សម្លាញ់នឹកដល់អាត្មាអញ ហើយត្រិះរិះថា ឥឡូវនេះ ព្រះរាជានោះ ទ្រង់ព្រះជរា ចម្រើនដោយព្រះរាជឱរស និងព្រះរាជធីតា អាត្មាអញនឹងទៅសម្ដែងធម៌ថ្វាយ ឲ្យទ្រង់បួស ដូច្នេះហើយ ទើបទៅតាមអាកាសដោយឫទ្ធិ ចុះត្រង់ព្រះរាជឧទ្យាន អង្គុយលើផ្ទាំងថ្ម ដូចបដិមាមាស ។ នាយឧទ្យានបាលឃើញលោកហើយ ចូលទៅជិត ទូលសួរថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់និមន្តមកអំពីទីណា ។

ព្រះបច្ចេកពុទ្ធតបថា អាត្មាមកអំពីញកភ្នំនន្ទមូលកៈ ។ អ្នករក្សាឧទ្យានសួរថា លោកម្ចាស់ឈ្មោះអ្វី ។ ព្រះបច្ចេកពុទ្ធពោលថា អ្នកមានអាយុ អាត្មាភាពឈ្មោះទរីមុខបច្ចេកពុទ្ធ ។ អ្នករក្សាឧទ្យានសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ស្គាល់ព្រះរាជារបស់ខ្ញុំដែរឬ ។

ព្រះបច្ចេកពុទ្ធពោលថា អាត្មាស្គាល់ កាលជាគ្រហស្ថ ទ្រង់ជាសម្លាញ់របស់អាត្មា ។ អ្នករក្សាឧទ្យានពោលថា បពិត្រលោកម្ចាស់ ព្រះរាជាមានបំណងចង់ចួបលោកម្ចាស់ ខ្ញុំនឹងទៅក្រាបទូលព្រះរាជាអំពីដំណើរដែលលោកម្ចាស់និមន្តមក ។

ព្រះបច្ចេកពុទ្ធពោលថា ចូរអ្នកទៅក្រាបទូលព្រះរាជាចុះ ។ អ្នករក្សាឧទ្យានទទួលថា សាធុ ហើយប្រញាប់ចេញទៅទូលថ្វាយព្រះរាជា

អំពីដំណើររបស់ព្រះទរីមុខបច្ចេកពុទ្ធ ដែលគង់នៅត្រង់ផ្ទាំងថ្មហើយ ។ ព្រះរាជាត្រាស់ថា បានឮថា សម្លាញ់របស់យើងមកហើយ យើងនឹងទៅសួរសុខទុក្ខលោក ហើយយាងឡើងរថទៅកាន់ព្រះរាជឧទ្យាន មួយអន្លើដោយបរិវារដ៏ច្រើន ថ្វាយបង្គំព្រះបច្ចេកពុទ្ធ ធ្វើបដិសណ្ឋារៈហើយគង់ក្នុងទីសមគួរនាចំណែកម្ខាង ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធធ្វើបដិសណ្ឋារៈចំពោះព្រះរាជាហើយ ពោលពាក្យជាដើមថា សូមថ្វាយព្រះពរព្រហ្មទត្តទ្រង់សោយរាជសម្បត្តិដោយធម៌ឬ ទ្រង់មិនលុះក្នុងអំណាចអគតិទេឬ ទ្រង់មិនបៀតបៀនមហាជនដើម្បីទ្រព្យទេឬ ទ្រង់បំពេញបុណ្យទាំងឡាយ មានទានជាដើមឬ ហើយពោលបន្តថា សូមថ្វាយព្រះពរព្រហ្មទត្ត ទ្រង់ជរាហើយ ឥឡូវនេះ ជាសម័យរបស់ព្រះអង្គដែលគួរលះបង់នូវកាម ហើយចេញបួស កាលនឹងសម្ដែងធម៌ថ្វាយព្រះរាជា ទើបពោលគាថាដំបូងថា

**បង្កោ ច កាមា បលិបោ ច កាមា**
**ភយញ្ច មេតំ តិមូលំ បវុត្តំ**
**រជោ ច ធូមោ ច មយា បកាសិតា**
**ហិត្វា តុវំ បព្វជ ព្រហ្មទត្ត ។**

កាមទាំងឡាយ ដូចភក់ផង កាមទាំងឡាយ ដូចគ្រឿងស្អិតផង នេះជាភ័យមានឫសគល់ ៣ យ៉ាង ដែលព្រះសម្ពុទ្ធពោលទុកហើយ កាមទាំងឡាយ ដូចធូលីផង ដូចផ្សែងផង

ដែលអាត្មាប្រកាសហើយ បពិត្រព្រះរាជាព្រហ្មទត្ត សូមព្រះអង្គលះបង់ ( កាមទាំងនោះ ) ហើយបួសចុះ ។

ព្រះរាជា កាលទ្រង់ស្តាប់ពាក្យនោះហើយ កាលប្រាប់ភាពដែលទ្រង់ជាប់ដោយកិលេសទាំងឡាយ ទើបត្រាស់គាថាទី ២ ថា

**គធិតោ ច រត្តោ ច អធិមុច្ឆិតោ ច**
**កាមេស្វាហំ ព្រាហ្មណ ភឹសរូបំ**
**តំ នុស្សហេ ជីវិកាត្ថោ បហាតុំ**
**កាហាមិ បុញ្ញានិ អនប្បកានិ ។**

បពិត្រព្រាហ្មណ៍ ខ្ញុំជាអ្នកជាប់ចំពាក់ ត្រេកអរជ្រុលជ្រប់ក្នុងកាមទាំងឡាយ ជាអ្នកត្រូវការដោយជីវិត មិនអាចដើម្បីលះនូវកាម មានសភាពគួរខ្លាចនោះ បានទេ ខ្ញុំនឹងធ្វើបុណ្យទាំងឡាយច្រើន ។

ដែលឈ្មោះថា បុគ្គលអ្នកមានកិលេសកាមយ៉ាងនេះ មិនអាចនឹងនាំកិលេសកាមនោះ ចេញចាកចិត្តបានទេ ព្រះមហាបុរសអ្នកមានចិត្តសៅហ្មងហើយ ព្រោះកិលេសកាមឯណា សូម្បីកាលព្រះបច្ចេកពុទ្ធត្រាស់ដល់គុណរបស់បព្វជ្ជាហើយ ក៏នៅតែត្រាស់ថា ខ្ញុំមិនអាចបួសបានទេ ។ ព្រះបាទព្រហ្មទត្តអង្គនេះ កាលទ្រង់ពិចារណាមើលពុទ្ធ-ការកធម៌ ដោយព្រះញាណដែលកើតឡើងក្នុងព្រះអង្គ ទៀបបាទមូល

ព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់ឃើញនេក្ខម្មបារមីទី ៣ ហើយ ទើបទ្រង់សរសើរគុណនេក្ខម្ម:យ៉ាងនេះថា

ឥមំ ត្វំ តតិយំ តាវ ទឡ្ហំ កត្វា សមាទិយ
នេក្ខម្មបារមិតំ គច្ឆ យទិ ពោធឹ បត្តុមិច្ឆសិ ។

អ្នកចូរសមាទាន ធ្វើនេក្ខម្មបារមីទី ៣ នេះ ឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវនេក្ខម្មបារមីចុះ ។

យថា អន្ទុឃរេ បុរិសោ ចិរំ វុដ្ឋោ ទុក្ខទ្ទិតោ
ន តត្ថ រាគំ អភិជនេតិ មុត្តឹយេវ គវេសតិ ។

បុរសដែលជាប់នៅក្នុងគុក អស់កាលយូរ ត្រូវសេចក្ដីទុក្ខបៀតបៀនហើយ រមែងមិនញុំាងសេចក្ដីត្រេកអរ ឲ្យកើតឡើងក្នុងគុកនោះទេ រមែងស្វែងរកការរួច ( ចាកគុកនោះ ) យ៉ាងណា ។

តថេវ ត្វំ សព្វភវេ បស្ស អន្ទុឃរេ វិយ
នេក្ខម្មាភិមុខោ ហោហិ ភវតោ បរិមុត្តិយា ។

អ្នក ចូរឃើញនូវភពទាំងអស់ ដូចជាគុកចុះ ចូរបែរមុខទៅរកនេក្ខម្ម: ដើម្បីរួចចាកភព យ៉ាងនោះដែរ [១] ។

ព្រះបាទព្រហ្មទត្តនោះ សូម្បីជាបុគ្គលដែលព្រះបច្ចេកពុទ្ធពោល

---

១-បិ.៧៧ ទំ.៤៣ ឃ.២ ។

សរសើរបព្វជ្ជា ហើយថ្វាយព្រះពរថា សូមមហាបពិត្រ ទ្រង់លះបង់កិលេសទាំងឡាយ ហើយទ្រង់ជាសមណៈចុះ ក៏នៅតែត្រាស់ថា ខ្ញុំមិនអាចលះបង់នូវកិលេសទាំងឡាយ ហើយបួសជាសមណៈបានទេ ។

បានឮថា មនុស្សឆ្កួតក្នុងលោកនេះ មាន ៨ ពួក ព្រោះហេតុនោះ ទើបបុរាណាចារ្យពោលទុកថា បុគ្គលដែលបានសញ្ញាថា ឆ្កួត មាន ៨ ពួកគឺ

**កាមុម្មត្តកោ** ឆ្កួតព្រោះកាម គឺធ្លាក់នៅក្នុងអំណាចលោភៈ ១ ។

**កោធុម្មត្តកោ** ឆ្កួតព្រោះក្រោធ គឺធ្លាក់នៅក្នុងអំណាចទោសៈ ១ ។

**ទិដ្ឋុម្មត្តកោ** ឆ្កួតព្រោះទិដ្ឋិ ឬឆ្កួតព្រោះលទ្ធិ គឺធ្លាក់ក្នុងអំណាចការយល់ខុស ១ ។

**មោហុម្មត្តកោ** ឆ្កួតព្រោះវង្វេង គឺធ្លាក់ក្នុងអំណាចការមិនដឹង ១ ។

**យក្ខុម្មត្តកោ** ឆ្កួតព្រោះយក្ខចូល គឺធ្លាក់ក្នុងអំណាចយក្ខ ១ ។

**បិត្តុម្មត្តកោ** ឆ្កួតព្រោះប្រមាត់កម្រើក គឺធ្លាក់ក្នុងអំណាចរបស់ប្រមាត់ ១ ។

**សុរុម្មត្តកោ** ឆ្កួតព្រោះសុរា គឺធ្លាក់ក្នុងអំណាចរបស់សុរា ១ ។

**ព្យសនុម្មត្តកោ** ឆ្កួតព្រោះវិនាស គឺធ្លាក់ក្នុងអំណាចនៃសេចក្ដីវិនាសទ្រព្យជាដើម ១ ។

ក្នុងឆ្កួត ៨ ពួកនេះ ព្រះមហាសត្វក្នុងជាតកនេះ ឆ្កួតព្រោះធ្លាក់

ក្នុងកាម ធ្លាក់ក្រោមអំណាចសេចក្ដីលោភ ទើបមិនដឹងគុណរបស់បព្វជ្ជា ។

សួរថា សេចក្ដីលោភនេះ ធ្វើវត្ថុដែលមិនជាប្រយោជន៍ ទម្លាយគុណដូចប្រការដែលពោលមកហើយនេះ តើហេតុអ្វី ទើបសត្វទាំងឡាយមិនអាចរួចផុតបាន ។

ឆ្លើយថា ព្រោះការលោភនោះ ចម្រើនមកហើយ ដោយរួមគ្នាច្រើនសែនកោដិកប្ប ក្នុងសំសារៈដែលមិនដឹងខាងដើមនិងទីបំផុត កាលបើដូច្នេះ ទើបបណ្ឌិតទាំងឡាយ លះដោយអំណាចការពិចារណាច្រើនយ៉ាងថា កាមទាំងឡាយ មានសេចក្ដីត្រេកអរតិចជាដើម ។

ព្រះទរីមុខបច្ចេកពុទ្ធ សូម្បីព្រះមហាសត្វត្រាស់ថា ខ្ញុំមិនអាចបួសបានទេ ក៏មិនដាក់ធុរៈ កាលនឹងថ្វាយព្រះឱវាទឲ្យក្រៃលែង ទើបពោលគាថា ២ ថា

**យោ អត្ថកាមស្ស ហិតានុកម្បិនោ**
**ឱវជ្ជមានោ ន ករោតិ សាសនំ**
**ឥទមេវ សេយ្យោ ឥតិ មញ្ញមានោ**
**បុនប្បុនំ គព្ភមុបេតិ មន្ទោ ។**

បុគ្គលណា កាលគេប្រាថ្នាសេចក្ដីចម្រើន អនុគ្រោះដោយប្រយោជន៍ ប្រៀនប្រដៅ តែមិនធ្វើតាមពាក្យប្រៀនប្រដៅ សម្គាល់ថា នេះឯងប្រសើរ ជាមនុស្ស

*លូង់ខ្លៅ រមែងចូលទៅកាន់គភ៌ញយៗ ។*

សោ ឃោររូបំ និរយំ ឧបេតិ

សុភាសុភំ មុត្តករីសបូរំ

សត្តា សកាយេ ន ជហន្តិ គិទ្ធា

យេ ហោន្តិ កាមេសុ អវីតរាគា ។

*បុគ្គលលូង់ខ្លៅនោះ រមែងចូលទៅកាន់នរក មានសភាពដ៏ពន្លឹក ជាទីមិនស្អាតដល់ពួកកុលបុត្តអ្នកស្អាត ពេញដោយមូត្រនិងករីសៈ សត្វទាំងឡាយណា ជាអ្នកមិនទាន់ប្រាសចាករាគៈ ជាប់ចំពាក់ក្នុងកាមទាំងឡាយ សត្វទាំងឡាយនោះ រមែងមិនលះបង់នូវសកាយៈ ( ការនៅក្នុងគភ៌ ) ។*

*ព្រះទវីមុខបច្ចេកពុទ្ធ កាលសម្តែងទុក្ខដែលមានការចុះកាន់គភ៌ជាមូលផង មានការបរិហារជាមូលផង ឥឡូវនេះ កាលសម្តែងដល់ទុក្ខព្រោះចេញចាកគភ៌ជាមូល ទើបពោលមួយគាថាកន្ទះថា*

មិឡ្ហេន លិត្តា រុហិរេន មក្ខិតា

សេម្ហេន លិត្តា ឧបនិក្ខមន្តិ

យំ យំ ហិ កាយេន ផុសន្តិ តាវទេ

សព្វំ អសាតំ ទុក្ខមេវ កេវលំ ។

*សត្វទាំងឡាយ ប្រសូត ( ចាកគភ៌នៃមាតា ) រមែង*

*ជាប់ដោយលាមក ប្រឡាក់ដោយឈាម ជាប់ដោយ*
*រម្អិល ប៉ះពាល់នូវទ្វារជាទីប្រសូតណា ៗ ដោយកាយ*
*ក្នុងខណៈនោះ ទ្វារទាំងអស់នោះ ជារបស់មិនស្អាត*
*សុទ្ធតែជាទុក្ខទាំងអស់ ។*

**ទិស្វា វទាមិ ន ហិ អញ្ញតោ សវំ**
**បុព្វេនិវាសំ ពហុកំ សរាមិ ។**

*អាត្មាឃើញ ទើបពោល មិនមែនស្តាប់អំពីបុគ្គល*
*ដទៃទេ អាត្មារឭកឃើញនូវបុព្វេនិវាសច្រើន ។*

*ឥឡូវនេះ ព្រះសាស្តាទ្រង់ត្រាស់ដឹងក្រៃលែងហើយ កាលត្រាស់ថា ព្រះបច្ចេកពុទ្ធនោះ សង្គ្រោះព្រះរាជាដោយព្រះគាថាជាសុភាសិតយ៉ាងនេះហើយ ទើបទ្រង់ត្រាស់កន្ទះគាថាចុងក្រោយថា*

**ចិត្រាហិ គាថាហិ សុភាសិតាហិ**
**ទរីមុខោ និជ្ឈាបយី សុមេធំ ។**

*ព្រះបច្ចេកពុទ្ធ ព្រះនាមទរីមុខៈ ពន្យល់ស្តេចព្រហ្មទត្ត*
*មានប្រាជ្ញាល្អ ដោយគាថាទាំងឡាយដ៏វិចិត្រ ដែល*
*សម្តែងហើយដោយល្អ ។*

*ព្រះបច្ចេកពុទ្ធ កាលសម្តែងទោសក្នុងកាមទាំងឡាយ ញុំាងព្រះរាជាឲ្យទ្រង់កាន់យកពាក្យរបស់លោកយ៉ាងនេះហើយ ទើបពោលថា*

សូមថ្វាយព្រះពរមហាបពិត្រ ឥឡូវនេះ ទ្រង់បួស ឬមិនបួស ក៏តាមព្រះរាជហឫទ័យចុះ តែអាត្មាភាពបានសម្តែងទោសក្នុងកាមទាំងឡាយ និងអានិសង្សក្នុងការបួស ថ្វាយមហាបពិត្រហើយ សូមទ្រង់កុំប្រមាទ ហើយបានហោះទៅក្នុងអាកាស ជាន់ពពក ទៅកាន់ញកភ្នំនន្ទមូលកៈវិញ ដូចស្តេចហង្សមាសដូច្នោះ ។ ព្រះមហាសត្វទ្រង់ផ្គងអញ្ជលីដ៏រុងរឿងដោយម្រាម ១០ ដាក់លើព្រះសិរសា នមស្ការ កាលព្រះបច្ចេកពុទ្ធទៅផុតកន្ទុយភ្នែកហើយ ទើបឲ្យហៅព្រះរាជបុត្តច្បងមកគាល់ ទ្រង់ប្រគល់រាជសម្បត្តិ កាលមហាជនកំពុងយំ ទ្រង់លះកាមទាំងឡាយទៅកាន់ព្រៃហិមពាន្ត សាងបណ្ណសាលា បួសជាឥសី មិនយូរប៉ុន្មាន ក៏បានញុំាងអភិញ្ញានិងសមាបត្តិឲ្យកើតឡើង ក្នុងកាលអស់ព្រះជន្មាយុ ក៏បានទៅកាន់ព្រហ្មលោក ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទើបប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈទាំងឡាយ ជនទាំងឡាយ បានជាព្រះសោតាបន្នបុគ្គលជាដើម ច្រើនសន្ធឹកសន្ធាប់ ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ គឺតថាគតនេះឯង ។

**ទរីមុខជាតក ចប់** [១]

---

១-ស្រង់ចាកអដ្ឋកថា ជាតក ឆក្កនិបាត បិ.៥៩ ទំ.៣៨ ឃ.១៤២ ។

# វិជ្ជាធរជាតក (១)

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធលោកត្តចរិយា ទើបត្រាស់រឿងនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វជាសក្កទេវរាជ ។ ក្នុងកាលនោះ វិជ្ជាធរម្នាក់រាយមន្តហើយ ចូលទៅកាន់បន្ទប់ដ៏មានសិរីក្នុងពេលរាត្រី ប្រព្រឹត្តកន្លងក្នុងអគ្គមហេសីនៃព្រះបាទពារាណសី ទាសីរបស់ព្រះនាងបានដឹងហើយ ទើបព្រះនាងចូលគាល់ព្រះរាជាខ្លួនឯង ក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព បុរសម្នាក់ចូលមកក្នុងបន្ទប់ដ៏មានសិរី កណ្តាលរាត្រី បំពានលើខ្ញុំម្ចាស់ ។

ព្រះរាជាត្រាស់សួរថា នាងអាចធ្វើគ្រឿងសម្គាល់ គឺសញ្ញាណាមួយទុកលើបុរសនោះ បានដែរឬទេ ។

ព្រះនាងក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់អាច ។ ព្រះនាងឲ្យដាក់ជាតិហិង្គុល ( ទឹកល័ក្ត ) ក្នុងថាសយកមកថ្វាយ កាលបុរសនោះ មកក្នុងពេលរាត្រី រួមអភិរម្យហើយ ព្រះនាងប្រថាប់ម្រាមទាំង ៥ លើខ្នង បានក្រាបទូលព្រះរាជាអំពីព្រលឹម ។ ព្រះរាជាបញ្ជាមនុស្ស

---

១-បិដកខ្មែរ ជា បព្វជិតវិហេឋកជាតក ។

ទាំងឡាយថា អ្នកទាំងឡាយ ចូរទៅ ចូរនាំគ្នាពិនិត្យគ្រប់ទិស ហើយចាប់បុរសដែលមានស្នាមល័ក្ខម្រាម ៥ នៅលើខ្នង ។ ចំណែកវិជ្ជាធរនោះ កាលធ្វើអនាចារក្នុងពេលយប់ហើយ ពេលថ្ងៃ ក៏ឈរជើងមួយនមស្ការព្រះអាទិត្យត្រង់ទីរហោឋាន ។ រាជបុរសឃើញបុរសនោះហើយក៏នាំគ្នាព័ទ្ធចាប់ ។ បុរសនោះគិតថា កម្មរបស់អញប្រាកដហើយ ទើបរាយវេទហោះទៅក្នុងអាកាស ។

ព្រះរាជាទ្រង់ឃើញបុរសនោះហោះទៅហើយដែរ ទើបត្រាស់សួររាជបុរសដែលមកហើយថា អ្នកទាំងឡាយបានឃើញដែរឬទេ ។ រាជបុរសក្រាបទូលថា បានឃើញព្រះអង្គ ។

ព្រះរាជាត្រាស់សួរថា គេនុ៎ះ ជានរណា ។ រាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព ជាបព្វជិត ។ បានឮថា ពេលយប់ បុរសនោះ ធ្វើអនាចារ តែពេលថ្ងៃ បុរសនោះ នៅដោយភេទបព្វជិត ។ ព្រះរាជាទ្រង់ខ្ញាល់នឹងបព្វជិតទាំងឡាយថា បព្វជិតទាំងនេះ ពេលថ្ងៃប្រព្រឹត្តភេទសមណៈ ពេលយប់ធ្វើអនាចារ ព្រះរាជាទ្រង់យល់ខុស ទើបទ្រង់ឲ្យវាយស្គរប្រកាសថា អ្នកទាំងឡាយ ចូរស្តាប់ព្រះរាជឱង្ការក្នុងទីដែលខ្លួនបានឮហើយថា បព្វជិតទាំងអស់ ចូរចៀសចេញអំពីអាណាចក្ររបស់យើង ដូច្នេះហើយ ទើបបព្វជិតទាំងអស់គេចចេញអំពីដែនកាសី ដែលមានទំហំ ៣០០ យោជន៍ បាននាំគ្នាទៅកាន់រាជធានីដទៃ ៗ ។

សមណព្រាហ្មណ៍ដែលទ្រទ្រង់ធម៌ សូម្បីតែម្នាក់ ដែលឲ្យឱវាទដល់មនុស្សទាំងឡាយក្នុងដែនកាសី មិនមាន ។ មនុស្សទាំងឡាយដែលមិនបានទទួលឱវាទ បានជាបុគ្គលពាលគ្រោតគ្រាត មនុស្សទាំងឡាយលះបង់ទាននិងសីលជាដើម ស្លាប់ហើយ ដោយច្រើន កើតក្នុងអបាយឈ្មោះថា កើតក្នុងស្ថានសួគ៌ មិនមាន ។

សក្កទេវរាជ កាលមិនឃើញទេវបុត្តថ្មី ៗ កើតឡើង ទើបពិចារណាមើលថា មានហេតុអ្វីហ្ន៎ ទ្រង់ជ្រាបថា ព្រះបាទពារាណសីទ្រង់ពិរោធព្រោះអាស្រ័យវិជ្ជាធរ ទ្រង់បណ្ដេញបព្វជិតចេញអំពីដែន ព្រោះទ្រង់យល់ខុស អ្នកដទៃក្រៅអំពីអញ ដែលអាចទម្លាយនូវការប្រកាន់ខុសរបស់ព្រះរាជាអង្គនេះ មិនមាន អញនឹងជាទីពឹងរបស់ព្រះរាជានិងអ្នកដែនទាំងឡាយ ហើយយាងទៅកាន់សម្នាក់ **ព្រះបច្ចេកពុទ្ធ** ទាំងឡាយត្រង់ញកភ្នំនន្ទមូលកៈ ទ្រង់ថ្វាយបង្គំហើយទូលថា បពិត្រលោកម្ចាស់សូមលោកម្ចាស់ទាំងឡាយ ឲ្យព្រះបច្ចេកពុទ្ធចាស់ជរាមួយអង្គដល់ខ្ញុំ ខ្ញុំនឹងឲ្យមហាជនក្នុងដែនកាសីជ្រះថ្លា ។ សក្កទេវរាជបានព្រះសង្ឃត្ថេរនោះឯង ។ លំដាប់នោះ ទើបទ្រង់ទទួលយកបាត្រនិងចីវររបស់ព្រះបច្ចេកពុទ្ធនោះ ឲ្យលោកនៅអំពីខាងមុខ ទ្រង់នៅអំពីខាងក្រោយ ទ្រង់កាឡាភេទជាមាណពដែលមានរូបឧត្តម ផ្គងអញ្ជលីលើសិរសា នមស្ការព្រះបច្ចេកសម្ពុទ្ធ បានហោះលើនគរទាំងមូល ៣ ជុំ មកដល់ទ្វារព្រះ

រាជវាំង បានប្រថាប់ឈរលើអាកាស ។ អាមាត្យទាំងឡាយក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព មាណពរូបស្អាតម្នាក់ នាំសមណៈមួយរូបមកឈរលើអាកាស ត្រង់ទ្វារព្រះរាជវាំង ។

ព្រះរាជាទ្រង់ក្រោកចាកអាសនៈ ប្រថាប់ឈរត្រង់បង្អួច ទ្រង់ចរចាជាមួយសក្កៈនោះថា នែមាណព អ្នកមានរូបស្អាត ហេតុអ្វី ទើបឈរកាន់បាត្រនិងចីវររបស់សមណៈដែលមានរូបអាក្រក់ ហើយនមស្ការដូច្នេះ ហើយត្រាស់ព្រះគាថាទី ១ ថា

ទុព្វណ្ណរូបំ ត្វមរិយវណ្ណី
បុរក្ខិត្វា បញ្ជលិកោ នមស្សសិ
សេយ្យោ នុ តេ សោ ឧទាហុ សរិក្ខោ
នាមំ បរស្សត្តនោ ចាបិ ព្រូហិ ។

អ្នកមានពណ៌ទ្រង់ទ្រាយដ៏ល្អ ផ្គងអញ្ជលីនមស្ការ
តម្កល់នូវបុគ្គលមានរូបអាក្រក់ អំពីខាងមុខ តើបុរស
នោះ ប្រសើរជាងអ្នក ឬប្រហែលគ្នា អ្នកចូរប្រាប់នូវ
ឈ្មោះនៃអ្នកឯទៀតផង នៃខ្លួនផង ។

លំដាប់នោះ សក្កទេវរាជត្រាស់តបព្រះរាជាថា មហាបពិត្រឈ្មោះថា សមណៈទាំងឡាយ រមែងជាបុគ្គលគួរគោរព ព្រោះហេតុនោះ ទើបខ្ញុំមិនបានហៅឈ្មោះរបស់លោក តែខ្ញុំនឹងប្រាប់ឈ្មោះរបស់

ខ្ញុំដល់ទ្រង់ ហើយបានត្រាស់គាថាទី ២ ថា

**ន នាមគោត្តំ គណ្ហន្តិ រាជ**
**សម្មគ្គតានុជ្ជុគតាន ទេវា**
**អហញ្ច តេ នាមធេយ្យំ វទាមិ**
**សក្កោហមស្មិ តិទសានមិន្ទោ ។**

*បពិត្រព្រះរាជា ទេវតាទាំងឡាយ មិនកាន់យកនូវនាមនិងគោត្ត ព្រះខីណាស្រព អ្នកដល់នូវការស្ងប់ ទាំងប្រព្រឹត្តតាមផ្លូវត្រង់ ប៉ុន្តែខ្ញុំនឹងសូមប្រាប់ឈ្មោះ ( ខ្លួនខ្ញុំ ) ដល់ព្រះអង្គ ខ្ញុំជាសក្កៈ ជាធំជាងទេវតាជាន់តាវត្តិង្ស ។*

*ព្រះរាជាស្តាប់ពាក្យនោះហើយ បានត្រាស់សួរដល់អានិសង្សនៃការថ្វាយបង្គំភិក្ខុ ដោយគាថាទី ៣ ថា*

**យោ ទិស្វា ភិក្ខុំ ចរណូបបន្នំ**
**បុរក្ខិត្វា បញ្ជលិកោ នមស្សតិ**
**បុច្ឆាមិ តំ ទេវរាជេតមត្ថំ**
**ឥតោ ចុតោ កឹ លភតេ សុខំ សោ ។**

*បុគ្គលណា ឃើញនូវភិក្ខុអ្នកបរិបូណ៌ដោយចរណៈ ហើយផ្គងអញ្ជលីនមស្ការ តម្កល់ទុកក្នុងខាងមុខ*

*បពិត្រទេវរាជ ខ្ញុំសូមសួរនូវដំណើរនុ៎ះ ចំពោះព្រះអង្គ បុគ្គលនោះ លុះច្យុតចាកលោកនេះទៅ រមែងបានសេចក្ដីសុខ ដូចម្ដេច ។*

*សក្កទេវរាជឆ្លើយតបដោយគាថាទី ៤ ថា*

**យោ ទិស្វា ភិក្ខុំ ចរណូបបន្នំ**
**បុរក្ខិត្វា បញ្ជលិកោ នមស្សតិ**
**ទិដ្ឋេវ ធម្មេ លភតេ បសំសំ**
**សគ្គញ្ច សោ យាតិ សរីរភេទា ។**

*បុគ្គលណា ឃើញនូវភិក្ខុដែលបរិបូណ៌ដោយចរណៈ ហើយផ្គងអញ្ជលីនមស្ការ តម្កល់ទុកក្នុងខាងមុខ បុគ្គលនោះ រមែងបាននូវសេចក្ដីសរសើរក្នុងបច្ចុប្បន្ន លុះបុគ្គលនោះ បែកធ្លាយសរីរកាយ រមែងទៅកាន់ឋានសួគ៌ ។*

*ព្រះរាជាទ្រង់ស្ដាប់គាថារបស់សក្កទេវរាជហើយ កម្ចាត់បង់នូវការប្រកាន់ខុសរបស់ខ្លួន ពេញព្រះរាជហឫទ័យ បានត្រាស់គាថាទី ៥ ថា*

**លក្ខី វត មេ ឧទបាទិ អជ្ជ**
**យំ វាសវំ ភូតិបតិទ្ទសប្បាម**
**ភិក្ខុញ្ច ទិស្វាន តុវញ្ច សក្ក**

កាហាមិ បុញ្ញានិ អនប្បកានិ ។

*ឱហ្ន៎ សិរីរបស់អញកើតឡើងក្នុងថ្ងៃនេះ ព្រោះអញបានឃើញនូវវាសវៈ ជាម្ចាស់នៃភូត បពិត្រសក្កៈ ខ្ញុំនឹងធ្វើនូវបុណ្យជាច្រើន ព្រោះបានឃើញនូវភិក្ខុផង ព្រះអង្គផង ។*

*សក្កទេវរាជបានស្តាប់ពាក្យនោះហើយ កាលទ្រង់សរសើរបណ្ឌិតទើបត្រាស់គាថាទី ៦ ថា*

អទ្ធា ហវេ សេវិតព្វា សបញ្ញា
ពហុស្សុតា យេ ពហុឋានចិន្តិនោ
ភិក្ខុញ្ច ឥស្វាន មមញ្ច រាជ
ករោហិ បុញ្ញានិ អនប្បកានិ ។

*បុគ្គលណា ប្រកបដោយបញ្ញា ជាពហុស្សូត អាចគិតឃើញនូវហេតុជាច្រើន ( ព្រះអង្គ ) គប្បីសេពគប់ ( បុគ្គលនោះ ) ដោយពិត បពិត្រព្រះរាជា ព្រោះព្រះអង្គបានឃើញភិក្ខុនិងខ្ញុំ សូមធ្វើបុណ្យជាច្រើនចុះ ។*

*ព្រះរាជាបានស្តាប់ព្រះតម្រាស់នោះហើយ ទើបត្រាស់គាថាចុងក្រោយថា*

អក្កោធនោ និច្ចបសន្នចិត្តោ
សព្វាតិថីយាចយោគោ ភវិត្វា
និហច្ច មានំ អភិវាទយិស្សំ
សុត្វាន ទេវិន្ទ សុភាសិតានិ ។

*បពិត្រព្រះអង្គជាធំជាងទេវតា ខ្ញុំនឹងជាអ្នកមិនមានសេចក្ដីក្រោធ មានចិត្តជ្រះថ្លាជានិច្ច ជាអ្នកគួរដល់អ្នកដំណើរ និងស្មូមទាំងអស់ សង្កត់សង្កិននូវមានះ ថ្វាយបង្គំ ព្រោះបានស្ដាប់នូវសុភាសិត ( របស់ព្រះអង្គ ) ។*

*ព្រះរាជា កាលត្រាស់ដូច្នេះហើយ ទ្រង់ចុះអំពីប្រាសាទ ថ្វាយបង្គំព្រះបច្ចេកពុទ្ធ រួចប្រថាប់ឈរនាចំណែកម្ខាង ។ ព្រះបច្ចេកពុទ្ធគង់ពត់ភ្នែនក្នុងអាកាស ថ្វាយឱវាទព្រះរាជាថា ថ្វាយព្រះពរមហាបពិត្រ វិជ្ជាធរនោះ មិនមែនជាសមណៈ ចាប់ពីពេលនេះទៅ សូមទ្រង់ជ្រាបថា លោកសន្និវាសមិនទទេឡើយ គង់មានសមណព្រាហ្មណ៍ដែលទ្រទ្រង់ធម៌ សូមទ្រង់ឲ្យទាន រក្សាសីល ធ្វើឧបោសថកម្មចុះ ។ សូម្បីសក្កទេវរាជក៏ទ្រង់ប្រថាប់ឈរត្រង់អាកាស ដោយអានុភាពរបស់សក្កៈ ប្រទានឱវាទដល់អ្នកនគរថា តាំងអំពីនេះទៅ អ្នកទាំងឡាយ ចូរកុំប្រមាទ ទ្រង់ឲ្យវាយស្គរប្រកាសថា សមណព្រាហ្មណ៍ទាំងឡាយ ដែលគេចទៅហើយ*

សូមត្រឡប់មក ។ សក្កទេវរាជនិងព្រះបច្ចេកពុទ្ធបានទៅកាន់លំនៅរបស់ខ្លួន ។ ព្រះរាជាទ្រង់តាំងនៅក្នុងឱវាទរបស់ព្រះបច្ចេកពុទ្ធ និងសក្កទេវរាជហើយ បានធ្វើបុណ្យទាំងឡាយ មានទានជាដើម ។

ព្រះសាស្តា លុះទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះបច្ចេកពុទ្ធក្នុងកាលនោះ បានបរិនិព្វានហើយ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែកសក្កទេវរាជ គឺតថាគតនេះឯង ។

**វិជ្ជាធរជាតក ចប់** (១)

១-ស្រង់ចាកអដ្ឋកថា ជាតក ឆក្កនិបាត បិ.៥៩ ទំ.៦២ ឃ.២៣៦ ។

# កុម្ភការជាតក

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការសង្កត់-សង្កិនកិលេស ទើបត្រាស់រឿងនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជ្យក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលស្មូនឆ្នាំង ក្នុងស្រុកក្បែរទ្វារក្រុងពារាណសីនោះ ចម្រើនវ័យហើយ សន្សំទុកដាក់ទ្រព្យសម្បត្តិ បានកូនប្រុសមួយ កូនស្រីមួយ ចិញ្ចឹមបុត្តភរិយាព្រោះអាស្រ័យការងារធ្វើឆ្នាំង ។ ក្នុងកាលនោះ ព្រះរាជាព្រះនាមករណ្ឌកៈ ក្នុងទន្តបុរនគរ ដែនកលិង្គៈ កាលយាងទៅកាន់ព្រះរាជឧទ្យានជាមួយរាជបរិវារធំ ទតឃើញដើមស្វាយក្បែរទ្វារព្រះរាជឧទ្យាន មានផ្លែគួរចង់សោយ ពេញទៅដោយផ្លែជាចង្កោម ៗ គង់លើកដំរីដ៏ប្រសើរដែលកំពុងទៅនោះឯង ទ្រង់លាព្រះហស្ត បេះផ្លែស្វាយមួយ ហើយយាងទៅកាន់ព្រះរាជឧទ្យាន ប្រថាប់គង់លើមង្គលសិលា ព្រះរាជទានដល់មនុស្សដែលគួរព្រះរាជទានហើយ ទើបសោយផ្លែស្វាយ ។ ចាប់តាំងពីពេលដែលព្រះរាជាទ្រង់បេះផ្លែស្វាយហើយ មនុស្សដ៏សេសទាំងឡាយ ក៏នាំគ្នាបេះ សូម្បីអាមាត្យ ព្រាហ្មណ៍ និងគហបតីជាដើម ក៏នាំគ្នាធ្វើផ្លែស្វាយឲ្យជ្រុះ ហើយបរិភោគ ។ ជនដែលមកឯក្រោយ ក៏ឡើងបេះ ប្រើដំបងគ្រវែង ធ្វើឲ្យបាក់បែកហើយបរិភោគ

សូម្បីតែផ្លែខ្ចី ៗ ក៏មិនមានសេសសល់ ។

ចំណែកព្រះរាជា ទ្រង់លេងកីឡាក្នុងព្រះរាជឧទ្យានពេញមួយថ្ងៃហើយ លុះពេលល្ងាច ទ្រង់ប្រថាប់គង់លើកដំរីដ៏ប្រសើរដែលគេតាក់តែងហើយ យាងមក ទតឃើញដើមស្វាយនោះ ទើបចុះអំពីដំរីចូលទៅត្រង់គល់ស្វាយ ទ្រង់សម្លឹងមើលបណ្តើរត្រិះរិះបណ្តើរថា ស្វាយនេះ ព្រឹកមិញពេញទៅដោយផ្លែ ជាចង្កោមល្អពេកណាស់ ធ្វើនូវការមិនឆ្អែតភ្នែកដល់អ្នកមើលទាំងឡាយ ឥឡូវនេះ គេបេះផ្លែអស់ហើយ សល់តែមែកទទេមិនស្អាត ។ កាលទ្រង់មើលហើយមើលទៀត ឃើញដើមស្វាយដទៃ មិនមានផ្លែ ប្រថាប់ឈរត្រង់គល់ស្វាយប៉ុណ្ណោះ ធ្វើដើមស្វាយដែលមិនមានផ្លែឲ្យជាអារម្មណ៍ថា ដើមឈើនោះ ឋិតនៅយ៉ាងស្រស់ត្រកាល ដូចកំពូលភ្នំកែវមណីត្រងិល ព្រោះមិនមានផ្លែ ចំណែកស្វាយនេះ ដល់នូវសេចក្តីវិនាស ព្រោះចេញផ្លែ សូម្បីត្រង់កណ្តាលផ្ទះនេះ ក៏ដូចគ្នានឹងដើមស្វាយដែលមានផ្លែ ឯបព្វជ្ជាដូចគ្នានឹងដើមឈើដែលមិនមានផ្លែ បុគ្គលមានទ្រព្យប៉ុណ្ណោះ ជាអ្នកមានភ័យ ចំណែកបុគ្គលមិនមានទ្រព្យ មិនមានភ័យទេ សូម្បីអាត្មាអញក៏គប្បីជាអ្នកដូចដើមឈើដែលមិនមានផ្លែ ដូច្នេះហើយ ទ្រង់កំណត់ត្រៃលក្ខណ៍ ចម្រើនវិបស្សនា ញ៉ាំងបច្ចេកពោធិញ្ញាណឲ្យកើតឡើងហើយ ទ្រង់ពិចារណាថា ឥឡូវនេះ អញទម្លាយខ្ទម គឺផ្ទៃមាតាហើយ បដិសន្ធិក្នុងភព ៣ អញផ្តាច់ផ្តិលហើយ បង្គន់នៃឧច្ចារៈគឺ

សំសារៈ អញលាងសម្អាតហើយ សមុទ្ទទឹកភ្នែក អញបាចឲ្យស្ងួតហើយ កំពែងឆ្អឹងអញទម្លាយហើយ អញមិនមានបដិសន្ធិទៀតឡើយ ព្រះរាជាទ្រង់កំពុងទ្រទ្រង់នូវគ្រឿងអលង្ការទាំងអស់នុ៎ះឯង ប្រថាប់ឈរហើយ ។

លំដាប់នោះ អាមាត្យទាំងឡាយក្រាបទូលថា **អតិពហុំ បិតត្ថ មហារាជ** បពិត្រមហារាជ ទ្រង់ប្រថាប់ឈរយូរពេកហើយ ។

ព្រះបច្ចេកពុទ្ធពោលថា **ន មយំ មហារាជានោ** អាត្មាមិនមែនព្រះរាជារបស់អ្នកទាំងឡាយ **បច្ចេកពុទ្ធា នាម មយំ** អាត្មាជា **ព្រះបច្ចេកពុទ្ធ** ។

អាមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេព ធម្មតាព្រះបច្ចេកពុទ្ធទាំងឡាយ មិនដូចទ្រង់ឡើយ ។

ព្រះបច្ចេកពុទ្ធសួរថា បើដូច្នោះ ដូចអ្វី ។

ពួកអាមាត្យក្រាបទូលថា ព្រះបច្ចេកពុទ្ធមិនមានសក់ មិនមានពុកមាត់ បិទបាំងរាងកាយដោយកាសាវពស្ត្រ មិនជាប់ចំពាក់ក្នុងត្រកូលនិងពួកគណៈ មានចំណែកប្រៀបដូចពពកដែលត្រូវខ្យល់បក់ និងប្រៀបដូចមណ្ឌលព្រះចន្ទផុតអំពីមាត់រាហូ គង់នៅត្រង់ញកភ្នំនន្ទមូលកៈ នាព្រៃហិមពាន្ត បពិត្រព្រះទេវៈ ព្រះបច្ចេកពុទ្ធទាំងឡាយមានសភាពបែបនេះ ។ ក្នុងខណៈនោះ ព្រះបច្ចេកពុទ្ធលើកព្រះហស្តឡើង ស្ទាបព្រះកេសា រំពេចនោះឯង គិហិភាវៈ ក៏អន្តរធានទៅ សមណភេទក៏ប្រាកដ

ឡើង ។ សមណបរិក្ខារទាំងឡាយ ដែលទ្រង់ត្រាស់យ៉ាងនេះថា

**តិចីវរញ្ច បត្តោ ច  វាសិ សូចិ ច ពន្ធនំ**
**បរិស្សាវនេន អដ្ឋេតេ  យុត្តយោគស្ស ភិក្ខុនោ ។**

ត្រៃចីវរ បាត្រ កាំបិតកោរ ម្ជុល វត្ថពន្ធចង្កេះ និង តម្រងទឹក ៨ យ៉ាងនេះ ជាបរិក្ខាររបស់ភិក្ខុដែលប្រកប សេចក្តីព្យាយាម ។

បានបិទបាំងកាយរបស់ទ្រង់មួយរំពេច ។ ព្រះបច្ចេកពុទ្ធឈរក្នុងអាកាស ឲ្យឱវាទដល់មហាជនហើយ បានទៅកាន់ញកភ្នំនន្ទមូលក: នាព្រៃហិមពាន្តទិសខាងជើង តាមអាកាសនុ៎ះឯង ។

ចំណែកព្រះរាជាព្រះនាមថា នគ្គជិ ក្នុងនគរតក្កសិលា ដែនគន្ធារ: យាងទៅគង់លើរាជបល្ល័ង្ក ខាងលើផ្ទៃប្រាសាទ ទតឃើញស្រីម្នាក់មានដៃប្រដាប់ដោយកងកែវមណី ម្ខាងមួយ អង្គុយបុកគ្រឿងក្រអូប ក្នុងទីមិនឆ្ងាយ ទ្រង់ទតបណ្តើរត្រិះរិះបណ្តើរថា កងដៃ ( កែវមណី ) ទាំងនោះមិនទង្គិចគ្នា មិនមានសំឡេង ព្រោះនៅម្ខាង ១ គឺនៅបែកគ្នា ។ ក្រោយមក ស្រីនោះ ក៏ដោះកងពីដៃខាងស្តាំ យកទៅពាក់ដៃខាងឆ្វេង ហើយក៏ចាប់ទាញនូវដុំលម្អិត មកបុក កងទី ២ ដែលនៅត្រង់ដៃឆ្វេង ក៏ប៉ះទង្គិចគ្នា ( ជាមួយកងទី ១ ) ធ្វើសំឡេងឡើង ។ ព្រះរាជាទ្រង់ទតឃើញកងទាំងពីរនោះ ប៉ះគ្នា មានសំឡេងខ្លាំង ទើបទ្រង់ព្រះតម្រិះថា

កងដៃនេះ កាលនៅក្នុងដៃម្ខាងមួយ មិនទង្គិចគ្នា កាលនៅរួមគ្នាទាំងពីរក្នុងដៃតែម្ខាង ក៏មានសំឡេងខ្លាំង យ៉ាងណា សូម្បីសត្វទាំងឡាយនេះ ក៏យ៉ាងនោះដូចគ្នា បើនៅម្នាក់ឯង មិនប៉ះទង្គិចគ្នា មិនមានសំឡេង តែលុះមានគ្នា ២-៣ នាក់ ឡើងទៅ ក៏ប៉ះគ្នានឹងគ្នា ធ្វើនូវជម្លោះទាស់ទែងឯអញពិចារណា ( គ្រប់គ្រង ) រាស្ត្រក្នុងរាជសម្បត្តិ ២ កន្លែង គឺក្នុងដែនកស្មីរៈនិងដែនគន្ធារៈ អញគួរដូចជាកងដៃតែម្ខាង មិនរក្សាបុគ្គលដទៃ រក្សាខ្លួនឯងប៉ុណ្ណោះ ហើយទ្រង់ធ្វើការប៉ះទង្គិចគ្នានៃកងដៃ ឲ្យជាអារម្មណ៍ ទាំងដែលកំពុងអង្គុយនោះឯង ទ្រង់កំណត់ត្រៃលក្ខណ៍ចម្រើនវិបស្សនា ញុំាងបច្ចេកពោធិញ្ញាណឲ្យកើតឡើងហើយ ។ សេចក្ដីដែលសេសសល់ ដូចគ្នានឹងន័យមុននោះឯង ។

នៅឯមិថិលានគរ ក្នុងវិទេហរដ្ឋ ព្រះរាជាព្រះនាមនិមិរាជ សោយព្រះក្រយាស្ងោយព្រឹកហើយ មានគណៈអាមាត្យហែហម ប្រថាប់ឈរទតចន្លោះវិថីតាមបង្អួចដែលបើក ។ លំដាប់នោះ ខ្លែងមួយឆាបដុំសាច់អំពីជ្រញ់អ្នកលក់ ហើយហើរទៅក្នុងអាកាស ។ សត្វទាំងឡាយ មានត្មាតជាដើម ក៏ហើរចោមរោមខ្លែងនោះ ខាងនោះខ្លះ ខាងនេះខ្លះ ប្រើចំពុះចឹក ប្រើស្លាបវាយ ប្រើជើងខ្ទាំ ព្រោះហេតុនៃអាហារ ។ ខ្លែងនោះ ទ្រាំនឹងការឈឺចាប់មិនបាន ទើបលែងដុំសាច់នោះទៅ សត្វដទៃក៏ពាំដុំសាច់នោះ សត្វដទៃនាំគ្នាបោះបង់ខ្លែងនោះ ហើយដេញតាមសត្វនោះទៅ ។

សូម្បីសត្វនោះក៏លែងដុំសាច់នោះទៀត សត្វដទៃក៏ពាំទៅ បក្សីទាំងឡាយក៏ចោមរោមចឹកសត្វនោះ យ៉ាងនោះដូចគ្នា ។ ព្រះរាជាទ្រង់ទតឃើញសត្វទាំងនោះហើយ ទ្រង់ព្រះតម្រិះថា បក្សីណា ៗ ពាំដុំសាច់ បក្សីនោះ ៗ ឯង ដល់នូវសេចក្ដីទុក្ខ ឯបក្សីណា ៗ លែងនូវដុំសាច់នោះចោល បក្សីនោះ ៗ ឯង មានសេចក្ដីសុខ កាមគុណ ៥ នេះ បុគ្គលណា ៗ ប្រកាន់ទុក បុគ្គលនោះ ៗ ឯង មានសេចក្ដីទុក្ខ ឯបុគ្គលណាមិនប្រកាន់ បុគ្គលនោះឯង មានសេចក្ដីសុខ ព្រោះកាមទាំងនេះ ជារបស់សាធារណៈសម្រាប់មនុស្សច្រើន ឯអញមានស្រីស្នំ ១៦ ពាន់នាក់ អញគួរលះកាមគុណ ៥ ហើយនៅជាសុខ ដូចខ្លែងដែលចោលដុំសាច់នេះ ។ ព្រះរាជានោះ ទ្រង់មនសិការដោយឧបាយ ទាំងដែលកំពុងឈរនុ៎ះឯង ទ្រង់កំណត់ត្រៃលក្ខណ៍ ចម្រើនវិបស្សនា ញុំាងបច្ចេកពោធិញ្ញាណឲ្យកើតឡើង ។ សេចក្ដីដែលសេសសល់ ដូចន័យមុននុ៎ះឯង ។

ក្នុងឧត្តរបញ្ចាលរដ្ឋ កបិលនគរ ព្រះរាជាព្រះនាមទុម្មុខៈ សោយព្រះក្រយាស្ងោយព្រឹកហើយ ទ្រង់ប្រដាប់គ្រឿងអលង្ការគ្រប់យ៉ាង មានពួកអាមាត្យចោមរោម ប្រថាប់ឈរទតលានព្រះរាជវាំង តាមសីហបញ្ជរដែលបើក ។ ក្នុងខណៈនោះ អ្នកចិញ្ចឹមគោទាំងឡាយក៏បើកក្រោលគោ ពួកគោបាចេញអំពីក្រោល ហើយដេញតាមគោញីមួយដោយអំណាចកិលេស ។ បណ្ដាគោទាំងនោះ គោឧសភៈមាឌធំមួយ មានស្នែងដ៏

មុត ឃើញគោដទៃកំពុងដើរមក ត្រូវសេចក្ដីកំណាញ់ដោយកិលេសគ្រប សង្កត់ ទើបយកស្នែងដ៏មុត បុះត្រង់ចន្លោះជើង ពោះវៀនធំទាំងឡាយ របស់គោនោះ ក៏ចេញមកក្រៅតាមមុខរបួស ដល់នូវការអស់ជីវិតក្នុង ទីនោះឯង ។ ព្រះរាជាទតឃើញហេតុការណ៍នោះ ទ្រង់ព្រះតម្រិះថា សត្វលោកទាំងឡាយ តាំងអំពីសត្វតិរច្ឆានជាដើមឡើងទៅ ដល់នូវ សេចក្ដីទុក្ខដោយអំណាចកិលេស គោនេះ អាស្រ័យកិលេស ដល់នូវការ អស់ជីវិត ។ ពួកសត្វដទៃក៏ញាប់ញ័រ ព្រោះកិលេសទាំងឡាយនោះឯង អញគួរប្រហារកិលេស ដែលជាហេតុឲ្យសត្វទាំងឡាយញាប់ញ័រ ។ ព្រះរាជាទ្រង់ប្រថាប់ឈរនុ៎ះឯង កំណត់ត្រៃលក្ខណ៍ ចម្រើនវិបស្សនា ញុំាងបច្ចេកពោធិញ្ញាណឲ្យកើតឡើងហើយ ។ អត្ថដ៏សេស ដូចគ្នានឹង រឿងមុននុ៎ះឯង ។

សម័យថ្ងៃមួយ ព្រះបច្ចេកពុទ្ធទាំងឡាយ ៤ អង្គនោះ កំណត់ កាលកិច្ចាចារហើយ ក៏ចេញអំពីញកភ្នំនន្ទមូលកៈ ទំពាឈើស្ទន់ឈ្មោះ នាគលតា ត្រង់អនោតត្តស្រះ ជម្រះព្រះកាយហើយ ប្រថាប់ឈរលើ ផ្ទាំងមនោសិលា ស្លៀកស្បង់ កាន់បាត្រនិងចីវរ ហោះឡើងទៅលើ អាកាសដោយឫទ្ធិ ជាន់ពពកដែលមានពណ៌ ៥ និមន្តទៅ ហើយចុះ ក្នុងទីមិនឆ្ងាយអំពីស្រុកក្បែរទ្វារនគរពារាណសី ដណ្ដប់ចីវរត្រង់ទីផាសុក មួយកន្លែង កាន់បាត្រចូលទៅក្នុងស្រុក ត្រាច់បិណ្ឌបាតដល់ទ្វារផ្ទះ

ព្រះពោធិសត្វ ។ ព្រះពោធិសត្វឃើញព្រះបច្ចេកពុទ្ធទាំងនោះហើយ ត្រេកអរ និមន្តឲ្យចូលទៅក្នុងផ្ទះ ឲ្យគង់លើអាសនៈដែលក្រាលទុក ថ្វាយទក្ខិណោទក អង្គាសដោយខាទនីយភោជនីយាហាររបស់ឆាន់ដ៏ប្រណីត ហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ថ្វាយបង្គំព្រះសង្ឃត្ថេរទូលសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន បព្វជ្ជារបស់លោកម្ចាស់ទាំងឡាយ ស្អាតពន់ពេក ឥន្ទ្រិយទាំងឡាយរបស់លោកម្ចាស់ក៏ផូរផង់ ឆវិវណ្ណក៏បរិសុទ្ធ លោកម្ចាស់ឃើញអារម្មណ៍ដូចម្តេចហ្ន៎ ទើបចូលដល់បព្វជ្ជា ហើយប្រព្រឹត្តបិណ្ឌបាត ។ ព្រះពោធិសត្វបានចូលទៅទូលសួរព្រះបច្ចេកពុទ្ធដ៏សេសដូចទូលសួរព្រះសង្ឃត្ថេរដូច្នោះ ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធទាំង ៤ អង្គនោះ បានប្រាប់រឿងចេញបួសរៀង ៗ ខ្លួន ដល់ព្រះពោធិសត្វនោះដោយន័យជាដើមថា អាត្មាជាព្រះរាជាឈ្មោះនោះ ក្នុងនគរឈ្មោះនោះ ក្នុងដែនឈ្មោះនោះ ហើយបានត្រាស់គាថាមួយអង្គ មួយគាថាថា

**អម្ពាហមទ្ទំ វនមន្តរស្មឹ**
**នីលោភាសំ ផលិតំ សំវិរូឡ្ហំ**
**តមទ្ទសំ ផលហេតុ វិភគ្គំ**
**តំ ទិស្វា ភិក្ខាចរិយំ ចរាមិ ។**

អាត្មាបានឃើញដើមស្វាយ ដុះលូតលាស់ ក្នុងកណ្តាលព្រៃ ស្វាយមានពណ៌ខៀវ មានផ្លែ អាត្មាឃើញស្វាយ

នោះ បាក់ខ្ទេចខ្ទី ព្រោះហេតុតែផ្លែ លុះឃើញស្វាយនោះហើយ ទើបអាត្មាប្រព្រឹត្តនូវភិក្ខាចារ ( ទៅបួស ) ។

សេលំ សុមដ្ឋំ នរវីរនិដ្ឋិតំ
នារី យុគំ ធារយិ អប្បសទ្ទំ
ទុតិយញ្ច អាគម្ម អហោសិ សទ្ទោ
តំ ទិស្វា ភិក្ខាចរិយំ ចរាមិ ។

នាងនារី (ម្នាក់) ពាក់កងជាវិការៈនៃកែវមណី ១ គូ ដ៏ស្អាតរលោង ដែលជនអ្នកចេះ ធ្វើឲ្យសម្រេចហើយ ឥតឮសូរសំឡេង ( ទង្គិចគ្នាឡើយ ) លុះដល់អាស្រ័យយកមកពាក់ ជាមួយគ្នានឹងកងទី ២ ក៏ (ទង្គិចគ្នា) ឮសូរសំឡេង អាត្មាបានឃើញនូវកងនោះហើយ ទើបប្រព្រឹត្តនូវភិក្ខាចារ ។

ទិជា ទិជំ កុណបមាហរន្តំ
ឯកំ សមានំ ពហុកា សមេច្ច
អាហារហេតុ បរិបាតយឹសុ
តំ ទិស្វា ភិក្ខាចរិយំ ចរាមិ ។

ពួកបក្សីច្រើន ចោមរោម ដេញចឹកបក្សី ១ កំពុងពាំដុំសាច់ ព្រោះហេតុតែអាហារ អាត្មាបានឃើញបក្សីនោះ

ហើយ ទើបប្រព្រឹត្តនូវភិក្ខាចារ ។

**ឧសភាហមទ្ទំ យូថស្ស មជ្ឈេ**
**វលកក្កុំ វណ្ណពលូបបន្នំ**
**តមទ្ទសំ កាមហេតុ វិតុន្នំ**
**តំ ទិស្វា ភិក្ខាចរិយំ ចរាមិ ។**

អាត្មាឃើញគោឧសភៈ ( មួយ ) កណ្ដាលហ្វូង មានបូកជ្រួញ ៗ បរិបូណ៌ដោយសម្បុរនិងកម្លាំង អាត្មាបានឃើញគោឧសភៈនោះ ត្រូវគោឧសភៈដទៃ បុះមុត ( ធ្លាយពោះវៀន ) ព្រោះហេតុតែកាម លុះបានឃើញគោឧសភៈនោះហើយ ទើបប្រព្រឹត្តនូវភិក្ខាចារ ។

ព្រះពោធិសត្វ កាលបានស្ដាប់គាថានីមួយ ៗ បានធ្វើការសរសើរព្រះបច្ចេកពុទ្ធគ្រប់ព្រះអង្គថា បពិត្រលោកម្ចាស់ដ៏ចម្រើន ប្រពៃហើយ អារម្មណ៍នោះ សមគួរសម្រាប់លោកម្ចាស់ទាំងឡាយ ពិតមែន ។ កាលព្រះពោធិសត្វស្ដាប់ធម្មកថា ដែលព្រះបច្ចេកពុទ្ធ ៤ អង្គនោះ សម្ដែងហើយ ជាអ្នកមិនជាប់ចំពាក់ក្នុងឃរាវាស ។ កាលព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តទៅហើយ បរិភោគអាហារព្រឹកហើយ អង្គុយជាសុខ បានហៅភរិយាមក ពោលថា នែនាងដ៏ចម្រើន ព្រះបច្ចេកពុទ្ធ ៤ អង្គនេះ លះរាជសម្បត្តិ ចេញបួស មិនមានសេចក្ដីប្រកាន់ មិនមានសេចក្ដីកង្វល់ ឲ្យ

កាលវេលាកន្លងទៅ ដោយសេចក្តីសុខដែលកើតអំពីបព្វជ្ជា ឯខ្ញុំចិញ្ចឹមជីវិតដោយថ្លៃឈ្នួល ប្រយោជន៍អ្វីដល់ខ្ញុំដោយការគ្រប់គ្រងផ្ទះ ចូរនាងសង្គ្រោះ គឺចិញ្ចឹមកូននៅក្នុងផ្ទះចុះ ហើយពោល ២ គាថាថា

ករណ្ឌកោ កលិង្គានំ  គន្ធារានញ្ច នគ្គជិ
និមិរាជា វិទេហានំ  បញ្ចាលានញ្ច ទុម្មុខោ
ឯតេ រដ្ឋានិ ហិត្វាន  បព្វជឹសុ អកិញ្ចនា ។

ព្រះរាជារបស់អ្នកដែនកលិង្គៈ ព្រះនាមករណ្ឌកៈ ព្រះរាជារបស់អ្នកដែនគន្ធារៈ ព្រះនាមនគ្គជិ ព្រះរាជារបស់អ្នកដែនវិទេហៈ ព្រះនាមនិមិរាជ ព្រះរាជារបស់អ្នកដែនបញ្ចាលៈ ព្រះនាមទុម្មុខៈ ព្រះរាជាទាំង ៤ ព្រះអង្គនុ៎ះ លះបង់នូវដែនទាំងឡាយ ជាអ្នកឥតកង្វល់ បួសហើយ ។

សព្វេបិមេ ទេវសមា សមាគតា
អគ្គី យថា បជ្ជលិតោ តថេវិមេ
អហំបិ ឯកោ ចរិស្សាមិ ភគ្គវិ
ហិត្វាន កាមានិ យថោធិកានិ ។

ព្រះរាជាទាំងអស់អង្គនេះ ប្រហែលគ្នានឹងវិសុទ្ធិទេវតា បានមកជួបគ្នាហើយ ព្រះរាជាទាំងនេះ ( រុងរឿងដោយគុណទាំងឡាយ មានសីលគុណជាដើម ) ដូច

ជាភ្លើងដែលភ្លឺរុងរឿងដូច្នោះឯង ម្នាលនាង មានភក្ត្រ
ចំណែកខាងបង ក៏នឹងលះបង់នូវកាមទាំងឡាយ ជា
ចំណែកដែលខ្លួននឿយណាយហើយ ប្រព្រឹត្តតែម្នាក់
ឯង ។

ភរិយានោះ កាលបានស្តាប់ពាក្យរបស់ព្រះពោធិសត្វហើយ ទើបពោលថា បពិត្រអ្នកជាម្ចាស់ តាំងអំពីកាលបានស្តាប់ធម្មកថារបស់ព្រះបច្ចេកពុទ្ធហើយ សូម្បីចិត្តខ្ញុំ ក៏មិនស្ថិតនៅក្នុងផ្ទះ ហើយបានពោលគាថានេះថា

**អយមេវ កាលោ ន ហិ អញ្ញោ អត្ថិ**
**អនុសាសិតោ មេ ន ភវេយ្យ បច្ឆា**
**អហម្បិ ឯកា ចរិស្សាមិ ភត្តរ**
**សកុណីវ មុត្តា បុរិសស្ស ហត្ថា ។**

កាលនេះ ជាកាលគួរ (នឹងបួសហើយ) ឥតមាន
កាលដទៃទៀតឡើយ (ព្រោះ) ដល់ទៅពេលក្រោយ
បុគ្គលជាអ្នកប្រៀនប្រដៅខ្ញុំ មិនមានទេ បពិត្រអ្នក
មានភក្ត្រ ខ្ញុំនឹងប្រព្រឹត្តតែម្នាក់ឯង ដូចជាមេបក្សីដែល
រួចអំពីដៃនៃបុរស ។

ព្រះពោធិសត្វ កាលបានស្តាប់ពាក្យរបស់នាងហើយ បាននៅ

ស្បៀម ។ ភរិយាព្រះពោធិសត្វនោះ បំណាងនឹងបញ្ឆោតព្រះពោធិសត្វ ហើយបួសមុន ទើបពោលថា បពិត្រអ្នកជាម្ចាស់ ខ្ញុំនឹងទៅកំពង់ទឹក សូមអ្នកមើលកូន ហើយកាន់យកក្អមទឹក ធ្វើអាកប្បកិរិយាដូចដើរទៅកំពង់ទឹក គេចទៅដល់សម្នាក់របស់ពួកតាបស ដែលនៅជិតនគរហើយ ក៏បួស ។ ព្រះពោធិសត្វដឹងថា នាងមិនមក ទើបចិញ្ចឹមទារកដោយខ្លួនឯង លុះក្មេងនោះធំបន្តិច ដល់នូវភាពជាអ្នកអាចដឹងនូវសេចក្តីចម្រើន និងសេចក្តីវិនាសរបស់ខ្លួន គឺដឹងក្តីហើយ កាលនឹងល្បងក្មេងទាំងនោះ ថ្ងៃមួយ ព្រះពោធិសត្វ កាលដណ្តាំបាយ បានដាំឲ្យឆៅបន្តិច ថ្ងៃមួយ ជ្រាយបន្តិច ថ្ងៃមួយឆ្អិនល្អ ថ្ងៃមួយជ្រាយខ្លាំង ថ្ងៃមួយចម្អិនអាហារសាប ថ្ងៃមួយចម្អិនឲ្យប្រៃ ។

ក្មេងទាំងឡាយពោលថា **តាត អជ្ជ ភត្តំ ឧត្តណ្ឌុលំ** បពិត្រលោកឪពុក ថ្ងៃនេះ បាយឆៅ **អជ្ជ កិលិន្នំ** ថ្ងៃនេះ បាយជ្រាយ **អជ្ជ សុបក្កំ** ថ្ងៃនេះ បាយឆ្អិនល្អ **អជ្ជ អតិកិលិន្នំ** ថ្ងៃនេះ បាយជ្រាយខ្លាំង **អជ្ជ អលោណកំ** ថ្ងៃនេះ សាប **អជ្ជ អតិលោណកំ** ថ្ងៃនេះ ប្រៃ ។

ព្រះពោធិសត្វពោលថា **អាម តាត** អើកូន ហើយគិតថា ឥឡូវនេះ ក្មេងទាំងនេះ ស្គាល់ឆៅ ឆ្អិន សាប និងប្រៃហើយ អាចចិញ្ចឹមជីវិតតាមធម្មតារបស់ខ្លួន អញគួរនឹងបួស ។ ក្រោយមក បានទុកដាក់

ក្មេងទាំងនោះ ឲ្យពួកញាតិ ហើយពោលថា នែអ្នកនិងនាង ចូរចិញ្ចឹមក្មេងទាំងនេះ ឲ្យល្អចុះ កាលពួកញាតិកំពុងយំរៀបរាប់នោះឯង បានចេញអំពីនគរ ទៅបួសជាឥសីនៅក្បែរ ៗ នគរនោះឯង ។

ថ្ងៃមួយ បរិព្វាជិកា គឺករិយាចាស់ បានឃើញព្រះពោធិសត្វកំពុងត្រាច់ទៅបិណ្ឌបាតក្នុងនគរពារាណសី ថ្វាយបង្គំហើយពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ទំនងជាឲ្យក្មេង គឺកូនទាំងឡាយវិនាសហើយ ។

ព្រះមហាសត្វឆ្លើយថា យើងមិនបានឲ្យក្មេង គឺកូនវិនាសឡើយ យើងចេញបួសក្នុងពេលដែលពួកក្មេងទាំងនោះ អាចដឹងសេចក្ដីចម្រើន និងសេចក្ដីវិនាស គឺដឹងល្អ ដឹងអាក្រក់របស់ខ្លួនហើយ នាងកុំគិតថ្វីឡើយ ចូរត្រេកអរក្នុងការបួសចុះ ហើយបានពោលគាថាចុងក្រោយថា

**អាមំ បក្កញ្ច ជានន្តិ  អថោ លោណំ អលោណកំ**
**តមហំ ទិស្វាន បព្វជឹ  ចរេវ ត្វំ ចរាមហំ ។**

( ទារកទាំងឡាយនោះ ) ស្គាល់បាយឆៅ បាយឆ្អិន ទាំងស្គាល់សម្ល និងសម្លសាបហើយ លុះយើងឃើញកិរិយារបស់ទារកនោះហើយ ទើបបួស នាងចូរប្រព្រឹត្តស្វែងរកនូវភិក្ខាចារចុះ យើងក៏នឹងប្រព្រឹត្តស្វែងរកនូវភិក្ខាចារដែរ ។

ព្រះពោធិសត្វដាស់តឿនបរិព្វាជិកានោះ ដោយប្រការដូច្នេះហើយ ក៏បញ្ជូននាងទៅ ឯបរិព្វាជិកាទទួលឱវាទ ថ្វាយបង្គំព្រះមហាសត្វហើយ

*ទើបទៅកាន់ទីតាមគាប់ចិត្ត ។ បានឮថា ក្រៅអំពីថ្ងៃនោះហើយ ជនទាំង ២ នោះ ក៏មិនបានចួបគ្នាទៀតឡើយ ។ ព្រះពោធិសត្វញុំាង ឈាននិងអភិញ្ញាឲ្យកើតឡើងហើយ បានជាអ្នកចូលដល់ព្រហ្មលោក ។*

*ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទើបប្រកាសសច្ចៈទាំងឡាយ ហើយទ្រង់ប្រជុំជាតក ។ ក្នុងទីបំផុតនៃសច្ចធម៌ ភិក្ខុ ៥០០ រូប បានសម្រេចអរហត្ត ។ កូនស្រីក្នុងកាលនោះ បានមកជាឧប្បលវណ្ណា កូនប្រុស បានមកជារាហុល បរិព្វាជិកា បានមកជារាហុលមាតា ចំណែកបរិព្វាជក គឺតថាគតនេះឯង ។*

**កុម្ភការជាតក ចប់** [១]

---

*១-ស្រង់ចាកអដ្ឋកថា ជាតក សត្តកនិបាត បិ.៥៩ ទំ.៩៤ ឃ.៣៥៥ ។*

# កុម្មាសបិណ្ឌិជាតក

ព្រះបរមសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាង មល្លិកាទេវី ទើបត្រាស់ព្រះធម្មទេសនានេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរ ពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអ្នកក្រីក្រមួយ ធំចម្រើនវ័យ ហើយ រស់នៅអាស្រ័យសេដ្ឋីម្នាក់ ធ្វើការងារស៊ីឈ្នួលចិញ្ចឹមជីវិត ។ ថ្ងៃ មួយ ព្រះពោធិសត្វកាន់នំកុម្មាសៈ ៤ ដុំ មកអំពីផ្សារ ដោយគិតថា នំ ទាំងនេះ ជាអាហារព្រឹករបស់អញ កាលដើរទៅធ្វើការងារ បានឃើញ **ព្រះបច្ចេកពុទ្ធ** ៤ អង្គ កំពុងនិមន្តមក បែរមុខទៅកាន់នគរពារាណសី ដើម្បីប្រយោជន៍ដល់ភិក្ខាចារ គិតថា ព្រះបច្ចេកពុទ្ធទាំងនេះ និមន្តទៅ កាន់នគរពារាណសីដើម្បីភិក្ខា អញមាននំកុម្មាសៈ ៤ ដុំ បើដូច្នោះ អញ គួរប្រគេននំទាំងនេះ ដល់ព្រះបច្ចេកពុទ្ធទាំងឡាយនោះ ដូច្នេះហើយ ចូលទៅជិត ពោលថា បពិត្រលោកម្ចាស់ ខ្ញុំមាននំកុម្មាសៈក្នុងដៃ ៤ ដុំ ខ្ញុំសូមប្រគេននំទាំងនេះ ដល់លោកម្ចាស់ទាំងឡាយ បពិត្រលោកម្ចាស់ ខ្ញុំ សូមឱកាស សូមលោកម្ចាស់ទាំងឡាយទទួលចុះ កាលបើដូច្នេះ បុណ្យ នេះ នឹងមានដល់ខ្ញុំ ដើម្បីប្រយោជន៍និងសេចក្តីសុខអស់កាលយូរ ។ បានដឹងការដែលលោកទទួលនិមន្តន៍ហើយ ក៏រៀបចំអាសនៈ ៤ ដោយ

ពូនខ្សាច់ឡើង ក្រាលនូវមែកឈើនិងសំពត់សម្បកឈើ លើពំនូកខ្សាច់នោះ និមន្តព្រះបច្ចេកពុទ្ធឲ្យគង់តាមលំដាប់ហើយ យកកន្ទោងស្លឹកឈើដងទឹកមកធ្វើជាទក្ខិណោទក ដាក់នំកុម្មាស: ៤ ក្នុងបាត្រទាំង ៤ នមស្ការហើយទូលថា

**ភន្តេ ឯតេសំ និស្សន្ទេន ទលិទ្ទគេហេ និព្វត្តិ នាម មា ហោតុ សព្វញ្ញុតញ្ញាណប្បដិវេធស្ស បច្ចយោ ហោតុ ។**

បពិត្រលោកម្ចាស់ដ៏ចម្រើន ដោយផលនៃការប្រគេននំកុម្មាស:ទាំងនេះ ឈ្មោះថា ការកើតក្នុងផ្ទះអ្នកក្រីក្រ កុំបីមានឡើយ ការថ្វាយទាននេះ សូមជាបច្ច័យនៃការសម្រេចនូវព្រះសព្វញ្ញុតញ្ញាណ ។

ព្រះបច្ចេកពុទ្ធទាំងឡាយនោះឆាន់ហើយ ក្នុងទីបំផុតនៃការឆាន់ធ្វើអនុមោទនាហើយ ហោះទៅកាន់ញកភ្នំនន្ទមូលក: ។ ព្រះពោធិសត្វផ្គងអញ្ជលី ហើយកាន់យកនូវបីតិក្នុងព្រះបច្ចេកពុទ្ធជាអារម្មណ៍ លុះព្រះបច្ចេកពុទ្ធទាំងនោះ លះក្រសែភ្នែកហើយ ក៏ទៅក្នុងទីធ្វើការរបស់ខ្លួន ។ ព្រះពោធិសត្វធ្វើកម្មមានប្រមាណប៉ុណ្ណេះ តែរឭកដល់ទាននោះដរាបដល់អស់អាយុ លុះធ្វើកាលកិរិយាហើយ ក៏បដិសន្ធិក្នុងព្រះឧទររបស់អគ្គមហេសីនៃព្រះបាទពារាណសី ព្រះញាតិទាំងឡាយបានថ្វាយព្រះនាមថា ព្រហ្មទត្តកុមារ ។ ព្រះរាជកុមារនោះ តាំងអំពីចេះយាងទៅដោយព្រះបាទ ទ្រង់ឃើញកិរិយាអាការ ( គឺកម្ម ) របស់ខ្លួនក្នុងជាតិ

មុនប្រាកដច្បាស់ ដោយការរឭកជាតិបាន ដូចការឃើញស្រមោលមុខក្នុងកញ្ចក់ដែលថ្លា គិតថា អញជាអ្នកស៊ីឈ្នួលក្នុងនគរនេះឯង កាលដើរទៅធ្វើការងារ បានប្រគេននំកុម្មាសៈ ៤ ដុំ ដល់ព្រះបច្ចេកពុទ្ធទាំងឡាយ បានកើតក្នុងទីនេះ ព្រោះផលនៃទាននោះ ។ ព្រះរាជកុមារទ្រង់ចម្រើនវ័យហើយ យាងទៅកាន់នគរតក្កសិលា រៀននូវសិល្បសាស្ត្រគ្រប់យ៉ាងហើយយាងត្រឡប់មក ទ្រង់សម្ដែងសិល្បសាស្ត្រដែលទ្រង់សិក្សាហើយថ្វាយព្រះរាជបិតាទត ព្រះរាជបិតាទ្រង់ពេញព្រះហឫទ័យ ស្ថាបនាទុកក្នុងតំណែងឧបរាជ ក្នុងកាលតមក អស់រជ្ជកាលរបស់ព្រះរាជបិតា ក៏បានគ្រប់គ្រងរាជសម្បត្តិ ។ សម័យនោះ អាមាត្យទាំងឡាយនាំព្រះរាជធីតារបស់ព្រះបាទកោសល ដែលទ្រទ្រង់នូវរូបដ៏ឧត្ដម មកថ្វាយ ឲ្យធ្វើជាអគ្គមហេសីរបស់ព្រះរាជកុមារ ។ ក្នុងថ្ងៃឆ្លងឆត្តមង្គល មនុស្សទាំង-ឡាយនាំគ្នាតាក់តែងព្រះនគរទាំងមូល បីដូចទេវនគរ ។

ព្រះរាជាទ្រង់ប្រទក្សិណព្រះនគរហើយ យាងឡើងប្រាសាទដែលតាក់តែងល្អហើយ ទ្រង់យាងឡើងកាន់ព្រះរាជបល្ល័ង្កដែលលើកមហាស្វេតច្ឆត្រឡើងត្រង់កណ្ដាលផ្ទៃប្រាសាទ គង់ប្រថាប់ ទតមើលពលនិករទាំងឡាយដែលនាំគ្នាគាល់ មួយផ្នែកជាអាមាត្យ មួយផ្នែកទៀត ជាព្រាហ្មណគហបតីជាដើម ដែលមានសម្បត្តិផ្សេង ៗ គ្នា មានការរុងរឿងដោយសិរីវិលាស មួយផ្នែកជាមហាជនអ្នកក្រុង មានដៃកាន់គ្រឿង

បណ្ណាការច្រើនប្រភេទ មួយផ្នែកជាគណៈស្រីរបាំ ដែលមានចំនួន ១៦ ពាន់នាក់ គួរនាដូចជាស្រីទេពអប្សរដែលតាក់តែងហើយដូច្នោះ សិរីរាជសម្បត្តិនេះ ជាទីត្រេកអរនៃព្រះរាជហឫទ័យក្រៃលែង ទ្រង់រឭកដល់កុសលកម្មដែលខ្លួនបំពេញក្នុងកាលមុនហើយ ទ្រង់រឭកដល់គុណរបស់ព្រះបច្ចេកពុទ្ធទាំងឡាយថា សិរីសម្បត្តិទាំងអស់នេះ គឺសុវណ្ណបិណ្ឌិក ( ដុំមាស ) ១ កញ្ចនមាលា ( កម្រងផ្កាមាស ) ១ សេ្វតច្ឆត្រ ១ ដំរីសេះនិងរថដែលជារាជពាហនៈទាំងនេះ ច្រើនពាន់ ១ ឃ្លាំងដែលពេញដោយកែវមណីនិងកែវមុក្តាជាដើម ១ ផែនដីធំដែលពេញដោយធញ្ញជាតិច្រើនប្រភេទ ១ ពួកនារីដែលប្រៀបបាននឹងស្រីទេពអប្សរ ១ ជាសិរីសម្បត្តិរបស់អញ មិនមែនរបស់អ្នកដទៃ តែជារបស់ដែលអាស្រ័យការប្រគេននំកុម្មាសៈ ៤ ដុំ ដល់ព្រះបច្ចេកពុទ្ធ ៤ អង្គប៉ុណ្ណោះ សម្បត្តិរបស់អញទាំងនេះ បានមកព្រោះអាស្រ័យព្រះបច្ចេកពុទ្ធទាំងនោះ ដូច្នេះ បានធ្វើកម្មរបស់ខ្លួនឲ្យប្រាកដហើយ ។ កាលទ្រង់រឭកដល់ផលកម្មនោះហើយ ព្រះសរីរៈទាំងមូលពេញទៅដោយបីតិ ។ ទ្រង់មានព្រះរាជហឫទ័យជ្រួតជ្រាបដោយបីតិ កាលទ្រង់ច្រៀងឧទានត្រង់កណ្តាលមហាជន បានត្រាស់ ២ គាថាថា

ន កិរត្ថិ អនោមទស្សិសុ
ចារិចរិយា ពុទ្ធេសុ អប្បកា

**សុក្ខាយ អលោណិកាយ ច**
**បស្ស ផលំ កុម្មាសបិណ្ឌិយា ។**

*បានឮថា ការបម្រើព្រះបច្ចេកពុទ្ធទាំងឡាយ ដែលលោកមានពោធិញ្ញាណមិនថោកថយ មិនមែនមានផលានិសង្សតិចតួចឡើយ អ្នកចូរមើលផលនៃដុំនំកុម្មាសៈ ដែលសោះកក្រោះ ឥតរសប្រៃ ។*

**ហត្ថី គវាស្សា ចិមេ ពហូ**
**ធនធញ្ញា បឋវី ច កេវលា**
**នារិយោ ចិមា អច្ឆរូបមា**
**បស្ស ផលំ កុម្មាសបិណ្ឌិយា ។**

*ដំរី គោ និងសេះដ៏ច្រើន ទាំងនេះផង ទ្រព្យ ស្រូវ និងផែនដីទាំងអស់ផង នាងនារីទាំងឡាយដែលប្រៀបដូចជាស្ត្រីអប្សរទាំងនេះផង សុទ្ធតែជារបស់ខ្ញុំ អ្នកចូរមើលនូវផលនៃដុំនំកុម្មាសៈ ។*

*ទក្ខិណាទានដែលទាយកកំណត់គុណ របស់សមណព្រាហ្មណ៍ទាំងឡាយ ដែលមានគុណ ហើយញុំាងចិត្តឲ្យជ្រះថ្លា ញុំាងចេតនាទាំង ៣ របស់បុគ្គលដែលប្រាថ្នានូវផលឲ្យផូរផង់ហើយ ទើបថ្វាយ ឈ្មោះថាមានផលតិច មិនមាន មានតែនាំមកនូវមហាសម្បត្តិ ក្នុងទីដែលកើត*

*ហើយប៉ុណ្ណោះ ។ ព្រោះហេតុនោះ ទើបក្នុងសេចក្តីនេះ លោកពោលជានាទុកថា*

ឧត្តិ ចិត្តេ បសន្នម្ហិ អប្បកា ឧាម ឧក្ខិណា
តថាគតេ វា សម្ពុទ្ធេ អថ វា តស្ស សាវកេ ។

*កាលបើចិត្តជ្រះថ្លា ចំពោះព្រះតថាគតជាសម្ពុទ្ធ ឬសាវ័ករបស់ព្រះតថាគតហើយ ទក្ខិណាទាន ឈ្មោះថា មានផលតិច មិនមែនឡើយ ។*

តិដ្ឋន្តេ និព្វុតេ វាបិ សមេ ចិត្តេ សមំ ផលំ
ចេតោបណិធិហេតូ ហិ សត្តា គច្ឆន្តិ សុគ្គតឹ ។

*កាលព្រះតថាគតបិតនៅក្តី បរិនិព្វានទៅក្តី បើតាំងចិត្តស្មើ ផលក៏ស្មើ ដ្បិតថា សត្វទាំងឡាយមានការតម្កល់ចិត្តទុកជាហេតុ ទើបទៅកាន់សុគតិបាន⁽១⁾ ។*

*ដើម្បីសម្តែងដល់សេចក្តីនោះ គួរនាំរឿងក្នុងវិមានវត្ថុទាំងឡាយមកសាធក:យ៉ាងនេះថា*

ទីពោឧមហំ អធាសឹ
ភិក្ខុនោ បិណ្ឌាយ ចរន្តស្ស
តស្សា មេ បស្ស វិមានំ

---

*១-បិ.៥៥ ទំ.១០០ ឃ.៤៧ ។*

អច្ឆរា កាមវណ្ណិនីហមស្មិ ។

ខ្ញុំបានឲ្យនូវបាយ លាយដោយទឹកដោះស្រស់ ដល់ភិក្ខុត្រាច់ទៅបិណ្ឌបាត សូមលោកមើលនូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្រីអប្សរមានសម្បុរជាទីប្រាថ្នា ។

អច្ឆរាសហស្សាហំ បវរា

បស្ស បុញ្ញានំ វិបាកំ

តេន មេតាទិសោ វណ្ណោ

តេន មេ ឥធ មិជ្ឈតិ ។

ខ្ញុំជាស្រីប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់ សូមលោកមើលនូវផលនៃបុណ្យទាំងឡាយ ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំក្នុងទីនេះផង [១] ។

ឧប្បជ្ជន្តិ ច មេ ភោគា

យេ កេចិ មនសោ បិយា

តេនម្ហិ ឯវញ្ចលិតានុភាវា

វណ្ណោ ច មេ សព្វទិសា បភាសតិ ។

ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈ

---

១-បិ.៥៥ ទំ.៦៨ ឃ.៣៣ ។

*ទាំងនោះ ក៏កើតឡើងដល់ខ្ញុំម្ចាស់ផង ខ្ញុំម្ចាស់មាន អានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំម្ចាស់ ក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យនោះ[១] ។*

*បានឮថា ព្រះពោធិសត្វទាំងឡាយក្តី ព្រះសព្វញ្ញុពុទ្ធទាំងឡាយក្តី ទ្រង់ជ្រាបផលរបស់ទាន ព្រោះហេតុនោះឯង ព្រះសាស្តា កាលត្រាស់ព្រះសូត្រក្នុងឥតិវុត្តកៈ ទើបត្រាស់ថា*

**ឯវញ្ចេ ភិក្ខវេ សត្តា ជានេយ្យុំ ទានសំវិភាគស្ស វិបាកំ យថាហំ ជានាមិ ន អទត្វា ភុញ្ជេយ្យុំ ន ច នេសំ មច្ឆេរមលំ ចិត្តំ បរិយាទាយ តិដ្ឋេយ្យ ។**

*ម្នាលភិក្ខុទាំងឡាយ បើពួកសត្វដឹងផលនៃការចែកទាន ដូចជាតថាគតដឹងដូច្នោះ បើមិនទាន់ឲ្យទានទេ ក៏មិនហ៊ានបរិភោគឡើយ មួយទៀត មន្ទិលគឺសេចក្តីកំណាញ់របស់សត្វទាំងនោះ ក៏មិនគ្របសង្កត់ចិត្តបានឡើយ ។*

**យោបិ នេសំ អស្ស ចរិមោ អាលោបោ ចរិមំ កពលំ តតោបិ ន អសំវិភជិត្វា ភុញ្ជេយ្យុំ សចេ នេសំ បដិគ្គាហកា អស្សុ ។**

*ទោះបីពំនូតបាយជាដំបូង ដុំបាយជាដំបូងឯណា របស់សត្វ*

---

*១-បិ.៥៥ ទំ.១៥ ឃ.៨ ។*

*ទាំងឡាយនោះ សត្វទាំងឡាយមិនបានរំលែកអំពីពំនូតបាយនោះ ក៏មិនបរិភោគឡើយ បើសត្វទាំងនោះ មានបដិគ្គាហកបុគ្គល ។*

**យស្មា ច ខោ ភិក្ខវេ សត្តា ន ឯវំ ជានន្តិ ទានសំវិភាគស្ស វិបាកំ យថាហំ ជានាមិ តស្មា អទត្វា ភុញ្ជន្តិ មច្ឆេរមលញ្ច នេសំ ចិត្តំ បរិយាទាយ តិដ្ឋតិ ។**

*ម្នាលភិក្ខុទាំងឡាយ តថាគតដឹងផលនៃការឲ្យ និងការចែករំលែក យ៉ាងណា សត្វទាំងឡាយ មិនដឹងយ៉ាងនោះទេ ព្រោះហេតុណាហេតុនោះ សត្វទាំងឡាយមិនបានឲ្យទានហើយ ទើបហ៊ានបរិភោគមួយទៀត មន្ទិលគឺសេចក្តីកំណាញ់ ក៏តែងគ្របសង្កត់ចិត្តសត្វទាំងឡាយនោះ[១] ។*

*ព្រះពោធិសត្វទ្រង់មានបីតិបាមោជ្ជកើតឡើង ក្នុងថ្ងៃឆ្លងឆត្តមង្គលរបស់ខ្លួន ទើបទ្រង់បន្លឺឧទានជាចម្រៀងដោយគាថាទាំង ២ នេះ ។ ចាប់តាំងអំពីនោះមក ពួកស្រីរបាំរបស់ព្រះពោធិសត្វ ក៏នាំគ្នាច្រៀងចម្រៀងនោះ ដោយគិតថា ជាចម្រៀងដែលព្រះរាជាទ្រង់សព្វព្រះហឫទ័យ ។ ពួកគន្ធព្វដែលជាអ្នកប្រគំជាដើមដ៏សេសក្តី មនុស្សទាំងឡាយខាងក្នុងបុរីក្តី នៅក្នុងព្រះនគរក្តី នៅខាងក្រៅព្រះនគរក្តី នាំគ្នាច្រៀងចម្រៀងនោះដូចគ្នា ត្រង់រានលក់គ្រឿងផឹកក្តី ត្រង់បរិវេណប្រជុំក្តី ក៏នាំគ្នាច្រៀងនូវ*

---

*១-បិ.៥៣ ទំ.២៥ ឃ.២៦ ។*

ចម្រៀងនោះ ដូចគ្នា ដោយគិតថា ជាចម្រៀងដែលព្រះរាជារបស់ពួកយើងទ្រង់សព្វព្រះរាជហឫទ័យ ។ ពេលវេលាកន្លងទៅអស់កាលដ៏យូរយ៉ាងនេះ អគ្គមហេសីមានព្រះរាជបំណងជ្រាបអត្ថនៃបទចម្រៀងនោះ តែមិនហ៊ានក្រាបទូលសួរព្រះមហាសត្វ ។ ថ្ងៃមួយ កាលព្រះរាជាទ្រង់ត្រេកអរក្នុងគុណឯណានីមួយរបស់ព្រះនាង ទើបត្រាស់ថា **ភទ្ទេ វរំ តេ ទស្សាមិ វរំ គណ្ហាហិ** នែនាងដ៏ចម្រើន យើងនឹងឲ្យពរដល់នាង ចូរនាងទទួលពរ ។

ព្រះនាងក្រាបទូលថា **សាធុ ទេវ គណ្ហាមិ** បពិត្រព្រះសម្មតិទេព ប្រពៃហើយ ខ្ញុំម្ចាស់សូមទទួលពរ ។

ព្រះពោធិសត្វពោលថា ដំរី សេះ ជាដើម យើងនឹងឲ្យនូវអ្វី ដល់នាង ។

ព្រះទេវីក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់អាស្រ័យព្រះអង្គ មិនមានអ្វីដែលខ្ញុំម្ចាស់មិនមាន ខ្ញុំម្ចាស់មិនមានសេចក្ដីត្រូវការដោយវត្ថុទាំងនោះ បើទ្រង់មានព្រះរាជបំណងប្រទានពរ សូមទ្រង់ត្រាស់ប្រាប់អត្ថនៃបទចម្រៀង ដែលទ្រង់ច្រៀងដល់ខ្ញុំម្ចាស់ចុះ ។

ព្រះរាជាត្រាស់ថា នែនាងដ៏ចម្រើន ប្រយោជន៍អ្វីដោយពរនេះ ចូរនាងទទួលពរដទៃចុះ ។

អគ្គមហេសីក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់មិនត្រូវការ

ពរជទៃទៀយ ត្រូវការអត្ថនៃបទចម្រៀងតែម្យ៉ាង ។

ព្រះរាជាត្រាស់ថា ប្រពៃហើយ នាងដ៏ចម្រើន យើងនឹងប្រាប់ តែយើងមិនប្រាប់ដល់នាងតែម្នាក់ក្នុងទីស្ងាត់ឡើយ យើងនឹងឲ្យវាយស្គរប្រកាសក្នុងនគរពារាណសីដែលមានប្រមាណ ១២ យោជន៍ ឲ្យសាងរតនមណ្ឌបត្រង់ទ្វារព្រះរាជវាំង ក្រាលរតនបល្ល័ង្ក មានអាមាត្យ និងព្រាហ្មណ៍ជាដើម និងអ្នកនគរទាំងឡាយ មួយអន្លើដោយស្រីស្នំ ១៦ ពាន់ចោមរោមហើយ យើងអង្គុយលើរតនបល្ល័ង្កកណ្តាលជនទាំងនោះ ហើយនឹងប្រាប់ ។

ព្រះនាងទទួលថា បពិត្រព្រះទេវៈ ប្រពៃហើយ ។ ព្រះរាជាទ្រង់ឲ្យធ្វើយ៉ាងនោះហើយ មានពួកមហាជនចោមរោមដូចសក្កទេវរាជមានពួកទេវតាហែហមដូច្នោះ ទ្រង់គង់លើរតនបល្ល័ង្ក ។ ចំណែកព្រះទេវីព្រះនាងប្រដាប់តាក់តែងដោយគ្រឿងអលង្ការគ្រប់យ៉ាង ឲ្យក្រាលនូវកម្រាលលើតាំងមាស ព្រះនាងផ្ទៀងព្រះនេត្រមើលទីសមគួរនាចំណែកម្ខាង គង់ប្រថាប់ហើយ ក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ប្រាប់អត្ថនៃបទចម្រៀងមង្គល ដែលទ្រង់ពេញព្រះហឫទ័យហើយ ដល់ខ្ញុំម្ចាស់ ឲ្យជាក់ច្បាស់ ដូចឲ្យព្រះចន្ទប្រាកដឰដ៏ផ្ទៃមេឃដូច្នោះ ហើយត្រាស់គាថាទី ៣ ថា

**អភិក្ខណំ រាជកុញ្ជរ**

គាថា ភាសសិ កោសលាធិប
បុច្ឆាមិ តំ រដ្ឋវឌ្ឍន
ពាឡ្ហំ បីតិមនោ បភាសសិ ។

*បពិត្រព្រះរាជកុញ្ជរ មានព្រះអធ្យាស្រ័យជាកុសល ទ្រង់ញ៉ាំងដែនឲ្យចម្រើន ព្រះអង្គត្រាស់គាថាទាំងឡាយរឿយ ៗ ខ្ញុំព្រះអង្គសូមក្រាបបង្គំទូលសួរទ្រង់ ព្រះអង្គមានព្រះទ័យប្រកបដោយបីតិក្រៃពេក ហើយទ្រង់ត្រាស់ (គាថាទាំងនុ៎ះ) ។*

*គ្រានោះ ព្រះមហាសត្វ កាលធ្វើអត្ថនៃគាថាទាំងឡាយឲ្យប្រាកដដល់ព្រះនាង បានត្រាស់ ៤ គាថាដូច្នេះថា*

ឥមស្មឹយេវ នគរេ កុលេ អញ្ញតរេ អហុំ
បរកម្មករោ អាសឹ ភតកោ សីលសំវុតោ ។

*យើងបានកើតក្នុងត្រកូលមួយ ក្នុងក្រុងនេះដែរ ជាអ្នកស៊ីឈ្នួលធ្វើការងាររបស់បុគ្គលដទៃ ជាអ្នកសង្រួមក្នុងសីល ។*

កម្មាយ និក្ខមន្តាហំ ចតុរោ សមណេទ្ទសំ
អាចារសីលសម្បន្នេ សីតិភូតេ អនាសវេ ។

*យើងចេញទៅធ្វើការងារ បានជួបនឹងសមណៈ ៤ អង្គ លោកបរិបូណ៌ដោយអាចារៈ និងសីល មានសេចក្តីត្រជាក់*

*ទាំងឥតមានអាសវៈឡើយ ។*

តេសុ ចិត្តំ បសាទេត្វា និសីទិត្វា បណ្ណសន្ថតេ
អទំ ពុទ្ធាន កុម្មាសំ បសន្នោ សេហិ បាណិភិ ។

*យើងបានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះសមណៈទាំងនោះ បាននិមន្តលោកឲ្យគង់លើកម្រាលស្លឹកឈើ លុះយើងមានចិត្តជ្រះថ្លាហើយ បានប្រគេននំកុម្មាសៈ ដល់ព្រះបច្ចេកពុទ្ធទាំង-ឡាយដោយដៃរបស់ខ្លួន ។*

តស្ស កម្មស្ស កុសលស្ស ឥទំ មេ ឯទិសំ ផលំ
អនុភោមិ ឥទំ រជ្ជំ ផីតំ ធរណិមុត្តមំ ។

*ឯផលរបស់យើងប្រាកដដូច្នេះនេះ ជាផលរបស់កម្មជាកុសលនោះ យើងសោយរាជ្យដ៏ស្តុកស្តម្ភ ប្រសើរលើធរណីនេះ ។*

*កាលព្រះមហាសត្វប្រាប់ផលនៃកម្មរបស់ខ្លួន ដោយពិស្តារយ៉ាងនេះហើយ ព្រះទេវី កាលព្រះនាងស្តាប់ហើយ មានព្រះហឫទ័យជ្រះថ្លា កាលធ្វើនូវការសរសើរដល់ព្រះពោធិសត្វ ទើបពោលថា បពិត្រមហារាជ បើទ្រង់ជ្រាបផលរបស់ទានដោយប្រចក្សយ៉ាងនេះហើយ តាំងអំពីឥឡូវនេះទៅ ទ្រង់បានដុំបាយមួយដុំហើយ ត្រូវប្រគេនដល់សមណព្រាហ្មណ៍ ដែលទ្រទ្រង់ធម៌នោះសិន សឹមទ្រង់សោយ ហើយបានពោលគាថានេះថា*

ទទំ ភុញ្ជ ច មា ច បមាទោ

ចក្កំ វត្តយ កោសលាធិប

មា រាជ អធម្មិកោ អហុ

ធម្មំ ចាលយ កោសលាធិប ។

*បពិត្រព្រះអង្គ មានព្រះអធ្យាស្រ័យជាកុសល ( បពិត្រព្រះអង្គមានការធ្វើកុសលធម៌ជាអធិបតី ) សូមព្រះអង្គទ្រង់ព្រះរាជទាន ហើយសឹមទ្រង់សោយ សូមព្រះអង្គកុំប្រមាទ ( ក្នុងបុណ្យទាំងឡាយ ) សូមព្រះអង្គញ៉ាំងចក្កធម៌ឲ្យប្រព្រឹត្តទៅ បពិត្រព្រះរាជា មានព្រះអធ្យាស្រ័យជាកុសល ព្រះអង្គកុំជាអ្នកមិនប្រកបដោយធម៌ សូមទ្រង់រក្សានូវអនុធម៌ ។*

*ព្រះមហាសត្វ កាលទ្រង់ទទួលព្រះតម្រាស់របស់ព្រះទេវី ទើបត្រាស់គាថានេះថា*

សោហំ តទេវ បុនប្បុនំ

វដុមំ អាចរិស្សាមិ សោភនេ

អរិយាចរិតំ សុកោសលេ

អរហន្តោ មេ មនាបាវ បស្សិតុំ ។

*ម្នាលនាងមានឆោមល្អ យើងនោះ នឹងដើរតាមតម្រាយដែលព្រះអរិយៈធ្លាប់ប្រព្រឹត្តរឿយៗ មកនោះឯង ម្នាល*

នាងដ៏ល្អ ជាធីតារបស់ព្រះបាទកោសល ការបានចួប
ប្រទះនូវព្រះអរហន្តទាំងឡាយ ជាទីគាប់ចិត្តរបស់យើង
ពន់ពេក ។

ព្រះរាជា កាលត្រាស់ពាក្យនេះហើយ ពិនិត្យមើលសម្បត្តិរបស់ព្រះទេវី ទើបត្រាស់សួរថា នៃនាងដ៏ចម្រើន យើងប្រាប់កុសលកម្មរបស់ខ្លួនក្នុងកពមុនយ៉ាងពិស្តារដល់នាងហើយ តែក្នុងចំណោមស្រីទាំងនេះមិនមានស្រី សូម្បីតែម្នាក់ ដែលស្មើនឹងនាងដោយរូបសម្បត្តិ ដោយលីលា និងកិរិយារបស់ស្ត្រី នាងធ្វើកម្មអ្វីទុក ទើបបានទទួលសម្បត្តិនេះដូច្នេះហើយ ត្រាស់គាថានេះថា

**ទេវី វិយ អច្ឆរូបមា**
**មជ្ឈេ នារិគណស្ស សោភសិ**
**កឹ កម្មមការិ ភទ្ទកំ**
**កេនាសិ វណ្ណវតី សុកោសលេ ។**

ម្នាលនាងសុកោសលធីតា នាងប្រៀបដូចជាស្ត្រី
ទេពអប្សរ ជាទេវធីតា ( របស់សក្កទេវរាជ ) ធើតឆាយ
ក្នុងកណ្តាលនៃពួកនាងនារី នាងបានធ្វើនូវកម្មដ៏
ចម្រើនដូចម្តេច នាងមានសម្បុរល្អ ដោយហេតុអ្វី ។

គាថានោះ មានអត្ថថា នៃនាងដ៏ចម្រើន ជាអ្នកកោសល នាងមាន

រូបល្អ ជាព្រះរាជជីតាល្អរបស់ព្រះបាទកោសល នាងប្រៀបដូចទេពអប្សរ ដោយរូបសម្បត្តិ ល្អល្អះពន់ពេកក្នុងកណ្តាលពួកនារី ដូចទេពធីតារបស់សក្កទេវរាជក្នុងស្ថានសួគ៌ ក្នុងសម័យមុន នាងបានធ្វើកុសលកម្មអ្វីទុក ព្រោះហេតុអ្វី ទើបនាងមានសម្បុរល្អម្ល៉េះ ។

លំដាប់នោះ ព្រះទេវីនោះ កាលប្រាប់នូវកល្យាណកម្មក្នុងភពមុន ទើបត្រាស់គាថា ២ ដ៏សេសថា

អម្ពដ្ឋកុលស្ស ខត្តិយ
ទាស្យាហំ បរបេសិយា អហុំ
សញ្ញតា ច ធម្មជីវិនី
សីលវតី ច អបាបទស្សនា ។

បពិត្រក្សត្រិយ៍ ខ្ញុំម្ចាស់ជាទាសីបម្រើអ្នកដទៃ របស់ត្រកូលអម្ពដ្ឋៈ ជាស្ត្រីសង្រួម ចិញ្ចឹមជីវិតដោយធម៌ មានសីលធម៌ មានការឃើញមិនអាក្រក់ ។

ឧទ្ធដភត្តំ អហំ តទា
ចរមានស្ស អទាសិ ភិក្ខុនោ
ចិត្តា សុមនា សយំ អហំ
តស្ស កម្មស្ស ផលំ មមេទិសំ ។

កាលនោះ ខ្ញុំជាស្ត្រីមានចិត្តត្រេកអរ រីករាយខ្លួនឯង

បានប្រគេនភត្តដែលគេដួស ( ទុកបម្រុងខ្ញុំ ) ដល់
ភិក្ខុ ( ព្រះបច្ចេកពុទ្ធ ) ដែលត្រាច់ទៅ ( ដើម្បី
បិណ្ឌបាត ) ផលប្រាកដដូច្នេះនេះ គឺជាផលនៃ
បុញ្ញកម្មនោះ ។

បានឮថា ព្រះរាជទេវីនោះ ព្រះនាងក៏រឭកជាតិបានដូចគ្នា ព្រោះហេតុនោះ ទើបព្រះនាងទូលព្រះរាជាកំណត់ដោយព្រះញាណ ដែលរឭកជាតិរបស់ខ្លួនបាននោះឯង ។

ក្នុងរឿងនោះ ដើម្បីសម្តែងដល់ទានដែលបុគ្គលថ្វាយហើយដល់លោកអ្នកសម្បូរដោយគុណ មានផលច្រើន គួរអាងគាថាឲ្យពិស្តារ ( ក្នុងឥតិវុត្តកៈ និងខុទ្ទកបាឋៈ ) ដូច្នេះថា

អគ្គតោ វេ បសន្នានំ អគ្គំ ធម្មំ វិជានតំ
អគ្គេ ពុទ្ធេ បសន្នានំ ទក្ខិណេយ្យេ អនុត្តរេ ។
អគ្គេ ធម្មេ បសន្នានំ វិរាគូបសមេ សុខេ
អគ្គេ សង្ឃេ បសន្នានំ បុញ្ញក្ខេត្តេ អនុត្តរេ ។
អគ្គស្មឹ ទានំ ទទតំ អគ្គំ បុញ្ញំ បវឌ្ឍតិ
អគ្គំ អាយុ ច វណ្ណោ ច យសោ កិត្តិ សុខំ ពលំ ។
អគ្គស្ស ទាតា មេធាវី អគ្គធម្មសមាហិតោ
ទេវភូតោ មនុស្សោ វា អគ្គប្បត្តោ បមោទតិ ។

*កាលបើពួកសត្វជ្រះថ្លាក្នុង ( ព្រះរតនត្រ័យ ) ថាជារបស់ប្រសើរ ដឹងច្បាស់ថា ជាសភាវៈប្រសើរ គឺថាជ្រះថ្លាក្នុងព្រះពុទ្ធដ៏ប្រសើរ ជាទក្ខិណេយ្យបុគ្គលដ៏ឧត្តម ជ្រះថ្លាក្នុងព្រះធម៌ដ៏ប្រសើរ ជាគ្រឿងប្រាសចាកតម្រេក ស្ងប់រម្ងាប់ ( កិលេស ) នាំមកនូវសេចក្ដីសុខ ជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ជាបុញ្ញក្ខេត្តយ៉ាងខ្ពង់ខ្ពស់ ឲ្យនូវទានក្នុងវត្ថុដ៏ប្រសើរ បុណ្យដ៏ប្រសើរ ក៏រមែងចម្រើន ទាំងអាយុ ពណ៌ យស កេរ្តិ៍ឈ្មោះ សេចក្ដីសុខ និងកម្លាំងដ៏ប្រសើរ ក៏រមែងចម្រើន អ្នកប្រាជ្ញជាអ្នកឲ្យ ( នូវទេយ្យធម៌ ) ចំពោះវត្ថុដ៏ប្រសើរ ហើយជាអ្នកមានចិត្តតាំងមាំ ក្នុងធម៌ដ៏ប្រសើរ លុះកើតជាទេវតា ឬកើតជាមនុស្ស សម្រេចនូវសម្បត្តិដ៏ប្រសើរ រមែងរីករាយ [១] ។*

**ឯស ទេវមនុស្សានំ សព្វកាមទទោ និធិ**
**យំ យំ ទេវាភិបត្ថេន្តិ សព្វមេតេន លព្ភតិ ។**

*កំណប់ទ្រព្យ គឺបុណ្យនុ៎ះ ឲ្យនូវសេចក្ដីប្រាថ្នាគ្រប់យ៉ាងដល់ទេវតា និងមនុស្សទាំងឡាយ ពួកទេវតា និងមនុស្សទាំងឡាយ ប្រាថ្នាណាស់ នូវផលណា ៗ ផលទាំងពួង*

---

*១-បិ.៥៣ ទំ.១១៨ ឃ.៩២ ។*

*នោះៗ រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ[១] ។*

*ក្សត្រទាំងពីរអង្គគឺព្រះរាជានិងព្រះមហេសីនោះ កាលត្រាស់កម្ម ចាស់ដោយពិស្តារយ៉ាងនេះហើយ តាំងអំពីនោះមក ទ្រង់ឲ្យសាង សាលាឆទាន ត្រង់ទ្វារព្រះនគរ ៤ កន្លែង កណ្តាលព្រះនគរ ១ ត្រង់ទ្វារព្រះរាជនិវេសន៍ ១ ទ្រង់ធ្វើជម្ពូទ្វីបទាំងមូល ឲ្យមាននន្ទ័លលើក ឡើងហើយ ញ៉ាំងមហាទានឲ្យប្រព្រឹត្តទៅ ទ្រង់រក្សាសីល ធ្វើឧបោសថ- កម្ម ក្នុងអវសាននៃព្រះជន្ម មានស្ថានសួគ៌ជាទីទៅខាងមុខ ។*

*ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ព្រះទេវីក្នុងកាលនោះ បានមកជារាហុលមាតា ក្នុង កាលឥឡូវនេះ ចំណែកព្រះរាជា គឺតថាគតនេះឯង ។*

## កុម្មាសបិណ្ឌិជាតក ចប់[២]

---

*១-បិ.៥២ ទំ.១៧ ឃ.៩ ។ ២-ស្រង់ចាកអដ្ឋកថា ជាតក សត្តកនិបាត បិ. ៥៩ ទំ.១០៧ ឃ.៤០៥ ។*

# គណ្ឌមាលជាតក

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបោសថកម្ម ទើបត្រាស់រឿងនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ក្នុងនគរនោះ មានសេដ្ឋីម្នាក់ឈ្មោះ សុចិបរិវារ មានសម្បត្តិ ៨០ កោដិ ជាអ្នកត្រេកអរក្នុងបុណ្យកុសល មានការឲ្យទានជាដើម ។ បុត្តក្ដី ភរិយាក្ដី ជនជាបរិវារក្ដី ដោយហោចទៅ សូម្បីក្មេងឃ្វាលគោ ក្នុងផ្ទះនោះ សុទ្ធតែជាអ្នករក្សាឧបោសថ មួយខែ ៦ ថ្ងៃ ។ ក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងត្រកូលអ្នកក្រីក្រមួយ ស៊ីឈ្នួលគេចិញ្ចឹមជីវិត រស់នៅដោយសេចក្ដីលំបាក ។ ព្រះពោធិសត្វគិតថា អញនឹងធ្វើការស៊ីឈ្នួល ទើបទៅកាន់ផ្ទះរបស់សុចិបរិវារសេដ្ឋី ថ្វាយបង្គំហើយ ឈរក្នុងទីសមគួរនាចំណែកម្ខាង ។ កាលសេដ្ឋីសួរថា អ្នកមកធ្វើអ្វី ក៏ពោលថា មកដើម្បីស៊ីឈ្នួលធ្វើការងារក្នុងផ្ទះរបស់លោក ។ សេដ្ឋីនោះ ធ្លាប់ប្រាប់កូនឈ្នួលដទៃ ៗ ក្នុងថ្ងៃដែលមកដល់ថា អ្នកដែលធ្វើការក្នុងផ្ទះនេះ រក្សាសីលគ្រប់ ៗ គ្នា បើអ្នកអាចរក្សាសីលបាន ក៏ចូរធ្វើការងារចុះ ។ តែសម្រាប់ព្រះពោធិសត្វ សេដ្ឋីនោះមិនបានប្រាប់ឲ្យរក្សាសីល ទទួលព្រះពោធិសត្វថា នៃបា ប្រពៃហើយ ចូរអ្នកដឹងនូវការងារឈ្នួលរបស់ខ្លួន ហើយធ្វើការងារចុះ ។

តាំងអំពីនោះមក ព្រះពោធិសត្វជាមនុស្សប្រដៅងាយ លះបង់ជីវិត មិនគិតដល់ការនឿយហត់របស់ខ្លួន ធ្វើការងារគ្រប់យ៉ាងឲ្យលោកសេដ្ឋី ។ ព្រះពោធិសត្វទៅធ្វើការងារអំពីព្រលឹម លុះពេលល្ងាច ទើបត្រឡប់មក ។

សម័យថ្ងៃមួយ មានគេប្រកាសមហោស្រពក្នុងនគរ ។ មហាសេដ្ឋីហៅទាសីមក ប្រាប់ថា ថ្ងៃនេះ ជាថ្ងៃឧបោសថ ចូរនាងចម្អិនបាយឲ្យពួកកម្មករក្នុងផ្ទះ តែក្នុងពេលព្រឹកបានហើយ ដល់ពេលវេលាពួកគេនឹងបានបរិភោគ ហើយរក្សាឧបោសថ ។ ព្រះពោធិសត្វក្រោកឡើងអំពីព្រលឹមទៅធ្វើការងារ មិនមានអ្នកណាប្រាប់ថា ថ្ងៃនេះ អ្នកគប្បីរក្សាឧបោសថ ។ ពួកកម្មករដ៏សេស បរិភោគអាហារអំពីព្រឹក ហើយរក្សាឧបោសថ សេដ្ឋីមួយអន្លើដោយបុត្ត ភរិយា ជនជាបរិវារ បានអធិដ្ឋានឧបោសថ ពួកជនដែលរក្សាឧបោសថទាំងអស់ បានទៅកាន់លំនៅរបស់ខ្លួន អង្គុយពិចារណាដល់សីល ។ ព្រះពោធិសត្វធ្វើការងារពេញមួយថ្ងៃ ត្រឡប់មកក្នុងកាលដែលព្រះអាទិត្យអស្តង្គតហើយ ។ លំដាប់នោះ អ្នករៀបចំអាហារបានឲ្យទឹកលាងដៃដល់ព្រះពោធិសត្វ ហើយដួសបាយដាក់ថាសឲ្យ ។

ព្រះពោធិសត្វសួរថា ក្នុងថ្ងៃដទៃ ៗ ពេលថ្មើរណោះ មានសំឡេងអឺងកង តែក្នុងថ្ងៃនេះ ជនទាំងនោះ ទៅណាអស់ហើយ ។ ស្ត្រីអ្នកចម្អិន

អាហារឆ្អើយថា ជនទាំងអស់នោះ សមាទានឧបោសថហើយ ទៅកាន់លំនៅរៀង ៗ ខ្លួន ។ ព្រះពោធិសត្វស្តាប់ពាក្យរបស់ស្ត្រីអ្នកចម្អិនអាហារនោះហើយ គិតថា អញជាបុគ្គលទ្រុស្តសីលតែម្នាក់ឯង នឹងនៅក្នុងចំណោមអ្នកមានសីលទាំងនេះ បានដូចម្តេច កាលអញអធិដ្ឋានអង្គឧបោសថឥឡូវនេះ ឈ្មោះថា ជាអ្នករក្សាឧបោសថដែរឬហ្ន៎ ។ ព្រះពោធិសត្វក៏ទៅសួរសេដ្ឋី ។ លំដាប់នោះ សេដ្ឋីពោលថា នែបា ជាឧបោសថកម្មទាំងអស់ មិនបានទេ ព្រោះមិនបានអធិដ្ឋានអំពីព្រលឹមត្រឹមតែជាឧបោសថកម្មពាក់កណ្តាលប៉ុណ្ណោះ ។ ព្រះពោធិសត្វពោលថា ត្រឹមប៉ុណ្ណោះក៏ដោយចុះ បានសមាទានសីលក្នុងសម្នាក់របស់លោកសេដ្ឋី ហើយអធិដ្ឋានឧបោសថ ចូលកាន់លំនៅរបស់ខ្លួន ដេកពិចារណាដល់សីល ។ កាលរាត្រីកន្លងចូលដល់បច្ឆិមយាម ខ្យល់ក៏កម្រើកឡើងដល់ព្រះពោធិសត្វ ព្រោះអត់អាហារមកមួយថ្ងៃហើយ ។ មហាសេដ្ឋីបានប្រកបភេសជ្ជៈផ្សេង ៗ នាំមក ហើយពោលថា ចូរបរិភោគ ។

ព្រះពោធិសត្វពោលថា ខ្ញុំនឹងមិនទម្លាយឧបោសថឡើយ ខ្ញុំសមាទានធ្វើឧបោសថឲ្យមានជីវិតជាទីបំផុត ។ វេទនាដ៏ខ្លាំងក្លាបានកើតឡើង ក្នុងពេលអរុណរះ ព្រះពោធិសត្វមិនអាចតម្កល់សតិទុកបាន ។ លំដាប់នោះ ជនទាំងឡាយ គិតថា បុរសនេះ នឹងធ្វើកាលកិរិយាឥឡូវនេះ ទើបសែងយកទៅឲ្យដេកក្នុងរោងខាងក្រៅ ។ សម័យនោះ

ព្រះបាទពារាណសីទ្រង់គង់លើរថព្រះទីន័ង ធ្វើប្រទក្សិណព្រះនគរដោយបរិវារធំដល់ទីនោះ ។ ព្រះពោធិសត្វឃើញសិរីរាជសម្បត្តិរបស់ព្រះបាទពារាណសី កើតនូវចំណង់ចង់បានរាជសម្បត្តិ ចុតិហើយ បានបដិសន្ធិក្នុងព្រះឧទររបស់អគ្គមហេសីព្រះបាទពារាណសី ដោយអានិសង្សនៃឧបោសថពាក់កណ្ដាល ។ អគ្គមហេសីបាននូវគព្ភបរិហារហើយ លុះគ្រប់ទសមាសក៏ប្រសូតព្រះរាជឱរស ។ ព្រះញាតិទាំងឡាយនាំគ្នាថ្វាយព្រះនាមថា ឧទយកុមារ ។ ឧទយកុមារនោះចម្រើនវ័យហើយ សម្រេចការសិក្សាក្នុងសិប្បៈគ្រប់យ៉ាង រឭកដល់បុព្វកម្មរបស់ខ្លួនបាន ដោយញាណជាគ្រឿងរឭកជាតិ ទើបបន្លឺឧទានរឿយ ៗ ថា **អប្បកស្ស កម្មស្ស ផលំ មម ឥទំ** នេះជាផលកម្មមានប្រមាណតិចរបស់យើង ។ អំណឹះតតអំពីព្រះរាជបិតាទៅ បានឡើងគ្រងរាជសម្បត្តិ ទតសិរីរាជសម្បត្តិដ៏ក្រៃលែងរបស់ព្រះអង្គហើយ បន្លឺឧទានបែបនោះទៀត ។

សម័យថ្ងៃមួយ អ្នកស្រុកត្រៀមការលេងមហោស្រពក្នុងនគរ ។ មហាជននាំគ្នាដាក់ចិត្តក្នុងការលេង ។ គ្រានោះ បុរសអ្នកស៊ីឈ្នួលម្នាក់នៅក្បែរទ្វារទិសខាងជើងក្រុងពារាណសី រក្សាទ្រព្យកន្លះមាសកៈ ដែលបានមកដោយការស៊ីឈ្នួលដងទឹក ទុកក្នុងចន្លោះឥដ្ឋកំពែង កាលធ្វើការងារស៊ីឈ្នួល បានទៅដល់ទ្វារទិសខាងត្បូង បាននៅរួមជាមួយស្រីកំព្រាម្នាក់ ដែលចិញ្ចឹមជីវិតដោយការស៊ីឈ្នួលដងទឹកដូចគ្នា ក្នុងនគរ

នោះ ។ ស្រីនោះ បានពោលនឹងបុរសនោះថា នៃអ្នក ក្នុងនគរមានមហោស្រព អ្នកមានទ្រព្យខ្លះទេ យើងទាំងពីរទៅលេងជាមួយគ្នា ។ បុរសនោះឆ្លើយថា បាទនាង ទ្រព្យខ្ញុំមាន ។

ស្រីនោះសួរថា មានប៉ុន្មាន ។ បុរសស៊ីឈ្នួលឆ្លើយថា មានកន្លះមាសក: ។ ស្រីនោះសួរទៀតថា ទ្រព្យនោះ នៅឯណា ។ បុរសស៊ីឈ្នួលប្រាប់ថា ខ្ញុំលាក់ទុកខាងក្នុងឥដ្ឋ ក្បែរទ្វារទិសខាងជើង ចម្ងាយអំពីទីនេះ ១២ យោជន៍ ចុះទ្រព្យក្នុងដៃរបស់នាងមានខ្លះឬ ។

នាងឆ្លើយថា ចាស មាន ។ បុរសនោះសួរថា មានប៉ុន្មាន ។ នាងឆ្លើយប្រាប់ថា កន្លះមាសក:ដូចគ្នា ហើយពោលបន្តថា ទ្រព្យរបស់អ្នកកន្លះមាសក: របស់ខ្ញុំកន្លះមាសក: រួមជា ១ មាសក: យើងនឹងយកទ្រព្យនោះ ទិញផ្កាមួយចំណែក ទិញគ្រឿងក្រអូបមួយចំណែក ទិញស្រាមួយចំណែក ហើយដើរលេងទាំងអស់គ្នា ចូរអ្នកទៅនាំទ្រព្យកន្លះមាសក:ដែលទុកនោះមក ។

បុរសអ្នកស៊ីឈ្នួលត្រេកអរថា ប្រពន្ធជឿពាក្យរបស់អញ ទើបពោលថា នៃនាងដ៏ចម្រើន នាងកុំគិតថ្វីឡើយ ខ្ញុំនឹងនាំទ្រព្យនោះមក ដូច្នេះហើយ ចៀសចេញទៅ ។ បុរសអ្នកស៊ីឈ្នួលនោះ មានកម្លាំងស្មើនឹងដំរីសារ ដើរឆ្លងផ្លូវទៅបាន ៦ យោជន៍ ក៏ដល់ពេលថ្ងៃត្រង់ ដើរជាន់លើខ្សាច់ក្តៅដូចរងើកភ្លើង គាត់ត្រេកអរព្រោះចង់បានទ្រព្យ ស្លៀកសំពត់

ដែលជ្រលក់ដោយទឹកអម្ចត់ ប្រដាប់ដោយកុណ្ឌលធ្វើអំពីស្លឹកត្នោត ត្រង់ត្រចៀក ដើរច្រៀងដោយអាយោគវត្ត ធ្វងកាត់តាមលានព្រះរាជវាំង ។

ព្រះបាទឧទយរាជបើកសីហបញ្ជរប្រថាប់ឈរ ទតឃើញបុរសអ្នកស៊ីឈ្នួលមកយ៉ាងនោះ ទ្រង់ព្រះតម្រិះថា ហេតុអ្វីហ្ន៎ ដែលធ្វើឲ្យបុរសនេះ មិនលំបាកដោយខ្យល់និងកម្ដៅថ្ងៃបែបនេះ មានសេចក្ដីត្រេកអរដើរច្រៀង អញនឹងសួរបុរសនេះ ដូច្នេះហើយ ទ្រង់បញ្ជូនរាជបុរសម្នាក់ឲ្យទៅហៅមក ។ រាជបុរសនោះទៅប្រាប់ថា ព្រះរាជាត្រាស់ហៅអ្នក ។

បុរសនោះឆ្លើយថា ព្រះរាជាជាអ្វីនឹងយើង យើងមិនស្គាល់ព្រះរាជាឡើយ ដូច្នេះ ទើបរាជបុរសនោះ នាំទៅដោយការប្រើកម្លាំង គាត់ក៏ឈរក្នុងចំណែកម្ខាង ។ លំដាប់នោះ ព្រះរាជា កាលនឹងសួរ ទើបត្រាស់ ២ គាថាថា

**អង្គារជាតា បឋវី កុក្កុឡានុគតា មហី**
**អថ គាយសិ វត្តានិ ន តំ តបតិ អាតបោ ។**

ប្រឹថពី ជាផែនដីក្ដៅដូចរងើកភ្លើង ប្រកបដោយដីខ្សាច់ (ក្ដៅ) ដូចផេះ (ដែលភ្លើងឆេះ) អ្នកច្រៀងនូវទំនុកទាំងឡាយ កម្ដៅថ្ងៃមិនដុតកម្ដៅអ្នកទេឬ ។

**ឧទ្ធំ តបតិ អាទិច្ចោ អធោ តបតិ វាលុកា**
**អថ គាយសិ វត្តានិ ន តំ តបតិ អាតបោ ។**

*ព្រះអាទិត្យក្តៅខាងលើ ដីខ្សាច់ក្តៅខាងក្រោម អ្នកច្រៀង*
*នូវទំនុកទាំងឡាយ កម្តៅថ្ងៃ មិនដុតកម្តៅអ្នកទេឬ ។*

*បុរសស៊ីឈ្នួលនោះ ស្តាប់ព្រះតម្រាស់របស់ព្រះរាជាហើយ បាន ពោលគាថាទី ៣ ថា*

**ន មំ តបតិ អាតបោ អាតប្បា តបយន្តិ មំ**
**អត្ថា ហិ វិវិធា រាជ តេ តបន្តិ ន អាតបោ ។**

*កម្តៅថ្ងៃ មិនដុតកម្តៅខ្ញុំព្រះអង្គបានទេ កម្តៅ គឺកាម*
*ទាំងឡាយ ទើបញ៉ាំងខ្ញុំព្រះអង្គឲ្យក្តៅបាន បពិត្រព្រះរាជា*
*ប្រយោជន៍ទាំងឡាយ មានប្រការផ្សេង ៗ ប្រយោជន៍*
*ទាំងនោះ តែងដុតកម្តៅ ឯកម្តៅថ្ងៃ មិនដុតកម្តៅទេ ។*

*លំដាប់នោះ ព្រះរាជាត្រាស់សួរបុរសនោះថា បំណងរបស់អ្នក តើដូចម្តេច ។ បុរសនោះក្រាបទូលថា បពិត្រព្រះទេវៈ ទូលព្រះបង្គំនៅ រួមជាមួយស្រីអនាថា ក្បែរទ្វារនគរទិសទក្សិណ នាងសួរទូលព្រះបង្គំថា នៃអ្នក យើងនឹងទៅមើលការលេងមហោស្រព អ្នកមានទ្រព្យក្នុងដៃខ្លះ ដែរឬទេ ទូលព្រះបង្គំបានប្រាប់នាងថា កំណាប់ទ្រព្យ ខ្ញុំទុកក្នុងចន្លោះ កំពែងក្បែរទ្វារទិសឧត្តរ នាងពោលថា ចូរអ្នកទៅនាំទ្រព្យនោះមក យើង ទាំងពីរនឹងទៅមើលការលេងមហោស្រព ហើយបញ្ជូនទូលព្រះបង្គំមក ពាក្យរបស់នាងចាប់ចិត្តទូលព្រះបង្គំពេកណាស់ កាលទូលព្រះបង្គំនឹក*

ដល់ពាក្យរបស់នាង កម្តៅ គឺកាមរមែងដុត បំណងរបស់ទូលព្រះបង្គំ យ៉ាងនេះឯង ។

ព្រះរាជាត្រាស់សួរថា ឯងច្រៀងដើរទៅ មិនអើពើនឹងខ្យល់ និងកម្តៅថ្ងៃបែបនេះ ជាអ្នកត្រេកអររីករាយ ព្រោះហេតុអ្វី ។ បុរសនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំនាំកំណាប់ទ្រព្យនោះមកហើយ នឹងអភិរម្យជាមួយស្រីនោះ ដោយហេតុដូចក្រាបទូលមកនេះ ទើបទូលព្រះបង្គំត្រេកអរ ហើយច្រៀង ។

ព្រះរាជាត្រាស់សួរថា នែបុរសដ៏ចម្រើន ទ្រព្យដែលអ្នកកប់ទុកត្រង់ទ្វារទិសខាងជើង មានប្រមាណមួយសែនឬ ។ បុរសនោះ ក្រាបទូលថា បពិត្រព្រះសម្មតិទេព មិនដល់ប៉ុណ្ណោះទេ ។

ព្រះរាជាត្រាស់សួរតាមលំដាប់ថា បើដូច្នោះ ៥ ម៉ឺនកហាបណៈឬ ។ ៤ ម៉ឺនកហាបណៈឬ ។ ៣ ម៉ឺនកហាបណៈឬ ។ ២ ម៉ឺនកហាបណៈឬ ។ ១ ម៉ឺនកហាបណៈឬ ។ ១ ពាន់កហាបណៈឬ ។ ៥ រយកហាបណៈឬ ។ ៤ រយកហាបណៈឬ ។ ៣ រយកហាបណៈឬ ។ ២ រយកហាបណៈឬ ។ ១ រយកហាបណៈឬ ។ ៥០ កហាបណៈឬ ។ ៤០ កហាបណៈឬ ។ ៣០ កហាបណៈឬ ។ ២០ កហាបណៈឬ ។ ១០ កហាបណៈឬ ។ ៥ កហាបណៈឬ ។ ៤ កហាបណៈឬ ។ ៣ កហាបណៈឬ ។ ២ កហាបណៈឬ ។ ១ កហាបណៈឬ ។ កន្លះ

កហាបណៈឬ ។ ១ បាទឬ ។ ៤ មាសកៈឬ ។ ៣ មាសកៈឬ ។ ២ មាសកៈឬ ។ ១ មាសកៈឬ ។

បុរសនោះ បដិសេធគ្រប់សំណួរតាមលំដាប់ថា មិនដល់ប៉ុណ្ណោះទេ ព្រះអង្គ ។ កាលព្រះរាជាត្រាស់សួរថា កន្វះមាសកៈឬ ។

បុរសអ្នកស៊ីឈ្នួលនោះក្រាបទូលថា ព្រះករុណាថ្លៃវិសេស ទ្រព្យរបស់ទូលព្រះបង្គំ មានប្រមាណប៉ុណ្ណោះឯង ទូលព្រះបង្គំដើរមកដោយនឹកក្នុងចិត្តថា នាំទ្រព្យមកហើយ នឹងអភិរម្យជាមួយនាង ដោយបីតិសោមនស្សនោះ ទើបខ្យល់និងកម្ដៅថ្ងៃមិនដុតទូលព្រះបង្គំ ។

លំដាប់នោះ ព្រះរាជាត្រាស់ថា នែបុរសដ៏ចម្រើន កម្ដៅថ្ងៃដល់ម្ល៉េះ អ្នកកុំទៅទីនោះឡើយ យើងនឹងឲ្យកន្វះមាសកៈដល់ឯង ។ បុរសនោះ ក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំនឹងតាំងនៅក្នុងព្រះតម្រាស់របស់ព្រះអង្គ ទទួលយកទ្រព្យកន្វះមាសកៈនោះផង នឹងមិនធ្វើទ្រព្យកន្វះមាសកៈដែលកប់ទុកឲ្យវិនាសទៅផង ទូលព្រះបង្គំនឹងទៅយកទ្រព្យនោះ មិនឲ្យវិនាសដោយការដើរផ្លូវដែលខំដើរមកផង ។

ព្រះរាជាត្រាស់ថា នែបុរសដ៏ចម្រើន ចូរឯងត្រឡប់ចុះ យើងនឹងឲ្យទ្រព្យ ១ មាសកៈ ២ មាសកៈ ( ហើយទ្រង់ត្រាស់ព្រះរាជទានបន្ថែមឡើងដោយទំនងនេះ រហូតដល់ ) ១ កោដិ ១ រយកោដិ និងទ្រព្យរាប់មិនអស់ ហើយឲ្យបុរសនោះ ត្រឡប់ ។

បុរសនោះក្រាបទូលថា បពិត្រព្រះទេវៈ ទូលព្រះបង្គំ សូមទទួលទ្រព្យ ដែលទ្រង់ព្រះរាជទានផង ទ្រព្យដែលកប់ទុកក៏នឹងទៅយកផង ។ បន្ទាប់អំពីនោះ ព្រះរាជាបានលួងលោមដោយឋានន្តរៈ មានតំណែងសេដ្ឋីជាដើម រហូតឲ្យតាំងនៅក្នុងតំណែងជាឧបរាជ ហើយត្រាស់ថា យើងនឹងឲ្យគ្រងរាជសម្បត្តិពាក់កណ្តាល ចូរត្រឡប់ចុះ ដូច្នេះ ទើបបុរសនោះ យល់ព្រមទទួលព្រះតម្រាស់ ។

ព្រះរាជាទ្រង់ត្រាស់បង្គាប់អាមាត្យទាំងឡាយថា ពួកអ្នក ចូរទៅកោរពុកមាត់ឲ្យសម្លាញ់របស់យើង ហើយឲ្យងូតទឹកតាក់តែងខ្លួន នាំមកជួបយើង ។ ពួកអាមាត្យបានធ្វើតាមព្រះតម្រាស់នោះ ។ ព្រះរាជាចែករាជសម្បត្តិជាពីរចំណែក ឲ្យបុរសនោះគ្រងរាជសម្បត្តិពាក់កណ្តាល ។ អាចារ្យពួកខ្លះពោលថា បុរសស៊ីឈ្នួលនោះ គ្រងរាជសម្បត្តិនោះហើយនៅតែទៅកាន់ទិសឧត្តរ ដោយការស្រឡាញ់ក្នុងទ្រព្យកន្លះមាសកៈនោះ ព្រោះហេតុនោះ ទើបព្រះរាជានោះ មានព្រះនាមថា អឌ្ឍមាសករាជ (ព្រះបាទកន្លះមាសកៈ) ។

ព្រះបាទឧទយរាជនិងព្រះបាទអឌ្ឍមាសករាជ ទ្រង់សាមគ្គីស្និទ្ធស្នាលគ្នា សោយរាជសម្បត្តិ ថ្ងៃមួយ យាងទៅកាន់ព្រះរាជឧទ្យាន ។ ព្រះបាទឧទយរាជ ទ្រង់លេងកីឡាក្នុងព្រះរាជឧទ្យាននោះ រហូតអស់កម្លាំង ទ្រង់យកសីសៈដាក់លើភ្លៅរបស់ព្រះបាទអឌ្ឍមាសករាជ ផ្ទំលក់

ទៅ ។ កាលព្រះបាទឧទយរាជទ្រង់ផ្ទំលក់ហើយ ពួករាជបរិវារក៏នាំគ្នាទៅលេងកីឡាក្នុងទីនោះ ៗ ។

ព្រះបាទអល្លមាសករាជទ្រង់ព្រះតម្រិះថា ប្រយោជន៍អ្វីដែលអញសោយរាជសម្បត្តិពាក់កណ្ដាលជានិច្ច អញនឹងផ្ដាច់ព្រះជន្មព្រះបាទឧទយរាជនេះ សោយរាជសម្បត្តិទាំងអស់ ម្នាក់ឯងល្អជាង ( ដូច្នេះហើយ ទើបហូតដាវចេញអំពីស្រោម គិតថា ) នឹងផ្ដាច់ព្រះជន្ម ( ព្រះបាទឧទយរាជ តែរឭកបានថា ) ព្រះរាជាអង្គនេះ ធ្វើអញដែលជាជនទុរគតអនាថា ឲ្យមានយសសក្តិស្មើនឹងព្រះអង្គ តែងតាំងអញទុកក្នុងភាពជាធំក្រៃលែង សេចក្តីប្រាថ្នាបានកើតឡើងដល់អញថា អញនឹងសម្លាប់ស្ដេចដែលឲ្យយសដល់អញបែបនេះ ហើយឡើងសោយរាជ្យ ជាអំពើដែលមិនគួរធ្វើឡើយ ។ កាលរឭកបានដូច្នេះហើយ ក៏ស៊កដាវក្នុងស្រោម តែគិតហើយគិតទៀត អស់វារៈ ៣ ដង ដើម្បីសម្លាប់ តែមិនអាចស្ងប់ចិត្តបាន ទើបព្រះតម្រិះថា ចិត្តនេះ កើតឡើងរឿយ ៗ គប្បីប្រកបអញទុកក្នុងកម្មលាមក ដូច្នេះហើយ បោះព្រះខ័នទៅលើផែនដីដាស់ព្រះបាទឧទយរាជឲ្យភ្ញាក់ពីបន្ទំ ហើយក្រាបចុះទៀបព្រះបាទាទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ព្រះរាជទានទោសដល់ខ្ញុំចុះ ។

ព្រះបាទឧទយរាជត្រាស់សួរថា នែសម្លាញ់ ទោសក្នុងរវាងអ្នកនិងយើង មិនមាន មិនមែនឬ ។ ព្រះបាទអល្លមាសកៈពោលថា

បពិត្រមហារាជ មាន ទូលព្រះបង្គំបានធ្វើយ៉ាងនេះ ។

ព្រះបាទឧទយពោលថា បើដូច្នោះ សម្លាញ់ ខ្ញុំអត់ទោសឲ្យទ្រង់ បើទ្រង់ចង់សោយរាជសម្បត្តិ ក៏ចូរសោយរាជ្យចុះ ខ្ញុំនឹងធ្វើជាឧបរាជ ទំនុកបម្រុងទ្រង់ ។ ព្រះបាទអឌ្ឍមាសកៈទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំមិនត្រូវការរាជសម្បត្តិ ព្រោះតណ្ហានេះ ធ្វើឲ្យខ្ញុំកើតក្នុងអបាយ សូមទ្រង់ទទួលរាជសម្បត្តិរបស់ទ្រង់វិញចុះ ខ្ញុំនឹងបួស ឫសគល់នៃកាមគុណ ខ្ញុំឃើញហើយ ការពិត កាមគុណនេះ ចម្រើនដល់បុគ្គលដែលត្រិះរិះ ឥឡូវនេះ ចាប់តាំងអំពីនេះទៅ ខ្ញុំនឹងមិនត្រិះរិះដល់ទៀតឡើយ កាលនឹងបន្លឺឧទាន ទើបពោលគាថាទី ៤ ថា

**អទ្ទសំ កាម តេ មូលំ  សង្កប្បា កាម ជាយសិ**
**ន តំ សង្កប្បយិស្សាមិ  ឯវំ កាម ន ហេហិសិ ។**

ម្នាលកាម យើងបានឃើញឫសគល់របស់អ្នកហើយ ម្នាលកាម អ្នកកើតអំពីសេចក្តីត្រិះរិះ យើងលែងត្រិះរិះអ្នកទៀតហើយ ម្នាលកាម កាលបើយ៉ាងនេះ អ្នកនឹងមិនកើតមាន (តទៅទៀតទេ) ។

លុះត្រាស់ដូច្នេះហើយ កាលនឹងសម្តែងធម៌ដល់មហាជនដែលប្រកបក្នុងកាមតទៅ ទើបពោលគាថាទី ៥ ថា

**អប្បាបិ កាមា ន អលំ  ពហូហិបិ ន តប្បតិ**

**អហោ ពាលាន លបនា បដិវិជ្ឈេថ ជគ្គតោ ។**

*កាមទាំងឡាយ សូម្បីតិច ក៏នៅតែមិនល្មម សូម្បីច្រើន ក៏នៅតែមិនស្កប់ស្កល់ ឱ មុខគួរសង្វេគ នឹងការចរចារបស់ពួកជនពាល បុគ្គលលុះតែប្រឹងប្រកបព្យាយាម ទើបត្រាស់ដឹងបាន ។*

*លោកពោលអធិប្បាយទុកដូច្នេះថា បពិត្រមហារាជ វត្ថុកាម និងកិលេសកាម សូម្បីតិចតួច ក៏មិនគ្រប់គ្រាន់សម្រាប់មហាជននេះ មហាជនរមែងមិនឆ្អែតដោយវត្ថុកាម និងកិលេសកាម សូម្បីច្រើន គួរសង្វេគដែលពួកជនពាលនាំគ្នារវើរវាយថា រូប សំឡេងទាំងនេះ ចូរមានដល់អញ កុលបុត្តដែលប្រកបសេចក្តីព្យាយាម ចម្រើនពោធិបក្ខិយធម៌ ញុំាងវិបស្សនាឲ្យចម្រើនហើយ គប្បីដឹងច្បាស់ ចាក់ធ្លុះបាន គឺចាក់ធ្លុះបានដោយការកំណត់ដឹង ការលះ និងការត្រាស់ដឹង ហើយលះបង់បាន ។*

*ព្រះបាទអឌ្ឍមាសកៈ កាលទ្រង់សម្តែងធម៌ដល់មហាជនដូច្នេះហើយ ថ្វាយរាជសម្បត្តិដល់ព្រះបាទឧទយរាជវិញ លះមហាជនដែលមានមុខជោកដោយទឹកភ្នែក ចូលកាន់ហិមវន្តប្បទេស ហើយបួស ញុំាងឈាននិងអភិញ្ញាឲ្យកើតហើយ ។ លុះព្រះបាទអឌ្ឍមាសកៈបួសហើយ ព្រះបាទឧទយរាជ កាលនឹងបន្លឺឧទាន ទើបត្រាស់គាថាទី ៦ ថា*

**អប្បស្ស កម្មស្ស ផលំ មមេទំ**

ឧឧយោ អជ្ឈគមា មហត្តបត្តំ
សុលទ្ធលាភោ វត មាណវស្ស
យោ បព្វជិ កាមរាគំ បហាយ ។

*នេះជាផលកម្ម មានប្រមាណតិចរបស់យើង ឧទយៈ បានសម្រេចនូវភាពជាធំ ឱហ្ន៎ មាណពណា បានលះនូវតម្រេកក្នុងកាម ហើយបួស មាណពនោះ ឈ្មោះថា បានល្អហើយ ។*

*អត្ថនៃគាថានេះ មិនមានអ្នកណាដឹង ។ ថ្ងៃមួយ អគ្គមហេសីក្រាបទូលសួរអត្ថនៃព្រះគាថានឹងព្រះរាជា ។ ព្រះរាជាទ្រង់មិនប្រាប់ ។ ព្រះរាជាមានជាងកោរកាត់ម្នាក់ ឈ្មោះគង្គមាល ។ នាយគង្គមាលនោះ កាលនឹងកោរព្រះមស្សុព្រះរាជា បានធ្វើបរិកម្មដោយកាំបិតកោរមុន ហើយទើបដកព្រះលោមាដោយសណ្ដាសឯក្រោយ កាលធ្វើបរិកម្មដោយកាំបិតកោរ ព្រះរាជាទ្រង់មានសេចក្ដីសុខ កាលដែលដកព្រះលោមា ព្រះរាជាទ្រង់មានសេចក្ដីទុក្ខ ។ ព្រះរាជាចង់ប្រទានពរដល់ជាងកោរកាត់មុន ទើបមានព្រះរាជបំណងកាត់ក្បាលជាខាងក្រោយ ។*

*ថ្ងៃមួយ ព្រះរាជាប្រាប់រឿងនោះដល់ព្រះរាជទេវីថា ម្នាលនាងដ៏ចម្រើន នាយគង្គមាលខ្មាន់ព្រះកេសរបស់យើង ជាបុគ្គលល្ងង់ ។ កាលព្រះទេវីទូលសួរថា បពិត្រព្រះសម្មតិទេព នាយគង្គមាលនោះ ធ្វើដូចម្ដេច*

ទើបគួរ ទើបព្រះរាជាត្រាស់ថា គួរដករោមទាំងឡាយដោយសណ្ដាសជាមុន ហើយសឹមធ្វើបរិកម្មដោយកាំបិតកោរ ក្នុងកាលជាក្រោយ ។

ព្រះទេវីហៅខ្មាន់ព្រះកេសមកប្រាប់ថា នែបា ឥឡូវនេះ ដល់ថ្ងៃដែលត្រូវសម្អាតព្រះមស្សុថ្វាយព្រះរាជា អ្នកគប្បីដកព្រះលោមាមុន រួចធ្វើបរិកម្មដោយកាំបិតកោរក្នុងកាលជាក្រោយ កាលព្រះរាជាប្រទានពរអ្នកគប្បីទូលថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំមិនត្រូវការពរដទៃ សូមទ្រង់ប្រាប់អត្ថនៃឧទានគាថារបស់ទ្រង់ ខ្ញុំនឹងឲ្យទ្រព្យច្រើនដល់អ្នក ។ ខ្មាន់ព្រះកេសទទួលព្រះសវនីយ៍ថា សាធុ ហើយក្នុងថ្ងៃកោរកាត់ព្រះមស្សុ បានប្រើសណ្ដាសមុន កាលព្រះរាជាត្រាស់សួរថា នែគង្គមាលហេតុអ្វី ទើបឯងមិនធ្វើដូចកាលមុន ។ គង្គមាលក្រាបទូលថា បពិត្រព្រះសម្មតិទេព ធម្មតាជាងកោរកាត់ រមែងធ្វើវត្ថុដែលមិនធ្លាប់ធ្វើ ក្រាបទូលហើយ ដកព្រះលោមាមុន ធ្វើបរិកម្មដោយកាំបិតកោរក្នុងកាលឯក្រោយ ។ ព្រះរាជាត្រាស់ថា ចូរទទួលពរ ។

ខ្មាន់ព្រះកេសក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំមិនត្រូវការពរដទៃ សូមទ្រង់ប្រាប់សេចក្ដីនៃឧទានគាថាចុះ ។ ព្រះរាជាទ្រង់ខ្មាសព្រោះជារឿងដែលទ្រង់ក្រីក្រ ទើបត្រាស់ថា នែបា ឯងត្រូវការពរនេះធ្វើអ្វី ចូរទទួលពរដទៃចុះ ។

ខ្មាន់ព្រះកេសក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ប្រទាន

ពរនេះ ដល់ទូលព្រះបង្គំចុះ ។ ព្រះរាជាទ្រង់ខ្មាចមុសាវាទ ទើបទទួលថា សាធុ ហើយឲ្យចាត់ចែងរៀបចំវត្ថុទាំងពួង តាមន័យដែលពោលហើយក្នុងកុម្មាសបិណ្ឌិជាតក គង់ប្រថាប់លើរតនបល្ល័ង្ក ត្រាស់និទានបុរិមកិរិយាទាំងពួងថា នៃគង្គមាល ក្នុងភពមុនយើងកើត ( ជាអ្នកក្រីក្រ ) ក្នុងនគរនេះឯង ( មានសទ្ធា បានរក្សាឧបោសថកន្លះថ្ងៃ ចុតិអំពីអត្តភាពនោះ មកកើតក្នុងត្រកូលក្សត្រ ឈ្មោះឧទយរាជ ) ព្រោះហេតុនេះ ទើបយើងពោលកន្លះគាថាខាងដើម កាលសម្មាញ់របស់យើងលះបង់កាមទៅបួសហើយ យើងជាបុគ្គលប្រមាទ វង្វេង នៅគ្រប់គ្រងរាជសម្បត្តិនេះឯង ដោយហេតុនេះ ទើបយើងពោលកន្លះគាថាខាងចុង ។ ព្រះរាជាត្រាស់ប្រាប់អត្ថនៃឧទានគាថាដោយប្រការដូច្នេះ ។

ខ្មាន់ព្រះកេសស្តាប់រឿងនោះហើយ គិតថា បានឮថា ព្រះរាជាបានរាជសម្បត្តិនេះ ដោយការរក្សាឧបោសថកន្លះថ្ងៃ ឈ្មោះថា កុសលបុគ្គលគួរតែធ្វើ បើដូច្នោះ អញគប្បីបួស ធ្វើទីពឹងដល់ខ្លួនចុះ គិតដូច្នេះហើយ ក៏លះពួកញាតិនិងភោគសម្បត្តិ សូមព្រះរាជាបួស ហើយទៅកាន់ហិមវន្តប្បទេស បួសជាឥសី លើកត្រៃលក្ខណ៍ឡើង ចម្រើនវិបស្សនាសម្រេចបច្ចេកពោធិញ្ញាណ ទ្រទ្រង់បាត្រនិងចីវរដែលកើតឡើងដោយឫទ្ធិ ចាំវស្សាត្រង់ភ្នំគន្ធមាទន៍បាន ៥-៦ វស្សា គិតថា នឹងសួរសុខទុក្ខព្រះបាទពារាណសី ទើបមកតាមអាកាស គង់លើមង្គលសិលាក្នុងរាជ

ឧទ្យាន ។ ឧទ្យានបាលចាំបាន ទើបទៅក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ជាងកោរកាត់ឈ្មោះគង្គមាល បានជា **ព្រះបច្ចេកពុទ្ធ** ហោះមក គង់ក្នុងរាជឧទ្យាន ។ ព្រះរាជាទ្រង់ស្ដាប់ហើយប្រញាប់យាងចេញមក ដោយបំណងថា នឹងថ្វាយបង្គំព្រះបច្ចេកពុទ្ធ ។ ព្រះរាជមាតាចេញទៅមួយអន្លើដោយព្រះរាជា ។ ព្រះរាជាយាងទៅកាន់ព្រះរាជឧទ្យាន ថ្វាយបង្គំព្រះបច្ចេកពុទ្ធ ហើយគង់ប្រថាប់ក្នុងទីសមគួរនាចំណែកម្ខាង មួយអន្លើដោយបរិស័ទ ។ ព្រះបច្ចេកពុទ្ធ កាលធ្វើបដិសណ្ឋារៈចំពោះព្រះរាជា បានហៅព្រះរាជាតាមនាមត្រកូលថា ហៃព្រហ្មទត្តទ្រង់មិនប្រមាទ គ្រងរាជសម្បត្តិដោយធម៌ បំពេញបុណ្យ មានឲ្យទានជាដើមដែរឬ ។

ព្រះរាជជននីបានស្ដាប់ដូច្នោះ ព្រះនាងពិរោធថា គង្គមាលនេះមានជាតិថោកទាប ជាអ្នកជូតមន្ទិលមិនស្អាត ជាជាងកោរកាត់ មិនស្គាល់ប្រមាណខ្លួនឯង ហៅឱរសរបស់អញដែលជាស្ដេចផែនដី ជាស្ដេចដោយជាតិ ដោយឈ្មោះថា ព្រហ្មទត្ត ទើបត្រាស់គាថាទី ៧ ថា

តបសា បជហន្តិ ចាបកម្មំ
តបសា ន្ហាបិតកុម្ភការភាវំ
តបសា អភិភុយ្យ គង្គមាល
នាមេនាលបសិជ្ជ ព្រហ្មទត្តំ ។

ពួកសត្វតែងលះបង់នូវបាបកម្ម (របស់ខ្លួន) ដោយ
តបៈ លះបង់នូវភាវៈនៃខ្លួនជាខ្មាន់ព្រះកេស និង
ស្នូនផ្ទាំង ដោយតបៈ នៃគង្គមាល ថ្ងៃនេះ អ្នកហ៊ាន
រំលោភ ហៅព្រហ្មទត្ត (កូនអញ) ដោយចំឈ្មោះ
ព្រោះអាងមានតបៈឬ ។

គាថានោះ មានអធិប្បាយដូច្នេះថា ព្រះជននីត្រាស់ថា សត្វទាំង-ឡាយនេះ រមែងលះបាបកម្មបានដោយតបៈ គឺតបៈគុណដែលខ្លួនសន្សំទុក តើតបៈទាំងនោះ នឹងលះភាពជាជាងកោរកាត់ និងស្នូនផ្ទាំងបានដែរឬ នៃគង្គមាល ការដែលអ្នកប្រើតបៈរបស់ខ្លួនសង្កត់សង្កិន ហៅឱរសរបស់យើងដោយឈ្មោះថា ព្រហ្មទត្ត ក្នុងថ្ងៃនេះ ជាការសមគួរឬ ។

ព្រះរាជាត្រាស់ហាមព្រះរាជជននីហើយ កាលប្រកាសគុណរបស់ព្រះបច្ចេកពុទ្ធ ទើបត្រាស់គាថាទី ៨ ថា

**សន្ទិដ្ឋិកមេវ អម្ម បស្សថ**
**ខន្តិសោរច្ចស្ស យោ វិបាកោ**
**សោ សព្វជនស្ស វន្ទិតោ អហុ**
**តំ វន្ទាម សរាជិកា សមច្ចា ។**

បពិត្រព្រះមាតា សូមទ្រង់ទតនូវផលនៃខន្តី និងសោរច្ចៈ
ដែលអាចឃើញជាក់ច្បាស់ដោយខ្លួនឯង (ក្នុងបច្ចុប្បន្ន)

ព្រះគន្ធមាលបច្ចេកពុទ្ធនោះ ជាបុគ្គលដែលជនទាំងអស់
ត្រូវថ្វាយបង្គំ យើងព្រមទាំងស្តេចនិងអាមាត្យ នាំគ្នា
ថ្វាយបង្គំនូវព្រះបច្ចេកពុទ្ធនោះ ។

កាលព្រះរាជាត្រាស់ហាមព្រះរាជជននីហើយ មហាជនដ៏សេស ក្រោកឡើងពោលថា បពិត្រព្រះសម្មតិទេព ការដែលមនុស្សជោកទាប បែបនេះ ហៅទ្រង់ដោយឈ្មោះ មិនសមគួរដល់ទ្រង់ឡើយ ។ ព្រះរាជាទ្រង់ហាមមហាជនហើយ ដើម្បីសម្តែងគុណរបស់ព្រះបច្ចេកពុទ្ធនោះ ទើបត្រាស់អវសានគាថាថា

**មា កិញ្ចិ អវចុត្ថ គន្ធមាលំ**
**មុនិនំ មោនបថេសុ សិក្ខមានំ**
**ឯសោ ហិ អតរិ អណ្ណវំ**
**យំ តរិត្វា វិចរន្តិ វីតសោកា ។**

អ្នកទាំងឡាយកុំនិយាយពាក្យតិចតួច នឹងព្រះបច្ចេកពុទ្ធ
ឈ្មោះគន្ធមាល ដែលជាអ្នកសិក្សាក្នុងគន្លងនៃប្រាជ្ញា
របស់ពួកអ្នកប្រាជ្ញឡើយ ព្រោះថា ព្រះបច្ចេកពុទ្ធនេះ
បានឆ្លងនូវអន្លង់ គឺវដ្តសង្សារ ដែលពួកបុគ្គលអ្នកប្រាស
ចាកសោកតែងឆ្លង ហើយត្រាច់ទៅ ។

ព្រះរាជា កាលត្រាស់ដូច្នេះហើយ បានថ្វាយបង្គំព្រះបច្ចេកពុទ្ធ

ត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់អត់នូវទោសដល់ព្រះជននីរបស់ខ្ញុំផងចុះ ។

ព្រះបច្ចេកពុទ្ធពោលតបថា ថ្វាយព្រះពរមហារាជ អាត្មាអត់ទោសឲ្យ ។ ពួករាជបរិស័ទក៏នាំគ្នាញុំាងព្រះបច្ចេកពុទ្ធឲ្យអត់ទោស ។ ព្រះរាជាសូមបេ្តជ្ញាអំពីព្រះបច្ចេកពុទ្ធ ដើម្បីនៅជាមួយទ្រង់តទៅ ព្រះបច្ចេកពុទ្ធមិនឲ្យនូវបេ្តជ្ញា កាលបរិស័ទមួយអន្លើដោយព្រះរាជាកំពុងមើលនោះឯង បានអណ្តែតទៅក្នុងអាកាស ថ្វាយឱវាទដល់ព្រះរាជាហើយ ហោះទៅកាន់ភ្នំគន្ធមាទន៍ ។

ព្រះសាស្តា លុះទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយទើបត្រាស់ថា ម្នាលឧបាសកទាំងឡាយ ឈ្មោះថា ការរក្សាឧបោសថជាកិច្ចដែលបុគ្គលគួររក្សាដោយប្រការដូច្នេះ ហើយទ្រង់ប្រជុំជាតកថា ព្រះបច្ចេកពុទ្ធក្នុងកាលនោះ បានបរិនិព្វានហើយ ព្រះបាទអឌ្ឍមាសកៈក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ព្រះរាជមាតា បានមកជាព្រះនាងមហាមាយា ព្រះអគ្គមហេសី បានមកជារាហុលមាតា ចំណែកព្រះបាទឧទយរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

## គង្គមាលជាតក ចប់ [១]

---

១-ស្រង់ចាកអដ្ឋកថា ជាតក អដ្ឋកនិបាត បិ.៥៩ ទំ.១២១ ឃ.៤៥៣ ។

# តិក្ខាបរម្បរជាតក

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តទ្រង់លះការលុះក្នុងអគតិ ទ្រង់មិនឲ្យរាជធម៌ទាំង ១០ ប្រការ កម្រើក សោយរាជសម្បត្តិដោយធម៌ក្នុងនគរពារាណសី កាលបើដូច្នេះ ការវិនិច្ឆ័យក្ដីរបស់ព្រះអង្គ ក៏មិនមានហាក់ដូចជាទទេ ។ ព្រះរាជាទ្រង់ស្វែងរកទោសរបស់ព្រះអង្គឯង ទ្រង់កំណត់មើលខាងក្នុងព្រះរាជនិវេសន៍ជាដើម មិនឃើញអ្នកពោលទោសរបស់ព្រះអង្គ ខាងក្នុងបុរី ខាងក្នុងព្រះនគរ និងត្រង់ទ្វារស្រុក ទ្រង់ព្រះតម្រិះថា នឹងស្វែងរកក្នុងជនបទ ទើបប្រគល់រាជសម្បត្តិឲ្យដល់ពួកអាមាត្យ ទ្រង់ក្លែងខ្លួនចារិកទៅក្នុងកាសិករដ្ឋជាមួយបុរោហិត មិនបានចួបបុគ្គលពោលទោសរបស់ទ្រង់ សូម្បីត្រឹមតែម្នាក់ ។ លុះយាងដល់និគមមួយក្នុងជាយដែន ទ្រង់ប្រថាប់គង់ត្រង់សាលាក្រៅទ្វារ (ស្រុក) ។ ខណៈនោះ កុដុម្ពិកៈមានសម្បត្តិ ៨០ កោដិ ជាអ្នកនិគមនោះ បានទៅកាន់កំពង់ទឹកជាមួយបរិវារច្រើន ឃើញព្រះរាជាមានព្រះសរីរៈសុខុមាលមានពណ៌សម្បុរដូចមាសគង់ត្រង់សាលា កើតនូវសេចក្ដីស្រឡាញ់ ចូលទៅកាន់សាលា ធ្វើបដិសណ្ឋារៈហើយទូលថា សូមទ្រង់គង់ត្រង់នេះសិនចុះ ហើយទៅកាន់ផ្ទះ រៀបចំភោជនមានរសប្រសើរផ្សេង ៗ ឲ្យបរិវារ

ច្រើននាក់ កាន់ភាជនៈដាក់ភត្តទៅ ។ ខណៈនោះ តាបសអ្នកនៅក្នុងហិមវន្តប្បទេស បានអភិញ្ញា ៥ មកអង្គុយក្នុងសាលានោះដែរ ។ សម័យនោះ មាន **ព្រះបច្ចេកពុទ្ធ** ចេញអំពីញកភ្នំនន្ទមូលកៈ មកតាមអាកាស គង់ក្នុងសាលានោះមួយអង្គដែរ ។

កុដុម្ពិកៈថ្វាយទឹកជម្រះព្រះហស្តដល់ព្រះរាជា រៀបចំថាសដាក់ភត្ត មួយអន្ទើដោយសម្លដែលមានរសផ្សេងៗ បង្អោនចូលទៅថ្វាយ ។ ព្រះរាជាទ្រង់ទទួលភត្តនោះហើយ ព្រះរាជទានដល់បុរោហិត ព្រាហ្មណ៍ទទួលភត្តនោះហើយ ប្រគេនដល់តាបស តាបសទទួលភត្តនោះហើយ ទៅកាន់សម្នាក់ព្រះបច្ចេកពុទ្ធ កាន់ថាសភត្តដោយដៃខាងឆ្វេង កាន់ឃ្នោកទឹកដោយដៃខាងស្តាំ ថ្វាយទក្ខិណោទកហើយដាក់ភត្តក្នុងបាត្រ ។ ព្រះបច្ចេកពុទ្ធមិនបានអញ្ជើញ មិនបានសាកសួរអ្នកណា ឆាន់ហើយ ក្នុងពេលដែលព្រះបច្ចេកពុទ្ធធ្វើភត្តកិច្ចស្រេចហើយ កុដុម្ពិកៈត្រិះរិះថា អញថ្វាយភត្តដល់ព្រះរាជា ព្រះរាជាព្រះរាជទានភត្តដល់ព្រាហ្មណ៍ ព្រាហ្មណ៍ប្រគេនដល់តាបស តាបសប្រគេនដល់ព្រះបច្ចេកពុទ្ធ ព្រះបច្ចេកពុទ្ធមិនបានសាកសួរអ្នកណាឡើយ ហើយឆាន់ អ្វីហ្ន៎ជាហេតុនៃការឲ្យរបស់ជនមានប្រមាណប៉ុណ្ណេះ អ្វីជាហេតុនៃការមិនសាកសួរបុគ្គលណាមួយ ហើយឆាន់របស់ព្រះបច្ចេកពុទ្ធអង្គនេះ អញនឹងត្រូវសួរលោកទាំងនោះ តាមលំដាប់ ។ កុដុម្ពិកៈនោះ ចូលទៅរកម្តងមួយអង្គ

ថ្វាយបង្គំហើយសួរ សូម្បីលោកទាំងនោះ ក៏ប្រាប់ដូចតទៅនេះថា

សុខុមាលរូបំ ជិស្វា រដ្ឋា វិវនមាគតំ
កូដាគារវរូបេតំ មហាសយនមុបោចិតំ ។

ខ្ញុំព្រះអង្គបានឃើញព្រះអង្គ មានព្រះរូបទន់ភ្លន់ ចេញចាក ដែនមកកាន់ព្រៃស្ងាត់ ប្រកបដោយផ្ទះកំពូលដ៏ប្រសើរ មាន អាសនៈដ៏ថ្លៃថ្លា ដែលគេក្រាលបម្រុងទុក ។

តស្ស តេ បេមកោជាហំ អជាសឹ វណ្ណមោទនំ
សាលីនំ វិចិត្តំ ភត្តំ សុចិមំសូបសេចនំ ។

ទើបថ្វាយក្រយាស្ងោយដ៏ឧត្តម ជាភត្តនៃស្រូវសាលីដ៏វិចិត្រ លាយដោយសាច់ដ៏ស្អាត ចំពោះព្រះអង្គនោះ ដោយសេចក្ដី ស្រឡាញ់ ។

តំ ត្វំ ភត្តំ បដិគ្គយ្ហ ព្រាហ្មណស្ស អជាបយិ
អត្តានំ អនសិត្វាន កោយំ ធម្មោ ជមត្ថុ តេ ។

ព្រះអង្គទទួលក្រយាស្ងោយនោះហើយ តែមិនសោយដោយ ព្រះអង្គឯង ត្រឡប់ជាប្រទានដល់ព្រាហ្មណ៍វិញ សូមក្រាប ថ្វាយបង្គំចំពោះព្រះអង្គ តើការណ៍នេះ ជាសភាពដូចម្ដេច ។

ព្រះរាជាត្រាស់ថា

អាចរិយោ ព្រាហ្មណោ មយ្ហំ កិច្ចាកិច្ចេសុ យ្យាវដោ

គរុ ច អាមន្តនិយោ ច　　ជាតុមរហាមិ ភោជនំ ។

*ព្រាហ្មណ៍ ( នេះ ) ជាអាចារ្យរបស់យើង ជាអ្នកខ្វល់ខ្វាយក្នុងកិច្ចតូចនិងកិច្ចធំផង ជាបុគ្គលគួរគោរពផង គួរឲ្យយើងហៅរកផង ( ព្រោះហេតុនោះ ) យើងគួរឲ្យភោជន ។*

*កុដុម្ពិកៈសួរព្រាហ្មណ៍ថា*

ព្រាហ្មណំ ទានិ បុច្ឆាមិ　　គោតមំ រាជបូជិតំ

រាជា តេ ភត្តំ ទាទាសិ　　សុចិមំសូបសេចនំ ។

*ឥឡូវនេះ ខ្ញុំសូមសួរព្រាហ្មណ៍ ជាគោតមគោត្ត ដែលស្តេចតែងបូជា ព្រះរាជាបានប្រទានភត្ត ដែលលាយដោយសាច់ដ៏ស្អាតដល់អ្នក ។*

តំ ត្វំ ភត្តំ បដិគ្គយ្ហ　　ឥសិស្ស ភោជនំ អទា

អខេត្តញ្ញូសិ ទានស្ស　　កោយំ ធម្មោ នមត្ថុ តេ ។

*អ្នកបានទទួលភត្តហើយ ក៏បានប្រគេននូវភោជនដល់ឥសីវិញ អ្នកប្រហែលជាដឹងថា ខ្លួនមិនមែនជាខេត្តនៃទាន ខ្ញុំសូមថ្វាយបង្គំចំពោះអ្នក តើការណ៍នេះ ជាសភាពដូចម្តេច ។*

*ព្រាហ្មណ៍ពោលថា*

ភរាមិ បុត្តទារេ ច　　ឃរេសុ គធិតោ អហំ

កុញ្ជេ មានុសកេ កាមេ　　អនុសាសាមិ រាជិនោ ។

*ខ្ញុំតែងចិញ្ចឹមកូន និងប្រពន្ធផង ចំពាក់ចិត្តក្នុងផ្ទះទាំងឡាយផង ប្រៀនប្រដៅព្រះរាជាថា សូមព្រះអង្គសោយនូវកាមទាំងឡាយ ជារបស់នៃមនុស្សផង ។*

**អារញ្ញិកស្ស ឥសិនោ ចិររត្តំ តបស្សិនោ**
**វុឌ្ឍស្ស ភាវិតត្តស្ស ជាតុមរហាមិ ភោជនំ ។**

*ហេតុនោះ បានជាខ្ញុំគួរប្រគេនភោជនដល់ឥសីវិញ ដែលនៅក្នុងព្រៃ មានតបៈអស់កាលវែង ចម្រើនដោយគុណមានចិត្តចម្រើនហើយ ។*

*កុដុម្ពិកៈសួរឥសីថា*

**ឥសិញ្ច ជានិ បុច្ឆាមិ កីសំ ធមនិសន្ថតំ**
**បរូឡ្ហកច្ឆនខលោមំ បង្កទន្តំ រជស្សិរំ ។**

*ឥឡូវនេះ ខ្ញុំសូមសួរឥសី ដែលស្គមរីមរាំមដោយសរសៃមានរោមក្លៀក និងក្រចកដុះវែង មានធ្មេញប្រកបដោយមន្ទិល មានធូលីលើក្បាល ។*

**ឯកោ អរញ្ញេ វិហរសិ នាវកង្ខសិ ជីវិតំ**
**ភិក្ខុ កេន តយា សេយ្យោ យស្ស ត្វំ ភោជនំ អទា ។**

*លោកនៅក្នុងព្រៃម្នាក់ឯង មិនស្តាយជីវិត លោកបានប្រគេនភោជនដល់ភិក្ខុណា ភិក្ខុនោះ ប្រសើរជាងលោក ដោយ*

*គុណដូចម្តេច ។*

*ឥសីពោលថា*

**ខណាមាលុកាលម្ពានិ ពិលាលិតក្កលានិ ច**
**ធុនំ សាមាកនិវារំ សំហារិយំ បហារិយំ ។**

*អាត្មាជីកដំឡូង ឈ្មោះអាលុកលម្ពៈនិងតាលកន្ទៈទាំងឡាយផង ដំឡូងឈ្មោះពិលាលិ និងតក្កលៈទាំងឡាយផង ប្រូតស្រងែនិងស្មៅ ( យកមក ) បែនបុក ( បរិភោគ ) ផង ។*

**សាកំ ភិសំ មធុំ មំសំ ពទរាមលកានិ ច**
**តានិ អាហត្វ ភុញ្ជាមិ អត្ថិ មេ សោ បរិគ្គហោ ។**

*នាំយកគ្រឿងអន្លក់ និងក្រឱឈូក ទឹកឃ្មុំ សាច់ ពុទ្រា និងកន្ទួតព្រៃ មកបរិភោគផង នោះជាកំណាន់របស់អាត្មា ។*

**បចន្តោ អបចន្តស្ស អមមស្ស សកិញ្ចនោ**
**អនាទានស្ស សាទានោ ជាតុមរហាមិ ភោជនំ ។**

*អាត្មាជាបុគ្គលដាំស្ល មានសេចក្តីខ្វល់ខ្វាយ មានសេចក្តីប្រកាន់នៅឡើយ គួរប្រគេនភោជនដល់ភិក្ខុ ដែលជាអ្នកមិនដាំស្ល មិនមានតណ្ហា មិនមានសេចក្តីប្រកាន់ ។*

*កុដុម្ពិកៈសួរព្រះបច្ចេកពុទ្ធថា*

**ភិក្ខុញ្ច ជានិ បុច្ឆាមិ តុណ្ហិមាសីន សុព្វតំ**

**ឥសិ តេ ភត្តំ ចាជាសិ សុចិមំសូបសេចនំ ។**

*ឥឡូវនេះ ខ្ញុំសូមសួរភិក្ខុដែលអង្គុយស្ងៀម មានវត្តល្អ ដូចត ទៅនេះ ( ឥសី ) បានប្រគេនភត្តដែលលាយដោយសាច់ដ៏ស្អាត ដល់លោក ។*

**តំ ត្វំ ភត្តំ បដិគ្គយ្ហ តុណ្ហី ភុញ្ជសិ ឯកកោ**

**ជាញ្ញំ កញ្ចិ និមន្តេសិ កោយំ ធម្មោ នមត្ថុ តេ ។**

*លោកទទួលភត្តនោះហើយ ក៏បរិភោគស្ងៀម ៗ ម្នាក់ឯង មិនបានអញ្ជើញបុគ្គលដទៃណាមួយ ( ឲ្យបរិភោគផង ) ឡើយ ខ្ញុំសូមថ្វាយបង្គំចំពោះលោក តើការណ៍នេះ ជាសភាពដូចម្ដេច ។*

*ព្រះបច្ចេកពុទ្ធពោលថា*

**ន បចាមិ ន បាចេមិ ន ឆិន្ទាមិ ន ឆេទយេ**

**តំ មំ អកិញ្ចនំ ញត្វា សព្វបាបេហិ អារតំ ។**

*អាត្មាមិនដាំស្លខ្លួនឯង មិនប្រើឲ្យគេដាំស្ល មិនកាត់ខ្លួនឯង មិនប្រើគេឲ្យកាត់ ហេតុនោះ បានជាឥសីដឹងថា អាត្មាជាអ្នកមិនមានសេចក្ដីកង្វល់ ជាអ្នកប្រាសចាកបាបគ្រប់ចំពូក ។*

**វាមេន ភិក្ខមាទាយ ទក្ខិណេន កមណ្ឌលុំ**

**ឥសិ មេ ភត្តំ បាទាសិ សុចិមំសូបសេចនំ ។**

*ទើបកាន់ចង្ក្រាន់ដោយដៃឆ្វេង កាន់សម្បកឃ្លោកដោយដៃ*

ស្ដាំ ហើយប្រគេនភត្ត ដែលលាយដោយសាច់ដ៏ស្អាតនោះ ដល់អាត្មា ។

ឯតេ ហិ ជាតុមរហន្តិ សមមា សបរិក្ខហា
បច្ចនីកមហំ មញ្ញេ យោ ជាតារំ ជិមន្តយេ ។

តាមពិត ជនទាំងឡាយ ( មានស្ដេចជាដើម ) នុ៎ះ ជាអ្នកប្រកាន់ថា របស់អញ មានសេចក្ដីហួងហែង គួរតែឲ្យទាន ( ដល់បុគ្គលប្រាកដស្មើដោយអាត្មា ) បុគ្គលណា អញ្ជើញនូវអ្នកឲ្យទាន ( មកបរិភោគ ) អាត្មាសម្គាល់ ( នូវបុគ្គលនោះ ) ថា ជាអ្នកប្រតិបត្តិខុសទំនង ។

កុដុម្ពិកៈស្ដាប់ពាក្យនោះ របស់លោកហើយ ត្រេកអរ ពោលគាថាចុងក្រោយ ២ គាថា ដូច្នេះថា

អត្ថាយ វត មេ អជ្ជ ឥធាគច្ឆិ រថេសភោ
យោហំ អជ្ជ បជានាមិ យត្ថ ទិន្នំ មហប្ផលំ ។

ក្នុងថ្ងៃនេះ ព្រះរាជាព្រះអង្គប្រសើរលើរថ បានយាងមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ខ្ញុំមែនហើយ ដ្បិតខ្ញុំបានដឹងច្បាស់ក្នុងថ្ងៃនេះថា ទានដែលគេឲ្យហើយ ចំពោះបុគ្គលណា ជាទានមានផលច្រើន ។

រដ្ឋេសុ គិទ្ធា រាជានោ កិច្ចាកិច្ចេសុ ព្រាហ្មណា

**ឥសី មូលផលេ គិទ្ធា វិប្បមុត្តា ច ភិក្ខវោ ។**

*ស្តេចទាំងឡាយ ជាប់ចំពាក់ក្នុងដែនដី ពួកព្រាហ្មណ៍ជាប់ចំពាក់ក្នុងកិច្ចតូចនិងកិច្ចធំ ពួកឥសីជាប់ចំពាក់ក្នុងមើមឈើនិងផ្លែឈើ ឯពួកភិក្ខុ ទើបរួចស្រឡះចាកកិលេស ។*

*ព្រះបច្ចេកពុទ្ធសម្តែងធម៌ដល់កុដុម្ពិកៈហើយ ត្រឡប់ទៅកាន់លំនៅរបស់ខ្លួនវិញ តាបសក៏ដូចគ្នា ។ ឯព្រះរាជាទ្រង់ស្នាក់នៅក្នុងសម្នាក់របស់កុដុម្ពិកៈ ២-៣ ថ្ងៃហើយ ទើបទៅកាន់នគរពារាណសីនោះឯង ។*

*ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលបិណ្ឌបាតមកដល់បុគ្គលដែលសមគួរបាន សូម្បីក្នុងកាលមុន ក៏បានដល់ហើយដូចគ្នា ហើយទ្រង់ប្រជុំជាតកថា កុដុម្ពិកៈ អ្នកបូជាធម៌ក្នុងកាលនោះ បានមកជាកុដុម្ពិកៈដែលធ្វើសក្ការៈដល់ព្រះធម្មរតនៈ ក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ បុរោហិតបានមកជាសារីបុត្ត ចំណែកតាបសដែលនៅក្នុងព្រៃហិមពាន្តក្នុងកាលនោះ គឺតថាគតនេះឯង ។*

## ភិក្ខាបរម្បរជាតក ចប់ [១]

---

*១-ស្រង់ចាកអដ្ឋកថា ជាតក បកិណ្ណកនិបាត បិ.៦០ ទំ.៩៧ ឃ.១៩៣ ។*

# សង្ខជាតក

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការថ្វាយបរិក្ខារទាំងពួង ទើបត្រាស់រឿងនេះថា

ក្នុងអតីតកាល នគរពារាណសីមានឈ្មោះមោលិនី ។ ព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិក្នុងនគរមោលិនីនោះ ។ មានព្រាហ្មណ៍ម្នាក់ឈ្មោះសង្ខៈ ជាអ្នកស្ដុកស្ដម្ភ មានភោគៈច្រើន មានគ្រឿងដែលធ្វើឲ្យត្រេកអរ ដូចជាទ្រព្យ ស្រូវ មាស និងប្រាក់ជាដើម គាត់ឲ្យធ្វើសាលាសម្រាប់ឲ្យទាន ៦ កន្លែង គឺត្រង់ទ្វារនគរទាំងបួន ត្រង់កណ្ដាលនគរ និងត្រង់ទ្វារផ្ទះ លះទ្រព្យមួយថ្ងៃ ៦ សែន ឲ្យមហាទានប្រព្រឹត្តទៅដល់មនុស្សកំព្រា និងអ្នកដំណើរដែលជាអាគន្តុកៈរាល់ថ្ងៃ ។ ថ្ងៃមួយ គាត់គិតថា កាលទ្រព្យក្នុងផ្ទះអស់ហើយ អញមិនអាចឲ្យទានបាន កាលទ្រព្យមិនទាន់អស់ អញនឹងចេញសំពៅទៅសុវណ្ណភូមិនាំទ្រព្យមក គិតដូច្នេះហើយ ទើបរៀបចំសំពៅ ផ្ទុកទំនិញទាល់តែពេញ ហើយហៅបុត្តភរិយាមកប្រាប់ថា ពួកនាង ចូរឲ្យទានរបស់យើងប្រព្រឹត្តទៅ កុំឲ្យដាច់ទម្រាំយើងត្រឡប់មក ហើយចោមរោមដោយទាសៈនិងកម្មករ បាំងឆត្រពាក់ស្បែកជើង ដើរតម្រង់ទៅកាន់កំពង់ក្នុងពេលថ្ងៃត្រង់ ។ ក្នុងខណៈនោះ នៅឯភ្នំគន្ធមាទន៍ មាន **ព្រះបច្ចេកពុទ្ធ** មួយអង្គរំពឹងមើល ក៏បាន

ឃើញព្រាហ្មណ៍នោះ កំពុងធ្វើដំណើរទៅ ដើម្បីនាំទ្រព្យមក ទើបគិតថា មហាបុរសទៅរកទ្រព្យ អន្តរាយនឹងមានក្នុងសមុទ្រដែរឬហ្ន៎ ក៏ជ្រាបថា នឹងមានអន្តរាយ ( ទើបគិតបន្តទៀតថា ) មហាបុរសនេះ ឃើញអាត្មាអញហើយ នឹងប្រគេនឆត្រ ស្បែកជើងដល់អញ កាលសំពៅបែកធ្លាយកណ្ដាលសមុទ្រ មហាបុរសនេះ នឹងបាននូវទីពឹងដោយអានិសង្សដែលឲ្យស្បែកជើង អញនឹងធ្វើនូវសេចក្ដីអនុគ្រោះដល់មហាបុរសនេះ ដូច្នេះហើយ ក៏ហោះមកតាមអាកាស ចុះក្នុងទីជិតសង្ខព្រាហ្មណ៍ និមន្តជាន់ដីខ្សាច់ក្ដៅ ដូចក្រាលដោយរងើកភ្លើង ព្រោះខ្យល់និងកម្ដៅដ៏ខ្លាំងក្លាតម្រង់មកកាន់សង្ខព្រាហ្មណ៍ ។

សង្ខព្រាហ្មណ៍គ្រាន់តែឃើញព្រះបច្ចេកពុទ្ធប៉ុណ្ណោះ ក៏ត្រេកអរថា បុញ្ញក្ខេត្តរបស់អញមកដល់ហើយ ថ្ងៃនេះ អញគួរព្រោះពូជ គឺទានក្នុងបុញ្ញក្ខេត្តនេះ ទើបប្រញាប់ចូលទៅនមស្ការព្រះបច្ចេកពុទ្ធ ហើយពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ចុះអំពីផ្លូវបន្តិច ដើម្បីអនុគ្រោះដល់ខ្ញុំ សូមចូលទៅត្រង់គល់ឈើនេះ ។ លុះព្រះបច្ចេកពុទ្ធចូលទៅត្រង់គល់ឈើ ក៏ពូនខ្សាច់ឡើង យកសំពត់ដណ្ដប់ក្រាល នមស្ការព្រះបច្ចេកពុទ្ធ ហើយលាងជើងព្រះបច្ចេកពុទ្ធ ដោយទឹកដែលអប់ និងត្រងស្អាត លាបជើងដោយប្រេងក្រអូប ដោះស្បែកជើងដែលខ្លួនពាក់លាបដោយគ្រឿងក្រអូប ហើយពាក់ត្រង់ជើងព្រះបច្ចេកពុទ្ធ ប្រគេនឆត្រ

និងស្បែកជើងដោយវាចាថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ពាក់ស្បែកជើងនេះ ហើយបាំងឆត្រនិមន្តទៅចុះ ។ ព្រះបច្ចេកពុទ្ធដើម្បីអនុគ្រោះសង្ខព្រាហ្មណ៍ ទើបទទួលឆត្រនិងស្បែកជើង ដើម្បីឲ្យសេចក្តីជ្រះថ្លារីងរឹតតែចម្រើនឡើង ទើបហោះទៅកាន់ភ្នំគន្ធមាទន៍ ឲ្យសង្ខព្រាហ្មណ៍ឃើញទុំះឯង ។ ព្រះពោធិសត្វបានឃើញដូច្នោះហើយមានចិត្តជ្រះថ្លាក្រៃលែង ដើរទៅកាន់កំពង់ ឡើងជិះសំពៅហើយ ។ លំដាប់នោះ កាលសំពៅកំពុងអណ្តែតទៅក្នុងមហាសមុទ្ទ ដល់ថ្ងៃទី ៧ សំពៅក៏បែកធ្លាយ ទឹកហូរចូល មិនមាននរណាអាចបាចទឹកឲ្យអស់បាន មហាជនខ្លាចចំពោះមរណភ័យ នាំគ្នានមស្ការទេវតាដែលខ្លួនរាប់អានរៀងៗ ខ្លួន ហើយស្រែកបន់ស្រន់ ។ ព្រះមហាសត្វនិងអ្នកបម្រើម្នាក់លាបសរីរៈដោយប្រេង ទំពាស្ករក្រាមនិងសប្បិ គ្រប់គ្រាន់ដល់សេចក្តីត្រូវការហើយ ឡើងលើសសរក្តោងជាមួយឧបដ្ឋាកនោះ កំណត់ទិសថានគររបស់យើងនៅទិសនេះ កាលនឹងដោះខ្លួនអំពីអន្តរាយ មានត្រីនិងអណ្តើកជាដើម ទើបលោតបំផ្លោងទៅក្នុងទីប្រមាណមួយឧសភៈ ជាមួយអ្នកបម្រើនោះ ។ មហាជនវិនាសគ្មានសល់ ចំណែកព្រះមហាសត្វនិងអ្នកបម្រើនោះ ព្យាយាមហែលឆ្លងសមុទ្ទអស់ ៧ ថ្ងៃ ។ ថ្ងៃនោះជាថ្ងៃឧបោសថ ព្រះពោធិសត្វបានខ្ពុរមាត់ដោយទឹកប្រៃ ហើយរក្សាឧបោសថ ។

ក្នុងកាលនោះ ទេពធីតាឈ្មោះមណិមេខលា បានទទួលការតែងតាំងអំពីស្ដេចចតុលោកបាលទាំង ៤ ឲ្យជាអ្នករក្សាសមុទ្រ ដោយប្រាប់ថា បើសំពៅបែកធ្លាយ មនុស្សដែលដល់ត្រៃសរណគមន៍ក្ដី មានសីលបរិបូណ៌ក្ដី បដិបត្តិប្រពៃក្នុងមាតាបិតាក្ដី ដែលដល់ហើយនូវសេចក្ដីទុក្ខក្នុងសមុទ្រនេះ នាងគប្បីរក្សាបុគ្គលនោះ ។ ទេពធីតាប្រមាទដោយភាពជាធំរបស់ខ្លួនអស់ ៧ ថ្ងៃ ដល់ថ្ងៃទី ៧ ទើបមកមើលសមុទ្រ បានឃើញសង្ខព្រាហ្មណ៍ប្រកបដោយសីលនិងអាចារៈ កើតសេចក្ដីសង្វេគគិតថា ព្រាហ្មណ៍នេះ លំបាកក្នុងសមុទ្រអស់ ៧ ថ្ងៃហើយ បើព្រាហ្មណ៍នេះ ស្លាប់ អញនឹងបានទទួលនូវការតិះដៀលជាច្រើន ដូច្នេះហើយនាងបានរៀបចំថាសមាសមួយ ពេញដោយទិព្វភោជន ដែលមានរសប្រសើរផ្សេង ៗ ហោះទៅក្នុងទីនោះ ដោយរហ័ស ឈរនៅលើអាកាសក្នុងទីចំពោះមុខសង្ខព្រាហ្មណ៍ ពោលថា បពិត្រព្រាហ្មណ៍ លោកអត់អាហារ ៧ ថ្ងៃហើយ ចូរបរិភោគភោជនទិព្វនេះចុះ ។

សង្ខព្រាហ្មណ៍សម្លឹងមើលទេពធីតាហើយ ពោលថា ចូរនាំភត្តរបស់នាងចេញទៅ យើងរក្សាឧបោសថ ។ លំដាប់នោះ ឧបដ្ឋាកដែលនៅខាងក្រោយ មិនឃើញទេវតា បានឮតែសំឡេង គិតថា ដោយប្រក្រតីព្រាហ្មណ៍នេះ ជាមនុស្សសុខុមាលជាតិ អត់អាហារលំបាកអស់ ៧ ថ្ងៃប្រហែលជារវើរវាយខ្លាចស្លាប់ អញនឹងលួងលោមព្រាហ្មណ៍ គិតដូច្នេះ

ហើយ បានពោលគាថាទី ១ ថា

ពហុស្សុតោ សុតធម្មោសិ សង្ខ
ទិដ្ឋា តយា សមណាព្រាហ្មណា ច
អថក្ខណេ ទស្សយសេ វិលាបំ
អញ្ញោ នុ កោ តេ បដិមន្តកោ មយា ។

បពិត្រសង្ខព្រាហ្មណ៍ អ្នកជាពហុស្សូត ធ្លាប់បានស្តាប់ធម៌ ទាំងសមណព្រាហ្មណ៍ អ្នកក៏បានចួបហើយ កាលបើដូច្នេះ ( ហេតុអ្វី ) ទើបអ្នកសម្តែងនូវពាក្យរវើរវាយ ក្នុងកាលមិនមែនជាខណៈ អ្នកណាទៀតហ្ន៎ ជាអ្នកប្រឹក្សាចំពោះអ្នក ក្រៅអំពីខ្ញុំ ។

សង្ខព្រាហ្មណ៍បានស្តាប់ពាក្យរបស់ឧបដ្ឋាកនោះហើយ ទើបគិតថា ប្រហែលជាទេវតានោះ មិនប្រាកដដល់បុរសនេះ ទើបពោលថា នែសម្លាញ់ យើងមិនបានខ្លាចមរណភ័យ អ្នកដទៃដែលមកប្រឹក្សាជាមួយនឹងយើង មាន ហើយពោលគាថាទី ២ ថា

សុព្ភា សុភា សុប្បដិមុក្កកម្ពុ
បគ្គយ្ហ សោវណ្ណមយាយ បាតិយា
ភុញ្ជស្សុ ភត្តំ ឥតិ មំ វទេតិ
សទ្ធាវិត្តា តមហំ នោតិ ព្រូមិ ។

ទេវធីតាមានមុខល្អ មានរូបល្អ មានមាសពាក់ដោយល្អ កាន់នូវ ( ភត្ត ) ដោយភាជន៍មាស មានសទ្ធាមានចិត្តរីករាយ និយាយនឹងយើងថា អ្នកចូរបរិភោគនូវភត្តចុះ យើងនិយាយនឹងទេវតានោះថា យើងមិន ( បរិភោគ ) ទេ ។

លំដាប់នោះ អ្នកបម្រើបានពោលគាថាទី ៣ ថា

**ឯតាទិសំ ព្រាហ្មណ ទិស្វាន យក្ខំ**

**បុច្ឆេយ្យ ចោសោ សុខមាសីសានោ**

**ឧដ្ឋេហិ នំ បញ្ជលិកាភិបុច្ឆ**

**ទេវី នុសិ ត្វំ ឧទ មានុសី នុ ។**

ម្នាលព្រាហ្មណ៍ ជម្មតាបុរសអ្នកប្រាថ្នាសេចក្ដីសុខកាលបានឃើញយក្ខប្រាកដដូច្នោះហើយ គួរណាស់តែសួរ ( ឲ្យដឹង ) អ្នកចូរក្រោកឡើង ហើយប្រណម្យដៃ សួរយក្ខនោះថា នាងជាទេវធីតា ឬជាមនុស្ស ។

ព្រះពោធិសត្វគិតថា ឧបដ្ឋាកនិយាយត្រូវ កាលនឹងសួរទេពធីតានោះ ទើបពោលគាថាទី ៤ ថា

**យំ ត្វំ សុខេនាភិសមេក្ខសេ មំ**

**ភុញ្ជស្សុ ភត្តំ ឥតិ មំ វទេសិ**

បុច្ឆាមិ តំ ជារិ មហានុភាវេ
ទេវី នុសិ ត្វំ ឧទ មានុសី នុ ។

*នាងបានគយគន់មើលយើង ដោយសេចក្ដីសុខ និយាយនឹងយើងថា អ្នកចូរបរិភោគនូវកត្តចុះ ម្នាលនាងនារី អ្នកមានអានុភាពធំ យើងសូមសួរនាង តើនាងជាទេវធីតា ឬជាមនុស្ស ។*

*លំដាប់នោះ ទេពធីតាពោលគាថា ២ ថា*

ទេវី អហំ សង្ខ មហានុភាវា
ឥធាគតា សាគរវារិមជ្ឈេ
អនុកម្បិកា នោ ច បទុដ្ឋចិត្តា
តវេវ អត្ថាយ ឥធាគតាស្មិ ។

*បពិត្រសង្ខព្រាហ្មណ៍ ខ្ញុំជាទេវធីតា មានអានុភាពធំ មកក្នុងកណ្ដាលសាគរនេះ ព្រោះខ្ញុំមានសេចក្ដីអនុគ្រោះ មិនមែនមានចិត្តប្រទូស្តទេ ទើបមកក្នុងទីនេះ ដើម្បីប្រយោជន៍ចំពោះអ្នកតែម្យ៉ាង ។*

ឥធន្នបានំ សយនាសនញ្ច
យានានិ នានាវិធានិ សង្ខ
សព្វស្ស ត្យាហំ បដិបាទយាមិ

**យំ កិញ្ចិ តុយ្ហំ មនសាភិបត្ថិតំ ។**

*បពិត្រសង្ខព្រាហ្មណ៍ ក្នុងសមុទ្រនេះ មានបាយ ទឹក ទីដេក ទីអង្គុយ និងយានផ្សេងៗ ជាច្រើន អ្នកមានចិត្តប្រាថ្នាចំពោះរបស់ណាមួយ ខ្ញុំនឹងប្រគល់ឲ្យរបស់ទាំងអស់នោះ ដល់អ្នក ។*

*ព្រះមហាសត្វបានស្តាប់ដូច្នោះហើយ គិតថា ទេវតានេះពោលថា នឹងឲ្យយ៉ាងនោះ យ៉ាងនេះ ដល់អញកណ្តាលផ្ទៃសមុទ្រ នាងប្រាថ្នានឹងឲ្យដោយបុញ្ញកម្មដែលអញធ្វើទុក ឬនឹងឲ្យដោយអានុភាពរបស់ខ្លួន អញនឹងសាកសួរមើល កាលនឹងសាកសួរបានពោលគាថាទី ៧ ថា*

**យំ កិញ្ចិ យិដ្ឋញ្ច ហុតញ្ច មយ្ហំ**
**សព្វស្ស នោ ឥស្សរា ត្វំ សុគត្តេ**
**សុស្សោណិ សុព្ភុ សុវិលាកមជ្ឈេ**
**កិស្ស មេ កម្មស្ស អយំ វិបាកោ ។**

*បពិត្រនាងទេវធីតា មានរាងខ្លួនល្អ មានត្រគាកល្អ មានរង្គចិញ្ចើមល្អ មានអវយវៈពាក់កណ្តាលខ្លួនល្អ ការបូជាធំក្តី បូជាតូចក្តី ណាមួយរបស់ខ្ញុំ នាងជាឥស្សរៈនៃបុញ្ញកម្មរបស់យើងនោះទាំងអស់ នេះជាផលនៃកម្មរបស់ខ្ញុំដូចម្តេច ។*

នាងទេវធីតាបានស្តាប់ពាក្យនោះហើយ គិតថា ព្រាហ្មណ៍នេះ ទំនងជាមិនដឹងថា កុសលកម្មណាដែលបុគ្គលនោះធ្វើហើយ ( បុគ្គលនោះ ) មិនដឹងនូវកុសលកម្មនោះទេ ទើបសួរ ។ ឥឡូវនេះ អញនឹងប្រាប់ដល់បុរសនេះ ( ឲ្យបានដឹង ) ទើបពោលគាថាទី ៨ ថា

**យម្ហេ បថេ ព្រាហ្មណ ឯកភិក្ខុំ**
**ឧគ្ឃដ្ដបាទំ តសិតំ កិលន្តំ**
**បដិបាទយិ សង្ខ ឧបាហនានិ**
**សា ទក្ខិណា កាមទុហា តវជ្ជ ។**

បពិត្រសង្ខព្រាហ្មណ៍ អ្នកបានប្រគេនស្បែកជើង ចំពោះភិក្ខុ ១ អង្គ ( ព្រះបច្ចេកពុទ្ធ ) ដែលមានជើងកំពុងរលាក ស្រេកឃ្លាន លំបាក ក្នុងផ្លូវដ៏ក្តៅ ទក្ខិណាទាននោះ ឲ្យនូវសេចក្តីប្រាថ្នាដល់អ្នក ក្នុងថ្ងៃនេះ ។

ព្រះមហាសត្វបានស្តាប់ដូច្នោះហើយ មានចិត្តត្រេកអរ គិតថា ការថ្វាយស្បែកជើងដែលអញបានឲ្យហើយ ឲ្យផលដែលគួរប្រាថ្នាគ្រប់យ៉ាង ក្នុងមហាសមុទ្រដែលមិនមានទីពឹងបែបនេះ ឱ ! ការដែលអញថ្វាយទានដល់ព្រះបច្ចេកពុទ្ធ ជាការថ្វាយល្អហើយ ដូច្នេះ ទើបពោលគាថាទី ៩ ថា

សា ហោតុ នាវា ផលកូបបន្នា
អនវស្សុតា ឯរកវាតយុត្តា
អញ្ញស្ស យានស្ស ន ហេត្ថ ភូមិ
អជ្ជេវ មំ មោលិនឹ បាបយស្សុ ។

*សូមឲ្យកើតសំពៅដែលពាសដោយផែនក្តារ ជាសំពៅមិនលិចទឹក ប្រកបដោយក្តោង និងខ្យល់ ព្រោះថា ក្នុងសមុទ្រនេះ មិនមែនជាភូមិនៃយានដទៃឡើយ សូមនាងចម្លងខ្ញុំឲ្យដល់នូវក្រុងមោលិនី ក្នុងថ្ងៃនេះ ។*

*គប្បីជ្រាបអត្ថនៃពាក្យដែលជាគាថានោះថា នៃទេពធីតា កាលបើដូច្នោះ សូមនាងនិម្មិតសំពៅមួយដល់ខ្ញុំចុះ តែសូមនិម្មិតសំពៅតូចមួយប្រមាណប៉ុនទូកកម្រោល ម្យ៉ាងទៀត សំពៅដែលនាងនិម្មិត ឲ្យជាសំពៅដែលធ្វើដោយបន្ទះក្តារច្រើនបន្ទះ ដែលបោះភ្ជាប់ល្អហើយ ឈ្មោះថាទឹកមិនលិច ព្រោះមិនមានប្រហោងដែលឲ្យទឹកហូរចូលទៅបាន ប្រកបដោយក្តោងដែលខ្យល់បក់ទៅយ៉ាងស្រួល ព្រោះក្នុងសមុទ្រនេះ ទីដែលប្រើយានពាហនៈដទៃ វៀរសំពៅទិព្វ មិនមាន សូមនាងបញ្ជូនខ្ញុំឲ្យដល់នគរមោលិនីដោយសំពៅនោះ ក្នុងថ្ងៃនេះចុះ ។ ទេពធីតាបានស្តាប់ពាក្យព្រះពោធិសត្វហើយ មានចិត្តត្រេកអរ និម្មិតសំពៅមួយ សម្រេច*

ដោយកែវ ៧ ប្រការ សំពៅនោះ បណ្តោយ ៨ ឧសភៈ ទទឹង ៤ ឧសភៈ ជម្រៅ ២០ ឈើច្រត់ មានសសរក្តោង ៣ សម្រេចដោយកែវឥន្ទនិល មានខ្សែរចងសម្រេចដោយមាស មានរ៉កសម្រេចដោយប្រាក់ មានកន្សែ្ស សម្រេចដោយមាស ទេវតាយករតនៈ ៧ ប្រការដាក់ពេញសំពៅហើយ បីព្រាហ្មណ៍ដាក់លើសំពៅដែលប្រដាប់ហើយ តែមិនបានក្រឡេកមើល បុរសដែលជាឧបដ្ឋាករបស់ព្រះពោធិសត្វឡើយ ។ ព្រាហ្មណ៍បានឲ្យ ចំណែកបុណ្យដែលខ្លួនធ្វើដល់ឧបដ្ឋាក ឧបដ្ឋាកក៏ទទួលអនុមោទនា ។ រំពេចនោះ ទេវតាក៏បីឧបដ្ឋាកនោះ ឡើងលើសំពៅដែរ ។ លំដាប់ នោះ ទេវតាក៏នាំសំពៅទៅកាន់នគរមោលិនី ធ្វើទ្រព្យឲ្យតាំងនៅក្នុងផ្ទះ ព្រាហ្មណ៍ហើយ ទៅកាន់លំនៅរបស់ខ្លួនវិញ ។

ព្រះសាស្តា កាលទ្រង់ត្រាស់ដឹងហើយ បានត្រាស់អភិសម្ពុទ្ធគាថា ដែលជាគាថាចុងក្រោយថា

សា តុដ្ឋចិត្តា សុមនា បតីតា
នាវំ សុចិត្តំ អភិនិម្មិនិត្វា
អាទាយ សង្ខំ បុរិសេន សទ្ធឹ
ឧបានយី នគរំ សាធុរម្មំ ។

ទេវតានោះ មានចិត្តត្រេកអរ រីករាយ សប្បាយ និម្មិត
សំពៅដ៏វិចិត្រល្អ ហើយនាំសង្ខព្រាហ្មណ៍ ព្រមទាំង

បុរសឧបដ្ឋាក ចូលទៅកាន់ក្រុងជាទីសុខសាន្ត ។

ព្រាហ្មណ៍គ្រប់គ្រងផ្ទះ ដែលមានទ្រព្យប្រមាណមិនបាន ឲ្យទាន រក្សាសីល ដរាបដល់អស់ជីវិត កាលអស់ជីវិតហើយ មួយអន្លើដោយ បរិស័ទបានទៅកើតក្នុងទេវនគរ ។

ព្រះសាស្តា លុះទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទើបប្រកាសសច្ចធម៌ ហើយទ្រង់ប្រជុំជាតក ។ លុះចប់សច្ចៈ ឧបាសក នោះ បានតាំងនៅក្នុងសោតាបត្តិផល ។ ទេពធីតាក្នុងកាលនោះ បាន មកជាឧប្បលវណ្ណាថេរីក្នុងកាលឥឡូវនេះ អ្នកបម្រើបានមកជាអានន្ទ ចំណែកសង្ខព្រាហ្មណ៍ គឺតថាគតនេះឯង ។

## សង្ខជាតក ចប់ [១]

---

១-ស្រង់ចាកអដ្ឋកថា ជាតក ទសកនិបាត បិ.៥៩ ទំ.១៧២ ឃ.៦៥៥ ។

# បានីយជាតក

ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការសង្កត់សង្កិនកិលេស ទើបត្រាស់ព្រះធម្មទេសនានេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី សម្លាញ់ពីរនាក់នៅក្នុងស្រុកតូចមួយ នាដែនកាសី នាំគ្នាកាន់ក្អមទឹកទៅកាន់ព្រៃ ដាក់ក្អមក្នុងចំណែកម្ខាងហើយ កាប់ចម្ការ ក្នុងពេលស្រេកទឹក ក៏នាំគ្នាផឹកទឹក ។ បណ្តាបុរសពីរនាក់នោះ បុរសម្នាក់ កាលមកផឹកទឹក ក៏រក្សាទឹករបស់ខ្លួនទុក ផឹកទឹកក្នុងក្អមរបស់សម្លាញ់ម្នាក់ទៀត ពេលល្ងាចចេញអំពីព្រៃហើយ ឈរងូតទឹក ពិចារណាថា ថ្ងៃនេះ អញបានធ្វើបាបណាមួយទុកដោយកាយទ្វារជាដើម មានដែរឬហ្ន៎ ឃើញការដែលលួចផឹកទឹករបស់សម្លាញ់ ទើបសង្វេគ គិតថា តណ្ហានេះ កាលចម្រើន គង់បោះអញទៅក្នុងអបាយ ដោយពិត អញនឹងសង្កត់កិលេសនេះឲ្យបាន ហើយធ្វើការលួចទឹកផឹករបស់សម្លាញ់នោះ ឲ្យជាអារម្មណ៍ចម្រើនវិបស្សនា ញុំាងបច្ចេកពោធិញ្ញាណឲ្យកើតឡើង ឈរពិចារណាដល់គុណដែលខ្លួនបានហើយ ។ លំដាប់នោះ បុរសម្នាក់ទៀត ងូតទឹកហើយឡើងមក ពោលថា **ឯហិ សម្ម ឃរំ គច្ឆាម** មកសម្លាញ់ យើងនាំគ្នាទៅផ្ទះ ។

*ព្រះបច្ចេកពុទ្ធតបថា អ្នកទៅចុះ អាត្មាមិនមានកិច្ចដោយផ្ទះឡើយ អាត្មាជា* **ព្រះបច្ចេកពុទ្ធ** *ហើយ ។ បុរសនោះពោលថា ព្រះបច្ចេកពុទ្ធទាំងឡាយ មិនមានសភាពដូចអ្នកទេ ។*

*លំដាប់នោះ ព្រះបច្ចេកពុទ្ធសួរថា តើព្រះបច្ចេកពុទ្ធទាំងឡាយប្រាកដដូចម្ដេច ។ បុរសនោះ ឆ្លើយថា ព្រះបច្ចេកពុទ្ធទាំងឡាយ មានសក់ត្រឹមតែ ២ ធ្នាប់ ដណ្ដប់សំពត់ដែលជ្រលក់ដោយទឹកអម្ពត់ គង់នៅត្រង់ញកភ្នំនន្ទមូលកៈ ក្នុងហិមវន្តប្បទេស ទិសខាងជើង ។*

*ព្រះបច្ចេកពុទ្ធក៏ស្ទាបសីសៈ ក្នុងខណៈនោះឯង គិហិភេទរបស់លោក ក៏អន្តរធានទៅ ក្លាយជាបុគ្គលដែលស្លៀកសំពត់ពីរជាន់ ជ្រលក់ល្អហើយ ចងវត្ថពន្ធចង្កេះ ដូចផ្លេកបន្ទោរ មានចីវរមានពណ៌ដូចល័ក្តដណ្ដប់ឆៀងស្មាម្ខាង មានសំពត់បង្សុកូលពណ៌ដូចមេឃ ដាក់លើចង្កួយស្មាខាងស្ដាំ មានបាត្រដីពណ៌ដូចកមរជាតិ ពាក់ត្រង់ចង្កួយស្មាខាងឆ្វេង លោកស្ថិតនៅក្នុងអាកាស សម្ដែងធម៌ ហើយហោះទៅចុះត្រង់ញកភ្នំនន្ទមូលកៈ ។*

*សម័យនោះដែរ មានកុដុម្ពិកៈម្នាក់ ក្នុងកាសិកគ្រាមនោះ អង្គុយត្រង់ផ្សារ ឃើញបុរសម្នាក់នាំភរិយាដើរទៅ ទម្លាយឥន្ទ្រិយ សម្លឹងមើលរូបសម្រស់របស់ភរិយាគេនោះ ( តម្រេកកើតឡើង ) ក៏ពិចារណាថា លោភៈនេះ កាលចម្រើនឡើង នឹងបោះអញទៅក្នុងអបាយទាំងឡាយបាន មាន*

ចិត្តសង្វេគ ចម្រើនវិបស្សនា សម្រេចបច្ចេកពោធិញ្ញាណ ស្ថិតនៅក្នុងអាកាស សម្តែងធម៌ ហើយហោះទៅកាន់ញកភ្នំនន្ទមូលកៈដូចគ្នា ។

មានជន ២ នាក់ដទៃទៀត គឺបិតានិងបុត្ត ជាអ្នកកាសិកគ្រាមដូចគ្នា ធ្វើដំណើរទៅជាមួយគ្នា ពួកចោរនាំគ្នាស្កាត់ផ្លូវត្រង់មាត់ព្រៃ ពួកចោរទាំងនោះ បើចាប់បិតានិងបុត្តបាន ទុកបុត្ត ហើយលែងបិតាទៅ ដោយប្រាប់ថា ចូរទៅនាំទ្រព្យមកលោះកូនរបស់អ្នកចុះ ។ បើចាប់បងប្អូនពីរនាក់បាន ក៏ទុកប្អូន ហើយលែងបងទៅ បើចាប់អាចារ្យនិងអន្តេវាសិកបាន ទុកអាចារ្យ លែងអន្តេវាសិកទៅ ។ អន្តេវាសិកត្រូវតែនាំទ្រព្យមកដើម្បីលោះអាចារ្យ ព្រោះចង់បាននូវសិប្បៈ ។ លំដាប់នោះ ឪពុកនិងកូននោះ ដឹងថា ពួកចោរស្កាត់ត្រង់ទីនោះ ទើបធ្វើកតិកាគ្នាទុកថា ឯងកុំហៅអញថា ពុក សូម្បីអញ ក៏មិនហៅឯងថា កូន ។ ក្នុងកាលពួកចោរចាប់បាន ហើយសួរថា ឯងជាអ្វីនឹងគ្នា ក៏នាំគ្នានិយាយកុហកទាំងដឹងខ្លួនថា ខ្ញុំមិនមែនជាអ្វីនឹងគ្នាឡើយ ។ ជនទាំងពីរចេញផុតអំពីព្រៃឈរង្ងូតទឹកក្នុងពេលល្ងាច កូនប្រុសជម្រះសីលរបស់ខ្លួន ឃើញមុសាវាទនោះ គិតថា បាបនេះ កាលចម្រើនឡើង នឹងបោះអញទៅក្នុងអបាយទាំងឡាយ អញនឹងសង្កត់កិលេសនេះ ឲ្យបាន ដូច្នេះហើយ ចម្រើនវិបស្សនា ញ៉ាំងបច្ចេកពោធិញ្ញាណ ឲ្យកើតឡើងហើយ ស្ថិតនៅក្នុងអាកាស សម្តែងធម៌ដល់បិតា ហើយទៅកាន់ញកភ្នំនន្ទមូលកៈដូចគ្នា ។

មានបុរសម្នាក់ទៀត ជាមេស្រុកក្នុងកាសិកគ្រាមនោះឯង ហាមឃាត់ហើយ មិនឲ្យមនុស្សសម្លាប់សត្វ ។ គ្រានោះ ក្នុងកាលធ្វើពលិកម្មមហាជនប្រជុំគ្នា ហើយពោលនឹងគាត់ថា បពិត្រលោកម្ចាស់ ពួកយើងនឹងសម្លាប់ម្រឹគនិងជ្រូកជាដើម ធ្វើពលិកម្មដល់ពួកយក្ខ កាលនេះ ជាកាលនៃពលិកម្ម ។ មេស្រុកនោះក៏ពោលថា ពួកលោកចូរធ្វើតាមបែបដែលធ្លាប់ធ្វើមកក្នុងកាលមុននោះចុះ ។ ពួកមនុស្សបានធ្វើបាណាតិបាតសន្ធឹកសន្ធាប់ ។ គាត់ឃើញត្រីនិងសាច់ជាច្រើន មានវិប្បដិសារៈថា មនុស្សទាំងនេះ សម្លាប់សត្វមានប្រមាណប៉ុណ្ណេះ គឺសម្លាប់តាមពាក្យរបស់អញតែម្នាក់ប៉ុណ្ណោះ ហើយឈរផ្អែកបង្អួច ចម្រើនវិបស្សនា ធ្វើបច្ចេកពោធិញ្ញាណឲ្យកើតឡើងហើយ ស្ថិតនៅក្នុងអាកាស សម្តែងធម៌ដល់មហាជន ហើយហោះទៅកាន់ញកភ្នំនន្ទមូលកៈដូចគ្នា ។

មានបុរសដទៃម្នាក់ទៀត ជាមេស្រុកក្នុងកាសិករដ្ឋនោះ ដូចគ្នា ឃាត់នូវការលក់ដូរទឹកស្រវឹង ត្រូវមហាជនសួរថា បពិត្រលោកម្ចាស់ ក្នុងកាលមុន ពេលនេះ ជាពេលនក្ខត្តឫក្ស ដែលឈ្មោះថា សុរាឆណៈ ពួកខ្ញុំនឹងធ្វើអ្វី ទើបពោលថា ពួកលោក ចូរធ្វើតាមទំនៀមអំពីមុននោះចុះ ។ ពួកមនុស្សនាំគ្នាលេងនូវមហោស្រព ផឹកស្រាស្រវឹង ធ្វើនូវជម្លោះកាប់ចាក់គ្នា ដាច់ដៃជើង បែកក្បាល ដាច់ត្រចៀក ត្រូវចងដោយអាជ្ញាជាច្រើន ។ មេស្រុកឃើញជនទាំងនោះហើយ គិតថា កាលអញមិន

អនុញ្ញាត ជនទាំងនេះ ក៏មិនចួបនូវទុក្ខ បុរសនោះ ធ្វើនូវការក្តៅក្រហាយចិត្ត ដោយហេតុមានប្រមាណប៉ុណ្ណោះ ឈរផ្អែកបង្អួច ចម្រើនវិបស្សនា សម្រេចបច្ចេកពោធិញ្ញាណ ហើយស្ថិតនៅក្នុងអាកាស សម្តែងធម៌ថា ពួកអ្នក ចូរកុំប្រមាទ ហើយហោះទៅកាន់ញកភ្នំនន្ទមូលកៈដូចគ្នា ។

ចំណេរកាលតមក ព្រះបច្ចេកពុទ្ធទាំង ៥ អង្គនោះ នាំគ្នាហោះមក ចុះត្រង់ទ្វារនគរពារាណសីដើម្បីភិក្ខាចារ ស្លៀកដណ្តប់នូវសំពត់រៀបរយ ត្រាច់បិណ្ឌបាតដោយឥរិយាបថ មានការឈានទៅមុខជាដើម ដែលគួរជ្រះថ្លា រហូតដល់ទ្វារព្រះរាជវាំង ។ ព្រះរាជាទ្រង់ទតឃើញព្រះបច្ចេកពុទ្ធទាំងនោះ ទ្រង់មានចិត្តជ្រះថ្លា និមន្តឲ្យចូលកាន់ព្រះរាជនិវេសន៍ លាងជើង លាបដោយប្រេងក្រអូប អង្គាសដោយខាទនីយៈ និងភោជនីយៈដ៏ប្រណីត ហើយប្រថាប់គង់ក្នុងចំណែកម្ខាង ត្រាស់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើនទាំងឡាយ ការបំពេញបព្វជ្ជាក្នុងបឋមវ័យរបស់លោកម្ចាស់ទាំងឡាយ មើលទៅល្អពិត ការបំពេញបព្វជ្ជាក្នុងវ័យនេះ តើលោកម្ចាស់ទាំងឡាយ ឃើញទោសក្នុងកាមទាំងឡាយដូចម្តេច អ្វីជាអារម្មណ៍របស់លោកម្ចាស់ ។ ព្រះបច្ចេកពុទ្ធទាំងនោះ ក៏ពោលគាថា ( មួយអង្គ ១ គាថា ) ដូចតទៅនេះថា

**មិត្តោ មិត្តស្ស ចាជីយំ　　អជិន្នំ បរិកុញ្ជិសំ**
**តេន បច្ឆា វិជិកុច្ឆឹ　　តំ ចាបំ បកតំ មយា**

មា បុន អការំ ចាបំ តស្មា បព្វជិតោ អហំ ។

*អាត្មាភាពជាមិត្ត ( នៃមិត្តម្នាក់ទៀត ) បានប្រើប្រាស់ទឹកដែលមិត្តនោះ មិនឲ្យហើយ ហេតុនោះ អាត្មាភាពខ្ពើមរអើមក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។*

បរទារញ្ច ទិស្វាន ឆន្ទោ មេ ឧបបជ្ជថ
តេន បច្ឆា វិជិគុច្ឆឹ តំ ចាបំ បកតំ មយា
មា បុន អការំ ចាបំ តស្មា បព្វជិតោ អហំ ។

*សេចក្ដីប្រាថ្នា ( ក្នុងកាម ) កើតឡើងដល់អាត្មាភាព ព្រោះឃើញនូវប្រពន្ធរបស់បុគ្គលដទៃ ព្រោះហេតុនោះ អាត្មាភាពខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។*

បិតរំ មេ មហារាជ ចោរាអគ្គណ្ហុ កាននេ
តេសាហំ បុច្ឆិតោ ជានំ អញ្ញថា នំ វិយាការឹ
តេន បច្ឆា វិជិគុច្ឆឹ តំ ចាបំ បកតំ មយា
មា បុន អការំ ចាបំ តស្មា បព្វជិតោ អហំ ។

*បពិត្រមហារាជ ពួកចោរបានចាប់បិតារបស់អាត្មាភាព ក្នុងព្រៃ អាត្មាភាពដែលពួកចោរនោះសួរហើយ ទុកជាដឹង ក៏ប្រាប់ហេតុនោះ ដោយចំណែកដទៃវិញ ព្រោះហេតុនោះ អាត្មាភាពខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។*

ចាណាតិចាតមការុំ សោមយាគេ ឧបដ្ឋិតេ
តេសាហំ សមនុញ្ញាសឹ
តេន បច្ឆា វិជិគុច្ឆឹ តំ ចាបំ បកតំ មយា
មា បុន អករំ ចាបំ តស្មា បព្វជិតោ អហំ ។

*ការសែនព្រេន ឈ្មោះសោមយាគតាំងឡើងហើយ ពួកមនុស្សបានធ្វើបាណាតិបាត អាត្មាភាពក៏អនុញ្ញាតឲ្យពួកមនុស្សនោះ ព្រោះហេតុនោះ អាត្មាភាពខ្ពើមរអើមក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។*

សុរាមេរយមធុកា យេ ជនា បឋមាសុនោ
ពហុន្នំ តេ អនត្ថាយ មជ្ជចានមកប្បយុំ

តេសាហំ សមនុញ្ញាសឹ
តេន បច្ឆា វិជិគុច្ឆឹ តំ ចាបំ បកតំ មយា
មា បុន អការំ ចាបំ តស្មា បព្វជិតោ អហំ ។

*ពួកជនណា ( ក្នុងស្រុក ) របស់យើង ដែលសម្គាល់សុរានិងមេរ័យថា ដូចទឹកឃ្មុំ ជាជន ( មានសភាពយ៉ាងនេះ ) ជាដំបូង ពួកជននោះ បានចាត់ចែងទឹកស្រវឹង ដើម្បីសេចក្ដីវិនាសដល់ពួកជនច្រើន អាត្មាភាពបានអនុញ្ញាតឲ្យពួកជននោះ ព្រោះហេតុនោះ អាត្មាភាពខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។*

*ព្រះបច្ចេកពុទ្ធទាំងឡាយបានពោលគាថាទាំង ៥ នេះ ដោយលំដាប់ ។ ចំណែកព្រះរាជា ទ្រង់ស្ដាប់ព្យាករណ៍របស់ព្រះបច្ចេកពុទ្ធមួយអង្គ ៗ ហើយ ទ្រង់សរសើរថា* **ភន្តេ អយំ បព្វជ្ជា តុម្ហាកំយេវានុច្ឆវិកា** *បពិត្រលោកម្ចាស់ដ៏ចម្រើន បព្វជ្ជានេះ សមគួរដល់លោកម្ចាស់ទាំងឡាយ មែនពិត ។*

*ព្រះរាជា ទ្រង់ស្ដាប់ព្រះធម្មទេសនារបស់ព្រះបច្ចេកពុទ្ធទាំងនោះហើយ ទ្រង់មានចិត្តជ្រះថ្លា ប្រគេនសំពត់ចីវរនិងភេសជ្ជៈទាំងឡាយ ។*

កាលព្រះបច្ចេកពុទ្ធទាំងឡាយនោះ ធ្វើអនុមោទនាហើយ ទ្រង់បញ្ជូនព្រះបច្ចេកពុទ្ធទាំងនោះទៅ ព្រះបច្ចេកពុទ្ធទាំងឡាយក៏បាននិមន្តទៅកាន់ញកភ្នំនន្ទមូលកៈវិញ ។ តាំងអំពីនោះមក ព្រះរាជាទ្រង់នឿយណាយមិនត្រេកអរក្នុងវត្ថុកាមទាំងឡាយ ទ្រង់សោយព្រះក្រយាស្ងោយ មានរសដ៏ប្រសើរផ្សេង ៗ ក៏ទ្រង់មិនបានហៅ ( បុគ្គលណាមួយ ) ទ្រង់មិនបានទតពួកស្ត្រី ទ្រង់មានចិត្តនឿយណាយ យាងចូលបន្ទប់ដ៏មានសិរី គង់ធ្វើកសិណបរិកម្ម ត្រង់ជញ្ជាំងដែលមានពណ៌ស ទ្រង់ញុំាងឈានឲ្យកើតឡើងហើយ ។ ព្រះរាជាទ្រង់សម្រេចឈានហើយ កាលទ្រង់តិះដៀលកាមទាំងឡាយ ទើបត្រាស់ព្រះគាថាថា

> ធិរត្ថុ ពហុកាមេ ទុគ្គន្ធេ ពហុកណ្ដកេ
> យេ អហំ បដិសេវន្តោ នាលភឹ តាទិសំ សុខំ ។
>
> គួរឲ្យតិះដៀលកាមដ៏ច្រើន ដែលមានក្លិនអាក្រក់ មានសត្រូវច្រើន ព្រោះថា អាត្មាអញបានសេពហើយ ក៏មិនបានសេចក្ដីសុខ ( ក្នុងឈាន ) ប្រាកដដូច្នោះ ។

គ្រានោះ អគ្គមហេសីរបស់ទ្រង់ ព្រះតម្រិះថា ព្រះរាជាអង្គនេះស្ដាប់ព្រះធម្មកថារបស់ព្រះបច្ចេកពុទ្ធទាំងឡាយហើយ ទ្រង់មានអាកប្បកិរិយានឿយណាយ មិនបានត្រាស់ជាមួយពួកយើងឡើយ ទ្រង់យាងចូលបន្ទប់ដ៏មានសិរី អញនឹងចាំចាប់ទោសរបស់ទ្រង់ ដូច្នេះហើយ ក៏

យាងទៅកាន់បន្ទប់ដ៏មានសិរី ប្រថាប់ឈរត្រង់ទ្វារ ស្តាប់ឧទានគាថារបស់ព្រះរាជាដែលកំពុងតិះដៀលនូវកាមទាំងឡាយហើយ មានព្រះសវនីយ៍ថា **មហារាជ ត្វំ កាមេ គរហសិ កាមសុខសទិសំ ឆាម សុខំ នត្ថិ** បពិត្រមហារាជ ទ្រង់តិះដៀលនូវកាមទាំងឡាយ (ឬ) សេចក្តីសុខប្រាកដស្មើដោយកាមសុខ មិនមានទេ ។ កាលព្រះនាងពណ៌នាដល់សេចក្តីសុខក្នុងកាម ទើបពោលគាថាបន្តថា

**មហស្សាទា សុខា កាមា នត្ថិ កាមា បរំ សុខំ**
**យេ កាមេ បដិសេវន្តិ សគ្គន្តេ ឧបបជ្ជរេ ។**

កាមទាំងឡាយ មានសេចក្តីរីករាយច្រើន ជាសុខ សេចក្តីសុខក្រៅអំពីកាម មិនមានទេ ពួកជនណា បានសេពកាមទាំងឡាយ ពួកជននោះ តែងកើតក្នុងឋានសួគ៌ ។

ព្រះពោធិសត្វបានស្តាប់គាថានោះហើយ កាលទ្រង់តិះដៀលថា **នស្ស វសលិ** នៃស្រីថោកទាប ចូរវិនាសទៅ **កឹ កថេសិ** នាងពោលអ្វី **កាមេសុ សុខំ ឆាម កុតោ អត្ថិ** ឈ្មោះថា សេចក្តីសុខក្នុងកាមទាំងឡាយ មានមកអំពីណា **វិបរិណាមទុក្ខា** **ឯតេ** កាមទាំងនេះ ជាទុក្ខ ព្រោះមានសេចក្តីប្រែប្រួលទៅនោះឯង ទើបពោលគាថាដ៏សេសថា

**អប្បស្សាទា ទុខា កាមា នត្ថិ កាមា បរំ ទុក្ខំ**

យេ កាមេ បដិសេវន្តិ និរយន្តេ ឧបបជ្ជរេ ។

*កាមទាំងឡាយ មានសេចក្តីរីករាយតិច ជាទុក្ខ សេចក្តីទុក្ខក្រៅអំពីកាម មិនមានទេ ពួកជនណា សេពកាមទាំងឡាយ ពួកជននោះ តែងកើតក្នុងនរក ។*

អសិ យថា សុនិសិតោ នេត្តិសោវ សុបាយិកោ
សត្តីវ ឧរសី ខិត្តា កាមា ទុក្ខតរា តតោ ។

*កាមទាំងឡាយ មានសេចក្តីទុក្ខ លើសជាងដាវដែលសំលៀង ហើយ ជាងព្រះខ័នដែលលាបដោយថ្នាំពិស ទាំងជាងលំពែងដែលពួយត្រង់ទ្រូង ។*

អង្គារានំវ ជលិតំ កាសុំ សាធិកបោរិសំ
ផាលំវ ទិវសន្តត្តំ កាមា ទុក្ខតរា តតោ ។

*កាមទាំងឡាយ មានសេចក្តីទុក្ខ លើសជាងរងើកភ្លើងដ៏ច្រាលឆ្អៅ ជាងរណ្តៅរងើកភ្លើង មានជម្រៅមួយទទូង ឬអណ្តាតភ្លើងដែលក្តៅពេញមួយថ្ងៃ ។*

វិសំ យថា ហលាហលំ តេលំ បក្កុថិតំ យថា
តម្ពលោហំ វិលីនំវ កាមា ទុក្ខតរា តតោ ។

*កាមទាំងឡាយ មានសេចក្តីទុក្ខ លើសជាងថ្នាំពុលដ៏ក្លៀវក្លាឬប្រេងកំពុងពុះ ឬក៏ទង់ដែងរលាយ ។*

ព្រះមហាសត្វ ទ្រង់សម្តែងធម៌ដល់ព្រះទេវីយ៉ាងនេះហើយ ទ្រង់ឲ្យពួកអាមាត្យប្រជុំគ្នា ហើយត្រាស់ថា នែអាមាត្យដ៏ចម្រើនទាំងឡាយ ពួកអ្នក ចូរទទួលរាជសម្បត្តិចុះ ខ្ញុំនឹងបួស ទាំងដែលមហាជនកំពុងយំរៀបរាប់ទ្រហ៊ុះឯង ទ្រង់ក្រោកឡើង ហោះទៅប្រថាប់ឈរក្នុងអាកាសប្រទានឱវាទ ហើយទៅកាន់ព្រៃហិមពាន្ត នាទិសខាងជើងតាមអាកាសនោះឯង ។ ទ្រង់សាងអាស្រមក្នុងប្រទេសដែលគួរត្រេកអរ បួសជាឥសី ក្នុងទីបំផុតនៃព្រះជន្មាយុ បានទៅកាន់ព្រហ្មលោកហើយ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា កិលេសជារបស់តិចតួចមិនមានឡើយ ទោះបីមានប្រមាណតិច បណ្ឌិតទាំងឡាយ ក៏គួរសង្កត់សង្កិននោះឯង ដូច្នេះហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ហើយទ្រង់ប្រជុំជាតក ។ ក្នុងកាលចប់សច្ចៈ ភិក្ខុ ៥០០ រូប តាំងនៅក្នុងអរហត្តផល ។ ព្រះបច្ចេកពុទ្ធទាំងឡាយក្នុងកាលនោះ បរិនិព្វានហើយ ព្រះទេវី បានមកជារាហុលមាតា ឯព្រះបាទពារាណសី គឺតថាគតនេះឯង ។

**បានីយជាតក ចប់** [១]

---

១-ស្រង់ចាកអដ្ឋកថា ជាតក ឯកាទសកនិបាត បិ.៥៩ ទំ.២២៤ ឃ.៨៤០ ។

# គោលបត្តជាតក

ព្រះសាស្តា កាលគង់នៅក្នុងដងព្រៃមួយកន្លែង អាស្រ័យនិគមឈ្មោះសេទកៈ ក្នុងសុម្ភរដ្ឋ ទ្រង់ប្រារព្ធជនបទកល្យាណីសូត្រ ទើបត្រាស់ព្រះធម្មទេសនានេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតជាឱរសចុងក្រោយ បណ្ដាឱរស ១០០ អង្គរបស់ព្រះរាជាអង្គនោះ ដល់នូវភាពជាអ្នកដឹងក្ដីដោយលំដាប់ ។ ក្នុងកាលនោះ **ព្រះបច្ចេកពុទ្ធ** ច្រើនអង្គឆាន់ក្នុងព្រះរាជវាំង ព្រះពោធិសត្វធ្វើនាទីជាវេយ្យាវច្ចកររបស់ព្រះបច្ចេកពុទ្ធទាំងនោះ ។ ថ្ងៃមួយ ទ្រង់ព្រះតម្រិះថា បងប្រុសរបស់អញមានច្រើន អញនឹងបានរាជសម្បត្តិបន្តវង្សក្នុងនគរនេះឬហ្ន៎ លំដាប់នោះ ទ្រង់មានបរិវិតក្កៈថា ត្រូវសួរព្រះបច្ចេក-ពុទ្ធ ទើបដឹង ។ ក្នុងថ្ងៃ ទី ២ កាលព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តមកហើយ ទ្រង់កាន់យកធម្មក្រកត្រងទឹកសម្រាប់ឆាន់ លាងជើង លាបប្រេង ក្នុងកាលដែលព្រះបច្ចេកពុទ្ធទាំងនោះ ឆាន់របស់គួរទំពាក្នុងវេលាចន្លោះកាល ទើបថ្វាយបង្គំ ហើយប្រថាប់គង់នាចំណែកម្ខាង ត្រាស់សួរសេចក្ដីនោះ ។

លំដាប់នោះ ព្រះបច្ចេកពុទ្ធទាំងនោះ ប្រាប់ថា នែកុមារ ទ្រង់មិន

បានសោយរាជសម្បត្តិក្នុងនគរនេះទេ តែបន្ទាប់អំពីនគរនេះទៅ ក្នុងទីបំផុត ១២០ យោជន៍ ក្នុងគន្ធាររដ្ឋ មាននគរឈ្មោះថា តក្កសិលា ទ្រង់ទៅក្នុងនគរនោះ នឹងបានរាជសម្បត្តិក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃនេះ តែក្នុងចន្លោះផ្លូវ ក្នុងព្រៃធំ មានអន្តរាយ កាលបើទៅវាងព្រៃនោះ នឹងមានចម្ងាយដល់ទៅ ១២០ យោជន៍ បើទៅផ្លូវត្រង់ ត្រឹមតែ ៥០ យោជន៍ ផ្លូវនោះ ឈ្មោះថា អមនុស្សកន្តារ ។ ពួកយក្ខិនីនាំគ្នានិម្មិតស្រុកនិងសាលាក្នុងចន្លោះផ្លូវ រៀបចំទីដេកដ៏មានតម្លៃ ខាងលើ ( មាន ) ពិតានលម្អដោយផ្កាយមាស បាំងរាំងននដែលជ្រលក់ដោយពណ៌ផ្សេង ៗ តាក់តែងអត្តភាពដោយអលង្ការដែលជាទិព្វ នាំគ្នាអង្គុយក្នុងសាលាទាំងឡាយ ទាក់យកពួកបុរសអ្នកដើរផ្លូវ ដោយពាក្យសម្ដីផ្អែមល្ហែម នាំគ្នាអញ្ជើញថា ពួកលោកទាំងឡាយ ប្រាកដដូចមនុស្សហត់នឿយ សូមមកអង្គុយក្នុងសាលានេះ ផឹកនូវរបស់ដែលគួរផឹក ហើយសឹមទៅចុះ ឲ្យទីអង្គុយដល់ជនដែលមកដល់ហើយ នាំគ្នាលួងលោមដោយអាកប្បកិរិយាម៉ិកម៉ក់របស់ខ្លួន ធ្វើឲ្យធ្លាក់នៅក្នុងអំណាចកិលេស ។ កាលបានធ្វើអជ្ឈាចារជាមួយនឹងខ្លួនហើយ ទំពាស៊ីជនទាំងនោះ ទាំងដែលឈាមកំពុងហូរ ឲ្យដល់នូវការអស់ជីវិតក្នុងទីនោះឯង ។ យក្ខិនីចាំចាប់សត្វដែលមានរូបជាអារម្មណ៍ ដោយរូបសម្រស់របស់ខ្លួននោះឯង អ្នកដែលមានសំឡេងជាអារម្មណ៍ ដោយសំឡេងច្រៀងលួងលោមដ៏ផ្អែមល្ហែម

អ្នកដែលមានក្លិនជាអារម្មណ៍ ដោយក្លិនទិព្វ អ្នកដែលមានរសជាអារម្មណ៍ ដោយភោជនដែលមានរសដ៏ប្រសើរផ្សេងៗ ដូចរសទិព្វ អ្នកដែលមានផោដ្ឋព្វៈជាអារម្មណ៍ ដោយទីដេកដូចជាទិព្វ មានកម្រាលមានពណ៌ក្រហមទាំងសងខាង បើព្រះអង្គមិនទម្លាយឥន្ទ្រិយ មិនសម្លឹងមើលនូវយក្ខិនីទាំងនោះ គ្រប់គ្រងសតិបាន យាងទៅ នឹងបានរាជសម្បត្តិក្នុងនគរនោះ ក្នុងថ្ងៃទី ៧ ។

ព្រះពោធិសត្វត្រាស់ថា បពិត្រលោកម្ចាស់ រឿងនេះ សូមស្ទេះទុកសិន ខ្ញុំទទួលឱវាទរបស់លោកម្ចាស់ទាំងឡាយហើយ នឹងសម្លឹងមើលពួកយក្ខិនីទាំងនោះ ដូចម្ដេចកើត ហើយនិមន្តព្រះបច្ចេកពុទ្ធទាំងឡាយឲ្យចម្រើនព្រះបរិត្ត ទទួលខ្សាច់ព្រះបរិត្តនិងអំបោះព្រះបរិត្ត ថ្វាយបង្គំលាព្រះបច្ចេកពុទ្ធ និងព្រះរាជមាតាបិតា យាងទៅកាន់ព្រះរាជដំណាក់ត្រាស់នឹងមនុស្សរបស់ព្រះអង្គថា ខ្ញុំនឹងទៅគ្រប់គ្រងរាជសម្បត្តិក្នុងនគរតក្កសិលា ពួកអ្នកចូរនៅក្នុងទីនេះចុះ ។ គ្រានោះ មនុស្ស ៥ នាក់ក្រាបទូលព្រះពោធិសត្វថា សូម្បីពួកទូលព្រះបង្គំ ក៏នឹងតាមទ្រង់ទៅ ។

ព្រះពោធិសត្វត្រាស់ថា ពួកអ្នកមិនអាចទៅតាមខ្ញុំបានទេ បានឮថា ក្នុងចន្លោះផ្លូវ មានពួកយក្ខិនីឃ្វាំលួងលោមពួកមនុស្ស ដែលមានរូបជាដើមជាអារម្មណ៍ ដោយកាមារម្មណ៍ មានរូបជាដើមច្រើនយ៉ាងច្រើនបែប ហើយចាប់ស៊ីជាអាហារ អន្តរាយធំក្រៃលែង ខ្ញុំត្រៀមខ្លួន

ហើយ ទើបទៅ ។

រាជបុរសក្រាបទូលថា បពិត្រព្រះទេវៈ កាលពួកទូលព្រះបង្គំទៅជាមួយព្រះអង្គ នឹងសម្លឹងមើលរូបជាទីស្រឡាញ់ជាដើម ដើម្បីខ្លួនដូចម្ដេចកើត ពួកទូលព្រះបង្គំនឹងទៅក្នុងទីនោះ បានដូចគ្នា ។

ព្រះពោធិសត្វត្រាស់ថា បើដូច្នោះ ពួកអ្នក ចូរជាអ្នកមិនប្រមាទចុះ ហើយនាំពួកមនុស្សទាំង ៥ នាក់នោះ ចេញទៅ ។

ពួកយក្ខិនីនាំគ្នានិម្មិតស្រុកជាដើម អង្គុយរង់ចាំហើយ ។ បណ្ដាជនទាំងនោះ អ្នកដែលពេញចិត្តក្នុងរូប សម្លឹងមើលយក្ខិនីនោះហើយមានចិត្តជាប់ចំពាក់ក្នុងរូបារម្មណ៍ ក៏មានចិត្តរារែកបន្តិច ។ កាលព្រះពោធិសត្វត្រាស់ថា នៃអ្នកដ៏ចម្រើន ហេតុអ្វីទើបអ្នករារែក ទើបក្រាបទូលថា បពិត្រព្រះទេវៈ ជើងរបស់ទូលព្រះបង្គំឈឺចាប់ ទូលព្រះបង្គំអង្គុយសម្រាកក្នុងសាលាបន្តិច ហើយនឹងទៅតាមព្រះអង្គ ។

ព្រះពោធិសត្វត្រាស់ថា នៃអ្នកដ៏ចម្រើន នុ៎ះជាពួកយក្ខិនី អ្នកកុំប្រាថ្នាឡើយ ។ បុរសនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ទោះជាអ្វីក៏ដោយ ទូលព្រះបង្គំមិនអាចទៅទៀតបានទេ ។

ព្រះពោធិសត្វត្រាស់ថា បើដូច្នោះ អ្នកនឹងប្រាកដ ( ដោយខ្លួនឯង ) ហើយនាំបុរស ៤ នាក់ ចេញដំណើរទៅ ។ អ្នកដែលគាប់ចិត្តក្នុងរូបបាននៅក្នុងសម្នាក់យក្ខិនី ។ យក្ខិនីទាំងនោះ កាលបុរសនោះ បានធ្វើ

អជ្ឈាចារជាមួយខ្លួនហើយ ក៏ធ្វើឲ្យអស់ជីវិតក្នុងទីនោះឯង ហើយទៅស្កាត់ខាងមុខ និម្មិតសាលាជទៃ អង្គុយលេងតន្ត្រី ច្រៀងនូវចម្រៀងផ្សេង ៗ ។ បណ្ដាមនុស្សទាំងនោះ បុរសដែលគាប់ចិត្តក្នុងសំឡេង ក៏រារែក ត្រូវពួកយក្ខិនីទំពាស៊ីដូចគ្នា ដោយន័យមុននោះឯង ។ យក្ខិនីទាំងនោះ លុះទំពាស៊ីរួចហើយ ក៏ទៅស្កាត់ខាងមុខ ដាក់គ្រឿងក្រអូបមានប្រការផ្សេង ៗ ពេញក្នុងប្រអប់ ហើយបានអង្គុយបើកប្រអប់ដាក់លើរោងតូចមួយ ។ បុរសដែលគាប់ចិត្តក្នុងក្លិន ក៏រារែក ត្រូវពួកយក្ខិនីទំពាស៊ីដូចគ្នា ។ នាងយក្ខិនីទាំងនោះ លុះទំពាស៊ីរួចហើយ ក៏ទៅស្កាត់ខាងមុខ រៀបចំភោជនដូចជាទិព្វ ដែលមានរសប្រសើរផ្សេង ៗ ពេញភាជនៈ អង្គុយលក់បាយនិងម្ហូប ។ កាលទៅដល់ទីនោះ ជនដែលជាប់ចិត្តក្នុងរស ក៏រារែក ពួកយក្ខិនីក៏ទំពាស៊ីជននោះ ហើយទៅស្កាត់ខាងមុខ រៀបចំទីដេកដូចជាទិព្វ អង្គុយរង់ចាំហើយ ។ លុះទៅដល់ទីនោះ បុរសដែលគាប់ចិត្តក្នុងផោដ្ឋព្វៈ ក៏រារែក ត្រូវពួកយក្ខិនីទំពាស៊ីទៀត សល់ព្រះពោធិសត្វតែមួយអង្គឯងប៉ុណ្ណោះ ។

លំដាប់នោះ យក្ខិនី ១ រូប គិតថា បុរសនេះ មានមន្តពូកែខ្លាំងណាស់ អញនឹងស៊ីឲ្យបាន សឹមត្រឡប់វិញ ហើយដើរតាមក្រោយ ៗ ព្រះពោធិសត្វ ។ ក្នុងទីមាត់ព្រៃនោះ ពួកជនដែលធ្វើការក្នុងព្រៃជាដើម ក៏សួរយក្ខិនីថា បុរសដែលដើរខាងមុខ ជាអ្វីនឹងនាង ។

យក្ខិនីនោះ ឆ្លើយថា ជាប្តីរបស់ខ្ញុំ នាយ ។

មនុស្សទាំងនោះពោលថា នៃអ្នកដ៏ចម្រើន កុមារិកានេះ ទន់ភ្លន់ដូចកម្រងផ្កា មានពណ៌សម្បុរល្អដូចមាស លះបង់ត្រកូលរបស់ខ្លួនចេញមក ព្រោះស្រឡាញ់ ទើបដើរតាមមក ហេតុអ្វីទើបឲ្យនាងលំបាក មិនដឹកដៃនាងដើរទៅ ។

ព្រះពោធិសត្វត្រាស់តបថា លោកទាំងឡាយ នាងនុ៎ះមិនមែនជាភរិយារបស់ខ្ញុំទេ នាងនុ៎ះជាយក្ខិនី មនុស្សរបស់ខ្ញុំ ៥ នាក់ ត្រូវយក្ខិនីនេះ ស៊ីអស់ហើយ ។

យក្ខិនីពោលថា បពិត្រលោកទាំងឡាយ ធម្មតាបុរស ក្នុងពេលក្រោធ ធ្វើភរិយារបស់ខ្លួនឲ្យជាយក្ខិនីក៏បាន ឲ្យជាប្រេតក៏បាន ។ យក្ខិនីដើរតាមមក កាឡាខ្លួនជាស្រីមានគភ៌ ជាស្រីកើតកូនម្តង បីកូនដើរតាមព្រះពោធិសត្វទៅ មនុស្សដែលឃើញហើយ ក៏នាំគ្នាសួរដោយន័យមុននោះឯង ។ ចំណែកព្រះពោធិសត្វក៏នៅតែត្រាស់យ៉ាងនោះថា នាងនុ៎ះជាយក្ខិនី ។ លុះមកដល់នគរតក្កសិលា យក្ខិនីធ្វើកូនឲ្យអន្តរធានទៅដើរតាមព្រះពោធិសត្វតែម្នាក់ឯង ។ ព្រះពោធិសត្វយាងដល់ទ្វារនគរហើយ ប្រថាប់គង់ក្នុងសាលាមួយកន្លែង យក្ខិនីនោះ មិនអាចចូលទៅបានដោយតេជះរបស់ព្រះពោធិសត្វ ក៏និម្មិតរូបស្អាតដូចទេពអប្សរ ឈរត្រង់ទ្វារសាលា ។

ក្នុងសម័យនោះ ព្រះរាជាតក្កសិលាយាងទៅកាន់ព្រះរាជឧទ្យាន ឃើញនាងហើយ មានចិត្តប្រតិព័ទ្ធ បញ្ជូនរាជបុរសទៅថា ចូរអ្នកទៅចូរដឹងថា ស្រីនេះ មានប្តី ឬមិនមាន ។ ពួករាជបុរសចូលទៅរកយក្ខិនីសួរថា នាងមានប្តីហើយឬ ។

នាងឆ្លើយថា បុរសដែលអង្គុយក្នុងសាលាជាប្តីរបស់ខ្ញុំ ។

ព្រះពោធិសត្វត្រាស់ថា នាងមិនមែនជាប្រពន្ធរបស់ខ្ញុំទេ នាងជាយក្ខិនី មនុស្សរបស់ខ្ញុំ ៥ នាក់ ត្រូវយក្ខិនីនេះ ស៊ីអស់ហើយ ។ យក្ខិនីពោលថា បពិត្រលោកទាំងឡាយ ធម្មតាបុរសក្នុងពេលខឹង ក៏នឹងពោលតាមគាប់ចិត្តរបស់ខ្លួន ។ រាជបុរសក៏ក្រាបទូលពាក្យរបស់ជនទាំងពីរដល់ព្រះរាជា ។ ព្រះរាជាត្រាស់ថា ធម្មតាកណ្ឌៈមិនមានម្ចាស់ រមែងជារបស់ព្រះរាជា ហើយត្រាស់ឲ្យហៅយក្ខិនីមក ឲ្យអង្គុយលើខ្នងដំរីជាមួយទ្រង់ ធ្វើប្រទក្សិណនគរហើយ ឡើងកាន់ប្រាសាទ ទ្រង់ស្ថាបនាយក្ខិនីនោះ ទុកក្នុងតំណែងអគ្គមហេសី ។

ព្រះរាជាទ្រង់ស្រពស្រង់ តែងព្រះកាយរៀបរយ សោយព្រះក្រយាស្ងោយក្នុងពេលល្ងាចហើយ យាងឡើងកាន់ព្រះទែនដ៏មានសិរី យក្ខិនីនោះ បរិភោគអាហារដែលគួរដល់ខ្លួនហើយ តាក់តែងខ្លួនប្រាណផ្ទំរួមជាមួយព្រះរាជាលើព្រះទែនដ៏មានសិរី កាលព្រះរាជាទ្រង់ស្កប់ស្កល់ទៅដោយសេចក្តីសុខ ដោយអំណាចសេចក្តីត្រេកអរ ទ្រង់ផ្ទំហើយ ក៏

ប្រែទៅម្ខាង ធ្វើជាយំ ។ លំដាប់នោះ ព្រះរាជាត្រាស់សួរថា នែនាងដ៏ចម្រើន ហេតុអ្វី ទើបនាងយំ ។

យក្ខិនីក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់ ទ្រង់ចួបតាមផ្លូវហើយនាំមក ម្យ៉ាងទៀត ក្នុងព្រះរាជវាំងរបស់ព្រះអង្គ មានស្រីជាច្រើន ខ្ញុំម្ចាស់បើនៅក្នុងក្រុមស្រីដែលរួមប្ដី កាលកើតពាក្យពោលឡើងថា អ្នកណាស្គាល់មាតាបិតា គោត្តឬជាតិរបស់នាង នាង ព្រះរាជាចួបក្នុងរវាងផ្លូវ ហើយទ្រង់នាំមកដូច្នេះ ខ្ញុំម្ចាស់ដូចត្រូវពួកគេចាប់ត្រង់ក្បាលបៀតបៀន នឹងខ្មាសគេពិត បើទ្រង់ព្រះរាជទានភាពជាធំ និងឲ្យនូវអាជ្ញាក្នុងដែនទាំងមូលដល់ខ្ញុំម្ចាស់ បុគ្គលណាម្នាក់ ក៏មិនអាចមានចិត្តកម្រើក ហ៊ានពោលដល់ខ្ញុំម្ចាស់ឡើយ ។

ព្រះរាជាទ្រង់ត្រាស់ថា នែនាងដ៏ចម្រើន អ្នកដែនទាំងមូល មិនមែនជាសម្បត្តិរបស់ខ្ញុំឡើយ ខ្ញុំមិនមែនជាម្ចាស់របស់ជនទាំងនោះ តែជនណាល្មើសព្រះរាជអាជ្ញា ធ្វើនូវវត្ថុដែលមិនគួរធ្វើ ខ្ញុំជាម្ចាស់របស់អ្នកទាំងនោះ ប៉ុណ្ណោះ ។ ដោយហេតុនេះ ទើបខ្ញុំមិនអាចឲ្យភាពជាធំនិងអាជ្ញាក្នុងដែនទាំងមូលដល់នាងបាន ។

យក្ខិនីក្រាបទូលថា បើទ្រង់មិនអាចព្រះរាជទានអាជ្ញាក្នុងដែនទាំងមូល ឬក្នុងនគរ ក៏សូមទ្រង់ព្រះរាជទានអំណាចលើពួកជនខាងក្នុងព្រះរាជវាំង ដើម្បីឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្ញុំម្ចាស់ចុះ ។

ព្រះរាជាទ្រង់ជាប់ព្រះហឫទ័យក្នុងផោដ្ឋព្វៈ ដែលជាទិព្វហើយ មិនអាចបដិសេធពាក្យរបស់នាងបាន ទើបត្រាស់ថា នែនាងដ៏ចម្រើន យើងយល់ព្រម យើងប្រគល់អាជ្ញាក្នុងពួកជនខាងក្នុងដល់នាង ចូរនាងគ្រប់គ្រងជនទាំងនោះ ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនចុះ ។ យក្ខិនីទទួលថា សាធុ ។ លុះព្រះរាជាផ្ទំលក់ស៊ប់សួន ក៏ទៅកាន់នគរយក្ខ នាំពួកយក្ខមក ញុំាងព្រះរាជារបស់ខ្លួនឲ្យអស់ជីវិត ទំពាស៊ីស្បែក សាច់ ឈាមនិងសរសៃ រហូតអស់ សល់ត្រឹមតែឆ្អឹង ពួកយក្ខដ៏សេស នាំគ្នាស៊ីមនុស្សនិងសត្វ ចាប់តាំងអំពីមាន់និងឆ្កែជាដើម ដែលនៅខាងក្នុងព្រះរាជនិវេសន៍ តាំងអំពីទ្វារធំរហូតអស់ សល់តែរាងឆ្អឹង ។

លុះព្រឹកឡើង មនុស្សទាំងឡាយឃើញទ្វារព្រះរាជវាំងនៅបិទនោះឯង នាំគ្នាពុះទ្វារដោយប៉ូវថៅ ហើយនាំគ្នាចូលទៅខាងក្នុង ឃើញព្រះរាជនិវេសន៍គ្រប់កន្លែង ដេរដាសដោយគ្រោងឆ្អឹង ទើបនិយាយថា បុរសនោះ ពោលថា ស្រីនុ៎ះ មិនមែនជាប្រពន្ធរបស់ខ្ញុំ ជាយក្ខិនី ជាពាក្យពិតហ្ន៎ តែព្រះរាជាទ្រង់មិនជ្រាប ទ្រង់នាំនាងមក តែងតាំងជាមហេសី យក្ខិនីនោះ ក៏បបួលពួកយក្ខមកស៊ីមនុស្សទាំងឡាយអស់ រួចហើយទៅ ដោយពិត ឥតសង្ស័យឡើយ ។

ក្នុងថ្ងៃនោះ ព្រះពោធិសត្វទ្រង់ដាក់ខ្សាច់ព្រះបរិត្តលើសីសៈ រុំដោយអំបោះព្រះបរិត្ត ទ្រង់កាន់ដាវប្រថាប់ឈរក្នុងសាលានោះ រហូត

ដល់ថ្ងៃរះ ។ ពួកមនុស្សនាំគ្នាសម្អាតព្រះរាជនិវេសន៍ លាបដោយពណ៌ខៀវ ប្រោះព្រំដោយគ្រឿងក្រអូប រោយដោយផ្កា ចងនូវកម្រងផ្កា អប់ដោយផ្សែងក្រអូប ចងកម្រងផ្កាជាថ្មី ហើយប្រឹក្សាគ្នាថា អ្នកដ៏ចម្រើនទាំងឡាយ ( កាលពីម្សិលមិញ ) បុរសនោះ មិនបានធ្វើ ត្រឹមតែការទម្វាយឥន្ទ្រិយ សម្លឹងមើលយក្ខិនីដែលកាឡាខ្លួនដូចជារូបទិព្វ ដើរមកតាមក្រោយឡើយ បុរសនោះ ជាសត្វប្រសើរក្រៃពេក ជាអ្នកមានវីរិយៈសម្បូរដោយញាណ បើបុរសនោះ គ្រប់គ្រងរាជ្យ ប្រៀនប្រដៅរឿយ ៗ ដែនទាំងអស់នឹងមានតែសេចក្តីសុខ ពួកយើងគួរធ្វើបុរសនោះ ឲ្យជាព្រះរាជាចុះ ។

លំដាប់នោះ ពួកអាមាត្យនិងអ្នកនគរទាំងឡាយ រួមគ្នាជាឯកច្ឆន្ទចូលទៅគាល់ព្រះពោធិសត្វ ក្រាបទូលថា បពិត្រព្រះទេវៈ សូមទ្រង់សោយរាជ្យចុះ យាងព្រះពោធិសត្វចូលក្នុងនគរហើយ យាងឲ្យឡើងប្រថាប់លើគំនររតនៈ អភិសេកធ្វើឲ្យជាព្រះរាជានៃតក្កសិលានគរ ។ ព្រះរាជាទ្រង់វៀរនូវការលុះក្នុងអគតិ ៤ មិនឲ្យទសពិធរាជធម៌កម្រើកសោយរាជសម្បត្តិដោយធម៌ ទ្រង់បំពេញកុសល មានឲ្យទានជាដើម ហើយទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់ត្រាស់ដឹងក្រៃលែងហើយ កាលទ្រង់នាំយករឿងក្នុងអតីតមកសាធកៈ ទើបត្រាស់ព្រះគាថានេះថា

**សមតិត្តិកំ អនវសេកំ**

**តេលបត្តំ យថា បរិហរេយ្យ**

**ឯវំ សចិត្តមនុរក្ខេ (សតិយា)**

**បត្ថយានោ ទិសំ អគតបុព្វំ ។**

*បុគ្គល គប្បីនាំទៅនូវភាជន៍ប្រេង ដែលពេញត្រឹម*

*កណ្ដាប់មាត់ មិនឲ្យស្រក់ទៅបាន យ៉ាងណាមិញ*

*(ព្រះយោគាវចរ) កាលប្រាថ្នានូវទិសដែលខ្លួន*

*មិនធ្លាប់ទៅ គឺព្រះនិព្វាន គប្បីរក្សានូវចិត្តរបស់ខ្លួន*

*(ដោយសតិ) យ៉ាងនោះដែរ ។*

*ព្រះសាស្ដា ទ្រង់កាន់យកកំពូលនៃទេសនា ដោយព្រះនិព្វាន ដោយប្រការដូច្នេះហើយ ទ្រង់ប្រជុំជាតកថា រាជបរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកព្រះរាជកុមារដែលគ្រង់រាជសម្បត្តិក្នុងកាលនោះ គឺតថាគតនេះឯង ។*

**តេលបត្តជាតក ចប់** [១]

*១-ស្រង់ចាកអដ្ឋកថា ជាតក ឯកនិបាត បិ.៥៨ ទំ.៤៣ ឃ.៩៦ ។*

# មហាមោរជាតក

ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុក មួយរូប ទើបត្រាស់ព្រះធម្មទេសនានេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរ ពារាណសី ព្រះពោធិសត្វកើតក្នុងផ្ទៃមេក្ងោក ក្នុងបច្ចន្តប្រទេស ។ កាលគភ៌ចាស់ហើយ ក្ងោកជាមាតាក៏ពងក្នុងទីរកស៊ី ហើយហើរទៅ ។ ធម្មតាស៊ុត បើមេមិនមានរោគ និងមិនមានអន្តរាយដទៃ ៗ មានទីយជាតិ (ពស់) ជាដើម បៀតបៀន រមែងមិនខូចឡើយ ហេតុនោះ ទើបស៊ុត នោះ ដូចផ្កាកណិការក្រពុំ មានពណ៌មាស លុះដល់គ្រប់កំណត់ ក៏ញាស់ តាមធម្មតារបស់ខ្លួន កូនក្ងោកមានពណ៌មាសចេញមកហើយ ។ កូន ក្ងោកនោះ មានភ្នែកទាំងគូដូចគ្នានឹងផ្លែជិញ្ចុកៈ (ផ្លែទំពាំងបាយជូរ) មានចំពុះដូចកែវប្រពាល មានផ្នួតកពណ៌ក្រហម ៣ ជាន់ និងឆ្នូតរហូត ដល់កណ្តាលខ្នង កាលក្ងោកមាសចម្រើនវ័យហើយ មានរាងកាយធំ ប៉ុនដុំរទេះ មានរូបល្អក្រៃពេក ។ ក្ងោកដែលមានពណ៌ខៀវទាំងអស់ មកប្រជុំគ្នា លើកក្ងោកនោះឲ្យជាព្រះរាជា នាំគ្នាចោមរោមជាបរិវារ ។

ថ្ងៃមួយ ក្ងោកមាសផឹកទឹកក្នុងត្រពាំង ឃើញរូបសម្បត្តិរបស់ខ្លួន គិតថា អញមានរូបស្អាតក្រៃលែងជាងក្ងោកទាំងអស់ បើអញនៅក្នុង ដែនដីមនុស្សជាមួយក្ងោកទាំងនេះ អន្តរាយនឹងកើតដល់អញ អញត្រូវ

ទៅកាន់ព្រៃហិមពាន្ត ដែលជាទីសុខសាន្ត នៅតែម្នាក់ឯងប្រសើរជាង ។ កាលហ្វូងក្ងោកនាំគ្នាចូលទ្រនំដេក ក្ងោកមាសនោះ មិនបានប្រាប់ក្ងោកណាមួយឲ្យដឹងឡើយ ហើរទៅកាន់ព្រៃហិមពាន្ត ឆ្លងជួរភ្នំ ៣ ដល់ជួរភ្នំទី ៤ មានជាតស្រះធំ ដេរដាសដោយផ្កាឈូក ក្នុងព្រៃមិនឆ្ងាយអំពីស្រះនោះ មានដើមជ្រៃធំកើតអាស្រ័យភ្នំមួយ ក៏ចុះសម្រាកកាយត្រង់មែកជ្រៃនោះ ។ម្យ៉ាងទៀត ត្រង់កណ្ដាលភ្នំនោះ មានគុហាដែលគួរជាទីត្រេកអរ ។ ស្ដេចក្ងោកបំណងនៅក្នុងគុហានោះ ទើបទំត្រង់មុខគុហានោះ ។ ក្នុងទីនោះ បុគ្គលដែលនៅខាងក្រោមមិនអាចឡើងទៅបានឡើយ បុគ្គលដែលនៅខាងលើសោត ក៏មិនអាចចុះបាន ជាទីផុតភ័យអំពីឆ្មា ពស់ និងមនុស្សទាំងឡាយ ។ ស្ដេចក្ងោកមាសត្រិះរិះថា ត្រង់នេះ ជាទីផាសុករបស់អញ ហើយសម្រាកនៅក្នុងទីនោះឯង អស់ថ្ងៃនោះ ។ លុះព្រឹកឡើង ក្រោកចាកគុហា ទំត្រង់កំពូលភ្នំ បែរមុខទៅកាន់ទិសខាងកើត ឃើញសុរិយមណ្ឌលកំពុងរះឡើង ក៏សូត្រព្រះបរិត្តដើម្បីការពារខ្លួនក្នុងពេលថ្ងៃថា

ឧទេតយញ្ចក្ខុមា ឯករាជា
ហរិស្សវណ្ណោ បឋវិប្បភាសោ
តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ
តយជ្ជ គុត្តា វិហរេមុ ទិវសំ ។

យេ ព្រាហ្មណា វេទគុ សព្វធម្មេ
តេ មេ នមោ តេ ច មំ បាលយន្តុ
នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា
នមោ វិមុត្តានំ នមោ វិមុត្តិយា
ឥមំ សោ បរិត្តំ កត្វា មោរោ ចរតិ ឯសនា ។

*សុរិយទេវបុត្តណា ជាឯករាជ មានចក្ខុ មានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី កំពុងរះឡើង ខ្ញុំសូមនមស្ការនូវសុរិយទេវបុត្តនោះ អ្នកមានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សាអស់វេលាថ្ងៃក្នុងថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយណា សម្រេចនូវវេទក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងឡាយនោះ ទទួលនូវការនមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងឡាយនោះ រក្សានូវខ្ញុំ ការនមស្ការ ចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការនមស្ការ ចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការ ចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការ ចូរមានដល់វិមុត្តិ ក្ងោកពោធិសត្វនោះ ធ្វើបរិត្តនេះរួចហើយ ទើបត្រាច់ទៅស្វែងរកអាហារ*[១] ។

---

*១-បិ.៥៨ ទំ.៧៣ ឃ.១៦៧ ។*

លុះដល់ពេលល្ងាច ទើបក្ងោកនោះ មកទំត្រង់កំពូលភ្នំ បែរមុខទៅកាន់ទិសខាងលិច សម្លឹងមើលសុរិយមណ្ឌលដែលអស្តង្គត សូត្រព្រះបរិត្តដើម្បីការពារខ្លួន ក្នុងពេលយប់ថា

អបេតយញ្ចក្ខុមា ឯករាជា
ហរិស្សវណ្ណោ បឋវិប្បភាសោ
តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ
តយជ្ជ គុត្តា វិហរេមុ រត្តឹ
យេ ព្រាហ្មណា វេទគុ សព្វធម្មេ
តេ មេ នមោ តេ ច មំ បាលយន្តុ
នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា
នមោ វិមុត្តានំ នមោ វិមុត្តិយា
ឥមំ សោ បរិត្តំ កត្វា មោរោ វាសមកប្បយិ ។

( សុរិយទេវបុត្តណា ) ជាឯករាជ មានចក្ខុ មានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី កំពុងអស្តង្គតទៅ ខ្ញុំសូមនមស្ការ នូវសុរិយទេវបុត្តនោះ អ្នកមានសម្បុរដូចមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សាអស់រាត្រីក្នុងថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយណា សម្រេចនូវវេទ ក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងនោះ ទទួលនូវការ

នមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងនោះ រក្សានូវខ្ញុំ ការនមស្ការ ចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការនមស្ការ ចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការ ចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការ ចូរមានដល់វិមុត្តិ ក្ងោកពោធិសត្វធ្វើបរិត្តនេះរួចហើយ ទើបបានសម្រេចការនៅ [១] ដោយឧបាយយ៉ាងនេះ ។

លំដាប់នោះ ថ្ងៃមួយ ព្រានព្រៃម្នាក់ ត្រាច់ទៅក្នុងព្រៃ ឃើញក្ងោកមាសនោះ ទំលើកំពូលភ្នំ លុះមកដល់លំនៅរបស់ខ្លួន កាលខ្លួនជិតស្លាប់ ក៏និយាយប្រាប់កូនថា នែបា ក្នុងព្រៃត្រង់ជួរភ្នំទី ៤ មានក្ងោកពណ៌មាស បើព្រះរាជាត្រាស់សួរ ចូរកូនក្រាបទូលឲ្យទ្រង់ជ្រាប ។ សម័យថ្ងៃមួយ អគ្គមហេសីរបស់ព្រះបាទពារាណសី ព្រះនាមខេមា ព្រះនាងសុបិនក្នុងពេលទៀបភ្លឺថា ក្ងោកមានពណ៌មាសកំពុងសម្តែងធម៌ ព្រះនាងស្តាប់ធម៌ហើយឲ្យសាធុការ ក្ងោកនោះសម្តែងធម៌ហើយ ក៏ហើរចេញទៅ ។ ព្រះនាងក៏ពោលថា ស្តេចក្ងោកហើរទៅហើយ ចូរនាំគ្នាចាប់ស្តេចក្ងោកនោះខណៈដែលកំពុងពោលនោះឯង ព្រះនាងក៏តើនឡើង កាលព្រះនាងជ្រាបថា ជាយល់សប្តិ ទើបព្រះតម្រិះថា បើអញក្រាបទូលថា យល់សប្តិ ព្រះរាជាទ្រង់មិនយកព្រះហឫទ័យអើពើ បើអញក្រាបទូលថា ខ្ញុំម្ចាស់

---

១-បិ.៥៨ ទំ.៧៣ ឃ.១៦៨ ។

ចាញ់គភ៌ ព្រះរាជានឹងយកព្រះហឫទ័យអើពើ ដូច្នេះហើយ ព្រះនាងក៏ផ្ដើធ្វើដូចជាចាញ់ព្រះគភ៌ ។ លំដាប់នោះ ព្រះរាជាចូលមកជិត ត្រាស់សួរថា **ភទ្ទេ កឹ តេ អផាសុកំ** នៃនាងដ៏ចម្រើន នាងមិនសប្បាយឬ ។

ព្រះនាងក្រាបទូលថា **ទោហឡោ មេ ឧប្បន្នោ** ការចាញ់គភ៌កើតឡើងដល់ខ្ញុំម្ចាស់ ។ ព្រះរាជាត្រាស់សួរថា **កឹ ឥច្ឆសិ ភទ្ទេ** នៃនាងដ៏ចម្រើន នាងត្រូវការអ្វី ។

ព្រះនាងក្រាបទូលថា **សុវណ្ណវណ្ណស្ស មោរស្ស ធម្មំ សោតុំ ទេវ** ខ្ញុំម្ចាស់ប្រាថ្នានឹងស្ដាប់ធម៌របស់ក្ងោកមានពណ៌មាស ព្រះអង្គ ។ ព្រះរាជាត្រាស់ថា **ភទ្ទេ កុតោ ឯវរូបំ មោរំ លច្ឆាមិ** នៃនាងដ៏ចម្រើន យើងនឹងរកក្ងោកមានរូបបែបនេះ ឯណាបាន ។

ព្រះនាងក្រាបទូលថា **ទេវ សចេ ន លភាមិ ជីវិតំ មេ នត្ថិ** បពិត្រព្រះសម្មតិទេព បើមិនបាន ជីវិតរបស់ខ្ញុំម្ចាស់ ក៏មិនមាន ។ ព្រះរាជាទ្រង់ត្រាស់លួងលោមថា នៃនាងដ៏ចម្រើន នាងកុំគិតថ្វីឡើយ បើសត្វនោះ មានក្នុងទីណា នាងនឹងបានពិត ហើយទ្រង់យាងទៅប្រថាប់គង់លើរាជាសនៈ ត្រាស់សួរពួកអាមាត្យថា រុំយអ្នកដ៏ចម្រើនទាំងឡាយ ព្រះទេវីប្រាថ្នានឹងស្ដាប់ធម៌របស់ក្ងោកមានពណ៌មាស ក្ងោកដែលមានពណ៌មាស មានដែរឬ ។

ពួកអាមាត្យក្រាបទូលថា បពិត្រព្រះទេវៈ ពួកព្រាហ្មណ៍គង់ដឹង ។

ព្រះរាជាឲ្យហៅពួកព្រាហ្មណ៍មកគាល់ ហើយត្រាស់សួរ ។ ពួកព្រាហ្មណ៍នាំគ្នាក្រាបទូលយ៉ាងនេះថា បពិត្រមហារាជ សត្វតិរច្ឆានទាំងនេះ ក្នុងពួកសត្វទឹក មានត្រី អណ្តើក ក្តាម ក្នុងពួកសត្វគោក មានម្រឹគ ហង្ស ក្ងោក ទទា ដែលមានពណ៌មាស ក៏មាន សូម្បីមនុស្សទាំងឡាយដែលមានសម្បុរមាស ក៏មាន ទាំងនេះ មានមកក្នុងគម្ពីរលក្ខណមន្តរបស់ទូលព្រះបង្គំទាំងឡាយ ។

ព្រះរាជាទ្រង់ឲ្យហៅកូនព្រានព្រៃក្នុងដែនរបស់ព្រះអង្គ មកប្រជុំគ្នា ត្រាស់សួរថា ពួកអ្នកធ្លាប់ឃើញក្ងោកមានពណ៌មាសដែរឬទេ ។ ព្រានដ៏សេសក្រាបទូលថា ពួកទូលព្រះបង្គំមិនដែលឃើញទេ ។ កូនព្រានដែលបិតាធ្លាប់ប្រាប់ ក្រាបទូលព្រះរាជាថា ទូលព្រះបង្គំក៏មិនធ្លាប់ឃើញ តែឪពុករបស់ទូលព្រះបង្គំបានប្រាប់ថា ក្ងោកមាសមានក្នុងទីឈ្មោះនោះ ។

លំដាប់នោះ ព្រះរាជាត្រាស់នឹងកូនព្រាននោះថា នែសម្លាញ់ អ្នកចូរឲ្យជីវិតដល់យើងនិងព្រះទេវី ចូរអ្នកទៅកាន់ទីនោះ ចាប់ក្ងោកមាសនោះ នាំមកចុះ ហើយទ្រង់ប្រទានទ្រព្យជាច្រើន បញ្ជូនទៅ ។ ព្រានព្រៃឲ្យទ្រព្យដល់បុត្តនិងភរិយាហើយ ទៅក្នុងទីនោះ ឃើញមហាសត្វ ក៏ធ្វើអន្ទាក់ដាក់ គិតថា ថ្ងៃនេះ គង់ជាប់ ថ្ងៃនេះ គង់ជាប់ ក៏ក្ងោកនោះ មិនជាប់អន្ទាក់សោះ រហូតដល់ព្រានអស់ជីវិតទៅ ។ សូម្បីព្រះទេវី កាលមិនបាន

តាមប្រាថ្នា ក៏អស់ព្រះជន្មទៅដែរ ។ ព្រះរាជាទ្រង់ពិរោធថា ព្រោះអាស្រ័យក្ងោកមាសនេះ ជាហេតុ ទើបភរិយាជាទីស្រឡាញ់របស់អញត្រូវអស់ព្រះជន្ម ទ្រង់មានព្រះហឫទ័យប្រព្រឹត្តទៅក្នុងអំណាចពៀរវេរា ឲ្យគេចារឹកអក្សរដាក់ក្នុងក្រាំងមាសថា ត្រង់ជួរភ្នំទី ៤ ក្នុងព្រៃហិមពាន្ត មានក្ងោកមានពណ៌មាស អាស្រ័យនៅ បុគ្គលណា បានស៊ីសាច់របស់ក្ងោកមានពណ៌មាសនោះហើយ នឹងមិនចាស់ មិនស្លាប់ ទ្រង់ដាក់ក្រាំងមាសនោះ ទុកក្នុងហិបដែលធ្វើអំពីឈើខ្លឹម ហើយសោយទិវង្គតទៅ ។

កាលក្សត្រដទៃបានជាព្រះរាជាហើយ ទ្រង់ទតឃើញអក្ខរាក្នុងក្រាំងមាស ទ្រង់ព្រះតម្រិះថា អញនឹងមិនចាស់ មិនស្លាប់ ហើយទ្រង់បញ្ជូនព្រានម្នាក់ ទៅចាប់ក្ងោកមានពណ៌មាសនោះ សូម្បីព្រាននោះ ក៏ស្លាប់ក្នុងទីនោះដូចគ្នា ។ ដោយទំនងនេះ កន្លងទៅ ៦ រជ្ជកាលហើយ កូនព្រានទាំង ៦ ស្លាប់ក្នុងព្រៃហិមពាន្តនោះឯង ។ លុះដល់ព្រានទី ៧ ដែលព្រះរាជាអង្គទី ៧ ទ្រង់បញ្ជូនទៅ ព្រាននោះគិតថា ( អញនឹងចាប់ក្ងោកពណ៌មាសនោះ បាន ) ក្នុងថ្ងៃនេះ ក្នុងថ្ងៃនេះ ។ កន្លងទៅ ៧ ឆ្នាំ ក៏មិនអាចចាប់ក្ងោកមាសនោះ បាន ទើបគិតថា ហេតុអ្វីហ្ន៎ អន្ទាក់ក៏មិនតម្លោះជាប់ជើងស្ដេចក្ងោកមាសនេះ ក៏ចាំសង្កេតមើលក្ងោកមាសនោះ ឃើញក្ងោកមាសនោះ សូធ្យព្រះបរិត្តរាល់ព្រឹកល្ងាច ក៏កំណត់បានដោយន័យថា ក្នុងទីនេះ ក្ងោកដទៃមិនមានឡើយ ក្ងោកមាសនេះ គង់

ប្រព្រឹត្តព្រហ្មចរិយៈ ដោយអានុភាពនៃព្រហ្មចរិយៈ និងដោយអានុភាពនៃព្រះបរិត្ត ទើបអន្ទាក់មិនជាប់ជើងក្ងោកនោះ ដូច្នេះហើយ ទើបទៅកាន់បច្ចន្តជនបទ ចាប់ក្ងោកញីបានមួយ បង្ហាត់ឲ្យរងាវក្នុងពេលដែលផ្ទាត់ម្រាមដៃ ឲ្យរាំក្នុងពេលដែលទះដៃ ហើយនាំទៅ ។ មុនពេលដែលព្រះពោធិសត្វចម្រើនព្រះបរិត្តនោះឯង ក៏រាយអន្ទាក់ ផ្ទាត់ម្រាមដៃឲ្យក្ងោកញីរងាវ កាលស្ដេចក្ងោកមាសបានស្ដាប់សំឡេងរបស់ក្ងោកញី កិលេសដែលស្ងប់អស់ ៧០០ ឆ្នាំ ក៏ផុសផុលឡើងមួយរំពេច ដូចអាសិរពិសដែលត្រូវវាយដោយដំបង បើកនូវពពារដូច្នោះ ។ ស្ដេចក្ងោករសាប់រសល់ដោយអំណាចកិលេស រហូតមិនអាចចម្រើនព្រះបរិត្តបានហើរទៅកាន់សម្នាក់ក្ងោកញីដោយរហ័ស គ្រាន់តែចុះពីអាកាស ស៊កជើងចូលទៅក្នុងអន្ទាក់តែម្ដង ។ អន្ទាក់មិនធ្លាប់តម្វោះអស់ ៧០០ ឆ្នាំ ក៏តម្វោះជាប់ជើងក្នុងខណៈនោះឯង ។

លំដាប់នោះ ព្រានព្រៃឃើញស្ដេចក្ងោកសំយុងខ្លួន ត្រង់ដងអន្ទាក់ហើយ គិតថា កូនព្រាន ៦ នាក់ មិនអាចចាប់ស្ដេចក្ងោកមាសនេះ បានឯខ្លួនអញ ក៏មិនអាចចាប់បានអស់ ៧ ឆ្នាំ តែថ្ងៃនេះ ពេលព្រឹក ស្ដេចក្ងោកអាស្រ័យក្ងោកញីនេះ ជាសត្វរសាប់រសល់ដោយអំណាចកិលេសព្រោះអាស្រ័យកិលេស មិនអាចសូធ្យព្រះបរិត្ត ចូលមកជាប់អន្ទាក់ មានក្បាលសំយុងចុះ សត្វមានសីលបែបនេះ ត្រូវអញធ្វើឲ្យលំបាកហើយ

ការនាំសត្វបែបនេះទៅ ដើម្បីជាបណ្ណាការដល់ព្រះរាជាមិនសមគួរឡើយ អញត្រូវការអ្វីដោយសក្ការៈដែលព្រះរាជាទ្រង់ព្រះរាជទាន អញនឹងលែងក្ងោកនេះ ទៅចុះ ។ ព្រានព្រៃនោះ គិតបន្តថា ស្តេចក្ងោកនេះ មានកម្លាំងដូចដំរីសារ សម្បូរដោយសន្ទុះ បើអញចូលទៅជិត គង់គិតថា បុរសនេះ នឹងមកសម្លាប់អញ ហើយខ្លាចស្លាប់ពន់ពេក នឹងរើបម្រះ ជើងក្តី ស្លាបក្តី នឹងបាក់ បើដូច្នោះ អញមិនចូលទៅជិត អញនឹងបាញ់ផ្តាច់អន្ទាក់ដោយព្រួញ បន្ទាប់អំពីនោះ ក្ងោកនឹងទៅតាមការគាប់ចិត្តរបស់ខ្លួន ។ ព្រានព្រៃនោះ ឈរក្នុងទីកំបាំង លើកធ្នូឡើងផ្តាប់កូនសរ ។ ស្តេចក្ងោកគិតថា ព្រាននេះ ធ្វើអញឲ្យលំបាកដោយកិលេសហើយ ដឹងនូវភាវៈនៃអញជាអ្នកជាប់អន្ទាក់ មិនមានសេចក្តីសង្ស័យ នឹងមក ព្រាននៅក្នុងទីណាហ្ន៎ សម្លឹងខាងនេះខាងនោះ ឃើញព្រានកំពុងឈរលើកធ្នូ សម្គាល់ថា ព្រាននឹងជាអ្នកប្រាថ្នាសម្លាប់អញ ហើយកាន់យកទៅ ជាអ្នកត្រូវមរណភ័យគំរាមហើយ កាលអង្វរសូមជីវិត ទើបពោលគាថាទី ១ ថា

សចេ ហិ ត្យាហំ ធនហេតុ គហិតោ
មា មំ អវធី ជីវគាហំ គហេត្វា
រញ្ញោ ច មំ សម្ម ឧបន្តិ នេហិ
មញ្ញេ ធនំ លច្ឆសិនប្បរូបំ ។

ម្នាលសម្លាញ់ ប្រសិនបើអ្នកចាប់ខ្ញុំ ព្រោះហេតុនៃទ្រព្យ

អ្នកកុំសម្លាប់ខ្ញុំឡើយ សូមចាប់ខ្ញុំទាំងរស់ ហើយនាំខ្ញុំទៅកាន់សម្នាក់ព្រះរាជាចុះ អ្នកទំនងជានឹងបាននូវទ្រព្យដ៏ច្រើន ។

ព្រានព្រៃបានឮពាក្យនោះហើយ ត្រិះរិះថា ស្តេចក្ងោកនេះ យល់ថា អញផ្ទាប់ព្រួញដើម្បីបាញ់ អញត្រូវលួងលោមស្តេចក្ងោកនេះ ។ កាលនឹងលួងលោម ទើបពោលគាថាទី ២ ថា

ន មេ អយំ តុយ្ហ វធាយ អជ្ជ
សមាហិតោ ចាបវរេ ខុរប្បោ
ចាសញ្ច ត្យាហំ អធិបាតយិស្សំ
យថាសុខំ គច្ឆតុ មោររាជា ។

ធ្នូដ៏ប្រសើរនិងព្រួញនេះ ខ្ញុំមិនមែនយឹត ប្រុងប្រៀប ដើម្បីនឹងបាញ់អ្នកក្នុងថ្ងៃនេះទេ ខ្ញុំនឹងបាញ់ផ្តាច់អន្ទាក់របស់អ្នកទេតើ (ដោយគិតថា) ស្តេចក្ងោកចូរទៅតាមសប្បាយចុះ ។

លំដាប់នោះ ស្តេចក្ងោកបានពោលគាថា ២ ថា

យំ សត្ត វស្សានិ មមានុពន្ធិ
រត្តិន្ទិវំ ខុប្បិបាសំ សហន្តោ
អថ កិស្ស មំ បាសវសូបនីតំ
បមុត្តវេ ឥច្ឆសិ ពន្ធនស្មា ។

*អ្នកខំអត់ទ្រាំនូវសេចក្ដីស្រេកឃ្លាន ទាំងយប់ទាំងថ្ងៃ ដើរដាប់តាមខ្ញុំអស់ប្រាំពីរឆ្នាំហើយ កាលបើយ៉ាង នេះ ព្រោះហេតុអ្វី ក៏អ្នកចង់ដោះខ្ញុំ ដែលកំពុង ជាប់អន្ទាក់ ឲ្យរួចអំពីអន្ទាក់វិញ ។*

ចាណាតិចាតា វិរតោ នុសជ្ជ
អភយន្នុ តេ សព្វភូតេសុ ទិន្នំ
យំ មំ តុវំ ចាសវសូបនីតំ
បមុត្តវេ ឥច្ឆសិ ពន្ធនស្មា ។

*អ្នកទើបនឹងវៀរចាកបាណាតិបាតក្នុងថ្ងៃនេះឬ ឬក៏ អ្នកឲ្យអភ័យដល់សត្វទាំងពួង បានជាអ្នកចង់ដោះ ខ្ញុំ ដែលកំពុងជាប់អន្ទាក់ ឲ្យរួចចាកអន្ទាក់វិញ ។*

*បន្ទាប់អំពីនេះ គប្បីជ្រាបការឆ្លើយឆ្លងរវាងនាយព្រាននិងស្ដេច ក្ងោកដូចតទៅនេះថា*

*កូនព្រានព្រៃសួរថា*

ចាណាតិចាតា វិរតស្ស ព្រូហិ
អភយញ្ច យោ សព្វភូតេសុ ទេតិ
បុច្ឆាមិ តំ មោររាជេតមត្ថំ
ឥតោ ចុតោ កឹ លភតេ សុខំ សោ ។

ម្នាលស្តេចក្អែក អ្នកចូរប្រាប់អំពីបុគ្គលដែលវៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវអភ័យដល់សត្វទាំងពួងផង ខ្ញុំសូមសួរអ្នកត្រង់សេចក្ដីនុ៎ះ បុគ្គលនោះ ច្យុតអំពីលោកនេះទៅ នឹងបាននូវសេចក្ដីសុខដូចម្ដេចខ្វះ ។

ស្តេចក្អែកពោលថា

ចាណាតិចាតា វិរតស្ស ព្រូមិ
អភយញ្ច យោ សព្វភូតេសុ ទេតិ
ឧិដ្ឋេវ ធម្មេ លភតេ បសំសំ
សគ្គញ្ច សោ យាតិ សរីរភេទា ។

ខ្ញុំនឹងប្រាប់អំពីបុគ្គល ដែលវៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវអភ័យដល់សត្វទាំងពួង បុគ្គលនោះ រមែងបាននូវសេចក្ដីសរសើរក្នុងបច្ចុប្បន្នផង លុះបែកធ្លាយសរីរៈទៅ នឹងបានទៅកើតនៅឋានសួគ៌ផង ។

កូនព្រានពោលថា

ន សន្តិ ទេវា ឥតិ អាហុ ឯកេ
ឥធេវ ជីវោ វិភវំ ឧបេតិ
តថា ផលំ សុកតទុក្កដានំ
ទត្តុប្បញ្ញត្តញ្ច វទន្តិ ទានំ

តេសំ វចោ អរហតំ សទ្ទហានោ
តស្មា អហំ សកុណេ ពាធយាមិ ។

*សមណព្រាហ្មណ៍ពួកខ្លះបានពោលថា ទេវតាទាំងឡាយមិនមានទេ ជីវៈក្នុងលោកនេះ រមែងដល់នូវសេចក្ដីដាច់សូន្យ ផលនៃអំពើដែលសត្វធ្វើល្អ ធ្វើអាក្រក់ រមែងដល់នូវសេចក្ដីដាច់សូន្យដូចគ្នា ទាំងពោលថា ទានជាគុណជាត គឺមនុស្សល្ងង់បញ្ញត្តហើយ ខ្ញុំជឿពាក្យរបស់សមណព្រាហ្មណ៍ ជាព្រះអរហន្តទាំងនោះ ហេតុនោះបានជាខ្ញុំសម្លាប់សត្វស្លាបទាំងឡាយ ។*

*បានឮថា ពួកអ្នកបួសអាក្រាត មានវាទៈថា ដាច់សូន្យ ជាអ្នកនៅជិតខាងត្រកូលនាយព្រាននោះ ជនទាំងនោះ នាំគ្នាដឹកនាំព្រានដែលជាសត្វដល់ព្រមដោយឧបនិស្ស័យនៃបច្ចេកពោធិញ្ញាណ ឲ្យកាន់យកនូវឧច្ឆេទវាទបាន ព្រោះការសេពគប់នឹងអ្នកបួសអាក្រាតនោះ ទើបនាយព្រាននោះ យល់ថា ផលនៃកុសលនិងអកុសល មិនមាន ហើយក៏សម្លាប់បក្សីជាច្រើន ។ ឈ្មោះថា ការគប់រកបុគ្គលអសប្បុរសនេះ មានទោសធំយ៉ាងនេះ ។ នាយព្រានសម្គាល់ពួកអចេលក៍ទាំងនោះ ថាជាព្រះអរហន្ត ទើបពោលយ៉ាងនេះ ។*

*មហាសត្វស្ដាប់ពាក្យនោះហើយ ត្រិះរិះថា អញត្រូវពោលដល់*

*ភាពដែលបរលោកមាន ដល់បុរសនេះ ទាំងក្បាលកំពុងសំយុងចុះ ត្រង់ចុងអន្ទាក់នោះឯង បានពោលគាថានេះថា*

ចន្ទោ ច សុរិយោ ច ឧភោ សុទស្សនា
គច្ឆន្តិ ឱភាសយមន្តលិក្ខេ
ឥមស្ស លោកស្ស បរស្ស វា តេ
កថន្នុ តេ អាហុ មនុស្សលោកេ ។

*ព្រះចន្ទនិងព្រះអាទិត្យទាំងពីរ ជារបស់ឃើញងាយ ភ្លឺរុងរឿងទៅឰដ៏អាកាស ព្រះចន្ទនិងព្រះអាទិត្យទាំងនោះ (ជារបស់) លោកនេះ ឬលោកដទៃ (ពួកជន) ក្នុងមនុស្សលោក ហៅព្រះចន្ទនិងព្រះអាទិត្យទាំងនោះ ថាជាអ្វី ។*

*កូនព្រានពោលគាថាថា*

ចន្ទោ ច សុរិយោ ច ឧភោ សុទស្សនា
គច្ឆន្តិ ឱភាសយមន្តលិក្ខេ
បរស្ស លោកស្ស ន តេ ឥមស្ស
ទេវាតិ តេ អាហុ មនុស្សលោកេ ។

*ព្រះចន្ទនិងព្រះអាទិត្យទាំងពីរ ជារបស់ឃើញងាយ ភ្លឺរុងរឿងទៅឰដ៏អាកាស ព្រះចន្ទនិងព្រះអាទិត្យទាំងនោះ*

(ជារបស់) លោកដទៃ មិនមែនរបស់លោកនេះទេ ពួកជនក្នុងមនុស្សលោក ហៅព្រះចន្ទ និងព្រះអាទិត្យទាំងនោះ ថាជាទេវតា ។

លំដាប់នោះ មហាសត្វពោលគាថានេះ បន្តទៀតថា

ឯត្ថេវ តេ នីហតា ហីនវាទា
អហេតុកា យេ ន វទន្តិ កម្មំ
តថា ផលំ សុកតទុក្កដានំ
ទត្តុបញ្ញត្តំ យេ ច វទន្តិ ទានំ ។

សមណព្រាហ្មណ៍ណា មិនពោលអាងកម្ម មិនពោលអាងផលនៃកម្ម ដែលសត្វធ្វើល្អ ធ្វើអាក្រក់ មួយទៀត សមណព្រាហ្មណ៍ណា ពោលថា ទានជាគុណជាតដែលមនុស្សល្ងង់បញ្ញត្តហើយ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកហីនវាទ ជាអ្នកអហេតុកវាទ ត្រូវគេដេញដើងទាល់ក្នុងព្យាករណ៍នេះ មិនខាន ។

កាលមហាសត្វពោលដូច្នេះហើយ កូនព្រាននោះ ក៏កំណត់បាន ទើបពោលគាថា ២ ថា

អទ្ធា ហិ សច្ចំ វចនំ តវេតំ
កថញ្ហិ ទានំ អផលំ ភវេយ្យ

តថា ផលំ សុកតទុក្កដានំ
ឧត្តុប្បញ្ញត្តញ្ច កថំ ភវេយ្យ ។

ពាក្យរបស់អ្នកនុ៎ះទៀងពិត ព្រោះទានជាគុណជាតផត ផលដូចម្តេចកើត ផលនៃអំពើដែលសត្វធ្វើល្អ ធ្វើអាក្រក់ ក៏ដូចគ្នា ម្យ៉ាងទៀត ទានជាគុណជាតដែលមនុស្សល្វង់ បញ្ញត្តហើយ ដូចម្តេចកើត ។

កថង្ករោ កិន្តិករោ កិមាចរំ
កិំ សេវមានោ កេន តបោគុណេន
អក្ខាហិ មេ មោរកជេតមត្ថំ
យថា អហំ នោ និរយំ បតេយ្យំ ។

ខ្ញុំធ្វើអំពើដូចម្តេច ធ្វើដោយហេតុដូចម្តេច ប្រព្រឹត្តដូចម្តេច សេពនូវអ្វី ដោយគុណនៃតបៈដូចម្តេច មិនគប្បីធ្លាក់ទៅក្នុងនរក យ៉ាងណា ម្នាលស្តេចក្ងោក អ្នកសូមប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ដោយឧបាយយ៉ាងនោះ ។

មហាសត្វស្តាប់ពាក្យនោះហើយ ត្រិះរិះថា បើអញមិនអាចឆ្លើយបញ្ហានេះ មនុស្សលោកហាក់ដូចជាទទេ អញនឹងពោលភាពដែលសមណព្រាហ្មណ៍ទ្រទ្រង់នូវធម៌ មាននៅក្នុងលោកមនុស្សនេះឯង ដល់បុរសនេះ ដូច្នេះហើយ បានពោលគាថា ២ ថា

យេ កេចិ អត្ថិ សមណា បថព្យា
កាសាយវត្ថា អនគារិយំ ចរន្តិ
ចាតោវ បិណ្ឌាយ ចរន្តិ កាលេ
វិកាលចរិយា វិរតា ហិ សន្តោ ។

*ពួកសមណៈណាមួយ នៅលើផែនដី ជាអ្នកស្លៀកសំពត់កាសាវៈ ប្រព្រឹត្តក្នុងភេទនៃបុគ្គលគ្មានផ្ទះ ត្រាច់ទៅបិណ្ឌបាតអំពីព្រឹកក្នុងកាលគួរ វៀរចាកកិរិយាត្រាច់ទៅក្នុងកាលខុស ជាអ្នកស្ងប់រម្ងាប់ ។*

តេ តត្ថ កាលេនុបសង្កមិត្វា
បុច្ឆាហិ យំ តេ មនសោ បិយំ សិយា
តេ តំ បវក្ខន្តិ យថាបជានំ
ឥមស្ស លោកស្ស បរស្ស ចត្ថំ ។

*អ្នកចូរចូលទៅរកសមណៈទាំងនោះ តាមកាលគួរ ក្នុងទីនោះ ហើយចូរសាកសួរចុះ ប្រយោជន៍ណាដែលជាទីពេញចិត្តរបស់អ្នក លោកនឹងប្រាប់នូវប្រយោជន៍នោះជាប្រយោជន៍ក្នុងលោកនេះ និងក្នុងលោកខាងមុខ ( ដល់អ្នក ) តាមទំនងនៃការចេះដឹង ( របស់លោក ) ។*

*កាលស្ដេចក្ងោកពោលឲ្យខ្លាចភ័យក្នុងនរក យ៉ាងនោះហើយ បុរស*

*នោះ ជាបច្ចេកពោធិសត្វ មានបារមីពេញហើយ មានញាណចាស់ក្លាហើយ ដូចផ្កាឈូកដែលចាស់ ហើយត្រូវពន្លឺព្រះអាទិត្យដូច្នោះ ។ កាលស្តាប់ធម្មកថារបស់ស្តេចក្មេក ដោយឥរិយាបថឈរនោះឯង កំណត់សង្ខារទាំងឡាយ ពិចារណាត្រៃលក្ខណ៍ សម្រេចបច្ចេកពោធិញ្ញាណហើយ ។ ការសម្រេចរបស់លោក និងការរួចផុតចាកអន្ទាក់របស់ក្មេកពោធិសត្វ មានដំណាលគ្នានោះឯង ។* **ព្រះបច្ចេកពុទ្ធ** *ទម្លាយកិលេសទាំងឡាយហើយ តាំងនៅក្នុងទីបំផុតនៃភព កាលលោកបន្លឺនូវឧទានទើបពោលគាថាដូច្នេះថា*

តចំវ ជិណ្ណំ ឧរគោ បុរាណំ
បណ្ឌុបលាសំ ហរិតោ ទុមោវ
ឯសប្បហីនោ មម លុទ្ទភាវោ
ជហាមហំ លុទ្ទកភាវមជ្ជ ។

*ភាពជាព្រានព្រៃនុ៎ះ អាត្មាអញបានលះបង់ហើយ អាត្មាអញបានលះបង់ នូវភាពនៃខ្លួនជាព្រានព្រៃ ក្នុងថ្ងៃនេះ ដូចពស់សកនូវសំណាកចាស់ជាន់មុន ឬក៏ដូចដើមឈើមានស្លឹកខៀវ (ជម្រុះចោល) នូវស្លឹកលឿង ។*

*អត្ថនៃគាថានោះ មានអធិប្បាយថា ពស់សកសំណាកចាស់ដែលចាស់គ្រាំគ្រាយ៉ាងណា ដើមឈើដែលមានស្លឹកពណ៌ខៀវ ជម្រុះនូវស្លឹក*

ពណ៌លឿងដែលជាប់ក្នុងទីណាមួយ ចោលបាន យ៉ាងណា អាត្មាអញ ក៏យ៉ាងនោះ លះបង់បាននូវភាពជាព្រាន ភាពជាមនុស្សឃោរឃៅ តាំងនៅហើយ ។ ឥឡូវនេះ ភាពជាព្រាន អាត្មាអញលះចោលបាន ហើយ ឱល្អហ្ន៎! អាត្មាអញលះបង់ភាពជាព្រានបានក្នុងថ្ងៃនេះ ។

កាលព្រះបច្ចេកពុទ្ធបន្លឺឧទាននេះហើយ ត្រិះរិះថា អាត្មាអញផុតចាកគ្រឿងជាប់ចំពាក់ គឺកិលេសទាំងពួងបានពិតប្រាកដ តែក្នុងលំនៅរបស់អញ មានបក្សីដែលប្រស់ទុកច្រើន អញនឹងដោះលែងបក្សីទាំងនោះបានដូចម្តេច ទើបសួរមហាសត្វថា នៃស្តេចក្ងោក ក្នុងលំនៅរបស់អាត្មា មានបក្សីដែលប្រស់ទុកច្រើន អាត្មានឹងដោះលែងបក្សីទាំងនោះ បានដូចម្តេច ។ សេចក្តីពិត ញាណក្នុងការកំណត់ឧបាយរបស់ព្រះសព្វញ្ញូ-ពោធិសត្វទាំងឡាយ រមែងធំជាងព្រះបច្ចេកពុទ្ធ ព្រោះហេតុនោះ ទើបស្តេចក្ងោកពោលថា បច្ចេកពោធិញ្ញាណដែលលោកម្ចាស់ទម្លាយកិលេសទាំងពួងហើយ សម្រេចដោយមគ្គណា សូមលោកម្ចាស់ប្រារព្ធមគ្គនោះ ធ្វើនូវសច្ចកិរិយាចុះ ឈ្មោះថា សត្វដែលត្រូវចងក្នុងជម្ពូទ្វីបទាំងមូល ក៏នឹងមិនមាន ។ ព្រះបច្ចេកពុទ្ធ តាំងនៅក្នុងន័យដែលព្រះពោធិសត្វឲ្យហើយ កាលធ្វើសច្ចកិរិយា ទើបពោលគាថានេះថា

យេ ចាបិ មេ សកុណា អត្ថិ ពទ្ធា
សតានិ នេកានិ និវេសនស្មឹ

**តេសំ អហំ ជីវិតមជ្ជ ឧម្មិ**
**មោក្ខញ្ច តេ អជ្ជសកំ និកេតំ ។**

ពួកបក្សីណា ច្រើនរយ ដែលអាត្មាអញបានចងទុកក្បែរ
លំនៅ ( របស់ខ្លួន ) អាត្មាអញនឹងឲ្យនូវជីវិតដល់សត្វ
ទាំងឡាយនោះ ក្នុងថ្ងៃនេះ អាត្មាអញបានរួចចាកកិលេស
ហើយ សត្វទាំងនោះ ចូរទៅកាន់លំនៅរបស់ខ្លួនចុះ ។

លំដាប់នោះ បក្សីទាំងពួង ក៏រួចចាកចំណង ចាកទីឃុំឃាំង ដំណាលគ្នានឹងព្រះបច្ចេកពុទ្ធធ្វើសច្ចកិរិយានោះឯង នាំគ្នាត្រេកអរ ហើរទៅកាន់លំនៅរបស់ខ្លួន ។ ខណៈនោះ សត្វក្នុងផ្ទះទាំងអស់របស់មនុស្សទាំងឡាយនោះ ៗ មានឆ្មាជាដើម ក្នុងជម្ពូទ្វីបទាំងមូល ឈ្មោះថា ជាសត្វដែលត្រូវចង មិនមានឡើយ ។ ព្រះបច្ចេកពុទ្ធលើកដៃស្ទាបសីសៈ រំពេចនោះឯង ឃរាវាសភេទក៏អន្តរធានទៅ បព្វជិតភេទក៏ប្រាកដឡើង លោកដូចជាព្រះថេរៈមានវស្សា ៦០ សម្បូរដោយមារយាទ ទ្រទ្រង់នូវបរិក្ខារ ៨ ពោលថា **ត្វមេវ មម បតិដ្ឋា អហោសិ** អ្នកប៉ុណ្ណោះបានជាទីពឹងរបស់ខ្ញុំ ផ្គងអញ្ជលីចំពោះស្ដេចក្ងោក ហើយធ្វើប្រទក្សិណ ហោះទៅក្នុងអាកាស ទៅកាន់ញកភ្នំឈ្មោះនន្ទមូលកៈ ។ ឯស្ដេចក្ងោកផុតអំពីដងអន្ទាក់ ស្វែងរកអាហារហើយ ទៅកាន់លំនៅរបស់ខ្លួនវិញ ។

ឥឡូវនេះ ព្រះសាស្ដា កាលទ្រង់ប្រកាសភាពដែលនាយព្រានកាន់

យកអន្ទាក់ត្រាច់ទៅអស់ ៧ ឆ្នាំ អាស្រ័យស្តេចក្ងោក ផុតចាកទុក្ខបាន ទើបត្រាស់គាថាចុងក្រោយថា

**លុទ្ទោ ចរី ចាសហត្ថោ អរញ្ញេ**
**ពាធេតុ មោរាធិបតឹ យសស្សឹ**
**ពន្ធិត្វា មោរាធិបតឹ យសស្សឹ**
**ទុក្ខា បមុញ្ចិ យថាហំ បមុត្តោ ។**

ព្រានព្រៃមានអន្ទាក់ក្នុងដៃ ត្រាច់ទៅក្នុងព្រៃ ដើម្បីទាក់នូវស្តេចក្ងោក ដែលមានយស លុះទាក់នូវស្តេចក្ងោកដែលមានយសបានហើយ ក៏បានរួចចាកសេចក្តីទុក្ខ ដូចតថាគតដែលបានរួច ( ចាកទុក្ខដោយសយម្ភូញាណ ) ដូច្នោះដែរ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ហើយទ្រង់ប្រជុំជាតក កាលចប់សច្ចៈហើយ ភិក្ខុអ្នកអផ្សុកនោះ តាំងនៅក្នុងអរហត្ត ។ ស្តេចក្ងោកក្នុងកាលនោះ គឺតថាគតនេះឯង ។

**មហាមោរជាតក ចប់** [១]

---

១-ស្រង់ចាកអដ្ឋកថា ជាតក បកិណ្ណកនិបាត បិ.៦០ ទំ.៣១ ឃ.៩០ ។

# សោណកជាតក

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនេក្ខម្មបារមី ទើបត្រាស់ព្រះធម្មទេសនានេះថា

ក្នុងអតីតកាល ព្រះរាជានៃដែនមគធៈ សោយរាជសម្បត្តិក្នុងនគររាជគ្រឹះ ព្រះពោធិសត្វកើតក្នុងព្រះឧទររបស់អគ្គមហេសីនៃព្រះរាជាអង្គនោះ ។ ក្នុងថ្ងៃដែលថ្វាយព្រះនាម ព្រះជនកនិងព្រះជននីបានថ្វាយព្រះនាមព្រះរាជឱរសនោះថា អរិន្ទមកុមារ ។ បុត្តរបស់បុរោហិត ក៏បានប្រសូតក្នុងថ្ងៃដែលព្រះរាជកុមារនោះ ប្រសូតហើយដូចគ្នា មាតាបិតាបានដាក់ឈ្មោះបុត្តនោះថា សោណកកុមារ ។ ជនទាំងពីរ គឺព្រះរាជកុមារនិងកុមារនោះ ចម្រើនវ័យដូចគ្នា កាលចម្រើនវ័យហើយ ជាអ្នកមានរូបស្អាត ជាអ្នកវិសេសដោយរូប បានទៅកាន់នគរតក្កសិលា រៀនសិល្បសាស្ត្រចប់ហើយ ចេញអំពីនគរតក្កសិលានោះ គិតថា យើងនឹងសិក្សាឲ្យចេះសិប្បៈក្នុងលទ្ធិទាំងអស់ និងប្រទេសជាទីត្រាច់ទៅ ( ស្គាល់ស្រុកទេស ) ដូច្នេះហើយ ទើបនាំគ្នាចារិកទៅដោយលំដាប់ រហូតដល់នគរពារាណសី ស្នាក់នៅក្នុងព្រះរាជឧទ្យាន លុះថ្ងៃស្អែកឡើង ទើបនាំគ្នាចូលទៅកាន់ព្រះនគរ ។ ក្នុងថ្ងៃនោះ មនុស្សពួកខ្លះ នាំគ្នាគិតថា ពួកយើងនឹងធ្វើទីសូធ្យមន្តរបស់ព្រាហ្មណ៍ ទើបរៀបចំបាយាស ក្រាល

សេនាសនៈ ឃើញកុមារទាំង ២ នោះ ដើរមក អញ្ជើញឲ្យចូលទៅក្នុងផ្ទះ ឲ្យអង្គុយលើអាសនៈដែលគេក្រាលទុកនោះ ។ ជនទាំងឡាយក្រាលសំពត់ពណ៌សស្អាត សម្រាប់ព្រះពោធិសត្វ ក្រាលសំពត់កម្ពលពណ៌ក្រហម សម្រាប់សោណកកុមារ ។ សោណកកុមារសម្ងឹងមើលគ្រឿងសម្គាល់ ក៏ដឹងថា ក្នុងថ្ងៃនេះ អរិន្ទមកុមារសម្លាញ់ ជាទីស្រឡាញ់របស់អញ នឹងបានជាព្រះរាជាគ្រប់គ្រងនគរពារាណសី នឹងព្រះរាជទានតំណែងសេនាបតីដល់អញ ។ កុមារទាំង ២ នោះ ធ្វើកត្តកិច្ចស្រេចហើយ ក៏បាននាំគ្នាទៅកាន់ព្រះរាជឧទ្យាននោះឯង ។

ក្នុងកាលនោះ ជាថ្ងៃដែលព្រះបាទក្រុងពារាណសីសោយទិវង្គតអស់ ៧ ថ្ងៃមកហើយ រាជត្រកូលមិនមានរាជឱរស ។ ជនទាំងឡាយមានអាមាត្យជាដើម ងូតទឹក កក់សក់ អំពីព្រលឹមហើយ ប្រជុំគ្នាត្រៀមបុស្សរថផ្សងទៅ ដោយគិតថា បុស្សរថនឹងទៅរកបុគ្គលដែលគួរដល់រាជសម្បត្តិ ។ បុស្សរថនោះ ចេញអំពីព្រះនគរទៅកាន់ព្រះរាជឧទ្យានដោយលំដាប់ ដល់ទ្វារព្រះរាជឧទ្យាន ក៏ត្រាច់ចរទៅ ឈប់រង់ចាំទទួលការយាងឡើងជិះរបស់ព្រះរាជកុមារ ។

ព្រះពោធិសត្វផ្ទំទទូរក្បាលលើផ្ទាំងថ្មដែលជាមង្គល សោណក-កុមារអង្គុយនៅក្បែរព្រះពោធិសត្វនោះ ។ សោណកកុមារនោះ បានឮសំឡេងតន្ត្រី ទើបត្រិះរិះថា បុស្សរថមកដើម្បីអរិន្ទមកុមារ ថ្ងៃនេះ ទ្រង់

នឹងបានជាព្រះរាជា នឹងព្រះរាជទានតំណែងសេនាបតីឲ្យដល់អញ តែអញមិនត្រូវការដោយឥស្សរិយយសឡើយ កាលព្រះរាជកុមារនេះ យាងទៅហើយ អញនឹងបួស ដូច្នេះ ទើបឈរពួនក្នុងទីមួយកន្លែង ។

បុរោហិតចូលទៅកាន់ឧទ្យាន ឃើញព្រះមហាសត្វកំពុងផ្ទំ ទើបឲ្យភ្នាក់ងារប្រគំតន្ត្រីឡើង ។ ព្រះមហាសត្វភ្ញាក់ឡើងដឹងខ្លួន ក៏ផ្ទំបន្តទៀតបន្តិច ទើបក្រោកឡើងអង្គុយពត់ភ្នែនលើផ្ទាំងថ្ម ។ លំដាប់នោះ បុរោហិតផ្គងអញ្ជលីក្រាបទូលថា **រជ្ជំ តេ ទេវ បាបុណាតិ** បពិត្រព្រះសម្មតិទេព រាជសម្បត្តិមកដល់ទ្រង់ហើយ ។

ព្រះមហាសត្វសួរថា **កឹ អបុត្តកំ រាជកុលំ** រាជត្រកូលមិនមានព្រះរាជឱរសទេឬ ។ បុរោហិតទូលថា **ឯវំ ទេវ** យ៉ាងនោះឯងព្រះអង្គ ។

ព្រះមហាសត្វទទួលថា **តេន ហិ សាធុ** បើដូច្នោះ ជាការល្អ ។ លំដាប់នោះ មហាជននាំគ្នាអភិសេកព្រះមហាសត្វក្នុងព្រះរាជឧទ្យាននោះឯង ហើយយាងឲ្យឡើងលើរថ ត្រឡប់ចូលកាន់នគរ ដោយបរិវារធំ ។ ព្រះរាជាទ្រង់ធ្វើប្រទក្សិណនគរហើយ ទ្រង់ឡើងកាន់ប្រាសាទ ទ្រង់មិនបានរឭកដល់សោណកកុមារ ព្រោះមានឥស្សរិយយសធំ ។

ឯសោណកកុមារនោះ កាលព្រះពោធិសត្វចូលកាន់នគរហើយ ក៏មកអង្គុយត្រង់ផ្ទាំងថ្ម ។ គ្រានោះ ស្លឹកសាលព្រឹក្ស ( រាំងភ្នំ ) ពណ៌

លឿន រុះចាកទង ធ្លាក់ចុះមកចំពោះមុខរបស់សោណកកុមារនោះ ។ លុះសោណកកុមារបានឃើញស្លឹកឈើទុំនោះហើយ ទើបគិតថា ស្លឹកឈើនេះ ជ្រុះយ៉ាងណា សូម្បីសរីរៈរបស់អញ ក៏នឹងដល់នូវជរា ជ្រុះទៅយ៉ាងនោះ ដូច្នេះហើយ ផ្តើមវិបស្សនាដោយសាមញ្ញលក្ខណៈ មានអនិច្ចលក្ខណៈជាដើម សម្រេចបច្ចេកពោធិញ្ញាណហើយ ។ ក្នុងខណៈនោះ ឃរាវាសភេទរបស់កុមារនោះ ក៏អន្តរធានទៅ បព្វជិតភេទ ក៏បានប្រាកដជំនួស ។ **ព្រះបច្ចេកពុទ្ធ** អង្គនោះ កាលបន្លឺឧទាន ក៏បន្លឺឧទានថា **នត្ថិ ជាតិ បុនព្ភវោ** ឥឡូវនេះ ភពថ្មីរបស់អញ មិនមានទៀតឡើយ ដូច្នេះ ហើយទៅកាន់ញកភ្នំនន្ទមូលកៈ ។

ឯព្រះមហាសត្វ ទ្រង់រឭកដល់ព្រះបច្ចេកពុទ្ធនោះ បាន ដោយកាលកន្លងទៅប្រមាណ ៤០ ឆ្នាំ ទ្រង់រឭកដល់សោណកៈរឿយ ៗ ថា សោណកៈសម្លាញ់របស់អញទៅណាហ្ន៎ ។ ទ្រង់មិនបានដំណឹងដែលអ្នកណានឹងពោលថា ខ្ញុំបានឮដំណឹង ឬខ្ញុំបានឃើញឡើយ ។ ព្រះរាជាទ្រង់គង់លើព្រះរាជបល្ល័ង្ក ក្នុងផ្ទៃប្រាសាទដ៏ធំទូលាយ ដែលប្រដាប់តាក់តែងហើយ ជាបុគ្គលដែលពួកជនប្រគំ រាំ ច្រៀង ចោមរោមហើយ សោយរាជសម្បត្តិ ទ្រង់ព្រះតម្រិះថា បុគ្គលណាបានឮក្នុងសម្នាក់នៃបុគ្គលណាម្នាក់ ហើយប្រាប់ដល់យើងថា សោណកៈនៅក្នុងទីឈ្មោះនោះ ដូច្នេះ យើងនឹងឲ្យទ្រព្យ ១០០ ដល់បុគ្គលនោះ បុគ្គលណាឃើញ

ដោយខ្លួនឯង ហើយប្រាប់ដល់យើង យើងនឹងឲ្យទ្រព្យ ១ ពាន់ ដល់បុគ្គលនោះ ដូច្នេះហើយ ទ្រង់និពន្ធឧទានឡើងមួយបទ ។

កាលទ្រង់បន្លឺឧទានដោយទំនងបទចម្រៀង ទើបត្រាស់គាថាទី ១ ថា

**កស្ស សុត្វា សតំ ទម្មិ សហស្សំ ទិដ្ឋ សោណកំ**
**កោ មេ សោណកមក្ខាតិ សហាយំ បំសុកីឡិតំ ។**

អ្នកណាបានឮ អញនឹងឲ្យទ្រព្យមួយរយ អ្នកណាបានឃើញ
សោណកៈ អញនឹងឲ្យទ្រព្យមួយពាន់ អ្នកណានឹងប្រាប់អញ
នូវសោណកៈ ជាសម្លាញ់ដែលលេងដីជាមួយគ្នា ។

លំដាប់នោះ ស្រីរបាំម្នាក់ បានច្រៀងនូវគាថានោះ ហាក់ដូចគេទទួលយកអំពីព្រះឱស្ឋរបស់ព្រះរាជាដូច្នោះ ។ ស្រីដទៃ ៗ ក៏ច្រៀងចម្រៀងគាថានោះត ៗ គ្នាមកជាលំដាប់ រហូតដល់ស្រីស្នំទាំងអស់ក្នុងព្រះរាជវាំង ក៏បានច្រៀងបទនោះ ដោយនាំគ្នាគិតថា ជាបទចម្រៀងដែលព្រះរាជារបស់យើង ទ្រង់សព្វព្រះហឫទ័យដោយប្រការដូច្នេះ ។ សូម្បីអ្នកនគរនិងអ្នកជនបទ ក៏បាននាំគ្នាច្រៀងនូវចម្រៀងនោះ ដោយលំដាប់ដូចគ្នា ។ សូម្បីព្រះរាជា ក៏ទ្រង់ច្រៀងនូវចម្រៀងនោះរឿយ ៗ ដូចគ្នា ។ លុះកន្លងទៅ ៥០ ឆ្នាំ ព្រះរាជាអង្គនោះ ក៏មានព្រះរាជឱរស និងព្រះរាជធីតាច្រើន ព្រះរាជឱរសច្បងព្រះនាមថា ទីឃាវុកុមារ ។

គ្រានោះ ព្រះសោណកបច្ចេកពុទ្ធ គិតថា ព្រះបាទអរិន្ទមរាជប្រាថ្នានឹងឃើញអាត្មាអញ អញនឹងទៅសម្តែងនូវទោសក្នុងកាម និងអានិសង្សក្នុងការចេញបួស ហើយនឹងធ្វើឲ្យព្រះរាជាអង្គនោះ ទ្រង់ចេញបួស ដូច្នេះហើយ ទើបហោះមកតាមអាកាសដោយឫទ្ធិ ហើយគង់ក្នុងឧទ្យាន ។ ក្នុងកាលនោះ កុមារម្នាក់ដែលមានជុក ៥ អាយុ ៧ ឆ្នាំ ត្រូវម្តាយប្រើឲ្យរកឧសក្នុងព្រៃក្បែរឧទ្យាន ក៏ច្រៀងចម្រៀងនោះរឿយ ៗ ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធហៅកុមារនោះមក សួរថា នែកុមារ ហេតុអ្វី ទើបឯងមិនច្រៀងបទដទៃខ្លះ ច្រៀងតែបទដដែលប៉ុណ្ណោះ ឯងមិនចេះបទដទៃខ្លះទេឬ ។

កុមារនោះឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន បទដទៃ ក៏ចេះ តែបទនេះ ជាទីគាប់ព្រះហឫទ័យនៃព្រះរាជារបស់ខ្ញុំព្រះករុណា ព្រោះហេតុនោះ ទើបខ្ញុំព្រះករុណាច្រៀងនូវបទចម្រៀងនេះ រឿយ ៗ ។

ព្រះបច្ចេកពុទ្ធសួរថា ឯងធ្លាប់ឃើញបុគ្គលណាម្នាក់ ច្រៀងឆ្លើយតបនឹងបទចម្រៀងនេះ ខ្លះដែរឬទេ ។

កុមារនោះឆ្លើយថា មិនធ្លាប់ឃើញទេ លោកម្ចាស់ ។

ព្រះបច្ចេកពុទ្ធសួរថា អាត្មានឹងបង្រៀនឲ្យឯងរៀនច្រៀងនូវចម្លើយនោះ ឯងអាចទៅកាន់សម្នាក់របស់ព្រះរាជា ហើយច្រៀងឆ្លើយឆ្លងដែរឬទេ ។ កុមារនោះឆ្លើយថា អាច លោកម្ចាស់ ។

*លំដាប់នោះ ព្រះសោណកបច្ចេកពុទ្ធនោះ កាលបង្រៀនចម្រៀងសម្រាប់ឆ្លើយដល់កុមារនោះ ទើបពោលគាថាថា*

**មយ្ហំ សុត្វា សតំ ទេហិ សហស្សំ ទិដ្ឋ សោណកំ**
**អហំ តេ សោណកមក្ខិស្សំ សហាយំ បំសុកីឡិតំ ។**

*ទូលព្រះបង្គំជាខ្ញុំបានឮ សូមព្រះអង្គប្រទានទ្រព្យមួយរយ*
*ទូលព្រះបង្គំជាខ្ញុំបានឃើញសោណកៈ សូមព្រះអង្គប្រទាន*
*ទ្រព្យមួយពាន់ ទូលព្រះបង្គំជាខ្ញុំនឹងក្រាបទូលដល់ព្រះអង្គ នូវ*
*សោណកៈជាសម្លាញ់ ដែលលេងដីជាមួយគ្នា ។*

*កាលឲ្យរៀនហើយ ទើបបញ្ជូនកុមារនោះទៅដោយពាក្យថា នែកុមារ ចូរឯងទៅច្រៀងបទនេះ ឆ្លើយជាមួយនឹងព្រះរាជា ព្រះរាជានឹងប្រទានឥស្សរិយយសធំដល់ឯង ឯងត្រូវការអ្វីដោយឧស ចូរប្រញាប់ទៅចុះ ។*

*កុមារនោះទទួលថា សាធុ រៀននូវចម្រៀងសម្រាប់ឆ្លើយហើយថ្វាយបង្គំព្រះបច្ចេកពុទ្ធ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់នៅក្នុងទីនេះ ទម្រាំខ្ញុំនាំព្រះរាជាមក ដូច្នេះហើយ ប្រញាប់ទៅកាន់សម្នាក់មាតា ពោលថា បពិត្រអ្នកម៉ែ សូមម៉ែងូតទឹកឲ្យខ្ញុំ ហើយតែងខ្លួនខ្ញុំឲ្យរហ័ស ថ្ងៃនេះ ខ្ញុំនឹងជួយម៉ែឲ្យផុតអំពីភាពក្រីក្រ ។ កាលមាតាងូតទឹកតែងខ្លួនឲ្យហើយ ទើបទៅកាន់ទ្វារព្រះរាជវាំង ពោលថា*

បពិត្រលោកទ្វារបាល សូមលោកទៅក្រាបទូលព្រះរាជាថា មានកុមារម្នាក់ មកឈរចាំត្រង់ទ្វារព្រះរាជវាំង ពោលថា នឹងច្រៀងឆ្លើយឆ្លងជាមួយទ្រង់ ។ នាយទ្វារបាលប្រញាប់ទៅក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាត្រាស់ឲ្យហៅកុមារមកថា ឲ្យចូលមកចុះ ហើយត្រាស់ថា នែបាឯងនឹងច្រៀងឆ្លើយឆ្លងជាមួយយើងឬ ។

កុមារនោះក្រាបទូលថា ព្រះករុណាថ្លៃវិសេស ។

ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរច្រៀងចុះ ។ កុមារនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំមិនច្រៀងក្នុងទីនេះទេ សូមទ្រង់ឲ្យពួករាជបុរសវាយស្គរប្រកាសក្នុងនគរ ហើយឲ្យមហាជនប្រជុំគ្នា ទូលព្រះបង្គំនឹងច្រៀងក្នុងកណ្ដាលមហាជន ។ ព្រះរាជាឲ្យធ្វើតាមអ្វីដែលកុមារនោះពោល ទ្រង់ប្រថាប់គង់កណ្ដាលរាជបល្ល័ង្ក ក្នុងមណ្ឌបដែលគេតាក់តែងហើយ ឲ្យអាសនៈដែលសមគួរដល់កុមារនោះ ហើយត្រាស់ថា ឥឡូវនេះ ឯងអាចច្រៀងចម្រៀងរបស់ឯងបានហើយ ។

កុមារនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ច្រៀងមុន ទូលព្រះបង្គំនឹងច្រៀងតប ។ គ្រានោះ ព្រះរាជា កាលទ្រង់ច្រៀងមុន ទើបត្រាស់ថា

កស្ស សុត្វា សតំ ទម្មិ សហស្សំ ទិដ្ឋ សោណកំ
កោ មេ សោណកមក្ខាតិ សហាយំ បំសុកីឡិតំ ។

អ្នកណាបានឮ អញនឹងឲ្យទ្រព្យមួយរយ អ្នកណាបានឃើញ
សោណក: អញនឹងឲ្យទ្រព្យមួយពាន់ អ្នកណានឹងប្រាប់អញ
នូវសោណក:ជាសម្លាញ់ ដែលលេងដីជាមួយគ្នា ។

កាលព្រះរាជាទ្រង់ច្រៀងឧទានគាថាទី ១ យ៉ាងនេះហើយ ព្រះសាស្តា កាលទ្រង់ត្រាស់ដឹងឯងដោយចំពោះ ទ្រង់ប្រកាសគាថាដែលកុមារមានជុក ៥ ច្រៀងតប ទើបត្រាស់ ១ គាថាកន្លះថា

**អថ ព្រវិ មាណវកោ ទហរោ បញ្ចចូឡកោ**
**មយ្ហំ សុត្វា សតំ ទេហិ សហស្សំ ទិដ្ឋ សោណកំ**
**អហំ តេ សោណកមក្ខិស្សំ សហាយំ បំសុកីឡិតំ ។**

គ្រានោះ មាណពក្មេង មានជុក ៥ បានក្រាបបង្គំទូលថា
ទូលព្រះបង្គំជាខ្ញុំ បានឮ សូមព្រះអង្គប្រទានទ្រព្យមួយរយ
ទូលព្រះបង្គំជាខ្ញុំ បានឃើញសោណក: សូមព្រះអង្គប្រទាន
ទ្រព្យមួយពាន់ ទូលព្រះបង្គំជាខ្ញុំ នឹងក្រាបទូលដល់ព្រះអង្គ
នូវសោណក:ជាសម្លាញ់ ដែលលេងដីជាមួយគ្នា ។

អត្ថនៃគាថាដែលកុមារនោះពោលហើយ មានអធិប្បាយដូចតទៅនេះថា បពិត្រមហារាជ ទ្រង់ត្រាស់ថា យើងនឹងឲ្យទ្រព្យ ១០០ ដល់អ្នកដែលបានឮដំណឹងនោះ ហើយមកប្រាប់ដល់យើង ដូច្នេះ សូមទ្រង់ព្រះរាជទានទ្រព្យនោះ ដល់ទូលព្រះបង្គំ ម្យ៉ាងទៀត ទ្រង់ត្រាស់ថា

យើងនឹងឲ្យទ្រព្យ ១ ពាន់ ដល់អ្នកដែលឃើញហើយមកប្រាប់ ដូច្នេះ សូមទ្រង់ប្រទានទ្រព្យនោះ ដល់ទូលព្រះបង្គំ ព្រោះទូលព្រះបង្គំឃើញសម្លាញ់ជាទីស្រឡាញ់របស់ទ្រង់ ទើបបានក្រាបទូលទ្រង់ថា ឥឡូវនេះ ទូលព្រះបង្គំបានឃើញសោណកៈនោះហើយ ។

តអំពីគាថានេះទៅ ជាគាថារបស់ព្រះសម្ពុទ្ធ ងាយយល់ហើយ បណ្ឌិតគប្បីជ្រាបតាមន័យព្រះបាលីនោះឯង ដែលមានដូចតទៅនេះថា

ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យនោះ ហើយត្រាស់សួរថា

**កតរស្មឹ សោ ជនបទេ រដ្ឋេសុ និគមេសុ ច**
**កត្ថ សោណកមទ្ទក្ខិ តំ មេ អក្ខាហិ បុច្ឆិតោ ។**

សោណកៈនោះ នៅក្នុងជនបទណា ក្នុងដែនណា ក្នុងនិគមណា ឯងបានឃើញសោណកៈក្នុងទីណា អញសួរហើយ ឯងចូរប្រាប់ពីសោណកៈនោះ ។

កុមារនោះ ក្រាបទូលថា

**តវេវ ទេវ វិជិតេ តវេវុយ្យានភូមិយា**
**ឧជុវំសា មហាសាលា នីលោភាសា មនោរមា ។**

បពិត្រព្រះសម្មតិទេព ត្រង់ទីឧទ្យានរបស់ព្រះអង្គ ក្នុងដែនរបស់ព្រះអង្គហ្នឹងឯង មានពួកឈើធំ មានដើមត្រង់ មានពន្លឺខៀវ ជាតម្រេកនៃចិត្ត ។

តិដ្ឋន្តិ មេឃសមានា រម្មា អញ្ញោញ្ញនិស្សិតា
តេសំ មូលស្មិ សោណកោ ឈាយតី អនុបាទិនោ
ឧបាទានេសុ លោកេសុ ឌយ្ហមានេសុ និព្វុតោ ។

*ពួកឈើទាំងនោះ មានពណ៌ដូចផ្ទៃមេឃ គួរឲ្យត្រេកអរ ដុះទាក់ទងគ្នាទៅវិញទៅមក កាលពួកសត្វលោកមានគ្រឿងឆេះកំពុងត្រូវភ្លើងឆេះ សោណកៈមិនមានគ្រឿងឆេះ ជាបុគ្គលរលត់ហើយ កំពុងចម្រើនឈានជិតគល់ឈើទាំងនោះ ។*

*ព្រះសាស្តា កាលទ្រង់ត្រាស់ដឹងហើយ ទើបត្រាស់អភិសម្ពុទ្ធគាថាទាំងនេះថា*

តតោ ច រាជា បាយាសិ សេនាយ ចតុរង្គិយា
ការាបេត្វា សមំ មគ្គំ អគមា យេន សោណកោ ។

*លំដាប់នោះ ព្រះរាជាទ្រង់ប្រើបម្រើឲ្យចាត់ចែងធ្វើផ្លូវរាបស្មើយាងចេញទៅដោយសេនាមានអង្គ ៤ សំដៅទៅត្រង់កន្លែងដែលព្រះបច្ចេកពុទ្ធ ព្រះនាមសោណកៈគង់នៅ ។*

ឧយ្យានភូមឹ គន្ត្វាន វិចរន្តោ ព្រហាវនេ
អាសីនំ សោណកំ ទក្ខិ ឌយ្ហមានេសុ និព្វុតំ ។

*លុះព្រះរាជាទ្រង់យាងទៅដល់ទីឧទ្យានហើយ ទ្រង់ត្រាច់ទៅក្នុងព្រៃធំ បានទតឃើញព្រះសោណកបច្ចេកពុទ្ធ កាលដែល*

ពួកសត្វលោកកំពុងត្រូវភ្លើងឆេះ លោកជាបុគ្គលរលត់ គង់នៅហើយ ។

ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះបាទអរិន្ទមៈគ្រាន់តែបានស្តាប់ពាក្យរបស់កុមារនោះហើយ ទ្រង់ព្រះតម្រិះថា អញនឹងឃើញនូវសោណកបច្ចេកពុទ្ធ ដូច្នេះ ហើយចេញទៅមួយអន្លើដោយចតុរង្គសេនាយាងមកតាមផ្លូវត្រង់នោះឯង ត្រាច់ទៅក្នុងដងព្រៃធំនោះ ដល់សម្នាក់របស់ព្រះសោណកៈ បានទតឃើញលោកកំពុងគង់ ។

ព្រះរាជាទ្រង់មិនថ្វាយបង្គំព្រះសោណកបច្ចេកពុទ្ធ ប្រថាប់គង់ក្នុងទីសមគួរ កាលទ្រង់សម្គាល់នូវព្រះសោណកៈនោះថា ជាអ្នកកម្សត់កំព្រា ព្រោះទ្រង់ត្រេកអរក្នុងកិលេសរបស់ខ្លួន ទើបត្រាស់គាថានេះថា

**កបណោ វតាយំ ភិក្ខុ មុណ្ឌោ សង្ឃាដិបារុតោ**
**អមាតិកោ អបីតិកោ រុក្ខមូលស្មិំ ឈាយតិ ។**

ភិក្ខុត្រងោលដណ្តប់សង្ឃាដិ មិនមានម៉ែ មិនមានឪនេះ កំព្រាណាស់តើ ស្ងួតស្ងប់ជិតគល់ឈើ ។

ព្រះសាស្តា កាលទ្រង់ត្រាស់ដឹងហើយ ទើបត្រាស់អភិសម្ពុទ្ធគាថាថា

**ឥមំ វាក្យំ និសាមេត្វា សោណកោ ឯតទព្រវិ**
**ន រាជ កបណោ ហោតិ ធម្មំ កាយេន ផស្សយំ ។**

ព្រះសោណកបច្ចេកពុទ្ធស្តាប់ព្រះបន្ទូលនេះហើយ បានថ្វាយព្រះពរយ៉ាងនេះថា បពិត្រព្រះរាជា បុគ្គលដែលពាល់ត្រូវនូវធម៌ដោយកាយ មិនមែនឈ្មោះថា កំព្រាទេ ។

**យោធ ធម្មំ និរង្កត្វា អធម្មំ អនុវត្តតិ**
**ស រាជ កបណោ ហោតិ ចាចោ ចាបបរាយណោ ។**

បុគ្គលណា ក្នុងលោកនេះ លះធម៌ចោលហើយ ប្រព្រឹត្តតាមអធម៌វិញ បពិត្រព្រះរាជា បុគ្គលនោះ ទើបឈ្មោះថា កំព្រា ជាបុគ្គលអាក្រក់ មានបាបជាទីទៅខាងមុខ ។

ព្រះសោណកៈនោះ តិះដៀលព្រះពោធិសត្វដោយពាក្យដូច្នេះ ។ ព្រះពោធិសត្វទ្រង់ធ្វើដូចជាមិនជ្រាបថា ព្រះសោណកៈតិះដៀលទ្រង់ ទ្រង់ប្រាប់ឈ្មោះ និងគោត្តរបស់ទ្រង់ កាលនឹងធ្វើបដិសណ្ឋារៈជាមួយនឹងព្រះសោណកៈនោះ ទើបត្រាស់ថា

**អរិន្ទមោតិ មេ ធាមំ កាសិរាជាតិ មំ វិទូ**
**កច្ចិ ភោតោ សុខសេយ្យា ឥធ បត្តស្ស សោណក ។**

ខ្ញុំឈ្មោះអរិន្ទមៈ អ្នកផងស្គាល់ខ្ញុំថា កាសិរាជ បពិត្រព្រះសោណកៈ លោកដ៏ចម្រើនមកដល់ក្នុងទីនេះ សិងនៅជាសុខទេឬ ។

លំដាប់នោះ ព្រះសោណកបច្ចេកពុទ្ធពោលតបព្រះរាជាថា សូម

*ថ្វាយព្រះពរមហារាជ ឈ្មោះថា ការដេកមិនសុខស្រួល រមែងមិនមាន ដល់អាត្មាដែលនៅក្នុងឧទ្យាននេះប៉ុណ្ណោះ ក៏ទេ ទោះបីអាត្មានៅក្នុងទីដទៃ ៗ ក៏ដូចគ្នា ហើយផ្ដើមគាថា សម្ដែងសេចក្ដីចម្រើនរបស់សមណៈ ថ្វាយព្រះរាជាអង្គនោះថា*

សធាបិ ភទ្រមធនស្ស អនាគារស្ស ភិក្ខុនោ
ន តេសំ កោដ្ឋេ ឱបេន្តិ ន កុម្ភេ ន កឡោបិយា
បរនិដ្ឋិតមេសានា តេន យាបេន្តិ សុព្វតា ។

*សេចក្ដីចម្រើន ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះសព្វកាល គឺ ( ទ្រព្យនិងធញ្ញជាតិទាំងឡាយ ) របស់ភិក្ខុទាំងនោះ លែងចូលទៅក្នុងជង្រុក លែងចូលទៅក្នុងឆ្នាំង លែងចូលទៅក្នុងកញ្ជ្រែងទៀតហើយ លោកមានវត្តល្អ មានការស្វែងរកសម្រេចហើយ រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះ ។*

ទុតិយម្បិ ភទ្រមធនស្ស អនាគារស្ស ភិក្ខុនោ
អនវជ្ជបិណ្ឌោ ភោតព្វោ ន ច កោចូបរោធតិ ។

*សេចក្ដីចម្រើនទី ២ ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺបរិភោគដុំបាយដែលមិនមានទោស កិលេសណាមួយ បៀតបៀនមិនបានទេ ។*

តតិយម្បិ ភទ្រមេតស្ស អនាគារស្ស ភិក្ខុនោ
និព្ពុតោ បិណ្ឌោ ភោតព្វោ ន ច កោចូបរោធតិ ។

*សេចក្តីចម្រើនទី ៣ ( តែងមាន ) ដល់ភិក្ខុ មិនមានទ្រព្យ មិនមានផ្ទះ គឺឆាន់ដុំបាយដ៏ត្រជាក់ ( មិនជាចេយ្យបរិភោគជាដើម ) កិលេសណាមួយ បៀតបៀនមិនបានទេ ។*

ចតុត្ថម្បិ ភទ្រមេតស្ស អនាគារស្ស ភិក្ខុនោ
មុត្តស្ស រដ្ឋេ ចរតោ សង្គោ យស្ស ន វិជ្ជតិ ។

*សេចក្តីចម្រើនទី ៤ ( តែងមាន ) ដល់ភិក្ខុ មិនមានទ្រព្យ មិនមានផ្ទះ គឺសេចក្តីជាប់ចំពាក់ មិនមានដល់ភិក្ខុដែលផុតស្រឡះ ( ចាកត្រកូល ) ត្រាច់ទៅក្នុងដែន ។*

បញ្ចមម្បិ ភទ្រមេតស្ស អនាគារស្ស ភិក្ខុនោ
នគរម្ហិ ឌយ្ហមានម្ហិ នាស្ស កិញ្ចិ អឌយ្ហថ ។

*សេចក្តីចម្រើនទី ៥ ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺកាលបើនគរកំពុងត្រូវភ្លើងឆេះ វត្ថុបន្តិចបន្តួចរបស់ភិក្ខុនោះ ភ្លើងមិនឆេះទេ ។*

ឆដ្ឋម្បិ ភទ្រមេតស្ស អនាគារស្ស ភិក្ខុនោ
រដ្ឋេ វិលុម្បមានម្ហិ នាស្ស កិញ្ចិ អហារថ ។

*សេចក្តីចម្រើនទី ៦ ( តែងមាន ) ដល់ភិក្ខុ មិនមានទ្រព្យ*

មិនមានផ្ទះ កាលបើដែនកំពុងត្រូវចោរប្លន់ វត្ថុបន្តិចបន្តួចរបស់ភិក្ខុនោះ ចោរមិនលួចទេ ។

**សត្តមម្បិ ភទ្រមធនស្ស អនាគារស្ស ភិក្ខុនោ**
**ចោរេហិ រក្ខិតំ មគ្គំ យេ ចញ្ញេ បរិបន្ថិកា**
**បត្តចីវរមាទាយ សោត្ថឹ គច្ឆតិ សុព្វតោ ។**

សេចក្តីចម្រើនទី ៧ (តែងមាន) ដល់ភិក្ខុ មិនមានទ្រព្យ មិនមានផ្ទះ គឺភិក្ខុមានវត្តល្អ នាំយកបាត្រនិងចីវរដើរទៅកាន់ផ្លូវដែលពួកចោរ និងពួកគយដទៃ រក្សាដោយស្រួល ។

**អដ្ឋមម្បិ ភទ្រមធនស្ស អនាគារស្ស ភិក្ខុនោ**
**យំ យំ ទិសំ បក្កមតិ អនបេក្ខោវ គច្ឆតិ ។**

សេចក្តីចម្រើនទី ៨ (តែងមាន) ដល់ភិក្ខុ មិនមានទ្រព្យ មិនមានផ្ទះ គឺភិក្ខុនោះ ដើរទៅកាន់ទិសណា ៗ ទៅបានដោយមិនមានទឹកនា ។

ព្រះសោណកបច្ចេកពុទ្ធ សម្តែងសេចក្តីចម្រើននៃសមណៈ ៨ យ៉ាង ដោយប្រការដូច្នេះ ។ តែសេចក្តីពិត លោកជាអ្នកអាចបង្ហាញសេចក្តីចម្រើននៃសមណៈឲ្យក្រៃលែងជាងនោះ បានរាប់រយ រាប់ពាន់ រហូតប្រមាណមិនបាន តែព្រះរាជាទ្រង់កាត់ពាក្យរបស់ព្រះសោណកៈនោះ ព្រោះទ្រង់ត្រេកអរក្រៃលែងក្នុងកាម ទើបត្រាស់ថា ខ្ញុំមិនត្រូវការ

សេចក្ដីចម្រើននៃសមណៈ ។

កាលទ្រង់ប្រកាសភាពដែលទ្រង់បង្អោនព្រះទ័យទៅក្នុងកាម ទើបត្រាស់ថា

**ពហូបិ ភទ្រា ឯតេសំ យោ ត្វំ ភិក្ខុ បសំសសិ**
**អហញ្ច គិទ្ធោ កាមេសុ កថំ កាហាមិ សោណក ។**

បពិត្រភិក្ខុ លោកសរសើរនូវសេចក្ដីចម្រើនរបស់ភិក្ខុទាំងនោះច្រើនមែន បពិត្រព្រះសោណកៈ តែខ្ញុំជក់ចិត្តក្នុងកាមទាំងឡាយ តើនឹងធ្វើយ៉ាងណា ។

**បិយា មេ មានុសា កាមា អថោ ទិព្យាបិ មេ បិយា**
**អថ កេន នុ វណ្ណេន ឧភោ លោកេ លភាមសេ ។**

កាមទាំងឡាយជារបស់មនុស្ស ជាទីស្រឡាញ់របស់ខ្ញុំ មួយទៀត កាមជាទិព្វ ក៏ជាទីស្រឡាញ់របស់ខ្ញុំ បើដូច្នេះ តើយើងនឹងបាននូវកាមទាំងពីរក្នុងលោក ដោយហេតុដូចម្ដេច ។

លំដាប់នោះ ព្រះបច្ចេកពុទ្ធក៏ពោលតបទៅព្រះរាជានោះថា

**កាមេ គិទ្ធា កាមរតា កាមេសុ អធិមុច្ឆិតា**
**នរា បាបានិ កត្វាន ឧបបជ្ជន្តិ ទុគ្គតឹ ។**

ពួកជនអ្នកជក់ចិត្តក្នុងកាម ត្រេកអរក្នុងកាម ងប់ក្នុងកាម រមែងធ្វើបាបទាំងឡាយ ហើយទៅកាន់ទុគ្គតិ ។

យេ ច កាមេ បហន្ត្វាន និក្ខន្តា អកុតោភយា
ឯកោទិភាវាធិគតា ន តេ គច្ឆន្តិ ទុគ្គតឹ ។

*ចំណែកពួកជនណា លះបង់កាមហើយចេញទៅ មិនមានភ័យអំពីកិលេសណាមួយ បាននូវភាពជាបុគ្គលឯក ពួកជននោះ មិនទៅកាន់ទុគ្គតិ ។*

ឧបមន្តេ ករិស្សាមិ តំ សុណោហិ អរិន្ទម
ឧបមាយ មិធេកច្ចេ អត្ថំ ជានន្តិ បណ្ឌិតា ។

*បពិត្រព្រះអរិន្ទមៈ អាត្មាភាពនឹងធ្វើសេចក្តីឧបមាថ្វាយព្រះអង្គ សូមព្រះអង្គទ្រង់ព្រះសណ្តាប់សេចក្តីឧបមានោះ ព្រោះពួកបណ្ឌិតខ្លះក្នុងលោកនេះ តែងយល់សេចក្តីដោយសារឧបមា ។*

គង្គាយ កុណបំ ទិស្វា វុយ្ហមានំ មហណ្ណវេ
វាយសោ សមចិន្តេសិ អប្បបញ្ញោ អចេតសោ ។
យានញ្ច វតិទំ លទ្ធំ ភក្ខោ ចាយំ អនប្បកោ
តត្ថ រត្តឹ តត្ថ ទិវា តត្ថេវ និរតោ មនោ ។

*ក្អែកឥតប្រាជ្ញា ឥតសេចក្តីគ្នេរគ្នាន់ ឃើញសាកសព ( ដំរី ) កំពុងអណ្តែតតាមទន្លេគង្គាទៅក្នុងសមុទ្រហើយ គិតថា អៃយ៉ា ! អញបានយាននេះហើយផង ដំរីនេះ នឹងបានជាចំណីអញយ៉ាងច្រើនផង ចិត្តរបស់ក្អែកនោះ ក៏ត្រេកអរក្នុង*

*ដំរីនោះ ទាំងថ្ងៃទាំងយប់ ។*

ខាទំ គជកុណបំ មំសានិ បិវំ ភាគីរសោទកំ
សម្បស្សំ វនចេត្យានិ ន បលេត្ថ វិហង្គមោ ។

*ក្អែកចឹកស៊ីសាច់ដំរី ផឹកទឹកទន្លេគង្គា ឃើញព្រៃដែលគេសន្មតថា ចេតិយ ក៏មិនហើរទៅ ។*

តញ្ច ឱតរណី គង្គា បមត្តំ កុណបេ រតំ
សមុទ្ទំ អជ្ឈគាហាសិ អគតី យត្ថ បក្ខិនំ ។

*ទន្លេគង្គាហូរទៅ បាននាំក្អែកនោះ ដែលប្រហែសធ្វេសត្រេកអរក្នុងសាកសព ទៅកាន់សមុទ្ទ ដែលមិនមែនជាទីទៅនៃបក្សី ។*

សោ ច ភក្ខបរិក្ខីណោ ឧបត្វា វិហង្គមោ
ន បច្ឆតោ ន បុរតោ នុត្តរំ នោបិ ទក្ខិណំ ។

*សត្វហើរនោះ អស់ចំណីរលីងហើយ ក៏ហើរឡើងទៅទិសខាងលិចមិនរួច ទៅទិសខាងកើតមិនរួច ទៅទិសខាងជើងមិនរួច ទៅទិសខាងត្បូងមិនរួច ។*

ទីបំ សោ នជ្ឈគាគញ្ឆិ អគតី យត្ថ បក្ខិនំ
សោ ច តត្ថេវ បាបត្ថ យថា ទុព្វលកោ តថា ។

*ក្អែកនោះ ទៅកាន់សមុទ្ទដែលមិនមែនជាទីទៅនៃពួកបក្សី ក៏*

*មិនបាននូវទីពឹង ធ្លាក់ទៅក្នុងសមុទ្រនោះឯង ដូចជាបុគ្គលមានកម្លាំងថយ ។*

**តញ្ច សាមុទ្ទិកា មច្ឆា កុម្ភីលា មករា សុសូ**
**បសយ្ហការា ខាទន្តិ ផន្ទមានំ វិបក្ខិកំ ។**

*ពួកត្រី ក្រពើ មករ ឆ្លាម ដែលកើតក្នុងសមុទ្រ កំហែងខាំក្អែកនោះ ដែលមានស្លាបរបោចហើយ កំពុងបម្រះ ( យ៉ាងណាមិញ ) ។*

**ឯវមេវ តុវំ រាជ យេ ចញ្ញេ កាមភោគិនោ**
**គិទ្ធា ចេ ន វមិស្សន្តិ កាកបញ្ញាយ តេ វិទូ ។**

*បពិត្រព្រះរាជា ព្រះអង្គនិងពួកជនដទៃ អ្នកបរិភោគកាម ក៏យ៉ាងនោះដែរ បើពួកជនដែលជក់ចិត្តហើយ មិនខ្ជាក់ ( កាម ) ចោលចេញទេ បណ្ឌិតទាំងឡាយ ( ស្គាល់ ) ពួកជននោះ ( ថា មានប្រាជ្ញាស្មើ ) ដោយប្រាជ្ញារបស់ក្អែក ។*

**ឯសា តេ ឧបមា រាជ អត្ថសន្ទស្សនី កតា**
**ត្វញ្ច បញ្ញាយសេ តេន យទិ កាហសិ វា ន វា ។**

*បពិត្រព្រះរាជា ឧបមាជាគ្រឿងបំភ្លឺនូវសេចក្ដីនេះ អាត្មាភាពបានធ្វើថ្វាយព្រះអង្គហើយ បើព្រះអង្គធ្វើ ឬមិនធ្វើ ព្រះអង្គនឹងប្រាកដតាមហេតុនោះ ។*

បពិត្រមហារាជ អាត្មានឹងធ្វើការប្រៀបធៀបហេតុមួយថ្វាយដល់ទ្រង់ ដែលមានសេចក្តីប្រាថ្នាក្នុងកាមដែលជាទិព្វ និងជារបស់មនុស្សដែលមិនផ្សេងអំពីក្អែក ដែលមានចិត្តជាប់ចំពាក់ក្នុងសាកសពដំរីដូច្នោះ សូមទ្រង់ស្តាប់ឧបមានោះចុះ ។ បានឮថា មានដំរីធំមួយត្រាច់ទៅតាមមាត់ច្រាំងនៃស្ទឹងគង្គា ធ្លាក់ចុះក្នុងស្ទឹងគង្គាមិនអាចឡើងបាន ត្រូវក្រសែទឹកបោកពន្ទិច ងាប់ក្នុងស្ទឹងនោះឯង ។ មានក្អែកមួយ ហើរមកតាមអាកាស ។ ក្អែកនោះ កាលឃើញសាកសពដំរីនោះហើយ ទើបទំត្រង់សាកសពដំរីនោះ បានធ្វើការសម្រេចចិត្តថា អញបានយាន គឺដំរីនេះហើយ អញនឹងទំលើយាន គឺដំរីនេះ នឹងត្រាច់ទៅយ៉ាងសប្បាយ ។ ម្យ៉ាងទៀត ដំរីនេះឯង ក៏ជាអាហារបានយ៉ាងច្រើន ឥឡូវនេះ អញមិនគួរទៅក្នុងទីដទៃ ។ ក្អែកនោះ មានចិត្តត្រេកអរក្រៃលែងក្នុងសាកសពដំរីនោះឯង អស់យប់និងថ្ងៃ ។ ក្អែកនោះ មិនហើរចៀសចេញទៅឡើយ ។

ស្ទឹងគង្គានោះ មានប្រក្រតីហូរទៅកាន់សមុទ្ទ ។ កាលស្បែកនិងសាច់របស់ដំរីនោះ អស់ទៅហើយ គ្រោងឆ្អឹងក៏ត្រូវកម្លាំងរលកបក់បោកលិចចុះក្នុងទឹក ។ លំដាប់នោះ ក្អែកនោះ កាលមិនអាចនៅក្នុងទឹកបាន ទើបហើរឡើងទៅកាន់ទិសខាងលិច កាលមិនបានទីសម្រាប់ទំក្នុងទីនោះ ហើរអំពីទិសខាងលិចនោះ ទៅកាន់ទិសខាងកើត ហើរអំពីទិសខាងកើត ទៅកាន់ទិសខាងជើង ហើរអំពីទិសខាងជើង ទៅកាន់ទិសខាងត្បូង ហើរ

ទៅកាន់ទិសទាំង ៤ ដោយអាការយ៉ាងនេះ ក៏មិនដល់ទីសម្រាប់ទំរបស់ខ្លួនកណ្ដាលសមុទ្ទ ដែលជាទីទៅមិនដល់នៃពួកបក្សីទាំងឡាយ ។ កាលក្អែកទៅយ៉ាងនេះហើយ បានហើរទៅក្នុងទិសនីមួយ ៗ បណ្ដាទិសទាំងឡាយ មានទិសខាងលិចជាដើម តែហើរទៅមិនដល់កោះ ក៏ធ្លាក់ ហើយលិចចុះ ដូចមនុស្សដែលអស់កម្លាំងលិចចុះដូច្នោះ ។ ពួកត្រីកាច មានត្រីឈ្មោះសុសុ (ឆ្លាម) ជាដើម ត្របាក់ស៊ីក្អែកនោះ ដែលមានរោមស្លាបវិនាសប្រើការមិនបាន ទាំងក្អែកមិនប្រាថ្នានោះឯង ដោយកម្លាំង ។

មហាបពិត្រ អាត្មាជាអ្នកប្រាថ្នាប្រយោជន៍ ទើបបានថ្វាយឱវាទដល់ទ្រង់ បើទ្រង់ធ្វើតាមឱវាទនោះសោត ទ្រង់ក៏នឹងកើតក្នុងទេវលោក បើទ្រង់មិនធ្វើតាមឱវាទនោះ ទ្រង់នឹងលិចចុះក្នុងភក់គឺកាម ក្នុងកាលអស់ព្រះជន្ម នឹងទៅកើតក្នុងនរក ព្រះអង្គឯង ទ្រង់នឹងជ្រាបស្ថានសួគ៌ ឬនរកដោយហេតុយ៉ាងនេះ ឯអាត្មារួចផុតហើយចាកភពទាំងពួង មិនបដិសន្ធិទៀតឡើយ ។

ព្រះបច្ចេកពុទ្ធថ្វាយឱវាទនេះ ដល់ព្រះរាជាអង្គនោះ បានសម្ដែងដល់ស្ទឹង ហើយសម្ដែងដល់សាកសពដំរី ដែលត្រូវទឹកហូរបន្សាត់ទៅក្នុងស្ទឹងគង្គា សម្ដែងដល់ក្អែកដែលស៊ីសាកសព សម្ដែងដល់ការដែលចឹកស៊ីសាកសព ហើយផឹកទឹករបស់ក្អែកនោះ សម្ដែងដល់ការដែល

សម្លឹងមើលដងព្រៃ ដែលគួរត្រេកអរ សម្ដែងដល់ការចូលទៅកាន់សមុទ្ទរបស់សាកសពដែលអណ្ដែតក្នុងស្ទឹង សម្ដែងដល់ការដែលក្អែកមិនបានទីទំអាស្រ័យលើសាកសពដំរី ហើយដល់នូវការវិនាសកណ្ដាលសមុទ្ទរបស់ក្អែក ។

បណ្ដាវត្ថុទាំងនោះ បណ្ឌិតគប្បីឃើញថា សំសារៈដែលមិនមានខាងដើមនិងខាងចុង ប្រៀបដូចជាស្ទឹង ។ កាមគុណ ៥ ក្នុងសំសារៈប្រៀបដូចសាកសពដំរីដែលអណ្ដែតក្នុងស្ទឹង ។ បុថុជ្ជនដែលជាបុគ្គលពាល ប្រៀបដូចក្អែក ។ កាលនៃបុថុជ្ជនដែលបរិភោគកាមគុណហើយប្រកបដោយសោមនស្ស ប្រៀបដូចកាលដែលក្អែកចឹកស៊ីសាកសពហើយផឹកទឹក ។ ការឃើញអារម្មណ៍ ៣៨ ប្រការ ដោយអំណាចការស្ដាប់របស់បុថុជ្ជន ដែលជាប់ចំពាក់ក្នុងកាមគុណទាំងឡាយ ប្រៀបដូចការឃើញដងព្រៃ ដែលគួរជាទីត្រេកអររបស់ក្អែក ដែលជាប់ចំពាក់ក្នុងសាកសពដំរីនោះ ។ បុគ្គលជាបណ្ឌិត ឃើញការដល់នូវសេចក្ដីវិនាសធំ ក្នុងមហានរករបស់បុថុជ្ជន ដែលជាបុគ្គលពាល ជាអ្នកត្រេកអរក្នុងកាមគុណ មានអំពើអាក្រក់ជាទីទៅខាងមុខ មិនអាចបានទីអាស្រ័យក្នុងកុសលធម៌ថា ប្រៀបដូចកាលដែលក្អែកមិនអាចរកទីទំអាស្រ័យបាន ក៏ដល់នូវសេចក្ដីវិនាស ក្នុងកាលដែលសាកសព ( ហូរ ) ទៅកាន់សមុទ្ទដូច្នោះ ។

ព្រះបច្ចេកពុទ្ធថ្វាយឱវាទដល់ព្រះរាជាអង្គនោះ ដោយឧបមានេះយ៉ាងនេះហើយ ឥឡូវនេះ បំណងនឹងធ្វើឱវាទនោះឯងឲ្យតាំងនៅយ៉ាងមាំទាំ ទើបពោលគាថានេះថា

**ឯកវាចំបិ ទ្វិវាចំ ភណេយ្យ អនុកម្បកោ**
**តតុត្តរឹ ន ភាសេយ្យ ទាសោវយ្យស្ស សន្តិកេ ។**

បុគ្គលអ្នកឈឺឆ្អាល គប្បីនិយាយត្រឹមតែមួយម៉ាត់ ឬពីរម៉ាត់ មិនគប្បីនិយាយឲ្យលើសហួសពីនោះទៅ ដូចទាសៈនិយាយក្នុងសម្នាក់នៃម្ចាស់ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

**ឥទំ វត្វាន បក្កាមិ សោណកោ អមិតពុទ្ធិមា**
**វេហាសេ អន្តលិក្ខស្មឹ អនុសាសិត្វាន ខត្តិយំ ។**

លុះព្រះសោណកបច្ចេកពុទ្ធ មានប្រាជ្ញារាប់មិនបាន ពោលពាក្យនេះ ប្រៀនប្រដៅក្សត្រិយ៍ហើយ ទើបចៀសចេញទៅឰដ៏អាកាសវេហាស៍ ។

ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកពុទ្ធនោះ ជាអ្នកមានបញ្ញា ដែលបុគ្គលរាប់មិនបាន ដោយបញ្ញាជាគ្រឿងត្រាស់ដឹង ដែលជាលោកុត្តរ ដែលបុគ្គលណាមួយរាប់មិនបាន លុះពោលពាក្យនេះហើយ ក៏ហោះទៅដោយឫទ្ធិ ទូន្មានបរមក្សត្រយ៉ាងនេះថា បើទ្រង់បួស ក៏ជារឿងរបស់ទ្រង់

នោះឯង ឬបើទ្រង់មិនបួស ក៏ជារឿងរបស់ទ្រង់ដូចគ្នា អាត្មាភាពថ្វាយឱវាទដល់ទ្រង់ហើយ សូមទ្រង់កុំប្រមាទ ដូច្នេះហើយ ក៏ចៀសចេញទៅ ។

ចំណែកព្រះពោធិសត្វប្រថាប់ឈរ ទតមើលព្រះបច្ចេកពុទ្ធដែលទៅតាមអាកាសដែលអាចឃើញបាន កាលផុតកន្ទុយភ្នែកហើយ ក៏បាននូវសេចក្ដីសង្វេគ ទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍នេះ មានជាតិថោកថយហោះទៅក្នុងអាកាស រោយនូវធូលីដែលជាប់នឹងជើង លើអំបែងក្បាលរបស់អញ ដែលកើតក្នុងត្រកូលស្ដេច មិនច្រឡូកច្រឡំដោយវង្សដទៃសូម្បីអញ ក៏គួរចេញបួសក្នុងថ្ងៃនេះឯង ។ ព្រះពោធិសត្វទ្រង់ប្រាថ្នាប្រគល់រាជសម្បត្តិ ហើយទ្រង់ព្រះផ្នួស ទើបពោលគាថា ២ ថា

កោ ឥមេ រាជកត្តារោ សុតា វេយ្យត្តិមាគតា
រដ្ឋំ និយ្យាទយិស្សាមិ ជាហំ រដ្ឋេន មត្ថិកោ ។

ពួកជនអ្នករៀបចំអភិសេកបុគ្គលដែលគួរដល់រាជ្យ ជាអ្នកបង្កក់ប្រសិទ្ធនេះ ចាំស្ដាត់ នៅក្នុងទីណា អញនឹងប្រគល់រាជ្យឲ្យ អញមិនត្រូវការដោយរាជ្យទេ ។

អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ
ជាហំ កាកោវ ទុម្មេធោ កាមានំ វសមន្វគា ។

អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែក អញលែងលុះក្នុងអំណាចនៃកាម

ទាំងឡាយ ដូចជាក្អែកឆោតហើយ ។

កាលព្រះរាជាទ្រង់ប្រគល់រាជសម្បត្តិយ៉ាងនេះ ពួកអាមាត្យបាន ស្តាប់ហើយ ទើបក្រាបទូលថា

**អត្ថិ តេ ទហរោ បុត្តោ ទីឃាវុ រដ្ឋវឌ្ឍនោ**

**តំ រជ្ជេ អភិសិញ្ចស្សុ សោ នោ រាជា ភវិស្សតិ ។**

ព្រះរាជបុត្តរបស់ព្រះអង្គ ព្រះនាមទីឃាវុ នៅក្មេង ជាអ្នកញ៉ាំង ដែនឲ្យចម្រើន សូមព្រះអង្គអភិសេកព្រះរាជបុត្តនោះ ក្នុងរាជ្យ ចុះ ព្រះរាជបុត្តនោះ នឹងបានជាព្រះរាជារបស់យើងខ្ញុំ ។

ខាងមុខអំពីនេះទៅ បណ្ឌិតគប្បីធ្វើនូវគាថាដែលព្រះរាជាត្រាស់ ហើយឲ្យជាលំនាំ គប្បីជ្រាបគាថាសម្ពន្ធដោយឧទាន ដោយន័យព្រះ បាលីនុ៎ះឯង ។

ព្រះរាជាត្រាស់ថា

**ខិប្បំ កុមារំ អានេថ ទីឃាវុំ រដ្ឋវឌ្ឍនំ**

**តំ រជ្ជេ អភិសិញ្ចិស្សំ សោ វោ រាជា ភវិស្សតិ ។**

អ្នកទាំងឡាយ ចូរនាំយកកុមារឈ្មោះទីឃាវុ អ្នកញ៉ាំងដែន ឲ្យចម្រើន មកឲ្យឆាប់ អញនឹងអភិសេកកុមារនោះ ក្នុងរាជ្យ កុមារនោះ នឹងជាព្រះរាជារបស់អ្នកទាំងឡាយ ។

ពួកអាមាត្យស្តាប់ព្រះតម្រាស់របស់ព្រះរាជាហើយ ទើបនាំគ្នាទៅ

យាងទីឃាវុរាជកុមារមក ព្រះរាជាក៏ទ្រង់ប្រគល់រាជសម្បត្តិដល់ព្រះរាជកុមារនោះហើយ ។ ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

តតោ កុមារមានេសុំ ទីឃាវុំ រដ្ឋវឌ្ឍនំ
តំ ទិស្វា អាលបិ រាជា ឯកបុត្តំ មនោរមំ ។
សដ្ឋី គាមសហស្សានិ បរិបុណ្ណានិ សព្វសោ
តេ បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។

លំដាប់នោះ ពួកអាមាត្យក៏បាននាំកុមារ ឈ្មោះទីឃាវុ អ្នកញុំាំងដែនឲ្យចម្រើន មកថ្វាយ ព្រះរាជាទតឃើញទីឃាវុកុមារនោះ ជាបុត្តតែមួយ ជាទីត្រេកអរពេញព្រះទ័យហើយ ទ្រង់ត្រាស់ថា នៃបុត្ត ស្រុកទាំង ៦០,០០០ បរិបូណ៌ដោយវត្ថុទាំងពួង ចូរបាថៃទាំស្រុកទាំងនោះចុះ អញនឹងប្រគល់រាជ្យដល់បា ។

អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ
មាហំ កាកោវ ទុម្មេធោ កាមានំ វសមន្វគំ ។

អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ ។

សដ្ឋី នាគសហស្សានិ សព្វាលង្ការភូសិតា
សុវណ្ណកច្ឆា មាតង្គា ហេមកប្បនវាសសា ។

*ដំរី ៦០,០០០ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង មានខ្សែរជង្គន់ធ្វើអំពីមាស បិទបាំងដោយកម្រាល ដែលធ្វើអំពីមាស ជាដំរីកើតក្នុងព្រៃមាតង្គៈ ។*

អារូឡ្ហា គាមណីយេភិ តោមរង្កុសបាណិភិ
តេ បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។

*ដំរីណា ដែលពួកហ្មដំរីមានដៃកាន់អាវុធ និងកង្វេរឡើងជិះ នែបុត្ត អ្នកចូរថែទាំពួកដំរីទាំងនោះចុះ អញប្រគល់រាជ្យដល់អ្នក ។*

អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ
មាហំ កាកោវ ទុម្មេធោ កាមានំ វសមន្វគំ ។

*អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ ។*

សដ្ឋី អស្សសហស្សានិ សព្វាលង្ការភូសិតា
អាជានីយា ច ជាតិយា សិន្ធវា សីឃវាហនា
អារូឡ្ហា គាមណីយេភិ ឥន្ទិយាចាបធារិភិ

តេ បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។

*សេះ ៦០,០០០ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង ជាសេះអាជានីយដោយកំណើត ជាសេះសិន្ធវៈ ជាពាហនៈយ៉ាងលឿន ដែលពួកសារថីកាន់សែ៊និងធ្នូជិះ នៃបុត្ត បាចូរថែទាំសេះទាំងនោះចុះ អញប្រគល់រាជ្យដល់បា ។*

អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ
មាហំ កាកោវ ទុម្មេធោ កាមានំ វសមន្វគំ ។

*អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ ។*

សដ្ឋី រថសហស្សានិ សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា ។

*រថ ៦០,០០០ ដែលគេទឹមហើយ ដោតទង់ជ័យ ស្រោបដោយស្បែកខ្លាដំបង ស្រោបដោយស្បែកខ្លាធំ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង ។*

អារូឡ្ហា គាមណីយេហិ ចាបហត្ថេហិ ចម្មិភិ
តេ បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។

*អ្នកបររថមានដៃកាន់ធ្នូ ស្លៀកខែលហើយឡើងជិះ នៃបុត្ត*

*បាចូរថែទាំរថទាំងនោះចុះ អញប្រគល់រាជ្យដល់បា ។*

**អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ**

**មាហំ កាកោវ ទុម្មេធោ កាមានំ វសមន្វគំ ។**

*អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ ។*

**សដ្ឋី ធេនុសហស្សានិ រោហញ្ញា បុង្គវូសភា**

**តា បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។**

*មេគោ ៦០,០០០ ជាមេគោក្រហម ប្រកបដោយគោខ្វាង (គោបា) នៃបុត្ត បាចូរថែទាំមេគោទាំងនោះចុះ អញប្រគល់រាជ្យដល់បា ។*

**អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ**

**មាហំ កាកោវ ទុម្មេធោ កាមានំ វសមន្វគំ ។**

*អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ ។*

**សោឡសិត្ថីសហស្សានិ សព្វាលង្ការភូសិតា**

**វិចិត្រវត្ថាភរណា អាមុត្តមណិកុណ្ឌលា**

**តា បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។**

*ស្ត្រី ១៦,០០០ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង មានសំពត់និងអាភរណៈដ៏វិចិត្រ ពាក់កុណ្ឌលកែវមណី នែបុត្ត បា ចូរថែទាំស្ត្រីទាំងនោះចុះ អញប្រគល់រាជ្យដល់បា ។*

**អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ**
**មាហំ កាកោវ ទុម្មេធោ កាមានំ វសមន្វគំ ។**

*អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ ។*

*ព្រះរាជកុមារក្រាបទូលថា*

**ទហរស្សេវ មេ តាត មាតា មតាតិ មេ សុតំ**
**តយា វិនា អហំ តាត ជីវិតុំបិ ន ឧស្សហេ ។**

*បពិត្រព្រះវរបិតា កាលដែលទូលព្រះបង្គំជាខ្ញុំនៅក្មេងនៅឡើយ ទូលព្រះបង្គំជាខ្ញុំ បានឮថា ព្រះវរមាតាទ្រង់សោយវិលាល័យទៅហើយ បពិត្រព្រះវរបិតា ទូលព្រះបង្គំជាខ្ញុំព្រាត់ប្រាសចាកព្រះអង្គហើយ មិនអាចនឹងរស់នៅបានទេ ។*

**យថា អារញ្ញកំ នាគំ បោតោ អន្វេតិ បច្ឆតោ**
**ជេស្សន្តំ គិរិទុគ្គេសុ សមេសុ វិសមេសុ ច ។**

កូនដំរី រមែងទៅតាមក្រោយដំរីដែលនៅក្នុងព្រៃ ដើរទៅក្នុងជង្ហុកនៃភ្នំទាំងឡាយ ដែលរាបស្មើ និងមិនរាបស្មើ យ៉ាងណាមិញ ។

ឯវន្តំ អនុគច្ឆាមិ បុត្តមាទាយ បច្ឆតោ
សុភរោ តេ ភវិស្សាមិ ន តេ ហេស្សាមិ ទុព្ភរោ ។

ទូលព្រះបង្គំជាខ្ញុំ នាំយកកូនទៅតាមព្រះអង្គ ក៏យ៉ាងនោះដែរ ទូលព្រះបង្គំជាខ្ញុំ ជាបុគ្គលព្រះអង្គចិញ្ចឹមងាយ ពុំមែនព្រះអង្គលំបាកចិញ្ចឹមឡើយ ។

ព្រះរាជាទ្រង់ត្រាស់ថា

យថា សាមុទ្ទិកំ នាវំ វាណិជានំ ធនេសិនំ
វោហារោ តត្ថ គណ្ហេយ្យ វាណិជា ព្យសនី សិយា
ឯវមេវាយំ បុត្តកា អន្តរាយករោ មម ។

សត្វត្រូវជាអ្នកបំផ្លាញ គប្បីចាប់សំពៅដែលដើរក្នុងសមុទ្ររបស់ពួកពាណិជ ដែលស្វែងរកទ្រព្យក្នុងសមុទ្រនោះ ពួកពាណិជត្រូវវិនាស យ៉ាងណាមិញ នៃកូនលាមកឯងនេះ ធ្វើសេចក្តីអន្តរាយដល់អញ ក៏យ៉ាងនោះដែរ ។

ព្រះរាជកុមារមិនអាចក្រាបទូលពាក្យណាមួយបាន ។ លំដាប់នោះ ព្រះរាជា កាលទ្រង់បង្គាប់ពួកអាមាត្យ ទើបត្រាស់ថា

ឥមំ កុមារំ បាបេថ បាសាទំ រតិវឌ្ឍនំ
តត្ថ កម្ពុសហត្ថាយោ យថា សក្កំវ អច្ឆរា
តា នំ តត្ថ រមិស្សន្តិ តាហិ ចេសោ រមិស្សតិ ។

*អ្នកទាំងឡាយ ចូរញុំាងកុមារនេះ ឲ្យដល់ប្រាសាទ ដែលញុំាងតម្រេកឲ្យចម្រើន ក្នុងប្រាសាទនោះ មានពួកស្រ្តី មានដៃស្អិតស្អាងដោយគ្រឿងអាភរណៈធ្វើអំពីមាស ស្រ្តីទាំងនោះនឹងត្រេកអរចំពោះកុមារនោះ ក្នុងប្រាសាទនោះ ដូចជាពួកស្រីអប្សរត្រេកអរនឹងសក្កទេវរាជ កុមារនុ៎ះនឹងត្រេកអរដោយស្រ្តីទាំងនោះ ។*

*ព្រះសាស្តា កាលទ្រង់ត្រាស់ដឹងហើយ ទើបត្រាស់អភិសម្ពុទ្ធគាថានេះថា*

តតោ កុមារំ បាបេសុំ បាសាទំ រតិវឌ្ឍនំ
តំ ទិស្វា អវចុំ កញ្ញា ទីឃាវុំ រដ្ឋវឌ្ឍនំ ។
ទេវតា នុសិ គន្ធព្វោ អាទុ សក្កោ បុរិន្ទទោ
កោ វា ត្វំ កស្ស វា បុត្តោ កថំ ជានេមុ តំ មយំ ។

*លំដាប់អំពីនោះមក ពួកអាមាត្យបានញុំាងកុមារឲ្យដល់ប្រាសាទដែលញុំាងតម្រេកឲ្យចម្រើន ឯពួកនាងកញ្ញាឃើញទីឃាវុកុមារនោះ ជាអ្នកញុំាងដែនឲ្យចម្រើនហើយ ក៏បាន*

ពោលថា លោកជាទេវតា ឬជាគន្ធព្វ ឬក៏ជាព្រះឥន្ទឈ្មោះ បុរិន្ទទៈ លោកជាអ្វី ជាបុត្តនៃអ្នកណា ធ្វើដូចម្ដេច យើងនឹងអាចស្គាល់លោកបាន ។

ព្រះរាជកុមារត្រាស់ថា

**នម្ហិ ទេវោ ន គន្ធព្វោ　　នបិ សក្កោ បុរិន្ទទោ**
**កាសិរញ្ញោ អហំ បុត្តោ　　ទីឃាវុ រដ្ឋវឌ្ឍនោ**
**មមំ ភរថ ភទ្ទំ វោ　　អហំ ភត្តា ភវាមិ វោ ។**

យើងមិនមែនជាទេវតា មិនមែនជាគន្ធព្វ ទាំងមិនមែនជាព្រះឥន្ទឈ្មោះបុរិន្ទទៈទេ យើងជាកូននៃព្រះរាជាក្នុងដែនកាសី ឈ្មោះទីឃាវុ ជាអ្នកញ៉ាំងដែនឲ្យចម្រើន នាងទាំងឡាយ ចូរប្រាប្ចថាយើងចុះ សេចក្ដីចម្រើននឹងមានដល់ពួកនាងទាំងឡាយ យើងជាភស្ដារបស់ពួកនាង ។

ព្រះសាស្ដា កាលទ្រង់ត្រាស់ដឹងហើយ ទើបត្រាស់អភិសម្ពុទ្ធគាថានេះថា

**តំ តត្ថ អវចុំ កញ្ញា　　ទីឃាវុំ រដ្ឋវឌ្ឍនំ**
**កុហឹ រាជា អនុប្បត្តោ　　ឥតោ រាជា កុហឹ គតោ ។**

ពួកនាងកញ្ញាបានទូលសួរទីឃាវុកុមារនោះ ដែលញ៉ាំងដែនឲ្យចម្រើន ក្នុងប្រាសាទនោះថា ព្រះរាជាស្ដេចយាងទៅក្នុង

*ទីណា ព្រះរាជាស្តេចចេញអំពីទីនេះ ទៅក្នុងទីណា ។*

*ព្រះរាជកុមារត្រាស់ថា*

បត្តំ រាជា អតិក្កន្តោ ចលេ រាជា បតិដ្ឋិតោ
អកណ្ដកំ អគហនំ បដិបន្នោ មហាបថំ ។

*ព្រះរាជាទ្រង់បានឈានកន្លងភក់ ( រាគាទិក្កិលេស ) ព្រះរាជាទ្រង់បានឋិតនៅស៊ប់លើគោក ( ផ្នួស ) ទ្រង់យាងទៅកាន់ផ្លូវធំ ( ជាទីទៅកាន់សួគ៌និងព្រះនិព្វាន ) ដែលមិនមានបន្លា មិនមានព្រៃញៀតស្បាត ( រគៈ ) ។*

អហញ្ច បដិបន្នោស្មិ មគ្គំ ទុគ្គតិគាមិនំ
សកណ្ដកំ សគហនំ យេន គច្ឆន្តិ ទុគ្គតឹ ។

*ចំណែកយើងជាអ្នកដើរទៅកាន់ផ្លូវជាទីទៅកាន់ទុគ្គតិ ប្រកបដោយបន្លា ប្រកបដោយព្រៃញៀតស្បាត សម្រាប់ទៅកាន់ទុគ្គតិរបស់ពួកសត្វ ។*

*ពួកនាងកញ្ញាទូលថា*

តស្ស តេ ស្វាគតំ រាជ សីហស្សេវ គិរិព្វជំ
អនុសាស មហារាជ ត្វំ នោ សព្វាសមិស្សរោតិ ។

*បពិត្រព្រះរាជា ព្រះអង្គនោះ យាងមកល្អហើយ ហាក់ដូចជាសីហៈ ដែលមកកាន់គិរិព្វជៈ ( គុហាមាស ) បពិត្រ*

មហារាជ សូមព្រះអង្គគ្រប់គ្រងចុះ ព្រះអង្គជាម្ចាស់របស់ពួកខ្ញុំម្ចាស់ទាំងអស់គ្នា ។

ព្រះមហាសត្វ កាលត្រាស់យ៉ាងនេះហើយ ទើបត្រាស់ឲ្យអភិសេកទីឃាវុកុមារនោះ ក្នុងទីនោះឯង ហើយឲ្យត្រឡប់ចូលកាន់ព្រះនគរ ។ ឯទ្រង់មួយអង្គឯងប៉ុណ្ណោះ ចេញអំពីព្រះរាជឧទ្យាន ចូលទៅកាន់ព្រៃហិមពាន្ត សាងបណ្ណសាលា ត្រង់ភូមិភាគដែលគួរត្រេកអរ ហើយទ្រង់បួសជាឥសី មានមើមឈើ និងផ្លែឈើក្នុងព្រៃជាអាហារ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ។ ចំណែកមហាជន ក៏យាងព្រះរាជកុមារទៅកាន់នគរពារាណសី ។ ព្រះរាជកុមារនោះ ទ្រង់ធ្វើប្រទក្សិណនគរហើយ ឡើងកាន់ប្រាសាទ ។ ពួកអ្នករបាំទាំងនោះ ឃើញព្រះរាជកុមារយាងមកហើយ ដោយសិរីដ៏ប្រសើរ មានបរិវារច្រើន មិនដឹងថា ព្រះរាជកុមារនេះមានឈ្មោះអ្វី ទើបនាំគ្នាក្រាបទូលសួរ ។ ព្រះរាជកុមារត្រាស់ថា ជនទាំងឡាយ រមែងដើរទៅកាន់ទុគ្គតិ ដោយផ្លូវដែលខុសណា យើងដើរទៅកាន់ផ្លូវខុសនោះ ។ សម័យនោះ ពួកអ្នករបាំទាំងនោះ គិតថា ព្រះរាជាទ្រង់លះបង់ពួកយើង ទ្រង់ព្រះផ្នួសហើយ សូម្បីព្រះរាជកុមារនេះសោត ក៏មានព្រះហឫទ័យមិនត្រេកអរក្នុងកាមទាំងឡាយ បើពួកយើងមិនព្រមអភិរម្យជាមួយទ្រង់ ទ្រង់នឹងចេញសាងបព្វជ្ជាទៀត ពួកយើងនឹងធ្វើអាការ គឺការត្រេកអរដល់ទ្រង់ ។ គ្រានោះ ពួកអ្នករបាំ កាលនឹង

ឲ្យព្រះរាជកុមារត្រេកអរ ទើបក្រាបទូលគាថាចុងក្រោយ ។

ពួកស្រ្តីទាំងនោះ កាលក្រាបទូលដូច្នេះហើយ ក៏នាំគ្នាប្រគំតូរ្យតន្ត្រីទាំងអស់ឡើង ធ្វើនូវការច្រៀងរាំ មានប្រការផ្សេង ៗ ឲ្យប្រព្រឹត្តទៅហើយ កិត្តិយសក៏ចម្រើនក្រៃលែងឡើង ។ ទីឃាវុរាជកុមារនោះ ជាអ្នកដល់ព្រមហើយដោយកិត្តិយស ទ្រង់មិនបានរឮកដល់ព្រះបិតាឡើយ បានសោយរាជសម្បត្តិដោយធម៌ ទៅតាមយថាកម្មហើយ ។ ព្រះពោធិសត្វបានញុំាងឈាននិងអភិញ្ញាឲ្យកើតឡើង ក្នុងទីបំផុតនៃព្រះជន្ម ក៏បានទៅកើតក្នុងព្រហ្មលោក ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតចេញសាងមហាភិនេស្រ្កមណ៍ តែក្នុងកាលឥឡូវនេះ ក៏មិនមែន សូម្បីក្នុងកាលមុន ក៏ធ្លាប់ចេញសាងមហាភិនេស្រ្កមណ៍ហើយដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ព្រះបច្ចេកពុទ្ធក្នុងកាលនោះ បរិនិព្វានហើយ បុត្ត ( ទីឃាវុកុមារ ) ក្នុងកាលនោះ បានមកជារាហុលកុមារ បរិស័ទដ៏សេសក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ព្រះបាទអរិន្ទមរាជ គឺតថាគតនេះឯង ។

## សោណកជាតក ចប់ [១]

---

១-ស្រង់ចាកអដ្ឋកថា ជាតក សដ្ឋិនិបាត បិ.៦១ ទំ.៤២ ឃ. ៦៦ ។

# បញ្ចុបោសថជាតក (១)

ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសក ៥០០ នាក់ ដែលរក្សាឧបោសថ ទើបត្រាស់ព្រះធម្មទេសនានេះថា

ក្នុងអតីតកាល មានបទេស គឺព្រៃគួរជាទីរីករាយ នៅក្នុងរវាងព្រំដែន នៃនគរទាំង ៣ មាននគរមគធៈជាដើម ។ ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងដែនមគធៈ ចម្រើនវ័យហើយ លះកាមទាំងឡាយចេញចាកផ្ទះ ចូលទៅកាន់ព្រៃនោះ សាងអាស្រមបទ បួសជាឥសីអាស្រ័យនៅ (ក្នុងទីនោះ) ។ ក្នុងទីមិនឆ្ងាយអំពីអាស្រមរបស់លោក ព្រាបឈ្មោលនិងព្រាបញី អាស្រ័យនៅត្រង់គុម្ពឫស្សីមួយកន្លែង ពស់អាស្រ័យនៅក្នុងដំបូកមួយកន្លែង ចចកអាស្រ័យនៅត្រង់គុម្ពឈើក្នុងព្រៃមួយកន្លែង ខ្លាឃ្មុំអាស្រ័យនៅត្រង់គុម្ពឈើក្នុងព្រៃមួយកន្លែង (ដូចគ្នា) ។ សត្វទាំង ៤ នោះ តែងនាំគ្នាទៅរកឥសីស្តាប់ធម៌តាមកាលដែលសមគួរ ។

សម័យថ្ងៃមួយ ព្រាបឈ្មោលនិងព្រាបញីហើរចេញអំពីសម្បុកទៅរកចំណីជាមួយគ្នា ។ ខ្លែងមួយឆាបយកព្រាបញីដែលហើរអំពីក្រោយព្រាបឈ្មោល ហើយហើរគេចទៅ ។ ព្រាបឈ្មោលបានឮសំឡេងស្រែករបស់ព្រាបញីនោះ បែរមើល បានឃើញព្រាបញីដែលត្រូវខ្លែងឆាប

---

១-បិដកខ្មែរជា បញ្ចុបោសថិកជាតក ។

ទៅ ។ ឯខ្លែង ក៏សម្លាប់ព្រាបញីដែលកំពុងស្រែកនោះឯង ឲ្យស្លាប់ ហើយចឹកស៊ី ។ ព្រាបឈ្មោលក្តៅក្រហាយ ព្រោះព្រាត់ចាកព្រាបញី នោះផង ព្រោះរាគៈផង ត្រិះរិះថា រាគៈនេះ ធ្វើឲ្យអញលំបាកក្រៃលែង ឥឡូវនេះ បើអញសង្កត់សង្កិនវាមិនបានទេ អញមិនចេញទៅរកចំណី ឡើយ ។ ព្រាបឈ្មោលកាត់ផ្លូវគោចរ ហើយទៅកាន់សម្នាក់របស់តាបស សមាទានឧបោសថដើម្បីសង្កត់សង្កិននូវរាគៈ ហើយសម្ងំក្នុងទីមួយ ។

ឯពស់គិតថា អញនឹងស្វែងរកចំណី ទើបចេញអំពីលំនៅ ស្វែង រកចំណីក្នុងទីដែលជាទីត្រាច់ទៅនៃមេគោក្នុងស្រុកជាយដែន ។ កាល នោះ គោឈ្មោលដែលជាមង្គល មានពណ៌សសុទ្ធរបស់មេស្រុក ស៊ីស្មៅ ហើយ ក៏លុតជង្គង់យកស្នែងវែធដីលេង ត្រង់ដំបូកនោះ ។ ពស់ខ្លាច សំឡេងសន្ធឹកជើងរបស់មេគោទាំងឡាយ ក៏លូនទៅដើម្បីចូលក្នុងដំបូក នោះ ។ លំដាប់នោះ គោឈ្មោលនោះក៏ជាន់ដោយជើង ។ ពស់ខឹង នឹងគោនោះ ក៏ចឹកគោនោះ ឲ្យអស់ជីវិតក្នុងទីនោះឯង ។ ពួកអ្នកស្រុក បានឮដំណឹងថា គោនោះស្លាប់ហើយ ក៏នាំគ្នាមកប្រជុំស្រែកយំរៀបរាប់ បូជាគោនោះ ដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម នាំគ្នាជីករណ្តៅ កប់ហើយ ចៀសចេញទៅ ។ ក្នុងពេលដែលពួកអ្នកស្រុកចេញទៅ ពស់ក៏លូនចេញមក គិតថា អញអាស្រ័យសេចក្តីក្រោធ សម្លាប់នូវគោ ឈ្មោលនេះ ធ្វើឲ្យមហាជននាំគ្នាសោកស្តាយ ឥឡូវនេះ បើអញ

សង្កត់សង្កិនសេចក្ដីក្រោធនេះ មិនបានទេ អញនឹងមិនទៅរកចំណីឡើយ ហើយត្រឡប់ទៅកាន់អាស្រមនោះ សមាទានឧបោសថដើម្បីសង្កត់សង្កិននូវសេចក្ដីក្រោធ ហើយសម្ងំក្នុងទីមួយ ។

ចំណែកចចក កាលស្វែងរកអាហារ ឃើញដំរីងាប់មួយ ត្រេកអរថា អញបានចំណីច្រើនណាស់ រត់ទៅខាំត្រង់ប្រមោយ ហាក់ដូចជាខាំសសរ មិនបាននូវសេចក្ដីត្រេកអរត្រង់ប្រមោយនោះ លុះមកខាំភ្លុក ហាក់ដូចខាំដុំថ្ម មកកកេរត្រង់ពោះ ដូចជាខាំចង្អេរ មកខាំកន្ទុយ ដូចជាខាំអង្រែ លុះមកខាំត្រង់ទ្វារធំ ដូចជាខាំនំផ្អែមឆ្ងាញ់ ។ ចចកក៏ស៊ីដោយអំណាចសេចក្ដីល្មោភ ហើយលុងចូលទៅក្នុងពោះដំរី លុះពេលឃ្លាន ក៏ស៊ីសាច់ខាងក្នុងពោះនោះ លុះពេលស្រេក ក៏ផឹកនូវឈាម ពេលដេកក៏ដេកលើពោះវៀននិងសួត ។ ចចកគិតថា បាយក្ដី ទឹកក្ដី ទីដេកក្ដីមានស្រាប់ក្នុងទីនេះឯង អញនឹងធ្វើអ្វីក្នុងទីដទៃ ត្រេកអរក្រែលែងក្នុងពោះដំរីនោះ មិនចេញមកខាងក្រៅឡើយ នៅក្នុងពោះដំរីប៉ុណ្ណោះ ។ ចំណេរកាលតមក សាកសពដំរីក៏ស្ងួតដោយខ្យល់និងកម្ដៅថ្ងៃ ទ្វារអាហារចាស់ ក៏បិទ ។ ចចកដេកខាងក្នុងពោះដំរី ក៏មានសាច់និងឈាមតិច មានរាងកាយស្គមល្ងឿង មិនឃើញផ្លូវចេញ ។ ថ្ងៃមួយ មេឃពុំជួកាល បណ្ដាលឲ្យភ្លៀងធ្លាក់ ទ្វារអាហារចាស់ ក៏សើមហើយទន់ប្រាកដប្រហោងឲ្យឃើញ ។ ចចកឃើញប្រហោង គិតថា អញលំបាក

អស់កាលយូរ ត្រូវគេចចេញតាមប្រហោងនេះ យកក្បាលត្បុលចេញមកតាមទ្វារធំ ។ ចចកមានសរីរៈស្គម ចេញអំពីទីចង្អៀត ដោយរហ័ស រោមក៏ជាប់ត្រង់ទ្វារធំនោះទាំងអស់ ចចកនោះ មានខ្លួនរលីងដូចគល់កូនត្នោត ចេញមក គិតថា ព្រោះអាស្រ័យសេចក្តីលោភ អញត្រូវសោយនូវទុក្ខនេះ ឥឡូវនេះ បើអញសង្កត់សង្កិនលោភៈនេះ មិនបានទេ អញនឹងមិនទៅរកចំណីឡើយ ហើយទៅកាន់អាស្រមនោះ សមាទានឧបោសថដើម្បីសង្កត់សង្កិននូវសេចក្តីលោភ ហើយសម្ងំក្នុងទីមួយ ។

ឯខ្លាឃ្មុំចេញអំពីព្រៃហើយ ត្រូវចំណង់ក្រៃលែងគ្របសង្កត់ ទើបចូលទៅកាន់ស្រុកជាយដែន ក្នុងដែនមល្ល: ។ ពួកអ្នកស្រុកបានឮថាខ្លាឃ្មុំមកហើយ ក៏កាន់ធ្នូនិងដំបង នាំគ្នាចេញទៅព័ទ្ធគុម្ពោតព្រៃនោះ ។ ខ្លាឃ្មុំដឹងថា មហាជនព័ទ្ធហើយ ទើបគេចចេញ កាលខ្លាឃ្មុំកំពុងគេចនុំះឯង មហាជននាំគ្នាវាយដោយធ្នូនិងដំបង ខ្លាឃ្មុំបែកក្បាលហូរឈាមទៅកាន់លំនៅរបស់ខ្លួន គិតថា ទុក្ខនេះកើតឡើង ព្រោះអំណាចសេចក្តីលោភ គឺចំណង់ក្រៃលែងរបស់អញ ឥឡូវនេះ បើអញគ្របសង្កត់នូវចំណង់នេះ មិនបានទេ អញនឹងមិនទៅរកចំណីឡើយ ហើយទៅកាន់អាស្រមនោះ សមាទានឧបោសថដើម្បីគ្របសង្កត់នូវចំណង់នោះ ហើយសម្ងំក្នុងទីមួយ ។

ចំណែកតាបសអាស្រ័យជាតិរបស់ខ្លួន ធ្លាក់ក្នុងអំណាចនៃមានះ

មិនអាចញ៉ាំងឈានឲ្យកើតបាន ។ លំដាប់នោះ **ព្រះបច្ចេកពុទ្ធ** មួយអង្គជ្រាបភាពដែលតាបសនោះ មានមានះ លោកត្រិះរិះថា តាបសនេះមិនមែនជាបុគ្គលថោកទាបទេ គឺជាពូជពន្ធកនៃព្រះពុទ្ធ នឹងសម្រេចនូវព្រះសព្វញ្ញុតញ្ញាណក្នុងភទ្ទកប្បនេះឯង អញត្រូវធ្វើការសង្កត់សង្កិននូវមានះរបស់តាបសនេះ ហើយនឹងធ្វើនូវអាការជាហេតុកើតឡើងនៃសមាបត្តិ (របស់ព្រះពោធិសត្វនោះ) ទើបហោះមកអំពីព្រៃហិមពាន្តទិសខាងជើង ខណៈដែលតាបសពោធិសត្វកំពុងអង្គុយក្នុងបណ្ណសាលាទ៉ុះឯង ហើយអង្គុយលើផ្ទាំងថ្មរបស់ព្រះពោធិសត្វនោះ ។ ព្រះពោធិសត្វចេញមកឃើញព្រះបច្ចេកពុទ្ធអង្គុយលើអាសនៈរបស់ខ្លួន អន់ចិត្ត ព្រោះភាពជាអ្នកមានមានះ ស្ទុះចូលទៅរកលោក ហើយទះដៃសម្តុតថា នែសមណៈត្រងោល ថោកទាប កាឡកណ្ណី ចូរវិនាសចុះ លោកឯងមកអង្គុយលើផ្ទាំងថ្មរបស់យើងដើម្បីអ្វី ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធពោលថា ម្នាលសប្បុរស អ្នកជាមនុស្សអាស្រ័យនូវមានះ ព្រោះហេតុអ្វី ។ អាត្មាសម្រេចនូវបច្ចេកពោធិញ្ញាណហើយ ចំណែកអ្នកនឹងបានត្រាស់ជាព្រះសព្វញ្ញុពុទ្ធក្នុងភទ្ទកប្បនេះឯង អ្នកជាពូជពន្ធកព្រះពុទ្ធ អ្នកបំពេញបារមីមកហើយ អស់កាលមានប្រមាណប៉ុណ្ណោះ ក្នុងអនាគតកាល អ្នកនឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមថា សិទ្ធត្ថ ។ ព្រះបច្ចេកពុទ្ធប្រាប់នាម គោត្ត ត្រកូល និងអគ្គសាវកជាដើម ហើយឲ្យឱវាទថា អ្នកនៅតែ

ស្រវឹងដោយមានះ ជាបុគ្គលគ្រោតគ្រាត ដើម្បីអ្វី នេះមិនសមគួរដល់អ្នកឡើយ ។ តាបសនោះ កាលព្រះបច្ចេកពុទ្ធពោលយ៉ាងនេះហើយ ក៏នៅតែមិនថ្វាយបង្គំ មិនសួរថា ខ្ញុំនឹងបានជាព្រះពុទ្ធក្នុងកាលណា ដូច្នេះជាដើមទេ ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធពោលថា អ្នកមិនដឹងនូវភាពជាធំនៃជាតិ និងភាពជាធំនៃគុណរបស់អាត្មា បើអ្នកអាច ក៏ចូរទៅតាមអាកាសដូចអាត្មា ព្រះបច្ចេកពុទ្ធហោះទៅក្នុងអាកាស ជម្រុះនូវធូលីដែលជាប់ត្រង់ជើង លើមណ្ឌលជដារបស់តាបសពោធិសត្វនោះ ហើយទៅកាន់ព្រៃហិមពាន្តទិសខាងជើងវិញ ។

លុះព្រះបច្ចេកពុទ្ធនិមន្តទៅហើយ តាបសសង្វេគគិតថា សមណៈនេះ មានសរីរៈធ្ងន់យ៉ាងនេះ តែអាចហោះទៅក្នុងអាកាសបាន ដូចប៉ុយគអណ្តែតទៅក្នុងអាកាស ព្រោះជាតិមានះ អញមិនបានក្រាបថ្វាយបង្គំនូវព្រះបាទារបស់ព្រះបច្ចេកពុទ្ធ ដែលមានសភាពបែបនេះ និងមិនបានសួរដោយពាក្យថា ខ្ញុំនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលណា ឈ្មោះថា ជាតិនឹងធ្វើអ្វីបាន សីលនិងចរណៈប៉ុណ្ណោះ ជាធំក្នុងលោកនេះ តែបើមានះរបស់អញចម្រើន នឹងនាំទៅកាន់នរកបាន ឥឡូវនេះ បើអញសង្កត់នូវមានះនេះ មិនបានទេ អញនឹងមិនទៅរកផ្លែឈើឡើយ ហើយចូលទៅកាន់បណ្ណសាលា សមាទានឧបោសថ ដើម្បីគ្របសង្កត់នូវមានះ អង្គុយលើក្តារសម្រាប់អង្គុយ ជាកុលបុត្តមានញាណធំ សង្កត់សង្កិនមានះបាន

ចម្រើនកសិណ ញុំាំងអភិញ្ញានិងសមាបត្តិឲ្យកើតឡើងហើយ ទើបចេញទៅអង្គុយលើផ្ទាំងថ្មខាងចុងទីចង្រ្កម ។

ក្នុងកាលនោះ សត្វទាំងឡាយ មានព្រាបជាដើម នាំគ្នាចូលមករកព្រះមហាសត្វ ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះមហាសត្វសួរព្រាបថា ក្នុងថ្ងៃដទៃ ៗ អ្នកមិនបានមក ក្នុងវេលានេះ គឺអ្នក (តែងទៅ) ស្វែងរកអាហារ ថ្ងៃនេះ អ្នករក្សាឧបោសថឬ ។ ព្រាបពោលថា លោកម្ចាស់ដ៏ចម្រើន ខ្ញុំរក្សា ។ លំដាប់នោះ ព្រះមហាសត្វកាលសួរថា ព្រោះហេតុអ្វី ទើបពោលបឋមគាថាថា

**អប្បោស្សុក្កោ ឥទានិ តុវំ កបោត**
**វិហង្គម ន តវ ភោជនត្ថោ**
**ខុទំ បិបាសំ អធិវាសយន្តោ**
**កស្មា ភវំបោសថិកោ កបោត ។**

ម្នាលព្រាប ឥឡូវនេះ អ្នកមានសេចក្ដីខ្វល់ខ្វាយតិច
ម្នាលបក្សី អ្នកមិនមានសេចក្ដីត្រូវការដោយចំណី
សោះ ម្នាលព្រាប អ្នកខំអត់ទ្រាំនូវគម្លាន និងសម្រេក
ជាសត្វរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

ព្រាបស្ដាប់ដូច្នោះហើយ បានពោលគាថា ២ ថា

**អហំ បុរេ គិទ្ធិគតោ កបោតិយា**

**តស្មឹ បទេសម្ហិ ឧភោ រមាម**

**អជត្តហី សាកុណិកោ កចោតឹ**

**អកាមកោ តាយ វិនា អហោសឹ ។**

*ក្នុងកាលមុន ខ្ញុំមានចិត្តជាប់នឹងមេព្រាប យើងខ្ញុំទាំងពីរនាក់កំពុងតែរីករាយ ( ក្នុងកាម ) ក្នុងប្រទេសនោះ ស្រាប់តែសត្វខ្មែង មកឆាបយកមេព្រាបទៅ ខ្ញុំក៏អស់សេចក្តីប្រាថ្នា ព្រោះប្រាសចាកមេព្រាបនោះ ។*

**នានាភាវា វិប្បយោគេន តស្សា**

**មនោមយំ វេទន វេទយាមិ**

**តស្មា អហំឧបោសថ បាលយាមិ**

**រាគោ មមំ មា បុនរាគមាសិ ។**

*ខ្ញុំរងនូវវេទនាធំក្នុងចិត្ត ព្រោះព្រាត់ប្រាសចាកមេព្រាបនោះ ហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យរាគៈគ្របសង្កត់ខ្ញុំបានទៀតឡើយ ។*

*កាលព្រាបរៀបរាប់ឧបោសថកម្មរបស់ខ្លួនហើយ ព្រះមហាសត្វក៏សួរ ( សត្វទាំងនោះ ) មានពស់ជាដើម ម្តងមួយ ៗ ។ សត្វទាំងនោះនាំគ្នារៀបរាប់សេចក្តីពិត ។ កាលនឹងសួរពស់ ទើបពោលថា*

**អនុជ្ជុគាមិ ឧរគ ទុជិវ្ហ**

ធាហវុធោ ឃោរវិសោសិ សប្ប
ខុជ្ជំ បិចាសំ អធិវាសយន្តោ
កស្មា ភវំ ចោសថិកោ នុ ឌីឃ ។

ម្នាលពស់ ជាឧរគជាតិ លូនទៅមិនត្រង់ មានអណ្តាតពីរ អ្នកមានចង្កូមជាអាវុធ មានពិសដ៏ពន្លឹក ម្នាលសត្វមានខ្លួនវែង អ្នកអត់ទ្រាំនូវគម្លាននិងសម្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

ពស់ពោលថា

ឧសកោ អហុ ពលវា គាមិកស្ស
ចលក្កកូ វណ្ណពលូបបន្នោ
សោ មំ អក្កមិ តំ កុបិតោ អឌំសឹ
ទុក្ខាភិតុន្នោ មរណំ ឧបាគា ។

គោឈ្មោលឡើងករបស់អ្នកស្រុក ជាគោមានកម្លាំង មានបូកដ៏យុរយារ បរិបូណ៌ដោយសម្បុរ និងកម្លាំង គោនោះ ដើរជាន់ខ្ញុំ ខ្ញុំខឹង បានចឹកវា វាត្រូវសេចក្តីទុក្ខគ្របសង្កត់ហើយ ក៏ស្លាប់ទៅ ។

តតោ ជនា និក្ខមិត្វាន គាមា
កន្ទិត្វា រោទិត្វា អបក្កមឹសុ

តស្មា អហំចោសថ ចាលយាមិ
កោជោ មមំ មា បុនភគមាសិ ។

*លំដាប់នោះ ពួកជនចេញអំពីស្រុក កន្ទក់កន្ទេញ យំទួញ ហើយដើរចៀសចេញទៅ ព្រោះហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យសេចក្ដីក្រោធ គ្របសង្កត់ខ្ញុំបានទៀតឡើយ ។*

*ព្រះមហាសត្វ កាលនឹងសួរចចក ទើបពោលថា*

មតាន មំសានិ ពហូ សុសានេ
មនុញ្ញរូបំ តវ ភោជនេតំ
ខុទ្ទំ បិចាសំ អធិវាសយន្តោ
កស្មា ភវំចោសថិកោ សិគាល ។

*ក្នុងព្រៃស្មសាន មានសាច់របស់សត្វស្លាប់ដ៏ច្រើន សាច់ទាំងនុ៎ះ ជាភោជនជាទីគាប់ចិត្តរបស់អ្នក ម្នាលចចក អ្នកខំអត់ទ្រាំនូវគម្លាន និងសម្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។*

*ចចកពោលថា*

បវិស្ស កុច្ឆឹ មហតោ គជស្ស
កុណបេ រតោ ហត្ថិមំសេសុ គិទ្ធោ

ឧណ្ហោ ច វាតោ តិខិណោ ច រស្មិយោ
តេ សោសយុំ តស្ស ករីសមគ្គំ ។

*ខ្ញុំជាសត្វត្រេកអរក្នុងសាកសព ញ៉ាមក្នុងសាច់ដំរីទាំងឡាយ បានចូលទៅក្នុងពោះនៃដំរីធំ ខ្យល់ដ៏ក្តៅផង រស្មីព្រះអាទិត្យដ៏ក្តៅក្លាផង របស់ទាំងនោះ ញុំាងទ្វារអាហារចាស់នៃដំរីនោះ ឲ្យស្ងួតក្រៀម ។*

កិសោ ច បណ្ឌូ ច អហំ ភទន្តេ
ន មេ អហុ និក្ខមនាយ មគ្គោ
មហា ច មេឃោ សហសា បវស្សិ
សោ តេមយិ តស្ស ករីសមគ្គំ ។

*បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំស្គមលឿង (ក្នុងពោះនៃដំរីនោះ) ខ្ញុំរកផ្លូវចេញមកវិញមិនរួច ស្រាប់តែភ្លៀងធំបង្អុរចុះភ្លាម (ក្នុងពេលនោះ) ភ្លៀងនោះ ធ្វើទ្វារអាហារចាស់នៃដំរីនោះ ឲ្យទទឹកសើម ។*

តតោ អហំ និក្ខមិសំ ភទន្តេ
ចន្ទោ យថា រាហុមុខា បមុត្តោ
តស្មា អហំ ចោសថ ចាលយាមិ
លោភោ មមំ មា បុនរាគមាសិ ។

បពិត្រលោកម្ចាស់ដ៏ចម្រើន លំដាប់នោះ ទើបខ្ញុំចេញមក ដូចជាព្រះចន្ទដែលរួចអំពីមាត់នៃរាហុ ព្រោះហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យលោភៈគ្របសង្កត់ខ្ញុំបានទៀតឡើយ ។

ព្រះមហាសត្វ កាលនឹងសួរខ្លាឃ្មុំ ទើបពោលថា

វម្មិកថូបស្មឹ កិបិល្លិកានិ
និប្បោថយន្តោ តុវំ បុរេ ចរាសិ
ខុទ្ទំ បិបាសំ អធិវាសយន្តោ
កស្មា ភវំ បោសថិកោ នុ អជ្ជ ។

កាលពីដើម អ្នកធ្លាប់ស៊ីនូវកណ្តៀរទាំងឡាយ លើក្បាលដំបូក ម្នាលខ្លាឃ្មុំ អ្នកខំអត់ទ្រាំនូវគម្លាន និងសម្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

ខ្លាឃ្មុំពោលថា

សកំ និកេតំ អតិហេឡយានោ
អត្រិច្ឆតាយ មលតំ អគច្ឆឹ
តតោ ជនា និក្ខមិត្វាន គាមា
កោទណ្ឌកេន បរិបោថយឹសុ មំ ។

ខ្ញុំមើលងាយនូវលំនៅរបស់ខ្លួន បានចូលទៅកាន់ស្រុក

នៃមល្ងជន ព្រោះតែសេចក្ដីប្រាថ្នាលើសលុប គ្រានោះ ពួកជនចេញមកពីស្រុក ហើយក៏វាយខ្ញុំដោយធ្នូ (និងដំបង) ។

សោ ភិន្នសីសោ រុហិរមក្ខិតង្គោ
បច្ចាគមាសឹ សកំ និកេតំ
តស្មា អហំ ចោសថ ចាលយាមិ
អត្រិច្ឆតា មា បុនរាគមាសិ ។

ខ្ញុំនោះបែកក្បាល ប្រឡាក់ឈាមអស់ទាំងខ្លួន ហើយត្រឡប់មកកាន់លំនៅរបស់ខ្លួនវិញ ព្រោះហេតុនោះ បានជាខ្ញុំរក្សាឧបោសថ កុំឲ្យសេចក្ដីប្រាថ្នាលើសលុបគ្របសង្កត់បានទៀតឡើយ ។

កាលសត្វទាំងបួននោះ ពណ៌នាឧបោសថកម្មរបស់ខ្លួនយ៉ាងនេះហើយ ក៏នាំគ្នាក្រោកឡើង ថ្វាយបង្គំព្រះមហាសត្វ កាលនឹងសួរថា ថ្ងៃដទៃ ក្នុងពេលថ្មើរណោះ លោកម្ចាស់ចេញទៅរកផ្លែឈើតូចធំ ថ្ងៃនេះ ហេតុអ្វី ទើបលោកម្ចាស់មិនទៅ ហើយធ្វើឧបោសថ ទើបពោលគាថានេះថា

យំ នោ អបុច្ឆិត្ថ តុវំ ភទន្តេ
សព្វេវ ព្យាករិម្ហា យថាបជានំ
មយម្បិ បុច្ឆាម តុវំ ភទន្តេ

**កស្មា ភវំទោសជិតោ ន ព្រហ្មេ ។**

*បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់បានសាកសួរនូវសេចក្ដីណាចំពោះយើងទាំងឡាយ យើងទាំងអស់គ្នា ក៏បានឆ្លើយនូវសេចក្ដីនោះ តាមទំនងដែលខ្លួនបានដឹងរួចហើយ បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកយើងសូមសួរលោកម្ចាស់វិញ បពិត្រព្រហ្ម លោកម្ចាស់បានរក្សាឧបោសថ តើព្រោះហេតុអ្វី ។*

*ចំណែកព្រះពោធិសត្វ ក៏ប្រាប់ដល់សត្វទាំងនោះថា*

**អនូបលិត្តោ មម អស្សមម្ហិ**

**បច្ចេកពុទ្ធោ មុហុត្តំ និសីទិ**

**សោ មំ អវេទី គតិមាគតិញ្ច**

**នាមញ្ច គោត្តំ ចរណញ្ច សព្វំ ។**

*ព្រះបច្ចេកពុទ្ធ មិនប្រឡាក់ (ដោយកិលេស) គង់ក្នុងអាស្រមរបស់យើងមួយរំពេច ព្រះអង្គបានញុំាងយើងឲ្យដឹងនូវទីដែលត្រូវទៅ និងទីដែលត្រូវមកផង នូវនាមផង នូវគោត្តផង នូវសេចក្ដីប្រព្រឹត្តទាំងអស់ផង ។*

**ឯវម្បិហំ វន្ទិ ន តស្ស បាទេ**

**ន ចាបិហំ មានគតេន បុច្ឆឹ**

**តស្មា អហំទោសជ ចាលយាមិ**

**មាគោ មមំ មា បុនរាគមាសិ ។**

*បើទុកជាយ៉ាងនេះ ក៏យើងនៅតែមិនថ្វាយបង្គំព្រះបាទានៃ*
*ព្រះបច្ចេកពុទ្ធនោះ ម្យ៉ាងទៀត យើងមិនបានសាកសួរ*
*ព្រោះលុះក្នុងអំណាចមានះ ហេតុនោះ បានជាយើងរក្សា*
*ឧបោសថ កុំឲ្យមានះគ្របសង្កត់យើងបានទៀតឡើយ ។*

*ព្រះមហាសត្វប្រាប់នូវហេតុ នៃការធ្វើឧបោសថរបស់ខ្លួនយ៉ាងនេះ ហើយ ឲ្យនូវឱវាទដល់សត្វទាំងនោះ រួចបញ្ជូនទៅ ហើយត្រឡប់ចូលបណ្ណសាលា ។ សត្វទាំងនោះ នាំគ្នាទៅកាន់លំនៅរបស់ខ្លួន ។ ព្រះមហាសត្វមានឈានមិនសាបសូន្យ មានព្រហ្មលោកជាទីទៅខាងមុខ សត្វទាំងនោះ តាំងនៅក្នុងឱវាទរបស់លោក បានទៅកាន់ឋានសួគ៌រៀង ៗ ខ្លួន ។*

*ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទ្រង់ត្រាស់ថា ម្នាលឧបាសកទាំងឡាយ ឧបោសថនេះ ជាបវេណីនៃពួកបណ្ឌិតអំពីបុរាណដោយប្រការដូច្នេះ ឧបោសថជាគុណ ដែលបុគ្គលគួររក្សា ហើយទ្រង់ប្រជុំជាតកថា ព្រាបក្នុងកាលនោះ បានមកជាអនុរុទ្ធក្នុងកាលឥឡូវនេះ ខ្លាឃ្មុំបានមកជាកស្សបៈ ចចកបានមកជាមោគ្គល្លានពស់បានមកជាសារីបុត្ត ឯតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។*

**បញ្ចុបោសថជាតក ចប់** (១)

---

*១-ស្រង់ចាកអដ្ឋកថា ជាតក បកិណ្ណកនិបាត បិ.៦០ ទំ.២៧ ឃ.៨០ ។*

# នាងបញ្ចបាបី

បក្សីកុណាលៈបានតំណាលរឿងដែលខ្លួនធ្លាប់ចួប ដល់បក្សីសុមុខៈថា

ក្នុងអតីតកាល ព្រះបាទពារាណសីព្រះនាមថា ពកៈ ទ្រង់គ្រងរាជ្យដោយធម៌ ។ ក្នុងកាលនោះ មានស្រីឈ្មោះបញ្ចបាបី ជាកូនស្រីរបស់អ្នកក្រីក្រម្នាក់ ដែលនៅក្បែរទ្វារទិសខាងកើតនៃក្រុងពារាណសី (ជាស្រីមានរូបអាក្រក់ក្រៃលែង តែជាអ្នកមានបុណ្យបានធ្វើទុកហើយ) ។ បានឮមកថា កាលពីជាតិមុន នាងកើតជាកូនស្រីអ្នកក្រីក្រម្នាក់ អង្គុយច្របាច់ដីបូកជញ្ជាំងផ្ទះ ។ ក្នុងកាលនោះ មាន **ព្រះបច្ចេកពុទ្ធ** មួយអង្គ ត្រូវការដីស្អិតយកមកបូកលាបជញ្ជាំងកុដិ ទើបគិតថា អាត្មាអញនឹងបានដីស្អិតក្នុងទីណាហ្ន៎ ឃើញថា នឹងបានក្នុងនគរពារាណសី ទើបដណ្តប់ចីវរកាន់បាត្រ ចូលទៅក្នុងនគរពារាណសី ហើយទៅឈរក្បែរស្រីនោះ ។ នាងឃើញព្រះបច្ចេកពុទ្ធហើយ ក៏ក្រោធ ទើបពោលដោយចិត្តប្រទូស្តថា គ្រាន់តែដុំដី ក៏ដើរសូមគេ ។ ព្រះបច្ចេកពុទ្ធនៅស្ងៀម មិនបានញាប់ញ័រ នាងឃើញព្រះបច្ចេកពុទ្ធមិនញាប់ញ័រ ក៏មានចិត្តជ្រះថ្លាពោលថា បពិត្រសមណៈ លោកម្ចាស់ត្រូវការដីស្អិតឬ ពោលហើយ ក៏លើកដីស្អិតមួយដុំធំដាក់ក្នុងបាត្រ ។ ព្រះបច្ចេកពុទ្ធក៏យកទៅបូកជញ្ជាំងកុដិ ។ មិន

យូរប៉ុន្មាន ស្រីនោះ ក៏ចុតិចាកអត្តភាពនោះ បដិសន្ធិក្នុងផ្ទៃស្រីទុគត ខាងក្រៅទ្វារស្រុក ជិតនគរនោះ ។ លុះគ្រប់ខែហើយ នាងក៏ប្រសូត ចាកផ្ទៃមាតា ដោយផលដែលបានប្រគេនដីស្អិតនោះ ទើបរាងកាយ របស់នាងប្រកបដោយសម្ផស្សល្អក្រៃលែង តែព្រោះបាបដែលនាងសម្លឹង មើលព្រះបច្ចេកពុទ្ធដោយសេចក្ដីក្រោធ ដៃ ជើង មាត់ ភ្នែក ច្រមុះ ទាំង ៥ នេះ ក៏វិកលវិបរិតទៅ ។ ព្រោះហេតុនោះ ទើបគេដាក់ឈ្មោះ ឲ្យថា បញ្ចបាបី ( ស្រីមានអវយវៈអាក្រក់ ៥ យ៉ាង ) ។

សម័យថ្ងៃមួយ ក្នុងពេលរាត្រី ព្រះបាទពារាណសីទ្រង់ក្លែងព្រះ កាយ ត្រាច់មើលនគរដល់កន្លែងនោះ ។ នាងបញ្ចបាបីលេងជាមួយ ទារិកាអ្នកស្រុក មិនស្គាល់ព្រះបាទពារាណសី ក៏យកដៃចាប់ព្រះហស្ត របស់ព្រះរាជា ។ ព្រះបាទពារាណសីប៉ះត្រូវសម្ផស្សដៃរបស់នាង ក៏ តម្កល់ព្រះហឫទ័យមិនបាន ដូចពាល់ត្រូវសម្ផស្សទិព្វ ទ្រង់មានតម្រេក ក្នុងសម្ផស្សដ៏ក្រៃលែង ទើបយកព្រះហស្តចាប់នាងបញ្ចបាបីដែលមាន រូបអាក្រក់បែបនោះ សួរថា នាងជាកូនស្រីរបស់អ្នកណា ។ កាលនាង ឆ្លើយថា ខ្ញុំជាកូនស្រីអ្នកស្រុកជិតទ្វារនគរ ទ្រង់ក៏សាកសួរ បានដឹងថា មិនទាន់មានប្ដី ក៏ត្រាស់ថា យើងនេះឯង ជាប្ដីរបស់នាង ចូរនាងទៅ សូមការអនុញ្ញាតអំពីមាតាបិតា ។

នាងបញ្ចបាបីក៏ចូលទៅរកមាតាបិតា ហើយប្រាប់ថា បពិត្រអ្នកម៉ែ

បុរសម្នាក់ គេត្រូវការខ្ញុំ ។ កាលមាតាបិតាពោលថា ជាការល្អហើយ បើគេចង់បាននាងទាំងមានសភាពដូច្នេះ សូម្បីគេក៏នឹងជាមនុស្សទុរគតដែរ ទើបនាងត្រឡប់មកប្រាប់ភាពដែលមាតាបិតាបានអនុញ្ញាតហើយ ។ ព្រះបាទពារាណសីក៏នៅជាមួយនាងបញ្ចបាបីក្នុងផ្ទះនោះ រហូតទៀបភ្លឺទើបត្រឡប់ទៅកាន់ព្រះរាជនិវេសន៍ ។ តាំងអំពីនោះមក ទ្រង់ក្លែងព្រះកាយទៅរកនាងបញ្ចបាបីជានិច្ច ទ្រង់មិនសម្លឹងមើលស្រីដទៃឡើយ ។

សម័យថ្ងៃមួយ បិតារបស់នាងបញ្ចបាបីកើតរោគចុះឈាម ថ្នាំដែលព្យាបាលរោគនោះ ត្រូវនឹងបាយាសដែលផ្សំដោយទឹកដោះស្រស់ សប្បិ ទឹកឃ្មុំ ស្ករក្រាមជាដើម តែគ្រួសាររបស់នាងក្រីក្រ មិនអាចរកមកបាន ។ គ្រានោះ មាតារបស់នាងបញ្ចបាបី ក៏និយាយនឹងកូនស្រីថា នែនាង ប្តីរបស់នាងអាចរកបាយាសបានដែរឬទេ ។

នាងបញ្ចបាបីពោលថា បពិត្រអ្នកម៉ែ ប្តីរបស់ខ្ញុំប្រហែលជាក្រជាងគ្រួសារយើង តែណ្ហើយចុះ ខ្ញុំនឹងសាកសួរគាត់ សូមម៉ែកុំគិតថ្វីឡើយ ពោលដូច្នេះហើយ ក្នុងវេលាដែលព្រះរាជាធ្លាប់យាងមក នាងក៏អង្គុយជាទុក្ខ ( ធ្វើមុខស្រពោន ) ។ លំដាប់នោះ ព្រះបាទពារាណសីយាងមក ហើយត្រាស់សួរថា **កឹ ទុម្មនាសិ** នាងកើតទុក្ខ ព្រោះរឿងអ្វី ។ នាងក៏ប្រាប់សេចក្តីនោះ ។ ព្រះរាជាបានស្តាប់សេចក្តីនោះហើយ ទើបត្រាស់ថា នែនាងដ៏ចម្រើន ថ្នាំមានរសក្រៃលែងបែបនេះ ខ្ញុំនឹងបានមក

អំពីណា ហើយទ្រង់ព្រះតម្រិះថា អញមិនអាចត្រាច់ទៅមកយ៉ាងនេះជានិច្ចកាលបានទេ ក្រែងចួបអន្តរាយតាមផ្លូវ បើនាំនាងបញ្ចបាបីចូលទៅខាងក្នុងព្រះរាជវាំង ជនទាំងឡាយមិនដឹងថា នាងមានសម្បត្តិ គឺសម្ផស្សល្អ ក៏នឹងនាំគ្នាសើចចំអកឲ្យអញថា ព្រះរាជារបស់យើង នាំយកយក្ខិនីមកអំពីណា អញនឹងធ្វើឲ្យអ្នកនគរដឹងសម្ផស្សរបស់នាងជាមុនទើបអាចដោះពាក្យនិន្ទាបាន ។

លំដាប់នោះ ព្រះរាជាត្រាស់ថា នាងកុំព្រួយឡើយ ខ្ញុំនឹងនាំបាយាសមកឲ្យឪពុករបស់នាង កាលទ្រង់អភិរម្យជាមួយនាងហើយ ក៏យាងត្រឡប់ទៅកាន់ព្រះរាជនិវេសន៍ ស្អែកឡើង ត្រាស់ឲ្យចម្អិនបាយាសឲ្យយកស្លឹកឈើមក ធ្វើជាកញ្ចប់ពីរ កញ្ចប់មួយដាក់បាយាស កញ្ចប់មួយទៀត ដាក់ព្រះចូឡាមណី ហើយចងទុក ។ លុះដល់ពេលរាត្រីទ្រង់យាងទៅ ពោលថា នែនាងដ៏ចម្រើន ខ្ញុំជាមនុស្សក្រក្រី រកបានមកដោយលំបាក ចូរនាងប្រាប់ឪពុករបស់នាងថា ថ្ងៃនេះ បរិភោគបាយាសកញ្ចប់មួយនេះ ស្អែកសឹមបរិភោគកញ្ចប់មួយទៀត ។ នាងបញ្ចបាបីក៏ធ្វើតាមពាក្យប្រាប់ ។ លំដាប់នោះ ឪពុករបស់នាងបញ្ចបាបីបរិភោគចូលទៅបានបន្តិច ក៏ឆ្អែតស្កប់ស្កល់ មានសេចក្តីសុខ ព្រោះបាយាសនោះ មានឱជារសក្រៃលែង ។ នាងបញ្ចបាបីក៏នាំយកបាយាសដ៏សេសទៅឲ្យម្តាយ ហើយបរិភោគឯង ក្នុងកាលជាខាងក្រោយ បាយាសក៏ល្មម

ឆ្អែតទាំង ៣ នាក់ ។ ចំណែកកញ្ចប់ដែលមានបង្កប់ព្រះចូឡាមណី ក៏ទុកដើម្បីថ្ងៃស្អែក ។

ព្រះបាទពារាណសីត្រឡប់ទៅកាន់ព្រះរាជនិវេសន៍ ទ្រង់ស្រេចព្រះភក្ត្រស្រេចហើយ ត្រាស់ថា ចូរនាំចូឡាមណីមកឲ្យយើង ។ កាលរាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព មិនឃើញទេ ក៏ត្រាស់ថា ចូររកឲ្យពេញនគរ ។ លុះរកពេញព្រះនគរមិនឃើញ ទើបត្រាស់ថា ចូរឲ្យមនុស្សរកខាងក្រៅនគរ ដោយហោច សូម្បីក្នុងផ្ទះមនុស្សក្រីក្រទុរគត ក៏កុំវៀរ ។ រាជបុរសទាំងឡាយនាំគ្នាឆែកឆេរ ទើបឃើញព្រះចូឡាមណីក្នុងផ្ទះរបស់នាងបញ្ចបាបី ក៏នាំគ្នាចងឪពុកម្តាយរបស់នាងដោយចោទថា ជាចោរ ។ លំដាប់នោះ បិតារបស់នាងបញ្ចបាបីពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនមែនចោរទេ អ្នកដទៃនាំមកឲ្យ ។

រាជបុរសសួរថា អ្នកណានាំមកឲ្យ ។

បិតារបស់នាងបញ្ចបាបីឆ្លើយថា កូនប្រសាប្រុសរបស់ខ្ញុំ ។

រាជបុរសសួររកថា កូនប្រសានោះ នៅឯណា ។

បិតារបស់នាងឆ្លើយថា កូនស្រីរបស់ខ្ញុំ ទើបដឹង ។ កាលនោះ បិតាបែរមកពោលជាមួយកូនស្រីថា នែកូនស្រី នាងស្គាល់ប្តីរបស់នាងឬទេ ។

នាងឆ្លើយថា ខ្ញុំមិនស្គាល់ទេ ។

បិតាពោលថា បើដូច្នោះ ជីវិតរបស់យើង នឹងមិនមាន ។

នាងបញ្ចបាបីពោលថា បពិត្រលោកឪពុក ប្ដីរបស់ខ្ញុំមកក្នុងពេលយប់ ត្រឡប់ទៅ ក៏ក្នុងពេលយប់ ព្រោះហេតុនោះ ទើបខ្ញុំមិនស្គាល់រូបរាងរបស់គាត់ តែបើបានស្ទាបដៃហើយ ក៏នឹងអាចដឹងបាន ។

បិតារបស់នាង ក៏ប្រាប់ដល់រាជបុរសទាំងឡាយ ។ ពួករាជបុរសទាំងឡាយ ក៏នាំសេចក្ដីទៅក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាធ្វើដូចជាទ្រង់មិនជ្រាប ត្រាស់ថា បើដូច្នោះ ចូរឲ្យស្រីនោះ អង្គុយក្នុងវាំងននត្រង់លានព្រះរាជវាំង ហើយចោះវាំងននល្មមលូកដៃបាន ឲ្យអ្នកនគរមកប្រជុំគ្នា ឲ្យស្រីនោះចាប់ចោរឲ្យបានដោយសម្ផស្សដៃ ។ រាជបុរសទាំងឡាយ ក៏ធ្វើតាមព្រះរាជតម្រាស់ នាំគ្នាទៅកាន់សម្នាក់របស់នាងបញ្ចបាបី សម្លឹងមើលរូបហើយ ក៏មានការខកចិត្តស្ដាយក្រោយ ពោលថា ថ្វីយ ៗ ស្រីបិសាច! ហើយខ្ពើមមិនហ៊ានប៉ះពាល់ ។ កាលនាំនាងមកហើយ ឲ្យអង្គុយក្នុងវាំងនន ត្រង់លានព្រះរាជវាំង រៀបចំឲ្យអ្នកនគរទាំងអស់ មកប្រជុំព្រមគ្នា ។ នាងបញ្ចបាបីក៏ចាប់ដៃបុរសដែលមកហើយលូកដៃចូលទៅក្នុងប្រហោងវាំងនន ប្រាប់រឿយ ៗ ថា នេះមិនមែនជាប្ដីរបស់ខ្ញុំទេ ។ បុរសទាំងឡាយបានប៉ះសម្ផស្ស ក៏ជាប់ចំពាក់ក្នុងសម្ផស្សរបស់នាងដូចសម្ផស្សទិព្វ មិនអាចចៀសចេញទៅ គិតក្នុងចិត្តថា បើស្រីនេះ គួរដល់បំណុល អញនឹងរកទ្រព្យមកលោះ ទោះបីធ្វើជា

ទាសកម្មករក៏ដោយ អញនឹងនាំនាងនេះ ទៅទុកក្នុងផ្ទះ ។ លំដាប់នោះ រាជបុរសវាយដោយរំពាត់ ទើបគេចទៅ ។ មនុស្សទាំងពួង តាំងអំពីឧបរាជឡើងទៅ ក៏មានអាការដូចមនុស្សឆ្កួត ។

លំដាប់នោះ ព្រះបាទពារាណសីត្រាស់ថា **កាចិ អហំ ភវេយ្យំ** ប្រហែលជាយើងទេដឹង ទើបលូកព្រះហស្តចូលទៅ ។ នាងក៏ចាប់ព្រះហស្តជាប់ ស្រែកដោយសំឡេងខ្លាំងថា **ចោរោ មេ គហិតោ** ខ្ញុំចាប់ចោរបានហើយ ។ លំដាប់នោះ ព្រះបាទពារាណសីត្រាស់សួររាជបុរសទាំងឡាយថា កាលនាងចាប់ដៃរបស់ពួកអ្នក តើពួកអ្នកគិតដូចម្តេច ។

រាជបុរសទាំងឡាយ ក៏ក្រាបបង្គំទូលតាមសេចក្តីពិត ។ លំដាប់នោះ ព្រះបាទពារាណសីត្រាស់ថា ដែលយើងឲ្យធ្វើយ៉ាងនេះ ដើម្បីនាំស្រីនេះ មកទុកក្នុងព្រះរាជវាំង ព្រោះគិតឃើញថា បើអ្នកទាំងឡាយមិនដឹងសម្បូរបស់ស្រីនេះ ក៏នឹងមើលងាយពេបជ្រាយឲ្យយើងបាន ព្រោះហេតុនោះ ទើបយើងរកឧបាយឲ្យអ្នកទាំងឡាយដឹង ចូរពោលទៅមើល ស្រីនេះ សមគួរនៅក្នុងផ្ទះអ្នកណា ។

រាជបុរសទាំងឡាយក្រាបទូលថា **តុម្ហាកំ ទេវ** សមគួរនៅក្នុងវាំងរបស់ព្រះអង្គ ។ លំដាប់នោះ ព្រះបាទពារាណសីក៏ឲ្យអភិសេកតែងតាំងជាអគ្គមហេសី និងព្រះរាជទានឥស្សរិយយសដល់ឪពុកម្តាយ

របស់នាង ។ តាំងអំពីនោះមក ព្រះបាទពារាណសីទ្រង់វង្វេងក្នុងព្រះនាងបញ្ចបាបី រហូតលែងខ្វល់ក្នុងការកាត់ក្តី ទ្រង់មិនសម្លឹងមើលស្រីដទៃ ពួកស្រីស្នំទាំងឡាយក៏ចាំចាប់កំហុស ។

សម័យថ្ងៃមួយ ព្រះនាងបញ្ចបាបីយល់សុបិននិមិត្ត ដែលខ្លួនត្រូវបានជាអគ្គមហេសីរបស់ស្តេចផែនដី ២ អង្គ ទើបព្រះនាងក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាប ។ ព្រះបាទពារាណសីឲ្យហៅហោរាមកគាល់ ត្រាស់សួរថា យល់សប្តិឃើញបែបនេះ នឹងមានផលដូចម្តេច ។

ពួកហោរាបានសំណូកពីស្នំដទៃ ៗ ក៏ទាយថា បពិត្រមហារាជការដែលព្រះទេវីទ្រង់សុបិនបានអង្គុយលើកដំរីសសុទ្ធនោះ ជាបុព្វនិមិត្តនាំមរណៈមកឲ្យព្រះអង្គ ការដែលព្រះនាងទ្រង់សុបិនថា អង្គុយលើកដំរីហើយស្ទាបព្រះចន្ទលេងនោះ ជាបុព្វនិមិត្តដែលនាំព្រះរាជាជាសត្រូវមកឲ្យដល់ព្រះអង្គ ។

ព្រះបាទពារាណសីត្រាស់សួរថា ឥឡូវនេះ គួរធ្វើដូចម្តេច ។

ពួកអ្នកទាយយល់សប្តិក្រាបទូលថា បពិត្រព្រះសម្មតិទេព មិនអាចសម្លាប់ព្រះនាងឡើយ គួរដាក់ទូកបណ្តែតព្រះនាងទៅតាមស្ទឹង ។ ព្រះរាជាឲ្យដាក់នាងបញ្ចបាបីក្នុងទូក មួយអន្ទើដោយស្បៀងអាហារសំពត់ និងគ្រឿងអលង្ការទាំងឡាយ ក្នុងពេលរាត្រី ហើយបន្សាត់ទូកទៅក្នុងស្ទឹង ។

ទូកនាងបញ្ចាបាបីអណ្តែតទៅតាមខ្សែទឹក រហូតដល់មុខទឹកទន្លេង ដែលព្រះបាទពាវរីទ្រង់ជិះទូកក្រសាលឧទកកីឡា នៅខាងក្រោមខ្សែទឹក សេនាបតីរបស់ព្រះបាទពាវរីឃើញទូកនោះ ក៏ស្រែកថា **អយំ ឆាវា មយ្ហំ** ទូកនោះជារបស់ខ្ញុំ ។

ព្រះបាទពាវរីត្រាស់ថា **ឆាវាយ កណ្ឌំ មយ្ហំ** ភណ្ឌៈនៅក្នុងទូកជារបស់យើង ។ លុះទូកមកដល់ ក៏ទតឃើញនាងបញ្ចាបាបី ទើបត្រាស់សួរថា **កា ឆាម ត្វំ បិសាចីសទិសា** ម្នាលនាងដូចបិសាច តើនាងឈ្មោះអ្វី ។

នាងបញ្ចាបាបីញញឹម ហើយទូលអំពីភាពដែលនាងជាអគ្គមហេសីរបស់ព្រះបាទពកៈ ទូលហេតុទាំងពួងឲ្យទ្រង់ជ្រាប ។ ឯនាងបញ្ចាបាបីនោះ មានឈ្មោះបោះសំឡេងប្រាកដពេញជម្ពូទ្វីប ព្រះបាទពាវរីក៏ទ្រង់ចាប់ដៃនាងទាញចេញអំពីទូក ដំណាលគ្នានឹងការចាប់ដៃប៉ុណ្ណោះ ទ្រង់ក៏ត្រេកអរដោយរាគៈក្នុងសម្ផស្ស រហូតមិនដឹងថា ស្រីដទៃមាន ទើបទ្រង់តែងតាំងនាងទុកក្នុងតំណែងអគ្គមហេសី នាងក៏ជាទីស្រឡាញ់ស្មើដោយជីវិត ។

ព្រះបាទពកៈបានស្តាប់ដំណឹងនោះ ទ្រង់ព្រះតម្រិះថា អញមិនព្រមឲ្យព្រះបាទពាវរីតែងតាំងនាងបញ្ចាបាបីជាអគ្គមហេសី ទើបរួបរួមពលសេនា ហើយលើកទ័ពទៅបោះជំរំត្រង់កំពង់ទឹក ហើយបានបញ្ជូន

សាសន៍ទៅថា ឲ្យមហេសីមកវិញ ឬក៏ច្បាំងគ្នា ។

ព្រះបាទពាវរីត្រាស់តបទៅថា យើងនឹងច្បាំង មិនឲ្យមហេសីរបស់យើងឡើយ ហើយទ្រង់ក៏លើកទ័ពមក ។ អាមាត្យទាំង ២ ពួកប្រឹក្សាគ្នាថា ពួកយើងនាំគ្នាមកស្លាប់ព្រោះអាស្រ័យមាតុគ្រាម មិនសមគួរឡើយ នាងបញ្ចបាបីគួរបានទៅព្រះបាទពកៈ ព្រោះធ្លាប់ជាស្វាមីអំពីមុន តែក៏គួរបានដល់ព្រះបាទពាវរី ព្រោះទ្រង់រើសបានក្នុងទូក ព្រោះហេតុនោះ ព្រះនាងបញ្ចបាបី គួរនៅក្នុងព្រះរាជដំណាក់របស់ព្រះរាជា មួយអង្គ ៧ ថ្ងៃ ទើបក្រាបទូលឲ្យព្រះរាជាទាំង ២ អង្គ យល់ព្រម ។

ព្រះរាជាទាំងពីរព្រះអង្គពេញព្រះហឫទ័យ ឲ្យសាងនគរត្រង់ឆ្មេរស្ទឹងទាំងសងខាង ហើយប្រថាប់គង់ ។ នាងបញ្ចបាបីធ្វើជាអគ្គមហេសីរបស់ព្រះរាជាទាំងពីរអង្គ ។ ព្រះរាជាទាំងពីរអង្គ វង្វេងក្នុងសម្ផស្សរបស់នាង ។ ចំណែកនាងបញ្ចបាបី កាលគង់នៅក្នុងដំណាក់របស់ព្រះរាជាមួយអង្គ គ្រប់ ៧ ថ្ងៃហើយ ក៏ចុះទូកទៅកាន់ព្រះរាជដំណាក់ព្រះរាជាមួយអង្គទៀត បានធ្វើអនាចារក្នុងស្ទឹងជាមួយអ្នកប្រមង់ខ្នងគម ចាស់ជរា ដែលជាអ្នកអុំទូកនាំព្រះនាងទៅ ។

កាលនោះ បក្សីកុណាលៈកើតជាព្រះបាទពកៈ ព្រោះហេតុនោះ កាលនាំរឿងដែលខ្លួនបានដឹងហើយមកសម្តែង ទើបពោលថា

**ពកស្ស ច ពាវរិយស្ស រញ្ញោ**

**អច្ចន្តកាមានុគតស្ស ភរិយា**

**អណាចរី បជ្ជវសានុគស្ស**

**កាំ វា ឥត្ថី ជាតិចរេ តជញ្ញំ ។**

*ភរិយារបស់ព្រះបាទពកៈ និងព្រះបាទពាវរិយៈ ( ដែល ) ជាព្រះរាជាល្មោភកាមដ៏ក្រៃលែង បានប្រព្រឹត្តក្បត់ចំពោះបុរសអ្នកលុះក្នុងអំណាច ដែលខ្លួនប្រាថ្នា ស្រីមិនប្រព្រឹត្តកន្ទង់ស្វាមី នឹងបុរសដទៃនោះ ឯណាកើត [១] ដូច្នេះ ។*

**នាងបញ្ចបាបី ចប់** [២]

---

*១-បិ.៦១ ទំ.១៧២ ឃ.៣០៨ ។ ២-ស្រង់ចាកអដ្ឋកថា ជាតក អសីតិនិបាត កុណាលជាតក បិ.៦១ ទំ.១៧២ ឃ.៣០៨ ។*

# កុសជាតក

ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះថា

ក្នុងអតីតកាល ព្រះរាជា ១ អង្គ ព្រះនាមថា ព្រះបាទឱក្កាករាជ ទ្រង់គ្រប់គ្រងរាជសម្បត្តិដោយធម៌ ក្នុងរាជធានីឈ្មោះកុសាវតី ក្នុងដែនមល្ល: ។ ព្រះរាជាមានអគ្គមហេសីព្រះនាមសីលវតី ដែលជាធំជាងស្រីស្នំ ១៦ ពាន់នាក់ ព្រះនាងសីលវតីនោះ មិនមានព្រះរាជឱរស និងព្រះរាជធីតាឡើយ ។ លំដាប់នោះ អ្នកនគរនិងអ្នកដែនទាំងឡាយ នាំគ្នាមកប្រជុំត្រង់ទ្វារព្រះរាជនិវេសន៍ ហើយស្រែកពោលទោសថា **រដ្ឋំ ឆស្សិស្សតិ រដ្ឋំ ឆស្សិស្សតិ** ដែននឹងវិនាស ដែននឹងវិនាស ។

ព្រះរាជាទ្រង់បើកសីហបញ្ជរហើយ ត្រាស់សួរថា កាលយើងគ្រប់គ្រងរដ្ឋ ឈ្មោះថា ការធ្វើវត្ថុមិនប្រកបដោយធម៌ មិនមានឡើយ ព្រោះហេតុអ្វី ទើបពួកអ្នកមកស្រែក ដូច្នេះ ។

មហាជនក្រាបទូលថា បពិត្រព្រះសម្មតិទេព សេចក្តីពិត ឈ្មោះថា ការធ្វើវត្ថុដែលមិនជាធម៌ មិនមានឡើយ តែព្រះរាជឱរសដែលបន្តវង្សរបស់ទ្រង់ មិនទាន់មាន ជនដទៃនឹងដណ្តើមយករាជសម្បត្តិ ដែននឹងវិនាស ព្រោះហេតុនោះ សូមទ្រង់ប្រាថ្នាព្រះរាជឱរសដែលអាចគ្រប់គ្រង

រាជសម្បត្តិដោយធម៌ចុះ ។

ព្រះរាជាត្រាស់សួរថា **បុត្តំ បត្ថេន្តោ កឹ ករោមិ** យើងកាលប្រាថ្នាព្រះរាជបុត្ត តើធ្វើដូចម្តេច ។

ជនទាំងនោះ ទូលថា ជាបឋម សូមទ្រង់ដោះលែងចុល្លនាដកា ( ស្រីរបាំថ្នាក់ទាប ) ធ្វើឲ្យជាអ្នករបាំដោយធម៌ទៅ ៧ ថ្ងៃ បើនាងបានបុត្ត ក៏ជាការល្អ បើមិនបានទេ បន្ទាប់អំពីនោះ សូមទ្រង់ដោះលែងមជ្ឈិមនាដកា ( ស្រីរបាំថ្នាក់កណ្តាល ) បន្ទាប់អំពីនោះ សូមដោះលែងជេដ្ឋនាដកា ( ស្រីរបាំថ្នាក់ខ្ពស់ ) បណ្តាស្រីរបាំមានប្រមាណប៉ុណ្ណោះ ស្រីរបាំដែលមានបុណ្យម្នាក់ នឹងបានព្រះរាជឱរស ដោយពិត ។

ព្រះរាជាទ្រង់ធ្វើតាមពាក្យរបស់អ្នកនគរទាំងនោះគ្រប់យ៉ាង ហើយត្រាស់សួរស្រីស្នំដែលទៅអភិរម្យជាមួយបុរសដទៃតាមគាប់ចិត្ត អស់ ៧ ថ្ងៃ ដែលនាំគ្នាត្រឡប់មកហើយថា នាងទាំងឡាយ បានបុត្តហើយឬ ។

ស្រីស្នំទាំងអស់នោះ ក្រាបទូលថា បពិត្រព្រះសម្មតិទេព មិនបានទេ ។ ព្រះរាជាទ្រង់ទោមនស្សថា បុត្តមិនកើតដល់អញ ដោយពិត ។ អ្នកនគរទាំងឡាយ ក៏នាំគ្នាស្រែកឡើងយ៉ាងនោះទៀត ។

ព្រះរាជាត្រាស់ថា ពួកអ្នកទាំងឡាយ នាំគ្នាមកស្រែក ដោយហេតុអ្វី យើងបានដោះលែងស្រីរបាំទាំងឡាយ ទៅតាមពាក្យរបស់ពួកអ្នកហើយ សូម្បីតែស្រីម្នាក់ ក៏មិនបានបុត្ត ឥឡូវនេះ ឲ្យយើងធ្វើដូចម្តេច ។

ពួកអ្នកនគរក្រាបទូលថា បពិត្រព្រះសម្មតិទេព ស្រីទាំងនោះ ជាស្រីទ្រុស្តសីល មិនមានបុណ្យ ស្រីទាំងនោះ មិនមានបុណ្យសម្រាប់បានបុត្តទេ បើពួកនាងមិនបានបុត្ត សូមទ្រង់កុំដាក់នូវព្រះឧស្សាហៈចោលឡើយ ព្រះនាងសីលវតីទេវី អគ្គមហេសីរបស់ទ្រង់ ព្រះនាងបរិបូណ៌ដោយសីល សូមទ្រង់ដោះលែងព្រះនាងទៅចុះ ព្រះនាងនឹងបានព្រះឱរស ដោយពិត ។

ព្រះរាជាទ្រង់ទទួលថា សាធុហើយ ទើបត្រាស់ឲ្យវាយស្គរប្រកាសថា បានឮថា ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះទៅ ព្រះរាជាទ្រង់ធ្វើព្រះនាងសីលវតីទេវី ឲ្យជាអ្នករបាំដោយធម៌ ហើយលែងទៅ បុរសទាំងឡាយចូរមកប្រជុំគ្នា ។ លុះដល់ថ្ងៃទី ៧ ទើបទ្រង់ឲ្យគេប្រដាប់តាក់តែងព្រះនាង ឲ្យចុះអំពីព្រះរាជនិវេសន៍ ហើយឲ្យចេញទៅ ។ ដោយតេជះនៃសីលរបស់ព្រះនាង សក្កពិភពក៏សម្តែងអាការក្តៅ សក្កៈទ្រង់ពិចារណាថា មានហេតុដូចម្តេចហ្ន៎ ក៏ទ្រង់ជ្រាបភាពដែលព្រះនាងប្រាថ្នាបុត្ត ទើបព្រះតម្រិះថា អញគួរឲ្យព្រះឱរសដល់ព្រះនាង ( កាលទ្រង់ពិចារណាបន្តថា ) ព្រះឱរសដែលសមគួរដល់ព្រះនាង ក្នុងទេវលោកនេះ មានឬហ្ន៎ ក៏បានឃើញព្រះពោធិសត្វ ។

បានឮថា ក្នុងកាលនោះ ព្រះពោធិសត្វអស់អាយុក្នុងឋានតាវត្តិង្សជាអ្នកប្រាថ្នាទៅកើតក្នុងទេវលោកខាងលើជាបន្ត សក្កទេវរាជក៏ទ្រង់យាង

ទៅកាន់ទ្វារវិមានរបស់ព្រះពោធិសត្វ ត្រាស់ថា នែអ្នកនិរទុក្ខ អ្នកគួរទៅកាន់មនុស្សលោក ហើយបដិសន្ធិក្នុងព្រះឧទរអគ្គមហេសីរបស់ព្រះបាទឱក្កាករាជ ឲ្យព្រះពោធិសត្វទទួលព្រមហើយ ទើបត្រាស់នឹងទេវបុត្តម្នាក់ទៀតថា សូម្បីអ្នក ក៏ត្រូវជាឱរសរបស់ព្រះនាង ហើយយាងទៅកាន់ទ្វារនិវេសន៍របស់ព្រះរាជា ដោយភេទជាព្រាហ្មណ៍ចាស់ ដោយទ្រង់ព្រះតម្រិះថា បុគ្គលណាមួយ កុំបីទម្លាយសីលរបស់ព្រះនាងឡើយ ។

មហាជនផ្ងូតទឹកតាក់តែងកាយហើយ ទៅប្រជុំត្រង់ទ្វារព្រះរាជនិវេសន៍ ដោយគិតថា អញនឹងទទួលយកព្រះទេវី អញនឹងទទួលយកព្រះទេវី កាលឃើញសក្កទេវរាជ ក៏សើចចំអកថា អ្នកមកព្រោះអ្វី ។

សក្កទេវរាជត្រាស់ថា ព្រោះហេតុអ្វី ទើបអ្នកទាំងឡាយតិះដៀលខ្ញុំ ទោះរាងកាយខ្ញុំចាស់ជរា ក៏ពិត តែរាគៈ មិនចាស់ទេ បើខ្ញុំបានព្រះនាងសីលវតី ខ្ញុំនឹងនាំព្រះនាងទៅ ហើយនាំមកវិញ ដូច្នេះហើយ ទើបទៅឈរខាងមុខគេបង្អស់ ដោយអានុភាពរបស់ខ្លួន ។ អ្នកដទៃ មិនអាចឈរពាំងមុខបានឡើយ ដោយតេជះរបស់សក្កនោះ ។ លុះព្រះនាងប្រដាប់គ្រឿងអលង្ការទាំងពួងហើយ យាងចេញអំពីព្រះរាជនិវេសន៍ សក្កៈចាប់ត្រង់ព្រះហស្ត នាំចៀសចេញទៅ ។

លំដាប់នោះ មហាជនទាំងឡាយដែលនៅក្នុងទីនោះ ក៏នាំគ្នាតិះដៀលថា មើលចុះ លោកដ៏ចម្រើន ព្រាហ្មណ៍ចាស់នាំព្រះទេវីដែល

ទ្រទ្រង់នូវព្រះរូបល្អឯកដល់ម៉្លេះទៅ ( តាចាស់នោះ ) មិនដឹងវត្ថុដែលសមគួរដល់ខ្លួនឡើយ ។ ឯព្រះទេវីក៏មិនខ្មាសអៀនក្នុងព្រះហឫទ័យថា ព្រាហ្មណ៍ចាស់នេះ នាំអញទៅ ។ សូម្បីព្រះរាជាទ្រង់ប្រថាប់ឈរក្បែរបង្អួច រង់ចាំមើលថា នរណាហ្ន៎ នាំព្រះទេវីទៅ កាលឃើញព្រាហ្មណ៍ចាស់ ទ្រង់ក៏ទោមនស្ស ។

សក្កទេវរាជនាំព្រះនាងចេញអំពីទ្វារព្រះនគរ ទ្រង់និម្មិតផ្ទះមួយខ្នង ក្បែរទ្វារនគរ ដែលមានទ្វារបើកទុក និងចាត់ចែងកម្រាលដែលធ្វើដោយឈើទុកហើយ ។ លំដាប់នោះ ព្រះនាងត្រាស់សួរថា នេះជាផ្ទះរបស់អ្នកឬ ។ សក្កទេវរាជត្រាស់ថា ពិតហើយ នាងដ៏ចម្រើន កាលមុនខ្ញុំនៅតែម្នាក់ឯង ឥឡូវនេះ ខ្ញុំនិងនាងនៅជាមួយគ្នាពីរនាក់ ខ្ញុំត្រូវត្រាច់ទៅរកស្បៀង មានអង្ករជាដើមមក សូមនាងសម្រាកលើកម្រាលក្តារនេះសិនចុះ ហើយយកព្រះហស្តដ៏ទន់ស្ទាបអង្អែលព្រះនាង ទិព្វសម្ផស្សក៏ផ្សាយទៅពេញព្រះកាយ ព្រះនាងក៏ផ្ទំលក់ក្នុងទីនោះ ។ ដោយការផ្សាយនៃទិព្វសម្ផស្ស ទើបព្រះនាងអស់នូវសញ្ញា គឺផ្ទំលក់ទៅ ។

លំដាប់នោះ សក្កទេវរាជក៏នាំព្រះនាងទៅកាន់ឋានតាវត្តិង្សដោយអានុភាពរបស់ខ្លួន ឲ្យព្រះនាងផ្ទំលើទិព្វសយនៈ ក្នុងវិមានដែលប្រដាប់តាក់តែងហើយ ។ ក្នុងថ្ងៃទី ៧ ព្រះនាងក៏តើនអំពីផ្ទំ ទតឃើញសម្បត្តិនោះ ជ្រាបបានថា ព្រាហ្មណ៍នេះ មិនមែនជាមនុស្ស ជាសក្កទេវរាជ

ដោយពិត ។

ក្នុងសម័យនោះ សក្កទេវរាជ ទ្រង់ចោមរោមដោយអ្នករបាំដ៏ជាទិព្វ ប្រថាប់គង់ត្រង់គល់បារិច្ឆត្តកព្រឹក្ស ។ ព្រះនាងក្រោកចាកទីបន្ទំយាងចូលទៅរកសក្កទេវរាជ ថ្វាយបង្គំ ហើយប្រថាប់ឈរក្នុងចំណែកម្ខាង ។ លំដាប់នោះ សក្កទេវរាជត្រាស់ថា ម្នាលនាងទេវី យើងនឹងឲ្យពរដល់ព្រះនាង ព្រះនាងចូរទទួលយកចុះ ។ ព្រះទេវីត្រាស់ថា បពិត្រព្រះទេវៈ បើដូច្នោះ សូមទ្រង់ប្រទានបុត្តមួយអង្គ ដល់ខ្ញុំម្ចាស់ចុះ ។

សក្កទេវរាជត្រាស់ថា ម្នាលនាងទេវី ព្រះរាជឱរស ១ អង្គ ចូរស្នេះទុកសិនចុះ យើងនឹងឲ្យព្រះរាជឱរស ២ អង្គ ដល់ព្រះនាង ។ បណ្ដាព្រះរាជឱរសទាំង ២ អង្គនោះ ១ អង្គមានបញ្ញា តែរូបសម្បត្តិមិនស្អាត ១ អង្គរូបស្អាត តែមិនសម្បូរដោយបញ្ញា ។ បណ្ដាព្រះឱរស ២ អង្គនោះ ព្រះនាងប្រាថ្នាមួយណាមុន ។ ព្រះនាងក្រាបទូលថា **បញ្ញវន្តំ ទេវ** បពិត្រព្រះទេវៈ ខ្ញុំម្ចាស់ប្រាថ្នាព្រះឱរសដែលមានបញ្ញាមុន ។

សក្កទេវរាជត្រាស់ថា សាធុ ហើយទ្រង់ប្រទានវត្ថុ ៥ យ៉ាង គឺស្បូវក្ខាំង ១ សំពត់ទិព្វ ១ ខ្លឹមចន្ទន៍ទិព្វ ១ ផ្កាបារិច្ឆត្តកទិព្វ ១ ពិណឈ្មោះកោកនុទៈ ១ ដល់ព្រះនាង ហើយនាំព្រះនាងហោះទៅកាន់ទីបន្ទំរបស់ព្រះរាជា ឲ្យព្រះនាងផ្ទំលើព្រះទែនជាមួយព្រះរាជា ទ្រង់ស្ទាបព្រះនាភី ( ផ្ចិត ) របស់ព្រះនាងដោយម្រាមព្រះហស្ត ។ ក្នុងខណៈនោះ

ព្រះពោធិសត្វទ្រង់បដិសន្ធិក្នុងព្រះឧទររបស់ព្រះនាង ។ សក្កទេវរាជក៏យាងទៅកាន់លំនៅរបស់ព្រះអង្គវិញ ។ ព្រះទេវីជាបណ្ឌិត ដឹងបានថា ព្រះនាងតាំងព្រះគភ៌ហើយ ។

លំដាប់នោះ ព្រះរាជាតើនចាកព្រះបន្ទំ ទ្រង់ទតឃើញព្រះទេវី ទើបសួរថា នែទេវី អ្នកណានាំនាងមក ។ ព្រះទេវីទូលថា សក្កទេវរាជព្រះអង្គ ។

ព្រះរាជាត្រាស់ថា យើងបានឃើញនាងនឹងភ្នែក ព្រាហ្មណ៍ចាស់ម្នាក់ បាននាំនាងទៅ ហេតុអ្វី ទើបនាងបោកបញ្ឆោតយើង ។ ព្រះទេវីក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ជឿចុះ សក្កទេវរាជនាំខ្ញុំម្ចាស់ទៅ បាននាំទៅដល់ទេវលោក ។

ព្រះរាជាត្រាស់ថា ម្នាលទេវី យើងមិនជឿឡើយ ។ លំដាប់នោះ ទើបព្រះនាងបង្ហាញស្បូវក្លាំងដែលសក្កៈប្រទាន ដល់ព្រះរាជា ហើយក្រាបទូលថា សូមទ្រង់ជឿខ្ញុំម្ចាស់ចុះ ។

ព្រះរាជាត្រាស់ថា នេះឈ្មោះថា ស្បូវក្លាំង ក្នុងទីណា បុគ្គលណាម្នាក់ ក៏អាចរកបាន ដូច្នេះហើយ ទ្រង់ក៏មិនជឿ ។ លំដាប់នោះ ព្រះនាងក៏នាំយកសំពត់ទិព្វជាដើម មកបង្ហាញដល់ព្រះរាជា ។ ព្រះរាជាលុះទ្រង់បានទតឃើញវត្ថុទាំងនោះហើយ ទើបទ្រង់ជឿ ហើយត្រាស់ថា នែនាងដ៏ចម្រើន រឿងសក្កទេវរាជនាំនាងទៅ ចូរស្ងេះទុកសិនចុះ

តើនាងបានបុត្តហើយឬ ។

ព្រះទេវីក្រាបទូលថា បពិត្រមហារាជ បានហើយ ខ្ញុំម្ចាស់តាំងគភ៌ហើយ ។ ព្រះរាជាទ្រង់បានស្តាប់ពាក្យនោះហើយ ក៏ទ្រង់ត្រេកអរ ទើបព្រះរាជទានគ្រឿងបរិហារគភ៌ដល់ព្រះនាង ។ លុះគ្រប់កំណត់ទសមាស ព្រះនាងក៏ប្រសូតព្រះរាជឱរស ព្រះជនកនិងព្រះជននីមិនបានថ្វាយព្រះនាមដទៃ ដល់ព្រះរាជឱរសនោះឡើយ ទ្រង់ថ្វាយព្រះនាមថា កុសតិណៈនោះឯង ។ ក្នុងកាលដែលកុសកុមារធំដើរទៅមកបាន ទេវបុត្តមួយអង្គទៀត ក៏បដិសន្ធិក្នុងព្រះឧទររបស់ព្រះនាង ។ លុះគ្រប់ទសមាស ព្រះនាងក៏ប្រសូតព្រះរាជឱរសមួយអង្គទៀត ព្រះជនកនិងព្រះជននី ក៏បានថ្វាយព្រះនាមព្រះរាជកុមារនោះថា ជយម្បតិ ។ ព្រះរាជកុមារទាំងពីរអង្គនោះ ទ្រង់ចម្រើនព្រះជន្មវស្សាដោយយសដ៏ធំ ។ ព្រះពោធិសត្វទ្រង់មានបញ្ញា ទ្រង់មិនចាំបាច់សិក្សាសិប្បៈណាមួយ ក្នុងសម្នាក់របស់អាចារ្យ ក៏ទ្រង់ដល់នូវការសម្រេចក្នុងសិប្បៈទាំងអស់បាន ដោយបញ្ញារបស់ទ្រង់ ។

លំដាប់នោះ ក្នុងកាលព្រះពោធិសត្វចម្រើនព្រះជន្មាយុ បាន ១៦ ព្រះវស្សា ព្រះរាជាទ្រង់ប្រាថ្នាប្រគល់រាជសម្បត្តិ ទើបឲ្យហៅព្រះទេវីមកហើយត្រាស់ថា ម្នាលនាងដ៏ចម្រើន យើងនឹងប្រគល់រាជសម្បត្តិឲ្យដល់បុត្ត ( ច្បង ) របស់នាង ហើយឲ្យស្រីរបាំទាំងឡាយបម្រើ ទាន់យើងទាំង

ពីរនៅមានជីវិត យើងនឹងបានឃើញកូនសោយរាជសម្បត្តិ ឯកូនរបស់យើងប្រាថ្នាព្រះរាជធីតារបស់ស្តេចអង្គណា ក្នុងជម្ពូទ្វីបទាំងមូល យើងនឹងនាំព្រះរាជធីតានោះ មកស្តាបនាឲ្យជាអគ្គមហេសី ចូរនាងដឹងចិត្តរបស់កូនថា គេពេញចិត្តព្រះរាជធីតាអង្គណា ។

ព្រះនាងត្រាស់ថា សាធុ ហើយបញ្ជូនបរិចារិកាម្នាក់ទៅ ដោយព្រះតម្រាស់ថា ចូរនាងទៅប្រាប់រឿងនេះ ដល់កុមារ ហើយចូរដឹងចិត្តរបស់គេ ។ បរិចារិកានោះក៏ទៅ ហើយទូលរឿងនោះដល់ព្រះរាជកុមារ ។ ព្រះមហាសត្វបានស្តាប់ពាក្យនោះហើយ គិតថា អញមានរូបអាក្រក់ ព្រះរាជធីតាដែលដល់ព្រមដោយរូប ទោះបីនាំមក គ្រាន់តែឃើញអញក៏នឹងគេចទៅ ដោយគិតថា ប្រយោជន៍អ្វីដោយកុមារដែលមានរូបគួរខ្ពើម ការខ្មាសអៀនគប្បីមានដល់អញដោយប្រការដូច្នេះ ប្រយោជន៍អ្វីដោយឃរាវាស អញបម្រើព្រះជនកនិងព្រះជននីដែលកំពុងមានព្រះជន្មអំណឹះតតអំពីទ្រង់ទាំងទ្វេទៅ អញនឹងចេញបួស ទើបត្រាស់ថា យើងមិនមានសេចក្តីត្រូវការដោយរាជសម្បត្តិ មិនត្រូវការដោយស្រីរបាំទេ អំណឹះតតអំពីព្រះជនកនិងព្រះជននីទៅ យើងនឹងបួស ។ បរិចារិកានោះ ស្តាប់ព្រះតម្រាស់នោះហើយ ទើបត្រឡប់មកក្រាបទូលព្រះទេវី ។ ចំណែកព្រះទេវីក៏ក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ទ្រង់ក៏ទោមនស្ស លុះកន្លងទៅពីរបីថ្ងៃ ក៏បញ្ជូនដំណឹងទៅ

ទៀត ។ ឯព្រះរាជកុមារនោះ ក៏នៅតែជំទាស់ដូចមុន ។ ព្រះរាជកុមារទ្រង់ជំទាស់យ៉ាងនេះ អស់វារៈ ៣ ដង ក្នុងវារៈទី ៤ ទើបព្រះតម្រិះថា ធម្មតាកូនដែលរឹងទទឹងនឹងមាតាបិតាជារឿយ ៗ មិនសមគួរឡើយ អញនឹងធ្វើឧបាយមួយ ។

ព្រះរាជកុមារឲ្យហៅមេជាងមាសម្នាក់មក ហើយព្រះរាជទានមាសជាច្រើន ត្រាស់ថា **ឯកំ ឥត្ថិរូបកំ ករោហិ** ចូរធ្វើរូបស្ត្រីមួយ ហើយបញ្ជូនជាងមាសនោះទៅ កាលជាងមាសនោះទៅហើយ ទើបទ្រង់នាំយកមាសដទៃមកធ្វើជារូបស្រីដោយព្រះអង្គឯង ធម្មតាបំណងរបស់ព្រះពោធិសត្វទាំងឡាយ រមែងសម្រេច ។ រូបមាសដែលព្រះពោធិសត្វទ្រង់ធ្វើនោះ ល្អពន់ពេក រហូតមិនមានពាក្យពណ៌នាដោយអណ្តាតបាន ។ លំដាប់នោះ ព្រះមហាសត្វទ្រង់ឲ្យរូបស្រីនោះ ស្លៀកខោមពស្ត្រ ហើយតម្កល់ទុកក្នុងបន្ទប់ដ៏មានសិរី ។ ព្រះមហាសត្វទតឃើញរូបស្រីដែលជាងមាសនាំមក ទ្រង់តិះដៀលរូបនោះ ហើយត្រាស់ថា ចូរអ្នកទៅនាំយករូបស្រី ដែលតម្កល់ទុកខាងក្នុងបន្ទប់ដ៏មានសិរីរបស់យើងមក ។

ជាងមាសនោះ ចូលទៅកាន់បន្ទប់ដ៏មានសិរី ឃើញរូបស្រីនោះហើយ ស្មានថា មានទេពអប្សរម្នាក់ មករួមអភិរម្យជាមួយព្រះរាជកុមារ ទើបមិនអាចលាដៃទៅចាប់ ត្រឡប់មកទូលថា បពិត្រព្រះសម្មតិទេព

ព្រះនាងម្ចាស់ប្រថាប់ឈរម្នាក់ឯង ក្នុងបន្ទប់ដ៏មានសិរី ទូលព្រះបង្គំមិនអាចចូលទៅបាន ។

ព្រះរាជកុមារទ្រង់បញ្ជូនទៅទៀត ដោយត្រាស់ថា នែលោក ចូរលោកទៅនាំយករូបមាសនោះមក ហើយទ្រង់បញ្ជូនទៅ ឲ្យនាំយករូបមាសនោះមក ។ ព្រះរាជកុមារឲ្យទុករូបមាសដែលជាងមាសធ្វើនោះក្នុងបន្ទប់សម្រាប់ដាក់មាស ហើយឲ្យមនុស្សតាក់តែងរូបដែលទ្រង់ធ្វើលើកឡើងដាក់លើរថ បញ្ជូនទៅកាន់សម្នាក់ព្រះមាតាដោយព្រះតម្រាស់ថា បើរកបានស្រីមានសភាពបែបនេះ ទូលព្រះបង្គំនឹងទទួល ។

ព្រះទេវីឲ្យហៅអាមាត្យទាំងឡាយមក ហើយមានព្រះសវនីយ៍ថា នែបាទាំងឡាយ បុត្តរបស់យើងមានបុណ្យច្រើន ជាព្រះរាជបុត្តដែលសក្កទេវរាជប្រទាន គួរបានកុមារិកាដែលមានរូបបែបនេះ ពួកអ្នក កាលបានកុមារិកាមានរូបបែបនេះ ចូរនាំមក ចូរតាំងរូបនេះទុកលើយានដែលបិទបាំង ហើយត្រាច់ទៅក្នុងជម្ពូទ្វីបទាំងមូល បើបានចួបព្រះរាជធីតារបស់ព្រះរាជាអង្គណា ដែលមានរូបបែបនេះសោត ចូរថ្វាយរូបមាសនេះ ចំពោះព្រះរាជាអង្គនោះ ហើយក្រាបទូលថា ព្រះបាទឱក្កាករាជទ្រង់នឹងធ្វើអាវាហវិវាហមង្គលជាមួយព្រះអង្គ ទូលកំណត់ថ្ងៃហើយ ចូរត្រឡប់មក ។

អាមាត្យទាំងនោះ ទទួលព្រះរាជសវនីយ៍ថា សាធុ ហើយនាំរូប

នោះ ចេញអំពីព្រះនគរមួយអន្លើដោយបរិវារច្រើន ត្រាច់ស្វែងរកដល់រាជធានីណា ក៏តាក់តែងរូបស្រីនោះ ដោយសំពត់ ផ្កា និងគ្រឿងអលង្ការលើកឡើងដាក់លើយានមាស តម្កល់ទុកត្រង់មាត់ផ្លូវដែលទៅកាន់កំពង់ទឹក ក្នុងទីដែលមហាជនមកប្រជុំគ្នាក្នុងពេលល្ងាច ក្នុងរាជធានីនោះ ចំណែកពួកខ្លួននាំគ្នាគេចទៅឈរក្នុងចំណែកម្ខាង ចាំស្តាប់ពាក្យរបស់មហាជន ដែលមកហើយ ។ ឯមហាជន កាលសម្លឹងមើលរូបស្រីនោះ មិនស្គាល់ថាជារូបមាស ទើបនាំគ្នាសរសើរថា ស្រីនេះ សូម្បីជាមនុស្ស ក៏ស្អាតដល់ម្ល៉េះ ប្រៀបដូចជាស្រីទេពអប្សរ ហេតុអ្វី ទើបមកឈរក្នុងទីនេះ នាងមកអំពីណា ស្រីមានសភាពបែបនេះ ក្នុងនគររបស់ពួកយើងមិនមានឡើយ ហើយនាំគ្នាចៀសចេញទៅ ។ ពួកអាមាត្យបានស្តាប់ពាក្យនោះហើយ ប្រឹក្សាគ្នាថា បើទារិកាស្អាតបែបនេះ មានក្នុងនគរនេះសោត ជនទាំងឡាយគប្បីពោលថា ស្រីនេះដូចព្រះរាជធីតាអង្គនោះ ស្រីនេះ ដូចធីតារបស់អាមាត្យឈ្មោះនោះ ក្នុងនគរនេះ គង់មិនមានស្រីស្អាតដូចរូបនេះ ពិត ទើបកាន់យករូបស្រីនោះ ទៅកាន់នគរដទៃទៀត ។

ពួកអាមាត្យត្រាច់ទៅយ៉ាងនេះ រហូតដល់សាគលនគរ ក្នុងដែនមទ្ទៈដោយលំដាប់ ។ ឯព្រះបាទមទ្ទរាជក្នុងសាគលនគរនោះ មានបុត្រី ៨ អង្គ មានរូបល្អឯក ប្រៀបដូចទេពអប្សរ ព្រះរាជធីតាច្បង មានព្រះនាមថា បភាវតី ព្រោះមានរស្មីផ្សាយចេញអំពីកាយរបស់ព្រះនាង ដូច

ពន្លឺព្រះអាទិត្យដែលទើបរះ ។ ក្នុងវេលាយប់ ក្នុងបន្ទប់ដែលមានផ្ទៃប្រមាណ ៤ ហត្ថ មិនចាំបាច់អុជប្រទីប ក្នុងបន្ទប់ទាំងមូលមានពន្លឺតែមួយដូចគ្នា ។ ព្រះនាងបភាវតីនោះ មានភីលៀងម្នាក់ជាស្រីគម ភីលៀងនោះ កាលឲ្យព្រះនាងបភាវតីសោយស្រេចហើយ ក៏ឲ្យនាងវណ្ណទាសី ៨ នាក់ កាន់ក្អមទឹក ៨ ទៅកាន់កំពង់ទឹក ក្នុងពេលល្ងាច ដើម្បីដងទឹកមកស្រពស្រង់ព្រះនាង ។ ស្រីភីលៀងនោះ កាលឃើញរូបមាសដែលតម្កល់ទុកក្បែរផ្លូវដើរទៅកាន់កំពង់ទឹក សម្គាល់ថាជាព្រះនាងបភាវតី ក៏គ្រោធថា ព្រះនាងនេះ ប្រដៅក្រមែន ពោលថា ខ្ញុំចង់ស្រង់ទឹកកក់សីសៈ បញ្ជូនពួកយើងមកដងទឹក បែរជាមកឈរត្រង់ផ្លូវទៅកាន់កំពង់ទឹកមុនយើងទៅទៀត ដូច្នេះហើយ ក៏ពោលថា នៃព្រះនាង ព្រះនាងធ្វើឲ្យត្រកូលបានទទួលនូវភាពអាម៉ាស់ ព្រោះហេតុអ្វីទើបព្រះនាងមកឈរក្នុងទីនេះ មុនពួកយើង បើព្រះរាជាទ្រង់ជ្រាបសោត គង់ធ្វើពួកយើងឲ្យវិនាសពិត ហើយយកដៃទះថ្ពាល់រូបមាសនោះ បាតដៃក៏ហាក់ដូចជាបែក ។ លំដាប់នោះ ដឹងថា ជារូបមាស ក៏សើចហើយទៅរកពួកនាងវណ្ណទាសី ពោលថា ពួកនាងចូរមើលការធ្វើរបស់ខ្ញុំចុះ ខ្ញុំបានវាយដោយស្មានថា រូបនេះ ជាព្រះនាងរបស់យើង រូបនេះមានតម្លៃអ្វី ក្នុងសម្នាក់នៃព្រះរាជធីតារបស់យើង បានត្រឹមតែឲ្យដៃរបស់ខ្ញុំទទួលនូវការឈឺចាប់តែម្យ៉ាងប៉ុណ្ណោះ ។

គ្រានោះ ពួករាជទូតនាំគ្នាកាន់យករូបមាសនោះ សួរស្រីភីលៀង នោះថា នាងពោលថា ព្រះរាជធីតារបស់យើងស្អាតជាងរូបនេះ នាង ពោលសំដៅដល់នរណា ។ ភីលៀងនោះឆ្លើយថា ព្រះរាជធីតារបស់ ព្រះបាទមទ្ទរាជ ព្រះនាមថា បភាវតី រូបនេះ មិនដល់ចំណែកទី ១៦ របស់ព្រះនាងឡើយ ។ អាមាត្យទាំងនោះត្រេកអរ នាំគ្នាទៅកាន់ទ្វារ ព្រះរាជវាំងឲ្យក្រាបទូលថា ពួករាជទូតរបស់ព្រះបាទឱក្កាករាជមកគាល់ នៅត្រង់ទ្វារ ។ ព្រះរាជាទ្រង់ក្រោកចាកអាសនៈ ប្រថាប់ឈរ ហើយ ត្រាស់ថា ចូរហៅឲ្យចូលមកចុះ ។

ពួករាជទូតក៏ចូលទៅ ហើយថ្វាយបង្គំព្រះរាជា ក្រាបទូលថា បពិត្រមហារាជ ព្រះរាជារបស់ទូលព្រះបង្គំត្រាស់សួរថា ព្រះអង្គទ្រង់ (មានសេចក្ដីសុខ) មិនមានរោគទេឬ ។ ព្រះរាជាទ្រង់ធ្វើសក្ការៈទទួល ហើយ ត្រាស់សួរពួកអាមាត្យថា ពួកលោកមកទីនេះ ដើម្បីអ្វី ។

ពួកអាមាត្យក្រាបទូលថា ព្រះរាជារបស់ទូលព្រះបង្គំ មានព្រះរាជ បុត្តព្រះនាមថា កុសកុមារ មានព្រះសូរសៀងដូចសំឡេងរាជសីហ៍ ព្រះ រាជាទ្រង់មានព្រះរាជបំណង ប្រគល់រាជសម្បត្តិដល់ព្រះរាជឱរសនោះ បានឮថា ព្រះអង្គមានព្រះរាជធីតាព្រះនាមថា បភាវតី សូមព្រះអង្គព្រះ រាជទានព្រះនាងបភាវតី ព្រះរាជធីតារបស់ព្រះអង្គដល់ព្រះរាជបុត្តនោះ ចុះ ហើយសូមទ្រង់ទទួលរូបមាសនេះ ជាបណ្ណាការ លុះក្រាបទូល

ហើយ ទើបថ្វាយរូបមាសនោះ ចំពោះព្រះរាជា ។ ឯព្រះបាទមទ្ទរាជនោះ ក៏ទ្រង់រីករាយ ព្រមទទួល ដោយទ្រង់មានព្រះតម្រិះថា នឹងមានវិវាហមង្គលជាមួយព្រះរាជាដែលមានសក្តិធំ មានសភាពបែបនេះ ។ លំដាប់នោះ ពួកទូតក្រាបទូលព្រះបាទមទ្ទរាជថា បពិត្រមហារាជ ពួកទូលព្រះបង្គំមិនអាចឃឹតយូរបានទេ នឹងប្រញាប់ទៅក្រាបទូលភាពដែលបានព្រះរាជធីតាដល់ព្រះបាទឱក្កាករាជ ឲ្យទ្រង់ជ្រាប ដើម្បីទ្រង់យាងមកទទួលព្រះនាងទៅ ។

ព្រះបាទមទ្ទរាជទ្រង់ទទួលថា សាធុ ចាត់ចែងគ្រឿងសក្ការៈដល់ពួកទូតទាំងនោះហើយ បញ្ជូនទៅ ។ ពួកទូតទាំងនោះ ត្រឡប់ទៅកាន់នគរកុសាវតីហើយ ក្រាបទូលរឿងនោះ ដល់ព្រះរាជានិងព្រះទេវីឲ្យទ្រង់ជ្រាប ។ ព្រះរាជាទ្រង់យាងចេញអំពីកុសាវតីនគរ មួយអន្ទើដោយបរិវារច្រើន ដល់សាគលនគរដោយលំដាប់ ។ ចំណែកព្រះបាទមទ្ទរាជក៏ទ្រង់ធ្វើការទទួល យាងព្រះរាជាចូលក្នុងនគរហើយ ទ្រង់បានធ្វើសក្ការៈដ៏ធំក្រៃលែង ។

លុះមួយថ្ងៃពីរថ្ងៃកន្លងទៅ ព្រះនាងសីលវតីទេវីទ្រង់ព្រះចិន្តាថា អ្នកណានឹងដឹងថា ព្រះរាជធីតានោះ ដូចម្ដេច ព្រោះភាពដែលព្រះនាងជាបណ្ឌិត ទើបក្រាបទូលព្រះបាទមទ្ទរាជថា បពិត្រមហារាជ ខ្ញុំម្ចាស់ប្រាថ្នាចង់ឃើញព្រះសុណិសា ។

ព្រះរាជាត្រាស់ថា សាធុ ហើយត្រាស់ឲ្យហៅព្រះនាងបភាវតីមកគាល់ ។ ព្រះនាងបភាវតីតាក់តែងព្រះកាយដោយគ្រឿងអលង្ការសព្វយ៉ាង ចោមរោមដោយកីលៀង ចេញមកថ្វាយបង្គំព្រះមាតាក្មេក ។

ព្រះនាងសីលវតី កាលទតឃើញព្រះនាងបភាវតី ទើបព្រះតម្រិះថា កុមារិកានេះ ជាស្រីមានរូបឆោមលោមពណ៌ល្អពេកណាស់ ចំណែកកូនរបស់អញ មានរូបមិនស្អាត បើកុមារិកានេះ បានឃើញកូនរបស់អញសូម្បីត្រឹមតែមួយថ្ងៃ គង់មិននៅរួមជាដាច់ខាត គង់គេចទៅ ដោយពិតអញត្រូវធ្វើឧបាយ ។

ព្រះនាងសីលវតីឲ្យយាងព្រះបាទមទ្ទរាជមក ហើយក្រាបទូលថា បពិត្រមហារាជ ព្រះសុណិសាសមគួរដល់ឱរសរបស់ខ្ញុំម្ចាស់ តែទំនៀមបន្តបវេណីនៃវង្សរបស់ខ្ញុំម្ចាស់ មាន បើព្រះរាជធីតាអង្គនេះ ប្រព្រឹត្តតាមបវេណីនេះបាន ខ្ញុំម្ចាស់ក៏នឹងនាំព្រះរាជធីតាអង្គនេះទៅ ។

ព្រះរាជាត្រាស់សួរថា បវេណីរបស់ព្រះនាង តើដូចម្តេច ។

ព្រះនាងសីលវតីតបថា បវេណីក្នុងរាជវង្សខ្ញុំម្ចាស់មានថា ព្រះជាយានឹងចួបមុខព្រះរាជស្វាមីក្នុងពេលថ្ងៃមិនបានទេ ទាល់តែតាំងព្រះគភ៌ជាមុនសិន ទើបចួបមុខគ្នាបាន បើព្រះរាជធីតាអង្គនេះ ធ្វើតាមបាន ខ្ញុំម្ចាស់ក៏នឹងនាំព្រះនាងទៅ ។

ព្រះរាជាក៏ត្រាស់សួរព្រះរាជធីតាថា នែបុត្រី នាងអាចប្រព្រឹត្តវត្ត

នេះ បានដែរឬទេ ។

ព្រះនាងឆ្លើយថា បពិត្រព្រះបិតា បាន ។ លំដាប់នោះ ព្រះបាទឱក្កាករាជ ក៏បានថ្វាយព្រះរាជទ្រព្យជាច្រើនដល់ព្រះបាទមទ្ទរាជ ហើយទ្រង់ទទួលយកព្រះនាងបភាវតីនោះ យាងត្រឡប់ទៅ ។ សូម្បីព្រះបាទមទ្ទរាជ ក៏ទ្រង់បញ្ជូនព្រះរាជធីតាទៅដោយបរិវារធំ ។

ព្រះបាទឱក្កាករាជទ្រង់ត្រឡប់មកដល់កុសាវតីនគរហើយ ត្រាស់ឲ្យតាក់តែងព្រះនគរ ដោះលែងអ្នកទោសទាំងអស់ ទ្រង់កំណត់កាលអភិសេកព្រះរាជឱរស ទ្រង់ស្ថាបនាព្រះនាងបភាវតីឲ្យជាអគ្គមហេសី ហើយឲ្យរាជបុរសត្រាច់វាយស្គរប្រកាសថា **កុសរាជស្ស អាណា** ( ឥឡូវនេះ ) រាជាណាចក្រជារបស់ព្រះបាទកុសរាជហើយ ។ ព្រះរាជាទាំងឡាយ ក្នុងសកលជម្ពូទ្វីប ព្រះរាជាអង្គណាមានព្រះរាជបុត្រី ព្រះរាជាអង្គនោះ ក៏បញ្ជូនបុត្រីមកថ្វាយព្រះបាទកុសរាជ ។ ព្រះរាជាទាំងឡាយណា ដែលមានព្រះរាជបុត្ត ហើយប្រាថ្នាភាពជាមិត្តជាមួយព្រះបាទកុសរាជនោះ ទ្រង់ក៏បញ្ជូនព្រះរាជឱរសរបស់ទ្រង់ទៅជាព្រះរាជឧបដ្ឋាក ។ ព្រះពោធិសត្វទ្រង់មានស្រីស្នំជាបរិវារច្រើន ទ្រង់គ្រងរាជសម្បត្តិដោយយសដ៏ធំក្រៃលែង ។ ព្រះពោធិសត្វមិនបានឃើញព្រះនាងបភាវតីក្នុងពេលថ្ងៃ ចំណែកព្រះនាងបភាវតី ក៏មិនបានឃើញព្រះពោធិសត្វក្នុងពេលថ្ងៃដូចគ្នា ក្សត្រទាំងពីរអង្គ គឺព្រះបាទកុសរាជ

និងព្រះនាងបភាវតីនោះ ឃើញគ្នាតែក្នុងវេលាយប់ប៉ុណ្ណោះ ។ សូម្បីរស្មីដែលផ្សាយចេញអំពីសរីរៈរបស់ព្រះនាងបភាវតី ក្នុងពេលយប់នោះ ក៏មិនអាចឲ្យឃើញព្រះភក្ត្រច្បាស់លាស់បាន ព្រះពោធិសត្វទ្រង់ចេញអំពីបន្ទប់ដ៏មានសិរីក្នុងពេលរាត្រីប៉ុណ្ណោះ ។

លុះពីរបីថ្ងៃកន្លងទៅ ព្រះពោធិសត្វទ្រង់ប្រាថ្នាចង់ឃើញព្រះភក្ត្ររបស់ព្រះនាងបភាវតីក្នុងពេលថ្ងៃ ទើបក្រាបទូលព្រះមាតាឲ្យទ្រង់ជ្រាប ។ ព្រះមាតាឃាត់ថា នែបា កូនកុំគាប់ចិត្តចួបនាងក្នុងពេលថ្ងៃឡើយ ចូរកូនរង់ចាំបានព្រះឱរសមួយអង្គសិន ។ ព្រះពោធិសត្វនៅតែអង្វររឿយ ៗ ។ លំដាប់នោះ ព្រះទេវីមានព្រះសវនីយ៍ថា បើដូច្នោះ ចូរបាទៅកាន់រោងដំរី ហើយឈរដោយភេទជាអ្នកចិញ្ចឹមដំរី មាតានឹងនាំនាងបភាវតីទៅក្នុងទីនោះ ចូរកូនមើលនាងឲ្យពេញភ្នែក កុំឲ្យនាងស្គាល់កូនឡើយ ។ ព្រះពោធិសត្វទទួលថា សាធុ ហើយបានយាងទៅកាន់រោងដំរី ។ លំដាប់នោះ ព្រះមាតារបស់ព្រះពោធិសត្វឲ្យតាក់តែងរោងដំរីហើយបបួលព្រះនាងបភាវតីថា មកបុត្រី យើងទៅមើលដំរីរបស់ព្រះភស្តានាងជាមួយគ្នា ហើយនាំព្រះនាងបភាវតីទៅកាន់រោងដំរីនោះ ។ ព្រះនាងសីលវតីទេវីបង្ហាញព្រះនាងបភាវតីថា ដំរីនេះ មានឈ្មោះយ៉ាងនេះ ដំរីនេះ មានឈ្មោះយ៉ាងនេះ ។ ព្រះរាជាទតឃើញព្រះនាងបភាវតីយាងមកតាមក្រោយព្រះមាតា ទើបចាប់អាចម៍ដំរីមួយដុំ គប់ត្រង់ខ្នងព្រះនាង

ដោយការបន្ទំខ្លួនជាហ្មដំរី ។ ព្រះនាងបភាវតីពិរោធយ៉ាងខ្លាំង មានព្រះសវនីយ៍ថា យើងនឹងទូលឲ្យព្រះរាជាកាត់ដៃរបស់អ្នក ហើយទូលព្រះទេវីឲ្យដាក់ទោស ។ ព្រះរាជមាតាទ្រង់លួងលោមព្រះរាជសុណិសាថា កុំក្រោធឡើយបុត្រី ហើយព្រះនាងអង្អែលខ្នង ។ ក្រោយមកព្រះរាជាប្រាថ្នាឃើញព្រះនាងម្តងទៀត ទើបយាងទៅទតព្រះនាងត្រង់រោងសេះ ដោយការបន្ទំខ្លួនជាអ្នកឃ្វាលសេះ ហើយយកអាចម៍សេះគប់ដូចមុនទៀត ។ ក្នុងកាលនោះ ព្រះនាងក្រោធយ៉ាងខ្លាំង ព្រះសស្សុក៏លួងលោមដូចថ្ងៃមុនទៀត ។

ថ្ងៃមួយ ព្រះនាងបភាវតីប្រាថ្នាចង់ឃើញព្រះមហាសត្វ ទើបទូលដល់ព្រះសស្សុ តែត្រូវព្រះនាងឃាត់ថា នាងកុំចង់ឃើញឡើយ ដូច្នេះក៏ទូលអង្វររឿយៗ ។

លំដាប់នោះ ព្រះទេវីត្រាស់ថា បើដូច្នោះ ថ្ងៃស្អែកនេះ កូនប្រុសរបស់យើងនឹងធ្វើប្រទក្សិណព្រះនគរ ចូរនាងបើកសីហបញ្ជរ ចាំមើលចុះ ។ កាលត្រាស់យ៉ាងនេះហើយ ស្អែកឡើង ព្រះនាងឲ្យតាក់តែងព្រះនគរ ឲ្យជយម្បតិរាជកុមារទ្រង់គ្រឿងដូចជាក្សត្រ ឲ្យប្រថាប់គង់លើខ្នងដំរី ឲ្យព្រះពោធិសត្វគង់លើអាសនៈខាងក្រោយ ឲ្យធ្វើប្រទក្សិណព្រះនគរ ហើយនាំព្រះនាងបភាវតីទៅឈរត្រង់សីហបញ្ជរ ត្រាស់ថា **បស្ស តវ សាមិកស្ស សិរិសោភគ្គំ** ចូរបុត្រីមើលនូវភាពល្អដ៏លើស

នៃសិរីរបស់ស្វាមីនាងចុះ ។

ព្រះនាងបភាវតីនោះ សម្គាល់ថា អញបានស្វាមីមានសភាពសមគ្នាហើយ ដូច្នេះ ក៏មានព្រះហឫទ័យរីករាយក្រៃលែង ។ ក្នុងថ្ងៃនោះ ព្រះមហាសត្វបន្ទំខ្លួនជាហ្មដំរី គង់លើអាសនៈខាងក្រោយរបស់ជយម្បតិរាជកុមារនោះឯង ក៏បានទតព្រះនាងបភាវតីពេញចំណង់ បានសម្តែងអាការក្រមិចក្រមើម តាមការពេញចិត្ត ដោយអំណាចការគ្រវីដៃប្លែក ៗ ជាដើម ។ កាលដំរីព្រះទីន័ងទៅផុតហើយ ព្រះរាជមាតាក៏ត្រាស់សួរព្រះនាងបភាវតីថា នាងឃើញកស្តារបស់នាងហើយឬ ។

ព្រះនាងក្រាបទូលថា ឃើញហើយព្រះមាតា តែហ្មដំរីដែលអង្គុយលើអាសនៈខាងក្រោយព្រះកស្តានោះ ជាមនុស្សរឹងរូស ទូន្មានលំបាកពន់ពេក ធ្វើដៃដោយអាការប្លែក ៗ ដល់ខ្ញុំម្ចាស់ ព្រោះហេតុអ្វី ទើបឲ្យមនុស្សដែលមិនមានសិរីបែបនេះ ឡើងអង្គុយលើអាសនៈ ខាងក្រោយស្តេចផែនដីបាន គួរនាំហ្មដំរីនោះចេញទៅ ។

ព្រះរាជមាតាមានព្រះសវនីយ៍ថា នៃបុត្រី ធម្មតាការរក្សាការពារក្នុងអាសនៈខាងក្រោយរបស់ព្រះរាជា បុគ្គលគប្បីប្រាថ្នា ។

ព្រះនាងបភាវតីមានព្រះតម្រិះថា ហ្មដំរីនេះ ប្រហែលជាបានអភ័យពិសេសពន់ពេក មិនសម្គាល់សូម្បីនូវព្រះរាជា ថាជាព្រះរាជាឡើយ ហ្មដំរីនេះ ជាព្រះបាទកុសរាជទេដឹងហ្ន៎ ឯព្រះបាទកុសរាជនេះ

គង់មានរូបគួរខ្ពើមដោយពិត ព្រោះហេតុនោះ ទើបមិនព្រមបង្ហាញខ្លួនព្រះបាទកុសរាជនោះ ដល់អញ ។ ព្រះនាងបភាវតីក៏ខ្សឹបស្រីគមថា អ្នកម៉ែ ចូរម៉ែទៅ ហើយដឹងថា បុរសគង់អាសនៈខាងមុខជាព្រះរាជា ឬអង្គុយអាសនៈខាងក្រោយជាព្រះរាជា ។

ស្រីគមក្រាបទូលសួរថា ខ្ញុំម្ចាស់នឹងដឹងបានដូចម្ដេច ។ ព្រះនាងបភាវតីប្រាប់ថា បើហ្មដំរីនោះ ជាព្រះរាជាសោត គង់នឹងចុះអំពីខ្នងដំរីមុន ម៉ែចូរដឹងដោយសញ្ញាយ៉ាងនេះ ។ ស្រីគមនោះ បានមកឈរក្នុងចំណែកម្ខាង សម្លឹងឃើញព្រះមហាសត្វចុះមកមុន ឃើញជយម្បតិរាជកុមារចុះមកខាងក្រោយ ។ ព្រះមហាសត្វទ្រង់ក្រឡេកមើលឆ្វេងស្ដាំ បានឃើញស្រីគម ក៏ជ្រាបថា ស្រីគមនេះ មក ព្រោះហេតុឈ្មោះនេះ ទើបឲ្យហៅស្រីគមមក ត្រាស់ផ្ដាំផ្ដាច់ថា នាងកុំប្រាប់រឿងនេះដល់ព្រះនាងបភាវតីឡើយ ហើយបញ្ជូនទៅ ។ ស្រីគមនោះ ត្រឡប់ទៅក្រាបទូលព្រះនាងបភាវតីថា បុរសគង់ត្រង់អាសនៈខាងមុខចុះមុន ។ ព្រះនាងបភាវតី ក៏ជឿពាក្យរបស់ស្រីគមនោះ ។

ថ្ងៃក្រោយមក ព្រះមហាសត្វមានបំណងនឹងទតព្រះនាងបភាវតីទៀត ទើបទូលអង្វរព្រះមាតា ។ ព្រះមាតាមិនអាចឃាត់បាន ទើបពោលថា បើដូច្នោះ ចូរបាក្លែងខ្លួនកុំឲ្យអ្នកណាស្គាល់ ហើយទៅកាន់ឧទ្យានចុះ ។ ព្រះពោធិសត្វយាងទៅកាន់ឧទ្យាន ហើយឈរត្រាំទឹកក្នុង

ស្រះបោក្ខរណីប្រមាណត្រឹមព្រះសូរង៍ យកស្លឹកឈូកបិទបាំងព្រះសិរសា ទ្រង់ឈរយកផ្កាឈូកដែលរីកបាំងព្រះភក្ត្រ ។ ឯព្រះមាតារបស់ព្រះពោធិសត្វនាំព្រះនាងបភាវតីទៅកាន់ព្រះរាជឧទ្យាន នាសាយណ្ហសម័យ ព្រះនាងលួងលោមឲ្យត្រេកអរថា ចូរនាងមើលព្រឹក្សាទាំងនេះ ចូរមើលពួកបក្សី ចូរមើលពួកម្រឹគ ក៏ទៅដល់មាត់ស្រះបោក្ខរណី ។ ព្រះនាងបភាវតីទតឃើញស្រះបោក្ខរណី ដែលដេរដាសទៅដោយផ្កាឈូក ៥ ប្រភេទ ព្រះនាងប្រាថ្នានឹងស្រង់ ទើបចុះកាន់ស្រះបោក្ខរណី មួយអន្លើដោយបរិចារិកាទាំងឡាយ កាលព្រះនាងកំពុងលេងនោះឯង ក៏ទតឃើញផ្កាឈូកដែលព្រះពោធិសត្វបាំងព្រះភក្ត្រនោះ ព្រះនាងប្រាថ្នានឹងបេះ ក៏លាព្រះហស្តចេញទៅ ។ លំដាប់នោះ ព្រះរាជាក៏បើកស្លឹកឈូកចេញ ហើយស្រវាចាប់ព្រះហស្តព្រះនាង ពោលថា យើងគឺព្រះបាទកុសរាជ ។

ព្រះនាងបភាវតី គ្រាន់តែទតឃើញព្រះភក្ត្ររបស់ព្រះពោធិសត្វប៉ុណ្ណោះ ក៏ស្រែកឡើងថា **យក្ខោ មំ គណ្ហិ** យក្ខចាប់ខ្ញុំហើយ ព្រះនាងក៏ដល់នូវវិសញ្ញីភាព គឺសន្លប់ក្នុងទីនោះឯង ។ លំដាប់នោះ ព្រះរាជាទ្រង់លែងព្រះហស្ត ។ លុះព្រះនាងដឹងខ្លួនហើយ ក៏ព្រះតម្រិះថា បានឮថា ព្រះបាទកុសរាជទ្រង់ចាប់អញត្រង់ដៃ ឯអញក៏ត្រូវព្រះបាទកុសរាជនេះ គប់ដោយអាចម៍ដំរី ត្រង់រោងដំរី គប់ដោយអាចម៍សេះ

ត្រង់រោងសេះ ព្រះបាទកុសរាជនេះឯង ប្រថាប់គង់ពីក្រោយខាងលើខ្នងដំរី បក់ដៃដាក់អញ អញមិនត្រូវការប្តីដែលមានមុខគួរខ្ពើមដល់ម្ល៉េះឡើយ អញនឹងលះបង់កស្តានេះ កាលអញនៅមានជីវិត នឹងបានកស្តាដទៃ ដូច្នេះហើយ ទើបហៅពួកអាមាត្យដែលតាមព្រះនាងមក ពោលថាពួកអ្នក ចូររៀបចំយានពាហនៈឲ្យយើង យើងនឹងទៅក្នុងថ្ងៃនេះឯង ។ ពួកអាមាត្យទាំងនោះ ក៏ក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ។ ព្រះរាជាទ្រង់ព្រះតម្រិះថា បើនាងមិនបានត្រឡប់ ហឫទ័យរបស់នាងនឹងបែកសញ្ជែកដោយពិត ឲ្យនាងត្រឡប់ទៅចុះ អញនឹងនាំនាងត្រឡប់មកដោយកម្លាំងរបស់ខ្លួននោះឯង កាលទ្រង់ព្រះតម្រិះដូច្នេះហើយ លំដាប់នោះ ទើបទ្រង់អនុញ្ញាតឲ្យព្រះនាងបភាវតី យាងត្រឡប់ទៅ ។ ព្រះនាងក៏យាងត្រឡប់ទៅនគររបស់ព្រះបិតាវិញ ។

ឯព្រះមហាសត្វក៏យាងចេញអំពីព្រះរាជឧទ្យាន ទៅកាន់ព្រះនគរឡើងកាន់ប្រាសាទដែលប្រដាប់តាក់តែងហើយ ។ ពិតហើយ ព្រះនាងមិនមានសេចក្តីត្រេកអរជាមួយនឹងព្រះពោធិសត្វ ដោយអំណាចព្រះនាងតាំងសេចក្តីប្រាថ្នាទុកក្នុងកាលមុន ។ ចំណែកព្រះពោធិសត្វ ដែលមានរូបមិនស្អាត ដោយអំណាចបុព្វកម្មរបស់ព្រះអង្គនុ៎ះឯង ។

បានឮថា ក្នុងអតីតកាល មានត្រកូល ២ គឺត្រកូលដែលអាស្រ័យនៅត្រង់វិថីខាងមុខ ១ អាស្រ័យនៅត្រង់វិថីខាងក្រោយ ១ ក្នុងស្រុកដែល

តាំងនៅក្បែរទ្វារនគរពារាណសី ។ ត្រកូលមួយ មានកូនប្រុស ២ នាក់ ត្រកូលមួយ មានកូនស្រីម្នាក់ ។ បណ្ដាកូនប្រុសទាំងពីរនាក់នោះ ព្រះពោធិសត្វជាកូនប្អូន ។ មាតាបិតាបានដណ្ដឹងកុមារិកានោះ ឲ្យកូនច្បង ។ ព្រះពោធិសត្វជាប្អូនប្រុសមិនទាន់មានភរិយា ទើបអាស្រ័យនៅជាមួយបងប្រុសនុ៎ះឯង ។ សម័យថ្ងៃមួយ បងថ្លៃស្រីបានចៀននំដែលមានរសឆ្ងាញ់ក្រៃលែង ក្នុងផ្ទះនោះ ឯព្រះពោធិសត្វបានចេញទៅព្រៃ បងថ្លៃស្រីក៏បានទុកនំ ១ ចំណែកឲ្យព្រះពោធិសត្វ ចំណែកដ៏សេសក៏ចែកគ្នាបរិភោគអស់ ។ ក្នុងខណៈនោះ **ព្រះបច្ចេកពុទ្ធ** បាននិមន្តមកដល់ទ្វារផ្ទះដើម្បីភិក្ខា បងថ្លៃរបស់ព្រះពោធិសត្វគិតថា អញនឹងចៀននំឲ្យប្អូនថ្លៃជាថ្មី ដូច្នេះ ទើបកាន់យកនំដែលជាចំណែករបស់ព្រះពោធិសត្វនោះទៅប្រគេនព្រះបច្ចេកពុទ្ធ ព្រះពោធិសត្វក៏ត្រឡប់មកអំពីព្រៃក្នុងខណៈនោះឯង ។ លំដាប់នោះ ទើបនាងពោលថា នែប្អូនប្រុស ចូរប្អូនធ្វើចិត្តឲ្យជ្រះថ្លាចុះ នំដែលជាចំណែករបស់ប្អូន បងបានប្រគេនព្រះបច្ចេកពុទ្ធហើយ ។ ព្រះពោធិសត្វក្រោធ ពោលថា បងស៊ីនំដែលជាចំណែកខ្លួនអស់ហើយ យកនំដែលជាចំណែករបស់ខ្ញុំទៅប្រគេនលោក តើខ្ញុំនឹងស៊ីអ្វី ដូច្នេះហើយ ទៅតាមព្រះបច្ចេកពុទ្ធ យកនំអំពីបាត្រត្រឡប់មក ។ បងថ្លៃស្រីនោះ ក៏ប្រញាប់ទៅកាន់ផ្ទះរបស់មាតា ហើយនាំយកសប្បិថ្មី ៗ ដែលថ្លាស្អាត មានពណ៌ដូចផ្កាចម្ប៉ាមក ហើយដាក់ក្នុងបាត្ររហូតពេញ

ប្រគេនព្រះបច្ចេកពុទ្ធ ។ សប្បិនោះ បានផ្សាយរស្មីចេញទៅហើយ ។ នាងបានឃើញរស្មីនោះ ទើបតាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ដ៏ចម្រើន ដោយកម្លាំងរបស់ទាននេះ ក្នុងទីដែលខ្ញុំកើតហើយ ៗ សូមឲ្យសរីរៈរបស់ខ្ញុំ កើតមានរស្មីចិញ្ចាចចិញ្ចែង មានរូបស្អាតក្រៃលែង ម្យ៉ាងទៀត សូមកុំឲ្យខ្ញុំបាននៅរួមក្នុងទីជាមួយបុគ្គលដែលជាអសប្បុរស ( ដូចប្អូនថ្លៃប្រុសរបស់ខ្ញុំនេះ ) ឡើយ ។ ព្រះនាងបភាវតីមិនត្រេកអរ មិនពេញចិត្តក្នុងព្រះពោធិសត្វនោះ ក៏ដោយអំណាចសេចក្តីប្រាថ្នាដែលព្រះនាងបានតាំងទុកហើយក្នុងកាលមុន ដោយប្រការដូច្នេះ ។ ឯព្រះពោធិសត្វក៏ដាក់នំនោះ ក្នុងបាត្រដែលពេញដោយសប្បិ ហើយតាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ ( បងថ្លៃស្រីរបស់ខ្ញុំនេះ ) សូម្បីនៅក្នុងទីឆ្ងាយ ១០០ យោជន៍ក្តី សូមឲ្យខ្ញុំអាចទៅនាំមកធ្វើជាបាទបរិចារិកាគឺភរិយារបស់ខ្ញុំបាន ។ ដោយអំណាចនៃបុព្វកម្មដែលព្រះពោធិសត្វនោះ ក្រោធ យកនំមកវិញ ទើបព្រះពោធិសត្វមានរូបមិនស្អាត គួរស្អប់ ចំណែកព្រះនាងបភាវតីមិនត្រូវការព្រះពោធិសត្វនោះ ព្រោះសេចក្តីប្រាថ្នាដែលបានតាំងទុកអំពីកាលមុននោះឯង ។

ព្រះរាជា កាលព្រះនាងបភាវតីយាងទៅហើយ ក៏សោយសោកសូម្បីស្រីដ៏សេសទាំងឡាយ នាំគ្នាបម្រើដោយប្រការផ្សេង ៗ ក៏មិនអាចឲ្យទ្រង់ក្រឡេកមើលបានឡើយ ។ កាលព្រះរាជាទ្រង់ព្រាត់អំពីព្រះនាង

បភាវតីហើយ ព្រះរាជនិវេសន៍ទាំងមូលក៏ប្រាកដដូចជាទទេ ។ ព្រះរាជាទ្រង់គិតថា ឥឡូវនេះ នាងទៅដល់សាគលនគរហើយ ។ លុះវេលាបច្ចូសសម័យ ទើបស្តេចទៅកាន់សម្នាក់ព្រះមាតា ក្រាបទូលថា បពិត្រព្រះមាតា ខ្ញុំនឹងទៅនាំនាងបភាវតីមកវិញ សូមព្រះមាតាគ្រប់គ្រងរាជសម្បត្តិចុះ ដូច្នេះហើយ ទើបត្រាស់គាថាទី ១ ថា

**ឥទន្តេ រដ្ឋំ សធនំ សយោគ្គំ**

**សកាយុរំ សព្វកាមូបបន្នំ**

**ឥទន្តេ រដ្ឋំ អនុសាស អម្ម**

**កច្ឆាមហំ យត្ថ បិយា បភាវតី ។**

បពិត្រព្រះមាតា ដែនរបស់ព្រះមាតានេះ ប្រកបដោយទ្រព្យ ប្រកបដោយយាន ប្រកបដោយគ្រឿងសម្រាប់រាជ្យ បរិបូណ៌ដោយកាមគ្រប់យ៉ាង សូមព្រះមាតាត្រួតត្រាដែនរបស់ព្រះមាតានេះចុះ ខ្ញុំនឹងទៅកាន់នគរជាទីនៅរបស់នាងបភាវតីជាទីស្រឡាញ់ ។

បានឮថា ព្រះរាជាអង្គនោះ ទ្រង់ព្រះតម្រិះថា ឈ្មោះថា ការប្រគល់រាជសម្បត្តិឲ្យដល់បុរសគ្រប់គ្រង ហើយកាន់យកមកវិញ ជាការមិនសមគួរ ទើបទ្រង់មិនប្រគល់រាជសម្បត្តិឲ្យព្រះរាជបិតា ឬព្រះអនុជកាលទ្រង់ប្រគល់ឲ្យព្រះរាជមាតា ទើបបានត្រាស់ដូច្នេះ ។

ព្រះរាជមាតាបានស្តាប់ព្រះរាជតម្រាស់នោះហើយ ព្រះនាងមានព្រះសវនីយ៍ថា នែបា បើដូច្នោះ ចូរកូនកុំប្រមាទ ឈ្មោះថា មាតុគ្រាមរមែងមានចិត្តមិនបរិសុទ្ធ ហើយព្រះនាងយកភោជនមានរសដ៏ប្រសើរផ្សេង ៗ ដាក់ពេញក្នុងផ្តិលមាស ពោលថា កូនគប្បីបរិភោគភោជននេះក្នុងរវាងផ្លូវ ហើយព្រះនាងបញ្ជូនទៅ ។ ព្រះពោធិសត្វទទួលផ្តិលនោះហើយ ថ្វាយបង្គំព្រះមាតា ធ្វើប្រទក្សិណ ៣ ជុំ ក្រាបទូលថា បើទូលព្រះបង្គំនៅមានជីវិត គង់បានត្រឡប់មកឃើញព្រះមាតាវិញ ហើយទៅកាន់បន្ទប់ដ៏មានសិរី សៀតអាវុធ ៥ យ៉ាង កាន់យកកហាបណៈ ១ ពាន់ ដាក់ក្នុងបង្វេច មួយអន្ទើដោយផ្តិលក្រយាស្ងោយ កាន់ពិណកោកនុទៈ ចេញអំពីនគរ ស្តេចទៅតាមផ្លូវ ទ្រង់មានកម្លាំងកាយច្រើនកម្លាំងចិត្តច្រើន យាងទៅរហូតដល់ថ្ងៃត្រង់ បាន ៥០ យោជន៍ សោយក្រយាស្ងោយហើយ ទ្រង់យាងទៅបាន ៥០ យោជន៍ទៀត ដោយថ្ងៃមួយប៉ុណ្ណោះ ទ្រង់យាងបានចម្ងាយផ្លូវ ១០០ យោជន៍ លុះដល់ពេលល្ងាចទ្រង់ស្រង់ទឹកហើយ ទ្រង់យាងចូលសាគលនគរ ។ កាលព្រះពោធិសត្វទ្រង់ចូលដល់នគរប៉ុណ្ណោះ ដោយតេជះរបស់ព្រះអង្គ ព្រះនាងបភាវតីផ្ទំលើសេយ្យាសនៈមិនបាន ក៏ចុះមកផ្ទំខាងក្រោម ។ ព្រះពោធិសត្វមានព្រះឥន្ទ្រិយហត់នឿយ យាងមកតាមផ្លូវ ស្រីម្នាក់ឃើញទ្រង់ ទើបប្រើឲ្យមនុស្សហៅមក អញ្ជើញឲ្យអង្គុយ យកទឹកលាងព្រះបាទ ហើយរៀបចំ

ទីបន្ទំថ្វាយ ។ ព្រះពោធិសត្វមានព្រះកាយហត់នឿយ ក៏ផ្ទំលក់ស៊ប់ ។

លំដាប់នោះ ស្រីនោះ កាលព្រះពោធិសត្វផ្ទំលក់ហើយ ក៏រៀបចំភោជន មានរសដ៏ប្រសើរផ្សេង ៗ ស្រេចហើយ ទើបដាស់ព្រះពោធិសត្វឲ្យសោយព្រះក្រយាស្ងោយ ។ ព្រះពោធិសត្វទ្រង់មានព្រះហឫទ័យត្រេកអរ បានប្រទានកហាបណៈ ១ ពាន់ មួយអន្ទើដោយផ្តិលមាសដែលដាក់ភត្តដល់ស្រីនោះ ។ ព្រះពោធិសត្វទ្រង់ទុកអាវុធទាំង ៥ ក្នុងផ្ទះរបស់ស្រីនោះហើយ ប្រាប់ថា ខ្ញុំមានទីដែលគួរទៅទៀត ហើយទ្រង់កាន់យកពិណទៅកាន់រោងដំរី ត្រាស់ថា ចូរឲ្យខ្ញុំស្នាក់នៅក្នុងទីនេះមួយថ្ងៃចុះ ខ្ញុំនឹងច្រៀងឲ្យពួកអ្នកស្តាប់ ដូច្នេះ កាលបានទទួលការអនុញ្ញាតអំពីអ្នកឃ្វាលដំរីហើយ ទើបផ្ទំលក់ក្នុងទីនោះ បានមួយសន្ទុះ រម្ងាប់ការហត់នឿយ និងសេចក្តីក្រវល់ក្រវាយហើយ ទើបក្រោកឡើង ស្រាយបង្វេចពិណ ទ្រង់ដេញពិណ ច្រៀងដោយសំឡេងដ៏ពីរោះ ដោយព្រះតម្រិះថា អ្នកសាគលនគរទាំងអស់ ចូរស្តាប់សំឡេងពិណនេះ ។ ព្រះនាងបភាវតីផ្ទំលើផែនដី បានស្តាប់សំឡេងនោះ ព្រះនាងក៏ដឹងបានថា សំឡេងពិណនេះ មិនមែនជាសំឡេងពិណរបស់អ្នកដទៃឡើយ ព្រះបាទកុសរាជយាងមក ដើម្បីយកអញត្រឡប់ទៅ ដោយឥតសង្ស័យឡើយ ។ ចំណែកព្រះបាទមទ្ទរាជ ទ្រង់ស្តាប់សំឡេងនោះហើយ ទ្រង់ព្រះតម្រិះថា អ្នកណាដេញពិណពីរោះម៉្លេះហ្ន៎ ស្អែកនេះ អញនឹងឲ្យមនុស្សហៅជន

នោះ មកដេញឲ្យអញស្តាប់ ។

ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា អញនៅក្នុងទីនេះ មិនអាចឃើញព្រះនាងបភាវតីឡើយ ទីនេះ មិនសមគួរដល់អញឡើយ ទើបយាងចេញទៅអំពីព្រលឹម សោយព្រះក្រយាហារព្រឹកក្នុងផ្ទះរបស់ស្រីដែលទ្រង់បានសោយហើយក្នុងពេលល្ងាចដំបូងនោះឯង ទ្រង់ទុកពិណក្នុងទីនោះ ទៅកាន់សម្នាក់នាយស្មូនឆ្នាំងរបស់ព្រះរាជា ហើយសូមផ្ញើខ្លួនជាសិស្សរបស់ស្មូនឆ្នាំងនោះ ។ ត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ទ្រង់ជញ្ជូនដីមកដរាបពេញផ្ទះ ហើយប្រាប់ថា លោកអាចារ្យ ខ្ញុំនឹងធ្វើភាជនៈឲ្យ កាលនាយស្មូនឆ្នាំងពោលថា អើធ្វើចុះ ទើបទ្រង់ដាក់ដីមួយដុំលើក្តារយន្ត ហើយបង្វិលក្តារយន្តនោះ ។ ព្រះពោធិសត្វទ្រង់បង្វិលតែម្តងប៉ុណ្ណោះ ក្តារយន្តក៏វិលទៅរហូតហួសថ្ងៃត្រង់ ព្រះពោធិសត្វសូនភាជនៈតូចធំបានច្រើនប្រភេទច្រើនទំហំ កាលទ្រង់សូនភាជនៈសម្រាប់ព្រះនាងបភាវតី ទ្រង់ធ្វើឲ្យមានក្បាច់ក្បូរជារូបភាពផ្សេង ៗ ។ ពិតមែន ឈ្មោះថា បំណងរបស់ព្រះពោធិសត្វទាំងឡាយ រមែងសម្រេច ។ ព្រះពោធិសត្វអធិដ្ឋានថា សូមឲ្យព្រះនាងបភាវតីបានឃើញរូបនោះ តែមួយអង្គឯងប៉ុណ្ណោះ ។ ទ្រង់ហាលភាជនៈទាំងអស់ឲ្យស្ងួត ទ្រង់ដុតស្រេចហើយ តម្រៀបទុកដរាបពេញផ្ទះ ។ នាយស្មូនឆ្នាំងក៏នាំភាជនៈទាំងនោះ ទៅកាន់រាជត្រកូល ។ ព្រះបាទមទ្ទរាជទតឃើញភាជនៈទាំងនោះហើយ ត្រាស់សួរថា ភាជនៈ

ទាំងនេះ នរណាធ្វើ ។ នាយស្នូនផ្ទាំងទូលថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាអ្នកធ្វើ ។

ព្រះរាជាត្រាស់ថា ភាជនៈដែលអ្នកធ្លាប់ធ្វើ យើងស្គាល់ អ្នកចូរប្រាប់មកថា ភាជនៈទាំងនេះ អ្នកណាធ្វើ ។ នាយស្នូនផ្ទាំងក្រាបទូលថា សិស្សរបស់ទូលព្រះបង្គំជាអ្នកធ្វើ ព្រះអង្គ ។

ព្រះរាជាត្រាស់ថា បុរសនោះ មិនមែនជាសិស្សរបស់អ្នកទេ បុរសនោះ ជាអាចារ្យរបស់អ្នក អ្នកចូរសិក្សាសិប្បៈក្នុងសម្នាក់របស់បុរសនោះចុះ ចាប់តាំងអំពីពេលនេះទៅ ចូរឲ្យគេធ្វើភាជនៈទាំងឡាយសម្រាប់ធីតារបស់យើងគ្រប់អង្គ ចូរអ្នកឲ្យទ្រព្យ ១ ពាន់នេះ ដល់បុរសនោះ ដូច្នេះហើយ ព្រះរាជទានទ្រព្យ ១ ពាន់ ត្រាស់ថា ចូរនាំភាជនៈតូច ៗ មានសណ្ឋានផ្សេង ៗ ទាំងនេះ ទៅឲ្យធីតាទាំងឡាយរបស់យើងចុះ ។

នាយស្នូនផ្ទាំងនាំយកភាជនៈទាំងនោះ ទៅកាន់ដំណាក់របស់ព្រះរាជធីតាទាំងនោះហើយ ក្រាបទូលថា ភាជនៈតូច ៗ ទាំងនេះ ទូលព្រះបង្គំសូមថ្វាយសម្រាប់ព្រះនាងលេង ។ ព្រះរាជធីតាទាំងនោះ យាងមកហើយ ។ ស្នូនផ្ទាំងក៏បានថ្វាយភាជនៈដែលព្រះមហាសត្វធ្វើ ដើម្បីប្រយោជន៍ដល់ព្រះនាងបភាវតី ចំពោះព្រះនាងនោះឯង ។ ព្រះនាងបភាវតីទទួលភាជនៈហើយ ទតឃើញរូបព្រះនាង រូបព្រះមហាសត្វ និងរូបស្រីគមក្នុងភាជនៈនោះឯង ព្រះនាងក៏ដឹងថា ភាជនៈនេះ មិនមែន

អ្នកដទៃធ្វើ ព្រះបាទកុសរាជនោះឯង ទ្រង់ជាអ្នកធ្វើ ។ ព្រះនាងពិពេធ បោករបស់ទាំងនោះលើផែនដី ហើយត្រាស់ថា យើងមិនត្រូវការដោយរបស់នេះទេ អ្នកណាចង់បាន ក៏ចូរយកទៅចុះ ។ លំដាប់នោះ ព្រះរាជធីតាដែលជាព្រះកនិដ្ឋកគិនីទាំងឡាយរបស់ព្រះនាង ដឹងថា ព្រះនាងទ្រង់ពិពេធ ក៏សើច ពោលថា ម្ចាស់បងសម្គាល់ថា ភាជនៈតូច ៗ នេះ ព្រះបាទកុសៈទ្រង់ជាអ្នកធ្វើឬ ។ ភាជនៈនេះ មិនមែនព្រះបាទកុសៈនោះធ្វើទេ ស្ទូនផ្ទាំងធ្វើទេតើ សូមម្ចាស់បងទទួលយកចុះ ។ ព្រះនាងក៏មិនបានប្រាប់រឿងដែលព្រះបាទកុសរាជនោះ ទ្រង់ធ្វើភាជនៈ និងរឿងដែលព្រះបាទកុសរាជនោះ យាងមក ដល់ប្អូនស្រីទាំងនោះឡើយ ។ នាយស្ទូនផ្ទាំងបានឲ្យកហាបណៈ ១ ពាន់ ដល់ព្រះពោធិសត្វ ហើយពោលថា នៃបា ព្រះរាជាទ្រង់ពេញព្រះហឫទ័យនឹងអ្នក ចាប់ពីពេលនេះទៅ អ្នកគប្បីធ្វើភាជនៈសម្រាប់ព្រះរាជធីតាគ្រប់ ៗ អង្គ ខ្ញុំនឹងនាំទៅថ្វាយដល់ព្រះរាជធីតាទាំងនោះ ។

ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា បើអញនៅក្នុងទីនេះ អញនឹងមិនបានឃើញព្រះនាងបភាវតីទេ ទើបឲ្យទ្រព្យ ១ ពាន់នោះ ដល់ស្ទូនផ្ទាំង ហើយទៅកាន់សម្នាក់របស់ជាងផែង ដែលជាឧបដ្ឋាករបស់ព្រះរាជា សូមធ្វើជាសិស្សរបស់ជាងផែងនោះ ទ្រង់ធ្វើស្លឹកត្នោត ដើម្បីប្រយោជន៍ដល់ព្រះនាងបភាវតី ហើយរចនារូបផ្សេង ៗ គឺរូបស្វេតច្ឆត្រ ទីសម្រាប់ផឹក

( រោងសុរា ) និងរូបព្រះនាងបភាវតីឈរចាប់សំពត់ជាដើម ក្នុងស្ទឹកត្នោតនោះ ។ ជាងផែងបានកាន់យកស្ទឹកត្នោតនោះ និងរបស់ដទៃ ៗ ទៀត ដែលព្រះពោធិសត្វធ្វើហើយ នាំទៅកាន់រាជត្រកូល ។

ព្រះរាជាទ្រង់ទតឃើញហើយ ត្រាស់សួរថា របស់ទាំងនេះ អ្នកណាធ្វើ ។ ជាងផែងក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាអ្នកធ្វើ ។

ព្រះរាជាត្រាស់ថា របស់ដែលអ្នកធ្លាប់ធ្វើ យើងស្គាល់ អ្នកចូរប្រាប់មកថា របស់ទាំងនេះ អ្នកណាធ្វើ ។ ជាងផែងក្រាបទូលថា បពិត្រព្រះសម្មតិទេព សិស្សរបស់ទូលព្រះបង្គំជាអ្នកធ្វើ ។

ព្រះរាជាត្រាស់ថា បុរសនោះ មិនមែនជាសិស្សរបស់អ្នកទេ បុរសនោះ ជាអាចារ្យរបស់អ្នក ចូរអ្នកសិក្សាសិប្បៈក្នុងសម្នាក់របស់បុរសនោះ តាំងអំពីពេលនេះទៅ ចូរឲ្យគេធ្វើរបស់បែបនេះ ដល់ធីតារបស់យើង ចូរអ្នកឲ្យទ្រព្យ ១ ពាន់នេះ ដល់បុរសនោះ ដូច្នេះហើយ ប្រទានទ្រព្យ ១ ពាន់ ហើយត្រាស់ថា ចូរនាំយកគ្រឿងប្រដាប់ទាំងនេះ ទៅឲ្យធីតាទាំងឡាយរបស់យើងចុះ ។

សូម្បីជាងផែងនោះ ក៏បានថ្វាយស្ទឹកត្នោត ដែលព្រះពោធិសត្វធ្វើ ដើម្បីប្រយោជន៍ដល់ព្រះនាងបភាវតី ចំពោះតែព្រះនាងប៉ុណ្ណោះ ។ ជនដទៃ រមែងមិនឃើញរូបទាំងឡាយក្នុងស្ទឹកត្នោតនោះ ។ ចំណែក

ព្រះនាងបភាវតី លុះបានទតឃើញ ក៏ដឹងថា ព្រះបាទកុសៈទ្រង់ជាអ្នកធ្វើ ព្រះនាងក៏ពិរោធ ចោលវត្ថុនោះលើផែនដី ត្រាស់ថា អ្នកណាចង់បាន ក៏យកទៅចុះ ។ លំដាប់នោះ ព្រះកនិដ្ឋភគិនីទាំងឡាយ ក៏សើចព្រះនាង ។ ដាងផែងកាន់យកទ្រព្យ ១ ពាន់ ទៅឲ្យព្រះពោធិសត្វហើយប្រាប់រឿងនោះ ។

ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា ទីនេះ មិនមែនជាទីដែលអញគួរនៅឡើយ ទើបប្រគល់ទ្រព្យ ១ ពាន់ ដល់ដាងផែងនោះ ហើយចូលទៅកាន់សម្នាក់នាយមាលាការរបស់ព្រះរាជា ប្រាប់នូវបំណង សូមធ្វើជាសិស្ស ទ្រង់ក្រងកម្រងផ្កាប្លែក ៗ ច្រើនបែប ច្រើនប្រភេទ និងធ្វើមកុដផ្កា ១ ដែលវិចិត្រដោយរូបផ្សេង ៗ ដើម្បីប្រយោជន៍ដល់ព្រះនាងបភាវតី ។ នាយមាលាការនោះ បានកាន់យកកម្រងផ្កាទាំងអស់នោះ ទៅកាន់រាជត្រកូល ។

ព្រះរាជាទ្រង់ទតឃើញ ត្រាស់សួរថា ផ្កាទាំងនេះ នរណាជាអ្នកក្រង ។ នាយមាលាការក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាអ្នកក្រង ។

ព្រះរាជាត្រាស់ថា ផ្កាដែលអ្នកធ្លាប់ក្រង យើងចាំបានល្អ ចូរអ្នកប្រាប់មកចុះថា ផ្កាទាំងនេះ អ្នកណាក្រង ។ នាយមាលាការក្រាបទូលថា បពិត្រព្រះសម្មតិទេព សិស្សរបស់ទូលព្រះបង្គំជាអ្នកក្រង ។

ព្រះរាជាត្រាស់ថា បុរសនោះ មិនមែនជាសិស្សរបស់អ្នកទេ បុរសនោះ ជាអាចារ្យរបស់អ្នក អ្នកចូររៀនសិប្បៈក្នុងសម្នាក់របស់បុរសនោះចុះ ចាប់អំពីពេលនេះទៅ ចូរឲ្យគេក្រងផ្កាថ្វាយធីតារបស់យើង ចូរឲ្យទ្រព្យ ១ ពាន់នេះ ដល់បុរសនោះ ដូច្នេះ ទ្រង់ព្រះរាជទានទ្រព្យ ១ ពាន់ ហើយត្រាស់ថា ចូរនាំផ្កាទាំងនេះ ទៅឲ្យព្រះរាជធីតាទាំងឡាយរបស់យើង ។ នាយមាលាការបានថ្វាយមកុដផ្កាដែលព្រះមហាសត្វធ្វើដើម្បីជាប្រយោជន៍ដល់ព្រះនាងបភាវតី ចំពោះព្រះហស្តរបស់ព្រះនាងនោះឯង ។ ព្រះនាងគ្រាន់តែឃើញរូបផ្សេង ៗ របស់ព្រះនាង និងរបស់ព្រះរាជា ព្រមទាំងរូបដទៃ ៗ ជាច្រើនទៀតក្នុងមកុដនោះ ក៏ដឹងថាព្រះបាទកុសរាជជាអ្នកធ្វើ ទើបព្រះនាងពិរោធ ហើយបោកចោលលើផែនដី ។ ព្រះកនិដ្ឋភគិនីដ៏សេស នាំគ្នាសើចព្រះនាងយ៉ាងនោះឯង ។ ចំណែកនាយមាលាការ ក៏បាននាំទ្រព្យ ១ ពាន់ មកឲ្យព្រះពោធិសត្វហើយប្រាប់រឿងនោះ ។

ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា សូម្បីទីនេះ ក៏មិនមែនជាទីដែលអញគួរនៅ ទើបឲ្យទ្រព្យ ១ ពាន់ដល់នាយមាលាការនោះ ហើយយាងទៅកាន់សម្នាក់នាយពិសេសរបស់ព្រះរាជា សូមធ្វើជាសិស្ស ។ សម័យថ្ងៃមួយ អ្នកពិសេសនោះ ចម្អិនព្រះស្ងោយរបស់ព្រះរាជា បានឲ្យដុំសាច់ជាប់ឆ្អឹងមួយដុំដល់ព្រះពោធិសត្វ ដើម្បីអាំងជាប្រយោជន៍ផ្ទាល់ខ្លួន ។

ព្រះពោធិសត្វទ្រង់អាំងសាច់នោះ ឲ្យមានក្លិនឈ្ងុយ ផ្សាយទៅពេញព្រះនគរ ។ ព្រះរាជាទ្រង់ស្រូបស្រង់ក្លិនសាច់អាំងនោះ ក៏ត្រាស់សួរថា អ្នកអាំងសាច់ដទៃ ទុកក្នុងផ្ទះបាយឬ ។

នាយពិសេសក្រាបទូលថា បពិត្រព្រះទេវៈ មិនមានឡើយ តែទូលព្រះបង្គំបានឲ្យសាច់ជាប់ឆ្អឹង ដល់កូនសិស្សរបស់ទូលព្រះបង្គំ ដើម្បីអាំង ក្លិននោះ ប្រហែលជាក្លិនសាច់នោះឯង ។ ព្រះរាជាទ្រង់ត្រាស់ឲ្យនាំសាច់នោះមក ហើយទ្រង់ដាក់សាច់នោះបន្តិច ត្រង់ចុងព្រះជិវ្ហា ។ ក្នុងខណៈនោះឯង រសនៃសាច់នោះ ក៏ជ្រួតជ្រាបទៅពេញបសាទសម្រាប់ទទួលរសទាំង ៧ ពាន់ ។ ព្រះរាជាទ្រង់ជាប់ក្នុងរសតណ្ហា ទើបប្រទានទ្រព្យ ១ ពាន់ ហើយត្រាស់ថា ចាប់តាំងអំពីនេះទៅ ចូរអ្នកឲ្យសិស្សរបស់អ្នកចម្អិនក្រយាស្ងោយ ឲ្យដល់ធីតាទាំងឡាយរបស់យើង និងយើងឯងចូរនាំមកឲ្យយើង ឯសិស្សរបស់ឯងនោះ ចូរនាំទៅឲ្យធីតាទាំងឡាយរបស់យើង ។ នាយពិសេសទៅប្រាប់សេចក្ដីនោះ ដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា ឥឡូវនេះ មនោរថរបស់អញដល់ទីបំផុតហើយ អញនឹងបានឃើញនាងបភាវតីក្នុងកាលឥឡូវនេះ ដោយពិតទ្រង់សប្បាយព្រះហឫទ័យ ឲ្យទ្រព្យ ១ ពាន់ ដល់នាយពិសេសនោះ ។ ស្អែកឡើង ទ្រង់ចាត់ចែងគ្រឿងស្ងោយស្រេចហើយ បញ្ជូនក្រយាស្ងោយរបស់ព្រះរាជាទៅ ចំណែកព្រះអង្គ ទ្រង់រែកល្អីដាក់ក្រយាស្ងោយរបស់

ព្រះរាជធីតាដោយខ្លួនឯង ហើយឡើងទៅកាន់ប្រាសាទ ដែលជាទីគង់នៅរបស់ព្រះនាងបភាវតី ។ ព្រះនាងបភាវតីទតឃើញព្រះពោធិសត្វរែកល្អីក្រយាស្ងោយឡើងកាន់ប្រាសាទ ព្រះនាងមានព្រះតម្រិះថា ព្រះបាទកុសៈនេះ មកធ្វើការងារដែលពួកទាសកម្មករគប្បីធ្វើ មិនសមគួរដល់ទ្រង់ឡើយ បើអញនៅស្ងៀមត្រឹមតែពីរបីថ្ងៃ ទ្រង់ក៏មានសេចក្តីសម្គាល់ថា ឥឡូវនេះ នាងបភាវតីប្រាថ្នាអញ ទ្រង់ក៏នឹងមិនទៅណាសម្ងំមើលតែអញ នឹងនៅក្នុងទីនេះឯង ឥឡូវនេះ អញនឹងជេរទ្រង់កុំឲ្យទ្រង់នៅក្នុងទីនេះ ត្រឹមតែមួយរំពេចឡើយ នឹងឲ្យទ្រង់គេចទៅ ។ ព្រះនាងបើកទ្វារទុកពាក់កណ្តាល យកព្រះហស្តម្ខាងកាន់សន្ទះទ្វារម្ខាងទៀតដាក់គន្លឹះ ហើយត្រាស់ព្រះគាថាទី ២ ថា

អទុជុភូតេឆ ហារំ មហាន្តំ
ទិវា ច រត្តោ ច ដិសីថកាលេ
បដិគច្ឆ ត្វំ ទិប្បំ កុសាវតឹ
ជិច្ឆាមិ ទុព្វណ្ណមហំ វសន្តំ ។

ព្រះអង្គមានព្រះទ័យមិនត្រង់ នាំយកអម្រែកធំ ( រង់ទុក្ខ ) ទាំងថ្ងៃ ទាំងយប់ ទាំងពេលអធ្រាត្រ សូមព្រះអង្គត្រឡប់ទៅក្រុងកុសាវតីវិញ ឲ្យឆាប់ ខ្ញុំម្ចាស់មិនចង់បានព្រះអង្គដែលមានរាងអាក្រក់ មកនៅ ( ក្នុងទី

នេះ ) ទេ ។

អត្ថនៃគាថានោះ មានអធិប្បាយដូចតទៅនេះថា បពិត្រមហារាជ ព្រះអង្គជាអ្នកចម្អិនភត្តាហារ ទ្រង់មិនបានធ្វើការងារនេះ ដោយចិត្តស្មោះត្រង់ ដល់បុគ្គលដែលវាយសីសៈរបស់ទ្រង់ឲ្យបែកទេ តែទ្រង់រែកនូវអម្រែកជំមួយមក ដើម្បីប្រយោជន៍ខ្ញុំ ដោយចិត្តដែលមិនស្មោះត្រង់ និងសោយទុក្ខធំ ទាំងក្នុងពេលថ្ងៃផង ក្នុងពេលយប់ផង ក្នុងកាលដែលជាចំណែកនៃរាត្រីផង នឹងមានប្រយោជន៍អ្វីដោយសេចក្ដីលំបាក ដែលទ្រង់បានទទួលនោះ សូមទ្រង់ត្រឡប់ទៅកុសាវតីដែលជានគររបស់ទ្រង់ចុះ សូមទ្រង់ស្ដាបនាយក្និនី ដែលមានមុខនិងទ្រង់ទ្រាយដូចនំអំបែង ដូចគ្នានឹងទ្រង់ ហើយសោយរាជសម្បត្តិចុះ ឯខ្លួនខ្ញុំ មិនប្រាថ្នាឲ្យទ្រង់ដែលមានពណ៌សម្បុរអាក្រក់ មានរូបរាងមិនស្អាតនៅក្នុងទីនេះឡើយ ។

ព្រះពោធិសត្វទ្រង់ត្រេកអរថា អញបានទទួលវាចាអំពីនាងបភាវតីហើយ ទើបត្រាស់ព្រះគាថា ៣ ថា

ឆាហំ គមិស្សាមិ ឥតោ កុសាវតឹ<br>
បភាវតី វណ្ណបលោភិតោ តវ<br>
រមាមិ មទ្ទស្ស និកេតរម្មេ<br>
ហិត្វាន រដ្ឋំ តវ ទស្សនេ រតោ ។

ហៃនាងបភាវតី អញនឹងមិនទៅអំពីទីនេះ កាន់

ក្រុងកុសាវតីទេ ព្រោះអញជាប់ចិត្តនឹងវណ្ណៈរបស់នាង ទើបត្រេកអរក្នុងដំណាក់ ជាទីត្រេកអររបស់ព្រះបាទមទ្ទៈ ស៊ូលះបង់ដែន មកត្រេកអរក្នុងការឃើញនាង ។

**បភាវតី វណ្ណុបលោភិតោ តវ**
**សម្ភុល្លុចោ វិចរាមិ មេទិនឹ**
**ទិសំ ន ជានាមិ កុតោម្ហិ អាគតោ**
**តយិម្ហិ មត្តោ មិគមន្ទលោចនេ ។**

ហៃនាងបភាវតី អញជាប់ចិត្តនឹងវណ្ណៈរបស់នាងមានសភាពវង្វេង ត្រាច់រង្គាត់ទៅកាន់ផែនដី មិនស្គាល់ទិសថា អញមកអំពីទីណា ហៃនាងមានភ្នែកថ្លាដូចភ្នែកម្រឹគ អញជាមនុស្សវក់ចិត្តក្នុងនាង ។

**សោវណ្ណចីរវសនេ ជាតរូបសុមេខលេ**
**សុស្សោណិ តវ កាមា ហិ ជាហំ រជ្ជេន មត្ថិកោ ។**

ហៃនាងមានគ្រឿងសម្លៀករំលេចដោយមាស មានខ្សែក្រវាត់ល្អ ជាវិការៈនៃមាស មានចង្កេះល្អ អញមិនត្រូវការដោយរាជសម្បត្តិ ព្រោះតែសេចក្ដីប្រាថ្នាចំពោះនូវនាង ។

កាលព្រះពោធិសត្វត្រាស់យ៉ាងនេះហើយ ព្រះនាងបភាវតីព្រះ

តម្រិះថា អញជេរព្រះបាទកុសៈនោះ ដោយបំណងថា ឲ្យទ្រង់ឈឺចាប់ តែព្រះបាទកុសៈនេះ បែរជាត្រេកអរ ពោលតបមកទៀត បើទ្រង់ពោលថា យើងជាព្រះបាទកុសរាជ ហើយមកចាប់ត្រង់ដៃ អ្នកណានឹងឃាត់ទ្រង់បាន អ្នកណាគប្បីឮពាក្យរបស់អញទាំងពីរនេះបាន ។ ព្រះនាងក៏បិទទ្វារដាក់គន្លឹះ ហើយចូលទៅខាងក្នុង ។ ចំណែកព្រះរាជាក៏ទ្រង់រែកអម្រែកក្រយាស្ងោយ ត្រាប់ចែកភត្តាហារឲ្យព្រះរាជធីតាទាំងឡាយបានសោយហើយ ។ ព្រះនាងបភាវតីបញ្ជូនស្រីគមទៅដោយព្រះតម្រាស់ថា ចូរម៉ែទៅនាំយកភត្តដែលព្រះបាទកុសៈចម្អិនមក ។

ស្រីគមនោះនាំមកហើយ ក្រាបទូលថា សូមព្រះនាងសោយ ។

ព្រះនាងបភាវតីពោលថា ខ្ញុំមិនសោយភត្តដែលព្រះបាទកុសៈនោះ ចម្អិនឡើយ ចូរម៉ែបរិភោគចុះ ហើយនាំយកបន្លែដែលម៉ែបានមកចម្អិនភត្ត នាំមកឲ្យខ្ញុំ ។ ចំណែករឿងដែលព្រះបាទកុសៈទ្រង់យាងមក ម៉ែកុំប្រាប់ដល់អ្នកណាឡើយ ។

ចាប់តាំងអំពីពេលនោះមក ស្រីគមក៏យកព្រះក្រយាស្ងោយដែលជាចំណែករបស់ព្រះនាងបភាវតី មកបរិភោគឯង ហើយនាំយកអាហារដែលជាចំណែករបស់ខ្លួនទៅថ្វាយព្រះនាងជំនួស ។ ចាប់តាំងអំពីនោះមក ព្រះបាទកុសៈក៏លែងបានឃើញព្រះនាងបភាវតីទៀតហើយ ទើបទ្រង់ព្រះតម្រិះថា ព្រះនាងបភាវតីនៅមានសេចក្តីស្នេហាក្នុងអញ ឬមិន

មានទេហ្ន៎ អញនឹងពិសោធនាងមើល ។ ព្រះពោធិសត្វ កាលទ្រង់ឲ្យព្រះរាជធីតាគ្រប់អង្គសោយស្រេចហើយ ទើបរើកកត្ថចេញមក លុះមកដល់ទ្វារដំណាក់របស់ព្រះនាង ទ្រង់ប្រហារផ្ទៃប្រាសាទដោយព្រះបាទ ( ទន្ទ្រាំជើង ) ធ្វើភាជនៈទាំងឡាយឲ្យទង្គិចគ្នា ហើយថ្ងូរដោយសំឡេងខ្លាំង ទ្រង់ធ្វើហាក់ដូចជាសន្ទប់ មានមុខផ្កាប់ចុះទៅខាងក្រោម ។ ដោយសំឡេងដែលព្រះពោធិសត្វថ្ងូរនោះ ព្រះនាងក៏បើកទ្វារចេញមក ទតឃើញព្រះពោធិសត្វ ត្រូវអម្រែកក្រយាស្ងោយសង្កត់ ទើបព្រះនាងមានព្រះតម្រិះថា ព្រះបាទកុសៈនេះ ជាព្រះរាជាដ៏ប្រសើរក្នុងជម្ពូទ្វីបទាំងមូលទ្រង់មកសោយទុក្ខទាំងយប់ទាំងថ្ងៃ ព្រោះអាស្រ័យអញ ទ្រង់ជាស្ដេចសុខុមាលជាតិ ត្រូវអម្រែកក្រយាស្ងោយសង្កត់ ដួលចុះហើយ ព្រះអង្គនៅមានព្រះជន្ម ឬអស់ព្រះជន្មហ្ន៎ ។ ព្រះនាងក៏ចេញអំពីដំណាក់ ឱនមើលព្រះភក្ត្រដើម្បីពិនិត្យមើលខ្យល់ដង្ហើម ត្រង់ព្រះនាសិករបស់ព្រះបាទកុសៈនោះ ។ ចំណែកព្រះបាទកុសរាជ ទ្រង់ប្រមូលព្រះខេឡៈ ( ទឹកមាត់ ) ពេញព្រះឱស្ឋហើយ ព្រួសលើសរីរៈរបស់ព្រះនាង ។ ព្រះនាងពិរោធជាខ្លាំង ជេរហើយ ត្រឡប់ចូលទៅក្នុងព្រះរាជដំណាក់ បើកទ្វារពាក់កណ្ដាល ប្រថាប់ឈរពោលគាថានេះថា

អកុ្ខតិ តស្ស កោ ហោតិ យោ អនិច្ឆន្តមិច្ឆតិ
អកាមំ រាជ កាមេហិ អកន្តោ កន្តមិច្ឆសិ ។

*បពិត្រព្រះអង្គដ៏ចម្រើន សេចក្ដីមិនចម្រើន តែងមាន ដល់បុគ្គល ដែលប្រាថ្នាបុគ្គលកាលមិនប្រាថ្នា ( ខ្លួន ) បពិត្រព្រះរាជា ព្រះអង្គមិនជាទីស្រឡាញ់ ចង់បានស្ត្រី ជាទីស្រឡាញ់ ដែលមិនមានសេចក្ដីប្រាថ្នា ដោយកាម ទាំងឡាយ ។*

*ឯព្រះបាទកុសរាជនោះ សូម្បីត្រូវព្រះនាងជេរ ក៏ទ្រង់មិនធ្វើនូវការក្ដៅក្រហាយចិត្តឲ្យកើតឡើងឡើយ ព្រោះមានព្រះហឫទ័យប្រតិព័ទ្ធ ក្នុងព្រះនាង ទើបត្រាស់ព្រះគាថាជាលំដាប់តទៅថា*

**អកាមំ វា សកាមំ វា យោ នរោ លភតេ បិយំ**
**លាភមេត្ថ បសំសាម អលាភោ តត្ថ បាបកោ ។**

*ជនណាបាននាងជាទីស្រឡាញ់ ទោះមិនមានសេចក្ដីប្រាថ្នាក្ដី មានសេចក្ដីប្រាថ្នាក្ដី យើងសរសើរនូវការបានរបស់ជននុ៎ះ បណ្ដាការបាន និងមិនបាននោះ ឯការមិនបាន ចាត់ថាជារបស់លាមក ។*

*កាលព្រះបាទកុសៈត្រាស់យ៉ាងនេះ ព្រះនាងក៏មិនបានកាត់បន្ថយពាក្យសម្ដី បែរជាពោលវាចាគ្រោតគ្រាតក្រៃលែងឡើង ព្រោះប្រាថ្នាឲ្យព្រះបាទកុសៈនោះ គេចទៅឲ្យផុត ទើបពោលគាថាមួយដទៃទៀតថា*

**បាសាណសារំ ខណសិ កណិការស្ស ទារុនា**

**រាគំ ជាលេន ពាធេសិ យោ អនិច្ឆន្តមិច្ឆសិ ។**

*ព្រះអង្គចង់បានស្ត្រី ដែលគេមិនចង់បានព្រះអង្គ ដូចជាគេជីកខ្ទឹមថ្ម ដោយដើមកណិការ ឬដូចជាគេទាក់ខ្យល់ដោយសំណាញ់ ។*

*ព្រះរាជាបានស្តាប់ពាក្យនោះហើយ ទើបត្រាស់ព្រះគាថា ៣ ថា*

**ចាសាណោ នូន តេ ហទយេ ឱហិតោ មុទុលក្ខណេ**
**យោ តេ សាតំ ន វិន្ទាមិ តិរោជនបទាគតោ ។**

*ហៃនាងមានលក្ខណៈទន់ភ្លន់ អញមកអំពីជនបទខាងក្រៅ មិនបានសេចក្តីស្រួល ( ក្នុងសម្នាក់ ) របស់នាង ឈ្មោះថា នាងយកថ្មសង្កត់លើហឫទ័យ ( នៃអញ ) ដោយពិត ។*

**យទា មំ ភកុដឹ កត្វា រាជបុត្តី ឧទិក្ខតិ**
**អាឡារិកោ តទា ហោមិ រញ្ញោ មទ្ទស្សន្តេបុរេ ។**

*ព្រះរាជបុត្រីធ្វើមុខក្រញូវ ហើយសម្លឹងមើលមកអញ ក្នុងវេលាណា អញក៏នៅជានាយពិសេស ក្នុងវាំងរបស់ព្រះបាទមទ្ទៈ ក្នុងវេលានោះ ។*

**យទា ឧម្ហយមានា មំ រាជបុត្តី ឧទិក្ខតិ**
**នាឡារិកោ តទា ហោមិ រាជា ហោមិ តទា កុសោ ។**

*ព្រះរាជបុត្រីញញឹមញញែម ក្រឡេកមើលអញ ក្នុងវេលា*

ណា អញមិននៅជានាយពិសេស ក្នុងវេលានោះទេ អញ នឹងជាព្រះបាទកុសៈ ក្នុងវេលានោះវិញ ។

ព្រះនាងបភាវតី បានស្តាប់ព្រះតម្រាស់របស់ព្រះបាទកុសរាជនោះហើយ ព្រះនាងព្រះតម្រិះថា ព្រះបាទកុសរាជនេះ កាន់តែពោលពាក្យធ្ងន់ក្រៃលែង អញនឹងពោលមុសាវាទឲ្យទ្រង់គេចទៅអំពីទីនេះ ដោយឧបាយ ទើបត្រាស់គាថានេះថា

**សចេ ហិ វចនំ សច្ចំ នេមិត្តានំ ភវិស្សតិ**

**នេវ មេ ត្វំ បតី អស្ស កាមំ ឆិន្ទន្តុ សត្តធា ។**

ប្រសិនបើពាក្យរបស់ហោរពិតមែន ព្រះអង្គមិនត្រូវបាន ជាកស្តារបស់ខ្ញុំម្ចាស់ទេ ស៊ូឲ្យគេកាត់ ( ខ្ញុំម្ចាស់ ) ជាប្រាំពីរកំណាត់ចុះ ។

អត្ថនៃគាថានោះ មានអធិប្បាយថា បពិត្រមហារាជ ពួកហោរាជាច្រើន កាលត្រូវសួរថា ព្រះបាទកុសៈបានជាស្វាមីរបស់ខ្ញុំ ឬក៏មិនបានទេ ដូច្នេះ ពួកហោរាទាំងនោះក៏ទាយថា បានឮថា ខ្ញុំម្ចាស់សុខចិត្តឲ្យគេច្រៀកជា ៧ ចម្រៀក ក៏មិនទទួលទ្រង់ជាស្វាមីរបស់ខ្ញុំម្ចាស់ ដោយពិត ។

ព្រះរាជាបានស្តាប់ពាក្យនោះហើយ កាលទ្រង់ជំទាស់ជាមួយព្រះនាង ទើបត្រាស់ថា នែនាងដ៏ចម្រើន សូម្បីខ្ញុំ ក៏បានសួរហោរាក្នុងនគររបស់ខ្ញុំដែរ ពួកហោរាទាំងនោះ ក៏ព្យាករថា ឈ្មោះថា ស្វាមីរបស់នាង

ក្រៅអំពីព្រះបាទកុសៈ ដែលមានព្រះសូរសៀងដូចរាជសីហ៍ហើយ នឹង ជាអ្នកដទៃ មិនមានឡើយ ទាំងខ្ញុំក៏ពោលយ៉ាងនេះដែរ ព្រោះហេតុនៃ កម្លាំងញាណរបស់ខ្លួន ដូច្នេះហើយ ទើបត្រាស់ព្រះគាថាតទៅទៀតថា

**សចេ ហិ វចនំ សច្ចំ អញ្ញេសំ យទិ វា មមំ**

**នេវ តុយ្ហំ បតី អត្ថិ អញ្ញោ សីហស្សរា កុសា ។**

ប្រសិនបើពាក្យរបស់ហោរដទៃ ឬរបស់អញ ពិតមែន ភស្តា របស់នាងក្រៅអំពីព្រះបាទកុសៈ ដែលមានព្រះសូរសព្ទស្មើ នឹងសំឡេងសីហៈ ក៏មិនមានទេ ។

អត្ថនៃគាថានោះ មានអធិប្បាយថា បើពាក្យរបស់គ្រូទាយដទៃជា ពាក្យពិត សូម្បីពាក្យរបស់យើង ក៏ជាពាក្យពិតដែរ ឈ្មោះថា ស្វាមីរបស់ នាងជាមនុស្សដទៃ មិនមានឡើយ ។

ព្រះនាងស្តាប់ពាក្យរបស់ព្រះបាទកុសរាជនោះហើយ ទើបព្រះ តម្រិះថា អញមិនអាចឲ្យព្រះបាទកុសៈនេះ ខ្មាស ឬគេចទៅបានឡើយ ព្រះបាទកុសៈនេះ នឹងមានប្រយោជន៍អ្វីដល់អញ ទើបបិទទ្វារហើយ ព្រះនាងក៏មិនបង្ហាញខ្លួន ។ ព្រះបាទកុសៈក៏រែកនូវអម្រែកក្រយាស្ងោយ ចុះមកហើយ តាំងអំពីកាលនោះ ទ្រង់ក៏មិនបានឃើញព្រះនាងទៀត ។ ព្រះពោធិសត្វធ្វើនាទីជាអ្នករៀបចំភត្តលំបាកក្រៃលែង សោយភត្តាហារ ព្រឹកហើយ ត្រូវពុះឧស លាងភាជនៈធំតូចស្រេចហើយ ទៅរែកទឹក

កាលផ្ទុំ ក៏ផ្ទុំខាងក្រោយស្នូកទឹក ភ្ញាក់ពីបន្ទំ ក៏ភ្ញាក់អំពីព្រលឹម ទ្រង់ចម្អិនបបរជាដើម រៃកទៅថ្វាយព្រះរាជធីតាទាំងឡាយ ទ្រង់សោយសេចក្តីទុក្ខដ៏ខ្លាំងក្លាបែបនេះ ក៏ព្រោះអាស្រ័យតម្រេក ដោយអំណាចការត្រេកអរជាប់ចំពាក់ក្នុងកាមារម្មណ៍ ។ ថ្ងៃមួយ ទ្រង់ទតឃើញស្រីគមត្រង់មាត់ទ្វាររោងចុងភៅ ទើបត្រាស់ហៅមក តែស្រីគមនោះ ក៏មិនអាចមកគាល់ព្រះពោធិសត្វបាន ព្រោះខ្លាចព្រះនាងបភាវតី ទើបប្រញាប់គេចទៅ ។ លំដាប់នោះ ព្រះពោធិសត្វស្ទុះចូលទៅជិតនាង ហើយត្រាស់ហៅថា អីនាងគម ។

ស្រីគមនោះ ត្រឡប់មកឈរ ហើយសួរថា នុ៎ះអ្នកណា ហើយពោលបន្តទៀតថា ខ្ញុំម្ចាស់មិនឮសំឡេង (ហៅ) របស់ព្រះអង្គ ។

លំដាប់នោះ ព្រះបាទកុសៈក៏ត្រាស់នឹងស្រីគមនោះថា នែនាងគមទាំងនាង ទាំងម្ចាស់របស់នាង អ្នកទាំងពីររឹងត្អឹងពន់ពេក យើងមកក្នុងសម្នាក់របស់ពួកនាង អស់កាលមានប្រមាណប៉ុណ្ណោះ មិនបាន សូម្បីត្រឹមតែការសាកសួរអំពីការមិនមានរោគ តើពួកនាងឲ្យនូវទេយ្យធម៌ដូចម្តេចកើត តែសេចក្តីនោះ ចូរស្ទេះទុកសិនចុះ តើនាងអាចធ្វើឲ្យនាងបភាវតី មានចិត្តទន់ភ្លន់ ឲ្យយើងចួបនាងបានឬទេ ។

ស្រីគមទទួលព្រះរាជតម្រាស់ថា អាចព្រះអង្គ ។

លំដាប់នោះ ព្រះបាទកុសៈក៏ត្រាស់លួងលោមស្រីគមថា បើនាង

អាចធ្វើឲ្យយើងបានចួបនាងបភាវតីនោះ យើងនឹងធ្វើឲ្យខ្នងរបស់នាងត្រង់ ហើយនឹងឲ្យគ្រឿងប្រដាប់កដល់នាង ដូច្នេះហើយ ត្រាស់គាថា ៥ ថា

នេត្តំ គីវំ តេ កាវេស្សំ បត្វា ខុជ្ជេ កុសាវតឹ
សចេ មំ ជាតជាស្សុ ឱលោកេយ្យ បភាវតី ។

នែនាងគម បើនាងបភាវតីមានភ្នែកដូចជាប្រមោយដំរី គប្បីក្រឡេកមើលអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសត្ពោរដល់នាង ។

នេត្តំ គីវំ តេ កាវេស្សំ បត្វា ខុជ្ជេ កុសាវតឹ
សចេ មំ ជាតជាស្សុ អាលបេយ្យ បភាវតី ។

នែនាងគម បើនាងបភាវតីមានភ្នែកដូចជាប្រមោយដំរី គប្បីហៅរកអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសត្ពោរដល់នាង ។

នេត្តំ គីវំ តេ កាវេស្សំ បត្វា ខុជ្ជេ កុសាវតឹ
សចេ មំ ជាតជាស្សុ ឧម្ហាយេយ្យ បភាវតី ។

នែនាងគម បើនាងបភាវតីមានភ្នែកដូចជាប្រមោយដំរី គប្បីញញឹមញញែមរកអញ លុះអញទៅដល់ក្រុងកុសាវតី នឹង

ឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសត្ពោរ ដល់នាង ។

**នេក្ខំ គីវំ តេ ការេស្សំ បត្វា ខុជ្ជេ កុសាវតឹ**
**សចេ មំ នាគនាសូរុ បម្ហាយេយ្យ បភាវតី ។**

នែនាងគម បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីសើចក្អាកក្អាយរកអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសត្ពោរ ដល់នាង ។

**នេក្ខំ គីវំ តេ ការេស្សំ បត្វា ខុជ្ជេ កុសាវតឹ**
**សចេ មេ នាគនាសូរុ ចាណីភិ ឧបសំផុសេ ។**

នែនាងគម បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីមកប៉ះពាល់អញដោយដៃទាំងឡាយ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសត្ពោរដល់នាង ។

ស្រីគមនោះ បានស្ដាប់ពាក្យរបស់ព្រះពោធិសត្វហើយ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់យាងត្រឡប់ទៅសិនចុះ ពីរបីថ្ងៃទៀត ខ្ញុំម្ចាស់នឹងធ្វើឲ្យព្រះនាងនៅក្នុងអំណាចរបស់ទ្រង់ សូមទ្រង់ចាំទតមើលសេចក្ដីព្យាយាមរបស់ខ្ញុំចុះ ដូច្នេះហើយ ពិចារណានូវកិច្ចដែល

ខ្លួនគួរធ្វើនោះ ស្រេចហើយ ទើបទៅកាន់ដំណាក់របស់ព្រះនាងបភាវតី ធ្វើជាបោសសម្អាតបន្ទប់ប្រថាប់របស់ព្រះនាង ធ្វើគ្រឿងបហារណវត្ថុ មិនឲ្យមានសេសសល់ សូម្បីតែដុំដី ដោយហោចទៅ ទ្រនាប់ជើងក៏យកចេញ បោសសម្អាតបន្ទប់ទាំងមូល រៀបចំតាំងខ្ពស់ត្រង់ធរណីទ្វារ តម្កល់តាំងទាបមួយដើម្បីព្រះនាងបភាវតី ហើយពោលថា បពិត្រព្រះនាង សូមព្រះនាងយាងមកចុះ ខ្ញុំម្ចាស់នឹងរកចៃលើសីសៈរបស់ព្រះនាង ហើយឲ្យព្រះនាងប្រថាប់គង់លើតាំងដែលទាប ដាក់សីសៈរបស់ព្រះនាងទុកក្នុងរវាងភ្លៅរបស់ខ្លួន បួតបានពង់ចៃមួយ ក៏ពោលថា ឱ! សីសៈរបស់ព្រះនាងមានចៃច្រើនណាស់! ចាប់យកចៃលើក្បាលរបស់ខ្លួន មកដាក់លើបាតព្រះហស្តរបស់ព្រះនាង ក្រាបទូលដោយពាក្យដែលជាទីស្រឡាញ់ថា សូមព្រះនាងទតមើលចៃ លើព្រះសិរសារបស់ព្រះនាងចុះ មានប្រមាណប៉ុនណា ។ កាលនឹងពោលគុណរបស់ព្រះមហាសត្វ ទើបពោលគាថាដូច្នេះថា

**ន ហិ ឆ្វនាយំ រាជបុត្តី ** **កុសេ សាតំបិ វិន្ទតិ**
**អាឡារិកោ ភតេ បោសេ** **វេត្តនេន អនត្ថិកោ ។**

ព្រះរាជបុត្រីនេះ មិនបាននូវសេចក្តីស្រួលចិត្តទៅរកព្រះបាទកុសៈ ជាបុរសនាយពិសេស អ្នកស៊ីឈ្នួល មិនត្រូវការដោយថ្លៃឈ្នួលទេ ។

អត្ថនៃគាថានោះ មានអធិប្បាយថា ព្រះរាជបុត្រីអង្គនេះ រមែង មិនបានទូវសេចក្តីសុខ សូម្បីមានប្រមាណបន្តិចបន្តួច ដោយប្រភេទនៃ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប សំពត់ និងគ្រឿងអលង្ការ ក្នុង សម្នាក់របស់ព្រះបាទកុសរាជ ដែលជាកំពូលនៃនរជន ក្នុងនគរកុសាវតី ក្នុងកាលមុន ត្រឹមតែមួយឡើយ សូម្បីវត្ថុត្រឹមតែម្ជូស្លា ដែលព្រះបាទ កុសៈព្រះរាជទានដល់ព្រះនាង ក៏គង់មិនធ្លាប់មានឡើយ ។

សួរថា ព្រោះហេតុអ្វី ។

ឆ្លើយថា ព្រោះធម្មតាស្រីទាំងឡាយ មិនអាចទម្លាយហឫទ័យនៃ ស្វាមីដែលដេកសង្កត់នូវអង្គៈ សូម្បីតែមួយថ្ងៃបានទេ ឯព្រះនាងនេះ ក៏ មិនធ្វើសូម្បីត្រឹមតែបដិសណ្ឋារៈ ក្នុងបុរសដែលជាអ្នកដាំស្ល អ្នកស៊ីឈ្នួល គឺបុរសម្នាក់ ដែលជាអ្នករៀបចំភត្ត សេចក្តីថា ជាអ្នកស៊ីឈ្នួលដោយមិន ត្រូវការតម្លៃ លះបង់រាជសម្បត្តិមកសោយទុក្ខយ៉ាងនេះ ព្រោះអាស្រ័យ ព្រះនាងមួយអង្គប៉ុណ្ណោះ បពិត្រព្រះនាង បើព្រះនាងមិនមានសេចក្តី ស្រឡាញ់ក្នុងព្រះបាទកុសរាជអង្គនោះ ដែលជាព្រះរាជាដ៏ប្រសើរក្នុង ជម្ពូទ្វីបទាំងមូល ដែលទ្រង់លំបាកព្រោះអាស្រ័យព្រះនាងទេ សូមព្រះ នាងព្រះរាជទានអ្វីតិចតួច ដល់ព្រះបាទកុសរាជនោះចុះ ។

ព្រះនាងបភាវតីបានស្តាប់ពាក្យនោះហើយ ព្រះនាងពិរោធចំពោះ ស្រីគម ។ លំដាប់នោះ ស្រីគមក៏ចាប់ព្រះនាងត្រង់ក បោះទៅក្នុងបន្ទប់

ខ្លួនឯងឈរខាងក្រៅ ហើយបិទទ្វារ ទាញខ្សែសម្រាប់ចងទ្វារមករក្សាទុក ។ ព្រះនាងបភាវតីមិនអាចចាប់ខ្សែនោះបាន ប្រថាប់ឈរក្បែរទ្វារ កាលមិនអាចបើកទ្វារបាន ទើបត្រាស់ព្រះគាថាមួយនេះថា

ន ហិ នូន អយំ ខុជ្ជា លភតិ ជិវ្ហាយ ឆេទនំ
សុនិសិតេន សត្ថេន ឯវំ ទុព្ភាសិតំ ភណំ ។

ស្ត្រីគមនេះ មិនហ៊ានកាត់អណ្ដាតដោយកាំបិតដ៏មុត ដោយពិត តែហ៊ាននិយាយពាក្យជាទុព្ភាសិតយ៉ាងនេះ ។

លំដាប់នោះ ស្រីគមនៅតែកាន់ខ្សែសម្រាប់ទាក់គន្ទឹះទ្វារនោះឯង ហើយពោលថា នែព្រះនាងមិនមានបញ្ញា ជាស្រីប្រដៅក្រ រូបរបស់ព្រះនាង នឹងធ្វើអ្វីបាន យើងទាំងឡាយ នឹងបរិភោគរូបរបស់នាងចិញ្ចឹមជីវិតបានឬ ។ កាលប្រកាសគុណរបស់ព្រះពោធិសត្វ ទើបពោលគាថា ១៣ ដែលមានឈ្មោះថា ខុជ្ជាគជ្ជិតៈ ( ពាក្យគំរាមរបស់ស្រីគម ) ដូចតទៅនេះថា

មា តំ រូបេន ធាមេសិ អារោហេន បភាវតិ
មហាយសោតិ កត្វាន ករស្សុ រុចិរេ បិយំ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកម្ពស់ ( និងទំហំរបស់ខ្លួននាង ) ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យ

ថា ព្រះបាទកុសៈនោះ ) មានយសធំ ហើយធ្វើនូវសេចក្តីស្រឡាញ់ ( ចំពោះព្រះបាទកុសៈនោះ ) ចុះ ។

**មា នំ រូបេន ចាមេសិ អារោហេន បភាវតិ**
**មហាយសោតិ កត្វាន ករស្សុ រុចិរេ បិយំ ។**

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកម្ពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានទ្រព្យច្រើន ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

**មា នំ រូបេន ចាមេសិ អារោហេន បភាវតិ**
**មហាធនោតិ កត្វាន ករស្សុ រុចិរេ បិយំ ។**

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកម្ពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានកម្លាំងច្រើន ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

**មា នំ រូបេន ចាមេសិ អារោហេន បភាវតិ**
**មហាពលោតិ កត្វាន ករស្សុ រុចិរេ បិយំ ។**

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកម្ពស់ឡើយ បពិត្រព្រះនាងស្រស់

ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈ នោះ ) មានដៃនធំ ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

មា ជំ រូបេន ចាមេសិ អារោហេន បភាវតិ
មហារជាតិ កាត្វាន ករស្សុ រុចិរេ បិយំ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈ នោះ ដោយរូប ដោយកម្ពស់ឡើយ បពិត្រព្រះនាងស្រស់ ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈ នោះ ) ជាព្រះរាជាធំ ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

មា ជំ រូបេន ចាមេសិ អារោហេន បភាវតិ
សីហស្សរោតិ កាត្វាន ករស្សុ រុចិរេ បិយំ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈ នោះ ដោយរូប ដោយកម្ពស់ឡើយ បពិត្រព្រះនាងស្រស់ ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈ នោះ ) មានសំឡេងស្មើនឹងសំឡេងនៃសីហៈ ហើយធ្វើនូវ សេចក្តីស្រឡាញ់ចុះ ។

មា ជំ រូបេន ចាមេសិ អារោហេន បភាវតិ
វគ្គុស្សរោតិ កាត្វាន ករស្សុ រុចិរេ បិយំ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈ

នោះ ដោយរូប ដោយកម្ពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានសំឡេងដ៏ពីរោះ ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

**មា នំ រូបេន ចាមេសិ អាពោហេន បភាវតិ**
**ពិន្ទុស្សរោតិ កត្វាន ករស្សុ រុចិរេ បិយំ ។**

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកម្ពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានសំឡេងមូល ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

**មា នំ រូបេន ចាមេសិ អាពោហេន បភាវតិ**
**មញ្ជុស្សរោតិ កត្វាន ករស្សុ រុចិរេ បិយំ ។**

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកម្ពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានសំឡេងល្អ ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

**មា នំ រូបេន ចាមេសិ អាពោហេន បភាវតិ**
**មធុរស្សរោតិ កត្វាន ករស្សុ រុចិរេ បិយំ ។**

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកម្ពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានសំឡេងដ៏ផ្អែមល្ហែម ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

**មា នំ រូបេន ចាមេសិ អារោហេន បភាវតិ**
**សតសិប្បោតិ កត្វាន ករស្សុ រុចិរេ បិយំ ។**

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកម្ពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានសិល្បៈច្រើន ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

**មា នំ រូបេន ចាមេសិ អារោហេន បភាវតិ**
**ខត្តិយោតិបិ កត្វាន ករស្សុ រុចិរេ បិយំ ។**

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកម្ពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) ជាក្សត្រិយ៍ ( សុទ្ធ ) ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

មា នំ រូបេន ចាមេសិ អាពោហេន បភាវតិ
កុសរាជាតិ កត្វាន ករស្សុ រុចិរេ បិយំ ។

*បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកម្ពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) ជាព្រះរាជា មាននាមស្មើនឹងស្បូវក្លាំង ( ដែលព្រះឥន្ទ្រប្រទាន ) ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។*

*ពិតហើយ ស្រីគមនោះពោលថា សូមព្រះនាងជ្រាបចុះថា ឈ្មោះថា ព្រះរាជាអង្គដទៃដែលមានសភាពដូច្នេះ មិនមានឡើយ សូមព្រះនាងធ្វើនូវសេចក្តីស្រឡាញ់ក្នុងព្រះបាទកុសរាជនោះចុះ ស្រីគមនោះបានពោលពាក្យពណ៌នាគុណរបស់ព្រះបាទកុសរាជនោះ ដោយគាថាទាំងឡាយមានប្រមាណប៉ុណ្ណេះ ។*

*ព្រះនាងបភាវតីបានស្តាប់ពាក្យរបស់ស្រីគមនោះ ទើបសម្គុតស្រីគមនោះថា នែនាងគម នាងគំរាមយើងច្រើនពេកហើយ បើយើងចាប់ដៃនាងបាន នឹងឲ្យនាងដឹងភាពដែលនាងមានម្ចាស់ ។ ឯស្រីគមនោះក៏គំរាមឲ្យព្រះនាងខ្លាចដោយសំឡេងខ្លាំងថា ខ្ញុំម្ចាស់រក្សាព្រះនាង មិនបានក្រាបទូលថា ព្រះបាទកុសរាជយាងមក ដល់ព្រះរាជបិតារបស់ព្រះនាង ណ្ហើយចុះ ទោះជាយ៉ាងណា ថ្ងៃនេះ ខ្ញុំម្ចាស់នឹងក្រាបទូលឲ្យព្រះ*

រាជាទ្រង់ជ្រាប ។ សូម្បីព្រះនាងក៏ព្រះតម្រិះថា (បើនៅជដែកទៀត) បុគ្គលណាមួយ គប្បីបានឮ ទើបធ្វើស្រីគមឲ្យយល់ព្រម ។

ព្រះពោធិសត្វ ទ្រង់មិនបានឃើញព្រះនាង ទ្រង់លំបាកព្រោះក្រយាស្ងោយដែលមិនល្អ ព្រោះការផ្ទំដ៏លំបាកអស់ ៧ ខែ ទ្រង់ព្រះតម្រិះថា ស្រីគមនេះ នឹងមានប្រយោជន៍អ្វីដល់អញ អញនៅទីនេះ អស់ ៧ ខែហើយ មិនបានឃើញនាងបភាវតីឡើយ ។ នាងបភាវតីនោះ រឹងរូសអាក្រក់ក្រៃពេក អញនឹងទៅសួរសុខទុក្ខព្រះមាតាបិតា ។

ក្នុងខណៈនោះ សក្កទេវរាជទ្រង់ពិចារណា បានជ្រាបភាពដែលព្រះពោធិសត្វនោះ ទ្រង់ធុញទ្រាន់ ទើបទ្រង់ព្រះតម្រិះថា ព្រះរាជាមិនបានឃើញព្រះនាងបភាវតីអស់ ៧ ខែហើយ អញនឹងឲ្យព្រះរាជាសមតាមព្រះរាជបំណង ទើបទ្រង់និម្មិតបុរសទាំងឡាយ ធ្វើជាទូតរបស់ព្រះបាទមទ្ទរាជ បញ្ជូនទៅកាន់ព្រះរាជាទាំង ៧ នគរ ទ្រង់បញ្ជូនព្រះរាជសាសន៍ដល់ព្រះរាជាមួយអង្គ ៗ ផ្សេង ៗ គ្នាថា ព្រះនាងបភាវតីលះបង់ព្រះបាទកុសរាជ ត្រឡប់មកហើយ (បើទ្រង់មានព្រះបំណង) ក៏ចូរយាងមកទទួលយកព្រះនាងបភាវតីទៅចុះ ។

ព្រះរាជាទាំង ៧ នគរនោះ ក៏នាំគ្នាមក មួយអន្លើដោយបរិវារច្រើន ដល់សាគលនគរ មិនបានដឹងដល់ហេតុដែលយាងមករបស់គ្នានឹងគ្នា ។ ព្រះរាជាទាំងនោះ ក៏ត្រាស់សួរគ្នាថា ព្រោះហេតុអ្វី ទើប

ទ្រង់យាងមក ព្រោះហេតុអ្វី ទើបទ្រង់យាងមក ។ កាលដឹងរឿងនោះ ក៏ទ្រង់ព្រះពិរោធ ត្រាស់ថា បានឮថា ព្រះបាទមទ្ទរាជលើកព្រះរាជធីតាតែមួយអង្គ ឲ្យដល់ព្រះរាជា ៧ នគរ ទ្រង់ទាំងឡាយ ចូរមើលការប្រព្រឹត្តមិនសមគួររបស់ព្រះរាជានេះ ទ្រង់មកលលេងជាមួយពួកយើង យើងនឹងនាំគ្នាចាប់ព្រះរាជានោះឲ្យបាន ដូច្នេះហើយ ព្រះរាជាទាំងនោះក៏បញ្ជូនព្រះរាជសាសន៍ទៅថា ចូរឲ្យព្រះនាងបភាវតីដល់ពួកយើង ឬក៏ច្បាំង ហើយលើកពលព័ទ្ធនគរ ។

ព្រះបាទមទ្ទរាជ ទ្រង់ស្ដាប់ព្រះរាជសាសន៍នោះហើយ ទ្រង់ភ័យតក់ស្លុត ទើបហៅអាមាត្យទាំងឡាយមក សួរថា យើងនឹងធ្វើដូចម្ដេច ។ លំដាប់នោះ អាមាត្យទាំងនោះ ក្រាបទូលព្រះរាជាថា បពិត្រព្រះទេវៈ ព្រះរាជាទាំង ៧ ព្រះអង្គនោះ មកព្រោះអាស្រ័យព្រះនាងបភាវតី គ្រប់អង្គត្រាស់ថា បើព្រះបាទមទ្ទរាជមិនឲ្យព្រះនាង យើងទាំងឡាយនឹងបំបាក់កំពែងចូលទៅក្នុងនគរ នឹងញុំាងព្រះបាទមទ្ទរាជនោះ ឲ្យដល់នូវការអស់ជីវិត ហើយនាំយកព្រះនាងបភាវតីនោះទៅ ដូច្នេះ កាលកំពែងមិនទាន់ត្រូវទម្លាយនោះឯង ពួកយើងគួរប្រញាប់ប្រញាល់បញ្ជូនព្រះនាងបភាវតីទៅឲ្យក្សត្រទាំងនោះមុន ដូច្នេះហើយ ពោលគាថានេះថា

ឯតេ ជាតា ឧបត្ថទ្ធា សព្វេ តិដ្ឋន្តិ វម្មិកា
ភិន្ទន្តិ បាការំ អានេថេតំ បភាវតឹ ។

ព្រះរាជាដ៏ប្រសើរទាំងអស់នុ៎ះ ជាព្រះរាជាគឃ្នើន មកហើយ ប្រដាប់ដោយគ្រឿងក្រោះ (សូមព្រះអង្គផ្ញើព្រះរាជសារទៅ ថា) អ្នកទាំងឡាយ ចូរនាំព្រះនាងបភាវតីនុ៎ះមក (បញ្ជូន ទៅថ្វាយព្រះរាជាទាំងនោះ) កុំឲ្យទម្លាយ កំពែងមុនទាន់ ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ទើបត្រាស់ថា បើយើងបញ្ជូននាងបភាវតីទៅឲ្យក្សត្រមួយអង្គ ក្សត្រដ៏សេសនឹងធ្វើសង្គ្រាម យើងមិនអាចឲ្យដល់ក្សត្រតែមួយអង្គបានទេ ឯនាងបភាវតីនេះ លះបង់ព្រះរាជាដ៏ប្រសើរក្នុងសកលជម្ពូទ្វីប មកហើយដោយរង្កៀសថា ជាស្ដេចដែលមានរូបគួរខ្ពើម ឥឡូវនេះ ចូរទទួលផលនៃការត្រឡប់មកនោះចុះ អញនឹងសម្លាប់នាង ហើយកាត់ជា ៧ កំណាត់ បញ្ជូនទៅថ្វាយក្សត្រទាំង ៧ អង្គនោះ ដូច្នេះហើយ ទើបត្រាស់គាថាជាលំដាប់ទៅថា

**សត្ត ពិលេ ករិត្វាន អហមេតំ បភាវតឹ**
**ខត្តិយានំ បទស្សាមិ យេ មំ ហន្តុំ ឥធាគតា ។**

អញនឹងធ្វើនាងបភាវតីនុ៎ះ ឲ្យជា ៧ កំណាត់ ហើយឲ្យដល់ពួកក្សត្រិយ៍ដែលមកក្នុងទីនេះ ដើម្បីសម្លាប់អញ ។

ព្រះរាជតម្រាស់របស់ព្រះបាទមទ្ទរាជនោះ បានប្រាកដទូទៅពេញព្រះរាជនិវេសន៍ទាំងមូល ។ ពួកបរិចារិកាក៏ចូលទៅទូលព្រះនាងបភាវតីថា បានឮថា ព្រះរាជាទ្រង់នឹងកាត់ព្រះនាងជា ៧ កំណាត់ ហើយ

បញ្ជូនទៅថ្វាយព្រះរាជា ៧ នគរ ។ ព្រះនាងស្តាប់ពាក្យនោះហើយ ខ្លាចចំពោះមរណភ័យ ក្រោកចាកទីប្រថាប់ មានព្រះគគិនីទាំងឡាយចោមរោម យាងទៅកាន់បន្ទប់ដ៏មានសិរីរបស់ព្រះមាតា ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

**អវុដ្ឋហិ រាជបុត្តី សាមា កោសេយ្យវាសិនី**
**អស្សុបុណ្ណេហិ នេត្តេហិ ទាសីគណបុរក្ខតា ។**

ព្រះរាជបុត្រីមានសម្បុរលឿង ទ្រង់ព្រះពស្ត្រជាវិការៈនៃសូត្រ (រំលេចដោយមាស) ដែលពួកទាសីហែហម មាននេត្រាដ៏ពេញដោយព្រះអស្សុជល បានក្រោក (ចាកអាសនៈ) ។

ព្រះនាងចូលទៅកាន់សម្នាក់ព្រះមាតា ថ្វាយបង្គំព្រះមាតាហើយ ព្រះកន្សែងក្រាបទូលថា

**តំ នូន កក្កូបនិសេវិតំ មុខំ**
**អាទាសទន្តាថរុបច្ចវេក្ខិតំ**
**សុភំ សុនេត្តំ វិរជំ អនង្គណំ**
**ឆុឌ្ឌំ វនេ បស្សតិ ខត្តិយេហិ ។**

បពិត្រព្រះមាតា មុខ (របស់ខ្ញុំ) នោះ ធ្លាប់លាបស្រឡាបគ្រឿងលម្អិត ដុះកញ្ចក់មានក្របជាវិការៈនៃភ្លុក ជាមុខល្អ មានភ្នែកល្អ រលីងរាបធេង ត្រូវពួក

*ក្សត្រិយ៍លះចោលហើយ នឹងតាំងនៅក្នុងព្រៃ ។*

តេ នូន មេ អសិតេ វេល្លិតគ្គេ
កោសេ មុទូ ចន្ទនសារលិត្តេ
សមាកុលេ សីវថិកាយ មជ្ឈេ
ចារេហិ គិជ្ឈា បរិកឌ្ឍយន្តិ ។

*ពួកត្មាតនឹងលើកជើងទាំងឡាយ កកាយនូវសក់ទាំងនោះ របស់ខ្ញុំ ជាសក់ខ្មៅមានចុងង ទន់ លាបដោយខ្លឹមចន្ទន៍ ឲ្យប្រឡូកប្រឡល់ ក្នុងកណ្តាលព្រៃស្មសាន ។*

តា នូន មេ តម្ពនខា សុលោមា
ពាហា មុទូ ចន្ទនសារលិត្តា
ឆិន្នា វនេ ឧជ្ឈិតា ខត្តិយេហិ
គយ្ហ ធង្ខោ គច្ឆតិ យេន កាមំ ។

*ភ្លៅកចឹកដៃរបស់ខ្ញុំនោះ ដែលមានក្រចកក្រហម មានរោមល្អ ទន់ លាបដោយខ្លឹមចន្ទន៍ ដាច់ខ្ចាត់ខ្ចាយ ដែលពួកក្សត្រិយ៍ចោលក្នុងព្រៃ ហើយហើរទៅតាមប្រាថ្នា ។*

តេ នូន តាលូបនិភេ អលម្ពេ
និសេវិតេ កាសិកចន្ទនេន
ថនេសុ មេ លម្ពិស្សតិ សិគាលោ

**មាតូ វ បុត្តោ តរុណោ តនុជោ ។**

*ចចក ( ឃើញស្តនរបស់ខ្ញុំ ) នោះ ស្រដៀងគ្នានឹងផ្លែត្នោត មិនយារ លាបដោយខ្លឹមចន្ទន៍ដ៏ល្អិត ហើយបៀមនូវស្តនរបស់ខ្ញុំនោះ ដូចជាកូនខ្ចីបង្កើត ដែលបៀមនូវស្តនរបស់មាតា ។*

**តំ នូន សោណឹ បុថុលំ សុកោដ្ដិតំ**
**និសេវិតំ កញ្ចនមេខលាហិ**
**ឋិន្នំ វនេ ខត្តិយេហិ អវត្ថំ**
**សិង្គាលសង្ឃា បរិកឌ្ឍយន្តិ ។**

*ហ្វូងចចកជញ្ជែងត្រគាក ( របស់ខ្ញុំ ) នោះ ជាអវយវៈទូលាយ ដែលគេដំល្អហើយ ពាក់ដោយខ្សែក្រវាត់មាសទាំងឡាយ ដាច់ខ្ចាត់ខ្ចាយ ដែលពួកក្សត្រិយ៍បោលក្នុងព្រៃ ។*

**សោណា ធង្កា សិគាលា ច យេ ចញ្ញេ សន្តិ ទាឋិនោ**
**អជរា នូន ហេស្សន្តិ ភក្ខយិត្វា បភាវតី ។**

*ពួកឆ្កែ ក្អែក ចចក និងសត្វឯទៀត ដែលមានចង្កូម ស៊ីនាងបភាវតី មុខជានឹងមិនចាស់គ្រាំគ្រា ដោយពិត ។*

**សចេ មំសានិ ហរិំសុ ខត្តិយា ទូរគាមិនោ**

**អជ្ជិនិ អម្ម យាចិត្វា អនុបន្ថេ ឧហាច ជំ ។**

*ប្រសិនបើពួកក្សត្រិយ៍ ដែលទៅឆ្ងាយ នាំយកសាច់ទាំងឡាយ (របស់ខ្ញុំ) ទៅ បពិត្រព្រះមាតា ចូរព្រះអង្គសូមយកឆ្អឹងទាំងឡាយ ហើយដុតឆ្អឹងនោះ ក្នុងទីបន្ទាប់ផ្លូវ (ក្នុងចន្លោះនៃផ្លូវដើរនិងផ្លូវធំ) ។*

**ខេត្តានិ អម្ម ការេត្វា កណិការេត្ថ ពេបយេ**

**យទា តេ បុប្ផិតា អស្សុ ហេមន្តានំ ហិមច្ចយេ**

**សំសេយ្យាថ មមំ អម្ម ឯវំវណ្ណា បភាវតិ ។**

*បពិត្រព្រះមាតា សូមព្រះមាតាប្រើគេធ្វើសួនច្បារ ហើយដាំដើមកណិការក្នុងសួនច្បារនុ៎ះ ក្នុងវេលាណា ដែលដើមកណិការទាំងនោះ មានផ្កា ក្នុងអំណើះទៅនៃកាល ជាទីធ្លាក់នៃទឹកសន្សើម ក្នុងហេមន្តរដូវ បពិត្រព្រះមាតា សូមព្រះមាតារឭកខ្ញុំថា នាងបភាវតីមានវណ្ណៈយ៉ាងនេះ ដូច្នេះ ។*

*ព្រះនាងបភាវតីត្រូវមរណភ័យគំរាមហើយ ក៏ពោលរៀបរាប់ក្នុងសម្នាក់របស់ព្រះមាតា ដោយប្រការដូច្នេះ ។ ឯព្រះបាទមទ្ទរាជត្រាស់បង្គាប់ថា នាយពេជ្ឈឃាតដែលសម្លាប់ចោរ ចូរមកណេះ ចូរយកប៉ូវថៅនិងជ្រញ៉មក ។ កាលនាយពេជ្ឈឃាដនោះ ចូលមក ក៏ប្រាកដទូទៅក្នុងព្រះរាជវាំងទាំងមូល ។ លំដាប់នោះ ព្រះមាតារបស់ព្រះនាងបភាវតី*

ព្រះនាងព្រះសណ្ដាប់អំពីភាពដែលនាយពេជ្ឈឃាដនោះ មកហើយ ក៏ក្រោកឡើងអំពីអាសនៈ ព្រះនាងពេញព្រៀបដោយសេចក្ដីសោក យាងទៅកាន់សម្នាក់របស់ព្រះរាជា ។

ព្រះសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់ថា

**តស្សា មាតា ឧដដ្ឋាសិ ខត្តិយា ទេវវណ្ណិនី**
**ទិស្វា អសិញ្ច សុនញ្ច រញ្ញោ មទ្ទស្សន្តេបុរេ ។**

ក្សត្រិយ៍មានវណ្ណៈដូចវណ្ណៈទេវតា ជាមាតារបស់នាងបភាវតីនោះ ក្រោកចាកអាសនៈ ទៅកាន់សម្នាក់ព្រះរាជាហើយ បានឃើញដាវនិងជ្រញ់ ក្នុងព្រះរាជវាំងព្រះបាទមទ្ទៈ ។

ព្រះនាងទតឃើញប៉ូវថៅនិងជ្រញ់ ដែលគេដាក់ខាងមុខព្រះភក្ត្រព្រះរាជា លើផ្ទៃមហាប្រាសាទដែលប្រដាប់តាក់តែងហើយ ខាងក្នុងបុរីទើបខ្សឹកខ្សួល ត្រាស់ព្រះគាថាដូច្នេះថា

**ឥមិនា នូន អសិនា សុសញ្ញំ តនុមជ្ឈិមំ**
**ធីតរំ មទ្ទ ហន្ត្វាន ខត្តិយានំ បទស្សសិ ។**

បពិត្រព្រះបាទមទ្ទៈ ព្រះអង្គនឹងសម្លាប់ធីតាដែលគេចំណាំបានដោយងាយ មានចង្កេះរៀវ ដោយប៉ូវថៅនេះ ហើយប្រទានដល់ពួកក្សត្រិយ៍ ដោយពិត ។

លំដាប់នោះ ព្រះរាជា កាលទ្រង់ឲ្យព្រះទេវីនោះរឭក ទើបត្រាស់

ថា នៃទេវី នាងនិយាយអ្វី ធីតារបស់នាងបោះបង់ព្រះរាជាដែលជាធំក្នុងជម្ពូទ្វីបទាំងមូល ដោយការស្អប់ខ្ពើមថា ជាអ្នកមានរូបអាក្រក់ កាលស្នាមជើងក្នុងផ្លូវដែលមក មិនទាន់វិនាសនោះឯង ក៏នាំយកសេចក្ដីស្លាប់មកដោយថ្វាស ដូច្នេះ ឥឡូវនេះ ចូរទទួលផលប្រាកដដូចនេះ ព្រោះអាស្រ័យរូបរបស់ខ្លួនចុះ ។ ព្រះនាងបានស្ដាប់ព្រះរាជតម្រាស់របស់ព្រះរាជាហើយ យាងទៅកាន់ដំណាក់របស់ព្រះរាជធីតា ទ្រង់ព្រះកន្សែងថា

ន មេ អកាសិ វចនំ អត្ថកាមាយ បុត្តិកេ
សាជ្ជ លោហិតសញ្ឆន្នា គច្ឆសិ យមសាធនំ ។

ហៃបុត្រី នាងមិនបានធ្វើតាមពាក្យរបស់អញ ដែលប្រាថ្នាប្រយោជន៍ នាងមុខជានឹងពេញពាសដោយឈាម ហើយទៅកាន់ភពរបស់មច្ចុរាជ ក្នុងថ្ងៃនេះ ។

ឯវមាបជ្ជតី ពោសោ បាបិយញ្ច និគច្ឆតិ
យោ ចេ ហិតានំ វចនំ ន ករោតិ អត្ថទស្សិនំ ។

បើសត្វដែលមិនធ្វើតាមពាក្យរបស់ពួកជន ដែលបង្ហាញសេចក្ដីចម្រើន បង្ហាញប្រយោជន៍ហើយ តែងប៉ះទង្គិចយ៉ាងនេះផង តែងចួបប្រទះនូវសេចក្ដីអាក្រក់ជាង (នេះ) ផង ។

សចេវ អជ្ជ ធារេសិ កុមារំ ចារុទស្សនំ
កុសេន ជាតំ ខត្តិយំ សុវណ្ណមណិមេខលំ

**បូជិតំ ញាតិសង្ឃេហិ ន គច្ឆសិ យមក្ខយំ ។**

*បើក្នុងថ្ងៃនេះ នាងនឹងបានទ្រទ្រង់កុមារស្រស់ប៉ប្រៃ ជាក្សត្រិយ៍ដែលកើតព្រោះព្រះបាទកុសៈ មានខ្សែក្រវាត់ជាវិការៈនៃមាសនិងកែវមណី ដែលពួកញាតិបូជាហើយ នាងនឹងមិនទៅកាន់លំនៅយមរាជទេ ។*

**យត្ថស្សុ ភេរី នទតិ កុញ្ជរោ ច និកូជតិ**
**ខត្តិយានំ កុលេ ភទ្ទេ កឹ នុ សុខតរំ តតោ ។**

*នៃនាងដ៏ចម្រើន ស្គរលាន់ឮក្តី ដំរីស្រែកក្តី ក្នុងខត្តិយត្រកូលណា (នាងឃើញ) អ្វី ដែលជាសុខក្រៃលែងជាងខត្តិយ-ត្រកូលនោះ (បានជានាងមកក្នុងទីនេះ) ។*

**អស្សោ ហសីយតិ ទ្វារេ កុមារោ ឧបរោទតិ**
**ខត្តិយានំ កុលេ ភទ្ទេ កឹ នុ សុខតរំ តតោ ។**

*សេះក្វាប្រធីប្របទ្វារ កុមារអ្នករបាំប្រគំក្នុងខត្តិយត្រកូលណា នៃនាងដ៏ចម្រើន (នាងឃើញ) អ្វី ដែលជាសុខក្រៃលែងជាងខត្តិយត្រកូលនោះ ។*

**មយូរកោញ្ចាភិរុទេ កោកិលាភិនិកូជិតេ**
**ខត្តិយានំ កុលេ ភទ្ទេ កឹ នុ សុខតរំ តតោ ។**

*កាលបើក្ងោកនិងក្រៀលយំ និងតាវ៉ៅយំ ឮទ្រហឹងអឺងកង*

ក្នុងខត្តិយត្រកូលណា នៃនាងដំបម្រើន (នាងឃើញ) អ្វី ដែលជាសុខក្រៃលែង ជាងខត្តិយត្រកូលនោះ ។

ព្រះទេវីចរចាជាមួយព្រះនាងបភាវតី ដោយគាថាមានប្រមាណប៉ុណ្ណោះ ដោយប្រការដូច្នេះហើយ ព្រះនាងមានព្រះចិន្តាថា បើក្នុងថ្ងៃនេះ ព្រះបាទកុសរាជដែលជាធំជាងជន គប្បីប្រថាប់គង់ក្នុងទីនេះសោត ទ្រង់ក៏នឹងញ៉ាំងព្រះរាជាទាំង ៧ នគរនេះ ឲ្យរត់ខ្ចាត់ខ្ចាយទៅ នឹងដោះនូវជីតារបស់អញឲ្យផុតចាកសេចក្ដីទុក្ខ ហើយនាំកូនរបស់អញត្រឡប់ទៅ ដូច្នេះហើយ ទើបពោលគាថាថា

**កហំ នុ សោ សត្តុមទ្ទនោ បររដ្ឋប្បមទ្ទនោ**
**កុសោ សោឡារបញ្ញាណោ យោ នោ ទុក្ខា បមោចយេ ។**

ព្រះបាទកុសៈ ជាអ្នកញាំញីខ្មាំងសត្រូវ ញាំញីដែនរបស់ព្រះរាជដទៃ មានប្រាជ្ញាធើត គប្បីដោះយើងឲ្យរួចចាកទុក្ខបាន តើនៅក្នុងទីណា ។

លំដាប់នោះ ព្រះនាងបភាវតីព្រះតម្រិះថា កាលព្រះមាតារបស់អញពណ៌នាគុណរបស់ព្រះបាទកុសៈនោះដោយព្រះឱស្ឋ ក៏មិនគ្រប់គ្រាន់ អញនឹងទូលភាពដែលព្រះបាទកុសៈនោះ ទ្រង់ធ្វើការងារជាអ្នកពិសេស ប្រថាប់នៅក្នុងទីនេះឯង ដល់ព្រះមាតា ទើបក្រាបទូលជាគាថាថា

**ឥធេវ សោ សត្តុមទ្ទនោ បររដ្ឋប្បមទ្ទនោ**

**កុសោ សោឡារបញ្ញាណោ យោ តេ សព្វេ វជិស្សតិ ។**

*ព្រះបាទកុសៈ ជាអ្នកញាំញីខ្មាំងសត្រូវ ញាំញីដែនរបស់ព្រះរាជាដទៃ មានប្រាជ្ញាឆេតឆ្លៀត សម្រាប់ក្សត្រិយ៍ទាំងអស់នោះ នៅក្នុងទីនេះឯង ។*

*លំដាប់នោះ ព្រះមាតារបស់ព្រះនាងបភាវតី ព្រះតម្រិះថា កូនរបស់អញនេះ ប្រហែលជាខ្លាចចំពោះមរណភ័យ ទើបរវើរវាយ ដូច្នេះហើយ ត្រាស់គាថាថា*

**ឧម្មត្តិកា នុ ភណសិ អន្ធពាលា បភាសសិ**
**កុសោ ចេ អាគតោ អស្ស កឹ នុ ជានេមុ តំ មយំ ។**

*នាងជាស្រីឆ្កួត ជាស្រីអន្ធពាល ចេះតែនិយាយ ( ឲ្យរួចតែពីមាត់ ) បើព្រះបាទកុសៈគប្បីមក ពួកយើងធ្វើដូចម្ដេច នឹងស្គាល់ព្រះបាទកុសៈនោះបាន ។*

*កាលព្រះមាតាត្រាស់យ៉ាងនេះហើយ ព្រះនាងបភាវតីព្រះតម្រិះថា ព្រះមាតារបស់អញ ទ្រង់មិនជឿ ទ្រង់មិនជ្រាបថា ព្រះបាទកុសរាជនោះ យាងមកប្រថាប់ក្នុងទីនេះ ៧ ខែហើយ អញនឹងបង្ហាញព្រះបាទកុសរាជនោះ ដល់ព្រះមាតា ទើបចាប់ព្រះហស្តព្រះមាតាទៅ ហើយបើកបង្អួច ចង្អុលបង្ហាញឲ្យព្រះមាតាទត បានពោលនូវគាថានេះថា*

**ឯសោ អាឡារិកោ ចោសោ កុមារីបុរមន្តរេ**

ឧជ្ជុំ កត្វាន សំវេល្លំ កុម្ភី ជោវតិ ឱនតោ ។

(ព្រះបាទកុស:) គឺបុរសនាយពិសេសនុ៎ះ ចង់ក្បិនយ៉ាងមាំ ឱន លាងផ្ទាំង (សូមព្រះមាតាទត) ត្រង់ចន្លោះដំណាក់កុមារី ។

បានឮថា ក្នុងកាលនោះ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា ថ្ងៃនេះ សេចក្តីប្រាថ្នារបស់អញគប្បីដល់ទីបំផុត ដោយពិត នាងបភាវតីត្រូវភ័យ អំពីសេចក្តីស្លាប់គំរាម គង់ក្រាបទូលនូវភាពដែលអញមកក្នុងទីនេះ (ចំពោះព្រះមាតា និងព្រះបិតាឲ្យទ្រង់ជ្រាប) អញនឹងចាត់ចែងលាង ចានទាំងឡាយ ហើយរក្សាទុក ដូច្នេះហើយ ទើបទៅដងទឹកមក ទ្រង់ ផ្តើមលាងចានទាំងឡាយ ។ លំដាប់នោះ ព្រះមាតាក៏បរិភាសតិះដៀល ព្រះនាងបភាវតីដោយគាថាថា

វេណី ត្វមសិ ចណ្ឌាលី អាទូសិ កុលគន្ធិនី
កថំ មទ្ទកុលេ ជាតា ទាសំ កយិរាសិ កាមុកំ ។

នាងជាស្រីនៃត្រកូលជាងចាំង ជាស្រីចណ្ឌាល ឬជាស្រី ទ្រុស្តត្រកូល នាងកើតក្នុងត្រកូលព្រះបាទមទ្ទ: គួរធ្វើស្វាមី (របស់ខ្លួន) ឲ្យជាទាស: ដូចម្តេចកើត ។

លំដាប់នោះ ព្រះនាងបភាវតីទ្រង់មានព្រះចិន្តាថា ព្រះមាតារបស់ អញ ប្រហែលទ្រង់មិនជ្រាបភាពដែលព្រះបាទកុសរាជនោះ យាងមក ព្រោះអាស្រ័យអញ ទើបពោលគាថាក្រៅអំពីនេះថា

នម្හិ វេណី ន ចណ្ឌាលី ន ចម្ហិ កុលគន្ធិនី
ឱក្កាកបុត្តោ ភទ្ទន្តេ ត្វំ នុ ទាសោតិ មញ្ញសិ ។

*ខ្ញុំមិនមែនជាស្រីត្រកូលជាងចាំង មិនមែនជាស្រីចណ្ឌាល មិនមែនជាស្រីទ្រុស្តត្រកូលទេ បពិត្រព្រះមាតា ( ព្រះបាទកុសៈនោះ ) ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថាជាទាសៈទៅវិញ ។*

*ឥឡូវនេះ ព្រះនាងបភាវតី កាលពណ៌នាដល់ព្រះកិត្តិយសរបស់ព្រះបាទកុសរាជនោះ ទើបពោលថា*

យោ ព្រាហ្មណសហស្សានិ សទា ភោជេតិ វីសតិ
ឱក្កាកបុត្តោ ភទ្ទន្តេ ត្វំ នុ ទាសោតិ មញ្ញសិ ។

*ព្រះបាទកុសៈណា ញ៉ាំងពួកព្រាហ្មណ៍ទាំងម្ភៃពាន់ ឲ្យបរិភោគសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថាជាទាសៈទៅវិញ ។*

យស្ស នាគសហស្សានិ សទា យោជេន្តិ វីសតិ
ឱក្កាកបុត្តោ ភទ្ទន្តេ ត្វំ នុ ទាសោតិ មញ្ញសិ ។

*ពួកជនតែងទឹមដំរី ទាំងម្ភៃពាន់ របស់ព្រះបាទកុសៈណា សព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្តរបស់*

*ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថាជាទាសៈទៅវិញ ។*

**យស្ស អស្សសហស្សានិ សទា យោជេន្តិ វីសតិ**
**ឱក្កាកបុត្តោ ភទ្ទន្តេ ត្វំ នុ ទាសោតិ មញ្ញសិ ។**

*ពួកជនតែងទឹមសេះ ទាំងម្ភៃពាន់ របស់ព្រះបាទកុសៈណា សព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថាជាទាសៈទៅវិញ ។*

**យស្ស រថសហស្សានិ សទា យោជេន្តិ វីសតិ**
**ឱក្កាកបុត្តោ ភទ្ទន្តេ ត្វំ នុ ទាសោតិ មញ្ញសិ ។**
**( យស្ស ឧសភសហស្សានិ សទា យោជេន្តិ វីសតី**
**ឱក្កាកបុត្តោ ភទ្ទន្តេ ត្វំ នុ ទាសោតិ មញ្ញសិ ) ។**

*ពួកជនតែងទឹមរថ ទាំងម្ភៃពាន់ របស់ព្រះបាទកុសៈណា សព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថាជាទាសៈទៅវិញ ។ ពួកជនតែងទឹមគោឧសភទាំងម្ភៃពាន់ របស់ព្រះបាទកុសៈណា សព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែក*

ខាង ) ព្រះមាតាទេតើ សម្គាល់ថា ជាទាសៈទៅវិញ [១] ។

**យស្ស ជេនុសហស្សានិ សទា ទុហន្តិ វីសតិ**
**ឱក្កាកបុត្តោ ភទ្ទន្តេ ត្វំ នុ ទាសោតិ មញ្ញសិ ។**

ពួកជន តែងរីតទឹកដោះមេគោទាំងម្ភៃពាន់ របស់ព្រះបាទកុសៈណា សព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថាជាទាសៈទៅវិញ ។

ព្រះនាងបភាវតីបានពណ៌នាអំពីយសរបស់ព្រះមហាសត្វ ដោយគាថា ៩ យ៉ាងនេះហើយ ។ លំដាប់នោះ ព្រះមាតារបស់ព្រះនាងក៏ជឿ ហើយព្រះតម្រិះថា កូនស្រីរបស់អញនេះ ពោលពាក្យមាំទាំ ពាក្យនេះ គង់ជាយ៉ាងនេះពិត ទើបប្រញាប់ទៅកាន់សម្នាក់របស់ព្រះរាជាក្រាបទូលសេចក្តីនោះ ឲ្យទ្រង់ជ្រាប ។ ព្រះរាជាស្តេចទៅកាន់ព្រះរាជដំណាក់របស់ព្រះនាងបភាវតី ដោយរួសរាន់ ហើយត្រាស់សួរថា នែបុត្រីពិតឬ បានឮថា ព្រះបាទកុសរាជទ្រង់យាងមកក្នុងទីនេះ ។

ព្រះនាងបភាវតីក្រាបទូលថា បពិត្រព្រះបិតា ពិតយ៉ាងនោះឯង ព្រះបាទកុសរាជអង្គនោះ ទ្រង់ធ្វើកិច្ចជាអ្នកពិសេស ដាំស្ងួថ្វាយព្រះរាជ

---

១-គាថាដែលនៅក្នុងវង្វង់ក្រចកនេះ មិនមានក្នុងបិដកខ្មែរ មានតែក្នុងអដ្ឋកថា កុសជាតក ច្បាប់ឆដ្ឋសង្គាយនាប៉ុណ្ណោះ ។

ធីតាទាំងឡាយរបស់ព្រះបិតា រាប់ទាំងថ្ងៃនេះ កន្លងទៅបាន ៧ ខែហើយ ។ ព្រះរាជាទ្រង់មិនជឿព្រះនាងបភាវតី ទើបត្រាស់សួរស្រីគម ស្រីគមក៏ក្រាបទូលការពិតគ្រប់ប្រការ ព្រះរាជាបានស្តាប់ពាក្យនោះហើយ កាលទ្រង់តិះដៀលព្រះរាជធីតា ទើបត្រាស់គាថានេះថា

**តស្ស តេ ទុក្កដំ ពាលេ យំ ខត្តិយំ មហព្វលំ**
**ជាតំ មណ្ឌូកវណ្ណេន ន នំ អក្ខាសិ អាគតំ ។**

ម្នាលស្រីពាល ហាងឯងធ្វើខុសដល់ក្សត្រិយ៍ ដែលមានកម្លាំងច្រើន ដូចជាដំរី ដោយភេទនៃកង្កែប នាងមិនបានប្រាប់ក្សត្រិយ៍នោះ ដែលយាងមកហើយ ។

ព្រះរាជា កាលទ្រង់តិះដៀលព្រះរាជធីតាហើយ ក៏រួតរះទៅកាន់សម្នាក់ព្រះពោធិសត្វ ទ្រង់មានបដិសណ្ឋារៈដែលព្រះពោធិសត្វធ្វើហើយ ទើបទ្រង់ផ្គងអញ្ជលី កាលសម្តែងទោសរបស់ព្រះអង្គ ទើបត្រាស់ព្រះគាថាថា

**អបរាធំ មហារាជ ត្វំ នោ ខម រថេសភ**
**យំ ត្វំ អញ្ញាតវេសេន នញ្ញាសិម្ហា ឥធាគតំ ។**

បពិត្រមហារាជ ជាបុគ្គលប្រសើរលើរថ សូមព្រះអង្គទ្រង់អត់កំហុសដល់យើង ព្រោះយើងមិនបានដឹងថា ទ្រង់យាងមកក្នុងទីនេះ ដោយក្លែងភេទសោះ ។

ព្រះមហាសត្វបានស្តាប់ពាក្យនោះហើយ ទ្រង់ព្រះតម្រិះថា បើអញនឹងពោលពាក្យទ្រគោះបោះបោក បេះដូងរបស់ព្រះរាជា ក៏នឹងបែកក្នុងទីនេះ អញគួរលួងលោមព្រះរាជា ទ្រង់ប្រថាប់ឈរក្នុងរវាងភាជនៈនោះឯង ត្រាស់គាថាក្រៅអំពីនេះថា

**មាធិសស្សុ ឯ តំ ឆន្ទំ យោហំ អាឡារិកោ ភវេ**
**ត្វញ្ញេវ មេ បសីទស្សុ ឯត្ថិ តេ នេវ ទុក្ខដំ ។**

បពិត្រព្រះសម្មតិទេព ដំណើរដែលទូលព្រះបង្គំជាខ្ញុំ ធ្វើជានាយពិសេសនោះ មិនកំបាំងដល់ជនដូចទូលព្រះបង្គំជាខ្ញុំទេ សូមព្រះអង្គជ្រះថ្លានឹងទូលព្រះបង្គំជាខ្ញុំចុះ អំពើខ្ជីខ្ជារបស់ព្រះអង្គ មិនមានទេ ។

ព្រះរាជា ទ្រង់បានទទួលបដិសណ្ឋារៈក្នុងសម្នាក់ព្រះពោធិសត្វហើយ ទ្រង់ឡើងកាន់ប្រាសាទ ត្រាស់ហៅព្រះនាងបភាវតីចូលគាល់កាលទ្រង់បញ្ជូនទៅដើម្បីឲ្យព្រះពោធិសត្វអត់ទោស ទើបត្រាស់គាថានេះថា

**គច្ឆ ពាលេ ខមាបេហិ កុសរាជំ មហព្វលំ**
**ខមាបិតោ កុសរាជា សោ តេ ទស្សតិ ជីវិតំ ។**

ម្នាលស្រីពាល នាងឯង ចូរទៅសូមខមាទោសនឹងព្រះបាទកុសៈ ដែលមានកម្លាំងច្រើន ព្រះបាទកុសៈនោះ កាលបើ

នាងសូមខមាទោសហើយ នឹងប្រទានជីវិតដល់នាង ។

ព្រះនាងបភាវតី បានស្តាប់ព្រះតម្រាស់របស់ព្រះរាជបិតាហើយ មានព្រះភគិនី និងពួកបរិចារិកាជាច្រើនចោមរោម យាងទៅកាន់សម្នាក់ព្រះពោធិសត្វនោះ ។ ចំណែកព្រះពោធិសត្វប្រថាប់ឈរដោយភេទជាអ្នកលាងចាននោះឯង កាលទ្រង់ជ្រាបថា ព្រះនាងបភាវតីយាងមកកាន់សម្នាក់ព្រះអង្គ ទ្រង់ព្រះតម្រិះថា ថ្ងៃនេះ អញនឹងទម្លាយមានះរបស់នាងបភាវតី ឲ្យនាងក្រាបក្នុងភក់ទៀបជើងរបស់អញ ដូច្នេះហើយ ទ្រង់ជះទឹកដែលដងមកទាំងអស់ ជាន់ឲ្យបែកក្នុងទីប្រមាណប៉ុនលានស្រូវធ្វើឲ្យទៅជាភក់ទាំងអស់ ។ ឯព្រះនាងបភាវតីយាងទៅកាន់សម្នាក់ព្រះបាទកុសៈ ក្រាបចុះលើភក់ទៀបព្រះបាទា ហើយសូមខមាទោស ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

**បិតុស្ស វចនំ សុត្វា ទេវវណ្ណី បភាវតី**
**សិរសា អគ្គហី ចាទេ កុសរាជំ មហព្វលំ ។**

នាងបភាវតីមានវណ្ណៈ ដូចជាវណ្ណៈនៃទេវតា ឮព្រះឱង្ការ
របស់ព្រះបិតា ( ក៏ក្រាប ) ដោយសីសៈ អាចចាប់ព្រះបាទ
កុសៈដ៏មានកម្លាំងច្រើន ត្រង់ព្រះបាទាបាន ។

កាលព្រះនាងចាប់ព្រះបាទាហើយ ដើម្បីញ៉ាំងព្រះពោធិសត្វឲ្យអត់ទោស ទើបពោលគាថា ៣ ថា

**យាវ រត្យា អតិក្កន្តា    តា មា ទេវ តយា វិនា**
**វន្ទេ តេ សិរសា បាទេ    មា មេ កុជ្ឈ រថេសភ ។**

*បពិត្រព្រះសម្មតិទេព រាត្រីទាំងនោះ វៀរចាកព្រះអង្គកន្លងទៅ បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ ខ្ញុំម្ចាស់សូម ( ក្រាប ) ដោយក្បាល ថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះអង្គ សូមព្រះអង្គកុំខ្ញាល់នឹងខ្ញុំម្ចាស់ ។*

**សច្ចន្តេ បដិជានាមិ    មហារាជ សុណោហិ មេ**
**ន ចាបិ អប្បិយំ តុយ្ហំ    ករេយ្យាមិ អហំ បុន ។**

*បពិត្រមហារាជ ខ្ញុំម្ចាស់សូមប្ដេជ្ញាពាក្យពិត ចំពោះព្រះអង្គ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ពាក្យរបស់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់លែងធ្វើនូវការមិនស្រឡាញ់ ព្រះអង្គទៀតហើយ ។*

**ឯវញ្ចេ យាចមានាយ    វចនំ មេ ន កាហសិ**
**ឥទានិ មំ តាតោ ហន្ត្វា    ខត្តិយានំ បទស្សតិ ។**

*កាលបើខ្ញុំម្ចាស់អង្វរករយ៉ាងនេះហើយ បើព្រះអង្គនឹងមិនធ្វើតាមពាក្យខ្ញុំម្ចាស់ទេ ព្រះរាជបិតាមុខជានឹងសម្លាប់ខ្ញុំម្ចាស់ ឥឡូវនេះ ហើយប្រទានដល់ពួកក្សត្រិយ៍មិនខាន ។*

*ព្រះរាជាបានស្តាប់ពាក្យនោះហើយ ទ្រង់ព្រះតម្រិះថា បើអញនឹងពោលថា នាងតែម្នាក់ប៉ុណ្ណោះ នឹងដឹងរឿងនេះ ដូច្នេះ ហឫទ័យរបស់*

*នាងក៏នឹងបែក អញនឹងលួងលោមនាង ដូច្នេះហើយ ទើបត្រាស់គាថាថា*

ឯវង្កេ យាចមានាយ កឹំ ន កាហាមិ តេ វចោ
វិកុទ្ធោ ត្យស្មិ កល្យាណិ មា ត្វំ ភាយិ បភាវតិ ។

*កាលបើនាងអង្វរករយ៉ាងនេះហើយ យើងនឹងមិនធ្វើតាមពាក្យរបស់នាងឯណាបាន នៃនាងបភាវតី ស្រីកល្យាណី បងលែងខឹងនឹងនាងហើយ នាងកុំភ័យឡើយ ។*

សច្ចង្កេ បដិជានាមិ រាជបុត្តី សុណោហិ មេ
ន ចាបិ អប្បិយំ តុយ្ហំ ករេយ្យាមិ អហំ បុន ។

*នៃរាជបុត្រី យើងសូមប្ដេជ្ញាពាក្យពិតចំពោះនាង នាងចូរស្ដាប់ពាក្យរបស់យើង យើងលែងធ្វើនូវសេចក្ដីមិនជាទីស្រឡាញ់នាងទៀត ។*

តវ កាមា ហិ សុស្សោណិ ពហុទុក្ខំ តិតិក្ខិសំ
ពហុមទ្ទកុលំ ហន្ត្វា នយិតុំ តំ បភាវតី ។

*នៃនាងបភាវតី ជាស្រីមានចង្កេះរៀវ យើងអត់ទ្រាំសេចក្ដីទុក្ខច្រើនដង ព្រោះតែចង់បាននាង យើងហ៊ានសម្លាប់ត្រកូលរបស់ព្រះបាទមទ្ទៈជាច្រើន ហើយនាំយកនាងទៅបាន ។*

*លំដាប់នោះ ព្រះពោធិសត្វទ្រង់ទតឃើញព្រះនាងបភាវតី អគ្គមហេសីរបស់ព្រះអង្គ ហាក់ដូចជាទេវកញ្ញា ជាបរិចារិការបស់សក្កទេវរាជ*

ក៏ទ្រង់ញ៉ាំងខត្តិយមានះឲ្យកើតឡើង ទ្រង់ព្រះតម្រិះថា កាលអញនៅមានជីវិត ព្រះរាជាដទៃមកដណ្ដើមយកអគ្គមហេសីរបស់អញ ទៅបានឬដូច្នេះហើយ ទើបទ្រង់មឹតពត់ព្រះកាយដូចរាជសីហ៍ដោយមានះ ត្រង់លានព្រះរាជវាំង ទះព្រះហស្ត ហើយបន្លឺនូវសំឡេងខ្លាំង ៗ ថា អ្នកនគរទាំងមូល ចូរដឹងនូវភាពដែលយើងមកហើយ ឥឡូវនេះ យើងនឹងចាប់ស្ដេច ( ទាំង ៧ នគរ ) នោះ ឲ្យបានទាំងរស់ អ្នកទាំងឡាយ ចូររៀបចំរថជាដើម មកឲ្យយើង ហើយត្រាស់គាថាជាលំដាប់តទៅថា

**យោជយន្តុ រថេ អស្សេ ជានាចិត្តេ សមាហិតេ**
**អថ ទក្ខថ មេ វេគំ វិធមេន្តស្ស សត្តវោ ។**

ពួកជនទាំងឡាយ ចូរទឹមសេះដ៏រំលេចដោយគ្រឿងប្រដាប់ផ្សេង ៗ ជាសត្វរៀបរយក្នុងរថ កាលបើទឹមហើយ អ្នកទាំងឡាយមុខជានឹងឃើញកម្លាំងរបស់ខ្ញុំ ដែលកម្ចាត់ពួកខ្មាំងបាន ។

ព្រះពោធិសត្វត្រាស់នឹងព្រះបាទមទ្ទរាជ ឲ្យស្ដេចយាងទៅវិញដោយព្រះតម្រាស់ថា ឈ្មោះថា ការចាប់ព្រះរាជាទាំងឡាយ ជាសត្រូវជាភារៈរបស់ខ្ញុំ សូមទ្រង់យាងទៅស្រពស្រង់ តាក់តែងព្រះកាយ ហើយឡើងកាន់ប្រាសាទចុះ ។ ព្រះបាទមទ្ទរាជក៏បានបញ្ជូនពួកអាមាត្យទៅដើម្បីធ្វើការបម្រើព្រះពោធិសត្វនោះ ។ ពួកអាមាត្យទាំងនោះ នាំគ្នា

ចាត់ចែងយកសំពត់បាំងត្រង់ទ្វារពេងបាយនោះហើយ ឲ្យខ្មាន់ព្រះកេស ចូលទៅកោរព្រះមស្សុថ្វាយព្រះពោធិសត្វ ។ ព្រះពោធិសត្វទ្រង់ឲ្យជាង ធ្វើការដាក់ព្រះមស្សុហើយ ទ្រង់ស្រង់ទឹក កក់ព្រះសិរសាស្រេចហើយ ប្រដាប់គ្រឿងអលង្ការទាំងពួង មានអាមាត្យទាំងឡាយចោមរោមជាបរិវារ យាងឡើងកាន់ប្រាសាទ ទ្រង់សម្លឹងមើលដោយជុំវិញ គ្រប់ទិសានុទិស ហើយទ្រង់ទះព្រះហស្ត ទីដែលព្រះពោធិសត្វទ្រង់សម្លឹងមើលហើយ ៗ ក៏ញាប់ញ័រ ។ ព្រះពោធិសត្វត្រាស់ថា ឥឡូវនេះ អ្នកទាំងឡាយនឹង ឃើញសេចក្តីព្យាយាមរបស់ខ្ញុំ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

**តញ្ច តត្ថ ឧទិក្ខិំសុ រញ្ញោ មទ្ទស្សន្តេបុរេ**
**វិជម្ភមាន សីហំវ ចោរេឥន្តំ ជីតុណំ កុដំ ។**

ពួកស្រីក្នុងព្រះរាជវាំងរបស់ព្រះបាទមទ្ទៈ ( នាំគ្នាបើកបង្អួច ) អើតមើលព្រះបាទកុសៈនោះ ដែលកំពុងមឹតពត់ កំពុងទង្គិច ដើមដៃទាំងពីរខាង ដូចជាសីហៈក្នុងទីនោះ ។

ពាក្យដែលជាគាថានោះ មានសេចក្តីអធិប្បាយថា ពួកស្ត្រីនាំគ្នា បើកបង្អួចខាងក្នុងបុរីរបស់ព្រះរាជា ហើយសម្លឹងមើលព្រះពោធិសត្វនោះ ដែលទ្រង់មឹតពត់និងទះព្រះហស្តក្នុងទីនោះ ៗ ។

លំដាប់នោះ ព្រះបាទមទ្ទរាជទ្រង់បញ្ជូនដំរីដ៏ប្រសើរ ដែលប្រដាប់

*ហើយ ជាដំរីដែលទូន្មានមិនឲ្យញាប់ញ័រ ថ្វាយព្រះពោធិសត្វ ។ ព្រះពោធិសត្វឡើងប្រថាប់លើកដំរី ដែលមានស្វេតច្ឆត្រលើកឡើងហើយ ត្រាស់ថា ចូរនាំព្រះនាងបភាវតីមក ទ្រង់ឲ្យព្រះនាងប្រថាប់គង់អំពីខាងក្រោយ ដែលចតុរង្គិនីសេនាចោមរោមជាក្បួនទ័ព ចេញតាមទ្វារទិសខាងកើត ទតឃើញកងទ័ពពួកសត្រូវ ទើបបន្លឺសីហនាទបីដងថា* **អហំ កុសរាជា ជីវិតត្ថិកា ឧបេរេ និបជ្ជន្តុ** *យើងគឺព្រះបាទកុសរាជ អ្នកណាត្រូវការជីវិត ចូរក្រាបចុះ ដូច្នេះហើយ ទ្រង់បានធ្វើការបង្ក្រាបក្សត្រទាំង ៧ នគរនោះ ។ ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថានេះថា*

**ហត្ថិក្ខន្ធញ្ច អារុយ្ហ អារោបេត្វា បភាវតឹ**
**សង្គាមំ ឱតរិត្វាន សីហនាទំ នទិ កុសោ ។**

*ព្រះបាទកុសៈ លើកព្រះនាងបភាវតីឡើងកាន់កដំរី លុកលុយចូលទៅក្នុងសង្គ្រាម ហើយក៏បន្លឺនូវសីហនាទ ។*

**តស្ស តំ នទតោ សុត្វា សីហស្សេវិតរេ មិគា**
**ខត្តិយា វិបលាយឹសុ កុសសទ្ទភយដ្ដិតា ។**

*ពួកក្សត្រិយ៍ ឮព្រះបាទកុសៈនោះ បន្លឺសីហនាទនោះ ត្រូវភ័យអំពីសំឡេងគំរាម នៃព្រះបាទកុសៈបៀតបៀនហើយ ក៏នាំគ្នារត់បែកខ្ញែក ដូចជាពួកម្រឹគដទៃ ( ដែលភ័យនឹង*

*សម្រែក ) នៃសីហៈ ។*

ហត្ថារោហា អនីកដ្ឋា  រថិកា បត្តិការកា
អញ្ញមញ្ញស្ស ធិឝ្ឋន្តិ  កុសសទ្ទភយដ្ដិតា ។

*ពួកទាហានដំរី ទាហានសេះ ទាហានរថ ទាហានថ្មើរជើង ត្រូវភ័យអំពីសំឡេងនៃព្រះបាទកុសៈបៀតបៀនហើយ ក៏រត់ជាន់គ្នាទៅវិញទៅមក ។*

តស្មិំ សង្គាមសីសស្មិំ  បស្សិត្វា ហដ្ឋមានសោ
កុសស្ស រញ្ញោ ទេវិន្ទោ  អទា វេរោចនំ មណឹ ។

*ទេវរាជជាធំជាងទេវតាបានឃើញហើយ ក៏មានព្រះហឫទ័យរីករាយ បានប្រទានកែវមណីឈ្មោះវេរោចនៈ ដល់ព្រះបាទកុសៈក្នុងប្រធាននៃសង្គ្រាមនោះ ។*

សោ តំ វិជិត្វា សង្គាមំ  លទ្ធា វេរោចនំ មណឹ
ហត្ថិក្ខន្ធគតោ រាជា  ចាវេក្ខិ នគរំ បុរំ ។

*ព្រះរាជានោះ លុះឈ្នះសង្គ្រាមនោះ បានកែវមណីឈ្មោះវេរោចនៈ ហើយគង់លើកដំរី ក៏យាងចូលទៅកាន់បុរី ។*

ជីវគ្គាហំ គហេត្វាន  ពន្ធិត្វា សត្ត ខត្តិយេ
សសុរស្សុបនាមេសិ  ឥមេ តេ ទេវ សត្តវោ ។

*ព្រះបាទកុសៈ បានចាប់យកក្សត្រិយ៍ទាំង ៧ អង្គ ទាំងរស់*

*ចង់នាំមកថ្វាយដល់ព្រះបិតាក្មេកថា បពិត្រព្រះសម្មតិទេព ក្សត្រិយ៍ទាំង ៧ នេះហើយ ជាសត្រូវរបស់ព្រះអង្គ ។*

**សព្វេ តេ វសំ គតា អមិត្តា វិហិតា តវ**
**កាមំ ករោហិ តេ តយា មុញ្ច វា តេ ហនស្សុ វា ។**

*ពួកក្សត្រិយ៍ជាសត្រូវទាំងអស់ ជាអ្នកបៀតបៀនព្រះអង្គ លុះក្នុងអំណាចរបស់ព្រះអង្គហើយ សូមព្រះអង្គធ្វើតាមបំណងរបស់ព្រះអង្គចុះ ទោះព្រះអង្គលែងក្សត្រិយ៍ទាំងនោះ ឬសម្លាប់នូវក្សត្រិយ៍ទាំងនោះចុះ ។*

*ព្រះបាទមទ្ទរាជទ្រង់ត្រាស់ថា*

**តុយ្ហេវ សត្តវោ ឯតេ ន ហិ តេ មយ្ហ សត្តវោ**
**ត្វញ្ញេវ នោ មហារាជ មុញ្ច វា តេ ហនស្សុ វា ។**

*បពិត្រមហារាជ ព្រះរាជាទាំងនុ៎ះ ជាសត្រូវរបស់ព្រះអង្គ ព្រះរាជាទាំងនោះ មិនមែនជាសត្រូវរបស់ខ្ញុំទេ ព្រះអង្គ ( ជាឥស្សរៈ ) របស់ពួកយើងស្រាប់ហើយ ទោះលែងក្សត្រិយ៍ទាំងនោះ ឬសម្លាប់នូវក្សត្រិយ៍ទាំងនោះចុះ ។*

*កាលព្រះបាទមទ្ទរាជត្រាស់យ៉ាងនេះហើយ ព្រះមហាសត្វទ្រង់ព្រះតម្រិះថា ប្រយោជន៍អ្វីដោយការសម្លាប់ស្តេចទាំងនេះ ការមករបស់ស្តេចទាំង ៧ នគរនោះ កុំទទេចាកប្រយោជន៍ឡើយ ព្រះរាជធីតារបស់*

ព្រះបាទមទ្ទរាជ ដែលជាកនិដ្ឋកគិនីរបស់ព្រះនាងបភាវតី ក៏មាន ៧ អង្គ អញនឹងលើកព្រះរាជធីតាទាំងនោះ ឲ្យទៅស្តេចទាំង ៧ នគរនោះ ដូច្នេះ ហើយ ត្រាស់ព្រះគាថាថា

**ឥមា តេ ធីតរោ សត្ត ទេវកញ្ញូបមា សុភា**
**ទទាហិ ទេសំ ឯកេកំ ហោន្តុ ជាមាតរោ តវ ។**

ធីតាទាំងឡាយរបស់ព្រះអង្គ ទាំង ៧ នេះ ល្អមានឧបមា ដោយទេវកញ្ញា សូមព្រះអង្គប្រទានធីតាមួយអង្គ ៗ ដល់ ព្រះរាជាទាំងនោះ ព្រះរាជាទាំងនោះ ចូរជាកូនប្រសាររបស់ ព្រះអង្គចុះ ។

លំដាប់នោះ ព្រះបាទមទ្ទរាជទ្រង់ត្រាស់ថា

**អម្ហាកញ្ចេវ តាសញ្ច ត្វំ ទោ សព្វេសមិស្សរោ**
**ត្វញ្ញេវ ទោ មហារាជ ទេហិ ទេសំ យទិច្ឆសិ ។**

បពិត្រមហារាជ ព្រះអង្គជាឥស្សរៈរបស់ពួកយើងទាំងអស់គ្នា គឺ ( ព្រះរាជាទាំង ៧ នេះផង ) ខ្ញុំផង ធីតាទាំងនោះផង ព្រះអង្គប្រាថ្នានឹង ( ប្រទាន ) ធីតាណា ( ដល់ព្រះរាជា ណា ) សូមប្រទាន ( ធីតានោះ ) ដល់ព្រះរាជានោះចុះ ។

កាលព្រះបាទមទ្ទរាជត្រាស់យ៉ាងនេះហើយ ព្រះមហាសត្វក៏ឲ្យ តាក់តែងព្រះរាជធីតារបស់ព្រះបាទមទ្ទរាជទាំង ៧ អង្គនោះ ហើយ

ព្រះរាជទានដល់ព្រះរាជាទាំង ៧ អង្គនោះ ។ ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ ៩ គាថាថា

ឯកមេកស្ស ឯកេកំ អទា សីហស្សរោ កុសោ
ខត្តិយានំ តទា តេសំ រញ្ញោ មទ្ទស្ស ធីតរោ ។

ព្រះបាទកុសៈ មានព្រះវាចាសព្ទស្មើនឹងសំឡេងសីហៈ បានប្រទានពួកធីតារបស់ព្រះបាទមទ្ទៈ មួយអង្គ ៗ ដល់ក្សត្រិយ៍ទាំងនោះ មួយអង្គ ៗ ។

បីណិតា តេន លាភេន តុដ្ឋា សីហស្សរេ កុសេ
សករដ្ឋានិ បាយឹសុ ខត្តិយា សត្ត តាវទេ ។

ពួកក្សត្រិយ៍ទាំង ៧ អង្គ មានព្រះហឫទ័យស្កប់ស្កល់ដោយលាភនោះហើយ ក៏ត្រេកអរចំពោះព្រះបាទកុសៈ ដែលមានព្រះសូរវាចាស្មើនឹងសំឡេងសីហៈ បានទៅកាន់ដែនទាំងឡាយរៀងខ្លួន ក្នុងលំដាប់នោះឯង ។

បភាវតិញ្ច អាទាយ មណឹ វេរោចនំ សុភំ
កុសាវតឹ កុសោ រាជា អគមាសិ មហព្វលោ ។

ចំណែកឯព្រះបាទកុសៈ មានកម្លាំងច្រើន បាននាំយកនាងបភាវតី និងកែវមណីឈ្មោះវេរោចនៈដ៏ល្អ ហើយទ្រង់ស្តេចវិលត្រឡប់ទៅកាន់ក្រុងកុសាវតីវិញ ។

**ត្យស្សុ ឯកសរថេ យន្តា   បវិសន្តា កុសាវតឹ**
**សមានា វណ្ណរូបេន   នាញ្ញមញ្ញាតិរោចិសុំ ។**

*ក្សត្រិយ៍ទាំងនោះ គង់លើរថជាមួយគ្នា បរសំដៅចូលទៅកាន់ក្រុងកុសាវតី ស្មើគ្នាដោយវណ្ណៈនិងរូប មិនរុងរឿងជាងគ្នាប៉ុន្មានទេ ។*

**មាតា បុត្តេន សង្គញ្ឆិ   ឧភយោ ច ជយម្បតី**
**សមគ្គា តេ តទា អាសុំ   ផីតំ ធរណិមាវសុំ ។**

*ព្រះមាតាបានចួបជុំដោយបុត្ត ចំណែកអគ្គមហេសី និងព្រះរាជស្វាមីទាំងពីរព្រះអង្គនោះ បានព្រមព្រៀងគ្នា នៅគ្រប់គ្រងរាជធរណីដ៏សម្បូណ៌សប្បាយ ក្នុងកាលនោះ ។*

*បានឮថា ព្រះមហាសត្វមានរូបស្អាត មានពណ៌សម្បុរដូចមាស គឺដល់នូវភាពជាបុគ្គលប្រសើរដោយលម្អ ព្រោះអានុភាពរបស់កែវមណី បានឮថា ព្រះពោធិសត្វបានជាអ្នកមានតេជះយ៉ាងនេះ ព្រោះផលនៃចង្ហាន់បិណ្ឌបាត ដែលបានថ្វាយដល់ព្រះបច្ចេកពុទ្ធ ក្នុងកាលមុនផង ព្រោះផលនៃការកសាងព្រះពុទ្ធបដិមាផង ។*

*លំដាប់នោះ ព្រះមាតារបស់ព្រះមហាសត្វ ព្រះនាងព្រះសណ្ដាប់ថា ព្រះមហាសត្វយាងមកហើយ ទើបឲ្យវាយស្គរប្រកាសពេញព្រះនគរ កាន់យកគ្រឿងបណ្ណាការជាច្រើនចេញទៅទទួល ហើយត្រឡប់មកជាមួយ*

គ្នា ។ ព្រះបាទកុសរាជនោះ ទ្រង់ធ្វើប្រទក្សិណនគរ មួយអន្លើដោយ ព្រះជននី ក្រសាលមហោស្រព ៧ ថ្ងៃហើយ ទ្រង់ឡើងកាន់ប្រាសាទ ដែលប្រដាប់តាក់តែងហើយ ។ ក្សត្រទាំងពីរអង្គ គឺព្រះភស្តានិងព្រះ ជាយានោះ មានការសាមគ្គីគ្នា តាំងអំពីនោះមក ទ្រង់គ្រប់គ្រងផែនដី ឲ្យរុងរឿង ដរាបអស់ព្រះជន្មទាំងពីរព្រះអង្គ ដោយប្រការដូច្នេះ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ហើយទ្រង់ប្រជុំជាតក ។ កាលចប់ សច្ចៈ ភិក្ខុដែលអផ្សុកនោះ តាំងនៅក្នុងសោតាបត្តិផល ។ ព្រះជនក និងព្រះជននីរបស់ព្រះបាទកុសរាជ ក្នុងកាលនោះ បានមកជាត្រកូល មហារាជក្នុងកាលឥឡូវនេះ ជយម្បតិរាជកុមារ ដែលជាព្រះអនុជរបស់ ព្រះបាទកុសរាជ បានមកជាអានន្ទ ស្រីគមបានមកជានាងខុជ្ជុត្តរា ព្រះ នាងបភាវតី បានមកជារាហុលមាតា បរិស័ទ បានមកជាពុទ្ធបរិស័ទ ចំណែកព្រះបាទកុសរាជ គឺតថាគតអរហន្តសម្មាសម្ពុទ្ធនេះឯង ។

## កុសជាតក ចប់ [១]

---

១-ស្រង់ចាកអដ្ឋកថា ជាតក សត្តតិនិបាត បិ.៦១ ទំ.៦៤ ឃ.៩៤ ។

# ព្រះនាងឧប្បលវណ្ណាថេរី

បានឮថា កុលធីតារូបនេះ ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមថា បទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល[១] ក្នុងនគរហង្សវតី ដល់នូវភាពជាអ្នកដឹងក្តីហើយ ចូលគាល់ព្រះសាស្តាជាមួយនឹងមហាជន ស្តាប់ធម៌ ឃើញព្រះសាស្តាស្តាបនាភិក្ខុនីមួយរូប ក្នុងតំណែងឯតទគ្គៈ ប្រសើរជាង ភិក្ខុនីទាំងឡាយខាងមានឫទ្ធិ បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ប្រាថ្នាតំណែងនោះ ។ នាងធ្វើកុសលដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ។ ក្នុងកាលសាសនាព្រះកស្សបសម្ពុទ្ធ នាងក៏បដិសន្ធិក្នុងព្រះរាជវាំងរបស់ព្រះបាទកាសីព្រះនាមកិកី ក្នុងនគរពារាណសី ជាព្រះរាជធីតាមួយអង្គក្នុងចំណោមព្រះរាជធីតាទាំង ៧ អង្គ ព្រះនាងប្រព្រឹត្តព្រហ្មចរិយៈអស់ពីរម៉ឺនឆ្នាំ សាងបរិវេណថ្វាយភិក្ខុសង្ឃ ហើយកើតក្នុងទេវលោក ។

កាលចុតិអំពីទេវលោកនោះហើយ ត្រឡប់មកកាន់មនុស្សលោកវិញ កើតក្នុងផ្ទះរបស់អ្នកធ្វើការងារដោយដៃចិញ្ចឹមជីវិត ក្នុងតំបន់មួយ ។ ថ្ងៃមួយ កំពុងដើរទៅកាន់ខ្ទមស្រែ ក្នុងចន្លោះផ្លូវ ឃើញផ្កាឈូករីកអំពី

---

១-ពាក្យថា ផ្ទះមានត្រកូល គឺត្រកូលនោះ មិនមែនជាត្រកូលខ្ញុំគេ មិនមែនជាត្រកូលអន់ គឺជាត្រកូលអ្នកជា ត្រកូលអ្នកមាន ។

ព្រលឹមក្នុងស្រះមួយ ក៏ចុះកាន់ស្រះនោះ បេះផ្កាឈូក និងស្លឹកឈូក សម្រាប់ដាក់លាជ ក្តិចស្រូវសាលី[១] អំពីស្រែមក អង្គុយក្នុងខ្ទម លីង ស្រូវធ្វើជាលាជ រើសលាជ ៥០០ គ្រាប់ទុក ។ ក្នុងខណៈនោះ នៅឯភ្នំ គន្ធមាទន៍ **ព្រះបច្ចេកពុទ្ធ** មួយអង្គ ចេញអំពីនិរោធសមាបត្តិ មកឈរ ក្នុងទីមិនឆ្ងាយ នាងឃើញព្រះបច្ចេកពុទ្ធហើយ កាន់យកផ្កាឈូកមួយអន្ទើ ដោយលាជ ចេញអំពីខ្ទម ដាក់លាជក្នុងបាត្ររបស់ព្រះបច្ចេកពុទ្ធ យក ផ្កាឈូកបិទបាត្រ ហើយប្រគេន ។ លំដាប់នោះ កាលព្រះបច្ចេកពុទ្ធ និមន្តទៅបានបន្តិច នាងក៏គិតថា ធម្មតាអ្នកបួសមិនត្រូវការផ្កា អញនឹង ទៅកាន់យកផ្កាមកប្រដាប់ខ្លួនឯង ទើបទៅកាន់យកផ្កាអំពីដៃរបស់ព្រះ បច្ចេកពុទ្ធ នាងក៏គិតទៀតថា បើលោកម្ចាស់មិនត្រូវការផ្កា គង់មិនឲ្យ ដាក់លើបាត្រ លោកម្ចាស់គង់នឹងត្រូវការពិត ទើបយកផ្កានោះ ទៅដាក់ លើបាត្រម្តងទៀត សូមខមាទោសព្រះបច្ចេកពុទ្ធហើយ ធ្វើសេចក្តីប្រាថ្នា ថា បពិត្រលោកម្ចាស់ដ៏ចម្រើន ដោយផលនៃការថ្វាយលាជរបស់ខ្ញុំនេះ សូមបុត្តរបស់ខ្ញុំមានចំនួនស្មើនឹងគ្រាប់លាជ ដោយផលនៃការថ្វាយផ្កា ឈូក សូមផ្កាឈូកផុសឡើងគ្រប់ ៗ ជំហានក្នុងទីដែលខ្ញុំកើតហើយ ៗ ។ ព្រះបច្ចេកពុទ្ធហោះទៅកាន់ភ្នំគន្ធមាទន៍ ទាំងដែលនាងកំពុងឃើញនោះ

---

១-ស្រូវសាលី ជាស្រូវមានគ្រាប់ខ្ញី ៗ តែធំជាងស្រូវធម្មតាបន្តិច ជាស្រូវមិន មានសម្បកស្រោបពីក្រៅទេ ។

ឯង ដាក់ផ្កាឈូកជាគ្រឿងជូតជើង ក្បែរជណ្តើររបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ក្នុងញកភ្នំនន្ទមូលកៈ ។

ដោយផលនៃកម្មនោះ នាងបដិសន្ធិក្នុងទេវលោក តាំងអំពីនាងកើត ផ្កាឈូកធំផុសឡើងគ្រប់ជំហានរបស់នាង នាងចុតិអំពីទេវលោកនោះហើយ កើតក្នុងផ្កាឈូក ក្នុងស្រះឈូកមួយកន្ទែង ក្បែរជើងភ្នំ ។ តាបសមួយរូបនៅអាស្រ័យក្បែរជើងភ្នំនោះ បានទៅកាន់ស្រះអំពីព្រលឹម ដើម្បីលុបមុខ ឃើញផ្កាឈូកនោះ ក៏គិតថា ផ្កាឈូកនេះ ធំជាងផ្កាឈូកដទៃ ផ្កាឈូកដទៃ ៗ រីកហើយ ផ្កាឈូកនេះនៅតែក្រពុំដដែល ប្រហែលជាមានហេតុនៅក្នុងផ្កាឈូកនេះ ទើបចុះទឹក ហើយចាប់ផ្កាឈូកនោះ ផ្កាឈូកនោះ គ្រាន់តែតាបសចាប់ប៉ុណ្ណោះ ក៏រីក តាបសឃើញទារិកាដេកក្នុងផ្កាឈូក គ្រាន់តែបានឃើញ ក៏កើតសេចក្តីស្រឡាញ់ដូចកូនស្រី នាំទៅកាន់បណ្ណសាលា មួយអន្លើដោយផ្កាឈូក ដាក់ឲ្យដេកលើគ្រែ ។ លំដាប់នោះ ទឹកដោះ ក៏កើតត្រង់ម្រាមមេដៃ (ទារិកា) ដោយអានុភាពរបស់នាង ។ កាលផ្កាឈូកនោះស្វិត តាបសក៏យកផ្កាឈូកដទៃមកដាក់ឲ្យទារិកានោះដេក ។ តាំងអំពីនាងចេះរត់ទៅមកបាន ផ្កាឈូកក៏ផុសឡើងគ្រប់ ៗ ជំហាន សម្បុរនៃសរីរៈរបស់នាងដូចផ្កាឈូក មិនដល់ពណ៌សម្បុររបស់ទេវតា តែក្រៃលែងជាងសម្បុររបស់មនុស្ស ។ កាលឥសីជាបិតាទៅរកផ្លៃឈើតូចធំ ក៏ទុកនាងឲ្យនៅក្នុងបណ្ណសាលា ។

នាងចម្រើនវ័យហើយ សម័យថ្ងៃមួយ កាលបិតាទៅស្វែងរកផ្លែឈើ ព្រានព្រៃម្នាក់ឃើញនាងហើយ គិតថា ឈ្មោះថា មនុស្សទាំងឡាយ មានរូបយ៉ាងនេះ មិនមានឡើយ អញនឹងសង្កេតពិនិត្យ ទើបអង្គុយរង់ចាំមើលតាបសត្រឡប់មក ។ កាលតាបសជាបិតាត្រឡប់មក នាងក៏ដើរប្រាសផ្លូវទៅទទួលអម្រែក និងបំពង់ទឹកអំពីដៃបិតា កាលបិតាអង្គុយហើយ ក៏សម្ដែងទំនៀម គឺកិច្ចដែលខ្លួនធ្លាប់ធ្វើ ។ ក្នុងកាលនោះ បុរសនោះដឹងភាពនៃទារិកាជាមនុស្សហើយ ទើបចូលមកអង្គុយថ្វាយបង្គំតាបស ។ តាបសអញ្ជើញព្រាននោះ ដោយមើមឈើនិងផ្លែឈើ មួយអន្ទើដោយទឹកផឹក ហើយសួរថា នៃបុរសដ៏ចម្រើន អ្នកស្នាក់នៅទីនេះ ឬត្រឡប់ទៅ ។ ព្រាននោះឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំនឹងទៅ ខ្ញុំនឹងធ្វើអ្វីក្នុងទីនេះ ។

តាបសពោលថា ហេតុការណ៍ដែលអ្នកឃើញហើយនេះ អ្នកចេញអំពីទីនេះទៅ កុំប្រាប់គេ បានឬទេ ។ ព្រានតបថា បើលោកម្ចាស់មិនប្រាថ្នា ខ្ញុំនឹងពោលធ្វើអ្វី ។ ថ្វាយបង្គំលាតាបស ធ្វើគ្រឿងសម្គាល់ត្រង់មែកឈើនិងដើមឈើ ដោយអាការល្មមចំណាំផ្លូវបាន ហើយត្រឡប់ទៅ ។

ព្រានព្រៃនោះ ទៅកាន់ក្រុងពារាណសី ហើយចូលគាល់ព្រះរាជា ។ ព្រះរាជាត្រាស់សួរថា អ្នកមកព្រោះហេតុអ្វី ។ ព្រានព្រៃក្រាបទូលថា

បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាព្រានព្រៃរបស់ព្រះអង្គ ចួបនារីរតន៍ដ៏អស្ចារ្យក្បែរជើងភ្នំ ទើបមកគាល់ ដូច្នេះហើយ ទូលថ្វាយដំណើររឿងសព្វអន្លើ ។ ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់ព្រានព្រៃហើយ ប្រញាប់យាងទៅកាន់ជើងភ្នំ បោះព្រះពន្លាក្នុងទីមិនឆ្ងាយ មួយអន្លើដោយព្រានព្រៃនិងពួកសេនា យាងទៅកាន់បណ្ណសាលានោះ ក្នុងពេលដែលតាបសឆាន់ស្រេចហើយអង្គុយសម្រាក ទ្រង់ថ្វាយបង្គំ ធ្វើបដិសណ្ឋារៈ ហើយប្រថាប់គង់ក្នុងទីសមគួរ ។ ព្រះរាជា ទ្រង់ដាក់គ្រឿងបរិក្ខារសម្រាប់បព្វជិត ទៀបបាទារបស់តាបស ហើយត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន តើខ្ញុំព្រះករុណានឹងធ្វើអ្វីខ្លះ ក្នុងទីនេះ ហើយក៏នឹងទៅ ។

តាបសថ្វាយព្រះពរថា មហាបពិត្រ សូមទ្រង់មានព្រះបន្ទូលមកចុះ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ បានឮមកថា បរិស័ទដែលមានចំណែកមិនស្មើគ្នា មាននៅក្បែរលោកម្ចាស់ បរិស័ទនោះ មិនគួរដល់បព្វជិត បរិស័ទនោះ សូមទៅជាមួយខ្ញុំព្រះករុណាចុះ ។

តាបសពោលថា ចិត្តរបស់មនុស្សមិនអាចឲ្យត្រេកអរបានទេ តើកូនស្រីអាត្មានឹងនៅត្រង់កណ្ដាលពួកមនុស្សជាច្រើន បានដូចម្ដេច ។

ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ តាំងអំពីខ្ញុំព្រះករុណាពេញចិត្តនាង ខ្ញុំព្រះករុណានឹងតាំងនាងទុកក្នុងតំណែងខ្ពង់ខ្ពស់ជាងស្រីដទៃ ហើយទំនុកបម្រុង ។

តាបសស្តាប់ព្រះរាជតម្រាស់ហើយ ទើបហៅធីតាតាមនាមដែលតាំងទុកគ្រានៅជាទារិកាថា បទុមវតីកូន ដោយការហៅត្រឹមតែម្តងប៉ុណ្ណោះ នាងក៏ចេញអំពីបណ្ណសាលា មកថ្វាយបង្គំឪពុក ហើយឈរ ។

លំដាប់នោះ តាបសពោលថា ម្នាលកូន នាងធំពេញវ័យហើយ តាំងអំពីព្រះរាជាទ្រង់បានឃើញកូន កូនមិនគួរនៅក្នុងទីនេះទេ ចូរកូនទៅតាមព្រះរាជាចុះ ។ នាងទទួលពាក្យបិតាថា សាធុ លោកឪពុក ថ្វាយបង្គំហើយ ឈរយំ ។

ព្រះរាជាត្រាស់ថា យើងនឹងតម្រូវចិត្តបិតារបស់នាង ទ្រង់ដាក់គំនរកហាបណៈក្នុងទីនោះឯង ហើយទ្រង់ធ្វើការអភិសេក ។ លំដាប់នោះ ព្រះរាជាទ្រង់នាំនាងទៅកាន់នគររបស់ព្រះអង្គ ចាប់តាំងអំពីនាងមកដល់ ទ្រង់មិនបានសម្ញឹងមើលស្រីដទៃ ត្រេកអរជាមួយនាងប៉ុណ្ណោះ ។ ស្រីស្នំទាំងនោះ ជាអ្នកត្រូវសេចក្តីច្រណែនគ្របសង្កត់ បំណងនឹងធ្វើឲ្យនាងបែកអំពីព្រះរាជា ទើបនាំគ្នាពិតទូលយ៉ាងនេះថា បពិត្រមហារាជ ស្រីនេះ មិនមែនមនុស្សទេ ទ្រង់ធ្លាប់ទតឃើញផ្កាឈូកផុសឡើង ត្រង់ទីដែលមនុស្សដើរទៅមកក្នុងទីណាដែរឬ ស្រីនេះ ជាយក្ខិនីពិត សូមមហារាជ និរទេសនាងចោលចុះ ។ ព្រះរាជាទ្រង់ស្តាប់ពាក្យស្រីទាំងនោះហើយ ទ្រង់ក៏នៅស្ងៀម ។

ក្នុងកាលតមក ជាយដែនរបស់ព្រះរាជាកើតការបះបោរ ព្រះរាជា

ទ្រង់ព្រះតម្រិះថា បទុមវតី មានគភ៌ចាស់ខែ ទើបទ្រង់ទុកព្រះនាងក្នុងនគរ ហើយយាងទៅកាន់ជាយដែន ។ ក្នុងកាលនោះ ស្រីទាំងនោះឲ្យសំណូកដល់ទាសីដែលបម្រើនាង ហើយប្រាប់ថា បើទារករបស់នាងបទុមវតីប្រសូតមក ចូរនាងនាំយកទៅបោះចោល ហើយយកឈាមលាបកំណាត់ឈើមួយ ដាក់ក្បែរនោះ ។ មិនយូរប៉ុន្មាន ព្រះនាងបទុមវតីក៏ប្រសូត ។ ព្រះមហាបទុមមួយអង្គប៉ុណ្ណោះ បដិសន្ធិក្នុងព្រះឧទរ ។ ទារក ៤៩៩ អង្គដទៃទៀត ជាសំសេទជកំណើត ( កើតអំពីញើស ) កើតហើយ ក្នុងកាលដែលព្រះមហាបទុមប្រសូតចាកព្រះឧទររបស់មាតាហើយដេក ។ ខណៈនោះ ស្រីអ្នកបម្រើរបស់ព្រះនាងដឹងថា ព្រះនាងមិនទាន់ដឹងខ្លួន ក៏យកឈាមលាបកំណាត់ឈើមួយដាក់ក្បែរនោះ ហើយឲ្យសញ្ញាដល់ស្រីទាំងនោះ ។ ស្រីទាំង ៥០០ ក៏នាំយកព្រះរាជកុមារម្នាក់មួយអង្គ ៗ ទៅកាន់សម្នាក់ជាងក្រឡឹង ឲ្យនាំជន្ទាប់ឈើមក ដាក់ព្រះរាជកុមារឲ្យផ្ទំក្នុងជន្ទាប់ឈើនោះ ហើយប្រថាប់ត្រា ។

ឯព្រះនាងបទុមវតី ដឹងខ្លួនហើយសួរស្រីអ្នកបម្រើថា នែនាង ខ្ញុំប្រសូតបុត្តហើយឬ ។ ស្រីបម្រើគំហកថា ព្រះនាងបានទារកមកអំពីណា ដាក់កំណាត់ឈើដែលមានឈាមក្នុងទីចំពោះព្រះភក្ត្រហើយពោលថា នេះជាទារកដែលប្រសូតចាកផ្ទៃរបស់ព្រះនាង ។

ព្រះនាងបទុមវតីទតឃើញកំណាត់ឈើនោះ ក៏ទោមនស្ស មាន

ព្រះសវនីយ៍ថា ចូរនាំចេញទៅឲ្យឆាប់ បើអ្នកណាម្នាក់ឃើញ ក៏នឹងខ្មាសអ្នកនោះ ។ ស្រីបម្រើនោះទទួលព្រះរាជសវនីយ៍ហើយ ធ្វើដូចជាបំណងល្អ ក៏នាំយកកំណាត់ឈើទៅពុះ ហើយដាក់លើជើងក្រាន ។

ចំណែកព្រះរាជាយាងត្រឡប់អំពីជាយដែន ទ្រង់រាប់អានទក្ខត្តឫក្សត្រាស់ឲ្យបោះព្រះពន្លាប្រថាប់ខាងក្រៅនគរ ។ លំដាប់នោះ ស្រីទាំង ៥០០ នោះ នាំគ្នាចេញទៅទទួលព្រះរាជា ក្រាបទូលថា បពិត្រមហារាជទ្រង់មិនជឿពួកខ្ញុំម្ចាស់ ពាក្យដែលពួកខ្ញុំម្ចាស់ក្រាបទូល ជាពាក្យដែលមិនសមហេតុ សូមទ្រង់ហៅអ្នកបម្រើរបស់ព្រះមហេសីមកសួរចុះ ព្រះទេវីរបស់ព្រះអង្គប្រសូតដុំឈើ ។ ព្រះរាជាទ្រង់មិនទាន់ពិចារណាហេតុនោះ គិតថា ស្រីនេះ មិនមែនមនុស្សពិត ទើបទ្រង់បណ្តេញព្រះនាងចេញអំពីព្រះរាជវាំង ។ ដំណាលគ្នានឹងការយាងចេញអំពីព្រះរាជវាំងផ្កាឈូក ក៏អន្តរធានទៅ សូម្បីតែពណ៌សម្បុរនៃសរីរៈ ក៏ស្រអាប់ ។ ព្រះនាងតែមួយអង្គឯងយាងទៅតាមវិថី ។ លំដាប់នោះ ស្ត្រីជរាម្នាក់ឃើញហើយ ក៏កើតសេចក្តីស្រឡាញ់ដូចជាកូនស្រីរបស់ខ្លួន ទើបសួរថា នែកូនស្រី នាងទៅណា ។

ព្រះនាងតបថា ខ្ញុំជាអ្នកដំណើរ កំពុងដើររកទីស្នាក់នៅ ។ ស្ត្រីចំណាស់ពោលថា មកនេះ កូនស្រី ហើយនាំនាងទៅកាន់លំនៅ រៀបចំអាហារផ្គត់ផ្គង់ ។

*កាលព្រះនាងគង់នៅក្នុងទីនោះ ដោយទំនងនោះឯង ស្រីទាំង ៥០០ ក៏នាំគ្នាក្រាបទូលព្រះរាជាថា បពិត្រមហារាជ កាលទ្រង់យាងទៅធ្វើសង្គ្រាម ខ្ញុំម្ចាស់ទាំងឡាយប្រាថ្នាថា កាលទ្រង់ឈ្នះសង្គ្រាមត្រឡប់មក ពួកខ្ញុំម្ចាស់នឹងធ្វើពលិកម្ម លេងឧទកកីឡា ថ្វាយដល់គង្គាទេវតា សូមទ្រង់ប្រកាសសេចក្ដីនេះ ឲ្យដឹងផងចុះ ។ ព្រះរាជាទ្រង់ត្រេកអរតាមពាក្យរបស់ស្ត្រីទាំងនោះ ទ្រង់ក៏យាងទៅដើម្បីលេងឧទកកីឡា ក្នុងស្ទឹងគង្គា ។ ស្ត្រីទាំងនោះ នាំគ្នាកាន់ជន្ទាប់ឈើដែលបិទជិត ម្នាក់មួយ ៗ ទៅកាន់ស្ទឹង យកសំពត់គ្របដើម្បីបិទបាំងជន្ទាប់ឈើទាំងនោះ រួចចុះក្នុងទឹក បណ្ដែតជន្ទាប់ឈើទៅ ។ ជន្ទាប់ឈើទាំងនោះ ទៅព្រមគ្នា ជាប់ត្រង់សំណាញ់ដែលគេសន្ទឹងក្រោមខ្សែទឹកទាំងអស់ ។ បន្ទាប់អំពីព្រះរាជាទ្រង់ក្រសាលឧទកកីឡាស្រេចហើយ ទ្រង់យាងឡើង ពួករាជបុរសឃើញជន្ទាប់ឈើទាំងនោះ ទើបនាំមកថ្វាយព្រះរាជា ។ ព្រះរាជាទ្រង់ទតជន្ទាប់ឈើនោះ ត្រាស់សួរថា នែបាទាំងឡាយ អ្វីនៅក្នុងជន្ទាប់ឈើនេះ ។*

*ពួករាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំមិនដឹងទេ ។ ព្រះរាជាទ្រង់ត្រាស់ឲ្យបើកជន្ទាប់ឈើទាំងនោះមើល ទ្រង់ឲ្យបើកជន្ទាប់ឈើរបស់ព្រះមហាបទុមរាជកុមារមុនគេ ។ តាំងពីថ្ងៃដែលគេដាក់ព្រះរាជកុមារទាំងនោះ ក្នុងជន្ទាប់ឈើ ទឹកដោះក៏កើតត្រង់មេដៃ*

សម្រាប់ព្រះរាជកុមារគ្រប់អង្គដោយបុញ្ញឫទ្ធិ ។ សក្កទេវរាជត្រាស់ឲ្យចារឹកអក្សរខាងក្នុងជន្ទាប់ឈើ ដើម្បីឲ្យព្រះរាជាអស់សេចក្ដីសង្ស័យថា ព្រះរាជកុមារទាំងនេះ កើតក្នុងព្រះឧទររបស់ព្រះនាងបទុមវតី ជាឱរសរបស់ព្រះបាទពារាណសី កាលនោះ ស្រីទាំង ៥០០ ដែលជាសត្រូវរបស់ព្រះនាងបទុមវតី ដាក់ព្រះរាជកុមារទាំងនេះ ក្នុងជន្ទាប់ឈើ ហើយបោះក្នុងទឹក សូមព្រះរាជាទ្រង់ជ្រាបហេតុការណ៍នេះ ។ លុះបើកជន្ទាប់ឈើ ព្រះរាជាទ្រង់អានអក្ខរា ឃើញព្រះរាជកុមារ ទ្រង់លើកព្រះមហាបទុមកុមារឡើង ឲ្យប្រញាប់ទឹមរថ ហើយត្រាស់ថា អ្នកទាំងឡាយចូររៀបចំសេះឲ្យឆាប់ ថ្ងៃនេះ យើងនឹងចូលទៅក្នុងព្រះនគរ ធ្វើព្រះនាងបទុមវតីឲ្យជាទីស្រឡាញ់របស់ពួកស្រីខ្វះ ដូច្នេះហើយ ឡើងកាន់មហាប្រាសាទ ឲ្យដាក់បង្វេចទ្រព្យ ១ ពាន់កហាបណៈ លើកដំរី ឲ្យវាយស្គរប្រកាសពេញព្រះនគរថា អ្នកណាឃើញព្រះនាងបទុមវតី អ្នកនោះ ចូរទទួលទ្រព្យ ១ ពាន់កហាបណៈនេះចុះ ។

ព្រះនាងបទុមវតីបានស្ដាប់ពាក្យប្រកាសនោះហើយ ឲ្យសញ្ញាដល់មាតាថា សូមអ្នកម៉ែទទួលទ្រព្យ ១ ពាន់កហាបណៈ អំពីកដំរី ។ ស្ត្រីចាស់ជរាពោលថា ម៉ែមិនហ៊ានទទួលទ្រព្យបែបនេះទេ ។ កាលព្រះនាងប្រាប់អស់វារៈ ២ ដង ៣ ដង ទើបពោលថា នែកូន ម៉ែត្រូវពោលដូចម្ដេច ទើបកាន់យកទ្រព្យ ។

ព្រះនាងមានព្រះសវនីយ៍ថា ( ចូរម៉ែប្រាប់គេថា ) ធីតារបស់ខ្ញុំឃើញព្រះនាងបទុមវតី ហើយទទួលទ្រព្យមក ។ ស្ត្រីជរាគិតថា រឿងនេះ ពិតជាមានហេតុ ទើបចូលទៅទទួលយកបង្វេចទ្រព្យ ១ ពាន់កហាបណៈនោះ ។ គ្រានោះ មនុស្សទាំងឡាយសួរថា អ្នកម៉ែឃើញព្រះនាងបទុមវតីឬ ។

ស្ត្រីជរាពោលថា ខ្ញុំមិនបានឃើញទេ តែកូនស្រីរបស់ខ្ញុំឃើញ ។ មនុស្សទាំងនោះសួរថា កូនស្រីរបស់អ្នកម៉ែ នៅឯណា ហើយក៏ទៅជាមួយ ស្គាល់ព្រះនាងបទុមវតី ក៏ក្រាបចុះទៀបបាទា ។ ក្នុងខណៈនោះ ស្ត្រីជរាដឹងថា នេះគឺព្រះនាងបទុមវតី ទើបពោលថា ព្រះមហេសីរបស់ព្រះរាជាឯណា នៅហើយប្រាសចាកការរក្សាបែបនេះ អំពើនោះជាកម្ម គឺស្ត្រីធ្វើយ៉ាងធ្ងន់ណាស់ហ្ន៎ ។

រាជបុរសទាំងនោះ ឲ្យបិទបាំងទីប្រថាប់គង់របស់ព្រះនាងបទុមវតីដោយរាំងននពណ៌ស រៀបចំការរក្សាត្រង់ទ្វារហើយ ត្រឡប់ទៅក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់បញ្ជូនយានមាសមក ។ ព្រះនាងបទុមវតីពោលថា ខ្ញុំម្ចាស់នឹងមិនទៅដោយរបៀបនេះ សូមទ្រង់ឲ្យក្រាលកម្រាលដ៏វិចិត្រ ដោយសំពត់សម្បកឈើដ៏ល្អ តាំងអំពីលំនៅរបស់ខ្ញុំម្ចាស់ រហូតដល់ព្រះរាជនិវេសន៍ ឲ្យបាំងពិតានដោយសំពត់ ដែលវិចិត្រដោយផ្កាយមាសអំពីខាងលើ កាលបញ្ជូនគ្រឿងអលង្ការគ្រប់យ៉ាងមក

ឲ្យខ្ញុំម្ចាស់ប្រដាប់តាក់តែងហើយ ខ្ញុំម្ចាស់នឹងដើរទៅដោយជើង អ្នកនគរនឹងឃើញសម្បត្តិរបស់ខ្ញុំម្ចាស់ ដោយវិធីយ៉ាងនេះ ។

ព្រះរាជាត្រាស់ថា ចូរធ្វើតាមព្រះហឫទ័យរបស់ព្រះនាងបទុមវតីចុះ ។ លំដាប់នោះ ព្រះនាងបទុមវតីប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាងហើយ ព្រះនាងព្រះតម្រិះថា អញនឹងទៅកាន់ព្រះរាជនិវេសន៍ ក៏ផ្ដើមធ្វើដំណើរ ។ គ្រានោះ ផ្កាឈូកទាំងឡាយក៏ផុសជ្រែកកម្រាលដែលវិចិត្រដោយសំពត់សម្បកឈើដ៏ល្អ ត្រង់ទីដែលព្រះនាងជាន់យាងទៅ ។ កាលព្រះនាងសម្ដែងសម្បត្តិរបស់ព្រះនាងដល់មហាជនហើយ យាងឡើងកាន់ព្រះរាជនិវេសន៍ ឲ្យព្រះរាជទានកម្រាលដ៏វិចិត្រទាំងអស់នោះដល់ស្ត្រីជរា ជាថ្លៃចិញ្ចឹម ។

ព្រះរាជាឲ្យហៅស្រីទាំង ៥០០ នោះមក ហើយត្រាស់ថា នែទេវី យើងឲ្យស្រីទាំងនេះ ធ្វើជាទាសីរបស់នាង ។ ព្រះនាងក្រាបទូលថា បពិត្រមហារាជ សូមទ្រង់ប្រកាសឲ្យអ្នកនគរទាំងអស់ ដឹងនូវភាពដែលទ្រង់ប្រទានស្រីទាំងនេះ ឲ្យជាទាសីដល់ខ្ញុំម្ចាស់ហើយ ។ ព្រះរាជាឲ្យវាយស្គរប្រកាសថា ស្រី ៥០០ ដែលជាសត្រូវរបស់ព្រះនាងបទុមវតី យើងបានឲ្យជាទាសីរបស់ព្រះនាងបទុមវតីហើយ ។

កាលព្រះនាងជ្រាបថា អ្នកនគរកំណត់ដឹងថា ស្រីទាំងនេះ ជាទាសីហើយ ទើបទូលសួរព្រះរាជាថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់នឹង

ធ្វើទាសីរបស់ខ្ញុំម្ចាស់ ឲ្យជាអ្នកជាបានដែរឬទេ ។

ព្រះរាជាត្រាស់ថា ម្នាលទេវី តាមតែនាងប្រាថ្នាចុះ ។ ព្រះនាងក្រាបទូលថា បើដូច្នោះ សូមទ្រង់ឲ្យវាយស្គរប្រកាសម្តងទៀតថា ស្ត្រីទាំង ៥០០ ដែលព្រះរាជាឲ្យវាយស្គរប្រកាស ព្រះរាជទានឲ្យធ្វើជាទាសីរបស់ព្រះនាងបទុមវតីនោះ ឥឡូវនេះ ព្រះនាងបទុមវតីធ្វើឲ្យជាអ្នកជាគ្រប់គ្នាហើយ ។ កាលព្រះនាងធ្វើស្រីទាំងនោះ ឲ្យជាអ្នកជាហើយ ព្រះនាងក៏ប្រគល់ព្រះរាជឱរស ៤៩៩ អង្គ ទុកក្នុងដៃស្ត្រីទាំងនោះ ដើម្បីថែរក្សាព្រះមហាបទុមកុមារមួយអង្គប៉ុណ្ណោះ ព្រះនាងថែរក្សាដោយដៃឯង ។

ក្នុងកាលតមក កាលព្រះរាជកុមារទាំងនោះដល់នូវវ័យលេង ព្រះរាជាឲ្យធ្វើទីសម្រាប់លេងច្រើនប្រភេទក្នុងព្រះរាជឧទ្យាន ។ លុះមានវស្សា ១៦ ព្រះរាជកុមារទាំងនោះ ស្រុះស្រួលគ្នាថា លេងក្នុងស្រះមង្គលបោក្ខរណី ដែលដេរដាសដោយផ្កាឈូកក្នុងព្រះរាជឧទ្យាន ទតឃើញផ្កាឈូករីកថ្មី និងផ្កាឈូកចាស់ដែលរុះរោយ ទ្រង់កាន់យកការរុះរោយនៃផ្កាឈូកឲ្យជាអារម្មណ៍ថា ជរាបែបនេះ គង់មកដល់អនុបាទិន្នកសង្ខារយ៉ាងនេះហ្ន៎ នឹងពោលទៅថ្វីថា ជរាមិនមកដល់សរីរៈរបស់ពួកយើង សរីរៈនេះ គង់មានគតិយ៉ាងនេះដូចគ្នា ដូច្នេះហើយ បានសម្រេចនូវបច្ចេកពោធិញ្ញាណគ្រប់អង្គ ទ្រង់ក្រោកឡើង គង់ពត់ភ្នែនក្នុងផ្កាឈូកទាំងឡាយ ។

*លំដាប់នោះ ពួករាជបុរសអ្នកថែរក្សាព្រះរាជកុមារ ដឹងថា ពេលថ្ងៃបានកន្លងទៅច្រើន ( ល្ងាច ) ហើយ ទើបទូលថា បពិត្រអយ្យបុត្តសូមទ្រង់ជ្រាបកាលរបស់ទ្រង់ចុះ ។ ព្រះរាជកុមារទាំងនោះ ក៏នៅស្ងៀម ។ ពួករាជបុរសទាំងនោះ ក៏ទៅក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ព្រះរាជកុមារទាំងឡាយប្រថាប់គង់ក្នុងផ្កាឈូក សូម្បីពួកទូលព្រះបង្គំក្រាបទូលថា ( ដល់កាលហើយ ) ក៏មិនមានព្រះវាចាអ្វីឡើយ ។*

*ព្រះរាជាត្រាស់ថា ពួកអ្នក ចូរឲ្យព្រះរាជកុមារទាំងនោះ អង្គុយតាមគាប់ចិត្តចុះ ។ ព្រះរាជកុមារទាំងនោះ បានទទួលការរក្សាមួយយប់ទល់ភ្លឺរហូតដល់ថ្ងៃរះ ក៏នៅតែគង់លើត្របកផ្កាឈូកនោះឯង ។*

*ថ្ងៃស្អែកឡើង ពួករាជបុរសចូលគាល់ ក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ជ្រាបកាលចុះ ។ ព្រះបច្ចេកពុទ្ធទាំងនោះ ត្រាស់ថា ពួកអាត្មាមិនមែនជាព្រះសម្មតិទេព ( របស់ពួកអ្នកទេ ) ពួកអាត្មាជា* **ព្រះបច្ចេកពុទ្ធ** *ទេតើ ។*

*ពួករាជបុរសក្រាបទូលថា បពិត្រព្រះអយ្យបុត្ត ទ្រង់ត្រាស់ពាក្យធ្ងន់ពេក ធម្មតាព្រះបច្ចេកពុទ្ធមិនមានសភាពដូចទ្រង់ទេ ព្រះបច្ចេកពុទ្ធទាំងឡាយ ជាអ្នកមានសក់ ពុកមាត់ពុកចង្កា ត្រឹម ២ ធ្នាប់ ទ្រទ្រង់បរិក្ខារ ៨ លើរាងកាយ ។ ព្រះបច្ចេកពុទ្ធទាំងនោះ យកព្រះហស្តស្ដាំស្ទាប*

សីសៈ រំពេចនោះឯង ភេទគ្រហស្ថក៏អន្តរធានទៅ បរិក្ខារ ៨ ក៏មកប្រដាប់ត្រង់កាយ ហើយហោះតាមអាកាស ទៅកាន់ញកភ្នំនន្ទមូលកៈ ទាំងមហាជនកំពុងឃើញនុ៎ះឯង ។

ចំណែកព្រះនាងបទុមវតីទេវីសោកសង្រេងថា អាត្មាអញមានកូនច្រើន ក៏ក្លាយជាមនុស្សឥតកូន ។ ព្រោះសេចក្តីសោកនោះឯង ក៏សោយព្រះវិលាល័យ ទៅកើតក្នុងផ្ទះរបស់អ្នកធ្វើការដោយដៃចិញ្ចឹមជីវិតក្នុងភូមិមួយ ក្បែរទ្វារនគររាជគ្រឹះ ។ សម័យក្រោយមក មានស្វាមីហើយ ថ្ងៃមួយ ទូលបបរទៅស្រែឲ្យស្វាមី ឃើញព្រះបច្ចេកពុទ្ធ ៨ អង្គក្នុងចំណោមនៃបុត្តទាំងឡាយរបស់ខ្លួន ( ក្នុងជាតិមុននោះ ) កំពុងហោះមកក្នុងពេលភិក្ខាចារ ទើបប្រញាប់ទៅប្រាប់ស្វាមីថា នែអ្នក សូមអ្នកមើលព្រះបច្ចេកពុទ្ធជាម្ចាស់ យើងនឹងនិមន្តលោកមកឆាន់ ។

ស្វាមីនោះពោលថា ធម្មតាសមណបក្សីទាំងនេះ ហោះទៅកាន់ទីផ្សេង ៗ យ៉ាងនេះ សមណបក្សីទាំងនោះ មិនមែនព្រះបច្ចេកពុទ្ធទេ ។ ខណៈដែលជនទាំងពីរកំពុងនិយាយគ្នានោះឯង ព្រះបច្ចេកពុទ្ធទាំងនោះក៏ចុះមកក្នុងទីមិនឆ្ងាយ ។ ស្រីនោះក៏ប្រគេនភោជន គឺភត្ត និងរបស់ដែលជាចំណែករបស់ខ្លួនក្នុងថ្ងៃនោះ ដល់ព្រះបច្ចេកពុទ្ធទាំងនោះ ហើយនិមន្តថា ស្អែកនេះ សូមលោកម្ចាស់ទាំង ៨ អង្គ ទទួលភិក្ខារបស់ខ្ញុំព្រះករុណា ។

ព្រះបច្ចេកពុទ្ធពោលថា សាធុឧបាសិកា នាងចូររៀបចំសក្ការៈមានប្រមាណស្មើនឹងថ្ងៃនេះ អាសនៈក៏ចូរមាន ៨ តែបើនាងឃើញព្រះបច្ចេកពុទ្ធដទៃ ៗ មកច្រើន ក៏គប្បីធ្វើចិត្តរបស់នាងឲ្យជ្រះថ្លា ។ ស្អែកឡើង នាងក្រាលអាសនៈ ៨ រៀបចំគ្រឿងសក្ការៈសម្រាប់ព្រះបច្ចេកពុទ្ធ ៨ អង្គ ហើយអង្គុយរង់ចាំ ។

ព្រះបច្ចេកពុទ្ធដែលបានទទួលនិមន្តន៍ ឲ្យសញ្ញាដល់ព្រះបច្ចេកពុទ្ធអង្គដទៃ ៗ ថា លោកនិរទុក្ខទាំងឡាយ ថ្ងៃនេះ លោកទាំងឡាយកុំទៅកាន់ទីដទៃ ទាំងអស់អង្គ ចូរធ្វើសេចក្ដីអនុគ្រោះដល់មាតារបស់លោកចុះ ។ ព្រះបច្ចេកពុទ្ធទាំងនោះ ស្ដាប់ពាក្យរបស់ព្រះបច្ចេកពុទ្ធ ៨ អង្គនោះហើយ ស្រុះស្រួលគ្នាគ្រប់អង្គ ហោះទៅប្រាកដក្បែរទ្វារផ្ទះរបស់មាតា ។ នាងឃើញព្រះបច្ចេកពុទ្ធច្រើនអង្គ មិនញាប់ញ័រ ព្រោះបានសញ្ញាអំពីមុនហើយ និមន្តព្រះបច្ចេកពុទ្ធទាំងនោះ ចូលកាន់ផ្ទះ ឲ្យគង់លើអាសនៈ កាលព្រះបច្ចេកពុទ្ធទាំងនោះ គង់តាមលំដាប់ ព្រះបច្ចេកពុទ្ធអង្គទី ៩ ក៏និម្មិតអាសនៈ ៨ ដទៃទៀត ខ្លួនឯងអង្គុយលើអាសនៈខាងដើម ( ទី ៩ ) ផ្ទះក៏ធំប៉ុនចំនួនអាសនៈដែលបន្ថែមឡើង ។ កាលព្រះបច្ចេកពុទ្ធទាំងឡាយអង្គុយរៀបរយយ៉ាងនេះ ស្ត្រីនោះ ក៏ថ្វាយសក្ការៈដែលខ្លួនរៀបចំសម្រាប់ព្រះបច្ចេកពុទ្ធ ៨ អង្គ រហូតគ្រប់គ្រាន់ដល់ព្រះបច្ចេកពុទ្ធ ៥០០ ហើយនាំយកផ្កាឧប្បលខៀវ ៨ ក្ដាប់ ដាក់ទៀបបាទមូល

ព្រះបច្ចេកពុទ្ធដែលខ្លួននិមន្តមកប៉ុណ្ណោះ ហើយពោលថា បពិត្រលោកម្ចាស់ សូមពណ៌សម្បុរនៃសរីរៈរបស់ខ្ញុំ ដូចពណ៌នៃបណ្តូលផ្កាឧប្បលខៀវនេះ ក្នុងទីដែលខ្ញុំកើតហើយ ៗ ។ ព្រះបច្ចេកពុទ្ធទាំងឡាយធ្វើអនុមោទនាដល់មាតាហើយ នាំគ្នាទៅកាន់ភ្នំគន្ធមាទន៍ ។

កុលធីតានោះ ធ្វើកុសលដរាបដល់អស់ជីវិត ចុតិអំពីមនុស្សហើយកើតក្នុងទេវលោក ។ ក្នុងពុទ្ធុប្បាទនេះ បដិសន្ធិក្នុងត្រកូលសេដ្ឋី ក្នុងក្រុងសាវត្ថី មាតាបិតាដាក់ឈ្មោះថា ឧប្បលវណ្ណា ព្រោះមានពណ៌សម្បុរដូចពណ៌នៃបណ្តូលផ្កាឧប្បលខៀវ ។ សម័យនោះឯង ក្នុងកាលដែលនាងពេញវ័យហើយ ព្រះរាជានិងសេដ្ឋីទាំងឡាយក្នុងជម្ពូទ្វីបនាំគ្នាបញ្ជូនទូតទៅកាន់សម្នាក់សេដ្ឋីថា សូមឲ្យធីតាដល់យើងចុះ ។ ព្រះរាជាដែលឈ្មោះថា មិនបញ្ជូនទូតទៅ មិនមានឡើយ ។ សេដ្ឋីគិតថា អញមិនអាចតម្រូវចិត្តព្រះរាជាបាន អញនឹងធ្វើឧបាយមួយ ដូច្នេះហើយ ទើបហៅធីតាមក សួរថា នែកូន តើនាងបួសឬ ។ ពាក្យរបស់បិតាប្រៀបដូចជាប្រេងដែលគេចម្រាញ់ហើយ អស់រាប់រយដង ស្រោចលើសីសៈ ព្រោះជាភពចុងក្រោយ ព្រោះហេតុនោះ ទើបនាងឆ្លើយនឹងបិតាថា **បព្វជិស្សាមិ តាត** កូននឹងបួស លោកឪពុក ។ សេដ្ឋីនោះ ក៏ធ្វើសក្ការៈដល់កូន នាំទៅកាន់សម្នាក់ភិក្ខុនី ហើយឲ្យបួស កាលនាងបួសមិនយូរប៉ុន្មាន វារៈតាមកាល គឺវេនក្នុងរោងឧបោសថ ក៏មកដល់ នាង

អុជប្រទីបហើយ ហោសពោធ៍ឧបោសថ កាន់យកនិមិត្តនៃអណ្តាតប្រទីបពិចារណារឿយ ៗ ធ្វើឈានដែលមានតេជោកសិណជាអារម្មណ៍ ឲ្យកើតឡើង ធ្វើឈាននោះឯងឲ្យជាបាទ សម្រេចអរហត្ត មួយអន្លើដោយអភិញ្ញានិងបដិសម្ភិទាដំណាលគ្នានឹងអរហត្តផលនុ៎ះឯង ក្រៃលែងជាងនោះ នាងក៏ជាអ្នកជំនាញក្នុងការនិម្មិតកាយដោយឫទ្ធិទៀតផង ។

សមដូចគាថាដែលលោកពោលទុកក្នុងអដ្ឋកថា ថេរីគាថាថា

**បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ**
**ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ។**

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ជាលោកនាយក កើតឡើងហើយ ក្នុងកប្បទីមួយសែន អំពីភទ្ទកប្បនេះ ។

**តទាហំ ហំសវតិយំ ជាតា សេដ្ឋិកុលេ អហុំ**
**នានារតនបជ្ជោតេ មហាសុខសមប្បិតា ។**

ក្នុងគ្រានោះ ខ្ញុំជាស្រីកើតក្នុងត្រកូលសេដ្ឋី ដែលរុងរឿងដោយរតនៈផ្សេង ៗ ជាស្រីស្កប់ស្កល់ដោយសេចក្តីសុខច្រើនក្នុងនគរហំសវតី ។

**ឧបេត្វា តំ មហាវីរំ អស្សោសឹ ធម្មទេសនំ**
**តតោ ជាតប្បសាទាហំ ឧបេមិ សរណំ ជិនំ ។**

ខ្ញុំបានចូលទៅជិតព្រះពុទ្ធអង្គនោះ ទ្រង់មានព្យាយាមធំ ហើយបានស្តាប់នូវព្រះធម្មទេសនា ខ្ញុំមានសេចក្តីជ្រះថ្លាកើតឡើង ក្នុងព្រះជិនស្រីអង្គនោះ ហើយបានដល់នូវព្រះជិនស្រីជាទីពឹង ។

ភគវា ឥទ្ធិមន្តីនំ អគ្គំ វណ្ណេសិ ជាយកោ
ភិក្ខុនឹ លជ្ជិនឹ តាទឹ សមាធិឈានកោវិទំ ។

ព្រះមានព្រះភាគជាលោកនាយក ទ្រង់សរសើរនូវភិក្ខុនីមួយរូប ជាស្រីនឹងធឹង ខ្មាសបាប ឈ្លាសក្នុងសមាធិឈានថា ជាកំពូលលើសភិក្ខុនីទាំងឡាយ អ្នកមានឫទ្ធិ ។

តទា មុទិតចិត្តាហំ តំ ឋានំ អភិកង្ខិនី
និមន្តិត្វា ទសពលំ សសង្ឃំ លោកនាយកំ ។

ក្នុងគ្រានោះ ខ្ញុំមានចិត្តត្រេកអររីករាយ ប្រាថ្នានូវតំណែងនោះ ក៏និមន្តព្រះទសពលជាលោកនាយក ព្រមទាំងភិក្ខុសង្ឃ ។

ភោជយិត្វាន សត្តាហំ ទត្វាន ច តិចីវរំ
សត្តមាលំ គហេត្វាន ឧប្បលានេវគន្ធិកំ ។

បានញុំាំងព្រះមានព្រះភាគអង្គនោះ ព្រមទាំងសាវ័ក ឲ្យឆាន់អស់ ៧ ថ្ងៃ ហើយប្រគេនត្រៃចីវរ កាន់យកផ្កាឧប្បលដែលមានក្លិនក្រអូប ដូចផ្កាឈើទិព្វ ៧ ផ្កា ។

សត្ថុ ចារេ បបេត្វាន ញាណម្ហិ អភិបូជយី
និបច្ច សិរសា ចារេ ឥទំ វចនមព្រវី ។
យាតិសា វណ្ណិតា វីរ ឥតោ អដ្ឋមកេ មុនិ
តាទិសាហំ ភវិស្សាមិ យទិ សិជ្ឈតិ នាយក ។

*តម្កល់ទុកទៀបព្រះបាទនៃព្រះសាស្តា ហើយបូជាចំពោះព្រះញាណ ក្រាបទៀបព្រះបាទដោយសិរសា បានពោលពាក្យនេះថា បពិត្រព្រះវីរមុនី ទ្រង់នាំសត្វលោក ភិក្ខុនីរូបណាដែលព្រះអង្គទ្រង់សរសើរក្នុងតំណែងដ៏ប្រសើរ ក្នុងថ្ងៃទី ៨ អំពីថ្ងៃនេះ បើតំណែងនោះ នឹងសម្រេចដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់នឹងជាស្រីមានសភាពដូច្នោះ ។*

តទា អវោច មំ សត្ថា វិស្សដ្ឋា ហោតិ ទារិកេ
អនាគតម្ហិ អទ្ធានេ លច្ឆសេ តំ មនោរថំ ។

*ក្នុងគ្រានោះ ព្រះសាស្តាទ្រង់ត្រាស់នឹងខ្ញុំថា ម្នាលនាងទារិកា សភាពថ្វាស្អាតពិតប្រាកដ រមែងមាន នាងនឹងបាននូវតំណែងនោះ តាមមនោរថ ក្នុងកាលជាអនាគត ។*

សតសហស្សិតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម គោត្តេន សត្ថា លោកេ ភវិស្សតិ ។

*ព្រះសាស្តាព្រះនាមគោតម តាមគោត្ត ទ្រង់សម្ភពក្នុងត្រកូល*

*ឱក្កាកៈ នឹងកើតឡើងក្នុងលោក ( ក្នុងកប្បទី ១ សែន អំពីកប្បនេះ ) ។*

**តស្ស ធម្មេសុ ទាយាទា ឱរសា ធម្មនិម្មិតា**
**ឧប្បលវណ្ណាតិ នាមេន រូបេន ច យសស្សិនី ។**

*នាងនឹងជាទាយាទក្នុងធម៌នៃព្រះពុទ្ធអង្គនោះ ជាឱរសដែលធម៌និម្មិតហើយ នឹងមានឈ្មោះថា ឧប្បលវណ្ណា ព្រោះរូបទាំងជាស្រីមានយស ។*

**អភិញ្ញាសុ វសិប្បត្តា សត្ថុសាសនការិកា**
**សព្វាសវបរិក្ខីណា ហេស្សសិ សត្ថុ សាវិកា ។**

*នាងនឹងដល់នូវការស្ទាត់ជំនាញក្នុងអភិញ្ញា ជាអ្នកធ្វើតាមសាសនានៃព្រះសាស្តា មានអាសវៈទាំងពួងអស់ហើយ ជាសាវិកានៃព្រះសាស្តា ។*

**តទាហំ មុទិតា ហុត្វា យាវជីវំ តទា ជិនំ**
**មេត្តចិត្តា បរិចរឹ សសង្ឃំ លោកនាយកំ ។**

*ក្នុងគ្រានោះ ខ្ញុំមានចិត្តរីករាយ មានចិត្តប្រកបដោយមេត្តា បម្រើនូវព្រះជិនស្រី ជាលោកនាយក ព្រមទាំងព្រះសង្ឃ ក្នុងគ្រានោះ រហូតអស់ជីវិត ។*

**តេន កម្មេន សុកតេន ចេតនាបណិធីហិ ច**

**ជហិត្វា មានុសំ ទេហំ តាវតឹសមគច្ឆហំ ។**

*ព្រោះកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ព្រោះការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។*

**តតោ ចុតាហំ មនុជេ ឧបបន្នា សយម្ភុនោ**
**ឧប្បលេហិ បដិច្ឆន្នំ បិណ្ឌបាតមទាសហំ ។**

*ខ្ញុំច្យុតចាកភពនោះហើយ កើតក្នុងពួកមនុស្ស បានប្រគេនបិណ្ឌបាត ដែលបិទបាំងដោយផ្កាឧប្បលទាំងឡាយ ដល់ព្រះសយម្ភូ ។*

**ឯកនវុតិតោ កប្បេ វិបស្សី នាម នាយកោ**
**ឧប្បជ្ជិ ចារុទស្សនោ សព្វធម្មេសុ ចក្ខុមា ។**

*ក្នុងកប្បទី ៩១ អំពីភទ្ទកប្បនេះ ព្រះពុទ្ធព្រះនាមវិបស្សី ជាលោកនាយក មានព្រះនេត្រល្អ មានចក្ខុក្នុងធម៌ទាំងពួង បានកើតឡើងហើយ ។*

**សេដ្ឋិធីតា តទា ហុត្វា ពារាណសិបុរុត្តមេ**
**និមន្តេត្វាន សម្ពុទ្ធំ សសង្ឃំ លោកនាយកំ ។**

*ក្នុងគ្រានោះ ខ្ញុំជាសេដ្ឋីធីតា ក្នុងក្រុងពារាណសី ជាបុរីដ៏ឧត្តម បាននិមន្តនូវព្រះសម្ពុទ្ធ ជាលោកនាយកព្រមទាំង*

*ព្រះសង្ឃ ។*

**មហាទានំ ទទិត្វាន ឧប្បលេហិ វិនាយកំ**
**បូជយិត្វា ចេតសាវ វណ្ណសោភំ អបត្ថយឹ ។**

*ខ្ញុំបានថ្វាយមហាទាន ហើយបូជានូវព្រះពុទ្ធ ទ្រង់ជាវិនាយក ដឹកនាំនូវសត្វលោកដោយវិសេស ដោយផ្កាឧប្បលទាំងឡាយ ហើយប្រាថ្នាឲ្យមានពណ៌សម្បុរល្អ ( ដូចពណ៌នៃបណ្តូលផ្កាឧប្បលខៀវ ) ដោយចិត្តប៉ុណ្ណោះ ។*

**ឥមម្ហិ ភទ្ទកេ កប្បេ ព្រហ្មពន្ធុ មហាយសោ**
**កស្សបោ នាម គោត្តេន ឧប្បជ្ជិ វទតំ វរោ ។**

*ក្នុងភទ្ទកប្បនេះ ព្រះពុទ្ធទ្រង់មានផៅពង្សដ៏ប្រសើរ មានយសធំ ប្រសើរជាងអ្នកប្រាជ្ញ មានព្រះនាមថា កស្សបៈ តាមគោត្ត បានកើតឡើងហើយ ។*

**ឧបដ្ឋាកោ មហេសិស្ស តទា អាសិ នរិស្សរោ**
**កាសិរាជា កិកី នាម ពារាណសិបុរុត្តមេ ។**

*ក្នុងគ្រានោះ ព្រះរាជាដែនកាសី ព្រះនាមកិកី ទ្រង់ជាឥស្សរៈជាងនរៈក្នុងក្រុងពារាណសី ជាបុរីដ៏ឧត្តម ជាឧបដ្ឋាករបស់ព្រះពុទ្ធជាមហេសី ទ្រង់ស្វែងរកគុណធំ ។*

**តស្សាសឹ ទុតិយា ធីតា សមណគុត្តសវ្ហយា**

ធម្មំ សុត្វា ជិនគ្គស្ស បព្វជ្ជំ សមរោចយឹ ។

ខ្ញុំជាធីតាទីពីរ នៃព្រះរាជាអង្គនោះ មាននាមប្រាកដថា សមណគុត្តា បានស្តាប់ព្រះធម៌របស់ព្រះជិនស្រី ដ៏ប្រសើរ ហើយ ពេញចិត្តក្នុងបព្វជ្ជា ។

អនុជានិ ន នោ តាតោ អគារេវ តទា មយំ

វីសវស្សសហស្សានិ វិចរិម្ហ អតន្ទិតា ។

តែព្រះបិតាទ្រង់មិនអនុញ្ញាតដល់យើងខ្ញុំទាំងឡាយ ក្នុងគ្រានោះ យើងខ្ញុំមិនខ្ជិលច្រអូស បានប្រព្រឹត្ត ( ព្រហ្មចរិយធម៌ ) អស់ ២ ម៉ឺន ឆ្នាំ ក្នុងផ្ទះប៉ុណ្ណោះ ។

កោមារិព្រហ្មចរិយំ រាជកញ្ញា សុខេធិតា

ពុទ្ធោបដ្ឋាននិរតា មុទិតា សត្តធីតរោ ។

ព្រះរាជកញ្ញា ជាធីតា ៧ អង្គ ( របស់ព្រះបាទកិកី ) មានសេចក្តីសុខ ប្រព្រឹត្តព្រហ្មចរិយធម៌ តាំងអំពីនៅជាកុមារី ត្រេកអររីករាយ ឧបដ្ឋាកព្រះពុទ្ធ ។

សមណី សមណគុត្តា ច ភិក្ខុនី ភិក្ខុទាយិកា

ធម្មា ចេវ សុធម្មា ច សត្តមី សង្ឃទាយិកា ។

គឺព្រះនាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាយិកា ១ ធម្មា ១ សុធម្មា ១ និងព្រះនាងសង្ឃទាយិកា ជាគម្រប់ ៧ ។

**អហំ ខេមា ច សប្បញ្ញា បដាចារា ច កុណ្ឌលា**
**កិសាគោតមី ធម្មទិន្នា វិសាខា ហោតិ សត្តមី ។**

*( ក្នុងពុទ្ធុប្បាទនៃព្រះសមណគោតមនេះ ព្រះរាជធីតាទាំង ៧ នោះ បានមកជា ) គឺខ្ញុំ ១ ព្រះនាងខេមាអ្នកមានបញ្ញា ១ នាងបដាចារា ១ កុណ្ឌលកេសី ១ កិសាគោតមី ១ ធម្មទិន្នា ១ និងនាងវិសាខាជាគម្រប់ ៧ ។*

**តេហិ កម្មេហិ សុកតេហិ ចេតនាបណិធីហិ ច**
**ជហិត្វា មានុសំ ទេហំ តាវតឹសមគច្ឆហំ ។**

*ព្រោះកុសលកម្មដែលខ្ញុំធ្វើហើយ ដោយល្អនោះផង ព្រោះការតម្កល់ចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្ស ហើយ បានទៅកាន់ឋានតាវត្តិង្ស ។*

**តតោ ចុតា មនុស្សេសុ ឧបបន្នា មហាកុលេ**
**បីតំ មដ្ឋំ វរំ ឧស្សំ អជំ អរហតោ អហំ ។**

*លុះខ្ញុំច្យុតចាកឋានតាវត្តិង្សនោះ មកកើតក្នុងមហាត្រកូល ក្នុងពួកមនុស្ស ហើយបានថ្វាយនូវសំពត់ពណ៌លឿង មានសាច់ម៉ដ្ឋល្អ ដល់ព្រះអរហន្ត ។*

**តតោ ចុតារិដ្ឋបុរេ ជាតា វិប្បកុលេ អហំ**
**ធីតា តិរិដិវច្ឆស្ស ឧម្មាទន្តី មនោហរា ។**

*លុះខ្ញុំច្យុតចាកអត្តភាពនោះ បានកើតក្នុងត្រកូលព្រាហ្មណ-មហាសាល ក្នុងអរិដ្ឋបុរី ជាធីតារបស់ព្រាហ្មណ៍ ឈ្មោះតិរិដិវច្ឆសេដ្ឋី ឈ្មោះឧម្មាទន្តី ជាស្រីទាក់ទាញចិត្ត ( នៃបុរសជាទៃឲ្យវង្វេង ) ។*

តតោ ចុតា ជនបទេ កុលេ អញ្ញតរេ អហំ
បសូតា ជាតិជីតម្ហិ សាលឹ គោបេមហំ តទា ។

*លុះខ្ញុំច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងជនបទ ក្នុងត្រកូលមួយ មិនជាអ្នកស្តុកស្តម្ភណាស់ណាទេ រក្សានូវស្រូវសាលីក្នុងគ្រានោះ ។*

ទិស្វា បច្ចេកសម្ពុទ្ធំ បញ្ចលាជសតានិហំ
ទត្វា បទុមច្ឆន្នានិ បញ្ច បុត្តសតានិហំ ។

*ខ្ញុំឃើញព្រះបច្ចេកពុទ្ធ ១ អង្គ បានថ្វាយលាជ ៥០០ គ្រាប់ បិទបាត្រដោយផ្កាឈូក ហើយប្រាថ្នានូវបុត្ត ៥០០ នាក់ ។*

បត្ថយឹ តេបិ បត្ថេសុំ មធុំ ទត្វា សយម្ភុនោ
តតោ ចុតា អរញ្ញេហំ អជាយឹ បទុមោទរេ ។

*ខ្ញុំថ្វាយនូវទឹកឃ្មុំដល់ព្រះសយម្ភូ ហើយប្រាថ្នានូវបុត្តទាំងនោះ លុះច្យុតចាកអត្តភាពនោះហើយ បានកើតក្នុងផ្កាឈូក ក្នុងព្រៃ ។*

កាសិរញ្ញោ មហេសីហំ ហុត្វា សក្កតបូជិតា
អជនឹ រាជបុត្តានំ អនូនំ សតបញ្ចកំ ។

*ខ្ញុំបានជាមហេសី នៃព្រះបាទកាសី ត្រូវពួកជនធ្វើសក្ការបូជា បានឲ្យកំណើតដល់ព្រះរាជបុត្ត ៥០០ អង្គ មិនខ្វះ ។*

យទា តេ យោព្វនប្បត្តា កីឡន្តា ជលកីឡិតំ
ទិស្វា ឱបត្តបទុមំ អាសុំ បច្ចេកនាយកា ។

*ព្រះរាជបុត្តចម្រើនវ័យហើយ ទ្រង់លេងទឹក បានឃើញផ្កាឈូកមានត្របកស្វិតស្រពោន ក្នុងកាលណា ក៏បានជាព្រះបច្ចេកពុទ្ធ ក្នុងកាលនោះ ។*

សាហំ តេហិ វិនាភូតា សុតវីរេហិ សោកិនី
ចុតា ឥសិគិលិបស្សេ គាមកាម្ហិ អជាយិហំ ។

*ខ្ញុំនោះ បានព្រាត់ប្រាសចាកបុត្តដ៏ប្រសើរទាំងឡាយនោះ ក៏មានសេចក្តីសោក បានច្យុតហើយ កើតក្នុងស្រុកតូច ទៀបភ្នំឥសិគិលិ ។*

យទា ពុទ្ធា សុតមតី សុតានំ ភត្តុនោបិ ច
យាគុំ អាទាយ គច្ឆន្តី អដ្ឋ បច្ចេកនាយកេ ។
ភិក្ខាយ គាមំ គច្ឆន្តេ ទិស្វា បុត្តេ អនុស្សរឹ
ខីរធារា វិនិគ្គច្ឆិ តទា មេ បុត្តបេមសា ។

*ខ្ញុំមានចិត្តនឹកភ្នកដល់កូន ដែលជាព្រះបច្ចេកពុទ្ធ កំពុងតែកាន់យកយាគូទៅដើម្បីប្តីក្នុងកាលណា ក្នុងកាលនោះ បានឃើញនូវព្រះបច្ចេកពុទ្ធ ៨ អង្គ ដែលកំពុងនិមន្តទៅកាន់ស្រុកដើម្បីភិក្ខា ក៏នឹករឭកកូនទាំងឡាយ កាលនោះ ផ្ការទឹកដោះរបស់ខ្ញុំក៏ខ្ចរចេញ ព្រោះសេចក្តីស្រឡាញ់ចំពោះកូន ។*

**តតោ តេសំ អហំ យាគុំ បសន្នា សេហិ ចាណិភិ**
**តតោ ចុតាហំ តិទសំ នន្ទនំ ឧបបជ្ជហំ ។**

*លំដាប់នោះ ខ្ញុំជ្រះថ្លា បានប្រគេនយាគូដល់ព្រះបច្ចេកពុទ្ធទាំងនោះ ដោយដៃរបស់ខ្លួន លុះខ្ញុំច្យុតចាកអត្តភាពនោះហើយ ក៏បានកើតក្នុងឧទ្យាន ឈ្មោះនន្ទនៈ ក្នុងឋានតាវត្តិង្ស ។*

**អនុភោត្វា សុខំ ទុក្ខំ សំសរិត្វា ភវាភវេ**
**តវត្ថាយ មហាវីរ បរិច្ចត្តញ្ច ជីវិតំ ។**

*បពិត្រព្រះមហាវីរៈ ខ្ញុំទទួលនូវសេចក្តីសុខនិងទុក្ខ អន្ទោលទៅក្នុងភពតូចនិងភពធំ ទាំងជីវិត ក៏លះបង់ដើម្បីប្រយោជន៍នៃព្រះអង្គ ។*

**ជីតា តុយ្ហំ មហាវីរ បញ្ញវន្ត ជុតិន្ធរ**
**ពហុញ្ច ទុក្ករំ កម្មំ កាតំ មេ អតិទុក្ករំ ។**

*បពិត្រព្រះមហាវីរៈ ទ្រង់មានបញ្ញា ទ្រទ្រង់នូវសេចក្តីរុងរឿង*

*ខ្ញុំម្ចាស់ជាធីតារបស់ព្រះអង្គ អំពើដ៏ច្រើន ដែលគេធ្វើបាន ដោយក្រ ខ្ញុំម្ចាស់បានធ្វើហើយ ទាំងអំពើដ៏កម្រក្រៃលែង ក៏ ខ្ញុំម្ចាស់បានធ្វើហើយដែរ ។*

**រាហុលោ ច អហញ្ចេវ នេកជាតិសតេពហូ**
**ឯកស្មឹ សម្ភវេ ជាតា សមានច្ឆន្ទមានសា ។**

*ព្រះរាហុលនិងខ្ញុំម្ចាស់ បានកើតក្នុងភពជាមួយគ្នា អស់ច្រើន រយជាតិជាអនេក ជាអ្នកមានចិត្តប្រកបដោយឆន្ទៈដូចគ្នា ។*

**និព្វត្តិ ឯកតោ ហោតិ ជាតិយាបិ ច ឯកតោ**
**បច្ឆិមេ ភវេ សម្បត្តេ ឧភោបិ នានាសម្ភវា ។**

*ការកើតក្នុងទីជាមួយគ្នា ក៏មាន កើតក្នុងជាតិជាមួយគ្នា ក៏ មាន លុះដល់ភពចុងក្រោយ យើងខ្ញុំទាំងពីរ កើតផ្សេងគ្នា ។*

**បុរិមានំ ជិនគ្គានំ សង្គមំ តេ និទស្សិតំ**
**អធិការំ ពហុំ មយ្ហំ តុយ្ហត្ថាយ មហាមុនិ ។**

*បពិត្រព្រះមហាមុនី ការគប់រកនូវព្រះជិនស្រីដ៏ប្រសើរ ទាំងឡាយ ក្នុងកាលមុន ព្រះអង្គសម្តែងហើយដល់ខ្ញុំម្ចាស់ អធិការដ៏ច្រើន គឺខ្ញុំម្ចាស់ធ្វើហើយ ដើម្បីប្រយោជន៍ គឺការ ត្រាស់ដឹងនូវព្រះសព្វញ្ញុតញ្ញាណរបស់ព្រះអង្គ ។*

**យំ មយា បូរិតំ កម្មំ កុសលំ សរ មេ មុនិ**

តវត្ថាយ មហាវីរ បុញ្ញំ ឧបចិតំ មយា ។

*បពិត្រព្រះមហាមុនី កុសលកម្មណា ដែលខ្ញុំម្ចាស់បានបំពេញហើយ សូមព្រះអង្គរឭកនូវកុសលកម្មរបស់ខ្ញុំ បពិត្រព្រះមហាវីរៈ បុណ្យគឺខ្ញុំម្ចាស់សន្សំហើយ ដើម្បីប្រយោជន៍នៃការត្រាស់ដឹងនូវព្រះសព្វញ្ញុតញ្ញាណរបស់ព្រះអង្គ ។*

អកព្វដ្ឋានេ វជ្ជេត្វា វារយន្តិ អនាចារំ
តវត្ថាយ មហាវីរ ចត្តំ មេ ជីវិតំ ពហុំ ។

*បពិត្រព្រះមហាវីរៈ ខ្ញុំម្ចាស់វៀរនូវឋានៈ មិនសមគួរទាំងឡាយ ហាមឃាត់នូវអនាចារ នៃជីវិតដ៏ច្រើន ខ្ញុំម្ចាស់លះបង់ហើយ ដើម្បីប្រយោជន៍នៃការត្រាស់ដឹង នូវព្រះសព្វញ្ញុតញ្ញាណរបស់ព្រះអង្គ ។*

ឯវំ ពហុវិធំ ទុក្ខំ សម្បត្តិ ច ពហុព្វិធា
បច្ឆិមេ ភវេ សម្បត្តេ ជាតា សាវត្ថិយំ បុរេ ។

*សេចក្តីទុក្ខច្រើនប្រការ និងសម្បត្តិច្រើនប្រការ គឺខ្ញុំម្ចាស់បានទទួលហើយយ៉ាងនេះ លុះដល់ភពចុងក្រោយ ខ្ញុំម្ចាស់បានកើតក្នុងក្រុងសាវត្ថី ។*

មហាធនសេដ្ឋិកុលេ សុខិតេ សជ្ជិតេ តថា
នានារតនបជ្ជោតេ សព្វកាមសមិទ្ធិនេ ។

*ក្នុងត្រកូលមហាធនសេដ្ឋី មានសេចក្ដីសុខ មានការចាត់ចែងល្អ រុងរឿងដោយរតនៈផ្សេងៗ សម្រេចតាមសេចក្ដីប្រាថ្នាគ្រប់យ៉ាង ។*

**សក្កតា បូជិតា ចេវ មានិតាបចិតា តថា**
**រូបសិរិមនុប្បត្តា កុលេសុ អភិសក្កតា ។**

*ខ្ញុំម្ចាស់ជាស្រីត្រូវគេធ្វើសក្ការៈ បូជា រាប់អាន និងគោរពកោតក្រែង ជាស្រីដល់តាមលំដាប់នូវរូបសិរី ដែលពួកជនក្នុងត្រកូលទាំងឡាយ ធ្វើសក្ការៈយ៉ាងក្រៃលែង ។*

**អតីវ បត្ថិតា ចាសឹ រូបសោភសិរីហិ ច**
**បត្ថិតា សេដ្ឋិបុត្តេហិ អនេកេហិ សតេហិបិ ។**

*ខ្ញុំម្ចាស់ជាស្រី ដែលពួកជនអ្នកមានសិរី ដោយលម្អនៃរូបប្រាថ្នាហើយ ដែលពួកកូនសេដ្ឋីច្រើនរយ ប្រាថ្នាហើយផង ។*

**អគារំ បជហិត្វាន បព្វជឹ អនគារិយំ**
**អឌ្ឍមាសេ អសម្បត្តេ ចតុសច្ចមបាបុណឹ ។**

*ខ្ញុំលះបង់នូវផ្ទះ ហើយបួស ដល់នូវភាពនៃខ្លួនមិនមានប្រយោជន៍ដោយការផ្ទះក្នុងផ្ទះ មិនទាន់ដល់កន្លះខែ ក៏បានលុះនូវសច្ចៈ ៤ ។*

**តទ្ធិយា អភិនិម្មិត្វា ចតុរស្សំ រថំ អហំ**

**ពុទ្ធស្ស ចាហំ វន្ទិស្សំ លោកនាថស្ស តាទិនោ ។**

*ខ្ញុំនិម្មិតនូវរថមានជ្រុង ៤ ដោយឫទ្ធិ ហើយថ្វាយបង្គំនូវព្រះបាទារបស់ព្រះពុទ្ធ ទ្រង់មានព្រះហឫទ័យនឹងធឹង ជាទីពឹងនៃសត្វលោក ។*

**ឥទ្ធីសុ ច វសី ហោមិ ទិព្វាយ សោតធាតុយា**
**ចេតោបរិយញ្ញាណស្ស វសី ហោមិ មហាមុនេ ។**

*បពិត្រព្រះមហាមុនី ខ្ញុំម្ចាស់ស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយផង ក្នុងសោតធាតុដ៏ជាទិព្វផង ស្ទាត់ជំនាញក្នុងចេតោ-បរិយញ្ញាណផង ។*

**បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុ វិសោធិតំ**
**សព្វាសវបរិក្ខីណា នត្ថិ ទានិ បុនព្ភវោ ។**

*ខ្ញុំម្ចាស់ដឹងនូវបុព្វេនិវាសក្នុងខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន ទិព្វចក្ខុខ្ញុំម្ចាស់បានជម្រះហើយ អាសវៈទាំងពួងអស់រលីងហើយ ភពថ្មីមិនមានទៀតទេ ក្នុងកាលឥឡូវនេះ ។*

**អត្ថធម្មនិរុត្តីសុ បដិភានេ តថេវ ច**
**ញាណំ មេ វិមលំ សុទ្ធំ បភាវេន មហេសិនោ ។**

*ញាណរបស់ខ្ញុំម្ចាស់ ប្រាសចាកមន្ទិល ស្អាតបរិសុទ្ធក្នុងអត្ថធម្ម និរុត្តិ និងបដិភាណ ព្រោះតេជះនៃព្រះមហេសី ។*

**ចីវរំ បិណ្ឌបាតញ្ច បច្ចយំ សយនាសនំ**
**ខណេន ឧបនាមេន្តិ សហស្សានិ សមន្តតោ ។**

*ត្រកូលច្រើនពាន់ដោយជុំវិញ បានបង្អោននូវចីវរ បិណ្ឌបាត សេនាសនប្បច្ច័យ ( ដល់ខ្ញុំម្ចាស់ ) ដោយមួយរំពេច ។*

**ជិនោ តម្ហិ គុណេ តុដ្ឋោ ឯតទគ្គេ ឋបេសិ មំ**
**អគ្គា ឥទ្ធិមតីនន្តិ បរិសាសុ វិនាយកោ ។**

*ព្រះជិនស្រី ទ្រង់ជាវិនាយក ដឹកនាំនូវសត្វលោកដោយវិសេស ទ្រង់មានព្រះហឫទ័យត្រេកអរក្នុងគុណរបស់ខ្ញុំ បានតាំងទុកនូវខ្ញុំក្នុងឯតទគ្គៈ ក្នុងបរិស័ទទាំងឡាយថា ឧប្បលវណ្ណាភិក្ខុនី ប្រសើរបំផុតជាងភិក្ខុនីទាំងឡាយ ផ្នែកខាងមានឫទ្ធិ ។*

**បរិចិណ្ណោ មយា សត្ថា កតំ ពុទ្ធស្ស សាសនំ**
**ឱហិតោ គរុកោ ភារោ ភវនេត្តិសមូហតា ។**

*ព្រះសាស្ដា ខ្ញុំបានប្រព្រឹត្តតាមហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ ខ្ញុំទម្លាក់ចោលហើយ ទាំងតណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានគាស់រម្លើងចេញហើយ ។*

**យស្សត្ថាយ បព្វជិតា អគារស្មានគារិយំ**
**សោ មេ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោ ។**

*ខ្ញុំបានចេញចាកផ្ទះ ចូលទៅកាន់ផ្នួស មិនមានប្រយោជន៍ដោយការនៅក្នុងផ្ទះ ដើម្បីប្រយោជន៍ដល់គុណវិសេសណា ប្រយោជន៍គឺគុណវិសេសនោះ ជាគ្រឿងអស់ទៅនៃសំយោជនៈទាំងអស់ ខ្ញុំបានដល់តាមលំដាប់ហើយ ។*

**កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា**
**ជាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។**

*កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រម្លើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។*

**ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ**
**តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។**

*ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់ព្រះពុទ្ធជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។*

**បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ**
**ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។**

*បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន*

*ប្រតិបត្តិហើយ*[១] ។

*ចំណែកក្នុងគម្ពីរអបទាន បិដកខ្មែរ មានសេចក្តីដូចតទៅនេះថា*

**ភិក្ខុនី ឧប្បលវណ្ណា ឥទ្ធិយា បារមឹ គតា**
**វន្ទិត្វា សត្ថុនោ បាទេ ឥមំ វចនមព្រវិ ។**

*ឧប្បលវណ្ណាភិក្ខុនី ដល់នូវត្រើយនៃឫទ្ធិ បានថ្វាយបង្គំព្រះបាទាព្រះសាស្តា ហើយពោលនូវពាក្យនេះថា*

**និតិណ្ណា ជាតិសំសារំ បត្តាហំ អចលំ បទំ**
**សព្វទុក្ខំ មយា ខីណំ អារោចេមិ មហាមុនិ ។**

*បពិត្រព្រះមហាមុនី ខ្ញុំម្ចាស់ឆ្លងផុតនូវជាតិសង្សារហើយ ដល់នូវព្រះនិព្វាន ជាទីមិនកម្រើក ខ្ញុំម្ចាស់សូមក្រាបទូលនូវទុក្ខទាំងពួង របស់ខ្ញុំម្ចាស់ដែលអស់ហើយ ។*

**យាវតា បរិសា អត្ថិ បសន្នា ជិនសាសនេ**
**យេសញ្ច មេបរាធោត្ថិ ខមន្តុ ជិនសម្មុខា ។**

*ពួកបរិស័ទទាំងប៉ុន្មាន ជ្រះថ្លាក្នុងសាសនានៃព្រះជិនស្រី កំហុសរបស់ខ្ញុំម្ចាស់ មានចំពោះពួកជនណា សូមពួកជន*

---

*១-អបទានគាថាទាំងនេះ មាននៅក្នុងអដ្ឋកថា ថេរីគាថា ច្បាប់ឆដ្ឋសង្គាយនា លើសខ្វះគ្នាខ្វះនឹងអបទានក្នុងបិដកឆដ្ឋសង្គាយនា និងនៅក្នុងគម្ពីរថេរិយាបទាន បិដកខ្មែរ ។*

នោះ អត់ទោស ក្នុងទីចំពោះព្រះភក្ត្រនៃព្រះជិនស្រី ឲ្យទាន ។

**សំសារេ សំសរន្តា មេ ខលិតំ មេ សចេ ភវេ**
**អាភោចេមិ មហាវីរ អបរាធំ ខមស្សុ មេ ។**

បពិត្រព្រះអង្គជាមហាវីរបុរស ខ្ញុំម្ចាស់កំពុងអន្ទោលទៅក្នុងសង្សារ បើខ្ញុំម្ចាស់មានសេចក្តីភ្ញាត់ភ្ញាំង ខ្ញុំម្ចាស់សូមអង្វរសូមព្រះអង្គអត់ទោស ចំពោះកំហុសនៃខ្ញុំម្ចាស់នោះ ។

**ឥទ្ធិញ្ចាបិ និទស្សេហិ មម សាសនការិកេ**
**ចតស្សោ បរិសា អជ្ជ កង្ខំ ឆិន្ទាហិ យាវតា ។**

ម្នាលនាង អ្នកធ្វើតាមសាសនារបស់តថាគត បើដូច្នោះចូរនាងសម្តែងនូវឫទ្ធិចុះ ចូរនាងញុំាងបរិស័ទទាំង ៤ ឲ្យកាត់នូវសេចក្តីសង្ស័យទាំងប៉ុន្មាន ក្នុងថ្ងៃនេះចុះ ។

**ធីតា តុយ្ហំ មហាវីរ បញ្ញវន្ត ជុតិន្ធរ**
**ពហុញ្ច ទុក្ករំ កម្មំ កតំ មេ អតិទុក្ករំ ។**

បពិត្រព្រះអង្គជាមហាវីរបុរស ទ្រង់មានបញ្ញា ទ្រទ្រង់នូវសេចក្តីរុងរឿង ខ្ញុំម្ចាស់ជាធីតារបស់ព្រះអង្គ ចំណែកខាងអំពើដ៏ច្រើន ដែលគេកម្រធ្វើបាន ខ្ញុំព្រះអង្គបានធ្វើឲ្យជាអំពើ រឹតតែកម្រក្រៃលែង ។

**ឧប្បលស្សេវ មេ វណ្ណោ ជាមេនុប្បលនាមិកា**
**សា ធីតា តេ មហាវីរ ចាទេ វន្ទាមិ ចក្ខុមា ។**

*បពិត្រព្រះអង្គជាមហាវីរបុរស ទ្រង់មានបញ្ញាចក្ខុ សម្បុរ របស់ខ្ញុំម្ចាស់ ដូចជាសម្បុរនៃផ្កាឧប្បល ខ្ញុំម្ចាស់មានឈ្មោះ ថា ឧប្បលវណ្ណា ជាធីតារបស់ព្រះអង្គ សូមថ្វាយបង្គំព្រះ បាទា ។*

**រាហុលោ ច អហាញ្ចេវ- នេកជាតិសតេ ពហូ**
**ឯកស្មឹ សម្ភវេ ជាតា សមានឆន្ទចេតសា ។**

*ព្រះរាហុលត្ថេរនិងខ្ញុំម្ចាស់ ធ្លាប់កើតក្នុងភពតែមួយ អស់ រយនៃជាតិជាច្រើន ជាអ្នកមានចិត្តនិងឆន្ទៈស្មើគ្នា ។*

**និព្វត្តិ ឯកតោ ហោតិ ជាតិយា ចាបិ ឯកតោ**
**បច្ឆិមេ ភវសម្បត្តេ ឧភយោ នាមសម្ភវា ។**

*ការកើតឡើងក្នុងទីជាមួយគ្នា ក៏មាន ក្នុងជាតិជាមួយគ្នា ក៏ មាន លុះដល់បច្ឆិមភព ជនទាំងពីរនាក់ កើតដោយឈ្មោះ ( ផ្សេងគ្នា ) ។*

**បុត្តោ ច រាហុលោ នាម ធីតា ឧប្បលសវ្ហយា**
**បស្ស វីរ មមំ ឥទ្ធឹ ពលំ ទស្សេមិ សត្ថុនោ ។**

*ព្រះរាជបុត្ត បានមកជាកុមារ ឈ្មោះរាហុល ខ្ញុំម្ចាស់បាន*

*មកជាធីតា ឈ្មោះឧប្បលវណ្ណា បពិត្រព្រះអង្គជាវីរបុរស សូមព្រះអង្គទតឫទ្ធិនៃខ្ញុំម្ចាស់ចុះ ខ្ញុំម្ចាស់នឹងសម្តែងកម្លាំងថ្វាយព្រះសាស្តា ។*

**មហាសមុទ្ទេ ចតុរោ បក្ខិបិ ហត្ថចាណិយំ**
**តេលំ ហត្ថគតញ្ចេវ វិឡោ កោមារកោ យថា ។**

*នាងឧប្បលវណ្ណា ដាក់មហាសមុទ្ទទាំង ៤ លើផ្ទៃបាតដៃ ហាក់ដូចកូនក្មេងលេងប្រេង ដែលតាំងនៅលើបាតដៃ ។*

**ឧព្វត្តយិត្វា បឋវឹ បក្ខិបិ ហត្ថចាណិយំ**
**ចិត្តមុញ្ជំ យថា ឆាម លុញ្ចិ កោមារកោ យុវា ។**

*នាងឧប្បលវណ្ណាធ្លុះផែនដី ដាក់លើផ្ទៃបាតដៃ ដូចជាក្មេងជំទង់ ដកនូវស្មៅយាប្លង់ដ៏វិចិត្រ ។*

**ចក្កវាឡសមំ ចាណឹ ឆទយិត្វាន មត្ថកេ**
**វស្សាបេត្វាន ផុសិតំ នានាវណ្ណំ បុនប្បុនំ ។**

*នាងឧប្បលវណ្ណា បាំងនូវបាតដៃស្មើចក្កវាឡ លើក្បាល ហើយញុំាងគ្រាប់ភ្លៀង មានពណ៌ផ្សេង ៗ ឲ្យធ្លាក់ចុះ ។*

**ភូមឹ ឧទុក្ខលំ កត្វា ធញ្ញំ កត្វាន សក្ខរំ**
**សិនេរុំ មុសលំ កត្វា មទ្ទិ កោមារិកា យថា ។**

*នាងធ្វើផែនដីជាត្បាល់ ធ្វើក្រួសជាស្រូវ ធ្វើភ្នំសិនេរុជា*

*អង្រ្វែ ដូចក្មេងស្រីបុកស្រូវ ។*

**ធីតាហំ ពុទ្ធសេដ្ឋស្ស ជាមេឧប្បលសវ្ហយា**
**អភិញ្ញាសុ វសីភូតា តវ សាសនការិកា ។**

*ខ្ញុំម្ចាស់ឈ្មោះឧប្បលវណ្ណា ជាធីតារបស់ព្រះពុទ្ធដ៏ប្រសើរ ជាអ្នកស្ទាត់ក្នុងអភិញ្ញាទាំងឡាយ ជាអ្នកធ្វើតាមសាសនារបស់ព្រះពុទ្ធអង្គ ។*

**ជានាវិកុព្វនំ កត្វា ទស្សេត្វា លោកនាយកំ**
**នាមគោត្តំ បកាសេត្វា ចាទេ វន្ទាមិ ចក្ខុមា ។**

*បពិត្រព្រះអង្គមានបញ្ញាចក្ខុ ខ្ញុំម្ចាស់សូមធ្វើនូវវិកុព្វនឫទ្ធិផ្សេងៗ សម្តែងថ្វាយព្រះលោកនាយក ហើយប្រកាសនូវនាមនិងគោត្ត ទើបថ្វាយបង្គំព្រះបាទាព្រះអង្គ ។*

**ឥទ្ធិយា ច វសី ហោមិ ទិព្វាយ សោតធាតុយា**
**ចេតោបរិយញ្ញាណស្ស វសី ហោមិ មហាមុនេ ។**

*បពិត្រព្រះមហាមុនី ខ្ញុំម្ចាស់ជាអ្នកស្ទាត់ក្នុងឫទ្ធិផង ក្នុងទិព្វសោតធាតុឫទ្ធិផង ជាអ្នកស្ទាត់ក្នុងចេតោបរិយញ្ញាណផង ។*

**បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ**
**សព្វាសវា បរិក្ខីណា នត្ថិ ទានិ បុនព្ភវោ ។**

ខ្ញុំម្ចាស់ដឹងនូវបុព្វេនិវាស ទាំងទិព្វចក្ខុ ក៏ខ្ញុំម្ចាស់ជម្រះហើយ អាសវៈទាំងអស់ ក៏អស់រលីងហើយ ឥឡូវនេះភពថ្មីទៀត មិនមានទៀតទេ ។

**អត្ថធម្មនិរុត្តីសុ បដិភាណេ តថេវ ច**
**ញាណំ មេ វិបុលំ សុទ្ធំ សភាវេន មហេសិនោ ។**

ញាណរបស់ខ្ញុំម្ចាស់ ដ៏ទូលាយស្អាតក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ តាមសភាពរបស់ព្រះពុទ្ធជាមហេសី ។

**បុរិមានំ ជិនគ្គានំ សង្គាមេន្តេន ចស្សិតំ**
**អធិការំ ពហុ មយ្ហំ តុយ្ហត្ថាយ មហាមុនិ ។**

បពិត្រព្រះមហាមុនី ព្រះអង្គធ្លាប់សម្តែងនូវសង្គ្រាម ចំពោះព្រះជិនស្រីដ៏ប្រសើរទាំងឡាយ ក្នុងកាលមុន កិច្ចការដ៏ក្រៃលែងច្រើនយ៉ាងរបស់ខ្ញុំម្ចាស់ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ព្រះអង្គ ។

**យំ មយា បុរិមំ កម្មំ កុសលំ សរ មេ មុនិ**
**តវត្ថាយ មហាវីរ បុញ្ញំ ឧបចិតំ មយា ។**

បពិត្រព្រះមហាមុនី អំពើណាមានក្នុងកាលមុន ដែលខ្ញុំម្ចាស់ធ្វើហើយ សូមព្រះអង្គរឭកនូវអំពើជាកុសលរបស់ខ្ញុំម្ចាស់នោះ បពិត្រព្រះមហាវីរបុរស បុណ្យដែលខ្ញុំម្ចាស់

*សន្សំទុកហើយ ដើម្បីប្រយោជន៍ដល់ព្រះអង្គ ។*

**អកព្ភដ្ឋានេ វជ្ជេត្វា បរិចាចេត្តា អជាចារំ**
**តវត្ថាយ មហាវីរ ចត្តំ មេ ជីវិតុត្តមំ ។**

*បពិត្រព្រះអង្គជាមហាវីរបុរស ខ្ញុំម្ចាស់វៀរ ( នូវអំពើ ) ក្នុងទីមិនគួរ ហើយបានទាត់ចោលនូវអានាចារ ជីវិតដ៏ឧត្តមដែលខ្ញុំម្ចាស់លះបង់ហើយ ដើម្បីប្រយោជន៍ដល់ព្រះអង្គ ។*

**ទសកោដិសហស្សានិ អទាសិ មម ជីវិតំ**
**បរិចត្តា ច មេ ហោមិ តវត្ថាយ មហាមុនិ ។**

*បពិត្រព្រះមហាមុនី ព្រះអង្គបានប្រទានជីវិតដល់ខ្ញុំម្ចាស់អស់ ១០ ពាន់កោដិ ទាំងខ្លួនខ្ញុំម្ចាស់ ដែលខ្ញុំម្ចាស់បានលះបង់ហើយ ដើម្បីប្រយោជន៍ដល់ព្រះអង្គ ។*

**តជាតិវិម្ហិតា សព្វា សិរសាវ កតញ្ជលី**
**អវោចយុំ កតំ អាសិ អតុលិទ្ធិ បរក្កមា ។**

*គ្រានោះ បរិស័ទទាំងអស់ ស្ញប់ស្ញែងក្រៃលែង ធ្វើអញ្ជលីដោយត្បូង ពោលថា បពិត្រនាងម្ចាស់ សេចក្ដីព្យាយាមមានឫទ្ធិថ្លឹងមិនបាន ដែលនាងធ្វើហើយ តើដូចម្ដេច ។*

**សតសហស្សេ ឥតោ កប្បេ ជាតកញ្ញា អហំ តទា**
**វិមលា ជាម ជាមេន កញ្ញានំ សាធុសម្មតា ។**

*ក្នុងកប្បទីមួយសែន អំពីកប្បនេះ កាលនោះ ខ្ញុំកើតជាកញ្ញានៃនាគ ឈ្មោះនាងវិមលា ដែលគេសន្មតហៅថា ស្រីល្អ ជាងនាគកញ្ញាទាំងឡាយ ។*

មហោរគោ មហានាគោ   បសន្នោ ជិនសាសនេ
បទុមុត្តរំ មហាតេជំ   និមន្តេសិ សសាវកំ ។

*ពស់ធំ ឈ្មោះមហានាគ ជ្រះថ្លាក្នុងសាសនានៃព្រះជិនស្រី បាននិមន្តព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់មានតេជៈច្រើន ព្រមទាំងសាវ័ក ។*

រតនមយញ្ច មណ្ឌបំ   បល្លង្កំ រតនាមយំ
រតនវាលុកាកិណ្ណំ   ឧបភោគំ រតនាមយំ ។

*មហានាគនោះ បានរៀបចំនូវមណ្ឌប ជាវិការៈនៃកែវផង នូវបល្ល័ង្ក ជាវិការៈនៃកែវផង នូវគ្រឿងឧបភោគ ជាវិការៈនៃកែវ ដែលលាយដោយខ្សាច់ ជាវិការៈនៃកែវផង ។*

មគ្គញ្ច បដិយាទេសិ   រតនធជភូសិតំ
បច្ចុគ្គន្ត្វាន សម្ពុទ្ធំ   វជ្ជន្តោ តុរិយេហិ សោ ។

*នូវផ្លូវដែលស្អិតស្អាងដោយទង់ជ័យ ជាវិការៈនៃកែវផង ហើយប្រគំដោយតូរ្យតន្ត្រី ទទួលព្រះសម្ពុទ្ធ ។*

បរិសាហិ ច ចតូហិ   ផរតេ លោកនាយកោ

មហោរគស្ស ភវនេ និសីទិ បរមាសនេ ។

*ចំណែកខាងព្រះលោកនាយក ដែលបរិស័ទទាំង ៤ បានហែហមហើយ ទ្រង់គង់លើអាសនៈដ៏ប្រសើរ ក្នុងលំនៅនៃមហានាគ ។*

អន្នចានំ ខាទនីយំ ភោជនញ្ច មហារហំ
វរំ វរញ្ច ចាទាសិ នាគរាជា មហាយសំ ។

*ស្ដេចនាគបានថ្វាយនូវបាយទឹកផង នូវភោជនដែលគួរបរិភោគ មានថ្លៃច្រើនផង នូវពរដ៏ប្រសើរផង ចំពោះព្រះពុទ្ធទ្រង់មានយសធំ ។*

ភុញ្ជិត្វាន ស សម្ពុទ្ធោ បត្តេ ធោវិត្វា យោនិសោ
អនុមោទនិយំកាសិ នាគកញ្ញា មហិទ្ធិកា ។

*លុះព្រះសម្ពុទ្ធនោះ ទ្រង់សោយហើយ ទ្រង់លាងបាត្រហើយធ្វើអនុមោទនា ដោយឧបាយនៃប្រាជ្ញាថា ចូរនាងនាគកញ្ញា មានឫទ្ធិច្រើនចុះ ។*

សព្វញ្ញុំ ផុស្សិតំ ទិស្វា នាគកញ្ញា មហាយសំ
បសន្នំ សត្ថុនោ ចិត្តំ សុនិវត្ថញ្ច មានសំ ។

*នាងនាគកញ្ញា បានឃើញព្រះសព្វញ្ញុពុទ្ធ ដែលទ្រង់ស្រស់បស់ មានយសច្រើន ចិត្តក៏ជ្រះថ្លាចំពោះព្រះសាស្ដា*

*ផង ចិត្តក៏ប្រតិព័ទ្ធចំពោះព្រះសាស្តាផង ។*

**មមញ្ច ចិត្តមញ្ញាយ ជលជុត្តមជាមកោ**
**តស្មឹ ខណេ មហាវីរោ ភិក្ខុនឹ ឧស្សយិទ្ធិយា ។**

*ក្នុងខណៈនោះ ព្រះសម្ពុទ្ធជាមហាវីរបុរស ព្រះនាម បទុមុត្តរៈ ជ្រាបច្បាស់នូវចិត្តរបស់ខ្ញុំ ទ្រង់បង្ហាញនូវភិក្ខុនី ដោយឫទ្ធិ ។*

**ឥទ្ធី អនេកា ទស្សេសិ ភិក្ខុនី សា វិសារទា**
**បមោទិតា វេទជាតា សត្ថារំ ឯតទព្រវី ។**

*ភិក្ខុនីនោះ ក្លៀវក្លា សម្តែងនូវឫទ្ធិច្រើនប្រការ ខ្ញុំក៏រីករាយ ត្រេកអរ បានពោលពាក្យនេះ ចំពោះព្រះសាស្តាថា*

**អទ្ទសាហំ ឥមា ឥទ្ធី សុមិតា ឥតរាយបិ**
**កថំ អហោសិ សា ធីរ ឥទ្ធិយា សុវិសារទា ។**

*បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ខ្ញុំម្ចាស់បានឃើញឫទ្ធិទាំងនេះ ដែលរាប់ថា ក្រៃលែងជាងឫទ្ធិឯទៀត ភិក្ខុនីនោះ ក្លៀវក្លា ដោយឫទ្ធិខ្លាំងម្ល៉េះ តើដោយប្រការដូចម្តេច ។*

**ឱរសា មុខតោ ជាតា ធីតា មម មហិទ្ធិកា**
**មមានុសាសនីការា ឥទ្ធិយា សុវិសារទា ។**

*ភិក្ខុនីនេះ ជាធីតា ជាឱរសកើតអំពីមាត់របស់តថាគត ទើប*

ជាភិក្ខុនីមានឫទ្ធិច្រើន ជាអ្នកធ្វើតាមអនុសាសនីរបស់តថាគត បានជាមានសេចក្តីក្លៀវក្លាក្រៃលែងដោយឫទ្ធិ ។

**ពុទ្ធស្ស វចនំ សុត្វា តុដ្ឋា ឯវំ អវោចហំ**
**អហំបិ តាទិសា ហោមិ ឥទ្ធិយា សុវិសារទា ។**

លុះខ្ញុំស្តាប់ព្រះវាចានៃព្រះពុទ្ធហើយ ក៏ត្រេកអរ ពោលនូវពាក្យយ៉ាងនេះថា សូមឲ្យខ្ញុំម្ចាស់ជាស្ត្រីក្លៀវក្លាក្រៃលែងដោយឫទ្ធិ ប្រាកដដូចជាភិក្ខុនីនោះ ។

**បមោទិតាហំ សុមនា បត្តឧត្តមមានសា**
**អនាគតម្ហិ អទ្ធានេ ឦទិសា ហោមិ នាយក ។**

បពិត្រព្រះអង្គជានាយក ខ្ញុំម្ចាស់មានចិត្តអរសប្បាយរីករាយ មានចិត្តខ្ពង់ខ្ពស់ សូមឲ្យបានដូចភិក្ខុនីនេះ ក្នុងកាលអនាគតពុំខាន ។

**មណិមយញ្ច បល្លង្កំ មណ្ឌបញ្ច បភស្សរំ**
**អន្នបានេន តប្បេត្វា សសង្ឃំ លោកនាយកំ ។**

( ខ្ញុំបានថ្វាយ ) នូវបល្ល័ង្កជាវិការៈនៃកែវមណីផង នូវមណ្ឌបដ៏ភ្លឺផ្ទេកផង ហើយញ៉ាំងព្រះពុទ្ធជាលោកនាយក ព្រមទាំងព្រះសង្ឃ ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹក ។

**នាគានំ បវរំ បុប្ផំ អរុណំ នាម ឧប្បលំ**

វណ្ណំ មេ ឦទិសំ ហោតុ   បូជេសឹ លោកនាយកំ ។

*ខ្ញុំបូជាផ្កាឧប្បល ឈ្មោះអរុណ ជាផ្កាដ៏ប្រសើរ របស់ពួកនាគចំពោះព្រះពុទ្ធ ជាលោកនាយក ហើយសូមឲ្យពណ៌សម្បុររបស់ខ្ញុំដូចផ្កានេះ ។*

តេន កម្មេន សុកតេន   ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ   តាវត្តឹសំ អគញ្ឆហំ ។

*ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។*

តតោ ចុតាហំ មនុជេ   ឧបបន្នា សយម្ភុនោ
ឧប្បលេហិ បដិច្ឆន្នំ   បិណ្ឌបាតមទាសហំ ។

*លុះខ្ញុំច្យុតចាកឋានតាវត្តិង្សនោះហើយ ក៏មកកើតក្នុងឋានមនុស្ស បានថ្វាយបិណ្ឌបាតដែលបិទបាំងដោយផ្កាឧប្បលទាំងឡាយ ចំពោះព្រះពុទ្ធជាសយម្ភូ ។*

ឯកនវុតេ ឥតោ កប្បេ   វិបស្សី នាម នាយកោ
ឧប្បជ្ជិ ចារុនយនោ   សព្វធម្មេសុ ចក្ខុមា ។

*ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះពុទ្ធជានាយក ព្រះនាមវិបស្សី មានព្រះនេត្រដ៏ភ្លឺថ្លា មានបញ្ញាចក្ខុក្នុងធម៌ទាំងពួង*

*ទ្រង់កើតឡើង ។*

សេដ្ឋិធីតា តទា ហុត្វា ពារាណសិបុរុត្តមេ
និមន្តេត្វាន សម្ពុទ្ធំ សសង្ឃំ លោកនាយកំ ។

*ក្នុងកាលនោះ ខ្ញុំបានកើតជាសេដ្ឋីធីតា ក្នុងបុរីដ៏ឧត្តម ឈ្មោះពារាណសី បាននិមន្តព្រះសម្ពុទ្ធជាលោកនាយក ព្រមទាំងព្រះសង្ឃ ។*

មហាទានំ ទទិត្វាន ឧប្បលេហិ វិនាយកំ
បូជយិត្វា ច តថេហេវ វណ្ណសោភំ អបត្ថយឹ ។

*ខ្ញុំថ្វាយមហាទាន បូជាព្រះពុទ្ធជានាយក ដោយផ្កាឧប្បលទាំងឡាយ ហើយប្រាថ្នាឲ្យមានពណ៌សម្បុរល្អ ដូចផ្កាឧប្បលទាំងនោះ ។*

ឥមម្ហិ ភទ្ទកេ កប្បេ ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន ឧប្បជ្ជិ វទតំ វរោ ។

*ក្នុងភទ្ទកប្បនេះ ព្រះពុទ្ធព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ មានយសច្រើន ប្រសើរជាងពួកជនអ្នកពោលទ្រង់កើតឡើង ។*

ឧបដ្ឋាកោ មហេសិស្ស តទា អាសិ នរិស្សរោ
កាសិរាជា កិកី នាម ពារាណសិបុរុត្តមេ ។

*គ្រានោះ ព្រះរាជាដែនកាសី ព្រះនាមកិកី ជាឥស្សរៈលើប្រជាជន ក្នុងពារាណសីបុរីដ៏ប្រសើរ បានជាឧបដ្ឋាកនៃព្រះពុទ្ធជាមហេសី ។*

តស្សាសឹ ទុតិយា ធីតា សមណីគុត្តសវ្ហយា
ធម្មំ សុត្វា ជិនគ្គស្ស បព្វជ្ជំ សមរោចយឹ ។

*ខ្ញុំជាធីតាទីពីររបស់ព្រះរាជាអង្គនោះ ឈ្មោះនាងសមណីគុត្តា បានស្តាប់ធម៌របស់ព្រះពុទ្ធជិនស្រី ជាបុគ្គលប្រសើរ ហើយពេញចិត្តនឹងបព្វជ្ជា ។*

អនុជានិ ន នោ តាតោ អគារេវ តទា មយំ
វីសំ វស្សសហស្សានិ វិចរិម្ហ អតន្ទិតា ។
កោមារិព្រហ្មចរិយំ រាជកញ្ញា សុខេធិតា
ពុទ្ធោបដ្ឋាននិរតា មុទិតា សត្ត ធីតរោ ។

*ក្នុងគ្រានោះ ព្រះវររាជបិតារបស់យើង ទ្រង់មិនអនុញ្ញាត យើងក៏មិនខ្ជិលច្រអូស ប្រព្រឹត្តព្រហ្មចរិយៈសម្រាប់កុមារីអស់ ២០ ពាន់ឆ្នាំ នៅក្នុងផ្ទះ ជាព្រះរាជកញ្ញា បិតនៅក្នុងសេចក្តីសុខ ត្រេកអររីករាយក្នុងការបម្រើព្រះពុទ្ធ ជាព្រះរាជធីតា ៧ អង្គ ។*

សមណី សមណគុត្តា ច ភិក្ខុនី ភិក្ខុទាសិកា

**ធម្មា ចេវ សុធម្មា ច សត្តមី សង្ឃទាសិកា ។**

*គឺនាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកា ជាគម្រប់ប្រាំពីរ ។*

**អហំ ខេមា ច សប្បញ្ញា បដាចារា ច កុណ្ឌលា**

**កិសាគោតមី ធម្មទិន្នា វិសាខា ហោតិ សត្តមី ។**

*( ក្នុងពុទ្ធុប្បាទព្រះសមណគោតមនេះ ជីតាទាំងនោះ បានមកជា ) ខ្លួនខ្ញុំ ១ នាងខេមាមានប្រាជ្ញា ១ បដាចារា ១ កុណ្ឌលកេសី ១ កិសាគោតមី ១ ធម្មទិន្នា ១ វិសាខា ជាគម្រប់ប្រាំពីរ ។*

**តេហិ កម្មេហិ សុកតេហិ ចេតនាបណិធីហិ ច**

**ជហិត្វា មានុសំ ទេហំ តាវត្តឹសំ អគញ្ឆហំ ។**

*ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។*

**តតោ ចុតា មនុស្សេសុ ឧបបន្នា មហាកុលេ**

**បីតមដ្ឋរំ ធុស្សំ អជំ អរហតោ អហំ ។**

*លុះច្យុតចាកឋានតាវត្តិង្សនោះហើយ ក៏មកកើតក្នុងមនុស្សត្រកូលធំ បានថ្វាយនូវសំពត់សាច់ម៉ដ្ឋ មានពណ៌លឿង*

*ដល់ព្រះអរហន្ត ។*

តតោ ចុតា អរិដ្ឋបុរេ ជាតា វិប្បកុលេ អហំ
ធីតា តិរិដិវច្ឆស្ស ឧម្មាទន្តី មនោហរា ។

*លុះខ្ញុំច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងអរិដ្ឋបុរី ក្នុងត្រកូលព្រាហ្មណ៍ ជាធីតានៃតិរិដិវច្ឆសេដ្ឋី ឈ្មោះនាងឧម្មាទន្តី ជាទីពេញចិត្ត ( របស់ជន ) ។*

តតោ ចុតា ជនបទេ កុលេ អញ្ញតរេ អហំ
បសុតា នាតិផីតម្ហិ សាលឹ គោបេមហន្តជា ។

*លុះខ្ញុំច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងជនបទ ក្នុងត្រកូលមួយ ជាអ្នកខ្វល់ខ្វាយ មិនជាអ្នកស្តុកស្តម្ភណាស់ណាទេ គ្រានោះ ខ្ញុំថែរក្សានូវស្រូវសាលី ។*

ទិស្វា បច្ចេកសម្ពុទ្ធំ បញ្ចលាជសតានហំ
ទត្វា បទុមឆន្នានិ បញ្ច បុត្តសតានិបិ ។
បត្ថយឹ តេសុ បុត្តេសុ មធុំ ទត្វា សយម្ភុនោ
តតោ ចុតា អរញ្ញេហំ អជាយឹ បទុមោទរេ ។

*ខ្ញុំបានឃើញព្រះបច្ចេកសម្ពុទ្ធ ហើយថ្វាយលាជប្រាំរយកន្សោង ដែលគ្របដោយផ្កាឈូក ហើយប្រាថ្នានូវកូនប្រាំរយរូប ខ្ញុំថ្វាយទឹកឃ្មុំដល់ព្រះពុទ្ធជាសយម្ភូ ព្រោះតែកូន*

*ទាំងនោះ លុះច្យុតចាកអត្តភាពនោះហើយ បានមកកើតក្នុងត្របកផ្កាឈូក នៅក្នុងព្រៃ ។*

**កាសិរញ្ញោ មហេសីហំ ហុត្វា សក្កតបូជិតា**
**អជនឹ រាជបុត្តានំ អដ្ឋវ សតបញ្ចកំ ។**

*ខ្ញុំបានជាមហេសីរបស់ស្តេចដែនកាសី ដែលគេធ្វើសក្ការ-បូជា បានបង្កើតព្រះរាជបុត្តចំនួនប្រាំរយឥតខ្វះ ។*

**យទា តេ យោព្វនប្បត្តា កីឡន្តា ជលកីឡិតំ**
**ទិស្វាន ឱបត្តបទុមំ អាសុំ បច្ចេកនាយកា ។**

*កាលណា ព្រះរាជបុត្តទាំងនោះ ដល់នូវវ័យចម្រើនឡើង កំពុងលេងល្បែងក្នុងទឹក បានឃើញស្លឹកនិងផ្កាឈូកសំយុង ចុះ ( មានចិត្តនឿយណាយក្នុងសង្ខារ ចម្រើនវិបស្សនា ) បានជាព្រះបច្ចេកពុទ្ធ ជានាយក ក្នុងកាលនោះ ។*

**សាហំ តេហិ វិនាភូតា សុតវរេហិ សោកិនី**
**ចុតា ឥសិគិលិបស្សេ គាមកម្ហិ អជាយិហំ ។**

*ខ្ញុំនោះ ជាអ្នកព្រាត់ប្រាសចាករាជបុត្តដ៏ប្រសើរទាំងនោះ ក៏មានសេចក្តីសោកស្តាយ លុះច្យុត ( ចាកអត្តភាពនោះហើយ ) បានមកកើតក្នុងស្រុកតូចមួយ ទៀបភ្នំឥសិគិលិ ។*

**យទា ពុទ្ធាសុតមតិ សុតានំ អត្តជោបិ ច**

**យាគុំ អាទាយ គច្ឆន្តិ អជ្ជ បច្ចេកនាយកោ ។**

*កាលណា ខ្ញុំមានចិត្តភ្ញាក់នឹកដល់កូន ដែលជាព្រះបច្ចេកពុទ្ធ ក៏នាំយកបបរដើរទៅ ដើម្បីកូនទាំងឡាយផង ដើម្បីខ្លួនផង ខ្ញុំបានឃើញព្រះបច្ចេកពុទ្ធជានាយក ៨ ព្រះអង្គ ។*

**ភិក្ខាយ គាមំ គច្ឆន្តេ និស្វា បុត្តេ អនុស្សរឹ**
**ខីរធារា វិនិក្ខន្តា តទា មេ បុត្តបេមសា ។**

*ដែលកំពុងដើរទៅកាន់ស្រុកដើម្បីភិក្ខា ក៏នឹករឭកកូនទាំងឡាយ កាលនោះ ទរនៃទឹកដោះរបស់ខ្ញុំក៏ខ្ចរចេញ ព្រោះសេចក្តីស្រឡាញ់ចំពោះកូន ។*

**តតោ តេសំ អហំ យាគុំ បសន្នា សេហិ បាណិភិ**
**តតោ ចុតាហំ តិទសំ នន្ទនំ ឧបបជ្ជហំ ។**

*លំដាប់នោះ ខ្ញុំជ្រះថ្លា បានប្រគេនបបរដល់ព្រះបច្ចេកពុទ្ធទាំងនោះ ដោយដៃរបស់ខ្លួន លុះច្យុតចាកអត្តភាពនោះ ក៏បានទៅកើតឯឧទ្យានឈ្មោះនន្ទនៈ ក្នុងឋានត្រៃត្រិង្ស ។*

**អនុភោត្វា សុខទុក្ខំ សំសរិត្វា ភវាភវេ**
**តវត្ថាយ មហាវីរ បរិច្ចត្តញ្ច ជីវិតំ ។**

*បពិត្រព្រះអង្គ ជាមហាវីរបុរស ខ្ញុំម្ចាស់បានទទួលសុខទុក្ខ អន្ទោលទៅក្នុងភពតូចភពធំ ទាំងជីវិត ក៏ខ្ញុំលះបង់ដើម្បី*

*ប្រយោជន៍នៃព្រះអង្គ ។*

ឯវំ ពហុវិធំ ទុក្ខំ សម្បត្តី ច ពហូវិធា
បច្ឆិមេ ភវសម្បត្តេ ជាតា សាវត្ថិយំ បុរេ ។

*សេចក្តីទុក្ខផ្សេង ៗ ជាច្រើនយ៉ាងក្តី សម្បត្តិផ្សេង ៗ ជាច្រើនក្តី (របស់ខ្ញុំ) រមែងមានយ៉ាងនេះឯង លុះដល់បច្ឆិមភព ខ្ញុំមកកើតក្នុងសាវត្ថីបុរី ។*

មហាធនេ សេដ្ឋិកុលេ សុខិតេ សជ្ឈិតេ តថា
នានារតនបជ្ជោតេ សព្វកាមសមិទ្ធិនេ ។

*ខ្ញុំកើតក្នុងត្រកូល នៃសេដ្ឋីមានទ្រព្យច្រើន ដល់នូវសេចក្តីសុខ ជាត្រកូលចាត់ចែងល្អហើយ រុងរឿងដោយរតនវត្ថុផ្សេង ៗ សម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង ។*

សក្កតបូជិតា ចេវ មានិតាបចិតា តថា
រូបសិរី អនុប្បត្តា កុលេសុ អតិសក្កតា ។

*ខ្ញុំត្រូវគេធ្វើសក្ការបូជាផង រាប់អានកោតក្រែងដូច្នោះផង ដល់នូវរូបសិរី ត្រូវគេធ្វើសក្ការៈក្រៃលែង ក្នុងត្រកូលទាំងឡាយ ។*

អតីវ បត្ថិតា ចាសឹ រូបភោគសិរីហិ ច
បត្ថិតា សេដ្ឋិបុត្តេហិ អនេកេហិ សតេហិ ច ។

*ខ្ញុំជាស្ត្រី ដែលពួកជនអ្នកមានសិរី ដោយរូបនិងភោគៈ ប្រាថ្នាលើសលុបផង ដែលពួកកូនសេដ្ឋីជាច្រើនរយនាក់ ប្រាថ្នាហើយផង ។*

អគារំ បជហិត្វាន បព្វជឹ អនគារិយំ
អឌ្ឍមាសេ អសម្បត្តេ ចតស្សច្ចំ អបាបុណឹ ។

*ខ្ញុំលះបង់នូវផ្ទះ ហើយចូលទៅកាន់ផ្នួស កាលមិនទាន់ដល់កន្លះខែនៅឡើយ ក៏បានលុះនូវសច្ចៈ ៤ ។*

ឥទ្ធិយា អភិនិម្មិត្វា ចតុរស្សំ រថំ អហំ
ពុទ្ធស្ស បាទេ អវន្ទឹ លោកនាថស្សិរីមតោ ។

*ខ្ញុំនិម្មិតនូវរថមានជ្រុង ៤ ដោយឫទ្ធិ ហើយថ្វាយបង្គំនូវព្រះបាទានៃព្រះពុទ្ធ ព្រះអង្គជាទីពឹងដ៏មានសិរីរបស់សត្វលោក ។*

សុបុប្ផិតគ្គំ ឧបគម្ម បាទបំ
ឯកា តុវំ តិដ្ឋសិ សាលមូលេ
ន ចាបិ តុយ្ហំ ទុតិយត្ថិ កោចិ
ពាលេ ន ត្វំ ភាយសិ ធុត្តកានំ ។

*( មារពោលថា ) នាងអាស្រ័យនូវដើមឈើដែលមានចុងរីកផ្កាស្គុសស្គាយ ឋិតនៅទៀបគល់រាំងតែម្នាក់ឯង*

*ទាំងអ្នកណាមួយ ជាគម្រប់ពីរនឹងនាង ក៏មិនមាន តើនាងមិនខ្លាចពួកជនពាល ឬពួកអ្នកលេងទេឬ ។*

**សតំ សហស្សានិបិ ធុត្តកានំ**
**ឥធាគតា ឯនិសកា ភវេយ្យុំ**
**លោមំ ន ឥញ្ជេ ន សម្បវេធេ**
**កឹ មេ តុវំ មារ ករិស្សសេកោ ។**

*( ខ្ញុំឆ្លើយថា ) ពួកជនអ្នកលេង ចំនួនមួយរយក្តី មួយពាន់ក្តី ដែលប្រាកដដូច្នោះ មកក្នុងទីនេះ យើងក៏ឥតព្រឺរោម ឥតញាប់ញ័រ ម្នាលមារ អ្នកជាបុគ្គលម្នាក់ឯង តើនឹងធ្វើម្តេចដល់យើង ។*

**ឯសា អន្តរធាយាមិ** **កុច្ឆឹ វា បវិសាមិ តេ**
**ភមុកន្តរិកាយម្បិ** **តិដ្ឋន្តឹ មំ ន ទក្ខសិ ។**

*យើងនុ៎ះ អាចបំបាត់ខ្លួនក៏បាន ចូលទៅក្នុងពោះអ្នកឯងក៏បាន កាលយើងឋិតនៅត្រង់ប្រជុំចិញ្ចើម ក៏អ្នកមើលមិនឃើញ ។*

**ចិត្តម្ហិ វសិភូតាហំ** **ឥទ្ធិបាទា សុភាវិតា**
**សព្វពន្ធនមុត្តាម្ហិ** **ន តំ ភាយាមិ អាវុសោ ។**

*យើងជាស្រីស្ទាត់ក្នុងផ្លូវចិត្ត ទាំងឥទ្ធិបាទទាំងឡាយ យើង*

*ក៏បានចម្រើនល្អហើយ យើងជាស្រីរួចចាកចំណងទាំងអស់ហើយ នៃអាវុសោ យើងមិនខ្លាចអ្នកទេ ។*

សត្តិសូលូបមា កាមា ខន្ធាបិ អធិកុដ្ដនា
យំ ត្វំ កាមរតឹ ព្រូសិ អរតិទានិ សា មម ។

*អ្នកពោលនូវសេចក្តីត្រេកអរក្នុងកាម ចំពោះគំនរកាមណា គំនរកាមនោះ ឧបមាដូចមុខលំពែងដ៏មុតក្រៃលែង ឥឡូវនេះ យើងមិនមានសេចក្តីត្រេកអរ ក្នុងកាមនោះទៀតទេ ។*

សព្វត្ថ វិហតា នន្ទិ តមោក្ខន្ធោ បទាលិតោ
ឯវំ ជានាហិ បាបិម និហតោ ត្វមសិ អន្តក ។

*សេចក្តីរីករាយក្នុងអារម្មណ៍ទាំងអស់ យើងបានកម្ចាត់បង់ហើយ ទាំងគំនរនៃសេចក្តីងងឹត យើងក៏ទម្លាយចេញហើយ ម្នាលមារមានចិត្តបាប អ្នកចូរដឹងយ៉ាងនេះចុះ ខ្លួនអ្នក ត្រូវយើងកម្ចាត់បានហើយ ។*

ជិនោ តស្មឹ គុណេ តុដ្ឋោ ឯតទគ្គេ ឋបេសិ មំ
សេដ្ឋា ឥទ្ធិមតីនន្តិ បរិសាសុ វិនាយកោ ។

*ព្រះជិនស្រីជានាយក ត្រេកអរចំពោះគុណនោះ តាំងខ្ញុំក្នុងទីជាឯតទគ្គៈ ក្នុងបរិស័ទទាំងឡាយថា នាងឧប្បលវណ្ណាជាស្រីប្រសើរបំផុត ជាងភិក្ខុនីដែលមានឫទ្ធិទាំងឡាយ ។*

បរិចិណ្ណោ មយា សត្ថា កតំ ពុទ្ធស្ស សាសនំ
ឱហិតោ គរុកោ ភារោ ភវនេត្តិ សមូហតា ។

*ព្រះសាស្តាខ្ញុំបានប្រព្រឹត្តតាមហើយ ទាំងសាសនរបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ ខ្ញុំក៏ទម្លាក់ចេញហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានគាស់រម្លើងចេញហើយ ។*

យស្សត្ថាយ បព្វជិតា អគារស្មា អនគារិយំ
សោ មេ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោ ។

*ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់គុណវិសេសណា ប្រយោជន៍ គឺគុណវិសេសនោះឯង ជាគ្រឿងអស់ទៅនៃសំយោជនៈទាំងអស់ ខ្ញុំក៏បានដល់ជាលំដាប់ហើយ ។*

ចីវរំ បិណ្ឌបាតញ្ច បច្ចយំ សយនាសនំ
ខណេន ឧបនាមេន្តិ សហស្សានិ សមន្តតោ ។

*ចំនួនពាន់នៃពួកជនដោយជុំវិញ រមែងបង្អោនមកនូវបច្ច័យ គឺចីវរ បិណ្ឌបាត សេនាសនៈ ដោយកាលភ្លាមៗ ។*

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។

*កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រម្លើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទឹង ។*

**ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ**
**តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។**

*ឱ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់ព្រះពុទ្ធជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។*

**បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ**
**ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។**

*បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ[១] ។*

*ព្រះនាងឧប្បលវណ្ណាថេរីនោះ ញ៉ាំងកាលវេលាឲ្យប្រព្រឹត្តកន្លងទៅដោយសេចក្តីសុខក្នុងឈាន សេចក្តីសុខក្នុងផល និងសេចក្តីសុខក្នុងព្រះនិព្វាន ថ្ងៃមួយ ពិចារណានូវទោសរបស់កាមដែលអន់ថយផង ដែលសៅហ្មងផង កាលនឹងពោលតាមឡើងវិញ នូវព្រះគាថាទាំងឡាយរបស់ព្រះមាតានៃព្រះគង្គាតីរិយត្ថេរ ព្រោះកើតនូវសេចក្តីសង្វេគ បំពោះការ*

---

*១-បិ.៧៦ ទំ.៩៤-១០៩ ឃ.១៩ ។*

នៅរួមជាមួយស្វាមីតែមួយ មួយអន្លើដោយកូនស្រី ( មានប្ដីរួមគ្នា ) នៃព្រះមាតារបស់ព្រះគង្គាតីរិយត្ថេរ ទើបពោលគាថា ៣ នេះថា

ឧភោ មាតា ច ធីតា ច មយំ អាសុំ សបត្តិយោ
តស្សា មេ អហុ សំវេគោ អព្ភុតោ លោមហំសនោ ។

យើងទាំងពីរនាក់ គឺមាតានិងធីតា មានប្ដីជាមួយគ្នា ( ភរិយារួមប្ដី ) សេចក្ដីតក់ស្លុត សេចក្ដីព្រឺរោម អស្ចារ្យចម្លែក កើតមានដល់ខ្ញុំនោះ ។

ធិរត្ថុ កាមា អសុចី ទុគ្គន្ធា ពហុកណ្ដកា
យត្ថ មាតា ច ធីតា ច សភរិយា មយំ អហុំ ។

ថ្វីយ កាមទាំងឡាយ ជារបស់មិនស្អាត មានក្លិនអាក្រក់ ដូចជាបន្លាច្រើនយ៉ាង ដែលនាំយើងទាំងពីរនាក់ គឺមាតានិងធីតា ឲ្យជាភរិយាជាមួយគ្នា ។

កាមេស្វាទីនវំ ទិស្វា នេក្ខម្មំ ទដ្ឋុខេមតោ
សា បព្វជឹ រាជគហេ អគារស្មា អនគារិយំ ។

លុះខ្ញុំឃើញទោសក្នុងកាមទាំងឡាយ ហើយឃើញនេក្ខម្មៈថា ជារបស់ក្សេម ទើបចេញចាកផ្ទះក្នុងក្រុងរាជគ្រឹះ ចូលកាន់ផ្នួស[១] ។

---

១-បិ.៥៧ ទំ.១៨៧ ឃ.៣២៩ ។

*បានឮថា ភរិយារបស់ឈ្មួញម្នាក់ ក្នុងនគរសាវត្ថី តាំងគភ៌ក្នុងពេលទៀបភ្លឺ នាងក៏មិនដឹងការតាំងគភ៌នោះ ។ លុះព្រឹកឡើង ឈ្មួញនោះ ក៏ផ្ទុកទំនិញក្នុងរទេះ ធ្វើដំណើរទៅជួញក្នុងក្រុងរាជគ្រឹះ ។ លុះកាលកន្លងទៅ គភ៌របស់នាងក៏ចម្រើនឡើង ចាស់ខែហើយ ។ លំដាប់នោះ ម្ដាយក្មេកពោលថា* **មម បុត្តោ ចិរប្បវុត្ថោ តូញ្ច គព្ភិនី ចាបកាំ តយា កាតំ** *កូនប្រុសរបស់យើងទៅយូរហើយ នាងក៏មានគភ៌ នាងធ្វើអាក្រក់ឬ ។*

*នាងពោលថា* **តវ បុត្តតោ អញ្ញំ បុរិសំ ន ជានាមិ** *ក្រៅអំពីកូនប្រុសរបស់ម៉ែ ខ្ញុំមិនស្គាល់បុរសដទៃ ។ ម្ដាយក្មេកស្ដាប់នាងហើយក៏មិនជឿ ទើបបណ្ដេញចេញអំពីផ្ទះ នាងក៏ទៅតាមរកស្វាមី ទៅដល់ក្រុងរាជគ្រឹះតាមលំដាប់ ។ ខណៈនោះ ខ្យល់កម្មជ្ជវាតក៏បក់ឡើង នាងចូលទៅកាន់សាលាមួយកន្ទែងក្បែរផ្លូវ ហើយក៏ប្រសូត នាងប្រសូតកូនប្រុសដូចគ្នានឹងបដិមាមាស ឲ្យកូនតូចដេកលើសាលាអនាថា ហើយចេញទៅរកទឹកខាងក្រៅសាលា ។ គ្រានោះ មេឈ្មួញរទេះម្នាក់ ជាមនុស្សមិនមានកូន ធ្វើដំណើរមកតាមផ្លូវនោះ ( ឃើញទារកនោះ ) គិតថា ទារករបស់ស្ត្រីមិនមានប្ដី នឹងជាកូនរបស់អញ ទើបយកទារកនោះទៅប្រគល់ក្នុងដៃមេដោះ ។ លំដាប់នោះ មាតារបស់ទារកនោះ ធ្វើកិច្ចដោយទឹកហើយ ត្រឡប់មកមិនឃើញកូន សោយសោកវិយោគពន់ពេក*

មិនចូលទៅកាន់ក្រុងរាជគ្រឹះ ធ្វើដំណើរតទៅ ។ មេចោរម្នាក់ចួបនាង ក្នុងរវាងផ្លូវ កើតចិត្តប្រតិព័ទ្ធ ទើបយកនាងធ្វើជាភរិយារបស់ខ្លួន ។ នាងនៅក្នុងផ្ទះចោរនោះ ប្រសូតបានកូនស្រីម្នាក់ ។ ថ្ងៃមួយ នាងឈរពកូនស្រី ព្រោះឈ្លោះជាមួយប្ដី ក៏ប្រោះទារិកាទៅលើគ្រែ ។ ក្បាលរបស់ទារិកា ក៏បែកបន្តិច ។ បន្ទាប់អំពីនោះ នាងខ្លាចប្ដី ទើបត្រាច់ទៅកាន់ក្រុងរាជគ្រឹះ រស់នៅតាមគាប់ចិត្ត កូនប្រុសរបស់នាងធំពេញកំលោះ មិនដឹងថាជាមាតា ក៏យកមាតាធ្វើជាភរិយារបស់ខ្លួន ។

តមក បុរសនោះ មិនដឹងថា កូនស្រីមេចោរជាប្អូនស្រី ក៏នាំមកផ្ទះ ។ បុរសនោះ ធ្វើមាតានិងប្អូនស្រីឲ្យជាភរិយារបស់ខ្លួន ដោយប្រការដូច្នេះ ។ ជនទាំងពីរនោះ នៅជាមួយគ្នាដោយការព្រមព្រៀងគ្នា ។ សម័យថ្ងៃមួយ មាតាស្រាយផ្នួងសក់របស់កូនស្រីរកចៃ ឃើញស្នាមត្រង់ក្បាល គិតថា ស្រីនេះ ពិតជាកូនស្រីរបស់អញ ហើយក៏សួរ កើតសេចក្ដីសង្វេគ ទើបទៅកាន់សម្នាក់ភិក្ខុនីក្នុងនគររាជគ្រឹះ ហើយបួស ធ្វើកិច្ចខាងដើមស្រេចហើយ នៅយ៉ាងស្ងប់ស្ងាត់ ពិចារណាវត្ថុដែលខ្លួនធ្វើក្នុងកាលមុន បានពោលគាថាថា **ឧភោ មាតា ច ធីតា ច** យើងទាំងពីរនាក់ គឺមាតានិងធីតា ដូច្នេះជាដើម ។

ព្រះនាងឧប្បលវណ្ណាថេរីនោះ ពិចារណាគុណវិសេសដែលខ្លួនសម្រេចហើយ កើតនូវបីតិសោមនស្ស បានពោលគាថា ២ ថា

**បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ**
**ចេតោបរិយញ្ញាណញ្ច សោតធាតុ វិសោធិតា ។**

*ខ្ញុំដឹងនូវបុព្វេនិវាស ឯទិព្វចក្ខុ និងចេតោបរិយញ្ញាណ ខ្ញុំជម្រះហើយ ទិព្វសោតធាតុ ខ្ញុំជម្រះហើយដែរ ។*

**ឥទ្ធិបិ មេ សច្ឆិកតា បត្តោ មេ អាសវក្ខយោ**
**ឆ មេ អភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។**

*ទាំងឫទ្ធិខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ការអស់ទៅនៃអាសវៈខ្ញុំបានដល់ហើយ អភិញ្ញា ៦ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ពុទ្ធសាសនា ខ្ញុំបានធ្វើហើយ[១] ។*

*ក្នុងកាលព្រះមានព្រះភាគ ស្តេចយាងចូលកាន់មណ្ឌលដើមស្វាយរបស់នាយកណ្ឌៈ ដើម្បីធ្វើយមកប្បាដិហារ្យ កាលនោះ ព្រះថេរីនិម្មិតរថចូលទៅគាល់ មួយអន្ទើដោយរថនោះ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់នឹងធ្វើបាដិហារ្យ ដើម្បីញាំញីសេចក្តីស្រវឹងរបស់តិរ្ថិយ សូមទ្រង់អនុញ្ញាតចុះ ហើយឈរក្នុងសម្នាក់ព្រះសាស្តា ។ ព្រះថេរីសំដៅដល់បាដិហារ្យនោះ ទើបពោលគាថានេះថា*

**ឥទ្ធិយា អភិនិម្មិត្វា ចតុរស្សំ រថំ អហំ**
**ពុទ្ធស្ស បាទេ វន្ទិត្វា លោកនាថស្ស សិរីមតោ ។**

---

*១-បិ.៥៧ ទំ.១៨៧ ឃ.៣២៩ ។*

ខ្ញុំនិម្មិតនូវរថ ទឹមសេះ ៤ ដោយឫទ្ធិ ហើយថ្វាយបង្គំព្រះបាទ
ទាំងគូនៃព្រះពុទ្ធដ៏មានសិរី ជាទីពឹងនៃសត្វលោក[១] ។

ព្រះសាស្តាទ្រង់ធ្វើហេតុនោះ ឲ្យជាអត្ថុប្បត្តិហេតុ គង់ប្រថាប់កណ្តាលពួកព្រះអរិយៈ ក្នុងវត្តជេតពន ទ្រង់ស្ថាបនាភិក្ខុនីទាំងឡាយទុកក្នុងតំណែងឯតទគ្គៈតាមលំដាប់ ហើយទ្រង់ស្ថាបនាភិក្ខុនីនេះ ទុកក្នុងតំណែងឯតទគ្គៈ គឺប្រសើរជាងភិក្ខុនីទាំងឡាយ ផ្នែកខាងមានឫទ្ធិ ។

បានឮថា ថ្ងៃមួយ មារឃើញព្រះថេរីអង្គុយសម្រាកក្នុងពេលថ្ងៃក្នុងព្រៃសាលព្រឹក្ស ដែលមានផ្ការីកស្គុសស្គាយមួយដើម មានប្រាថ្នាដើម្បីញ៉ាំងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើងដល់ព្រះថេរី មានប្រាថ្នាឲ្យព្រះថេរីឃ្លាតចាកសមាធិ ទើបចូលទៅរកព្រះថេរីបានពោលគាថានេះថា

**សុបុប្ផិតគ្គំ ឧបគម្ម បាទបំ**
**ឯកា តុវំ តិដ្ឋសិ រុក្ខមូលេ**
**ន ចាបិ តេ ទុតិយោ អត្ថិ កោចិ**
**ន ត្វំ ពាលេ ភាយសិ ធុត្តកានំ ។**

នាងជាស្រីម្នាក់ឯងចូលមកកាន់ដើមរាំងភ្នំ ដែលនៅចុង
មានផ្ការីកស្គុសស្គាយ ហើយឈរនៅទៀបគល់ឈើ

---

១-បិ.៥៧ ទំ.១៨៧ ឃ.៣២៩ ។

បុគ្គលណាមួយ ជាគម្រប់ពីររបស់នាងក៏មិនមាន នែ
ស្ត្រីពាល នាងមិនខ្លាចពួកអ្នកលេងទេឬ[១] ។

លំដាប់នោះ ឧប្បលវណ្ណាភិក្ខុនី មានសេចក្តីត្រិះរិះយ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្ស ឬជាអមនុស្ស មកពោលគាថាដូច្នេះ ទើបឧប្បលវណ្ណាភិក្ខុនីមានសេចក្តីចូលចិត្តដូច្នេះថា នេះពិតជាមារមានចិត្តបាប មានប្រាថ្នាដើម្បីញ៉ាំងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើងដល់អាត្មាអញ ប្រាថ្នាឲ្យអាត្មាអញឃ្លាតចាកសេចក្តីស្ងប់ស្ងាត់ បានជាពោលនូវគាថា ។ លុះឧប្បលវណ្ណាភិក្ខុនីស្គាល់ច្បាស់ថា នេះជាមារមានចិត្តបាបហើយ ក៏ពោលគាថាទាំងឡាយនឹងមារមានចិត្តបាបថា

**សតំ សហស្សានិបិ ធុត្តកានំ**
**សមាគតា ឯទិសកា ភវេយ្យុំ**
**លោមំ ន ឥញ្ជេ នបិ សម្បវេធេ**
**កឹ មេ តុវំ មារ ករិស្សសេកោ ។**

បើទុកជាអ្នកលេងទាំងឡាយ មួយរយ ឬមួយពាន់
ជាបុគ្គលមានសភាពយ៉ាងនេះ មកចួបជុំគ្នា ក៏រោម
( របស់យើង ) មិនព្រឺព្រួច មិនញាប់ញ័រ នៃមារ
អ្នកម្នាក់ឯង នឹងធ្វើនូវអ្វីដល់យើងកើត ។

---

១-បិ.៥៧ ទំ.១៨៧ ឃ.៣២៩ ។

ឯសា អន្តរធាយាមិ កុច្ឆឹ វា បវិសាមិ តេ
ភមុកន្តរេបិ តិដ្ឋាមិ តិដ្ឋន្តឹ មំ ន ទក្ខសិ ។

*យើងនេះនឹងបាត់ទៅ ឬនឹងចូលទៅកាន់ផ្ទៃរបស់អ្នកក៏បាន ឬបើទុកជាឈរនៅក្បែរចន្លោះចិញ្ចើមរបស់អ្នក ក៏អ្នកមើលមិនឃើញយើងឈរដែរ ។*

ចិត្តម្ហិ វសីភូតាហំ ឥទ្ធិបាទា សុភាវិតា
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

*យើងជាស្ត្រីស្ទាត់ក្នុងអធិចិត្ត ឥទ្ធិបាទទាំងឡាយ យើងបានចម្រើនហើយដោយប្រពៃ អភិញ្ញា ៦ យើងបានធ្វើឲ្យជាក់ច្បាស់ហើយ ពុទ្ធសាសនា យើងបានធ្វើហើយ ។*

សត្តិសូលូបមា កាមា ខន្ធានំ អធិកុដ្ដនា
យំ ត្វំ កាមរតឹ ព្រូសិ អរតិ ទានិ សា មម ។

*កាមទាំងឡាយប្រៀបដោយលំពែង និងឈើស្រួច សម្រាប់ចិញ្ច្រាំនូវខន្ធទាំងឡាយ អ្នកពោលនូវតម្រេកក្នុងកាមណា ឥឡូវនេះ តម្រេកក្នុងកាមនោះ មិនមែនជាតម្រេករបស់យើងឡើយ ។*

សព្វត្ថ វិហតា នន្ទិ តមោក្ខន្ធោ បទាលិតោ
ឯវំ ជានាហិ បាបិម និហតោ ត្វមសិ អន្តក ។

សេចក្ដីរីករាយក្នុងកាមទាំងអស់ យើងបានកម្ចាត់ចេញហើយ គំនរនៃងងឹត ( អវិជ្ជា ) យើងបានទម្លាយចោលហើយ នែមារ មានចិត្តបាប អ្នកចូរដឹងយ៉ាងនេះចុះ នែមារថោកទាប អ្នក យើងកម្ចាត់ចេញហើយ(១) ។

សម័យដទៃ ព្រះថេរីនោះ ត្រាច់ចារិកទៅក្នុងជនបទ ត្រឡប់មក ហើយចូលទៅកាន់ព្រៃអន្ធវ័ន ។ ក្នុងកាលនោះ ព្រះសាស្ដាទ្រង់មិនទាន់ ហាមការនៅព្រៃរបស់ភិក្ខុនី ។ គ្រានោះ ពួកមនុស្សធ្វើតូប ដាក់គ្រែ បាំង វាំងននទុកក្នុងព្រៃនោះ ដើម្បីព្រះថេរីនោះ ។ ព្រះថេរីចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ចេញមកហើយ ។

ចំណែកនន្ទមាណពជាកូននៃអ៊ំរបស់ព្រះថេរីនោះ មានចិត្តប្រតិព័ទ្ធ តាំងអំពីកាលព្រះថេរីនៅជាគ្រហស្ថ ស្ដាប់ភាពដែលព្រះថេរីមក ទើប ទៅកាន់ព្រៃអន្ធវ័នមុនព្រះថេរីមកនោះឯង ចូលទៅកាន់តូប ហើយលាក់ ខ្លួនក្រោមគ្រែ លុះព្រះថេរីមកហើយ ចូលទៅកាន់តូប បិទទ្វារអង្គុយលើ គ្រែ កាលភាពងងឹតក្នុងគន្ធងចក្ខុមិនទាន់បាត់ ព្រោះមកពីទីភ្លឺត្រូវកម្ដៅ ថ្ងៃខាងក្រៅ ទើបនន្ទមាណពចេញអំពីខាងក្រោមគ្រែ ឡើងលើគ្រែ ហើយ ត្រូវព្រះថេរីឃាត់ថា ជនពាល អ្នកកុំវិនាសឡើយ ជនពាល អ្នកកុំវិនាសឡើយ ក៏ចាប់បង្ខំធ្វើកម្មដែលខ្លួនប្រាថ្នា ហើយចៀសចេញ

---

១-បិ.៥៧ ទំ.១៨៨ ឃ.៣២៩ ។

ទៅ ។ ក្នុងកាលនោះ មហាប្រឹថពីហាក់ដូចជាមិនអាចទ្រទ្រង់នូវទោសកំហុសរបស់នន្ទមាណពនោះបាន ក៏ប្រេះជាពីរចំណែក នន្ទមាណពចូលទៅកាន់ផែនដី កើតក្នុងអវិចីមហានរក ។

ឯព្រះថេរីប្រាប់សេចក្ដីនោះ ដល់ភិក្ខុនីទាំងឡាយហើយ ពួកភិក្ខុនីប្រាប់សេចក្ដីនោះ ដល់ភិក្ខុទាំងឡាយ ពួកភិក្ខុក្រាបបង្គំទូលចំពោះព្រះសាស្ដា ។ ព្រះសាស្ដា កាលទ្រង់ព្រះសណ្ដាប់រឿងនោះហើយ ទើបហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុ ភិក្ខុនី ឧបាសកឧបាសិកាទាំងឡាយ អ្នកណាមួយជាបុគ្គលពាល កាលធ្វើបាបកម្ម ជាអ្នកត្រេកអររីករាយ ហាក់ដូចបុរសទំពាស៊ីនូវវត្ថុណាមួយ មានទឹកឃ្មុំនិងស្ករក្រាមជាដើម ដែលមានរសផ្អែម រមែងធ្វើ ( នូវបាបកម្ម ) ហាក់ដូចបុគ្គលមានកាយនិងចិត្តអណ្ដែតឡើង ( ដោយអំណាចនៃបីតិ ) ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**មធុវា មញ្ញតី ពាលោ យាវ ចាបំ ន បច្ចតិ**
**យទា ច បច្ចតី ចាបំ អថ ( ពាលោ ) ទុក្ខំ និគច្ឆតិ ។**

បាបមិនទាន់ឲ្យផលត្រឹមណា ជនពាលតែងសម្គាល់នូវបាប
នោះថា ដូចទឹកឃ្មុំ លុះតែកាលណាបាបឲ្យផល ជនពាល
ទើបប្រទះនូវសេចក្ដីទុក្ខ ក្នុងកាលណោះ [១] ។

---

១-បិ.៥២ ទំ.៣៥ ឃ.១៥ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផល មានសោតាបត្តិផលជាដើម ។

សម័យក្រោយមក មហាជនសន្ទនាគ្នាក្នុងធម្មសភាថា ព្រះខីណាស្រពទាំងឡាយ ប្រហែលជានៅត្រេកអរក្នុងកាមសុខ នៅសេពកាម ហេតុអ្វីថា មិនសេព ព្រោះព្រះខីណាស្រពទាំងនោះ មិនមែនឈើពុក មិនមែនដំបូក មានសាច់ស្រស់ឈាមស្រស់ដូចគ្នា ព្រោះហេតុនោះ សូម្បីព្រះខីណាស្រពទាំងនោះ គង់នៅត្រេកអរក្នុងកាមសុខ នៅសេពកាម ។ ព្រះសាស្ដាយាងមក ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលពួកភិក្ខុក្រាបបង្គំទូលថា ដោយរឿងឈ្មោះនេះ ព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះខីណាស្រពទាំងឡាយ មិនត្រេកអរក្នុងកាមសុខ មិនសេពកាម ដូចដំណក់ទឹកលើស្លឹកឈូក រមែងមិនជាប់ មិនតាំងនៅ រមែងរមៀលធ្លាក់ទៅដោយពិត និងដូចគ្រាប់ស្ពៃ មិនជាប់ មិនតាំងនៅ ត្រង់ចុងដែកស្រួច រមែងរអិលធ្លាក់ទៅដោយពិត យ៉ាងណា កាមពីរយ៉ាង រមែងមិនជ្រួតជ្រាប មិនតាំងនៅក្នុងចិត្តរបស់ព្រះខីណាស្រព ក៏យ៉ាងនោះដែរ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្ដែងព្រះធម៌ ទើបត្រាស់ព្រះគាថានេះ ក្នុងព្រាហ្មណវគ្គថា

វារិ បោក្ខរបត្តេវ អារគ្គេរិវ សាសបោ
យោ ន លិម្បតិ កាមេសុ តមហំ ព្រូមិ ព្រាហ្មណំ ។

*បុគ្គលណា មានចិត្តមិនបានជាប់នៅក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍*[១] ។

*ព្រះសាស្តាឲ្យយាងព្រះបាទបសេនទិកោសលមក ហើយត្រាស់ថា មហាបពិត្រ កុលធីតាទាំងឡាយក្នុងសាសនានេះ លះពួកញាតិដ៏ធំ និងគំនរនៃភោគៈដ៏ច្រើន បួសហើយ រមែងនៅក្នុងព្រៃដូចកុលបុត្តទាំងឡាយដែរ បុគ្គលលាមក ត្រូវរាគៈគ្របសង្កត់ហើយ រមែងបៀតបៀនភិក្ខុនីទាំងនោះ ដែលនៅក្នុងព្រៃ ដោយអំណាចនៃការមើលងាយខ្លះ ឲ្យដល់នូវអន្តរាយនៃព្រហ្មចរិយៈខ្លះ ព្រោះហេតុនោះ ទ្រង់គួរធ្វើលំនៅខាងក្នុងព្រះនគរដល់ភិក្ខុនីសង្ឃ ។ ព្រះរាជាទ្រង់ទទួលថា សាធុ ដូច្នេះហើយ ឲ្យសាងលំនៅដើម្បីភិក្ខុនីសង្ឃ ត្រង់ចំណែកម្ខាងនៃព្រះនគរ ចាប់តាំងអំពីនោះមក ពួកភិក្ខុនី រមែងនៅក្នុងចន្លោះស្រុកប៉ុណ្ណោះ ។*

ព្រះនាងឧប្បលវណ្ណាថេរី ចប់[២]

---

*១-បិ.៥២ ទំ.១០៦ ឃ.៣៦ ។ ២-ស្រង់ចាកអដ្ឋកថា ថេរីគាថា បិ.៥៧ ទំ.១៨៧ ឃ.៣២៩ និងអដ្ឋកថា ធម្មបទ ឧប្បលវណ្ណត្ថេរីវត្ថុ មួយអន្លើដោយថេរិយាបទាន បិ.៧៦ ទំ.៩៤ ឃ.១៩ ។*

# មុនាឡិពោធិសត្វទី ១

បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វកើតក្នុងត្រកូលសូទ្រៈ ជាអ្នកមិនមានកេរ្តិ៍ឈ្មោះ មិនមានជំនាញណាមួយ ជាអ្នកលេង ឈ្មោះ មុនាឡិ ។ ក្នុងកាលនោះ **ព្រះបច្ចេកពុទ្ធ** ព្រះនាមសុរភិ មានឫទ្ធិច្រើន មានអានុភាពច្រើន ទៅជិតលំនៅរបស់អ្នកលេងនោះ ដោយកិច្ចឯណានីមួយ ។ ព្រះពោធិសត្វឃើញព្រះបច្ចេកពុទ្ធនោះ បានជេរដោយពាក្យជាដើមថា សមណៈនេះ ទ្រុស្តសីល មានធម៌ដ៏លាមក ។ ព្រោះផលរបស់អកុសលនោះ ព្រះពោធិសត្វបានសោយទុក្ខក្នុងនរកជាដើម ច្រើនពាន់ឆ្នាំ ។ ព្រះមានព្រះភាគ កាលព្រះអង្គនៅជាព្រះពោធិសត្វគង់នៅក្នុងស្ថានតុសិត ពួកតិរ្ថិយមានឈ្មោះបោះសំឡេងមុន ត្រាច់សម្តែងទិដ្ឋិ ៦២ បោកបញ្ឆោតមហាជន ព្រះពោធិសត្វបានចុតិអំពីតុសិតបុរី កើតក្នុងសក្យត្រកូល ក្នុងអត្តភាពចុងក្រោយនេះ ហើយបានត្រាស់ជាព្រះពុទ្ធដោយលំដាប់ ។ ពួកតិរ្ថិយសាបសូន្យចាកលាភសក្ការៈ ដូចអំពិលអំពែកក្នុងពេលព្រះអាទិត្យរះឡើង ទើបចង់អាឃាតនឹងព្រះមានព្រះភាគ ។

សម័យមួយ សេដ្ឋីអ្នកក្រុងរាជគ្រឹះ ឲ្យសន្ទឹងសំណាញ់ក្នុងទន្លេគង្គាដើម្បីសេចក្តីផុតភ័យ និងដើម្បីរក្សាអាភរណៈជាដើម ដែលរបូតទៅដោយការភ្លេចភ្លាំង ពេលលេងកីឡាក្នុងស្ទឹងគង្គា ។ ក្នុងកាលនោះ

ដើមចន្ទន៍ក្រហមមួយដើមកើតត្រង់ច្រាំងស្ទឹង មានឫសត្រូវទឹកក្នុងស្ទឹងគង្គាច្រោះ បាក់ខ្ទាត់ខ្ទាយនៅលើថ្មនោះ ៗ ។ លំដាប់នោះ ពកមួយមានប្រមាណប៉ុនក្អម ត្រូវថ្មកួត ត្រូវរលកបក់នាំមក ជារបស់រលោងរសាត់ទៅដោយលំដាប់ ត្រូវសារាយរួបរឹត មកជាប់ត្រង់សំណាញ់របស់សេដ្ឋីនោះ ។ សេដ្ឋីពោលថា នុ៎ះជាអ្វី កាលបានស្តាប់ថា នុ៎ះជាពកនៃដើមឈើ ទើបឲ្យនាំពកឈើនោះមក ឲ្យថាំងដោយចុងកាំបិត ដើម្បីពិចារណាថា នុ៎ះជាឈើអ្វី ។ រំពេចនោះឯង ចន្ទន៍ក្រហមមានពណ៌ដូចល័ក្ខស្រស់ក៏ប្រាកដ ។ សេដ្ឋីមិនជាសម្មាទិដ្ឋិ មិនជាមិច្ឆាទិដ្ឋិ ដាក់ខ្លួនជាកណ្តាល គិតថា ចន្ទន៍ក្រហមក្នុងផ្ទះរបស់អញមានច្រើន អញនឹងយកចន្ទន៍ក្រហមនេះធ្វើអ្វីហ្ន៎ ។ លំដាប់នោះ គាត់គិតយ៉ាងនេះថា ក្នុងលោកនេះ ជនដែលពោលថា យើងជាព្រះអរហន្ត យើងជាព្រះអរហន្ត មានច្រើន អញមិនឃើញព្រះអរហន្តសូម្បីតែមួយ អញនឹងប្រកបគ្រឿងក្រឡឹងក្នុងផ្ទះ ឲ្យក្រឡឹងជាបាត្រហើយ ដាក់សង្រែកព្យួរទុកក្នុងអាកាស ប្រមាណ ៦០ ហត្ថ ដោយយកឫស្សីតគ្នា ហើយពោលថា បើព្រះអរហន្តមាន ចូរមកតាមអាកាស ហើយកាន់យកបាត្រនេះ ។ បុគ្គលណាកាន់យកបាត្រនេះបាន ខ្ញុំមួយអន្ទើដោយបុត្តនិងភរិយា នឹងដល់បុគ្គលនោះ ជាសរណៈ ដូច្នេះហើយ ឲ្យក្រឡឹងបាត្រដោយទំនងដែលគិតហើយនុ៎ះឯង លើកឡើងដោយឫស្សីដែលតគ្នា ពោលថា ក្នុង

លោកនេះ បុគ្គលណា ជាព្រះអរហន្ត បុគ្គលនោះ ចូរមកតាមអាកាស កាន់យកបាត្រនេះចុះ ។

ក្នុងកាលនោះ គ្រូទាំង ៦ នាក់ គឺគ្រូឈ្មោះបូរណកស្សបៈ ១ មក្ខលិគោសាល ១ អជិតកេសកម្ពល ១ បកុធកច្ចាយនៈ ១ សញ្ជយវេឡដ្ឋបុត្ត ១ និគណ្ឋនាដបុត្ត ១ បានចូលទៅរករាជគហសេដ្ឋី ។ លុះចូលទៅដល់ហើយ ក៏និយាយយ៉ាងនេះ នឹងរាជគហសេដ្ឋីថា នែគហបតី អាត្មាជាព្រះអរហន្ត ទាំងមានឫទ្ធិផង សូមអ្នកឲ្យបាត្រមកអាត្មាចុះ ។ សេដ្ឋីនិយាយថា បពិត្រលោកដ៏ចម្រើន បើលោកមានអាយុជាព្រះអរហន្ត ទាំងមានឫទ្ធិមែន ចូរលោកដាក់យកបាត្រដែលយើងឲ្យ ហើយទៅចុះ[១] ។

លំដាប់នោះ ក្នុងថ្ងៃទី ៦ គ្រូឈ្មោះនិគណ្ឋនាដបុត្ត បញ្ជូនពួកអន្តេវាសិកទៅ ដោយពាក្យថា ពួកអ្នកចូរទៅ ចូរនិយាយនឹងសេដ្ឋីនោះយ៉ាងនេះថា បាត្រនុ៎ះ សមគួរដល់អាចារ្យរបស់យើងទាំងឡាយ កុំធ្វើកិរិយាមកតាមអាកាស ព្រោះហេតុនៃវត្ថុបន្តិចបន្តួចឡើយ សូមលោកឲ្យបាត្រនោះមកពួកយើងចុះ ។ ពួកអន្តេវាសិករបស់គ្រូឈ្មោះនិគណ្ឋនាដបុត្ត ទៅនិយាយនឹងសេដ្ឋីដោយប្រការដូច្នោះ ។ សេដ្ឋីពោលថា អ្នកដែលអាចមកតាមអាកាស ហើយកាន់យកបាត្រនេះបាន ចូរកាន់យកទៅចុះ ។ និគណ្ឋនាដបុត្តជាអ្នកប្រាថ្នានឹងទៅខ្លួនឯង ទើបឲ្យសញ្ញាពួក

---

១-បិ.១០ ទំ.១៤៣ យ.១៤០ ។

អន្តេវាសិកថា យើងនឹងលើកដៃនិងជើងម្ខាង ដូចជាប្រាថ្នានឹងហោះឡើង ពួកអ្នកចូរឃាត់យើងថា លោកអាចារ្យ លោកប្រុងធ្វើអ្វី លោកកុំសម្តែងភាពជាព្រះអរហន្ត ដែលជាគុណជាតដ៏កំបាំង ព្រោះហេតុនៃបាត្រឈើដល់មហាជនឡើយ លុះពោលដូច្នេះហើយ ចូរនាំគ្នាចាប់ជើងនិងដៃរបស់យើង ទាញមកឲ្យដួលទៅលើផែនដី ។ គ្រូឈ្មោះនិគ្គណ្ឋនាដបុត្តទៅកាន់ទីនោះ ហើយពោលនឹងសេដ្ឋីថា មហាសេដ្ឋី បាត្រនេះ សមគួរដល់យើង មិនសមគួរដល់ពួកជនដទៃទេ លោកកុំគាប់ចិត្តនឹងការហោះឡើងទៅក្នុងអាកាសរបស់អាត្មាភាព ព្រោះហេតុនៃរបស់ត្រឹមតែបន្តិចបន្តួចឡើយ ចូរឲ្យបាត្រនោះ ដល់អាត្មាភាពចុះ ។ សេដ្ឋីពោលថា លោកដ៏ចម្រើន លោកចូរហោះឡើងទៅលើអាកាស ហើយកាន់យកចុះ ។

គ្រានោះ នាដបុត្តពោលថា បើដូច្នោះ ពួកអ្នកចូរចៀសចេញ ចូរចៀសចេញ លុះពួកអន្តេវាសិកចៀសចេញហើយ ក៏ពោលថា យើងនឹងហោះឡើងទៅក្នុងអាកាស ហើយក៏លើកដៃម្ខាង និងជើងម្ខាងឡើង ។ លំដាប់នោះ ពួកអន្តេវាសិកពោលថា បពិត្រលោកអាចារ្យ លោកធ្វើអ្វី ប្រយោជន៍អ្វីដោយគុណដ៏កំបាំងដែលលោកសម្តែងដល់មហាជន ព្រោះហេតុនៃបាត្រឈើដុតខ្មោច ដែលប្រឡាក់លាមកនេះ ហើយនាំគ្នាចាប់នាដបុត្តនោះ ត្រង់ដៃនិងជើង ទាញឲ្យដួលទៅលើផែនដី ។

និគ្គណ្ឋនាដបុត្តប្រាប់សេដ្ឋីថា មហាសេដ្ឋី អន្តេវាសិកទាំងនេះ មិន

ឲ្យអាត្មាភាពហោះទេ លោកចូរឲ្យបាត្រដល់អាត្មាភាពចុះ ។ សេដ្ឋីពោលថា លោកម្ចាស់ចូរហោះឡើង ហើយកាន់យកចុះ ។ ពួកតិរ្ថិយ សូម្បីព្យាយាមដោយអាការយ៉ាងនេះ អស់ ៦ ថ្ងៃ ក៏មិនបានបាត្រនោះឡើយ ។

ក្នុងថ្ងៃទី ៧ ក្នុងកាលដែលព្រះមហាមោគ្គល្លានដ៏មានអាយុ និងព្រះបិណ្ឌោលភារទ្វាជៈដ៏មានអាយុ ទៅឈរត្រង់ថ្មដាមួយកន្ទែង ហើយឃ្លុំចីវរ ដោយតាំងចិត្តថា ពួកយើងនឹងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ពួកអ្នកលេងជជែកគ្នាថា ម្នាលគ្នាយើង ក្នុងកាលមុនគ្រូទាំង ៦ ពោលថា ពួកយើងជាព្រះអរហន្តក្នុងលោក កាលសេដ្ឋីអ្នកក្រុងរាជគ្រឹះលើកបាត្រឡើងហើយ ពោលថា បើព្រះអរហន្តមាន ចូរមកតាមអាកាសហើយកាន់យកចុះ ថ្ងៃនេះ ជាថ្ងៃទី ៧ បុគ្គលសូម្បីត្រឹមតែម្នាក់ ដែលហោះទៅក្នុងអាកាស ហើយពោលថា យើងជាព្រះអរហន្ត ក៏មិនមាន ថ្ងៃនេះ ពួកយើងដឹងនូវភាពដែលព្រះអរហន្ត មិនមានក្នុងលោកហើយ ។

ចំណែកព្រះមហាមោគ្គល្លានដ៏មានអាយុ បានឮពាក្យនោះហើយ ទើបពោលនឹងព្រះបិណ្ឌោលភារទ្វាជៈដ៏មានអាយុថា អាវុសោភារទ្វាជៈ លោកបានឮពាក្យរបស់ពួកអ្នកលេងទាំងនេះដែរឬទេ ពួកអ្នកលេងទាំងនេះ ពោលញាំញីព្រះពុទ្ធសាសនា លោកម្ចាស់មានឫទ្ធិច្រើន មានអានុភាពច្រើន សូមលោកទៅ ហើយកាន់យកបាត្រនោះ មកតាមអាកាសចុះ ។

ព្រះបិណ្ឌោលភារទ្វាជៈពោលថា អាវុសោមហាមោគ្គល្លាន លោកជាកំពូលលើសសាវ័កទាំងឡាយផ្នែកខាងមានឫទ្ធិ សូមលោកម្ចាស់កាន់យកបាត្រនោះ តែបើលោកម្ចាស់មិនកាន់យក ខ្ញុំនឹងកាន់យក ។

កាលព្រះមហាមោគ្គល្លានដ៏មានអាយុពោលយ៉ាងនេះថា អាវុសោ សូមលោកកាន់យកចុះ ព្រះបិណ្ឌោលភារទ្វាជៈក៏ចូលចតុត្ថជ្ឈាន មានអភិញ្ញាជាបាទ ចេញចាកឈានហើយ យកចុងជើងញៀបថ្មដាទំហំប្រមាណ ៣ គាវុត ហោះឡើងទៅកាន់អាកាសដូចប៉ុយគ ហើយប្រទក្សិណលើនគររាជគ្រឹះ ៧ ជុំ ។ ថ្មដានោះ ប្រាកដដូចគម្របគ្របនគរទុកប្រមាណ ៣ គាវុត ពួកអ្នកនគរភ័យខ្លាចថា ថ្មនឹងធ្លាក់សង្កត់ពួកយើង ធ្វើគ្រឿងការពារ មានចង្អេរជាដើម ទុកខាងលើក្បាល ហើយពួនក្នុងទីនោះៗ ។ ក្នុងវារៈទី ៧ ព្រះថេរៈទម្លាយថ្ម ហើយបង្ហាញខ្លួន ។

មហាជនឃើញព្រះថេរៈហើយ ពោលថា បពិត្រលោកម្ចាស់បិណ្ឌោលភារទ្វាជៈ សូមលោកម្ចាស់ចាប់ថ្មរបស់លោកម្ចាស់ទុកឲ្យមាំ កុំឲ្យពួកខ្ញុំទាំងអស់គ្នាវិនាសឡើយ ។ ព្រះថេរៈយកចុងជើងគ្រវាត់ថ្មចោលថ្មនោះទៅតាំងនៅក្នុងទីដើមនោះឯង ព្រះថេរៈបានឈរក្នុងទីបំផុតផ្ទះរបស់សេដ្ឋី ។ សេដ្ឋីឃើញលោកហើយ ក្រាបចុះ ពិតថា សូមលោកម្ចាស់ចុះមក ។ និមន្តព្រះថេរៈចុះអំពីអាកាស ឲ្យគង់ហើយ ឲ្យនាំបាត្រចុះ ធ្វើឲ្យពេញដោយមធុរស ៤ យ៉ាង ហើយប្រគេនដល់ព្រះថេរៈ ព្រះ

ថេរៈទទួលបាត្រហើយ បែរមុខទៅកាន់វិហារ និមន្តទៅ ។

លំដាប់នោះ ជនទាំងឡាយណា ដែលនៅក្នុងព្រៃក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី មិនឃើញបាដិហារ្យរបស់ព្រះថេរៈ ជនទាំងនោះ ប្រជុំគ្នាហើយអង្វរព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់សម្តែងបាដិហារ្យដល់ពួកខ្ញុំ ហើយនាំគ្នាជាប់តាមព្រះថេរៈទៅ ។ ព្រះថេរៈសម្តែងបាដិហារ្យនោះ ៗ ដល់ជនទាំងនោះ ហើយបានទៅកាន់វិហារ ។

ព្រះសាស្តាទ្រង់ព្រះសណ្តាប់សំឡេងទ្រហឹងអឺងកង របស់មហាជនដែលជាប់តាមព្រះបិណ្ឌោលភារទ្វាជត្ថេរនោះហើយ ទើបត្រាស់សួរព្រះអានន្ទថា ម្នាលអានន្ទ នុ៎ះសំឡេងអ្វី កាលទ្រង់ព្រះសណ្តាប់ពាក្យដែលព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបិណ្ឌោល-ភារទ្វាជៈហោះទៅក្នុងអាកាស ហើយកាន់យកបាត្រខ្លឹមចន្ទន៍ នុ៎ះជាសំឡេងក្នុងសម្នាក់របស់លោក ទើបឲ្យហៅព្រះបិណ្ឌោលភារទ្វាជៈមកត្រាស់សួរថា បានឮថា អ្នកធ្វើយ៉ាងនោះ ពិតឬ ។ កាលព្រះថេរៈក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពិតមែន ទើបទ្រង់ត្រាស់ថា ម្នាលភារទ្វាជៈ ព្រោះហេតុអ្វី ទើបអ្នកធ្វើយ៉ាងនេះ ទ្រង់តិះដៀលព្រះថេរៈហើយ ត្រាស់ឲ្យបំបែកបាត្រនោះ ជាកំណាត់តូចធំ ចែកដល់ភិក្ខុទាំងឡាយ ដើម្បីប្រយោជន៍ផ្សំធ្វើជាថ្នាំបន្តក់ភ្នែក ហើយទ្រង់បញ្ញត្តសិក្ខាបទដល់សាវ័កទាំងឡាយ ដើម្បីមិនឲ្យធ្វើបាដិហារ្យ ។

ចំណែកពួកតិរ្ថិយបានឮថា ព្រះមានព្រះភាគឲ្យទម្លាយបាត្រនោះ ហើយទ្រង់បញ្ញត្តនូវសិក្ខាបទដល់សាវ័កទាំងឡាយ ហាមសាវ័កមិនឲ្យធ្វើបាដិហារ្យ ទើបដើរប្រាប់គ្នាក្នុងថ្នល់នគរថា សាវ័កទាំងឡាយរបស់ព្រះសមណគោតម មិនឈានកន្លងសិក្ខាបទដែលទ្រង់បញ្ញត្តហើយ សូម្បីព្រោះហេតុនៃជីវិត សូម្បីព្រះសមណគោតម ក៏នឹងរក្សាសិក្ខាបទដែលទ្រង់បញ្ញត្តនោះដែរ ។ ឥឡូវនេះ ពួកយើងបានឱកាសហើយ ។ ក្នុងកាលមុន ពួកយើងរក្សាគុណរបស់ខ្លួន ទើបមិនសម្តែងនូវគុណរបស់ខ្លួនដល់មហាជន ព្រោះហេតុនៃបាត្រឈើ ចំណែកពួកសាវ័ករបស់ព្រះសមណគោតមសម្តែងគុណរបស់ខ្លួន ព្រោះហេតុត្រឹមតែបាត្រ ព្រះសមណគោតមត្រាស់ឲ្យទម្លាយបាត្រនោះ ហើយទ្រង់បញ្ញត្តនូវសិក្ខាបទដល់ពួកសាវ័ក ព្រោះព្រះអង្គជាបណ្ឌិត ឥឡូវនេះ ពួកយើងនឹងធ្វើបាដិហារ្យជាមួយព្រះសមណគោតម ។

ព្រះបាទពិម្ពិសារទ្រង់បានស្តាប់ពាក្យនោះហើយ យាងទៅកាន់សម្នាក់ព្រះសាស្តា ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ព្រះអង្គបញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ដើម្បីមិនឲ្យធ្វើបាដិហារ្យឬ ។ ព្រះសាស្តាត្រាស់ថា ពិតហើយ មហារាជ ។

ព្រះរាជាត្រាស់សួរថា ឥឡូវនេះ ពួកនិគ្រន្ថនាំគ្នាពោលថា ពួកគេនឹងធ្វើបាដិហារ្យជាមួយទ្រង់ ឥឡូវនេះ ទ្រង់ធ្វើដូចម្តេច ។ ព្រះសាស្តា

ត្រាស់តបថា មហាបពិត្រ កាលតិរ្ថិយទាំងនោះធ្វើ តថាគតក៏នឹងធ្វើ ។

ព្រះរាជាត្រាស់សួរទៀតថា ព្រះអង្គបញ្ញត្តសិក្ខាបទទុកហើយ មិនមែនឬ ។ ព្រះសាស្តាត្រាស់តបថា មហាបពិត្រ តថាគតមិនបានបញ្ញត្តសិក្ខាបទដើម្បីខ្លួនទេ សិក្ខាបទនោះ តថាគតបញ្ញត្តដើម្បីសាវ័កទាំងឡាយប៉ុណ្ណោះ ។

ព្រះរាជាត្រាស់សួរថា សិក្ខាបទ ឈ្មោះថា ទ្រង់បញ្ញត្តក្នុងសាវ័កទាំងឡាយ វៀរទ្រង់ខ្លួនឯងចេញឬ ។ ព្រះសាស្តាត្រាស់សួរព្រះរាជាថា មហាបពិត្រ បើដូច្នោះ តថាគតនឹងសួរព្រះអង្គក្នុងរឿងនេះ មហាបពិត្រ ព្រះរាជឧទ្យានក្នុងដែនរបស់ព្រះអង្គ មានឬ ។

ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន មាន ។

ព្រះសាស្តាត្រាស់សួរទៀតថា មហាបពិត្រ បើមហាជនបរិភោគផ្លែឈើ មានផ្លែស្វាយជាដើម ក្នុងព្រះរាជឧទ្យានរបស់ព្រះអង្គ ទ្រង់គប្បីធ្វើដូចម្តេច ដល់ជនទាំងនោះ ។ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន គប្បីដាក់ទោស ។

ព្រះសាស្តាត្រាស់សួរថា ចុះព្រះអង្គរមែងសោយបានឬ ។ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន បាន អាជ្ញាមិនមានដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គអាចសោយរបស់ខ្លួនបាន ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ រាជអាជ្ញារបស់ព្រះអង្គដែល

ផ្សាយទៅក្នុងដែនប្រមាណ ៣០០ យោជន៍ អាជ្ញារមែងមិនមានដល់ព្រះអង្គដែលសោយផ្លែឈើទាំងឡាយ មានផ្លែស្វាយជាដើម ក្នុងព្រះរាជឧទ្យានរបស់ព្រះអង្គ តែមានដល់ជនដទៃ យ៉ាងណា សូម្បីអាជ្ញារបស់តថាគត ក៏យ៉ាងនោះ រមែងផ្សាយទៅក្នុងសែនកោដិចក្កវាឡ ឈ្មោះថាការឈានកន្លងនូវបញ្ញត្តិ គឺសិក្ខាបទ រមែងមិនមានដល់ខ្លួន តែរមែងមានដល់សាវ័កដទៃ ទើបតថាគតអាចធ្វើបាដិហារ្យបាន ។

ពួកតិរ្ថិយស្តាប់ពាក្យនោះហើយ ប្រឹក្សាគ្នាថា ឥឡូវនេះ ពួកយើងវិនាសហើយ បានឮថា ព្រះសមណគោតម ទ្រង់បញ្ញត្តសិក្ខាបទដើម្បីពួកសាវ័កប៉ុណ្ណោះ ទ្រង់មិនបញ្ញត្តដើម្បីខ្លួនព្រះអង្គឡើយ ។ បានឮថាទ្រង់បំណងនឹងធ្វើបាដិហារ្យដោយខ្លួនព្រះអង្គឯង តើពួកយើងនឹងធ្វើដូចម្តេច ។

ព្រះរាជាក្រាបបង្គំទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើនទ្រង់នឹងធ្វើបាដិហារ្យក្នុងកាលណា ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រតថាគតនឹងធ្វើក្នុងតិថីពេញបូណ៌មីនៃខែអាសាឍ ដោយកាលកន្លងទៅ ៤ ខែទៀត អំពីថ្ងៃនេះ ។

ព្រះរាជាត្រាស់សួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គនឹងទ្រង់ធ្វើនៅក្នុងទីណា ។ ព្រះសាស្តាតបថា មហាបពិត្រ តថាគតនឹងធ្វើនៅក្នុងក្រុងសាវត្ថី ។

បើមានពាក្យជ្រៀតចូលមកថា ហេតុអ្វី ទើបព្រះសាស្តាត្រាស់អាង ដល់ទីឆ្ងាយយ៉ាងនេះ ។ ឆ្លើយថា ព្រោះទីនោះ ជាទីធ្វើមហាបាដិហារ្យ របស់ព្រះពុទ្ធគ្រប់ព្រះអង្គ ម្យ៉ាងទៀត ទ្រង់អាងទីឆ្ងាយ ដើម្បីប្រយោជន៍ ឲ្យមហាជនប្រជុំគ្នា ។

ពួកតិរ្ថិយស្តាប់ពាក្យនោះហើយ ពោលថា បានឮថា បន្ទាប់អំពី នេះទៅ ៤ ខែទៀត ព្រះសមណគោតមនឹងធ្វើបាដិហារ្យក្នុងនគរសាវត្ថី ឥឡូវនេះ ពួកយើងមិនលះបង់ យើងនឹងជាប់តាមព្រះអង្គទៅ មហាជន ឃើញពួកយើងហើយ នឹងសួរថា ពួកលោកម្ចាស់នឹងធ្វើអ្វី ពេលនោះ ពួកយើងនឹងប្រាប់ដល់ជនទាំងនោះថា ពួកយើងពោលទុកហើយថា ពួក យើងនឹងធ្វើបាដិហារ្យជាមួយព្រះសមណគោតម ព្រះគោតមនោះ រមែង គេចទៅ ពួកយើងមិនឲ្យព្រះសមណគោតមនោះគេច ទើបជាប់តាមទៅ ។

ព្រះសាស្តាស្តេចត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ហើយ ចេញមក ។ ចំណែកពួកតិរ្ថិយក៏ចេញមកអំពីខាងក្រោយព្រះអង្គ ហើយ បិតនៅក្នុងទីជិតព្រះអង្គ ធ្វើភត្តកិច្ច ។ ថ្ងៃស្អែកឡើង ពួកតិរ្ថិយនោះ នាំ គ្នាបរិភោគអាហារពេលព្រឹកក្នុងទីដែលខ្លួននៅនោះឯង ។ ពួកតិរ្ថិយ ទាំងនោះ ត្រូវមនុស្សទាំងឡាយសួរថា ហេតុការណ៍នេះ ដូចម្តេច ក៏ ប្រាប់តាមន័យដូចដែលបានពោលខាងដើម ។ ចំណែកមហាជនគិត ថា ពួកយើងនឹងមើលបាដិហារ្យ ដូច្នេះហើយ បានជាប់តាមទៅ ។

ព្រះសាស្តាទ្រង់យាងដល់នគរសាវត្ថីដោយលំដាប់ ។ ពួកតិរ្ថិយក៏ទៅជាមួយព្រះអង្គ បបួលឧបដ្ឋាកបានទ្រព្យ ១ សែនហើយ ឲ្យធ្វើមណ្ឌបដោយសសរគគីរ ប្រក់ដោយផ្កាឧប្បលខៀវ អង្គុយនិយាយគ្នាថា ពួកយើងនឹងធ្វើបាដិហារ្យក្នុងទីនេះ ។

ព្រះបាទបសេនទិកោសលចូលគាល់ព្រះសាស្តា ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកតិរ្ថិយធ្វើមណ្ឌបហើយ ខ្ញុំព្រះអង្គនឹងធ្វើមណ្ឌបដើម្បីទ្រង់ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ កុំឡើយ អ្នកធ្វើមណ្ឌបរបស់តថាគត មានហើយ ។

ព្រះរាជាក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន អ្នកដទៃវៀរខ្ញុំព្រះអង្គ តើអ្នកណានឹងធ្វើបាន ។ ព្រះសាស្តាត្រាស់តបថា គឺសក្កទេវរាជ ។

ព្រះរាជាក្រាបបង្គំទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់នឹងធ្វើបាដិហារ្យក្នុងទីណា ។ ព្រះសាស្តាត្រាស់ថា ត្រង់មណ្ឌលកណ្ឌម្ពព្រឹក្ស ។

ពួកតិរ្ថិយបានឮថា ព្រះសមណគោតមនឹងធ្វើបាដិហារ្យត្រង់គល់ស្វាយ ទើបប្រាប់ឧបដ្ឋាករបស់ខ្លួន ឲ្យដកដើមស្វាយតូច ៗ ដោយហោចទៅ សូម្បីដុះក្នុងថ្ងៃនោះ ក្នុងរវាងទី ១ យោជន៍ ហើយឲ្យបោះចោលក្នុងព្រៃ ។

ក្នុងថ្ងៃ ១៥ កើត ខែអាសាឍ ព្រះសាស្តាទ្រង់យាងចូលទៅខាងក្នុងនគរ ។ អ្នករក្សាឧទ្យានរបស់ព្រះរាជា ឈ្មោះកណ្ឌៈ ឃើញផ្លែស្វាយទុំធំមួយនៅក្នុងសម្បុកអង្រ្កង ដេញក្អែកដែលមកចោមរោមដោយចំណង់ក្នុងក្លិននិងរសនៃផ្លែស្វាយនោះ ឲ្យគេចទៅ ហើយកាន់យកដើម្បីប្រយោជន៍ដល់ព្រះរាជា ដើរទៅឃើញព្រះសាស្តាក្នុងរវាងផ្លូវ គិតថា ព្រះរាជាសោយស្វាយនេះហើយ គប្បីប្រទានកហាបណៈ ៨ ឬ ១៦ ដល់អញ កហាបណៈនោះ មិនគ្រប់គ្រាន់ដើម្បីចិញ្ចឹមជីវិតក្នុងអត្តភាពមួយរបស់អញ បើអញថ្វាយផ្លែស្វាយនេះ ចំពោះព្រះសាស្តា នឹងជាគុណនាំមកនូវប្រយោជន៍ឲ្យដល់អញ អស់កាលមិនមានទីបំផុត ទើបបង្អោនផ្លែស្វាយនោះ ចំពោះព្រះសាស្តា ។ ព្រះសាស្តាទ្រង់ទតព្រះអានន្ទត្ថេរហើយ ។ លំដាប់នោះ ព្រះថេរៈនាំបាត្រដែលមហារាជទាំង ៤ ថ្វាយមក ហើយដាក់ក្នុងព្រះហស្តរបស់ព្រះអង្គ ។ ព្រះសាស្តាទ្រង់បង្អោនបាត្រទទួលផ្លែស្វាយ ហើយទ្រង់សម្តែងអាការដើម្បីប្រថាប់គង់ក្នុងទីនោះឯង ។ ព្រះថេរៈបានក្រាលចីវរថ្វាយហើយ ។ លំដាប់នោះ កាលព្រះសាស្តាប្រថាប់គង់លើចីវរនោះ ព្រះថេរៈត្រងទឹកស្អាត ហើយច្របាច់ផ្លែស្វាយនោះ ធ្វើជាទឹកបានថ្វាយ ។ ព្រះសាស្តាសោយទឹកបានផ្លែស្វាយហើយ ត្រាស់នឹងនាយកណ្ឌៈថា ចូរកកាយដីផង់ឡើង ហើយដាំគ្រាប់ស្វាយនេះ ក្នុងទីនេះឯង ។ បុរសនោះ បានធ្វើយ៉ាងនោះហើយ ។

ព្រះសាស្ដាទ្រង់លាងព្រះហស្ដលើទីនោះ គ្រាន់តែទ្រង់លាងព្រះហស្ដហើយប៉ុណ្ណោះ ដើមស្វាយប៉ុនចុងនង្គ័ល ប្រមាណ ៥០ ហត្ថ ដោយកម្ពស់ ដុះឡើងហើយ ។ មែកធំ មាន ៥ ចេញទៅគ្រប់ទិសទាំង ៤ និងមែកមួយត្រង់ឡើងទៅលើ មែកនីមួយ ៗ មានប្រមាណ ៥០ ហត្ថ ។ ដើមស្វាយនោះ ដេរដាសដោយផ្កានិងផ្លែ ទ្រទ្រង់ទុកនូវចង្កោមនៃផ្លែស្វាយទុំក្នុងទីមួយកន្លែង ក្នុងខណៈនោះឯង ។ ពួកភិក្ខុមកខាងក្រោយទំពាធាន់នូវផ្លែស្វាយទុំនោះឯង ។ ព្រះរាជាទ្រង់បានឮថា ស្វាយបែបនេះ កើតឡើងហើយ ទើបទ្រង់ចាត់ចែងរក្សាទុក ដោយព្រះតម្រាស់ថា បុគ្គលណាមួយ កុំកាប់ដើមស្វាយនេះ ។ ដើមស្វាយនោះ ប្រាកដឈ្មោះថា កណ្ឌម្ពព្រឹក្ស ព្រោះនាយកណ្ឌៈជាអ្នកដាំ ។ សូម្បីពួកអ្នកលេងទំពាស៊ីផ្លែស្វាយទុំហើយ ពោលថា នែពួកតិរ្ថិយថោកទាប ពួកឯងដឹងថា ព្រះសមណគោតមទ្រង់នឹងធ្វើបាដិហារ្យត្រង់គល់កណ្ឌម្ពព្រឹក្ស ក៏ឲ្យដកដើមស្វាយតូច ៗ សូម្បីកើតក្នុងថ្ងៃនោះ ក្នុងទីមួយយោជន៍ ដើមស្វាយនេះ ឈ្មោះថា កណ្ឌម្ពៈ ហើយយកគ្រាប់ស្វាយដែលជាសំណល់ប្រហារពួកតិរ្ថិយទាំងនោះ ។

សក្កទេវរាជទ្រង់ត្រាស់បង្គាប់វាតវលាហកទេវបុត្តថា ចូរបក់បំបើងមណ្ឌបរបស់ពួកតិរ្ថិយ ឲ្យរលំចុះលើផែនដីដែលកខ្វក់ ។ ទេវបុត្តនោះបានធ្វើយ៉ាងនោះហើយ ។ សក្កទេវរាជត្រាស់បង្គាប់សុរិយទេវបុត្តថា ចូរ

ពង្រីកមណ្ឌលព្រះអាទិត្យ ញុាំងពួកតិរ្ថិយឲ្យក្តៅ សុរិយទេវបុត្តនោះ ក៏បានធ្វើយ៉ាងនោះ ។ សក្កទេវរាជត្រាស់បង្គាប់វាតវលាហកទេវបុត្តទៀតថា ចូរញុាំងមណ្ឌលខ្យល់កំបុតត្បូងឲ្យតាំងឡើង ហើយបក់ទៅ ទេវបុត្តនោះ ក៏ធ្វើយ៉ាងនោះ ហើយក្ខួចនូវធូលីរោយលើសរីរៈរបស់ពួកតិរ្ថិយដែលកំពុងបែកញើស ។ ពួកតិរ្ថិយទាំងនោះ មានខ្លួនដូចកណ្ដៀរក្រហម ។ សក្កទេវរាជត្រាស់បង្គាប់វស្សវលាហកទេវបុត្តថា ចូរឲ្យតំណក់ទឹកធំ ៗ ធ្លាក់ចុះ ។ ទេវបុត្តនោះ បានធ្វើយ៉ាងនោះហើយ ។ លំដាប់នោះ កាយរបស់ពួកតិរ្ថិយទាំងនោះ ដូចគ្នានឹងមេគោពពាល ។ ពួកតិរ្ថិយខ្មាសអៀន បែកគ្នា គេចទៅ (តាមផ្លូវដែលមាន) ក្នុងទីចំពោះមុខនោះឯង ។ កាលពួកជនទាំងនោះ រត់ទៅយ៉ាងនោះ អ្នកស្រែម្នាក់ជាឧបដ្ឋាករបស់បូរណកស្សបៈ គិតថា ឥឡូវនេះ ជាពេលធ្វើបាដិហារ្យនៃលោកម្ចាស់របស់យើង យើងនឹងទៅមើលបាដិហារ្យនោះ ហើយលែងគោ កាន់ឆ្នាំងបបរនិងខ្សែ ដែលខ្លួននាំមកអំពីព្រលឹម ដើរមក ឃើញបូរណកស្សបៈរត់ទៅយ៉ាងនោះ ពោលថា លោកម្ចាស់ ថ្ងៃនេះ ខ្ញុំមកដោយបំណងថា នឹងមើលបាដិហារ្យរបស់លោកម្ចាស់ លោកម្ចាស់ទៅណា ។ បូរណកស្សបៈពោលថា អ្នកត្រូវការអ្វីដោយបាដិហារ្យ ចូរឲ្យឆ្នាំងនិងខ្សែនេះ ដល់យើង ។ កាន់យកឆ្នាំងនិងខ្សែដែលឧបដ្ឋាកនោះឲ្យហើយ ទៅកាន់ច្រាំងស្ទឹង យកខ្សែចងឆ្នាំងហើយរុំត្រង់ករបស់ខ្លួន មិន

ពោលពាក្យណាមួយ ព្រោះអៀនខ្មាស លោតចូលទៅក្នុងអន្លង់ទឹក ញ៉ាំងពពុះទឹកឲ្យតាំងឡើង ធ្វើកាលកិរិយា កើតក្នុងអវិចីនរកហើយ ។

សក្កទេវរាជទ្រង់និម្មិតរតនចង្រ្កមក្នុងអាកាស ទីបំផុតមួយនៃរតន-ចង្រ្កមនោះ ទល់គ្នានឹងកណ្ដាប់ចក្កវាឡទិសខាងកើត ទីបំផុតមួយទៀត ទល់គ្នានឹងកណ្ដាប់ចក្កវាឡទិសខាងលិច ។ ព្រះសាស្ដា កាលបរិស័ទ ប្រមាណ ៣៦ យោជន៍ ប្រជុំគ្នាហើយ ក្នុងពេលរសៀល ទ្រង់ចេញអំពី ព្រះគន្ធកុដិ ដោយទ្រង់ព្រះតម្រិះថា ឥឡូវនេះ ជាពេលដែលធ្វើបាដិហារ្យ ហើយបានប្រថាប់ឈរត្រង់យ៉មុខ ។ គ្រានោះ ឧបាសិកាជាអនាគាមិ-បុគ្គលម្នាក់ (គឺនន្ទមាតា) ឈ្មោះឃរណី ចូលទៅគាល់ព្រះសាស្ដាហើយ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលធីតាដូចខ្ញុំម្ចាស់ មាន កិច្ច ដែលទ្រង់លំបាក រមែងមិនមាន ខ្ញុំម្ចាស់នឹងធ្វើបាដិហារ្យ ។

ព្រះសាស្ដាត្រាស់សួរថា ម្នាលឃរណី នាងនឹងធ្វើដូចម្ដេច ។

នាងឃរណីក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់នឹង ធ្វើផែនដីធំក្នុងផ្ទៃនៃចក្កវាឡមួយ ឲ្យទៅជាទឹក ហើយមុជចុះដូចជាបក្សី ទឹក[១] បង្ហាញខ្លួនត្រង់កណ្ដាប់ចក្កវាឡទិសខាងកើត មុជពីកណ្ដាប់ ចក្កវាឡទិសខាងកើត ផុសត្រង់ទិសខាងលិច ទិសខាងជើង ទិសខាង ត្បូង ត្រង់កណ្ដាលក៏ដូចគ្នា កាលបើដូច្នោះ មហាជនឃើញខ្ញុំម្ចាស់

---

១-បក្សីទឹកមានច្រើន មានហង្ស ក្ងាន កុកជាដើម ណាមួយ ។

ហើយ កាលបុគ្គលណាមួយពោលឡើងថា នុ៎ះជាអ្នកណា ក៏ប្រាប់ថា នុ៎ះជានាងយរណី អានុភាពរបស់ស្រីម្នាក់គង់អស្ចារ្យដល់ម៉្លេះ ចំណែកអានុភាពរបស់ព្រះពុទ្ធ នឹងដូចម្តេចហ្ន៎ ពួកតិរ្ថិយមិនទាន់ឃើញព្រះអង្គ ក៏នឹងគេចទៅដោយអាការយ៉ាងនេះ ។

លំដាប់នោះ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលយរណី តថាគតដឹងថា នាងអាចធ្វើបាដិហារ្យបែបនេះបាន តែកម្រងផ្កានេះ គេមិនបានចងទុកដើម្បីប្រយោជន៍ដល់នាងទេ ហើយទ្រង់ហាម ។ នាងយរណីនោះគិតថា ព្រះសាស្តាទ្រង់មិនអនុញ្ញាតដល់អញ បុគ្គលដទៃអាចធ្វើបាដិហារ្យក្រៃលែងជាងអញ នឹងមានពិត ហើយឈរក្នុងចំណែកម្ខាង ។

ចំណែកព្រះសាស្តាទ្រង់ព្រះតម្រិះថា គុណរបស់សាវ័កទាំងនោះនឹងប្រាកដដោយអាការយ៉ាងនេះឯង ទ្រង់សម្គាល់ថា ពួកសាវ័កនឹងបន្លឺសីហនាទក្នុងកណ្តាលបរិស័ទមានប្រមាណ ៣៦ យោជន៍ ដោយអាការយ៉ាងនេះ ទើបត្រាស់សួរសាវ័កដទៃថា ពួកអ្នកនឹងធ្វើបាដិហារ្យដូចម្តេច សាវ័កទាំងនោះ ក្រាបបង្គំទូលថា ពួកខ្ញុំព្រះអង្គនឹងធ្វើយ៉ាងនេះៗ ហើយឈរក្នុងទីចំពោះព្រះភក្ត្រព្រះសាស្តានោះឯង បន្លឺសីហនាទ ។

បណ្តាសាវ័កទាំងនោះ បានឮថា ចូឡអនាថបិណ្ឌិកសេដ្ឋី គិតថា បើអនាគាមិឧបាសកដែលជាបុត្តដូចអាត្មាអញ មាន កិច្ចដែលព្រះសាស្តាត្រូវលំបាក រមែងមិនមាន ទើបក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំ

ព្រះអង្គនឹងធ្វើបាដិហារ្យ ។ ព្រះសាស្ដាត្រាស់សួរថា អ្នកនឹងធ្វើដូចម្ដេច ។ ចូឡអនាថបណ្ឌិកសេដ្ឋីក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងនិម្មិតអត្តភាពជាព្រហ្មមានប្រមាណ ១២ យោជន៍ និងបន្ទឺសំឡេងព្រហ្មទះដៃ ដូចគ្នានឹងផ្គរគ្រហឹម ក្នុងកណ្ដាលបរិស័ទនេះ មហាជននឹងសួរថា នេះជាសំឡេងអ្វីហ្ន៎ ហើយនឹងពោលថា បានឮថា នេះជាសំឡេងព្រហ្មទះដៃរបស់ចូឡអនាថបិណ្ឌិក ពួកតិរ្ថិយនឹងគិតថា អានុភាពរបស់គហបតីគង់ដល់ម៉្លេះ ចុះអានុភាពរបស់ព្រះពុទ្ធ យ៉ាងណាហ្ន៎ ទាំងមិនទាន់បានឃើញព្រះអង្គ ក៏នឹងគេចទៅ ។ ព្រះសាស្ដាត្រាស់ដូចមុនដល់ចូឡអនាថបិណ្ឌិកនោះថា តថាគតដឹងអានុភាពរបស់អ្នកហើយ ហើយទ្រង់មិនអនុញ្ញាតការធ្វើបាដិហារ្យ ។

លំដាប់នោះ សាមណេរីមួយរូបឈ្មោះចីរា អាយុ ៧ ឆ្នាំ សម្រេចបដិសម្ភិទា ថ្វាយបង្គំព្រះសាស្ដាហើយ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់នឹងធ្វើបាដិហារ្យ ត្រូវព្រះសាស្ដាត្រាស់សួរថា ម្នាលចីរា នាងនឹងធ្វើដូចម្ដេច ទើបក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់នឹងនាំភ្នំសិនេរុ ភ្នំកណ្ដាប់ចក្កវាឡ និងភ្នំហិមពាន្ត តម្រៀបគ្នាទុកក្នុងទីនេះ ហើយចេញអំពីភ្នំនោះ ៗ ទៅ មិនឲ្យទើសទាក់ ដូចហង្សញី មហាជនឃើញខ្ញុំម្ចាស់ នឹងសួរថា នុ៎ះជានរណា ហើយនឹងពោលថា សាមណេរីចីរា ។ ពួកតិរ្ថិយនឹងគិតថា អានុភាពរបស់សាមណេរីអាយុ

៧ ឆ្នាំ គង់ដល់ម៉្ងៃ ចំណែកអានុភាពរបស់ព្រះពុទ្ធ យ៉ាងណាហ្ន៎ ទាំង មិនទាន់បានឃើញព្រះអង្គ ក៏នឹងគេចទៅ ។ តអំពីនេះទៅ គប្បីជ្រាប ពាក្យបែបនេះ ដោយទំនងដូចពោលហើយនុ៎ះឯង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា តថាគតដឹងអានុភាពរបស់នាងហើយ ដូច្នេះហើយ ទ្រង់ មិនអនុញ្ញាតការធ្វើបាដិហារ្យ ។

លំដាប់នោះ សាមណេរឈ្មោះចុន្ទៈ ជាព្រះខីណាស្រព សម្រេច បដិសម្ភិទាមួយរូប អាយុ ៧ ឆ្នាំអំពីកំណើត ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងធ្វើ បាដិហារ្យ ។ ព្រះសាស្តាត្រាស់សួរថា អ្នកនឹងធ្វើដូចម្តេច ។ សាមណេរ ឈ្មោះចុន្ទៈនោះ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹង ចាប់ដើមព្រីងធំ ដែលជាទង់នៃជម្ពូទ្វីប ត្រង់ដើម អង្រួនហើយនាំផ្លែព្រីង ធំមក ឲ្យបរិស័ទទាំងនេះ ទំពាស៊ី ខ្ញុំព្រះអង្គនឹងនាំផ្កាបារិច្ឆត្តកព្រឹក្សមក ហើយថ្វាយបង្គំព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា តថាគតដឹងអានុភាព របស់អ្នកហើយ ដូច្នេះហើយ ទ្រង់ហាមបាដិហារ្យរបស់សាមណេរនោះ ។

លំដាប់នោះ ព្រះនាងឧប្បលវណ្ណាថេរី ក្រាបថ្វាយបង្គំព្រះសាស្តា ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់នឹងធ្វើបាដិហារ្យ កាលព្រះសាស្តាត្រាស់សួរថា នាងនឹងធ្វើដូចម្តេច ទើបក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់នឹងបង្ហាញបរិស័ទប្រមាណ ១២ យោជន៍

ដោយជុំវិញ ជាស្តេចចក្កពត្តិដែលមានបរិស័ទប្រមាណ ៣៦ យោជន៍ ចោមរោមហើយមកថ្វាយបង្គំព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា តថាគត ដឹងអានុភាពរបស់នាងហើយ ដូច្នេះហើយ ទ្រង់ហាមបាដិហារ្យរបស់ព្រះថេរីនោះ ។

លំដាប់នោះ ព្រះមហាមោគ្គល្លានត្ថេរក្រាបថ្វាយបង្គំព្រះមានព្រះ-ភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យ ។ កាលព្រះសាស្តាត្រាស់សួរថា អ្នកនឹងធ្វើដូចម្តេច ទើបក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងដាក់ស្តេចភ្នំសិនេរុត្រង់ចន្លោះធ្មេញ ហើយទំពាភ្នំនោះ ដូចទំពាគ្រាប់ស្ពៃ ។ ព្រះសាស្តាត្រាស់សួរថា អ្នកនឹងធ្វើអ្វីទៀត ។ ព្រះមហាមោគ្គល្លានត្ថេរក្រាបបង្គំទូលថា ខ្ញុំព្រះអង្គនឹងមូរផែនដីធំនេះ ដូចមូរកន្ទេលផែង ហើយញាត់ក្នុងចន្លោះម្រាមដៃ ។ ព្រះសាស្តាត្រាស់សួរថា អ្នកនឹងធ្វើអ្វីទៀត ។ ព្រះមហាមោគ្គល្លានត្ថេរក្រាបបង្គំទូលថា ខ្ញុំព្រះអង្គនឹងបង្វិលផែនដីធំ ឲ្យដូចជាក្តារយន្តបង្វិលភាជនៈរបស់ស្មូនឆ្នាំង ហើយឲ្យមហាជនទំពាស៊ុិឱជៈនៃផែនដី ។ ព្រះសាស្តាត្រាស់សួរថា អ្នកនឹងធ្វើអ្វីទៀត ។ ព្រះមហាមោគ្គល្លានត្ថេរក្រាបបង្គំទូលថា ខ្ញុំព្រះអង្គនឹងដាក់ផែនដីទុកក្នុងដៃខាងឆ្វេង ហើយដាក់សត្វទាំងនេះ ទុកក្នុងដៃខាងស្តាំ ។ ព្រះសាស្តាត្រាស់សួរថា អ្នកនឹងធ្វើអ្វីទៀត ។ ព្រះមហាមោគ្គល្លានត្ថេរក្រាបបង្គំទូលថា ខ្ញុំ

*ព្រះអង្គនឹងធ្វើភ្នំសិនេរុឲ្យដូចជាដងឆត្រ យកផែនដីធំដាក់លើភ្នំសិនេរុនោះ យកដៃម្ខាងកាន់ ដូចភិក្ខុមានដងឆត្រក្នុងដៃ ចង្ក្រមក្នុងអាកាស ។ ព្រះសាស្ដាត្រាស់ថា តថាគតដឹងអានុភាពរបស់អ្នកហើយ ដូច្នេះហើយ ទ្រង់មិនអនុញ្ញាតការធ្វើបាដិហារ្យដល់ព្រះថេរៈនោះ ។ ព្រះថេរៈគិតថា ប្រហែលព្រះសាស្ដាទ្រង់ជ្រាប អ្នកអាចធ្វើបាដិហារ្យក្រៃលែងជាងអាត្មាអញ ទើបឈរក្នុងចំណែកម្ខាង ។*

*លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងព្រះថេរៈថា ម្នាលមោគ្គល្លាន កម្រងផ្កានេះ មិនមែនចងទុកដើម្បីប្រយោជន៍ដល់អ្នកទេ ព្រោះថា តថាគតជាអ្នកមានធុរៈមិនមានប្រមាណ បុគ្គលដទៃដែលឈ្មោះថា អាចនាំធុរៈរបស់តថាគតទៅបាន មិនមាន ការដែលបុគ្គលអាចនាំធុរៈរបស់តថាគតទៅបាន មិនគប្បីមាន ក្នុងកាលឥឡូវនេះ មិនជាអស្ចារ្យទេ សូម្បីក្នុងកាលដែលតថាគតកើតក្នុងកំណើតសត្វតិរច្ឆាន ដែលជាអហេតុក-កំណើត បុគ្គលដទៃដែលអាចនាំធុរៈរបស់តថាគតទៅបាន ក៏មិនមានដូចគ្នា ។ កាលព្រះថេរៈក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន តើក្នុងកាលណា ទើបទ្រង់នាំអតីតនិទានមក ត្រាស់កណ្ហឧសភជាតក (កណ្ហជាតក) នេះថា*

យតោ យតោ គរុ ធុរំ យតោ គម្ភីរវត្តនិ
តទាស្សុ កណ្ហំ យុញ្ជន្តិ ស្វាស្សុ តំ វហតេ ធុរំ ។

*ធុរៈធ្ងន់ ក្នុងទីណា ៗ ផ្លូវដ៏ជ្រៅក្នុងទីណា កាលនោះឯង ពួកជននាំគ្នាទឹមគោ ឈ្មោះកណ្ហៈ គោឈ្មោះកណ្ហៈនោះ ក៏អូសនូវធុរៈដ៏ធ្ងន់នោះ ទៅបាន(១) ។*

*កាលទ្រង់សម្ដែងរឿងនោះឲ្យពិស្ដារ ទើបត្រាស់នន្ទិវិសាលជាតកថា*

**មនុញ្ញមេវ ភាសេយ្យ ណាមនុញ្ញំ កុទាចនំ**

**មនុញ្ញំ ភាសមានស្ស គរុភារំ ឧទទ្ធរិ**

**ធនញ្ច នំ អលាភេសិ តេន ចត្តមនោ អហុ ។**

*បុគ្គលគប្បីនិយាយពាក្យជាទីគាប់ចិត្តតែម្យ៉ាង មិនគប្បីនិយាយពាក្យមិនជាទីគាប់ចិត្ត ក្នុងកាលណាឡើយ កាលព្រាហ្មណ៍និយាយពាក្យជាទីគាប់ចិត្ត ( គោនន្ទិវិសាល ) បានទាញភារៈដ៏ធ្ងន់រួច ញុាំងព្រាហ្មណ៍នោះ ឲ្យបានទ្រព្យផង ជាសត្វមានចិត្តរីករាយ ដោយការញុាំងព្រាហ្មណ៍នោះ ឲ្យបានទ្រព្យនោះផង(២) ។*

*ក្នុងកាលនោះ ព្រះសាស្ដា កាលត្រាស់ហើយ ទ្រង់យាងឡើងកាន់រតនចង្ក្រម ខាងមុខមានបរិស័ទប្រមាណ ១២ យោជន៍ ខាងក្រោយ ខាងឆ្វេង និងខាងស្ដាំ ក៏ ១២ យោជន៍ ៗ ដូចគ្នា ។ ចំណែកដោយត្រង់ ( ពីម្ខាងទៅម្ខាង ) មានប្រមាណ ២៤ យោជន៍ ។ ព្រះមានព្រះភាគ*

---

*១-បិ.៥៨ ទំ.១៣ ឃ.២៩ ។ ២-បិ.៥៨ ទំ.១៣ ឃ.២៨ ។*

ទ្រង់បានធ្វើយមកប្បាដិហារ្យ ក្នុងកណ្តាលបរិស័ទ យកមប្បាដិហារ្យនេះ បណ្ឌិតគប្បីជ្រាបតាមបាលី ( ព្រះត្រៃបិដក ) យ៉ាងនេះថា

យមកប្បាដិហិរញ្ញាណរបស់ព្រះតថាគត តើដូចម្តេច ។

ព្រះតថាគតទ្រង់ធ្វើយមកប្បាដិហារ្យ ដែលមិនទូទៅដល់ពួកសាវ័កក្នុងលោកនេះ ។

គឺគំនរភ្លើងចេញអំពីព្រះកាយខាងលើ ផ្ការទឹកចេញអំពីព្រះកាយខាងក្រោម ។ គំនរភ្លើងចេញអំពីព្រះកាយខាងក្រោម ផ្ការទឹកចេញអំពីព្រះកាយខាងលើ ។ គំនរភ្លើងចេញអំពីព្រះកាយខាងមុខ ផ្ការទឹកចេញអំពីព្រះកាយខាងក្រោយ ។ គំនរភ្លើងចេញអំពីព្រះកាយខាងក្រោយ ផ្ការទឹកចេញអំពីព្រះកាយខាងមុខ ។ គំនរភ្លើងចេញអំពីព្រះនេត្រខាងស្តាំ ផ្ការទឹកចេញអំពីព្រះនេត្រខាងឆ្វេង ។ គំនរភ្លើងចេញអំពីព្រះនេត្រខាងឆ្វេង ផ្ការទឹកចេញអំពីព្រះនេត្រខាងស្តាំ ។ គំនរភ្លើងចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ ផ្ការទឹកចេញអំពីរន្ធព្រះកាណ៌ខាងឆ្វេង ។ គំនរភ្លើងចេញអំពីរន្ធព្រះកាណ៌ខាងឆ្វេង ផ្ការទឹកចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ ។ គំនរភ្លើងចេញអំពីរន្ធព្រះនាសិកាខាងស្តាំ ផ្ការទឹកចេញអំពីរន្ធព្រះនាសិកាខាងឆ្វេង ។ គំនរភ្លើងចេញអំពីរន្ធព្រះនាសិកាខាងឆ្វេង ផ្ការទឹកចេញអំពីរន្ធព្រះនាសិកាខាង

ស្តាំ ។ គំនរភ្លើងចេញអំពីចង្កួយព្រះអង្សាខាងស្តាំ ផ្ការទឹកចេញអំពីចង្កួយព្រះអង្សាខាងឆ្វេង ។ គំនរភ្លើងចេញអំពីចង្កួយព្រះអង្សាខាងឆ្វេង ផ្ការទឹកចេញអំពីចង្កួយព្រះអង្សាខាងស្តាំ ។ គំនរភ្លើងចេញអំពីព្រះហស្តខាងស្តាំ ផ្ការទឹកចេញអំពីព្រះហស្តខាងឆ្វេង ។ គំនរភ្លើងចេញអំពីព្រះហស្តខាងឆ្វេង ផ្ការទឹកចេញអំពីព្រះហស្តខាងស្តាំ ។ គំនរភ្លើងចេញអំពីខាងខាងស្តាំ ផ្ការទឹកចេញអំពីខាងខាងឆ្វេង ។ គំនរភ្លើងចេញអំពីខាងខាងឆ្វេង ផ្ការទឹកចេញអំពីខាងខាងស្តាំ ។ គំនរភ្លើងចេញអំពីព្រះបាទខាងស្តាំ ផ្ការទឹកចេញអំពីព្រះបាទខាងឆ្វេង ។ គំនរភ្លើងចេញអំពីព្រះបាទខាងឆ្វេង ផ្ការទឹកចេញអំពីព្រះបាទខាងស្តាំ ។ គំនរភ្លើងចេញអំពីព្រះអង្គុលីមួយ ៗ ផ្ការទឹកចេញអំពីចន្លោះនៃព្រះអង្គុលី ។ គំនរភ្លើងចេញអំពីចន្លោះនៃព្រះអង្គុលី ផ្ការទឹកចេញអំពីព្រះអង្គុលីមួយ ៗ ។ គំនរភ្លើងចេញអំពីព្រះលោមាមួយ ៗ ផ្ការទឹកចេញអំពីព្រះលោមាមួយ ៗ ។ គំនរភ្លើងចេញអំពីរណ្តៅព្រះលោមាមួយ ៗ ផ្ការទឹកចេញអំពីរណ្តៅព្រះលោមាមួយ ៗ ។ ( ព្រះមានព្រះភាគទ្រង់បញ្ចេញ ) នូវព្រះឆព្វណ្ណរង្សី ខៀវ លឿង ក្រហម ស ហង្សបាទ ផ្លេក ៗ ។ ព្រះមានព្រះភាគទ្រង់ចង្រ្កម ព្រះពុទ្ធនិម្មិតទ្រង់ឈរ ឬទ្រង់គង់

ឬទ្រង់ផ្ទំ ។ ព្រះមានព្រះភាគទ្រង់ឈរ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់គង់ ឬទ្រង់ផ្ទំ ។ ព្រះមានព្រះភាគទ្រង់គង់ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់ផ្ទំ ។ ព្រះមានព្រះភាគទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់គង់ ។ ព្រះមាន-ព្រះភាគទ្រង់ចង្រ្កម ឬទ្រង់គង់ ឬទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ឈរ ។ ព្រះមានព្រះភាគទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់គង់ ។ ព្រះមានព្រះភាគទ្រង់ឈរ ឬទ្រង់គង់ ឬទ្រង់ចង្រ្កម ព្រះពុទ្ធនិម្មិតទ្រង់ផ្ទំ ។ នេះឈ្មោះថា យមកប្បាដិហិរញ្ញាណរបស់ព្រះតថាគត[១] ។

ព្រះសារីបុត្តត្ថេរពោលថា ព្រះសាស្តាទ្រង់ចង្រ្កមលើទីចង្រ្កមនោះ បានធ្វើយមកប្បាដិហារ្យនេះហើយ គឺចេញអំពីព្រះកាយខាងលើ ចេញអំពីព្រះកាយខាងក្រោម ដើម្បីសម្តែងសេចក្តីនោះថា ផ្ការភ្លើងរមែងផ្សាយចេញអំពីព្រះកាយខាងលើ ដោយអំណាចតេជោកសិណសមាបត្តិរបស់ព្រះអង្គ ផ្ការទឹកហូរចេញអំពីព្រះកាយខាងក្រោម ដោយអំណាចអាបោ-កសិណសមាបត្តិ ។ ផ្ការភ្លើងផ្សាយចេញអំពីទីដែលផ្ការទឹកហូរចេញ ផ្ការទឹកក៏ហូរចេញអំពីទីដែលផ្ការភ្លើងផ្សាយចេញ ។ ក្នុងបទទាំងពួង អ្នកសិក្សាគប្បីជ្រាបការផ្លាស់ប្តូរឆ្លាស់គ្នាបែបនេះ ។ ក្នុងយមកប្បាដិហារ្យ

---

១-បិ.៦៩ ទំ.២៨០ ឃ.២៨៤ ។

នេះ ផ្ការភ្លើងមិនលាយជាមួយផ្ការទឹក ម្យ៉ាងទៀត ផ្ការទឹកក៏មិនបាន លាយជាមួយផ្ការភ្លើង ។ បានឮថា ផ្ការភ្លើងនិងផ្ការទឹកទាំងពីរនេះ ផ្សាយឡើងដល់ព្រហ្មលោក ហើយក៏ផ្សាយទៅកាន់កណ្តាប់ចក្កវាឡ ។ ឯព្រះសារីបុត្តត្ថេរពោលទុកថា ឆព្វណ្ណរង្សី ព្រះរស្មីមានពណ៌ ៦ ប្រការ របស់ព្រះសាស្តានោះ ផ្សាយឡើងអំពីល្វែងនៃចក្កវាឡមួយ ដូចមាស ដែលគេរម្ងាយហូរចេញអំពីស្នប់ និងដូចផ្ការទឹកមាសដែលហូរចេញអំពី នាឡិកយន្តរហូតដល់ព្រហ្មលោក ហើយវិលត្រឡប់មកកាន់កណ្តាប់ ចក្កវាឡវិញ ។ ល្វែងនៃចក្កវាឡមួយ មានពន្លឺតែមួយ ដូចជាផ្ទះពោធិ- ព្រឹក្សដែលមានបង្អួច ។

ក្នុងថ្ងៃនោះ ព្រះសាស្តាទ្រង់យាងចង្រ្កមធ្វើបាដិហារ្យ សម្តែង ធម្មកថាដល់មហាជន ក្នុងចន្លោះ ៗ កាលទ្រង់សម្តែង ទ្រង់មិនធ្វើឲ្យ មហាជនធុញចិត្ត ប្រទានឲ្យស្រោលចិត្ត ។ ក្នុងខណៈនោះ មហាជន ញុំាំងសាធុការឲ្យប្រព្រឹត្តទៅហើយ ក្នុងកាលដែលសាធុការរបស់មហាជន នោះ ប្រព្រឹត្តទៅ ព្រះសាស្តាទ្រង់ប្រមើលមើលចិត្តរបស់បរិស័ទដ៏ច្រើន មានប្រមាណប៉ុណ្ណោះ ទ្រង់ជ្រាបវារៈចិត្តរបស់បរិស័ទនីមួយ ៗ ដោយ អំណាចអាការ ១៦ យ៉ាង ។ ចិត្តរបស់ព្រះពុទ្ធទាំងឡាយ ប្រព្រឹត្តទៅ រហ័សយ៉ាងនេះ បុគ្គលណា ៗ ជ្រះថ្លាក្នុងធម៌ណានិងក្នុងបាដិហារ្យណា ព្រះសាស្តាទ្រង់សម្តែងធម៌នោះ និងធ្វើបាដិហារ្យនោះ ដោយអំណាច

អធ្យាស្រ័យនៃបុគ្គលនោះ ៗ ។ កាលទ្រង់សម្ដែងធម៌ ទ្រង់ធ្វើបាដិហារ្យដោយអាការយ៉ាងនេះ ធម្មាភិសម័យមានដល់មហាជនហើយ ។

ព្រះសាស្ដាទ្រង់កំណត់ព្រះហឫទ័យរបស់ទ្រង់ មិនឃើញបុគ្គលដទៃ ដែលអាចសួរបញ្ហាក្នុងសមាគមនោះ ទើបទ្រង់និម្មិតនូវពុទ្ធនិម្មិត ( គឺហាក់ដូចមានព្រះពុទ្ធពីរព្រះអង្គសួរ ឆ្លើយបញ្ហា ) ។ ពុទ្ធនិម្មិតនោះសួរបញ្ហា ព្រះសាស្ដាទ្រង់ឆ្លើយ ។ ព្រះសាស្ដាត្រាស់សួរបញ្ហា ពុទ្ធនិម្មិតឆ្លើយ ។ ក្នុងកាលដែលព្រះមានព្រះភាគទ្រង់ចង្ក្រម ពុទ្ធនិម្មិតសម្រេចឥរិយាបថ មានការឈរជាដើម ណាមួយ ។ ក្នុងកាលដែលពុទ្ធនិម្មិតចង្ក្រម ព្រះមានព្រះភាគទ្រង់សម្រេចឥរិយាបថ មានការប្រថាប់ឈរជាដើមណាមួយ ។ ដើម្បីសម្ដែងសេចក្ដីនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលពាក្យថា ពុទ្ធនិម្មិតរមែងចង្ក្រមខ្វះជាដើម ។ ធម្មាភិសម័យ មានដល់សត្វ ២០ កោដិ ក្នុងសមាគមនោះ ព្រោះឃើញបាដិហារ្យរបស់ព្រះសាស្ដាដែលទ្រង់ធ្វើយ៉ាងនោះ និងព្រោះបានស្ដាប់ធម្មកថា ។

ព្រះសាស្ដាកំពុងធ្វើបាដិហារ្យនោះឯង ទ្រង់ពិចារណាថា ព្រះពុទ្ធក្នុងអតីតទាំងឡាយ ធ្វើបាដិហារ្យនេះហើយ ចាំវស្សាក្នុងទីណាហ្ន៎ ទ្រង់បានឃើញថា ចាំវស្សាក្នុងតាវត្តិង្សពិភព ហើយសម្ដែងអភិធម្មបិដកដល់ព្រះពុទ្ធមាតា ដូច្នេះហើយ ទ្រង់លើកព្រះបាទស្ដាំជាន់លើកំពូលភ្នំយុគន្ធរ ទ្រង់លើកព្រះបាទម្ខាងទៀត ជាន់លើកំពូលភ្នំសិនេរុ វារៈគឺចន្លោះដំហាន

២ ទៅជំហាន ៣ មានហើយ ក្នុងទីប្រមាណ ៦ លាន ៨ សែន ( ៦៨ សែន ) យោជន៍[១] យ៉ាងនេះ ។ បុគ្គលមិនគប្បីកំណត់ថា ចន្លោះជំហានព្រះបាទទាំងពីរ ព្រះសាស្តាទ្រង់លាតព្រះបាទទៅជាន់នោះទេ ព្រោះក្នុងកាលដែលទ្រង់លើកព្រះបាទនុ៎ះឯង កំពូលភ្នំនោះ ឱនមកជិតព្រះបាទ ទទួលហើយ ក្នុងកាលដែលព្រះសាស្តាទ្រង់ជាន់ហើយ កំពូលភ្នំនោះ ក៏ប្រតិស្ឋានកន្លែងដើមវិញ ( ទ្រង់យាងទៅដោយជំហានធម្មតាប៉ុណ្ណោះ កំពូលភ្នំមកទទួលដោយអានុភាពនៃបុណ្យរបស់ព្រះអង្គ ) ។ សក្កទេវរាជទតឃើញព្រះសាស្តាហើយ ទ្រង់ព្រះតម្រិះថា ព្រះសាស្តាទ្រង់នឹងចាំវស្សាត្រង់បណ្ឌុកម្ពលសិលា ឧបការៈនឹងមានដល់ពួកទេវតា

---

១-ក្នុងមធុរត្ថវិលាសិនី អដ្ឋកថា ពុទ្ធវង្ស ពោលថា ក្នុងកាលព្រះមានព្រះ-ភាគ ព្រះនាមមង្គល ព្រះពោធិសត្វនៃយើង កើតជាព្រាហ្មណ៍ ឈ្មោះសុរុចិ បាននិមន្តព្រះសាស្តា និងភិក្ខុសង្ឃ ប្រមាណ ១ សែនកោដិ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ហើយអង្គុយគិតថា អញអាចថ្វាយចង្ហាន់ដល់ព្រះមានព្រះភាគនិងភិក្ខុសង្ឃ ប្រមាណប៉ុណ្ណោះបាន តែទីសេនាសនៈ ( រោងទាន ) នឹងធ្វើដូចម្តេច ។ ដំណាលគ្នានឹងការគិត បណ្ឌុកម្ពលសិលារបស់សក្កទេវរាជដែលនៅចម្ងាយ ៨៤,០០០ យោជន៍ ក៏ក្តៅឡើង ... បានន័យថា ពីជម្ពូទ្វីបទៅឋានតាវត្តិង្ស មានចម្ងាយតែ ៨៤,០០០ យោជន៍ ឯក្នុងទីនេះ មានចម្ងាយដល់ទៅ ៦៨ សែនយោជន៍ បណ្ឌិតគប្បីកាន់យកតាមការគួរ ។

ច្រើនហ្ន៎ តែកាលព្រះសាស្តាចាំវស្សាក្នុងទីនោះ ទេវតាដទៃ ៗ មិនអាចដាក់ សូម្បីដៃឲ្យបិតនៅបាន ។ ឯបណ្ឌុកម្ពលសិលានេះ បណ្ដោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្រាស់ ១៥ យោជន៍ កាលព្រះសាស្តាទ្រង់ប្រថាប់គង់ហើយ ក៏ហាក់ដូចជាទីវាលទទេ ( ថ្មធំជាងព្រះអង្គ ) ។ ព្រះសាស្តាទ្រង់ជ្រាបអធ្យាស្រ័យរបស់សក្កទេវរាជ ទ្រង់បោះសង្ឃាដិរបស់ព្រះអង្គឲ្យគ្របថ្មហើយ សក្កទេវរាជទ្រង់ព្រះតម្រិះថា ព្រះសាស្តាទ្រង់បោះចីវរមកឲ្យគ្របថ្ម ទ្រង់នឹងប្រថាប់គង់ក្នុងទីបន្តិចបន្តួចដោយព្រះអង្គឯង ។ ព្រះសាស្តាទ្រង់ជ្រាបអធ្យាស្រ័យរបស់សក្កទេវរាជ ទ្រង់ប្រថាប់គង់ ធ្វើបណ្ឌុកម្ពលសិលា ទុកខាងក្នុងផ្នត់ចីវរនោះឯង ហាក់ដូចភិក្ខុដែលទ្រទ្រង់សំពត់មហាបំសុកូល ធ្វើតាំងទាបទុកខាងក្នុងផ្នត់ចីវរដូច្នោះ ។

ខណៈនោះឯង មហាជនរកមើលព្រះសាស្តា ក៏មិនឃើញ កាលនោះ ហាក់ដូចជាពេលព្រះចន្ទលិច និងដូចពេលព្រះអាទិត្យលិច ។ មហាជនយំរៀបរាប់ពោលគាថានេះថា

គតោ នុ ចិត្តកូដំ វា កេលាសំ វា យុគន្ធរំ
ន នោ ទក្ខេមុ សម្ពុទ្ធំ លោកជេដ្ឋំ នរាសភំ ។

ព្រះសាស្តាយាងទៅកាន់ភ្នំចិត្តកូដ ឬភ្នំកៃលាស ឬភ្នំយុគន្ធរ បានជាពួកយើង មិនឃើញនូវព្រះសម្ពុទ្ធ ទ្រង់ជាចម្បងជាងសត្វលោក ប្រសើរជាងនរជន ។

មនុស្សមួយពួកទៀត យំរៀបរាប់ថា ព្រះសាស្តាទ្រង់ត្រេកអរហើយក្នុងវិវេក ទ្រង់នឹងទៅកាន់ដែនដទៃ ឬជនបទដទៃហើយ ព្រោះទ្រង់ខ្មាសថា តថាគតធ្វើបាដិហារ្យបែបនេះដល់បរិស័ទ ឥឡូវនេះ យើងទាំងឡាយមិនបានឃើញទ្រង់ ដូច្នេះហើយ ពោលគាថានេះថា

**បវិវេករតោ ធីរោ        ឥមំ លោកំ បុនេហិតិ**
**ន នោ នក្ខេមុ សម្ពុទ្ធំ        លោកជេដ្ឋំ នរាសភំ ។**

ព្រះសាស្តាជាអ្នកប្រាជ្ញ ទ្រង់ត្រេកអរហើយក្នុងវិវេក ទ្រង់មិនត្រឡប់មកកាន់លោកនេះទៀត យើងទាំងឡាយ មិនឃើញព្រះសម្ពុទ្ធ ទ្រង់ជាចម្បងជាងសត្វលោក ប្រសើរជាងនរជន ។

ជនទាំងនោះ សួរព្រះមហាមោគ្គល្លានដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះសាស្តាយាងទៅណា ទោះបីលោកជ្រាប ក៏ពោលថា ចូរសួរអនុរុទ្ធចុះ ដោយបំណងថា គុណរបស់សាវ័កដទៃ ចូរប្រាកដដូច្នេះ ។ ជនទាំងនោះ សួរព្រះថេរៈយ៉ាងនោះថា បពិត្រលោកម្ចាស់ព្រះសាស្តាយាងទៅណា ។

ព្រះអនុរុទ្ធឆ្លើយថា ទ្រង់យាងទៅចាំវស្សាត្រង់បណ្ឌុកម្ពលសិលាក្នុងឋានតាវត្តិង្ស ហើយទ្រង់សម្តែងព្រះអភិធម្មបិដកដល់ព្រះពុទ្ធមាតា ។ មហាជនសួរថា បពិត្រលោកម្ចាស់ ទ្រង់នឹងយាងមកក្នុងកាលណា ។

ព្រះអនុរុទ្ធឆ្លើយថា ទ្រង់សម្តែងព្រះអភិធម្មបិដក អស់កាល ៣

ខែហើយ ទ្រង់នឹងយាងមកក្នុងថ្ងៃមហាបវារណា ។ ជនទាំងនោះនិយាយគ្នាថា បើពួកយើងមិនបានឃើញព្រះសាស្តា នឹងមិនទៅ ដូច្នេះហើយបោះជំរុំស្នាក់នៅក្នុងទីនោះឯង ។ បានឮថា ជនទាំងនោះ មានអាកាសនោះឯង ជាគ្រឿងប្រក់ ។ ឈ្មោះថា ញើសដែលហូរចេញអំពីខ្លួនរបស់បរិស័ទច្រើនដល់ម៉្លោះ មិនប្រាកដឡើយ ផែនដីបានបើកឱកាសឲ្យហើយ ផ្ទៃនៃផែនដីក្នុងទីគ្រប់កន្លែង ជាទីរាបស្មើស្អាតនោះឯង ។

ព្រះសាស្តា ទ្រង់ត្រាស់ប្រាប់ព្រះមហាមោគ្គល្លានត្ថេរមុនគេថា ម្នាលមោគ្គល្លាន អ្នកគប្បីសម្តែងធម៌ដល់បរិស័ទនោះ ចូឡអនាថបិណ្ឌិកនឹងឲ្យអាហារ ។ ព្រោះហេតុនោះ ចូឡអនាថបិណ្ឌិកបានឲ្យហើយនូវបបរ បាយ របស់ទំពា ប្រេង គ្រឿងក្រអូប ផ្កាកម្រង និងគ្រឿងប្រដាប់ដល់បរិស័ទទាំងនោះ រហូត ៣ ខែនោះ ។ ព្រះមហាមោគ្គល្លានត្ថេរសម្តែងធម៌ វិសជ្ជនាបញ្ហាដែលសួរហើយ ដល់ពួកជនដែលមកហើយដើម្បីមើលបាដិហារ្យ ។ ទេវតាក្នុងម៉ឺនចក្កវាឡចោមរោមព្រះសាស្តាដែលទ្រង់ចាំវស្សាត្រង់បណ្ឌុកម្ពលសិលា ដើម្បីទ្រង់សម្តែងព្រះអភិធម្មដល់ព្រះមាតា ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា

**តាវតឹ្តសេ យទា ពុទ្ធោ   សិលាយំ បណ្ឌុកម្ពលេ**
**ចារិច្ឆត្តកមូលម្ហិ   វិហាសិ បុរិសុត្តមោ ។**

កាលណា ព្រះពុទ្ធឧត្តមជាងបុរស គង់នៅលើថ្មបណ្ឌុកម្ពល

*ជិតគល់នៃបារិច្ឆត្តកព្រឹក្ស ក្នុងជាន់តាវត្តិង្ស ។*

**ទសសុ លោកធាតូសុ　　សន្និបតិត្វាន ទេវតា**

**បយិរុបាសន្តិ សម្ពុទ្ធំ　　វសន្តំ នគមុទ្ធនិ ។**

*ទេវតាទាំងឡាយក្នុងលោកធាតុទាំង ១០ បានប្រជុំគ្នា ចូលទៅអង្គុយជិតព្រះសម្ពុទ្ធ ដែលគង់នៅលើកំពូលភ្នំ ( សុមេរុ ) ។*

**ន កោចិ ទេវោ វណ្ណេន　　សម្ពុទ្ធំ អតិរោចតិ**

**សព្វេ ទេវេ អតិក្កម្ម　　សម្ពុទ្ធោវ វិរោចតិ ។**

*ទេវតាណាមួយ រុងរឿងជាងព្រះសម្ពុទ្ធដោយវណ្ណៈ មិនមានឡើយ មានតែព្រះសម្ពុទ្ធមួយព្រះអង្គឯងប៉ុណ្ណោះ រុងរឿងកន្លងនូវទេវតាទាំងអស់[១] ។*

*កាលព្រះសាស្តាទ្រង់គង់គ្របសង្កត់ទេវតាគ្រប់ពួក ដោយរស្មីនៃព្រះសរីរៈរបស់ទ្រង់យ៉ាងនេះ ពុទ្ធមាតាយាងមកអំពីវិមានក្នុងជាន់តុសិតអង្គុយខាងស្តាំ ឥន្ទកទេវបុត្តក៏មកអង្គុយខាងស្តាំដូចគ្នា ឯអង្កុរទេវបុត្តអង្គុយខាងឆ្វេង ។ អង្កុរទេវបុត្តនោះ កាលទេវតាទាំងឡាយដែលមានសក្តិធំ ប្រជុំគ្នា ខ្ចាតចេញទៅហើយ បានឱកាសក្នុងទីប្រមាណ ១២ យោជន៍ ចំណែកឥន្ទកទេវបុត្តអង្គុយក្នុងទីនោះឯង ។ ព្រះសាស្តាទ្រង់ទតទេវបុត្តទាំងពីរអង្គនោះហើយ មានព្រះបំណងនឹងញុំាងបរិស័ទឲ្យ*

---

*១-បិ.៥៦ ទំ.៥៤ ឃ.២១ ។*

ដឹង នូវទានដែលបុគ្គលឲ្យហើយដល់ទក្ខិណេយ្យបុគ្គល ក្នុងសាសនារបស់ព្រះអង្គថា មានផលច្រើន ទើបត្រាស់យ៉ាងនេះថា ម្នាលអង្កុរៈ អ្នកធ្វើចង្ក្រានបណ្ដោយ ១២ យោជន៍ ឲ្យមហាទានអស់កាល ១ ម៉ឺនឆ្នាំ នេះជារយៈកាលយូរ ឥឡូវនេះ អ្នកមកក្នុងសមាគមរបស់តថាគត បានឱកាសក្នុងទីចម្ងាយ ១២ យោជន៍ អ្វីហ្ន៎ជាហេតុក្នុងសេចក្ដីនេះ ។ សមដូចព្រះធម្មសង្គាហកាចារ្យទាំងឡាយពោលទុកថា

ឱលោកេត្វាន សម្ពុទ្ធោ អង្កុរញ្ចាបិ ឥន្ទកំ
ទក្ខិណេយ្យំ សម្ភាវេន្តោ ឥទំ វចនមព្រវិ
មហាទានំ តយា ទិន្នំ អង្កុរ ទីឃមន្តរំ
អតិទូរេ និសិន្នោសិ អាគច្ឆ មម សន្តិកំ ។

ព្រះសម្ពុទ្ធ ទ្រង់រមិលមើលនូវអង្កុរទេវបុត្ត និងឥន្ទកទេវបុត្ត កាលទ្រង់សរសើរនូវទក្ខិណេយ្យបុគ្គល បានត្រាស់សម្ដែងនូវពាក្យនេះថា ម្នាលអង្កុរៈ មហាទានដែលអ្នកឲ្យហើយអស់ចន្លោះនៃកាលដ៏វែង អ្នកអង្គុយក្នុងទីឆ្ងាយពេកណាស់ ចូរមកជិតតថាគតមក[១] ។

ព្រះសូរសៀងនោះឮដល់ផែនដី បរិស័ទទាំងអស់បានឮព្រះសូរ-សៀងនោះ ។

---

១-បិ.៥៦ ទំ.៥៤ ឃ.២១ ។

ចោទិតោ ភាវិតត្តេន អង្គុរោ ឥធមព្រវិ
កឹ មយ្ហំ តេន ទានេន ទក្ខិណេយ្យេន សុញ្ញតំ ។

*អង្កុរទេវបុត្តដែលព្រះសម្ពុទ្ធមានព្រះអង្គអប់រំហើយ ទ្រង់ដាស់តឿនហើយ ក៏បានក្រាបបង្គំទូលដូច្នេះថា ប្រយោជន៍អ្វីដោយទាននោះ របស់ខ្ញុំព្រះអង្គ ព្រោះ ( ទាននោះ ) សូន្យចាកទក្ខិណេយ្យបុគ្គល ។*

អយំ សោ ឥន្ទកោ យក្ខោ ទជ្ជា ទានំ បរិត្តកំ
អតិរោចតិ អម្ហេហិ ចន្ទោ តារគណេយថា ។

*ឥន្ទកយក្ខនេះឯង ឲ្យទានតិចតួចទេ រុងរឿងជាងពួកខ្ញុំព្រះអង្គ ដូចជាព្រះចន្ទក្នុងពួកផ្កាយ[១] ។*

*កាលអង្កុរទេវបុត្តក្រាបបង្គំទូលដូច្នេះហើយ ព្រះសាស្តាត្រាស់នឹងឥន្ទកទេវបុត្តថា ម្នាលឥន្ទកៈ អ្នកអង្គុយខាងស្តាំតថាគត ព្រោះហេតុអ្វីមិនខ្វាតចេញទៅឆ្ងាយ ។*

*ឥន្ទកទេវបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានបុគ្គលអ្នកដល់ព្រមដោយទក្ខិណេយ្យហើយ ដូចអ្នកស្រែព្រោះពូជបន្តិចបន្តួចក្នុងស្រែល្អដូច្នោះ កាលសម្តែងទក្ខិណេយ្យបុគ្គល ទើបក្រាបទូលថា*

---

*១-បិ.៥៦ ទំ.៥៤ ឃ.២១ ។*

ឧជ្ជង្គលេ យថា ខេត្តេ ពីជំ ពហុំបិ រោបិតំ
ន ផលំ វិបុលំ ហោតិ នបិ តោសេតិ កស្សកំ ។
តថេវ ទានំ ពហុកំ ទុស្សីលេសុ បតិដ្ឋិតំ
ន ផលំ វិបុលំ ហោតិ នបិ តោសេតិ ទាយកំ ។

*ពូជដែលបុគ្គលព្រោះហើយ សូម្បីមានប្រមាណច្រើន ក្នុងស្រែទួល ផលរមែងមិនបរិបូណ៌ ទាំងមិនញ៉ាំងអ្នកស្រែឲ្យត្រេកអរបាន ដូចម្តេចមិញ ទានដែលបុគ្គលតម្កល់ទុកហើយមានប្រមាណច្រើន ក្នុងបុគ្គលទ្រុស្តសីលទាំងឡាយ ផលរមែងមិនបរិបូណ៌ ទាំងមិនបានញ៉ាំងទាយកឲ្យត្រេកអរបានក៏ដូច្នោះដែរ ។*

យថាបិ ភទ្ទកេ ខេត្តេ ពីជំ អប្បម្បិ រោបិតំ
សម្មាធារំ បវេច្ឆន្តេ ផលំ តោសេតិ កស្សកំ
តថេវ សីលវន្តេសុ គុណវន្តេសុ តាទិសុ
អប្បកំបិ កតំ ការំ បុញ្ញំ ហោតិ មហប្ផលំ ។

*ពូជដែលបុគ្គលព្រោះហើយ សូម្បីតិច ក្នុងស្រែដ៏ល្អ កាលភ្លៀងធ្លាក់ស្រួល ផលរមែងញ៉ាំងអ្នកស្រែឲ្យត្រេកអរបាន ដូចម្តេចមិញ សក្ការៈដែលបុគ្គលធ្វើហើយ សូម្បីតិចតួចក្នុងតាទិបុគ្គលទាំងឡាយ មានសីល មានគុណ បុណ្យរមែង*

មានផលច្រើន ក៏ដូច្នោះឯង [១] ។

សួរថា បុព្វកម្មរបស់ឥន្ទកទេវបុត្តនោះ ដូចម្តេច ។

ឆ្លើយថា បានឮថា ឥន្ទកទេវបុត្តនោះ បានប្រគេនបាយ ១ វែក ដែលគេនាំមកដើម្បីខ្លួន ដល់ព្រះអនុរុទ្ធត្ថេរ ដែលចូលទៅបិណ្ឌបាតក្នុងស្រុក ។ បុណ្យរបស់ឥន្ទកៈនោះ មានផលច្រើនជាងទានដែលអង្កុរទេវបុត្តធ្វើហើយដោយជួរនៃជើងក្រាន ប្រវែង ១២ យោជន៍ ឲ្យហើយរាប់ម៉ឺនឆ្នាំ ព្រោះហេតុនោះ ទើបឥន្ទកទេវបុត្តក្រាបបង្គំទូលយ៉ាងនោះ ។

កាលឥន្ទកទេវបុត្តក្រាបបង្គំទូលយ៉ាងនោះហើយ ព្រះមានព្រះភាគត្រាស់នឹងអង្កុរទេវបុត្តថា ម្នាលអង្កុរៈ ការជ្រើសរើសមុន ហើយឲ្យទានទើបគួរ ទាននោះ រមែងមានផលច្រើនដោយអាការយ៉ាងនេះ ដូចពូជដែលគេព្រោះល្អក្នុងស្រែល្អដូច្នោះ តែអ្នកមិនបានធ្វើយ៉ាងនោះឡើយ ហេតុនោះ ទើបទានរបស់អ្នកមិនមានផលច្រើន ។ កាលទ្រង់ប្រកាសអត្ថនេះ ឲ្យជាក់ច្បាស់ ទើបត្រាស់ថា

**វិចេយ្យ ទានំ ទាតព្វំ យត្ថ ទិន្នំ មហប្ផលំ**
**វិចេយ្យ ទានំ ឧត្វាន សគ្គំ គច្ឆន្តិ ទាយកា ។**

ទានដែលបុគ្គលឲ្យហើយដល់បុគ្គលណា រមែងមានផលច្រើន
បុគ្គលគួរពិចារណាហើយ សឹមឲ្យទាន ទាយកទាំងឡាយ

---

១-បិ.៥៦ ទំ.៥៥ ឃ.២១ ។

ពិចារណាហើយឲ្យនូវទាន តែងទៅកាន់ឋានសួគ៌ ។

វិចេយ្យ ទានំ សុគតប្បសដ្ឋំ
យេ ទក្ខិណេយ្យា ឥធ ជីវលោកេ
ឯតេសុ ទិន្នានិ មហប្ផលានិ
ពីជានិ វុត្តានិ យថា សុខេត្តេ ។

ទានដែលបុគ្គលពិចារណាហើយ ទើបឲ្យ ព្រះសុគតទ្រង់សរសើរហើយ ទក្ខិណេយ្យបុគ្គលណា ដែលមាននៅក្នុងជីវលោកនេះ ទានដែលបុគ្គលឲ្យហើយ ដល់ទក្ខិណេយ្យបុគ្គលទាំងនោះ រមែងមានផលច្រើន ដូចពូជដែលបុគ្គលព្រោះហើយ ក្នុងស្រែល្អ [១] ។

កាលទ្រង់សម្តែងធម៌ឲ្យក្រៃលែងឡើង ទើបត្រាស់ព្រះគាថានេះថា

តិណទោសានិ ខេត្តានិ រាគទោសា អយំ បជា
តស្មា ហិ វីតរាគេសុ ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានរាគៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់អ្នកមានរាគៈអស់ហើយ រមែងជាទានមានផលច្រើន ។

តិណទោសានិ ខេត្តានិ ទោសទោសា អយំ បជា

១-បិ.៥៦ ទំ.៥៥ ឃ.២១ ។

តស្មា ហិ វីតទោសេសុ ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានទោសៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានទោសៈអស់ហើយ រមែងជាទានមានផលច្រើន ។

តិណទោសានិ ខេត្តានិ មោហទោសា អយំ បជា
តស្មា ហិ វីតមោហេសុ ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានមោហៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានមោហៈអស់ហើយ រមែងជាទានមានផលច្រើន ។

តិណទោសានិ ខេត្តានិ ឥច្ឆាទោសា អយំ បជា
តស្មា ហិ វិគតិច្ឆេសុ ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានសេចក្ដីប្រណែនជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានសេចក្ដីប្រណែនអស់ហើយ រមែងជាទានមានផលច្រើន [១] ។

ក្នុងកាលចប់ទេសនា អង្កុរទេវបុត្ត និងឥន្ទកទេវបុត្ត តាំងនៅហើយក្នុងសោតាបត្តិផល ។ ព្រះធម្មទេសនាមានប្រយោជន៍ច្រើន ដល់

---

១-បិ.៥២ ទំ.៩៧ ឃ.៣៨ ។

មហាជនដទៃទៀត ។

លំដាប់នោះ ព្រះសាស្តាប្រថាប់គង់កណ្តាលទេវបរិស័ទ ប្រារព្ធព្រះមាតា ផ្តើមសម្តែងព្រះអភិធម្មបិដកថា **កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា** ដូច្នេះជាដើម ។ ព្រះអង្គទ្រង់សម្តែងហើយនូវព្រះអភិធម្មបិដក ដោយន័យនេះ អស់កាល ៣ ខែ ជាប់មិនដាច់ ដោយប្រការយ៉ាងនេះ ។ កាលទ្រង់កំពុងសម្តែងធម៌ ក្នុងវេលាភិក្ខាចារ ទ្រង់និម្មិតព្រះពុទ្ធនិម្មិត ដោយទ្រង់អធិដ្ឋានថា ពុទ្ធនិម្មិតនេះ ចូរសម្តែងធម៌ឈ្មោះនេះ ទម្រាំតថាគតមក ហើយទ្រង់យាងទៅកាន់ព្រៃហិមពាន្ត ទ្រង់ទំពាឈើស្ទន់ឈ្មោះនាគលតា ខ្ពុរព្រះឱស្ឋត្រង់អនោតត្តស្រះ នាំបិណ្ឌបាតមកអំពីឧត្តរកុរុទ្វីប ប្រថាប់គង់ធ្វើភត្តកិច្ចក្នុងមហាសាលាមាឡកៈ ( រោងធំល្អ ) ។ ព្រះសារីបុត្តត្ថេរនិមន្តទៅធ្វើវត្ត ចំពោះព្រះសាស្តាក្នុងទីនោះ ។ ព្រះសាស្តាទ្រង់ធ្វើភត្តកិច្ចហើយ ត្រាស់ប្រាប់ព្រះថេរៈថា ម្នាលសារីបុត្ត ថ្ងៃនេះ តថាគតសម្តែងធម៌ឈ្មោះនេះ ចូរអ្នកប្រាប់ដល់ភិក្ខុ ៥០០ ដែលជាអន្តេវាសិករបស់ខ្លួន ។ បានឮថា កុលបុត្ត ៥០០ នោះ ជ្រះថ្លាក្នុងយមកប្បាដិហារ្យ បួសហើយក្នុងសម្នាក់របស់ព្រះថេរៈ ។ ព្រះសាស្តាទ្រង់ត្រាស់ហើយយ៉ាងនោះ សំដៅយកភិក្ខុទាំងនោះ ។ កាលត្រាស់ហើយ ទ្រង់យាងទៅកាន់ទេវលោក ទ្រង់សម្តែងធម៌ដោយព្រះអង្គឯងបន្តអំពីពុទ្ធនិម្មិត ។ ព្រះថេរៈក៏ទៅសម្តែងធម៌ដល់ភិក្ខុទាំងនោះ ។ ភិក្ខុ

ទាំងនោះ កាលព្រះសាស្តាគង់នៅក្នុងទេវលោកនោះឯង បានជាអ្នកជំនាញក្នុងបករណ៍ ៧ ហើយ ។

បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ ភិក្ខុទាំងនោះ ជាសត្វប្រចៀវ សំយុងខ្លួនត្រង់ញកភ្នំមួយកន្លែង កាលព្រះថេរៈ ២ រូបចង្រ្កមហើយសាធ្យាយអភិធម្ម បានស្តាប់ កាន់យកនិមិត្តក្នុងសំឡេងហើយ ។ ប្រចៀវទាំងនោះ មិនដឹងថា នេះឈ្មោះថា ខន្ធ នេះឈ្មោះថា ធាតុ ដោយហេតុត្រឹមតែកាន់យកនិមិត្តក្នុងសំឡេងប៉ុណ្ណោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក បានសោយទិព្វសម្បត្តិអស់ ១ ពុទ្ធន្តរ ចុតិអំពីទេវលោកនោះហើយ កើតក្នុងផ្ទះមានត្រកូលក្នុងក្រុងសាវត្ថី ។ កើតសេចក្តីជ្រះថ្លាក្នុងយមកបា្បដិហារ្យ បួសក្នុងសម្នាក់ព្រះថេរៈហើយ បានជាអ្នកជំនាញក្នុងបករណ៍ ៧ មុនភិក្ខុទាំងពួង ។ ព្រះសាស្តាទ្រង់សម្តែងព្រះអភិធម្មដោយទំនងនោះឯង អស់ ៣ ខែ ។ ក្នុងកាលចប់ទេសនា ធម្មាភិសម័យមានដល់ទេវតា ៨ ម៉ឺនកោដិ សូម្បីទេវបុត្តដែលជាព្រះនាងមហាមាយា ក៏តាំងនៅក្នុងសោតាបត្តិផលហើយ ។

បរិស័ទមានបរិមណ្ឌល ៣៦ យោជន៍នោះ គិតថា បន្ទាប់អំពីនេះទៅ ក្នុងថ្ងៃទី ៧ ត្រូវជាថ្ងៃមហាបវារណា ទើបចូលទៅរកព្រះមហាមោគ្គល្លានត្ថេរ ពោលថា បពិត្រលោកម្ចាស់ ពួកយើងគួរដឹងថ្ងៃយាងចុះរបស់ព្រះសាស្តា ព្រោះយើងទាំងឡាយ បើមិនបានឃើញព្រះសាស្តា ក៏

មិនទៅ ។ ព្រះមហាមោគ្គល្លានដ៏មានអាយុស្តាប់ពាក្យនោះហើយ ទទួលថា ប្រពៃហើយ អ្នកមានអាយុ ហើយមុជចុះក្នុងផែនដីត្រង់នោះឯងអធិដ្ឋានថា សូមបរិស័ទឃើញអាត្មាអញដែលទៅដល់ជើងភ្នំសិនេរុ ហើយផុសឡើង មានរូបប្រាកដដូចអំបោះក្រហម ដែលដោតទុកក្នុងកែវមណីឡើងទៅហើយត្រង់កណ្តាលភ្នំសិនេរុ ។ សូម្បីពួកមនុស្សក៏ឃើញលោកថា ឡើងទៅហើយ ១ យោជន៍ ឡើងទៅហើយ ២ យោជន៍ ។ ព្រះថេរៈឡើងទៅថ្វាយបង្គំព្រះយុគលបាទរបស់ព្រះសាស្តា ដូចទូលដោយក្បាលក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បរិស័ទបំណងនឹងគាល់ព្រះអង្គសិន ទើបទៅ តើព្រះអង្គទ្រង់យាងចុះក្នុងកាលណា ។

ព្រះសាស្តាត្រាស់សួរថា ម្នាលមោគ្គល្លាន សារីបុត្តបងប្រុសរបស់អ្នក នៅឯណា ។ ព្រះមហាមោគ្គល្លានដ៏មានអាយុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន លោកចាំវស្សានៅក្នុងសង្កស្សនគរ ។ ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះតថាគតនឹងចុះត្រង់ទ្វារនគរសង្កស្សៈ ក្នុងថ្ងៃមហាបវារណា បុគ្គលណាប្រាថ្នាចង់ឃើញតថាគត ចូរទៅក្នុងទីនោះចុះ នគរសង្កស្សៈ ឆ្ងាយអំពីក្រុងសាវត្ថី ប្រមាណ ៣០ យោជន៍ ក្នុងផ្លូវចម្ងាយប៉ុណ្ណោះ កិច្ចដែលត្រូវត្រៀមស្បៀង រមែងមិនមានដល់បុគ្គលណាឡើយ អ្នកគប្បីប្រាប់ដល់មនុស្សទាំងនោះថា អ្នកទាំងឡាយ ចូរជាអ្នករក្សាឧបោសថ ដូចទៅកាន់

វិហារដែលនៅជិត ស្តាប់ធម៌ចុះ ។ ព្រះថេរៈទទួលថា បពិត្រព្រះអង្គដ៏ចម្រើន ប្រពៃហើយ ហើយបានប្រាប់តាមព្រះបណ្តាំ ។

ព្រះសាស្តាទ្រង់ចាំវស្សាបវារណាហើយ ត្រាស់ប្រាប់សក្កទេវរាជថា មហាបពិត្រ តថាគតនឹងទៅកាន់ដែនដីមនុស្ស ។ សក្កទេវរាជទ្រង់និម្មិតជណ្តើរបី គឺជណ្តើរមាស ជណ្តើរកែវមណី ជណ្តើរប្រាក់ ។ ជើងជណ្តើរទាំងនោះ តាំងនៅត្រង់ខ្លោងទ្វារនគរសង្កស្សៈ ក្បាលជណ្តើរទាំងនោះ តាំងនៅត្រង់កំពូលភ្នំសិនេរុ ។ ក្នុងជណ្តើរទាំងនោះ ជណ្តើរមាសនៅខាងស្តាំដើម្បីពួកទេវតាទាំងឡាយ ជណ្តើរប្រាក់នៅខាងឆ្វេងដើម្បីពួកព្រហ្មទាំងឡាយ ជណ្តើរកែវមណីនៅត្រង់កណ្តាលដើម្បីព្រះតថាគត ។ ព្រះសាស្តាទ្រង់ប្រថាប់ឈរលើកំពូលភ្នំសិនេរុ ធ្វើយមកប្បាដិហារ្យក្នុងកាលដែលទ្រង់ចុះអំពីទេវលោក ទ្រង់សម្លឹងមើលខាងលើ ទីដែលទ្រង់ទតហើយទាំងឡាយ ក្លាយជាបើកចំហតែមួយដល់ព្រហ្មលោក ។ កាលទ្រង់ទតខាងក្រោម ទីដែលទ្រង់ទតហើយទាំងឡាយ ក្លាយជាបើកចំហតែមួយដល់អវិចីនរក ទ្រង់សម្លឹងមើលទិសតូចទិសធំទាំងឡាយ ចក្កវាឡច្រើនសែន បើកចំហដូចគ្នាតែមួយ ។ ទេវតាឃើញពួកមនុស្ស ពួកមនុស្សឃើញទេវតា ពួកទេវតានិងមនុស្សទាំងអស់ ឃើញគ្នាហើយចំពោះមុខនោះឯង ។

ព្រះមានព្រះភាគ ទ្រង់បញ្ចេញព្រះឆព្វណ្ណរង្សី មនុស្សក្នុងបរិស័ទ

ដែលមានបរិមណ្ឌល ៣៦ យោជន៍ បុគ្គលសូម្បីតែម្នាក់ កាលសម្លឹងមើលសិរីរបស់ព្រះពុទ្ធក្នុងថ្ងៃនោះហើយ ឈ្មោះថា មិនប្រាថ្នាភាពជាព្រះពុទ្ធមិនមានឡើយ ។ ពួកទេវតាចុះតាមជណ្តើរមាស ពួកមហាព្រហ្មចុះតាមជណ្តើរប្រាក់ ព្រះសម្មាសម្ពុទ្ធយាងចុះតាមជណ្តើរកែវមណី ។ គន្ធព្វទេវបុត្តឈ្មោះបញ្ចសិខៈ កាន់ពិណពណ៌លឿងដូចផ្លែព្នៅ ឈរខាងស្តាំបូជាដោយការច្រៀង អមដោយសំឡេងពិណដ៏ពីរោះ ចំពោះព្រះសាស្តាចុះមក មាតលិសង្គាហកទេវបុត្តឈរខាងឆ្វេង កាន់ផ្កាកម្រង និងគ្រឿងក្រអូបដែលជាទិព្វ នមស្ការបូជា ចុះមក មហាព្រហ្មបាំងឆត្រ ស្តេចសុយាមៈកាន់ផ្លិតវាលវីជនី ។ ព្រះសាស្តាយាងចុះមក មួយអន្លើដោយបរិវារនេះ ទ្រង់ប្រថាប់ឈរត្រង់ខ្លោងទ្វារនគរសង្កស្សៈ ។ ព្រះសារីបុត្តត្ថេរថ្វាយបង្គំព្រះសាស្តាហើយ ព្រោះព្រះសាស្តាយាងចុះដោយពុទ្ធសិរីបែបនេះ ដែលលោកមិនធ្លាប់បានឃើញក្នុងកាលមុនអំពីនេះ ព្រោះហេតុនោះ ទើបប្រកាសសេចក្តីត្រេកអររបស់ខ្លួន ដោយគាថាជាដើមថា

**ន មេ ទិដ្ឋោ ឥតោ បុព្វេ ន សុតោ ឧទ កស្សចិ**
**ឯវំ វគ្គុវទោ សត្ថា តុសិតា គណិមាគតោ ។**

ព្រះមានព្រះភាគ ជាសាស្តាចារ្យ ព្រះអង្គចុះចាកតុសិត
មកជាគណាចារ្យ ព្រះអង្គមានព្រះវាចាពីរោះយ៉ាងនេះ ខ្ញុំ
ព្រះអង្គមិនដែលឃើញ មិនដែលឮ អំពីសម្នាក់អ្នកណា

មួយ ក្នុងកាលមុនអំពីកាលដែលព្រះអង្គស្ដេចចុះមកកាន់ក្រុងសង្កស្សៈសោះឡើយ (១) ។

ហើយក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះ ទេវតានិងមនុស្សទាំងឡាយ រមែងទន្ទឹងចំពោះព្រះអង្គ ។ លំដាប់នោះ ព្រះសាស្ដាត្រាស់ថា ម្នាលសារីបុត្ត ព្រះពុទ្ធទាំងឡាយដែលប្រកបព្រមដោយគុណបែបនេះ រមែងជាទីស្រឡាញ់របស់ទេវតានិងមនុស្សទាំងឡាយដោយពិត ។ កាលទ្រង់សម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**យេ ឈានបសុតា ធីរា នេក្ខម្មូបសមេ រតា**
**ទេវាបិ តេសំ បិហយន្តិ សម្ពុទ្ធានំ សតីមតំ ។**

អ្នកប្រាជ្ញទាំងឡាយណា ជាអ្នកខ្វល់ខ្វាយក្នុងឈាន ត្រេកអរក្នុងនេក្ខម្មៈ ជាឋានស្ងប់រម្ងាប់កិលេស សូម្បីទេវតានិងមនុស្សទាំងឡាយ តែងរាប់រកចំពោះអ្នកប្រាជ្ញទាំងឡាយនោះ ដែលជាអ្នកត្រាស់ដឹងខ្លួនឯង ទាំងមានស្មារតី (២) ។

ក្នុងកាលចប់ទេសនា ធម្មាភិសម័យមានដល់សត្វប្រមាណ ៣០ កោដិ ភិក្ខុ ៥០០ ដែលជាសទ្ធិវិហារិករបស់ព្រះថេរៈ តាំងនៅហើយក្នុងអរហត្ត ។

បានឮថា ការធ្វើយមកប្បាដិហារ្យ ហើយចាំវស្សាក្នុងទេវលោក

---

១-បិ.៥៤ ទំ.៣១៨ ឃ.១១០ ។ ២-បិ.៥២ ទំ.៦០ ឃ.២៤ ។

ចុះត្រង់ទ្វារនគរសង្កស្សៈ ព្រះពុទ្ធគ្រប់ព្រះអង្គទ្រង់មិនដែលលះបង់ឡើយ ។ ទីដែលព្រះបាទខាងស្តាំប្រតិស្ឋាន ក្នុងទីដែលទ្រង់ចុះនោះមានឈ្មោះថា អចលចេតិយស្ថាន ។ ព្រះសាស្តាប្រថាប់ឈរក្នុងទីនោះត្រាស់សួរបញ្ហាក្នុងវិស័យរបស់បុថុជ្ជនជាដើម ពួកបុថុជ្ជនឆ្លើយបញ្ហាបានក្នុងវិស័យរបស់ខ្លួនប៉ុណ្ណោះ មិនអាចឆ្លើយបញ្ហាក្នុងវិស័យព្រះសោតាបន្នបាន ។ ព្រះអរិយបុគ្គលទាំងឡាយ មានព្រះសោតាបន្នជាដើម ក៏ដូចគ្នា មិនអាចឆ្លើយបញ្ហាក្នុងវិស័យព្រះអរិយបុគ្គលទាំងឡាយ មានព្រះសកទាគាមីជាដើម មហាសាវ័កដ៏សេស មិនអាចឆ្លើយបញ្ហាក្នុងវិស័យរបស់ព្រះមហាមោគ្គល្លានត្ថេរ ព្រះមហាមោគ្គល្លានមិនអាចឆ្លើយបញ្ហាក្នុងវិស័យរបស់ព្រះសារីបុត្តត្ថេរបាន ព្រះសារីបុត្តក៏មិនអាចឆ្លើយបញ្ហាក្នុងពុទ្ធវិស័យបានដូចគ្នា ។ ព្រះសាស្តាទ្រង់សម្លឹងមើលទិសទាំងពួងតាំងអំពីទិសបូព៌ទៅ ស្ថានទីទាំងពួង បើកចំហដូចគ្នាទុំះឯង ។ ទេវតានិងមនុស្សក្នុងទិសទាំង ៨ និងទេវតាខាងលើ ទល់នឹងព្រហ្មលោក យក្ខនាគ និងគ្រុឌ ដែលនៅត្រង់ផ្ទៃខាងក្រោម ផ្គងអញ្ជលីក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឈ្មោះថា បុគ្គលវិសជ្ជនាបញ្ហានេះ មិនមានក្នុងសមាគមនេះ សូមទ្រង់ពិចារណាក្នុងសមាគមនេះឯង ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា សារីបុត្តរមែងលំបាក ព្រោះថា សារីបុត្តបានស្តាប់បញ្ហាដែលតថាគតសួរហើយ ក្នុងពុទ្ធវិស័យនេះថា

យេ ច សង្ខាតធម្មាសេ យេ ច សេក្ខា បុថូ ឥធ
តេសំ មេ និបកោ ឥរិយំ បុដ្ឋោ បព្រូហិ មារិស ។

ពួកអសេក្ខបុគ្គល អ្នកមានធម៌ពិចារណាហើយ និងពួកសេក្ខបុគ្គលជាច្រើនណា ក្នុងសាសនានេះ ម្នាលអ្នកនិរទុក្ខ តថាគតសួរនូវសេចក្តីប្រព្រឹត្តទៅ នៃបុគ្គលទាំងនោះ អ្នកមានបញ្ញាចាស់ក្លា ចូរសម្តែងប្រាប់ដល់តថាគត[១] ។

សារីបុត្តជាអ្នកមិនមានសេចក្តីសង្ស័យក្នុងបញ្ហាថា ព្រះសាស្តាទ្រង់ត្រាស់សួរនូវបដិបទាជាទីមក គឺមគ្គបដិបទារបស់សេក្ខៈ និងអសេក្ខៈ នឹងអាត្មាអញ ប៉ុន្តែកាលពោលនូវបដិបទានេះ ដោយប្រធានណាមួយហ្ន៎ ក្នុងធម៌ទាំងឡាយ មានខន្ធជាដើម ទើបសង្ស័យក្នុងអធ្យាស្រ័យរបស់តថាគតថា អញនឹងមិនអាចដើម្បីកាន់យកនូវអធ្យាស្រ័យរបស់ព្រះសាស្តាបានទេ ។ សារីបុត្តនោះ កាលបើតថាគតមិនឲ្យន័យ នឹងមិនអាចដើម្បីឆ្លើយបានទេ តថាគតនឹងឲ្យន័យដល់សារីបុត្តនោះ ទើបត្រាស់ថា ម្នាលសារីបុត្ត ចូរអ្នកពិចារណានូវភូតនេះ ។ បានឮថា ព្រះអង្គទ្រង់ព្រះតម្រិះយ៉ាងនេះថា សារីបុត្ត កាលកាន់យកអធ្យាស្រ័យរបស់តថាគតបានហើយ កាលឆ្លើយ នឹងឆ្លើយដោយអំណាចខន្ធ (ជាដើម) បាន ។ បញ្ហានោះ

---

១-បិ.៥៤ ទំ.៣៣៦ ឃ.១១២ ។ សេចក្តីនៃព្រះគាថានេះ ប្រែតម្រូវតាមព្រះសាស្តាទ្រង់ត្រាស់សួរ ព្រះសារីបុត្តជាអ្នកឆ្លើយ សប្បុរសគប្បីជ្រាប ។

ប្រាកដដល់ព្រះថេរៈរាប់រយរាប់ពាន់ន័យ មួយអន្លើដោយការប្រទានន័យ លោកតាំងនៅក្នុងន័យដែលព្រះសាស្តាទ្រង់ប្រទាន ឆ្លើយបញ្ហានោះបានហើយ ។ បានឮថា អ្នកដទៃ វៀរព្រះមានព្រះភាគចេញ ឈ្មោះថាអាចទាន់នូវបញ្ញារបស់ព្រះសារីបុត្ត មិនមាន ។ បានឮថា ព្រោះហេតុនោះឯង ទើបព្រះថេរៈឈរចំពោះព្រះភក្ត្រព្រះសាស្តា បន្លឺសីហនាទថា បពិត្រព្រះអង្គដ៏ចម្រើន កាលភ្លៀងធ្លាក់អស់មួយកប្ប ខ្ញុំព្រះអង្គក៏អាចរាប់បានថា តំណក់ទឹកទាំងឡាយ ធ្លាក់ក្នុងមហាសមុទ្រប៉ុណ្ណោះតំណក់ ធ្លាក់លើផែនដីប៉ុណ្ណោះតំណក់ លើភ្នំប៉ុណ្ណោះតំណក់ ។ សូម្បីព្រះសាស្តាក៏ត្រាស់នឹងលោកថា ម្នាលសារីបុត្ត តថាគតក៏ដឹងភាពដែលអ្នកអាចរាប់បាន ។ ឈ្មោះថា ឧបមាប្រៀបដោយបញ្ញារបស់លោកមានអាយុនោះរមែងមិនមាន ។ ព្រោះហេតុនោះ ទើបលោកក្រាបបង្គំទូលថា

**គង្គាយ វាលុកា ខីយេ ឧទកំ ខីយេ មហណ្ណវេ**
**មហិយា មត្តិកា ខីយេ ន ខីយេ មម ពុទ្ធិយា ។**

ខ្សាច់ក្នុងស្ទឹងគង្គា គប្បីអស់ទៅ ទឹកក្នុងមហាសមុទ្រ គប្បីអស់ទៅ ដីក្នុងផែនដី គប្បីអស់ទៅ ការឆ្លើយបញ្ហាដោយការដឹងរបស់ខ្ញុំព្រះអង្គ រមែងមិនអស់ទៅដោយការគណនា ដូច្នេះ ។

មានពាក្យអធិប្បាយទុកដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់បរិបូណ៌ដោយការដឹង ជាទីពឹងរបស់លោក បើខ្ញុំព្រះអង្គឆ្លើយបញ្ហា

មួយហើយ បុគ្គលគប្បីដាក់ខ្សាច់មួយគ្រាប់ ឬទឹកមួយតំណក់ ឬដីមួយដុំ កាលខ្ញុំព្រះអង្គឆ្លើយបញ្ហាមួយរយ ឬមួយពាន់ ឬមួយសែន គប្បីដាក់ខ្សាច់ទាំងឡាយ មានខ្សាច់ជាដើម មួយ ៗ ក្នុងចំណែកម្ខាងនៃស្ទឹងគង្គា ខ្សាច់ទាំងឡាយ មានខ្សាច់ជាដើម ក្នុងស្ទឹងគង្គាជាដើម គប្បីអស់ទៅមុន ឯការឆ្លើយបញ្ហារបស់ខ្ញុំព្រះអង្គមិនអស់ទៅឡើយ ។

ភិក្ខុមានបញ្ញាច្រើនយ៉ាងនេះ ក៏មិនឃើញចំណុចខាងដើម ឬចំណុចខាងចុងនៃបញ្ហាដែលព្រះសាស្តាទ្រង់សួរហើយ ក្នុងពុទ្ធវិស័យ ទាល់តែតាំងនៅក្នុងន័យដែលព្រះសាស្តាប្រទានហើយ ទើបឆ្លើយបញ្ហាបាន ។ ភិក្ខុទាំងឡាយស្តាប់ហេតុនោះហើយ សន្ទនាគ្នាថា ជនទាំងអស់ដែលព្រះសាស្តាត្រាស់សួរបញ្ហាណា មិនអាចឆ្លើយបាន ព្រះសារីបុត្តត្ថេរដែលជាធម្មសេនាបតីម្នាក់ប៉ុណ្ណោះ ឆ្លើយបញ្ហានោះបាន ។ ព្រះសាស្តាទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់ថា សារីបុត្តឆ្លើយបញ្ហាដែលមហាជនមិនអាចឆ្លើយបានតែក្នុងឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុន សារីបុត្តក៏ឆ្លើយបានហើយដូចគ្នា ហើយទ្រង់នាំអតីតនិទានមក ត្រាស់ជាតកនេះថា

បញ្ចសហស្សម្បិ សមាគតានំ
កាន្ទេយ្យុំ តេ វស្សសតំ អបញ្ញា
ឯកោវ សេយ្យោ បុរិសោ សបញ្ញោ
យោ ភាសិតស្ស វិជានាតិ អត្ថំ ។

ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីជាងពាន់នាក់ ជនទាំងនោះ ឥតប្រាជ្ញា គប្បីកន្ទក់កន្ទេញអស់ ១០០ ឆ្នាំ បុរសណា ប្រកបដោយប្រាជ្ញា បានដឹងច្បាស់នូវអត្ថនៃភាសិត បុរសនោះតែម្នាក់ឯង ប្រសើរជាង(១) ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់មានលាភសក្ការៈហូរជោរជន់ទូទៅទាំងជម្ពូទ្វីប ដូចស្ទឹងធំ ៥ ខ្សែដូច្នោះ ។

កាលនោះ ពួកតិរ្ថិយវិនាសចាកលាភសក្ការៈ កើតទុក្ខទោមនស្សអង្គុយមានកសំយុង មានមុខឱនចុះ ។ ក្នុងកាលនោះ ឧបាសិការបស់ពួកតិរ្ថិយទាំងនោះ ឈ្មោះចិញ្ចមាណវិកា ដល់នូវភាពជាអ្នកល្អលើសដោយរូបឆោម ឃើញពួកតិរ្ថិយទាំងនោះ អង្គុយយ៉ាងនោះ ទើបសួរថាបពិត្រលោកម្ចាស់ ព្រោះហេតុអ្វី ទើបលោកទាំងឡាយអង្គុយជាទុក្ខទោមនស្សយ៉ាងនេះ ។ ពួកតិរ្ថិយពោលថា ហៃប្អូនស្រី ព្រោះហេតុអ្វីទើបនាងមានសេចក្តីខ្វល់ខ្វាយតិច ។

នាងចិញ្ចមាណវិកាសួរថា មានរឿងអ្វី ។ ពួកតិរ្ថិយពោលថានៃប្អូនស្រី តាំងអំពីព្រះសមណគោតមកើតឡើងមក ពួកយើងវិនាសចាកលាភសក្ការៈអស់ អ្នកនគរមិនសម្គាល់ពួកយើងថា មានឡើយ ។

នាងចិញ្ចមាណវិកាសួរថា ក្នុងរឿងនេះ ខ្ញុំគួរធ្វើដូចម្តេច ។

---

១-បិ.៥៨ ទំ.៤៤ ឃ.៩៩ ។

ពួកតិរ្ថិយពោលថា នាងគួរធ្វើពាក្យនិន្ទាឲ្យកើតឡើងដល់ព្រះសមណគោតម ។ នាងចិញ្ចមាណវិកាពោលថា សេចក្តីនោះ មិនជាការលំបាកសម្រាប់ខ្ញុំឡើយ ។ កាលព្យាយាមធ្វើក្នុងរឿងនេះ ទើបទៅកាន់វត្តជេតពន ក្នុងវេលាដែលមហាជនចេញអំពីអារាម ហើយនៅក្នុងសម្នាក់របស់ពួកតិរ្ថិយក្បែរវត្តជេតពន ព្រឹកឡើង ក្នុងពេលដែលអ្នកនគរកាន់គ្រឿងក្រអូបជាដើម ទៅដើម្បីថ្វាយបង្គំព្រះមានព្រះភាគ ទើបចេញមក ធ្វើដូចជាចេញអំពីវត្តជេតពន កាលត្រូវសួរថា នាងដេកឯណា ក៏ឆ្លើយថា ប្រយោជន៍អ្វីដល់អ្នកទាំងឡាយ ដោយទីដេករបស់ខ្ញុំ ដូច្នេះហើយ ចៀសចេញទៅ ។ ពេលវេលាកន្លងទៅដោយលំដាប់ កាលនាងត្រូវសួរហើយ ទើបឆ្លើយថា ខ្ញុំដេកក្នុងព្រះគន្ធកុដិជាមួយព្រះគោតមហើយចេញមក ។ ពួកបុថុជ្ជនល្ងង់ខ្លៅក៏ជឿ បណ្ឌិតទាំងឡាយ មានព្រះសោតាបន្នជាដើម មិនជឿឡើយ ។

ថ្ងៃមួយ នាងចងកំណាត់ឈើមូលត្រង់ពោះ ដណ្តប់សំពត់ក្រហមពីលើ ហើយទៅពោលនឹងព្រះមានព្រះភាគ ដែលគង់សម្តែងធម៌ដល់បរិស័ទ ព្រមទាំងព្រះរាជាយ៉ាងនេះថា ព្រះសមណៈដ៏ចម្រើន ព្រះអង្គរវល់តែសម្តែងធម៌ មិនស្វែងរកខ្ទឹមនិងម្រេចជាដើមឲ្យដល់ខ្ញុំម្ចាស់ ដែលមានទារកក្នុងគភ៌ អាស្រ័យនូវព្រះអង្គកើតឡើងហើយ ។ ព្រះមានព្រះ-ភាគត្រាស់ថា ម្នាលប្អូនស្រី នាងនិងតថាគតប៉ុណ្ណោះដឹងនូវភាពនៃរឿង

នោះ ។ នាងចិញ្ចមាណវិកាពោលថា យ៉ាងនោះឯង ក្នុងកាលប្រឡូក-ប្រឡំដោយមេថុន ក៏ដឹងត្រឹមតែ ២ នាក់ អ្នកដទៃមិនដឹងទេ ។

ខណៈនោះ បណ្ឌុកម្ពលសិលាសនៈរបស់សក្កៈ សម្ដែងអាការក្ដៅ ។ សក្កៈទ្រង់ពិចារណាជ្រាបហេតុនោះ ទើបត្រាស់បង្គាប់ទេវបុត្ត ២ អង្គថា បណ្ដាអ្នកទាំងពីរ មួយអង្គចូរនិម្មិតជាសត្វកណ្ដុរ កាត់ចំណងដុំឈើមូលរបស់នាងឲ្យដាច់ មួយអង្គចូរបណ្ដាលមណ្ឌលខ្យល់ឲ្យតាំងឡើងបក់សំពត់ដណ្ដប់ឲ្យប៉ើងឡើងទៅខាងលើ ។ ទេវបុត្ត ២ អង្គនោះ បានទៅ ហើយធ្វើតាមនោះ ។ កំណាត់ឈើមូលធ្លាក់ចុះមក ត្រូវខ្នងជើងនាងបែក ។ បុថុជ្ជនទាំងឡាយដែលប្រជុំគ្នាក្នុងធម្មសភាទាំងអស់ ពោលថា នែមេចោរអាក្រក់ចង្រៃ នាងឯងធ្វើការមួលបង្កាច់បែបនេះ ដល់បុគ្គលដែលជាលោកនាយកក្នុងភព ៣ បែបនេះ ហើយក្រោកឡើង យកកណ្ដាប់ដៃប្រហារ ម្នាក់មួយដៃ ដេញចេញអំពីទីប្រជុំ កាលនាងផុតទស្សនៈគឺការឃើញរបស់ព្រះមានព្រះភាគ ផែនដីបានបើកឱកាស ។ ខណៈនោះ អណ្ដាតភ្លើងចេញអំពីអវិចីនរក តាំងឡើង លេបត្របាក់នាង ដូចដណ្ដប់សំពត់កម្ពលក្រហម ដែលត្រកូលប្រគល់ឲ្យ ហើយទាញទៅក្នុងអវិចីនរក ។ ចំណែកព្រះមានព្រះភាគទ្រង់រីងរឹតតែមានលាភសក្ការៈដ៏លើសលុប ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុកថា

សព្វាភិភុស្ស ពុទ្ធស្ស ជង្ឃោ ជាមាសិ សាវកោ

**តំ អព្ភាចិក្ខាយ និរយេ ចិរំ សំសរិតំ មយា ។**

*មួយទៀត តថាគតពោលបង្កាច់សាវ័ក ឈ្មោះនន្ទរបស់ព្រះពុទ្ធ ទ្រង់គ្រប់សង្កត់នូវសត្វលោកទាំងពួង តថាគតបានអន្ទោលទៅក្នុងនរកអស់កាលដ៏យូរ ព្រោះការពោលបង្កាច់នូវសាវ័កនោះ ។*

**ទសវស្សសហស្សានិ និរយេ សំសរឹ ចិរំ**

**មនុស្សលាភំ លទ្ធាហំ អព្ភក្ខានំ ពហុំ លភឹ ។**

*តថាគតបានអន្ទោលទៅក្នុងនរក អស់កាលដ៏យូរ ចំនួន ១ ម៉ឺនឆ្នាំ លុះតថាគតបានមកជាមនុស្ស ក៏បាននូវការពោលបង្កាច់ជាច្រើន ។*

**តេន កម្មាវសេសេន ចិញ្ចមាណវិកា មមំ**

**អព្ភាចិក្ខិ អភូតេន ជនកាយស្ស អាគតោ ។**

*ដោយសំណល់នៃកម្មនោះ នាងចិញ្ចមានវិកាមកពោលបង្កាច់តថាគត ក្នុងប្រជុំជន ដោយពាក្យមិនពិត*[១] *។*

**មុនាឡិពោធិសត្វទី ១ ចប់**[២]

---

*១-បិ.៧៤ ទំ.១២៥ ឃ.៩០ ។ ២-ស្រង់ចាកអដ្ឋកថា អបទាន បិ.៧៤ ទំ.១២៥ ឃ.៩០ និងអដ្ឋកថា ធម្មបទ ទេវោរោហណវត្ថុ ។*

# មុនាឡិពោធិសត្វទី ២

*បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វកើតជាមនុស្សមិនមានកេរ្តិ៍ឈ្មោះ ជាអ្នកលេង ឈ្មោះមុនាឡិ ព្រោះប្រឡូកប្រឡំជាមួយបុគ្គលពាល ទើបជេរ* **ព្រះបច្ចេកពុទ្ធ** *ព្រះនាមសុរភី ថា* **ទុស្សីលោ ចាប-ធម្មោ អយំ ភិក្ខុ** *ភិក្ខុនេះ ទ្រុស្តសីល មានធម៌ដ៏លាមក ។ ព្រោះវចីកម្មដែលជាអកុសលនោះ ព្រះពោធិសត្វឆេះក្នុងនរកច្រើនពាន់ឆ្នាំ ក្នុងអត្តភាពចុងក្រោយនេះ បានត្រាស់ដឹងជាព្រះពុទ្ធដោយកម្លាំងនៃបារមី ១០ ដល់នូវភាពជាអ្នកប្រសើរដោយលាភនិងយស ។ ពួកតិរ្ថិយកើតឧស្សាហៈឡើងម្តងទៀត គិតគ្នាថា ពួកយើងនឹងញុំាងទោសដែលមិនមែនជាយស ឲ្យកើតដល់ព្រះសមណគោតមបានដូចម្តេចហ្ន៎ ហើយនាំគ្នាអង្គុយជាទុក្ខទោមនស្ស ។*

*ក្នុងកាលនោះ បរិព្វាជិកាម្នាក់ ឈ្មោះសុន្ទរី ចូលទៅរកតិរ្ថិយទាំងនោះ ថ្វាយបង្គំហើយឈរ ឃើញតិរ្ថិយនៅស្ងៀមមិននិយាយអ្វី ទើបសួរថា* **កឹ មយ្ហំ ទោសោ** *ខ្ញុំមានកំហុសអ្វីឬ ។ ពួកតិរ្ថិយពោលថា ពួកយើងត្រូវសមណគោតមបៀតបៀន នាងបែរជាមានសេចក្តីខ្វល់ខ្វាយតិច នេះឯងជាទោសរបស់នាង ។ នាងសុន្ទរីពោលថា កាលបើដូច្នោះ ខ្ញុំនឹងធ្វើដូចម្តេច ក្នុងរឿងនេះ ។ ពួកតិរ្ថិយទាំងនោះ សួរនាងសុន្ទរីថា*

នាងអាចធ្វើការតិះដៀលឲ្យកើតដល់សមណគោតមបានដែរឬ ។ នាងសុន្ទរីឆ្លើយថា អាចលោកម្ចាស់ ។

ចាប់តាំងពីនោះមក ក៏ប្រាប់ដល់ពួកជនដែលបានចួបថា ខ្ញុំនដេកក្នុងព្រះគន្ធកុដិជាមួយនឹងព្រះសមណគោតមហើយ ទើបចេញមកដោយន័យដូចពោលខាងដើម ហើយដេរបរិភាស ។ ចំណែកពួកតិរ្ថិយក៏ដេរបរិភាសថា អ្នកដ៏ចម្រើនទាំងឡាយ ចូរមើលកម្មរបស់ព្រះសមណគោតម ។ សមដូចព្រះមានព្រះភាគទ្រង់ត្រាស់ថា

បុនាលិ នាមហំ ធុត្តោ ‌ ‌ បុព្វេ អញ្ញាសុ ជាតិសុ
បច្ចេកពុទ្ធំ សុរភឹ ‌ ‌ អព្ភាចិក្ខឹ អទូសកំ ។

ក្នុងភពមុន ក្នុងជាតិដទៃ តថាគតជាអ្នកលេង ឈ្មោះបុនាលិ បានពោលបង្កាច់នូវព្រះបច្ចេកពុទ្ធ ព្រះនាមសុរភី ព្រះអង្គជាបុគ្គលមិនប្រទូស្តឡើយ ។

តេន កម្មវិបាកេន ‌ ‌ និរយេ សំសរឹ ចិរំ
ពហូ វស្សសហស្សានិ ‌ ‌ ទុក្ខំ វេទេសិ វេទនំ ។

ដោយវិបាកនៃកម្មនោះ តថាគតអន្ទោលទៅក្នុងនរក អស់កាលដ៏យូរ រងទុក្ខវេទនា អស់ពាន់នៃឆ្នាំដ៏ច្រើន ។

តេន កម្មាវសេសេន ‌ ‌ ឥធ បច្ឆិមកេ ភវេ
អព្ភក្ខានំ មយា លទ្ធំ ‌ ‌ សុន្ទរិកាយ ការណា ។

ដោយសំណល់នៃកម្មនោះ ក្នុងបច្ឆិមភពនេះ តថាគតបាន
នូវការពោលបង្កាច់ ព្រោះហេតុនៃនាងសុន្ទរិកា [១] ។

ដោយការជេរយ៉ាងនេះ ពួកតិរ្ថិយនៅមិនអស់ចិត្ត ទើបគិតជាមួយនាងសុន្ទរី ឲ្យធ្វើការពោលទោសទៀត ហើយហៅអ្នកលេងមក ឲ្យថ្លៃឈ្នួល រួចប្រាប់ថា ពួកអ្នកចូរទៅសម្លាប់នាងសុន្ទរី ហើយកប់ទុកក្នុងគំនរសំរាមផ្កា ក្នុងទីជិតព្រះគន្ធកុដិរបស់ព្រះសមណគោតម ។ ពួកអ្នកលេង ក៏បានធ្វើយ៉ាងនោះ ។ បន្ទាប់អំពីនោះ ពួកតិរ្ថិយទាំងនោះ ក៏ក្រាបទូលព្រះរាជាថា ទូលព្រះបង្គំទាំងឡាយ មិនឃើញនាងសុន្ទរី ។

ព្រះរាជាត្រាស់ថា លោកម្ចាស់ទាំងឡាយ ចូរស្វែងរកមើល ។ ពួកតិរ្ថិយទាំងនោះ ក៏អូសសពមកអំពីទីដែលខ្លួនកប់ លើកឡើងដាក់លើគ្រែតូច នាំទៅឲ្យព្រះរាជាទ្រង់ទត ហើយត្រាច់ឃោសនាអំពីទោសរបស់ព្រះមានព្រះភាគនិងភិក្ខុសង្ឃ ក្នុងនគរទាំងមូលថា អ្នកទាំងឡាយចូរមើលកម្មរបស់ពួកសមណសក្យបុត្ត ហើយដាក់សពនាងសុន្ទរីលើគ្រែក្នុងទីស្មសាន ។ ព្រះរាជាត្រាស់បង្គាប់រាជបុរសថា អ្នកទាំងឡាយ ចូរស្វែងរកមនុស្សដែលសម្លាប់នាងសុន្ទរី ។

ក្នុងកាលនោះ ពួកអ្នកលេង ផឹកស្រាហើយឈ្លោះគ្នាថា ឯងសម្លាប់នាងសុន្ទរី ឯងសម្លាប់នាងសុន្ទរី ។ រាជបុរសទាំងឡាយ ក៏ចាប់

---

១-បិ.៧៤ ទំ.១២៥ ឃ.៩០ ។

ពួកអ្នកលេងទាំងនោះ ថ្វាយព្រះរាជា ។ ព្រះរាជាត្រាស់សួរថា ពួកអ្នកសម្លាប់នាងសុន្ទរីឬ ។

អ្នកលេងទាំងនោះ ក្រាបទូលថា ព្រះករុណាថ្លៃវិសេស ។

ព្រះរាជាត្រាស់សួរថា អ្នកណាបញ្ជា ។ កាលពួកអ្នកលេងក្រាបទូលថា ពួកតិរ្ថិយ ទើបឲ្យនាំពួកតិរ្ថិយមក ហើយឲ្យចង ត្រាស់បង្គាប់ថា ពួកអ្នក ចូរត្រាច់ទៅប្រកាសថា ពួកយើងឲ្យសម្លាប់នាងសុន្ទរីដោយខ្លួនឯង ដើម្បីឲ្យកើតនូវការតិះដៀលព្រះពុទ្ធ ព្រះមានព្រះភាគនិងពួកសាវ័ក មិនមែនជាអ្នកធ្វើឡើយ ។ ពួកតិរ្ថិយបានធ្វើតាមនោះ ។ ក្នុងកាលនោះ មហាជនល្ងង់ខ្លៅ ក៏អស់សេចក្តីសង្ស័យ ។ ព្រះរាជាទ្រង់ឲ្យសម្លាប់ពួកតិរ្ថិយ និងពួកអ្នកលេង ហើយឲ្យចោលសាកសព ។ ក្នុងកាលនោះ លាភសក្ការៈរបស់ព្រះមានព្រះភាគរឹងរឹតតែចម្រើនក្រៃលែងឡើង ។

## មុនាឡិពោធិសត្វទី ២ ចប់ [១]

---

១-ស្រង់ចាកអដ្ឋកថា អបទាន បិ.៧៤ ទំ.១២៩ ឃ.៩០ និងអដ្ឋកថាធម្មបទ សុន្ទរីបរិព្វាជិកាវត្ថុ ។

# អញ្ញតរទហរពោធិសត្វ

*បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វបានកើតក្នុងត្រកូលមួយ ក្នុងវ័យកុមារ លេងនៅតាមផ្លូវធំ ឃើញ* **ព្រះបច្ចេកពុទ្ធ** *កំពុងត្រាច់បិណ្ឌបាតតាមផ្លូវ ក៏មានចិត្តប្រទូស្តឡើងថា* **អយំ មុណ្ឌកោ សមណោ កុហឹ គច្ឆតិ** *សមណៈត្រងោលនេះកំពុងទៅណា ហើយក៏ចាប់ដុំថ្មគប់ត្រូវខ្នងជើងព្រះបច្ចេកពុទ្ធ ឈាមហូរចេញ ព្រោះដាច់ស្បែកត្រង់ខ្នងជើង ។ ព្រោះបាបកម្មនោះព្រះពោធិសត្វរងទុក្ខដ៏ធំក្នុងនរក ច្រើនពាន់ឆ្នាំ សូម្បីបានត្រាស់ជាព្រះពុទ្ធហើយ ក៏ជាំឈាម ព្រោះអំបែងដុំថ្មប៉ះត្រូវខ្នងជើង ដោយអំណាចនៃកម្មចាស់ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា*

**បុរេហំ ទារកោ ហុត្វា កីឡមានោ មហាបថេ**
**បច្ចេកពុទ្ធំ ឧិស្វាន មគ្គេ សកលិកំ ខិបឹ ។**

*កាលពីជាតិមុន តថាគតជាទារក កំពុងលេងក្នុងផ្លូវថ្នល់ធំ ឃើញព្រះបច្ចេកពុទ្ធ បានយកដុំថ្មក្នុងផ្លូវនោះគប់លោក ។*

តេន កម្មវិបាកេន ឥធ បច្ឆិមកេ ភវេ
វធត្ថំ មំ ទេវទត្តោ អភិមារេ បយោជយិ ។

*ព្រោះបាបកម្មនោះ ក្នុងជាតិចុងក្រោយនេះ ទេវទត្ត បានប្រមៀលថ្មមកសម្លាប់តថាគត* [១] ។

អញ្ញតរទហរពោធិសត្វ ចប់

---

*១-គាថាពីរនេះ យើងកាន់យកតាមអដ្ឋកថា វិសុទ្ធជនវិលាសិនី ( អដ្ឋកថាអបទាន ) ទើបមានន័យសមតាមទំនងនៃរឿង ។*

# ហត្ថាចារ្យពោធិសត្វ

បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វកើតជាអ្នកចិញ្ចឹមដំរី ជិះដំរីត្រាច់ទៅ ឃើញ **ព្រះបច្ចេកពុទ្ធ** ក្នុងផ្លូវធំ គិតថា សមណៈត្រងោលនេះ មកអំពីណា ។ ជាអ្នកមានចិត្តចង្អៀតចង្អល់ ដូចជាចម្រឹងដោតក្នុងចិត្ត បានធ្វើដំរីឲ្យអាក់អន់ ហើយពន្យុះដំរីឲ្យដេញជាន់ ។ ដោយកម្មនោះ ព្រះពោធិសត្វបានសោយទុក្ខក្នុងអបាយ ច្រើនពាន់ឆ្នាំ ក្នុងអត្តភាពចុងក្រោយ បានត្រាស់ដឹងជាព្រះពុទ្ធ ទេវទត្តធ្វើព្រះបាទអជាតសត្តុឲ្យជាសម្លាញ់ហើយ ធ្វើកតិកាគ្នាថា បពិត្រមហារាជ ទ្រង់ផ្តាច់ព្រះជន្មព្រះបិតាហើយ ចូរជាព្រះរាជា អាត្មាសម្លាប់ព្រះពុទ្ធហើយ នឹងធ្វើជាព្រះពុទ្ធ ដូច្នេះ ។ ថ្ងៃមួយ ទៅកាន់រោងដំរីតាមដែលព្រះរាជាទ្រង់អនុញ្ញាតបង្គាប់ហ្មដំរីថា ស្អែកនេះ អ្នកចូរឲ្យដំរីនាឡាគិរីផឹកស្រា ១៦ ក្អម ហើយចូរលែងទៅ ក្នុងកាលដែលព្រះមានព្រះភាគត្រាច់បិណ្ឌបាត ។ នគរទាំងមូលកើតកោលាហលធំ ជនទាំងឡាយនិយាយគ្នាថា យើងនឹងមើលចម្បាំងរបស់ដំរីដ៏ប្រសើរ ជាមួយនឹងព្រះពុទ្ធដ៏ប្រសើរ នាំគ្នាចងគ្រែត្រួតលើគ្រែ ក្នុងផ្លូវធំទាំងសងខាង ហើយរង់ចាំមើលអំពីព្រលឹម ។

ចំណែកព្រះមានព្រះភាគទ្រង់ធ្វើការជម្រះព្រះសរីរៈហើយ មានភិក្ខុសង្ឃចោមរោម ទ្រង់យាងចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ។

ក្នុងខណៈនោះ ពួកអ្នកចិញ្ចឹមដំរី លែងដំរីនាឡាគិរីដោយទំនងដែលពោលហើយនោះឯង ។ ដំរីនាឡាគិរីដើរឆ្វេងកាត់ផ្លូវបែកជា ៤ ជាដើមមក ។ ក្នុងកាលនោះ ស្រីម្នាក់ពទារកដើរឆ្វេងថ្នល់ ដំរីឃើញស្រីនោះ ក៏ដេញតាម ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនាឡាគិរី គេមិនបានបញ្ជូនអ្នកមក ដើម្បីសម្លាប់ស្រីនោះទេ ចូរមកផ្លូវនេះ ។ ដំរីនាឡាគិរីបានស្តាប់សំឡេងនោះហើយ ក៏រត់បែរមុខទៅរកព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ផ្សាយមេត្តា ដែលគួរផ្សាយទៅក្នុងសត្វដែលមិនមានទីបំផុត ក្នុងចក្កវាឡដែលប្រមាណមិនបាន ដាក់ក្នុងដំរីនាឡាគិរីមួយប៉ុណ្ណោះ ។ ដំរីនាឡាគិរីនោះ ដែលព្រះមេត្តារបស់ព្រះមានព្រះភាគពាល់ត្រូវហើយ ក្លាយជាដំរីដែលមិនមានភ័យ ក្រាបចុះទៀបបាទមូលរបស់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ដាក់ព្រះហស្តលើក្បាលរបស់ដំរីនាឡាគិរីនោះ ។ ក្នុងកាលនោះ ទេវតានិងព្រហ្មជាដើម កើតអស្ចារ្យក្នុងចិត្តដែលមិនធ្លាប់មាន នាំគ្នាបូជាដោយផ្កានិងកេសរផ្កាជាដើមក្នុងនគរទាំងមូល មានគំនរទ្រព្យប្រមាណត្រឹមជង្គង់ ។

ព្រះរាជាត្រាស់បង្គាប់ឲ្យត្រាច់វាយស្គរប្រកាសថា ទ្រព្យត្រង់ទ្វារទិសខាងលិច ចូរជារបស់អ្នកនគរ ទ្រព្យត្រង់ទ្វារទិសខាងកើត ចូរនាំចូលរាជឃ្លាំង ។ មនុស្សទាំងពួង បានធ្វើយ៉ាងនោះ ។ ក្នុងកាលនោះ ដំរីនាឡាគិរីនោះ ក៏បានឈ្មោះថា ដំរីធនបាល ។ ព្រះមានព្រះភាគបាន

*យាងទៅកាន់វេឡុវនារាម ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុកថា*

**ហត្ថារោហោ បុរេ អាសឹ បច្ចេកមុនិមុត្តមំ**
**បិណ្ឌាយ វិចរន្តំបិ អាសាទេសឹ តជេនហំ ។**

*កាលពីជាតិមុន តថាគតកើតជាហ្មដំរី បានបរដំរីបំព្រេចព្រះបច្ចេកមុនីដ៏ឧត្តម ព្រះអង្គកំពុងត្រាច់ទៅ ដើម្បីបិណ្ឌបាត ។*

**តេន កម្មវិបាកេន ភន្តោ នាឡាគិរី គជោ**
**គិរិព្វជេ បុរវរេ ទារុណោ សមុបាគមិ ។**

*ដោយវិបាកនៃកម្មនោះ ដំរីនាឡាគិរីចុះប្រេងកាច ចូលមកព្រេចតថាគត ក្នុងគិរិព្វជបុរីដ៏ប្រសើរ ( រាជគហៈ ) ។*

ហត្ថាចារ្យពោធិសត្វ ចប់ [១]

---

*១-ស្រង់ចាកអដ្ឋកថា អបទាន បិ.៧៤ ទំ.១២៧ ឃ.៩០ ។*

# ឃោសកសេដ្ឋី

*កាលទុព្ភិក្ខភ័យកើតហើយក្នុងដែនអល្លកប្បៈ បុរសម្នាក់ ឈ្មោះកោតុហលិកៈ មិនអាចរស់នៅបាន ទើបនាំភរិយាឈ្មោះកាឡី ដែលមានកូនខ្ចី រៀបចំស្បៀងចេញទៅហើយ ដោយបំណងថា អាត្មាអញនឹងទៅរស់នៅក្នុងក្រុងកោសម្ពី ។ អាចារ្យពួកខ្លះពោលថា ប្តីប្រពន្ធនោះចេញទៅហើយ ក្នុងកាលមហាជនកំពុងស្លាប់ដោយអហិវាតករោគ ក៏មាន ។ ប្តីប្រពន្ធពីរនាក់នោះ ធ្វើដំណើរទៅ កាលស្បៀងអស់ហើយ ត្រូវសេចក្តីឃ្លានគ្របសង្កត់ មិនអាចនាំកូនទៅបាន ។ លំដាប់នោះ ស្វាមីពោលនឹងភរិយាថា នែនាង បើយើងនៅមានជីវិត ក៏នឹងបានកូនទៀត យើងចោលកូន ហើយនឹងទៅ ។ ធម្មតាទឹកចិត្តរបស់មាតា ទន់ ព្រោះហេតុនោះ ទើបនាងពោលថា ខ្ញុំមិនអាចចោលកូនទាំងដែលនៅមានជីវិតបានទេ ។ ស្វាមីពោលថា បើដូច្នោះ យើងធ្វើដូចម្តេច ។*

*ភរិយាពោលថា យើងប្តូរវារៈគ្នា នាំទៅ ។ មាតាលើកកូនឡើងដូចលើកកម្រងផ្កា ក្នុងវាររបស់ខ្លួន ឲ្យដេកត្រង់ទ្រូង ពត្រង់ចង្កេះ ធ្វើដំណើរទៅ ហើយក៏ឲ្យដល់ឪពុក ។ ក្នុងពេលដែលបុរសជាប្តីទទួលកូននោះព កាលដើរទៅ ឃ្លានខ្លាំងផង លំបាកខ្លាំងផង ក៏ពោលនឹងភរិយានោះរឿយ ៗ ថា នាងដ៏ចម្រើន បើពួកយើងនៅមានជីវិត នឹងបានកូន*

ទៀត ពួកយើងចោលកូននេះចុះ ។ ភរិយាក៏ឃាត់រឿយ ៗ ហើយក៏នៅស្ងៀម ។ ទារកត្រូវផ្លាស់ប្តូរតាមវេន នឿយហត់ ទន់ខ្សោយ ក៏ដេកលក់ក្នុងដៃរបស់ឪពុក ។ បុរសនោះដឹងថា កូនប្រុសដេកលក់ហើយ ទើបបណ្តោយឲ្យម្តាយដើរទៅមុន ហើយយកកូននោះ ផ្តេកទុកលើកម្រាលស្លឹកឈើ ក្រោមដើមឈើមួយ ហើយដើរទៅ ។ នាងបែរមក ក្រឡេកមើលមិនឃើញកូន ទើបសួរថា នែអ្នក កូនយើងនៅឯណា ។

ប្តីពោលថា ខ្ញុំឲ្យវាដេកក្រោមគុម្ពឈើមួយគុម្ព ។ ភរិយាពោលថា អ្នកកុំញ៉ាំងខ្ញុំឲ្យវិនាសឡើយ ខ្ញុំវៀរកូនហើយ មិនអាចរស់នៅបានទេ សូមអ្នកនាំកូនមកឲ្យខ្ញុំ គក់ទ្រូង យំរៀបរាប់ហើយ ។ គ្រានោះ ទើបបុរសជាប្តីត្រឡប់ទៅយកទារកនោះមក ។ កូននោះ ក៏ស្លាប់ហើយក្នុងរវាងផ្លូវ ។ នាយកោតុហលិកៈចោលកូនក្នុងឋានៈមានប្រមាណប៉ុណ្ណោះ ទើបត្រូវគេបោះចោលអស់ ៧ ដង ក្នុងភពដទៃ ដោយផលនៃកម្មនោះ ដោយប្រការដូច្នេះ ។ ឈ្មោះថា បាបកម្ម បុគ្គលមិនគួរមើលងាយថា មានប្រមាណតិចឡើយ ។

ជនទាំងពីរនោះ ធ្វើដំណើរទៅដល់ត្រកូលអ្នកចិញ្ចឹមគោមួយកន្លែងហើយ ។ ក្នុងថ្ងៃនោះ មានការធ្វើពិធីមង្គលដល់មេគោទឹកដោះរបស់នាយគោបាល ។ ក្នុងផ្ទះរបស់នាយគោបាលនោះ **ព្រះបច្ចេកពុទ្ធ** មួយអង្គ ឆាន់ជានិច្ច ។ នាយគោបាលនោះ និមន្តព្រះបច្ចេកពុទ្ធឆាន់

ស្រេចហើយ ទើបបានធ្វើពិធីមង្គល ។ បាយាសគេរៀបចំទុកជាច្រើន ។ នាយគោបាលឃើញប្តីប្រពន្ធទាំងពីរនាក់នោះមក ទើបសួរថា ពួកអ្នកមកអំពីណា ដឹងរឿងនោះហើយ ជាអ្នកមានចិត្តទន់ ទើបធ្វើសេចក្តីសង្គ្រោះក្នុងជនទាំងពីរនោះ ឲ្យបាយាសនិងសប្បិជាច្រើន ។ ភរិយាពោលថា នៃអ្នក បើអ្នកមានជីវិត ខ្ញុំក៏មានជីវិតដែរ អ្នកអត់អាហារមកអស់កាលយូរហើយ សូមបរិភោគតាមសេចក្តីត្រូវការចុះ ហើយដាក់បាយាសខាងមុខ មួយអន្ទើដោយសប្បិ ខ្លួនឯងបរិភោគសប្បិរាវតែបន្តិចប៉ុណ្ណោះ ។ នាយកោតុហលិកៈនោះ បរិភោគច្រើនពេក មិនអាចកាត់ចំណង់ក្នុងអាហារបាន ព្រោះស្រេកឃ្លានមក ៧-៨ ថ្ងៃហើយ ។ នាយគោបាលឲ្យបាយាសដល់ប្តីប្រពន្ធពីរនាក់នោះហើយ ទើបផ្តើមបរិភោគខ្លួនឯង ។ នាយកោតុហលិកៈអង្គុយមើលបុរសនោះហើយ ឃើញដុំបាយាសដែលនាយគោបាលពូតឲ្យដល់សុនខី ដែលដេកក្រោមតាំង គិតថា សុនខីនេះ មានបុណ្យ ទើបបានភោជនបែបនេះជានិច្ច ។ លុះដល់កណ្តាលយប់ នាយកោតុហលិកៈមិនអាចញ៉ាំងបាយាសនោះ ឲ្យរលួយបាន ទើបធ្វើកាលកិរិយាទៅកើតក្នុងផ្ទៃរបស់សុនខីនោះ ។

លំដាប់នោះ ភរិយារបស់គាត់ធ្វើសរីរកិច្ចហើយ ក៏ធ្វើការស៊ីឈ្នួលក្នុងផ្ទះនោះឯង បានអង្ករមួយនាឡិ ចម្អិនហើយដាក់បាត្រព្រះបច្ចេកពុទ្ធ ពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមកុសលនេះ សម្រេចដល់

ទាសៈរបស់លោកម្ចាស់ចុះ ហើយគិតថា អាត្មាអញគួរនៅក្នុងទីនេះឯង លោកម្ចាស់តែងនិមន្តមកក្នុងទីនេះជានិច្ច ទេយ្យធម៌ ទោះមានក្តី មិនមានក្តី អញនឹងថ្វាយបង្គំ ធ្វើនូវសេចក្តីខ្វល់ខ្វាយ ញុំាងចិត្តឲ្យជ្រះថ្លារាល់ថ្ងៃ នឹងបាននូវបុណ្យច្រើន គិតដូច្នេះហើយ ទើបនាងធ្វើការស៊ីឈ្នួលនៅក្នុងផ្ទះនុ៎ះឯង ។ ក្នុងខែទី ៦ ឬទី ៧ សុនខីនោះ ក៏កើតកូនតែមួយ ទើបនាយគោបាលឲ្យនាំយកទឹកដោះរបស់មេគោមួយ ឲ្យដល់កូនសុនខនោះ ។ មិនយូរប៉ុន្មាន កូនសុនខនោះ ក៏ធំធាត់ ។ គ្រានោះព្រះបច្ចេកពុទ្ធ កាលឆាន់ តែងឲ្យដុំបាយដល់កូនសុនខនោះ មួយដុំជានិច្ច អាស្រ័យដុំបាយ ទើបកូនសុនខនោះ មានសេចក្តីស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធ ។ នាយគោបាលតែងទៅកាន់ទីបម្រើព្រះបច្ចេកពុទ្ធ ២ ដងជានិច្ច ។ នាយគោបាលនោះ កាលដើរទៅ ក៏យកដំបងវាយគុម្ពឈើនិងដី ក្នុងទីដែលមានសត្វកាច ត្រង់រវាងផ្លូវ ហើយបន្លឺសំឡេងថា សុសុ ៣ ដង ញុំាងសត្វសាហាវឲ្យគេចទៅហើយ ឯកូនសុនខ ក៏ទៅជាមួយនាយគោបាលនោះ ។

ថ្ងៃមួយ នាយគោបាលនោះ ទូលព្រះបច្ចេកពុទ្ធថា បពិត្រលោកម្ចាស់ដ៏ចម្រើន កាលណា ខ្ញុំមិនមានឱកាសទំនេរ កាលនោះ ខ្ញុំនឹងបញ្ជូនសុនខនេះទៅ សូមលោកម្ចាស់និមន្តមកដោយសញ្ញានៃសុនខនេះដែលខ្ញុំបញ្ជូនទៅហើយ ។ តាំងអំពីនោះមក ក្នុងថ្ងៃដែលមិនមានឱកាស

នាយគោបាលនោះ ក៏បញ្ជូនសុនខទៅដោយពាក្យថា នែបា ឯងចូរទៅ ចូរនាំលោកម្ចាស់មក ដោយពាក្យប្រើត្រឹមតែមួយម៉ាត់ប៉ុណ្ណោះ សុនខនោះ ក៏រត់ទៅ ដល់ទីដែលម្ចាស់វាយគុម្ពឈើនិងផែនដី ព្រុសបីដង ដឹងថា សត្វកាចគេចទៅហើយដោយសំឡេងនោះ ទើបរត់ទៅកាន់លំនៅរបស់ព្រះបច្ចេកពុទ្ធដែលធ្វើសរីរកិច្ចអំពីព្រលឹម ចូលក្នុងបណ្ណសាលាគង់ហើយ ។ សុនខនោះ ទៅដល់ទ្វារបណ្ណសាលា ក៏ព្រុស ៣ ដង ឲ្យព្រះបច្ចេកពុទ្ធដឹងថា ខ្លួនមកហើយ ទើបដេកក្រាបនៅត្រង់ចំណែកម្ខាង កាលព្រះបច្ចេកពុទ្ធកំណត់កាលចេញទៅហើយ សុនខនោះ ក៏ព្រុសរត់ទៅខាងមុខទន្ទុះឯង ។ ព្រះបច្ចេកពុទ្ធ កាលសាកល្បងសុនខនោះ ទើបទៅកាន់ផ្លូវដទៃ ត្រង់ចន្លោះៗ លំដាប់នោះ សុនខនោះ ឈរព្រុសរាំងខាងមុខព្រះបច្ចេកពុទ្ធ ហើយនាំលោកត្រឡប់មកកាន់ផ្លូវវិញ ។ សម័យថ្ងៃមួយ ព្រះបច្ចេកពុទ្ធ កាលសាកល្បងសុនខនោះ ទើបទៅកាន់ផ្លូវដទៃ សុនខនោះ ក៏ឈររារាំងនៅខាងមុខ មិនត្រឡប់ ព្រះបច្ចេកពុទ្ធយកជើងធ្គឹះសុនខនោះ ហើយក៏ទៅ សុនខដឹងថា ព្រះបច្ចេកពុទ្ធមិនត្រឡប់ ក៏ខាំជាយស្បង់ទាញមក នាំលោកមកកាន់ផ្លូវវិញ ។ កូនសុនខនោះ បានញុំាងសេចក្ដីស្រឡាញ់ដ៏មានកម្លាំង ឲ្យកើតឡើងហើយ ក្នុងព្រះបច្ចេកពុទ្ធនោះ ដោយប្រការដូច្នេះ ។

តមកក្នុងកាលដទៃ ចីវររបស់ព្រះបច្ចេកពុទ្ធចាស់ហើយ ។ លំដាប់

នោះ នាយគោបាលប្រគេនសំពត់សម្រាប់ធ្វើចីវរដល់ព្រះបច្ចេកពុទ្ធ ។ ព្រះបច្ចេកពុទ្ធពោលនឹងនាយគោលបាលនោះថា អាវុសោ ឈ្មោះថា ការធ្វើចីវរ បុគ្គលម្នាក់ឯងធ្វើបានលំបាក អាត្មាទៅកាន់ទីដែលសប្បាយហើយនឹងធ្វើ ។

នាយគោបាលពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ធ្វើទីនេះចុះ ។ ព្រះបច្ចេកពុទ្ធពោលថា អាវុសោ អាត្មាមិនអាចធ្វើក្នុងទីនេះបានទេ ។

នាយគោបាលពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់កុំទៅខាងក្រោយយូរពេក ។ សុនខបានឈរស្តាប់ពាក្យរបស់ព្រះបច្ចេកពុទ្ធ និងនាយគោបាលហើយ ។ ព្រះបច្ចេកពុទ្ធពោលនឹងនាយគោបាលនោះថា ចូរឈប់ទីនេះចុះ ឧបាសក ឲ្យនាយគោបាលត្រឡប់ហើយ ហោះឡើងទៅកាន់អាកាស មានមុខឆ្ពោះទៅកាន់ភ្នំគន្ធមាទន៍ ។ សុនខសម្លឹងមើលព្រះបច្ចេកពុទ្ធដែលអណ្តែតទៅក្នុងអាកាស ឈរព្រុសហើយ កាលព្រះបច្ចេកពុទ្ធនោះ ផុតអំពីគន្លងចក្ខុ ហឫទ័យក៏បែកស្លាប់ទៅ ។ ឈ្មោះថា សត្វតិរច្ឆានទាំងឡាយ ជាសត្វមានជាតិស្មោះត្រង់មិនវៀចវេរ ចំណែកមនុស្សចិត្តគិតផ្សេង មាត់និយាយផ្សេង ព្រោះហេតុនោះឯង ទើបនាយបេស្សៈជាកូនរបស់ហ្មដំរីពោលថា

គហនញ្ហេតំ ភន្តេ យទិទំ មនុស្សា ឧត្តានកញ្ហេតំ ភន្តេ

**យថិជំ បសវោ** បពិត្រព្រះអង្គដ៏ចម្រើន ពួកមនុស្សមានចិត្តសាំញាំ បពិត្រព្រះអង្គដ៏ចម្រើន ពួកសត្វចិញ្ចឹម មានចិត្តងាយយល់[១] ។

សុនខនោះ ធ្វើកាលកិរិយាហើយ ទៅកើតក្នុងឋានតាវត្តិង្ស ព្រោះជាសត្វស្មោះត្រង់ មិនវៀចវេរ មានស្រីទេពអប្សរ ១ ពាន់ ចោមរោម បានសោយនូវមហាសម្បត្តិ ដោយប្រការដូច្នេះ ។ កាលទេវបុត្តនោះ ខ្សឹបត្រង់ត្រចៀករបស់បុគ្គលណាមួយ សំឡេងរមែងលាន់ឮទៅឆ្ងាយរហូត ១៦ យោជន៍ ចំណែកសំឡេងពោលដោយប្រក្រតី រមែងឮពេញទេវនគរទាំងមូល ដែលមានប្រមាណមួយម៉ឺនយោជន៍ ព្រោះហេតុនោះឯង ទើបទេវបុត្តនោះ មានឈ្មោះថា ឃោសកទេវបុត្ត ។

សួរថា នេះជាផលនៃកម្មអ្វី ។

ឆ្លើយថា ជាផលនៃការព្រុស ដោយសេចក្ដីស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធ ។

ឃោសកទេវបុត្តនោះ តាំងនៅក្នុងទេវនគរនោះ មិនយូរប៉ុន្មាន ក៏ចុតិហើយ ។ មែនពិត ទេវបុត្តទាំងឡាយ រមែងឃ្លាតចាកទេវលោក ដោយហេតុ ៤ យ៉ាង គឺដោយអស់អាយុ ១ ដោយអស់បុណ្យ ១ ដោយការភ្លេចបរិភោគអាហារ ១ ដោយសេចក្ដីក្រោធ ១ ។

ក្នុងហេតុ ៤ យ៉ាងនោះ ទេវបុត្តអង្គណា ធ្វើបុញ្ញកម្មទុកច្រើន

---

១-បិ.២៣ ទំ.៧ ឃ.៣ ។

ទេវបុត្តអង្គនោះ កើតក្នុងទេវលោក នៅដរាបអស់អាយុហើយ ក៏កើតក្នុងទេវលោកជាន់ខ្ពស់បន្ត ៗ ទៅ យ៉ាងនេះឈ្មោះថា ចុតិដោយការអស់អាយុ ។

ទេវបុត្តអង្គណាធ្វើបុណ្យតិច បុណ្យរបស់ទេវបុត្តអង្គនោះ អស់ទៅក្នុងចន្លោះ ដូចធញ្ញជាតិដែលបុគ្គលទុកក្នុងជង្រុកធំ ត្រឹមតែ ៤-៥ នាឡិដូច្នោះ ។ ទេវបុត្តនោះ រមែងធ្វើកាលកិរិយាក្នុងរវាងនោះឯង យ៉ាងនេះឈ្មោះថា ចុតិដោយការអស់បុណ្យ ។

ទេវបុត្តអង្គខ្លះ ច្រើនដោយការបរិភោគកាមគុណ មិនបរិភោគអាហារព្រោះភ្លេចស្មារតី មានកាយទន់ខ្សោយ ក៏ធ្វើកាលកិរិយា យ៉ាងនេះឈ្មោះថា ចុតិដោយការភ្លេចបរិភោគអាហារ ។

ទេវបុត្តអង្គខ្លះ មិនអត់ធន់ក្នុងសម្បត្តិអ្នកដទៃ ខឹងក្រោធហើយទើបធ្វើកាលកិរិយា យ៉ាងនេះឈ្មោះថា ចុតិដោយសេចក្តីក្រោធ ។

ឃោសកទេវបុត្តនេះ ច្រើនដោយការបរិភោគកាមគុណ ភ្លេចស្មារតី ទើបចុតិដោយការភ្លេចបរិភោគអាហារ ។ កាលចុតិហើយបដិសន្ធិក្នុងផ្ទៃនៃស្រីនគរសោភិនី ក្នុងក្រុងកោសម្ពី ។ ក្នុងថ្ងៃប្រសូតនាងសួរទាសីថា កូនរបស់យើង ប្រុសឬស្រី ។ កាលទាសីឆ្លើយថាកូនប្រុស អ្នកនាងម្ចាស់ ទើបប្រាប់ឲ្យទាសីយកទៅចោលដោយពាក្យថាបើដូច្នោះ ចូរនាងយកទារកនេះ ដាក់ក្នុងចង្អេរ ហើយយកទៅចោល

ត្រង់ទីចាក់សំរាមចុះ ។ មែនពិត ស្រីនគរសោភិនីទាំងឡាយ រមែង ចិញ្ចឹមតែកូនស្រី មិនចិញ្ចឹមកូនប្រុស ព្រោះពូជពង្សរបស់ពួកនាងបន្ត ទៅបាន ក៏ដោយសារកូនស្រី ។ ក្អែកខ្លះ ឆ្កែខ្លះ នាំគ្នាចោមរោមកុមារ នោះ ។ ដោយផលនៃការព្រុសដែលកើតអំពីសេចក្តីស្រឡាញ់ក្នុងព្រះ បច្ចេកពុទ្ធ សត្វសូម្បីតែមួយ ក៏មិនអាចចូលជិតបាន ។ ក្នុងខណៈនោះ បុរសម្នាក់ចេញទៅខាងក្រៅស្រុក ឃើញការចោមរោមរបស់ក្អែកនិងឆ្កែ នោះ គិតថា មានហេតុអ្វីហ្ន៎ ទើបដើរទៅកាន់ទីនោះ ឃើញទារក ក៏ កើតសេចក្តីស្រឡាញ់ដូចកូន នាំទៅកាន់ផ្ទះដោយត្រេកអរថា អញបាន បុត្តហើយ ។ ក្នុងកាលនោះ សេដ្ឋីអ្នកក្រុងកោសម្ពីទៅកាន់រាជត្រកូល ចួបបុរោហិតដើរមកអំពីព្រះរាជវាំង ទើបសួរថា លោកអាចារ្យ ថ្ងៃនេះ លោកបានពិនិត្យមើលការប្រកបរបស់ផ្កាយនក្ខត្តឫក្ស ដែលជាគ្រោះល្អ គ្រោះអាក្រក់ហើយឬ ។

បុរោហិតពោលថា អើ មហាសេដ្ឋី កិច្ចដទៃរបស់យើងមានឬ ។ សេដ្ឋីសួរថា នឹងមានអ្វីកើតឡើងដល់ជនបទឬ ។

បុរោហិតពោលថា ហេតុដទៃ មិនមាន តែទារកដែលកើតក្នុងថ្ងៃ នេះ នឹងបានជាសេដ្ឋីធំក្នុងនគរនេះ ។ គ្រានោះ ភរិយារបស់សេដ្ឋី មានគភ៌ចាស់ ព្រោះហេតុនោះ ទើបសេដ្ឋីនោះ បញ្ជូនអ្នកបម្រើទៅ កាន់ផ្ទះយ៉ាងរហ័ស ដោយពាក្យថា នែនាយ ឯងចូរទៅ ហើយចូរដឹង

ថា ភរិយារបស់ខ្ញុំ ប្រសូតបុត្តហើយឬនៅ លុះដឹងថា មិនទាន់ប្រសូត ចូលគាល់ព្រះរាជាស្រេចហើយ ប្រញាប់ត្រឡប់ទៅកាន់ផ្ទះ ហៅស្រីបម្រើឈ្មោះកាឡីមក ហើយឲ្យទ្រព្យ ១ ពាន់ ពោលថា នាងចូរទៅពិនិត្យមើលក្នុងនគរនេះ ហើយឲ្យទ្រព្យ ១ ពាន់ នាំទារកដែលកើតក្នុងថ្ងៃនេះមក ។

នាងកាឡីនោះ កាលពិនិត្យមើល បានទៅដល់ផ្ទះនោះ ឃើញទារកហើយ ទើបសួរស្រីមេផ្ទះថា **អយំ ទារកោ កទា ជាតោ** ទារកនេះ កើតក្នុងកាលណា ។ កាលស្រីនោះ ឆ្លើយថា **អជ្ជ ជាតោ** កើតក្នុងថ្ងៃនេះឯង ទើបពោលថា **ឥមំ មយ្ហំ ទេហិ** ចូរឲ្យទារកនេះដល់ខ្ញុំ ទើបឲ្យថ្លៃតាំងពីមួយកហាបណៈជាដើម រហូតដល់ឲ្យទ្រព្យមួយពាន់ ហើយនាំទារកនោះទៅឲ្យសេដ្ឋី ។ សេដ្ឋីគិតថា បើកូនរបស់អញកើតមកជាស្រី អញនឹងឲ្យទារកនេះ នៅរួមជាមួយកូនស្រីរបស់អញនោះ ហើយធ្វើទារកនេះ ឲ្យជាម្ចាស់នៃតំណែងសេដ្ឋី បើកូនរបស់អញកើតមកជាកូនប្រុស អញនឹងសម្លាប់វាចោល ដូច្នេះហើយ ទើបទទួលទារកនោះ ទុកក្នុងផ្ទះ ។

ក្នុងកាលតមក ភរិយារបស់សេដ្ឋីនោះ ប្រសូតកូនប្រុស ដោយកន្លងទៅពីរបីថ្ងៃ ។ សេដ្ឋីគិតថា បើមិនមានក្មេងនេះ កូនប្រុសរបស់អញ ក៏នឹងបានតំណែងសេដ្ឋី ឥឡូវនេះ អញគួរតែសម្លាប់វាចោល

ដូច្នេះហើយ ទើបហៅនាងកាឡីមកប្រាប់ថា ចូរនាងទៅ ក្នុងកាលដែលពួកគោចេញអំពីក្រោល ចូរដាក់ក្មេងនេះ ឲ្យដេកទទឹងត្រង់កណ្ដាលទ្វារក្រោល មេគោទាំងឡាយនឹងជាន់វាស្លាប់ តែចូរដឹងថា មេគោជាន់ឬមិនជាន់ ហើយសឹមមក ។ នាងកាឡីនោះទៅហើយ លុះនាយគោបាលបើកទ្វារក្រោលប៉ុណ្ណោះ ក៏ដាក់ក្មេងនោះឲ្យដេក តាមពាក្យសេដ្ឋីបង្គាប់ ។ គោឧសភៈចេញខាងក្រោយគោទាំងពួងក្នុងកាលដទៃ តែក្នុងថ្ងៃនោះ ចេញមកមុនគោដទៃទាំងអស់ បានឈរក្រុងទារកក្នុងរវាងជើងទាំងបួន ។ មេគោច្រើនរយ ក៏នាំគ្នាប្រជ្រៀតសងខាងគោឧសភៈចេញទៅ ។ សូម្បីនាយគោបាលក៏គិតថា គោឧសភៈនេះ កាលមុនចេញក្រោយគោទាំងអស់ តែថ្ងៃនេះ ចេញមកមុនគេ ហើយឈរស្ងៀមត្រង់កណ្ដាលទ្វារក្រោល តើមានហេតុអ្វីហ្ន៎ ទើបដើរទៅ កាលឃើញទារកដេកនៅក្រោមពោះគោនោះ ក៏បាននូវសេចក្ដីស្រឡាញ់ដូចបុត្ត នាំទៅផ្ទះ ដោយគិតថា អញបានកូនប្រុសហើយ ។

នាងកាឡីទៅហើយ ត្រូវសេដ្ឋីសួរ ទើបប្រាប់រឿងនោះ សេដ្ឋីពោលថា ចូរនាងទៅ ឲ្យទ្រព្យមួយពាន់ទៅនាយគោបាលនោះ ហើយនាំក្មេងនោះមក នាងកាឡីទៅហើយ ឲ្យទ្រព្យមួយពាន់ បាននាំទារកនោះ ត្រឡប់មកទៀត ។ គ្រានោះ សេដ្ឋីពោលនឹងនាងកាឡីថា នៃកាឡី ក្នុងក្រុងនេះ មានពួករទេះ ៥០០ តែងក្រោកឡើងអំពីព្រលឹម

ទៅលក់ដូរ ចូរនាងយកក្មេងនេះ ទៅឲ្យដេកត្រង់ផ្លូវរទេះ ពួកគោនឹងជាន់ ឬរទេះនឹងកិន នាងដឹងរឿងនេះហើយ សឹមត្រឡប់មក ។ នាងកាឡីនាំក្មេងនោះទៅហើយ ដាក់ឲ្យដេកត្រង់ផ្លូវរទេះ ។ ក្នុងកាលនោះ ប្រធានក្រុមរទេះបានទៅខាងមុខ ។ គ្រានោះ គោទាំងពីររបស់គាត់ដល់ទីនោះហើយ នាំគ្នាទម្លាក់នឹមចោល សូម្បីគាត់លើកនឹមឡើង ហើយដេញទៅច្រើនដង ក៏មិនដើរទៅខាងមុខ ។ កាលគាត់ព្យាយាមជាមួយគោទាំងពីរនោះយ៉ាងនេះឯង អរុណក៏រះឡើង ទើបគាត់គិតថា គោទាំងពីរធ្វើហេតុនេះ ព្រោះអ្វីហ្ន៎ ទើបពិនិត្យមើលផ្លូវ ឃើញទារកហើយគិតថា កម្មរបស់អញធ្ងន់ហ្ន៎ មានចិត្តត្រេកអរថា អញបានកូនប្រុសហើយ ទើបនាំក្មេងនោះទៅកាន់ផ្ទះ ។

នាងកាឡីទៅហើយ កាលសេដ្ឋីសួរ ទើបប្រាប់ការប្រព្រឹត្តទៅនោះ សេដ្ឋីក៏ប្រាប់ថា ចូរនាងទៅ ចូរឲ្យទ្រព្យមួយពាន់ដល់បុរសនោះ ហើយនាំក្មេងនោះត្រឡប់មក នាងក៏ធ្វើតាមនោះ ។ លំដាប់នោះ សេដ្ឋីពោលនឹងនាងកាឡីនោះថា ឥឡូវនេះ ចូរនាងនាំវាទៅកាន់ព្រៃខ្មោច ហើយឲ្យដេកក្នុងចន្លោះគុម្ពឈើ វានឹងត្រូវសត្វ មានឆ្កែជាដើមខាំ ឬត្រូវអមនុស្សប្រហារឲ្យស្លាប់ក្នុងទីនោះ នាងដឹងថា វាស្លាប់ហើយ ឬមិនស្លាប់ សឹមត្រឡប់មក ។ នាងកាឡីនោះ នាំក្មេងនោះ ទៅឲ្យដេកក្នុងព្រៃខ្មោចហើយ បានឈរក្នុងទីមួយកន្លែង ។ ឆ្កែក្តី ក្អែកក្តី អមនុស្សក្តី មិន

អាចចូលជិតក្មេងនោះបាន ។

មានពាក្យសួរថា ឪពុកម្តាយ និងបងប្អូនប្រុសស្រីជាដើម បុគ្គលណាមួយ ឈ្មោះថា រក្សាក្មេងនោះ មិនមាន មិនមែនឬ អ្នកណារក្សាក្មេងនោះ ។

ឆ្លើយថា កម្មត្រឹមតែការព្រុសប៉ុណ្ណោះ ដែលក្មេងឲ្យប្រព្រឹត្តទៅហើយដោយការស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធ ក្នុងកាលកើតជាសុនខ ជាអ្នករក្សាក្មេងនោះទុក ។ គ្រានោះ នាយអជបាលម្នាក់ គៀងមេពពែជាច្រើនពាន់ក្បាលទៅឲ្យរកស៊ី ដើរទៅក្បែរព្រៃខ្មោចនោះ ។ មេពពែមួយស៊ីស្លឹកឈើជាដើម ចូលទៅកាន់គុម្ពឈើឃើញទារកហើយ ទើបលុតជង្គង់ឲ្យទឹកដោះដល់ទារក ។ សូម្បីនាយអជបាលធ្វើសំឡេងហេ ហេ ក៏មិនចេញទៅឡើយ ។ បុរសនោះគិតថា នឹងយករំពាត់វាយឲ្យចេញ ទើបចូលទៅកាន់គុម្ពឈើ ឃើញមេពពែលុតជង្គង់ឲ្យទារកតូចបៅដោះ ក៏បាននូវសេចក្តីស្រឡាញ់ក្នុងទារកដូចបុត្ត ទើបនាំទារកនោះទៅ ដោយគិតថា អញបានកូនប្រុសហើយ ។

នាងកាឡីឃើញហេតុនោះហើយ ទើបទៅ ត្រូវសេដ្ឋីសួរហើយក៏ប្រាប់ការប្រព្រឹត្តទៅនោះ ។ លំដាប់នោះ សេដ្ឋីពោលថា ចូរនាងទៅឲ្យទ្រព្យ ១ ពាន់ ហើយនាំក្មេងនោះត្រឡប់មក នាងកាឡីបានធ្វើតាមនោះហើយ ។ លំដាប់នោះ សេដ្ឋីពោលនឹងទាសីនោះថា នៃកាឡី ចូរ

នាងយកក្មេងនេះ ទៅឡើងភ្នំដែលជាទីទម្លាក់ចោរ ចូរបោះវាទៅក្នុងជ្រោះ ក្មេងនេះប៉ះនឹងថ្មភ្នំ នឹងដាច់ជាកំណាត់តូចធំ ធ្លាក់ចុះត្រង់ផែនដី នាងដឹងថា វាស្លាប់ហើយ ឬមិនទាន់ស្លាប់ សឹមត្រឡប់មក ។ នាងកាឡីនាំក្មេងនោះទៅក្នុងទីនោះ ឈរនៅលើកំពូលភ្នំ បោះទម្លាក់ទៅហើយ ។ គុម្ពឫស្សីធំអាស្រ័យបាតជ្រោះនោះ លូតលាស់ឡើងតាមលំអានបាតភ្នំនុ៎ះឯង វល្លិទំពាំងបាយជូរមានស្លឹកក្រាស់ បានចាក់ស្រែះលើគុម្ពឫស្សីនោះ ទារកកាលធ្លាក់ ក៏ធ្លាក់លើវល្លិនោះ ដូចគេដាក់លើសំពត់រោមសត្វ ។ ក្នុងថ្ងៃនោះ មេជាងផែងមានសេចក្ដីត្រូវការដោយឫស្សី គាត់ទៅជាមួយកូនប្រុស ផ្ដើមកាប់គុម្ពឫស្សីនោះ កាលដើមឫស្សីរង្គើ ទារកក៏យំឡើង គាត់ពោលថា ដូចសំឡេងក្មេង ហើយឡើងទៅតាមផ្លូវមួយ ឃើញទារក មានចិត្តត្រេកអរ ទើបនាំទៅ ដោយគិតថា អញបានកូនប្រុសហើយ ។

នាងកាឡីទៅកាន់សម្នាក់សេដ្ឋី ត្រូវសេដ្ឋីនោះសួរហើយ ទើបប្រាប់រឿងនោះ កាលសេដ្ឋីពោលថា ចូរនាងទៅ ឲ្យទ្រព្យបុរសនោះ ១ ពាន់ ហើយនាំក្មេងនោះមក នាងបានធ្វើយ៉ាងនោះហើយ ។ កាលសេដ្ឋីធ្វើកម្មនោះៗ ទារកចម្រើនធំធាត់ហើយ ។ ទារកនោះ មានឈ្មោះថា ឃោសកៈ ។ ឃោសកកុមារនោះ ប្រាកដដល់សេដ្ឋីដូចបន្លាក្នុងភ្នែក សេដ្ឋីមិនអាចសម្លឹងមើលដោយត្រង់ ៗ បាន ។ លំដាប់នោះ សេដ្ឋី

កាលត្រិះរិះរកឧបាយសម្លាប់ឃោសកៈនោះ ទើបទៅកាន់សម្នាក់នាយស្នូនផ្ទាំងដែលជាសម្លាញ់របស់ខ្លួន ហើយសួរថា ក្នុងកាលណា ទើបអ្នកដុតឡ ។ បុរសនោះឆ្លើយថា ស្អែកនេះ ។

សេដ្ឋីពោលថា បើដូច្នោះ ចូរកាន់យកទ្រព្យមួយពាន់នេះ ហើយចូរធ្វើការឲ្យខ្ញុំមួយ ។ នាយស្នូនផ្ទាំងសួរថា ការងារអ្វី លោកម្ចាស់ ។

សេដ្ឋីពោលថា ខ្ញុំមានកូនជាតិអាក្រក់ម្នាក់ ខ្ញុំនឹងបញ្ជូនវាមកកាន់សម្នាក់របស់អ្នក ពេលនោះ ចូរអ្នកឲ្យវាចូលកាន់បន្ទប់ យកកាំបិតដែលមុត កាត់ឲ្យជាកំណាត់តូចធំ ដាក់ក្នុងថ្លាង ហើយដុតក្នុងឡ ទ្រព្យមួយពាន់នេះ ជារង្វាន់សម្រាប់អ្នក ពេលដែលកិច្ចការនេះ សម្រេច ខ្ញុំនឹងធ្វើវត្ថុដែលគួរធ្វើដល់អ្នកឲ្យក្រៃលែងឡើង ។ ស្នូនផ្ទាំងទទួលថា សាធុ ។

ស្អែកឡើង សេដ្ឋីហៅឃោសកៈមក ហើយពោលថា ម្សិលមិញនេះ អញប្រាប់ការងារមួយដល់នាយស្នូនផ្ទាំង ឯងចូរមក ចូរទៅកាន់សម្នាក់របស់គាត់ ហើយពោលយ៉ាងនេះថា បានឮថា ម្សិលមិញនេះ ឪពុកខ្ញុំពឹងលោកអ៊ំឲ្យជួយធ្វើការងារមួយ សូមលោកអ៊ំញុំាងការងារនោះឲ្យសម្រេចចុះ ។ ឃោសកៈនោះទទួលថា សាធុ ហើយក៏ទៅ ។

ចំណែកកូនប្រុសរបស់សេដ្ឋី កំពុងលេងអង្គុញជាមួយពួកក្មេង កាលឃោសកកុមារដើរទៅក្នុងទីនោះ ក៏ហៅឃោសកៈនោះ ហើយសួរថា បងប្រុសទៅណា ។

នាយឃោសកៈពោលថា បងយកដំណឹងរបស់លោកឪពុក ទៅកាន់ផ្ទះនាយស្នូនផ្ទាំង ។

កូនប្រុសរបស់សេដ្ឋីពោលថា ខ្ញុំនឹងទៅក្នុងទីនោះ ក្មេងទាំងនេះឈ្នះខ្ញុំច្រើនខ្ទាច់ហើយ សូមបងយកឈ្នះខ្ទាច់សងឲ្យខ្ញុំវិញ ។

ឃោសកៈ ពោលថា បងខ្លាចលោកឪពុក ។

កូនប្រុសរបស់សេដ្ឋីពោលថា សូមបងកុំខ្លាច ខ្ញុំនឹងនាំដំណឹងនោះទៅដោយខ្លួនឯង ពួកក្មេងច្រើននាក់ ឈ្នះខ្ញុំហើយ សូមបងយកឈ្នះខ្ទាច់ឲ្យខ្ញុំ ទម្រាំខ្ញុំត្រឡប់មក ។

បានឮថា នាយឃោសកៈជាអ្នកឈ្លាសក្នុងការលេងអង្គញ់ ព្រោះហេតុនោះ ទើបកូនប្រុសរបស់សេដ្ឋីទាក់ទាញនាយឃោសកៈនោះទុកយ៉ាងនេះ ។ ឯឃោសកៈនោះ ពោលនឹងកូនសេដ្ឋីនោះថា បើដូច្នោះចូរឯងទៅប្រាប់នាយស្នូនផ្ទាំងនោះថា បានឮថា កាលពីម្សិលមិញ ឪពុករបស់ខ្ញុំប្រាប់ឲ្យលោកធ្វើការងារមួយ សូមលោកញ៉ាំងការងារនោះ ឲ្យសម្រេចចុះ ហើយក៏បញ្ជូនកូនសេដ្ឋីនោះទៅ ។ កូនប្រុសរបស់សេដ្ឋីទៅកាន់សម្នាក់របស់នាយស្នូនផ្ទាំងនោះ បានពោលតាមពាក្យនោះ ។ លំដាប់នោះ នាយស្នូនផ្ទាំងបានសម្លាប់កូនប្រុសរបស់សេដ្ឋី តាមពាក្យសេដ្ឋីប្រាប់នោះឯង ហើយបោះទៅក្នុងឡ ។ ចំណែកឃោសកកុមារលេងអស់ចំណែកនៃថ្ងៃ លុះល្ងាច ក៏ត្រឡប់ទៅផ្ទះ សេដ្ឋីឃើញហើយ

សួរថា នែបា ឯងមិនបានទៅទេឬ ។ ឃោសកកុមារក៏ប្រាប់ដល់ហេតុដែលខ្លួនមិនបានទៅ និងហេតុដែលប្អូនប្រុសទៅ ដល់សេដ្ឋី ។ សេដ្ឋីស្តាប់ពាក្យនោះហើយ ទើបស្រែកដោយសំឡេងខ្លាំងថា អញគួរឲ្យតិះដៀលណាស់ ហាក់បីដូចមានឈាមពុះកញ្ច្រោលក្នុងសរីរៈទាំងមូល ផ្គងដើមដៃកន្ទក់កន្ទេញថា ស្ទូនផ្ទាំងដ៏ចម្រើន កុំឲ្យខ្ញុំវិនាសឡើយ កុំឲ្យខ្ញុំវិនាសឡើយ ដូច្នេះហើយ បានទៅកាន់សម្នាក់នាយស្ទូនផ្ទាំងនោះ ។

នាយស្ទូនផ្ទាំងឃើញសេដ្ឋីមកដោយអាការយ៉ាងនោះ ទើបពោលថា បពិត្រលោកម្ចាស់ សូមកុំធ្វើសំឡេងខ្លាំងឡើយ ការងាររបស់លោកសម្រេចហើយ ។ សេដ្ឋីនោះ ត្រូវសេចក្តីសោកប្រៀបដូចភ្នំធំសង្កត់ហើយ សោយទោមនស្សមានប្រមាណមិនមែនតិច ដូចបុគ្គលប្រទូស្តចំពោះបុគ្គលដែលមិនប្រទូស្តដូច្នោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

យោ ទណ្ឌេន អទណ្ឌេសុ អប្បទុដ្ឋេសុ ទុស្សតិ
ទសន្នមញ្ញតរំ ឋានំ ខិប្បមេវ និគច្ឆតិ
វេទនំ ផរុសំ ជានឹ សរីរស្ស វ ភេទនំ
គរុកំ វាបិ អាពាធំ ចិត្តក្ខេបំ វ បាបុណេ
រាជតោ វា ឧបសគ្គំ អព្ភក្ខានំ វ ទារុណំ
បរិក្ខយំ វ ញាតីនំ ភោគានំ វ បភង្គុណំ

អជវស្ស អតាភជិ អគ្គិ ឌហតិ ចាវកោ
កាយស្ស ភេទា ទុប្បញ្ញោ និរយំ សោ ឧបបជ្ជតិ ។

*បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយដែលមិនមានអាជ្ញា មិនប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្តីទុក្ខណាមួយ ក្នុងហេតុ ១០ យ៉ាង ដោយទាន់ហន់ គឺគប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្តីវិនាសទ្រព្យ ១ បែកធ្លាយសរីរៈ ១ អាពាធជាទម្ងន់ ១ ក្រឡកចិត្ត (ឆ្កួត) ១ រឹបជាន់អំពីស្តេច ១ ពោលពាក្យបង្កាច់ដ៏អាក្រក់ ១ អស់ពួកញាតិរលីង ១ ពុកផុយភោគសម្បត្តិទាំងឡាយ ១ ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ ១ បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក[១] ។*

*ព្រោះហេតុនោះ សេដ្ឋីក៏មិនអាចសម្លឹងមើលនាយឃោសកៈនោះត្រង់ ៗ បាន ត្រិះរិះរកឧបាយថា ធ្វើដូចម្តេចហ្ន៎ ទើបសម្លាប់វាបាន ក៏ឃើញឧបាយថា អញនឹងបញ្ជូនវាទៅកាន់សម្នាក់របស់អ្នកប្រមូលសួយក្នុងស្រុក ១០០ របស់អញ ឲ្យសម្លាប់វាឲ្យស្លាប់ ដូច្នេះហើយ ទើបសរសេរសំបុត្រទៅឲ្យអ្នកប្រមូលសួយនោះថា ជននេះ ជាកូនដែលមាន*

---

*១-បិ.៥២ ទំ.៥១ ឃ.២០ ។*

ជាតិអាក្រក់របស់ខ្ញុំ សូមមាតុលៈ[១] សម្លាប់វា ហើយបោះទៅក្នុងរណ្ដៅលាមក កាលធ្វើការងារនេះ សម្រេចហើយ ខ្ញុំនឹងដឹងវត្ថុដែលតបស្នងដល់មាតុលៈក្នុងកាលជាខាងក្រោយ ដូច្នេះហើយ ទើបពោលថា នៃបាឃោសកៈ អ្នកហូតពន្ធរបស់ពុក មាននៅត្រង់ស្រុកសួយ ១០០ ស្រុក ឯងចូរនាំសំបុត្រនេះទៅឲ្យជននោះ ដូច្នេះហើយ យកសំបុត្រចងត្រង់ជាយសំពត់ឃោសកកុមារ ។

នាយឃោសកៈនោះ មិនចេះអក្ខរសម័យឡើយ ព្រោះតាំងអំពីនៅជាកុមារ សេដ្ឋីគិតសម្លាប់រហូត តែមិនអាចសម្លាប់បាន តើនឹងឲ្យគេសិក្សាអក្សរបានដូចម្ដេច ។ នាយឃោសកៈនោះ ចងសំបុត្រសម្លាប់ខ្លួនឯង ទុកត្រង់ជាយសំពត់ដោយប្រការដូច្នេះ កាលនឹងចេញដំណើរ ទើបពោលថា បពិត្រលោកឪពុក ខ្ញុំមិនមានស្បៀងសម្រាប់ដើរផ្លូវ ។

សេដ្ឋីពោលថា ឯងមិនចាំបាច់មានកិច្ចកង្វល់ដោយស្បៀងដើរផ្លូវឡើយ ក្នុងស្រុកឈ្មោះនោះ ក្នុងរវាងផ្លូវ សេដ្ឋីជាសម្លាញ់របស់អញមាន ឯងចូរទៅបរិភោគអាហារព្រឹកក្នុងផ្ទះរបស់គេ ហើយសឹមចេញដំណើរទៅ ។ នាយឃោសកៈទទួលថា សាធុ ថ្វាយបង្គំបិតាហើយ ចេញដំណើរទៅដល់ស្រុកនោះ សួររកផ្ទះសេដ្ឋី ចួបនឹងភរិយារបស់សេដ្ឋី ។

---

១-បងប្រុសឬប្អូនប្រុស របស់ម្ដាយ ហៅថា មាតុលៈ ( ពូឬអ៊ំប្រុស ខាងម្ដាយ ) ។

ភរិយារបស់សេដ្ឋីសួរថា ឯងមកអំពីណា ។

នាយឃោសកៈឆ្លើយថា ខ្ញុំមកពីក្នុងក្រុង ។ ភរិយារបស់សេដ្ឋីសួរថា ឯងជាកូនរបស់អ្នកណា ។

នាយឃោសកៈឆ្លើយថា ខ្ញុំជាកូនរបស់សេដ្ឋី ដែលជាសម្លាញ់របស់អ្នកម៉ែ ។ ភរិយារបស់សេដ្ឋីសួរថា ឯងឈ្មោះឃោសកៈឬ ។

នាយឃោសកៈឆ្លើយថា បាទអ្នកម៉ែ ។ ដំណាលគ្នានឹងបានឃើញនោះឯង សេចក្តីស្រឡាញ់ដូចកូនក្នុងនាយឃោសកៈនោះ កើតឡើងដល់នាងហើយ ។ សេដ្ឋីមានកូនក្រមុំម្នាក់ អាយុ ១៥-១៦ ឆ្នាំ រូបស្រស់ប៉ប្រិមគួរឲ្យជ្រះថ្លា សេដ្ឋីឲ្យស្រីបម្រើម្នាក់ ដើម្បីរក្សានាង ឲ្យនៅក្នុងបន្ទប់ដ៏មានសិរី ត្រង់ជាន់ខាងលើនៃប្រាសាទ ៧ ជាន់ ។ ក្នុងខណៈនោះ កូនក្រមុំសេដ្ឋីបានប្រើឲ្យស្រីបម្រើទៅផ្សារ ។ គ្រានោះ ភរិយាសេដ្ឋីឃើញទាសីនោះហើយ សួរថា នាងទៅណា ។

នាងឆ្លើយថា ខ្ញុំទៅដោយកិច្ចរបស់ធីតានៃអ្នកស្រី ។ ភរិយារបស់សេដ្ឋីពោលថា ចូរនាងមកខាងណេះសិន វៀរការបម្រើនោះទុក ចូររៀបគ្រែ លាងជើង លាបប្រេង ក្រាលទីដេកឲ្យកូនរបស់អញសិន សឹមធ្វើការបម្រើឯក្រោយ ។ នាងបានធ្វើតាមពាក្យប្រាប់ហើយ ។

លំដាប់នោះ កូនស្រីរបស់សេដ្ឋីបានរករឿងស្រីបម្រើនោះ ដែលមកយឺត ទើបស្រីបម្រើនោះពោលថា អ្នកនាង កុំខឹងនឹងខ្ញុំឡើយ កូនសេដ្ឋី

ឈ្មោះឃោសកៈមកហើយ ខ្ញុំធ្វើវត្ថុនេះ វត្ថុនេះ ដល់គាត់ហើយ ទើបទៅ ( ផ្សារ ) ហើយមក ។ គ្រាន់តែបានឮឈ្មោះថា ឃោសកៈជាកូនសេដ្ឋីដូច្នេះ សេចក្តីស្រឡាញ់ជ្រាបចូលតាំងអំពីស្បែក រហូតដល់ខួរក្នុងឆ្អឹង តាំងឡើងដល់កូនស្រីសេដ្ឋីហើយ ។ មែនពិត កូនស្រីសេដ្ឋីនោះជាភរិយារបស់នាយឃោសកៈនោះ ក្នុងកាលនៅជានាយកោតុហលិកៈបានប្រគេនបាយ ១ នាឡិ ដល់ព្រះបច្ចេកពុទ្ធ ដោយអានុភាពនៃផលទាននោះ ទើបនាងមកកើតក្នុងត្រកូលសេដ្ឋីនោះ ។ សេចក្តីស្រឡាញ់ក្នុងកាលមុន បានលិចលង់គ្របដណ្តប់កូនស្រីសេដ្ឋីនោះ ទុកដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

**បុព្វេវ សន្និវាសេន បច្ចុប្បន្នហិតេន វា**
**ឯវន្តំ ជាយតេ បេមំ ឧបលំវ យថោទកេតិ ។**

សេចក្តីស្រឡាញ់នោះ រមែងកើតដោយហេតុពីរយ៉ាង គឺដោយធ្លាប់នៅរួមគ្នា ក្នុងកាលមុន ១ ដោយការទំនុកបម្រុងគ្នា ក្នុងបច្ចុប្បន្ននេះ ១ ដូចជាឧប្បលដែលដុះក្នុងទឹកដោយហេតុពីរយ៉ាង គឺទឹក ១ ភក់ ១[១] ។

លំដាប់នោះ នាងសួរស្រីបម្រើថា នែនាង បុរសនោះនៅឯណា ។ ស្រីបម្រើឆ្លើយថា បុរសនោះ ដេកលក់លើទីដេក ។

---

១-បិ.៥៨ ទំ.១២៧ យ.៣២៤ ។

សេដ្ឋីធីតាសួរថា ក្នុងដៃរបស់បុរសនោះ មានអ្វីខ្លះ ។

ស្រីបម្រើឆ្លើយថា មានសំបុត្រត្រង់ជាយសំពត់ ។

សេដ្ឋីធីតា គិតថា នុ៎ះជាសំបុត្រអ្វីហ្ន៎ ។ កាលនាយឃោសកៈ កំពុងដេកលក់ កាលមាតាបិតាមិនឃើញ ព្រោះរវល់បញ្ជូនចិត្តទៅក្នុងរឿងដទៃ ក៏ចុះទៅកាន់សម្នាក់នាយឃោសកៈ ហើយស្រាយយកសំបុត្រនោះ ទៅកាន់បន្ទប់របស់ខ្លួន បិទទ្វារ បើកបង្អួច អានសំបុត្រ ព្រោះនាងឈ្លាសក្នុងអក្ខរសម័យ ( កាលដឹងសេចក្ដីហើយ ) គិតថា ឱ ! មនុស្សល្ងង់ខ្លៅ ចងសំបុត្រសម្រាប់សម្លាប់ខ្លួនឯង ត្រង់ជាយសំពត់ ហើយត្រាច់ទៅ បើអញមិនបានឃើញសំបុត្រនេះ គង់មិនមានជីវិត ដូច្នេះហើយ ហែកសំបុត្រនោះចោល សរសេរសំបុត្រមួយច្បាប់ទៀត តាមពាក្យរបស់សេដ្ឋីថា កូនប្រុសរបស់ខ្ញុំនេះ ឈ្មោះឃោសកៈ សូមអ៊ំនាំបណ្ណាការមកអំពីស្រុកទាំង ១០០ ធ្វើមង្គលជាមួយកូនស្រីសេដ្ឋីក្នុងជនបទនេះ ហើយធ្វើផ្ទះ ២ ជាន់ ត្រង់កណ្ដាលស្រុក ជាលំនៅរបស់ខ្លួន ធ្វើការរក្សាឲ្យរឹងមាំ ដោយរបងគឺកំពែង និងការគ្រប់គ្រងរបស់បុរស ហើយចូរបញ្ជូនដំណឹងមកឲ្យខ្ញុំថា ការងារនេះ ការងារនេះ ខ្ញុំធ្វើស្រេចហើយ កាលកម្មយ៉ាងនេះ អ៊ំធ្វើស្រេចហើយ ខ្ញុំនឹងដឹងវត្ថុដែលគួរធ្វើដល់អ៊ំ ក្នុងកាលជាខាងក្រោយ ។ កាលសរសេរស្រេចហើយ ទើបបត់សំបុត្រ ចុះទៅចងទុកត្រង់ជាយសំពត់របស់នាយឃោសកៈនោះវិញ ។

នាយឃោសកៈនោះ ដេកលក់ពេញមួយថ្ងៃ ក្រោកឡើងបរិភោគហើយ ក៏ចៀសចេញទៅ ។ ស្អែកឡើង ចូលទៅកាន់ស្រុកនោះ អំពីព្រលឹម ក្រឡេកឃើញអ្នកហូតពន្ធធ្វើកិច្ចក្នុងស្រុកនោះឯង ។ អ្នកហូតពន្ធដារនោះ ឃើញនាយឃោសកៈនោះហើយ សួរថា មានការអ្វីបា ។ នាយឃោសកៈឆ្លើយថា លោកឪពុកខ្ញុំបញ្ជូនសំបុត្រមកជូនលោក ។

អ្នកហូតពន្ធនោះ ពោលថា សំបុត្រដើម្បីកិច្ចការអ្វី ចូរបានាំមកចុះ ទទួលសំបុត្រ អានហើយ ក៏មានការពេញចិត្ត ទើបពោលនឹងគហបតីទាំងឡាយថា នែអ្នកទាំងឡាយ សូមមើលការស្រឡាញ់ក្នុងខ្ញុំរបស់លោកម្ចាស់យើងចុះ លោកសេដ្ឋីបញ្ជូនកូនប្រុសមកកាន់សម្នាក់ខ្ញុំ ដោយប្រាប់ថា ចូរធ្វើមង្គលដល់កូនប្រុសច្បងរបស់ខ្ញុំ ពួកអ្នក ចូរប្រញាប់យកឈើជាដើម មកឲ្យរហ័ស ដូច្នេះហើយ ឲ្យសង់ផ្ទះដូចពោលហើយត្រង់កណ្ដាលស្រុក ឲ្យនាំបណ្ណាការមកអំពីស្រុក ១០០ នាំកូនស្រីរបស់សេដ្ឋីក្នុងជនបទ មកធ្វើមង្គលស្រេចហើយ ទើបបញ្ជូនដំណឹងទៅប្រាប់សេដ្ឋីថា ការងារនេះ ការងារនេះ ខ្ញុំធ្វើស្រេចហើយ ។

ព្រោះបានស្ដាប់ដំណឹងនោះ ទោមនស្សដ៏ធំកើតឡើងដល់សេដ្ឋីហើយថា អញឲ្យធ្វើវត្ថុណា វត្ថុនោះមិនសម្រេច វត្ថុណាមិនឲ្យធ្វើ វត្ថុនោះ ក៏បែរជាសម្រេច ការសោយសោកនោះ ផ្សំគ្នានឹងការសោយសោកដល់បុត្ត រួមចូលគ្នាតែមួយ ញ៉ាំងការក្ដៅក្នុងផ្ទៃឲ្យកើតឡើង ឲ្យកើតរោគ

អតិសារៈ ( រោគចុះឈាម ) ហើយ ។ ចំណែកសេដ្ឋីធីតាប្រាប់ពួកមនុស្សថា បើបុគ្គលណាមួយមកអំពីសម្នាក់របស់សេដ្ឋី កាលមិនទាន់បានប្រាប់ខ្ញុំ កុំប្រាប់ដល់សេដ្ឋីបុត្តមុនឡើយ ។ សូម្បីសេដ្ឋីសោត ក៏គិតថា ឥឡូវនេះ អញមិនធ្វើបុត្តអាក្រក់ជួជាតិនោះ ឲ្យជាម្ចាស់ទ្រព្យសម្បត្តិរបស់អញឡើយ ហើយប្រាប់នាយស្មៀនម្នាក់ថា នែអ៊ំ ខ្ញុំប្រាថ្នានឹងចួបកូនរបស់ខ្ញុំ ចូរអ៊ំបញ្ជូនអ្នកបម្រើម្នាក់ ឲ្យហៅកូនរបស់ខ្ញុំមក ។

បុរសនោះទទួលថា បាទ លោកម្ចាស់ ឲ្យសំបុត្រហើយ បញ្ជូនមនុស្សម្នាក់ទៅ ។ ចំណែកកូនស្រីរបស់សេដ្ឋីដឹងថា បុរសនោះ មកឈរត្រង់ទ្វារ ឲ្យហៅមក ហើយសួរថា នែអ្នក តើអ្នកមកមានការអ្វី ។

អ្នកបម្រើនោះពោលថា បពិត្រអ្នកនាងម្ចាស់ លោកសេដ្ឋីមានជំងឺត្រូវការចួបកូនប្រុស ទើបឲ្យហៅ ។ សេដ្ឋីធីតាសួរថា នែអ្នក លោកសេដ្ឋីនោះ នៅមានកម្លាំង ឬថមថយកម្លាំងហើយ ។

អ្នកបម្រើនោះពោលថា បពិត្រអ្នកនាងម្ចាស់ នៅមានកម្លាំងនៅឡើយ នៅបរិភោគអាហារបាន ។ សេដ្ឋីធីតាមិនឲ្យសេដ្ឋីបុត្តនោះដឹងឡើយ ឲ្យលំនៅនិងអាហារដល់បុរសនោះ ហើយពោលថា គាត់នឹងទៅបាន ក្នុងកាលដែលខ្ញុំបញ្ជូនទៅ សូមអ្នកស្នាក់នៅសិនចុះ ។

សេដ្ឋីសួរស្មៀននោះទៀតថា នែអ៊ំ អ៊ំមិនទាន់បានបញ្ជូនសំបុត្រទៅកាន់សម្នាក់កូនរបស់ខ្ញុំទេឬ ។ នាយស្មៀនឆ្លើយថា ខ្ញុំបញ្ជូនទៅ

ហើយ លោកម្ចាស់ តែបុរសនោះ មិនទាន់មក ។

សេដ្ឋីពោលថា បើដូច្នោះ ចូរអឺបញ្ជូនមនុស្សដទៃទៅទៀត ។ នាយស្មៀននោះ បញ្ជូនមនុស្សទៅហើយ ។ កូនស្រីរបស់សេដ្ឋីនោះ បដិបត្តិក្នុងបុរសនោះយ៉ាងនោះ ដូចគ្នា ។ ក្នុងកាលនោះ រោគរបស់សេដ្ឋីធ្ងន់ហើយ ភាជនៈមួយចូល ភាជនៈមួយចេញ ។ សេដ្ឋីសួរនាយស្មៀនទៀតថា នែអឺ អឺមិនទាន់បានបញ្ជូនសំបុត្រទៅកាន់សម្នាក់កូនរបស់ខ្ញុំទេឬ ។

នាយស្មៀនឆ្លើយថា ខ្ញុំបញ្ជូនសំបុត្រទៅហើយ លោកម្ចាស់ តែបុរសដែលទៅមិនទាន់ត្រឡប់មក ។ សេដ្ឋីពោលថា បើដូច្នោះ ចូរអឺបញ្ជូនមនុស្សទៅទៀត ។ នាយស្មៀននោះ បញ្ជូនមនុស្សទៅហើយ ។

សេដ្ឋីធីតាសួរអំពីដំណើររឿងនោះ អំពីបុរសដែលមកក្នុងវារៈទី ៣ ។ បុរសនោះប្រាប់ថា បពិត្រអ្នកនាង សេដ្ឋីឈឺធ្ងន់ ដាច់អាហារហើយ មានការស្លាប់ជាទីទៅខាងមុខ ភាជនៈមួយចេញ ភាជនៈមួយចូល ។ សេដ្ឋីធីតាគិតថា ឥឡូវនេះ ជាកាលដែលសេដ្ឋីបុត្តគួរទៅបាន ទើបប្រាប់ដល់សេដ្ឋីបុត្តថា បានឮថា ឪពុករបស់លោកមានជំងឺ ។

សេដ្ឋីបុត្តសួរថា នែនាងដ៏ចម្រើន នាងនិយាយអ្វី ។ សេដ្ឋីធីតាពោលថា ឪពុករបស់លោក ឈឺធ្ងន់ណាស់ ។

នាយឃោសកៈសួរថា ឥឡូវនេះ ខ្ញុំគួរធ្វើដូចម្តេច ។ សេដ្ឋីធីតា

ពោលថា អ្នកជាម្ចាស់ យើងនឹងកាន់គ្រឿងបណ្ណាការដែលកើតអំពីស្រុកសួយ ១០០ ស្រុក ទៅសួរសុខទុក្ខលោក ។ នាយឃោសកៈទទួលថា សាធុ ទើបឲ្យមនុស្សនាំគ្រឿងបណ្ណាការមក យករទេះដឹកចេញដំណើរទៅ ។

គ្រានោះ សេដ្ឋីធីតាពោលថា ឪពុករបស់លោកថមថយកម្លាំង បើយើងកាន់គ្រឿងបណ្ណាការមានប្រមាណប៉ុណ្ណេះទៅ នឹងធ្វើឲ្យយឺតយូរ សូមលោកឲ្យបញ្ជូនបណ្ណាការនេះត្រឡប់ចុះ ដូច្នេះហើយ ទើបបញ្ជូនបណ្ណាការទាំងនោះ ទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួន ហើយពោលទៀតថា នៃលោក លោកគប្បីឈរខាងចុងជើងបិតារបស់លោក ខ្ញុំនឹងឈរខាងក្បាលដំណេក ។ កាលចូលទៅដល់ផ្ទះនោះហើយ នាងក៏បង្គាប់ពួកមនុស្សរបស់ខ្លួន ឲ្យកាន់យកនូវការរក្សាទាំងខាងមុខផ្ទះ និងខាងក្រោយផ្ទះ ។ ក្នុងកាលដែលជនទាំងពីរចូលទៅ សេដ្ឋីបុត្តបានឈរខាងចុងជើងបិតា ចំណែកភរិយាបានឈរខាងក្បាលដំណេក ។

ក្នុងខណៈនោះ សេដ្ឋីដេកផ្ងារហើយ ចំណែកនាយស្មៀនច្របាច់ជើងរបស់សេដ្ឋីនោះ ពោលថា បពិត្រលោកម្ចាស់ កូនរបស់លោកមកហើយ ។ សេដ្ឋីសួរថា គេនៅឯណា ។

នាយស្មៀនប្រាប់ថា គេឈរត្រង់ចុងជើង ។ លំដាប់នោះ សេដ្ឋីឃើញកូនប្រុសនោះហើយ ទើបហៅនាយស្មៀនមកសួរថា ក្នុងផ្ទះរបស់

ខ្ញុំ មានទ្រព្យប៉ុន្មាន ។

នាយស្មៀនប្រាប់ថា បពិត្រលោកម្ចាស់ ទ្រព្យមាន ៤០ កោដិ ប៉ុណ្ណោះ តែគ្រឿងឧបភោគបរិភោគ ស្រុក ស្រែ សត្វជើង ២ ជើង ៤ យាន ពាហនៈ មានចំនួនប៉ុណ្ណោះៗ ។ លោកសេដ្ឋីនោះ ប្រាថ្នានឹងពោលថា ខ្ញុំមិនឲ្យទ្រព្យមានប្រមាណប៉ុណ្ណោះ ដល់ឃោសកៈជាកូនរបស់ខ្ញុំឡើយ បែរជាពោលថា ខ្ញុំឲ្យ ។ សេដ្ឋីធីតាស្តាប់ពាក្យនោះហើយ គិតថា សេដ្ឋីនេះ កាលពោលម្តងទៀត គប្បីពោលពាក្យដទៃ ដូច្នេះហើយ ធ្វើហាក់ដូចក្តៅក្រហាយដោយសេចក្តីសោក រំសាយសក់ ទ្រហោយំ ហើយពោលថា លោកឪពុកពោលអ្វីហ្នឹង ពួកខ្ញុំស្តាប់ពាក្យរបស់លោកយ៉ាងនេះ ពួកខ្ញុំមិនមានបុណ្យពិត ហើយក៏យកក្បាលប្រហារសេដ្ឋីនោះត្រង់កណ្តាលទ្រូង យកក្បាលទន្គិចត្រង់ទ្រូង សម្តែងអាការយំសោក ដោយប្រការដែលលោកសេដ្ឋីមិនអាចពោលបានម្តងទៀត ។ សេដ្ឋីក៏ធ្វើមរណកាលក្នុងខណៈនោះឯង ។

ជនទាំងឡាយបានឮថា សេដ្ឋីធ្វើមរណកាលហើយ ទើបទៅក្រាបទូលព្រះបាទឧទេន ។ ព្រះបាទឧទេនទ្រង់ឲ្យធ្វើឈាបនកិច្ចសរីរៈរបស់សេដ្ឋីនោះ ហើយត្រាស់សួរថា កូនប្រុស ឬកូនស្រីរបស់សេដ្ឋីនោះ មានដែរឬទេ ។

ជនទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេព មាន កូនប្រុស

*របស់សេដ្ឋីនោះ ឈ្មោះឃោសកៈ សេដ្ឋីនោះ ប្រគល់ទ្រព្យសម្បត្តិទាំងអស់ ឲ្យដល់ឃោសកៈនោះហើយ ទើបធ្វើមរណកាលទៅ ។*

*ក្នុងកាលខាងក្រោយមក ព្រះរាជាឲ្យហៅបុត្តសេដ្ឋីមកហើយ ។ ក្នុងថ្ងៃនោះ មានភ្លៀងធ្លាក់ ត្រង់លានព្រះរាជវាំងមានទឹកដក់ក្នុងទីនោះ ៗ សេដ្ឋីបុត្តទៅហើយដោយបំណងថា នឹងគាល់ព្រះរាជា ។ ព្រះរាជាទ្រង់បើកបង្អួចទតមើលនាយឃោសកៈនោះ ទ្រង់ឃើញនាយឃោសកៈលោតរំលងទីដែលមានទឹកដក់ត្រង់លានព្រះរាជវាំង ដើរមក ទើបត្រាស់សួរនាយឃោសកៈដែលមកថ្វាយបង្គំ ហើយឈរថា* **ត្វំ ឃោសកោ ជាម តាត** *នែបា ឯងឈ្មោះឃោសកៈឬ ។*

*នាយឃោសកៈក្រាបទូលថា ព្រះករុណាថ្ងៃវិសេស ។*

*ព្រះរាជាទ្រង់លួងលោមឃោសកៈថា បាកុំទោមនស្សឡើយថា បិតារបស់អញទទួលអនិច្ចកម្មហើយ យើងនឹងឲ្យតំណែងសេដ្ឋីដែលជារបស់ឪពុក ដល់បាប៉ុណ្ណោះ ហើយទើបទ្រង់បញ្ជូនឃោសកៈទៅថា ចូរបាទៅចុះ ។ ព្រះរាជាបានប្រថាប់ឈរមើលឃោសកៈកំពុងទៅទុំះឯង នាយឃោសកៈនោះ មិនលោតរំលងទឹក ដូចលោតក្នុងកាលមក បានដើរទៅសន្សឹម ៗ ។*

*លំដាប់នោះ ព្រះរាជាត្រាស់ឲ្យហៅឃោសកៈនោះ មកអំពីទីនោះឯង ហើយត្រាស់សួរថា នែបា ព្រោះហេតុអ្វី កាលបាមកកាន់សម្នាក់*

យើង លោតរំលងទឹកមក កាលទៅ ក៏ដើរទៅសន្សឹមៗ ។

នាយឃោសកៈក្រាបទូលថា យ៉ាងនោះឯងព្រះអង្គ ក្នុងកាលនោះ ទូលព្រះបង្គំនៅជាកុមារ នេះឈ្មោះថា ជាកាលដែលត្រូវលេង ក្នុងពេលនេះ ទូលព្រះបង្គំបានទទួលតំណែងអំពីព្រះអង្គហើយ ព្រោះហេតុនោះ ទូលព្រះបង្គំមិនទៅដូចកាលមុន ក្នុងកាលឥឡូវនេះ ដើរសន្សឹមៗ ទៅ ទើបគួរ ។

ព្រះរាជាស្តាប់ពាក្យនោះហើយ ទ្រង់ព្រះតម្រិះថា បុរសនេះ មានបញ្ញា អញនឹងឲ្យតំណែងសេដ្ឋីដល់គេក្នុងកាលឥឡូវនេះចុះ ដូច្នេះហើយ ព្រះរាជទានភោគៈដែលបិតាបរិភោគហើយ បានប្រទានតំណែងសេដ្ឋី មួយអន្លើដោយវត្ថុមួយមុខមួយរយៗ ។

ឃោសកៈនោះឈរនៅលើរថ បានធ្វើប្រទក្សិណព្រះនគរហើយ ទីដែលឃោសកៈនោះ សម្លឹងមើលហើយ រមែងញាប់ញ័រ ។ សេដ្ឋីធីតាអង្គុយប្រឹក្សាជាមួយនាងកាឡីស្រីបម្រើថា អ្នកម៉ែកាឡី សម្បត្តិមានប្រមាណប៉ុណ្ណេះ សម្រេចដល់សេដ្ឋីបុត្តរបស់ម៉ែ ក៏ព្រោះអាស្រ័យខ្ញុំ ។

នាងកាឡីសួរថា ព្រោះហេតុអ្វី កូនស្រី ។ សេដ្ឋីធីតាឆ្លើយថា សេដ្ឋីនេះ ចងសំបុត្រសម្រាប់ខ្លួនទុកត្រង់ជាយសំពត់ មកកាន់ផ្ទះរបស់ខ្ញុំ កាលនោះ ខ្ញុំហែកសំបុត្រនោះចោល សរសេរសំបុត្រដទៃ ដើម្បីធ្វើមង្គលជាមួយខ្ញុំ ខ្ញុំរក្សាគាត់អស់កាលមានប្រមាណប៉ុណ្ណោះ ។

នាងកាឡីពោលថា អ្នកនាងដឹងត្រឹមតែប៉ុណ្ណោះ តែសេដ្ឋីមានបំណងសម្លាប់សេដ្ឋីបុត្ត តាំងអំពីនៅជាកុមារ តែមិនអាចសម្លាប់បានអាស្រ័យលោកម្ចាស់ឃោសកៈនេះ អស់ទ្រព្យសន្ធឹកសន្ធាប់ ។

សេដ្ឋីធីតាពោលថា អ្នកម៉ែ លោកសេដ្ឋីធ្វើកម្មធ្ងន់ហ្ន៎ ។ សេដ្ឋីធីតាឃើញនាយឃោសកៈនោះ ធ្វើប្រទក្សិណនគរ ហើយចូលមកកាន់ផ្ទះអស់សំណើចដោយគិតថា សម្បត្តិមានប្រមាណប៉ុណ្ណោះ សម្រេចហើយព្រោះអាស្រ័យអញ ។ គ្រានោះ សេដ្ឋីបុត្តឃើញអាការនោះ ទើបសួរថា នាងសើចអ្វី ។ សេដ្ឋីធីតាពោលថា ព្រោះអាស្រ័យហេតុមួយ ។

ឃោសកសេដ្ឋីពោលថា ចូរប្រាប់ហេតុនោះ ។ សេដ្ឋីធីតាពោលថា ខ្ញុំមិនប្រាប់ទេ ។

ឃោសកសេដ្ឋីសម្លុតថា បើនាងមិនប្រាប់ ខ្ញុំនឹងកាប់ជាពីរកំណាត់ដូច្នេះ ដកដាវចេញហើយ ។ សេដ្ឋីធីតានោះប្រាប់ថា ខ្ញុំសើច ព្រោះគិតថា សម្បត្តិមានប្រមាណប៉ុណ្ណោះ លោកបានហើយព្រោះអាស្រ័យខ្ញុំ ។

ឃោសកសេដ្ឋីពោលថា ឪពុករបស់ខ្ញុំប្រគល់មរតករបស់ខ្លួនឲ្យដល់ខ្ញុំហើយ នាងទាក់ទិនអ្វីក្នុងទ្រព្យនេះ ។ បានឮថា ឃោសកសេដ្ឋីមិនដឹងរឿងអ្វីសោះ អស់កាលមានប្រមាណប៉ុណ្ណោះ ព្រោះហេតុនោះទើបមិនជឿពាក្យរបស់សេដ្ឋីធីតានោះ ។ លំដាប់នោះ សេដ្ឋីធីតាបាននិទានរឿងទាំងអស់នោះ ដល់សេដ្ឋីបុត្តថា បិតារបស់លោកឲ្យសំបុត្រ

សម្លាប់ បញ្ជូនលោកមកហើយ ខ្ញុំធ្វើកម្មយ៉ាងនេះ ៗ រក្សាលោកទុកហើយ ។

ឃោសកសេដ្ឋីពោលថា នាងនិយាយមិនពិត ហើយគិតថា អញនឹងសួរម៉ែកាឡី ដូច្នេះហើយ ទើបពោលថា បានឮថា សេចក្ដីនោះយ៉ាងនេះឬ អ្នកម៉ែ ។

នាងកាឡីពោលថា នែបា កាលបានៅកុមារ សេដ្ឋីមានបំណងសម្លាប់បា តែមិនអាចសម្លាប់បាន អាស្រ័យបា លោកម្ចាស់អស់ទ្រព្យសន្ធឹកសន្ធាប់ បារួចផុតហើយអំពីសេចក្ដីស្លាប់ក្នុងទី ៧ កន្លែង ឥឡូវនេះ មកហើយអំពីស្រុកសួយ បានតំណែងសេដ្ឋីនេះ មួយអន្លើដោយវត្ថុសព្វយ៉ាង មួយមុខមួយរយ ៗ ។ សេដ្ឋីស្តាប់ពាក្យនោះហើយ គិតថា ( វិបាក ) កម្មរបស់អញធ្ងន់ហ្ន៎ អញផុតហើយអំពីសេចក្ដីស្លាប់បែបនេះ ហើយរស់នៅដោយសេចក្ដីប្រមាទ មិនសមគួរឡើយ អញនឹងមិនប្រមាទ ដូច្នេះហើយ លះទ្រព្យមួយថ្ងៃមួយពាន់ ផ្ដើមតាំងទានទុក ដើម្បីអ្នកដើរផ្លូវឆ្ងាយ និងមនុស្សកំព្រាជាដើម កុដុម្ពិកៈឈ្មោះថា មិត្តៈ បានជាអ្នកខ្វល់ខ្វាយក្នុងទានរបស់សេដ្ឋីនោះឯង ។

ក្នុងកាលនោះ សេដ្ឋីឈ្មោះភទ្ទវតិយៈ ក្នុងភទ្ទវតីនគរ បានជាអទិដ្ឋបុព្វសហាយៈ គឺសម្លាញ់ដែលមិនធ្លាប់ឃើញគ្នារបស់ឃោសកសេដ្ឋីនោះ ។ ឃោសកសេដ្ឋីបានស្ដាប់អំពីសម្បត្តិ វ័យ និងប្រទេស របស់

ភទ្ទវតិយសេដ្ឋី ក្នុងសម្នាក់របស់ពួកឈ្មួញដែលមកអំពីភទ្ទវតីនគរ ប្រាថ្នានូវភាពជាសម្លាញ់ជាមួយសេដ្ឋីនោះ ទើបបញ្ជូនបណ្ណាការទៅ ។ ភទ្ទវតិយសេដ្ឋីបានស្តាប់អំពីសម្បត្តិ វ័យ និងប្រទេស របស់ឃោសកសេដ្ឋី ក្នុងសម្នាក់របស់ពួកឈ្មួញដែលមកអំពីនគរកោសម្ពី ប្រាថ្នានូវភាពជាសម្លាញ់ជាមួយសេដ្ឋីនោះ ទើបបញ្ជូនបណ្ណាការទៅ សេដ្ឋីទាំងពីរនោះបានជាអទិដ្ឋបុព្វសហាយៈនៃគ្នានឹងគ្នាហើយ ដោយប្រការយ៉ាងនេះ ។

ក្រោយមក អហិវាតករោគធ្លាក់ចុះហើយ ក្នុងផ្ទះរបស់ភទ្ទវតិយ-សេដ្ឋី ។ កាលអហិវាតករោគនោះធ្លាក់ចុះហើយ រុយរមែងស្លាប់មុន បន្ទាប់អំពីនោះ កន្លាត កណ្តុរ មាន់ ជ្រូក គោ អ្នកបម្រើស្រី អ្នកបម្រើប្រុស ស្លាប់ទៅដោយលំដាប់នោះឯង មនុស្សជាម្ចាស់ផ្ទះ រមែងស្លាប់ក្រោយគេ ។ ក្នុងជនទាំងនោះ ពួកជនណាទម្លាយជញ្ជាំងផ្ទះគេចទៅ ពួកជននោះ រមែងបានរួចជីវិត ។ ក្នុងកាលនោះ សេដ្ឋី ភរិយានិងកូនស្រី ក៏គេចទៅដោយវិធីនោះ ប្រាថ្នានឹងឃើញឃោសកសេដ្ឋី ទើបធ្វើដំណើរទៅកាន់នគរកោសម្ពី ។ ជនទាំង ៣ នាក់នោះ អស់ស្បៀងក្នុងរវាងផ្លូវ មានសរីរៈទន់ខ្សោយដោយខ្យល់និងកម្តៅថ្ងៃ និងដោយការស្រេកឃ្លាន ដល់នគរកោសម្ពីយ៉ាងលំបាក ងូតទឹកក្នុងទីដែលសម្បូរដោយទឹកហើយ ក៏ចូលទៅកាន់សាលាមួយត្រង់ទ្វារក្រុង ។

ក្នុងកាលនោះ សេដ្ឋីពោលនឹងភរិយាថា នែនាងដ៏ចម្រើន បុគ្គល

ដែលមកទាំងសភាពបែបនេះ រមែងមិនជាទីពេញចិត្ត សូមប្រិម្តាយបង្កើតបានឮថា សម្លាញ់របស់យើងលះទ្រព្យមួយថ្ងៃមួយពាន់ ឲ្យទានដល់អ្នកដំណើរ មនុស្សកំព្រាជាដើម យើងបញ្ជូនកូនស្រីទៅក្នុងទីនោះ ឲ្យនាំអាហារមកទំនុកបម្រុងសរីរៈក្នុងទីនេះឯង មួយថ្ងៃពីរថ្ងៃហើយ សឹមទៅសួរសុខទុក្ខសម្លាញ់ ។

នាងទទួលថា សាធុ អ្នកជាម្ចាស់ ។ ជនទាំងនោះ នាំគ្នាស្នាក់នៅក្នុងសាលានោះឯង ។ ស្អែកឡើង កាលមហាជនប្រាប់កាលហើយ មនុស្សកំព្រា អ្នកដើរផ្លូវជាដើម នាំគ្នាទៅដើម្បីអាហារ មាតានិងបិតាក៏បញ្ជូនកូនស្រីទៅដោយពាក្យថា នែនាង នាងចូរទៅនាំអាហារមក ដើម្បីពួកយើង ។ ធីតារបស់ត្រកូលដែលមានភោគៈច្រើន កាត់សេចក្ដីខ្មាសអៀន កាន់ថាសទៅជាមួយមនុស្សអនាថាដើម្បីអាហារ កាលមិត្តកុដុម្ពិកៈសួរថា នែនាង នាងទទួលប៉ុន្មានចំណែក ក៏ប្រាប់ថា បីចំណែក ។ លំដាប់នោះ មិត្តកុដុម្ពិកៈឲ្យអាហារ ៣ ចំណែកដល់នាង ។ កាលនាំភត្តមកហើយ ជនទាំងបីក៏អង្គុយដើម្បីបរិភោគរួមគ្នា ។

លំដាប់នោះ មាតានិងកូនស្រីក៏ពោលនឹងសេដ្ឋីថា បពិត្រលោកម្ចាស់ បពិត្រលោកឪពុក វិបត្តិរមែងកើតឡើង សូម្បីក្នុងត្រកូលធំ កុំគិតពួកខ្ញុំឡើយ សូមបរិភោគចុះ អង្វរដោយប្រការផ្សេងៗ ញុំាងសេដ្ឋីឲ្យបរិភោគហើយដោយប្រការដូច្នេះ ។ សេដ្ឋីនោះបរិភោគហើយ មិនអាច

ឲ្យអាហាររលាយបាន កាលអរុណរះឡើង ក៏ធ្វើកាលកិរិយា ភរិយានិង កូនស្រីយំសោកដោយប្រការផ្សេងៗ ។ ក្នុងថ្ងៃស្អែកឡើង កុមារិកាដើរយំទៅដើម្បីអាហារ ។ មិត្តកុដុម្ពិកៈនោះឃើញហើយសួរថា នាងទទួលប៉ុន្មានចំណែក ។

នាងប្រាប់ថា ២ ចំណែក ។ នាងនាំអាហារមកហើយ អង្វរឲ្យមាតាបរិភោគ មាតានោះ កាលធីតារបស់ខ្លួនអង្វរហើយ ក៏បរិភោគ មិនអាចឲ្យអាហាររលាយបានក្នុងថ្ងៃនោះ ក៏ធ្វើកាលកិរិយាទៅ ។ កុមារិកាម្នាក់ឯងប៉ុណ្ណោះ យំរៀបរាប់ ជាអ្នកមានសេចក្តីទុក្ខព្រោះបាត់បង់មាតាបិតា និងព្រោះសេចក្តីឃ្លានដែលកើតឡើងហើយដ៏ខ្លាំងក្លា ។ ថ្ងៃស្អែកឡើង ក៏យំដើរទៅជាមួយពួកយាចកដើម្បីអាហារ ។ មិត្តកុដុម្ពិកៈសួរថា នាងទទួលប៉ុន្មានចំណែក ។

នាងឆ្លើយថា មួយចំណែក ។ មិត្តកុដុម្ពិកៈចាំនាងដែលទទួលភត្តបានទាំង ៣ ថ្ងៃ ព្រោះហេតុនោះ ទើបពោលថា ចូរវិនាសចុះ ស្រីថោកទាប ថ្ងៃនេះ នាងស្គាល់ប្រមាណក្នុងពោះរបស់នាងហើយឬ ។

ធីតាមានត្រកូល សម្បូរដោយហិរិឱត្តប្បៈ ដូចត្រូវប្រហារដោយលំពែង ត្រង់ទ្រូង និងដូចស្រោចដោយទឹកក្បុងត្រង់ដំបៅ សួរថា តើលោកម្ចាស់និយាយអ្វី ។ មិត្តកុដុម្ពិកៈពោលថា ថ្ងៃមុន នាងទទួលយកទៅបីចំណែក ម្សិលមិញ ពីរចំណែក ថ្ងៃនេះ ទទួលមួយចំណែក ថ្ងៃ

នេះ នាងដឹងប្រមាណក្នុងពោះរបស់នាងហើយឬ ។

កុលធីតាពោលថា សូមលោកម្ចាស់កុំសម្គាល់ថា ខ្ញុំទទួលទៅដើម្បីបរិភោគម្នាក់ឯងឡើយ ។ មិត្តកុដុម្ពិកៈសួរថា បើដូច្នោះ ថ្ងៃនេះហេតុអ្វី ទើបទទួលតែមួយចំណែក ។

កុលធីតាពោលថា ថ្ងៃមុន ពួកខ្ញុំមានគ្នាបីនាក់ ម្សិលមិញ មានពីរនាក់ ថ្ងៃនេះ មានតែខ្ញុំម្នាក់ឯងប៉ុណ្ណោះ ។ មិត្តកុដុម្ពិកៈសួរថា សេចក្តីនេះ ដូចម្តេច ។ បានស្តាប់រឿងទាំងអស់ដែលនាងប្រាប់ហើយ តាំងអំពីដើម មិនអាចទប់ទឹកភ្នែកបាន ដល់នូវទោមនស្សដ៏ខ្លាំងក្លា ទើបប្រាប់នាងថា នៃកូនស្រី បើមានហេតុយ៉ាងនេះ កុំគិតថ្វីឡើយ នាងជាធីតារបស់ភទ្ទវតិយសេដ្ឋី ចាប់អំពីថ្ងៃនេះទៅ នាងចូរជាធីតារបស់ខ្ញុំចុះ ហើយថើបត្រង់ក្បាល នាំទៅកាន់ផ្ទះ តាំងទុកក្នុងតំណែងកូនស្រីច្បងរបស់ខ្លួន ។

សេដ្ឋីធីតានោះ ឮសំឡេងខ្ទៀវខ្ទារក្នុងរោងទាន ទើបសួរថា បពិត្រលោកឪពុក ហេតុអ្វីទើបមិនធ្វើជនទាំងនេះ ឲ្យស្ងាត់ស្ងៀម ហើយឲ្យទាន ។ មិត្តកុដុម្ពិកៈពោលថា ម្នាលកូនស្រី យើងមិនអាចធ្វើបាន ។

សេដ្ឋីធីតាពោលថា ខ្ញុំអាចធ្វើបាន លោកឪពុក ។ មិត្តកុដុម្ពិកៈសួរថា តើនាងអាចធ្វើដូចម្តេច កូនស្រី ។

សេដ្ឋីធីតាពោលថា បពិត្រលោកឪពុក សូមលោកឪពុកព័ទ្ធរោងទាន ទុកទ្វារពីរកន្លែង ល្មមប្រមាណបុគ្គលម្នាក់ចូលទៅបាន ហើយ

ប្រាប់ថា ពួកអ្នក ចូរចូលតាមទ្វារមួយ ចេញតាមទ្វារមួយ ដោយអាការយ៉ាងនេះ ជនទាំងឡាយក៏ស្ងាត់ស្ងៀម ហើយទទួលយកនូវទាន ។

មិត្តកុដុម្ពិកៈស្តាប់ហើយពោលថា ឧបាយនេះល្អ កូនស្រី ដូច្នេះហើយ ទើបឲ្យធ្វើយ៉ាងនោះ ។ សេដ្ឋីធីតានោះ ក្នុងកាលមុនឈ្មោះថា សាមា កាលនាងឲ្យធ្វើរបង ទើបបានឈ្មោះថា សាមាវតី ។ តាំងអំពីកាលនោះមក កោលាហលក្នុងរោងទានក៏បាត់ទៅ ។ ឃោសកសេដ្ឋីបានឮសំឡេងនោះ ក្នុងកាលមុន ក៏ពេញចិត្តថា នេះជាសំឡេងក្នុងរោងទានរបស់អញ តែកាលមិនបានឮសំឡេងពីរបីថ្ងៃ ទើបសួរមិត្តកុដុម្ពិកៈដែលមកកាន់កន្លែងខ្លួនថា នែអ្នក ទានដើម្បីមនុស្សកំព្រា និងជនអ្នកធ្វើដំណើរឆ្ងាយជាដើម អ្នកនៅតែឲ្យឬ ។

មិត្តកុដុម្ពិកៈឆ្លើយថា បាទលោកម្ចាស់ ។ ឃោសកសេដ្ឋីសួរថា បើដូច្នោះ ហេតុអ្វី ទើបមិនឮសំឡេងអស់ពីរបីថ្ងៃហើយ ។

មិត្តកុដុម្ពិកៈឆ្លើយថា ខ្ញុំធ្វើឧបាយដោយអាការដែលពួកគេមិនមានសំឡេង ហើយទទួល ។ ឃោសកសេដ្ឋីសួរថា បើដូច្នោះ ហេតុអ្វីទើបអ្នកមិនធ្វើក្នុងកាលមុន ។

មិត្តកុដុម្ពិកៈឆ្លើយថា ព្រោះខ្ញុំមិនដឹងលោកម្ចាស់ ។ ឃោសកសេដ្ឋីសួរថា ចុះឥឡូវនេះ អ្នកដឹងបានដូចម្តេច ។

មិត្តកុដុម្ពិកៈឆ្លើយថា កូនស្រីរបស់ខ្ញុំជាអ្នកប្រាប់ ។ ឃោសកសេដ្ឋី

សួរថា កូនស្រីរបស់អ្នកដែលខ្ញុំមិនស្គាល់ មានឬ ។ មិត្តកុដុម្ពិកៈនោះ និទានរឿងរបស់ភទ្ទវតិយសេដ្ឋីទាំងអស់ តាំងអំពីកើតអហិវាតករោគ ហើយប្រាប់អំពីភាពដែលខ្លួនតាំងធីតារបស់សេដ្ឋីនោះ ទុកក្នុងតំណែងកូនស្រីច្បងរបស់ខ្លួន ។ គ្រានោះ ឃោសកសេដ្ឋីពោលថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបអ្នកមិនប្រាប់ដល់ខ្ញុំ ធីតារបស់សម្លាញ់ខ្ញុំ ក៏ឈ្មោះថា ជាធីតារបស់ខ្ញុំដែរ ដូច្នេះហើយ ឲ្យហៅនាងសាមាវតីនោះមក សួរថា នែនាង នាងជាកូនស្រីរបស់សេដ្ឋីឬ ។

នាងសាមាវតីឆ្លើយថា ចាស លោកឪពុក ។ ឃោសកសេដ្ឋីពោលថា បើដូច្នោះ នាងកុំគិតថ្វីឡើយ នាងជាធីតារបស់ខ្ញុំ ទើបនាងត្រង់ក្បាល ឲ្យស្រី ៥០០ នាក់ដល់នាង ដើម្បីប្រយោជន៍ដល់ភាពជាបរិវារ តាំងនាងទុកក្នុងតំណែងកូនស្រីច្បងរបស់ខ្លួនហើយ ។

សម័យថ្ងៃមួយ ក្នុងនគរនោះ មានការប្រកាសនក្ខត្តឫក្សហើយ ក្នុងបុណ្យនក្ខត្តឫក្សនោះ កុលធីតាទាំងឡាយដែលមិនបានចេញទៅខាងក្រៅ ក៏នាំគ្នាដើរទៅកាន់ស្ទឹង ងូតទឹកជាមួយបរិវាររៀង ៗ ខ្លួន ។ ព្រោះហេតុនោះ ក្នុងថ្ងៃនោះ នាងសាមាវតី មានស្រីទាំង ៥០០ ចោមរោមហើយ ក៏បានទៅងូតទឹក កាត់តាមលានព្រះរាជវាំងដូចគ្នា ។ ចំណែកព្រះបាទឧទេនប្រថាប់ឈរត្រង់សីហបញ្ជរ ទតឃើញនាងសាមាវតីនោះ ទើបត្រាស់សួរថា ស្រីទាំងនេះ ជាស្រីបម្រើរបស់អ្នកណា ។

រាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព មិនមែនជាស្រីបម្រើរបស់អ្នកណាឡើយ ។ ព្រះបាទឧទេនត្រាស់សួរថា បើដូច្នោះ នាងជាកូនស្រីរបស់អ្នកណា ។

រាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព នាងជាកូនស្រីរបស់ឃោសកសេដ្ឋី ឈ្មោះនាងសាមាវតី ។

ព្រះបាទឧទេនទតឃើញ ទ្រង់កើតសេចក្តីស្នេហា ទើបត្រាស់ឲ្យបញ្ជូនរាជសាសន៍ទៅឲ្យសេដ្ឋីថា សូមលោកសេដ្ឋីបញ្ជូនធីតាមកឲ្យយើង ។

សេដ្ឋីក្រាបទូលថា បពិត្រព្រះសម្មតិទេព បញ្ជូនមិនបានទេ ។

ព្រះបាទឧទេនត្រាស់ថា សូមលោកសេដ្ឋីកុំធ្វើយ៉ាងនេះឡើយ ចូរបញ្ជូនមកចុះ ។

ឃោសកសេដ្ឋីពោលថា បពិត្រព្រះសម្មតិទេព ពួកទូលព្រះបង្គំជាគហបតី ឲ្យមិនបាន ព្រោះភ័យខ្លាចការវាយដំ រុញច្រានកុមារិការបស់ទូលព្រះបង្គំ ។ ព្រះរាជាទ្រង់ពិរោធ ទើបត្រាស់ឲ្យវាយត្រាផ្ទះចាប់សេដ្ឋីនិងភរិយារបស់សេដ្ឋីទុកខាងក្រៅ នាងសាមាវតីងូតទឹកហើយត្រឡប់មក មិនបានឱកាសចូលក្នុងផ្ទះ ទើបសួរថា បពិត្រលោកឪពុក តើមានរឿងអ្វី ។

សេដ្ឋីឆ្លើយថា ម្នាលកូនស្រី ព្រះរាជាបញ្ជូនព្រះរាជសាសន៍មក

ព្រោះហេតុតែនាង កាលពួកយើងពោលថា មិនឲ្យ ទើបទ្រង់បញ្ជាឲ្យវាយត្រាផ្ទះ ហើយធ្វើពួកយើងទុកខាងក្រៅ ។

នាងសាមាវតីពោលថា បពិត្រលោកឪពុក លោកឪពុកធ្វើកម្មធ្ងន់ហើយ ធម្មតាព្រះរាជា កាលបញ្ជូនរាជសាសន៍មកហើយ មិនគួរទូលថា មិនឲ្យ គួរទូលថា បើព្រះអង្គទ្រង់ទទួលធីតារបស់ទូលព្រះបង្គំព្រមទាំងបរិវារ ក៏នឹងថ្វាយ ។

សេដ្ឋីពោលថា ប្រពៃហើយ បើនាងពេញចិត្ត ឪពុកនឹងធ្វើយ៉ាងនេះ ដូច្នេះហើយ ទើបបញ្ជូនដំណឹងទៅថ្វាយព្រះរាជាតាមនោះ ។ ព្រះរាជាទទួលថា សាធុ ទ្រង់នាំនាងសាមាវតីនោះមក មួយអន្លើដោយបរិវារ ទ្រង់អភិសេក តាំងទុកក្នុងតំណែងអគ្គមហេសីហើយ ។ ស្រីដ៏សេស ក៏បានជាបរិវាររបស់នាងដូចដែល ។

ព្រះបាទឧទេននោះ មានព្រះទេវីមួយអង្គទៀត ព្រះនាមថា ព្រះនាងវាសុលទត្តា ជាព្រះរាជធីតារបស់ព្រះបាទចណ្ឌប្បជ្ជោត ។ សេចក្តីពិស្តារថា ក្នុងក្រុងឧជ្ជេនី មានព្រះរាជាទ្រង់ព្រះនាមថា ចណ្ឌប្បជោត ។ ថ្ងៃមួយ ទ្រង់មកអំពីព្រះរាជឧទ្យាន ទតមើលសម្បត្តិរបស់ព្រះអង្គហើយត្រាស់ថា សម្បត្តិបែបនេះ បុគ្គលដទៃណាមួយ មានដែរឬ ។ កាលអាមាត្យទាំងឡាយក្រាបទូលថា ឈ្មោះថា សម្បត្តិ (របស់ព្រះអង្គ) នឹងមានដូចម្តេច សម្បត្តិរបស់ព្រះបាទឧទេនក្នុងក្រុងកោសម្ពី ច្រើនពេក

ណាស់ ទើបត្រាស់ថា បើដូច្នោះ យើងនឹងចាប់ស្តេចឧទេននោះ ។

អាមាត្យទាំងឡាយពោលថា បុគ្គលណាមួយ ក៏មិនអាចចាប់ទ្រង់បានឡើយ ។ ព្រះរាជាត្រាស់ថា យើងនឹងធ្វើឧបាយណាមួយ ចាប់ឲ្យបាន ។

ពួកអាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព មិនអាចទេ ។ ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វី ។

អាមាត្យទាំងនោះពោលថា ព្រោះព្រះបាទឧទេននោះ ចេះសិប្បៈឈ្មោះហត្ថិកន្តៈ ទ្រង់រាយមន្តហើយ ដេញពិណហត្ថិកន្តៈ នឹងឲ្យដំរីគេចទៅក៏បាន នឹងចាប់យកក៏បាន បុគ្គលដែលដល់ព្រមដោយពាហនៈ គឺដំរី ស្មើនឹងទ្រង់ មិនមានឡើយ ។ ព្រះរាជាត្រាស់សួរពួកអាមាត្យថា យើងមិនអាចចាប់ស្តេចអង្គនេះ បានទេឬ ។

អាមាត្យទាំងនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព បើទ្រង់សម្រេចព្រះហឫទ័យបែបនេះ ដោយចំណែកមួយហើយ បើដូច្នោះ សូមទ្រង់បញ្ជាឲ្យជាងធ្វើដំរីឈើ ហើយបញ្ជូនទៅកាន់លំនៅរបស់ព្រះបាទឧទេននោះ ។ ព្រះបាទឧទេននោះ កាលទ្រង់បានឮដំណឹងអំពីពាហនៈដំរី ឬពាហនៈសេះហើយ នឹងយាងទៅ សូម្បីនៅក្នុងទីឆ្ងាយ យើងនឹងអាចចាប់ទ្រង់ ដែលយាងមកក្នុងទីនោះបាន ។

ព្រះរាជាត្រាស់ថា ឧបាយនេះ ប្រើការបាន ដូច្នេះហើយ ទើប

ប្រាប់ឲ្យជាងឈើធ្វើដំរីយន្ត សម្រេចដោយឈើ យកសំពត់ចាស់ស្រោបខាងក្រៅ ធ្វើឲ្យស្អាត ឲ្យលែងទៅត្រង់មាត់ស្រះមួយកន្លែង ក្នុងទីជិតដែនរបស់ព្រះបាទឧទេននោះ ។ បុរស ៦០ នាក់ ដើរទៅមកក្នុងពោះដំរី បុរសទាំងនោះ នាំមូលដំរីមកបោះក្នុងទីនោះៗ ។ ព្រានព្រៃម្នាក់ឃើញដំរីហើយ គិតថា ដំរីនេះ គួរដល់ស្តេចផែនដីរបស់យើង ដូច្នេះហើយទើបទៅក្រាបទូលព្រះបាទឧទេនថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំបានឃើញដំរីដ៏ប្រសើរ មានពណ៌សសុទ្ធ មានចំណែកប្រៀបដោយកំពូលភ្នំកៃលាស គួរដល់ព្រះអង្គប៉ុណ្ណោះ ។ ព្រះបាទឧទេនឲ្យនាយព្រាននោះឯង នាំផ្លូវ ទ្រង់ឡើងលើដំរីព្រមទាំងបរិវារ ចេញទៅហើយ ។ ពួកចារបុរសដឹងការយាងមករបស់ទ្រង់ ទើបទៅក្រាបទូលដល់ព្រះបាទចណ្ឌប្បជ្ជោត ។ ព្រះបាទចណ្ឌប្បជ្ជោតនោះ យាងមកហើយ បង្កប់ពលនិកាយទុកសងខាងផ្លូវ បើកផ្លូវទុកត្រង់កណ្តាល ។ ព្រះបាទឧទេនមិនបានជ្រាបដល់ការយាងមករបស់ព្រះបាទចណ្ឌប្បជ្ជោត ទើបដេញតាមដំរីទៅ ។ ពួកមនុស្សដែលនៅខាងក្នុង ប្រញាប់បញ្ឆោដំរីឈើគេចទៅដោយរហ័ស កាលព្រះរាជាទ្រង់រាយមន្ត ដេញពិណ ដំរីឈើធ្វើហាក់ដូចជាមិនបានឮសំឡេងខ្សែពិណ គេចទៅតែម្យ៉ាង ។ ព្រះរាជាមិនអាចដេញទាន់ដំរី ទើបទ្រង់ផែលឡើងជិះសេះ ដេញតាមទៅ ។ កាលទ្រង់ប្រញាប់តាមទៅដោយរហ័ស ពលនិកាយក៏នៅខាងក្រោយ

ព្រះរាជាទ្រង់ដាច់ឆ្ងាយអំពីពលនិកាយមួយអន្លើឯងប៉ុណ្ណោះ ។ លំដាប់នោះ ពួកបុរសរបស់ព្រះបាទចណ្ឌប្បជ្ជោត ដែលបង្កប់ខ្លួនសងខាងផ្លូវ ក៏ចាប់ព្រះបាទឧទេនថ្វាយស្តេចផែនដីរបស់ខ្លួន ។ លុះពលនិកាយរបស់ទ្រង់បានដឹងថា ព្រះរាជារបស់ខ្លួនធ្លាក់ក្នុងអំណាចរបស់សត្រូវហើយ ក៏បោះបន្ទាយរង់ចាំនៅខាងក្រៅនគរ ។

ចំណែកព្រះបាទចណ្ឌប្បជ្ជោត ទ្រង់បញ្ជាឲ្យចាប់ព្រះបាទឧទេនបានទាំងរស់ហើយ ឃុំទុកក្នុងគុកសម្រាប់ដាក់ចោរមួយកន្លែង ឲ្យបិទទ្វារ ទ្រង់សោយទឹកជ័យបានអស់បីថ្ងៃ ។ ក្នុងថ្ងៃទី ៣ ព្រះបាទឧទេនសួរអ្នកយាមថា នែបា ព្រះរាជារបស់ពួកអ្នក នៅឯណា ។

ពួកអ្នកយាមទូលថា ព្រះរាជាទ្រង់សោយទឹកជ័យបាន (ទ្រង់ត្រេកអរថា) យើងចាប់បច្ចាមិត្តបានហើយ ។

ព្រះបាទឧទេនត្រាស់ថា ព្រះរាជារបស់ពួកអ្នក មានកិរិយាដូចមនុស្សស្រី កាលចាប់ព្រះរាជាដែលជាសត្រូវបានហើយ បើមិនដោះលែង ក៏គួរតែសម្លាប់ មិនមែនឬ តែនេះបែរជាយកយើងមកឲ្យរងទុក្ខហើយទៅអង្គុយផឹកទឹកជ័យបាន ។ អ្នកយាមទាំងនោះ ក៏នាំគ្នាក្រាបទូលសេចក្តីនោះ ដល់ព្រះរាជា ។

ព្រះបាទចណ្ឌប្បជ្ជោតយាងទៅ ត្រាស់សួរថា បានឮថា ទ្រង់ពោលយ៉ាងនេះមែនឬ ។ ព្រះបាទឧទេនពោលថា មែនហើយ មហារាជ ។

ព្រះបាទចណ្ឌប្បជ្ជោតពោលថា សាធុ ខ្ញុំនឹងដោះលែងទ្រង់ តែបានឮថា ទ្រង់មានមន្តបែបនេះ ដូច្នេះ សូមទ្រង់ឲ្យមន្តនោះដល់ខ្ញុំ ។ ព្រះបាទឧទេនពោលថា ប្រពៃហើយ ខ្ញុំនឹងថ្វាយ តែក្នុងពេលរៀន ត្រូវថ្វាយបង្គំខ្ញុំ ហើយរៀនមន្តនោះ តើទ្រង់ថ្វាយបង្គំខ្ញុំដែរឬទេ ។

ព្រះបាទចណ្ឌប្បជ្ជោតពោលថា ខ្ញុំថ្វាយបង្គំទ្រង់ឬ ខ្ញុំមិនថ្វាយបង្គំទេ ។ ព្រះបាទឧទេនពោលថា បើទ្រង់មិនថ្វាយបង្គំ ខ្ញុំមិនឲ្យទេ ។

ព្រះបាទចណ្ឌប្បជ្ជោតពោលថា ខ្ញុំមិនថ្វាយបង្គំឡើយ ។ ព្រះបាទឧទេនពោលថា បើដូច្នោះ ខ្ញុំមិនឲ្យ ។

ព្រះបាទចណ្ឌប្បជ្ជោតពោលថា បើដូច្នោះ ខ្ញុំនឹងដាក់រាជអាជ្ញាដល់ទ្រង់ ។ ព្រះបាទឧទេនពោលថា សូមធ្វើចុះ ទ្រង់ជាឥស្សរៈលើរាងកាយរបស់ខ្ញុំ តែមិនជាឥស្សរៈលើចិត្តខ្ញុំឡើយ ។

ព្រះរាជា ទ្រង់ស្តាប់ពាក្យដ៏អង់អាចរបស់ព្រះបាទឧទេនហើយ ទ្រង់ព្រះតម្រិះថា អញនឹងរៀនមន្តរបស់ស្តេចឧទេននេះ បានដូចម្តេចហ្ន៎ ទ្រង់គិតឃើញថា អញមិនអាចឲ្យអ្នកដទៃចេះមន្តនេះទេ អញនឹងឲ្យធីតារបស់អញរៀនក្នុងសម្នាក់ព្រះបាទឧទេននេះ ហើយសឹមរៀនបន្តក្នុងសម្នាក់របស់នាង ។ លំដាប់នោះ ព្រះបាទចណ្ឌប្បជ្ជោតត្រាស់សួរព្រះបាទឧទេនថា តើទ្រង់ឲ្យដល់បុគ្គលដទៃ ដែលថ្វាយបង្គំហើយរៀនដែរឬទេ ។

ព្រះបាទឧទេនត្រាស់ថា បើដូច្នោះ បាន មហារាជ ។ ព្រះបាទចណ្ឌប្បជ្ជោតពោលថា បើដូច្នោះ ក្នុងវាំងរបស់ខ្ញុំមានស្រីគមម្នាក់ ទ្រង់ឈរខាងក្រៅវាំងនន ចូរប្រាប់មន្តដល់ស្រីនោះ ដែលថ្វាយបង្គំហើយអង្គុយខាងក្នុងវាំងននចុះ ។

ព្រះបាទឧទេនពោលថា ប្រពៃហើយ មហារាជ ទោះនាងជាស្រីគមក្តី ខ្វិនក្តី កាលនាងថ្វាយបង្គំ ខ្ញុំនឹងឲ្យ ។ លំដាប់នោះ ព្រះរាជាក៏យាងទៅត្រាស់ប្រាប់ព្រះនាងវាសុលទត្តាជាព្រះរាជធីតាថា នែកូនស្រី បុរសកើតរោគឃ្លង់ល្ពៅម្នាក់ ចេះមន្តមានតម្លៃកាត់ថ្លៃមិនបាន បិតាមិនអាចឲ្យអ្នកដទៃចេះមន្តនោះបានទេ ចូរនាងអង្គុយខាងក្នុងវាំងននថ្វាយបង្គំបុរសនោះ ហើយរៀនមន្តអំពីបុរសនោះ បុរសនោះឈរខាងក្រៅវាំងនននឹងប្រាប់ដល់នាង បិតានឹងរៀនអំពីសម្នាក់របស់នាង ។

ព្រះបាទចណ្ឌប្បជ្ជោតនោះ ត្រាស់ធ្វើព្រះរាជធីតាឲ្យជាស្រីគមធ្វើព្រះបាទឧទេនឲ្យជាបុរសឃ្លង់ល្ពៅយ៉ាងនេះ ព្រោះទ្រង់ខ្លាចជនទាំងពីរនោះប្រព្រឹត្តខុស ។ ព្រះបាទឧទេននោះ ប្រថាប់ឈរខាងក្រៅវាំងនន ហើយបានប្រាប់មន្តដល់ព្រះនាង ដែលថ្វាយបង្គំហើយ អង្គុយខាងក្នុងវាំងនន ។

សម័យតមក សូម្បីទ្រង់ត្រាស់ប្រាប់រឿយៗ ក៏ព្រះនាងមិនអាចពោលបទនៃមន្តបាន ទើបព្រះបាទឧទេនត្រាស់ថា រ៉ឺយស្រីគមចង្រៃ

បបូរមាត់របស់នាងក្រាស់ម្ល៉េះ នាងចូរថាយ៉ាងនេះ ។ ព្រះនាងពិរោធ ទើបពោលថា រ៉ឺយអាឃ្លង់ ឯងនិយាយអ្វី មនុស្សដូចអញនេះឬ ជាស្រីគម ហើយព្រះនាងបើកជាយវាំងននឡើង ។

កាលព្រះបាទឧទេនសួរថា នាងជានរណា ទើបប្រាប់ថា យើងឈ្មោះវាសុលទត្តា ជាធីតារបស់ព្រះរាជា ។ ព្រះបាទឧទេនពោលថា បិតារបស់នាងប្រាប់យើងថា នាងជាស្រីគម ។

នាងវាសុលទត្តាពោលថា កាលត្រាស់ប្រាប់ដល់ខ្ញុំ ព្រះបិតាក៏ពោលថា អ្នកជាមនុស្សឃ្លង់ ។ ជនទាំងពីរនោះត្រិះរិះថា ពាក្យនោះព្រះរាជាត្រាស់ដោយខ្លាចក្រែងយើងធ្វើសន្ថវៈ ជនទាំងពីរ ក៏សេពសន្ថវៈក្នុងវាំងនននោះឯង ។

ចាប់តាំងអំពីនោះ ទើបការរៀនមន្ត ឬការរៀនសិល្បវិជ្ជា មិនមាន ។ ព្រះរាជាទ្រង់សួរព្រះរាជធីតាជានិច្ចថា នាងរៀនសិល្បវិជ្ជាឬ ។ ព្រះនាងក្រាបទូលថា បពិត្រព្រះបិតា ខ្ញុំម្ចាស់នៅរៀន ។

បន្ទាប់មក ថ្ងៃមួយ ព្រះបាទឧទេនត្រាស់នឹងព្រះនាងថា នែនាងដ៏ចម្រើន ឈ្មោះថា កិច្ចដែលស្វាមីគប្បីធ្វើបាន តែមាតាបិតា បងប្អូនប្រុសនិងបងប្អូនស្រី មិនអាចធ្វើបានឡើយ បើនាងឲ្យជីវិតដល់យើង យើងនឹងឲ្យស្រី ៥០០ ជាបរិវារ ហើយឲ្យតំណែងអគ្គមហេសីដល់នាង ។

ព្រះនាងពោលថា បើទ្រង់អាចតាំងនៅក្នុងព្រះតម្រាស់នេះ ខ្ញុំ

ម្ចាស់នឹងថ្វាយជីវិតដល់ទ្រង់ ។

ព្រះបាទឧទេនត្រាស់ថា ម្នាលនាងដ៏ចម្រើន យើងអាច ។ ព្រះនាងទទួលព្រះតម្រាស់ថា ប្រពៃហើយព្រះស្វាមី ហើយយាងទៅកាន់សម្នាក់ព្រះបិតា ថ្វាយបង្គំហើយ បានឈរក្នុងចំណែកម្ខាង ។

លំដាប់នោះ ព្រះរាជាត្រាស់សួរថា ម្នាលបុត្រី សិប្បៈសម្រេចហើយឬ ។ ព្រះនាងវាសុលទត្តាក្រាបទូលថា បពិត្រព្រះបិតា សិប្បៈមិនទាន់សម្រេចទេ ។

លំដាប់នោះ ព្រះបាទចណ្ឌប្បជ្ជោតត្រាស់សួរព្រះនាងថា នែបុត្រី ព្រោះហេតុអ្វី ទើបមិនសម្រេច ។ ព្រះនាងក្រាបទូលថា បពិត្រព្រះបិតា ខ្ញុំម្ចាស់គួរបានទ្វារមួយ និងពាហនៈមួយ ។

ព្រះបាទចណ្ឌប្បជ្ជោតសួរថា នែកូន ហេតុអ្វី ក៏ដូច្នេះទៅវិញ ។ ព្រះនាងវាសុលទត្តាក្រាបទូលថា បពិត្រព្រះបិតា បានឮថា មានឱសថមួយប្រភេទត្រូវយកក្នុងពេលយប់ ដោយសញ្ញាផ្កាយ ដើម្បីប្រយោជន៍ជាឧបចារៈនៃមន្ត ព្រោះហេតុនោះ ក្នុងកាលដែលខ្ញុំម្ចាស់ចេញទៅ ក្នុងកាល ឬមិនមែនកាល ទើបគួរបានទ្វារមួយនិងពាហនៈមួយ ។

ព្រះរាជាទ្រង់ទទួលថា សាធុ ។

ព្រះបាទឧទេននិងព្រះនាងវាសុលទត្តានោះ បានទ្វារមួយដែលខ្លួនពេញចិត្តក្នុងកណ្តាប់ដៃហើយ ។ ព្រះរាជាមានពាហនៈ ៥ គឺដំរី

ញីឈ្មោះភទ្ទវតី ដើរមួយថ្ងៃបានចម្ងាយ ៥០ យោជន៍ ទាសៈឈ្មោះកាកៈដើរមួយថ្ងៃបាន ៦០ យោជន៍ សេះពីរ គឺសេះឈ្មោះចេលកណ្ឋិ និងសេះឈ្មោះមុញ្ចកេសី ទៅមួយថ្ងៃបាន ១០០ យោជន៍ និងដំរីនាឡាគិរី ទៅមួយថ្ងៃបាន ១២០ យោជន៍ ។

បានឮមកថា ព្រះរាជាអង្គនោះ ក្នុងកាលព្រះពុទ្ធមិនទាន់កើតឡើង ជាអ្នកបម្រើរបស់ឥស្សរជនម្នាក់ ។ ក្នុងសម័យថ្ងៃមួយ កាលឥស្សរជននោះ ទៅក្រៅនគរ ផ្ងូតទឹកហើយមក ព្រះបច្ចេកពុទ្ធមួយអង្គ ចូលកាន់នគរដើម្បីបិណ្ឌបាត មិនបានភិក្ខាសូម្បីមួយវែក ព្រោះអ្នកក្រុងទាំងមូលត្រូវមារបណ្ដាលចិត្ត មានបាត្រដែលលាងហើយ គឺបាតទទេនិមន្តចេញទៅ ។ លំដាប់នោះ មារចូលទៅរកព្រះបច្ចេកពុទ្ធនោះ ដោយភេទដែលមិនមានអ្នកណាស្គាល់ ហើយសួរក្នុងខណៈដែលលោកនិមន្តដល់ទ្វារនគរថា បពិត្រលោកម្ចាស់ លោកម្ចាស់បានអ្វីខ្លះឬ ។

ព្រះបច្ចេកពុទ្ធសួរថា អ្នកជាបុគ្គលធ្វើឲ្យអាត្មាមិនបានអ្វីសោះឬ ។ មារពោលថា បើដូច្នោះ សូមលោកម្ចាស់ត្រឡប់ទៅវិញ ឥឡូវនេះ ខ្ញុំនឹងមិនធ្វើ ( ដូចមុនទៀត ) ។

ព្រះបច្ចេកពុទ្ធពោលថា អាត្មាមិនត្រឡប់ឡើយ បើព្រះបច្ចេកពុទ្ធគប្បីត្រឡប់សោត មារនោះ គប្បីចូលសណ្ឋិតក្នុងសរីរៈរបស់អ្នកនគរទាំងមូល ហើយទះដៃ ធ្វើការសើចចំអកទៀត កាលព្រះបច្ចេកពុទ្ធមិន

ត្រឡប់ មារក៏អន្តរធានទៅ ក្នុងទីនោះឯង ។ ខណៈនោះ ឥស្សរជន នោះ ឃើញព្រះបច្ចេកពុទ្ធនិមន្តមកដោយបាត្រដែលលាងហើយ ទើប ថ្វាយបង្គំ ហើយសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់បានអ្វីខ្លះឬ ។

ព្រះបច្ចេកពុទ្ធត្រាស់ថា អ្នកមានអាយុ អាត្មាចូលទៅ ចេញមក វិញហើយ ។ បុរសនោះ គិតថា លោកម្ចាស់មិនឆ្លើយពាក្យដែលអញ សួរ បែរជាពោលពាក្យដទៃ គង់មិនបានអ្វីឡើយ ។ ក្នុងរំពេចនោះ គាត់ក្រឡេកមើលបាត្ររបស់លោក ឃើញបាត្រទទេ ក៏ជាអ្នកក្លៀវក្លា តែមិនអាចទទួលបាត្រ ព្រោះមិនដឹងថា ភត្តក្នុងផ្ទះរបស់ខ្លួនសម្រេច ហើយ ឬមិនទាន់សម្រេច ទើបពោលថា បពិត្រលោកម្ចាស់ សូមលោក ម្ចាស់បង្អង់បន្តិចសិន ដូច្នេះហើយ ក៏ទៅកាន់ផ្ទះដោយរហ័ស សួរថា ភត្តសម្រាប់ខ្ញុំ សម្រេចហើយឬ ។

អ្នកបម្រើឆ្លើយថា ស្រេចហើយ ។ បុរសនោះពោលថា នែបា អ្នកដទៃដែលសម្បូរដោយសន្ទុះដើររហ័សជាងអ្នក មិនមាន អ្នកចូរទៅ កាលចួបលោកម្ចាស់អង្គនោះហើយ គប្បីពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យបាត្រមកចុះ ហើយទទួលបាត្រមកដោយរហ័ស ។ បុរសនោះ រត់ទៅដោយពាក្យប្រើត្រឹមតែមួយម៉ាត់ប៉ុណ្ណោះ ទទួលបាត្រ នាំមកហើយ ឥស្សរជននោះ ធ្វើបាត្រឲ្យពេញដោយភោជនរបស់ខ្លួន ហើយពោលថា ឯងចូរប្រញាប់ទៅ ប្រគេនបាត្រនេះ ដល់លោកម្ចាស់ ខ្ញុំ

នឹងឲ្យចំណែកបុណ្យដែលសម្រេចអំពីទាននេះដល់ឯង ។ បុរសនោះទទួលបាត្រ ហើយរត់ទៅដោយកម្លាំងដើងដ៏រហ័ស ប្រគេនបាត្រដល់ព្រះបច្ចេកពុទ្ធ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយពោលថា បពិត្រលោកម្ចាស់ កាលជិតហួសហើយ ខ្ញុំទៅនិងមកដោយសន្ទុះដើងដ៏រហ័សក្រៃលែង ដោយផលនៃសន្ទុះរបស់ខ្ញុំនេះ សូមពាហនៈទាំងឡាយ ៥ ដែលអាចទៅបាន មួយថ្ងៃ ៥០ យោជន៍ ៦០ យោជន៍ ១០០ យោជន៍ ១២០ យោជន៍ កើតឡើងដល់ខ្ញុំ ម្យ៉ាងទៀត សរីរៈរបស់ខ្ញុំមកនិងទៅត្រូវកម្តៅព្រះអាទិត្យជុតពេលហើយ ដោយផលនៃរាងកាយត្រូវកម្តៅព្រះអាទិត្យនោះ សូមអាជ្ញារបស់ខ្ញុំផ្សាយទៅដូចពន្លឺនៃព្រះអាទិត្យ ក្នុងទីដែលខ្ញុំកើតហើយ ៗ រីឯចំណែកបុណ្យក្នុងបិណ្ឌបាតនេះ ដែលចៅហ្វាយឲ្យហើយដល់ខ្ញុំ ដោយអានិសង្សនៃបុណ្យនោះ សូមឲ្យខ្ញុំជាអ្នកមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយ ។

ព្រះបច្ចេកពុទ្ធត្រាស់ថា **ឯវំ ហោតុ** សេចក្តីប្រាថ្នាដែលអ្នកតម្កល់ទុកនេះ ចូរសម្រេចចុះ ហើយបានធ្វើអនុមោទនាថា

**ឥច្ឆិតំ បត្ថិតំ តុយ្ហំ ខិប្បមេវ សមិជ្ឈតុ**
**សព្វេ បូរេន្តុ សង្កប្បា ចន្ទោ បន្នរសោ យថា ។**

សូមឥដ្ឋផល គឺផលជាទីគាប់ចិត្ត ដែលអ្នកប្រាថ្នាហើយ
តាំងចិត្តហើយ ចូរសម្រេចដល់អ្នក ឲ្យបានឆាប់រួសរាន់

*ទាន់ចិត្ត សូមតម្រិះត្រូវទាំងពួងចូរពេញដល់អ្នក ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត ។*

**ឥច្ឆិតំ បត្ថិតំ តុយ្ហំ ខិប្បមេវ សមិជ្ឈតុ**
**សព្វេ បូរេន្តុ សង្កប្បា មណិជោតិរសោ យថា ។**

*សូមឥដ្ឋផល គឺផលជាទីគាប់ចិត្ត ដែលអ្នកប្រាថ្នាហើយតាំងចិត្តហើយ ចូរសម្រេចដល់អ្នក ឲ្យបានឆាប់រួសរាន់ទាន់ចិត្ត សូមតម្រិះត្រូវទាំងពួង ចូរពេញដល់អ្នក ដូចកែវមណី មានរស្មីដ៏រុងរឿង ជាកែវវិសេស អាចញុំាងសេចក្តីប្រាថ្នាទាំងពួង ឲ្យសម្រេចបាន ។*

*បានឮថា គាថាពីរនេះឯង ឈ្មោះថា គាថាអនុមោទនារបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ។ រតនៈ គឺកែវមណីដែលឲ្យបំណងប្រាថ្នាទាំងពួង សម្រេច ហៅថា មណិជោតិរស ក្នុងគាថានេះ ។ នេះជាបុព្វចរិយារបស់អ្នកបម្រើនោះ ។ អ្នកបម្រើនោះ បានមកជាព្រះបាទចណ្ឌប្បជ្ជោតក្នុងកាលឥឡូវនេះ និងដោយផលដែលហូរចេញអំពីកម្មនោះ ទើបពាហនៈទាំង ៥ នេះ កើតឡើង ។*

*ថ្ងៃមួយ ព្រះរាជាយាងចេញដើម្បីក្រសាលក្នុងព្រះរាជឧទ្យាន ។ ព្រះបាទឧទេនទ្រង់ព្រះតម្រិះថា អញគួរគេចទៅក្នុងថ្ងៃនេះ ទើបទ្រង់ដាក់ថង់ស្បែកធំ ៗ ឲ្យពេញដោយមាសប្រាក់លើខ្នងដំរីញី ហើយនាំ*

ព្រះនាងវាសុលទត្តា គៀសខ្លួនទៅ ។ ទាហានរក្សាវាំងទាំងឡាយឃើញព្រះបាទឧទេនកំពុងគេចទៅ ទើបក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់បញ្ជូនពលទៅ ដោយព្រះតម្រាស់ថា ចូរដេញតាមឲ្យរហ័ស ។ ព្រះបាទឧទេនទ្រង់ជ្រាបថា ពលនិកាយដេញតាម ទើបទ្រង់ស្រាយថង់កហាបណៈ ធ្វើកហាបណៈឲ្យធ្លាក់ចុះ ។ ពួកមនុស្សរើសកហាបណៈហើយដេញតាមទៀត ។ ព្រះបាទឧទេនទ្រង់ស្រាយថង់មាស ហើយធ្វើឲ្យធ្លាក់ចុះ ពួកមនុស្សទាំងនោះ រវល់តែយឺតយូរព្រោះចង់បានមាស ទ្រង់ក៏យាងដល់បន្ទាយរបស់ព្រះអង្គ ដែលតាំងនៅខាងក្រៅនគរ ។ ខណៈនោះ ពលនិកាយគ្រាន់តែឃើញទ្រង់យាងមក ក៏ចោមរោមដង្ហែចូលកាន់ព្រះនគរ ។ ព្រះរាជា កាលយាងទៅដល់ហើយ ក៏អភិសេកព្រះនាងវាសុលទត្តាតាំងទុកក្នុងតំណែងអគ្គមហេសី ។

ស្រីម្នាក់ទៀត ឈ្មោះមាគណ្ឌិយា ក៏បានតំណែងជាអគ្គមហេសីរបស់ព្រះរាជាដែរ ។ បានឮថា នាងជាកូនស្រីរបស់ព្រាហ្មណ៍ឈ្មោះមាគណ្ឌិយៈ ក្នុងដែនកុរុ ។ មាតារបស់នាង ក៏ឈ្មោះមាគណ្ឌិយាដូចគ្នា ។ សូម្បីឪពុកមារបស់នាង ក៏ឈ្មោះមាគណ្ឌិយៈដែរ ។ នាងជាស្រីមានរូបស្អាតប្រៀបដូចទេពអប្សរ ។ ឪពុករបស់នាង កាលមិនបានប្ដីដែលសមគួរដល់នាង សូម្បីត្រូវត្រកូលធំ ៗ អង្វរ ក៏និយាយទ្រគោះបោះបោកថា ពួកអ្នកមិនសមនឹងកូនស្រីរបស់ខ្ញុំ ហើយដេញចេញ

ទៅ ។ សម័យថ្ងៃមួយ ព្រះសាស្តាទ្រង់ប្រមើលមើលសត្វលោកក្នុងពេលទៀបភ្លឺ ទ្រង់ឃើញឧបនិស្ស័យនៃអនាគាមិផល របស់មាគណ្ឌិយ-ព្រាហ្មណ៍ មួយអន្លើដោយបជាបតី គឺប្រពន្ធរបស់គាត់ ទ្រង់កាន់បាត្រនិងចីវរ ហើយបានយាងទៅកាន់ទីបម្រើភ្លើងរបស់ព្រាហ្មណ៍នោះ ខាងក្រៅនិគម ។ ព្រាហ្មណ៍នោះ ក្រឡេកឃើញអត្តភាពដែលលម្អដោយសិរីនៃព្រះរូបរបស់ព្រះតថាគតហើយ ក៏គិតថា បុរសដទៃ ស្មើបុរសនេះរមែងមិនមានក្នុងលោកនេះ បុរសនេះ សមគួរដល់ធីតារបស់អញ អញនឹងឲ្យធីតារបស់អញដល់បុរសនេះ ដើម្បីប្រយោជន៍ឲ្យបុរសនេះចិញ្ចឹមដូច្នេះហើយ ទើបពោលថា បពិត្រសមណៈ ខ្ញុំមានកូនស្រីម្នាក់ ខ្ញុំមិនទាន់ឃើញបុរសដែលសមនឹងនាង អស់កាលមានប្រមាណប៉ុណ្ណោះ លោកជាបុគ្គលសមនឹងនាង ហើយនាងក៏ជាបុគ្គលសមនឹងលោកពិត លោកគួរបាននាងទុកជាបាទបរិចារិកា នាងក៏គួរបានលោកទុកជាកស្តា ខ្ញុំនឹងឲ្យនាងដល់លោក ចូរលោកឈរក្នុងទីនេះឯង ទម្រាំខ្ញុំទៅហើយត្រឡប់មក ។

ព្រះសាស្តាទ្រង់មិនត្រាស់ពាក្យណាមួយ ទ្រង់ព្រះតុណ្ហីភាព ។ ព្រាហ្មណ៍ទៅកាន់ផ្ទះដោយរហ័ស ពោលនឹងព្រាហ្មណីថា នៃនាងដ៏ចម្រើន ខ្ញុំឃើញបុរសដែលសមនឹងកូនស្រីរបស់យើងហើយ ចូរនាងតាក់តែងខ្លួនកូនឲ្យរហ័ស ឲ្យតែងខ្លួនធីតាហើយ នាំទៅមួយអន្លើដោយ

ព្រាហ្មណី បានទៅកាន់សម្នាក់របស់ព្រះសាស្តា ។ ពួកអ្នកនគរភ្ញាក់ផ្អើលថា ព្រាហ្មណ៍នេះ មិនឲ្យកូនស្រីដល់បុគ្គលណាមួយ ដោយអាងថា មិនមានបុរសដែលសមនឹងកូនស្រីរបស់ខ្លួន អស់កាលមានប្រមាណប៉ុណ្ណោះ ។ បានឮថា ថ្ងៃនេះ គាត់ឃើញបុរសសមនឹងកូនស្រីរបស់គាត់ហើយ បុរសនោះ ជាអ្នកណាហ្ន៎ ពួកយើងនឹងទៅមើលបុរសនោះ ទើបមហាជនចេញទៅជាមួយព្រាហ្មណ៍នោះឯង ។

កាលព្រាហ្មណ៍នាំធីតាមក ព្រះសាស្តាមិនបានប្រថាប់ឈរក្នុងទីដែលព្រាហ្មណ៍នោះពោលទុក ទ្រង់បង្ហាញចេតិយ គឺស្នាមព្រះបាទទុកក្នុងទីនោះហើយ យាងទៅប្រថាប់ឈរក្នុងទីដទៃ ។ មែនពិត ចេតិយគឺស្នាមព្រះបាទរបស់ព្រះពុទ្ធទាំងឡាយ រមែងប្រាកដក្នុងទីដែលទ្រង់អធិដ្ឋានហើយជាន់ទុកប៉ុណ្ណោះ រមែងមិនប្រាកដក្នុងទីដទៃ ម្យ៉ាងទៀត ចេតិយ គឺស្នាមព្រះបាទជាវត្ថុដែលទ្រង់អធិដ្ឋានទុក ដើម្បីបំណាងដល់បុគ្គលណា បុគ្គលពួកនោះប៉ុណ្ណោះ រមែងឃើញចេតិយគឺស្នាមព្រះបាទនោះ ។ ឯសត្វទាំងឡាយ មានដំរីជាដើម ដើរជាន់ក្តី មហាមេឃគឺភ្លៀងធំបង្អុរចុះមកក្តី ខ្យល់កំបុតត្បូងបក់បោកក្តី ដើម្បីមិនឲ្យបុគ្គលទាំងនោះឃើញ បុគ្គលណាមួយក៏មិនអាចលុបចេតិយ គឺស្នាមព្រះបាទនោះបានឡើយ ។ លំដាប់នោះ ព្រាហ្មណីសួរព្រាហ្មណ៍នោះថា បុរសនោះនៅឯណា ។

ព្រាហ្មណ៍គិតថា ខ្ញុំនិយាយនឹងគាត់ថា លោកចូរឈរក្នុងទីនេះ គាត់ទៅក្នុងទីណាហ្ន៎ ក្រឡេកមើល ក៏ឃើញចេតិយ គឺស្នាមព្រះបាទ ទើបពោលថា នេះជាស្នាមជើងរបស់បុរសនោះ ។ ព្រាហ្មណីសូធ្យលក្ខណមន្ត ហើយពិនិត្យមើលលក្ខណៈនៃស្នាមព្រះបាទ ព្រោះភាពជាអ្នកជំនាញក្នុងវេទទាំង ៣ ព្រមទាំងមន្តសម្រាប់ទាយលក្ខណៈ ពោលថា បពិត្រព្រាហ្មណ៍ នេះមិនមែនស្នាមជើងអ្នកសេពកាមគុណ ៥ ទេ ហើយពោលគាថាថា

**រត្តស្ស ហិ ឧក្កុដិកំ[1] បទំ ភវេ**
**ទុដ្ឋស្ស ហោតិ សហសានុបីឡិតំ**
**មូឡ្ហស្ស ហោតិ អវកាឌ្ឍិតំ បទំ**
**វិវដ្ដច្ឆទស្ស ឥទមីទិសំ បទំ ។**

បុគ្គលជារាគចរិត មានស្នាមជើងកំពុងកណ្ដាល បុគ្គល
ជាទោសចរិត មានស្នាមជើងធ្ងន់មុខ ចុចចុងម្រាម
បុគ្គលជាមោហចរិត មានស្នាមជើងធ្ងន់កែង បុគ្គល

---

១-ឧក្កុដិកសព្ទនេះ បើបាតជើង ក៏គួរប្រែថា ផត ឬខ្វង់ត្រង់កណ្ដាល ធម្មតាបុគ្គលដែលមានបាតជើងផតឬខ្វង់ បើជាន់ដីទន់ ស្នាមជើង រមែងកំពុងឡើង បើជាន់ដីរឹង ក៏បាត់ទៅត្រង់កណ្ដាល ទើបក្នុងទីនេះ យើងប្រែថា មានស្នាមជើងកំពុងឡើង ។ បណ្ឌិតគប្បីកាន់យកតាមការគួរ ។

ដែលមានកិលេសជាគ្រឿងប្រក់បើកហើយ មានស្នាម
ដើងប្រាកដយ៉ាងនេះ ។

លំដាប់នោះ ព្រាហ្មណ៍ពោលថា នៃនាងដ៏ចម្រើន នាងជាអ្នកមានប្រក្រតីឃើញមន្តដូចឃើញក្រពើក្នុងពាងទឹក ដូចឃើញចោរនៅក្នុងកណ្តាលផ្ទះ ចូរស្ងៀមចុះ ។

នាងព្រាហ្មណីពោលថា បពិត្រព្រាហ្មណ៍ លោកចង់ពោលពាក្យណា សូមពោលពាក្យនោះចុះ តែថាស្នាមជើងបែបនេះ មិនមែនស្នាមជើងរបស់អ្នកសេពកាមគុណ ៥ ទេ ។

ព្រាហ្មណ៍ក្រឡេកមើលឆ្វេងស្តាំ ឃើញព្រះសាស្តាហើយពោលថា នេះ គឺបុរសនោះ ទើបចូលទៅពោលថា សមណៈ ខ្ញុំនឹងឲ្យធីតាដល់លោក ដើម្បីឲ្យលោកចិញ្ចឹម ។

ព្រះសាស្តាមិនត្រាស់ថា តថាគតត្រូវការធីតារបស់អ្នក ឬមិនត្រូវការ តែត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតពោលហេតុមួយដល់អ្នក ។

ព្រាហ្មណ៍ពោលថា ព្រះសមណៈ សូមពោលមកចុះ ។

ព្រះសាស្តាត្រាស់ប្រាប់ការដែលព្រះអង្គត្រូវមារជាប់តាម តាំងអំពីចេញបួសរហូតដល់គល់អជបាលនិគ្រោធ និងការដែលមារធីតាទាំងឡាយមកប្រលោម ដើម្បីរម្ងាប់សេចក្តីសោករបស់មារនោះ ដែលសោកសៅថា ឥឡូវនេះ ព្រះសមណគោតមនេះ កន្លងបង់នូវវិស័យរបស់អញហើយ ។

មារធីតានោះ និម្មិតភេទជាកុមារិកាជាដើម ត្រង់គល់អជបាលនិគ្រោធ ហើយ សូម្បីក្នុងកាលនោះ ឆន្ទរាគៈក៏មិនមានដល់តថាគតដែរ ដូច្នេះ ហើយ ទើបត្រាស់ព្រះគាថានេះថា

**ទិស្វាន តណ្ហំ អរតិញ្ច រាគំ**
**នាហោសិ ឆន្ទោ អបិ មេថុនស្មឹ**
**កិមេវិទំ មុត្តករីសបុណ្ណំ**
**បាទាបិ នំ សម្ផុសិតុំ ន ឥច្ឆេ ។**

*អើក៏សេចក្តីប្រាថ្នាក្នុងមេថុនមិនមាន ( ដល់តថាគត ) ព្រោះ ឃើញនាងតណ្ហា នាងអរតី និងនាងរាគា ( ដែលជាធីតានៃ មារ ) សោះទៅហើយ ធ្វើម្តេចឡើយ តថាគតនឹងមានសេចក្តី ប្រាថ្នាក្នុងមេថុន ព្រោះឃើញរូបរបស់ទារិកា ដែលពោរពេញ ដោយមូត្រនិងករីសៈនេះ តថាគតមិនគួរត្រូវការដើម្បីប៉ះពាល់ នូវធីតារបស់អ្នកនោះ សូម្បីតែដោយជើងឡើយ[១] ។*

ក្នុងទីបំផុតនៃគាថា ព្រាហ្មណ៍និងព្រាហ្មណីតាំងនៅក្នុងអនាគាមិផល ចំណែកនាងមាគណ្ឌិយាជាធីតាចងអាឃាតក្នុងព្រះសាស្តាថា បើ សមណៈនេះ មិនមានសេចក្តីត្រូវការអញទេ ក៏គួរពោលដល់ភាពដែល ខ្លួនមិនមានសេចក្តីត្រូវការ តែសមណៈនេះ បែរជាធ្វើអញឲ្យពេញដោយ

---

១-បិ.៥៤ ទំ.២៨២ ឃ.១០៣ ។

មូត្រនិងករីសៈទៅវិញ ហើយមិនប្រាថ្នាប៉ះ សូម្បីដោយជើង ណ្ហើយចុះ អញអាស្រ័យការដល់ព្រមដោយជាតិ ត្រកូល ប្រទេស ភោគៈ យស និងវ័យរបស់ខ្លួន បានកស្តាំបែបនោះហើយ អញនឹងដឹងកម្មដែលគួរធ្វើដល់ព្រះសមណគោតម ។

សួរថា តើព្រះសាស្តា ទ្រង់ជ្រាបការកើតឡើងនៃអាឃាតក្នុងព្រះអង្គរបស់នាង ឬមិនជ្រាប ។

ឆ្លើយថា ទ្រង់ជ្រាបនោះឯង ។

សួរថា កាលទ្រង់ជ្រាប ហេតុអ្វីទើបត្រាស់ព្រះគាថានេះ ។

ឆ្លើយថា ទ្រង់ត្រាស់គាថានេះ ដោយអនុគ្រោះជនទាំងពីរ គឺព្រាហ្មណ៍និងព្រាហ្មណី ពិតហើយ ព្រះពុទ្ធទាំងឡាយ ទ្រង់មិនអើពើដល់ការចងអាឃាត ទ្រង់សម្តែងធម៌ដោយអំណាចនៃបុគ្គលដែលគួរសម្រេចមគ្គផលប៉ុណ្ណោះ ។ មាតាបិតានាំនាងមាគណ្ឌិយានោះ ទៅផ្ញើនឹងនាយចូឡមាគណ្ឌិយៈដែលជាប្អូនប្រុស ហើយទៅកាន់សម្នាក់ព្រះសាស្តា ជនទាំងពីរបួសហើយ ក៏បានសម្រេចអរហត្ត ។ ចំណែកនាយចូឡមាគណ្ឌិយៈគិតថា កូនស្រីរបស់អញមិនគួរដល់សត្វថោកទាប គួរដល់ព្រះរាជាតែម្យ៉ាង ទើបនាំនាងទៅកាន់នគរកោសម្ពី តាក់តែងនាងដោយគ្រឿងអលង្ការទាំងពួង បានថ្វាយដល់ព្រះបាទឧទេនដោយពាក្យថា ឥត្ថីរតនៈនេះ សមគួរដល់ព្រះសម្មតិទេព ។ ព្រះបាទឧទេនគ្រាន់តែ

ទតឃើញ ក៏កើតស្នេហាដ៏ខ្លាំងក្លា ទើបធ្វើការអភិសេក ឲ្យនូវមាតុគ្រាម ៥០០ ជាបរិវាររបស់នាង តាំងទុកក្នុងតំណែងអគ្គមហេសីហើយ ។

ព្រះបាទឧទេននោះ មានអគ្គមហេសី ៣ មានស្រីស្នំ ១៥០០ ជាបរិវារ ដោយប្រការដូច្នេះ ។

ក្នុងសម័យនោះ ក្នុងក្រុងកោសម្ពី មានសេដ្ឋី ៣ នាក់ គឺ ឃោសកសេដ្ឋី ១ កុក្កុដសេដ្ឋី ១ បាវារិកសេដ្ឋី ១ ។ សេដ្ឋីទាំងនោះ កាលថ្ងៃចូលវស្សាជិតចូលមកដល់ហើយ ឃើញតាបស ៥០០ មកអំពីហិមវន្តប្បទេស កំពុងត្រាច់បិណ្ឌបាតក្នុងព្រះនគរ ក៏ជ្រះថ្លា ទើបនិមន្តឲ្យគង់ ឲ្យឆាន់ហើយ ទទួលបេ្ដជ្ញាឲ្យនៅក្នុងសម្នាក់របស់ខ្លួនអស់កាល ៤ ខែ ឲ្យបេ្ដជ្ញាដើម្បីត្រឡប់មកទៀត ក្នុងសម័យដែលជោកជាំដោយភ្លៀង ហើយបញ្ជូនទៅ ។ ចាប់តាំងអំពីនោះមក តាបសទាំងឡាយនៅក្នុងហិមវន្តប្បទេស អស់ ៨ ខែហើយ ទើបមកនៅក្នុងសម្នាក់របស់សេដ្ឋីទាំងនោះ អស់កាល ៤ ខែ ។ តាបសទាំងនោះ កាលមកអំពីហិមវន្តប្បទេសក្នុងកាលដទៃ ឃើញដើមជ្រៃធំមួយដើមក្នុងព្រៃ ទើបអង្គុយត្រង់គល់ជ្រៃនោះ ។ បណ្ដាតាបសទាំងនោះ តាបសដែលជាប្រធានគិតថា ទេវតាដែលអាស្រ័យដើមឈើនេះ នឹងមិនមែនជាទេវតាថោកថយឡើយ ទេវរាជសក្តិធំនោះឯង គប្បីនៅត្រង់ដើមជ្រៃនេះ ជាការល្អហ្ន៎ បើទេវតានេះ គប្បីឲ្យទឹកដែលគួរផឹកដល់ពួកឥសី ។ ទេវតា

នោះ បានប្រគេនទឹកផឹកហើយ ។ តាបសគិតដល់ទឹកផ្លូត ទេវតាក៏បានប្រគេនទឹកផ្លូតនោះ ។ បន្ទាប់អំពីនោះ តាបសដែលជាប្រធាន ក៏គិតដល់ភោជន ទេវតាក៏ប្រគេនភោជននោះ ។ លំដាប់នោះ តាបសក៏មានបរិវិតក្កៈថា ទេវរាជនេះ ឲ្យវត្ថុសព្វយ៉ាងដែលអញគិតហើយ ៗ អើហ្ន៎ អញគប្បីឃើញទេវរាជនេះ ។ ទេវរាជនោះ ជ្រែកដើមជ្រៃបង្ហាញខ្លួនហើយ ។ លំដាប់នោះ តាបសទាំងនោះ សួរទេវរាជនោះថា នែទេវរាជអ្នកមានសម្បត្តិច្រើន សម្បត្តិនេះ អ្នកបានហើយ ព្រោះធ្វើកម្មអ្វីហ្ន៎ ។ ទេវតាពោលថា សូមលោកម្ចាស់ទាំងឡាយ កុំសួរឡើយ ។

តាបសពោលថា នែទេវរាជ ចូរប្រាប់មកចុះ ។ ទេវរាជនោះខ្មាសអៀន ព្រោះកម្មដែលខ្លួនធ្វើទុក ជាកម្មតិចតួច ទើបមិនហ៊ានប្រាប់ តែកាលតាបសនោះ អង្វររឿយ ៗ ក៏ពោលថា បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយចាំស្តាប់ចុះ ដូច្នេះហើយ ទើបពោល ។

បានឮថា ទេវតានោះ ជាអ្នកក្រីក្រម្នាក់ ស្វែងរកការងារស៊ីឈ្នួល បានការងារក្នុងសម្នាក់អនាថបិណ្ឌិកសេដ្ឋី ហើយក៏អាស្រ័យការងារនោះចិញ្ចឹមជីវិត ។ សម័យតមក កាលដល់ថ្ងៃឧបោសថ អនាថបិណ្ឌិកសេដ្ឋីមកអំពីវិហារហើយ សួរថា ក្នុងថ្ងៃនេះ បុគ្គលណាបានប្រាប់ភាពជាថ្ងៃឧបោសថ ដល់បុរសស៊ីឈ្នួលនោះហើយឬ ។ មនុស្សក្នុងផ្ទះឆ្លើយថា បពិត្រលោកម្ចាស់ មិនបានប្រាប់ទេ ។

អនាថបិណ្ឌិកសេដ្ឋីពោលថា បើដូច្នោះ ពួកអ្នក ចូរចម្អិនអាហារល្ងាចសម្រាប់បុរសនោះផង ។ គ្រានោះ មនុស្សទាំងនោះ ក៏ចម្អិនបាយនៃអង្ករមួយកម្បង់ទុកដើម្បីបុរសនោះ ។ បុរសនោះ ធ្វើការងារក្នុងព្រៃពេញមួយថ្ងៃ មកក្នុងវេលាល្ងាច កាលគេដួសបាយឲ្យ ក៏មិនប្រញាប់បរិភោគ ដោយគិតថា អញជាអ្នកឃ្លានហើយ ក្នុងថ្ងៃទាំងឡាយដទៃកោលាហលធំ រមែងមានក្នុងផ្ទះនេះថា ចូរអ្នកឲ្យបាយ ចូរឲ្យសម្ល ចូរឲ្យសម្លគោក ក្នុងថ្ងៃនេះ មនុស្សគ្រប់គ្នាជាអ្នកស្ងប់ស្ងៀម ដេកហើយនាំគ្នាដួសអាហារទុកដើម្បីអញតែម្នាក់ប៉ុណ្ណោះ សេចក្ដីនេះ ដូចម្ដេចហ្ន៎ ទើបសួរថា មនុស្សដ៏សេសបរិភោគហើយ ឬមិនទាន់បរិភោគទេ ។

មនុស្សទាំងនោះឆ្លើយថា មិនបរិភោគទេ អ្នក ។ បុរសស៊ីឈ្នួលសួរថា ព្រោះហេតុអ្វីហ្ន៎ ។

មនុស្សទាំងនោះឆ្លើយថា ក្នុងផ្ទះនេះ គេមិនចម្អិនអាហារពេលល្ងាចក្នុងថ្ងៃឧបោសថឡើយ មនុស្សគ្រប់គ្នារមែងជាអ្នករក្សាឧបោសថ ។ ដោយហោចទៅ សូម្បីទារកដែលនៅបៅដោះ ក៏មហាសេដ្ឋីឲ្យខ្ពុរមាត់ ឲ្យដាក់របស់មានមធុរស ៤ យ៉ាងចូលក្នុងមាត់ ធ្វើឲ្យជាអ្នករក្សាឧបោសថហើយ ។ កាលប្រទីបដែលលាយដោយប្រេងក្រអូបកំពុងភ្លឺ កុមារតូចធំទាំងឡាយទៅកាន់ទីដេកហើយ រមែងស្វាធ្យាយអាការ ៣២ តែពួកយើងមិនបានធ្វើសតិទុក ដើម្បីប្រាប់ភាពដែលថ្ងៃនេះ ជាថ្ងៃឧបោសថ

ដល់អ្នក ព្រោះហេតុនោះ ទើបពួកយើងចម្អិនបាយទុកសម្រាប់អ្នកម្នាក់ឯង ចូរអ្នកបរិភោគអាហារនោះចុះ ។

បុរសស៊ីឈ្នួលពោលថា បើការដែលខ្ញុំជាអ្នករក្សាឧបោសថក្នុងកាលឥឡូវនេះ រមែងគួរសោត ខ្ញុំក៏គប្បីជាអ្នករក្សាដែរ ។ មនុស្សទាំងនោះ ពោលថា លោកសេដ្ឋីរមែងដឹងរឿងនេះ ។

បុរសនោះពោលថា បើដូច្នោះ សូមពួកអ្នកសួរលោកសេដ្ឋីនោះ ។ មនុស្សទាំងនោះ ទៅសួរសេដ្ឋីហើយ ។ សេដ្ឋីពោលយ៉ាងនេះថា បើបុរសនោះ មិនបរិភោគក្នុងកាលឥឡូវនេះ ខ្ពុរមាត់ ហើយអធិដ្ឋានអង្គឧបោសថទាំងឡាយ នឹងបានឧបោសថកម្មពាក់កណ្តាល ។ បុរសស៊ីឈ្នួលស្តាប់ពាក្យនោះ បានធ្វើតាមនោះហើយ ។

បុរសនោះស្រេកឃ្លានហើយ ព្រោះធ្វើការងារពេញមួយថ្ងៃ ខ្យល់កម្រើកហើយក្នុងសរីរៈរបស់គាត់ គាត់យកខ្សែចងពោះ ចាប់ត្រង់ចុងខ្សែហើយបម្រះននៀល សេដ្ឋីស្តាប់ព្រឹត្តិការណ៍នោះហើយ មានមនុស្សកាន់គប់ភ្លើង ហើយឲ្យមនុស្សកាន់យកមធុរស ៤ ប្រភេទ មកកាន់សម្នាក់បុរសនោះ សួរថា នែបា ឯងកើតអ្វី ។ បុរសនោះប្រាប់ថា បពិត្រលោកម្ចាស់ ខ្យល់កម្រើកកើតដល់ខ្ញុំ ។

សេដ្ឋីពោលថា បើដូច្នោះ ចូរក្រោកឡើងទំពាស៊ីភេសជ្ជៈនេះ ។ បុរសនោះសួរថា បពិត្រលោកម្ចាស់ សូម្បីអ្នកទាំងឡាយ ក៏ទទួលទាន

ដែរឬ ។

សេដ្ឋីពោលថា ជំងឺរបស់ពួកយើងមិនមានទេ អ្នកទំពាស៊ីចុះ ។ បុរសនោះពោលថា បពិត្រលោកម្ចាស់ ខ្ញុំកាលធ្វើឧបោសថកម្ម មិនអាចធ្វើឧបោសថកម្មទាំងមូលបាន សូម្បីក្នុងឧបោសថកម្មពាក់កណ្តាលរបស់ខ្ញុំ កុំបីជារបស់ខ្វះខាតឡើយ ដូច្នេះហើយ ក៏មិនប្រាថ្នានឹងទំពាស៊ី ។

បុរសនោះ សូម្បីសេដ្ឋីពោលថា អ្នកកុំធ្វើយ៉ាងនេះ ក៏មិនប្រាថ្នាហើយ កាលអរុណរះ ធ្វើកាលកិរិយាហើយដូចផ្កាដែលស្រពោនដូច្នោះ កើតជាទេវតាត្រង់ដើមជ្រៃនោះ ព្រោះហេតុនោះ ទេវតានោះ កាលពោលសេចក្តីនេះហើយ ទើបពោលថា លោកសេដ្ឋីនោះ ជាអ្នករាប់អានព្រះពុទ្ធ រាប់អានព្រះធម៌ រាប់អានព្រះសង្ឃ សម្បត្តិនេះ ខ្ញុំបានហើយ ដោយអានិសង្សនៃឧបោសថកម្មពាក់កណ្តាល ដែលអាស្រ័យសេដ្ឋីនោះធ្វើហើយ ។

តាបស ៥០០ គ្រាន់តែស្តាប់ពាក្យថា **ពុទ្ធោ** ក៏ក្រោកឡើងផ្គងអញ្ជលីចំពោះទេវតា ពោលថា **ពុទ្ធោតិ វទេសិ ពុទ្ធោតិ វទេសិ** អ្នកពោលថា ព្រះពុទ្ធឬ អ្នកពោលថា ព្រះពុទ្ធឬ ហើយឲ្យទេវតានោះប្តេជ្ញាបីដងថា **ពុទ្ធោតិ វទាមិ ពុទ្ធោតិ វទាមិ** ខ្ញុំពោលថា ព្រះពុទ្ធ ខ្ញុំពោលថា ព្រះពុទ្ធ ។

តាបសបន្លឺឧទានថា ឃោសៈ ( សំឡេងប្រកាស ) នេះឯង រក

បានក្រក្នុងលោក ហើយពោលថា នៃទេវតា ពួកអាត្មាដែលអ្នកឲ្យស្តាប់សំឡេងដែលមិនធ្លាប់ស្តាប់ហើយ អស់សែនកប្បជាអនេក ។ លំដាប់នោះ ពួកតាបសដែលជាអន្តេវាសិកបានពោលទៅកាន់អាចារ្យថា បើដូច្នោះ ពួកយើងនឹងនាំគ្នាទៅកាន់សម្នាក់របស់ព្រះសាស្តា ។

អាចារ្យពោលថា នៃលោកទាំងឡាយ សេដ្ឋី ៣ នាក់ ជាអ្នកមានឧបការៈច្រើនដល់ពួកយើង ស្អែកនេះ ពួកយើងទទួលភិក្ខាក្នុងលំនៅរបស់សេដ្ឋីទាំងនោះ ប្រាប់ដល់សេដ្ឋីទាំងនោះហើយ សឹមទៅ ចូរពួកលោកឈប់បង្អង់សិន ។ តាបសទាំងនោះ ឈប់បង្អង់ហើយ ។ ស្អែកឡើង សេដ្ឋីទាំងនោះត្រៀមបបរនិងកត្ត ហើយក្រាលអាសនៈទុក ដឹងថាថ្ងៃនេះ ជាថ្ងៃមករបស់លោកម្ចាស់នៃយើងទាំងឡាយ ធ្វើការទទួលហើយ នាំតាបសទាំងនោះទៅកាន់លំនៅ និមន្តឲ្យគង់ បានប្រគេនភិក្ខាហើយ ។ តាបសទាំងនោះ ធ្វើភត្តកិច្ចស្រេចហើយ ពោលនឹងមហាសេដ្ឋីទាំងឡាយថា ពួកអាត្មានឹងទៅ ។

សេដ្ឋីទាំងឡាយពោលថា លោកម្ចាស់ទាំងឡាយទទួលបដិញ្ញារបស់ពួកយើងអស់ ៤ ខែ ក្នុងរដូវវស្សា មិនមែនឬ ឥឡូវនេះ លោកម្ចាស់ទាំងឡាយនឹងនិមន្តទៅណា ។ តាបសពោលថា បានឮថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ព្រះធម៌កើតឡើងហើយក្នុងលោក ព្រះសង្ឃកើតឡើងហើយក្នុងលោក ព្រោះហេតុនោះ ពួកអាត្មានឹងទៅកាន់សម្នាក់

របស់ព្រះសាស្តា ។

សេដ្ឋីពោលថា ការទៅក្នុងសម្នាក់ព្រះសាស្តាអង្គនោះ គួរដល់លោកម្ចាស់ទាំងឡាយប៉ុណ្ណោះឬ ។ តាបសឆ្លើយថា សូម្បីជនដទៃ ក៏គួរ មិនហាមឃាត់ឡើយ អាវុសោ ។

សេដ្ឋីពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយបង្អង់សិន ពួកខ្ញុំនឹងធ្វើការប្រុងប្រៀបហើយក៏ទៅ ។ តាបសទាំងនោះពោលថា បើអ្នកទាំងឡាយធ្វើការប្រុងប្រៀប ការយឺតយូររមែងមានដល់ពួកយើង ពួកយើងនឹងទៅមុន អ្នកទាំងឡាយគប្បីមកក្នុងកាលឯក្រោយ ដូច្នេះហើយ ក៏ទៅមុន គាល់ព្រះសម្មាសម្ពុទ្ធ ក្រាបថ្វាយបង្គំសរសើរហើយ អង្គុយក្នុងចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាទ្រង់ត្រាស់អនុបុព្វីកថា សម្តែងធម៌ដល់តាបសទាំងនោះ ។ ក្នុងទីបំផុតនៃទេសនា តាបសទាំងនោះ សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ហើយក្រាបបង្គំទូលសូមបព្វជ្ជា បានជាបុគ្គលទ្រទ្រង់នូវបាត្រនិងចីវរ សម្រេចដោយឫទ្ធិ ដូចព្រះថេរៈមានវស្សា ១០០ ក្នុងលំដាប់នៃព្រះតម្រាស់ថា **ឯថ ភិក្ខវោ** អ្នកទាំងឡាយ ចូរមកជាភិក្ខុចុះ ។

ចំណែកសេដ្ឋីទាំង ៣ នោះ រៀបចំរទេះម្នាក់ ៥០០ ផ្ទុកគ្រឿងឧបករណ៍ដើម្បីទាន មានគ្រឿងបរិភោគ សំពត់ គ្រឿងស្លៀកដណ្តប់

សប្បិ ទឹកឃ្មុំ និងស្ករអំពៅជាដើម ទៅដល់ក្រុងសាវត្ថី ចូលកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្តា ស្តាប់ធម្មកថាហើយ ក្នុងទីបំផុតនៃកថាក៏តាំងនៅក្នុងសោតាបត្តិផល ថ្វាយទានក្នុងសម្នាក់របស់ព្រះសាស្តាប្រមាណកន្លះខែហើយ អារាធនាព្រះសាស្តា ដើម្បីប្រយោជន៍យាងទៅកាន់នគរកោសម្ពី ។ កាលព្រះសាស្តាទ្រង់ប្រទានប្តេជ្ញាដោយត្រាស់ថា ម្នាលគហបតីទាំងឡាយ ព្រះតថាគតទាំងឡាយ រមែងត្រេកអរក្នុងផ្ទះស្ងាត់ ទើបសេដ្ឋីទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើនសេចក្តីនោះ ខ្ញុំព្រះអង្គទាំងឡាយដឹងហើយ ការដែលព្រះអង្គយាងទៅដោយដំណឹងដែលពួកខ្ញុំព្រះអង្គបញ្ជូនមក រមែងគួរ ដូច្នេះហើយ ទៅកាន់នគរកោសម្ពី ឲ្យសាងវិហារ ៣ គឺឃោសកសេដ្ឋី សាងឃោសិតារាម កុក្កុដសេដ្ឋី សាងកុក្កុដារាម បាវារិកសេដ្ឋី សាងបាវារិការាម ហើយបញ្ជូនដំណឹងទៅ ដើម្បីប្រយោជន៍ដល់ការយាងមករបស់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់ព្រះសណ្តាប់ដំណឹងរបស់សេដ្ឋីទាំងនោះ ក៏យាងទៅក្នុងទីនោះ ។ សេដ្ឋីទាំងនោះទទួល និងក្រាបបង្គំទូលសូមឲ្យព្រះសាស្តាទ្រង់យាងចូលទៅក្នុងវិហារ បដិបត្តិតាមវារៈ ។ (តាមវេនម្នាក់ម្តង) ។ ព្រះសាស្តាទ្រង់គង់នៅក្នុងវិហារនីមួយ ៗ រាល់ ៗ ថ្ងៃ គង់នៅក្នុងវិហាររបស់សេដ្ឋីណា ទ្រង់ក៏យាងទៅបិណ្ឌបាតត្រង់ទ្វារផ្ទះរបស់សេដ្ឋីនោះ ។

សេដ្ឋីទាំង ៣ នាក់នោះ មាននាយមាលាការឈ្មោះសុមនៈ ជា

អ្នកឧបដ្ឋាក ។ នាយសុមនមាលាការនោះ ពោលនឹងសេដ្ឋីទាំងនោះដូច្នេះថា ខ្ញុំជាឧបដ្ឋាករបស់លោកទាំងឡាយ អស់កាលដ៏យូរមកហើយ ខ្ញុំជាអ្នកប្រាថ្នាដើម្បីញុំាងឲ្យព្រះសាស្តាទ្រង់សោយ សូមលោកទាំងឡាយឲ្យព្រះសាស្តាដល់ខ្ញុំមួយថ្ងៃ ។ សេដ្ឋីទាំង ៣ នោះ ពោលថា បើដូច្នោះសូមអ្នកនិមន្តព្រះសាស្តាសោយ ក្នុងថ្ងៃស្អែកចុះ ។ នាយសុមនៈនោះទទួលថា ប្រពៃហើយលោកម្ចាស់ ដូច្នេះ ទើបនិមន្តព្រះសាស្តា ហើយចាត់ចែងគ្រឿងសក្ការៈ ។

ក្នុងកាលនោះ ព្រះរាជាប្រទានកហាបណៈ ៨ ឲ្យជាតម្លៃផ្កាដល់នាងសាមាវតីរាល់ៗ ថ្ងៃ ។ ទាសីរបស់នាងសាមាវតីនោះ ឈ្មោះនាងខុជ្ជុត្តរា ទៅកាន់សម្នាក់របស់នាយសុមនមាលាការ ទទួលផ្កាទាំងឡាយជានិច្ច ។ លំដាប់នោះ នាយសុមនមាលាការពោលទៅកាន់នាងខុជ្ជុត្តរានោះ ដែលមកក្នុងថ្ងៃនោះថា ខ្ញុំនិមន្តព្រះសាស្តាទុកហើយ ថ្ងៃនេះ ខ្ញុំនឹងបូជាព្រះសាស្តាដោយផ្កាទាំងឡាយ ចូរនាងបង្អង់ជួយក្នុងការអង្គាសភិក្ខុសង្ឃ ស្តាប់ធម៌សិន ហើយសឹមទទួលផ្កាដ៏សេសទៅ ។

នាងទទួលថា សាធុ ។ នាយសុមនៈនោះ អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ បានទទួលបាត្រ ដើម្បីប្រយោជន៍ដល់ការធ្វើអនុមោទនា ។ ព្រះសាស្តាទ្រង់ប្រារព្ធព្រះធម្មទេសនា អនុមោទនាហើយ ចំណែកនាងខុជ្ជុត្តរាស្តាប់ធម្មកថារបស់ព្រះសាស្តានោះឯង តាំង

នៅក្នុងសោតាបត្តិផលហើយ ។ ក្នុងថ្ងៃទាំងឡាយដទៃ នាងកាន់យក កហាបណៈ ៤ ទុកសម្រាប់ខ្លួន ទិញផ្កាដោយកហាបណៈ ៤ ហើយ ទៅ ។ ក្នុងថ្ងៃនោះ នាងទទួលផ្កាដោយកហាបណៈ ៨ ហើយទៅ ។

លំដាប់នោះ នាងសាមាវតីសួរនាងខុជ្ជុត្តរានោះថា នែនាង ព្រះ រាជាប្រទានតម្លៃផ្កាដល់ខ្ញុំបន្ថែមឡើងពីរដងឬ ។ នាងខុជ្ជុត្តរាពោលថា មិនមែនដូច្នោះឡើយ ព្រះនាង ។

នាងសាមាវតីសួរថា បើដូច្នោះ ហេតុអ្វី ទើបផ្កាច្រើន ។ នាង ខុជ្ជុត្តរាឆ្លើយថា ក្នុងថ្ងៃទាំងឡាយដទៃ ខ្ញុំម្ចាស់កាន់យកកហាបណៈ ៤ ទុកសម្រាប់ខ្លួនឯង នាំផ្កាមកដោយកហាបណៈ ៤ ។

នាងសាមាវតីសួរថា ថ្ងៃនេះ ព្រោះហេតុអ្វី ទើបមិនកាន់យក ។ នាងខុជ្ជុត្តរាពោលថា ព្រោះខ្ញុំម្ចាស់ស្តាប់ធម្មកថារបស់ព្រះសម្មាសម្ពុទ្ធ ហើយសម្រេចធម៌ ។

លំដាប់នោះ នាងសាមាវតីមិនបានគំរាមនាងខុជ្ជុត្តរានោះ ដោយ ពាក្យថា វ៉ឺយទាសីអាក្រក់ នាងចូរឲ្យកហាបណៈដែលកាន់យកហើយ អស់កាលមានប្រមាណប៉ុណ្ណេះដល់យើង បែរជាពោលថា នែនាង នាង ចូរឲ្យយើងទាំងឡាយផឹកអមតរស ដែលនាងផឹកហើយ ។ កាលនាង ពោលថា បើដូច្នោះ សូមព្រះនាងឲ្យខ្ញុំងូតទឹក ទើបឲ្យនាងងូតទឹកក្រអូប ដោយក្អមទាំងឡាយ ១៦ ហើយប្រទានសាដកសាច់ល្អ ២ ផ្ទាំង ។

នាងខុជ្ជុត្តរានោះ ស្ទៀកមួយផ្ទាំង ដណ្ដប់មួយផ្ទាំង ឲ្យក្រាលអាសនៈ ហើយ ឲ្យនាំផ្ចិតមួយមក អង្គុយលើអាសនៈ ចាប់ផ្ចិតដ៏វិចិត្រ ហៅមាតុគ្រាម ៥០០ មក ហើយសម្ដែងធម៌ដល់ស្រីទាំងនោះ ដោយទំនងដែលព្រះសាស្ដាទ្រង់សម្ដែងហើយនោះឯង ។ ស្រីទាំងឡាយនោះ ស្ដាប់ធម្មកថារបស់នាងហើយ ក៏តាំងនៅក្នុងសោតាបត្តិផល ។

ស្រីទាំងឡាយនោះ ថ្វាយបង្គំនាងខុជ្ជុត្តរា ហើយពោលថា បពិត្រអ្នកម៉ែ តាំងអំពីថ្ងៃនេះទៅ អ្នកម៉ែកុំធ្វើការងារដែលសៅហ្មង ចូរតាំងនៅក្នុងឋានៈជាមាតា និងឋានៈជាអាចារ្យរបស់ពួកខ្ញុំ ទៅកាន់សម្នាក់របស់ព្រះសាស្ដា ស្ដាប់ធម៌ដែលព្រះសាស្ដាទ្រង់សម្ដែងហើយ ចូរមកសម្ដែងដល់ពួកខ្ញុំ ។ នាងខុជ្ជុត្តរាក៏ធ្វើយ៉ាងនោះ ។ ក្នុងកាលតមក ក៏បានជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ។ លំដាប់នោះ ព្រះសាស្ដាទ្រង់តាំងនាងខុជ្ជុត្តរានោះ ទុកក្នុងតំណែងឯតទគ្គៈថា

**ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ ពហុស្សុតានំ យទិទំ ខុជ្ជុត្តរា ។** ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកឧបាសិកាអ្នកចេះដឹងច្រើន ដែលជាសាវិការបស់តថាគត ស្រេចនឹងនាងខុជ្ជុត្តរា ប្រសើរជាងគេ[១] ។

ស្រី ៥០០ នោះ ពោលនឹងនាងខុជ្ជុត្តរាយ៉ាងនេះថា បពិត្រអ្នក

---

១-បិ.៤០ ទំ.៥៧ ឃ.១៥២ ។

ម៉ែ ពួកខ្ញុំប្រាថ្នាដើម្បីគាល់ព្រះសាស្តា សូមអ្នកម៉ែបង្ហាញព្រះសាស្តាដល់យើងខ្ញុំទាំងឡាយ ពួកខ្ញុំនឹងបូជាព្រះអង្គដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម ។

នាងខុជ្ជុត្តរាពោលថា ព្រះនាងទាំងឡាយ ឈ្មោះថា រាជត្រកូលជាភារៈធ្ងន់ ខ្ញុំមិនអាចនាំព្រះនាងទាំងឡាយទៅខាងក្រៅបានទេ ។ ស្រីទាំងនោះពោលថា បពិត្រអ្នកម៉ែ អ្នកម៉ែកុំឲ្យពួកខ្ញុំវិនាសឡើយ សូមអ្នកម៉ែបង្ហាញព្រះសាស្តាដល់ពួកខ្ញុំចុះ ។

នាងខុជ្ជុត្តរាពោលថា បើយ៉ាងនោះ ការសម្លឹងមើល ជាការដែលព្រះនាងទាំងឡាយអាចធ្វើបាន តាមប្រហោងមានប្រមាណប៉ុនណា ចូរចោះប្រហោងមានប្រមាណប៉ុណ្ណោះ ត្រង់ជញ្ជាំងបន្ទប់ដែលជាលំនៅរបស់ពួកព្រះនាង ឲ្យនាំគ្រឿងក្រអូបនិងផ្កាកម្រងជាដើមមក ហើយឈរខាងក្នុងទីនោះៗ ចូរសម្លឹងមើល ចូរលាព្រះហស្តទាំងពីរចេញថ្វាយបង្គំនិងចូរបូជាព្រះសាស្តា ដែលទ្រង់យាងទៅកាន់ផ្ទះរបស់សេដ្ឋីទាំងបី ។ ស្រីទាំងនោះ ធ្វើយ៉ាងនោះហើយ សម្លឹងមើលព្រះសាស្តាដែលយាងទៅនិងយាងមក ថ្វាយបង្គំនិងបូជាហើយ ។

សម័យថ្ងៃមួយ ព្រះនាងមាគណ្ឌិយាចេញអំពីប្រាសាទរបស់ខ្លួនទៅកាន់លំនៅរបស់ស្រីទាំងនោះ ឃើញប្រហោងក្នុងបន្ទប់ទាំងឡាយហើយ សួរថា នេះជាប្រហោងអ្វី ។ កាលស្រីទាំងនោះ មិនដឹងនូវ

អាឃាតដែលនាងចងទុកក្នុងព្រះសាស្តា ទើបឆ្លើយថា ព្រះសាស្តាយាង មកនគរយើងនេះ ពួកខ្ញុំឈរក្នុងទីនេះ ថ្វាយបង្គំព្រះសាស្តាផង បូជាព្រះសាស្តាផង ។ នាងមាគណ្ឌិយាគិតថា ព្រះសមណគោតមមកកាន់នគរនេះហើយ ឥឡូវនេះ អញនឹងដឹងកម្មដែលគួរធ្វើដល់ព្រះសមណគោតមនោះ សូម្បីស្រីទាំងនេះ ក៏ជាឧបដ្ឋាយិការបស់ព្រះសមណគោតមនោះ អញនឹងដឹងកម្មដែលគួរធ្វើដល់ស្រីទាំងនេះ ទើបទៅក្រាបទូលដល់ព្រះរាជាថា បពិត្រមហារាជ ស្រី ៥០០ មួយអន្លើដោយនាងសាមាវតី មានការប្រាថ្នាខាងក្រៅ ទ្រង់នឹងមិនមានព្រះជន្មក្នុងរយៈពេលពីរបីថ្ងៃ ដោយពិត ។ ព្រះរាជាទ្រង់មិនជឿ ដោយទ្រង់ព្រះតម្រិះថា ស្រីទាំងនេះ នឹងមិនធ្វើកម្មបែបនេះ ។ កាលនាងមាគណ្ឌិយាក្រាបទូលទៀត ក៏ទ្រង់នៅតែមិនជឿ ។ លំដាប់នោះ នាងមាគណ្ឌិយាក៏ក្រាបទូលព្រះរាជានោះទៀត កាលក្រាបទូលយ៉ាងនេះអស់វារៈ ៣ ដង ក៏ព្រះរាជានៅតែមិនជឿ ទើបពោលថា បពិត្រមហារាជ បើទ្រង់មិនជឿខ្ញុំម្ចាស់សោតសូមទ្រង់យាងទៅកាន់លំនៅរបស់ស្រីទាំងនោះ ហើយពិនិត្យមើលចុះ ។

ព្រះរាជាយាងទៅទតឃើញប្រហោងក្នុងបន្ទប់ទាំងឡាយ ទើបត្រាស់សួរថា **ឥដំ កឹ** នេះប្រហោងអ្វី ។ កាលស្រីទាំងនោះ ក្រាបទូលសេចក្តីនោះហើយ ទ្រង់មិនពិរោធចំពោះស្រីទាំងនោះ មិនត្រាស់ពាក្យណាមួយឡើយ បញ្ជាឲ្យបិទប្រហោងទាំងឡាយ ហើយឲ្យធ្វើបង្អួច

មានប្រហោងតូច ក្នុងបន្ទប់ទាំងពួង ។ បានឮថា បង្អួចមានប្រហោងតូចទាំងឡាយ កើតឡើងហើយក្នុងកាលនោះ ។

នាងមាគណ្ឌិយាមិនអាចធ្វើអ្វីដល់ស្រីទាំងនោះបាន ក៏ត្រិះរិះថា អញនឹងធ្វើកម្មដែលគួរធ្វើដល់ព្រះសមណគោតមឲ្យបាន ទើបឲ្យឈ្នួលដល់អ្នកស្រុក ហើយពោលថា ពួកអ្នកមួយអន្ទើដោយពួកបុរសដែលជាទាសៈនិងបុរសដែលជាកម្មករ ចូរជេរបរិភាសព្រះសមណគោតមដែលចូលទៅខាងក្នុងព្រះនគរឲ្យគេចទៅ ។ ពួកមិច្ឆាទិដ្ឋិមិនជ្រះថ្លាក្នុងរតនៈ ៣ ក៏ជាប់តាមព្រះសាស្តាដែលយាងទៅខាងក្នុងនគរ ហើយជេរបរិភាសដោយអក្កោសវត្ថុ ១០ យ៉ាងថា អ្នកជាចោរ ១ អ្នកជាបុគ្គលពាល ១ អ្នកជាមនុស្សឆ្កួត ១ អ្នកជាសត្វអូដ្ឋ ១ អ្នកជាសត្វគោ ១ អ្នកជាសត្វលា ១ អ្នកជាសត្វនរក ១ អ្នកជាសត្វតិរច្ឆាន ១ សុគតិរបស់អ្នកមិនមាន ១ អ្នកមានតែទុគ្គតិដោយពិត ១ ។

ព្រះអានន្ទបានស្តាប់ពាក្យនោះហើយ ក្រាបបង្គំទូលព្រះសាស្តាយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្នកនគរទាំងនេះ តែងជេរបរិភាសពួកយើង ពួកយើងនឹងចេញអំពីទីនេះ ទៅក្នុងទីដទៃ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលអានន្ទ យើងនឹងទៅកាន់ទីណា ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទៅកាន់នគរដទៃ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលអានន្ទ កាលពួកមនុស្សក្នុងនគរ

នោះ ដេរទៀត យើងនឹងទៅកាន់ទីណា ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទៅកាន់នគរដទៃអំពីនគរនោះទៀត ។

ព្រះសាស្តាត្រាស់សួរថា បើមនុស្សក្នុងនគរនោះ ដេរទៀត យើងនឹងទៅកាន់ទីណាទៀត ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទៅកាន់នគរដទៃអំពីនគរនោះទៀត ។

ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលអានន្ទ ការធ្វើយ៉ាងនេះ មិនគួរ អធិករណ៍កើតឡើងក្នុងទីណា កាលអធិករណ៍នោះ រម្ងាប់ហើយក្នុងទីនោះឯង ទើបគួរទៅកាន់ទីដទៃ ។ ម្នាលអានន្ទ ពួកជនអ្នកដេរនោះ ជានរណា ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងពួង រាប់យកទាំងទាសៈនិងកម្មករ កំពុងដេរ ។

ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលអានន្ទ តថាគតដូចស្តេចដំរីចុះកាន់សង្គ្រាម ការអត់ធន់នឹងព្រួញដែលមកអំពីទិសទាំង ៤ រមែងជាភារៈរបស់ដំរីដែលចុះកាន់សង្គ្រាមយ៉ាងណា ឈ្មោះថា ការអត់ធន់ចំពោះពាក្យសម្តីដែលបុគ្គលទ្រុស្តសីលជាច្រើន ពោលហើយ ជាភារៈរបស់តថាគត ក៏យ៉ាងនោះដែរ ដូច្នេះហើយ កាលទ្រង់ប្រារព្ធព្រះអង្គឯង ទើបសម្តែងធម៌ក្នុងនាគវគ្គទាំងបីគាថានេះថា

អហំ នាគោវ សង្គាមេ ចាបាតោ បតិតំ សរំ
អតិវាក្យន្តិតិក្ខិស្សំ ទុស្សីលោ ហិ ពហុជ្ជនោ ។

តថាគតនឹងអត់ទ្រាំពាក្យល្មើស ដូចដំរី កាលអត់ទ្រាំចំពោះព្រួញដែលរបូតចេញអំពីធ្នូ ក្នុងសង្រ្គាមដូច្នោះ ព្រោះថា ជនទ្រុស្តសីលមានច្រើននាក់ ។

**ទន្តំ នយន្តិ សមិតឹ ទន្តំ រាជាភិរូហតិ**
**ទន្តោ សេដ្ឋោ មនុស្សេសុ យោតិវាក្យន្តិតិក្ខតិ ។**

ពួកជនតែងនាំវាហនៈ ដែលទូន្មានហើយទៅកាន់ទីប្រជុំ ព្រះរាជាតែងស្តេចឡើងកាន់វាហនៈ ដែលទូន្មានហើយ បណ្តាមនុស្សទាំងឡាយ មនុស្សណាអត់សង្កត់នឹងពាក្យល្មើសបាន មនុស្សនោះ ជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថា បុគ្គលប្រសើរបំផុត ។

**វរមស្សតរា ទន្តា អាជានីយា វ សិន្ធវា**
**កុញ្ជរា វ មហានាគា អត្តទន្តោ តតោ វរំ ។**

ពួកសេះអស្សតរក្តី សេះអាជានេយ្យក្តី សេះសិន្ធពក្តី ដំរីកុញ្ជរដ៏ប្រសើរក្តី ដែលបុគ្គលប្រៀនប្រដៅបានបទហើយ រាប់ថាជាសត្វប្រសើរ បុគ្គលដែលមានខ្លួនទូន្មានបានបទហើយ ប្រសើរជាងសត្វទាំងអស់នោះ (១) ។

ធម្មកថា បានជាប្រយោជន៍ដល់មហាជនដែលដល់ព្រម គឺប្រជុំគ្នា

---

១-បិ.៥២ ទំ.៨៨ ឃ.៣៣ ។

ហើយ ។ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងព្រះធម្មទេសនាយ៉ាងនេះ ហើយ ត្រាស់ថា ម្នាលអានន្ទ អ្នកកុំគិតឡើយ ជនទាំងនោះនឹងដេរបាន ត្រឹមតែ ៧ ថ្ងៃប៉ុណ្ណោះ ក្នុងថ្ងៃទី ៨ នឹងជាអ្នកស្ងៀម ព្រោះថា អធិករណ៍ ដែលកើតឡើងដល់ព្រះពុទ្ធទាំងឡាយ រមែងមិនលើស ៧ ថ្ងៃទេ ។

នាងមាគណ្ឌិយានោះ ឲ្យមនុស្សដេរព្រះសាស្ដាហើយ តែមិនអាច ឲ្យទ្រង់គេចទៅបាន ទើបគិតថា អញនឹងធ្វើដូចម្ដេចហ្ន៎ ដូច្នេះហើយ គិតថា ស្រីទាំងនេះ ជាអ្នកឧបត្ថម្ភព្រះសមណគោតមនោះ អញនឹងធ្វើ សេចក្ដីវិនាសឲ្យដល់ស្រីទាំងនោះ ។ ថ្ងៃមួយ កាលធ្វើនូវការបម្រើក្នុង ទីសោយទឹកច័ណ្ឌរបស់ព្រះរាជា បញ្ជូនដំណឹងទៅឲ្យឪពុកមាថា សូម លោកមាជ្រាបថា ខ្ញុំត្រូវការមាន់ទាំងឡាយ សូមលោកមានាំយកមាន់ ងាប់ ៨ មាន់រស់ ៨ កាលមកហើយ ចូរឈរត្រង់ក្បាលជណ្ដើរ ប្រាប់ ភាពដែលខ្លួនមកហើយ កាលមានមនុស្សប្រាប់ថា ចូរចូលមក ក៏កុំចូល មកឡើយ ចូរបញ្ជូនមាន់រស់ ៨ ទៅមុន បញ្ជូនមាន់ងាប់ ៨ ទៅឯ ក្រោយ ។ នាងមាគណ្ឌិយានោះ បានឲ្យសំណូកដល់អ្នកបម្រើ ដោយ ប្រាប់ថា អ្នកគប្បីធ្វើតាមពាក្យរបស់យើង ។ នាយមាគណ្ឌិយៈមកហើយ ឲ្យក្រាបទូលដល់ព្រះរាជាឲ្យទ្រង់ជ្រាប កាលមនុស្សប្រាប់ថា ចូរចូលមក ក៏ពោលថា ខ្ញុំនឹងមិនចូលទៅកាន់ទីសោយទឹកច័ណ្ឌរបស់ព្រះរាជាទេ ។ ចំណែកនាងមាគណ្ឌិយាបញ្ជូនអ្នកបម្រើទៅដោយពាក្យថា នែបា ចូរបា

ទៅកាន់សម្នាក់ឪពុកមារបស់យើង ។ អ្នកបម្រើនោះទៅហើយ នាំមាន់រស់ ៨ ដែលនាយមាគណ្ឌិយៈនោះឲ្យហើយ មកក្រាបទូលថា បពិត្រព្រះសម្មតិទេព បុរោហិតបញ្ជូនគ្រឿងបណ្ណាការមកហើយ ។

ព្រះរាជាត្រាស់ថា ល្អហើយ សម្ងូឧត្តរិកត្តកើតឡើងដល់ពួកយើង អ្នកណាហ្ន៎ គួរចម្អិន ។ នាងមាគណ្ឌិយាក្រាបទូលថា បពិត្រមហារាជ ស្រី ៥០០ មានព្រះនាងសាមាវតីជាប្រធាន ជាអ្នកមិនមានការងារ ដើរចុះឡើង សូមទ្រង់បញ្ជូនទៅឲ្យស្រីទាំងនោះ ស្រីទាំងនោះ ស្ងូហើយនឹងនាំមក ។

ព្រះរាជាទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា អ្នកចូរទៅ ហើយឲ្យដល់ស្រីទាំងនោះ ស្រីទាំងនោះ ចូរកុំប្រគល់ឲ្យអ្នកដទៃ ចូរសម្លាប់មាន់ ហើយចម្អិនដោយខ្លួនឯង ។ អ្នកបម្រើនោះ ទទួលព្រះតម្រាស់ថា ប្រពៃហើយ ព្រះសម្មតិទេព ហើយទៅប្រាប់យ៉ាងនោះ ។

ស្រីទាំងនោះជំទាស់ថា ពួកខ្ញុំមិនធ្វើបាណាតិបាត ។ អ្នកបម្រើនោះ ត្រឡប់មកក្រាបទូលសេចក្ដីនោះដល់ព្រះរាជា ។ នាងមាគណ្ឌិយាក្រាបទូលព្រះរាជាថា បពិត្រមហារាជ ទ្រង់ឃើញទេ ឥឡូវនេះ ទ្រង់នឹងជ្រាប ការធ្វើ ឬមិនធ្វើបាណាតិបាតនៃស្រីទាំងនោះ សូមទ្រង់ត្រាស់ថា ពួកនាង ចូរស្ងូ ហើយបញ្ជូនទៅថ្វាយដល់ព្រះសមណគោតមដូច្នេះចុះ ។ ព្រះរាជាក៏ត្រាស់យ៉ាងនោះ ហើយបញ្ជូនទៅ ។ អ្នកបម្រើនោះ

កាន់មាន់ធ្វើជាដើរចេញទៅ ហើយឲ្យមាន់ទាំងនោះដល់បុរោហិត ទទួលមាន់ងាប់ទៅកាន់សម្នាក់របស់ស្រីទាំងនោះ ពោលថា ព្រះនាងទាំងឡាយចូរស្ងោមាន់ទាំងនេះ ហើយបញ្ជូនទៅកាន់សម្នាក់ព្រះសាស្តា ។

ស្រីទាំងនោះក្រោកទទួលថា សូមលោកនាំមកចុះ ឈ្មោះថា ការស្ងោ ( មាន់ងាប់ ) នេះ ជាកិច្ចរបស់ពួកយើង ហើយក៏ទទួល ។ អ្នកបម្រើនោះ មកកាន់សម្នាក់របស់ព្រះរាជា ។ កាលព្រះរាជាសួរថា នែបាសេចក្តីនោះដូចម្តេច ទើបក្រាបទូលថា ទូលព្រះបង្គំគ្រាន់តែពោលថា សូមព្រះនាងទាំងឡាយស្ងោ ហើយបញ្ជូនទៅថ្វាយព្រះសមណគោតម ប៉ុណ្ណោះ ស្រីទាំងនោះ ក៏ស្ទុះមកទទួលយកទៅ ។

នាងមាគណ្ឌិយាក្រាបទូលថា បពិត្រមហារាជ សូមទ្រង់ទតចុះ ស្រីទាំងនោះ មិនធ្វើដល់បុគ្គលដូចព្រះអង្គឡើយ កាលខ្ញុំម្ចាស់ទូលថា ស្រីទាំងនោះ មានសេចក្តីប្រាថ្នាខាងក្រៅ ទ្រង់មិនជឿ ។ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះ ទ្រង់ក៏អត់សង្កត់នៅស្ងៀមដូចមុន ។ នាងមាគណ្ឌិយាគិតថា យើងនឹងធ្វើដូចម្តេចហ្ន៎ ។

កាលនោះ ព្រះរាជាទ្រង់គង់ប្រាំពីរថ្ងៃ ៗ តាមវារៈក្នុងប្រាសាទនៃស្រីទាំង ៣ នោះ គឺព្រះនាងសាមាវតី ព្រះនាងវាសុលទត្តា និងព្រះនាងមាគណ្ឌិយា ។ គ្រានោះ នាងមាគណ្ឌិយាដឹងថា ស្អែកនេះ ឬខានស្អែក ព្រះរាជាទ្រង់នឹងយាងទៅកាន់ប្រាសាទរបស់ព្រះនាងសាមាវតី

ទើបបញ្ជូនដំណឹងទៅកាន់ឪពុកមាថា សូមលោកមាជ្រាបថា ខ្ញុំមានសេចក្ដីត្រូវការដោយពស់ពិស សូមមាដកចង្កូមទាំងឡាយ ហើយបញ្ជូនពស់មួយក្បាលមក ។ នាយមាគណ្ឌិយៈធ្វើយ៉ាងនោះ ហើយបញ្ជូនទៅ ។ ព្រះរាជាទ្រង់កាន់យកពិណាហត្ថិកន្តៈ យាងទៅកាន់ទីដែលទ្រង់យាងទៅ ស្នូកពិណានោះ មានប្រហោងមួយ នាងមាគណ្ឌិយាលែងពស់ចូលក្នុងប្រហោងនោះ ហើយបិទប្រហោងនោះ ដោយសំណុំផ្កា ។ ពស់បាននៅក្នុងពិណានោះឯង ពីរបីថ្ងៃ ។ ក្នុងថ្ងៃយាងទៅនៃព្រះរាជា នាងមាគណ្ឌិយានោះ ទូលសួរថា បពិត្រព្រះសម្មតិទេព ថ្ងៃនេះ ទ្រង់យាងទៅប្រាសាទរបស់មហេសីអង្គណា ។

ព្រះរាជាត្រាស់ថា ទៅប្រាសាទរបស់នាងសាមាវតី ។ ព្រះនាងមាគណ្ឌិយាក្រាបទូលថា បពិត្រមហារាជ ថ្ងៃនេះ ខ្ញុំម្ចាស់សុបិនឃើញហេតុមិនជាទីពេញចិត្ត បពិត្រព្រះសម្មតិទេព ទ្រង់មិនអាចយាងទៅក្នុងទីនោះបានទេ ។

ព្រះរាជាត្រាស់ថា យើងនឹងទៅនោះឯង ។ ព្រះនាងឃាត់អស់វារៈ ៣ ដង ហើយទូលថា បពិត្រព្រះសម្មតិទេព បើដូច្នោះ ខ្ញុំម្ចាស់នឹងទៅជាមួយទ្រង់ដែរ ។ ព្រះរាជាឲ្យត្រឡប់ក៏មិនត្រឡប់ ក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់មិនដឹងថា នឹងមានហេតុអ្វីកើតឡើងទេ ដូច្នេះហើយ ក៏បានទៅជាមួយព្រះរាជានោះឯង ។

ព្រះរាជាទ្រទ្រង់នូវសំពត់ ផ្កា គ្រឿងក្រអូប និងគ្រឿងអាភរណៈទាំងឡាយ ដែលពួកស្រីទាំងនោះ មានព្រះនាងសាមាវតីជាដើម ថ្វាយហើយ សោយហើយនូវព្រះក្រយាដ៏ល្អ ដាក់ពិណាទុកត្រង់ក្បាលដំណេកហើយផ្ទំលើទីបន្ទំ ។ នាងមាគណ្ឌិយាធ្វើជាដើរទៅមក បានយកសំណុំផ្កាចេញអំពីប្រហោងពិណា ។ ពស់ដែលអត់អាហារពីរបីថ្ងៃ លូនចេញអំពីប្រហោងនោះ បើកពពារ ដេកលើទីបន្ទំហើយ ។ នាងឃើញពស់នោះ ក៏ស្រែកឡើងថា ថ្វីយ ថ្វីយ ព្រះសម្មតិទេព ពស់ ។ កាលជេរព្រះរាជានិងស្រីទាំងនោះ ទើបពោលថា ស្តេចល្ងង់នេះ មិនមានបុណ្យមិនស្តាប់ពាក្យរបស់ខ្ញុំម្ចាស់សោះ សូម្បីស្រីទាំងនេះ ក៏ជាមនុស្សមិនមានសិរី ក្បាលរឹង ពួកនាងមិនបានអ្វីអំពីសម្នាក់របស់ព្រះរាជាឬ ពួកនាងកាលព្រះរាជាអង្គនេះ សោយទិវង្គតហើយ នឹងជាអ្នករស់នៅស្រួលឬកាលព្រះរាជានៅមានព្រះជន្ម ពួកនាងរស់នៅលំបាកឬ ថ្ងៃនេះ យើងឃើញសុបិនអាក្រក់ហើយ បពិត្រព្រះសម្មតិទេព ព្រះអង្គមិនស្តាប់ពាក្យរបស់ខ្ញុំម្ចាស់ ដែលអង្វរថា ទ្រង់មិនគួរយាងទៅកាន់ប្រាសាទរបស់ព្រះនាងសាមាវតីទេ ។

ព្រះរាជាទតឃើញពស់ ក៏ទ្រង់ស្លុតព្រះហឫទ័យ ខ្លាចចំពោះមរណៈ ទ្រង់ព្រះពិរោធយ៉ាងខ្លាំង ដូចភ្លើងឆេះសន្ធោសន្ធៅ មានព្រះរាជឱង្ការថា យីអើ! ពួកស្រីថោកទាប! ពួកស្រីនេះ ធ្វើកម្មមានសភាពបែប

នេះ អញមិនជឿពាក្យរបស់នាងមាគណ្ឌិយា ដែលប្រាប់នូវភាពនៃស្រីទាំងនេះ ជាមនុស្សលាមក ក្នុងកាលមុន វាចោះប្រហោងក្នុងបន្ទប់ទាំងឡាយរបស់ខ្លួនអង្គុយហើយ កាលអញបញ្ជូនមាន់ទៅឲ្យ ក៏បញ្ជូនត្រឡប់មកវិញ ថ្ងៃនេះ លែងពស់ទុកលើទីដេក ។

ចំណែកនាងសាមាវតី ក៏បានឲ្យឱវាទដល់ស្រី ៥០០ ថា នែនាងទាំងឡាយ ទីពឹងដទៃរបស់ពួកយើង មិនមាន ចូរនាងញុំាងមេត្តាចិត្តឲ្យស្មើ ឲ្យប្រព្រឹត្តទៅក្នុងព្រះរាជាដែលជាកំពូលនៃនរជន ក្នុងព្រះនាងមាគណ្ឌិយាទេវី និងក្នុងខ្លួននាងទាំងឡាយ កុំធ្វើសេចក្តីក្រោធចំពោះបុគ្គលណាមួយឡើយ ។ ព្រះរាជាទ្រង់កាន់ធ្នូស្នែង ដែលលើកដោយកម្លាំងរបស់បុរស ១ ពាន់នាក់ ទ្រង់ទាញខ្សែហើយ ផ្គាប់ព្រួញដែលលាបដោយថ្នាំពិស ធ្វើព្រះនាងសាមាវតីឲ្យនៅខាងមុខ ឲ្យស្រីទាំងនោះ ឈរតាមលំដាប់គ្នាហើយ ទើបលែងព្រួញទៅ តម្រង់ដើមទ្រូងរបស់ព្រះនាងសាមាវតី ។ ព្រួញនោះ បែរមុខមករកព្រះរាជាហើយ ហាក់ដូចចូលមកកាន់ហទយៈរបស់ព្រះរាជា បានតាំងនៅហើយដោយមេត្តានុភាពរបស់ព្រះនាងសាមាវតីនោះ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ព្រួញដែលអញបាញ់ទៅ អាចទម្លុះសូម្បីថ្ម ទីដែលប៉ះខ្ទប់ក្នុងអាកាស ក៏មិនមានសោះ តែថាព្រួញនេះ ត្រឡប់បែរមុខមករកបេះដូងរបស់អញវិញ មែនពិតព្រួញនេះ មិនមែនសត្វ មិនមានជីវិត គង់ដឹងគុណរបស់នាងសាមាវតី

ចំណែកអញជាមនុស្សឲ្យត្រឡាំង ហេតុអ្វី ក៏មិនដឹងគុណរបស់នាង ។ ព្រះរាជាបោះធ្នូចោល អង្គុយច្រហោង ផ្គងអញ្ជលីទៀបបាទារបស់ព្រះនាងសាមាវតី ត្រាស់គាថានេះថា

**សម្មុយ្ហាមិ បមុយ្ហាមិ សព្វា មុយ្ហន្តិ មេ ទិសា**
**សាមាវតិ មំ តាយស្សុ ត្វញ្ច មេ សរណំ ភវ ។**

ខ្ញុំញាប់ញ័រ ភាន់ភាំង វង្វេង ទិសទាំងពួងងងឹតដល់ខ្ញុំ នែនាងសាមាវតី សូមនាងការពារនូវខ្ញុំ សូមនាងជាទីពឹងរបស់ខ្ញុំ ។

ព្រះនាងសាមាវតីស្តាប់ព្រះតម្រាស់របស់ព្រះរាជាហើយ ក៏មិនបានក្រាបទូលថា ប្រពៃហើយ ព្រះសម្មតិទេព ទ្រង់ដល់នូវខ្ញុំម្ចាស់ជាទីពឹងចុះ តែក្រាបទូលថា បពិត្រមហារាជ ខ្ញុំម្ចាស់ដល់បុគ្គលណាជាទីពឹង សូមព្រះអង្គដល់នូវបុគ្គលនោះឯង ជាទីពឹងចុះ ។ ព្រះនាងសាមាវតីដែលជាសាវិការបស់ព្រះសម្មាសម្ពុទ្ធ កាលពោលពាក្យនេះហើយ ទើបពោលថា

**មា មំ ត្វំ សរណំ គច្ឆ យមហំ សរណំ គតា**
**ឯស ពុទ្ធោ មហារាជ ឯស ពុទ្ធោ អនុត្តរោ**
**សរណំ គច្ឆ តំ ពុទ្ធំ ត្វញ្ច មេ សរណំ ភវ ។**

សូមទ្រង់កុំដល់ខ្ញុំម្ចាស់ជាទីពឹងឡើយ ខ្ញុំម្ចាស់ដល់បុគ្គល

*ណាជាទីពឹង បពិត្រមហារាជ បុគ្គលនោះគឺព្រះពុទ្ធ ព្រះពុទ្ធអង្គនោះ ប្រសើរលើសលុប សូមទ្រង់ដល់នូវព្រះពុទ្ធអង្គនោះ ជាទីពឹងផង ទ្រង់ជាទីពឹងរបស់ខ្ញុំម្ចាស់ផង ។*

*ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់នាងសាមាវតីនោះហើយ ទើបត្រាស់ថា ឥឡូវនេះ យើងរឹងរឹតតែខ្វាចខ្លាំងឡើង ហើយត្រាស់គាថានេះថា*

**ឯស ភិយ្យោ បមុយ្ហាមិ សព្វា មុយ្ហន្តិ មេ ទិសា**
**សាមាវតិ មំ តាយស្សុ ត្វញ្ច មេ សរណំ ភវ ។**

*ខ្ញុំរឹងរឹតតែវង្វេងខ្លាំងឡើង ទិសទាំងពួងងងឹតដល់ខ្ញុំ នាងសាមាវតី សូមនាងការពារនូវខ្ញុំ សូមនាងជាទីពឹងរបស់ខ្ញុំ ។*

*លំដាប់នោះ ព្រះនាងសាមាវតីក៏ទូលទាស់ព្រះរាជាទៀតដោយន័យមុននោះឯង ។ កាលព្រះរាជាត្រាស់ថា បើដូច្នោះ ខ្ញុំសូមដល់នាងជាទីពឹងផង ខ្ញុំសូមដល់ព្រះសាស្ដាជាទីពឹងផង ហើយខ្ញុំនឹងឲ្យពរដល់នាង ទើបព្រះនាងក្រាបទូលថា បពិត្រមហារាជ ពរចូរជារបស់ដែលខ្ញុំម្ចាស់បានទទួលចុះ ។*

*ព្រះរាជាយាងទៅគាល់ព្រះសាស្ដា ទ្រង់ដល់ព្រះពុទ្ធជាសរណៈហើយ ទ្រង់និមន្តព្រះសាស្ដា ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ទ្រង់ហៅព្រះនាងសាមាវតីមក ត្រាស់ថា* **ឧដ្ឋេហិ វរំ គណ្ហ** *ចូរនាងក្រោកឡើង ទទួលពរ ។*

ព្រះនាងសាមាវតីក្រាបទូលថា បពិត្រមហារាជ ខ្ញុំម្ចាស់មិនមានសេចក្តីត្រូវការដោយវត្ថុទាំងឡាយ មានប្រាក់ជាដើមឡើយ តែសូមទ្រង់ព្រះរាជទានពរនេះ ដល់ខ្ញុំម្ចាស់ គឺព្រះសាស្តាមួយអន្លើដោយភិក្ខុ ៥០០ រូប នឹងយាងមកក្នុងទីនេះជានិច្ច បានដោយប្រការណា សូមទ្រង់ធ្វើដោយប្រការនោះចុះ ខ្ញុំម្ចាស់នឹងស្តាប់ធម៌ ។

ព្រះរាជាថ្វាយបង្គំព្រះសាស្តា ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់យាងមកក្នុងទីនេះជានិច្ច ព្រមទាំងភិក្ខុ ៥០០ រូប ដ្បិតពួកស្រីដែលរួមទាំងព្រះនាងសាមាវតីផង ពោលថា ខ្ញុំម្ចាស់នឹងស្តាប់ធម៌ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ ធម្មតាការទៅក្នុងទីមួយជានិច្ច មិនគួរដល់ព្រះពុទ្ធទាំងឡាយ ព្រោះមហាជនទន្ទឹងការមករបស់ព្រះសាស្តា ។ ព្រះរាជាក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើយ៉ាងនោះ សូមទ្រង់ឲ្យភិក្ខុមួយរូបចុះ ។

ព្រះសាស្តាទ្រង់ប្រគល់នាទីដល់ព្រះអានន្ទត្ថេរហើយ ។ ចាប់តាំងអំពីកាលនោះ ព្រះអានន្ទត្ថេរក៏នាំភិក្ខុ ៥០០ ទៅកាន់រាជត្រកូលជានិច្ច ព្រះទេវីទាំងនោះ អង្គាសព្រះថេរៈមួយអន្លើដោយបរិវារ ស្តាប់ធម៌ជានិច្ចកាល ។ ថ្ងៃមួយ ស្រីទាំងនោះ ស្តាប់ធម្មកថារបស់ព្រះអានន្ទត្ថេរ ហើយជ្រះថ្លា បានបូជាព្រះធម៌ដោយសំពត់ឧត្តរាសង្គៈ ៥០០ ផ្ទាំង ។

ឧត្តរាសង្គៈនីមួយ ៗ មានតម្លៃ ៥០០ ។

ព្រះរាជាទ្រង់មិនឃើញសំពត់ សូម្បីមួយផ្ទាំងរបស់ស្រីទាំងនោះ ទើបត្រាស់សួរថា សំពត់ឧត្តរាសង្គៈនៅឯណា ។ ស្រីទាំងនោះ ក្រាបទូលថា ខ្ញុំម្ចាស់ប្រគេនដល់លោកម្ចាស់របស់យើងហើយ ។

ព្រះរាជាត្រាស់សួរថា លោកម្ចាស់អង្គនោះ ទទួលទាំងអស់ឬ ។ ស្រីទាំងនោះក្រាបទូលថា **អាម គហិតា** បពិត្រព្រះអង្គ លោកទទួលទាំងអស់ ។

ព្រះរាជាយាងចូលទៅរកព្រះអានន្ទត្ថេរ ថ្វាយបង្គំហើយ ត្រាស់សួរភាពដែលស្រីទាំងនោះ ប្រគេនសំពត់ឧត្តរាសង្គៈ ទ្រង់ស្ដាប់ភាពនៃសំពត់ដែលស្រីទាំងនោះ ប្រគេនហើយ និងភាពដែលព្រះថេរៈទទួលហើយ ទើបត្រាស់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន សំពត់ទាំងឡាយច្រើនពេក មិនមែនឬ លោកម្ចាស់នឹងធ្វើអ្វី ដោយសំពត់មានប្រមាណប៉ុណ្ណោះ ។

ព្រះអានន្ទត្ថេរពោលតបថា បពិត្រមហារាជ អាត្មាភាពទទួលសំពត់ល្មមសមគួរហើយ នឹងប្រគេនសំពត់ដ៏សេសដល់ភិក្ខុទាំងឡាយដែលមានចីវរចាស់ ។ ព្រះរាជាត្រាស់សួរថា ភិក្ខុទាំងឡាយនឹងធ្វើចីវរចាស់របស់ខ្លួនឲ្យជាអ្វី ។

ព្រះអានន្ទពោលតបថា នឹងឲ្យដល់ភិក្ខុទាំងឡាយ ដែលមានចីវរ

ចាស់ជាង ។ ព្រះរាជាត្រាស់សួរថា ភិក្ខុទាំងនោះ នឹងធ្វើចីវរចាស់របស់ខ្លួន ឲ្យជាអ្វី ។

ព្រះអានន្ទពោលតបថា លោកនឹងធ្វើឲ្យជាសំពត់ក្រាលដេក ។ ព្រះរាជាត្រាស់សួរថា លោកនឹងធ្វើសំពត់ក្រាលដេកចាស់ឲ្យជាអ្វី ។

ព្រះថេរៈពោលតបថា លោកនឹងធ្វើជាសំពត់កម្រាលផ្ទៃ ( ដី ) ។ ព្រះរាជាត្រាស់សួរថា លោកនឹងធ្វើសំពត់កម្រាលផ្ទៃចាស់ឲ្យជាអ្វី ។

ព្រះថេរៈពោលតបថា សូមថ្វាយព្រះពរមហារាជ លោកនឹងធ្វើឲ្យជាសំពត់ជូតជើង ។ ព្រះរាជាត្រាស់សួរថា លោកនឹងធ្វើសំពត់ជូតជើងចាស់ឲ្យជាអ្វី ។

ព្រះថេរៈតបថា លោកនឹងជាន់ឲ្យល្អិត ហើយផ្សំជាមួយដីឥដ្ឋបូកជញ្ជាំង ។ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ សំពត់ទាំងឡាយដែលប្រគេនដល់លោកម្ចាស់ នឹងមិនវិនាស ព្រោះធ្វើកម្មមានប្រមាណប៉ុណ្ណេះឬ ។

ព្រះថេរៈតបថា យ៉ាងនោះឯង មហាបពិត្រ ។

ព្រះរាជាទ្រង់ជ្រះថ្លាហើយ ត្រាស់ឲ្យនាំសំពត់ ៥០០ ដទៃទៀត ឲ្យតាំងទុកទៀបបាទមូលរបស់ព្រះថេរៈហើយ ។ បានឮថា ព្រះថេរៈបានសំពត់មានតម្លៃ ៥០០ ដែលគេតម្កល់ទុកទៀបបាទមូល ហើយប្រគេនដោយចំណែក ៥០០ ដល់ទៅ ៥០០ ដង បានសំពត់មានតម្លៃ

មួយពាន់ ដែលគេតម្កល់ទុកទៀបបាទមូល ប្រគេនដោយចំណែកមួយពាន់ ដល់ទៅមួយពាន់ដង បានសំពត់មានតម្លៃមួយសែន ដែលគេតម្កល់ទុកទៀបបាទមូល ប្រគេនដោយចំណែកមួយសែន ដល់ទៅមួយសែនដង ។ ឈ្មោះថា ការរាប់សំពត់ដែលព្រះអានន្ទបានហើយ ដោយន័យជាដើមថា ១ ២ ៣ ៤ ៥ ១០ ដូច្នេះ មិនមានឡើយ ។ បានឮថា កាលព្រះតថាគតបរិនិព្វានហើយ ព្រះថេរៈត្រាច់ទៅពេញជម្ពូទ្វីប បានប្រគេនបាត្រ និងចីវរទាំងឡាយដែលជារបស់ខ្លួនប៉ុណ្ណោះ ដល់ពួកភិក្ខុក្នុងវត្តទាំងអស់ ។

នាងមាគណ្ឌិយាគិតថា អញធ្វើវត្ថុណា វត្ថុនោះ មិនបានយ៉ាងនេះ បែរជាបានរបស់ដទៃទៅវិញ ឥឡូវនេះ អញនឹងធ្វើដូចម្តេចហ្ន៎ ដូច្នេះហើយ គិតថា ឧបាយនេះ ប្រើការបាន ។ កាលព្រះរាជាយាងទៅក្រសាលក្នុងព្រះរាជឧទ្យាន បញ្ជូនដំណឹងទៅកាន់ឪពុកមាថា សូមមាទៅកាន់ប្រាសាទរបស់នាងសាមាវតី បើកឃ្លាំងសំពត់ និងឃ្លាំងប្រេង ជ្រលក់សំពត់ក្នុងពាងប្រេង ហើយរុំសសរ ធ្វើស្រីទាំងនោះទុកជាមួយគ្នា បិទទ្វារដាក់គន្លឹះខាងក្រៅ យកគប់ភ្លើងមានដងដុតដំណាក់ហើយ ចូរទៅចុះ ។ នាយមាគណ្ឌិយៈនោះ ឡើងកាន់ប្រាសាទ ឲ្យបើកឃ្លាំងទាំងឡាយ ជ្រលក់សំពត់ក្នុងពាងប្រេង ហើយរុំសសរ ។ លំដាប់នោះ ស្រីទាំងឡាយ មានព្រះនាងសាមាវតីជាប្រធានចូលទៅរក ហើយសួរ

នាយមាគណ្ឌិយៈថា លោកមាធ្វើអ្វី ។

នាយមាគណ្ឌិយៈពោលយ៉ាងនេះថា ព្រះនាងទាំងឡាយ ព្រះរាជាប្រាប់ឲ្យរុំសសរទាំងនេះ ដោយសំពត់ជ្រលក់ប្រេង ដើម្បីធ្វើឲ្យរឹងមាំ ធម្មតាក្នុងព្រះរាជវាំង កម្មដែលប្រកបល្អនិងអាក្រក់ ជារបស់ដឹងបានដោយក្រ ព្រះនាងទាំងឡាយ កុំនៅក្នុងទីជិតខ្ញុំឡើយ ដូច្នេះហើយ ឲ្យស្រីទាំងនោះចូលទៅខាងក្នុងបន្ទប់ បិទទ្វារហើយដាក់គន្លឹះខាងក្រៅ ដុតភ្លើងតាំងអំពីដំណាក់ខាងដើម ហើយចុះមក ។

ព្រះនាងសាមាវតីបានឲ្យឱវាទដល់ស្រីទាំងនោះថា ការកំណត់អត្តភាពដែលត្រូវភ្លើងឆេះយ៉ាងនេះ របស់ពួកយើង ដែលអន្ទោលទៅក្នុងសង្សារ មិនមានទីបំផុតខាងដើម សូម្បីពុទ្ធញ្ញាណ ក៏មិនធ្វើបានដោយងាយ នាងទាំងឡាយ ចូរជាអ្នកមិនប្រមាទចុះ ។ ស្រីទាំងនោះកាលដំណាក់ត្រូវភ្លើងឆេះ មនសិការដល់វេទនាបរិគ្គហកម្មដ្ឋាន ស្ត្រីពួកខ្លះ សម្រេចផលទី ២ ស្ត្រីពួកខ្លះ សម្រេចផលទី ៣ ។

ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា គ្រានោះឯង ភិក្ខុជាច្រើនត្រឡប់អំពីបិណ្ឌបាតខាងក្រោយភត្ត ព្រះមានព្រះភាគគង់នៅក្នុងទីណា ក៏ចូលទៅគាល់ក្នុងទីនោះ លុះចូលទៅដល់ហើយក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ

ថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ កាលព្រះបាទឧទេន ទ្រង់ស្តេចទៅកាន់ឧទ្យាន មានភ្លើងឆេះខាងក្នុងព្រះរាជវាំង ពួកស្ត្រីទាំង ៥០០ នាក់ មាននាងសាមាវតីជាប្រធាន ធ្វើមរណកាលទាំងអស់ បពិត្រព្រះអង្គដ៏ចម្រើន គតិរបស់ឧបាសិកាទាំងនោះ តើដូចម្តេច លោកខាងមុខតើដូចម្តេច ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តាឧបាសិកាទាំងនុ៎ះ ឧបាសិកាដែលជាសោតាបន្នា ក៏មាន ជាសកទាគាមិនី ក៏មាន ជាអនាគាមិនី ក៏មាន ម្នាលភិក្ខុទាំងឡាយ ឧបាសិកាទាំងអស់នោះដែលធ្វើកាលកិរិយា មិនមែនឥតផលទេ ។

លុះព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

**មោហសម្ពន្ធនោ លោកោ ភព្វរូបោវ ទិស្សតិ**
**ឧបធិពន្ធនោ ពាលោ តមសា បរិវារិតោ**
**សស្សតោរិវ ខាយតិ បស្សតោ នត្ថិ កិញ្ចនំ ។**

*សត្វលោកមានមោហៈជាចំណង ប្រាកដដូចជាមានរូបចម្រើន បុគ្គលពាល មានឧបធិក្កិលេសជាចំណង ត្រូវងងឹតគឺអវិជ្ជាចោមរោមហើយ ប្រាកដដូចជាទៀងទាត់ សេចក្តីកង្វល់ មានរាគៈជាដើម របស់បុគ្គលអ្នកពិចារណាឃើញ*

ច្បាស់ មិនមានទេ [១] ។

ព្រះសាស្តា កាលទ្រង់ត្រាស់យ៉ាងនេះហើយ ទ្រង់សម្តែងធម៌ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាសត្វទាំងឡាយ អន្ទោលទៅក្នុងវដ្តៈ ជាអ្នកមិនប្រមាទអស់កាលជានិច្ច ធ្វើបុញ្ញកម្មតែម្យ៉ាង ក៏ទេ ជាបុគ្គលមានសេចក្តីប្រមាទ ធ្វើបាបកម្ម ក៏មាន ព្រោះហេតុនោះ សត្វដែលត្រាច់ទៅក្នុងវដ្តៈ ទើបសោយសុខខ្លះ ទុក្ខខ្លះ ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ថា ដំណាក់របស់ព្រះនាងសាមាវតីត្រូវភ្លើងឆេះ ទ្រង់ប្រញាប់យាងមក ក៏មិនអាចទាន់ដំណាក់ដែលភ្លើងមិនទាន់ឆេះបាន កាលយាងមកដល់ហើយ ទ្រង់ញ៉ាំងដំណាក់ឲ្យរលត់ហើយ ទ្រង់កើតទោមនស្សដ៏មានកម្លាំង ចោមរោមដោយពួកអាមាត្យ គង់រឭករឿយ ៗ នូវគុណរបស់ព្រះនាងសាមាវតី ទ្រង់ព្រះតម្រិះថា នេះជាការធ្វើរបស់អ្នកណាហ្ន៎ ដូច្នេះហើយ ទ្រង់ជ្រាបថា កម្មនេះ គឺជាកម្មដែលនាងមាគណ្ឌិយាឲ្យធ្វើហើយ ទ្រង់ព្រះតម្រិះថា នាងមាគណ្ឌិយានេះ បើអញធ្វើឲ្យភ័យខ្លាចហើយសួរ គង់មិនប្រាប់ អញនឹងសួរដោយឧបាយសន្សឹម ៗ ទើបត្រាស់នឹងអាមាត្យទាំងឡាយថា នៃអ្នកដ៏ចម្រើនទាំងឡាយ ក្នុងកាលមុន យើងក្រោកឡើងហើយ ជាអ្នកសង្ស័យដោយជុំវិញតែម្យ៉ាង នាងសាមាវតីស្វែងរកទោសយើងជានិច្ច ឥឡូវនេះ នាង

---

១-បិ.៥២ ទំ.៣១៨ ឃ.១៥៧ ។

ក៏ស្លាប់ទៅហើយ យើងនឹងត្រជាក់ចិត្តបាន យើងនឹងបាននៅដោយសេចក្ដីសុខ ។

អាមាត្យទាំងឡាយក្រាបទូលសួរថា បពិត្រព្រះសម្មតិទេព កម្មនេះ អ្នកណាហ្ន៎ ធ្វើហើយ ។ ព្រះរាជាត្រាស់តបថា គឺបុគ្គលណាមួយធ្វើហើយដោយសេចក្ដីស្រឡាញ់ក្នុងយើង ។

ព្រះនាងមាគណ្ឌិយាឈរគាល់ក្នុងទីជិត ស្ដាប់ព្រះតម្រាស់នោះហើយ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព អ្នកដទៃមិនអាចធ្វើបានកម្មនេះ ខ្ញុំម្ចាស់ធ្វើហើយ ខ្ញុំម្ចាស់ប្រើឪពុកមាឲ្យធ្វើ ។

ព្រះរាជាត្រាស់តបថា ឈ្មោះថា សត្វមានសេចក្ដីស្រឡាញ់ក្នុងយើងដទៃ លើកទុកចុះ ក្រៅអំពីនាង រមែងមិនមាន យើងពេញចិត្ត នែទេវី យើងនឹងឲ្យពរដល់នាង នាងចូរឲ្យគេហៅពួកញាតិរបស់ខ្លួនមក ។

នាងមាគណ្ឌិយាបញ្ជូនដំណឹងទៅប្រាប់ពួកញាតិថា ព្រះរាជាទ្រង់សព្វព្រះហឫទ័យនឹងព្រះរាជទានពរដល់ខ្ញុំ ចូរប្រញាប់មក ។ ព្រះរាជាបញ្ជាឲ្យធ្វើសក្ការៈធំ ដល់ញាតិទាំងឡាយរបស់នាងមាគណ្ឌិយា ដែលមកហើយ សូម្បីពួកជនដែលមិនមែនញាតិរបស់នាងមាគណ្ឌិយា ឃើញសក្ការៈនោះហើយ ក៏ឲ្យសំណូកពោលថា ពួកខ្ញុំជាញាតិរបស់ព្រះនាងមាគណ្ឌិយា នាំគ្នាមកហើយ ។ ព្រះរាជាបញ្ជាឲ្យចាប់មនុស្សទាំងនោះទុក ហើយឲ្យជីករណ្ដៅទាំងឡាយប្រមាណត្រឹមផ្ចិត ត្រង់លានព្រះរាជ

រាំង ហើយឲ្យមនុស្សទាំងនោះអង្គុយចុះ ក្នុងរណ្តៅទាំងនោះ យកដីលុប ឲ្យដាក់ចំបើងអំពីខាងលើ ហើយដុតភ្លើង ក្នុងពេលដែលស្បែកត្រូវភ្លើង ឆេះហើយ បញ្ជាឲ្យភ្ជួរដោយនង្គ័លដែកទាំងឡាយ ធ្វើឲ្យជាកំណាត់តូច និងកំណាត់ធំ ឲ្យជាចម្រៀកតូចនិងចម្រៀកធំ ។ ព្រះរាជាទ្រង់បញ្ជាឲ្យ ចៀរសាច់អំពីសរីរៈរបស់នាងមាគណ្ឌិយា ត្រង់ទីដែលមានសាច់ ដោយ កាំបិតដ៏មុត ហើយឲ្យលើកឡើងកាន់ជើងក្រាន ដែលមានផ្ទាំងក្តៅ ដោយខ្លាញ់ ឲ្យចៀនដូចនំ ហើយឲ្យនាងមាគណ្ឌិយាទំពាស៊ីសាច់ខ្លួន ឯងនោះវិញ ។

តមក ថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោ ទាំងឡាយ ការស្លាប់ដូច្នេះ របស់ឧបាសិកាដែលដល់ព្រមដោយសទ្ធា បែបនេះ មិនសមគួរសោះហ្ន៎ ។ ព្រះសាស្តាស្តេចយាងមក ទ្រង់ត្រាស់ សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំ គ្នាដោយកថាអ្វីហ្ន៎ ។ កាលពួកភិក្ខុទាំងនោះ ក្រាបបង្គំទូលថា ដោយ កថាឈ្មោះនេះ ព្រះអង្គ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការស្លាប់ របស់ស្រីទាំងឡាយនោះ មាននាងសាមាវតីជាប្រធាន មិនគួរហើយក្នុង អត្តភាពនេះ តែការស្លាប់របស់ស្រីទាំងនោះ សមគួរដល់កម្មដែលនាងធ្វើ ទុកក្នុងកាលមុន កាលភិក្ខុទាំងនោះ ក្រាបបង្គំទូលអារាធនាថា បពិត្រ ព្រះអង្គដ៏ចម្រើន កម្មអ្វីដែលស្រីទាំងនោះ ធ្វើទុកក្នុងកាលមុន សូមទ្រង់

ត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គទាំងឡាយ ទើបទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល ស្តេចព្រហ្មទត្តគ្រងរាជសម្បត្តិក្នុងនគរពារាណសី ព្រះបច្ចេកពុទ្ធ ៨ អង្គ ឆាន់ក្នុងព្រះរាជវាំងជានិច្ច ស្រី ៥០០ នាក់ ទំនុកបម្រុងព្រះបច្ចេកពុទ្ធទាំងនោះ ។ បណ្តាព្រះបច្ចេកពុទ្ធទាំងនោះ ព្រះបច្ចេកពុទ្ធ ៧ អង្គ ទៅកាន់ហិមវន្តប្បទេស មួយអង្គទៀត អង្គុយចូលឈានត្រង់ទីស៊ុមទ្រុមដោយស្មៅមួយកន្លែង ក្បែរមាត់ស្ទឹង ។ សម័យថ្ងៃមួយ កាលព្រះបច្ចេកពុទ្ធទាំងឡាយទៅហើយ ព្រះរាជានាំស្រីទាំងនោះទៅ ដើម្បីលេងទឹកក្នុងស្ទឹង ។ ក្នុងទីនោះ ស្រីទាំងនោះលេងទឹករហូតអស់ចំណែកនៃថ្ងៃ ឡើងមកហើយ ត្រូវរងាបៀតបៀន ប្រាថ្នានឹងអាំងភ្លើង ពោលថា អ្នកទាំងឡាយ គប្បីរកទីសម្រាប់បង្កាត់ភ្លើងរបស់ពួកយើង ដើរទៅមក ៗ ឃើញទីស៊ុមទ្រុមដោយស្មៅនោះ ទើបឈរជុំវិញ បង្កាត់ភ្លើងហើយដោយសម្គាល់ថា ជាគំនរស្មៅ ។ កាលស្មៅទាំងឡាយឆេះហើយក៏រលត់ ស្រីទាំងនោះឃើញព្រះបច្ចេកពុទ្ធ ទើបពោលថា ពួកយើងវិនាសហើយ ព្រះបច្ចេកពុទ្ធរបស់ព្រះរាជាត្រូវភ្លើងឆាបឆេះ កាលព្រះរាជាទ្រង់ជ្រាប នឹងធ្វើពួកយើងឲ្យវិនាស យើងនឹងដុតលោកឲ្យឆេះទាំងអស់ ។ ជនទាំងនោះ នាំឧសមកអំពីទិសផ្សេង ៗ ធ្វើឲ្យជាគំនរខាងលើនៃព្រះបច្ចេកពុទ្ធនោះ គំនរឧសធំ បានកើតមានហើយ ។ លំដាប់នោះ ស្រីទាំងនោះ ដុតគំនរឧសហើយចៀសចេញទៅ ដោយសម្គាល់ថា នឹងឆេះ

អស់ឥឡូវនេះ ។ មុនដំបូង ស្រីទាំងនោះ ជាអ្នកមិនមានចេតនា ទើបមិនត្រូវចំណែងកម្ម តែក្រោយមក ត្រូវចំណែងកម្ម ព្រោះមានចេតនាហើយ ។ មនុស្សទាំងឡាយនាំឧសមួយពាន់រទេះមកដុត ក៏មិនអាចធ្វើព្រះបច្ចេកពុទ្ធដែលនៅក្នុងសមាបត្តិ ឲ្យមានអាការៈ ត្រឹមតែក្តៅបាន ។ ព្រោះហេតុនោះ ព្រះបច្ចេកពុទ្ធនោះ ក្នុងថ្ងៃទី ៧ ក៏ក្រោកឡើងទៅតាមសប្បាយហើយ ។ ស្រីទាំងនោះ ឆេះក្នុងនរកអស់ច្រើនសែនឆ្នាំ ព្រោះកម្មដែលធ្វើទុកហើយ ឆេះហើយក្នុងផ្ទះដែលត្រូវភ្លើងឆេះ ដោយទំនងនេះ អស់មួយរយអត្តភាព ដោយវិបាកដ៏សេសនៃកម្មនោះឯង ។ នេះជាបុព្វកម្មរបស់ស្រីទាំងនោះ ដោយប្រការដូច្នេះ ។

កាលព្រះសាស្តាត្រាស់យ៉ាងនោះហើយ ភិក្ខុទាំងឡាយក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ចំណែកនាងខុជ្ជុត្តរានោះ តើព្រោះកម្មដូចម្តេច ទើបកើតជាស្រីគម ព្រោះកម្មដូចម្តេច ទើបមានបញ្ញាច្រើន ព្រោះកម្មដូចម្តេច ទើបសម្រេចសោតាបត្តិផល ព្រោះកម្មដូចម្តេច ទើបកើតជាអ្នកបម្រើរបស់អ្នកដទៃ ។

ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដែលព្រះរាជាអង្គនោះឯង សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះបច្ចេកពុទ្ធអង្គនោះឯង បានជាបុគ្គលមានធាតុនៃមនុស្សគមបន្តិច ។ លំដាប់នោះស្រីឧបដ្ឋាកយិកាម្នាក់ ដណ្តប់សំពត់កម្ពល កាន់ផ្តិលមាស ធ្វើជាមនុស្ស

គម សម្តែងអាកប្បកិរិយាត្រាច់ទៅនៃព្រះបច្ចេកពុទ្ធអង្គនោះ ដោយពោលថា ព្រះបច្ចេកពុទ្ធរបស់ពួកយើង រមែងត្រាច់ទៅយ៉ាងនេះ យ៉ាងនេះ ។ ព្រោះផលដែលហូរចេញអំពីកម្មនោះ ទើបនាងជាស្រីគម ។

ម្យ៉ាងទៀត ក្នុងថ្ងៃដំបូង ព្រះរាជាទ្រង់និមន្តព្រះបច្ចេកពុទ្ធទាំងនោះ ឲ្យគង់ក្នុងព្រះរាជនិវេសន៍ ឲ្យរាជបុរសទទួលបាត្រ ដាក់បាត្រឲ្យពេញដោយបាយាស ហើយប្រគេន ។ ព្រះបច្ចេកពុទ្ធទាំងឡាយ កាន់បាត្រដែលពេញដោយបាយាសក្តៅ ត្រូវផ្លាស់ប្តូរដៃរឿយ ៗ ស្រីនោះឃើញលោកធ្វើយ៉ាងនេះ ក៏ប្រគេនកងដៃភ្លុក ៨ ដែលជារបស់ផ្ទាល់ខ្លួនដោយពោលថា សូមលោកម្ចាស់ដាក់ (បាត្រ) លើកងដៃនេះ ហើយកាន់យក ។ ព្រះបច្ចេកពុទ្ធទាំងនោះ ធ្វើយ៉ាងនេះ ហើយសម្លឹងមើលស្រីនោះ ។ នាងដឹងបំណងរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ទើបពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនមានសេចក្តីត្រូវការកងទាំងនេះឡើយ ខ្ញុំបរិច្ចាគកងទាំងនេះ ដល់លោកម្ចាស់ទាំងឡាយហើយ សូមលោកម្ចាស់ទទួលចុះ ។ ព្រះបច្ចេកពុទ្ធទាំងនោះទទួលហើយ បានទៅកាន់ញកភ្នំនន្ទមូលកៈ ។ សូម្បីសព្វថ្ងៃនេះ កងទាំងនោះ ក៏នៅតែល្អនោះឯង ។ ព្រោះផលដែលហូរចេញអំពីកម្មនោះ ក្នុងកាលឥឡូវនេះ ទើបនាងជាអ្នកទ្រទ្រង់ព្រះត្រៃបិដក មានបញ្ញាច្រើន ព្រោះផលដែលហូរចេញអំពីការបម្រើ ដែលនាងធ្វើចំពោះព្រះបច្ចេកពុទ្ធទាំងឡាយ ទើបនាងសម្រេច

សោតាបត្តិផល ។ នេះជាបុព្វកម្មក្នុងពុទ្ធន្តរ ( ចន្លោះព្រះពុទ្ធ ) របស់នាង ។

ចំណែកក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធកស្សបៈ កូនស្រីរបស់សេដ្ឋីក្រុងពារាណសីម្នាក់ ចាប់កញ្ចក់ អង្គុយតែងខ្លួនក្នុងកាលមានស្រមោលចម្រើន គឺពេលរសៀល ។ លំដាប់នោះ ភិក្ខុនីជាព្រះខីណាស្រពមួយរូប ជាអ្នកស្និទ្ធស្នាលរបស់នាង បានទៅដើម្បីសួរសុខទុក្ខ ។ មែនពិតភិក្ខុនី សូម្បីជាព្រះខីណាស្រព ក៏ជាអ្នកប្រាថ្នាដើម្បីឃើញត្រកូលឧបដ្ឋាកក្នុងពេលល្ងាច ។ ក្នុងខណៈនោះ ស្រីបម្រើណាមួយក្នុងសម្នាក់របស់សេដ្ឋីធីតានោះ មិនមានឡើយ ទើបនាងពោលថា ខ្ញុំសូមថ្វាយបង្គំអ្នកនាងម្ចាស់ សូមហុចកំប្រោងគ្រឿងប្រដាប់នោះ ឲ្យដល់ខ្ញុំបន្តិច ។

ព្រះថេរីគិតថា បើអញមិនហុចកំប្រោងនេះ ឲ្យដល់នាងសោត នាងនឹងធ្វើអាឃាតក្នុងអាត្មាអញ ហើយកើតក្នុងនរក តែបើអញហុចឲ្យនាង នាងក៏នឹងកើតជាស្រីបម្រើរបស់អ្នកដទៃ តែការកើតជាអ្នកបម្រើរបស់អ្នកដទៃ គង់ប្រសើរជាងការក្តៅក្រហាយក្នុងនរក ។ ព្រះថេរីនោះអាស្រ័យករុណា ទើបហុចកំប្រោងគ្រឿងប្រដាប់នោះ ឲ្យដល់នាង ។ ព្រោះផលនៃកម្មនោះ ទើបនាងបានជាអ្នកបម្រើរបស់អ្នកដទៃ ។

ស្អែកឡើង ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា ស្រី ៥០០ មានព្រះនាងសាមាវតីជាប្រធាន ត្រូវភ្លើងឆេះហើយ ក្នុងព្រះរាជដំណាក់

ពួកញាតិរបស់នាងមាគណ្ឌិយា ត្រូវដុតដោយចំបើង ដែលគ្របខាងលើ ហើយទម្លាយដោយនង្គ័លដែក នាងមាគណ្ឌិយាត្រូវចៀនដោយខ្ទះដ៏ក្តៅ បណ្តាមនុស្សទាំងនោះ អ្នកណាហ្ន៎ ឈ្មោះថា រស់នៅ អ្នកណាហ្ន៎ ឈ្មោះថា ស្លាប់ហើយ ។

ព្រះសាស្តាស្តេចយាងមក ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ ។ កាលពួកភិក្ខុទាំងនោះក្រាបបង្គំទូលថា ដោយកថាឈ្មោះនេះ ព្រះអង្គ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយប្រមាទហើយ បុគ្គលនោះ សូម្បីរស់នៅមួយរយឆ្នាំ ក៏ឈ្មោះថា ស្លាប់ហើយដោយពិត បុគ្គលណា មិនប្រមាទ បុគ្គលនោះ ទោះបីស្លាប់ហើយ ក៏ឈ្មោះថា រស់នៅ ព្រោះហេតុនោះ នាងមាគណ្ឌិយា សូម្បីរស់នៅ ក៏ឈ្មោះថា ស្លាប់ហើយមែនពិត ស្រី ៥០០ មាននាងសាមាវតីជាប្រធាន សូម្បីស្លាប់ហើយ ក៏ឈ្មោះថា រស់នៅមែនពិត ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលមិនប្រមាទ ឈ្មោះថា មិនស្លាប់ ដូច្នេះហើយ ទ្រង់ត្រាស់ព្រះគាថាទាំងឡាយនេះថា

**អប្បមាទោ អមតំបទំ បមាទោ មច្ចុនោ បទំ**
**អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា ។**

សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទ

*ជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយដែលមិនប្រមាទហើយ ឈ្មោះថា មិនស្លាប់ ជនទាំងឡាយដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។*

ឯតំ វិសេសតោ ញត្វា អប្បមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ អរិយានំ គោចរេ រតា ។

*ពួកបណ្ឌិតបានជ្រាបនូវដំណើរនេះ ដោយប្លែកគ្នា ( ទើបឋិតនៅ ) ក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរក្នុងធម៌ជាគោចរនៃអរិយបុគ្គលទាំងឡាយ ។*

តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា
ផុសន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ ។

*មានការពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញា តែងប៉ះពាល់នូវព្រះនិព្វានជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាតដ៏ប្រសើរបំផុត*(១) ។

## ឃោសកសេដ្ឋី ចប់ (២)

---

*១-បិ.៥២ ទំ.២៥ ឃ.១២ ។ ២- ស្រង់ចាកអដ្ឋកថា ធម្មបទ សាមាវតីវត្ថុ ។*

# សុត្តប្រេត

បានឮថា ក្នុងស្រុកមួយ មិនឆ្ងាយអំពីក្រុងសាវត្ថី មុនពេលព្រះសាស្តារបស់យើងទ្រង់កើតឡើង ៧០០ ឆ្នាំ មានទារកម្នាក់ ជាឧបដ្ឋាករបស់ **ព្រះបច្ចេកពុទ្ធ** មួយអង្គ ។ កាលចម្រើនវ័យហើយមាតារបស់ទារកនោះ ទៅសូមកុលធីតាម្នាក់មកអំពីត្រកូលស្មើគ្នា ដើម្បីជាប្រយោជន៍ដល់បុត្តនោះ ។ ក្នុងថ្ងៃរៀបការនោះឯង កុមារនោះ ទៅងូតទឹកជាមួយសម្លាញ់ ត្រូវពស់ចឹកស្លាប់ទៅ ។ អាចារ្យពួកខ្លះពោលថាត្រូវយក្ខចាប់ ក៏មាន ។ កុមារនោះ ធ្វើកុសលកម្មទុកច្រើន ដោយការឧបដ្ឋាកព្រះបច្ចេកពុទ្ធ ដោយអំណាចខ្លួនមានចិត្តប្រតិព័ទ្ធក្នុងទារិកានោះ ទើបកើតជាវេមានិកប្រេត តែជាប្រេតមានឫទ្ធិច្រើន មានអានុភាពច្រើន ។

លំដាប់នោះ វេមានិកប្រេតនោះ ប្រាថ្នានឹងនាំទារិកានោះ មកកាន់វិមានរបស់ខ្លួន គិតថា ដោយឧបាយដូចម្តេចហ្ន៎ ទើបនាងអាចធ្វើកម្មដែលត្រូវឲ្យផលក្នុងបច្ចុប្បន្ន ហើយមកត្រេកអរក្នុងទីនេះជាមួយអញទើបពិចារណាដល់ហេតុ ដែលបានសោយភោគសម្បត្តិដែលជាទិព្វនោះ ឃើញព្រះបច្ចេកពុទ្ធកំពុងធ្វើចីវរកម្ម ទើបនិម្មិតខ្លួនជាមនុស្សទៅថ្វាយបង្គំ ហើយពោលថា **កឹ ភន្តេ សុត្តកោន អត្ថោ អត្ថិ** បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ត្រូវការអំបោះឬ ។

*ព្រះបច្ចេកពុទ្ធឆ្លើយថា* **ចីវរកម្មំ ករោមិ ឧបាសក** *អាត្មាធ្វើចីវរកម្ម ឧបាសក ។ វេមានិកប្រេតនោះ ក៏ពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់ស្វែងរកអំបោះ ក្នុងទីឈ្មោះនោះ ដូច្នេះហើយ ក៏ចង្អុលផ្ទះរបស់កុមារិកានោះ ។ ព្រះបច្ចេកពុទ្ធបានទៅក្នុងទីនោះ ហើយឈរត្រង់ទ្វារផ្ទះ ។ លំដាប់នោះ ទារិកាឃើញព្រះបច្ចេកពុទ្ធឈរក្នុងទីនោះ មានចិត្តជ្រះថ្លា ដឹងថា លោកម្ចាស់របស់យើងមានសេចក្តីត្រូវការអំបោះ ទើបប្រគេនអំបោះមួយដុំ ។ លំដាប់នោះ អមនុស្សនោះបានកាឡាខ្លួនជាមនុស្ស ទៅកាន់ផ្ទះរបស់ទារិកា អង្វរមាតារបស់នាងហើយនៅជាមួយនាង ពីរបីថ្ងៃ ដើម្បីអនុគ្រោះដល់មាតារបស់នាង ទើបធ្វើភាជនៈគ្រប់យ៉ាងក្នុងផ្ទះនោះ ឲ្យពេញដោយប្រាក់និងមាស ហើយសរសេរឈ្មោះទុកលើភាជនៈទាំងអស់នោះ ដោយសេចក្តីថា នេះជាទ្រព្យដែលទេវតាឲ្យ អ្នកដទៃមិនគួរដណ្តើមយក ដូច្នេះហើយ នាំទារិកានោះ ទៅកាន់វិមានរបស់ខ្លួន ។ មាតារបស់នាងបានទ្រព្យជាច្រើន ឲ្យដល់ពួកញាតិរបស់ខ្លួន មនុស្សកំព្រានិងអ្នកដំណើរជាដើម ចំណែកខ្លួនបរិភោគហើយ កាលជិតធ្វើកាលកិរិយា បានផ្តាំពួកញាតិទាំងឡាយថា បើកូនស្រីរបស់ខ្ញុំមក សូមឲ្យទ្រព្យនេះ ហើយក៏ស្លាប់ទៅ ។*

*ក្នុងកាលកន្លងទៅ ៧០០ ឆ្នាំ បន្ទាប់អំពីកាលនោះ ព្រះមានព្រះភាគនៃយើង ទ្រង់កើតឡើងក្នុងលោក ទ្រង់ប្រកាសធម្មចក្កដ៏បវរ*

*ប្រថាប់គង់នៅក្នុងនគរសាវត្ថីដោយលំដាប់ កាលស្រីនោះ នៅរួមជាមួយអមនុស្សនោះ ការអផ្សុកក៏កើតឡើង ។ នាងពោលនឹងអមនុស្សនោះថា អយ្យបុត្ត សូមលោកនាំខ្ញុំត្រឡប់ទៅកាន់ផ្ទះវិញ ដូច្នេះហើយ បានពោលគាថាទាំងនេះថា*

**អហំ បុរេ បព្វជិតស្ស ភិក្ខុនោ សុត្តំ**
**អទាសិ ឧបគម្ម យាចិតា តស្ស**
**វិបាកោ វិបុលំ ផលូបលព្ភតិ**
**ពហូ ច មេ ឧប្បជ្ជរេ វត្ថកោដិយោ ។**

*ក្នុងកាលមុន បព្វជិតភិក្ខុ គឺព្រះបច្ចេកពុទ្ធ បានចូលមកសុំអំបោះ ខ្ញុំក៏បានប្រគេន (ឥឡូវនេះ) ខ្ញុំបានផលនៃការប្រគេនអំបោះនោះ ជាផលចម្រើនលើសលុប ទាំងសំពត់ច្រើនកោដិ ក៏កើតឡើងដល់ខ្ញុំ ។*

**បុប្ផាភិកិណ្ណំ រមិតំ វិមានំ**
**អនេកចិត្តំ នរនារិសេវិតំ**
**សាហំ ភុញ្ជាមិ ច ចារុចាមិ ច**
**បហូតវិត្តា ន ច តាវ ខីយតិ ។**

*ខ្ញុំនោះ បានប្រើប្រាស់នូវវិមានជាទីត្រេកអរ ដ៏ដេរដាសដោយផ្កា វិចិត្រដោយកែវច្រើនយ៉ាង ដែលជនប្រុសស្រី*

សេពហើយផង បានស្លៀកដណ្តប់ ( សំពត់តាមចំណង់ )
ផង ទាំងទ្រព្យដ៏ច្រើន ក៏មិនចេះអស់ផង ។

តស្សេវ កម្មស្ស វិបាកមន្វយា
សុខញ្ច សាតញ្ច ឥធូបលព្ភតិ
សាហំ គន្ត្វា បុនទេវ មានុសំ
កាហាមិ បុញ្ញានិ នយយ្យបុត្ត មំ ។

ខ្ញុំបានសេចក្តីសុខនិងសេចក្តីស្រួល ក្នុងវិមាននេះ ព្រោះ
អាស្រ័យផលនៃកម្មនោះឯង ខ្ញុំនោះ នឹងទៅកាន់មនុស្ស
លោកវិញ ហើយធ្វើបុណ្យទាំងឡាយ បពិត្រព្រះអយ្យបុត្ត
សូមអ្នកនាំខ្ញុំទៅ ( ឯមនុស្សលោកចុះ ) ។

អមនុស្សនោះ កាលបានស្តាប់ដូច្នោះហើយ មិនប្រាថ្នានឹងឲ្យទៅ ដោយសេចក្តីអនុគ្រោះ ព្រោះអំណាចដែលខ្លួនមានចិត្តប្រតិព័ទ្ធក្នុងភរិយា ទើបពោលគាថាថា

សត្ត តុវំ វស្សសតា ឥធាគតា
ជិណ្ណា ច វុឌ្ឍា ច តហឹ ភវិស្សសិ
សព្វេវ តេ កាលកតា ច ញាតកា
ត្វំ តត្ថ គន្ត្វាន ឥតោ ករិស្សសិ ។

នាងមកក្នុងវិមាននេះ បាន ៧០០ ឆ្នាំហើយ ( បើនាង

ទៅអំពីទីនេះវិញ ទៅនៅ) ក្នុងមនុស្សលោកនោះ នឹង
គ្រាំគ្រាចាស់ ពួកញាតិរបស់នាងទាំងអស់ ស្លាប់អស់
ហើយ ( ព្រោះហេតុនោះ ) នាងនឹងទៅអំពីទេវលោក
នេះ ធ្វើអ្វី ក្នុងមនុស្សលោកនោះ ។

អធិប្បាយថា នាងមានអត្តភាពដែលឧតុនិងអាហារជាទិព្វ ឧបត្ថម្ភក្នុងវិមាននេះ តាំងនៅដោយអាការក្មេងខ្ចីដដែល អស់កាលមានប្រមាណប៉ុណ្ណោះ ដោយអានុភាពនៃកម្ម ។ម្យ៉ាងទៀត កាលនាងទៅអំពីទេវលោកនេះ នឹងក្លាយជាមនុស្សចាស់ជរា តាមវ័យក្នុងមនុស្សលោកនោះ ព្រោះកម្មអស់ទៅ និងព្រោះអំណាចនៃឧតុ និងអាហាររបស់មនុស្ស ។ ដើម្បីចៀសវាងនូវពាក្យសួរថា តើសេចក្តីនេះដូចម្តេច ទើបវេមានិកប្រេតពោលថា ពួកញាតិទាំងអស់របស់នាង ស្លាប់អស់ហើយ អធិប្បាយថា ញាតិរបស់នាងទាំងអស់នោះឯង ស្លាប់ទៅអស់ហើយ ព្រោះកាលកន្លងទៅយូរ ហេតុនោះ នាងចេញអំពីទេវលោកនេះ ទៅកាន់មនុស្សលោកនោះ នឹងធ្វើអ្វីក្នុងមនុស្សលោកនោះ អធិប្បាយថា ចូរនាងញុំាងអាយុឲ្យអស់ទៅក្នុងទីនេះ កុំឲ្យសេសសល់ គឺចូរនៅក្នុងទីនេះ ។

ស្រីនោះ កាលអមនុស្សពោលហើយយ៉ាងនេះ មិនស្តាប់ពាក្យនៃអមនុស្សនោះ ទើបពោលគាថាទៀតថា

**សត្តេវ វស្សានិ ឥធាគតាយ មេ**

ទិព្វញ្ច សុខញ្ច សមប្បិតាយ
សាហំ គន្ត្វា បុនរេវ មានុសំ
កាហាមិ បុញ្ញានិ នយេយ្យបុត្ត មំ ។

*ខ្ញុំបានមកក្នុងវិមាននេះ ជាស្រីបរិបូណ៌ដោយវត្ថុទិព្វ និងសេចក្តីសុខអស់ត្រឹម ៧ ឆ្នាំ ខ្ញុំនោះនឹងទៅកាន់មនុស្សលោកវិញ ហើយធ្វើបុណ្យទាំងឡាយ បពិត្រព្រះអយ្យបុត្ត សូមអ្នកនាំខ្ញុំទៅចុះ ។*

*ក្នុងគាថានេះ មានអធិប្បាយថា បពិត្រអយ្យបុត្ត កាលខ្ញុំនៅក្នុងទីនេះ ប្រហែលជាកន្លងទៅត្រឹម ៧ ឆ្នាំ ។ នាងកំណត់កាលដែលកន្លងទៅដ៏ច្រើន មិនបាន ទើបពោលយ៉ាងនេះ ព្រោះអំណាចដែលខ្លួនដល់ព្រមដោយទិព្វសម្បត្តិនិងសុខសម្បត្តិ ដល់ទៅ ៧០០ ឆ្នាំ ។*

*វេមានិកប្រេតនោះ កាលនាងរំអុកយ៉ាងនេះហើយ ទើបប្រៀនប្រដៅ មានប្រការផ្សេង ៗ ហើយពោលថា ឥឡូវនេះ នាងមិននៅក្នុងទីនោះ លើស ៧ ថ្ងៃ ទ្រព្យដែលយើងឲ្យម្តាយរបស់នាងកប់ទុក មាន ចូរនាងឲ្យទ្រព្យនោះ ដល់សមណព្រាហ្មណ៍ ហើយប្រាថ្នាមកកើតក្នុងទីនេះវិញ ទើបចាប់ដើមដៃ នាំមកដាក់កណ្តាលស្រុក ពោលថា ចូរនាងប្រាប់ជនដទៃដែលមកកាន់ទីនេះថា អ្នកទាំងឡាយ ចូរធ្វើបុណ្យតាមកម្លាំងចុះ ដូច្នេះហើយ ក៏ទៅវិញ ។*

ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា

**សោ តំ គហេត្វាន បសយ្ហ ពាហាយំ**

**បច្ចានយិត្វាន បុរេ ថេរី សុទុព្វលំ**

**វជ្ជេសិ អញ្ញំបិ ជនំ ឥធាគតំ**

**ករោថ បុញ្ញានិ សុខូបលព្ភតិ ។**

វេមានិកប្រេតនោះ ក៏កំហែងចាប់ស្រីនោះ ត្រង់ដើមដៃនាំមក ( កាន់ស្រុកផៅពង្ស ) វិញ ហើយនិយាយនឹងស្រីចាស់មានកម្លាំងទន់ខ្សោយនោះថា នាងត្រូវប្រាប់ដល់ជនដទៃទៀត ដែលមកក្នុងទីនេះថា អ្នកទាំងឡាយ ចូរធ្វើបុណ្យទាំងឡាយ អ្នកទាំងឡាយ នឹងបានសេចក្ដីសុខ ។

បានឮថា ក្នុងលំដាប់នៃការចេញអំពីវិមានប៉ុណ្ណោះ នាងក៏ក្លាយជាមនុស្សចាស់គ្រាំគ្រា ជរា ទុព្វលភាព ព្រោះមានវ័យកន្លងទៅ ទើបវេមានិកប្រេតនោះ ប្រាប់ថា នែនាងដ៏ចម្រើន នាងគប្បីធ្វើបុណ្យ សូម្បីមនុស្សដែលមកកាន់ទីនេះ ដើម្បីសួរសុខទុក្ខ នាងក៏គប្បីពោលទូន្មានថា នែអ្នកមានមុខល្អ ចូរសម្លឹងមើលសីសៈ ឬសំពត់ដែលត្រូវភ្លើងឆេះ ហើយបំពេញបុណ្យ មានទាននិងសីលជាដើម និងប្រាប់ថា កាលធ្វើបុណ្យហើយ អ្នកនឹងបានទទួលសេចក្ដីសុខ ដែលជាផលនៃបុណ្យនោះ ដោយពិតប្រាកដ មិនគួរធ្វើសេចក្ដីសង្ស័យក្នុងបុណ្យនោះឡើយ ។

កាលវេមានិកប្រេតនោះ ពោលយ៉ាងនេះហើយ ទើបទៅ ស្រីនោះ ទៅកាន់លំនៅពួកញាតិរបស់ខ្លួន ឲ្យញាតិទាំងនោះ ស្គាល់ខ្លួនហើយ ទើបកាន់យកទ្រព្យទាំងនោះ ដែលញាតិប្រគល់ឲ្យ កាលនឹងឲ្យទានដល់សមណៈនិងព្រាហ្មណ៍ ទើបបានឲ្យឱវាទដល់ពួកជនដែលមកហើយកាន់សម្នាក់ខ្លួន ដោយគាថានេះថា

**ទិដ្ឋា មយា អកតេន សាធុនា**
**បេតា វិហញ្ញន្តិ តថេវ មានុសា**
**កម្មញ្ច កត្វា សុខវេទនីយំ**
**ឋេរា មនុស្សា ច សុខេ ឋិតា បជា ។**

ពួកប្រេតដែលខ្ញុំបានឃើញហើយ ជាអ្នកមានអំពើល្អមិនបានធ្វើ តែងលំបាក យ៉ាងណាមិញ ពួកមនុស្សក៏យ៉ាងនោះដែរ ពួកសត្វ គឺទេវតានិងមនុស្ស ដែលបានធ្វើកម្មមានសេចក្តីសុខជាកម្រៃហើយ តែងតាំងនៅក្នុងសេចក្តីសុខ ។

ក្នុងសេចក្តីនេះ មានអធិប្បាយដូច្នេះថា ខ្ញុំឃើញពួកមនុស្សក្តៅក្រហាយ ព្រោះមិនបានធ្វើកុសលទុក ធ្វើតែអកុសល ដល់នូវការលំបាកដោយការឃ្លាននិងការស្រេកជាដើម សោយទុក្ខយ៉ាងមហន្ត (ធំ) ដូចពួកប្រេត ។ ម្យ៉ាងទៀត ខ្ញុំបានឃើញពួកជនដែលរាប់បញ្ចូលក្នុងទេវតានិងមនុស្ស អ្នកធ្វើកម្មដែលជាហេតុឲ្យនូវសេចក្តីសុខ ដោយកុសលកម្ម

ដែលខ្លួនធ្វើទុកនោះ និងអកុសលកម្មដែលខ្លួនមិនបានធ្វើ តាំងនៅក្នុងសេចក្តីសុខ ហេតុនោះ បានប្រាកដច្បាស់ចំពោះខ្លួនឯង ព្រោះហេតុនោះ អ្នកទាំងឡាយ កាលវៀរនូវអំពើអាក្រក់ឲ្យឆ្ងាយហើយ ក៏ចូរប្រកបខ្វល់ខ្វាយក្នុងការបំពេញបុណ្យ ។

ស្រីនោះ កាលឲ្យឱវាទយ៉ាងនេះហើយ បានបំពេញមហាទានអស់ ៧ ថ្ងៃ ដល់សមណៈនិងព្រាហ្មណ៍ជាដើម ក្នុងថ្ងៃទី ៧ ស្លាប់ទៅកើតក្នុងស្ថានតាវត្តិង្ស ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលរឿងនោះ ចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់បានធ្វើរឿងនោះ ឲ្យជាអត្ថុប្បត្តិហេតុហើយ ទើបសម្តែងធម៌ដល់បរិស័ទដែលដល់ព្រមហើយ ។ តែពោលដោយការប្លែកគ្នា ទ្រង់ប្រកាសនូវភាពនៃទានដែលឲ្យក្នុងព្រះបច្ចេកពុទ្ធថា មានផលច្រើន មានអានិសង្សច្រើន ។ មហាជនបានស្តាប់ដូច្នោះហើយ ជាអ្នកប្រាសចាកសេចក្តីកំណាញ់ ដែលជាមន្ទិលត្រេកអរក្រៃលែងក្នុងបុណ្យ មានទានជាដើម ដូច្នេះឯង ៕

## សុត្តប្រេត ចប់ [១]

# បច្ចេកពុទ្ធសំយុត្តកថា ភាគទី ១ ចប់ ។

---

១-ស្រង់ចាកអដ្ឋកថា បេតវត្ថុ បិ.៥៦ ទំ.៥៧ ឃ.២៣ ។

# ព្រះនាម និងនាមពុទ្ធបរិស័ទ
# ជួយពិនិត្យសេចក្ដី និងអក្ខរាវិរុទ្ធ

*ព្រះភិក្ខុ ចន្ទប្បញ្ញោ ឌឹន តារា*
*ព្រះភិក្ខុ ធម្មកាម មិត្តសាន*
*ព្រះភិក្ខុ ពុទ្ធង្កុរ គុល ណារិន*
*ព្រះភិក្ខុ សុចិណ្ណោ ញិប យ័ន្ត*
*ព្រះភិក្ខុ រតនសារី វ៉េន ភិរម្យ*
*ព្រះភិក្ខុ ធម្មបញ្ញោ ម៉ុង ហេង*
*ព្រះភិក្ខុ វីរិយមុនី សួម កុសល្យ*
*លោកគ្រូធម្មាចារ្យ អ៊ឹម វ៉េយ៉ា*
*មហាសទ្ធម្មជោតិកៈ សុទ្ធរ៍ សាមៀន*
*លោកគ្រូធម្មាចារ្យ ហួយ វ៉ាន់ថន*
*ឧ.ស.ឡាន សុខុម*
*ឧ.សិ.ហេង ចន្ទរចនា*
*ឧ.សិ.ហេង ចន្ទបុញ្ញវន្តី ។*

# នាមពុទ្ធបរិស័ទវាយអត្ថបទ

*ឧ.សិ.ហេង ចន្ទរចនា* *ឧ.សិ.ហេង ចន្ទបុញ្ញវន្តី ។*

# នាមពុទ្ធបរិស័ទជួយឧបត្ថម្ភសម្ភារៈ
# សម្រាប់ការចារធម្មទាន

*ឧ.ស.ហេង វីរិន្ទ ឧ.ស.ហេង វណ្ណៈ ឧ.ស.ហេង វណ្ណា*
*ឧ.សិ.ហេង ចន្ទកុលសុកៈ ឧ.ស.ហេង រស្មី និងក្រុមគ្រួសារ ។*

# នាមពុទ្ធបរិស័ទដែលមានឧបការគុណ ក្នុងការខារធម្មទាន

ព្រះភិក្ខុ កទ្ធប្បញ្ញោ ឌុន គុណាធីម
ព្រះភិក្ខុ រាមបណ្ឌិតោ ហោ តូរ៉
ព្រះភិក្ខុ ឥន្ទ្រិយសំវរៈ ប៉ូ ផែន
ព្រះភិក្ខុ ធម្មបាលៈ ជឹម ជិត
ឧ.ស.ម៉េត សុម៉ារ៉ា
ឧ.សិ.រស់ គឹមថាន
ឧ.សិ.ជុន ស៊ូគី
ឧ.សិ.ហេង៏ចន្ទកុលសុកៈ
ឧ.សិ.លី ធីតា
ឧ.ស.លន់ សេង៏ឡុង
ឧ.សិ.ស្រីលក្ខណ៍
ឧ.ស.មង្គល បិតា
ឧ.សិ.ស្រី វណ្ណី
ឧ.សិ.ឡាច ធុំ ។

ព្រះភិក្ខុ រតននាថោ មាស សាពួន
ព្រះភិក្ខុ សីលសំវរៈ ប៉ុន មករា
ព្រះភិក្ខុ គម្ភីរប្បញ្ញោ រូ ច័ន្ទរតនា
លោកគ្រូធម្មាចារ្យ ហួយ វ៉ាន់ថន
ឧ.ស.ប៊ូ សុភាព
ឧ.សិ.ឈឿន ម៉ារ៉ានី
ឧ.សិ.ស៊ីម យ៉េកហួយ
ឧ.សិ.ស្រីតូច
ឧ.សិ.គង់ ប៊ុនជា
ឧ.ស.លឹម ប៊ុនស៊ូ
ឧ.សិ.តៃ សុមាលី ( ចែបួយ )
ឧ.ស.យិច ឈីន
ឧ.សិ.ដាណេ

# ព្រះនាម និងនាមសប្បុរសជន ចូលរួម
# កសាងសៀវភៅបច្ចេកពុទ្ធសំយុត្តកថានេះ

ព្រះវិសុទ្ធិមុនីសាសនវង្ស គង់ សួស ព្រះមង្គលជោតិប្បញ្ញោ អ៊ឹម ឌុន

ព្រះធម្មឃោសាចារ្យ អ៊ុក រ៉ន ព្រះតេជគុណ ហ៊ី

ឧ.ស.ជួន ហ៊ឺ ឧ.សិ.ខ្វាន់ ទឹម ព្រមទាំងកូនចៅ

ឧ.ស.ហុក ហេង ឧ.សិ.ស៊ុយ ឡែ + កូនចៅ + ឧ.ស.ហុក ស៊ុក

ឧ.ស.ជួន ស៊ីមគ្រី ភរិយា ម៉ាទី ព្រមទាំងបុត្រ

ឧ.ស.ហេង សមអាន ភរិយា លាន សារុន ព្រមទាំងកូនចៅ

ឧ.ស.ហេង វិរិន្ទ ឧ.សិ.ទួន បុប្ផាធារី កូនប្រុសហេង មរកត

ឧ.ស.ហុក តាំងអ៊ន់ ឧ.សិ.ជួន ស៊ីមយន់ ព្រមទាំងបុត្រ

ឧ.ស.ពាង ម៉ានសូភិន្ទ ឧ.សិ.ជួន ស៊ីមហ៊ាង ព្រមទាំងបុត្រ

ឧ.សិ.ហេង គីមហ៊ន់ ស្វាមី លាន សុខ ព្រមទាំងបុត្រ

ឧ.សិ.ហេង គីមហៃ ស្វាមី អ៊ិត ពាំរី ព្រមទាំងបុត្រ

ឧ.សិ.ហេង កាដែត ស្វាមី សាន នារី ព្រមទាំងបុត្រ

ឧ.សិ.ហេង គីមហេ ឧ.សិ.ហេង សុធនី ឧ.សិ.ហេង សុធម្មី

ឧ.សិ.ហេង ចន្ទលក្ខណា ឧ.សិ.ហេង ចន្ទធជាភា តាំងអ៊ន់ លក្ស្មី

តាំងអ៊ន់ បុញ្ញរាសី តាំងអ៊ន់ មូលវត្តី តាំងអ៊ន់ និមល ។

ពុទ្ធបរិស័ទដែលមានព្រះនាម និងនាមខាងលើនេះ បានឧបត្ថម្ភសៀវភៅបច្ចេកពុទ្ធសំយុត្តកថានេះ ចំនួន ៩០០$ ។

# ព្រះនាមសប្បុរសជន មានសទ្ធាជ្រះថ្លា ចូលរួម
# បោះពុម្ពសៀវភៅបច្ចេកពុទ្ធសំយុត្តកថានេះ
# ផ្នែកខាងព្រះសង្ឃ

១-ព្រះភិក្ខុ ធម្មកាម មិត្ត សាន និងញោមស្រី ................. ៣៥៥$

២-ព្រះភិក្ខុ ឥន្ទ្រិយសំវរៈ ប៉ូ ផែន និងឧ.ស.ហេង សុជា ........ ១២៥$

៣-ព្រះភិក្ខុ តបសីល ចៅ សុខវី ................................. ៨០$

៤-ព្រះភិក្ខុ ជោតិសម្បន្ន ណុប ណេង .............................. ៨០$

៥-ព្រះភិក្ខុ ធម្មវាសី ហេង សុកទ្ធ និងក្រុមញាតិ ................. ៥០$

៦-ព្រះភិក្ខុ ភទ្ទប្បញ្ញោ ឌុន គុណធីម ........................... ៥០$

៧-ព្រះភិក្ខុ វ៉ាត ជំនាញ ញោមប្រុសស្រី ......................... ៣០$

៨-ព្រះគ្រូចៅអធិការវត្តអង្គបី ព្រះនាម ផុន សុភី .................. ២០$

៩-ព្រះភិក្ខុ គុល វុត្ថា ........................................... ២០$

១០-ព្រះភិក្ខុ កល្យាណធម្មោ វីរៈ នឿន .......................... ២០$

១១-ព្រះភិក្ខុ ហ៊ី ហេង ............................................ ១៦$

១២-ព្រះភិក្ខុ ចាគរតោ ផាត់ សុភន ................................. ១៥$

១៣-ព្រះភិក្ខុ រតននាថោ មាស សាពួន និងញោមប្រុសស្រី ......... ១០$

១៤-សាមណេរ សុខ សែ + សាមណេរ គ្រួច ណាត .......... ១០$

១៥-សាមណេរ គង់ សន ..................................... ១០$

១៦-សាមណេរ អន ថៃ ............................. ១០$

១៧-ព្រះភិក្ខុ សន្តិបាលោ សំ សាន ..................... ៤៨៧,០០០៛

១៨-សា.ថៃ សា.ខាវ សា.សំណាង សា.ឋាន ........... ១៣០,០០០៛

១៩-ព្រះមហាជយបណ្ឌិតោ លាង សុវណ្ណ .............. ១០០,០០០៛

២០-ព្រះភិក្ខុ ផន សុភាព ( វត្តមុច្ចលិន្ទ ) ............... ១០០,០០០៛

២១-ព្រះភិក្ខុ ធម្មបាលៈ ជឹម ជិត ......................... ១០០,០០០៛

២២-ព្រះភិក្ខុ ធម្មបាលោ ហ៊ុល ប្រាក់ ................... ១០០,០០០៛

២៣-ព្រះមហាព្រហ្មជាតោ គង់ ផែង ..................... ១០០,០០០៛

២៤-ព្រះភិក្ខុ ឥន្ទ្រិយសំវរៈ ប៉ូ ផែន .......................... ៨១,០០០៛

២៥-ព្រះភិក្ខុ សង្ឃបណ្ឌិតោ លុយ សេងហ៊ាត ............... ៨០,០០០៛

២៦-សាមណេរ វិនយរក្ខិតោ សុខ ផណ្ណារ៉ា ................. ៨០,០០០៛

២៧-ព្រះភិក្ខុ គុបសីល អ៊ុំ គឹមអាន ........................... ៦០,០០០៛

២៨-ព្រះភិក្ខុ ជោតធម្មោ ជា ម៉ុន ............................ ៥០,០០០៛

២៩-ព្រះភិក្ខុ ឃួន ប៊ុន ............................ ៣២,០០០៛

# នាមសប្បុរសជន មានសទ្ធាជ្រះថ្លា ចូលរួម
# បោះពុម្ពសៀវភៅបច្ចេកពុទ្ធសំយុត្តកថានេះ
# ផ្នែកខាងឧបាសក ឧបាសិកា

*១-ឧ.ស.ពូន ភួង ក្រុមវេនមហាសង្គហ: ...... ៣០០$ + ១,០០០,០០០៛*

*២-ឧ.ស.ប៊ូ សុភាព ឧ.សិ.ងិន ស៊ីម ព្រមទាំងកូនចៅ ............. ៣០០$*

*៣-លោកគ្រូធម្មាចារ្យ ហួយ វ៉ាន់ថន ឧ.សិ.សៅ ស្រីដែត ......... ១៥០$*

*៤-ឧ.សិ.សុវណ្ណគន្ធា និងស្វាមី ព្រមទាំងកូនចៅ .................... ១៣០$*

*៥-លោកស្រី ម៉ានារី ខាន និងស្វាមី ព្រមទាំងកូនចៅ ............. ១១០$*

*៦-ឧ.សិ.ហេង ចន្ទរចនា និងក្រុមគ្រួសារ ................................ ១១០$*

*៧-ឧ.ស.ម៉េត សុម៉ារ៉ា (មង្គល) និងក្រុមគ្រួសារ .................. ១១០$*

*៨-ឧ.ស.សឹក មុនី និងភរិយា បុត្រ + ឧ.ស.ទុយ ហ៊ាន់ និងភរិយា បុត្រ .... ១០០$*

*៩-លោកអ៊ីវ វិសាល ឧ.សិ.សុង ចន្ថា ព្រមទាំងកូនចៅ ......... ១០០$*

*១០-ឧ.សិ.ច័ន្ទ បុប្ផាណា ព្រមទាំងកូនចៅ ........................... ១០០$*

*១១-មហាឧ.សិ.សឹម ស៊ីវ៉ាណែត និងស្វាមី ព្រមទាំងកូនចៅ ..... ១០០$*

*១២-ឧ.ស.ឆាំង ហៃ ឧ.សិ.ឆេង សៀកងីម ព្រមទាំងបុត្រ ............. ៩០$*

*១៣-សិស្សព្រះអភិធម្មរបស់លោកម្ចាស់គ្រូ សីលសំវរ: ប៊ុន មករា ... ៧០$*

*១៤-ឧ.សិ.ទេព ផលម៉ាឡា និងស្វាមី ព្រមទាំងបុត្រ + ញាតិមិត្ត .... ៥៦$*

*១៥-លោកគ្រូ អភិធម្មាចារ្យ សុខ ហឿន និងក្រុមញាតិ ............. ៥៥$*

១៦-ឧ.សិ.ភួង ភក្តី ............................................ ៥៥$

១៧-ឧ.ស.តាំង សុផល ឧ.សិ.ឡុង កេង ព្រមទាំងកូនចៅ .......... ៥០$

១៨-ឧ.សិ.ដាណេ និងស្វាមី .................................... ៥០$

១៩-ឧ.ស.ង៉ាន់ សិរីវុធ ភរិយា សំណាង វណ្ណា ង៉ាន់ + បុត្រ ........ ៥០$

២០-ឧ.សិ.សំ ស្រីម៉ៅ និងស្វាមី ព្រមទាំងបុត្រ ....................... ៥០$

២១-ឧ.ស.ទឹម សុខា ឧ.សិ.អៀប គន្ធា ........................... ៥០$

២២-ឧ.សិ.គង់ ប៊ុនធា និងមាតាបិតា ....................................... ៤៥$

២៣-លោកគ្រូធម្មាចារ្យ សុន្ទរ៍ សាមៀន និងភរិយា + បុត្រ ......... ៤០$

២៤-ឧ.សិ.ជាម ធុច ព្រមទាំងក្រុមញាតិ ......................... ៣៥$

២៥-ឧ.ស.ប៊ុត វិសាល ឧ.ស.លុន ធីលុច និងមាតាបិតា + ញាតិធម៌ ....... ៣៣$

២៦-ឧ.ស.ឈាង សុវណ្ណរស្មី និងមាតាបិតា ព្រមទាំងញាតិធម៌ .... ៣២.៥$

២៧-ឧ.សិ.សួន រំដួល ( អ្នកគ្រូ សុមិត្តា ) និងក្រុមគ្រួសារ ........ ២៥$

២៨-ឧ.សិ.គឹម សឿន និងស្វាមី ព្រមទាំងកូនចៅ ................... ២៣$

២៩-លោក ម៉ក់ សុភាព ព្រមទាំងក្រុមញាតិ ............ ២០$ + ៥០,០០០៛

៣០-ឧ.សិ.ហេង ស៊ីវខេង និងក្រុមញាតិ ............................ ២០$

៣១-ឧ.សិ.ប៉ែន គា និងកូនចៅ ......................................... ២០$

៣២-ឧ.ស.ជា សុថារី និងកូនចៅ ....................................... ២០$

៣៣-ឧ.សិ.កាំង ដានី និងស្វាមី ព្រមទាំងបុត្រ ......................... ២០$

៣៤-ឧ.ស.ឈូក វេន ឧ.សិ.សំនាង និងកូនចៅ .................. ២០$

៣៥-អ្នកម្តាយធម៌ ភូមិសារាម ខេត្តកំពង់ស្ពឺ និងក្រុមញាតិ ......... ២០$

៣៦-លោកពុក ហាក់ អ្នកម៉ែ ស៊ាប និងកូនចៅ ................ ២០$

៣៧-លោកពុក ម៉ាប់ អ្នកម៉ែ នីន និងកូនចៅ .................. ២០$

៣៨-លោកពូញាណ អ្នកមីង សើ និងកូនចៅ ................. ២០$

៣៩-លោកពុក យ័ន្ត អ្នកម៉ែ រ៉េត និងកូនចៅ ................. ២០$

៤០-លោកជំទាវ គង់ណាម ទន់ចាយ និងកូនចៅ ............... ២០$

៤១-ឧ.សិ.ហួន អូន និងកូនចៅ ........................................ ១៥$

៤២-ឧ.សិ.អ៊ុត នារី និងកូនចៅ .................................... ១៥$

៤៣-ឧ.សិ.ជឹន ធារីម និងស្វាមី ព្រមទាំងបុត្រ ..................... ១៥$

៤៤-ឧ.សិ.ឃឹម វ៉ន ព្រមទាំងកូនចៅ ............................. ១៣$

៤៥-ឧ.ស.ជុកមិល សន្តិភាព ឧ.សិ.ដា កែវមុនី និងកូនចៅ ........ ១០$

៤៦-ឧ.ស.ព្រហ្ម-មេត្តា ( ហៅ ជយវិទ្ធ ) ......................... ១០$

៤៧-ឧ.សិ.សំ ចេង និងកូនចៅ ................................... ១០$

៤៨-ឧ.សិ.វណ្ណ មុនី និងកូនចៅ .................................... ១០$

៤៩-ឧ.សិ.ទូច ចន្ថា ក្មួយស្រី ហ៊ុយ លីដា .......................... ១០$

៥០-ឧ.សិ.ឌួង វណ្ណធឿន និងកូនចៅ ................................ ១០$

៥១-ឧ.ស.លាង សំណាង ព្រមទាំងមាតា ........................ ១០$

៥២-ឧ.សិ.ដា សាមីន និងស្វាមី ព្រមទាំងកូនចៅ ................. ១០$

៥៣-ឧ.សិ.ប៉ាល់ ធីតា និងស្វាមី ព្រមទាំងកូនចៅ ................. ១០$

៥៤-ឧ.ស.ថុច ម៉េងឃាង ឧ.សិ.ហែម វ៉ាន់ណា ព្រមទាំងកូនចៅ ..... ១០$

៥៥-ឧ.សិ.ហ៊ិន ដារុង ព្រមទាំងកូនចៅ .......................... ១០$

៥៦-ឧ.សិ.អៀរ គឹមហេង ព្រមទាំងកូនចៅ ........................ ១០$

៥៧-ឧ.សិ.ប៊ិច សារី ព្រមទាំងកូនចៅ ............................ ១០$

៥៨-ឧ.សិ.អ៊ា ឈុនហេង ព្រមទាំងកូនចៅ ........................ ១០$

៥៩-ឧ.សិ.លឹម ណាលី ព្រមទាំងកូនចៅ ............................ ១០$

៦០-ឧ.ស.យិច ឈីន ឧ.សិ.តៃ សុមាលី ( ចៃបួយ ) និងបុត្រ ....... ១០$

៦១-ឧ.សិ.ស្រេង គ្រឹង ព្រមទាំងកូនចៅ ............................ ១០$

៦២-ឧ.សិ.រស់ សូរិយា + ឧ.សិ.ទូន សេង ព្រមទាំងកូនចៅ .......... ១០$

៦៣-ឧ.ស.ទ្រី ប៉ាវ ឧ.សិ.តាត់ ណៃដា និងកូនចៅ ..................... ៨$

៦៤-ឧ.សិ.អ៊ឹង សៀកមួយ ព្រមទាំងកូនចៅ ........................ ៨$

៦៥-ឧ.សិ.ឈួន សុ ព្រមទាំងកូនចៅ ............................ ៨$

៦៦-ឧ.សិ.លី សាវន ព្រមទាំងកូនចៅ ..................... ៨$

៦៧-ឧ.ស.ម៉ៅ សុវណ្ណឌ៍ និងភរិយា ព្រមទាំងកូនចៅ ................ ៨$

៦៨-ឧ.សិ.ប៉ែន ផាសុន្ទរី និងស្វាមី ព្រមទាំងកូនចៅ ................. ៨$

៦៩-ឧ.សិ.ម៉ន ចិន្តា ព្រមទាំងកូនចៅ ........................ ៨$

៧០-ឧ.សិ.ង៉ូវ ឡេង ស៊ីវហេង ព្រមទាំងកូនចៅ ...................... ៨$

៧១-ឧ.សិ.ប៉ុក សុខ ព្រមទាំងកូនចៅ .................................. ៨$

៧២-ឧ.ស.តាក គីអ៊ាង ឧ.សិ.ឱម លាងគ្រី កូន តាក វីរវណ្ណ .......... ៨$

៧៣-ឧ.សិ.ជ្រុន ស៊ីដេត ................................. ៧$ + ១០,០០០៛

៧៤-ឧ.សិ.ហេង ស្រីនី និងក្រុមញាតិ .............................. ៣០០,០០០៛

៧៥-ឧ.សិ.នៅ សុជានី និងស្វាមី ព្រមទាំងបុត្រ ................ ២៨០,០០០៛

៧៦-ឧ.ស.សំ វុឌ្ឍី និងកូនចៅ ( USA ) ..................... ១០០,០០០៛

៧៧-ឧ.សិ.លឹម វួច និងស្វាមី ព្រមទាំងបុត្រ ............... ១០០,០០០៛

៧៨-ឧ.ស.សួន ឧត្តម + មាតា និងក្រុមគ្រួសារ ................ ៧០,០០០៛

៧៩- ឧ.សិ.ដួង រ៉ាវី ស្វាមី ហង្ស ចន្ទរិទ្ធ ព្រមទាំងបុត្រ .......... ៦៥,០០០៛

៨០-ឧ.សិ.យូ ប៉ូលីន និងស្វាមី ព្រមទាំងកូនចៅ ............... ៥០,០០០៛

៨១-ឧ.សិ.ឃុត វ៉ាន់ថា និងស្វាមី ព្រមទាំងកូនចៅ .............. ៥០,០០០៛

៨២-លោកវេជ្ជ.ម៉ី សំបូរ ឧ.សិ.ឌួង ធវីវណ្ណ និងកូនចៅ ......... ៥០,០០០៛

៨៣-ឧ.សិ.គឹម ណាង ( បុញ្ញការី ) និងមាតាបិតា .............. ៥០,០០០៛

៨៤-ឧ.សិ.កង កញ្ញា និងអ្នកម្តាយ ព្រមទាំងកូនចៅ .......... ៤០,០០០៛

៨៥-ឧ.សិ.យិន សំណាង និងអ្នកម្តាយ ព្រមទាំងកូនចៅ ....... ៤០,០០០៛

៨៦-ឧ.សិ.ឈាន សុខាន់ និងស្វាមី ព្រមទាំងកូនចៅ ............ ៤០,០០០៛

៨៧-ឧ.ស.យូ ភារ៉ាន់ និងក្រុមញាតិ .............................. ៤០,០០០៛

៨៨-ឧ.ស.នរៈ មេត្តា ឧ.សិ.ឌួង គុយអេង និងកូនចៅ .......... ៤០,០០០៛

៨៩-ឧ.សិ.សេង គឹមអ៊ាន និងកូនចៅ ........................ ៤០,០០០៛

៩០-ឧ.សិ.ហែម ណាយ និងកូនចៅ ........................ ៤០,០០០៛

៩១-ឧ.សិ.សួន គីមផល និងស្វាមី ព្រមទាំងកូនចៅ ........... ៤០,០០០៛

៩២-ឧ.ស.ស៊ុន សុផាន និងភរិយា ព្រមទាំងបុត្រ ............... ៤០,០០០៛

៩៣-ឧ.សិ.អាំ ស៊ីម និងក្រុមគ្រួសារ ........................ ៤០,០០០៛

៩៤-ឧ.សិ.អាង សុខា និងក្រុមគ្រួសារ ........................ ៤០,០០០៛

៩៥-ឧ.សិ.កូវ សីហា និងស្វាមី ព្រមទាំងបុត្រ .................. ៤០,០០០៛

៩៦-ឧ.សិ.ស៊ុន ជា ( កៅ ជា ) និងកូនចៅ ..................... ៣៥,០០០៛

៩៧-ឧ.ស.ផាន់ កោគ និងកូនចៅ ........................ ៣៥,០០០៛

៩៨-ឧ.សិ.អ៊ួង ឈុនហួង និងកូនចៅ ........................ ៣៥,០០០៛

៩៩-ឧ.ស.លឹម ឈុនសុង ឧ.សិ.តាំង មុយខេង និងកូនចៅ .... ៣៣,០០០៛

១០០-ឧ.សិ.ស្រី វណ្ណី និងស្វាមី ព្រមទាំងកូនចៅ ............. ៣៣,០០០៛

១០១-ឧ.សិ.សុខ សារឿន និងកូនចៅ ........................ ៣២,០០០៛

១០២-ឧ.សិ.ស៊ុំ សូនី និងកូនចៅ .......................... ៣២,០០០៛

១០៣-ឧ.សិ.ហឿន ហ៊ន និងកូនចៅ ......................... ៣២,០០០៛

១០៤-ឧ.សិ.អ៊ុយ សំណាង ព្រមទាំងកូនចៅ ..................... ៣២,០០០៛

សប្បុរសជនឧបត្ថម្ភ ១០,០០០៛ មានចំនួន ៣ នាក់ = ៣០,០០០៛

## តាមរយៈ ព្រះភិក្ខុ រាមបណ្ឌិតោ ហោ តូរ៉ា

១-ព្រះភិក្ខុ រាមបណ្ឌិតោ ហោ តូរ៉ា ...................................... ៥០$

២-លោកម្ចាស់ ប្រាក់ ឫទ្ធិ + លោកម្ចាស់តា យុត ............ ២១$

៣-ឧ.ស.គីម ប៉ោស៊ីម ឧ.សិ.សាម យ៉េកឡាង និងកូនចៅ ...... ១០០$

៤-ឧ.សិ.ប៊ួន ផល និងកូនចៅ ............................ ១០០$

៥-លោកទន្តបណ្ឌិត ប៉ូច សុភារ័ត្ន អ្នកស្រី ស៊ឹម សៀវគុង និងកូនចៅ ... ១០០$

៦-ឧ.សិ.លី ធីតា និងស្វាមី ព្រមទាំងបុត្រ ............................ ៥០$

៧-បងខុម ( អ៊ី គុណា ) និងស្វាមី ព្រមទាំងបុត្រ ..................... ៥០$

៨-ម៉ាទ្រព្យ កុងហាក់ ( ថ្នាំពេទ្យ ) ព្រមទាំងកូនចៅ .................. ៣០$

៩-ផាន់ណា + សុភី + ម៉ាភាព ( ពេទ្យធ្មេញ ) .................. ៣០$

១០-ឧ.សិ.សុង ស៊ីឡែន និងស្វាមី ( ចៃទូច ) ................... ២០$

១១-ឧ.ស.សំអុល ឧ.សិ.ទូច កាក់ និងកូនចៅ ................. ១៤$

១២-ឧ.សិ.ហែម សុភាត ..................................... ១០$

១៣-ឧ.សិ.យាយ ជូ .................................. ១០$

១៤-អ្នកស្រី សុផល លោកគ្រូរិទ្ធិ ព្រមទាំងបុត្រ .......... ១,០០០,០០០៛

១៥-ឧ.ស.ម៉េង ហុង .................................. ២០០,០០០៛

១៦-ចាយ សូលីកា និងស្វាមី ( ស្រីកា ) .................. ២០០,០០០៛

១៧-លោក និក គិបទៀប ឧ.សិ.យ៉ុង ទ្រុម និងកូនចៅ ..... ៦៤,០០០៛

១៨-ឧ.សិ.នាង ស្រីពៅ និងកូនចៅ ........................... ៦០,០០០៛

១៩-ឧ.សិ.ស៊ូ សង់រាសី និងកូនចៅ ........................... ៥០,០០០៛

២០-ឧ.សិ.ហេង ធន់ និងកូនចៅ ............................ ៤០,០០០៛

២១-ឧ.ស.ឈឿក ឡា ឧ.សិ.គិន និងកូនចៅ .............. ៤០,០០០៛

២២-ឧ.សិ.គង់ ពៅ និងស្វាមី ............................ ៤០,០០០៛

២៣-ឧ.សិ.ឈិន លី ..................................... ៤០,០០០៛

២៤-ឧ.ស.ពៅ សុខុម ឧ.សិ.ឯម ស៊ីណា ................... ៤០,០០០៛

២៥-ឧ.សិ.គីម ស្រ៉ាង ................................. ៤០,០០០៛

២៦-ឧ.សិទ្បៀ ហ៊ាង ................................. ៤០,០០០៛

២៧-ឧ.សិ.ឈឿក សាអែម ...................... ៣២,០០០៛

២៨-យាយភាន់ គ្រូជីម ................................. ២០,០០០៛

២៩-ឧ.សិលាង ស្រ៊ី ព្រមទាំងបុត្រ ............................. ២០,០០០៛

៣០-កុងអ៊ីម ម៉ារ៉ាត ................................. ២០,០០០៛

៣១-ឧ.សិ.ម៉េង ជូ និងស្វាមី ................................. ២០,០០០៛

៣២-កុងអ៊ីម ................................. ២០,០០០៛

សប្បុរសជនឧបត្ថម្ភ ១២,០០០៛ មានចំនួន ២ នាក់ = ២៤,០០០៛

សប្បុរសជនឧបត្ថម្ភ ១០,០០០៛ មានចំនួន ៦ នាក់ = ៦០,០០០៛

សប្បុរសជនឧបត្ថម្ភ ៥,០០០៛ មានចំនួន ៨ នាក់ = ៤០,០០០៛

## តាមរយៈព្រះភិក្ខុ ឥន្ទ្រិយសំវរៈ ប៉ូ ផែន

១-ព្រះភិក្ខុ ឥន្ទ្រិយសំវរៈ ប៉ូ ផែន និងញោមប្រុសស្រី ....... ២០០,០០០៛

២-ព្រះភិក្ខុ សមាធិកាមោ លឿន ប៊ុនធា ................ ១០០,០០០៛

៣-លោក លី រ៉ាឌី អ្នកស្រី ប៉ាត់ ស្រីពៅ ព្រមទាំងបុត្រ ........ ១០០,០០០៛

៤-កញ្ញា លី ស្រីពីន និងក្រុមគ្រួសារ ......................... ៥០,០០០៛

៥-ឧ.ស.ស៊ិប សួរ ឧ.សិ.សុនិន ព្រមទាំងបុត្រ .............. ៥០,០០០៛

## តាមរយៈ ឧ.សិ.ស្រីលក្ខណ៍

១-ឧ.ស.ម៉េង ឧ.សិ.លក្ខណ៍ ព្រមទាំងបុត្រ ................ ១០០,០០០៛

២-ឧ.សិ.ទេព សុវណ្ណា និងស្វាមី ព្រមទាំងបុត្រ ................. ១០០,០០០៛

៣-ឧ.សិ.ញ៉ ស្រីឡែន និងស្វាមី ព្រមទាំងបុត្រ ................... ៥០,០០០៛

៤-ឧ.សិ.គន្ធា និងស្វាមី គុយ សៅលី ព្រមទាំងបុត្រ .......... ៣០,០០០៛

៥-ឧ.សិ.ទៀង នាង ឧ.សិ.សើរ លេខ ព្រមទាំងបុត្រ ...... ២៥,០០០៛

៦-ឧ.សិ.ទូច ងី + ស្វាមី ទៀង គុជ ព្រមទាំងបុត្រ ............. ២០,០០០៛

៧-ឧ.សិ.ហេង លាភ ព្រមទាំងកូនចៅ .......................... ២០,០០០៛

៨-ឧ.ស.មុត្ត រ៉េន ឧ.សិ.ហុង នាថ ព្រមទាំងកូនចៅ ........... ២០,០០០៛

# តាមរយៈ ឧ.សិ.ជុន ស៊ូគី

១-ឧ.សិ.ម៉ម គឹមមុំ និងកូនចៅ ........................................ ១០០$

២-ឧ.ស.សឹង សំណាង ឧ.សិ.អ៊ូ សិទ្ធីរី និងកូនចៅ .................. ៨២$

៣-ឧ.សិ.ម៉ម សុភាព និងកូនចៅ ....................................... ៥០$

៤-ឧ.ស.អ៊ុំ ច័ន្ទរស្មី និងកូនចៅ ........................................ ៥០$

៥-ឧ.សិ.សៀវ ស៊ីវអ៊ាង និងកូនចៅ ...................................... ៥០$

៦-ឧ.សិ.ប៊ុន គឹមមួយ និងកូនចៅ ...................................... ៤០$

៧-លោក ឡុង ឆេង ភរិយា ទៀវ មួយ និងកូនចៅ ................ ២០$

៨-ឧ.សិ.ហួត អេងហៀង និងក្មួយ ....................................... ១៨$

៩-ឧ.សិ.ហ៊ាន ហ៊ង និងកូនចៅ .......................................... ១៦$

១០-ឧ.សិ.ជុន ស៊ូគី .............................................................. ១០$

១១-ឧ.សិ.លាង ម៉ាឡាលីន និងកូនចៅ ................................... ១០$

១២-លោក អ៊ឹង ផៃស្រុន ភរិយា ឡុង សុភាព និងបុត្រ ............ ១០$

១៣-លោក ជា ផាន់ណា ភរិយា ទិត សុខនី និងបុត្រ ............ ១០$

១៤-ឧ.សិ.ម៉ម លាំងសាត និងកូនចៅ ................................. ៨$

១៥-ឧ.សិ.សាន់ ហា និងកូនចៅ ....................................... ៨$

## តាមរយៈ ឧ.សិ.រស់ គឹមថាន

១-ឧ.សិ.ឈឿន ម៉ារ៉ានី ព្រមទាំងកូនចៅ ........................ ១៥០$

២-ឧ.សិ.ច័ន្ទ សុវត្ថិ ឯ.ឧ.រឹម លឹមសេង និងកូនចៅ ................ ១០៨$

៣-លោកស្រី ឈីវ ចាន់ណា និងស្វាមី ព្រមទាំងបុត្រ ............. ១០០$

៤-បុគ្គលិក អ៊ឹម ស៊ីម៉ារ៉ានី ................................. ៨០$

៥-លោកស្រី ឈង់ កន្និការ និងស្វាមី ព្រមទាំងបុត្រ ( USA ) ...... ៥៦$

៦-លោកស្រី ឡុង សុភាព និងស្វាមី ព្រមទាំងបុត្រ ............... ៥០$

៧-អ្នកនាង ស៊ុន សោភ័ណ្ឌ ព្រមទាំងក្រុមគ្រួសារ .................. ៥០$

៨-លោកស្រី ជុំ ចាន់ខេង និងស្វាមី ព្រមទាំងបុត្រ .............. ៥០$

៩-ឧ.ស.ច័ន្ទ សុជាតិ ភរិយា គឹម លក្ខិណា និងបុត្រ .............. ៥០$

១០-ឧ.សិ.លី ជាវណ្ណា និងស្វាមី ព្រមទាំងបុត្រ ........................ ៥០$

១១-លោកជំទាវ ជា សុមាលី លោកឧកញ៉ា និងក្រុមគ្រួសារ ...... ៥០$

១២-លោកស្រី ពៅ វណ្ណា ព្រមទាំងបុត្រ ( USA ) .............. ៥០$

១៣-លោកជំទាវ ឈឿន ហេម៉ាវត្តី ឯ.ឧ. ឯម កុសល និងកូនចៅ ..... ៤៨$

១៤-លោកស្រី ជា វណ្ណា ព្រមទាំងក្រុមគ្រួសារ .................. ៤០$

១៥-ឧ.សិ.រស់ គឹមថាន និងស្វាមី ព្រមទាំងបុត្រ .................. ៣២$

១៦-ឧ.សិ.ហ៊ូ ស្រីពេជ្រ និងស្វាមី ព្រមទាំងកូនចៅ ................ ៣០$

១៧-លោកស្រី យិន មុយអ៊ី ព្រមទាំងកូនចៅ .................. ៣០$

១៨-លោកស្រី ហេង ដាណាន និងស្វាមី ព្រមទាំងបុត្រ ( USA ) ..... ៣០$

១៩-ឧ.សិ.សុខ ប៊ួយ និងស្វាមី ព្រមទាំងកូនចៅ ...................... ២០$

២០-ឧ.សិ.អាំង គីណូ និងស្វាមី ព្រមទាំងបុត្រ ................... ១០$

២១-លោកស្រី ប៊ិន រ៉ាមី និងស្វាមី ព្រមទាំងបុត្រ ............... ១០$

២២-លោកស្រី សាយ គន្ធា និងស្វាមី ព្រមទាំងបុត្រ ........... ១០$

២៣-លោកស្រី យិន មុយហ្គិច និងស្វាមី ព្រមទាំងបុត្រ .......... ១០$

២៤-លោកស្រី លឹម ពេជ្រចិន្តា និងស្វាមី ព្រមទាំងបុត្រ .......... ១០$

២៥-ឧ.សិ.អ៊ុក សុជាតា និងស្វាមី ព្រមទាំងបុត្រ ................... ១០$

២៦-លោកស្រី ឆាយ សុភាព ព្រមទាំងបុត្រ ................... ១០$

២៧-ឧ.សិ.ឡេង គឹមនី ព្រមទាំងកូនចៅ ........................... ១០$

២៨-ឧ.សិ.អ៊ឹង ណារី និងស្វាមី ព្រមទាំងបុត្រ ............. ១៥០,០០០៛

២៩-ឧ.សិ.ជុង ច័ន្ទឌៀប និងស្វាមី ព្រមទាំងកូនចៅ .......... ៥០,០០០៛

៣០-លោកស្រី ឡេក ពណ្ណរាយ និងស្វាមី ព្រមទាំងបុត្រ .... ៤០,០០០៛

៣១-ឧ.សិ.លី ផល្លី ឧ.សិ.លី គីមលុយ និងកូនចៅ ............. ៣៣,០០០៛

៣២-ឧ.ស.សំ ហ៊ែល ឧ.សិ.យូ ផលាព្វ និងកូនចៅ ............. ៣២,០០០៛

៣៣-ឧ.សិ.អ៊ឹង យឹមស្រ៊ាន ព្រមទាំងកូនចៅ ................ ៣០,០០០៛

៣៤-ឧ.ស.សំណាង ប៉ូ និងក្រុមគ្រួសារ ................ ៣០,០០០៛

៣៥-ឧ.ស.ផូ ចាន់ណា ព្រមទាំងភរិយា ..................... ២០,០០០៛

# តាមរយៈ ឧ.សិ.ស៊ីម យ៉េកហួយ

១-ព្រះភិក្ខុ ណាំ ស្រ៊ន់ ........................................ ១០$

២-ឧ.សិ.អ៊ឹង ចាន់ថា ឧ.ស.គិត ម៉េងគង់ ព្រមទាំងបុត្រ .......... ៥០$

៣-ឧ.សិ.ស៊ីម យ៉េកហួយ ..................................... ២៥$

៤-ឧ.សិ.ជា យានារី ព្រមទាំងកូនចៅ .................................. ១០$

៥-ឧ.សិ.អ៊ុង វឌ្ឍនា ............................. ១០$

៦-ទាយិកាហួត ឆេងអ៊ង់ ទាយក ជីង ឈុនង្ហួន + បុត្រ ... ១០០,០០០៛

៧-ឧ.សិ.ឡាយ សំណាង ឧ.ស.ហេង ផុណ្ណា + បុត្រ ....... ៥០,០០០៛

៨-ឧ.សិ.សៀក សែហេង និងស្វាមី ព្រមទាំងបុត្រ .......... ៤០,០០០៛

៩-ឧ.សិ.សុខ ហ៊ាង និងអ្នកម្ដាយស៊ី ចាន់ ................. ៤០,០០០៛

១០-ឧ.សិ.ហាក់ ហុងលី ព្រមទាំងបុត្រ .......................... ៤០,០០០៛

១១-ឧ.ស.អ៊ាម ង្ហួនឆេង ឧ.សិ.ឱ ដាលី ព្រមទាំងបុត្រ .......... ៤០,០០០៛

១២-ឧ.ស.ស៊ាង ហាក់ ឧ.សិ.អ៊ាង ឆេង ព្រមទាំងបុត្រ ......... ៣៣,០០០៛

១៣-ឧ.សិ.ប៊ុត ម៉ាឡៃ ព្រមទាំងបុត្រ ......................... ៣៣,០០០៛

១៤-ឧ.សិ.ហេង ដានី លោក កែវ វិចិត្រ ព្រមទាំងបុត្រ ....... ៣២,៥០០៛

១៥-ឧ.សិ.ហេង ដាលី និងលោកឪពុក ព្រមទាំងបុត្រ ....... ៣២,៥០០៛

១៦-ឧ.សិ.យក់ ដាង និងបងប្អូន ...................... ៣២,០០០៛

១៧-ឧ.សិ.យិន យាបរ៉ាទី ព្រមទាំងបុត្រ ................. ៣២,០០០៛

១៨-ឧ.ស.ជឿង ថេង ឧ.សិ.នូ សុខុម ព្រមទាំងបុត្រ ........ ៣២,០០០៛

១៩-ឧ.សិ.ចាន់ គីមហេង ព្រមទាំងបុត្រ .................... ៣២,០០០៛

២០-ឧ.ស.កៅ ប៊ុណ្ណា ឧ.សិ.ស៊ុយ ស៊ីណេត ព្រមទាំងបុត្រ ... ៣២,០០០៛

២១-ឧ.សិ.យក់ ស៊ាង ឧ.សិ.គីវ សាយ ព្រមទាំងបុត្រ ....... ២៥,០០០៛

## តាមរយៈ ព្រះភិក្ខុ គម្ពីរប្បញ្ញោ រូ ច័ន្ទរតនា

១-ឧ.សិ.វ៉ាត សុខជា និងកូនចៅ ........................... ៣៣០$

២-ឧ.សិ.ញោមស្រី និងកូនចៅ ចូល ១៥ ក. ................ ១១១.៥$

៣-ឧ.សិ.កន្សៃ្យសារពេជ្ជ ស្រី ស្រស់ និងស្វាមី ព្រមទាំងបុត្រ ...... ១០០$

៤-ឧ.សិ.សែង សុភា និងស្វាមី ព្រមទាំងបុត្រ .............. ១០០$

៥-លោកយាយឧ.សិ.តាំង ណៃហួយ និងកូនចៅ ... ៧០$ + ១៨០,០០០៛

៦-ឧ.សិ.ហុក ណារី និងស្វាមី ព្រមទាំងកូនចៅ .............. ៥០$

៧-ឧ.សិ.ភិន រចនាធដា និងក្រុមគ្រួសារ ....................... ៤០$

៨-ឧ.សិ.វ៉ាត ផៃលាង និងស្វាមី ព្រមទាំងកូនចៅ ............... ២០$

៩-ឧ.សិ.ផែន ចាន់ថុល និងស្វាមី ព្រមទាំងកូនចៅ ............. ៦០,០០០៛

សរុបប្រាក់បានទទួលពីលោកម្ចាស់គ្រូ = ៩២២$

ពេជពុម្ព អិមភី
MP Publishing House